# ព្រះត្រៃបិដក

## ប្រែរួមនឹងព្រះអដ្ឋកថា

## ភាគ៥៩

បាលីប្រែ ៧២

ពុទ្ធសករាជ ២៥៥៣

ច្បាប់ពិនិត្យ លើកទី២

# ព្រះ

# សុត្តន្តបិដក

## និង

# វិសុទ្ធជនវិលាសិនី អដ្ឋកថា

## សេចក្តីប្រែជាភាសាខ្មែរ

# ខុទ្ទកនិកាយ អបទាន

## បឋមភាគ

# ៥៩

# បាលីប្រែ ៧២



*បោះពុម្ពលើកទី ១ ពុទ្ធសករាជ ២៥៥៣*

# ក្បាលទី ៥៩
# សុត្តន្តបិដក
# ខុទ្ទកនិកាយ អបទាន
# បឋមភាគ

*សូមនមស្ការ ចំពោះព្រះអរហន្តសម្មាសម្ពុទ្ធ អង្គនោះ*

## ពុទ្ធវគ្គទី ១

### ពុទ្ធាបទានទី ១

*[ ១ ] ទតង្គៈ ជាអ្នកប្រាជ្ញ ជាបុត្តនៃនាងទេវី ក្នុងដែនវេទេហៈ បានសួរព្រះតថាគត កាលគង់នៅក្នុងវត្តជេតពនថា បានឮថា ព្រះសព្វញ្ញុពុទ្ធទាំងឡាយតែងមាន តើព្រះសព្វញ្ញុពុទ្ធ ជាអ្នកប្រាជ្ញទាំងនោះ ទ្រង់កើតមាន ដោយហេតុដូចម្តេច ។ គ្រានោះ ព្រះសព្វញ្ញុពុទ្ធដ៏ប្រសើរ ទ្រង់ស្វែងរកនូវគុណដ៏ធំ ទ្រង់បែរទៅត្រាស់នឹងព្រះអានន្ទដ៏ចម្រើន ដោយព្រះសូរសៀងដ៏ពីរោះថា ពោធិសត្វទាំងឡាយណា មានការកសាងបានធ្វើទុកហើយ ក្នុងសម្នាក់នៃព្រះពុទ្ធទាំងពួង តែមិនទាន់បានមោក្ខធម៌ ក្នុងសាសនានៃព្រះជិនស្រីទេ ពោធិសត្វទាំងនោះ ជាអ្នកប្រាជ្ញ មានបញ្ញាមុតថ្លា រមែងបាននូវភាពជាសព្វញ្ញុពុទ្ធ ព្រោះប្រធាននៃការត្រាស់ដឹងនោះផង ព្រោះអធ្យាស្រ័យមានកម្លាំង*

ដ៏ធំនោះផង ព្រោះតេជះនៃបញ្ញានោះផង ។ សូម្បីតថាគត ក៏បាន ប្រាថ្នានូវភាពជាព្រះពុទ្ធ ក្នុងសម្នាក់នៃព្រះពុទ្ធមុនៗ ទាំងឡាយ រាប់មិនអស់ ដែលជាព្រះរាជាហេតុធម៌ បរិបូណ៌ដោយបារមី ៣០ ។ តថាគតបាននមស្ការថ្វាយបង្គំដោយម្រាមដៃដប់ ដោយក្បាល ចំពោះព្រះសម្ពោធិញ្ញាណ របស់ព្រះពុទ្ធដ៏ប្រសើរទាំងឡាយផង ចំពោះព្រះសម្ពុទ្ធទាំងឡាយ ជានាយកនៃសត្វលោក ព្រមទាំងព្រះសង្ឃផង ។ រតនៈទាំងឡាយ រាប់មិនអស់ មានក្នុងពុទ្ធក្ខេត្តទាំងប៉ុន្មាន ទេវតាដែលស្ថិតនៅឰដ៏អាកាសផង ស្ថិតនៅលើផែនដីផង រមែងនាំមកនូវរតនៈទាំងពួងនោះ ដោយចិត្ត ។ ក្នុងទីនោះ តថាគតបានសាងប្រាសាទ ជាវិការនៃកែវមានជាន់ច្រើន ខ្ពស់ត្រដែតទៅក្នុងអាកាស ត្រង់ភូមិភាគ ជាវិការនៃប្រាក់ មានសសរធ្វើល្អ ដ៏វិចិត្រហើយ ចែកជាល្វែងល្អហើយ ជាប្រាសាទមានតម្លៃច្រើន មានក្របជាវិការនៃមាស ប្រដាប់ដោយឆត្រកំពូលស្រួច ។ ជាន់ទីមួយ ជាវិការនៃកែវពៃទូរ្យ ប្រាសចាកមន្ទិល ល្អស្មើពពក ដ៏ដេរដាសដោយឈូក ដ៏ល្អជាងជាន់ ដែលក្រាលដោយមាសដ៏ប្រសើរ ។ ( ជាន់ខ្លះ ) វិចិត្រដោយកែវប្រពាល មានពណ៌នៃកែវប្រពាល ( ជាន់ខ្លះ ) មានពណ៌ក្រហមល្អ ( ជាន់ខ្លះ ) មានពន្លឺដូចស្នាបអណ្តើកមាស ( ជាន់ខ្លះ ) ភ្លឺផ្លេកគ្រប់ទិស ។ ទីអង្គុយ ដៃកែវ បង្អួច សុទ្ធសឹងចាត់ត្រូវរបៀប មានកម្រងផ្កា ក្លិនក្រអូបជាទីគាប់

ចិត្ត ( សំយុងចុះមក ) តាមចម្រឹងទាំង ៤ និងតាមសន្ទះបង្អួច ។ ( ជាន់ប្រាសាទទាំងឡាយ ) មានពណ៌ខៀវ លឿង ក្រហម ស និងពណ៌ខ្មៅសុទ្ធ ដែលប្រដាប់ដោយផ្ទះកំពូលដ៏ប្រសើរ តាក់តែង ហើយដោយកែវ ៧ ប្រការ ។ មានក្បាច់ផ្កាឈូក គួរក្រឡេកមើល ស្រស់ដោយរូបម្រឹគ និងបក្សី ដេរដាសដោយរូបផ្កាយនក្ខត្តឫក្ស ដោយរូបព្រះចន្ទ្រ និងព្រះអាទិត្យ ទាំងជាសពាសដោយបណ្តាញ មាស ប្រកបដោយកណ្តឹងមាស សន្ទឹកផ្កាមាស ជាទីត្រេកអរនៃចិត្ត រមែងលាន់ឮដោយកម្លាំងខ្យល់ ។ ( ផ្ទៃនៃប្រាសាទនោះ ) មានទង់ ពណ៌ហង្សបាទ ពណ៌ក្រហម ពណ៌លឿង ពណ៌លឿងទុំ មានទង់ វិចិត្រល្អដោយពណ៌ផ្សេងៗ ប្រកបរបៀបទង់ដែលគេលើកឡើង ។ មានផែនក្តារផ្សេងៗ ច្រើនរយជាអនេក ជាក្តារប្រាក់ខ្លះ ក្តារកែវមណី ខ្លះ ក្តារកែវទទឹមខ្លះ ក្តារកែវមរកតខ្លះ ។ ( ផ្ទៃខាងក្នុងប្រាសាទនោះ ) វិចិត្រដោយសយនៈផ្សេងៗ ក្រាលដោយសំពត់កាសិក មានសាច់ ល្អិត សំពត់រោមសត្វ សំពត់សូត្រ សំពត់ស្រុកចិនៈ សំពត់ស្រុក បត្តុណ្ណៈ សំពត់ស្រុកបណ្ឌុ ។ តថាគតបានក្រាលនូវកម្រាលផ្សេងៗ ទាំងអស់ ដោយចិត្តឯង តថាគតតាក់តែងនូវហោជាង កែវក្នុងជាន់ នោះៗ ។ មានពួកជនឈរកាន់ប្រទីបកែវមណី ភ្លឺរុងរឿង ឯសសរ ខឿន សសរផ្ទះ ខ្លោងទ្វារជាវិការនៃមាស ជាវិការនៃមាសជម្ពូនទ ជាវិការនៃឈើខ្លឹម ជាវិការនៃប្រាក់ដ៏ស្រស់ល្អ ទាំងទីតំណដ៏ច្រើន

ដែលបែកល្អ វិចិត្រដោយសន្ទះទ្វារ និងគន្លឹះ សុទ្ធសឹងល្អៗ ។ ក្អម ពេញ ( ដោយទឹក ) ច្រើន ដែលដាក់ផ្កាឈូក និងឧប្បលជាតិ រៀបតាំងទាំងសងខាងនៃប្រាសាទនោះ ។ ព្រះបច្ចេកពុទ្ធទាំងពួង ព្រមទាំងសាវ័ក និម្មិតនូវព្រះសព្វញ្ញុពុទ្ធ ជានាយកនៃសត្វលោក ព្រមទាំងព្រះសង្ឃ ក្នុងកាលដ៏កន្លងទៅហើយផង ( នូវព្រះ បច្ចេកពុទ្ធទាំងឡាយ ) ព្រមទាំងសាវ័ក ដោយរូបភេទជាប្រក្រតីផង ហើយចូលទៅតាមទ្វារនោះ រួចគង់ជាអរិយមណ្ឌល លើតាំងជា វិការនៃមាសទាំងអស់ ព្រះពុទ្ធទាំងឡាយណា ប្រសើរផុតក្នុង លោក មានក្នុងកាលឥឡូវនេះក្ដី ព្រះពុទ្ធទាំងឡាយណា កន្លងទៅ ហើយក្ដី ព្រះពុទ្ធទាំងអស់អង្គនោះ បានឡើងមកគង់ក្នុងប្រាសាទ របស់តថាគត ឯតថាគតក៏បានអង្គាសព្រះបច្ចេកពុទ្ធជាច្រើនរយអង្គ ដែលជាអ្នកត្រាស់ដឹងឯង ជាអ្នកឈ្នះមារក្នុងអតីតកាល និងបច្ចុប្បន្នកាល ( ឲ្យឆ្អែតស្កប់ស្កល់ ) ។ មានដើមកប្បព្រឹក្សច្រើនដើម ទាំង ជាទិព្វ ទាំងជារបស់មនុស្ស តថាគតបាននាំយកសំពត់ទាំងពួង ( អំពីដើមកប្បព្រឹក្សនោះ ) មកធ្វើជាត្រៃចីវរ ហើយថ្វាយ ( ព្រះ បច្ចេកពុទ្ធ ) ឲ្យស្លៀកដណ្ដប់ ( រួចនិមន្តឲ្យឆាន់ ) នូវបង្អែម និង ចម្អាប ដែលមានរសឆ្ងាញ់ ព្រមទាំងទឹក និងភោជន ។ តថាគត បានញុំាងបាត្រដ៏ល្អ ជាវិការនៃកែវមណីឲ្យពេញ ( ដោយវត្ថុទាំង នោះ ) ហើយ ប្រគេនសំពត់ទិព្វមានសាច់ដ៏រលីងដែលគួរដល់ចីវរ ។

មណ្ឌលនៃព្រះអរិយៈទាំងអស់ ផ្អែតស្កប់ស្កល់ហើយ ដោយទឹកឃ្មុំផង ស្ករក្រាមផង ប្រេងផង ទឹកឃ្មុំ និងស្ករអំពៅផង បាយដ៏ប្រសើរផង ។ ( ព្រះអរិយៈទាំងនោះ ) ចូលទៅកាន់បន្ទប់កែវ សម្រេចសីហសេយ្យា លើសយនៈ មានតម្លៃច្រើន ដូចកេសររាជសីហ៍ក្នុងគុហា ។ ( ព្រះអរិយៈទាំងនោះ ) មានសម្បជញ្ញៈ ក្រោកឡើងហើយ ផ្គត់ព្រះភ្នែនលើសំណឹង បំពេញសេចក្តីត្រេកអរក្នុងឈានជាអារម្មណ៍ របស់ព្រះពុទ្ធទាំងពួង ។ ពួកព្រះអរិយៈខ្លះសម្តែងធម៌ ពួកខ្លះក្រសាលដោយឫទ្ធិ ពួកខ្លះក្រសាលដោយអប្បនាសមាធិ ពួកខ្លះចម្រើននូវវសីក្នុងអភិញ្ញា ធ្វើវិកុព្វនាឥទ្ធិ[១] ច្រើនសែន ។ ព្រះពុទ្ធទាំងឡាយទ្រង់សួរនូវប្រស្នា ជាវិស័យព្រះពុទ្ធជារបៀបនៃសព្វញ្ញុពុទ្ធ ចំពោះព្រះពុទ្ធទាំងឡាយ ដែលត្រាស់ដឹងហេតុដ៏ជ្រៅល្អិត ដោយប្រាជ្ញា សាវ័កទាំងឡាយសួរព្រះពុទ្ធទាំងឡាយ ឯព្រះពុទ្ធទាំងឡាយ ក៏សួរសាវ័កទាំងឡាយ ។ ព្រះពុទ្ធព្រះបច្ចេកពុទ្ធ និងសាវ័ក ជាអ្នកបម្រើទាំងនោះ សួរគ្នានិងគ្នាផងឆ្លើយដល់គ្នានិងគ្នាផង ។ ព្រះអរិយបុគ្គលទាំងនោះ កាលត្រេកអរក្នុងពុទ្ធកិច្ចយ៉ាងនេះហើយ រមែងរីករាយលើប្រាសាទ ឯឆត្ររួតប្រាកដស្មើដោយរបៀបនៃកែវក៏ស្ថិតនៅ ។ តថាគតប្រកាសថាឆត្រដែលប៉ាក់ដោយបណ្តាញមាស ដែលរចនាដោយបណ្តាញប្រាក់

---

១- បានដល់ឫទ្ធិដែលធ្វើមនុស្សម្នាក់ ឲ្យទៅជាមនុស្សច្រើននាក់ ។

ដែលព័ទ្ធព័ទ្ធដោយបណ្ដាញកែវមុក្តា ឆត្រទាំងអស់នោះ សូមបាំងលើព្រះកេសព្រះពុទ្ធ ។ ពិតានសំពត់ ដែលវិចិត្រដោយរូបផ្កាយមាស ដែលវិចិត្រដោយរបៀបផ្កា ពិតានទាំងនោះ សូមបាំងលើព្រះកេសព្រះពុទ្ធ ។ សូមស្រះបោក្ខរណី ដេរដាសដោយចង្កោមផ្កា ( មានក្លិនក្រអូប ) និងចង្កោមផ្កាឈើ មានក្លិនក្រអូប ល្អដោយចង្កោមផ្កាក្រអូប ដេរដាសដោយផ្ទាំងសំពត់ តាក់តែងដោយចង្កោមកែវ ។ សូមស្រះបោក្ខរណី ដេរដាសដោយផ្កាវិចិត្រល្អ អប់ដោយក្លិនក្រអូប តាក់តែងដោយគ្រឿងប្រោះព្រំដ៏ក្រអូប បិទបាំងដោយពិតានមាស ។ សូមស្រះបោក្ខរណី ក្នុងទិសទាំង ៤ ព្រោងព្រាតដោយឈូក និងឧប្បល ពេយពាយដោយលម្អងផ្កាឈូក កើតប្រាកដក្បែរប្រាសាទមាស ។ ដើមឈើទាំងអស់ ជុំវិញប្រាសាទ សូមបញ្ចេញផ្កា លុះបញ្ចេញផ្កាហើយ សូមពេយពាយក្លិនទៅលើប្រាសាទ ។ សូមពួកក្ងោកពង់លើប្រាសាទនោះ សូមពួកហង្សជាទិព្វស្រែកកញ្ឆ្រៀវ សូមពួកករវិកយំ សូមពួកបក្សីរងាវ ជុំវិញប្រាសាទនោះ ។ សូមពួកស្គរទាំងអស់ លាន់ឮខ្ទរខ្ទារ សូមពួកពិណទាំងអស់លាន់ឮ សូមពួកចម្រៀងទាំងអស់ ច្រៀងជុំវិញប្រាសាទ ។ សូមបល្ល័ង្កមាសដ៏ធំ ដែលបរិបូណ៌ដោយពន្លឺមិនដាច់ ដែលរចនាដោយកែវ ស្ថិតនៅក្នុងចក្រវាល ជាពុទ្ធក្ខេត្តទាំងប៉ុន្មានផង ក្នុងចក្រវាល ( ដទៃពីនោះផង ) ។ សូមពួកឈើប្រទីប ភ្លឺរុងរឿង សូមឈើ

ទាំងហ្នឹង មានពន្លឺតែបែបមួយគត់ៗ គ្នា ។ សូមពួកស្ត្រីគណិកា ពួកស្ត្រីរបាំ និងពួកស្ត្រីអប្សរ ដែលប្រដាប់ដោយពណ៌ផ្សេងៗ នាំគ្នារាំ នាំគ្នាច្រៀង ជុំវិញប្រាសាទ ។ តថាគតឲ្យគេលើកទង់ជ័យទាំងអស់ ដ៏វិចិត្រមានពណ៌ប្រាំ លើចុងឈើខ្លះ លើកំពូលភ្នំខ្លះ លើកំពូលភ្នំសិនេរុខ្លះ ។ តថាគតប្រកាសថា សូមពួកមនុស្ស នាគ គន្ធព្វ និងទេវតាទាំងអស់នោះ នាំគ្នាមកនមស្ការ ធ្វើអញ្ជលិកម្ម ចោមរោមប្រាសាទរបស់យើងនេះ ។ អំពើជាកុសលណាមួយ ដែលខ្ញុំគប្បីធ្វើដោយកាយ វាចា ចិត្ត ( អំពើជាកុសលនោះ ) ដែលខ្ញុំបានធ្វើហើយ ជាកុសលគួរដល់ការកើតក្នុងសុគតិ ក្នុងត្រៃត្រិង្ស ។ សត្វទាំងឡាយណា មានសញ្ញា និងសត្វទាំងឡាយណា មិនមានសញ្ញា សត្វទាំងអស់នោះ ចូរបាននូវចំណែកផលនៃបុណ្យ ដែលខ្ញុំបានធ្វើហើយ សត្វទាំងឡាយណា បានដឹងច្បាស់នូវបុណ្យដែលខ្ញុំបានធ្វើហើយនោះ សត្វទាំងនោះ ( ចូរបានទទួល ) នូវផលនៃបុណ្យដែលខ្ញុំឲ្យហើយ ម្យ៉ាងទៀត បណ្តាសត្វទាំងនោះ សត្វទាំងឡាយណា មិនបានដឹង សូមទេវតាទាំងឡាយអញ្ជើញទៅឲ្យដំណឹង ( ដល់សត្វទាំងនោះ ) ផង ។ សត្វទាំងអស់ណា ក្នុងលោក ដែលអាស្រ័យអាហារ ហើយរស់នៅ សត្វទាំងអស់នោះ ចូរបាននូវភោជន ជាទីគាប់ចិត្ត តាមចិត្តខ្ញុំចុះ ។ តថាគតបានឲ្យទានដោយចិត្ត តថាគតបានបណ្តុះនូវសេចក្តីជ្រះថ្លាដោយចិត្ត បានបូជាចំពោះព្រះសម្ពុទ្ធទាំង

ពួន បូជាចំពោះព្រះបច្ចេកពុទ្ធទាំងឡាយ ។ តថាគតលះបង់រាងកាយជារបស់មនុស្សហើយ ទៅកើតក្នុងស្ថានតាវត្តិង្ស ព្រោះកម្មដែលតថាគតធ្វើល្អនោះផង ព្រោះការតម្កល់ទុកចេតនានោះផង ។ តថាគតស្គាល់ច្បាស់នូវភពទាំងពីរ គឺភពជារបស់ទេវតា ១ ជារបស់មនុស្ស ១ តថាគតមិនស្គាល់គតិដទៃឡើយ នេះជាផលនៃសេចក្តីប្រាថ្នាដោយចិត្ត ។ តថាគត បានជាបុគ្គលប្រសើរជាងទេវតាទាំងឡាយ ជាធំក្នុងពួកមនុស្ស បរិបូណ៌ដោយរូបឆោម និងលក្ខណៈឥតមានបុគ្គលស្មើដោយប្រាជ្ញា ។ ភោជនដ៏ប្រសើរផ្សេងៗ ផង កែវច្រើនយ៉ាងផង សំពត់មានបែបផ្សេងៗ ផង ក៏ធ្លាក់ចុះចាកអាកាសមកកាន់ទីជិតតថាគត ឆាប់រហ័ស ។ តថាគត លាដៃក្នុងទីណា គឺផែនដី ភ្នំ អាកាស ទឹក និងព្រៃ អាហារជាទិព្វ ក៏មកដល់តថាគត ( អំពីទីនោះ ) ។ តថាគតលាដៃក្នុងទីណា គឺផែនដី ភ្នំ និងអាកាស ទឹក និងព្រៃ កែវទាំងពួង ក៏មកដល់តថាគត ( អំពីទីនោះ ) ។ តថាគតលាដៃក្នុងទីណា គឺផែនដី ភ្នំ អាកាស ទឹក និងព្រៃ គ្រឿងក្រអូបទាំងពួង ក៏មកដល់តថាគត ( អំពីទីនោះ ) ។ តថាគតលាដៃក្នុងទីណា គឺផែនដី ភ្នំ អាកាស ទឹក និងព្រៃ យានទាំងពួង ក៏មកដល់តថាគត ( អំពីទីនោះ ) ។ តថាគតលាដៃក្នុងទីណា គឺផែនដី ភ្នំ អាកាស ទឹក និងព្រៃ កម្រងផ្កាទាំងពួង ក៏មកដល់តថាគត ( អំពីទីនោះ ) ។ តថាគតលាដៃក្នុងទីណា គឺផែនដី ភ្នំ អាកាស ទឹក

និងព្រៃ គ្រឿងអលង្ការទាំងឡាយ ក៏មកដល់តថាគត ( អំពីទីនោះ ) ។ តថាគតលាដៃក្នុងទីណា គឺផែនដី ភ្នំ អាកាស ទឹក និងព្រៃ ស្ត្រីកញ្ញាទាំងអស់ ក៏មកដល់តថាគត ( អំពីទីនោះ ) ។ តថាគតលាដៃក្នុងទីណា គឺផែនដី ភ្នំ អាកាស ទឹក និងព្រៃ ទឹកឃ្មុំ និងស្ករ ក៏មកដល់តថាគត ( អំពីទីនោះ ) ។ តថាគតលាដៃក្នុងទីណា គឺផែនដី ភ្នំ អាកាស ទឹក និងព្រៃ គ្រឿងបន្ថែមគ្រប់យ៉ាង ក៏មកដល់តថាគត ( អំពីទីនោះ ) ។ ដើម្បីដល់នូវសម្ពោធិញ្ញាណដ៏ប្រសើរ តថាគតឲ្យនូវទានដ៏ប្រសើរនោះ ដល់ជនអ្នកឥតទ្រព្យ ( ជនអ្នកដំណើរ ) យាចក និងអ្នកដើរតាមផ្លូវ ។ តថាគតញ៉ាំងភ្នំថ្ម ឲ្យលាន់ឮ ញ៉ាំងភ្នំដ៏ក្រាស់ឲ្យឮខ្ទរខ្ទារ ញ៉ាំងលោក ព្រមទាំងទេវតាឲ្យរីករាយ ទើបបានជាព្រះពុទ្ធក្នុងលោក ។ ទីបំផុតនៃសត្វ កាលទៅកាន់ទិសទាំង ១០ ក្នុងលោក មិនមានឡើយ ចំណែកខាងពុទ្ធក្ខេត្តក្នុងចំណែកនៃទិសនោះ គេមិនអាចរាប់បាន ។ ពន្លឺជាគ្រឿងនាំទៅនូវរស្មីទាំងគូ ប្រាកដហើយដល់តថាគត ពន្លឺ គឺបណ្តាញនៃរស្មីដ៏ធំទូលាយ ក៏កើតឡើងក្នុងចន្លោះនៃលោកធាតុនេះ ។ ចូរពួកជនទាំងអស់នោះ ក្នុងលោកធាតុ ឃើញនូវតថាគតចុះ ចូរពួកជនគ្រប់គ្នាមានចិត្តល្អចុះ ចូរពួកជនរាល់រូប ប្រព្រឹត្តតាមតថាគតចុះ ។ តថាគតទូងស្គរ គឺព្រះនិព្វាន ឈ្មោះអមតៈ ដោយពាក្យដ៏ពីរោះ ប្រសើរក្រៃលែង ចូរពួកជនគ្រប់គ្នា ក្នុងលោកធាតុនេះ ស្តាប់នូវសំឡេងដ៏

ពីរោះចុះ ។ កាលបើតថាគតបង្អុរចុះ ដោយទឹកភ្លៀង គឺធម៌ ចូរពួកជនគ្រប់គ្នា ជាអ្នកមិនមានអាសវៈចុះ បណ្តាសត្វទាំងនោះ ពួកសត្វណា មាននិស្ស័យជាន់ក្រោម ចូរពួកសត្វទាំងនោះ បានជាសោតាបន្នបុគ្គលចុះ ។ ព្រោះតថាគតឲ្យទាន ដែលគួរឲ្យ បានបំពេញសីល ឥតមានសេសសល់ ដល់នូវនេក្ខម្មបារមី ទើបបាននូវសម្ពោធិញ្ញាណដ៏ឧត្តម ។ ព្រោះតថាគត បានប្រឹក្សានឹងពួកបណ្ឌិត ហើយធ្វើនូវវីរិយបារមី ឲ្យខ្ពង់ខ្ពស់ ដល់នូវខន្តិបារមី ទើបបាននូវសម្ពោធិញ្ញាណដ៏ឧត្តម ។ ព្រោះតថាគត ធ្វើអធិដ្ឋានបារមី ឲ្យមាំមួនបំពេញនូវសច្ចបារមី ដល់នូវមេត្តាបារមី ទើបបាននូវសម្ពោធិញ្ញាណដ៏ឧត្តម ។ ព្រោះតថាគត ជាអ្នកមានចិត្តស្មើ ក្នុងលោកធម៌ទាំងអស់ គឺលាភ និងឥតលាភ សុខ និងទុក្ខ ការសរសើរ និងនិន្ទា ទើបបាននូវសម្ពោធិញ្ញាណដ៏ឧត្តម ។ អ្នកទាំងឡាយ ចូរឃើញនូវកោសជ្ជៈ ថាជាភ័យផង ឃើញនូវវីរិយៈថាជាធម៌ក្សេមផង ហើយចូរជាអ្នកប្រារព្ធព្យាយាមឡើង នេះជាអនុសាសនីរបស់ព្រះពុទ្ធ ។ អ្នកទាំងឡាយ ចូរឃើញនូវវិវាទថា ជាភ័យផង ឃើញនូវការមិនវិវាទថាជាគុណដ៏ក្សេមផង ហើយចូរជាអ្នកព្រមព្រៀងស្រុះស្រួលនឹងគ្នាចុះ នេះជាអនុសាសនីរបស់ព្រះពុទ្ធ ។ អ្នកទាំងឡាយ ចូរឃើញនូវបមាទៈថា ជាភ័យផង ឃើញនូវអប្បមាទៈថាជាគុណដ៏ក្សេមផង ហើយចូរចម្រើនមគ្គមានអង្គ ៨ នេះជាអនុ-

សាសនីរបស់ព្រះពុទ្ធ ។ ព្រះពុទ្ធ និងព្រះអរហន្តច្រើនអង្គ បានមកជួបជុំ ដោយសព្វគ្រប់ ហើយអ្នកទាំងឡាយ ចូរថ្វាយបង្គំនមស្ការចំពោះព្រះសម្ពុទ្ធ និងព្រះអរហន្តចុះ ។ ព្រះពុទ្ធទាំងឡាយ ជាអចិន្តិយបុគ្គល ( បុគ្គលដែលគេមិនគប្បីគិតកើត ) ធម៌របស់ព្រះពុទ្ធជាអចិន្តិយធម៌យ៉ាងនេះ កាលបុគ្គលជ្រះថ្លាចំពោះគុណជាអចិន្តិយៈ រមែងបានផលជាអចិន្តិយៈ ។

បានឮថា ព្រះមានព្រះភាគ កាលត្រាស់ដឹងនូវពុទ្ធចរិតរបស់ព្រះអង្គ ទើបសម្តែងនូវធម្មបរិយាយ ឈ្មោះពុទ្ធាបទាន ដោយប្រការដូច្នេះ ។

ពុទ្ធាបទាន ចប់

# អដ្ឋកថា
# វិសុទ្ធជនវិលាសិនី
# ខុទ្ទកនិកាយ អបទាន
# ពុទ្ធវគ្គទី ១

សូមនមស្ការចំពោះព្រះអរហន្តសម្មាសម្ពុទ្ធអង្គនោះ

## ពុទ្ធាបទានទី ១
### គន្ថារម្ភកថា

ខ្ញុំព្រះករុណាសូមនមស្ការព្រះពុទ្ធដ៏ប្រសើរ មិនមានបុគ្គលប្រៀប ទ្រង់ឡើងកាន់សាគរ គឺញេយ្យធម៌ ទ្រង់ឆ្លងសាគរ គឺសង្សារបានហើយ ដោយសិរសា គឺត្បូង ។

សូមថ្វាយបង្គំព្រះធម៌ដ៏ឧត្តម ជាធម៌ស្ងប់ល្អិតជ្រាលជ្រៅ ឃើញបានដោយក្រ ដែលធ្វើភពតូច និងភពធំឲ្យបរិសុទ្ធ ដែលព្រះសម្ពុទ្ធបូជាហើយ ដោយសិរសា គឺត្បូង ។

សូមថ្វាយបង្គំព្រះសង្ឃដ៏ប្រសើរ លោកប្រាសចាកទុក្ខ មិនមានគ្រឿងជាប់ជំពាក់ គឺកិលេស ជាទក្ខិណេយ្យបុគ្គលដ៏ឧត្តម មានឥន្ទ្រិយស្ងប់រម្ងាប់ ជាអ្នកប្រាសចាកអាសវៈ ដោយសិរសា គឺត្បូង ។

ដោយបទនមស្ការ ព្រះរតនត្រ័យដ៏វិសេស ដែលខ្ញុំបានតាំងចិត្តធ្វើដោយវិសេសនេះ ខ្ញុំដែលព្រះថេរៈទាំងឡាយ ជាអ្នកប្រាជ្ញ ក្រៃលែងជាងអ្នកប្រាជ្ញ ជាអ្នកចេះនូវអាគម គឺបរិយត្តិ ដែលវិញ្ញូជនអារាធនាថា បពិត្រលោកម្ចាស់ លោកម្ចាស់គួររចនាអដ្ឋកថាអបទាន ។

ខ្ញុំត្រូវព្រះថេរៈមានយសធំ អារាធនាដោយដាក់ចិត្តហើយ ដាក់ចិត្តទៀត ជាពិសេសបែបនោះ ព្រោះហេតុនោះ ខ្ញុំនឹងសម្ដែងអត្ថវណ្ណនាដ៏វិចិត្រនៃអបទាន ពោលអំពីរឿងដែលធ្លាប់ប្រព្រឹត្តមកក្នុងកាលមុន ដែលសម្ដែងន័យពិសេសនៃព្រះបាលីក្នុងព្រះត្រៃបិដកពិតជាវិសេស ។

ដោយប្រើវិធីដែលលោកពោលថា ធម៌ដ៏កំពូលនេះ អ្នកណាពោល ពោលក្នុងទីណា ពោលក្នុងកាលណា និងពោលដើម្បីអ្វី ។ ព្រោះហេតុនោះ ដើម្បីភាពជាអ្នកឈ្លាសក្នុងនិទានទាំងឡាយ ខ្ញុំនឹងពោលវិធីនោះៗ ចង្អុលឲ្យឃើញតាមដែលកើតមុន និងក្រោយ នឹងធ្វើឲ្យការរៀនសូធ្យ និងការទន្ទេញបានងាយឡើង ។

លំនាំដើម លោករចនាជាសីហឡភាសា និងមានក្នុងអដ្ឋកថាបុរាណរមែងមិនឲ្យសម្រេចប្រយោជន៍តាមដែលសាធុជនត្រូវការ ហេតុនោះ ខ្ញុំអាស្រ័យន័យតាមអដ្ឋកថាបុរាណនោះ កាត់សេចក្ដីដែលឃ្មៀងឃ្មាតចោលប្រកាសតែអត្ថដែលវិសេស ធ្វើកិច្ចពណ៌នាអត្ថដែលប្លែក និងដែលល្អបំផុតនោះឯង ។

# និទានកថា

ព្រោះខ្ញុំបានប្តេជ្ញាហើយថា ធម៌ដ៏កំពូលនេះ អ្នកណាពោល ពោលក្នុងទីណា ពោលក្នុងកាលណា ខ្ញុំនឹងពណ៌នាអត្ថ ដូច្នេះ កិច្ចពណ៌នាអត្ថនៃអបទាននេះ កាលខ្ញុំសម្តែងនិទានទាំង ៣ នេះ គឺ **ទូរេនិទាន ១ អវិទូរេ-និទាន ១ សន្តិកេនិទាន ១** ហើយពណ៌នា និងធ្វើឲ្យយល់បានជាក់ច្បាស់ ព្រោះអ្នកស្តាប់អបទាននោះ ជ្រាបរឿងមកតាំងអំពីដើម ព្រោះហេតុនោះ ខ្ញុំនឹងសម្តែងនិទានទាំងនោះហើយ ទើបពណ៌នាអបទាននោះតទៅ ។

បណ្តានិទានទាំងនោះ ជាបឋម គប្បីជ្រាបបរិច្ឆេទរបស់និទានទាំងនោះជាមុនសិន ។ កថាមគ្គដែលពោលរឿងតាំងអំពីព្រះមហាសត្វសន្សំអភិនីហារទៀបបាទមូលនៃព្រះពុទ្ធទីបង្ករ រហូតដល់ចុតិចាកអត្តភាពជាព្រះវេស្សន្តរទៅកើតក្នុងស្ថានសួគ៌ជាន់តុសិត ចាត់ជា **ទូរេនិទាន** ។ កថាមគ្គដែលផ្តើមតាំងអំពីចុតិចាកស្ថានសួគ៌ជាន់តុសិត រហូតដល់សម្រេចសព្វញ្ញុតញ្ញាណត្រង់មណ្ឌលពោធិព្រឹក្ស ចាត់ជា **អវិទូរេនិទាន** ។ ឯ **សន្តិកេនិទាន** បានដល់ រឿងដែលមានឡើង កាលព្រះមានព្រះភាគគង់នៅក្នុងទីនោះៗ មានរឿងកើតឡើងក្នុងទីនោះៗ ដូច្នេះ ។

# ទូរេនិទាន

ក្នុងនិទានទាំងនោះ ឈ្មោះថា **ទូរេនិទាន** មានដូចតទៅ

បានឮថា ក្នុងទីបំផុត ៤ អសង្ខេយ្យ និង ១ សែនកប្ប រាប់អំពីភទ្ទកប្បនេះទៅ មាននគរមួយឈ្មោះអមរវតី ក្នុងនគរនោះ មានព្រាហ្មណ៍ឈ្មោះសុមេធនៅអាស្រ័យ សុមេធមានកំណើតល្អទាំង ២ ចំណែក គឺចំណែកខាងមាតា និងខាងបិតា មានគភ៌បរិសុទ្ធរាប់បាន ៧ តំណាត្រកូល មិនមានបុគ្គលណាម្នាក់ជំទាស់ ឬត្រូវពោលដល់រឿងជាតិបាន ជាអ្នកមានរូបស្អាត គួរគយគន់ គួរជ្រះថ្លា ប្រកបដោយពណ៌សម្បុរដ៏វិចិត្រក្រៃលែង មិនធ្វើការងារដទៃឡើយ សិក្សាតែសិប្បៈរបស់ព្រាហ្មណ៍ប៉ុណ្ណោះ ។ មាតាបិតារបស់សុមេធអនិច្ចកម្ម តាំងអំពីសុមេធនៅក្មេង បន្ទាប់មក នាយឃ្លាំងដែលចាត់ចែកគំនរទ្រព្យរបស់សុមេធ នាំបញ្ជីទ្រព្យទាំងអស់មកឲ្យមើល បើកបន្ទប់ដែលពេញដោយមាស ប្រាក់ កែវមណី និងកែវមុក្តាជាដើម រួចប្រាប់ឲ្យជ្រាបដល់ទ្រព្យទាំង ៧ ជួរ ត្រកូលថា បពិត្រកុមារ ទ្រព្យប៉ុណ្ណោះជារបស់មាតា ប៉ុណ្ណោះជារបស់បិតា ប៉ុណ្ណោះជារបស់ជីតា និងតាទួត ហើយប្រាប់ថា សូមលោកម្ចាស់គ្រប់គ្រង ទ្រព្យមានប្រមាណប៉ុណ្ណោះចុះ សុមេធបណ្ឌិតគិតថា បិតា និងជីតាជាដើមរបស់អញ សន្សំទ្រព្យនេះទុកហើយ កាលទៅកាន់បរលោក មិននាំយកទ្រព្យ សូម្បីតែមួយកហាបណៈទៅបាន អញគួរធ្វើហេតុឲ្យនាំទ្រព្យទៅបាន ទើបក្រាបទូលដល់ព្រះរាជាឲ្យវាយស្គរប្រកាសក្នុងព្រះនគរ ឲ្យទានដល់មហាជនហើយ បួសជាតាបស ។ គប្បីឲ្យអត្ថនេះជាក់ច្បាស់ គួរពោលសុមេធកថា ក្នុងទីនេះផងដែរ ។ តែសុមេធកថា

នេះ មានក្នុងពុទ្ធវង្សហើយក៏ពិត តែយល់បានលំបាក ព្រោះជាគាថាព័ន្ធ ព្រោះហេតុនោះ ខ្ញុំនឹងពោលសុមេធកថានោះ មួយអន្លើដោយការពង្រីកសេចក្តីក្នុងគាថាព័ន្ធ ក្នុងវគ្គនោះៗ ផងដែរ ។

## សុមេធកថា

ក្នុងទីបំផុត ៤ អសង្ខេយ្យក្រៃលែងដោយសែនកប្ប រាប់អំពីភទ្ទកប្បនេះទៅ មាននគរមួយឈ្មោះថា **អមរវតី** និងឈ្មោះមួយទៀតថា **អមរ** ដែលអឺងកងដោយសំឡេង ១០ ប្រការ ដែលលោកពោលក្នុងពុទ្ធវង្សថា

ក្នុង ៤ អសង្ខេយ្យ និងមួយសែនកប្ប មាននគរឈ្មោះអមរវតី ជានគរគួរពិតពិលរមិលមើល ជាទីរីករាយនៃចិត្ត ជានគរបរិបូណ៌ដោយបាយ និងទឹក ទាំងមិនស្ងាត់ដោយមានសំឡេង ១០ យ៉ាង ។

បណ្តាបទទាំងនោះ បទថា **ទសហិ សទ្ទេហិ អវិវិត្តំ** សេចក្តីថា ជានគរមិនស្ងាត់ចាកសំឡេង ១០ ប្រការ គឺសំឡេងដំរី សំឡេងសេះ សំឡេងរថ សំឡេងស្គរ សំឡេងសម្ភោរ សំឡេងពិណ សំឡេងច្រៀង សំឡេងស័ង្ខ សំឡេងឈិង និងសំឡេងជាគម្រប់ ១០ ថា ចូរបរិភោគ ចូរផឹក ចូរទំពា ។ ទ្រង់ចែកចំពោះសំឡេងទាំងនោះ ទើបត្រាស់គាថានេះ ក្នុងពុទ្ធវង្សថា

គឺសំឡេងដំរី សំឡេងសេះ សំឡេងស្គរ សំឡេងស័ង្ខ និងសំឡេងរថជាដើម ។ ទាំងជានគរគឹកកងដោយសំឡេង ដែលប្រកបដោយបាយ

និងទឹកថា ចូរស៊ី ចូរផឹក ។ ហើយពោលបន្តថា

ជានគរសម្បូរដោយសត្វ និងគ្រឿងឧបករណ៍ទាំងពួង បរិបូណ៌ដោយការងារគ្រប់យ៉ាង បរិបូណ៌ដោយកែវ ៧ ប្រការ កុះករដោយជនជាតិផ្សេងៗ សម្រេច ( ដោយគ្រឿងបរិភោគ និងឧបភោគទាំងពួង ) ដូចជានគរនៃទេវតា ជាទីនៅនៃជនអ្នកមានបុណ្យទាំងឡាយ ។

វេលានោះ មានសុមេធព្រាហ្មណ៍ នៅក្នុងនគរអមរវតី ជាអ្នកសន្សំនូវទ្រព្យដ៏ច្រើនកោដិ មានទ្រព្យ និងស្រូវច្រើន ។ ជាអ្នករៀនមន្ត្រ ចងចាំនូវមន្ត្រ ដល់នូវត្រើយនៃវេទទាំង ៣ ដល់នូវបារមី ក្នុងលក្ខណៈផង ក្នុងគម្ពីរឥតិហាសៈផង ក្នុងធម៌របស់ព្រាហ្មណ៍ផង ។

ថ្ងៃមួយ សុមេធបណ្ឌិតនៅក្នុងទីស្ងាត់ លើផ្ទៃប្រាសាទជាន់លើដ៏ប្រសើរ អង្គុយពត់ភ្នែនគិតយ៉ាងនេះថា នែបណ្ឌិត ធម្មតា បដិសន្ធិក្នុងភពថ្មីជាទុក្ខ ការបែកធ្លាយសរីរៈក្នុងទីដែលកើតហើយ ក៏ជាទុក្ខដូចគ្នា អាត្មាអញមានការកើត ការចាស់ ការឈឺ ការស្លាប់ជាធម្មតា អាត្មាអញជាបុគ្គលយ៉ាងនេះ គួរស្វែងរកអមតមហានិព្វាន ដែលមិនកើត មិនចាស់ មិនឈឺ មិនស្លាប់ មិនមានទុក្ខ មានតែសុខ ជាធម៌ត្រជាក់ ជាផ្លូវតែមួយ ដែលផុតចាកភព មានប្រក្រតីនាំទៅកាន់ព្រះនិព្វាន គប្បីមានពិតប្រាកដ សមដូចព្រះតម្រាស់ថា

កាលនោះ តថាគតនៅក្នុងទីស្ងាត់ ក៏គិតយ៉ាងនេះថា ធម្មតាភពថ្មីទៀតតែងនាំមកនូវសេចក្តីទុក្ខ ការបែកធ្លាយសរីរៈ ក៏នាំមកនូវសេចក្តីទុក្ខដូច

គ្នា ( សេចក្តីស្ងាប់ប្រកបដោយមោហៈ នាំមកនូវទុក្ខ រូបដែលជរាញាំញី ហើយ ក៏នាំមកនូវទុក្ខ ) អាត្មាអញមានជាតិជាធម្មតា មានជរាជាធម្មតា មានព្យាធិជាធម្មតា អាត្មាអញនឹងស្វែងរកព្រះនិព្វាន ដែលមិនចាស់មិនស្លាប់ ជាទីក្សេមក្សាន្ត ។ បើដូច្នោះ អាត្មាអញ គួរតែលះបង់កាយស្អុយនេះ ដែលពេញដោយសាកសពផ្សេងៗ ជាអ្នកមិនអាឡោះអាល័យ មិនមានសេចក្តីត្រូវការ ហើយនឹងចេញទៅ ។ ផ្លូវនោះ នឹងមានពិត ផ្លូវនោះ មិនមែនជាមិនមានហេតុទេ បុគ្គលអាចទៅបាន អាត្មាអញ នឹងស្វែងរកផ្លូវនោះ ដើម្បីដោះខ្លួនចាកភព ។

បន្ទាប់អំពីនោះ សុមេធបណ្ឌិត ក៏គិតទៅទៀតថា ឈ្មោះថា សុខ ជាបដិបក្ខចំពោះទុក្ខ រមែងមានក្នុងលោក យ៉ាងណា កាលភពមាន វត្ថុដែលប្រាសចាកភព ដែលជាបដិបក្ខចំពោះភពនោះ ក៏រមែងមាន ដូច្នោះ កាលក្តៅមាន ត្រជាក់ដែលជាគ្រឿងរម្ងាត់កម្តៅនោះក៏មាន យ៉ាងណា ព្រះនិព្វានជាគ្រឿងស្ងប់រម្ងាប់ភ្លើង គឺរាគៈជាដើម ក៏រមែងមានយ៉ាងនោះ ធម៌ល្អតមិនមានទោស ជាបដិបក្ខចំពោះធម៌ដែលជាបាបលាមក ក៏រមែងមាន យ៉ាងណា កាលការកើតដ៏លាមកមានព្រះនិព្វាន ពោល គឺការមិនកើត ព្រោះការកើតទាំងពួងអស់ទៅ ក៏រមែងមាន យ៉ាងនោះ ។ សមដូចព្រះតម្រាស់ថា

កាលបើទុក្ខមាន សុខក៏មាន យ៉ាងណា កាលបើភពមាន
ការប្រាសចាកភពបុគ្គលគួរតែប្រាថ្នារក ក៏យ៉ាងនោះដែរ ។
កាលបើក្តៅមានត្រជាក់ដទៃក៏មានយ៉ាងណា កាលបើភ្លើង ៣

ប្រការមានព្រះនិព្វានដែលបុគ្គលគួរប្រាថ្នា ក៏មានយ៉ាងនោះ
ដែរ កាលបើបាបមាន បុណ្យក៏មាន យ៉ាងណា កាលបើ
ជាតិមាន ព្រះនិព្វាន មិនមានជាតិ ដែលបុគ្គលគប្បីប្រាថ្នា
ក៏មានយ៉ាងនោះដែរ ។

សុមេធបណ្ឌិតគិតបន្តទៀតថា បុរសធ្លាក់ក្នុងរណ្តៅលាមក ឃើញស្រះធំ ដេរដាសដោយផ្កាឈូកមានពណ៌ ៥ អំពីចម្ងាយ គួរស្វែងរកផ្លូវទៅកាន់ស្រះនោះថា អញគួរទៅកាន់ស្រះធំនោះតាមផ្លូវណាហ្ន៎ ការមិនទៅរកស្រះនោះ មិនជាទោសរបស់ស្រះឡើយ ជាទោសរបស់បុរសនោះប៉ុណ្ណោះ យ៉ាងណា កាលស្រះទឹក គឺអមតមហានិព្វាន ដែលជាគ្រឿងជម្រះមន្ទិល គឺកិលេសមាន ការមិនទៅរកស្រះទឹក គឺអមតមហានិព្វាននោះ មិនជាទោសរបស់ស្រះ គឺអមតមហានិព្វានឡើយ ជាទោសរបស់បុរសនោះប៉ុណ្ណោះឯង ។ ម្យ៉ាងទៀត បុរសត្រូវពួកចោរ ចោមរោម កាលផ្លូវសម្រាប់រត់គេចមាន បើបុគ្គលនោះមិនគេច សេចក្តីនោះ មិនជាទោសនៃផ្លូវនោះឡើយ តែជាទោស របស់បុរសនោះប៉ុណ្ណោះ យ៉ាងណា បុរសដែលត្រូវកិលេសទាំងឡាយរឹតរុំ កាលផ្លូវដ៏ត្រជាក់ ជាទីទៅកាន់ព្រះនិព្វានមាន តែមិនស្វែងរកផ្លូវ មិនជាទោសនៃផ្លូវឡើយ តែជាទោសរបស់បុរសប៉ុណ្ណោះ យ៉ាងនោះ ដូចគ្នា ។ ម្យ៉ាងទៀត បុរស ត្រូវព្យាធិបៀតបៀន កាលគ្រូពេទ្យអ្នកព្យាបាលរោគមាន បើមិនស្វែងរកគ្រូពេទ្យព្យាបាលជំងឺនោះ សេចក្តីនោះ មិនជាទោសរបស់គ្រូពេទ្យឡើយ តែជាទោសរបស់បុរសប៉ុណ្ណោះ យ៉ាងណា បុគ្គលណា

ត្រូវព្យាធិ គឺកិលេសបៀតបៀន មិនស្វែងរកអាចារ្យ អ្នកឈ្លាសក្នុងផ្លូវដែលធ្វើឲ្យស្ងប់កិលេស ដែលកំពុងមាន សេចក្ដីនោះ ជាទោសរបស់បុរសនោះប៉ុណ្ណោះ មិនជាទោសរបស់អាចារ្យអ្នកធ្វើកិលេសឲ្យវិនាសឡើយ យ៉ាងនោះដូចគ្នា ។ សមដូចព្រះតម្រាស់ថា

បុរសដែលប្រឡាក់លាមក ឃើញស្រះពេញដោយទឹក ហើយ មិនស្វែងរកស្រះ ទោសនោះ មិនមែនជាទោសនៃស្រះទេ យ៉ាងណាមិញ កាលបើស្រះ គឺព្រះនិព្វានមាន ហើយ បុគ្គលមិនស្វែងរកស្រះសម្រាប់លាងនូវកិលេស ជាមន្ទិលចេញទេ ទោសនោះមិនមែនជាទោសនៃស្រះ គឺនិព្វានទេ គឺជាទោសរបស់បុរស ក៏យ៉ាងនោះដែរ ។ បុរសដែលត្រូវ សត្រូវទាំងឡាយចោមព័ទ្ធហើយ កាលបើផ្លូវសម្រាប់រត់ទៅមាន តែបុរសនោះមិនរត់ទៅ ទោសនោះមិនមែនជាទោសនៃផ្លូវទេ យ៉ាងណា បុគ្គលត្រូវកិលេសរួបរឹតហើយ កាលបើផ្លូវព្រះនិព្វានមាន តែមិនស្វែងរកផ្លូវនោះ ទោសនោះ មិនមែនជាទោសនៃផ្លូវនិព្វានទេ គឺជាទោសរបស់បុគ្គលនោះឯង យ៉ាងនោះដែរ ។ បុរសដែលមានជំងឺ កាលបើពេទ្យមាន តែមិនឲ្យពេទ្យនោះព្យាបាលជំងឺនោះទេ ទោសនោះ មិនមែនជាទោសនៃពេទ្យទេ យ៉ាងណា បុគ្គលត្រូវជំងឺ គឺកិលេសទាំងឡាយបៀតបៀនហើយ ដល់នូវ

សេចក្តីទុក្ខ មិនស្វះស្វែងរកអាចារ្យ ទោសនោះ មិនមែន
ជាទោសនៃអាចារ្យទេ គឺជាទោសរបស់បុគ្គលនោះឯង យ៉ាង
នោះដែរ ។

សុមេធបណ្ឌិតគិតបន្តទៀតថា បុគ្គលអ្នកចូលចិត្តតែងខ្លួន រមែងបោះនូវគំរង់ដែលព្យួរត្រង់ក ហើយទៅតាមគាប់ចិត្ត យ៉ាងណា អាត្មាអញគប្បីលះបង់នូវរាងកាយស្អុយនេះ មិនអាឡោះអាល័យ ចូលទៅកាន់នគរ គឺព្រះនិព្វានក៏យ៉ាងនោះ ។

ម្យ៉ាងទៀត បុរសស្ត្រីទាំងឡាយបន្ទោបង់ឧច្ចារៈ និងបស្សាវៈលើផែនដី ដែលស្មោកគ្រោក មិនមែនរើសឧច្ចារៈ ឬបស្សាវៈនោះដាក់ថ្នក់ ឬយកជាយសំពត់ខ្ចប់យកទៅ តែងរង្កៀស លះបង់ទៅ មិនមានអាឡោះអាល័យគេចទៅ យ៉ាងណា អាត្មាអញ ក៏គួរមិនមានសេចក្តីអាល័យ លះបង់រាងកាយស្អុយ ចូលទៅកាន់នគរ គឺអមតមហានិព្វានក៏យ៉ាងនោះ ។

ធម្មតាម្ចាស់ទូក មិនមានសេចក្តីអាល័យ បោះបង់ទូកដែលចាស់គ្រាំគ្រាទៅ យ៉ាងណា អាត្មាអញ ក៏លះបង់រាងកាយនេះ ដែលជាវត្ថុមិនស្អាត ហូរចេញតាមមុខដំបៅទាំង ៩ មិនអាឡោះអាល័យ ចូលទៅកាន់និព្វានបុរីក៏យ៉ាងនោះ ។

បុគ្គលនាំយករតនៈផ្សេងៗ ធ្វើដំណើរទៅជាមួយនឹងពួកចោរ ព្រោះខ្លាចរតនៈរបស់ខ្លួនវិនាស ទើបលះបង់ពួកចោរ ហើយទៅកាន់ផ្លូវដែលផុតភ័យ យ៉ាងណា ករជកាយនេះ ដូចជាចោរប្លន់រតនៈ ក៏យ៉ាងនោះ ។

បើអាត្មាអញធ្វើចំណង់ទុកក្នុងករជកាយនេះ ធម្មរតនៈ គឺអរិយមគ្គ-កុសលរបស់អាត្មាអញនឹងវិនាសទៅ ព្រោះហេតុនោះ អញគួរលះបង់កាយនេះ ដែលដូចជាចោរ ហើយចូលទៅកាន់នគរ គឺអមតមហានិព្វាន ។ សមដូចព្រះតម្រាស់ថា

( បើដូច្នោះ ) គួរតែអាត្មាអញលះបង់កាយស្អុយនេះ ដែលពេញដោយសាកសពផ្សេងៗ ចេញ គប្បីជាអ្នកមិនមានសេចក្តីអាឡោះអាល័យ មិនមានសេចក្តីត្រូវការរូប ហើយចេញទៅ ។ បុរសបានស្រាយសាកសព ដ៏គួរខ្ពើមរអើមដែលជាប់ពួជ័ក គប្បីជាអ្នកមានសេចក្តីសុខ នៅតាមទំនើងខ្លួន មានអំណាចខ្លួនឯង យ៉ាងណាមិញ ។ អាត្មាអញគួរតែលះបង់កាយស្អុយនេះ ដែលជាទីប្រមូលមកនូវសាកសពផ្សេងៗ ចេញ ហើយគប្បីជាអ្នកមិនអាឡោះអាល័យ មិនមានសេចក្តីត្រូវការចេញទៅ យ៉ាងនោះដែរ ។ បុរស ស្ត្រីទាំងឡាយទៅបន្ទោបង់នូវករីស ក្នុងបង្គន់ហើយ ឥតមានអាឡោះអាល័យ ឥតមានសេចក្តីត្រូវការ ដើរចេញទៅ យ៉ាងណាមិញ ឯអាត្មាអញនឹងលះបង់នូវកាយស្អុយនេះ ដែលពេញដោយសាកសពផ្សេងៗ ចេញទៅ ដូចបុរស ស្ត្រីទាំងឡាយដែលបន្ទោបង់វច្ចៈក្នុងបង្គន់ ដូច្នោះឯង ។ ម្ចាស់ទូកទាំងឡាយតែងលះបង់ទូកចាស់ ដែលពុកផុយ លេចចូលទឹក ឥតមាន

អាឡោះអាល័យ ឥតត្រូវការវិញ យ៉ាងណាមិញ អាត្មាអញនឹងលះបង់នូវកាយនេះ ដែលមានរន្ធ ៩ ហូរជានិច្ច ហើយចេញទៅ ដូចជាម្ចាស់ទូក លះចោលទូកចាស់ ដូច្នោះឯង ។ បុរសកាលដើរទៅជាមួយនឹងពួកចោរ យកទ្រព្យជាប់ទៅផង ឃើញភ័យអំពីការខូចខាតទ្រព្យ ក៏លះបង់ហើយដើរទៅយ៉ាងណា កាយនេះ ក៏មានឧបមាស្មើដោយមហាចោរ អាត្មាអញនឹងលះបង់កាយនេះចេញ ព្រោះខ្លាចខូចខាតកុសលធម៌ យ៉ាងនោះដែរ ។

សុមេធបណ្ឌិតគិតអត្ថដែលប្រកបដោយនេក្ខម្មៈនេះ ដោយឧបមាបែបផ្សេងៗ យ៉ាងនេះហើយ លះបង់នូវគំនរកោគទ្រព្យ ដែលរាប់មិនអស់ ក្នុងផ្ទះរបស់ខ្លួនដល់ពួកជន មានមនុស្សកំព្រា និងអ្នកដំណើរជាដើម តាមន័យដែលបានពោលមកហើយខាងដើម ឲ្យមហាទាន លះវត្ថុកាម និងកិលេស-កាមទាំងឡាយ ហើយចេញអំពីអមរនគរម្នាក់ឯងប៉ុណ្ណោះ អាស្រ័យភ្នំឈ្មោះធម្មិក ក្នុងព្រៃហិមពាន្ត សាងអាស្រម សាងបណ្ណសាលា និងទីចង្រ្កមក្បែរអាស្រមនោះ ដើម្បីនាំមកនូវអភិញ្ញាពល ដែលប្រាសចាកទោស គឺនីវរណៈ ៥ ដែលប្រកបដោយគុណ ដែលជាហេតុ ៨ ប្រការ ដែលលោកពោលទុកដោយន័យជាដើមថា កាលចិត្តតាំងមាំយ៉ាងនេះ ដូច្នេះ ទើបលះសំពត់សាដក ដែលប្រកបដោយទោស ៩ ប្រការ ទុកក្នុងអាស្រមបទនោះ ហើយស្លៀកដណ្ដប់សំពត់សម្បកឈើ ដែលប្រកបដោយគុណ ១២ ប្រការ បួស

ជាឥសី លោកបួសយ៉ាងនេះហើយ លះនូវបណ្ណសាលានោះ ដែលដេរដាស ដោយទោស ៨ ប្រការ ចូលទៅកាន់គល់ឈើ ដែលប្រកបដោយគុណ ១០ ប្រការ លះនូវធញ្ញវិកត្តិ គឺស្រូវមានប្រភេទផ្សេងៗ ឆាកមកបរិភោគផ្លែឈើ ផ្តើមនូវសេចក្តីព្យាយាម ដោយអំណាចការអង្គុយ ការឈរ និងការចង្រ្កម ខាងក្នុង ៧ ថ្ងៃនោះឯង ក៏បាននូវសមាបត្តិ ៨ និងអភិញ្ញា ៥ សម្រេច អភិញ្ញា និងពលតាមដែលប្រាថ្នា ដោយប្រការដូច្នេះ សមដូចព្រះតម្រាស់ថា

លុះតថាគតគិតឃើញយ៉ាងនេះហើយ ក៏ឲ្យទ្រព្យជាច្រើនរយកោដិ ដល់ពួកជនដែលមានទីពឹង និងពួកជនដែលឥតទីពឹង ហើយចូលទៅកាន់ ព្រៃហិមពាន្ត ។ មានភ្នំមួយឈ្មោះធម្មិក នៅជិតព្រៃហិមពាន្ត តថាគតធ្វើ អាស្រម សាងបណ្ណសាលា ក្បែរភ្នំនោះ ។ តថាគតនិម្មិតនូវទីចង្រ្កមដែល ប្រាសចាកទោស ៥ ប្រការ នៅក្បែរអាស្រមបទនោះ នាំមកនូវអភិញ្ញា- ពល ដែលប្រកបដោយគុណ ៨ ប្រការ ។ លះបង់សំពត់សាដកដែល ប្រកបដោយទោស ៩ ប្រការ ក្នុងអាស្រមបទនោះ ស្លៀកសំពត់សម្បក ឈើ ដែលប្រកបដោយគុណ ១២ ប្រការវិញ ។ លះបង់បណ្ណសាលាដែល ប្រកបដោយទោស ៨ ប្រការ ចូលទៅកាន់គល់ឈើដែលប្រកបដោយ គុណ ១០ យ៉ាង ។ លះបង់ស្រូវ ដែលគេព្រោះ គេដាំដោយមិនសេសសល់ កាន់យកផ្លែឈើដែលជ្រុះឯង បរិបូណ៌ដោយគុណច្រើនប្រការ ។ តថាគតផ្គងព្យាយាម ក្នុងអាស្រមបទនោះ ( ញុំាំងយប់ និងថ្ងៃឲ្យកន្លងទៅ ) ក្នុងទីអង្គុយ ទីឈរ និងទីចង្រ្កម បានលុះអភិញ្ញាពលក្នុងរវាង ៧ ថ្ងៃ ។

ក្នុងគាថានោះ ដោយបាលីថា **អស្សមោ សុកតោ មយ្ហំ បណ្ណសាលា សុមាបិតា** នេះ ទ្រង់ត្រាស់ហាក់បីដូចសុមេធបណ្ឌិតសាងអាស្រម បណ្ណ-សាលា និងទីចង្ក្រមដោយដៃរបស់ខ្លួន តែក្នុងពាក្យនេះ មានសេចក្តីដូចតទៅ

សក្កទេវរាជ ទ្រង់សម្លឹងឃើញថា ព្រះមហាសត្វចូលព្រៃហិមពាន្ត ហើយ នឹងចូលទៅដល់ធម្មិកបព៌តក្នុងថ្ងៃនេះ ទើបត្រាស់ហៅវិស្សុកម្ម ទេវបុត្រមកប្រាប់ថា នែបា សុមេធបណ្ឌិតចេញទៅ ដោយគិតថា នឹងបួស ចូរអ្នកនិម្មិតលំនៅ ឲ្យសុមេធបណ្ឌិតនោះ ។ វិស្សុកម្មទេវបុត្រនោះ ទទួល ព្រះតម្រាស់របស់សក្កទេវរាជនោះហើយ ទើបនិម្មិតអាស្រមគួរជាទីត្រេកអរ បណ្ណសាលាដ៏ល្អ និងទីចង្ក្រមដែលគួរជាទីត្រេកអរនៃចិត្ត ។ តែព្រះមាន ព្រះភាគ ទ្រង់សំដៅយកអាស្រមបទនោះ ដែលសម្រេចដោយបុញ្ញានុភាព របស់ព្រះអង្គ ក្នុងកាលនោះ ទើបត្រាស់ថា ម្នាលសារីបុត្រ ត្រង់ភ្នំធម្មិក-បព៌តនោះ

តថាគតធ្វើអាស្រម សាងបណ្ណសាលា ក្បែរភ្នំនោះ តថាគតនិម្មិត នូវទីចង្ក្រមដែលប្រាសចាកទោស ៥ ប្រការ នៅក្បែរអាស្រមបទនោះ ។

បណ្តាបទទាំងនោះ បទថា **សុកតោ មយ្ហំ** ( តថាគតសាង...យ៉ាងល្អ ) សេចក្តីថា តថាគតសាងអាស្រមល្អហើយ ។ បទថា **បណ្ណសាលា សុមាបិតា** ( សាងបណ្ណសាលាយ៉ាងល្អ ) សេចក្តីថា សូម្បីសាលា ប្រក់ដោយស្លឹកឈើ ក៏តថាគតបានសាងយ៉ាងល្អ ។

ពាក្យថា នូវទីចង្ក្រមដែលប្រាសចាកទោស ៥ ប្រការ សេចក្តីថា

ឈ្មោះថា ទោសរបស់ទីចង្រ្កមមាន ៥ យ៉ាង គឺមានដីរឹងមិនរាបស្មើ ១ មានដើមឈើនៅខាងក្នុង ១ គ្របដណ្ដប់ដោយមែកឈើ ១ តូចពេក ១ ធំពេក ១ ។

ពិតហើយ កាលព្រះយោគីចង្រ្កមក្នុងទីចង្រ្កម ដែលមានផែនដីរឹង និង ពុំរាបស្មើ ជើងទាំង ២ នឹងឈឺចាប់ ហើមប៉ោងឡើង ចិត្តមិនមានឯកគ្គតា កម្មដ្ឋានទីនវិបត្តិ តែកម្មដ្ឋានទីនដល់ព្រម លុះណាបាននៅ ដោយការផុត ភ័យ ក្នុងផ្ទៃដីដែលទន់ និងរាបស្មើ ព្រោះហេតុនោះ គប្បីជ្រាបថា ផ្ទៃដីរឹង និង ពុំរាបស្មើជាទោសប្រការទី ១ ។

កាលមានដើមឈើនៅខាងក្នុង ត្រង់កណ្ដាល ឬខាងចុងទីចង្រ្កម កាលអាស្រ័យសេចក្ដីប្រមាទ ដើរចង្រ្កម ថ្ងាស ឬក្បាល រមែងទង្គិចដើម ឈើ ព្រោះហេតុនោះ ទីចង្រ្កមដែលមានដើមឈើនៅខាងក្នុង ជាទោស ប្រការទី ២ ។

ព្រះយោគីកាលចង្រ្កមក្នុងទីចង្រ្កម ដែលស្ទុកដោយមែកឈើ ស្មៅ និង វល្លិជាដើម ក្នុងកាលងងឹត ក៏នឹងជាន់សត្វមានពស់ជាដើមស្លាប់ ឬត្រូវពស់ ជាដើមនោះចឹក ទទួលទុក្ខវេទនា ព្រោះហេតុនោះ ទីចង្រ្កមដែលគ្របដណ្ដប់ ដោយមែកឈើ ជាទោសប្រការទី ៣ ។

កាលព្រះយោគីចង្រ្កមក្នុងទីចង្រ្កមដែលតូចពេក គឺទទឹងប្រមាណមួយ ហត្ថ ឬកន្លះហត្ថ អាចភ្លាត់ចាកទីដើរ ក្រចកខ្លះ ម្រាមខ្លះ នឹងប៉ះសងខាង ទីចង្រ្កម ជើងនឹងបែក ព្រោះហេតុនោះ ទីចង្រ្កមដែលតូចពេក ជាទោស

ប្រការទី ៤ ។

កាលព្រះយោគីចង្រ្កមក្នុងទីចង្រ្កមដែលធំពេក ចិត្តរមែងស្ទុះទៅ មិនបានឯកគ្គតា ព្រោះហេតុនោះ ទីចង្រ្កមធំពេក ជាទោសប្រការទី ៥ ។

ទីចង្រ្កមខ្នាតតូច គួរមានទទឹងប្រមាណ ២ ហត្ថកន្លះ និងជាយម្ខាងមួយហត្ថ បណ្តោយប្រមាណ ៦០ ហត្ថ មានផ្ទៃដីទន់ រោយខ្សាច់រាបស្មើ ដូចទីចង្រ្កមរបស់ព្រះមហាមហិន្ទត្ថេរដែលធ្វើអ្នកកោះឲ្យជ្រះថ្លា ក្នុងចេតិយគិរីវិហារ ទីចង្រ្កមរបស់សុមេធមានសភាពដូច្នោះ ព្រោះហេតុនោះ ទើបព្រះមានព្រះភាគត្រាស់ថា តថាគតនិម្មិតនូវទីចង្រ្កមដែលប្រាសចាកទោស ៥ ប្រការ នៅក្បែរអាស្រមបទនោះ ។

ពាក្យថា ដែលប្រកបដោយគុណ ៨ ប្រការ បានដល់ ប្រកបដោយសមណសុខ ៨ ប្រការ ។ សមណសុខ ៨ ប្រការ បានដល់ មិនចាំបាច់រក្សាទ្រព្យ និងស្រូវ ១ ស្វែងរកតែបិណ្ឌបាតដែលមិនមានទោស ១ បរិភោគតែដុំបាយដែលត្រជាក់ ១ មិនមានកិលេស ដែលជាហេតុបៀតបៀននូវរដ្ឋ ( មិនចាំបាច់បង់ពន្ធអាករ ) ក្នុងកាលរាជត្រកូលបៀតបៀន អ្នកស្រុកកាន់យកទ្រព្យដែលមានតម្លៃ មានគជ់ និងកហាបណៈជាដើម ១ ប្រាសចាកតម្រេកដោយការពេញចិត្តក្នុងគ្រឿងឧបករណ៍ទាំងឡាយ ១ មិនខ្លាចចោរប្លន់ដណ្តើមយក ១ មិនចាំបាច់ប្រឡូកប្រឡំជាមួយព្រះរាជា និងមហាមាត្យរបស់ព្រះរាជា ១ មិនទើសទាក់ក្នុងទិសទាំងបួន ១ លោកអធិប្បាយថា នៅក្នុងអាស្រមនោះ អាចបានទទួលសេចក្តីសុខទាំង ៨ ប្រការនេះ ទើប

តថាគតសាងអាស្រមនោះ ដែលប្រកបដោយគុណ ៨ ប្រការនេះ ។

ពាក្យថា បានលុះអភិញ្ញាពល សេចក្តីថា ខាងក្រោយ កាលតថាគតនៅក្នុងអាស្រមនោះ ធ្វើកសិណបរិកម្ម ហើយផ្តើមចម្រើនវិបស្សនា ដោយភាពជារបស់មិនទៀង ដោយភាពជាទុក្ខ ដើម្បីឲ្យអភិញ្ញា និងសមាបត្តិកើតឡើងហើយ ទើបបានវិបស្សនាពល ដែលប្រកបដោយកម្លាំង អធិប្បាយថា តថាគតនៅក្នុងអាស្រមនោះ អាចនាំយកពលនោះមកបាន ដោយប្រការណា តថាគតបានសាងអាស្រមនោះ ឲ្យសមគួរដល់វិបស្សនាពល ដើម្បីអភិញ្ញា ដោយប្រការនោះ ។

ក្នុងពាក្យថា លះបង់សំពត់សាដកដែលប្រកបដោយទោស ៩ ប្រការនេះ មានរឿងតាមលំដាប់ មានអនុបុព្វីកថា ពោលតាមលំដាប់ដូចតទៅ

បានឮថា ក្នុងកាលនោះ កាលវិស្សកម្មទេវបុត្រនិម្មិតអាស្រម ដែលប្រកបដោយកុដិទីពួនសម្ងំ និងទីចង្ក្រមជាដើម ដេរដាសដោយផ្កា និងផ្លែឈើ គួរជាទីត្រេកអរ មានអណ្តូងទឹកមានរសឆ្ងាញ់ ប្រាសចាកម្រឹគកាច និងបក្សី ដែលមានសំឡេងគួរខ្លាច គួរដល់ការស្ងប់ស្ងាត់ មានក្តារដែក្នុងទីបំផុតទាំងសងខាងនៃទីចង្ក្រមដែលរៀបចំហើយ និម្មិតថ្មាំងថ្មដែលមានពណ៌ដូចសណ្តែកបាយ មានផ្ទៃរាបស្មើត្រង់កណ្តាលទីចង្ក្រម ដើម្បីអង្គុយ ។ ខាងក្នុងបណ្ណសាលា បាននិម្មិតវត្ថុគ្រប់យ៉ាង ដែលប្រព្រឹត្តទៅដើម្បីឧបការៈដល់បព្វជិតដូចតទៅនេះ គឺបរិក្ខារតាបស មានជដាមូល សំពត់សម្បកឈើ ឈើចម្តាម ៣ និងកណ្តីទឹកជាដើម ត្រង់បារាំ មានក្អមទឹក ស័ង្ខជងទឹកផឹក

និងផ្តិលដងទឹកត្រង់រោងភ្លើង មានអំបែងសម្រាប់ទ្រទ្រង់ដើកភ្លើង និងខស ជាដើម ត្រង់ជញ្ជាំងបណ្ណសាលា បានរចនាអក្សរថា បុគ្គលណាម្នាក់ មានបំណងនឹងបួស ចូរកាន់យកបរិក្ខារទាំងនេះ ហើយបួសចុះ ស្រេចហើយ ត្រឡប់ទៅកាន់ទេវលោក ។ សុមេធបណ្ឌិតពិនិត្យមើលទីផាសុក ដែលសមគួរដល់ការនៅអាស្រ័យរបស់ខ្លួនតាមញកភ្នំ នាជើងភ្នំហិមពាន្ត បានឃើញអាស្រមដែលគួរត្រេកអរ ដែលសក្កទេវរាជប្រទាន ដែលវិស្សកម្មទេវបុត្រនិម្មិតក្នុងទីដែលមានទឹកវល់ ទើបទៅកាន់ខាងចុងទីចង្ក្រម មិនបានឃើញស្នាមជើង ទើបគិតថា បព្វជិតទាំងឡាយ គង់ទៅស្វែងរកកិក្ខាក្នុងស្រុកជិតហត់នឿយមកហើយ នឹងចូលទៅកាន់បណ្ណសាលា ហើយអង្គុយពិត ទើបរង់ចាំមួយស្របក់ គិតថា យូរណាស់ហើយ អាត្មាអញចង់ដឹងពន់ពេក ទើបបើកទ្វារបណ្ណសាលា ចូលទៅខាងក្នុងហើយ សម្លឹងមើលដោយជុំវិញ បានឃើញអក្សរលើជញ្ជាំងធំហើយ គិតថា កប្បិយបរិក្ខារទាំងនេះជារបស់អញ អញនឹងកាន់យកកប្បិយបរិក្ខារទាំងនេះ ហើយបួស ក៏ដោះគូសំពត់សាដកដែលខ្លួនស្លៀកដណ្តប់ចោល ដោយហេតុនោះ ទើបទ្រង់ត្រាស់ថា លះបង់សំពត់សាដក ម្នាលសារីបុត្ត តថាគតចូលទៅយ៉ាងនេះហើយ ដោះចោលនូវសំពត់សាដក ក្នុងបណ្ណសាលានោះ ។

ពាក្យថា ប្រកបដោយទោស ៩ ប្រការនេះ ទ្រង់សម្តែងថា តថាគតកាលលះបង់សំពត់សាដក ព្រោះបានឃើញទោស ៩ ប្រការ ទើបលះចោល ។ ពិតហើយ សម្រាប់អ្នកបួសជាតាបស ទោស ៩ ប្រការ រមែង

ប្រាកដក្នុងសំពត់សាដក គឺភាពជារបស់មានតម្លៃច្រើនជាទោស ១ កើតឡើងព្រោះទាក់ទងនឹងអ្នកដទៃជាទោស ១ សៅហ្មងរហ័ស សំពត់ដែលប្រឡាក់ត្រូវបោកគក់ ត្រូវជ្រលក់ជាទោស ១ ទ្រុឌទ្រោមអំពីការប្រើប្រាស់ត្រូវធ្វើការដេរភ្ជិត ឬដេរប៉ះជាទោស ១ ស្វែងរកថ្មី ក៏បានដោយលំបាកជាទោស ១ មិនសមគួរដល់ការបួសជាតាបសជាទោស ១ ជារបស់ទូទៅដល់សត្រូវ គឺត្រូវគ្រប់គ្រងរក្សាកុំឲ្យសត្រូវកាន់យកទៅបានជាទោស ១ នៅក្នុងឋានៈជាគ្រឿងប្រដាប់អ្នកប្រើប្រាស់ ( គ្រហស្ថ ) ជាទោស ១ កាលនាំសំពត់ជាប់តាមខ្លួនទៅ ធ្វើឲ្យជាភារៈ ឲ្យកើតនូវការប្រាថ្នាច្រើនជាទោស ១ ។

ពាក្យថា ស្លៀកសំពត់សម្បកឈើ សេចក្ដីថា ម្នាលសារីបុត្រ ក្នុងកាលនោះ តថាគតឃើញទោស ៩ ប្រការនេះ ទើបលះសំពត់សាដក រួចស្លៀកសំពត់សម្បកឈើ គឺកាន់យកសំពត់សម្បកឈើ ដែលធ្វើអំពីស្មៅជំណោកទន្សាយ មកធ្វើជាចម្រៀកៗ ហើយត្បាញ ដើម្បីប្រើប្រាស់ជាសំពត់ដណ្ដប់ ។

ពាក្យថា ដែលប្រកបដោយគុណ ១២ ប្រការ សេចក្ដីថា ប្រកបដោយអានិសង្ស ១២ ប្រការ ។ ពិតហើយ សំពត់សម្បកឈើមានអានិសង្ស ១២ ប្រការ គឺមានតម្លៃថោកសមគួរ នេះជាអានិសង្សទី ១ អាចធ្វើដោយដៃខ្លួនឯងបាន នេះជាអានិសង្សទី ២ សៅហ្មងយឺតយូរ ក្នុងការប្រើប្រាស់កាលបោកគក់ក៏មិនយឺតយូរ នេះជាអានិសង្សទី ៣ កាលរហែក មិនចាំបាច់ដេរប៉ះ នេះជាអានិសង្សប្រការទី ៤ កាលស្វែងរកថ្មី ក៏ធ្វើបានងាយ នេះជា

អានិសង្សទី ៥ សមគួរដល់ការបួសជាតាបស នេះជាអានិសង្សទី ៦ ពួកសត្រូវមិនចង់ប្រើប្រាស់ នេះជាអានិសង្សទី ៧ មិនតាំងនៅក្នុងឋានៈជាគ្រឿងប្រដាប់សម្រាប់អ្នកប្រើប្រាស់ នេះជាអានិសង្សទី ៨ ក្នុងពេលប្រើប្រាស់ជារបស់ស្រាល នេះជាអានិសង្សទី ៩ កាលជាអ្នកប្រាថ្នាតិចក្នុងបច្ច័យ គឺចីវរ នេះជាអានិសង្សទី ១០ ការកើតឡើងនៃសំពត់សម្បកឈើ ជារបស់បានមកដោយធម៌ មិនមានទោស នេះជាអានិសង្សទី ១១ កាលសំពត់សម្បកឈើបាត់ទៅ ក៏មិនសោកស្តាយ នេះជាអានិសង្សទី ១២ ។ ក្នុងពាក្យថា លះបង់បណ្ណសាលាដែលប្រកបដោយទោស ៨ ប្រការនេះ មានពាក្យសួរថា ព្រះតថាគតលះបង់ដូចម្តេច ឆ្លើយថា បានឮថា សុមេធបណ្ឌិតនោះ ដោះនូវគូសំពត់សាដកយ៉ាងល្អចេញ ហើយកាន់យកសំពត់សម្បកឈើពណ៌ក្រហមដូចគ្នានឹងកម្រងផ្កានទោង ដែលពាក់ត្រង់ខ្សែស្បៀង យកមកស្លៀក ហើយដណ្តប់សំពត់សម្បកឈើមួយផ្ទាំងទៀត ដែលមានពណ៌ដូចមាសពីលើសំពត់សម្បកឈើដែលស្លៀកនោះ ហើយធ្វើស្បែកខ្លាទាំងក្រចក ដូចគ្នានឹងសណ្ឋានផ្កាបុសនាគ ធ្វើជាសំពត់ឆៀងស្មា ពាក់នូវជដាមូល ហើយសៀតស្នៀតសក់ធ្វើអំពីឈើខ្លឹមត្រង់ផ្នួងសក់ ដើម្បីឲ្យណែន ដាក់កុណ្ឌីទឹកដែលមានពណ៌ដូចកែវប្រពាលក្នុងសង្រែក ដូចគ្នានឹងសំណាញ់កែវមុក្តា កាន់យកដងរែកដែលឯទន្ទាំ ក្នុងទី ៣ អន្លើ ហើយពាក់កណ្ឌីទឹកត្រង់ចុងដងរែកម្ខាង ពាក់នូវតម្ពក់ល្អី និងឈើចម្ពាម ៣ ជាដើម ត្រង់ចុងដងរែកម្ខាង ហើយយកអំរែកដែលដាក់បរិក្ខារតាបស ដាក់លើចង្កួយស្មា ដៃស្តាំកាន់ឈើច្រត់

ចេញអំពីបណ្ណសាលា ដើរចង្ក្រមត្រឡប់ទៅត្រឡប់មកក្នុងទីចង្ក្រម ជំប្រមាណ ៦០ ហត្ថ សម្លឹងមើលភេទរបស់ខ្លួនហើយ គិតថា មនោរថរបស់អាត្មាអញដល់ទីបំផុតហើយ បព្វជ្ជារបស់អញល្អហ្ន៎ បព្វជ្ជានេះ វីរបុរសទាំងឡាយទាំងពួង មានព្រះពុទ្ធ និងព្រះបច្ចេកពុទ្ធជាដើម សរសើរហើយ គ្រឿងចងរបស់គ្រហស្ថ អញលះបានហើយ អញជាអ្នកចេញបួសហើយ បព្វជ្ជាដ៏កំពូល អញបានហើយ អញនឹងធ្វើសមណធម៌ អញនឹងបានសុខក្នុងមគ្គនិងផល ដូច្នេះហើយ កើតនូវឧស្សាហ៍ ដាក់អម្រែកតាបសបរិក្ខារចុះ ហើយអង្គុយលើផ្ទាំងថ្ម ដែលមានពណ៌ដូចសណ្តែកបាយ ត្រង់ពាក់កណ្តាលទីចង្ក្រម ដូចរូបបដិមាមាស ឲ្យពេលថ្ងៃកន្លងទៅ ក្នុងវេលាល្ងាច ទើបចូលបណ្ណសាលា ដេកលើគ្រែដែលត្បាញដោយមែកឈើ និងផ្តៅ សំដិលខ្លួនឲ្យទទួលអាកាសដ៏ស្រស់ថ្លា ភ្ញាក់ឡើងក្នុងពេលទៀបភ្លឺ ពិចារណាដល់ការមករបស់ខ្លួនថា អញឃើញទោសក្នុងការគ្រប់គ្រងផ្ទះ ទើបលះនូវកោគទ្រព្យរាប់មិនអស់ និងយស ដែលមិនមានទីបំផុត ចូលព្រៃ បួសហើយ ស្វែងរកនេក្ខម្ម: ចាប់តាំងអំពីឥឡូវនេះទៅ អញមិនគួរប្រព្រឹត្តដោយសេចក្តីប្រមាទ ដ្បិតថា រុយ គឺមិច្ឆាវិតក្ក រមែងទំពាស៊ីបុគ្គលដែលលះបង់នូវវិវេកគ្រាច់ទៅ អាត្មាអញចម្រើននូវវិវេកក្នុងឥឡូវនេះ ព្រោះអញឃើញការគ្រប់គ្រងផ្ទះដោយភាពជារបស់មានតែកង្វល់ ទើបចេញបួស បណ្ណសាលានេះ គួរពេញចិត្ត ផ្ទៃដីក៏ធ្វើនូវការពង្រាបយ៉ាងល្អ មានពណ៌ដូចផ្លែព្នៅទុំ ជញ្ជាំងពណ៌សដូចប្រាក់ ដំបូលប្រក់ដោយស្លឹកឈើ មានពណ៌ដូចជើងព្រាប គ្រែផ្តៅមាន

ពណ៌ដូចសំពត់ដ៏ត្រកាល លំនៅនេះ ជាទីផាសុក ផ្ទះរបស់អញ ក៏មិនមានការដល់ព្រមជាងនេះ កាលពិចារណាទោសរបស់បណ្ណសាលា ក៏បានឃើញទោស ៨ ប្រការ ។

ពិតហើយ ការប្រើប្រាស់បណ្ណសាលា មានទោស ៨ ប្រការ គឺត្រូវស្វែងរកដោយការប្រមូលទព្វសម្ភារៈធ្វើដោយការផ្ដើមយ៉ាងធំជាទោសទី ១ ត្រូវជួសជុលជានិច្ច ព្រោះកាលស្មៅ ស្លឹកឈើ និងដីឥដ្ឋរបេះ ត្រូវយកវត្ថុទាំងនោះមកទុកក្នុងទីដើមវិញម្ដងហើយម្ដងទៀតជាទោសទី ២ ធម្មតាសេនាសនៈ ត្រូវបានដល់បុគ្គលដែលចាស់ជាង កាលអាត្មាអញ ត្រូវដាស់ឲ្យក្រោកឡើងពុំជួកាល ឯកគ្គតាចិត្តនឹងមិនមាន ព្រោះហេតុនោះ ការត្រូវដាស់ឲ្យក្រោកឡើងជាទោសទី ៣ ធ្វើរាងកាយឲ្យទន់ខ្សោយ ព្រោះមិនត្រូវត្រជាក់ និងកម្ដៅជាដើមជាទោសទី ៤ បុគ្គលនៅក្នុងផ្ទះ អាចធ្វើនូវអំពើអាក្រក់ណាមួយបាន ព្រោះហេតុនោះ ការបិទបាំងនូវការនិន្ទា ជាទោសទី ៥ កើតនូវការហួងហែងថា ជារបស់អញជាទោសទី ៦ ត្រូវនឹកគិតថា មានផ្ទះត្រូវមានគូជាទោសទី ៧ ភាពជារបស់សាធារណៈដល់មនុស្សច្រើន ព្រោះជារបស់សាធារណៈសម្រាប់សត្វ មានស្អុច សង្កើច និងតុកកែ ជាដើម ជាទោសទី ៨ ។

ព្រះមហាសត្វឃើញទោស ៨ ប្រការនេះ ទើបលះបង់នូវបណ្ណសាលា ដោយប្រការដូច្នេះ ព្រោះហេតុនោះ ទើបទ្រង់ត្រាស់ថា តថាគតលះបង់បណ្ណសាលាដែលប្រកបដោយទោស ៨ ប្រការ ដូច្នេះ ។

ពាក្យថា ចូលទៅកាន់គល់ឈើដែលប្រកបដោយគុណ ១០ យ៉ាង សេចក្ដីថា ព្រះមានព្រះភាគត្រាស់ថា តថាគតបដិសេធនូវទីប្រក់ប្រាំង ចូលទៅអាស្រ័យគល់ឈើ ដែលប្រកបដោយគុណ ១០ ប្រការ ។

ក្នុងការនៅដោយគល់ឈើនោះ មានគុណ ១០ ប្រការ គឺមានការប្រារព្ធ គឺការកសាងតិចជាគុណទី ១ ព្រោះត្រឹមតែចូលទៅ ក៏នៅក្នុងទីនោះបាន មានការថែទាំតិចជាគុណទី ២ ព្រោះគល់ឈើនោះ បោសក្ដី មិនបោសក្ដី ក៏ប្រើប្រាស់បានតាមសប្បាយ ការដែលមិនត្រូវជាស់ឲ្យក្រោកឡើងជាគុណទី ៣ មិនបិទបាំងនូវពាក្យនិន្ទា កាលធ្វើអាក្រក់ត្រង់គល់ឈើនោះ រមែងខ្មាស ព្រោះហេតុនោះ ការបិទបាំងនូវការនិន្ទាមិនបាន ជាគុណទី ៤ មិនធ្វើរាងកាយឲ្យទន់ខ្សោយ ដូចគ្នានឹងនៅក្នុងទីវាល ព្រោះហេតុនោះ ការដែលរាងកាយមិនទន់ខ្សោយជាគុណទី ៥ មិនមានការហួងហែងជាគុណទី ៦ ឃាត់នូវអាល័យ គឺមិនហួងហែងថាជាផ្ទះជាគុណទី ៧ មិនមានការដេញដោយពាក្យថា ខ្ញុំនឹងបោស ខ្ញុំនឹងជូតត្រង់នេះ ចូលចេញទៅ ដូចក្នុងផ្ទះដែលទូទៅដល់មនុស្សច្រើនជាគុណទី ៨ បុគ្គលអ្នកនៅមានបីតិជាគុណទី ៩ មិនមានការជាប់ជំពាក់ព្រោះសេនាសនៈ គឺគល់ឈើរកបានងាយ ក្នុងទីគ្រប់អន្លើជាគុណទី ១០ ។

ព្រោះទ្រង់ឃើញគុណ ១០ ប្រការនេះ ទើបត្រាស់ថា តថាគតចូលទៅកាន់គល់ឈើ ដូច្នេះ ។

ព្រះមហាសត្វពិចារណាឃើញហេតុមានប្រមាណប៉ុណ្ណោះហើយ ស្អែក

ឡើង ទើបចូលទៅរកភិក្ខាក្នុងស្រុក ។ កាលនោះ ពួកមនុស្សក្នុងស្រុក ដែលសុមេធទៅដល់ បានប្រគេនភិក្ខាដោយឧស្សាហ៍ធំ ។ សុមេធធ្វើភត្ត-កិច្ចស្រេចហើយ ត្រឡប់មកកាន់អាស្រម អង្គុយហើយ គិតថា អញមិនមែនបួសដោយទន្ទឹងថា នឹងបានអាហារ ធម្មតាអាហារដ៏ល្អិតនេះ រមែងចម្រើននូវការស្រវឹងព្រោះមានះ និងស្រវឹងក្នុងភាពជាបុរស សេចក្ដីទុក្ខដែលមានអាហារជាមូល ក៏នឹងមិនមានទីបំផុត បើដូច្នោះ អញគប្បីលះនូវអាហារដែលកើតអំពីការសាបព្រោះ និងស្រូវដែលដាំ បរិភោគផ្លែឈើដែលជ្រុះឯង ។ ចាប់តាំងអំពីនោះ ព្រះមហាសត្វបានធ្វើតាមនោះ ព្យាយាមខាងក្នុងមួយសប្ដាហ៍ប៉ុណ្ណោះ ក៏ធ្វើនូវសមាបត្តិ ៨ និងអភិញ្ញា ៥ ឲ្យកើតឡើង ព្រោះហេតុនោះ សមដូចព្រះតម្រាស់ថា

លះបង់ស្រូវដែលគេព្រោះ គេដាំ ដោយមិនសេសសល់ កាន់យកផ្លែឈើដែលជ្រុះឯង បរិបូណ៌ដោយគុណច្រើនប្រការ ។

តថាគតផ្គងព្យាយាម ក្នុងអាស្រមបទនោះ ( ញុំាងយប់ និងថ្ងៃឲ្យកន្លងទៅ ) ក្នុងទីអង្គុយ ទីឈរ និងទីចង្ក្រម បានលុះអភិញ្ញាពលក្នុងរវាង ៧ ថ្ងៃ ។

កាលសុមេធតាបស សម្រេចអភិញ្ញាពលយ៉ាងនេះហើយ ឲ្យពេលវេលាកន្លងទៅដោយសេចក្ដីសុខ ដែលកើតអំពីសមាបត្តិ ។ ព្រះសាស្ដាព្រះនាមទីបង្ករ បានកើតឡើងក្នុងលោក ។ ក្នុងបដិសន្ធិ ប្រសូត ត្រាស់ដឹង និងការប្រកាសធម្មចក្ររបស់ព្រះសាស្ដាអង្គនោះ លោកធាតុមួយម៉ឺនរំពើក

ញាប់ញ័រ ។ បុព្វនិមិត្ត ៣២ ប្រការ ប្រាកដឡើងហើយ ។ សុមេធតាបស ឲ្យពេលវេលាកន្លងទៅ ដោយសេចក្ដីសុខក្នុងសមាបត្តិ មិនបានឮសំឡេងនោះ មិនបានឃើញបុព្វនិមិត្តទាំងនោះ ព្រោះហេតុនោះ ទើបព្រះមានព្រះភាគត្រាស់ថា

កាលតថាគតសម្រេចអភិញ្ញាហើយ ជាអ្នកមានវសី ក្នុង
សាសនានៃតាបស កាលនោះ ព្រះជិនស្រី ព្រះនាមទីបង្ករ
ជានាយកនៃលោក ទ្រង់កើតឡើង ។

កាលព្រះពុទ្ធចាប់បដិសន្ធិផង ប្រសូតផង កាលត្រាស់ដឹងផង សម្ដែងធម្មចក្កផង តថាគតជាអ្នកឆ្អែតស្កប់ស្កល់ ដោយសេចក្ដីត្រេកអរក្នុងឈាន ប៉ុន្តែ មិនបានឃើញនូវនិមិត្តទាំង ៤ ឡើយ ។

ក្នុងកាលនោះ ព្រះទសពលព្រះនាមទីបង្ករ មានព្រះខីណាស្រព ៤ សែនចោមរោមហើយ ចារិកទៅដោយលំដាប់ រហូតដល់រម្មនគរ ទ្រង់គង់ក្នុងសុទស្សនមហាវិហារ ។ អ្នកស្រុករម្មនគរបានដំណឹងថា បានឮថា ព្រះសម្ពុទ្ធព្រះនាមទីបង្ករ ជាធំជាងសមណៈ ទ្រង់សម្រេចអភិសម្ពោធិញ្ញាណដ៏កំពូល ទ្រង់ប្រកាសធម្មចក្រដ៏បវរ ទ្រង់ចារិកទៅដោយលំដាប់ មកដល់រម្មនគររបស់ពួកយើងហើយ ទ្រង់នៅអាស្រ័យក្នុងសុទស្សនមហាវិហារ នាំគ្នាកាន់យកភេសជ្ជៈ មានសប្បិ និងទឹកដោះខាប់ជាដើម និងគ្រឿងស្លៀកដណ្ដប់ កាន់គ្រឿងក្រអូប និងផ្កាជាដើម នាំគ្នារូតរះទៅ រហូតដល់ទីដែលព្រះពុទ្ធ ព្រះធម៌ និងព្រះសង្ឃគង់ ចូលគាល់ព្រះសាស្ដា ថ្វាយបង្គំហើយ

បូជាដោយគ្រឿងក្រអូប និងផ្កាជាដើម ហើយអង្គុយក្នុងទីសមគួរនាចំណែកម្ខាង ស្តាប់ព្រះធម្មទេសនា ទូលនិមន្តដើម្បីសោយក្នុងថ្ងៃស្អែក ហើយនាំគ្នាក្រោកចាកអាសនៈ ត្រឡប់ទៅ ។

ស្អែកឡើង ជនទាំងនោះ នាំគ្នាត្រៀមមហាទាន ប្រដាប់តាក់តែងព្រះនគរ ធ្វើផ្លូវសម្រាប់យាងមកនៃព្រះទសពលក្នុងទីដែលមានទឹកជក់ យកដីលុប ធ្វើផ្ទៃដីឲ្យរាបស្មើ រោយខ្សាច់ ដែលមានពណ៌ដូចប្រាក់ បាចលាជ និងផ្កា យកសំពត់ដែលមានពណ៌ផ្សេងៗ លើកជាទង់មានជាយ និងទង់ជ្វាលា តម្កល់នូវដើមចេក និងក្អមដែលមានទឹកពេញ ។ ក្នុងកាលនោះ សុមេធ-តាបសហោះពីអាស្រមរបស់ខ្លួន ឡើងកាន់អាកាស ហើយហោះអំពីខាងលើមនុស្សទាំងនោះ ឃើញពួកមហាជនរីករាយ គិតថា មានហេតុអ្វីហ្ន៎ ទើបចុះអំពីអាកាស ឈរក្នុងចំណែកម្ខាង សួរមនុស្សទាំងឡាយថា លោកដ៏ចម្រើន ពួកលោកនាំគ្នាតាក់តែងផ្លូវដែលមិនរាបស្មើក្នុងទីនេះ ដើម្បីអ្នកណាហ្ន៎ ។ សមដូចព្រះមានព្រះភាគត្រាស់ថា

ពួកមហាជន ក្នុងបច្ចន្តប្រទេស មានចិត្តត្រេកអរ និមន្តព្រះ
តថាគត បាននាំគ្នាជម្រះផ្លូវជាទីមកនៃព្រះតថាគតនោះ ។

សម័យនោះឯង តថាគតចេញអំពីអាស្រមរបស់ខ្លួន កាលរលាស់ចីវរសម្បកឈើ ហោះទៅឯអាកាស តថាគតឃើញជនកំពុងតែពេញចិត្ត ត្រេកអរ ស្រស់ស្រាយ រីករាយ ក៏ចុះអំពីអាកាសហើយ សួរមនុស្សទាំងឡាយ ក្នុងខណៈនោះថា មហាជនត្រេកអរ ស្រស់ស្រាយ រីករាយ ពេញចិត្ត ជម្រះ

ផ្លូវគន្ធប្រឡាយ ដើម្បីអ្នកណា ។

មនុស្សទាំងឡាយប្រាប់ថា បពិត្រសុមេធដ៏ចម្រើន លោកម្ចាស់មិនដឹងទេឬថា ព្រះទសពលសម្មាសម្ពុទ្ធ ព្រះនាមទីបង្ករ ត្រាស់ដឹងនូវសម្ពោធិញ្ញាណហើយ ប្រកាសធម្មចក្រដ៏បវរ ទ្រង់ចារិកមកដល់នគររបស់ពួកយើង ទ្រង់អាស្រ័យក្នុងសុទស្សនមហាវិហារ ពួកយើងទូលនិមន្តព្រះមានព្រះភាគមក ទើបនាំគ្នាធ្វើផ្លូវរបស់ព្រះមានព្រះភាគ សម្មាសម្ពុទ្ធអង្គនោះ ។ លំដាប់នោះ សុមេធតាបសគិតថា ត្រឹមតែពាក្យប្រកាសថា **ពុទ្ធោ** ក៏រកបានដោយក្រក្នុងលោក នឹងពោលថ្វី ដល់ការកើតឡើងនៃព្រះពុទ្ធ អាត្មាអញ ក៏គួររួមចំណែកជាមួយមនុស្សទាំងនេះ ធ្វើផ្លូវដើម្បីព្រះទសពលផងដែរ ។ ទើបពោលនឹងមនុស្សទាំងនោះថា អ្នកដ៏ចម្រើន បើអ្នកទាំងឡាយតាក់តែងផ្លូវនេះ ដើម្បីព្រះពុទ្ធសោត ចូរពួកអ្នកឲ្យឱកាសមួយកន្លែងដល់ខ្ញុំ ខ្ញុំនឹងតាក់តែងផ្លូវជាមួយពួកអ្នក មនុស្សទាំងនោះទទួលថា សាធុ ដឹងថាសុមេធតាបសមានឫទ្ធិ ទើបកំណត់យកឱកាសដែលមានទឹកដក់ឲ្យ ដោយពាក្យថា សូមលោកធ្វើក្នុងទីនេះ ។ សុមេធតាបសកាន់យកបីតិ មានព្រះពុទ្ធជាអារម្មណ៍ថា អញអាចតាក់តែងឱកាសនេះដោយឫទ្ធិបាន តែឱកាសទទេដែលអញតាក់តែងដោយឫទ្ធិយ៉ាងនេះ មិនធ្វើឲ្យអញត្រេកអរ ថ្ងៃនេះ អញគួរធ្វើការខ្វល់ខ្វាយដោយកាយ ទើបដញ្ជូនដីមកលុបក្នុងទីនោះ ។

កាលសុមេធតាបសធ្វើទីនោះមិនទាន់ស្រេច ព្រះពុទ្ធទីបង្ករទសពលមានព្រះខីណាស្រព ៤ សែនរូប សុទ្ធសឹងតែបានអភិញ្ញា ៦ ចោមរោម

កាលពួកទេវតាបូជាដោយគ្រឿងក្រអូប និងផ្កាទិព្វជាដើម បន្លឺតន្ត្រីទិព្វ ច្រៀងនូវចម្រៀងទិព្វ កាលពួកមនុស្សបូជាដោយគ្រឿងក្រអូប និងផ្កាជាដើម មួយអន្លើដោយតន្ត្រីដែលជារបស់មនុស្ស ទ្រង់ក៏យាងតាមផ្លូវដែលតាក់តែងនោះ ដោយពុទ្ធលីលា មិនអាចប្រៀបបាន ដូចរាជសីហ៍សម្តែងឫក លើមនោសិលា ដូច្នោះ ។ កាលព្រះទសពលយាងមកតាមផ្លូវ ដែលតាក់តែងទុកហើយនោះ សុមេធតាបសបើកភ្នែកសម្លឹងព្រះវរកាយរបស់ព្រះទសពល ដែលដល់នូវលម្អដោយព្រះរូបឆោម ដែលប្រដាប់ដោយមហាបុរិសលក្ខណៈ ៣២ ប្រការ លម្អដោយអនុព្យញ្ជនៈ ៨០ ចោមរោមដោយព្រះរស្មីប្រមាណមួយព្យាម បញ្ចេញព្រះពុទ្ធរស្មីមានពណ៌ ៦ ជាវង់ធំៗ និងជាគូៗ ដូចផ្លេកបន្ទោរច្រើនពណ៌ក្នុងអាកាស ដែលមានពណ៌ដូចកែវមណី ទើបគិតថា ថ្ងៃនេះ អញគួរបរិច្ចាគជីវិតដើម្បីព្រះទសពល ព្រះមានព្រះភាគកុំបីជាន់ភក់ តែសូមទ្រង់ជាន់លើខ្នងអញយាងទៅជាមួយព្រះខីណាស្រព ៤ សែនអង្គ ដូចជាន់ស្ពានកែវមណី ដូច្នោះ សេចក្តីនោះ នឹងប្រព្រឹត្តទៅដើម្បីជាប្រយោជន៍ និងសេចក្តីសុខដល់អាត្មាអញអស់កាលយូរ កាលគិតហើយ ក៏រំសាយសក់ ហើយយកស្បែកខ្លាជជាមណ្ឌល និងសំពត់សម្បកឈើក្រាលលើភក់ ដែលមានពណ៌ខ្មៅ ហើយដេកលើភក់ សណ្តូកដូចជាស្ពានកែវមណី ។ សមដូចព្រះតម្រាស់ថា

ពួកជនទាំងនោះ ដែលតថាគតសួរហើយ ក៏ឆ្លើយប្រាប់ថា
ព្រះពុទ្ធដ៏ប្រសើរក្នុងលោក ជាព្រះជិនស្រី ព្រះនាមទីបង្ករ

ជាលោកនាយក ទ្រង់កើតឡើងហើយ ពួកយើងខ្ញុំជម្រះផ្លូវ គន្ទងប្រឡាយ ដើម្បីព្រះពុទ្ធទីបង្ករនោះ ។ បីតិកើតឡើង ដល់តថាគតក្នុងខណៈនោះ ព្រោះតែឮពាក្យថា ព្រះពុទ្ធ តថាគតទន្ទេញថា ព្រះពុទ្ធ ព្រះពុទ្ធ ដូច្នេះហើយ ក៏បានទនូវ សោមនស្ស ។ តថាគតស្ថិតនៅក្នុងប្រទេសនោះ ត្រេកអរ មានចិត្តតក់ស្លុត គិតថា អាត្មាអញនឹងបណ្តុះពូជកុសលក្នុង បុញ្ញក្ខេត្តនេះ កុំឲ្យខណៈកន្លងទៅទទេឡើយ ។ ( លុះគិត ដូច្នេះហើយ ក៏និយាយទៅរកមហាជនថា ) បើអ្នកទាំងឡាយ ជម្រះផ្លូវថ្វាយព្រះពុទ្ធ ចូរឲ្យឱកាសមួយដល់អាត្មាផង អាត្មា នឹងជម្រះផ្លូវប្រឡាយដែរ ។ កាលនោះ ពួកជនទាំងនោះក៏ឲ្យ ឱកាសមួយដល់តថាគត ដើម្បីជម្រះផ្លូវ តថាគតគិតថា ព្រះ ពុទ្ធ ព្រះពុទ្ធ ដូច្នេះ ជម្រះផ្លូវបណ្តើរ ក្នុងឱកាសនោះ ។ កាលដែលឱកាស ( ផ្លូវ ) របស់តថាគតធ្វើមិនទាន់សម្រេច នៅឡើយ ស្រាប់តែព្រះជិនស្រីជាអ្នកប្រាជ្ញធំ ព្រះនាមទីបង្ករ ស្តេចយាងមកតាមផ្លូវ ជាមួយនឹងព្រះខីណាស្រព ៤ សែន រូប សុទ្ធតែជាអ្នកបានអភិញ្ញា ៦ ជាតាទិបុគ្គល ប្រាសចាក មន្ទិល ។ ការក្រោកទទួល ( ព្រះសាស្តា ) ក៏ប្រព្រឹត្តទៅ ស្គរទាំងឡាយជាច្រើន ក៏លាន់ឮឡើងគគ្រឹកគគ្រេង ពួកមនុស្ស និងទេវតា ក៏ត្រេកអរ ញ៉ាំងសាធុការឲ្យប្រព្រឹត្តទៅ ។ ពួក

ទេវតា ឃើញពួកមនុស្ស ឯពួកមនុស្ស ក៏ឃើញពួកទេវតា ទេវតា និងមនុស្សទាំងពីរពួកនេះ បានផ្គងអញ្ជលី ដើរដង្ហែព្រះតថាគត ។ ពួកទេវតាប្រគំតូរ្យតន្ត្រីទិព្វទាំងឡាយ ពួកមនុស្ស ក៏ប្រគំតូរ្យតន្ត្រីជារបស់មនុស្សទាំងឡាយ ពួកទេវតានិង មនុស្សទាំងពីរក្រុមនេះ ប្រគំភ្លេងដង្ហែព្រះតថាគត ។ ពួកទេវតាដែលស្ថិតនៅឰដ៏អាកាស ក៏រោយរាយផ្កាមន្ទារវបុស្ស ផ្កាឈូក ផ្កាបារិច្ឆត្តកព្រឹក្សជាទិព្វ ឰដ៏អាកាស អំពីទិសតូចទិសធំ ។ ពួកទេវតាដែលស្ថិតនៅឰដ៏អាកាស ក៏រោយរាយលម្អិតខ្លឹមចន្ទន៍ទិព្វផង គ្រឿងក្រអូបដ៏ប្រសើរទាំងអស់ផង អំពីទិសតូចទិសធំឰដ៏អាកាស ។ ពួកមនុស្សដែលស្ថិតនៅលើផែនដី ក៏រោយរាយផ្កាចម្ប៉ា ផ្កាស្រល់ ផ្កាខ្ទម្ព ផ្កាខ្លឹង ផ្កាបុសនាគ និងផ្កាកាកេស អំពីទិសតូចទិសធំ ។ តថាគតរំសាយសក់ត្រង់ប្រទេសនោះ ហើយក្រាលចីវរសម្បកឈើ និងកំណាត់ស្បែកលើភក់ ហើយដេកផ្កាប់មុខ ( អធិដ្ឋានថា ) សូមព្រះពុទ្ធ ព្រមទាំងពួកសិស្ស ជាន់អាត្មាអញយាងទៅចុះ សូមកុំជាន់ភក់ឡើយ ការមិនជាន់លើភក់នោះនឹងជាប្រយោជន៍ដល់អាត្មាអញ ។

សុមេធតាបសនោះ ដេកលើភក់នោះឯង បើកភ្នែកសម្លឹងម្ខាងទៀត ឃើញពុទ្ធសិរីរបស់ព្រះទីបង្ករទសពល ទើបគិតថា បើអញត្រូវការរម្ងត់

កិលេស ក៏រមែងធ្វើបាន តែអញក៏ត្រឹមតែអ្នកបួសថ្មីក្នុងសង្ឃ ដែលដុតកិលេសបានអស់ហើយដើរនៅក្នុងរម្មនគរ ។ អាត្មាអញមិនមានកិច្ចដោយការដុតនូវកិលេសហើយសម្រេចនិព្វាន ដោយភេទដែលមិនមានអ្នកណាស្គាល់ បើដូច្នោះ អញគួរសម្រេចអភិសម្ពោធិញ្ញាណដ៏ប្រសើរ ដូចព្រះទីបង្ករទសពល ហើយលើកមហាជនឡើងកាន់ធម្មនាវា នាំឆ្លងសង្សារសាគរមុន សឹមបរិនិព្វានខាងក្រោយ សេចក្តីនេះ សមគួរដល់អញ បន្ទាប់អំពីនោះ ក៏ធ្វើសេចក្តីប្រាថ្នាយ៉ាងធំក្រៃលែង ដើម្បីត្រាស់ជាព្រះពុទ្ធ ហើយដេក ជាការប្រមូលសមោធានធម៌ ៨ ប្រការ ឲ្យគ្រប់គ្រាន់ សមដូចព្រះតម្រាស់ថា

> កាលតថាគតដេកលើផែនដី ក៏មានសេចក្តីត្រិះរិះដោយចិត្តយ៉ាងនេះថា បើអាត្មាអញប្រាថ្នាដុតកិលេសទាំងឡាយ របស់អញក្នុងថ្ងៃនេះក៏បាន ។ តែថា ប្រយោជន៍អ្វី អាត្មាអញធ្វើឲ្យជាក់ច្បាស់នូវធម៌ ដោយភេទដែលគេមិនស្គាល់ ក្នុងទីនេះ អាត្មាអញ គប្បីដល់នូវសព្វញ្ញុតញ្ញាណ ជាអ្នករួចស្រឡះចាកកិលេស ញុំាំងលោក ព្រមទាំងទេវលោក ឲ្យរួចរដោះ ( ចាកសង្សារ ) ។ ប្រយោជន៍អ្វី អាត្មាអញ ជាបុរសសម្តែងកម្លាំងឆ្លងទៅម្នាក់ឯង អាត្មាអញគួរដល់នូវសព្វញ្ញុ-តញ្ញាណ ចម្លងមនុស្សលោក ព្រមទាំងទេវលោក ។ អាត្មាអញ នឹងបានដល់នូវសព្វញ្ញុតញ្ញាណ ចម្លងប្រជុំជនច្រើន

ដោយអធិការនេះ ដែលអាត្មាអញធ្វើចំពោះព្រះពុទ្ធ ជាបុរសខ្ពង់ខ្ពស់ ។ តថាគតនឹងកាត់ខ្សែសង្សារ កម្ចាត់បង់កពទាំង ៣ ឡើងជិះលើនាវា គឺធម៌ នឹងចម្លងមនុស្សលោក ព្រមទាំងទេវលោក ។

ព្រោះថា ការប្រាថ្នាដ៏ធំក្រៃលែងអាចសម្រេចបាន ព្រោះសមោធានធម៌ ៨ ប្រការ គ្រប់គ្រាន់ គឺភាពជាមនុស្ស ១ ដល់ព្រមដោយភេទ ១ មានហេតុ ១ បានជួបព្រះសាស្តា ១ កាន់យកភេទបព្វជ្ជា ១ មានគុណសម្បត្តិ ១ ធ្វើអធិការ ១ មានឆន្ទៈ ១ ។

ពិតហើយ បុគ្គលដែលប្រាថ្នាភាពជាព្រះពុទ្ធ ត្រូវតាំងនៅក្នុងអត្តភាពមនុស្សប៉ុណ្ណោះ ហើយប្រាថ្នា ទើបការប្រាថ្នាសម្រេច ការប្រាថ្នារបស់នាគ គ្រុឌ ទេវតា ឬសក្កទេវរាជ មិនសម្រេចឡើយ ។

ក្នុងអត្តភាពមនុស្ស ត្រូវតាំងនៅក្នុងភេទបុរសប៉ុណ្ណោះ ទើបសេចក្តីប្រាថ្នាសម្រេច សេចក្តីប្រាថ្នារបស់ស្រី ឬរបស់ខ្ទើយ និងឧភតោព្យញ្ជនៈ មិនសម្រេចឡើយ ។

សូម្បីបុរស សម្រាប់បុគ្គលដែលមានហេតុ គឺអាចសម្រេចអរហត្តក្នុងអត្តភាពនោះបានប៉ុណ្ណោះ ទើបសេចក្តីប្រាថ្នាសម្រេច បុគ្គលក្រៅពីនេះ មិនសម្រេចឡើយ ។

កាលបុគ្គលសម្បូរដោយហេតុ ត្រូវប្រាថ្នាក្នុងសម្នាក់របស់ព្រះពុទ្ធ ដែលគង់ព្រះជន្មនៅប៉ុណ្ណោះ ទើបសេចក្តីប្រាថ្នាសម្រេច កាលព្រះសម្ពុទ្ធ

បរិនិព្វានហើយ បុគ្គលនោះ ប្រាថ្នាក្នុងទីជិតព្រះចេតិយ ឬត្រង់គល់ពោធិ-ព្រឹក្ស មិនសម្រេចឡើយ ។

បុគ្គលប្រាថ្នាក្នុងសម្នាក់របស់ព្រះពុទ្ធ បុគ្គលនោះ ត្រូវតាំងនៅក្នុងបព្វជ្ជាភេទប៉ុណ្ណោះ ទើបសេចក្ដីប្រាថ្នាសម្រេច សម្រាប់បុគ្គលដែលតាំងនៅក្នុងភេទយាវាស មិនសម្រេចឡើយ ។

បុគ្គលដែលបួសហើយ ត្រូវបានអភិញ្ញា ៥ និងសមាបត្តិ ៨ ប៉ុណ្ណោះ ទើបសេចក្ដីប្រាថ្នាសម្រេច បុគ្គលប្រាសចាកគុណសម្បត្តិនេះ មិនសម្រេចឡើយ ។

បុគ្គលដែលសម្បូរហើយដោយគុណក្ដី បុគ្គលណាដល់ព្រមដោយអធិការ គឺការបរិច្ចាគជីវិតខ្លួនដល់ព្រះពុទ្ធ ដូចសុមេធតាបសនេះប៉ុណ្ណោះ ទើបសេចក្ដីប្រាថ្នាសម្រេច បុគ្គលក្រៅអំពីនេះ មិនសម្រេចឡើយ ។

បុគ្គលដែលដល់ព្រមដោយអធិការ សេចក្ដីប្រាថ្នា រមែងសម្រេចបានដល់បុគ្គលដែលមានឆន្ទៈ ឧស្សាហៈ សេចក្ដីព្យាយាម និងការស្វែងរកដ៏ធំដើម្បីបានជាព្រះពុទ្ធប៉ុណ្ណោះ បុគ្គលក្រៅអំពីនេះ មិនសម្រេចឡើយ ។

ក្នុងឆន្ទៈដែលធំក្រៃលែងនោះ មានសេចក្ដីឧបមាដូចតទៅ បើបុគ្គលណា អាចប្រើកម្លាំងដៃរបស់ខ្លួនហែលឆ្លងចក្កវាឡ ដែលពោរពេញទៅដោយទឹក រហូតដល់ត្រើយបាន បុគ្គលនោះរមែងសម្រេចជាព្រះពុទ្ធបាន ឬបុគ្គលណា អាចដើរលុយល្វែងចក្កវាឡ ដែលប្រកបដោយគុម្ពឫស្សីបាន បុគ្គលនោះ រមែងសម្រេចភាពជាព្រះពុទ្ធបាន ឬថា បុគ្គលណា យកជើង

ជាន់ល្បែងចក្កវាឡទាំងមូល ដែលដោតដោយលំពែងជាប់គ្នាទៅ ហើយឆ្លង ទៅបាន បុគ្គលនោះ រមែងសម្រេចភាពជាព្រះពុទ្ធ ឬបុគ្គលណា អាចប្រើ ជើងទាំងពីរ ជាន់ល្បែងចក្កវាឡទាំងមូល ដែលពេញដោយរងើកភ្លើង ប្រាស ចាកអណ្តាតដល់ត្រើយម្ខាងបាន បុគ្គលនោះ រមែងសម្រេចភាពជាព្រះពុទ្ធ បាន បុគ្គលណា មិនគិតដល់ការធ្វើនោះថា ជាវត្ថុដែលខ្លួនធ្វើបានលំបាក តែជាអ្នកប្រកបដោយឆន្ទៈ ឧស្សាហៈ សេចក្តីព្យាយាម និងការស្វែងរកដ៏ធំ យ៉ាងនេះថា អញនឹងឆ្លងវត្ថុនេះ ទៅដល់ត្រើយនាយឲ្យបាន ការប្រាថ្នារបស់ បុគ្គលនោះឯង រមែងសម្រេច បុគ្គលក្រៅអំពីនេះ រមែងមិនសម្រេចឡើយ ព្រោះហេតុនោះ ដើម្បីឲ្យសមោធានធម៌ ៨ ប្រការនេះ រួមគ្នាគ្រប់គ្រាន់ សុមេធតាបស ក៏ធ្វើសេចក្តីប្រាថ្នាដ៏ធំក្រៃលែង ដើម្បីភាពជាព្រះពុទ្ធទើបដេក ។

ឯព្រះមានព្រះភាគទីបង្ករយាងមកហើយ ទ្រង់ឈរខាងក្បាលសុមេធ-តាបស បើកព្រះនេត្រដែលសម្បូរដោយបសាទ មានពណ៌ ៥ ដូចបើក បង្អួចកែវមណី ទ្រង់ឃើញសុមេធតាបសដេកលើភក់ ទ្រង់ត្រិះរិះថា តាបស នេះ ធ្វើនូវសេចក្តីប្រាថ្នាធំក្រៃលែង ដើម្បីភាពជាព្រះពុទ្ធ ទើបដេក សេចក្តី ប្រាថ្នារបស់តាបសនេះសម្រេចឬហ្ន៎ ទើបទ្រង់បញ្ជូនអនាគតំសញ្ញាណ ពិចារណា ទ្រង់ជ្រាបថា អំណឹះតទៅ ៤ អសង្ខេយ្យក្រៃលែងដោយសែន កប្ប រាប់អំពីកប្បនេះទៅ តាបសនេះ នឹងបានជាព្រះពុទ្ធ ព្រះនាមគោតម ខណៈទ្រង់ឈរនោះឯង ទ្រង់ព្យាករក្នុងកណ្តាលបរិស័ទថា អ្នកទាំងឡាយ ឃើញតាបសអ្នកមានតបៈដ៏ខ្ពង់ខ្ពស់នេះ កំពុងដេកលើភក់ដែរឬ ភិក្ខុទាំង

ឡាយទូលថា បពិត្រព្រះអង្គដ៏ចម្រើន ខ្ញុំព្រះអង្គឃើញ ។ ព្រះមុនីត្រាស់ថា តាបសនេះធ្វើសេចក្តីប្រាថ្នាដ៏ក្រៃលែង ដើម្បីភាពជាព្រះពុទ្ធ ទើបជេក សេចក្តីប្រាថ្នារបស់តាបសនេះ នឹងសម្រេច ដ្បិតថា ក្នុងទីបំផុត ៤ អសង្ខេយ្យ និង ១ សែនកប្ប រាប់អំពីកប្បនេះទៅ តាបសនេះនឹងបានជាព្រះពុទ្ធ ព្រះនាមគោតម ក្នុងអត្តភាពនោះ នគរឈ្មោះកបិលពស្តុ ជាទីនៅអាស្រ័យរបស់បុរសនេះ ព្រះទេវីព្រះនាមមាយា ជាព្រះមាតា ព្រះរាជាព្រះនាមសុទ្ធោទនៈ ជាព្រះបិតា ។ ព្រះថេរៈឈ្មោះឧបតិស្សៈ ជាអគ្គសាវក ព្រះថេរៈឈ្មោះកោលិតៈ ជាទុតិយសាវក ព្រះថេរៈឈ្មោះអានន្ទ ជាពុទ្ធុបដ្ឋាក ព្រះថេរីឈ្មោះខេមា ជាអគ្គសាវិកា ព្រះថេរីឈ្មោះឧប្បលវណ្ណា ជាទុតិយ-សាវិកា តាបសនេះ មានញាណចាស់ក្លាហើយ នឹងចេញមហាភិនេស្រ្កមណ៍ តាំងមហាបធាន ទទួលបាយាសត្រង់គល់និគ្រោធ ហើយបរិភោគត្រង់ឆ្នេរស្ទឹងនេរញ្ជរា ហើយឡើងកាន់ពោធិមណ្ឌល នឹងត្រាស់ដឹងព្រម ត្រង់គល់អស្សត្ថព្រឹក្ស សមដូចព្រះតម្រាស់ថា

> ព្រះពុទ្ធព្រះនាមទីបង្ករ ទ្រង់ជ្រាបច្បាស់នូវលោក ទ្រង់គួរទទួលគ្រឿងបូជាទាំងឡាយ ទ្រង់ឈរក្បែរសីសៈ របស់តថាគត ត្រាស់ពាក្យនេះថា ( ម្នាលភិក្ខុទាំងឡាយ ) អ្នកទាំងឡាយ ចូរមើលតាបសនេះ ជាជដិល មានតបៈដ៏ខ្ពង់ខ្ពស់ តាបសនេះ នឹងបានត្រាស់ជាព្រះពុទ្ធក្នុងលោក ក្នុងកប្បប្រមាណមិនបានអំពីកប្បនេះទៅ ។ សត្វនេះ នឹងចេញចាក

ក្រុងឈ្មោះកបិលវត្ថុ ជាទីរីករាយ តម្កល់ព្យាយាម ធ្វើទុក្ករ-កិរិយា ។ សត្វនេះ អង្គុយទៀបគល់អជបាលព្រឹក្ស ទទួលបាយាសដែលនាងសុជាតាថ្វាយក្នុងទីនោះ នឹងចូលទៅកាន់ស្ទឹងនេរញ្ជរា ។ ព្រះជិនស្រីនោះ បានទទួលបាយាស ទៀបឆ្នេរស្ទឹងនេរញ្ជរាហើយ នឹងត្រឡប់មកតាមផ្លូវដែលគេតាក់តែងយ៉ាងប្រសើរ ( អង្គុយ ) ទៀបគល់ពោធិព្រឹក្សលំដាប់នោះ តាបសមានយសធំនេះ ធ្វើប្រទក្សិណពោធិ-មណ្ឌល នឹងបានត្រាស់ដឹងនូវអនុត្តរសម្ពោធិញ្ញាណ ទៀបគល់អស្សត្ថព្រឹក្ស ។ ព្រះជនិកាមាតារបស់តាបសនោះ នឹងមាននាមថា ព្រះនាងមាយាទេវី ព្រះបិតាព្រះនាមសុទ្ធោទនៈ ឯតាបសនេះ នឹងមានឈ្មោះថាព្រះគោតម អគ្គសាវកទាំងពីររូប គឺកោលិតៈ ១ ឧបតិស្សៈ ១ ជាអ្នកមិនមានអាសវៈប្រាសចាករាគៈ មានចិត្តស្ងប់រម្ងាប់ មានចិត្តខ្ជាប់ខ្ជួន ភិក្ខុជាឧបដ្ឋាកឈ្មោះអានន្ទ នឹងបម្រើព្រះជិនស្រីនេះ ។ អគ្គសាវិកាពីររូប គឺខេមា ១ ឧប្បលវណ្ណា ១ ជាអ្នកមិនមានអាសវៈប្រាសចាករាគៈ មានចិត្តស្ងប់រម្ងាប់ មានចិត្តខ្ជាប់ខ្ជួន ។ ឈើជាទីត្រាស់ដឹង របស់ព្រះមានព្រះភាគនោះ ហៅថាអស្សត្ថព្រឹក្ស ។

សុមេធតាបសបានស្តាប់ដូច្នោះ កើតសោមនស្សថា បានឮថា សេចក្តី

ប្រាថ្នារបស់អញនឹងសម្រេច ។ មហាជនបានស្តាប់ព្រះតម្រាស់របស់ព្រះទីបង្ករទសពលហើយ នាំគ្នាត្រេកអរថា បានឮថា សុមេធតាបស ជាពន្លកនៃសពេជ្ញុតាញាណ គឺជាពន្លកនៃព្រះពុទ្ធ ពួកជនទាំងនោះ មានការគិតយ៉ាងនេះថា ធម្មតាមនុស្សឆ្លងស្ទឹង កាលមិនអាចឆ្លងតាមកំពង់ដែលនៅក្នុងទីចំពោះមុខបាន រមែងទៅឆ្លងកំពង់ខាងក្រោម យ៉ាងណា ឯយើងទាំងឡាយក៏ដូច្នោះដូចគ្នា កាលមិនបានមគ្គ និងផលក្នុងសាសនា របស់ព្រះទីបង្ករ-ទសពល ក៏សូមធ្វើឲ្យជាក់ច្បាស់នូវមគ្គ និងផល ចំពោះមុខបុរសនេះ ក្នុងកាលបុរសនេះបានជាព្រះពុទ្ធ ក្នុងអនាគតកាល ដូច្នេះហើយ នាំគ្នាតម្កល់សេចក្តីប្រាថ្នា ។

ចំណែកព្រះទសពលទីបង្ករ សរសើរព្រះពោធិសត្វហើយ ទ្រង់បូជាដោយផ្កា ៨ ក្តាប់ ទ្រង់ធ្វើប្រទក្សិណហើយចៀសចេញទៅ ព្រះខីណា-ស្រពប្រមាណ ៤ សែនអង្គនោះ ក៏បូជាព្រះពោធិសត្វដោយគ្រឿងក្រអូប និងផ្កា ធ្វើប្រទក្សិណហើយចៀសចេញទៅ ។ ទេវតា និងមនុស្សទាំងឡាយក៏បូជាយ៉ាងនោះដូចគ្នា ថ្វាយបង្គំហើយ ចៀសចេញទៅ ។

ក្នុងកាលដែលមនុស្សទាំងពួងចៀសចេញទៅហើយ ព្រះពោធិសត្វក៏ក្រោកឡើងចាកទីដេក ហើយគិតថា អញនឹងស្រាវជ្រាវរកនូវបារមីទាំងឡាយទើបអង្គុយពត់ភ្នែនលើគំនរផ្កា ។ កាលព្រះពោធិសត្វអង្គុយយ៉ាងនេះហើយ ទេវតាទាំងឡាយក្នុងម៉ឺនចក្រវាលទាំងមូលឲ្យសាធុការ ហើយនាំគ្នាពោលថា បពិត្រសុមេធតាបស ក្នុងកាលដែលបុរាណពោធិសត្វអង្គុយពត់ភ្នែន ដោយ

គិតថា នឹងជញ្ជីងរកនូវបារមីទាំងឡាយ បុព្វនិមិត្តឯណាប្រាកដមកហើយ បុព្វនិមិត្តទាំងអស់នោះ ក៏ប្រាកដហើយក្នុងថ្ងៃនេះ លោកនឹងបានជាព្រះពុទ្ធ ដោយឥតសង្ស័យ ពួកយើងដឹងសេចក្ដីនេះថា និមិត្តទាំងនេះ ប្រាកដដល់បុគ្គលណា បុគ្គលនោះ នឹងបានជាព្រះពុទ្ធដោយពិត សូមលោកផ្គងសេចក្ដីព្យាយាមរបស់ខ្លួនឲ្យមាំទាំចុះ ហើយពោលសរសើរព្រះពោធិសត្វ ដោយពាក្យសរសើរជាអនេក សមដូចព្រះតម្រាស់ថា

ពួកមនុស្ស និងទេវតា លុះឮពាក្យព្យាកររបស់ព្រះពុទ្ធទីបង្ករ ទ្រង់ស្វែងរកគុណដ៏ធំ ឥតមានបុគ្គលស្មើនេះហើយ ក៏រីករាយ ដោយគិតថា សុមេធតាបសនេះ ជាពូជពន្លកនៃព្រះពុទ្ធ ។ សំឡេងហ៊ោទាំងឡាយ ក៏ប្រព្រឹត្តទៅ ពួកលោក ព្រមទាំងទេវលោក ទាំងមួយម៉ឺនលោកធាតុ ទះដៃផង សើចផង ផ្គងអញ្ជលីនមស្ការផង ពោលថា បើពួកយើង ឃ្លាងមគ្គផល ក្នុងសាសនាព្រះលោកនាថនេះ ក្នុងកាលជាអនាគត ពួកយើងនឹងបានសម្រេចក្នុងទីចំពោះព្រះភក្ត្រនៃព្រះគោតមនេះ ។ ពួកមនុស្សកាលឆ្លងស្ទឹង បើឃ្លាងកំពង់ចំពោះមុខហើយ តែងកាន់យកកំពង់ខាងក្រោម ក៏ឈ្មោះថា ឆ្លងស្ទឹងធំដែរ យ៉ាងណាមិញ ពួកយើងទាំងអស់គ្នា បើឃ្លាងព្រះជិនស្រីនេះ ហើយ ក្នុងកាលជាអនាគត គង់នឹងបានសម្រេច ក្នុងទីចំពោះព្រះភក្ត្រនៃព្រះគោតមនេះ ក៏យ៉ាងនោះដែរ ។ ព្រះពុទ្ធ

ទីបង្គរ ទ្រង់ជ្រាបច្បាស់នូវលោក គួរទទួលគ្រឿងបូជា ទ្រង់សរសើរអំពើរបស់តថាគតហើយ ទ្រង់លើកព្រះបាទខាងស្តាំ ។ សាវ័កទាំងឡាយណា ជាបុត្រនៃព្រះជិនស្រីក្នុងទីនោះ ពួកសាវ័កទាំងនោះ ក៏ធ្វើប្រទក្សិណតថាគត ពួកទេវតា ពួកមនុស្ស ពួកអសុរ ពួកយក្ខ ក៏ក្រាបថ្វាយបង្គំតថាគត ហើយចៀសចេញទៅ ។ កាលព្រះលោកនាយក ព្រមទាំងព្រះសង្ឃ កន្លងនូវការឃើញរបស់តថាគតទៅ តថាគតក៏ក្រោកចាកទីដេក ហើយពែនភ្នែនក្នុងកាលនោះ ។ តថាគត ជាអ្នកមានសេចក្តីសុខ ដោយសេចក្តីសុខ រីករាយ ដោយបាមោជ្ជ ផ្សព្វផ្សាយដោយបីតិ អង្គុយពែនភ្នែន ក្នុងកាលនោះ ។ តថាគត អង្គុយពែនភ្នែនគិតយ៉ាងនេះ ក្នុងកាលនោះថា អាត្មាអញជាអ្នកស្ទាត់ក្នុងឈាន ដល់នូវត្រើយនៃអភិញ្ញា ។ ក្នុងលោកធាតុទាំងមួយពាន់ មិនមានពួកឥសីស្មើដោយអាត្មាអញឡើយ អាត្មាអញឥតមានបុគ្គលស្មើក្នុងឥទ្ធិធម៌ទាំងឡាយ អញបាននូវសេចក្តីសុខបែបនេះ ។ ក្នុងកាលដែលតថាគត អង្គុយពែនភ្នែន គិតយ៉ាងនេះ ពួកមហាព្រហ្មដែលនៅអាស្រ័យក្នុងលោកធាតុមួយម៉ឺន ក៏ញ៉ាំងសំឡេងខ្លាំងឲ្យលាន់ឮថា លោកនឹងបានត្រាស់ជាព្រះពុទ្ធប្រាកដ ។ និមិត្តទាំងឡាយណា ក្នុងកាលជាទីពត់ភ្នែននៃ

ពោធិសត្វទាំងឡាយ ប្រាកដក្នុងកាលមុន និមិត្តទាំងនោះ ក៏ប្រាកដក្នុងថ្ងៃនេះ ។ ត្រជាក់ក៏ស្ងាត់បាត់ទៅ ទាំងក្តៅក៏ស្ងប់រម្ងាប់ និមិត្តទាំងនោះ ក៏ប្រាកដក្នុងថ្ងៃនេះ លោកនឹងបានត្រាស់ជាព្រះពុទ្ធប្រាកដ ។ លោកធាតុទាំងមួយម៉ឺន ក៏ឥតមានសំឡេង ឥតវឹកវរ និមិត្តទាំងនោះ ក៏ប្រាកដក្នុងថ្ងៃនេះ លោកនឹងបានត្រាស់ជាព្រះពុទ្ធប្រាកដ ។ ខ្យល់ធំទាំងឡាយ ក៏ឈប់បក់ ស្ទឹងទាំងឡាយក៏ឈប់ហូរ និមិត្តទាំងនោះ ក៏ប្រាកដក្នុងថ្ងៃនេះ លោកនឹងបានត្រាស់ជាព្រះពុទ្ធប្រាកដ ។ ផ្កាទាំងពួងដែលកើតលើគោក កើតក្នុងទឹក ក៏រីកក្នុងខណៈនោះ ផ្កាទាំងអស់នោះ ក៏បញ្ចេញផ្កាក្នុងថ្ងៃនេះ លោកនឹងបានត្រាស់ជាព្រះពុទ្ធប្រាកដ ។ វល្លិ៍ទាំងឡាយក្តី ឈើទាំងឡាយក្តី ទ្រទ្រង់នូវផ្លែក្នុងខណៈនោះ វល្លិ៍ និងឈើទាំងអស់នោះ ក៏បញ្ចេញផ្លែក្នុងថ្ងៃនេះ លោកនឹងបានត្រាស់ជាព្រះពុទ្ធប្រាកដ ។ កែវទាំងឡាយ ដែលស្ថិតនៅឰដ៏អាកាសក្តី ស្ថិតនៅលើផែនដីក្តី ដែលរុងរឿងក្នុងខណៈនោះ កែវទាំងនោះ ក៏រុងរឿងក្នុងថ្ងៃនេះ លោកនឹងបានត្រាស់ជាព្រះពុទ្ធប្រាកដ ។ គ្រឿងតូរ្យតន្ត្រីទាំងឡាយ ជារបស់មនុស្ស និងជាទិព្វ ដែលប្រគំក្នុងខណៈនោះ តូរ្យតន្ត្រីទាំងពីរនោះ ក៏លាន់ឮឡើងក្នុងថ្ងៃនេះ លោកនឹងបានត្រាស់ជាព្រះពុទ្ធប្រាកដ ។ ផ្កាដ៏វិចិត្រ

ទាំងឡាយរុះរោយ ចុះអំពីអាកាសក្នុងខណៈនោះ ផ្កាដ៏វិចិត្រទាំងនោះ ក៏ប្រាកដក្នុងថ្ងៃនេះ លោកនឹងបានត្រាស់ជាព្រះពុទ្ធប្រាកដ ។ មហាសមុទ្រក៏ស្រកចុះ លោកធាតុទាំងមួយម៉ឺនក៏ញាប់ញ័រ ក្នុងខណៈនោះ មហាសមុទ្រ និងលោកធាតុទាំងពីរនោះ ក៏លាន់ឮកងរំពងក្នុងថ្ងៃនេះ លោកនឹងបានត្រាស់ជាព្រះពុទ្ធប្រាកដ ។ ភ្លើងក្នុងនរកទាំងមួយម៉ឺន ក៏រលត់ក្នុងខណៈនោះ ភ្លើងទាំងនោះក៏រលត់ក្នុងថ្ងៃនេះ លោកនឹងបានត្រាស់ជាព្រះពុទ្ធប្រាកដ ។ ព្រះអាទិត្យប្រាសចាកមន្ទិល ផ្កាយទាំងពួងក៏ប្រាកដ ព្រះអាទិត្យ និងផ្កាយទាំងនោះ ក៏បានប្រាកដក្នុងថ្ងៃនេះ លោកនឹងបានត្រាស់ជាព្រះពុទ្ធប្រាកដ ។ ក្នុងកាលគ្មានភ្លៀង ទឹកក៏ផុសផុលឡើងលើផែនដី ក្នុងខណៈនោះ ទឹកក៏ផុសឡើងលើផែនដី ក្នុងថ្ងៃនេះ លោកនឹងបានត្រាស់ជាព្រះពុទ្ធប្រាកដ ។ ពួកផ្កាយទាំងឡាយ ក៏រុងរឿងផ្កាយនក្ខត្តឫក្សទាំងឡាយ ប្រកបដោយព្រះចន្ទ ខែវិសាខ ( ក៏រុងរឿង ) ក្នុងមណ្ឌលនៃអាកាស លោកនឹងបានត្រាស់ជាព្រះពុទ្ធប្រាកដ ។ ចំណែកឯពួកសត្វនៅក្នុងរន្ធ ពួកសត្វដេកក្នុងជ្រោះ ក៏ចេញចាកលំនៅរបស់ខ្លួន ពួកសត្វទាំងអស់នោះ ក៏បោះបង់លំនៅចោល ក្នុងថ្ងៃនេះ លោកនឹងបានត្រាស់ជាព្រះពុទ្ធប្រាកដ ។ សេចក្តីអផ្សុក មិនមានដល់សត្វ

ទាំងឡាយ សត្វទាំងឡាយ ជាអ្នកត្រេកអរក្នុងខណៈនោះ ពួកសត្វទាំងអស់នោះ ជាអ្នកត្រេកអរក្នុងថ្ងៃនេះ លោកនឹងបានត្រាស់ជាព្រះពុទ្ធប្រាកដ ។ រោគទាំងឡាយដ៏ស្រាលៗ ក៏ស្ងប់រម្ងាប់ទៅ ទាំងសេចក្តីស្រេកឃ្លានក៏វិនាសទៅ ការស្ងប់រោគ និងការវិនាសសេចក្តីស្រេកឃ្លានទាំងនោះ ក៏ប្រាកដក្នុងថ្ងៃនេះ លោកនឹងបានត្រាស់ជាព្រះពុទ្ធប្រាកដ ។ រោគក៏ស្រាកស្រាន្តទៅ ទោសៈមោហៈ ក៏បាត់បង់ទៅក្នុងកាលនោះ រោគ និងកិលេសទាំងអស់នោះ ក៏ប្រាសចេញទៅ ក្នុងថ្ងៃនេះ លោកនឹងបានត្រាស់ជាព្រះពុទ្ធប្រាកដ ។ ឯភ័យមិនមានក្នុងកាលនោះ ការមិនមានភ័យនុ៎ះ ក៏ប្រាកដក្នុងថ្ងៃនេះ ព្រោះហេតុនោះ ទើបយើងដឹងថា លោកនឹងបានត្រាស់ជាព្រះពុទ្ធប្រាកដ ។ ធូលីក៏ខ្ចាត់ខ្ចាយទៅខាងលើ ការខ្ចាត់ខ្ចាយធូលីក៏ប្រាកដក្នុងថ្ងៃនេះ ព្រោះហេតុនោះ ទើបពួកយើងដឹងថា លោកនឹងបានត្រាស់ជាព្រះពុទ្ធប្រាកដ ។ ក្លិនស្អុយក៏ផាត់ចេញ ក្លិនទិព្វក៏ផ្សាយទៅ ក្លិនទិព្វនោះ ក៏ផ្សាយចេញ ក្នុងថ្ងៃនេះ លោកនឹងបានត្រាស់ជាព្រះពុទ្ធប្រាកដ ។ ពួកទេវតាទាំងពួង វៀរលែងតែអរូបព្រហ្មចេញ ដែលប្រាកដ ពួកទេវតាទាំងអស់នោះ ក៏ប្រាកដក្នុងថ្ងៃនេះ លោកនឹងបានត្រាស់ជាព្រះពុទ្ធប្រាកដ ។ ពួកសត្វនរកទាំងអម្បាលម៉ាន

ដែលប្រាកដក្នុងខណៈនោះ ពួកសត្វនរកទាំងអស់នោះឯង ក៏ប្រាកដក្នុងថ្ងៃនេះ លោកនឹងបានត្រាស់ជាព្រះពុទ្ធប្រាកដ ។ ក្នុងកាលនោះ ជញ្ជាំងទាំងឡាយក្តី សន្ទះទ្វារទាំងឡាយក្តី ភ្នំទាំងឡាយក្តី ជាគ្រឿងរាំងមិនមានឡើយ កំពែងសន្ទះទ្វារ និងភ្នំទាំងឡាយនោះ ក៏ក្លាយទៅជាអកាស ( ប្រាកដ ) ក្នុងថ្ងៃនេះ លោកនឹងបានត្រាស់ជាព្រះពុទ្ធប្រាកដ ។ ចុតិ និងឧបបត្តិមិនមានក្នុងខណៈនោះ និមិត្តទាំងនោះ ក៏ប្រាកដក្នុងថ្ងៃនេះ លោកនឹងបានត្រាស់ជាព្រះពុទ្ធប្រាកដ ។ ( និមិត្តទាំងនេះ ក៏ប្រាកដដល់សត្វទាំងឡាយ ដើម្បីត្រាស់ដឹងនូវអនុត្តរសម្មោធិញ្ញាណ ) ( ពួកសត្វពោលថា បពិត្រសុមេធតាបស ) សូមលោកផ្គងព្យាយាមឲ្យមាំមួនឡើង កុំត្រឡប់ កុំថយក្រោយឡើយ ពួកយើងដឹងច្បាស់នូវហេតុនុះថា លោកនឹងបានត្រាស់ជាព្រះពុទ្ធប្រាកដ ។

ព្រះពោធិសត្វ បានស្តាប់ព្រះតម្រាស់របស់ព្រះទីបង្ករទសពល និងពាក្យរបស់ទេវតា ក្នុងម៉ឺនចក្កវាឡហើយ កើតនូវឧស្សាហៈដ៏ក្រៃលែង ទើបគិតថា ធម្មតាព្រះពុទ្ធទាំងឡាយ មានព្រះតម្រាស់មិនទទេ ព្រះតម្រាស់របស់ព្រះពុទ្ធ មិនប្រែប្រួលទៅជាប្រការដទៃ ដូចដុំដីដែលបុគ្គលបោះទៅក្នុងអាកាស នឹងត្រូវធ្លាក់ចុះមកពិតប្រាកដ សត្វកើតហើយ ត្រូវស្លាប់ កាលរាត្រីអស់ហើយ ព្រះអាទិត្យក៏ត្រូវរះឡើង រាជសីហ៍ចេញអំពីលំនៅ ត្រូវ

បន្លឺសីហនាទ ស្រីមានគតិចាស់ ក៏ត្រូវប្រសូតជារបស់ពិតប្រាកដ មិនមាន មិនបាន យ៉ាងណា ធម្មតាព្រះតម្រាស់របស់ព្រះពុទ្ធទាំងឡាយក៏យ៉ាងនោះ ដូចគ្នា ជារបស់ពិតប្រាកដមិនទទេ អាត្មាអញនឹងបានត្រាស់ជាព្រះពុទ្ធពិត សមដូចព្រះតម្រាស់ដែលត្រាស់ថា

តថាគត លុះឮពាក្យរបស់ជនទាំងពីរពួក គឺព្រះពុទ្ធ និង ទេវតាទាំងមួយម៉ឺនចក្រវាឡហើយ ក៏ត្រេកអរ ស្រស់ស្រាយ រីករាយ គិតក្នុងកាលនោះ យ៉ាងនេះថា ធម្មតាព្រះពុទ្ធទាំង ឡាយ មិនដែលមានព្រះពុទ្ធដីការបែកជាពីរទេ ព្រះជិនស្រី ទាំងឡាយមិនដែលមានព្រះពុទ្ធដីកាឥតអំពើទេ ព្រះពុទ្ធដីកា របស់ព្រះពុទ្ធទាំងឡាយ មិនដែលឃ្លៀងឃ្លាតទេ អាត្មាអញ នឹងបានត្រាស់ជាព្រះពុទ្ធប្រាកដ ។ ដុំដី ដែលគេចោលទៅ ឮដ៏អាកាស ទៀងតែធ្លាក់មកលើផែនដីវិញ យ៉ាងណា ពាក្យ របស់ព្រះពុទ្ធដ៏ប្រសើរទាំងឡាយ ក៏ទៀងទាត់ប្រាកដ យ៉ាង នោះដែរ ។ ព្រះបន្ទូលរបស់ព្រះពុទ្ធទាំងឡាយ មិនចេះ ឃ្លៀងឃ្លាត អាត្មាអញនឹងបានត្រាស់ជាព្រះពុទ្ធប្រាកដ សេចក្តី ស្លាប់របស់សព្វសត្វទៀងទាត់ ប្រាកដ យ៉ាងណា ព្រះបន្ទូល របស់ព្រះពុទ្ធដ៏ប្រសើរទាំងឡាយ ទៀងទាត់ ប្រាកដ ដូច្នោះ ដែរ ។ កាលដែលរាត្រីអស់ទៅ ព្រះអាទិត្យទៀងតែរះឡើង យ៉ាងណា ព្រះបន្ទូលរបស់ព្រះពុទ្ធដ៏ប្រសើរទាំងឡាយ ក៏ទៀង

ទាត់ប្រាកដយ៉ាងនោះដែរ ។ សីហៈ ដែលចេញអំពីជំណោក

តែងបន្លឺសំឡេង យ៉ាងណា ព្រះបន្ទូលរបស់ព្រះពុទ្ធដ៏ប្រសើរ

ទាំងឡាយ ក៏ទៀងទាត់ ប្រាកដយ៉ាងនោះដែរ ។ ការសម្រាល

គភ៌នៃស្រីដែលមានគភ៌ធ្ងន់ ជារបស់ទៀងទាត់ យ៉ាងណា

ព្រះបន្ទូលរបស់ព្រះពុទ្ធ ដ៏ប្រសើរទាំងឡាយ ក៏ទៀងទាត់

ប្រាកដ យ៉ាងនោះដែរ ។

សុមេធតាបសនោះ ធ្វើនូវការសម្រេចចិត្តយ៉ាងនេះថា អាត្មាអញនឹងបានត្រាស់ជាព្រះពុទ្ធពិតប្រាកដ ដើម្បីនឹងពិចារណាដល់ធម៌ដែលធ្វើឲ្យបានជាព្រះពុទ្ធ ទើបគិតថា ធម៌ដែលធ្វើឲ្យបានជាព្រះពុទ្ធនៅទីណា ខាងលើ ឬខាងក្រោម ក្នុងទិសធំ ឬទិសតូច កាលពិចារណាធម្មធាតុទាំងមូលដោយលំដាប់ ក៏ឃើញទានបារមីជាទី ១ ដែលបុរាណពោធិសត្វទាំងឡាយបដិបត្តិជាប្រចាំ ទើបពោលទូន្មានខ្លួនយ៉ាងនេះថា នែសុមេធបណ្ឌិត ចាប់អំពីពេលនេះទៅ អ្នកត្រូវបំពេញទានបារមីជាបឋមឲ្យបរិបូណ៌ ដូចក្អមទឹកផ្កាប់ រមែងហូរទឹកចេញអស់ មិនមានទឹកចូលទៅ យ៉ាងណា អ្នកក៏យ៉ាងនោះដូចគ្នា មិនគប្បីជាប់ជំពាក់ក្នុងទ្រព្យ យស បុត្រ និងភរិយា អវយវៈតូចធំ ឲ្យនូវវត្ថុដែលគេចង់បានទាំងអស់ដល់យាចក ដែលមកដល់ ធ្វើមិនឲ្យមានចំណែកសេសសល់ ក៏នឹងបានអង្គុយត្រង់គល់ពោធិព្រឹក្សពិតប្រាកដ កាលពោលទូន្មានខ្លួនហើយ ក៏អធិដ្ឋានទានបារមីជាបឋម ធ្វើឲ្យមាំទាំហើយ ។ សមដូចព្រះតម្រាស់ថា

បើដូច្នោះ អាត្មាអញនឹងជ្រើសរើសរកពុទ្ធការកធម៌ទាំងឡាយ ពីខាងនេះ ពីខាងនោះ គឺខាងលើ ខាងក្រោម ទិសទាំង ១០ ដរាបដល់ធម្មធាតុ ។ កាលនោះ តថាគតកំពុងជ្រើសរើស ក៏បានឃើញទានបារមីជាដំបូង ជាគន្លងធំ ដែលពោធិសត្វទាំងឡាយ អំពីបុរាណធ្លាប់សន្សំមក ( ហើយទូន្មានខ្លួនឯងថា ម្នាលសុមេធបណ្ឌិត ) អ្នកចូរសមាទាន ធ្វើនូវទានបារមីជាដំបូងនេះ ឲ្យមាំមួន បើអ្នកចង់លុះនូវពោធិញ្ញាណ ចូរបំពេញនូវទានបារមីចុះ ។ ក្អមដែលមានទឹកពេញ បុគ្គលណាមួយផ្កាប់ចុះ ចាក់មិនឲ្យសល់ទឹក ទឹកមិនដក់នៅក្នុងក្អមនោះ យ៉ាងណា អ្នកបើឃើញពួកស្មូមមក ទោះថោកទាបខ្ពង់ខ្ពស់ ឬមធ្យម ចូរឲ្យទាន កុំឲ្យសេសសល់ ឲ្យដូចជាក្អមដែលគេផ្កាប់ ដូច្នោះ ។

លំដាប់នោះ កាលសុមេធតាបសនោះគិតថា ធម៌ដែលធ្វើឲ្យបានត្រាស់ជាព្រះពុទ្ធ មិនមានប្រមាណប៉ុណ្ណោះឡើយ ទើបពិចារណាឲ្យក្រៃលែងតទៅទៀត បានឃើញសីលបារមីទី ២ ទើបមានការគិតដូច្នេះថា នៃសុមេធបណ្ឌិត ចាប់អំពីនេះទៅ អ្នកក៏ត្រូវបំពេញសីលបារមីឲ្យបរិបូណ៌ ដូចសត្វចាមរីមិនសោកស្តាយជីវិត រក្សារោមកន្ទុយរបស់ខ្លួនប៉ុណ្ណោះ យ៉ាងណា សូម្បីអ្នកក៏ដូច្នោះ ចាប់តាំងអំពីនេះទៅ កុំឃើញតែជីវិត រក្សាតែសីលប៉ុណ្ណោះ នឹងបានត្រាស់ជាព្រះពុទ្ធ ហើយបានអធិដ្ឋានសីលបារមីជាលំដាប់ទី

២ ធ្វើឲ្យមាំទាំហើយ ។ សមដូចព្រះតម្រាស់ថា

ពុទ្ធធម៌ទាំងឡាយ មិនមែនមានត្រឹមប៉ុណ្ណោះទេ អាត្មាអញនឹងជ្រើសរើសរកពុទ្ធធម៌ដទៃទៀត ដែលជាធម៌ញ៉ាំងពោធិញ្ញាណឲ្យសម្រេច ។ កាលនោះ តថាគតកំពុងជ្រើសរើសរក ក៏ឃើញសីលបារមីទី ២ ដែលពោធិសត្វទាំងឡាយអំពីបុរាណធ្លាប់សេព ធ្លាប់អាស្រ័យមក ( ហើយទូន្មានខ្លួនឯងថា ម្នាលសុមេធបណ្ឌិត ) អ្នកឯងចូរសមាទាន ធ្វើសីលបារមីទី ២ នេះឲ្យមាំមួន បើអ្នកចង់លុះនូវពោធិញ្ញាណ ចូរបំពេញនូវសីលបារមីចុះ ។ សត្វចាមរី ( កាលឃើញ ) រោមកន្ទុយជំពាក់នឹងរបស់អ្វីមួយ ស៊ូស្លាប់ក្នុងទីនោះ មិនព្រមផ្តាច់កន្ទុយចោលឡើយ យ៉ាងណាមិញ អ្នកចូរបំពេញនូវសីលទាំងឡាយ ក្នុងភូមិទាំង ៤ ចូររក្សាសីលសព្វកាល ឲ្យដូចជាសត្វចាមរីរក្សាកន្ទុយ យ៉ាងនោះចុះ ។

លំដាប់នោះ កាលសុមេធតាបសនោះគិតថា ពុទ្ធការកធម៌ទាំងឡាយមិនមានប្រមាណប៉ុណ្ណោះឡើយ ទើបពិចារណាឲ្យក្រៃលែងឡើងតទៅទៀត បានឃើញនេក្ខម្មបារមីជាទី ៣ ទើបគិតដូច្នេះថា នែសុមេធបណ្ឌិត ចាប់ពីនេះទៅ អ្នកត្រូវបំពេញនេក្ខម្មបារមីឲ្យបរិបូណ៌ ដូចបុរសដែលនៅក្នុងគុកអស់កាលយូរ មិនមានអាឡោះអាល័យក្នុងគុកនោះឡើយ ដោយពិត រមែងកន្ទក់កន្ទេញតែម្យ៉ាង មិនចង់នៅ យ៉ាងណា សូម្បីអ្នក ក៏យ៉ាងនោះដូចគ្នា

ចូរធ្វើភពទាំងពួងឲ្យដូចជាគុក នឿយណាយ ចង់ចេញឲ្យផុតចាកភពទាំងពួង បែរមុខចំពោះនេក្ខម្មៈ គឺការចេញចាកកាមប៉ុណ្ណោះ អ្នកនឹងបានត្រាស់ជាព្រះពុទ្ធ ដោយអាការយ៉ាងនេះ ហើយបានអធិដ្ឋាននេក្ខម្មបារមី ជាគម្រប់ ៣ ធ្វើឲ្យមាំទាំ ។ សមដូចព្រះតម្រាស់ថា

*ពុទ្ធធម៌ទាំងឡាយ មិនមែនមានត្រឹមតែប៉ុណ្ណោះទេ អាត្មាអញនឹងជ្រើសរើសរកពុទ្ធធម៌ដទៃទៀត ដែលជាធម៌ញុាំងពោធិញ្ញាណឲ្យសម្រេច ។ កាលនោះ តថាគតកំពុងជ្រើសរើសរក ក៏បានឃើញនេក្ខម្មបារមីទី ៣ ដែលពោធិសត្វទាំងឡាយអំពីបុរាណធ្លាប់សេព ធ្លាប់អាស្រ័យមក ( ហើយទូន្មានខ្លួនឯងថា ម្នាលសុមេធបណ្ឌិត ) អ្នកចូរសមាទាន ធ្វើនេក្ខម្មបារមីទី ៣ នេះឲ្យមាំមួន បើអ្នកចង់លុះនូវពោធិញ្ញាណ ចូរបំពេញនូវនេក្ខម្មបារមីចុះ ។ បុរសដែលជាប់នៅក្នុងគុកអស់កាលយូរត្រូវសេចក្តីទុក្ខបៀតបៀនហើយ រមែងមិនញុាំងសេចក្តីត្រេកអរ ឲ្យកើតឡើងក្នុងគុកនោះទេ រមែងស្វែងរកការរួច ( ចាកគុកនោះ ) យ៉ាងណា អ្នកចូរឃើញនូវភពទាំងអស់ដូចជាគុកចុះ ចូរបែរមុខទៅរកនេក្ខម្ម ដើម្បីរួចចាកភពយ៉ាងនោះដែរ ។*

លំដាប់នោះ កាលសុមេធតាបសនោះគិតថា ពុទ្ធការកធម៌ទាំងឡាយមិនមែនមានត្រឹមប៉ុណ្ណោះឡើយ ទើបពិចារណាឲ្យក្រៃលែងឡើង ក៏បានឃើញ

បញ្ញាបារមីជាទី ៤ ហើយគិតយ៉ាងនេះថា នែសុមេធបណ្ឌិត ចាប់អំពីនេះទៅ អ្នកត្រូវបំពេញបញ្ញាបារមីឲ្យបរិបូណ៌ អ្នកនឹងចូលទៅរកបណ្ឌិតទាំងអស់ មិនជ្រើសរើសថាជាអ្នកណា ទោះជាថោកទាប កណ្តាល ខ្ពង់ខ្ពស់ ហើយសាកសួរនូវបញ្ហា ដូចភិក្ខុដែលសមាទានបិណ្ឌបាតជាវត្ត មិនវៀរត្រកូលណាមួយ ទោះជាត្រកូលទាបថោកជាដើម ត្រាច់ទៅបិណ្ឌបាតតាមលំដាប់ បានអាហារល្មមចិញ្ចឹមជីវិតដោយរួសរាន់ យ៉ាងណា សូម្បីអ្នកក៏យ៉ាងនោះ ចូលទៅរកបណ្ឌិតទាំងពួង សាកសួរបញ្ហា នឹងបានជាព្រះពុទ្ធ កាលគិតហើយ ទើបអធិដ្ឋានបញ្ញាបារមីទី ៤ ធ្វើឲ្យមាំទាំហើយ ។ សមដូចព្រះតម្រាស់ថា

ពុទ្ធធម៌ទាំងឡាយ មិនមែនមានត្រឹមតែប៉ុណ្ណេះទេ អាត្មាអញនឹងជ្រើសរើសរកពុទ្ធធម៌ដទៃទៀត ដែលជាធម៌ញុំាងពោធិញ្ញាណឲ្យសម្រេច ។ កាលនោះ តថាគតកំពុងជ្រើសរើសរក ក៏បានឃើញបញ្ញាបារមីទី ៤ ដែលពោធិសត្វទាំងឡាយអំពីបុរាណធ្លាប់សេព ធ្លាប់អាស្រ័យមក ( ហើយទូន្មានខ្លួនឯងថា ម្នាលសុមេធបណ្ឌិត ) អ្នកចូរសមាទាន ធ្វើបញ្ញា-បារមីទី ៤ នេះឲ្យមាំមួន បើអ្នកចង់ដល់នូវពោធិញ្ញាណ ចូរបំពេញនូវបញ្ញាបារមីចុះ ។ ភិក្ខុ កាលប្រព្រឹត្តបិណ្ឌបាត មិនវំលងនូវត្រកូលទាំងឡាយ ទោះថោកទាប ខ្ពង់ខ្ពស់ ឬមធ្យម រមែងបានចង្ហាន់ល្មមញុំាងអត្តភាព ឲ្យប្រព្រឹត្តទៅ យ៉ាងណា អ្នកបើសាកសួរជន ជាអ្នកប្រាជ្ញសព្វកាល នឹងដល់នូវបញ្ញា-

បារមី ហើយបានលុះនូវពោធិញ្ញាណមិនខាន ក៏យ៉ាងនោះដែរ ។

លំដាប់នោះ កាលសុមេធតាបសនោះគិតថា ពុទ្ធការកធម៌ទាំងឡាយ មិនមានត្រឹមប៉ុណ្ណោះឡើយ ទើបពិចារណាឲ្យក្រៃលែងតទៅទៀត ក៏បាន ឃើញវីរិយបារមីទី ៥ ទើបគិតយ៉ាងនេះថា នែសុមេធបណ្ឌិត ចាប់អំពីពេល នេះទៅ អ្នកត្រូវបំពេញវីរិយបារមីឲ្យបរិបូណ៌ ដូចសីហមិគរាជ ជាអ្នកមាន សេចក្តីព្យាយាមមាំក្នុងឥរិយាបថទាំងពួង យ៉ាងណា សូម្បីអ្នកក៏យ៉ាងនោះ ចូរជាអ្នកមានព្យាយាមមាំ ក្នុងឥរិយាបថទាំងពួងគ្រប់ភព ជាអ្នកមានការ ព្យាយាមមិនធូរថយ នឹងបានត្រាស់ជាព្រះពុទ្ធ កាលគិតហើយ ទើបអធិដ្ឋាន វីរិយបារមីទី ៥ ធ្វើឲ្យមាំទាំហើយ ។ សមដូចព្រះតម្រាស់ថា

ពុទ្ធធម៌ទាំងឡាយ មិនមែនមានត្រឹមប៉ុណ្ណោះទេ អាត្មា អញនឹងជ្រើសរើសរកពុទ្ធធម៌ដទៃទៀត ដែលជាធម៌ញ៉ាំង ពោធិញ្ញាណឲ្យសម្រេច ។ កាលនោះ តថាគតកំពុងជ្រើស រើសរក ក៏បានឃើញវីរិយបារមីទី ៥ ដែលពោធិសត្វទាំង ឡាយ អំពីបុរាណធ្លាប់សេព ធ្លាប់អាស្រ័យមក ( ហើយ ទូន្មានខ្លួនឯងថា ម្នាលសុមេធបណ្ឌិត ) អ្នកចូរសមាទាន ធ្វើវីរិយបារមីទី ៥ នេះឲ្យមាំមួន បើអ្នកចង់លុះនូវពោធិញ្ញាណ ចូរបំពេញនូវវីរិយបារមីចុះ ។ សត្វសីហៈ ជាស្តេចនៃម្រឹគ មានព្យាយាមមិនរួញរា មានចិត្តផ្គងផ្គង សព្វកាល ក្នុងការ អង្គុយ ឈរ ដើរ យ៉ាងណា អ្នកគួរផ្គងផ្គងព្យាយាម ឲ្យ

មាំមួន ក្នុងកពទាំងពួង យ៉ាងនោះចុះ លុះដល់វីរិយបារមី
ហើយ នឹងបានសម្រេចពោធិញ្ញាណមិនខានឡើយ ។

លំដាប់នោះ កាលសុមេធតាបសនោះគិតថា ពុទ្ធការកធម៌ទាំងឡាយ មិនមែនមានត្រឹមប៉ុណ្ណេះឡើយ ទើបពិចារណាឲ្យក្រៃលែងតទៅទៀត ក៏បាន ឃើញខន្តិបារមីជាទី ៦ ទើបមានការគិតដូច្នេះថា នែសុមេធបណ្ឌិត ពីពេល នេះទៅ អ្នកត្រូវបំពេញខន្តិបារមីឲ្យបរិបូណ៌ អ្នកគប្បីជាអ្នកអត់ធន់ ទាំងក្នុង ការរាប់អាន់ និងក្នុងការមើលងាយ ដូចមនុស្សទាំងឡាយចោលវត្ថុស្អាតខ្លះ មិនស្អាតខ្លះ លើផែនដី ផែនដី ក៏មិនបានធ្វើនូវសេចក្ដីស្រឡាញ់ និងការ អាក់អន់ ព្រោះការធ្វើនោះ រមែងអត់ធន់ អត់ធ្មត់បាន យ៉ាងណា សូម្បីអ្នក ក៏យ៉ាងនោះដូចគ្នា ចូរជាអ្នកអត់ធន់ ទាំងក្នុងការរាប់អាន ទាំងក្នុងការមើល ងាយ នឹងបានត្រាស់ជាព្រះពុទ្ធ កាលគិតហើយ ទើបអធិដ្ឋានខន្តិបារមីទី ៦ ធ្វើឲ្យមាំទាំហើយ ។ សមដូចព្រះតម្រាស់ថា

ពុទ្ធធម៌ទាំងឡាយ មិនមែនមានត្រឹមប៉ុណ្ណេះទេ អាត្មា
អញនឹងជ្រើសរើសរកពុទ្ធធម៌ដទៃទៀត ដែលជាធម៌ញុំាង
ពោធិញ្ញាណឲ្យសម្រេច ។ កាលនោះ តថាគតកំពុងជ្រើស
រើសរក ក៏បានឃើញខន្តិបារមីទី ៦ ដែលពោធិសត្វទាំង
ឡាយ អំពីបុរាណធ្លាប់សេព ធ្លាប់អាស្រ័យមក ( ហើយ
ទូន្មានខ្លួនឯងថា ម្នាលសុមេធបណ្ឌិត ) អ្នកចូរសមាទាន
ធ្វើនូវខន្តិបារមីទី ៦ នេះ ឲ្យមាំមួន អ្នកកុំមានចិត្តបែកជាពីរ

ក្នុងខន្តិបារមីនោះ នឹងបានដល់នូវពោធិញ្ញាណ មិនខាន
ឡើយ ។ ធម្មតាផែនដី រមែងអត់ទ្រាំចំពោះវត្ថុទាំងពួង
ទោះស្អាតក្តី មិនស្អាតក្តី ដែលគេដាក់ចុះហើយ រមែងមិន
ធ្វើនូវសេចក្តីថ្នាំងថ្នាក់ និងសេចក្តីត្រេកអរឡើយ យ៉ាង
ណា ។ អ្នកក៏គួរអត់ទ្រាំនូវការរាប់អាន និងការមើលងាយ
របស់ពួកជនទាំងពួង យ៉ាងនោះដែរ លុះដល់នូវខន្តិបារមី
ហើយ នឹងបានសម្រេចសម្ពោធិញ្ញាណ មិនខានឡើយ ។

លំដាប់នោះ សុមេធតាបសក៏គិតថា ពុទ្ធការកធម៌ទាំងឡាយ មិនមានត្រឹមប៉ុណ្ណោះឡើយ ហើយពិចារណាឲ្យក្រៃលែងឡើង ក៏បានឃើញសច្ចបារមីទី ៧ ក៏មានការគិតយ៉ាងនេះថា នែសុមេធបណ្ឌិត ចាប់តាំងពីនេះទៅ អ្នកត្រូវបំពេញសច្ចបារមីឲ្យបរិបូណ៌ ទោះបីអសនីបាតធ្លាក់លើអំបែងក្បាល អ្នកកុំបីពោលមុសាវាទទាំងដឹងខ្លួន ដោយអំណាចធនៈជាដើម ដើម្បីទ្រព្យជាដើម ដូចផ្កាយព្រឹកក្នុងរដូវទាំងពួង មិនលះវិថីគោចររបស់ខ្លួន ទៅក្នុងវិថីដទៃឡើយ រមែងគោចរក្នុងវិថីរបស់ខ្លួនប៉ុណ្ណោះ យ៉ាងណា សូម្បីអ្នក ក៏ចូរយ៉ាងនោះដូចគ្នា កាលមិនលះបង់សច្ចៈ ពោលនូវពាក្យកុហក ក៏នឹងបានត្រាស់ជាព្រះពុទ្ធ កាលគិតហើយ ទើបអធិដ្ឋានសច្ចបារមីទី ៧ ធ្វើឲ្យមាំទាំហើយ ។ សមដូចព្រះតម្រាស់ថា

ពុទ្ធធម៌ទាំងឡាយ មិនមែនមានត្រឹមប៉ុណ្ណោះទេ អាត្មា
អញនឹងជ្រើសរើសរកពុទ្ធធម៌ដទៃទៀត ដែលជាធម៌ញុំាង

ពោធិញ្ញាណឲ្យសម្រេច ។ កាលនោះ តថាគតកំពុងជ្រើសរើសរក ក៏បានឃើញសច្ចបារមីទី ៧ ដែលពោធិសត្វទាំងឡាយអំពីបុរាណជាប់សេព ជាប់អាស្រ័យមក ( ហើយទូន្មានខ្លួនឯងថា ម្នាលសុមេធបណ្ឌិត ) អ្នកចូរសមាទានធ្វើសច្ចបារមីទី ៧ នេះឲ្យមាំមួន កុំមានពាក្យបែកជាពីរក្នុងសច្ចបារមីនោះ នឹងបានសម្រេចសម្ពោធិញ្ញាណមិនខានឡើយ ។ ធម្មតាផ្កាយព្រឹក ជាជញ្ជីងរបស់លោក ព្រមទាំងទេវលោក រមែងមិនឃ្លាតចាកវិថី ក្នុងរដូវភ្លៀង ឬហេមន្ត-រដូវឡើយ យ៉ាងណា ។ អ្នកកុំឃ្លាតចាកវិថីក្នុងសច្ចៈទាំងឡាយ យ៉ាងនោះដែរ លុះដល់នូវសច្ចបារមីហើយ នឹងបានសម្រេចសម្ពោធិញ្ញាណ មិនខានឡើយ ។

លំដាប់នោះ សុមេធតាបសនោះគិតថា ពុទ្ធការកធម៌ទាំងឡាយ មិនមានត្រឹមប៉ុណ្ណេះឡើយ ទើបពិចារណាឲ្យក្រៃលែងទៀត ក៏បានឃើញអធិដ្ឋានបារមីទី ៨ ទើបគិតយ៉ាងនេះថា នែសុមេធបណ្ឌិត ចាប់ពីនេះទៅចូរអ្នកបំពេញអធិដ្ឋានបារមីឲ្យបរិបូណ៌ ចូរជាអ្នកមិនញាប់ញ័រក្នុងធម៌ដែលបានអធិដ្ឋាន ដូចថ្មភ្នំតាន់ត្រូវខ្យល់បក់ក្នុងទិសទាំងពួង មិនញាប់ញ័រ មិនរង្គោះរង្គើ តាំងនៅក្នុងទីរបស់ខ្លួន យ៉ាងណា សូម្បីអ្នកក៏យ៉ាងនោះដូចគ្នា មិនញាប់ញ័រក្នុងធម៌ដែលខ្លួនអធិដ្ឋាន នឹងបានត្រាស់ជាព្រះពុទ្ធពិតប្រាកដ កាលគិតហើយ ក៏អធិដ្ឋាននូវអធិដ្ឋានបារមីទី ៨ ធ្វើឲ្យមាំហើយ ។ សមដូច

ព្រះតម្រាស់ថា

ពុទ្ធធម៌ទាំងឡាយ មិនមែនមានត្រឹមប៉ុណ្ណោះទេ អាត្មាអញនឹងជ្រើសរើសរកពុទ្ធធម៌ដទៃទៀត ដែលជាធម៌ញុំាងពោធិញ្ញាណឲ្យសម្រេច ។ កាលនោះ តថាគតកំពុងជ្រើសរើសរក ក៏បានឃើញអធិដ្ឋានបារមីទី ៨ ដែលពោធិសត្វទាំងឡាយអំពីបុរាណធ្លាប់សេព ធ្លាប់អាស្រ័យមក ( ហើយទូន្មានខ្លួនឯងថា ម្នាលសុមេធបណ្ឌិត ) អ្នកចូរសមាទាន ធ្វើអធិដ្ឋានបារមីទី ៨ នេះឲ្យមាំមួន អ្នកកុំញាប់ញ័រក្នុងអធិដ្ឋាន-បារមីនោះ នឹងបានសម្រេច សម្ពោធិញ្ញាណមិនខានឡើយ ។ ភ្នំថ្មឥតកម្រើក តាំងនៅស៊ប់ មិនរញ្ជួយ ដោយខ្យល់ដ៏ខ្លាំងក្លារមែងតាំងនៅក្នុងទីរបស់ខ្លួនដដែល យ៉ាងណា អ្នកចូរកុំកម្រើកក្នុងអធិដ្ឋានបារមីសព្វកាល យ៉ាងនោះដែរ លុះដល់នូវអធិដ្ឋានបារមីហើយ នឹងបានសម្រេចសម្ពោធិញ្ញាណមិនខានឡើយ ។

លំដាប់នោះ សុមេធតាបសគិតថា ពុទ្ធការកធម៌ទាំងឡាយ មិនមែនមានត្រឹមប៉ុណ្ណោះឡើយ ទើបពិចារណាឲ្យក្រៃលែងទៀត ក៏បានឃើញមេត្តា-បារមីទី ៩ ហើយគិតយ៉ាងនេះថា នែសុមេធបណ្ឌិត ចាប់អំពីនេះទៅ អ្នកត្រូវបំពេញមេត្តាបារមីឲ្យបរិបូណ៌ គប្បីជាអ្នកមានចិត្តតែមួយ ក្នុងបុគ្គលដែលអនុគ្រោះដោយប្រយោជន៍ និងមិនជាប្រយោជន៍ ដូចទឹក ជាធម្មតា

រមែងផ្សព្វផ្សាយនូវភាពត្រជាក់តែមួយ ដល់មនុស្សអាក្រក់ និងមនុស្សល្អ យ៉ាងណា សូម្បីអ្នកក៏យ៉ាងនោះដូចគ្នា ត្រូវជាអ្នកមានចិត្តតែមួយ ដោយមេត្តាក្នុងសត្វទាំងពួង នឹងបានត្រាស់ជាព្រះពុទ្ធពិតប្រាកដ កាលគិតហើយ ក៏អធិដ្ឋាននូវមេត្តាបារមីទី ៩ ធ្វើឲ្យមាំទាំហើយ ។ សមដូចព្រះតម្រាស់ថា

ពុទ្ធធម៌ទាំងឡាយ មិនមែនមានត្រឹមតែប៉ុណ្ណោះទេ អាត្មាអញនឹងជ្រើសរើសរកពុទ្ធធម៌ដទៃទៀត ដែលជាធម៌ញុំាងពោធិញ្ញាណឲ្យសម្រេច ។ កាលនោះ តថាគតកំពុងជ្រើសរើសរក ក៏ឃើញមេត្តាបារមីទី ៩ ដែលពោធិសត្វទាំងឡាយអំពីបុរាណធ្លាប់សេព ធ្លាប់អាស្រ័យមក ( ហើយទូន្មានខ្លួនឯងថា ម្នាលសុមេធបណ្ឌិត ) អ្នកចូរសមាទាន ធ្វើនូវមេត្តាបារមីទី ៩ នេះឲ្យមាំមួន អ្នកចូរកុំឲ្យមានបុគ្គលដទៃស្មើដោយមេត្តា បើអ្នកចង់លុះនូវពោធិញ្ញាណ ។ ធម្មតាទឹក រមែងផ្សព្វផ្សាយត្រជាក់ស្មើ ចំពោះជនទាំងល្អ ទាំងអាក្រក់ រមែងកម្ចាត់បង់នូវធូលីនិងមន្ទិល យ៉ាងណា ។ អ្នកចូរចម្រើនមេត្តាឲ្យស្មើចំពោះមិត្តនិងសត្រូវ យ៉ាងនោះដែរ លុះដល់នូវមេត្តាបារមីហើយ នឹងបានសម្រេចសម្ពោធិញ្ញាណ មិនខានឡើយ ។

លំដាប់នោះ សុមេធតាបសនោះគិតថា ពុទ្ធការកធម៌ទាំងឡាយ មិនមានត្រឹមប៉ុណ្ណោះឡើយ ទើបពិចារណាឲ្យក្រៃលែងឡើង ក៏បានឃើញឧបេក្ខាបារមីទី ១០ ហើយគិតយ៉ាងនេះថា នែសុមេធបណ្ឌិត ចាប់អំពីនេះ

ទៅ អ្នកត្រូវបំពេញឧបេក្ខាបារមីឲ្យបរិបូណ៌ គប្បីដាក់ចិត្តជាកណ្តាលក្នុងសុខ និងទុក្ខ ដូចផែនដី កាលមនុស្សចោលរបស់ស្អាតខ្លះ មិនស្អាតខ្លះ រមែងជាកណ្តាល យ៉ាងណា សូម្បីអ្នកក៏យ៉ាងនោះដូចគ្នា ដាក់ចិត្តជាកណ្តាលក្នុងសុខ និងទុក្ខ ក៏នឹងបានត្រាស់ជាព្រះពុទ្ធពិតប្រាកដ កាលគិតហើយ ទើបអធិដ្ឋានឧបេក្ខាបារមីទី ១០ ធ្វើឲ្យមាំទាំហើយ សមដូចព្រះតម្រាស់ថា

ពុទ្ធធម៌ទាំងឡាយ មិនមែនមានត្រឹមប៉ុណ្ណោះទេ អាត្មាអញនឹងជ្រើសរើសរកពុទ្ធធម៌ដទៃទៀត ដែលជាធម៌ញុំាងពោធិញ្ញាណឲ្យសម្រេច ។ កាលនោះ តថាគតកំពុងជ្រើសរើសរក ក៏ឃើញឧបេក្ខាបារមីទី ១០ ដែលពោធិសត្វទាំងឡាយអំពីបុរាណ ធ្លាប់សេព ធ្លាប់អាស្រ័យមក ( ហើយទូន្មានខ្លួនឯងថា ម្នាលសុមេធបណ្ឌិត ) អ្នកចូរសមាទាន ធ្វើឧបេក្ខាបារមីទី ១០ នេះឲ្យមាំមួន អ្នកគួរជាបុគ្គលដូចជាជញ្ជីងដ៏មាំមួន នឹងបានសម្រេចពោធិញ្ញាណ មិនខានឡើយ ។ ធម្មតាផែនដី តែងព្រងើយកន្តើយចំពោះវត្ថុមិនស្អាតក្តី ស្អាតក្តី ដែលគេដាក់ចុះហើយ តែងវៀរចាកសេចក្តីក្រោធ និងសេចក្តីត្រេកអរ ចំពោះវត្ថុទាំងពីរនោះ យ៉ាងណា អ្នកចូរធ្វើខ្លួនឲ្យដូចជាជញ្ជីង ចំពោះសុខ និងទុក្ខសព្វកាល យ៉ាងនោះដែរ អ្នកលុះដល់នូវឧបេក្ខាបារមីហើយ នឹងបានសម្រេចសម្ពោធិញ្ញាណពុំខាន ។

បន្ទាប់អំពីនោះ សុមេធតាបសគិតថា ពុទ្ធការកធម៌ទាំងឡាយ ដែល

ជាគ្រឿងបន្ទុំពោធិញ្ញាណ ដែលព្រះពោធិសត្វទាំងឡាយគប្បីបដិបត្តិក្នុងលោកនេះ មានត្រឹមនេះប៉ុណ្ណោះ វៀរបារមី ១០ ធម៌ដទៃរមែងមិនមាន បារមីទាំង ១០ នេះ ក្នុងអាកាសខាងលើក៏មិនមាន ក្នុងផែនដីខាងក្រោមក៏មិនមាន ក្នុងទិសទាំងឡាយ មានទិសខាងកើតជាដើមក៏មិនមាន តែនៅចំពោះខាងក្នុងហទយៈរបស់អាត្មាអញប៉ុណ្ណោះ ។ កាលបានឃើញថា បារមីទាំងនោះតាំងនៅចំពោះក្នុងហទយៈយ៉ាងនោះហើយ ទើបអធិដ្ឋានបារមីទាំងអស់ ធ្វើឲ្យមាំទាំ ពិចារណាហើយពិចារណាទៀត ទាំងអនុលោម និងបដិលោម ពីខាងចុងមកដល់ខាងដើម ពីខាងដើមរហូតដល់ខាងចុង កាន់យកចំណែកកណ្ដាលឲ្យមកបញ្ចប់ទាំងសងខាង កាន់យកទីបំផុតទាំងសងខាង ឲ្យមកបញ្ចប់ត្រង់កណ្ដាល ។

កិច្ចបរិច្ចាគវត្ថុខាងក្រៅ ចាត់ជាទានបារមី បរិច្ចាគអវយវៈតូចធំ ចាត់ជាទានឧបបារមី បរិច្ចាគជីវិត ចាត់ជាទានបរមត្ថបារមី សុមេធតាបសពិចារណាបារមី ៣០ ដូចពោលមកនេះ ដូចបុគ្គលបង្វិលគ្រឿងយន្តគាបប្រេងទៅមក និងដូចយកមហាភ្នំសិនេរុធ្វើជាត្បាល់ កូរមហាសមុទ្រក្នុងចក្កវាឡ ដូច្នោះ ។ កាលសុមេធតាបសនោះ ពិចារណាបារមី ១០ យ៉ាងនោះ ដោយតេជៈនៃធម៌ មហាប្រឹថពីនេះ ដែលមានកម្រាស់ ២ សែន ៤ ម៉ឺនយោជន៍ ក៏លាន់សំឡេងញាប់ញ័រ ដូចដើមបបុសដែលត្រូវដំរីជាន់ និងដូចគ្រឿងយន្តគាបអំពៅ និងដូចថាសយន្តរបស់ជាងឆ្នាំង និងដូចគ្រឿងយន្តសម្រាប់គាបប្រេង សមដូចព្រះតម្រាស់ថា

ធម៌ទាំងឡាយណា ជាគ្រឿងញុំាងពោធិញ្ញាណឲ្យសម្រេច ធម៌ទាំងនោះ មានក្នុងលោក ត្រឹមតែប៉ុណ្ណោះ ពុទ្ធការកធម៌ដទៃក្រៅអំពីបារមី ១០ នោះ មិនមានទេ អ្នកចូរតាំងនៅក្នុងបារមីធម៌ទាំង ១០ នោះ ឲ្យមាំមួនចុះ ។ កាលតថាគតពិចារណានូវបារមីធម៌ទាំងនេះ ដោយសភាវសរសលក្ខណៈ ផែនដីទាំងមួយម៉ឺនលោកធាតុ ក៏ញាប់ញ័រដោយតេជះនៃធម៌ ។ ផែនដីកម្រើកបន្ទឺឡើង ដូចជាឃ្នាបអំពៅ ដែលត្រូវគេគាបឬចក្កយន្តប្រេង ត្រូវគេគាបហើយ ( រមែងវិលញ័រ ) យ៉ាងណា ផែនដីក៏ញាប់ញ័រ យ៉ាងនោះដែរ ។

កាលមហាប្រឹថពីកំពុងញាប់ញ័រ បុគ្គលដែលអាស្រ័យក្នុងរម្មនគរមិនអាចតម្កល់ខ្លួនបាន អ្នកខ្លះដួលចុះ ហាក់ដូចសាលាធំត្រូវខ្យល់យុគន្តវាតបោកបក់ ដូច្នោះ ។ ភាជន៍ដី មានក្អមជាដើម រមៀលទង្គិចគ្នាបាក់បែក មហាជនភិតភ័យ ចូលទៅគាល់ព្រះសាស្តា ទូលសួរថា បពិត្រព្រះមានព្រះភាគ ខ្ញុំព្រះអង្គមិនជ្រាបសោះថា ផែនដីនេះ នាគ ភូត យក្ខ ឬទេវតាអង្គណាមួយធ្វើឲ្យញាប់ញ័រ ម្យ៉ាងទៀត មហាជនទាំងអស់នេះ ត្រូវធ្វើឲ្យក្តៅក្រហាយអំពើអាក្រក់ ឬអំពើល្អ នឹងមានដល់លោកនេះ សូមទ្រង់ត្រាស់ប្រាប់ហេតុនោះ ដល់យើងខ្ញុំព្រះអង្គទាំងឡាយផងចុះ ។ លំដាប់នោះ ព្រះសាស្តាកាលបានស្តាប់ពាក្យរបស់ជនទាំងនោះ ទើបត្រាស់ថា អ្នកទាំងឡាយ កុំខ្លាចឡើយ កុំគិតថ្វីឡើយ ភ័យដែលកើតអំពីហេតុនេះ មិនមានដល់ពួកអ្នក

បុគ្គលដែលតថាគតព្យាករក្នុងថ្ងៃនេះថា សុមេធបណ្ឌិត នឹងបានជាព្រះពុទ្ធព្រះនាមគោតម ក្នុងអនាគតនោះ ឥឡូវនេះ ពិចារណាបារមី ១០ កាលកុលបុត្រនោះកំពុងពិចារណា ព្រោះតេជះនៃធម៌ ទើបលោកធាតុទាំងមួយម៉ឺនញាប់ញ័រ លាន់ឮព្រមគ្នានោះឯង ។ សមដូចព្រះតម្រាស់ថា

បរិស័ទរបស់ព្រះពុទ្ធ មានចំនួនប៉ុន្មាន ក្នុងទីដែលអង្គាសបរិស័ទនោះ ក៏ញាប់ញ័រ ដេកជ្រប់លើផែនដីក្នុងទីអង្គាសនោះ ។ ឆ្នាំងជាច្រើនពាន់ និងក្អមជាច្រើនរយ ក៏ទង្គិចគ្នាបែកខ្ទេចខ្ទីអស់ ក្នុងទីនោះ ។ ពួកមហាជនមានចិត្តរន្ធត់ តក់ស្លុតភិតភ័យ ភ្ញាក់ផ្អើល មានចិត្តញ័រចំប្រប់ មកប្រជុំគ្នាហើយចូលទៅគាល់ព្រះពុទ្ធទីបង្ករ ( ហើយទូលសួរថា ) បពិត្រព្រះអង្គមានចក្ខុ ហេតុល្អ ឬហេតុអាក្រក់ដូចម្តេច នឹងមានដល់មនុស្សលោក លោកទាំងមូល ត្រូវសេចក្តីអន្តរាយបៀតបៀនហើយ សូមព្រះអង្គទ្រង់មេត្តាប្រោស បន្ទោបង់សេចក្តីអន្តរាយនោះចេញ ។ គ្រានោះ ព្រះមហាមុនីទីបង្ករទ្រង់ញុំាំងមហាជនទាំងនោះឲ្យយល់ច្បាស់ថា អ្នកទាំងឡាយចូរកុំមានសេចក្តីរង្កៀស កុំខ្លាច ចំពោះការញាប់ញ័រផែនដីនេះឡើយ ។ ដ្បិតតថា គតបានព្យាករក្នុងថ្ងៃនេះថា សុមេធ-បណ្ឌិតនេះ នឹងបានត្រាស់ជាព្រះពុទ្ធក្នុងលោក ( ក្នុងកាលជាអនាគត ) សុមេធបណ្ឌិតនុ៎ះ កំពុងពិចារណាធម៌ ដែល

ព្រះជិនស្រីអំពីបុរាណធ្លាប់សេពមក ។ កាលសុមេធបណ្ឌិត
ពិចារណាធម៌ គឺពុទ្ធភូមិដោយឥតសេសសល់ ព្រោះហេតុ
នោះ បានជាផែនដីទាំងមួយម៉ឺនលោកធាតុ ក្នុងលោក ព្រម
ទាំងទេវលោក ញាប់ញ័រ ។

មហាជនបានស្តាប់ព្រះតម្រាស់របស់ព្រះតថាគតហើយ នាំគ្នាត្រេកអរ នាំគ្នាកាន់យកផ្កា គ្រឿងក្រអូប និងគ្រឿងលាប ចេញអំពីរម្មនគរ ចូលទៅរកព្រះពោធិសត្វ បូជាដោយផ្កា និងគ្រឿងក្រអូបជាដើម ថ្វាយបង្គំហើយ ធ្វើប្រទក្សិណ ចូលទៅកាន់រម្មនគរវិញ ។ ឯព្រះពោធិសត្វពិចារណាបារមី ១០ អធិដ្ឋានសេចក្តីព្យាយាមធ្វើឲ្យមាំ ហើយក្រោកចាកអាសនៈ ចៀសចេញទៅ សមដូចព្រះតម្រាស់ថា

ចិត្ត ( នៃមហាជន ) ក៏រលត់ស្ងប់ក្នុងខណៈនោះភ្លាម ព្រោះ
បានស្តាប់ព្រះបន្ទូលរបស់ព្រះពុទ្ធ ពួកមហាជនទាំងអស់គ្នា
ក៏ចូលមករកតថាគត ហើយក្រាបថ្វាយបង្គំម្តងទៀត ។ គ្រា
នោះ តថាគតសមាទាន នូវពុទ្ធគុណធ្វើចិត្តឲ្យមាំមួន ក្រាប
ថ្វាយបង្គំព្រះពុទ្ធទីបង្ករ ហើយក្រោកចាកអាសនៈ ។

លំដាប់នោះ ទេវតាក្នុងម៉ឺនចក្រវាឡប្រជុំគ្នាបូជាព្រះពោធិសត្វ ដែលក្រោកឡើងចាកអាសនៈ ដោយផ្កា និងគ្រឿងក្រអូបជាទិព្វ ថ្វាយបង្គំហើយ ប្រកាសពាក្យសរសើរដែលជាមង្គលថា បពិត្រសុមេធតាបស ថ្ងៃនេះ លោកតាំងសេចក្តីប្រាថ្នាធំក្រៃលែង ទៀបបាទមូលរបស់ព្រះទីបង្ករទសពល ការ

ប្រាថ្នានោះ សូមសម្រេចដល់លោក កុំបីមានអន្តរាយឡើយ ការខ្វាច ឬការតក់ស្លុត កុំបីមានដល់លោក រោគសូម្បីមានប្រមាណតិចតួច កុំកើតឡើងក្នុងរាងកាយ សូមលោកប្រញាប់បំពេញបារមីឲ្យបរិបូណ៌ ហើយដឹងច្បាស់នូវសម្មាសម្ពោធិញ្ញាណ ដើមឈើដែលមានផ្កា មានផ្លែ រមែងចេញផ្កា ចេញផ្លែ តាមរដូវកាល យ៉ាងណា សូម្បីលោកក៏យ៉ាងនោះដូចគ្នា កុំបីកន្លងរដូវកាលនោះ សូមបានពាល់ត្រូវនូវសម្ពោធិញ្ញាណដ៏ឧត្តម ដោយរួសរាន់ចុះ កាលប្រកាសយ៉ាងនេះហើយ បានត្រឡប់ទៅកាន់ទេវស្ថានរៀងៗ ខ្លួន ។ ឯព្រះពោធិសត្វដែលទេវតាទាំងឡាយសរសើរហើយ ទើបគិតថា អញនឹងបំពេញបារមី ១០ ឲ្យបរិបូណ៌ នឹងបានត្រាស់ជាព្រះពុទ្ធក្នុងទីបំផុត ៤ អសង្ខៃយ្យ និង ១ សែនកប្ប ដូច្នេះហើយ អធិដ្ឋានសេចក្តីព្យាយាម ធ្វើឲ្យមាំទាំ ហើយបានហោះទៅកាន់អាកាស ទៅកាន់ព្រៃហិមពាន្តមួយរំពេច ។ សមដូចព្រះតម្រាស់ថា

ពួកទេវតា ពួកមនុស្ស ទាំងពីរពួក ក៏រោយរាយផ្កាទិព្វ និងផ្កាជារបស់មនុស្សចំពោះសុមេធបណ្ឌិត ដែលក្រោកចាកអាសនៈ ។ ពួកទេវតា និងពួកមនុស្ស ទាំងពីរពួកនោះ បាននូវសួស្តី ( ពោលថា ) តំណែងដ៏ធំដែលលោកប្រាថ្នាហើយ សូមលោកបាននូវតំណែងនោះ សមគួរតាមប្រាថ្នាចុះ ។ ចង្រៃទាំងពួង ចូរបវៀសចៀសចេញទៅ សេចក្តីសោក និងរោគ ក៏ចូរចៀសវាងចេញទៅ សេចក្តីអន្តរាយកុំបីមានដល់លោក

ឡើយ សូមលោកបានលុះនូវសព្វញ្ញុតញ្ញាណ ដ៏ខ្ពង់ខ្ពស់ ឆាប់ៗចុះ ។ កាលដល់រដូវផ្កា ពួកឈើមានផ្កា រមែងបញ្ចេញផ្កា យ៉ាងណា បពិត្រតាបសមានព្យាយាមធំ លោកចូរបញ្ចេញផ្កាដោយពុទ្ធញ្ញាណ យ៉ាងនោះដែរ ។ ព្រះសម្ពុទ្ធទាំងឡាយណាមួយ ទ្រង់បំពេញហើយនូវបារមីទាំង ១០ យ៉ាងណា បពិត្រតាបសមានព្យាយាមធំ លោកចូរបំពេញបារមីទាំង ១០ យ៉ាងនោះ ។ ព្រះសម្ពុទ្ធទាំងឡាយណាមួយ ទ្រង់ត្រាស់ដឹងទៀបគល់ពោធិមណ្ឌៈ យ៉ាងណា បពិត្រតាបសមានព្យាយាមធំ លោកចូរត្រាស់ដឹង ទៀបគល់ពោធិមណ្ឌៈនៃព្រះជិនស្រី យ៉ាងនោះ ។ ព្រះសម្ពុទ្ធទាំងឡាយណាមួយ ទ្រង់ញ៉ាំងធម្មចក្កឲ្យប្រព្រឹត្តទៅ យ៉ាងណា បពិត្រតាបសមានព្យាយាមធំ សូមលោកញ៉ាំងធម្មចក្កឲ្យប្រព្រឹត្តទៅ យ៉ាងនោះចុះ ។ ព្រះចន្ទពេញវង់ រមែងរុងរឿងក្នុងថ្ងៃពេញបូណ៌មី យ៉ាងណា លោកក៏មានចិត្តពេញ ចូររុងរឿងក្នុងលោកធាតុទាំងមួយម៉ឺន យ៉ាងនោះ ។ ព្រះអាទិត្យ ដែលរួចផុតអំពីរាហុ រមែងរុងរឿងដោយកម្តៅ យ៉ាងណា លោកចូររួចចាកលោកធម៌ ចូររុងរឿងដោយពុទ្ធសិរី យ៉ាងនោះដែរ ។ ស្ទឹង

ទាំងឡាយណាមួយ រមែងហូរទៅប្រជុំក្នុងមហាសមុទ្រ យ៉ាងណា ពួកលោក ព្រមទាំងទេវលោក ក៏រមែងប្រជុំក្នុងសម្នាក់របស់លោក យ៉ាងនោះដែរ ។ គ្រានោះ សុមេធបណ្ឌិតនោះ ដែលពួកទេវតា និងមនុស្សទាំងនោះ ស្ញើចសរសើរហើយ ក៏សមាទានទូវបារមីធម៌ទាំង ១០ បំពេញបារមីធម៌ទាំងនោះ ចូរទៅកាន់ព្រៃធំ ។

## សុមេធកថា ចប់

# សុរុចិព្រាហ្មណកថា

ឯអ្នករម្មនគរកាលចូលទៅកាន់នគរហើយ បានថ្វាយមហាទានដល់ភិក្ខុសង្ឃ មានព្រះពុទ្ធជាប្រធាន ព្រះសាស្តាទ្រង់បានសម្តែងធម៌ដល់ពួកជនទាំងនោះឲ្យមហាជនតាំងនៅក្នុងសរណៈជាដើម ហើយយាងចេញអំពីរម្មនគរទៅ ។

បន្ទាប់អំពីនោះ ទ្រង់តាំងនៅដរាបដល់អស់ព្រះជន្មាយុ ទ្រង់ធ្វើពុទ្ធកិច្ចគ្រប់យ៉ាង ហើយបរិនិព្វានដោយអនុបាទិសេសនិព្វានធាតុដោយលំដាប់ ។ ពាក្យទាំងអស់ ដែលគួរពោលក្នុងរឿងនោះ គប្បីជ្រាបដោយពិស្តារតាមន័យដែលពោលក្នុងពុទ្ធវង្សនោះឯង ។ សមដូចព្រះតម្រាស់ដែលត្រាស់ក្នុងពុទ្ធវង្សនោះថា

> គ្រានោះ ពួកឧបាសក ឧបាសិកាទាំងនោះ ញុំាងព្រះលោកនាយក ព្រមទាំងព្រះសង្ឃឲ្យឆាន់រួចហើយ ក៏ដល់នូវព្រះសាស្តាទីបង្ករនោះជាទីពឹង ។ ព្រះតថាគត ទ្រង់ញុំាងបុគ្គលខ្លះ ឲ្យតម្កល់នៅក្នុងសរណគមន៍ ញុំាងបុគ្គលខ្លះឲ្យតាំងនៅក្នុងសីល ៥ ញុំាងបុគ្គលដទៃទៀត ឲ្យតម្កល់នៅក្នុងសីល ១០ ។ ព្រះអង្គទ្រង់ប្រទានមគ្គដល់បុគ្គលខ្លះ ប្រទានផលដ៏ឧត្តមទាំង ៤ ដល់បុគ្គលខ្លះ ប្រទានបដិសម្ភិទា ជាធម៌ឥតមានអ្វីស្មើដល់បុគ្គលខ្លះ ។ ព្រះពុទ្ធដ៏ប្រសើរជាងនរៈ ទ្រង់ប្រទានសមាបត្តិ ៨ ដ៏ប្រសើរ ដល់បុគ្គលខ្លះ ប្រទានវិជ្ជា ៣ ដល់បុគ្គលខ្លះ អភិញ្ញា ៦ ដល់បុគ្គលខ្លះ ។ ព្រះមហាមុនីទ្រង់ទូន្មានពួកជន ដោយន័យជាគ្រឿងប្រកបនោះ ព្រោះ

ហេតុនោះ បានជាសាសនានៃព្រះលោកនាថ ជាគុណជាត ដ៏ធំទូលាយ ។ ព្រះពុទ្ធព្រះនាមទីបង្ករ មានព្រះហនុកា ( ដូច ព្រះចន្ទក្នុងថ្ងៃ ១២ កើត ) មានជង្ឃនូនមូលក្លំ ដូចគោឧសភ ទ្រង់ចម្លងពួកជនច្រើន ឲ្យរួចចាកទុគ្គតិ ។ ព្រះមហាមុនី ទ្រង់ឃើញពួកជនដែលគួរត្រាស់ដឹង ស្ថិតនៅក្នុងទីមួយសែន យោជន៍ ទ្រង់ចូលទៅជិត ហើយញុំាងពួកជននោះឲ្យត្រាស់ ដឹងក្នុងខណៈនោះ ។ ក្នុងការត្រាស់ដឹងទី ១ ព្រះពុទ្ធទ្រង់ ញុំាងពួកទេវតា ១០០ កោដិឲ្យត្រាស់ដឹង ក្នុងការត្រាស់ដឹងទី ២ ព្រះលោកនាថ ទ្រង់ញុំាងពួកទេវតា និងមនុស្ស ៩០ កោដិ ឲ្យត្រាស់ដឹង ។ កាលណាព្រះពុទ្ធ ទ្រង់សម្តែងធម៌ក្នុងភពនៃ ទេវតា កាលនោះ ពួកទេវតា ៩០ ពាន់កោដិ ( បានត្រាស់ ដឹង ) នេះជាការត្រាស់ដឹងទី ៣ ។ ព្រះសាស្តាទីបង្ករ មាន សាវកសន្និបាត ( ការជួបជុំសាវក ) ៣ លើក គឺសន្និបាត លើកទី ១ មានភិក្ខុសង្ឃមួយសែនកោដិ ។ កាលដែល ព្រះជិនស្រីទ្រង់យាងទៅក្នុងទីស្ងាត់ លើកំពូលភ្នំនារទៈ ពួក ព្រះខីណាស្រពប្រាសចាកមន្ទិល ចំនួន ១០០ កោដិ មក ប្រជុំគ្នា ( នេះជាសន្និបាតលើកទី ២ ) ។ កាលព្រះមហា មុនីមានព្យាយាមធំ ទ្រង់បវារណាជាមួយនឹងពួកភិក្ខុ ៩០ កោដិ ព្ទដ៏ក្នុំសុទស្សនៈ ( នេះជាសន្និបាតលើកទី ៣ ) ។

សម័យនោះ តថាគតជាតាបស មានផ្នួងសក់ មានព្យាយាមដ៏ក្លៀវក្លា ត្រាច់ទៅក្នុងអាកាស ជាអ្នកបានដល់នូវត្រើយនៃអភិញ្ញាទាំង ៥ ។ ពួកសត្វចំនួន ៣ ម៉ឺន បានត្រាស់ដឹងនូវសច្ចៈ ការត្រាស់ដឹងរបស់សត្វ នឹងរាប់ថា ១ ឬ ២ រាប់មិនអស់ឡើយ ។ សាសនារបស់ព្រះទីបង្ករមានព្រះភាគ ជាគុណជាតធំទូលាយ មានជនច្រើន ស្កុកស្កម្ភ សាយកាយ គឺព្រះអង្គទ្រង់ជម្រះល្អហើយ ក្នុងកាលនោះ ។ ពួកព្រះខីណាស្រពចំនួន ៤ សែនរូប បានលុះអភិញ្ញា ៦ មានឫទ្ធិច្រើន តែងហែហមព្រះពុទ្ធទីបង្ករ ដែលទ្រង់ជ្រាបច្បាស់នូវលោក សព្វកាល ។ ក្នុងសម័យនោះ ពួកជនណាមួយ ដែលមិនបានលុះព្រះអរហត្ត នៅជាសេក្ខបុគ្គល លះបង់នូវការកើតជាមនុស្ស ពួកជននោះ រមែងត្រូវគេតិះដៀល ។ សាសនា ( របស់ព្រះពុទ្ធទីបង្ករនោះ ) រីកសាយល្អ រុងរឿងដោយពួកព្រះអរហន្តខីណាស្រព ជាតាទិបុគ្គល ប្រាសចាកមន្ទិល សព្វកាល ។ នគររបស់ព្រះសាស្តាព្រះនាមទីបង្ករ ឈ្មោះរម្មាវតី ក្សត្រិយ៍ព្រះនាមសុទេវៈ ( ជាព្រះបិតា ) ព្រះជនិកា ព្រះនាមសុមេធា ។ ព្រះជិនស្រីនៅគ្រប់គ្រងផ្ទះអស់មួយម៉ឺនឆ្នាំ ប្រាសាទដ៏ខ្ពង់ខ្ពស់មាន ៣ ខ្នង គឺ ហង្សប្រាសាទ ១ កោញ្ចប្រាសាទ ១ មាយុរប្រាសាទ ១ ។

ពួកនារី ៣ សែនទាក់ សុទ្ធសឹងតែតាក់តែងយ៉ាងល្អ នារីឈ្មោះបទុមានោះ ( ជាមហេសី ) ព្រះឱរសព្រះនាមឱសភក្ខន្ធ ។ ព្រះជិនស្រី ឃើញនិមិត្តទាំង ៤ ទ្រង់ចេញទៅ ( បួស ) ដោយយានដំរី ទ្រង់ផ្គងព្យាយាមអស់ ១០ ខែឥតខ្វះ ។ លុះព្រះមុនី មានព្រះហឫទ័យ ប្រព្រឹត្តព្យាយាមហើយ ក៏បានត្រាស់ជាព្រះពុទ្ធ មហាមុនីទីបង្ករ ត្រូវព្រហ្មអារាធនាហើយ ។ ព្រះជិនស្រី មានព្យាយាមធំ ទ្រង់ញ៉ាំងធម្មចក្កឲ្យប្រព្រឹត្តទៅក្នុងវត្តនន្ទៈ ទ្រង់គង់ទៀបគល់ប្រេសធ្វើនូវការញ៉ាំញីតិរ្ថិយ ។ ព្រះសុមង្គលៈ និងព្រះតិស្សៈ ជាអគ្គសាវក ព្រះសាគតៈ ជាឧបដ្ឋាករបស់ព្រះសាស្ដាទីបង្ករ ។ នាងនន្ទា និងសុនន្ទា ជាអគ្គសាវិកា ពោធិព្រឹក្សរបស់ព្រះមានព្រះភាគអង្គនោះ គេហៅថា ដើមលៀប ។ ឧបាសកឈ្មោះតបុស្សៈ និងភល្លិកៈជាឧបដ្ឋាកដ៏ប្រសើរ នាងសិរិមានិងនាងសោណា ជាឧបដ្ឋាយិការបស់ព្រះសាស្ដាទីបង្ករ ។ ព្រះមហាមុនីទីបង្ករមានកម្ពស់ ៨០ ហត្ថ ល្អដូចឈើប្រចាំទ្វីប ឬដូចដើមសាលរាជព្រឹក្ស មានផ្ការីកស្គុសស្គាយ ។ រស្មីរបស់ព្រះអង្គផ្សាយទៅចម្ងាយ ១០ យោជន៍ជុំវិញ ព្រះមហេសីនោះមានព្រះជន្មមួយសែនឆ្នាំ កាលព្រះអង្គគង់ធរមាននៅឡើយ ទ្រង់ញ៉ាំងព្រះសទ្ធម្មឲ្យរុងរឿង ចម្លង

មហាជន ញ៉ាំងប្រជុំជនច្រើន ឲ្យឆ្លងចាកសង្សារវដ្ត ។ ព្រះទីបង្ករនោះ ព្រមទាំងសាវ័ក និព្វានទៅ ដូចគំនរភ្លើងដែលរុងរឿងរលត់ទៅ ដូច្នោះ ឫទ្ធិនោះក្តី យសនោះក្តី ទាំងចក្ករតនៈឰដ៏ព្រះបាទានោះក្តី ក៏រលត់ទៅ ។ សម្បត្តិទាំងអស់ ក៏អន្តរធានទៅ ឱហ្ន៎ ! សង្ខារទាំងពួង ជារបស់សូន្យទទេ ព្រះជិនស្រីជាសាស្តាចារ្យ ព្រះនាមទីបង្ករ ទ្រង់បរិនិព្វានក្នុងវត្តនន្ទៈ ។ ព្រះស្តូបរបស់ព្រះជិនស្រីនោះ កម្ពស់ ៣៦ យោជន៍ ( គេសាងទុក ) ក្នុងវត្តនន្ទៈនោះឯង ។ គ្រានោះ ( ពួកជនកសាង ) ព្រះស្តូបកម្ពស់ ៣ យោជន៍ ទៀបគល់ពោធិព្រឹក្ស ( សម្រាប់បញ្ចុះ ) បាត្រ និងចីវរ គ្រឿងបរិក្ខារ និងគ្រឿងប្រើប្រាស់របស់ព្រះសាស្តា ។

ក្នុងកាលបន្ទាប់ពីព្រះមានព្រះភាគទីបង្ករមក កន្លងបានមួយអសង្ខេយ្យ ព្រះសាស្តាព្រះនាមកោណ្ឌញ្ញៈ ទ្រង់កើតឡើង ព្រះសាស្តាអង្គនោះ មានសាវកសន្និបាត ៣ ដង ។ សន្និបាតលើកទី ១ មានសាវ័ក ១ សែនកោដិ សន្និបាតលើកទី ២ មានសាវ័ក ១ ពាន់កោដិ សាវកសន្និបាតលើកទី ៣ មានសាវ័ក ៩០ កោដិ ។

កាលនោះ ព្រះពោធិសត្វជាស្តេចចក្រពត្តិ ព្រះនាមវិជិតាវី បានថ្វាយមហាទានដល់ភិក្ខុសង្ឃ ១ សែនកោដិ មានព្រះពុទ្ធជាប្រធាន ។ ព្រះសាស្តាទ្រង់ព្យាករព្រះពោធិសត្វថា នឹងបានត្រាស់ជាព្រះពុទ្ធ ហើយទ្រង់

សម្ដែងធម៌ ។ ព្រះពោធិសត្វនោះ ទ្រង់ស្ដាប់ធម្មកថារបស់ព្រះសាស្ដាហើយ លះបង់រាជសម្បត្តិចេញបួស រៀនព្រះត្រៃបិដក ធ្វើសមាបត្តិ ៨ និងអភិញ្ញា ៥ ឲ្យកើតឡើង មានឈានមិនសាបសូន្យ ទៅកើតក្នុងព្រហ្មលោក ។

ព្រះកោណ្ឌញ្ញសម្ពុទ្ធ មាននគរឈ្មោះរម្មវតី ព្រះរាជាព្រះនាមសុនន្ទ ជាព្រះបិតា ព្រះទេវីព្រះនាមសុជាតា ជាព្រះជននី អគ្គសាវក ២ រូប គឺ ព្រះភទ្ទៈ ១ ព្រះសុភទ្ទៈ១ ព្រះថេរៈព្រះនាមអនុរុទ្ធ ជាពុទ្ធុបដ្ឋាក អគ្គសាវិកា ២ រូប គឺព្រះនាងតិស្សា ១ ព្រះនាងឧបតិស្សា ១ ដើមក្មៅនាងជាឈើ ត្រាស់ដឹង ព្រះសរីរៈកម្ពស់ ៨៨ ហត្ថ ព្រះជន្មាយុ ១ សែនឆ្នាំ ។

> សម័យខាងក្រោយ អំពីព្រះសម្ពុទ្ធទីបង្ករមក ព្រះលោក-
> នាយកព្រះនាមកោណ្ឌញ្ញៈ ទ្រង់មានតេជះ រកទីបំផុតគ្មាន
> មានយសរាប់មិនបាន មានគុណប្រមាណមិនបាន មិនងាយ
> បុគ្គលគ្របសង្កត់បាន ។

ក្នុងកាលបន្ទាប់អំពីព្រះកោណ្ឌញ្ញសម្ពុទ្ធនោះ កន្លងទៅ ១ អសង្ខេយ្យ មានព្រះពុទ្ធ ៤ អង្គ កើតឡើងក្នុងកប្បតែមួយ គឺព្រះពុទ្ធព្រះនាមមង្គលៈ ព្រះពុទ្ធព្រះនាមសុមនៈ ព្រះពុទ្ធព្រះនាមរេវតៈ ព្រះពុទ្ធព្រះនាមសោភិតៈ ។ ព្រះមានព្រះភាគព្រះនាមមង្គលៈ មានការប្រជុំសាវក ៣ ដង ក្នុងការប្រជុំ លើកដំបូង មានភិក្ខុ ១ សែនកោដិ លើកទីពីរ ១ សែនកោដិ លើកទីបី ៩០ កោដិ ។

បានឮថា ព្រះភាតាមាតាដទៃរបស់ព្រះអង្គ ព្រះនាមអានន្ទកុមារ បាន

យានទៅកាន់សម្នាក់របស់ព្រះសាស្ដាដើម្បីស្ដាប់ធម៌ មួយអន្លើដោយបរិស័ទ ៩០ កោដិ ព្រះសាស្ដាត្រាស់អនុបុព្វីកថាដល់ព្រះរាជកុមារៗ មួយអន្លើដោយបរិស័ទបានសម្រេចអរហត្ត ព្រមទាំងដោយបដិសម្ភិទា ។ ព្រះសាស្ដាទ្រង់ប្រមើលមើលបុព្វចរិយារបស់កុលបុត្រទាំងនោះ ទ្រង់ឃើញឧបនិស្ស័យនៃបាត្រ និងចីវរ ដែលសម្រេចដោយឫទ្ធិ ទើបទ្រង់លាព្រះហស្ដខាងស្ដាំត្រាស់ថា ចូរពួកអ្នកជាភិក្ខុចុះ ។

ក្នុងខណៈនោះឯង ជនទាំងអស់ក៏ទ្រទ្រង់នូវបាត្រ និងចីវរដែលសម្រេចដោយឫទ្ធិ ដល់ព្រមដោយអាកប្បកិរិយា ដូចព្រះថេរៈមានវស្សា ៦០ ថ្វាយបង្គំព្រះសាស្ដាហើយ ចោមរោម ។ នេះបានជាការប្រជុំសាវកលើកទី ៣ របស់ព្រះអង្គ ។ ព្រះពុទ្ធអង្គដទៃៗ មានព្រះរស្មីផ្សាយចេញអំពីព្រះសរីរៈដោយជុំវិញប្រមាណ ៨០ ហត្ថប៉ុណ្ណោះ យ៉ាងណា តែរស្មីរបស់ព្រះមង្គលៈមិនដូច្នោះឡើយ ព្រោះព្រះរស្មីចេញអំពីសរីរៈរបស់ព្រះមានព្រះភាគអង្គនោះផ្សាយទៅ ១ ម៉ឺនលោកធាតុ តាំងនៅសព្វកាល ។ ដើមឈើ ផែនដី ភ្នំ និងសមុទ្រជាដើម ដោយហោច សូម្បីឆ្នាំងបាយជាដើម ហាក់ដូចជាស្រោបដោយបន្ទះមាស ។

ម្យ៉ាងទៀត ប្រមាណព្រះជន្មាយុរបស់ព្រះអង្គ ៩ ម៉ឺនឆ្នាំ ។ អស់កាលប្រមាណប៉ុណ្ណោះ ព្រះចន្ទ និងព្រះអាទិត្យជាដើម មិនអាចបញ្ចេញពន្លឺដោយរស្មីរបស់ខ្លួន ការកំណត់ពេលយប់ និងពេលថ្ងៃមិនប្រាកដ ពេលថ្ងៃពួកសត្វត្រាច់ទៅដោយពន្លឺរបស់ព្រះពុទ្ធនោះឯង ដូចទៅដោយពន្លឺរបស់

ព្រះអាទិត្យ សត្វលោកដឹងពេលយប់ ដោយផ្កាឈើដែលរីកក្នុងពេលល្ងាច និងដឹងពេលថ្ងៃ ដោយសំឡេងបក្សីយំជាដើម ក្នុងពេលព្រឹក ។

សួរថា ព្រះពុទ្ធអង្គដទៃៗ មិនមានអានុភាពនេះឬ ឆ្លើយថា មិនមានក៏មិនមែន ពិតហើយ ព្រះពុទ្ធទាំងនោះ កាលទ្រង់ប្រាថ្នាគប្បីផ្សាយព្រះរស្មីទៅរហូតម៉ឺនលោកធាតុ ឬក្រៃលែងជាងនោះក៏បាន តែព្រះរស្មីផ្សាយចេញអំពីសរីរៈរបស់ព្រះមានព្រះភាគ ព្រះនាមមង្គលៈ ផ្សាយទៅអស់ម៉ឺនលោកធាតុ តាំងនៅសព្វកាល ដូចគ្នានឹងរស្មីមួយព្យាមរបស់ព្រះពុទ្ធអង្គដទៃៗដោយអំណាចការប្រាថ្នាក្នុងកាលមុន ។

បានឮថា ក្នុងកាលទ្រង់នៅបំពេញចរិយារបស់ព្រះពោធិសត្វ ទ្រង់តាំងនៅក្នុងអត្តភាព ដូចគ្នានឹងព្រះបាទវេស្សន្តរ មួយអន្លើដោយបុត្រ និងភរិយានៅត្រង់ភ្នំវង្កបព៌ត ។ កាលនោះ មានយក្ខមួយឈ្មោះខរទាឋិកៈ បានដឹងថា ព្រះមហាបុរសមានអធ្យាស្រ័យក្នុងការឲ្យទាន ទើបចូលទៅរក ដោយភេទជាព្រាហ្មណ៍ សុំទារកទាំង ២ នឹងព្រះមហាសត្វ ។ ព្រះមហាសត្វត្រាស់ថា នែព្រាហ្មណ៍ យើងឲ្យបុត្តតូចទាំង ២ ដល់អ្នក ដូច្នេះហើយ ត្រេកអរបានឲ្យទារកទាំង ២ ធ្វើឲ្យផែនដីមានទឹកជាទីបំផុតញាប់ញ័រ ។ យក្ខឈរផ្អែកភ្នាក់ដៃខាងចុងទីចង្រ្កម កាលព្រះមហាសត្វកំពុងឃើញនោះឯង បានស៊ីទារកទាំង ២ ដូចទំពាក្រអៅឈូកដូច្នោះ ព្រះមហាសត្វសម្លឹងមើលយក្ខឃើញមាត់យក្ខហាឡើងមានតំណក់ឈាម ដូចអណ្តាតភ្លើង ហូរចុះមក ក៏មិនកើតទោមនស្ស សូម្បីប៉ុនចុងសក់ ។ កាលព្រះមហាសត្វគិតថា ទាន

ដែលអញឲ្យហើយល្អហ្ន៎ បីតិ និងសោមនស្សយ៉ាងធំ កើតឡើងក្នុងសរីរៈព្រះពោធិសត្វប្រាថ្នាថា ដោយផលនៃទានរបស់អាត្មាអញនេះ ក្នុងអនាគត-កាល សូមឲ្យរស្មីផ្សាយចេញអំពីសរីរៈដោយទំនងនេះឯងចុះ ព្រោះអាស្រ័យសេចក្ដីប្រាថ្នានោះ ទើបរស្មីផ្សាយចេញអំពីសរីរៈរបស់ព្រះអង្គ ក្នុងកាលដែលបានត្រាស់ជាព្រះពុទ្ធ អស់ទីប្រមាណប៉ុណ្ណេះ ។

បុព្វចរិយារបស់ព្រះអង្គដទៃទៀតក៏មាន បានឮថា ក្នុងកាលជាព្រះពោធិសត្វ បានឃើញព្រះចេតិយរបស់ព្រះសម្មាសម្ពុទ្ធមួយអង្គ គិតថា អញគួរបរិច្ចាគជីវិតដល់ព្រះពុទ្ធអង្គនេះ ទើបរុំសរីរៈទាំងមូល ដោយទំនងដូចជាប្រទីប យកសប្បិដាក់ក្នុងថាសមាស ដែលមានតម្លៃ ១ សែន កម្ពស់ប្រមាណ ១ ហត្ថក្ដាប់ ដាក់ប្រឆេះ ១ ពាន់ ក្នុងថាសមាសនោះ យកក្បាលទូលថាសមាសនោះ ហើយឲ្យដុតភ្លើងត្រង់ខ្លួន ធ្វើប្រទក្សិណព្រះចេតិយអស់មួយយប់ កាលព្រះពោធិសត្វនោះព្យាយាមយ៉ាងនោះ រហូតអរុណរះ កម្ដៅមិនបានបៀតបៀន សូម្បីត្រឹមតែរណ្ដៅរោម ហាក់បីដូចចូលទៅកាន់បន្ទប់ផ្កាឈូក ។ ព្រោះថា ធម៌រមែងរក្សាបុគ្គលអ្នកប្រព្រឹត្តធម៌ សមដូចព្រះតម្រាស់ ( ក្នុងថេរគាថា ) ថា

ធម៌ រមែងរក្សាបុគ្គលអ្នកប្រព្រឹត្តធម៌ដោយពិត ធម៌ដែលបុគ្គលសន្សំល្អហើយ រមែងនាំមកនូវសេចក្ដីសុខ នេះជាអានិសង្សក្នុងធម៌ ដែលបុគ្គលសន្សំល្អហើយ បុគ្គលអ្នកប្រព្រឹត្តធម៌ រមែងមិនទៅកាន់ទុគ្គតិ ដូច្នេះ ។

ព្រោះផលនៃកម្មនេះឯង ពន្លឺអំពីសរីរៈរបស់ព្រះមានព្រះភាគអង្គនោះ បានផ្សាយទៅរហូតម៉ឺនលោកធាតុ ។

ក្នុងកាលនោះ ព្រះពោធិសត្វនៃយើងទាំងឡាយ ជាព្រាហ្មណ៍ឈ្មោះ សុរុចិ គិតថា នឹងនិមន្តព្រះសាស្តា ទើបចូលទៅគាល់ស្តាប់ធម្មកថាដ៏ពីរោះ រួចក្រាបទូលថា បពិត្រព្រះអង្គដ៏ចម្រើន សូមទ្រង់ទទួលភិក្ខារបស់ខ្ញុំព្រះអង្គ ក្នុងថ្ងៃស្អែកនេះ ។ ព្រះសាស្តាត្រាស់សួរថា ម្នាលព្រាហ្មណ៍ អ្នកត្រូវការ ភិក្ខុប៉ុន្មាន ព្រាហ្មណ៍ក្រាបទូលថា បពិត្រព្រះអង្គដ៏ចម្រើន ភិក្ខុជាបរិវារ របស់ព្រះអង្គមានប្រមាណប៉ុន្មាន គ្រានោះ ព្រះសាស្តាទ្រង់មានការប្រជុំ សាវកជាលើកដំបូងល្មម ព្រោះហេតុនោះ ទើបត្រាស់ថា មានភិក្ខុ ១ សែន កោដិ ។ ព្រាហ្មណ៍ក្រាបទូលថា បពិត្រព្រះអង្គដ៏ចម្រើន សូមទ្រង់ មួយ អន្លើដោយភិក្ខុទាំងអស់ ទទួលភិក្ខារបស់ខ្ញុំព្រះអង្គចុះ ព្រះសាស្តាទ្រង់ទទួល និមន្តហើយ ។

ព្រាហ្មណ៍ទូលនិមន្តដើម្បីសោយក្នុងថ្ងៃស្អែកនេះ ហើយត្រឡប់ទៅផ្ទះ បានគិតថា អាត្មាអញអាចថ្វាយបបរ កត្ត និងសំពត់ជាដើម ដល់ភិក្ខុទាំង ឡាយប្រមាណប៉ុណ្ណោះបាន តែទីអង្គុយនឹងមានដូចម្តេច ការគិតរបស់ព្រាហ្មណ៍ ធ្វើឲ្យក្តៅដល់បណ្ឌុកម្ពលសិលាអាសនៈរបស់សក្កទេវរាជ ដែលនៅឆ្ងាយ រហូត ៨៤០០០ យោជន៍ ។ សក្កទេវរាជទ្រង់ព្រះតម្រិះថា នរណាហ្ន៎ មាន បំណងនឹងឲ្យអាត្មាអញឃ្លាតចាកទីនេះ ទើបប្រមើលមើលដោយទិព្វចក្ខុ បានឃើញព្រះមហាបុរស ទើបទ្រង់ព្រះតម្រិះថា ព្រាហ្មណ៍ឈ្មោះសុរុចិ

និមន្តភិក្ខុសង្ឃ មានព្រះពុទ្ធជាប្រធាន ហើយត្រូវការទីអង្គុយ អាត្មាអញគួរទៅក្នុងទីនោះ ហើយកាន់យកចំណែកបុណ្យ ទើបទ្រង់និម្មិតអត្តភាពជាជាងឈើ កាន់កាំបិត និងពូថៅ ទៅប្រាកដខាងមុខរបស់មហាបុរស ពោលថា អ្នកណាមានការងារដែលត្រូវស៊ីឈ្នួល ធ្វើដែរឬទេ ។

ព្រះមហាបុរសឃើញជាងឈើនោះហើយ ក៏ពោលថា អ្នកធ្វើការងារអ្វីបានខ្លះ សក្កទេវរាជត្រាស់ថា សិប្បៈដែលខ្ញុំមិនចេះមិនមាន អ្នកណាឲ្យធ្វើការងារណា ផ្ទះក្តី មណ្ឌបក្តី ខ្ញុំរកវិធីធ្វើការងារឲ្យបុគ្គលនោះបាន ។ ព្រះមហាបុរសពោលថា បើយ៉ាងនោះ ខ្ញុំមានការងារឲ្យអ្នកធ្វើ ។ សក្កទេវរាជសួរថា ការងារអ្វីលោកម្ចាស់ មហាបុរសពោលថា ខ្ញុំនិមន្តភិក្ខុ ១ សែនកោដិ មកឆាន់ក្នុងថ្ងៃស្អែកនេះ ខ្ញុំនឹងធ្វើមណ្ឌបសម្រាប់ជាទីអង្គុយរបស់ភិក្ខុទាំងនោះ ។ សក្កទេវរាជត្រាស់ថា ខ្ញុំធ្វើបាន លោកហ៊ានឲ្យថ្លៃឈ្នួលខ្ញុំទេ មហាបុរសពោលថា ខ្ញុំឲ្យបាន ។ សក្កទេវរាជពោលថា សាធុ ខ្ញុំនឹងធ្វើ ហើយទៅសម្លឹងមើលដីមួយកន្លែង ដែលមានប្រមាណ ១២-១៣ យោជន៍ មានផ្ទៃរាបស្មើ ដូចមណ្ឌលកសិណ ។ សក្កទេវរាជគិតថា មណ្ឌបដែលសម្រេចដោយកែវ ៧ ប្រការ ចូរផុសឡើងក្នុងទីប្រមាណប៉ុណ្ណោះ ហើយសម្លឹងមើល ។ រំពេចនោះ មណ្ឌបក៏ជ្រែកផែនដីផុសឡើង ។

មណ្ឌបនោះ មានសសរសម្រេចដោយមាស មានក្បាលសសរសម្រេចដោយប្រាក់ ត្រង់សសរដែលសម្រេចដោយប្រាក់ មានក្បាលសសរសម្រេចដោយមាស ត្រង់សសរដែលសម្រេចដោយកែវមណី មាន

ក្បាលសសរសម្រេចដោយកែវប្រពាល ត្រង់សសរដែលសម្រេចដោយកែវប្រពាល មានក្បាលសសរដែលសម្រេចដោយកែវមណី ត្រង់សសរដែលសម្រេចដោយរតនៈទាំង ៧ មានក្បាលសសរសម្រេចដោយរតនៈទាំង ៧ ។ បន្ទាប់អំពីនោះ ទើបទ្រង់ត្រិះរិះថា បណ្ដាញកណ្ដឹង ចូរសំយុងក្នុងចន្លោះៗ របស់មណ្ឌប ហើយសម្លឹងមើល ដំណាលគ្នានឹងការសម្លឹងមើលប៉ុណ្ណោះ បណ្ដាញក៏សំយុងចុះ សំឡេងដ៏ពីរោះនៃសំណាញកណ្ដឹង ដែលត្រូវខ្យល់បក់ត្រសៀកៗ ក៏លាន់ឮដូចតន្ត្រីដែលប្រកបដោយអង្គ ៥ ដូចតន្ត្រីទិព្វប្រគំ ដូច្នោះ ។

កាលសក្កទេវរាជទ្រង់ព្រះតម្រិះថា សូមកម្រងគ្រឿងក្រអូប និងកម្រងផ្កា សំយុងចុះក្នុងចន្លោះៗ កម្រងផ្កាទាំងឡាយ ក៏សំយុងចុះ ។ សក្កទេវរាជទ្រង់ព្រះតម្រិះថា សូមអាសនៈ និងទែនអង្គុយរបស់ភិក្ខុ ១ សែនកោដិ ចូរជ្រែកផែនដីផុសឡើង ក្នុងវេលានោះ វត្ថុទាំងនោះ ក៏ផុសឡើង ទ្រង់ព្រះតម្រិះថា គ្រប់ជ្រុង សូមថ្លាងទឹកផុសឡើងមួយជ្រុង ១ ថ្លាងទឹកទាំងឡាយក៏ផុសឡើងមក ។

សក្កទេវរាជ ទ្រង់និម្មិតវត្ថុប្រមាណប៉ុណ្ណោះស្រេចហើយ ទើបទៅកាន់សម្នាក់របស់ព្រាហ្មណ៍ ពោលថា មក សូមលោកម្ចាស់ពិនិត្យមើលមណ្ឌបរបស់លោកហើយ ចូរឲ្យតម្លៃដល់ខ្ញុំ ។ មហាបុរសក៏ទៅមើលមណ្ឌប កាលកំពុងមើលនោះឯង សរីរៈទាំងមូលបានពាល់ត្រូវដោយបីតិ ៥ សព្វកាល ។

លំដាប់នោះ មហាសត្វសម្លឹងមើលមណ្ឌបហើយ គិតដូច្នេះថា មណ្ឌប

នេះ មនុស្សមិនអាចធ្វើបាន តែព្រោះអធ្យាស្រ័យរបស់អញ និងគុណរបស់អញ ភពរបស់សក្កទេវរាជនឹងក្តៅពិត បន្ទាប់អំពីនោះ សក្កទេវរាជនឹងសាងមណ្ឌបនេះឡើង ។ មហាសត្វគិតថា អញថ្វាយទានត្រឹមមួយថ្ងៃក្នុងមណ្ឌបបែបនេះ មិនសមគួរដល់អញឡើយ អញនឹងថ្វាយ ៧ ថ្ងៃ ។ ព្រោះថា ទានខាងក្រៅ សូម្បីមានច្រើនដល់ម៉្លេះ ក៏មិនអាចធ្វើឲ្យព្រះពោធិសត្វទាំងឡាយត្រេកអរបាន តែកាលព្រះពោធិសត្វកាត់ក្បាលដែលប្រដាប់ហើយក្តី ខ្វេះភ្នែកដែលបន្តក់ហើយក្តី ឬពុះទ្រូងរូងយកបេះដូងឲ្យទៅជាទានក្តី ទើបធ្វើឲ្យព្រះពោធិសត្វ កើតនូវសេចក្តីត្រេកអរក្នុងការបរិច្ចាគ ។

ពិតហើយ ក្នុងសិវិរាជជាតក កាលព្រះពោធិសត្វនៃយើង លះបង់នូវទ្រព្យ ៥ សែនកហាបណៈឲ្យទានត្រង់ទ្វារទាំង ៤ និងត្រង់កណ្តាលនគរ ទាននោះក៏មិនអាចធ្វើឲ្យកើតនូវការត្រេកអរក្នុងការបរិច្ចាគ តែក្នុងកាលណា សក្កទេវរាជកាឡាខ្លួនជាព្រាហ្មណ៍ សូមភ្នែកទាំងគូ ក្នុងកាលនោះ កាលព្រះពោធិសត្វខ្វេះភ្នែកទាំងនោះឲ្យទាននោះឯង ទើបការត្រេកអរកើតឡើង ចិត្តមិនគិតដទៃសូម្បីប៉ុនចុងសក់ ឈ្មោះថា ការឆ្អែត ព្រោះអាស្រ័យទានដែលឲ្យហើយយ៉ាងនេះ មិនមានដល់ព្រះពោធិសត្វទាំងឡាយឡើយ ព្រោះហេតុនោះ មហាបុរសនោះគិតថា អញគួរថ្វាយទានដល់ភិក្ខុ ១ សែនកោដិអស់ ៧ ថ្ងៃ ទើបនិមន្តឲ្យគង់ក្នុងមណ្ឌបនោះ ហើយបានថ្វាយទាន ឈ្មោះគវបានៈអស់ ៧ ថ្ងៃ ។

ដែលហៅថា គវបានៈនោះ បានដល់ ភោជនដែលគេដាក់ទឹកដោះស្រស់

ពេញខ្ទះធំ ហើយដាក់លើជើងក្រាន ដាក់អង្ករបន្តិចបន្តួចក្នុងទឹកដោះស្រស់រម្ងាស់របហូតខះ ហើយផ្សំដោយទឹកឃ្មុំ និងស្ករអំពីខាងលើ មួយអន្ទើដោយសប្បិដែលរម្ងាស់ហើយ ។ ចំពោះមនុស្សមិនអាចអង្គាសបាន សូម្បីទេវតាក៏ត្រូវប្តូរគ្នា ទើបអង្គាសបាន ។ ទីប្រមាណ ១២-១៣ យោជន៍ មិនអាចដាក់ភិក្ខុទាំងឡាយបានគ្រប់គ្រាន់ តែភិក្ខុទាំងនោះ អង្គុយបានដោយអានុភាពរបស់ខ្លួន ។ ក្នុងថ្ងៃចុងក្រោយ មហាបុរសឲ្យលាងបាត្រ ភិក្ខុគ្រប់រូបហើយដាក់សប្បិ នវនីត ប្រេង ទឹកឃ្មុំ និងស្ករអំពៅ របហូតពេញបាត្រ ដើម្បីជាភេសជ្ជៈ ហើយក៏ប្រគេន មួយអន្ទើដោយត្រៃចីវរ សំពត់ដែលធ្វើជាចីវរដែលភិក្ខុថ្មីក្នុងសង្ឃបានទទួល មានតម្លៃ ១ សែន ។

ព្រះសាស្តា កាលទ្រង់ធ្វើអនុមោទនា ទ្រង់ពិចារណាថា បុរសនេះបានថ្វាយមហាទានបែបនេះ គេនឹងកើតជាអ្វីហ្ន៎ ទ្រង់បានឃើញថា ក្នុងអនាគត-កាល ក្នុងទីបំផុតនៃ ២ អសង្ខេយ្យ និង ១ សែនកប្ប បុរសនេះ នឹងបានជាព្រះពុទ្ធព្រះនាមគោតម ទើបត្រាស់ហៅព្រះមហាបុរសមក ហើយទ្រង់បានព្យាករថា កាលកន្លងទៅប៉ុណ្ណេះ អ្នកនឹងបានជាព្រះពុទ្ធ ព្រះនាមគោតម ព្រះមហាបុរសបានស្តាប់ព្យាករនោះហើយ គិតថា បានឮថា អាត្មាអញនឹងបានត្រាស់ជាព្រះពុទ្ធ អញត្រូវការអ្វីដោយការនៅគ្រប់គ្រងផ្ទះ អញនឹងបួស ទើបលះនូវសម្បត្តិបែបនោះ ដូចដុំទឹកមាត់ ហើយបួសក្នុងសម្នាក់របស់ព្រះសាស្តា រៀនពុទ្ធវចនៈបានហើយ ធ្វើអភិញ្ញា និងសមាបត្តិឲ្យកើតឡើង ក្នុងពេលអស់អាយុ បានទៅកើតក្នុងព្រហ្មលោក ។

ព្រះមានព្រះភាគមង្គលៈ មាននគរឈ្មោះឧត្តរៈ បិតាជាក្សត្រព្រះនាមឧត្តរៈ ព្រះមាតាជាព្រះទេវី ព្រះនាមឧត្តរា អគ្គសាវក ២ រូប គឺសុទេវៈ ១ ធម្មសេនៈ ១ ព្រះថេរៈឈ្មោះបាលិតៈ ជាឧបដ្ឋាក អគ្គសាវិកា ២ រូប គឺព្រះនាងសីវលី[១] ១ អសោកា ១ ដើមឪឹងជាឈើត្រាស់ដឹង មានព្រះសរីរៈកម្ពស់ ៨៨ ហត្ថ ។ កាលទ្រង់តាំងព្រះជន្មាយុ ៩ ម៉ឺនឆ្នាំ ហើយបរិនិព្វានចក្កវាឡទាំង ១ ម៉ឺន ក៏ងងឹតព្រមគ្នានោះឯង ។ មនុស្សទាំងឡាយក្នុងចក្កវាឡនោះ នាំគ្នាយំរៀបរាប់យ៉ាងធំ ។

កាលខាងក្រោយ អំពីព្រះសម្ពុទ្ធកោណ្ឌញ្ញៈមក ព្រះ
លោកនាយក ព្រះនាមមង្គលៈ ទ្រង់កម្ចាត់បង់ងងឹតក្នុង
លោក ព្រះអង្គទ្រទ្រង់នូវគប់ភ្លើង គឺព្រះធម៌ ដូច្នេះ ។

ក្នុងកាលខាងក្រោយ ព្រះមានព្រះភាគអង្គនោះ ទ្រង់បរិនិព្វាន ធ្វើម៉ឺនលោកធាតុឲ្យងងឹត ដោយប្រការយ៉ាងនេះហើយ ព្រះសាស្តាព្រះនាមសុមនៈកើតឡើងក្នុងលោក ទ្រង់មានសាវកសន្និបាត ៣ ដង ក្នុងការប្រជុំគ្រាដំបូង មានភិក្ខុ ១ សែនកោដិ លើកទី ២ត្រង់កញ្ចនបព៌ត មានភិក្ខុ ៩ ម៉ឺនកោដិ លើកទី ៣ មានភិក្ខុ ៨ ម៉ឺនកោដិ ។

កាលនោះ ព្រះមហាសត្វបានជាស្តេចនាគ ឈ្មោះអតុល មានឫទ្ធិច្រើន មានអានុភាពច្រើន ព្រះមហាសត្វនោះបានស្តាប់ថា ព្រះពុទ្ធទ្រង់កើតឡើងហើយ ដែលពួកញាតិចោមរោម ចេញអំពីនាគពិភព ឲ្យធ្វើនូវការប្រគំ

---

១- បិដកខ្មែរលេខ ៧៧ ជាសីវលា ។

ដោយទិព្វតន្ត្រីថ្វាយដល់ព្រះមានព្រះភាគអង្គនោះ ដែលមានភិក្ខុ ១ សែនកោដិជាបរិវារ ញុំាងមហាទានឲ្យប្រព្រឹត្តទៅ ថ្វាយសំពត់ ១ អង្គ ១ គូ តាំងនៅក្នុងសរណៈ ៣ ។

ព្រះសាស្តាអង្គនោះ ទ្រង់ព្យាករស្តេចនាគថា នឹងបានត្រាស់ជាព្រះពុទ្ធក្នុងអនាគតកាល ។ ព្រះមានព្រះភាគអង្គនោះ មាននគរឈ្មោះមេខលៈ ព្រះរាជាព្រះនាមសុទត្តៈ ជាព្រះបិតា ព្រះទេវីព្រះនាមសិរិមា ជាព្រះជននី អគ្គសាវក ២ រូប គឺសរណៈ ១ ភាវិតត្តៈ ១ ព្រះថេរៈនាមឧទេន ជាឧបដ្ឋាក អគ្គសាវិកា ២ រូប គឺសោណា ១ ឧបសោណា ១ ដើមឪឹងជាឈើត្រាស់ដឹង ព្រះសរីរៈកម្ពស់ ៩០ ហត្ថ ប្រមាណព្រះជន្មាយុ ៩ ម៉ឺនឆ្នាំ ។

កាលខាងក្រោយ អំពីព្រះមង្គលសម្ពុទ្ធមក ព្រះលោកនាយក
ព្រះនាមសុមនៈ រកបុគ្គលស្មើគ្មាន ដោយធម៌ទាំងពួង
ព្រះអង្គឧត្តមជាងសព្វសត្វ ដូច្នេះ ។

ក្រោយអំពីព្រះពុទ្ធ ព្រះនាមសុមនៈអង្គនោះ ព្រះសាស្តាព្រះនាមរេវតៈ ទ្រង់បានកើតឡើង ។ សាវកសន្និបាតរបស់ព្រះអង្គមាន ៣ ដង ក្នុងសន្និបាតលើកដំបូង មានភិក្ខុរាប់មិនបាន លើកទី ២ មានភិក្ខុ ១ សែនកោដិ លើកទី ៣ ក៏មានភិក្ខុ ១ សែនកោដិដូចគ្នា ។

ក្នុងកាលនោះ ព្រះពោធិសត្វកើតជាព្រាហ្មណ៍ ឈ្មោះអតិទេវៈ ស្តាប់ព្រះធម្មទេសនារបស់ព្រះសាស្តាហើយ តាំងនៅក្នុងសរណៈ ៣ ផ្គងអញ្ជលីលើសិរសា បានស្តាប់ពាក្យសរសើរក្នុងការលះកិលេសរបស់ព្រះសាស្តាអង្គ

នោះហើយ បានបូជាដោយសំពត់ឧត្តរាសង្គៈ ទ្រង់ក៏ព្យាករថា នឹងបានត្រាស់ជាព្រះពុទ្ធ ។

ព្រះមានព្រះភាគអង្គនោះ មាននគរឈ្មោះសុធញ្ញវតី[១] ព្រះរាជាព្រះនាមវិបុល ជាព្រះបិតា ព្រះទេវីព្រះនាមវិបុលា ជាព្រះមាតា អគ្គសាវក ២ រូប គឺវរុណៈ ១ ព្រហ្មទេវៈ ១ ព្រះថេរៈឈ្មោះសម្ភវៈ ជាឧបដ្ឋាក អគ្គសាវិកា ២ រូប គឺភទ្ទា ១ សុភទ្ទា ១ ដើមឈើជាឈើត្រាស់ដឹង ព្រះសរីរៈកម្ពស់ ៨០ ហត្ថ ព្រះជន្មាយុ ៦ ម៉ឺនឆ្នាំ ។

កាលខាងក្រោយ អំពីព្រះសម្ពុទ្ធ ព្រះនាមសុមនៈមក មាន
ព្រះលោកនាយកព្រះនាមរេវតៈ មិនមានបុគ្គលប្រៀប មិន
មានបុគ្គលស្មើ មិនមានបុគ្គលប្រៀបបាន ព្រះអង្គឧត្តម ទ្រង់
ឈ្នះពួកមារ ដូច្នេះ ។

ក្រោយអំពីព្រះពុទ្ធ ព្រះនាមរេវតៈនោះ ព្រះសាស្ដាព្រះនាមសោភិតៈបានកើតឡើង ទ្រង់មានសាវកសន្និបាត ៣ ដង សន្និបាតលើកទី ១ មានភិក្ខុ ១០០ កោដិ លើកទីពីរមានភិក្ខុ ៩០ កោដិ លើកទីបី មានភិក្ខុ ៨០ កោដិ ។

ក្នុងកាលនោះ ព្រះពោធិសត្វកើតជាព្រាហ្មណ៍ ឈ្មោះអជិតៈ ស្ដាប់ព្រះធម្មទេសនារបស់ព្រះសាស្ដាហើយ តាំងនៅក្នុងសរណៈ ៣ បានថ្វាយមហាទានដល់ភិក្ខុសង្ឃ មានព្រះពុទ្ធជាប្រធាន ទ្រង់ក៏បានព្យាករព្រះ

---

១- បិដកខ្មែរលេខ ៧៧ ជាសុធញ្ញកៈ ។

ពោធិសត្វថា នឹងបានត្រាស់ជាព្រះពុទ្ធ ។

ព្រះមានព្រះភាគអង្គនោះ មានព្រះនគរឈ្មោះសុធម្មៈ ព្រះរាជាព្រះនាមសុធម្មៈ ជាព្រះបិតា ព្រះទេវីព្រះនាមសុធម្មា ជាព្រះមាតា អគ្គសាវក ២ រូប គឺអសមៈ ១ សុនេត្តៈ ១ ព្រះថេរៈឈ្មោះអនោមៈ ជាឧបដ្ឋាក អគ្គសាវិកា ២ រូប គឺនកុលា ១ សុជាតា ១ ដើមឪឹងជាឈើត្រាស់ដឹង ទ្រង់មានព្រះសរីរៈកម្ពស់ ៥៨ ហត្ថ ប្រមាណព្រះជន្មាយុ ៩ ម៉ឺនឆ្នាំ ។

កាលខាងក្រោយអំពីព្រះសម្ពុទ្ធ ព្រះនាមរេវតៈមក មាន
ព្រះលោកនាយក ព្រះនាមសោភិតៈ មានព្រះហឫទ័យតម្កល់
ខ្ជាប់ មានព្រះហឫទ័យស្ងប់ មិនមានបុគ្គលស្មើ មិនមាន
បុគ្គលប្រៀបផ្ទឹម ដូច្នេះ ។

ខាងក្រោយអំពីព្រះសម្ពុទ្ធ ព្រះនាមសោភិតៈនោះ កន្លងទៅបាន ១ អសង្ខេយ្យ ក្នុងកប្បតែមួយ មានព្រះពុទ្ធកើតឡើង ៣ អង្គ គឺព្រះពុទ្ធព្រះនាមអនោមទស្សី ១ ព្រះពុទ្ធព្រះនាមបទុម ១ ព្រះពុទ្ធព្រះនាមនារទៈ ១ ។

ព្រះមានព្រះភាគព្រះនាមអនោមទស្សី មានសាវកសន្និបាត ៣ ដង លើកទី ១ មានភិក្ខុ ៨ សែន លើកទី ២ មានភិក្ខុ ៧ សែន លើកទី ៣ មានភិក្ខុ ៦ សែន ។

កាលនោះ ព្រះពោធិសត្វកើតជាយក្ខសេនាបតី ជាអ្នកមានឫទ្ធិច្រើន មានអានុភាពច្រើន ជាធំជាងយក្ខច្រើនសែនកោដិ ។ ព្រះពោធិសត្វនោះបានដំណឹងថា ព្រះពុទ្ធកើតឡើងហើយ ទើបមកថ្វាយមហាទានដល់ភិក្ខុសង្ឃ មាន

ព្រះពុទ្ធជាប្រធាន ព្រះសាស្តាអង្គនោះទ្រង់ក៏ព្យាករព្រះពោធិសត្វនោះថា នឹងបានត្រាស់ជាព្រះពុទ្ធ ក្នុងអនាគតកាល ។

ព្រះមានព្រះភាគព្រះនាមអនោមទស្សី មាននគរឈ្មោះចន្ទវតី ព្រះរាជាព្រះនាមយសវា ជាព្រះបិតា ព្រះទេវីព្រះនាមយសោធរា ជាព្រះមាតា អគ្គសាវក ២ រូប គឺនិសភៈ ១ អនោមៈ ១ ភិក្ខុឈ្មោះវរុណ ជាឧបដ្ឋាក អគ្គសាវិកា ២ រូប គឺ សុន្ទរី(១) ១ សុមនា ១ ដើមអជ្ជុនព្រឹក្ស ( ដើមអង្គ្រង ) គឺជាឈើត្រាស់ដឹង មានព្រះសរីរៈកម្ពស់ ៥៨ ហត្ថ មានព្រះជន្មាយុប្រមាណ ១ សែនឆ្នាំ ។

កាលជាខាងក្រោយ អំពីព្រះសោភិតសម្ពុទ្ធមក មានព្រះ
សម្ពុទ្ធ ព្រះនាមអនោមទស្សី ព្រះអង្គប្រសើរជាងសត្វ
ទ្វេបាទ ទ្រង់មានយសរាប់មិនបាន ទ្រង់មានតេជះ ទ្រង់កម្រ
បុគ្គលកន្លងបាន ដូច្នេះ ។

ខាងក្រោយអំពីព្រះពុទ្ធព្រះនាមអនោមទស្សី ព្រះសាស្តាព្រះនាមបទុមទ្រង់កើតឡើង ព្រះសាស្តាអង្គនេះ ក៏មានសាវកសន្និបាត ៣ ដង សន្និបាតដំបូងមានភិក្ខុ ១ សែនកោដិ លើកទី ២ មានភិក្ខុ ៣ សែន លើកទី ៣ មានភិក្ខុ ២ សែន ក្នុងព្រៃធំ ឈ្មោះមហាវ័ន ជាព្រៃមិនមានស្រុក ។

គ្រានោះ កាលព្រះតថាគតគង់នៅក្នុងដងព្រៃនោះឯង ព្រះពោធិសត្វកើតជារាជសីហ៍ ឃើញព្រះសាស្តា ទ្រង់ចូលនិរោធសមាបត្តិ មានចិត្តជ្រះថ្លា

---

១- បិដកខ្មែរលេខ ៧៧ ជាសុន្ទរា ។

ថ្វាយបង្គំហើយធ្វើប្រទក្សិណ កើតនូវបីតិសោមនស្ស បន្លឺសីហនាទ ៣ ដង មិនលះបីតិដែលមានព្រះពុទ្ធជាអារម្មណ៍អស់ ៧ ថ្ងៃ ព្រោះសុខដែលកើតអំពីបីតិនោះឯង ទើបមិនចេញទៅរកស៊ី បរិច្ចាគជីវិត ឈរគាល់ព្រះមានព្រះភាគ លុះកន្លងទៅ ៧ ថ្ងៃ ព្រះសាស្ដាទ្រង់ចេញអំពីនិរោធ ទតឃើញរាជសីហ៍ ទ្រង់ព្រះតម្រិះថា សត្វនេះ ញុំាងចិត្តឲ្យជ្រះថ្លាក្នុងភិក្ខុសង្ឃ បានថ្វាយបង្គំភិក្ខុសង្ឃ ទើបទ្រង់ព្រះតម្រិះថា ចូរភិក្ខុសង្ឃមកចុះ ។ វេលានោះឯង ភិក្ខុទាំងឡាយក៏មក ឯរាជសីហ៍ក៏ធ្វើចិត្តឲ្យជ្រះថ្លាក្នុងភិក្ខុសង្ឃ ។ ព្រះសាស្ដាទ្រង់ប្រមើលមើលចិត្តរបស់រាជសីហ៍នោះ ទ្រង់ព្យាករថា រាជសីហ៍នេះ នឹងបានជាព្រះពុទ្ធក្នុងអនាគតកាល ។ ព្រះមានព្រះភាគបទុម មាននគរឈ្មោះចម្បកៈ ព្រះរាជាព្រះនាមអសមៈ ជាព្រះបិតា ព្រះទេវីព្រះនាមអសមា ជាព្រះមាតា អគ្គសាវក ២ រូប គឺសាលៈ ១ ឧបសាលៈ ១ ភិក្ខុឈ្មោះវរុណៈ ជាឧបដ្ឋាក អគ្គសាវិកា ២ រូប គឺរាមា ១ សុរាមា[១] ១ ដើមឈើត្រាស់ដឹង ឈ្មោះសោណព្រឹក្ស ( ដើមម្រុម ) ព្រះសរីរៈកម្ពស់ ៥៨ ហត្ថ មានព្រះជន្មាយុ ១ សែនឆ្នាំ ។

ក្នុងកាលខាងក្រោយ អំពីព្រះសម្ពុទ្ធព្រះនាមអនោមទស្សីមក
មានព្រះសម្ពុទ្ធព្រះនាមបទុមៈ ទ្រង់ឧត្ដមជាងសត្វជើងពីរ ឥត
មានបុគ្គលស្មើ ឥតមានបុគ្គលប្រៀបផ្ទឹម ដូច្នេះ ។

ខាងក្រោយអំពីព្រះពុទ្ធព្រះនាមបទុមនោះ ព្រះសាស្ដាព្រះនាមនារទៈ

---

១- បិដកខ្មែរលេខ ៧៧ ជារាធា និងសុរាធា ។

ទ្រង់កើតឡើង សូម្បីព្រះអង្គក៏មានសាវកសន្និបាត ៣ ដង សន្និបាតលើកទី ១ មានភិក្ខុ ១ សែនកោដិ លើកទីពីរ ៩ ម៉ឺនកោដិ លើកទីបី ៨ ម៉ឺនកោដិ[១] ។

កាលនោះ ព្រះពោធិសត្វបួសជាឥសី ជាអ្នកជំនាញក្នុងអភិញ្ញា ៥ និងសមាបត្តិ ៨ បានថ្វាយមហាទានដល់ភិក្ខុសង្ឃ មានព្រះពុទ្ធជាប្រធាន ហើយធ្វើនូវការបូជាដោយចន្ទន៍ក្រហម ។ ព្រះសាស្តាអង្គនោះ ទ្រង់ព្យាករព្រះពោធិសត្វនោះថា នឹងបានត្រាស់ជាព្រះពុទ្ធ ក្នុងអនាគតកាល ។

ព្រះមានព្រះភាគអង្គនោះ មាននគរឈ្មោះធញ្ញវតី មានក្សត្រព្រះនាមសុទេវៈ ជាព្រះបិតា មានព្រះទេវីព្រះនាមអនោមា ជាព្រះមាតា អគ្គសាវក ២ រូប គឺកុទ្ទសាលៈ ១ ជិតមិត្តៈ ១ ភិក្ខុឈ្មោះវាសេដ្ឋៈ ជាឧបដ្ឋាក អគ្គសាវិកា ២ រូប គឺឧត្តរា ១ ផគ្គុនី ១ ដើមឈើត្រាស់ដឹងឈ្មោះមហាសោណព្រឹក្ស ( ដើមម្រុម ) មានព្រះសរីរៈកម្ពស់ ៨៨ ហត្ថ មានព្រះជន្មាយុ ៩ ម៉ឺនឆ្នាំ ។

ក្នុងកាលជាខាងក្រោយ នៃព្រះពុទ្ធព្រះនាមបទុមមក មាន
ព្រះសម្ពុទ្ធព្រះនាមនារទៈ ទ្រង់ឧត្តមជាងសត្វជើងពីរ ឥត
មានបុគ្គលស្មើ ឥតមានបុគ្គលប្រៀបផ្ទឹម ដូច្នេះ ។

ខាងក្រោយអំពីព្រះពុទ្ធព្រះនាមនារទៈមក ក្នុងទីបំផុត ១ សែនកប្បរាប់អំពីភទ្ទកប្បនេះ ក្នុងកប្បមួយ មានព្រះពុទ្ធតែ ១ អង្គ ព្រះនាមបទុមៈ

---

១- បិដកខ្មែរលេខ ៧៧ ជា ៨០ សែន ។

ទ្រង់កើតឡើង ។ ទ្រង់មានសាវកសន្និបាត ៣ ដង សន្និបាតលើកទី ១ មានភិក្ខុ ១ សែនកោដិ លើកទី ២ ត្រង់វេភារបព៌ត មានភិក្ខុ ៩ ម៉ឺនកោដិ លើកទី ៣ មានភិក្ខុ ៨ ម៉ឺនកោដិ ។

កាលនោះ ព្រះពោធិសត្វឈ្មោះជដិល ជាអ្នកគ្រប់គ្រងដែនធំ បានថ្វាយទាន មួយអន្លើដោយចីវរដល់ភិក្ខុសង្ឃ មានព្រះពុទ្ធជាប្រធាន ។ ព្រះសាស្តាអង្គនោះ ទ្រង់ក៏ព្យាករព្រះពោធិសត្វនោះថា នឹងបានត្រាស់ជាព្រះពុទ្ធក្នុងអនាគតកាល ។ ក្នុងសាសនាព្រះមានព្រះភាគបទុមុត្តរៈ មិនមានពួកតិរ្ថិយឡើយ ទេវតា និងមនុស្សទាំងពួងដល់នូវព្រះពុទ្ធប៉ុណ្ណោះជាសរណៈ ។

ព្រះអង្គមាននគរឈ្មោះហង្សវតី ព្រះរាជាព្រះនាមអានន្ទ ជាព្រះបិតា ព្រះទេវីព្រះនាមសុជាតា ជាព្រះមាតា អគ្គសាវក ២ រូប គឺទេវលៈ ១ សុជាតៈ ១ ភិក្ខុឈ្មោះសុមនៈ ជាឧបដ្ឋាក អគ្គសាវិកា ២ រូប គឺអមិតា ១ អសមា ១ មានសាលព្រឹក្ស ( ដើមរាំងភ្នំ )[១] ជាឈើត្រាស់ដឹង មានព្រះសរីរៈកម្ពស់ ៥៨ ហត្ថ មានព្រះរស្មីផ្សាយចេញអំពីព្រះសរីរៈ ១២ យោជន៍ដោយជុំវិញ មានព្រះជន្មាយុ ១ សែនឆ្នាំ ។

> ក្នុងកាលខាងក្រោយ អំពីព្រះពុទ្ធព្រះនាមនារទៈមក មានព្រះសម្ពុទ្ធព្រះនាមបទុមុត្តរៈ ទ្រង់ឧត្តមជាងសត្វជើងពីរ ទ្រង់ឈ្នះមារ ទ្រង់មិនរំភើប ឧបមាដូចសាគរ ដូច្នេះ ។

ខាងក្រោយអំពីព្រះពុទ្ធ ព្រះនាមបទុមុត្តរៈនោះ កន្លងទៅបាន ៣

---

១- បិដកខ្មែរលេខ ៧៧ ជាដើមស្រល់ ។

ម៉ឺនកប្ប ក្នុងកប្ប ១ មានព្រះពុទ្ធ ២ អង្គ គឺព្រះសុមេធ និងព្រះសុជាត បានកើតឡើងហើយ ។

ព្រះសុមេធសម្ពុទ្ធក៏មានសាវកសន្និបាត ៣ ដង សន្និបាតលើកទី ១ ក្នុងសុទស្សននគរ មានព្រះខីណាស្រព ១០០ កោដិ លើកទីពីរ ៩០ កោដិ លើកទីបី ៨០ កោដិ ។

កាលនោះ ព្រះពោធិសត្វជាមាណពឈ្មោះឧត្តរៈ លះទ្រព្យសម្បត្តិ ៨០ កោដិ ដែលកប់ទុករហូតមក ថ្វាយមហាទានដល់ភិក្ខុសង្ឃ មានព្រះពុទ្ធជាប្រធាន ស្តាប់ធម៌ហើយ តាំងនៅក្នុងសរណៈ ៣ ហើយចេញបួស ។ ព្រះសាស្តាអង្គនោះ ទ្រង់ព្យាករព្រះពោធិសត្វនោះថា នឹងបានត្រាស់ជាព្រះពុទ្ធ ក្នុងអនាគតកាល ។

ព្រះមានព្រះភាគព្រះនាមសុមេធ មាននគរឈ្មោះសុទស្សនៈ ព្រះរាជាព្រះនាមសុទត្តៈ ជាព្រះបិតា ព្រះទេវីព្រះនាមសុទត្តា ជាព្រះមាតា អគ្គសាវក ២ រូប គឺសរណៈ ១ សព្វកាមៈ ១ ភិក្ខុឈ្មោះសាគរ ជាឧបដ្ឋាក អគ្គសាវិកា ២ រូប គឺរាមា ១ សុរាមា ១ ដើមស្តៅជាឈើត្រាស់ដឹង មានព្រះសរីរៈកម្ពស់ ៨៨ ហត្ថ មានព្រះជន្មាយុ ៩ ម៉ឺនឆ្នាំ ។

ក្នុងកាលជាខាងក្រោយ អំពីព្រះសម្ពុទ្ធព្រះនាមបទុមុត្តរៈ មក
មានព្រះពុទ្ធព្រះនាមសុមេធៈ ព្រះអង្គជានាយក គេគ្រប
សង្កត់បានដោយក្រ ទ្រង់មានព្រះតេជះដ៏ខ្ពង់ខ្ពស់ ជាព្រះ
ជិនស្រីដ៏ប្រសើរ ឧត្តមជាងលោកទាំងមូល ដូច្នេះ ។

ខាងក្រោយអំពីព្រះពុទ្ធព្រះនាមសុមេធៈ ព្រះសាស្តាសុជាតៈ បានកើតឡើង ។ ព្រះសាស្តាអង្គនេះ ក៏មានសាវកសន្និបាត ៣ ដង សន្និបាតលើកទី ១ មានភិក្ខុ ៦ លាន លើកទីពីរ ៥ លាន លើកទីបី ៤ លាន ។

កាលនោះ ព្រះពោធិសត្វជាស្តេចចក្រពត្តិ បានដំណឹងថា ព្រះពុទ្ធកើតឡើងហើយ ក៏ចូលទៅគាល់ ស្តាប់ធម៌ហើយ ថ្វាយរាជសម្បត្តិក្នុងមហាទ្វីបទាំង ៤ មួយអន្លើដោយរតនៈទាំង ៧ ដល់ភិក្ខុសង្ឃ មានព្រះពុទ្ធជាប្រធាន ហើយបួសក្នុងសម្នាក់របស់ព្រះសាស្តា ។ អ្នកនគរទាំងអស់ កាន់យកសួយដែលកើតក្នុងនគរទៅទំនុកបម្រុងកិច្ចក្នុងអារាម ហើយបានថ្វាយមហាទានដល់ភិក្ខុសង្ឃ មានព្រះពុទ្ធជាប្រធានអស់កាលជានិច្ច ។ ព្រះសាស្តាអង្គនោះទ្រង់ព្យាករព្រះពោធិសត្វថា នឹងបានត្រាស់ជាព្រះពុទ្ធ ក្នុងអនាគតកាល ។

ព្រះមានព្រះភាគអង្គនោះ មាននគរឈ្មោះសុមង្គលៈ ព្រះរាជាព្រះនាមឧគ្គតៈ ជាព្រះបិតា ព្រះទេវីព្រះនាមបភាវតី ជាព្រះមាតា អគ្គសាវក ២ រូប គឺសុទស្សនៈ ១ សុទេវៈ ១ ភិក្ខុឈ្មោះនារទៈ ជាឧបដ្ឋាក អគ្គសាវិកា ២ រូប គឺនាគា ១ នាគសមាលា ១[១] មានដើមមហាវេឡុ ( ដើមឫស្សីធំ ) ជាឈើត្រាស់ដឹង បានឮថា មហាវេឡុនោះ មានប្រហោងខាងក្នុងតូច មានសាច់ក្រាស់ មានដៃ និងស្លឹកធំៗ ផ្សាយឡើងទៅខាងលើ មើលទៅហាក់ដូចសំណុំនៃកន្ទុយក្ងោក ។ ព្រះមានព្រះភាគអង្គនោះ មានព្រះសរីរៈកម្ពស់ ៥០ ហត្ថ មានព្រះជន្មាយុ ៩ ម៉ឺនឆ្នាំ ។

---

១- បិដកខ្មែរលេខ ៧៧ ជានាគសមានា ។

ក្នុងមណ្ឌកប្បនោះឯង មានព្រះសម្មាសម្ពុទ្ធជានាយក ព្រះនាមសុជាតៈ ទ្រង់មានព្រះហនុកា ដូចជាចង្កានៃរាជសីហ៍ ទ្រង់មានព្រះសូរង ដូចជាកនៃគោឧសភៈ ទ្រង់មានព្រះគុណប្រមាណមិនបាន គេគ្របសង្កត់មិនបាន ដូច្នេះ ។

ខាងក្រោយអំពីព្រះពុទ្ធព្រះនាមសុជាតៈ រាប់ពីកប្បនេះថយក្រោយទៅ ១៨០០ កប្ប ក្នុងកប្បតែមួយនោះ មានព្រះពុទ្ធកើតឡើង ៣ អង្គ គឺព្រះពុទ្ធព្រះនាមបិយទស្សី ១ អត្ថទស្សី ១ និងធម្មទស្សី ១ ។ ព្រះមានព្រះភាគបិយទស្សី មានសាវកសន្និបាត ៣ ដង លើកទី ១ មានភិក្ខុ ១ សែនកោដិ លើកទី ២ មានភិក្ខុ ៩០ កោដិ លើកទី ៣ មានភិក្ខុ ៨០ កោដិ ។

កាលនោះ ព្រះពោធិសត្វជាមាណពឈ្មោះកស្សបៈ ជាអ្នករៀនចប់ត្រៃវេទ បានស្តាប់ព្រះធម្មទេសនារបស់ព្រះសាស្តាហើយ ទើបឲ្យសាងសង្ឃារាម ដោយបរិច្ចាគទ្រព្យ ១ សែនកោដិ តាំងនៅក្នុងសរណៈ និងសីល ។ លំដាប់នោះ ព្រះសាស្តាទ្រង់ព្យាករព្រះពោធិសត្វនោះថា កន្លងទៅ ១៨០០ កប្ប កុលបុត្រនេះ នឹងបានត្រាស់ជាព្រះពុទ្ធ ។ ព្រះមានព្រះភាគអង្គនោះ មាននគរឈ្មោះអនោមៈ ព្រះរាជាព្រះនាមសុទិន្ន ជាព្រះបិតា ព្រះទេវីព្រះនាមចន្ទា[១] ជាព្រះមាតា អគ្គសាវក ២ រូប គឺបាលិតៈ ១ សព្វទស្សី ១ ភិក្ខុឈ្មោះសោភិតៈ ជាឧបដ្ឋាក អគ្គសាវិកា ២ រូប គឺសុជាតា ១

---

១- បិដកខ្មែរលេខ ៧៧ នគរជាសុធញ្ញៈ ព្រះបិតាជាសុទត្តៈ ព្រះមាតាជាសុចន្ទា ។

ធម្មទិន្នា ១ មានដើមថ្នាន់ជាឈើត្រាស់ដឹង មានព្រះសរីរៈកម្ពស់ ៨០ ហត្ថ មានព្រះជន្មាយុ ៩ ម៉ឺនឆ្នាំ ។

ក្នុងកាលជាខាងក្រោយ នៃព្រះសម្ពុទ្ធព្រះនាមសុជាតៈមក
មានព្រះពុទ្ធទ្រង់ព្រះនាមបិយទស្សី ជាសយម្ភូ ជាលោក-
នាយក ទ្រង់មានយសច្រើន គេគ្របសង្កត់បានដោយក្រ
ព្រះអង្គស្មើដោយព្រះពុទ្ធ ដែលឥតមានបុគ្គលស្មើ ដូច្នេះ ។

ខាងក្រោយអំពីព្រះពុទ្ធព្រះនាមបិយទស្សីនោះ ព្រះមានព្រះភាគព្រះនាមអត្ថទស្សីកើតឡើង ទ្រង់មានសាវកសន្និបាត ៣ ដង លើកទី ១ មានភិក្ខុ ៩ លាន ៨ សែន លើកទីពីរ ៨ លាន ៨ សែន លើកទី ៣ មានភិក្ខុចំនួនប៉ុណ្ណោះដូចគ្នា[1] ។

កាលនោះ ព្រះពោធិសត្វជាតាបសមានឫទ្ធិច្រើន ឈ្មោះសុសីមៈ នាំយកឆត្រដែលធ្វើដោយផ្កាមន្ទារវៈមកអំពីទេវលោក ហើយបូជាព្រះសាស្តា ព្រះសាស្តាក៏ទ្រង់ព្យាករព្រះពោធិសត្វនោះថា នឹងបានត្រាស់ជាព្រះពុទ្ធ ក្នុងអនាគតកាល ។

ព្រះមានព្រះភាគអង្គនោះ មាននគរឈ្មោះសោភណៈ ព្រះរាជាព្រះនាមសាគរ ជាព្រះបិតា ព្រះទេវីព្រះនាមសុទស្សនា ជាព្រះមាតា អគ្គសាវក ២ រូប គឺសន្តៈ ១ ឧបសន្តៈ ១ ភិក្ខុឈ្មោះអភយៈ ជាឧបដ្ឋាក អគ្គសាវិកា

---

១- បិដកខ្មែរលេខ ៧៧ សន្និបាតលើកទីមួយជា ៩៨ ពាន់ លើកទីពីរ ៨៨ ពាន់ លើកទីបី ៧៨ ពាន់ ។

២ រូប គឺធម្មា ១ សុធម្មា ១ ដើមចម្ប៉ាជាឈើត្រាស់ដឹង មានព្រះសរីរៈកម្ពស់ ៨០ ហត្ថ មានរស្មីផ្សាយចេញអំពីព្រះសរីរៈទៅ ប្រមាណ ១ យោជន៍ ដោយជុំវិញសព្វកាល មានព្រះជន្មាយុ ១ សែនឆ្នាំ ។

ក្នុងមណ្ឌកប្បនោះឯង មានព្រះពុទ្ធព្រះនាមអត្ថទស្សី មាន
យសធំ ទ្រង់កម្ចាត់បង់ងងឹតធំ សម្រេចសម្ពោធិញ្ញាណ
ដ៏ឧត្តម ដូច្នេះ ។

ខាងក្រោយអំពីព្រះពុទ្ធ ព្រះនាមអត្ថទស្សីនោះ ព្រះសាស្តាព្រះនាមធម្មទស្សី ទ្រង់កើតឡើង ទ្រង់មានសាវកសន្និបាត ៣ ដង លើកទីមួយមានភិក្ខុ ១០០ កោដិ លើកទីពីរ ៩០ កោដិ[១] លើកទីបី ៨០ កោដិ ។

ក្នុងកាលនោះ ព្រះពោធិសត្វកើតជាសក្កទេវរាជ បានធ្វើនូវការបូជាដោយផ្កា និងគ្រឿងក្រអូបដែលជាទិព្វ និងតន្ត្រីទិព្វ ។ ព្រះសាស្តាអង្គនោះទ្រង់ក៏ព្យាករព្រះពោធិសត្វនោះថា នឹងបានត្រាស់ជាព្រះពុទ្ធក្នុងអនាគតកាល ។

ព្រះមានព្រះភាគអង្គនោះ មាននគរឈ្មោះសរណៈ ព្រះរាជាព្រះនាមសរណៈ ជាព្រះបិតា ព្រះទេវីព្រះនាមសុនន្ទា ជាព្រះមាតា អគ្គសាវក ២ រូប គឺបទុមៈ ១ ផុស្សទេវៈ ១[២] ភិក្ខុឈ្មោះសុនេត្ត ជាឧបដ្ឋាក អគ្គសាវិកា ២ រូប គឺខេមា ១ សព្វនាមា ១[៣] រត្តង្កុរព្រឹក្ស ឬពិម្ពិជាលព្រឹក្ស[៤]

---

១- បិដកខ្មែរលេខ ៧៧ សាវកសន្និបាតលើកទីមួយមានភិក្ខុ ១០០០ កោដិ លើកទីពីរ ១០០ កោដិ ។ ២- បិដកខ្មែរលេខ ៧៧ ជាបុស្សទេវៈ ។ ៣- បិដកខ្មែរលេខ៧៧ ជាសច្ចនាមា ។ ៤- បិដកខ្មែរលេខ ៧៧ ជាតិម្ពជាលព្រឹក្ស ។

ជាឈើត្រាស់ដឹង មានព្រះសរីរៈ កម្ពស់ ៨០ ហត្ថ មានព្រះជន្មាយុ ១ សែនឆ្នាំ ។

ក្នុងមណ្ឌកប្បនោះឯង មានព្រះពុទ្ធព្រះនាមធម្មទស្សី មាន
យសធំ ទ្រង់កម្ចាត់បង់ងងឹតអន្ធការ ហើយញ៉ាំងមនុស្ស-
លោក ព្រមទាំងទេវលោក ឲ្យរុងរឿង ដូច្នេះ ។

ខាងក្រោយអំពីព្រះពុទ្ធព្រះនាមធម្មទស្សីនោះ ក្នុងទីបំផុត ៩៤ កប្ប បន្ទាប់អំពីកទ្ទកប្បនេះ ក្នុងកប្បមួយ មានព្រះសម្មាសម្ពុទ្ធព្រះនាមសិទ្ធត្ថៈ ១ អង្គប៉ុណ្ណោះ ទ្រង់កើតឡើង ទ្រង់មានសាវកសន្និបាត ៣ ដង សន្និបាតលើកទីមួយ មានភិក្ខុ ១០០ កោដិ លើកទីពីរ ៩០ កោដិ លើកទីបី ៨០ កោដិ ។ ក្នុងកាលនោះ ព្រះពោធិសត្វជាតាបសឈ្មោះមង្គលៈ មានតេជះខ្លាំងក្លា សម្បូរដោយអភិញ្ញាពល នាំយកផ្លែព្រីង ធំមក ថ្វាយព្រះទសពល ព្រះសាស្ដាទ្រង់សោយផ្លែព្រីងនោះហើយ ទ្រង់ព្យាករថា ក្នុងទីបំផុតនៃកប្បទី ៩៤ តាបសនេះ នឹងបានត្រាស់ជាព្រះពុទ្ធ ក្នុងអនាគតកាល ។

ព្រះមានព្រះភាគអង្គនោះ មាននគរឈ្មោះវេភារៈ ព្រះរាជាព្រះនាមជយសេន[១] ជាព្រះបិតា ព្រះទេវីព្រះនាមសុផស្សា ជាព្រះមាតា អគ្គសាវក ២ រូប គឺសម្ពលៈ ១ សុមិត្តៈ ១ ព្រះថេរៈឈ្មោះរេវតៈ ជាឧបដ្ឋាក អគ្គ-សាវិកា ២ រូប គឺសីវលា ១ សុរាមា ១ ដើមកណិការជាឈើត្រាស់ដឹង មានព្រះសរីរៈកម្ពស់ ៦០ ហត្ថ មានព្រះជន្មាយុ ១ សែនឆ្នាំ ។

---

១- បិដកខ្មែរលេខ ៧៧ ជាឧទេនៈ ។

ក្រោយអំពីព្រះធម្មទស្សីមក មានព្រះលោកនាយក ព្រះនាម សិទ្ធត្ថៈ ទ្រង់កម្ចាត់បង់ងងឹតទាំងអស់ បីដូចព្រះអាទិត្យរះឡើង ដូច្នេះ ។

បន្ទប់អំពីព្រះសិទ្ធត្ថសម្ពុទ្ធនោះ ក្នុងទីបំផុតនៃកប្បទី ៩២ រាប់ ថយអំពីភទ្ទកប្បនេះ មានព្រះពុទ្ធ ២ ព្រះអង្គកើតឡើងក្នុងកប្បតែមួយ គឺព្រះសម្ពុទ្ធព្រះនាមតិស្សៈ និងព្រះពុទ្ធព្រះនាមផុស្សៈ ។ ព្រះមានព្រះភាគតិស្សៈ មានសាវកសន្និបាត ៣ ដង សន្និបាតលើកទីមួយ មានភិក្ខុ ១០០ កោដិ លើកទីពីរ ៩០ កោដិ លើកទីបី ៨០ កោដិ[១] ។

កាលនោះ ព្រះពោធិសត្វជាក្សត្រព្រះនាមសុជាត មានភោគសម្បត្តិច្រើន មានយសធំ បួសជាឥសី ដល់នូវភាពជាអ្នកមានឫទ្ធិច្រើន បានដំណឹងថា ព្រះពុទ្ធកើតឡើងហើយ ទើបកាន់យកផ្កាមន្ទារវៈ ផ្កាបទុម និងផ្កាបារិច្ឆត្តកៈដែលជាទិព្វ ទៅបូជាព្រះតថាគតដែលយាងទៅក្នុងកណ្ដាលបរិស័ទ ៤ បានធ្វើពិតានផ្កាក្នុងអាកាស ។ ព្រះសាស្ដាអង្គនោះ ទ្រង់ព្យាករព្រះពោធិសត្វនោះថា ក្នុងទីបំផុតនៃកប្បទី ៩២ បន្ទាប់អំពីកប្បនេះទៅ នឹងបានត្រាស់ជាព្រះពុទ្ធ ។

ព្រះមានព្រះភាគអង្គនោះ មាននគរឈ្មោះខេមៈ ព្រះរាជាព្រះនាមជនសន្ធៈ[២] ជាព្រះបិតា ព្រះទេវីព្រះនាមបទុមា ជាព្រះមាតា អគ្គសាវក ២

---

១- បិដកខ្មែរលេខ ៧៧ សាវកសន្និបាតលើកទីមួយ ១ សែន លើកទីពីរ ៩០ សែន លើកទីបី ៨០ សែន ។ ២- បិដកខ្មែរលេខ ៧៧ ជាជនសន្ធៈ ។

រូប គឺព្រហ្មទេវៈ ១ ឧទយៈ ១ ព្រះថេរៈឈ្មោះសុមនៈ[១] ជាឧបដ្ឋាក អគ្គសាវិកា ២ រូប គឺផុស្សា ១ សុទត្តា ១ ដើមធ្នង់ជាឈើត្រាស់ដឹង មានព្រះសរីរៈកម្ពស់ ៦០ ហត្ថ មានព្រះជន្មាយុ ១ សែនឆ្នាំ ។

ក្រោយពីព្រះពុទ្ធព្រះនាមសិទ្ធត្ថៈមក មានព្រះពុទ្ធព្រះនាម
តិស្សៈ ជានាយកដ៏ប្រសើរក្នុងលោក ទ្រង់មិនមានបុគ្គលស្មើ
មិនមានបុគ្គលប្រៀបផ្ទឹមបាន មានសីលរកទីបំផុតគ្មាន មាន
យសរាប់ពុំបាន ទ្រង់មានសេចក្ដីអាណិតអាសូរ មានព្យាយាម
ធំ មានចក្ខុ ទ្រង់កើតឡើងក្នុងលោក កម្ចាត់បង់ងងឹតអន្ធការ
ញុំាងលោកនេះ ព្រមទាំងទេវលោកឲ្យភ្លឺស្វាងហើយ ដូច្នេះ ។

បន្ទាប់អំពីព្រះពុទ្ធព្រះនាមតិស្សៈនោះទៅ ព្រះសាស្ដាព្រះនាមផុស្សៈ បានកើតឡើងហើយ ។ ទ្រង់មានសាវកសន្និបាត ៣ ដង សន្និបាតលើកទីមួយ មានភិក្ខុ ៦ លាន លើកទីពីរ ៥ លាន លើកទីបី ៣ លាន ២ សែន[២] ។

កាលនោះ ព្រះពោធិសត្វជាព្រះរាជាឈ្មោះវិជិតាវី ទ្រង់លះបង់រាជសម្បត្តិធំ បួសក្នុងសម្នាក់ព្រះសាស្ដា រៀនព្រះត្រៃបិដកហើយ សម្ដែងធម្មកថាដល់មហាជន និងបំពេញសីលបារមី ។ ព្រះសាស្ដាអង្គនោះ ទ្រង់ព្យាករព្រះពោធិសត្វថា នឹងបានត្រាស់ជាព្រះពុទ្ធ ។

ព្រះមានព្រះភាគអង្គនោះ មាននគរឈ្មោះកាសី ព្រះរាជាព្រះនាម

---

១- បិដកខ្មែរលេខ ៧៧ ជាសមតៈ ។ ២- បិដកខ្មែរលេខ ៧៧ ជា ៤០ សែន ។

ជយសេន ជាព្រះបិតា ព្រះទេវីព្រះនាមសិរិមា ជាព្រះមាតា អគ្គសាវក ២ រូប គឺសុរក្ខិតៈ ១ ធម្មសេនៈ ១ ភិក្ខុឈ្មោះសភិយៈ ជាឧបដ្ឋាក អគ្គសាវិកា ២ រូប គឺចាលា ១ ឧបចាលា ១ មានដើមកន្ទួតព្រៃជាឈើត្រាស់ដឹង មានព្រះសរីរៈកម្ពស់ ៥៨ ហត្ថ មានព្រះជន្មាយុ ៩ ម៉ឺនឆ្នាំ ។

ក្នុងមណ្ឌកប្បនោះឯង មានព្រះសាស្តាព្រះនាមបុស្សៈ ទ្រង់
មិនមានបុគ្គលក្រៃលែងជាង មិនមានបុគ្គលប្រៀបផ្ទឹមបាន
ស្មើដោយព្រះពុទ្ធ ដែលមិនមានបុគ្គលស្មើ ជានាយក
ប្រសើរក្នុងលោក ដូច្នេះ ។

បន្ទាប់អំពីព្រះពុទ្ធព្រះនាមផុស្សៈអង្គនោះ ក្នុងកប្បទី ៩១ រាប់ថយអំពីភទ្ទកប្បនេះ ព្រះមានព្រះភាគព្រះនាមវិបស្សី ទ្រង់កើតឡើង ។ ទ្រង់មានសាវកសន្និបាត ៣ លើក សន្និបាតលើកទីមួយ មានភិក្ខុ ៦ លាន ៨ សែន លើកទីពីរ ១ សែន លើកទីបី ៨ ម៉ឺន ។

កាលនោះ ព្រះពោធិសត្វជាស្តេចនាគឈ្មោះអតុល មានឫទ្ធិច្រើន មានអានុភាពច្រើន បានថ្វាយតាំងធំដែលធ្វើដោយមាស រំលេចដោយកែវ ៧ ប្រការដល់ព្រះមានព្រះភាគ ។ ព្រះមានព្រះភាគទ្រង់ព្យាករព្រះពោធិសត្វថា ក្នុងកប្បទី ៩១ អំពីកប្បនេះទៅ ស្តេចនាគនឹងបានត្រាស់ជាព្រះពុទ្ធ ។

ព្រះមានព្រះភាគអង្គនោះ មាននគរឈ្មោះពន្ធុមតី ព្រះរាជាព្រះនាមពន្ធុមៈ ជាព្រះបិតា ព្រះទេវីព្រះនាមពន្ធុមតី ជាព្រះមាតា អគ្គសាវក ២ រូប

គឺខណ្ឌៈ[១] ១ តិស្សៈ ១ ភិក្ខុឈ្មោះអសោក ជាឧបដ្ឋាក អគ្គសាវិកា ២ រូប គឺចន្ទា ១ ចន្ទមិត្តា ១ មានដើមប្រទៀងជាឈើត្រាស់ដឹង មានព្រះសរីរៈ កម្ពស់ ៨០ ហត្ថ រស្មីផ្សាយចេញអំពីព្រះកាយ ៧ យោជន៍ សព្វៗ កាល មានព្រះជន្មាយុ ៨ ម៉ឺនឆ្នាំ ។

ក្រោយអំពីព្រះពុទ្ធព្រះនាមបុស្សៈមក មានព្រះសម្ពុទ្ធព្រះនាម
វិបស្សី ដ៏ឧត្តមជាងសត្វជើងពីរ ទ្រង់មានចក្ខុ កើតឡើងក្នុង
លោក ដូច្នេះ ។

បន្ទាប់អំពីព្រះពុទ្ធព្រះនាមវិបស្សីអង្គនោះ ក្នុងកប្បទី ៣១ រាប់អំពី ភទ្ទកប្បនេះទៅ មានព្រះពុទ្ធ ២ អង្គ គឺព្រះសិខី និងព្រះវេស្សភូ ។ ព្រះ សិខីសម្ពុទ្ធនោះ មានសាវកសន្និបាត ៣ លើក សន្និបាតលើកទីមួយ មាន ភិក្ខុ ១ សែន លើកទីពីរ ៨ ម៉ឺន លើកទីបី ៧ ម៉ឺន ។

កាលនោះ ព្រះពោធិសត្វជាព្រះរាជាព្រះនាមអរិន្ទមៈ បានថ្វាយនូវ មហាទាន មួយអន្លើដោយចីវរដល់ភិក្ខុសង្ឃ មានព្រះពុទ្ធជាប្រធាន ហើយ ថ្វាយដំរីកែវ ដែលប្រដាប់ដោយកែវ ៧ ប្រការ ហើយបានថ្វាយកប្បិយភណ្ឌ ទំហំប៉ុនដំរី ព្រះសាស្តាអង្គនោះក៏ទ្រង់ព្យាករព្រះពោធិនោះថា ក្នុងកប្បទី ៣១ អំពីកប្បនេះទៅ ព្រះរាជាអង្គនេះ នឹងបានត្រាស់ជាព្រះពុទ្ធ ។

ព្រះមានព្រះភាគអង្គនោះ មាននគរឈ្មោះអរុណវតី ក្សត្រព្រះនាម អរុណ ជាព្រះបិតា ព្រះទេវីព្រះនាមបភាវតី ជាព្រះមាតា អគ្គសាវក ២ រូប

---

១- បិដកខ្មែរលេខ ៧៧ ជាខន្ធៈ ។

គឺអភិភូ ១ សម្ភវៈ ១ ភិក្ខុឈ្មោះខេមង្ករៈ ជាឧបដ្ឋាក អគ្គសាវិកា ២ រូប គឺសខិលា ១ បទុមា ១ មានដើមបុណ្ឌរីក ( ដើមស្វាយស ) ជាឈើត្រាស់ដឹង មានព្រះសរីរៈកម្ពស់ ៧០ ហត្ថ ព្រះរស្មីផ្សាយចេញអំពីព្រះសរីរៈអស់ ៣ យោជន៍ មានព្រះជន្មាយុ ៧ ម៉ឺនឆ្នាំ ។

ក្រោយព្រះពុទ្ធវិបស្សីមក មានព្រះសម្ពុទ្ធព្រះនាមសិខីជិនស្រី
ទ្រង់ឧត្តមជាងសត្វជើងពីរ ឥតមានបុគ្គលស្មើ ឥតមានបុគ្គល
ប្រៀបផ្ទឹមបាន ដូច្នេះ ។

ក្នុងកាលបន្ទាប់អំពីព្រះពុទ្ធព្រះនាមសិខីអង្គនោះ ព្រះសាស្តាព្រះនាមវេស្សភូ ទ្រង់កើតឡើង ។ ទ្រង់មានសាវកសន្និបាត ៣ លើក សន្និបាតលើកទីមួយ មានភិក្ខុ ៨ ម៉ឺន លើកទីពីរ ៧ ម៉ឺន លើកទីបី ៦ ម៉ឺន[១] ។

ក្នុងកាលនោះ ព្រះពោធិសត្វបានជាព្រះរាជា ព្រះនាមសុទស្សនៈ ថ្វាយមហាទាន មួយអន្លើដោយចីវរដល់ភិក្ខុសង្ឃ មានព្រះពុទ្ធជាប្រធាន ហើយបួសក្នុងសម្នាក់របស់ព្រះវេស្សភូនោះ សម្បូរដោយអាចារគុណ ច្រើនទៅដោយការកោតក្រែង និងបីតិក្នុងពុទ្ធរតនៈ ។ ព្រះមានព្រះភាគអង្គនោះ ទ្រង់ព្យាករពោធិសត្វនោះថា ក្នុងកប្បទី ៣១ បន្ទាប់អំពីនេះទៅ ព្រះរាជាអង្គនេះ នឹងបានត្រាស់ជាព្រះពុទ្ធ ។

---

១- បិដកខ្មែរលេខ ៧៧ សន្និបាតលើកទីមួយ ៨០ ពាន់កោដិ លើកទីពីរ ៧០ ពាន់កោដិ លើកទីបី ៦០ ពាន់កោដិ តែបាលីសន្និបាតលើកទីពីរ និងសន្និបាតលើកទីបីមិនមានកោដិទេ ។

ព្រះសាស្តាអង្គនោះ មាននគរឈ្មោះអនោមៈ ព្រះរាជាព្រះនាមសុប្បតីតៈ ជាព្រះបិតា ព្រះទេវីព្រះនាមយសវតី ជាព្រះមាតា អគ្គសាវក ២ រូប គឺសោណៈ ១ ឧត្តរៈ ១ ព្រះថេរៈឈ្មោះឧបសន្តៈ ជាឧបដ្ឋាក អគ្គសាវិកា ២ រូប គឺរាមា ១ សុរាមា ១[១] មានដើមសាលព្រឹក្សជាឈើត្រាស់ដឹង មានព្រះសរីរៈកម្ពស់ ៦០ ហត្ថ មានព្រះជន្មាយុ ៦ ម៉ឺនឆ្នាំ ។

ក្នុងមណ្ឌកប្បនោះឯង មានព្រះជិនស្រីព្រះនាមវេស្សភូ ព្រះ
អង្គមិនមានបុគ្គលស្មើ មិនមានបុគ្គលប្រៀបផ្ទឹមបាន ទ្រង់
កើតឡើងក្នុងលោក ដូច្នេះ ។

ក្នុងកាលបន្ទាប់អំពីព្រះវេស្សភូនោះ ក្នុងកប្បនេះ មានព្រះពុទ្ធកើតឡើង ៤ អង្គ គឺព្រះពុទ្ធព្រះនាមកកុសន្ធៈ ព្រះពុទ្ធព្រះនាមកោនាគមនៈ ព្រះពុទ្ធព្រះនាមកស្សបៈ និងព្រះមានព្រះភាគនៃយើងទាំងឡាយ ។ ព្រះកកុសន្ធៈ មានសាវកសន្និបាតតែម្តងប៉ុណ្ណោះ ក្នុងសន្និបាតនោះ មានភិក្ខុ ៤ ម៉ឺនរូប ។

ក្នុងកាលនោះ ព្រះពោធិសត្វបានជាព្រះរាជាព្រះនាមខេមៈ ថ្វាយនូវមហាទាន មួយអន្លើដោយចីវរ និងភេសជ្ជៈ មានថ្នាំបន្តក់ភ្នែកជាដើមដល់ភិក្ខុសង្ឃ មានព្រះពុទ្ធជាប្រធាន ស្តាប់ធម្មទេសនារបស់ព្រះសាស្តា ហើយបួស ព្រះសាស្តាអង្គនោះទ្រង់ក៏ព្យាករព្រះពោធិសត្វនោះថា នឹងបានត្រាស់ជាព្រះពុទ្ធ ។

ព្រះមានព្រះភាគកកុសន្ធៈ មាននគរឈ្មោះខេមៈ ព្រាហ្មណ៍ឈ្មោះ

---

១- បិដកខ្មែរលេខ ៧៧ ជាសមាលា ។

អគ្គិទត្តៈ ជាបិតា ព្រាហ្មណីឈ្មោះវិសាខាជាមាតា អគ្គសាវក ២ រូប គឺវិធុរៈ ១ សញ្ជីវៈ ១ ភិក្ខុឈ្មោះពុទ្ធិជៈ ជាឧបដ្ឋាក អគ្គសាវិកា ២ រូប គឺសាមា ១ ចម្ប៉ា ១ មានដើមប្រេសធំជាឈើត្រាស់ដឹង មានព្រះសរីរៈកម្ពស់ ៤០ ហត្ថ មានព្រះជន្មាយុ ៤ ម៉ឺនឆ្នាំ ។

ក្នុងកាលជាក្រោយ នៃព្រះវេស្សភូសម្ពុទ្ធមក មានព្រះសម្ពុទ្ធ
ព្រះនាមកកុសន្ធៈ ទ្រង់ប្រសើរជាងពួកសត្វទ្វេបាទ មាន
គុណរាប់មិនបាន គេគ្របសង្កត់បានដោយកម្រ ព្រះអង្គ
រម្ងើងនូវភពទាំងពួង ដល់នូវបារមីដោយចរិយាហើយ
សម្រេចនូវពោធិញ្ញាណដ៏ឧត្តម ដូចសីហៈទម្លាយនូវទ្រុង
ដូច្នេះ ។

បន្ទាប់អំពីព្រះកកុសន្ធៈនោះ ព្រះសាស្ដាព្រះនាមកោនាគមនៈ ទ្រង់កើតឡើង ។ ទ្រង់មានសាវកសន្និបាតត្រឹមតែម្ដងប៉ុណ្ណោះ ក្នុងសាវក-សន្និបាតនោះ មានភិក្ខុ ៣ ម៉ឺនរូប ។

កាលនោះ ព្រះពោធិសត្វជាព្រះរាជាព្រះនាមបព្វតៈ ដែលពួកអមាត្យចោមរោម យាងទៅកាន់សម្នាក់របស់ព្រះសាស្ដា ស្ដាប់ព្រះធម្មទេសនាហើយនិមន្តភិក្ខុសង្ឃ មានព្រះពុទ្ធជាប្រធាន ញុំាំងមហាទានឲ្យប្រព្រឹត្តទៅហើយថ្វាយនូវសំពត់បត្តុណ្ណៈ សំពត់ចីនៈ សំពត់សូត្រ សំពត់កម្ពល សំពត់ទុកូលនិងសំពត់ត្បាញដោយមាស ហើយទ្រង់បួសក្នុងសម្នាក់របស់ព្រះសាស្ដា ព្រះសាស្ដាអង្គនោះ ទ្រង់ព្យាករព្រះពោធិសត្វនោះថា នឹងបានត្រាស់ជា

ព្រះពុទ្ធ ។

ព្រះមានព្រះភាគអង្គនោះ មាននគរឈ្មោះសោភវតី ព្រាហ្មណ៍ឈ្មោះយញ្ញទត្តៈ ជាបិតា ព្រាហ្មណីឈ្មោះឧត្តរា ជាមាតា អគ្គសាវក ២ រូប គឺកិយ្យសៈ ១ ឧត្តរៈ ១ ភិក្ខុឈ្មោះសោត្ថិជៈ ជាឧបដ្ឋាក អគ្គសាវិកា ២ រូប គឺសមុទ្ទា ១ ឧត្តរា ១ មានដើមល្វាជាឈើត្រាស់ដឹង មានព្រះសរីរៈកម្ពស់ ៣០ ហត្ថ មានព្រះជន្មាយុ ៣ ម៉ឺនឆ្នាំ ។

កាលជាខាងក្រោយ អំពីព្រះកកុសន្ធៈមក មានព្រះជិនស្រី
សម្ពុទ្ធព្រះនាមកោនាគមនៈ ព្រះអង្គឧត្តមជាងសត្វទ្វេបាទ
ជាធំក្នុងលោក ទ្រង់ប្រសើរជាងពួកជន ដូច្នេះ ។

បន្ទាប់អំពីព្រះកោនាគមនៈនោះ ព្រះសាស្តាព្រះនាមកស្សបៈ កើតឡើង សូម្បីព្រះសាស្តាអង្គនេះ ក៏មានសាវកសន្និបាតតែម្តងប៉ុណ្ណោះ ក្នុងសាវកសន្និបាតនោះ មានភិក្ខុ ២ ម៉ឺនរូប ។

កាលនោះ ព្រះពោធិសត្វជាមាណពឈ្មោះជោតិបាល សម្រេចត្រៃវេទ ជាអ្នកមានកេរ្តិ៍ឈ្មោះល្បីទៅលើផែនដី និងអាកាស បានជាមិត្ររបស់ស្មូនឆ្នាំង ឈ្មោះឃដិការ ព្រះពោធិសត្វនោះ ទៅគាល់ព្រះសាស្តា ជាមួយនឹងស្មូនឆ្នាំងនោះ បានស្តាប់ធម្មកថាហើយបួស ជាអ្នកប្រារព្ធសេចក្តីព្យាយាម រៀនព្រះត្រៃបិដក ធ្វើពុទ្ធសាសនាឲ្យស្អាត ព្រោះដល់ព្រមដោយវត្តបដិបត្តិតូចធំ ព្រះសាស្តាអង្គនោះ ទ្រង់ព្យាករព្រះពោធិសត្វនោះថា នឹងបានត្រាស់ជាព្រះពុទ្ធ ។

នគរដែលជាទីប្រសូតរបស់ព្រះមានព្រះភាគអង្គនោះ មានឈ្មោះថា ពារាណសី ព្រាហ្មណ៍ឈ្មោះព្រហ្មទត្តៈ ជាបិតា ព្រាហ្មណីឈ្មោះធនវតី ជាមាតា អគ្គសាវក ២ រូប គឺតិស្សៈ ១ ភារទ្វាជៈ ១ ព្រះថេរៈឈ្មោះសព្វមិត្ត ជាឧបដ្ឋាក អគ្គសាវិកា ២ រូប គឺអនុឡា ១ ឧរុវេឡា ១ មានដើមនិគ្រោធ ជាឈើត្រាស់ដឹង មានព្រះសរីរៈកម្ពស់ ២០ ហត្ថ មានព្រះជន្មាយុ ២ ម៉ឺនឆ្នាំ ។

កាលខាងក្រោយ អំពីព្រះពុទ្ធព្រះនាមកោនាគមនមក មាន
ព្រះសម្ពុទ្ធព្រះនាមកស្សបៈ ដ៏ឧត្តមជាងសត្វទ្វេបាទ ជា
ធម្មរាជ ទ្រង់ធ្វើពន្លឺ ដូច្នេះ ។

ក្នុងកប្បដែលព្រះទីបង្ករទសពលកើតឡើងនោះ មានព្រះសម្ពុទ្ធអង្គដទៃ ៣ អង្គទៀត តែព្រះពោធិសត្វមិនបានទទួលព្យាករក្នុងសម្នាក់នៃព្រះពុទ្ធទាំងនោះ ព្រោះហេតុនោះ ទើបលោកមិនសម្តែងព្រះពុទ្ធទាំងឡាយនោះក្នុងទីនេះ ។ តែក្នុងអដ្ឋកថា ដើម្បីនឹងសម្តែងព្រះពុទ្ធទាំងអស់ ចាប់តាំងអំពីមុនព្រះពុទ្ធទីបង្ករមក ទើបពោលពាក្យនេះថា

ព្រះពុទ្ធទាំងនេះ គឺព្រះតណ្ហង្ករ ព្រះមេធង្ករ ព្រះសរណង្ករ
ព្រះទីបង្ករសម្ពុទ្ធ ព្រះកោណ្ឌញ្ញៈឧត្តមជាង សត្វជើងពីរ ។
ព្រះមង្គលៈ ព្រះសុមនៈ ព្រះរេវតៈ ព្រះសោភិតមុនី ព្រះ
អនោមទស្សី ព្រះបទុមៈ ព្រះនារទៈ ព្រះបទុមុត្តរៈ ។
ព្រះសុមេធៈ ព្រះសុជាតៈ ព្រះបិយទស្សី ទ្រង់មានយសធំ

ព្រះអត្ថទស្សី ព្រះធម្មទស្សី ព្រះសិទ្ធត្ថៈជាលោកនាយក ។
ព្រះតិស្សៈ ព្រះផុស្សសម្ពុទ្ធ ព្រះវិបស្សី ព្រះសិខី ព្រះវេស្សភូ ព្រះកកុសន្ធៈ ព្រះកោនាគមនៈ និងព្រះកស្សបៈជាលោកនាយក ។
ព្រះពុទ្ធទាំងនោះ សុទ្ធតែប្រាសចាករាគៈ មានព្រះហឫទ័យតាំងមាំ ទ្រង់បន្ទោបង់នូវងងឹតយ៉ាងធំបាន ដូចព្រះអាទិត្យរះឡើងហើយ ព្រះសម្ពុទ្ធទាំងនោះ មួយអន្លើនឹងសាវក រុងរឿងដូចគំនរភ្លើង បរិនិព្វានហើយ ។

បណ្ដាព្រះពុទ្ធទាំងនោះ ព្រះពោធិសត្វនៃយើងទាំងឡាយ បានធ្វើនូវអធិការក្នុងសម្នាក់ព្រះពុទ្ធ ២៤ អង្គ មានព្រះពុទ្ធទីបង្ករជាដើម អស់ ៤ អសង្ខេយ្យ និង ១ សែនកប្ប ។ បន្ទាប់អំពីព្រះមានព្រះភាគព្រះនាមកស្សបៈ វៀរព្រះសម្មាសម្ពុទ្ធអង្គនេះហើយ ព្រះពុទ្ធអង្គដទៃមិនមាន[១] ព្រះពោធិសត្វបានទទួលពាក្យព្យាករក្នុងសម្នាក់របស់ព្រះពុទ្ធ ២៤ អង្គ មានព្រះពុទ្ធទីបង្ករជាដើម ដូចពណ៌នាមកដូច្នេះហើយ ទ្រង់ក៏បំពេញពុទ្ធការកធម៌ មានទានបារមីជាដើម ដែលទ្រង់ធ្វើអភិនីហារ ទៀបបាទមូលរបស់ព្រះពុទ្ធទីបង្ករ ដោយសមោធានធម៌ ៨ ប្រការឲ្យគ្រប់គ្រាន់ គឺ

សេចក្ដីប្រាថ្នា ដែលធំក្រៃលែង សម្រេចបាន ព្រោះសមោធានធម៌ ៨ ប្រការ គឺភាពជាមនុស្ស ១ ភាពជាអ្នកដល់ព្រម

---

១ មិនមានក្នុងទីនេះ គឺមិនមានក្នុងទូរេនិទាន មិនមែនមិនមានក្នុងអនាគត ។

ដោយភេទ ១ មានហេតុ ១ បានជួបព្រះសាស្តា ១ បាន
បួស ១ មានគុណសម្បត្តិ ១ ធ្វើអធិការទុក ១ មានឆន្ទៈ
មាំមួន ១ ។

ហើយបណ្តុះនូវឧស្សាហៈថា បើដូច្នោះ អាត្មាអញនឹងជ្រើសរើសរក ពុទ្ធការកធម៌ទាំងឡាយ ពីខាងនេះ ពីខាងនោះ ក៏បានឃើញពុទ្ធការកធម៌ មានការបំពេញទានបារមីជាដើម ដូចព្រះតម្រាស់ថា កាលនោះ តថាគត កំពុងជ្រើសរើស ក៏បានឃើញទានបារមីជាដំបូង ទ្រង់បំពេញពុទ្ធការកធម៌ ទាំងនោះយ៉ាងគ្រប់គ្រាន់ រហូតមកដល់ជាតិជាព្រះវេស្សន្តរ ក្នុងរវាងដែល ព្រះពោធិសត្វអន្ទោលនោះ ក៏បានទទួលអានិសង្សនៃព្រះពោធិសត្វនោះ ដែលបានបំពេញអភិនីហារ ដូចលោកពណ៌នាថា

នរជនមានអវយវៈគ្រប់គ្រាន់ ជាអ្នកទៀងចំពោះពោធិញ្ញាណ
យ៉ាងនេះ អន្ទោលទៅអស់កាលយូរ រាប់រយកោដិកប្ប ។
រមែងមិនកើតក្នុងអវិចី និងមិនកើតក្នុងលោកន្តរនរក កាល
កើតក្នុងទុគ្គតិ ក៏មិនកើតជានិជ្ឈាមតណ្ហិកប្រេត ខុប្បិបាសិក
ប្រេត និងកាលកញ្ជិកាសុរ ។
មិនកើតជាសត្វល្អិត កាលកើតក្នុងមនុស្ស មិនជាមនុស្សខ្វាក់
អំពីកំណើត ។
មិនជាមនុស្សត្រចៀកថ្លង់ មិនជាមនុស្សគ មិនកើតជាស្ត្រី
មិនកើតជាឧភតោព្យញ្ជនកៈ និងមិនកើតជាខ្ទើយ ។

នរជនដែលទៀងចំពោះពោធិញ្ញាណ មិនអាស្រ័យបុគ្គលដទៃ ផុតចាកអនន្តរិយកម្ម ជាអ្នកមានគោចរ ( ទីស្វែងរកអាហារ ) ស្អាតក្នុងទីគ្រប់ស្ថាន ។

មិនសេពនូវមិច្ឆាទិដ្ឋិ ជាអ្នកឃើញក្នុងកម្ម និងផលនៃកម្ម សូម្បីទៅកើតក្នុងស្ថានសួគ៌ ក៏មិនកើតជាអសញ្ញីសត្វ ។

មិនមានហេតុ ដែលទៅកើតក្នុងទេវតាជាន់សុទ្ធាវាស ជាសប្បុរស បង្អោនចិត្តទៅក្នុងនេក្ខម្ម: មិនជាប់ជំពាក់ក្នុងភពតូចធំ ប្រព្រឹត្តតែប្រយោជន៍ដល់លោក បំពេញបារមីទាំងពួងដូច្នេះ ។

កាលព្រះពោធិសត្វនោះបំពេញបារមីទាំងឡាយ ក្នុងកាលជាព្រាហ្មណ៍ឈ្មោះអកិត្តិ ក្នុងកាលជាព្រាហ្មណ៍ ឈ្មោះសង្ខ: ក្នុងកាលជាព្រះបាទធនញ្ជ័យ ក្នុងកាលជាព្រះបាទមហាសុទស្សន: ក្នុងកាលជាមហាគោវិន្ទ ក្នុងកាលជាព្រះបាទនិមិមហារាជ ក្នុងកាលជាព្រះចន្ទកុមារ ក្នុងកាលជាវិសយ្ហសេដ្ឋី ក្នុងកាលជាព្រះបាទសិវិរាជ ក្នុងកាលជាព្រះវេស្សន្តររាជាជាដើម មិនដល់លំដាប់ជាទានបារមីបរិបូណ៌ ។ តែការបំពេញទានបារមី ដ៏កំពូលរបស់ព្រះពោធិសត្វ ដែលបរិច្ចាគរាងកាយ ក្នុងសសបណ្ឌិតជាតក ដោយត្រិះរិះយ៉ាងនេះថា

តថាគតឃើញយាចក ចូលមកដើម្បីភិក្ខា ក៏បានលះបង់ខ្លួនជារបស់ខ្លួន បុគ្គលអ្នកឲ្យទានស្មើដោយទានរបស់តថាគត មិន

មានឡើយ នេះជាទានបារមីរបស់តថាគត ។

ចាត់ជាបរមត្ថបារមី ។

ដូចគ្នានេះដែរ ក្នុងកាលជាស្តេចដំរីឈ្មោះសីលវៈ ក្នុងកាលជាចម្បេយ្យនាគរាជ ក្នុងកាលជាភូរិទត្តនាគរាជ ក្នុងកាលជាស្តេចដំរីឆទ្ទន្ត ក្នុងកាលជាជយទិសរាជបុត្រ ក្នុងកាលជាអលីនសត្តកុមារជាដើម កាលបំពេញសីលបារមីមិនដល់លំដាប់ ជាសីលបារមីដែលបរិបូណ៌ តែការបំពេញសីលបារមីដ៏កំពូល រមែងមានដល់ព្រះពោធិសត្វ ដែលធ្វើនូវការលះរាងកាយក្នុង សង្ខបាលជាតក ដោយត្រិះរិះយ៉ាងនេះថា

កាលតថាគតជាសង្ខបាលនាគរាជ បានប្រគល់ជីវិតឲ្យដល់បុគ្គលណាមួយ សព្វកាលៗ ហេតុនោះ បារមីនោះ ជាសីលបរមត្ថបារមី ( នៃតថាគត ) ។

ចាត់ជាបរមត្ថបារមី ។

ដូចគ្នានេះដែរ កាលព្រះពោធិសត្វលះមហារាជសម្បត្តិ ក្នុងកាលជាសោមនស្សកុមារ ក្នុងកាលជាហត្ថិបាលកុមារ ក្នុងកាលជាអយោឃរបណ្ឌិត ក៏មិនដល់លំដាប់ជានេក្ខម្មបារមីបរិបូណ៌ តែកាលព្រះអង្គលះរាជសម្បត្តិចេញបួស ដោយមិនអាឡោះអាល័យ ដែលជាការលះបង់ដ៏កំពូល ក្នុងចូឡសុត្តសោមជាតក ដោយព្រះតម្រិះយ៉ាងនេះថា

តថាគតលះរាជសម្បត្តិធំ ដែលនៅក្នុងកណ្តាប់ដៃ ដូចដុំទឹកមាត់ដែលស្តោះចោល មិនមានអាឡោះអាល័យឡើយ

នេះជានេក្ខម្មបារមីរបស់តថាគត ។

ការបំពេញនេក្ខម្មបារមីនេះ ចាត់ជាបរមត្ថបារមី ។

ដូចគ្នានេះដែរ កាលបំពេញបញ្ញាបារមី ក្នុងកាលជាវិធុរបណ្ឌិត ក្នុងកាលជាមហាគោវិន្ទបណ្ឌិត ក្នុងកាលជាកុទ្ទាលបណ្ឌិត ក្នុងកាលជាអរកបណ្ឌិត ក្នុងកាលជាពោធិបរិញ្វាជក ក្នុងកាលជាមហោសធបណ្ឌិតជាដើម មិនដល់លំដាប់ជាបញ្ញាបារមីដែលបរិបូណ៌ តែកាលព្រះពោធិសត្វបង្ហាញពស់ដែលនៅក្នុងថៃ ដែលជាការបង្ហាញដ៏កំពូល ក្នុងកាល ជាក្នុងកាលជាសេនកបណ្ឌិត ក្នុងសត្តុកត្តជាតក ដោយត្រិះរិះយ៉ាងនេះថា

តថាគតប្រើបញ្ញាពិចារណា បានជួយដោះនូវព្រាហ្មណ៍ ឲ្យផុតចាកទុក្ខ បុគ្គលស្មើដោយបញ្ញារបស់តថាគត មិនមាន នេះជាបញ្ញាបារមីរបស់តថាគត ។

ការបំពេញបញ្ញាបារមីនេះ ចាត់ជាបរមត្ថបារមី ។

ដូចគ្នានេះដែរ ការបំពេញបារមី មិនដល់លំដាប់ថា ជាវីរិយបារមីជាដើមដែលបរិបូណ៌ តែកាលព្រះអង្គហែលឆ្លងមហាសមុទ្រ ដែលជាសេចក្តីព្យាយាមដ៏កំពូល ក្នុងមហាជនកជាតក ដោយព្រះតម្រិះយ៉ាងនេះថា

ក្នុងកណ្តាលមហាសមុទ្រ មើលមិនឃើញកោះត្រើយ ពួកមនុស្សត្រូវស្លាប់អស់ តថាគតមិនមានចិត្តដទៃឡើយ នេះជាវីរិយបារមីរបស់តថាគត ។

ការបំពេញវីរិយបារមីនេះ ចាត់ជាបរមត្ថបារមី ។

ក្នុងខន្តិវាទីជាតក ព្រះពោធិសត្វអត់ធន់ចំពោះទុក្ខ ធ្វើខ្លួនដូចមិនមានចិត្តដោយត្រិះរិះយ៉ាងនេះថា

កាលព្រះបាទកាសីកាប់តថាគត ដែលដូចជាមិនមានចិត្ត
ដោយពូថៅដ៏មុត តថាគតមិនក្រោធ នេះជាខន្តិបារមីរបស់
តថាគត ។

ការបំពេញខន្តិបារមីនេះ ចាត់ជាបរមត្ថបារមី ។

ក្នុងមហាសុត្តសោមជាតក ព្រះពោធិសត្វលះបង់ជីវិត រក្សាសច្ចៈដោយព្រះតម្រិះយ៉ាងនេះថា

កាលតថាគតតាមរក្សាសច្ចវាចា បានលះបង់ជីវិតរបស់
តថាគត ជួយឲ្យក្សត្រ ១០១ អង្គ រួចផុត នេះជា សច្ចបារមី
របស់តថាគត ។

ការបំពេញសច្ចបារមីនេះ ចាត់ជាបរមត្ថបារមី ។

ក្នុងមូគបក្ខជាតក ( តេមិយជាតក ) ព្រះពោធិសត្វលះបង់ជីវិតអធិដ្ឋានវត្ត ដោយព្រះតម្រិះយ៉ាងនេះថា

មាតាបិតា មិនមែនជាទីស្អប់របស់តថាគតទេ យសធំ ក៏មិន
មែនជាទីស្អប់ខ្ពើមរបស់តថាគតដែរ តែសព្វញ្ញុតញ្ញាណ
ជាទីស្រឡាញ់របស់តថាគត ព្រោះហេតុនោះ បានជាតថាគត
តម្កល់នូវអធិដ្ឋាននោះ ។

ការបំពេញអធិដ្ឋានបារមីនេះ ចាត់ជាបរមត្ថបារមី ។

ក្នុងសុវណ្ណសាមជាតក ព្រះពោធិសត្វ មិនគិតដល់សូម្បីជីវិត នៅដោយមេត្តា ដោយត្រិះរិះយ៉ាងនេះថា

សត្វណាមួយ មិនធ្វើតថាគតឲ្យតក់ស្លុតទេ ទាំងតថាគត
ក៏មិនខ្លាចសត្វណាមួយឡើយ កាលនោះ កម្លាំងមេត្តាឧបត្ថម្ភ
តថាគត ឲ្យតថាគតនៅក្នុងព្រៃដោយសួស្តី ។

ការបំពេញមេត្តាបារមីនេះ ចាត់ជាបរមត្ថបារមី ។

ក្នុងលោមហំសជាតក ព្រះពោធិសត្វ ត្រូវក្មេងអ្នកស្រុកញ៉ាំងសេចក្តីសុខ និងទុក្ខឲ្យកើតឡើង ដោយការស្តោះទឹកមាត់ដាក់ជាដើម និងដោយការនាំផ្កា និងគ្រឿងក្រអូបមកបូជាជាដើម ក៏មិនប្រព្រឹត្តកន្លងឧបេក្ខា ដោយត្រិះរិះយ៉ាងនេះថា

តថាគតសម្រេចសេយ្យាសន៍ កើយឆ្អឹងសាកសពក្នុងព្រៃ
ស្មសាន ពួកក្មេងអ្នកស្រុកចូលមកជិត ( តថាគត ) ហើយ
សម្តែងនូវប្រការដ៏ប្លែកច្រើនយ៉ាង ។

ការបំពេញឧបេក្ខាបារមីនេះ ចាត់ជាបរមត្ថបារមី ។

នេះជាសេចក្តីសង្ខេបក្នុងទីនេះ ឯសេចក្តីពិស្តារនោះ គប្បីកាន់យកអំពីចរិយាបិដក ។ ព្រះពោធិសត្វបំពេញបារមីទាំងឡាយយ៉ាងនេះហើយ តាំងនៅក្នុងអត្តភាពជាព្រះវេស្សន្តរ ធ្វើបុណ្យធំ ដែលជាហេតុឲ្យផែនដីញាប់ញ័រយ៉ាងនេះថា

ប្រឹថពីមិនមានចេតនាទេ មិនដឹងសុខ និងទុក្ខទេ តែមហា-

ប្រើថពីនោះ បានកម្រើកញាប់ញ័រអស់វារៈ ៧ ដង ព្រោះកម្លាំងទានរបស់តថាគត ដូច្នេះ ។

ក្នុងពេលអស់អាយុ ចុតិចាកអត្តភាពនោះ បានទៅកើតក្នុងស្ថានតុសិត ។ ចាប់តាំងអំពីបាទមូលរបស់ព្រះពុទ្ធទីបង្ករ រហូតដល់ព្រះពោធិសត្វកើតក្នុងតុសិតបុរី គប្បីជ្រាបថា ជាទូរេនិទាន ដោយប្រការដូច្នេះ ។

**ទូរេនិទានកថា ចប់**

# អាទិត្តបេដិទានកថា

កាលព្រះពោធិសត្វនៅក្នុងតុសិតបុរីនោះឯង កោលាហល ដែលហៅថា ពុទ្ធកោលាហល បានកើតឡើងហើយ ។ ពិតហើយ ក្នុងលោក រមែងមានកោលាហលធំ ៣ ប្រការ កើតឡើង គឺកប្បកោលាហល ១ ពុទ្ធ-កោលាហល ១ ចក្កវត្តិកោលាហល ១ ។

បណ្ដាកោលាហលទាំង ៣ នោះ ទេវតាជាន់កាមាវចរ ឈ្មោះលោក-ព្យូហៈ ជ្រាបថា អំណឹះតទៅ ១ សែនឆ្នាំ នឹងកើតហេតុការណ៍វិនាសកប្ប ទើបរំសាយសក់ មានមុខជោកដោយទឹកភ្នែក យកដៃជូតទឹកភ្នែក ស្លៀកសំពត់ក្រហម កាឡាខ្លួនខុសប្រក្រតីច្រើនបែបយ៉ាង ត្រាច់ទៅក្នុងដែនដីមនុស្ស ពោលយ៉ាងនេះថា អ្នកនិទ្ទុក្ខទាំងឡាយ កន្លង ១ សែនឆ្នាំ អំពីនេះទៅ នឹងកើតហេតុការណ៍វិនាសកប្ប លោកនេះនឹងវិនាស មហាសមុទ្រនឹងរីង មហាប្រឹថពីនេះ និងភ្នំសិនេរុ នឹងត្រូវភ្លើងឆេះ នឹងវិនាស លោកវិនាសនឹងមានរហូតដល់ព្រហ្មលោក អ្នកនិទ្ទុក្ខទាំងឡាយ សូមអ្នកទាំងឡាយចម្រើនមេត្តា ករុណា មុទិតា ឧបេក្ខា ចូរបម្រើមាតាបិតា ចូរប្រព្រឹត្តឱនលំទោនចំពោះគ្រកូលរៀមច្បង នេះឈ្មោះថា **កប្បកោលាហល** ។

ពួកលោកបាលទេវតាជ្រាបថា កាលកន្លងទៅ ១០០០ ឆ្នាំ ព្រះសព្វញ្ញុពុទ្ធ នឹងកើតឡើងក្នុងលោក ទើបត្រាច់ប្រកាសថា នែលោកនិទ្ទុក្ខទាំងឡាយ កន្លង ១០០០ ឆ្នាំអំពីនេះទៅ ព្រះសព្វញ្ញុពុទ្ធនឹងកើតឡើងក្នុងលោក នេះ ឈ្មោះថា **ពុទ្ធកោលាហល** ។

ទេវតាទាំងឡាយជ្រាបថា កន្លងទៅ ១០០ ឆ្នាំ ស្ដេចចក្រពត្តិនឹងកើត

ឡើង ទើបត្រាច់ប្រកាសថា នែអ្នកនិទ្ទុកទាំងឡាយ កន្លងទៅ ១០០ ឆ្នាំអំពីនេះ ស្តេចចក្រពត្តិនឹងកើតឡើងក្នុងលោក នេះ ឈ្មោះថា **ចក្កវត្តិ-កោលាហល** នេះគឺកោលាហលធំ ៣ យ៉ាង ។

បណ្តាកោលាហលទាំង ៣ នោះ ទេវតាក្នុងម៉ឺនចក្កវាឡទាំងមូល បានស្តាប់សំឡេងពុទ្ធកោលាហលហើយ ទើបរួមប្រជុំគ្នា បានជ្រាបថា សត្វឈ្មោះនោះ នឹងបានជាព្រះពុទ្ធ ទើបចូលទៅរកទេវតាអង្គនោះ នាំគ្នាអារាធនាកាលអារាធនា ក៏អារាធនាចំពោះកាលបុព្វនិមិត្តកើតឡើងហើយ ។

ក្នុងកាលនោះ ទេវតាទាំងពួងអំពីចក្កវាឡនីមួយៗ មកប្រជុំគ្នាក្នុងចក្កវាឡតែមួយ មួយអន្លើដោយចាតុម្មហារាជ សក្កទេវរាជ ស្តេចសុយាម ស្តេចសន្តុសិត ស្តេចសុនិម្មិត ស្តេចវសវត្តី និងមហាព្រហ្ម ហើយទៅកាន់សម្នាក់របស់ព្រះពោធិសត្វ ក្នុងតុសិតភព នាំគ្នាអារាធនាថា បពិត្រលោកនិទ្ទុក លោកបំពេញបារមី ១០ មក មិនមែនបំពេញដោយប្រាថ្នា សក្កសម្បត្តិ មារសម្បត្តិ ព្រហ្មសម្បត្តិ និងចក្កវត្តិសម្បត្តិឡើយ តែលោកបំពេញដើម្បីប្រាថ្នាព្រះសព្វញ្ញុតញ្ញាណ ដើម្បីចម្លងសត្វឆ្លងចាកលោក បពិត្រលោកនិទ្ទុក ឥឡូវនេះ ជាកាលដែលលោកនឹងត្រាស់ជាព្រះពុទ្ធហើយ ជាសម័យដែលលោកគួរត្រាស់ជាព្រះពុទ្ធហើយ ។

លំដាប់នោះ ព្រះមហាសត្វមិនទាន់ឲ្យប្តេជ្ញាដល់ទេវតាទាំងឡាយភ្លាមៗឡើយ ពិនិត្យមើលបញ្ចមហាវិលោកនៈ គឺវត្ថុដែលត្រូវជ្រើសរើស ៥ ប្រការ គឺកាល ១ ទ្វីប ១ ប្រទេស ១ ត្រកូល ១ និងកំណត់អាយុរបស់មាតា ១ ។

ក្នុង ៥ ប្រការនោះ ព្រះពោធិសត្វប្រមើលមើលកាលជំបូងថា ជាកាលសមគួរ ឬកាលមិនសមគួរ ។ ក្នុងរឿងកាលនោះ កាលដែលមនុស្សមានអាយុច្រើនជាង ១ សែនឆ្នាំ ឈ្មោះថា កាលមិនសមគួរ ព្រោះហេតុអ្វី ព្រោះថា ក្នុងកាលនោះ ជាតិ ជរា និងមរណៈរបស់សត្វទាំងឡាយ មិនប្រាកដ ព្រះធម្មទេសនារបស់ព្រះពុទ្ធទាំងឡាយ ឈ្មោះថា ផុតចាកត្រៃលក្ខណ៍ មិនមាន កាលព្រះពុទ្ធទាំងនោះត្រាស់ថា **អនិច្ចំ ទុក្ខំ អនត្តា** ពួកជនទាំងនោះគិតថា ព្រះអង្គត្រាស់រឿងអ្វី ទើបមិនយល់ថាជាព្រះតម្រាស់ មិនគួរស្តាប់ និងមិនគួរជឿ បន្ទាប់អំពីនោះ ការត្រាស់ដឹងមគ្គផល ក៏មានមិនបាន កាលមិនមានការត្រាស់ដឹងមគ្គផល សាសនា គឺពាក្យប្រៀនប្រដៅ មិនជាគ្រឿងនាំចេញចាកទុក្ខ ព្រោះហេតុនោះ កាលនោះ ទើបជាកាលមិនសមគួរ ។ កាលដែលមនុស្សមានអាយុតិចជាង ១០០ ឆ្នាំ ក៏ឈ្មោះថា ជាកាលមិនសមគួរ ព្រោះហេតុអ្វី ព្រោះថា ក្នុងកាលនោះ សត្វទាំងឡាយមានកិលេសក្រាស់ ឱវាទដែលឲ្យដល់សត្វមានកិលេសក្រាស់ មិនតាំងនៅក្នុងឋានៈជាឱវាទ នឹងបាត់ទៅដោយឆាប់រហ័ស ដូចគំនូសដែលគូសក្នុងទឹក ព្រោះដូច្នោះ សូម្បីកាលនោះ ក៏ជាកាលមិនសមគួរ ។ កាលដែលមនុស្សមានអាយុតាំងអំពី ១ សែនឆ្នាំចុះមក និងតាំងអំពី ១០០ ឆ្នាំឡើងទៅ ឈ្មោះថា ជាកាលសមគួរ កាលនោះ ជាកាលដែលមនុស្សមានអាយុ ១០០ ឆ្នាំ លំដាប់នោះ ព្រះមហាសត្វក៏សម្លឹងឃើញកាលថា ជាកាលដែលគួរកើត ។

បន្ទាប់អំពីនោះ កាលនឹងប្រមើលមើលទ្វីប បានពិនិត្យមើលទ្វីបទាំង ៤ ព្រមទាំងទ្វីបបរិវារទើប ឃើញទ្វីប ១ ថា ព្រះពុទ្ធទាំងឡាយមិនកើតក្នុងទ្វីបទាំង ៣ កើតក្នុងជម្ពូទ្វីបប៉ុណ្ណោះ ។

បន្ទាប់អំពីនោះ ក៏គិតថា ឈ្មោះថា ជម្ពូទ្វីប ជាទ្វីបធំ មានប្រមាណ ១ ម៉ឺនយោជន៍ ព្រះពុទ្ធទាំងឡាយកើតក្នុងប្រទេសណាហ្ន៎ កាលប្រមើលមើលទីកន្លែង ក៏បានឃើញមជ្ឈិមប្រទេស ។ ឈ្មោះថា មជ្ឈិមប្រទេស គឺប្រទេសដែលលោកពោលក្នុងវិន័យ ( មហាវគ្គ ) យ៉ាងនេះថា បណ្តាជនបទទាំងនោះ ជនបទទាំងឡាយនេះ ដែលជាបច្ចន្តិមជនបទ គឺក្នុងទិសខាងកើត មាននិគមឈ្មោះកជង្គល ខាងនាយកជង្គលនិគមនោះ មាននិគមឈ្មោះមហាសាលា ខាងនាយនិគមឈ្មោះមហាសាលានោះ ហៅថា បច្ចន្តិមជនបទ ខាងអាយចូលមក ជាមជ្ឈិមជនបទ ។ ក្នុងទិសអាគ្នេយ៍ មានស្ទឹងឈ្មោះសល្លវតី ខាងនាយស្ទឹងសល្លវតីនោះ ហៅថា បច្ចន្តិមជនបទ ខាងអាយចូលមកជាមជ្ឈិមជនបទ ។ ក្នុងទិសខាងត្បូង មាននិគមឈ្មោះសេតកណ្ណិក ខាងនាយសេតកណ្ណិកនិគមនោះ ហៅថា បច្ចន្តិមជនបទ ខាងអាយចូលមកជាមជ្ឈិមជនបទ ។ ក្នុងទិសខាងលិច មានស្រុកព្រាហ្មណ៍ឈ្មោះថូនគ្រាម ខាងនាយស្រុកថូនគ្រាមនោះ ហៅថា បច្ចន្តិមជនបទ ខាងអាយចូលមកជាមជ្ឈិមជនបទ ។ ក្នុងទិសខាងជើង មានភ្នំឈ្មោះឧសីរធជ ខាងនាយភ្នំនោះ ហៅថា បច្ចន្តិមជនបទ ខាងអាយចូលមក ជាមជ្ឈិមជនបទ ។ មជ្ឈិមបទេសនោះ បណ្តោយ ៣០០ យោជន៍ ទទឹង ២៥០ យោជន៍

វាស់ដោយជុំវិញបាន ៩០០ យោជន៍ ដូច្នោះ ក្នុងប្រទេសនោះ ព្រះពុទ្ធ ព្រះបច្ចេកពុទ្ធ ព្រះអគ្គសាវក ព្រះអសីតិមហាសាវក ស្ដេចចក្រពត្តិ ខត្តិយមហាសាល ព្រាហ្មណមហាសាល និងគហបតិមហាសាល ដែលមានសក្តិធំ រមែងកើតក្នុងប្រទេសនេះ ហើយនគរឈ្មោះកបិលពស្តុនេះ ក៏តាំងនៅក្នុងមជ្ឈិមបទេសនេះ ទើបព្រះពោធិសត្វសម្រេចចិត្តថា អញនឹងកើតក្នុងនគរនោះ ។

បន្ទាប់អំពីនោះ ព្រះពោធិសត្វកាលនឹងជ្រើសរើសត្រកូល ទ្រង់ឃើញត្រកូលថា ធម្មតាព្រះពុទ្ធទាំងឡាយ រមែងមិនកើតក្នុងត្រកូលវេស្សៈ ឬក្នុងត្រកូលសូទ្រៈ កើតតែក្នុង ២ ត្រកូលប៉ុណ្ណោះ គឺត្រកូលក្សត្រ ឬត្រកូលព្រាហ្មណ៍ ដែលលោកសរសើរហើយ ឥឡូវនេះ ត្រកូលក្សត្រជាត្រកូលដែលសត្វលោកសរសើរហើយ អញនឹងកើតក្នុងត្រកូលក្សត្រនោះ ព្រះរាជាព្រះនាមសុទ្ធោទនៈ នឹងជាបិតារបស់អញ ។

បន្ទាប់អំពីនោះ ទើបជ្រើសរើសមាតា បានឃើញថា ធម្មតាមាតារបស់ព្រះពុទ្ធ មិនមែនជាស្រីឡេះឡោះ មិនជាអ្នកលេងសុរា តែជាអ្នកបានបំពេញបារមីមកអស់សែនកប្ប ជាអ្នកមានសីល ៥ មិនដាច់ តាំងពីកើតមក ឯព្រះទេវីព្រះនាមមហាមាយានេះ ទ្រង់មានសភាពដូច្នេះ ព្រះនាងមហាមាយានេះ នឹងជាមាតារបស់អញ កាលប្រមើលមើលថា ព្រះនាងមានព្រះជន្មាយុប៉ុន្មាន ក៏ឃើញថា ក្រោយអំពី ១០ ខែទៅហើយ នឹងមានព្រះជន្មបាន ៧ ថ្ងៃ ។

ព្រះពោធិសត្វពិនិត្យមើលមហាវិលោកនៈ ៥ ប្រការនេះ ដោយប្រការដូច្នេះហើយ ទើបពោលថា អ្នកនិទ៌ុក្ខទាំងឡាយ ដល់កាលដែលខ្ញុំជាព្រះពុទ្ធហើយ កាលធ្វើនូវសេចក្តីសង្គ្រោះដល់ទេវតាទាំងឡាយ ទើបឲ្យបេ្តជ្ញាបញ្ជូនទេវតាទាំងនោះទៅដោយពាក្យថា សូមពួកលោកទៅចុះ ដែលទេវតាជាន់តុសិតចោមរោមហើយ ចូលទៅកាន់នន្ទនវ័នក្នុងតុសិតបុរី ។ ពិតហើយ ក្នុងទេវលោកគ្រប់ជាន់ មាននន្ទនវ័នទាំងអស់ ក្នុងនន្ទនវ័ននោះ ទេវតាទាំងឡាយ ចាំជាស់តឿនឲ្យព្រះពោធិសត្វរឭកដល់ឱកាសនៃកុសលកម្ម ដែលបានឲ្យធ្វើក្នុងកាលមុនថា លោកចុតិអំពីនេះហើយ ចូរទៅកាន់សុគតិចុះ លោកចុតិអំពីនេះហើយ ចូរទៅកាន់សុគតិចុះ ។ ព្រះពោធិសត្វនោះ ដែលទេវតាទាំងឡាយជាស់តឿនឲ្យរឭកដល់កុសលកម្មយ៉ាងនេះ ចោមរោមត្រាច់ទៅក្នុងនន្ទនវ័ននោះឯង បានចុតិហើយបដិសន្ធិក្នុងព្រះគភ៌ របស់ព្រះនាងមហាមាយាទេវី ។ ដើម្បីឲ្យយល់រឿងបដិសន្ធិនោះ ទើបសូមពោលរឿងដែលកើតមកដូចតទៅ

បានឮថា កាលនោះ ក្នុងនគរកបិលពស្តុ មានអាសាឡ្ហនក្ខត្តឫក្សយ៉ាងគគ្រឹកគគ្រេង មហាជនលេងនក្ខត្តឫក្សគ្រប់គ្នា ។ ឯព្រះនាងមហាមាយាទេវីមុខដល់ថ្ងៃ ១៥ កើត ៧ ថ្ងៃ ព្រះនាងលេងនក្ខត្តឫក្សដែលដល់ព្រមដោយផ្កា និងគ្រឿងក្រអូប មិនមានការផឹកសុរា ក្នុងថ្ងៃទី ៧ តាំងអំពីព្រលឹម ព្រះនាងស្រង់ដោយទឹកក្រអូប លះរាជទ្រព្យ ៤ សែន ថ្វាយមហាទានហើយប្រដាប់ដោយគ្រឿងរាជអលង្ការទាំងពួង សោយព្រះក្រយាហារដ៏ល្អ

អធិដ្ឋានអង្គឧបោសថ យាងចូលបន្ទប់ដ៏មានសិរី ដែលប្រដាប់តាក់តែង ហើយ ផ្ទំលើព្រះសិរីសេយ្យាសនៈ ឈានចុះកាន់និទ្រា ព្រះនាងសុបិន ដូច្នេះថា

ស្តេចមហារាជ ៤ អង្គ លើកព្រះនាងទាំងព្រះទែនសយនា ហើយ នាំទៅកាន់ព្រៃហិមពាន្ត ដាក់លើផ្ទាំងមនោសិលា មានប្រមាណ ៦០ យោជន៍ ខាងក្រោមដើមមហាសាលព្រឹក្ស មានកម្ពស់ ៧ យោជន៍ ហើយបានឈរ ក្នុងទីបំផុតម្ខាង ៗ លំដាប់នោះ ពួកទេវីរបស់មហារាជទាំងនោះ នាំគ្នាមក នាំព្រះទេវីទៅកាន់អនោតត្តស្រះ ឲ្យព្រះនាងស្រពស្រង់ដើម្បីលាងជម្រះ មន្ទិលរបស់មនុស្ស ហើយឲ្យស្លៀកដណ្តប់សំពត់ទិព្វ ឲ្យលាបស្រឡាប នូវគ្រឿងក្រអូប ឲ្យប្រដាប់នូវកម្រងផ្កាដែលជាទិព្វ ក្នុងទីមិនឆ្ងាយអំពីទីនោះ មានភ្នំប្រាក់ ១ ខាងក្នុងភ្នំប្រាក់នោះ មានវិមានមាស ដែលពួកទេវតាឲ្យរៀបចំ សេយ្យាសនៈដែលជាទិព្វ មានក្បាលបែរទៅកាន់ទិសខាងកើត ហើយឲ្យព្រះ នាងផ្ទំលើសេយ្យាសនៈនោះ ៗ លំដាប់នោះ ព្រះពោធិសត្វ ជាដំរីពណ៌ស ដ៏ប្រសើរ ត្រាច់ទៅក្នុងភ្នំមាស ដែលនៅមិនឆ្ងាយអំពីទីនោះ បានចុះអំពី ភ្នំមាសនោះហើយ ឡើងទៅកាន់ភ្នំប្រាក់ ដើរមកអំពីទិសខាងជើង យក ប្រមោយដែលមានពណ៌ដូចកម្រងប្រាក់ចាប់ផ្កាបទុមពណ៌ស បន្លឺកោញ្ចនាទ ចូលទៅកាន់វិមានមាស ធ្វើប្រទក្សិណសេយ្យាសនៈព្រះមាតា ៣ ជុំ ហាក់ ដូចជាជ្រែកចូលត្រង់ឆ្អឹងជំនីរខាងស្តាំ ចូលទៅកាន់ព្រះគភ៌ ៗ ព្រះពោធិសត្វ បានបដិសន្ធិក្នុងអាសាឡ្ហនក្ខត្តឫក្ស ដោយប្រការដូច្នេះ ៗ

ស្អែកឡើង ព្រះទេវីទ្រង់ភ្ញាក់ពីបន្ទំ ហើយក្រាបទូលព្រះសុបិននោះដល់ព្រះរាជាៗ ត្រាស់ឲ្យអញ្ជើញព្រាហ្មណ៍ដែលជាប្រធានប្រមាណ ៦៤ នាក់ចូលគាល់ ឲ្យក្រាលអាសនៈដែលគួរដល់តម្លៃច្រើន លើផ្ទៃដែលបូកលាបដោយគោម័យស្រស់ មានគ្រឿងសក្ការៈដែលជាមង្គល ដែលធ្វើដោយលាជជាដើម ឲ្យដាក់បាយាសដ៏ប្រសើរដែលផ្សំដោយសប្បិ ទឹកឃ្មុំ និងស្ករក្រាមពេញថាសមាស និងថាសប្រាក់ យកថាសមាស និងថាសប្រាក់នោះឯងគ្របហើយ ប្រទានដល់ពួកព្រាហ្មណ៍ដែលអង្គុយលើអាសនៈនោះ ទ្រង់ឲ្យព្រាហ្មណ៍ទាំងនោះ ឆ្អែតស្កប់ស្កល់ដោយទ្រព្យដទៃៗ មានការប្រទានសំពត់ថ្មី និងមេគោក្រហមជាដើម ពេលនោះ ទើបត្រាស់ឲ្យប្រាប់សុបិនដល់ព្រាហ្មណ៍ទាំងនោះ ដែលឆ្អែតស្កប់ស្កល់ដោយវត្ថុដែលខ្លួនត្រូវការគ្រប់យ៉ាង ហើយត្រាស់សួរថា នឹងមានហេតុដូចម្តេច ព្រាហ្មណ៍ទាំងឡាយក្រាបទូលថា បពិត្រមហារាជ ទ្រង់កុំព្រះវិតក្កឡើយ ព្រះទេវីទ្រង់មានគភ៌ហើយ ព្រះគភ៌ដែលតាំងឡើងនោះ ជាគភ៌បុរស មិនមែនជាស្ត្រី ទ្រង់នឹងមានព្រះរាជបុត្រ បើព្រះរាជបុត្រនោះគ្រប់គ្រងផ្ទះ នឹងបានជាស្តេចចក្រពត្តិ បើចេញចាកផ្ទះសាងផ្នួស នឹងបានត្រាស់ជាព្រះពុទ្ធ មានកិលេសដូចដំបូល បើកហើយក្នុងលោក ។

ខណៈដែលព្រះពោធិសត្វបដិសន្ធិ ក្នុងព្រះគភ៌របស់ព្រះមាតានោះឯង លោកធាតុទាំង ១ ម៉ឺន បានញាប់ញ័រមួយរំពេច បុព្វនិមិត្ត ៣២ ប្រការបានប្រាកដឡើងហើយ ពន្លឺមិនមានប្រមាណបានផ្សាយទៅក្នុងម៉ឺនចក្កវាឡ ពួក

មនុស្សក្អែកខ្វាក់ ក៏ត្រឡប់ជាមើលឃើញ ហាក់ដូចជាមានបំណងនឹងមើល ព្រះសិរីរបស់ព្រះពោធិសត្វនោះ ពួកមនុស្សត្រចៀកថ្លង់ បានឮសំឡេង មនុស្សគនិយាយបាន ពួកមនុស្សគមមានខ្នងត្រង់ ពួកមនុស្សខ្វិនបែរជាដើរបាន សត្វទាំងពួងដែលត្រូវចង ក៏រួចចាកចំណង មានខ្នោះឃ្នាងជាដើម ភ្លើងទាំងពួងក្នុងនរកក៏រលត់ ក្នុងបេត្តវិស័យ ការស្រេកឃ្លានក៏រម្ងាប់ ពួកសត្វតិរច្ឆាន ក៏មិនមានការខ្លាច រោគរបស់សត្វទាំងពួងក៏ស្ងប់ សត្វទាំងឡាយ ក៏ពោលនូវពាក្យគួរជាទីស្រឡាញ់ សេះទាំងឡាយ កញ្ជ្រៀវដោយអាការដ៏ពីរោះ ដំរីទាំងឡាយក៏កន្ទ្រចដោយអាការដ៏ពីរោះ តន្ត្រីគ្រប់ប្រភេទ ក៏បន្លឺសំឡេងកងរំពងរៀងៗ ខ្លួន ។ គ្រឿងអាភរណៈ ដែលពាក់ក្នុងដៃជាដើមរបស់ពួកមនុស្ស មិនប៉ះទង្គិចគ្នា ក៏ឮសំឡេងបាន គ្រប់ទិសភ្លឺស្វាង ខ្យល់ត្រជាក់ស្រទន់បក់មក ធ្វើសេចក្ដីសុខ ឲ្យកើតឡើងដល់សត្វទាំងឡាយ ភ្លៀងពុំជូកាលក៏ធ្លាក់ចុះមក ទឹកក៏ផុសចេញពីផែនដីហូរទៅ ពួកបក្សីក៏ផ្អាកការហើរទៅក្នុងអាកាស ស្ទឹងទាំងឡាយក៏ឈប់ហូរ មហាសមុទ្រមានទឹកផ្អែម ផ្ទៃទឹកដេរដាសដោយឈូកមានពណ៌ ៥ គ្រប់កន្លែង ផ្កាគ្រប់ប្រភេទ ទាំងលើគោក និងក្នុងទឹក ក៏រីកស្គុសស្គាយ ផ្កាឈូកប្រភេទដើម ក៏រីកត្រង់ដើម ផ្កាឈូកប្រភេទមែក ក៏រីកត្រង់មែក ផ្កាឈូកប្រភេទវល្លិ ក៏រីកត្រង់វល្លិ ផ្កាឈូកប្រភេទទង ក៏ជ្រែកថ្មាំងថ្ម ជាផ្កាត្រួតគ្នាជាជាន់ៗ ចេញមក ក្នុងអាកាស ក៏មានផ្កាឈូកសំយុងចុះមក ភ្លៀងធ្លាក់ចុះមកជុំទិស តន្ត្រីទិព្វបន្លឺក្នុងអាកាស លោកធាតុទាំង ១ ម៉ឺនហាក់ដូចជាកម្រងផ្កា ដែលគេបង្វិលហើយបោះទៅ

ដូចបាច់ផ្កាដែលគេចង ដូចអាសនៈផ្កាដែលគេរចនា មានកម្រងតែមួយ និងដូចផ្ទិតវាលរីជនីដែលកំពុងបក់ អប់ទៅដោយក្លិនក្រអូបនៃផ្កា និងផ្សែងក្រអូប មានលម្អក្រៃលែង ។

ចាប់តាំងពីបដិសន្ធិរបស់ព្រះពោធិសត្វ ដែលបដិសន្ធិហើយយ៉ាងនេះ ដើម្បីការពារអន្តរាយដល់ព្រះពោធិសត្វ និងមាតារបស់ព្រះពោធិសត្វ ទេវបុត្រ ៤ អង្គ កាន់ដាវ ធ្វើនូវការរក្សា ការគិតទាក់ទងដោយរាគៈ ក្នុងបុរសទាំងឡាយ មិនកើតឡើងដល់ព្រះមាតារបស់ព្រះពោធិសត្វ ព្រះនាងដល់នូវភាពប្រសើរដោយលាភ និងប្រសើរដោយយស មានសេចក្តីសុខ មានព្រះវរកាយមិនលំបាក និងទតឃើញព្រះពោធិសត្វដែលនៅខាងក្នុងគភ៌ ដូចសរសៃអំបោះពណ៌លឿង ដែលដោតក្នុងកែវមណី ដូច្នោះ ព្រោះហេតុដែលគភ៌ដែលព្រះពោធិសត្វនៅ ដូចគ្នានឹងបន្ទប់ក្នុងចេតិយ សត្វដទៃមិនអាចនៅ ឬប្រើប្រាស់បាន ព្រោះហេតុនោះ កាលព្រះពោធិសត្វប្រសូតបាន ៧ ថ្ងៃ ព្រះមាតារបស់ព្រះពោធិសត្វ ក៏សោយព្រះទិវង្គត ទៅកើតក្នុងតុសិតបុរី ។ ស្រីដទៃៗ មិនគ្រប់ ១០ ខែប្រសូតខ្លះ ហួសទៅ ប្រសូតខ្លះ អង្គុយប្រសូតខ្លះ ដេកប្រសូតខ្លះ យ៉ាងណា មាតារបស់ព្រះពោធិសត្វ មិនដូច្នោះឡើយ ។ ព្រះមាតារបស់ព្រះពោធិសត្វ ថែព្រះពោធិសត្វដោយគភ៌ អស់ ១០ ខែ ហើយប្រថាប់ឈរប្រសូត នេះជាធម្មតារបស់មាតានៃព្រះពោធិសត្វ ។

ឯព្រះនាងមហាមាយាទេវី បរិហារព្រះពោធិសត្វដោយគភ៌អស់ ១០

ខែ ដូចរក្សាប្រេងដោយបាត្រ កាលព្រះគភ៌ចាស់គ្រប់កំណត់ហើយ ព្រះនាងមានបំណងយាងទៅកាន់ផ្ទះញាតិ ទើបក្រាបទូលដល់ព្រះបាទសុទ្ធោទនមហារាជថា បពិត្រសម្មតិទេព ខ្ញុំម្ចាស់ប្រាថ្នានឹងទៅកាន់ទេវទហនគរ ដែលជារបស់ត្រកូល ។ ព្រះបាទសុទ្ធោទនមហារាជ ទ្រង់ទទួលថា សាធុ ហើយត្រាស់ឲ្យធ្វើផ្លូវអំពីនគរកបិលពស្ដុ រហូតដល់នគរទេវទហៈឲ្យរាបស្មើ ឲ្យប្រដាប់ដោយគ្រឿងប្រដាប់ មានដើមចេក ក្អមដែលមានទឹកពេញ ទង់ជ័យ និងទង់ផ្កាលាជាដើម ឲ្យព្រះទេវីគង់ប្រថាប់ក្នុងវិមាស ឲ្យអមាត្យ ១០០០ នាក់ សែងបញ្ជូនទៅដោយបរិវារសន្ធឹកសន្ធាប់ ។ ក្នុងចន្លោះនគរទាំង ២ មានព្រៃសាលវ័នដែលជាមង្គល ឈ្មោះលុម្ពិនីវ័ន ជាទីសម្រាករបស់អ្នកនគរទាំង ២ ។ សម័យនោះ ព្រៃសាលវ័នទាំងមូល មានផ្ការីកតជាប់គ្នាតាំងអំពីគល់ រហូតដល់ចុងមែក តាមចន្លោះមែក និងចន្លោះផ្កា មានពួកភមរ ៥ ពណ៌ និងពួកបក្សីច្រើនប្រការ យំដោយសំឡេងដ៏ពីរោះ លុម្ពិនីវ័នទាំងមូល ដូចចិត្តលតាវ័ន ហាក់បីដូចទីលានសម្រាប់ផឹក ដែលគេរៀបចំយ៉ាងល្អសម្រាប់ព្រះរាជាដែលមានអានុភាពច្រើន ។ ព្រះទេវីទតឃើញដូច្នោះកើតនូវបំណងចង់លេងក្នុងសាលវ័ន ។ អមាត្យទាំងឡាយ ក៏នាំព្រះទេវីចូលទៅកាន់សាលវ័ន ។ ព្រះនាងយាងចូលទៅកាន់គល់សាលព្រឹក្ស ដែលជាមង្គលហើយ មានបំណងនឹងចាប់មែកសាលព្រឹក្សៗ ក៏ទោរទន់មកដល់ព្រះហស្ដរបស់ព្រះទេវី ដូចចុងផ្ដៅដែលរោលភ្លើងជុំវិញ ដូច្នោះ ។ ព្រះនាងទ្រង់លាព្រះហស្ដ ចាប់មែកសាលព្រឹក្ស ។ ខណៈនោះឯង ខ្យល់កម្មជវាតរបស់

ព្រះទេវីក៏បក់ឡើង លំដាប់នោះ មហាជនក៏ចាំងវាំងននដើម្បីព្រះនាង ហើយក៏ថយចេញទៅ ព្រះនាងទ្រង់ឈរចាប់មែកសាលព្រឹក្សនោះឯង បានប្រសូតហើយ ។

ក្នុងខណៈនោះឯង មហាព្រហ្មអ្នកមានចិត្តបរិសុទ្ធ ៤ អង្គ កាន់នូវបណ្តាញមាសមកដល់ មហាព្រហ្មទាំងនោះយកបណ្តាញមាសនោះទទួលព្រះពោធិសត្វ ដាក់ក្នុងទីចំពោះព្រះភក្ត្ររបស់មាតា ទូលថា បពិត្រព្រះទេវី សូមព្រះនាងត្រេកអរចុះ ព្រះរាជបុត្រមានសក្តិធំកើតឡើងសម្រាប់ព្រះនាងហើយ ។ ធម្មតាសត្វដទៃចេញអំពីផ្ទៃមាតា រមែងប្រឡាក់ដោយវត្ថុបដិកូលមិនស្អាត ប្រសូតមក យ៉ាងណា ព្រះពោធិសត្វ មិនមែនដូច្នោះឡើយ ព្រះពោធិសត្វនោះ សណ្តូកដៃ និងជើងទាំង ២ ហើយឈរបានមួយរំពេច ដូចធម្មកថិកចុះអំពីធម្មាសនៈ និងដូចបុរសចុះអំពីជណ្តើរ មិនប្រឡាក់ដោយរបស់មិនស្អាតណាមួយដែលមាននៅក្នុងគភ៌របស់មាតា ជាអ្នកស្អាតបរិសុទ្ធរុងរឿង ដូចកែវមណីដែលគេដាក់លើសំពត់កាសិកភស្ត្រ ដូច្នោះ ប្រសូតចាកគភ៌ព្រះមាតា ។ កាលបើដូច្នោះ ដើម្បីធ្វើសក្ការៈព្រះពោធិសត្វ និងព្រះមាតារបស់ព្រះពោធិសត្វ ធ្លារទឹក ២ ខ្សែ ក៏ហូរអំពីអាកាស ស្រពស្រង់ព្រះវរកាយរបស់ព្រះពោធិសត្វ និងព្រះមាតារបស់ព្រះពោធិសត្វឲ្យកក់ក្តៅសប្បាយ ។

លំដាប់នោះ ទេវមហារាជទាំង ៤ បានទទួលព្រះពោធិសត្វនោះអំពីដៃរបស់មហាព្រហ្ម ដែលឈរយកបណ្តាញមាសទទួល ដោយកម្រាល

ដែលធ្វើដោយស្បែកខ្លាបន្ទន់ ដែលមានសម្ផស្សទន់ ដែលគេសន្មតថាជាមង្គល បន្ទាប់មក ពួកមនុស្សយកសំពត់ទុកូលពស្ត្រ ទទួលអំពីដៃរបស់មហារាជទាំងនោះ លុះផុតអំពីដៃរបស់ពួកមនុស្ស ព្រះពោធិសត្វ ក៏ប្រថាប់ឈរលើផែនដី ទតមើលទិសខាងកើត ចក្កវាឡច្រើនពាន់ ហាក់ដូចជាប់គ្នាជាលានតែមួយ ទេវតា និងមនុស្សទាំងឡាយក្នុងទីនោះ នាំគ្នាបូជាដោយគ្រឿងក្រអូប និងកម្រងផ្កាជាដើម ពោលថា បពិត្រមហាបុរស អ្នកដទៃដែលស្មើដូចទ្រង់ ក្នុងលោកនេះ មិនមាន តើបុគ្គលដែលក្រៃលែងជាងព្រះអង្គនឹងមានមកអំពីណា ព្រះពោធិសត្វសម្លឹងមើលរហូតទាំង ១០ ទិស គឺទិសធំ ៤ ទិសតូច ៤ ទិសខាងក្រោម និងទិសខាងលើ ដោយប្រការដូច្នេះហើយ ទ្រង់មិនឃើញបុគ្គលណាមួយដែលស្មើនឹងព្រះអង្គ ទ្រង់ព្រះតម្រិះថា នេះជាទិសខាងជើង ទើបឈានព្រះបាទទៅ ៧ ជំហាន ដែលមានមហាព្រហ្មបាំងស្វេតច្ឆត្រ ស្តេចសុយាមកាន់ផ្លិតវាលវីជនី ទេវតាដទៃៗកាន់គ្រឿងរាជកកុធភណ្ឌដ៏សេសដើរតាម ។ បន្តអំពីនោះ ព្រះពោធិសត្វប្រថាប់ឈរត្រង់ជំហានទី ៧ បន្លឺសីហនាទ គឺអាសភិវាចាជាដើមថា យើងជាកំពូលនៃលោក ដូច្នេះ ។

ពិតហើយ ព្រះពោធិសត្វប្រសូតចាកគភ៌នៃព្រះមាតាប៉ុណ្ណោះ បន្លឺនូវវាចាបាន ក្នុង ៣ អត្តភាព គឺក្នុងអត្តភាពជាមហោសថ ១ អត្តភាពជាព្រះវេស្សន្តរ ១ និងអត្តភាពនេះ ១ ។

បានឮថា ក្នុងអត្តភាពជាមហោសថ កាលព្រះពោធិសត្វនោះ កំពុង

ប្រសូតចាកគភ៌មាតានោះឯង សក្កទេវរាជយាងមកដាក់ខ្លឹមចន្ទន៍ក្នុងដៃ រួចយាងទៅ ព្រះពោធិសត្វក្តាប់ខ្លឹមចន្ទន៍នោះហើយ ទើបប្រសូត ។ កាលនោះ មាតាសួរព្រះពោធិសត្វនោះថា នែកូន កូនកាន់អ្វី ព្រះពោធិសត្វពោលថា ឱសថ ព្រោះហេតុនោះ ទើបមាតាបិតាដាក់ឈ្មោះថា ឱសថកុមារ ព្រោះកាន់យកថ្នាំមក ។ មាតាបិតាយកឱសថនោះដាក់ក្នុងថ្លាង ឱសថនោះឯង បានជាថ្នាំព្យាបាលរោគសព្វយ៉ាងដល់មនុស្សខ្វាក់ មនុស្សថ្លង់ជាដើមដែលមករក ។ តមក ព្រោះពាក្យដែលពោលថា ថ្នាំនេះមានគុណច្រើន ថ្នាំនេះមានគុណច្រើន ទើបកើតឈ្មោះថា មហោសថ ។

ឯក្នុងអត្តភាពជាព្រះវេស្សន្តរ ព្រះពោធិសត្វកាលប្រសូតចាកព្រះគភ៌មាតា ទ្រង់លាព្រះហស្តស្តាំ ហើយត្រាស់ថា បពិត្រមាតា ទ្រព្យក្នុងផ្ទះមានដែរឬទេ ខ្ញុំនឹងឲ្យទាន ។ លំដាប់នោះ មាតារបស់ព្រះពោធិសត្វត្រាស់ថា អើកូន កូនកើតក្នុងត្រកូលមានទ្រព្យ ទើបឲ្យព្រះរាជឱរសដាក់ដៃលើដៃព្រះនាង ហើយឲ្យដាក់ថង់ទ្រព្យ ១០០០ ។

ឯក្នុងអត្តភាពនេះ ព្រះពោធិសត្វបន្លឺសីហនាទនេះ ។ ព្រះពោធិសត្វប្រសូតចាកគភ៌ព្រះមាតាប៉ុណ្ណោះ ទ្រង់និយាយបានក្នុងអត្តភាពទាំង ៣ ដោយប្រការដូចពណ៌នាមកនេះ ។

ក្នុងខណៈដែលព្រះពោធិសត្វប្រសូត បុព្វនិមិត្ត ៣២ ប្រការ ក៏ប្រាកដឡើង ដូចក្នុងខណៈបដិសន្ធិដែរ ក្នុងខណៈដែលព្រះពោធិសត្វនៃយើងទាំងឡាយប្រសូតក្នុងលុម្ពិនីវ័ននោះឯង មានវត្ថុដែលកើតព្រម ( សហជាត ) ៧

យ៉ាង គឺព្រះទេវីមាតាព្រះរាហុល ១ ព្រះអានន្ទត្ថេរ ១ ឆន្នអមាត្យ ១ កាឡុទាយិអមាត្យ ១ កណ្ឋកអស្សរាជ ១ មហាពោធិព្រឹក្ស ១ កំណប់ទ្រព្យទាំងបួន ១ ។ ក្នុងកំណប់ទ្រព្យទាំង ៤ នោះ កំណប់ទ្រព្យរណ្តៅទី ១ មានទំហំ ១ គាវុត កំណប់ទ្រព្យរណ្តៅទី ២ មានទំហំកន្លះយោជន៍ កំណប់ទ្រព្យរណ្តៅទី ៣ មានទំហំ ៣ គាវុត កំណប់ទ្រព្យរណ្តៅទី ៤ មានទំហំ ១ យោជន៍ ជម្រៅទល់គ្នានឹងទឹកទ្រផែនដីនោះឯង ។

អ្នកនគរទាំង ២ បាននាំព្រះពោធិសត្វ ត្រឡប់ទៅកាន់នគរកបិលពស្តុវិញ ។ ក្នុងថ្ងៃនោះឯង ទេវតាទាំងឡាយក្នុងស្ថានតាវត្តិង្សត្រេកអរថា ព្រះរាជបុត្ររបស់ព្រះបាទសុទ្ធោទនមហារាជ ក្នុងនគរកបិលពស្តុប្រសូតហើយ ព្រះរាជកុមារនេះនឹងអង្គុយត្រង់មណ្ឌលពោធិព្រឹក្ស ហើយនឹងបានត្រាស់ជាព្រះពុទ្ធ ទើបនាំគ្នាគ្រវីសំពត់ជាដើមលេងយ៉ាងសប្បាយ ។

សម័យនោះ តាបសឈ្មោះកាលទេវិល ដែលស្និទស្នាលនឹងរាជត្រកូលរបស់ព្រះបាទសុទ្ធោទនមហារាជ ជាអ្នកបាននូវសមាបត្តិ ៨ ធ្វើភត្តកិច្ចហើយ ទៅកាន់ស្ថានតាវត្តិង្សពិភព ដើម្បីសម្រាកពេលថ្ងៃ អង្គុយសម្រាកពេលថ្ងៃ ក្នុងស្ថានតាវត្តិង្សពិភពនោះ ឃើញទេវតាទាំងនោះលេងសប្បាយយ៉ាងនោះ ទើបសួរថា ព្រោះហេតុអ្វី ទើបអ្នកទាំងឡាយត្រេកអរ លេងសប្បាយយ៉ាងនេះ សូមប្រាប់ហេតុនោះដល់អាត្មាផង ។ ទេវតាទាំងឡាយពោលថា បពិត្រលោកនិទ្ទុក្ខ ព្រះរាជបុត្ររបស់ព្រះបាទសុទ្ធោទនមហារាជប្រសូតហើយ ព្រះរាជបុត្រនោះ នឹងអង្គុយត្រង់ពោធិមណ្ឌល បានជាព្រះ

សម្ពុទ្ធ ប្រកាសធម្មចក្រ ពួកយើងនឹងបានឃើញពុទ្ធលីលា ដែលប្រមាណ មិនបានរបស់ព្រះអង្គ នឹងបានស្តាប់ធម៌ ព្រោះហេតុនោះ ទើបពួកយើងទាំងឡាយត្រេកអរដោយហេតុនេះ ។ តាបសបានស្តាប់ពាក្យរបស់ទេវតាទាំងនោះហើយ ក៏ប្រញាប់ចុះអំពីទេវលោក ចូលទៅកាន់រាជនិវេសន៍ អង្គុយលើអាសនៈដែលគេក្រាល ទូលសួរថា បពិត្រមហារាជ បានឮថា រាជបុត្ររបស់ព្រះអង្គប្រសូតហើយ អាត្មាចង់ឃើញព្រះរាជបុត្រនោះ ។ ព្រះរាជាទ្រង់ឲ្យនាំព្រះរាជកុមារដែលតាក់តែងហើយមក ពទៅដើម្បីឲ្យថ្វាយបង្គំតាបស ។ ព្រះបាទទាំង ២ របស់ព្រះពោធិសត្វបែរជាទៅប្រតិស្ឋានលើជដារបស់តាបស ។ ពិតហើយ មិនមានបុគ្គលដទៃណាដែលព្រះពោធិត្រូវថ្វាយបង្គំ ក្នុងព្រះអត្តភាពនោះ ព្រោះថា បើបុគ្គលមិនដឹង គប្បីដាក់ព្រះសិរសារបស់ព្រះពោធិសត្វ ទៀបបាទមូលរបស់តាបស ក្បាលរបស់តាបសនោះនឹងបែកជា ៧ ភាគ ។

តាបសគិតថា អញមិនគួរធ្វើខ្លួនរបស់អញឲ្យវិនាស ទើបក្រោកចាកអាសនៈ ផ្គងអញ្ជលីថ្វាយបង្គំព្រះពោធិសត្វ ។ ព្រះរាជាទ្រង់ឃើញភាពអស្ចារ្យនោះ ទ្រង់ក៏ថ្វាយបង្គំព្រះរាជបុត្ររបស់ព្រះអង្គ ។

តាបសរឭកជាតិបាន ៨០ កប្ប គឺក្នុងអតីត ៤០ កប្ប ក្នុងអនាគត ៤០ កប្ប ឃើញលក្ខណសម្បត្តិរបស់ព្រះពោធិសត្វហើយ គិតថា បុរសនេះ នឹងបានជាព្រះពុទ្ធពិតឬហ្ន៎ កាលពិចារណាមើលក៏ដឹងថា នឹងបានត្រាស់ជាព្រះពុទ្ធដោយឥតសង្ស័យ ទើបញញឹមឲ្យឃើញ ដើម្បីឲ្យដឹងថា ព្រះ

រាជបុត្រនេះ ជាអច្ឆរិយបុរស ។ បន្ទាប់អំពីនោះ ទើបពិចារណាថា អាត្មាអញនឹងបានឃើញអច្ឆរិយបុរសនេះត្រាស់ជាព្រះពុទ្ធឬទេហ្ន៎ បានឃើញថា ខ្លួនមិនអាចទាន់ នឹងស្លាប់មុននោះឯង កើតក្នុងអរូបភព ដែលព្រះពុទ្ធ ១០០ អង្គក្តី ១០០០ អង្គក្តី មិនអាចយាងទៅប្រោសឲ្យត្រាស់ដឹងបាន គិតថា អញមិនបានឃើញអច្ឆរិយបុរសបែបនេះ ត្រាស់ជាព្រះពុទ្ធ អាត្មាអញវិនាសធំហ្ន៎ ទើបទ្រហោយំ ។

មនុស្សទាំងឡាយឃើញហើយ ទើបសាកសួរថា លោកម្ចាស់របស់ពួកយើងសើចអម្បាញ់មិញសោះ បែរជាយំទៅវិញ បពិត្រលោកម្ចាស់ អន្តរាយណាមួយ នឹងមានដល់អយ្យបុត្ររបស់ពួកយើងឬ តាបសប្រាប់ថា ព្រះរាជបុត្រនេះមិនមានអន្តរាយ នឹងបានត្រាស់ជាព្រះពុទ្ធដោយឥតសង្ស័យ ។ ទើបមនុស្សទាំងឡាយសាកសួរថា បពិត្រលោកម្ចាស់ បើដូច្នោះ ព្រោះហេតុអ្វី ទើបលោកម្ចាស់យំ តាបសប្រាប់ថា ខ្ញុំអាណិតខ្លួនថា មិនបានឃើញមហាបុរសនេះត្រាស់ជាព្រះពុទ្ធ ខ្ញុំមានសេចក្តីវិនាសដ៏ធំហ្ន៎ ទើបយំ ។

លំដាប់នោះ ទើបតាបសពិចារណាថា បណ្តាពួកញាតិរបស់អាត្មាអញ ញាតិណាមួយ នឹងបានទាន់បុរសនេះត្រាស់ជាព្រះពុទ្ធឬទេហ្ន៎ ក៏បានឃើញនាលកទារក ជាក្មួយរបស់ខ្លួន ទើបលោកទៅកាន់ផ្ទះរបស់ប្អូនស្រី ហើយសួរថា នាលកៈ កូនរបស់នាងនៅឯណា ប្អូនស្រីឆ្លើយថា បពិត្រលោកម្ចាស់ គេនៅក្នុងផ្ទះ តាបសពោលថា ចូរហៅមក ។ កាលហៅមកហើយ ទើបពោលនឹងកុមារ ដែលមកកាន់សម្នាក់របស់ខ្លួនថា នែក្មួយប្រុស ព្រះ

រាជបុត្រប្រសូតក្នុងរាជត្រកូលរបស់ព្រះបាទសុទ្ធោទនមហារាជ ព្រះរាជបុត្រនោះ ជាពូជពន្ធកនៃព្រះពុទ្ធ កន្លងទៅបាន ៣៥ ឆ្នាំ នឹងបានត្រាស់ជាព្រះពុទ្ធ ក្មួយនឹងទាន់ទ្រង់ ចូរក្មួយបួសក្នុងថ្ងៃនេះឯង ។

ឯទារកកើតក្នុងត្រកូលមានទ្រព្យ ៨៧ កោដិ គិតថា លោកអ៊ំ នឹងមិនដឹកនាំអញ ក្នុងវត្ថុដែលមិនមានប្រយោជន៍ រំពេចនោះឯង ទើបឲ្យមនុស្សទៅទិញសំពត់កាសាវពស្ត្រ និងបាត្រដីមកអំពីផ្សារ ហើយកោរសក់ និងពុកមាត់ ស្លៀកដណ្តប់សំពត់កាសាវៈ ផ្គងអញ្ជលី បែរមុខទៅរកព្រះពោធិសត្វ ពោលថា ខ្ញុំបួសឧទ្ទិសឧត្តមបុរសក្នុងលោក ដូច្នេះហើយ ក្រាបថ្វាយបង្គំដោយបញ្ចង្គប្រតិស្ឋាន យកបាត្រដាក់ក្នុងស្ពាយ ពាក់ត្រង់ចង្កេះស្មា ចូលព្រៃហិមពាន្ត បំពេញសមណធម៌ ។

នាលកៈនោះ ចូលទៅគាល់ព្រះតថាគត ដែលបានសម្រេចបរិមាភិសម្ពោធិញ្ញាណហើយ សូមឲ្យត្រាស់នាលកបដិបទា ហើយត្រឡប់ចូលព្រៃហិមពាន្តវិញ សម្រេចអរហត្តហើយ សូមឲ្យព្រះមានព្រះភាគត្រាស់នាលកបដិបទា ហើយត្រឡប់ចូលព្រៃហិមពាន្តវិញ សម្រេចអរហត្តហើយ បដិបត្តិបដិបទាយ៉ាងឧក្រិដ្ឋ រក្សាជីវិតបាន ៧ ខែប៉ុណ្ណោះ ឈរផ្អែកភ្នំមាស ១ បរិនិព្វានហើយ ដោយអនុបាទិសេសនិព្វានធាតុ ។

ក្នុងថ្ងៃទី ៥ ព្រះញាតិទាំងឡាយ ឲ្យព្រះពោធិសត្វ ស្រពស្រង់កក់សិរសា គិតថា នឹងថ្វាយព្រះនាម ទើបឲ្យបូកលាបព្រះរាជមន្ទីរ ដោយគន្ធជាតិ ៤ ប្រភេទ រោយនូវផ្កា មានលាជជាគម្រប់ ៥ ឲ្យរៀបចំបាយាស

សុទ្ធៗ ហើយអញ្ជើញពួកព្រាហ្មណ៍ ១០៨ នាក់ ដែលរៀនចប់ត្រៃវេទ ឲ្យអង្គុយក្នុងព្រះរាជមន្ទីរ ឲ្យឆាន់បណិតភោជន ធ្វើសក្ការៈយ៉ាងច្រើន ហើយឲ្យទាយព្រះលក្ខណៈថា អ្វីនឹងកើតមានហ្ន៎ ។ បណ្តាព្រាហ្មណ៍ទាំងនោះ

កាលនោះ ព្រាហ្មណ៍ ៨ នាក់ គឺរាមព្រាហ្មណ៍ ១ ធជព្រាហ្មណ៍ ១ លក្ខណព្រាហ្មណ៍ ១ មន្តីព្រាហ្មណ៍ ១ យញ្ញព្រាហ្មណ៍ ១ សុភោជព្រាហ្មណ៍១ សុយាមព្រាហ្មណ៍ ១ សុទត្តព្រាហ្មណ៍ ១ ជាអ្នកចប់វេទង្គសាស្ត្រ មានអង្គ ៦ បានព្យាករដោយមន្តហើយ ។

ព្រាហ្មណ៍ ៨ នាក់នេះប៉ុណ្ណោះ បានជាអ្នកទាយលក្ខណៈ ។ ព្រាហ្មណ៍ទាំង ៨ នោះ បានទាយសុបិន្តក្នុងថ្ងៃបដិសន្ធិផងដែរ ។ បណ្តាពួកព្រាហ្មណ៍ទាំង ៨ នោះ ៧ នាក់ លើកម្រាម ២ ទាយព្រះពោធិសត្វជា ២ ផ្លូវថា បុគ្គលប្រកបដោយលក្ខណៈទាំងនេះ បើនៅគ្រប់គ្រងផ្ទះ នឹងបានជាស្តេចចក្រពត្តិ បើបួស នឹងបានជាព្រះពុទ្ធ ហើយប្រាប់សិរិសម្បត្តិរបស់ស្តេចចក្រពត្តិទាំងអស់ ។ តែមាណពឈ្មោះកោណ្ឌញ្ញៈដោយគោត្រ ក្មេងជាងពួកព្រាហ្មណ៍ទាំងអស់ ពិនិត្យមើលលក្ខណសម្បត្តិដ៏ប្រសើររបស់ព្រះពោធិសត្វហើយ លើកម្រាម ១ ព្យាករដោយផ្លូវ ១ ប៉ុណ្ណោះថា ព្រះរាជកុមារ នេះមិនមានហេតុដែលនៅគ្រប់គ្រងផ្ទះ ព្រះរាជកុមារនេះនឹងបានត្រាស់ជាព្រះពុទ្ធមានកិលេសដូចដំបូលបើកហើយ ដោយចំណែកមួយ ។ កោណ្ឌញ្ញមាណពនេះ បានធ្វើបុញ្ញាធិការ ជាសត្វកើតក្នុងភពចុងក្រោយ មានបញ្ញាក្រៃលែង

ជាងជនទាំង ៧ ក្រៅអំពីនេះ បានឃើញគតិ ១ ប៉ុណ្ណោះ ពោល គឺព្រះពោធិសត្វដែលប្រកបដោយលក្ខណៈទាំងនេះ នឹងបានត្រាស់ជាព្រះពុទ្ធដោយពិតប្រាកដ ព្រោះហេតុនោះ ទើបលើកម្រាម ១ ហើយព្យាករយ៉ាងនោះ ។ លំដាប់នោះ ព្រាហ្មណ៍ទាំងឡាយ កាលថ្វាយព្រះនាមរបស់ព្រះពោធិសត្វ ព្រាហ្មណ៍ទាំងឡាយថ្វាយព្រះនាមថា សិទ្ធត្ថៈ ព្រោះជាបុគ្គលធ្វើឲ្យសម្រេចសេចក្ដីត្រូវការដល់លោកទាំងពួង ។

តមក ព្រាហ្មណ៍ទាំងនោះ ត្រឡប់ទៅកាន់ផ្ទះរៀងៗ ខ្លួន ហៅកូនមកប្រាប់ថា នែបាទាំងឡាយ ឪពុកជាមនុស្សចាស់ នៅមិនទាន់ព្រះរាជបុត្រនៃព្រះបាទសុទ្ធោទនមហារាជសម្រេចសព្វញ្ញុតញ្ញាណ ឬក៏មិនទាន់ឡើយ កាលបើព្រះរាជកុមារនោះ សម្រេចសព្វញ្ញុតញ្ញាណហើយ ពួកបាគប្បីបួសក្នុងសម្នាក់របស់ព្រះអង្គ ។ ព្រាហ្មណ៍ទាំង ៧ នាក់នោះ រស់នៅដរាបដល់អាយុក្ខយ្យ ហើយបានស្លាប់ទៅតាមយថាកម្ម កោណ្ឌញ្ញមាណពប៉ុណ្ណោះជាអ្នកមិនមានរោគ គឺនៅមានជីវិត ។

កាលព្រះមហាសត្វទ្រង់ចម្រើនវ័យ យាងចេញមហាភិនេស្រ្កមណ៍ហើយ ទ្រង់យាងដល់ឧរុវេលាប្រទេសដោយលំដាប់ ទ្រង់ព្រះតម្រិះថា ភូមិភាគនេះ គួរត្រេកអរពិតហ្ន៎ ទីនេះ សមគួរបំពេញព្យាយាមនៃកុលបុត្រអ្នកត្រូវការបំពេញព្យាយាម ទើបគង់នៅក្នុងទីនោះ កោណ្ឌញ្ញមាណព បានដំណឹងថា មហាបុរសបួសហើយ ក៏ចូលទៅរក កូនព្រាហ្មណ៍ទាំងនោះពោលយ៉ាងនេះថា បានឮថា ព្រះសិទ្ធត្ថកុមារបួសហើយ ទ្រង់បានជាព្រះពុទ្ធ

ដោយឥតសង្ស័យ បើឪពុករបស់អ្នកទាំងឡាយ នៅមានជីវិត ក៏គង់បួសក្នុងថ្ងៃនេះ បើអ្នកទាំងឡាយប្រាថ្នា ចូរមក ពួកយើងនឹងបួសតាមមហាបុរសនោះ ។ ពួកជនទាំងនោះ មិនអាចមានធុរៈតែមួយបាន បណ្ដាជនទាំង ៧ នាក់នោះ ៣ នាក់ មិនបួស ៤ នាក់ ចេញបួស ដោយតាំងឲ្យកោណ្ឌញ្ញព្រាហ្មណ៍ជាប្រធាន ទើបព្រាហ្មណ៍ទាំង ៥ នោះ មានឈ្មោះថា បញ្ចវគ្គិយត្ថេរ ។ ក្នុងកាលនោះ ព្រះបាទសុទ្ធោទនៈត្រាស់សួរថា បុត្ររបស់យើងឃើញអ្វី ទើបចេញបួស ពួកអមាត្យក្រាបទូលថា ឃើញបុព្វនិមិត្ត ៤ យ៉ាង ។ ព្រះរាជាត្រាស់សួរថា បុព្វនិមិត្តអ្វីខ្លះ ពួកអមាត្យក្រាបទូលថា មនុស្សចាស់ មនុស្សឈឺ មនុស្សស្លាប់ និងបព្វជិត ព្រះរាជាត្រាស់ថា ចាប់ពីនេះទៅ ពួកអ្នកកុំឲ្យមនុស្សបែបនេះ ចូលទៅកាន់សម្នាក់កូនរបស់យើង កូនរបស់យើង មិនត្រូវការឲ្យបានជាព្រះពុទ្ធ យើងចង់ឃើញកូនរបស់យើង គ្រប់គ្រងសម្បត្តិចក្រពត្តិ ដែលជាឥស្សរិយាធិបតីក្នុងទ្វីបទាំង ៤ មានទ្វីបតូច ២ ពាន់ជាបរិវារ ចោមរោមដោយបរិស័ទដែលមានបរិមណ្ឌល ៣៦ យោជន៍ ត្រាច់ទៅក្នុងអាកាស កាលត្រាស់យ៉ាងនេះហើយ ដើម្បីហាមឃាត់មិនឲ្យបុព្វនិមិត្តទាំង ៤ ប្រការនេះ មកកាន់គន្លងចក្ខុរបស់ព្រះរាជកុមារ ទើបទ្រង់តាំងការរក្សា គ្រប់គាវុត ក្នុងទិសទាំង ៤ ។

ថ្ងៃនោះ កាលត្រកូលញាតិ ៨ ម៉ឺន ប្រជុំគ្នាក្នុងមង្គលដ្ឋាន ព្រះញាតិនីមួយៗ បានអនុញ្ញាតបុត្រម្នាក់ៗ ថា រាជកុមារនេះ បានជាព្រះពុទ្ធក្តី ជា ស្ដេចក្តី ពួកយើងនឹងឲ្យកូនម្នាក់មួយ បើបានជាព្រះពុទ្ធ នឹងមានពួក

ខត្តិយសមណៈចោមរោមត្រាច់ទៅ បើបានជាស្តេច នឹងមានខត្តិយកុមារចោមរោមអំពីខាងមុខ ខាងក្រោយ ត្រាច់ទៅ ។ ឯព្រះរាជា ទ្រង់ក៏តាំងស្នំដែលប្រាសចាករោគ សម្បូរដោយរូបបលក្ខណៈដ៏ឧត្តមសម្រាប់ព្រះពោធិសត្វៗ ចម្រើនដោយបរិវារធំ ដោយសិរីធំក្រៃលែង ។

ថ្ងៃមួយ ព្រះរាជាទ្រង់មានព្រះរាជពិធីឈ្មោះថា វប្បមង្គល គឺពិធីច្រត់ព្រះនង្គ័ល ។ ថ្ងៃនោះ មហាជននាំគ្នាប្រដាប់តាក់តែងនគរទាំងមូល ដូចទេវនគរ ជនទាំងអស់ មានទាសៈ និងកម្មករជាដើម ស្លៀកដណ្តប់សំពត់ថ្មីប្រដាប់ដោយគ្រឿងក្រអូប និងកម្រងផ្កាជាដើម ប្រជុំគ្នាក្នុងរាជត្រកូល ទឹមនង្គ័ល ១០០០ ក្នុងរាជពិធី ។ ក្នុងថ្ងៃនោះ នង្គ័ល ១០៨ ខ្វះ ១ មួយអន្ទើដោយគោ ខ្សែទឹម និងខ្សែប្រស្រោបដោយប្រាក់ ឯនង្គ័លដែលព្រះរាជាទ្រង់កាន់ ស្រោបដោយមាស ។ សូម្បីស្នែងគោ ខ្សែទាម និងជន្ទួញ ក៏ស្រោបដោយមាសទាំងអស់ ។

ព្រះរាជាយាងចេញដោយបរិវារធំ ទ្រង់នាំព្រះរាជបុត្រទៅផង ក្នុងទីដែលប្រកបដោយព្រះរាជពីធី មានដើមព្រីងមួយ មានស្លឹកក្រាស់ មានម្លប់ត្រឈឹងត្រឈៃ ។ ព្រះរាជាឲ្យក្រាលទីបន្ទំរបស់រាជកុមារក្រោមដើមព្រីងនោះឲ្យបងពិតាន រំលេចដោយផ្កាយមាសអំពីខាងលើ ឲ្យបាំងរបង គឺរាំងននរៀបចំការរក្សាស្រេចហើយ ទ្រង់ប្រដាប់គ្រឿងរាជអលង្ការទាំងពួង ចោមរោមដោយពួកអមាត្យ យាងដល់ទីច្រត់ព្រះនង្គ័ល ក្នុងទីនោះ ព្រះរាជាទ្រង់កាន់ព្រះនង្គ័លមាស អមាត្យទាំងឡាយកាន់នង្គ័លប្រាក់ ១០៧ ពួក អ្នកស្រែ

កាន់នូវទង្គ័លដ៏សេស ពួកជនទាំងនោះ បានក្ជួរទៅដោយជុំវិញ ចំណែកព្រះរាជាទ្រង់ក្ជួរគន្ទងខាងក្នុង ទៅកាន់គន្ទងខាងក្រៅ ក្ជួរគន្ទងខាងក្រៅទៅកាន់គន្ទងខាងក្នុង ។ កើតមានភាពអស្ចារ្យជំក្នុងទីនោះ ។ ពួកស្រីស្នំដែលអង្គុយចោមរោមព្រះពោធិសត្វគិតថា ពួកយើងនឹងទៅមើលភាពជាធំរបស់ព្រះរាជា ក៏ចេញពីវាំងននទៅខាងក្រៅ ។

ព្រះពោធិសត្វ ទ្រង់សម្លឹងមើលដោយជុំវិញ មិនឃើញបុគ្គលណាមួយ ទើបក្រោកឡើងដោយរហ័ស អង្គុយពត់ភ្នែន កំណត់ខ្យល់ដង្ហើមចូល ខ្យល់ដង្ហើមចេញ ធ្វើបឋមជ្ឈានឲ្យកើតឡើងហើយ ។ ពួកស្រីស្នំត្រាច់លេងក្នុងចន្លោះពេលបរិភោគនូវអាហារ ទើបយឺតយូរបន្តិច ។ ស្រមោលរបស់ដើមឈើដ៏សេសជ្រេទៅ តែស្រមោលរបស់ដើមព្រីងនោះ តាំងនៅជាបរិមណ្ឌលត្រង់នោះ ។ ពួកស្រីស្នំគិតថា អយ្យបុត្រប្រថាប់នៅមួយអង្គឯង ទើបប្រញាប់លើកវាំងននឡើង ចូលទៅខាងក្នុង ឃើញព្រះពោធិសត្វ អង្គុយពត់ភ្នែនលើទីបន្ទំ និងឃើញបាដិហារ្យនោះ ក៏ទៅក្រាបទូលដល់ព្រះរាជាថា បពិត្រព្រះសម្មតិទេព ព្រះរាជកុមារប្រថាប់គង់យ៉ាងនេះ ។ ស្រមោលរបស់ដើមឈើដទៃៗ ជ្រេទៅ តែស្រមោលរបស់ដើមព្រីងតាំងនៅជាបរិមណ្ឌល ។ ព្រះរាជាប្រញាប់យាងមក ទ្រង់ឃើញបាដិហារ្យ ទើបថ្វាយបង្គំព្រះរាជឱរសដោយត្រាស់ថា នែបា នេះជាការថ្វាយបង្គំលើកទី ២ ។

តមក កាលព្រះពោធិសត្វមានព្រះជន្មាយុ ១៦ វស្សា ព្រះរាជាឲ្យសាងប្រាសាទ ៣ ដែលសមគួរដល់រដូវទាំង ៣ ដើម្បីព្រះពោធិសត្វ គឺមួយ

ខ្នង មាន ៩ ជាន់ មួយខ្នង មាន ៧ ជាន់ មួយខ្នង មាន ៥ ជាន់ និងឲ្យស្រីរបាំ ៤ ម៉ឺននាក់ចាំបម្រើ ។ ព្រះពោធិសត្វ កាលស្រីរបាំ ដែលប្រដាប់កាយយ៉ាងល្អចោមរោម ដូចទេវបុត្រដែលពួកទេពអប្សរចោមរោមបម្រើដោយតន្ត្រី មិនមានបុរសលាយឡំ សោយមហាសម្បត្តិ ក្នុងប្រាសាទទាំង ៣ តាមរដូវ ។ ចំណែកព្រះទេវីរាហុលមាតា បានជាអគ្គមហេសីរបស់ព្រះអង្គ ។

កាលទ្រង់សោយសម្បត្តិយ៉ាងនោះ ថ្ងៃមួយ មានការពោលឡើងក្នុងរវាងពួកញាតិដូច្នេះថា ព្រះសិទ្ធត្ថខ្វល់ខ្វាយតែក្នុងការលេងប៉ុណ្ណោះ មិនសិក្សាសិប្បៈណាមួយ បើមានចម្បាំងកំពងដល់ នឹងធ្វើដូចម្តេច ព្រះរាជាត្រាស់ឲ្យហៅព្រះពោធិសត្វមកហើយ ត្រាស់ថា នែបា ពួកញាតិរបស់កូន នាំគ្នានិយាយថា សិទ្ធត្ថកុមារមិនរៀនសូត្រសិប្បៈណាមួយ ត្រាច់ខ្វល់ខ្វាយតែក្នុងការលេង លុះមកដល់ពេលនេះ បានឹងគិតដូចម្តេច ។ ព្រះពោធិសត្វទូលថា បពិត្រព្រះសម្មតិទេព ទូលបង្គំមិនមានកិច្ចដែលត្រូវសិក្សាសិប្បៈ សូមទ្រង់ឲ្យគេវាយស្គរប្រកាសក្នុងព្រះនគរ ដើម្បីឲ្យមកមើលសិប្បៈរបស់ទូលបង្គំក្នុងថ្ងៃទី ៧ បន្ទាប់អំពីថ្ងៃនេះ ទូលបង្គំនឹងសម្តែងសិប្បសាស្ត្រដល់ពួកញាតិ ។ ព្រះរាជាបានធ្វើតាមនោះ ។ ព្រះពោធិសត្វឲ្យប្រជុំពួកខ្មាន់ធ្នូ ដែលបាញ់រហ័សដូចផ្លេកបន្ទោរ ដែលអាចបាញ់រោមទ្រាយបាន ហើយទ្រង់សម្តែងសិប្បៈទាំង ១២ ប្រភេទដល់ញាតិ ដែលជាសិប្បៈមិនទូទៅដល់ពួកខ្មាន់ធ្នូដទៃៗ ក្នុងកណ្តាលមហាជន ។ រឿងនោះ គប្បីជ្រាបតាមន័យដែលមានមក

ក្នុងសរកន្ធជាតកនោះឯង ។ កាលនោះ ពួកញាតិរបស់ព្រះអង្គ ក៏អស់សេចក្ដីសង្ស័យ ។

ថ្ងៃមួយ ព្រះពោធិសត្វមានបំណងយាងទៅកាន់ឧទ្យានភូមិ ទើបហៅនាយសារថីមកប្រាប់ថា ចូរអ្នកទឹមរថ ។ នាយសារថីនោះទទួលបញ្ជាហើយ រៀបចំរថដ៏ឧត្ដម ដែលមានតម្លៃច្រើន ដោយគ្រឿងប្រដាប់ទាំងពួង ទឹមដោយសេះសិន្ធពដែលជាមង្គល ៤ មានពណ៌ដូចត្របកផ្កាឈូកស ស្រេចបាច់ហើយ ទើបទូលដល់ព្រះពោធិសត្វឲ្យទ្រង់ជ្រាប ។ ព្រះពោធិសត្វឡើងកាន់រថ ដែលដូចគ្នានឹងទេវវិមាន បែរព្រះភក្ត្រទៅកាន់ឧទ្យាន ។ ទេវតាទាំងឡាយគិតថា កាលត្រាស់ដឹងព្រមរបស់ព្រះសិទ្ធត្ថកុមារ ជិតចូលមកដល់ហើយ ពួកយើងនឹងសម្ដែងបុព្វនិមិត្ត ទើបឲ្យទេវបុត្រមួយអង្គ ធ្វើជាមនុស្សចាស់ជរា មានធ្មេញបាក់ សក់ស្កូវ ខ្នងកោង មានរាងកាយឱនចុះកាន់ឈើច្រត់ដើរទ្រេតទ្រោត ។ ព្រះពោធិសត្វ និងនាយសារថី ក៏បានឃើញជនជរានោះ ។ លំដាប់នោះ ព្រះពោធិសត្វបានត្រាស់សួរនាយសារថីដោយន័យដែលមកក្នុងមហាបទានសូត្រថា នែសម្លាញ់ បុរសនោះ ឈ្មោះអ្វី សក់របស់គេមិនដូចជនដទៃ ដូច្នេះជាដើម ទ្រង់បានស្ដាប់ពាក្យរបស់នាយសារថីនោះហើយ គិតថា នែអ្នកដ៏ចម្រើន ការកើតនេះ គួរតិះដៀលពិតហ្ន៎ ព្រោះការចាស់ នឹងប្រាកដដល់សត្វដែលកើតហើយ ដូច្នេះ មានព្រះហឫទ័យសង្វេគ បានត្រឡប់អំពីទីនោះ ឡើងកាន់ប្រាសាទមួយរំពេច ។ ព្រះរាជាត្រាស់សួរថា ព្រោះហេតុអ្វី ទើបកូនយើងត្រឡប់ឆាប់ម៉្លេះ នាយសារថីក្រាប

ទូលថា បពិត្រព្រះសម្មតិទេព ព្រោះឃើញមនុស្សចាស់ ។ ព្រះរាជាត្រាស់ថា បានឮថា កូនយើង ឃើញមនុស្សចាស់នឹងបួស ចុះហេតុអ្វី ទើបពួកលោក ធ្វើអញឲ្យវិនាស ចូរប្រញាប់ឲ្យអ្នករបាំរាំឲ្យកូនអញមើល កូនអញសោយសម្បត្តិ នឹងមិននឹកនាដល់ការបួស ហើយទ្រង់បន្ថែមការរក្សាឲ្យក្រៃលែងជាងមុន គ្រប់ទិកន្លះយោជន៍ក្នុងទិសទាំងពួង ។

ស្អែកឡើង ព្រះពោធិសត្វទៅកាន់ឧទ្យានដូចមុន ទតឃើញមនុស្សឈឺដែលទេវតានិម្មិត ទើបត្រាស់សួរដោយន័យមុននោះឯង មានព្រះហឫទ័យសង្វេគ ទើបត្រឡប់ឡើងកាន់ប្រាសាទ ។ ឯព្រះរាជាត្រាស់សួរ ហើយទ្រង់រៀបចំ ដោយន័យដូចពោលហើយនោះឯង តែបន្ថែមការរក្សាក្រៃលែងឡើងទៀត ទ្រង់ឲ្យធ្វើការរក្សាក្នុងទីប្រមាណ ៣ គាវុតដោយជុំវិញ ។

ថ្ងៃមួយ ព្រះពោធិសត្វយាងទៅឧទ្យានដូចមុន ទតឃើញមនុស្សស្លាប់ដែលទេវតានិម្មិត ត្រាស់សួរដោយន័យមុននោះឯង មានព្រះហឫទ័យសង្វេគក៏ត្រឡប់ឡើងកាន់ប្រាសាទ ។ ចំណែកព្រះរាជាត្រាស់សួរហើយ ទ្រង់ក៏ចាត់ចែង ដោយន័យដូចពោលខាងដើមនោះឯង ហើយទ្រង់បន្ថែមការរក្សាឡើងទៀត ទ្រង់ដាក់នូវការរក្សាក្នុងទីប្រមាណ ១ យោជន៍ដោយជុំវិញ ។

ស្អែកឡើង ព្រះពោធិសត្វយាងទៅកាន់ឧទ្យាន ទតឃើញបព្វជិតស្លៀកដណ្តប់រៀបរយ ដែលទេវតានិម្មិតយ៉ាងនោះដូចគ្នា ទើបត្រាស់សួរនាយសារថីថា នែសម្លាញ់ បុរសនេះឈ្មោះអ្វី នាយសារថីមិនស្គាល់បព្វជិតឬគុណធម៌របស់បព្វជិត ព្រោះមិនមានព្រះពុទ្ធកើតឡើងក៏ពិត តែព្រោះអានុភាពរបស់ទេវតា ទើបក្រាបទូលថា បពិត្រព្រះសម្មតិទេព បុរសនេះ

ឈ្មោះថា បព្វជិត ហើយពណ៌នាគុណនៃការបួស ។ ព្រះពោធិសត្វញុំាង
ការពេញចិត្តឲ្យកើតឡើងក្នុងការបួស ថ្ងៃនោះ បានយាងទៅកាន់ឧទ្យានពេញ
មួយថ្ងៃ ។ ឯព្រះទីឃភាណកាចារ្យទាំងឡាយពោលថា ព្រះពោធិសត្វបាន
ឃើញនិមិត្តទាំង ៤ ក្នុងថ្ងៃតែមួយ ហើយយាងទៅ ( កាន់ឧទ្យាន ) ។

ព្រះពោធិសត្វទ្រង់លេងក្នុងឧទ្យាននោះ អស់មួយថ្ងៃ ហើយស្រង់ទឹក
ក្នុងស្រះបោក្ខរណីដែលជាមង្គល កាលព្រះអាទិត្យអស្តង្គតហើយ ប្រថាប់
គង់លើផ្ទាំងថ្មដែលជាមង្គល មានបំណងឲ្យគេតែងព្រះកាយ ។ ពេលនោះ
ពួកបរិចារិការបស់ព្រះអង្គកាន់យកសំពត់មានពណ៌ផ្សេងៗ គ្រឿងអាភរណៈ
ច្រើនប្រភេទ និងកម្រងផ្កា គ្រឿងក្រអូប គ្រឿងលាប មកឈរចោមរោម
ដោយជុំវិញ ។ ខណៈនោះ អាសនៈដែលសក្កទេវរាជប្រថាប់គង់ មានកម្តៅ
សក្កៈនោះក៏ពិចារណាថា អ្នកណាហ្ន៎ មានបំណងឲ្យអញឃ្លាតចាកទីនេះ
ទ្រង់ជ្រាបថា ព្រះពោធិសត្វបំណងនឹងតាក់តែងព្រះកាយ ទើបហៅវិស្ស-
កម្មទេវបុត្រមកត្រាស់ថា នៃវិស្សកម្មសម្លាញ់ ថ្ងៃនេះ សិទ្ធត្ថកុមារនឹងចេញ
មហាភិនេស្ក្រមណ៍ក្នុងកណ្តាលរាត្រី ការប្រដាប់នេះ ជាការប្រដាប់ចុងក្រោយ
របស់ព្រះអង្គ ចូរអ្នកទៅកាន់ឧទ្យាន ស្អិតស្អាងព្រះមហាបុរសដោយគ្រឿង
អលង្ការដែលជាទិព្វ ។ វិស្សកម្មទេវបុត្រទទួលទេវបញ្ជាហើយ ចូលទៅរក
ព្រះពោធិសត្វមួយរំពេច ដោយទេវានុភាពដូចជាងកោរកាត់របស់ព្រះអង្គ
នោះឯង យកសំពត់ទិព្វព័ទ្ធព័ន្ធសីសៈរបស់ពោធិសត្វ ត្រឹមតែសម្ផស្សដៃ
ប៉ុណ្ណោះ ព្រះពោធិសត្វក៏បានដឹងថា បុរសនេះមិនមែនជាមនុស្ស បុរសនេះ

ជាទេវបុត្រ ។ កាលវិស្សកម្ម រុំព័ទ្ធដោយសំពត់ជូតក្បាល សំពត់ ១០០០ ផ្ទាំង ក៏ត្រូតលើគ្នាមានរូបដូចគ្នានឹងកែវមណី ខាងលើព្រះមោលី លើព្រះសិរសា កាលសំពត់ដែលហៅថា ១០០០ ផ្ទាំង ត្រួតលើគ្នា ១០ ជុំ ក៏មានសំពត់ត្រួតលើគ្នា ១ ម៉ឺនផ្ទាំង មិនគួរគិតថា ព្រះសិរសាតូច សំពត់ច្រើន តើនឹងត្រួតលើគ្នាបានដូចម្ដេច ព្រោះបណ្ដាសំពត់ទាំងនោះ សំពត់ដែលធំជាងគេ មានទំហំប៉ុនផ្កាកន្ទួតព្រៃ សំពត់ដ៏សេសមានទំហំប៉ុនផ្កាកុម្ភ សីសៈរបស់ព្រះពោធិសត្វ ហាក់ដូចជាផ្កាសារភី ដែលក្រាស់ដោយកេសរ ដូច្នោះ ។

លំដាប់នោះ កាលព្រះពោធិសត្វ ប្រដាប់ដោយគ្រឿងអលង្ការទាំងពួងហើយ កាលពួកអ្នកតន្ត្រីទាំងពួងសម្ដែងបដិភាណរៀងៗ ខ្លួន កាលពួកព្រាហ្មណ៍ដែលប្រកាន់ការបានឮ បានស្ដាប់សំឡេងដែលល្អ ថាជាមង្គលជាដើម សរសើរដោយការប្រកាសពាក្យល្អ ដែលជាពាក្យមង្គលច្រើនប្រការ ដូចជាសូមទ្រង់ត្រេកអរក្នុងជ័យជម្នះជាដើម ព្រះពោធិសត្វយាងឡើងរថដ៏ប្រសើរដែលប្រដាប់ដោយគ្រឿងប្រដាប់ទាំងពួង ។ សម័យនោះព្រះបាទសុទ្ធោទនមហារាជទ្រង់ស្ដាប់ថា រាហុលមាតាប្រសូតព្រះឱរស ទើបបញ្ជូនដំណឹងទៅថា អ្នកទាំងឡាយ ចូរប្រាប់ដំណឹងដែលគួរត្រេកអរដល់កូនរបស់យើងផង ។ ព្រះពោធិសត្វបានស្ដាប់ដំណឹងនោះហើយ ត្រាស់ថា **រាហុ ជាតោ ពន្ធនំ ជាតោ** អន្ទាក់កើតហើយ ចំណងកើតហើយ ។ ព្រះរាជាត្រាស់សួរថា កូនរបស់យើងបាននិយាយអ្វីខ្លះ ពេលបានស្ដាប់ពាក្យនោះហើយ ទើបត្រាស់ថា ចាប់ពីពេលនេះទៅ ចៅរបស់យើង ចូរ

មានឈ្មោះថា រាហុលកុមារ ។

ឯព្រះពោធិសត្វក៏យាងឡើងរថដ៏ប្រសើរ យាងចូលទៅកាន់នគរដោយយសដ៏ធំ ដោយព្រះសិរី ដែលគួរត្រេកអរក្រៃពេក សម័យនោះ ខត្តិយកញ្ញាឈ្មោះកិសាគោតមី នៅលើប្រាសាទជាន់ត្រង់ជាន់ខាងលើ ឃើញលម្អព្រះរូបកាយរបស់ព្រះពោធិសត្វ ដែលធ្វើប្រទក្សិណព្រះនគរ ព្រះនាងកើតបីតិសោមនស្ស ទើបបន្លឺឧទានថា

> បុរសនេះ ជាបុត្តរបស់មាតាណា មាតានោះ រលត់ទុក្ខពិត
> ជាបុត្តរបស់បិតាណា បិតានោះ រលត់ទុក្ខពិត ជាស្វាមី
> របស់នារីណា នារីនោះ រលត់ទុក្ខពិត ។

ព្រះពោធិសត្វស្តាប់ពាក្យជាគាថានោះ ទ្រង់ព្រះតម្រិះថា ព្រះនាងកិសាគោតមីនេះ ត្រាស់យ៉ាងនេះថា ហទយៈរបស់មាតា ហទយៈរបស់បិតា ហទយៈរបស់ភរិយា ដែលឃើញអត្តភាពបែបនេះ រមែងរម្ងត់ទុក្ខបាន កាលណាហ្ន៎ ទើបរលត់ កាលណា ទើបហទយៈឈ្មោះថារម្ងត់ទុក្ខបាន ។

លំដាប់នោះ ព្រះពោធិសត្វមានហទយៈប្រាសចាកតម្រេកក្នុងកិលេស ហើយមានព្រះតម្រិះដូច្នេះថា កាលភ្លើង គឺរាគៈរលត់ ហទយៈ ឈ្មោះថារលត់ក៏មាន កាលភ្លើង គឺទោសៈរលត់ ហទយៈ ឈ្មោះថា រលត់ក៏មាន កាលភ្លើង គឺមោហៈរលត់ ហទយៈ ឈ្មោះថា រលត់ក៏មាន កាលកិលេសធ្វើឲ្យក្តៅទាំងពួង មានមានះ ទិដ្ឋិជាដើមរលត់ ហទយៈ ឈ្មោះថា រលត់ក៏មាន ព្រះនាងឲ្យអញស្តាប់ពាក្យដែលល្អ សេចក្តីពិត អញកំពុងត្រាច់ស្វែង

រកនូវការរលត់ថ្ងៃនេះឯង អញគួរលះបង់ការគ្រប់គ្រងផ្ទះ ចេញបួស ស្វែង រកនូវការរម្ងត់ក្នុងថ្ងៃនេះឯង វត្ថុនេះ ចូរជារបស់បូជាអាចារ្យសម្រាប់ព្រះនាង ចុះ រួចដោះកែវមុក្តាហារ ដែលមានតម្លៃ ១ សែនអំពីព្រះសូរង បញ្ជូនទៅ ប្រទានដល់ព្រះនាងកិសាគោតមី ។ ព្រះនាងកើតនូវសោមនស្សថា សិទ្ធត្ថ-កុមារ មានចិត្តប្រតិព័ទ្ធអាត្មាអញ ទើបបញ្ជូនគ្រឿងបណ្ណាការមកឲ្យ ។

ចំណែកព្រះពោធិសត្វឡើងកាន់ប្រាសាទរបស់ព្រះអង្គ ដោយសិរីដ៏ក្រៃលែង ទ្រង់ផ្ទំលើសិរីសយនៈ ។ ក្នុងវេលានោះឯង ពួកស្ត្រីអ្នករបាំ ប្រដាប់ដោយគ្រឿងអលង្ការទាំងពួង ជាអ្នកសិក្សាមកយ៉ាងល្អ ក្នុងការរាំ និងការច្រៀងជាដើម ជាស្រីល្អដោយរូប ដូចទេវកញ្ញា កាន់គ្រឿងតូរ្យតន្ត្រី ច្រើនប្រភេទ មកចោមរោម ធ្វើការរាំច្រៀង និងការប្រគំ ឲ្យព្រះពោធិសត្វ ឲ្យត្រេកអរ ។ ព្រះពោធិសត្វមិនត្រេកអរក្នុងការរាំជាដើម ព្រោះទ្រង់មាន ព្រះហឫទ័យនឿយណាយក្នុងកិលេសទាំងឡាយ មួយស្របក់ប៉ុណ្ណោះ ទ្រង់ក៏ចូលកាន់និទ្រា ។ ឯស្ត្រីទាំងនោះ គិតគ្នាថា ពួកយើងប្រកបការរាំជាដើម ដើម្បីប្រយោជន៍ដល់រាជកុមារណា រាជកុមារនោះ យាងចូលនិទ្រាហើយ ឥឡូវនេះ ពួកយើងលំបាកធ្វើអ្វី នាំគ្នាដាក់គ្រឿងតូរ្យតន្ត្រីដែលកាន់ ហើយក៏ដេកលក់ទៅ ប្រទីបប្រេងនៅភ្លឺនៅឡើយ ។

ព្រះពោធិសត្វទ្រង់តើនពីបន្ទំ អង្គុយពត់ភ្នែនលើទីបន្ទំ ទតឃើញ ស្ត្រីទាំងនោះដេកលក់លើគ្រឿងតន្ត្រី ពួកខ្លះមានទឹកមាត់ហូរ មានខ្លួនប្រឡាក់ ដោយទឹកមាត់ ពួកខ្លះសង្កៀតធ្មេញ ពួកខ្លះដេកស្រមុក ពួកខ្លះមមើមមាយ

ពួកខ្លះហាមាត់ ពួកខ្លះរបូតសំពត់ប្រាកដអវយវៈកំបាំងដែលគួរខ្ពើម ព្រះពោធិសត្វទតឃើញអាការវិបរិតរបស់ស្ត្រីទាំងនោះ ទ្រង់មានព្រះហឫទ័យនឿយណាយក្នុងកាមទាំងឡាយពន់ប្រមាណ ល្វែងប្រាសាទដ៏ធំ ដែលតាក់តែងដូចភពរបស់សក្កៈ ក៏ប្រាកដដល់ព្រះអង្គ ហាក់បីដូចជាព្រៃខ្មោចស្រស់ដែលពេញដោយសាកសពច្រើនប្រភេទ ភពទាំង ៣ ប្រាកដដូចផ្ទះត្រូវភ្លើងឆេះ ទើបទ្រង់បន្លឺឧទានថា វិកវហ្ន៎ សាំញ៉ាំហ្ន៎ ព្រះហឫទ័យរបស់ព្រះអង្គបង្អោនទៅដើម្បីបព្វជ្ជាក្រៃលែង ។

ព្រះពោធិសត្វទ្រង់ព្រះតម្រិះថា អញនឹងចេញមហាភិនេស្រ្កមណ៍ក្នុងថ្ងៃនេះឯង ទើបក្រោកឡើងពីទីបន្ទំ យាងទៅក្បែរទ្វារ ត្រាស់ថា អ្នកណានៅក្នុងទីនេះ ។ ឆន្នអមាត្យដេកយកក្បាលកើយធរណីទ្វារ ក្រាបទូលថា បពិត្រអយ្យបុត្រ ខ្ញុំឆន្ន ។ ព្រះពោធិសត្វត្រាស់ថា ថ្ងៃនេះ ខ្ញុំមានបំណងចេញមហាភិនេស្រ្កមណ៍ ចូររៀបចំសេះមួយ ។ ឆន្នអមាត្យទទួលថា សាធុហើយកាន់យកគ្រឿងរៀបចំសេះទៅកាន់រោងសេះ កាលប្រទីបប្រេងក្រអូបកំពុងឆេះ ឃើញស្តេចសេះកណ្ឋកឈរលើភូមិភាគដែលគួរត្រេកអរ ខាងក្រោមពិតានផ្កាម្លិះ គិតថា ថ្ងៃនេះ អញគួររៀបសេះនេះថ្វាយ ទើបរៀបចំសេះកណ្ឋក ។ សេះកណ្ឋកនោះ កាលនាយឆន្នកំពុងរៀងចំ បានដឹងថា ការរៀបចំលើកនេះខ្ជាប់ខ្ជួនពិត មិនដូចរៀបចំក្នុងកាលទ្រង់យាងប្រពាតឧទ្យានជាដើមក្នុងថ្ងៃដទៃៗ ឡើយ ថ្ងៃនេះ អយ្យបុត្ររបស់អញ គង់មានបំណងចេញមហាភិនេស្រ្កមណ៍ ពេលនោះ មានចិត្តសោមនស្ស ទើបស្រែកដោយ

សំឡេងកងរំពង សំឡេងនោះគប្បីឮពេញនគរ តែទេវតានាំគ្នារារាំងនូវសំឡេងនោះ មិនឲ្យអ្នកណាបានឮឡើយ ។

ឯព្រះពោធិសត្វ កាលទ្រង់ឲ្យឆន្នទៅហើយ ទ្រង់ព្រះតម្រិះថា អញនឹងមើលកូនបន្តិចសិន ទើបក្រោកឡើងចាកទីប្រថាប់ យាងទៅកាន់លំនៅរបស់រាហុលមាតា ទ្រង់បើកទ្វារបន្ទប់ ខណៈនោះ ប្រទីបប្រេងក្រអូប នៅឆេះនៅឡើយ នៅក្នុងបន្ទប់រាហុលមាតា ព្រះនាងផ្ទំដាក់ព្រះហស្តលើសិរសាព្រះរាជឱរស លើទីបន្ទំដែលដេរដាសដោយផ្កាម្លិះរួត និងផ្កាម្លិះលាជាដើមប្រមាណ ១ អម្ពណៈ ។ ព្រះពោធិសត្វគ្រាន់តែឈរប្រថាប់ ដាក់ព្រះបាទលើធរណីទ្វារ ទតមើលហើយ គិតថា បើអញលើកដៃព្រះទេវីចេញ ហើយស្ទាបអង្អែលកូនសោត ព្រះទេវីនឹងភ្ញាក់ កាលបើដូច្នោះ អន្តរាយនឹងមានដល់អញ អញបានត្រាស់ជាព្រះពុទ្ធជាមុនសិន ហើយសឹមមកសួរសុខទុក្ខកូន កាលទ្រង់ព្រះតម្រិះហើយ ទើបចុះអំពីផ្ទៃប្រាសាទ ។ ពាក្យដែលពោលក្នុងអដ្ឋកថាជាតកថា ពេលនោះ រាហុលកុមារ ប្រសូតបាន ៧ ថ្ងៃ ដូច្នេះ មិនមានក្នុងអដ្ឋកថាដទៃ ព្រោះហេតុនោះ គប្បីកាន់យកតាមនេះ ។

ព្រះពោធិសត្វ ចុះចាកប្រាសាទយ៉ាងនេះហើយ យាងទៅក្បែរសេះ ត្រាស់យ៉ាងនេះថា នែបាកណ្ឋក យប់នេះ ចូរអ្នកជូនយើងឆ្លង យើងអាស្រ័យអ្នកបានត្រាស់ជាព្រះពុទ្ធហើយ នឹងញុំាងលោក ព្រមទាំងទេវលោកឲ្យឆ្លងដែរ ។

លំដាប់នោះ ព្រះពោធិសត្វក៏ឡើងផែលលើខ្នងសេះកណ្ឋក ។ សេះ

កណ្តូកដែលមានបណ្តោយចាប់ពីកទៅ ១៨ ហត្ថ ប្រកបដោយកម្ពស់ដែលសមនឹងបណ្តោយនោះ សម្បូរដោយកម្លាំង និងសម្ទុះ មានខ្លួនពណ៌ស ដូចស័ង្ខដែលខាត់ហើយ បើសេះកណ្តូកនោះស្រែក ឬធ្វើទន្រ្ទាំជើង សំឡេងលាន់ឮពេញនគរ ព្រោះដូច្នោះ ទើបទេវតាទាំងឡាយរារាំងសំឡេងរបស់សេះនោះ ដោយមិនឲ្យអ្នកណាបានឮ ដោយអានុភាពរបស់ខ្លួន ហើយយកបាតដៃទទួលក្នុងវារៈដែលសេះឈានជើងជាន់ទៅ ។ ព្រះពោធិសត្វនៅត្រង់កណ្តាលខ្នងសេះដ៏ប្រសើរ ឲ្យឆន្នចាប់កន្ទុយសេះ ទៅកាន់ជិតទ្វារធំត្រង់កណ្តាលរាត្រី ។

ក្នុងកាលនោះ ព្រះរាជាទ្រង់ឲ្យធ្វើសន្ទះទ្វារ ២ បន្ទះ មួយបន្ទះត្រូវប្រើកម្លាំងបុរស ១០០០ នាក់បើក ដោយទ្រង់ព្រះតម្រិះថា កាលបើដូច្នេះ បុត្ររបស់អញនឹងមិនអាចបើកទ្វារចេញទៅបាន មិនថាក្នុងកាលណាឡើយ ។ តែព្រះពោធិសត្វទ្រង់សម្បូរដោយកម្លាំង បើប្រៀបនឹងដំរី ទ្រទ្រង់នូវកម្លាំងស្មើនឹងដំរី ១០០០ កោដិ កាលប្រៀបនឹងកម្លាំងបុរស ទ្រទ្រង់នូវកម្លាំងស្មើនឹងបុរស ១០០០០ កោដិ ទើបទ្រង់ព្រះតម្រិះថា បើអ្នកណាមិនបើកទ្វារ ថ្ងៃនេះអញនឹងអង្គុយលើខ្នងសេះកណ្តូកនេះឯង និងយកភ្លៅកៀបសេះកណ្តូក ព្រមទាំងនាយឆន្ន ដែលចាប់ត្រង់កន្ទុយ លោតផ្លោះកំពែង ១៨ ហត្ថ ចេញទៅ ឯនាយឆន្នគិតថា បើទ្វារមិនបើក អញនឹងឲ្យអយ្យបុត្រ ប្រថាប់គង់លើកយកដៃស្តាំឱបជុំវិញសេះកណ្តូក ធ្វើសេះឲ្យនៅក្នុងប្រឡោះក្លៀក លោតឆ្លងកំពែងទៅ ឯសេះកណ្តូកគិតថា បើទ្វារមិនបើក អញនឹងលើកម្ចាស់របស់ខ្លួន

ដែលអន្ទាក់ដែលចូលទៅគេ ដែលអន្ទាក់នៅខ្លួនដោយគិតគ្នាជួបរកភាពដោយ ដែលហើយពុំដែលជួបកំពែង ចេញទៅ បើទ្វារមិនបើក ជនទាំង ៣ នោះ អ្នកណាមួយគប្បីធ្វើឲ្យសម្រេច តាមដែលគិតពិត តែទេវតាដែលអាស្រ័យនៅត្រង់ទ្វារបើកឲ្យ ។

ក្នុងខណៈនោះឯង មារមានចិត្តបាបគិតថា នឹងឲ្យព្រះពោធិសត្វត្រឡប់ ទើបឈរក្នុងអាកាស ហើយទូលថា លោកនិទ្ទុក្ខ កុំចេញបួសឡើយ ក្នុងថ្ងៃទី ៧ បន្ទាប់អំពីថ្ងៃនេះ ចក្ករតនៈនឹងប្រាកដដល់លោក លោកនឹងគ្រប់គ្រងរាជសម្បត្តិក្នុងទ្វីបធំទាំង ៤ មានទ្វីបតូច ២ ពាន់ជាបរិវារ សូមត្រឡប់ចុះ ។ ព្រះពោធិសត្វត្រាស់សួរថា អ្នកជានរណា មារឆ្លើយថា ខ្ញុំជាវសវត្តីមារ ។ ព្រះពោធិសត្វត្រាស់ថា នែមារ ខ្ញុំដឹងថា ចក្ករតនៈនឹងប្រាកដដល់ខ្ញុំ ខ្ញុំមិនត្រូវការរាជសម្បត្តិទេ ខ្ញុំនឹងជាព្រះពុទ្ធ ធ្វើលោកធាតុ ១ ម៉ឺនឲ្យញាប់ញ័រ ។ មារពោលថា ចាប់ពីថ្ងៃនេះទៅ ក្នុងពេលដែលលោកគិតដល់កាមវិតក្ក ព្យាបាទវិតក្ក ឬវិហិង្សាវិតក្ក ខ្ញុំនឹងដឹង ទើបឃ្លាំរកឱកាស ជាប់តាមទៅ ដូចស្រមោលអន្ទោលតាមប្រាណ ។

ឯព្រះពោធិសត្វ ទ្រង់មិនអាឡោះអាល័យ លះចក្កពត្តិរាជសម្បត្តិ ដែលនៅក្នុងកណ្តាប់ដៃ ដូចលះដុំទឹកមាត់ យាងចេញអំពីព្រះនគរ ដោយសក្ការៈធំក្រៃលែង ព្រះពោធិសត្វចេញបួសក្នុងថ្ងៃ ១៥ កើត ខែអាសាឍ កាលអាសាឡ្ហនក្ខត្តឫក្សកំពុងគោចរទៅ មានបំណងនឹងត្រឡប់ទៅទតព្រះនគរម្តងទៀត កាលព្រះពោធិសត្វមានការគិតឡើងប៉ុណ្ណោះ មហាប្រឹថពីហាក់ដូចជាទូលថា បពិត្រមហាបុរស ទ្រង់មិនចាំបាច់ត្រឡប់មកទតទេ ហើយ

បានវិលត្រឡប់ឲ្យព្រះពោធិសត្វទត ដូចជាសយន្តរបស់ស្មូនឆ្នាំង ដូច្នោះ ។ ព្រះពោធិសត្វបែរព្រះភក្ត្រទៅកាន់នគរ ទតមើលព្រះនគរ ហើយទ្រង់សម្តែងចេតិយដ្ឋានដែលសេះកណ្ឋកវិលត្រឡប់ត្រង់បឹង ពីបទេសនោះ ហើយទ្រង់ធ្វើសេះកណ្ឋកឲ្យបែរមុខទៅកាន់ផ្លូវ ដែលទ្រង់យាងទៅ បានយាងទៅហើយដោយសក្ការៈដ៏ធំក្រៃលែង ដោយលម្អដ៏ឧឡារ ។

បានឮថា ក្នុងកាលនោះ ទេវតាទាំងឡាយឈួលគប់ភ្លើងខាងមុខព្រះពោធិសត្វ ៦ ម៉ឺន ខាងក្រោយ ៦ ម៉ឺន ខាងស្តាំ ៦ ម៉ឺន និងខាងឆ្វេង ៦ ម៉ឺន ។ ទេវតាមួយពួកទៀត ឆួលគប់ភ្លើងប្រមាណមិនបាន ត្រង់ភ្នំកណ្តាប់ចក្កវាឡ ។ ទេវតា នាគ និងគ្រុឌជាដើម មួយពួកទៀត ត្រាច់បូជាដោយគ្រឿងក្រអូប ផ្កា លម្អិតក្រអូប ធូមគន្ធៈដែលជាទិព្វ ។ អាកាសដូចជាពេញទៅដោយផ្កាបារិច្ឆត្តកៈ និងផ្កាមន្ទារវៈ ដូចពេញដោយធ្លារទឹក ក្នុងពេលដែលមានមេឃភ្លៀង ។ ទិព្វសង្គីតទាំងឡាយក៏បន្លឺតន្ត្រី ៦ លាន ៨ សែនប្រភេទ បានបន្លឺជុំវិញ សំឡេងតន្ត្រីទាំងនោះកងរំពង ដូចពេលដែលផ្គរគំរាមក្នុងផ្ទៃមហាសមុទ្រ និងដូចពេលដែលសមុទ្រមានសំឡេងកងរំពងត្រង់ភ្នំយុគន្ធរ ។

ព្រះពោធិសត្វយាងទៅដោយសិរីនេះ រំលងរាជអាណាចក្រទាំង ៣ ដោយរាត្រីមួយប៉ុណ្ណោះ ដល់ឆ្នេរស្ទឹងអនោមានទី ក្នុងទីបំផុត ៣០ យោជន៍ ។ សួរថា សេះអាចទៅជាងនោះបានឬទេ ឆ្លើយថា មិនអាចក៏មិនមែន ព្រោះសេះនោះអាចត្រាច់ទៅដល់កណ្តាប់ចក្កវាឡមួយ ទៅបាន ១ ជុំ ត្រឡប់មក

ទាន់ពេលអាហារព្រឹក បរិភោគអាហារដែលគេរៀបចំទុកឲ្យ ដូចជាន់ខ្នងកន់ដែលជាប់ត្រង់ជុំ ដូច្នោះ ។ ក្នុងកាលនោះ សេះលំបាកកាយដែលជាន់លើគ្រឿងក្រអូប និងផ្កាជាដើម ដែលទេវតា នាគ និងគ្រុឌជាដើមដែលឈរក្នុងអាកាសបាចចុះមកស្មើភ្លៅ ហើយត្រូវលុយកាត់គ្រឿងក្រអូប និងផ្កា ទើបមានការយឺតយូរ ព្រោះហេតុនោះ ទើបទៅបានត្រឹម ៣០ យោជន៍ប៉ុណ្ណោះ ។ លំដាប់នោះ ព្រះពោធិសត្វឈរត្រង់ឆ្នេរស្ទឹង ត្រាស់សួរនាយឆន្នថា ស្ទឹងនេះ ឈ្មោះអ្វី នាយឆន្នទូលថា បពិត្រព្រះអង្គ ឈ្មោះអនោមានទី ។ ព្រះពោធិសត្វទ្រង់ព្រះតម្រិះថា បព្វជ្ជារបស់អញមិនថោកថយ ទើបយកកែងជើងឲ្យសញ្ញាដល់សេះ សេះក៏បានលោតឆ្លង ទៅឈរត្រង់ត្រើយនាយនៃស្ទឹង ដែលមានទទឹង ៨ ឧសភ[១] ។

១- ១ ឧសភ = ២០ យដ្ឋិ ( ១៤០ ហត្ថ ) ។

ព្រះពោធិសត្វចុះអំពីខ្នងសេះ ប្រថាប់ឈរលើផ្នូកខ្សាច់ ដែលដូចគ្នានឹងបន្ទះប្រាក់ ហើយត្រាស់ហៅនាយឆន្នមកថា ឆន្នសម្លាញ់ ចូរអ្នកនាំយកអាភរណៈ និងសេះកណ្ឋករបស់ខ្ញុំទៅ ខ្ញុំនឹងបួស ។ នាយឆន្នទូលថា បពិត្រព្រះសម្មតិទេព ខ្ញុំក៏នឹងបួស ។ ព្រះពោធិសត្វឃាត់អស់វារៈ ៣ ដងថា អ្នកបួសមិនបានទេ អ្នកត្រូវត្រឡប់ទៅ ទើបប្រគល់គ្រឿងអលង្ការ និងសេះឲ្យ ហើយទ្រង់ព្រះតម្រិះថា សក់ទាំងឡាយ របស់អញនេះ មិនសមគួរដល់សមណៈ បុគ្គលដទៃដែលសមគួរនឹងកាត់សក់របស់ព្រះពោធិសត្វមិនមាន ។ លំដាប់នោះ ទើបទ្រង់ព្រះតម្រិះថា អញនឹងយកដាវកាត់ដោយខ្លួនឯង ទើប

យកព្រះហស្តស្តាំចាប់ព្រះខ័ន យកព្រះហស្តឆ្វេងចាប់ព្រះចូឡា ព្រមទាំងព្រះមោលីហើយ ទើបកាត់ ។ ព្រះកេសានៅសល់ប្រមាណ ២ ធ្នាប់ វិលទៅខាងស្តាំជាប់នឹងព្រះសីសៈ ។ ព្រះកេសាទាំងនោះ មានប្រមាណប៉ុណ្ណោះដរាបដល់អស់ព្រះជន្ម ។ ព្រះមស្សុក៏មានសមល្មមនឹងព្រះកេសានោះ ។ ឈ្មោះថា កិច្ចក្នុងការកោរសក់ និងព្រះមស្សុ មិនមានទៀតឡើយ ។ ព្រះពោធិសត្វកាន់ព្រះចូឡា និងព្រះមោលី ហើយទ្រង់អធិដ្ឋានថា បើអាត្មាអញបានត្រាស់ជាព្រះសម្ពុទ្ធ ចូរអណ្តែតទៅក្នុងអាកាស បើមិនបានត្រាស់ជាព្រះពុទ្ធទេ ចូរធ្លាក់លើផែនដី ហើយទ្រង់បោះឡើងទៅក្នុងអាកាស ព្រះចូឡានោះអណ្តែតឡើងទៅក្នុងទីប្រមាណ ១ យោជន៍ ហើយតាំងនៅក្នុងអាកាស ។ សក្កទេវរាជទ្រង់ប្រមើលមើលដោយទិព្វចក្ខុ ទើបទ្រង់យកប្រអប់កែវ មានប្រមាណ ១ យោជន៍ទទួលយកទៅ ប្រតិស្ឋានក្នុងចេតិយ ឈ្មោះចូឡា-មណីចេតិយ ក្នុងស្ថានតាវត្តិង្ស ។

> ព្រះសក្យៈដ៏ប្រសើរ បានកាត់ព្រះមោលីដែលអប់ដោយក្លិន
> ក្រអូបដ៏ប្រសើរ ហើយបោះឡើងទៅកាន់អាកាស ស្តេច
> វាសវៈមានព្រះនេត្រ ១០០០ យកប្រអប់កែវដ៏ប្រសើរទទួល
> ទូលលើសិរសា ដូច្នេះ ។

ព្រះពោធិសត្វទ្រង់ព្រះតម្រិះបន្តថា សំពត់កាសិកពស្ត្រទាំងនេះ មិនសមគួរដល់សមណៈសម្រាប់អញ ។ កាលនោះ ឃដិការមហាព្រហ្មជាសម្លាញ់ចាស់របស់ព្រះពោធិសត្វ ក្នុងកាលព្រះកស្សបសម្ពុទ្ធ មានភាពជា

មិត្រ មិនទាន់សាបសូន្យ រហូត ១ ពុទ្ធន្តរ គិតថា ថ្ងៃនេះ សម្លាញ់របស់អញចេញមហាភិនេស្រ្កមណ៍ អញនឹងនាំយកសមណបរិក្ខារទៅឲ្យសម្លាញ់អញ ទើបនាំយកបរិក្ខារ ៨ មកថ្វាយ បរិក្ខារទាំង ៨ គឺ

ត្រៃចីវរ បាត្រ កាំបិត ម្ជុល វត្ថពន្ធ និងសំពត់តម្រងទឹកជាគម្រប់ ៨ រមែងសមគួរ ដល់ភិក្ខុដែលប្រកបសេចក្តីព្យាយាម ។

ព្រះពោធិសត្វស្លៀកដណ្តប់ទង់ជ័យព្រះអរហន្ត កាន់យកភេទបព្វជិតដ៏ឧត្តម ហើយត្រាស់ថា ឆន្ន ចូរអ្នកក្រាបទូលថា យើងសុខសប្បាយ មិនមានរោគដល់ព្រះបិតា និងព្រះមាតាមពាក្យរបស់ខ្ញុំ ហើយទ្រង់បញ្ជូនទៅ ។ ឆន្នថ្វាយបង្គំព្រះពោធិសត្វ ធ្វើប្រទក្សិណហើយ ចេញទៅ ។ ឯសេះកណ្ឋកបានឮព្រះតម្រាស់របស់ព្រះពោធិសត្វត្រាស់ជាមួយឆន្ន គិតថា ឥឡូវនេះ អញមិនបានឃើញម្ចាស់របស់អញតទៅទៀតឡើយ កាលផុតគន្លងចក្ខុ មិនអាចអត់ធន់នឹងសេចក្តីសោកបាន មានហទយៈបែក កើតជាទេវបុត្រឈ្មោះកណ្ឋក ក្នុងស្ថានតាវត្តិង្ស ។ ដំបូង ឆន្នមានសេចក្តីសោកតែមួយ លុះសេះកណ្ឋកស្លាប់ទៅ ត្រូវសេចក្តីសោក ២ គ្របសង្កត់ ទើបស្រែកទ្រហោយំដើរទៅកាន់ព្រះនគរ ។

កាលព្រះពោធិសត្វបួសហើយ ទ្រង់សម្ងំនៅក្នុងអនុបិយម្ពវ័ន ក្នុងតំបន់នោះអស់ ៧ ថ្ងៃ ដោយសេចក្តីសុខដែលកើតអំពីបព្វជ្ជា ហើយយាងដោយព្រះបាទអស់ផ្លូវ ៣០ យោជន៍ ក្នុង ១ ថ្ងៃប៉ុណ្ណោះ ដល់ក្រុងរាជគ្រឹះ ។ កាល

យាងទៅដល់ ក៏ត្រាច់បិណ្ឌបាតតាមលំដាប់ប្រេក ព្រះនគរទាំងមូលដល់នូវការភ្ញាក់ផ្អើល គ្រាន់តែបានឃើញព្រះរូបកាយ របស់ព្រះពោធិសត្វប៉ុណ្ណោះ ក្នុងនគរភ្ញាក់ផ្អើលទូទៅ ដូចកាលដំរីធនបាលកៈ ចូលទៅកាន់ក្រុងរាជគ្រឹះ និងដូចទេវនគរភ្ញាក់ផ្អើល ក្នុងកាលអសុរិន្ទរាហូចូលទៅ ។ រាជបុរសទាំងឡាយទៅក្រាបទូលព្រះរាជាថា បពិត្រព្រះសម្មតិទេព មានបុគ្គលបែបនេះ ត្រាច់បិណ្ឌបាតក្នុងព្រះនគរ ទូលបង្គំទាំងឡាយមិនជ្រាបថា បុគ្គលនោះ ជាទេវតា ឬមនុស្ស នាគ ឬគ្រុឌ ។ ព្រះរាជាប្រថាប់ឈរត្រង់ផ្ទៃប្រាសាទបានឃើញព្រះមហាបុរស អស្ចារ្យក្នុងព្រះហឫទ័យ ទើបបញ្ជាពួករាជបុរសថា នែអ្នក ចូរពួកអ្នកទៅសង្កេតមើល បើមិនមែនមនុស្ស ចេញអំពីនគរហើយ ក៏នឹងបាត់ទៅ បើជាទេវតា នឹងទៅតាមអាកាស បើជានាគនឹងមុជក្នុងដី បើជាមនុស្សនឹងបរិភោគភិក្ខាហារដែលបាន ។

ឯមហាបុរសបិណ្ឌបាតភត្ត ដែលលាយឡំគ្នាច្រើនយ៉ាងហើយ ដឹងថាភត្តមានប្រមាណប៉ុណ្ណេះ ល្មមចិញ្ចឹមជីវិតបានហើយ ទើបយាងចេញអំពីព្រះនគរតាមទ្វារដែលចូលមកនោះឯង បែរព្រះភក្ត្រទៅកាន់ទិសខាងកើត គង់ប្រថាប់ស្រមោលភ្នំបណ្ឌវៈ ផ្ដើមសោយព្រះក្រយាហារ ។ លំដាប់នោះពោះវៀនធំរបស់ព្រះមហាបុរសនោះ ដល់នូវអាការនឹងត្រឡប់ចេញតាមព្រះឱស្ឋ ។ លំដាប់នោះ ទ្រង់ខ្ពើមរអើមដោយអាហារបដិកូលនោះ ព្រោះក្នុងអត្តភាពនោះ ទ្រង់មិនធ្លាប់ឃើញអាហារនោះសូម្បីដោយចក្ខុ ទើបទ្រង់ទូន្មានខ្លួនយ៉ាងនេះថា នែសិទ្ធត្ថ អ្នកកើតក្នុងត្រកូលដែលរកបាយ និងទឹក

បានឆាយ ជាត្រកូលដែលបរិភោគភោជននៃស្រូវសាលីក្រអូប ដែលរក្សា ៣ ឆ្នាំ មានរសដ៏ប្រសើរផ្សេងៗ បានឃើញភិក្ខុអ្នកសមាទានបង្សុកូលជាវត្ត ១ រូប គិតថា កាលណាហ្ន៎ អាត្មាអញគប្បីជាបុគ្គលបែបនេះ ត្រាច់បិណ្ឌ-បាតបរិភោគ កាលនោះ នឹងមានដល់អញក្នុងកាលណាហ្ន៎ ដូច្នេះ ទើបចេញបួស ឥឡូវនេះ អ្នកធ្វើនូវការគិតនោះដូចម្តេច កាលទ្រង់ទូន្មានខ្លួនឯងយ៉ាងនេះហើយ មិនមានអាការខុសប្លែក ឆាន់ព្រះក្រយាហារ ។

រាជបុរសទាំងឡាយឃើញហេតុនោះហើយ ទើបទៅក្រាបទូលដល់ព្រះរាជាៗ ទ្រង់ស្តាប់ពាក្យរបស់ទូតហើយ ទើបប្រញាប់ចេញអំពីព្រះនគរ យាងទៅកាន់សម្នាក់របស់ព្រះពោធិសត្វ ទ្រង់ជ្រះថ្លាក្នុងឥរិយាបថក្រៃលែង ទើបទ្រង់លើកភាពជាធំទាំងពួងឲ្យដល់ព្រះពោធិសត្វ ។ ព្រះពោធិសត្វត្រាស់ថា បពិត្រមហារាជ អាត្មាមិនត្រូវការដោយវត្ថុកាម ឬកិលេសកាម អាត្មាប្រាថ្នាអភិសម្ពោធិញ្ញាណដ៏ក្រៃលែង ទើបចេញបួស ។ ព្រះរាជា ទោះបីទ្រង់អង្វរជាច្រើនប្រការ ក៏ទ្រង់មិនអាចយកឈ្នះព្រះហឫទ័យ របស់ព្រះពោធិសត្វបាន ទើបទ្រង់សូមពាក្យប្តេជ្ញាថា ទ្រង់នឹងបានជាព្រះពុទ្ធពិតប្រាកដ បើទ្រង់បានត្រាស់ជាព្រះពុទ្ធហើយ សូមយាងមកដែនរបស់ខ្ញុំមុន នេះជាសេចក្តីសង្ខេបក្នុងរឿងនេះ ឯសេចក្តីពិស្តារគប្បីមើលក្នុងបព្វជ្ជាសូត្រថា ខ្ញុំនឹងសម្តែងនូវបព្វជ្ជា ដែលព្រះពុទ្ធមានចក្ខុនោះ ទ្រង់បានព្រះផ្នួសហើយជាដើម ព្រមទាំងអដ្ឋកថា ហើយគប្បីជ្រាបតាមនោះចុះ ។

ចំណែកព្រះពោធិសត្វ ទ្រង់ឲ្យប្តេជ្ញាដល់ព្រះរាជាហើយ ទ្រង់ចារិកទៅ

ដោយលំដាប់ ចូលទៅរកអាឡារតាបសកាលាមគោត្រ និងឧទកតាបសរាមបុត្រ ធ្វើសមាបត្តិឲ្យកើតហើយ គិតថា នេះមិនមែនជាផ្លូវដើម្បីការត្រាស់ដឹង ទើបមិនពេញព្រះហឫទ័យនឹងសមាបត្តិភាវនានោះ ដើម្បីសម្តែងកម្លាំង និងសេចក្តីព្យាយាមរបស់ព្រះអង្គដល់លោក ព្រមទាំងទេវលោកមានបំណងតាំងនូវសេចក្តីព្យាយាមធំ ទើបយាងទៅកាន់ឧរុវេលាបទេសទ្រង់ព្រះតម្រិះថា ភូមិភាគនេះ គួរត្រេកអរហ្ន៎ អាស្រ័យនៅត្រង់ឧរុវេលាបទេសនោះ ផ្តើមតាំងមហាបធានធំ ។ បញ្ចវគ្គិយ មានព្រះកោណ្ឌញ្ញៈជាប្រធាន ត្រាច់ទៅដើម្បីភិក្ខាក្នុងគាមនិគម និងរាជធានីទាំងឡាយ បានជួបព្រះពោធិសត្វក្នុងឧរុវេលាបទេសនោះ ។ លំដាប់នោះ បញ្ចវគ្គិយទាំងនោះបាននៅក្នុងសម្នាក់ ចាំបម្រើព្រះពោធិសត្វ ដែលផ្តើមតាំងមហាបធានអស់ ៦ ឆ្នាំ ដោយវត្តបដិបត្តិ មានការបោសបរិវេណជាដើម ដោយសង្ឃឹមថានឹងបានត្រាស់ជាព្រះពុទ្ធឥឡូវនេះ នឹងបានត្រាស់ជាព្រះពុទ្ធឥឡូវនេះ ។ ឯព្រះពោធិសត្វទ្រង់ព្រះតម្រិះថា អញនឹងធ្វើទុក្ករកិរិយាឲ្យដល់ទីបំផុត ទើបទ្រង់ញ៉ាំងជីវិតឲ្យប្រព្រឹត្តទៅដោយអង្ករមួយគ្រាប់ ល្ងមួយគ្រាប់ជាដើម រហូតដល់អត់អាហារតែម្តង ។ ទេវតាទាំងឡាយ នាំយកឱជៈដាក់ចូលទៅតាមរន្ធរោម ។

លំដាប់នោះ ព្រះវរកាយរបស់ព្រះពោធិសត្វនោះ សូម្បីមានពណ៌ដូចមាស ក៏មានពណ៌ខ្មៅ ព្រោះមិនមានអាហារ និងព្រោះបានទទួលនូវការលំបាកលំបិនយ៉ាងក្រៃលែង ។ ព្រះមហាបុរិសលក្ខណៈ ៣២ ប្រការ មិន

បានប្រាកដឲ្យឃើញ ។ ជួនកាល កាលទ្រង់សម្ងំអានាបានកជ្ឈាន គឺខ្យល់ដង្ហើមចូល ខ្យល់ដង្ហើមចេញ ត្រូវវេទនាជំគ្របសង្កត់ ដួលសន្លប់ខាងចុងទីចង្រ្កម ។ លំដាប់នោះ ទេវតាពួកខ្លះពោលដល់ព្រះពោធិសត្វនោះថា ព្រះសមណគោតមធ្វើកាលកិរិយាហើយ ទេវតាពួកខ្លះពោលថា នេះជាវិហារធម៌របស់ព្រះអរហន្តទេតើ ។ បណ្តាទេវតាទាំងនោះ ទេវតាដែលសម្គាល់ថាព្រះសមណគោតមធ្វើកាលកិរិយាហើយ បានទៅប្រាប់ដល់ព្រះបាទសុទ្ធោ-ទនមហារាជថា ព្រះរាជបុត្ររបស់ព្រះអង្គសោយទិវង្គតហើយ ។ ព្រះបាទសុទ្ធោទនមហារាជត្រាស់ថា កូនរបស់ខ្ញុំ បើមិនទាន់ត្រាស់ជាព្រះពុទ្ធ មិនស្លាប់ឡើយ ។ ទេវតាទាំងនោះក្រាបទូលថា ព្រះរាជបុត្ររបស់ព្រះអង្គមិនអាចបានជាព្រះពុទ្ធទេ ទ្រង់ដួលលើផែនដី ក្នុងទីបំពេញព្យាយាម សោយទិវង្គតហើយ ។ ព្រះរាជាបានស្តាប់ដូច្នោះ ទ្រង់ជំទាស់ថា ខ្ញុំមិនជឿ កូនរបស់ខ្ញុំ បើមិនទាន់សម្រេចពោធិញ្ញាណ នឹងមិនធ្វើកាលកិរិយាឡើយ ។ សួរថា ព្រោះហេតុអ្វី ទើបព្រះរាជាមិនជឿ ឆ្លើយថា ព្រោះទ្រង់បានឃើញបាដិហារ្យក្នុងថ្ងៃដែលឲ្យថ្វាយបង្គំកាលទេវិលតាបស និងត្រង់គល់ព្រីង ។

កាលព្រះពោធិសត្វដឹងខ្លួន ទ្រង់ក្រោកឡើង ទេវតាទាំងនោះ បានទៅក្រាបទូលដល់ព្រះរាជាទៀតថា បពិត្រមហារាជ ឱរសរបស់ព្រះអង្គប្រាសចាករោគហើយ ។ ព្រះរាជាត្រាស់ថា ខ្ញុំដឹងថា កូនរបស់ខ្ញុំមិនស្លាប់ ។ កាលព្រះមហាសត្វទ្រង់ធ្វើទុក្ករកិរិយា ៦ វស្សា ពេលវេលាហាក់ដូចជាក្តិចកំណួចក្នុងអាកាស ។ ព្រះមហាសត្វទ្រង់ព្រះតម្រិះថា ឈ្មោះថា ការធ្វើ

ទុក្ករកិរិយានេះ មិនជាផ្លូវដើម្បីត្រាស់ដឹងទេ ទើបត្រាច់បិណ្ឌបាតក្នុងគាម និគម ដើម្បីនាំនូវអាហារគ្រោតគ្រាតមក ហើយសោយ ។ កាលនោះ មហាបុរិសលក្ខណៈ ៣២ ប្រការរបស់ព្រះមហាសត្វ ក៏បានត្រឡប់ជាប្រក្រតី ព្រះវរកាយក៏មានវណ្ណៈដូចមាស ។ បញ្ចវគ្គិយភិក្ខុនាំគ្នាគិតថា ព្រះមហាបុរសនេះ ខំធ្វើទុក្ករកិរិយាអស់ ៦ ឆ្នាំ ក៏មិនអាចត្រាស់ដឹងនូវសព្វញ្ញុតញ្ញាណ ឥឡូវនេះ ត្រាច់បិណ្ឌបាតក្នុងគាមនិគមជាដើម នាំយកអាហារគ្រោតគ្រាតមក តើត្រាស់ដឹងបានដូចម្ដេច ព្រះមហាបុរសនេះបោះបង់ព្យាយាម វិលមករកភាពប្រាថ្នាច្រើន កាលបើពួកយើងសង្ឃឹមបានគុណវិសេសអំពីព្រះមហាបុរសនេះ ដូចបុគ្គលចង់បានទឹកសន្សើមមកកក់ក្បាល ដូច្នោះ ព្រះមហាបុរសនេះ មិនមានប្រយោជន៍សម្រាប់ពួកយើង ទើបនាំគ្នាលះមហាបុរស កាន់បាត្រ និងចីវររៀងៗខ្លួន ធ្វើដំណើរទៅអស់ចម្ងាយ ១៨ យោជន៍ ស្នាក់នៅត្រង់ព្រៃឥសិបតនៈ ។

សម័យនោះឯង ទារិកាឈ្មោះសុជាតា កើតក្នុងផ្ទះរបស់សេនានិកុដុម្ពិកៈ ក្នុងឧរុវេលាសេនានិគម ចម្រើនវ័យហើយ បានធ្វើការបន់ស្រន់ត្រង់ដើមជ្រៃមួយដើមថា បើខ្ញុំទៅកាន់ផ្ទះត្រកូលដែលមានជាតិស្មើគ្នា ហើយបានកូនប្រុសក្នុងគភ៌ដំបូងសោត ខ្ញុំនឹងធ្វើពលីកម្ម ដោយបរិច្ចាគទ្រព្យ ១ សែនដល់លោករាល់ៗ ឆ្នាំ ។ សេចក្ដីប្រាថ្នានោះរបស់នាងសម្រេចហើយ កាលព្រះមហាសត្វ ទ្រង់ធ្វើទុក្ករកិរិយាអស់ ៦ ឆ្នាំ ពេញបរិបូណ៌ នាងបានលែងមេគោទឹកដោះ ១០០០ ឲ្យត្រាច់ទៅក្នុងព្រៃឈើឯម ឲ្យមេគោ ៥០០ ផឹកទឹកដោះ

របស់មេគោ ១០០០ នោះ ហើយឲ្យមេគោទឹកដោះ ២៥០ ផឹកនូវទឹកដោះមេគោ ៥០០ នោះ នាងធ្វើបែបនេះ រហូតដល់មេគោ ៨ ផឹកទឹកដោះមេគោ ១៦ ដើម្បីទឹកដោះដែលខាប់បំផុត ផ្អែមបំផុត ឆ្ងាញ់បំផុត មកផ្សំជាអាហារទឹកដោះគោ ។ ក្នុងថ្ងៃ ១៥ កើត ខែពិសាខ នាងគិតថា នឹងធ្វើពលីកម្មអំពីព្រលឹម ទើបក្រោកឡើងក្នុងពេលទៀបភ្លឺ ហើយឲ្យរីតទឹកដោះរបស់មេគោ ៨ នោះ កូនគោទាំងឡាយមិនទាន់មកដល់កន្សោមដោះរបស់មេគោ ។ គ្រានាំកាជនៈថ្មីចូលទៅក្បែរកន្សោមដោះ ធារទឹកដោះក៏ហូរចេញដោយមកឯង ។ នាងសុជាតាឃើញសេចក្តីអស្ចារ្យនោះ ទើបកាន់ទឹកដោះទៅដោយដៃខ្លួនឯង ដាក់ក្នុងកាជនៈថ្មី ហើយប្រញាប់បង្កាត់ភ្លើង ដោយដៃខ្លួនឯង ។

កាលនាងកំពុងចម្អិនបាយាសនោះ ពពុះធំៗ ផុសឡើង ហូរវិលជាទក្ខិណាវដ្ត សូម្បីតែទឹកដោះមួយតំណក់ ក៏មិនខ្ចាតទៅខាងក្រៅ ផ្សែងសូម្បីតិចតួចក៏មិនហុយឡើងអំពីជើងក្រាន ។ សម័យនោះ ស្តេចចតុលោកបាលធ្វើនូវការរក្សាជើងក្រាន មហាព្រហ្មបាំងឆត្រ សក្កទេវរាជទ្រង់នាំឧសមកដុតឲ្យឆេះត្រលោមសព្វកាល ទេវតាទាំងឡាយយកឱជកប្បនឱជាសម្រាប់ទេវតា និងមនុស្សក្នុងទ្វីបធំទាំង ៤ មានទ្វីបតូច ២០០០ ជាបរិវារមកដាក់ក្នុងបាយាសនោះ ដោយទេវានុភាពរៀងៗ ខ្លួន ដូចប្រេបាច់សម្បុកឃ្មុំដែលជាប់ត្រង់បង្គង កាន់យកតែទឹកផ្អែម ដូច្នោះ ។ ពិតហើយ ក្នុងកាលដទៃៗ ទេវតាទាំងឡាយដាក់ឱជៈគ្រប់ៗ ពំនូតបាយ តែក្នុងថ្ងៃសម្រេចព្រះសម្ពោធិញ្ញាណ និងថ្ងៃបរិនិព្វាន ដាក់ក្នុងឆ្នាំងតែម្តង ។ ក្នុងថ្ងៃនោះឯង នាង

សុជាតា បានឃើញសេចក្តីអស្ចារ្យច្រើនយ៉ាង ដែលប្រាកដដល់ខ្លួនក្នុងទីនោះ ទើបហៅនាងបុណ្ណទាសីមក ពោលថា នែនាងបុណ្ណា ថ្ងៃនេះ ទេវតារបស់ពួកយើង គួរជ្រះថ្លាក្រៃលែង ព្រោះថា ខ្ញុំមិនធ្លាប់ឃើញភាពអស្ចារ្យបែបនេះ ក្នុងកាលមានប្រមាណប៉ុណ្ណោះ ចូរនាងប្រញាប់ទៅបោសសម្អាតទេវស្ថាន ឲ្យឆាប់ ។ នាងបុណ្ណទាសីទទួលពាក្យរបស់នាងហើយ ប្រញាប់ប្រញាល់ ទៅកាន់គល់ជ្រៃ ។

ក្នុងរាត្រីថ្ងៃនោះ ព្រះពោធិសត្វបានឃើញមហាសុបិន ៥ ប្រការ កាលទ្រង់ពិចារណាមើល ទើបទ្រង់ធ្វើសន្និដ្ឋានថា ថ្ងៃនេះ អាត្មានឹងបាន ត្រាស់ជាព្រះពុទ្ធដោយឥតសង្ស័យ កាលរាត្រីនោះកន្លងទៅ ទើបទ្រង់ បដិបត្តិសរីរៈ ទ្រង់រង់ចាំពេលភិក្ខាចារ ។ លុះព្រឹកឡើង ទើបយាងមកគង់ ត្រង់គល់ឈើនោះ ធ្វើគល់ឈើទាំងមូលឲ្យភ្លឺស្វាង ដោយព្រះរស្មីរបស់ ព្រះអង្គ ។ លំដាប់នោះ នាងបុណ្ណទាសីនោះមក បានឃើញព្រះពោធិសត្វ គង់ត្រង់គល់ឈើ សម្លឹងមើលលោកធាតុទិសខាងកើត ។ ដើមឈើទាំង មូលមានពណ៌ដូចមាស ព្រោះព្រះរស្មីដែលផ្សាយចេញអំពីសរីរៈ របស់ ព្រះអង្គ ។ នាងបុណ្ណទាសីនោះបានឃើញហើយ គិតដូច្នេះថា ថ្ងៃនេះ ទេវតា របស់យើង ប្រហែលជាចុះអំពីដើមឈើមកអង្គុយរង់ចាំ ចាំទទួលពលីកម្ម ដោយដៃខ្លួនឯង ទើបភ្ញាក់ផ្អើល រួតរះមកប្រាប់សេចក្តីនោះដល់នាងសុជាតា ។

នាងសុជាតាបានស្តាប់ពាក្យរបស់នាងបុណ្ណទាសីនោះហើយ មានចិត្ត ត្រេកអរ គិតថា តាំងអំពីថ្ងៃនេះទៅ ចូរនាងតាំងនៅក្នុងឋានៈជាកូនស្រីច្បង

របស់យើង ហើយបានឲ្យគ្រឿងអលង្ការទាំងពួង ដែលសមគួរដល់ឋានៈកូនស្រី ។ ព្រោះក្នុងថ្ងៃបានសម្រេចនូវភាពជាព្រះពុទ្ធ គួរនឹងបានថាសមាស ១ ដែលមានតម្លៃ ១ សែន ហេតុនោះ ទើបធ្វើឲ្យនាងគិតថា អញនឹងដាក់បាយាសក្នុងថាសមាស ទើបឲ្យនាំថាសមាសតម្លៃ ១ សែនមក ដើម្បីដាក់បាយាសក្នុងថាសមាសនោះ ទើបរំពឹងដល់ភាជនៈដាក់របស់ ដែលឆ្អិនហើយ បាយាសទាំងអស់ បានរមៀលមកតាំងនៅក្នុងថាស ដូចទឹករមៀលអំពីស្លឹកឈូក ដូច្នោះ បាយាសនោះ មានប្រមាណពេញថាសមាសមួយល្មម ទើបនាងយកថាសដទៃគ្របថាសនោះ ហើយយកសំពត់សស្រោប ចំណែកខ្លួនប្រដាប់តាក់តែងរាងកាយ ដោយគ្រឿងអលង្ការ គ្រប់យ៉ាងស្រេចហើយ ទូលថាសនោះលើសីសៈរបស់ខ្លួន ទៅកាន់គល់ជ្រៃដោយអានុភាពធំ ឃើញព្រះពោធិសត្វហើយ កើតនូវសោមនស្សជាកម្លាំង សម្គាល់ថា ជារុក្ខទេវតា ទើបឱនដើរចូលទៅ តាំងអំពីទីដែលខ្លួនឃើញ ដាក់ថាសមាសអំពីក្បាល បើកសំពត់ដែលខ្ចប់ចេញ យកកុណ្ឌីមាស ជងទឹកដែលអប់ដោយផ្កាក្រអូប ចូលទៅរកព្រះពោធិសត្វ ហើយបានឈរ ។ បាត្រដីដែលឃដិការមហាព្រហ្មថ្វាយ មិនបានឃ្លាតឆ្ងាយអំពីព្រះពោធិសត្វ អស់កាលមានប្រមាណប៉ុណ្ណេះ ខណៈនោះ ក៏បាត់ទៅ ។ ព្រះពោធិសត្វមិនឃើញបាត្រ ក៏លាព្រះហស្តស្តាំទទួលទឹក ទើបនាងសុជាតាដាក់បាយាសព្រមទាំងថាសក្នុងព្រះហស្តរបស់ព្រះមហាបុរសៗ ទ្រង់សម្លឹងមើលនាងសុជាតាៗ ដឹងព្រះអាការ ទើបទូលថា បពិត្រលោកម្ចាស់ ខ្ញុំបរិច្ចាគដល់លោកទាំងថាស លោកទទួលថាសនោះ

ទៅហើយ ចូរធ្វើតាមគាប់ចិត្តចុះ ថ្វាយបង្គំហើយ ទូលថា មនោរថរបស់ខ្ញុំសម្រេចហើយ យ៉ាងណា សូមមនោរថរបស់លោក សម្រេចយ៉ាងនោះ នាងបរិច្ចាគថាសមាសដែលមានតម្លៃ ១ សែន ដោយមិនអាឡោះអាល័យ ដូចដើមឈើជម្រុះស្លឹកចាស់ ហើយត្រឡប់ទៅ ។

ឯព្រះពោធិសត្វក្រោកឡើងចាកទីអង្គុយ ទ្រង់ធ្វើប្រទក្សិណដើមឈើ ហើយកាន់ថាសយាងទៅកាន់ឆ្នេរស្ទឹងនេរញ្ជរា ។ មានកំពង់ ១ ឈ្មោះសុបតិដ្ឋិតៈ ជាទីដែលព្រះពោធិសត្វច្រើនសែនអង្គស្រពស្រង់ ក្នុងថ្ងៃត្រាស់ដឹង ទើបទ្រង់ដាក់ថាសត្រង់ឆ្នេរស្ទឹងនោះ ហើយទ្រង់ចុះស្រង់ត្រង់កំពង់ឈ្មោះសុបតិដ្ឋិតៈ ហើយទ្រង់ស្លៀកដណ្តប់ទង់ជ័យរបស់ព្រះអរហន្ត ដែលជាគ្រឿងស្លៀកដណ្តប់របស់ព្រះពុទ្ធច្រើនសែនអង្គ គង់បែរព្រះភក្ត្រទៅទិសខាងកើត សោយមធុបាយាសដែលមានទឹកតិច ទាំងអស់ដោយទ្រង់ធ្វើឲ្យជា ៤៩ ពំនូត ១ ពំនូតមានទំហំប៉ុនគ្រាប់ត្នោតទុំ បាយាសនោះឯង បានជាព្រះក្រយាហារអស់ ៤៩ ថ្ងៃ សម្រាប់ព្រះពោធិសត្វដែលបានជាព្រះពុទ្ធ ហើយគង់នៅត្រង់បរិវេណពោធិមណ្ឌលអស់ ៧ សប្តាហ៍ ។ អស់កាលមានប្រមាណប៉ុណ្ណោះ មិនមានព្រះក្រយាហារដទៃ មិនមានការស្រង់ មិនមានការជម្រះព្រះឱស្ឋ មិនមានការបន្ទោបង់ព្រះឧច្ចារៈ ទ្រង់ញុំាំងកាលវេលាឲ្យកន្លងទៅ ដោយឈានសុខ និងផលសមាបត្តិសុខ កាលសោយមធុបាយាសនោះហើយ ទ្រង់កាន់យកថាសមាស ត្រាស់ថា បើអាត្មាអញបានជាព្រះពុទ្ធក្នុងថ្ងៃនេះ ថាសនេះ ចូរអណ្តែតច្រាស់ខ្សែទឹកទៅ បើមិនបានត្រាស់ជាព្រះពុទ្ធ

ចូរបណ្ដែតតាមខ្សែទឹក ហើយទ្រង់បណ្ដែតថាសទៅក្នុងក្រសែស្ទឹង ។

ថាសនោះ អណ្ដែតទៅដល់កណ្ដាលស្ទឹងនោះឯង បានអណ្ដែតច្រាស់ខ្សែទឹកត្រង់កណ្ដាលស្ទឹង ទៅបានចម្ងាយ ៨០ ហត្ថ ដូចសេះដែលសម្បូរដោយសម្ទុះជើងដ៏រហ័ស ដូច្នោះហើយ លិចចុះត្រង់អន្លង់មួយកន្លែង ទៅដល់កពស្ដេចកាឡនាគ ប៉ះនឹងថាស ជាគ្រឿងប្រើប្រាស់របស់ព្រះពុទ្ធទាំង ៣ អង្គ លាន់សំឡេងក្រឹកៗ ហើយតាំងនៅពីក្រោមថាសទាំងនោះ ស្ដេចកាឡនាគបានឮសំឡេងនោះហើយ ក៏ពោលថា ម្សិលមិញ ព្រះពុទ្ធកើតឡើង ១ អង្គ ថ្ងៃនេះ កើតឡើង ១ អង្គទៀត ហើយក្រោកឡើង ពោលសរសើរដោយបទច្រើនរយ បានឮថា ក្នុងកាលមហាប្រឹថពីដុះឡើង លើប្រមាណ ១ យោជន៍ ៣ គាវុត ពេលវេលាហាក់បីដូចជាថ្ងៃនេះ ឬថ្ងៃស្អែកសម្រាប់កាឡនាគរាជនោះ ។

ចំណែកព្រះពោធិសត្វ ទ្រង់សម្រាកពេលថ្ងៃ ក្នុងសាលវនដែលមានផ្ការីកស្គុះស្គាយត្រង់ឆ្នេរស្ទឹង លុះដល់ពេលល្ងាច ក្នុងគ្រាផ្កាឈើទាំងឡាយជ្រុះចាកទង ទើបទ្រង់បែរព្រះភក្ត្រទៅកាន់គល់ពោធិ៍តាមផ្លូវដែលទទឹង ៨ ឧសភ ដែលទេវតាទាំងឡាយប្រដាប់តាក់តែង ដូចសីហៈលីលា ដូច្នោះ ។ ពួកនាគ យក្ខ និងគ្រុឌជាដើម បូជាដោយគ្រឿងក្រអូប និងផ្កាជាដើមដែលជាទិព្វ ដេញនូវទិព្វតន្ត្រីជាដើម មុឺនលោកធាតុមានក្លិនក្រអូបតែមួយ មានកម្រងផ្កាដូចគ្នាតែមួយ មានសំឡេងសាធុការដូចគ្នាតែមួយ ។

សម័យនោះ អ្នករែកស្មៅឈ្មោះសោត្ថិយៈ រែកស្មៅដើរបញ្ច្រាស់ផ្លូវ

មក ដឹងអាការរបស់ព្រះមហាបុរស ទើបបានប្រគេនស្មៅ ៨ ក្ដាប់ ។ ព្រះពោធិសត្វទ្រង់កាន់យកស្មៅឡើងកាន់ពោធិមណ្ឌល ទ្រង់ឈរក្នុងទិសខាងត្បូង បែរព្រះភក្ត្រទៅទិសខាងជើង ខណៈនោះ ចក្កវាឡទិសខាងត្បូង បានស្រុតចុះហាក់ដូចដល់អវិចីខាងក្រោម ចក្កវាឡទិសខាងជើងបានខ្ពស់ឡើងហាក់ទាល់នឹងភវគ្គព្រហ្មខាងលើ ។ ព្រះពោធិសត្វទ្រង់ព្រះតម្រិះថា ទីនេះប្រហែលជាមិនមែនជាទីសម្រេចសម្ពោធិញ្ញាណ ទើបទ្រង់ធ្វើប្រទក្សិណហើយយាងទៅកាន់ទិសខាងលិច ទ្រង់ឈរបែរព្រះភក្ត្រទៅកាន់ទិសខាងកើតលំដាប់នោះ ចក្កវាឡទិសខាងលិច ហាក់ដូចជាផ្អៀង ដល់អវិចីខាងក្រោមចក្កវាឡទិសខាងកើត ហាក់ដូចជាបះឡើង ដល់ទាល់ភវគ្គព្រហ្មខាងលើ ។ បានឮថា ក្នុងទីដែលព្រះពោធិសត្វទ្រង់ឈរហើយ មហាប្រឹថពីស្រុតចុះនិងបះឡើង ដូចកង់រទេះធំ ដែលមានដុំត្រង់កណ្ដាល ត្រូវគេជាន់ជាយម្ខាងឲ្យបះ ដូច្នោះ ។ ព្រះពោធិសត្វទ្រង់ព្រះតម្រិះថា ក្នុងទីនេះ ប្រហែលជាមិនមែនជាទីឲ្យសម្រេចព្រះសម្ពោធិញ្ញាណ ទើបទ្រង់ធ្វើប្រទក្សិណ យាងទៅកាន់ទិសខាងជើង ទ្រង់ឈរបែរព្រះភក្ត្រទៅទិសខាងត្បូង ។ គ្រានោះចក្កវាឡទិសខាងជើង ហាក់ដូចជាស្រុតចុះដល់អវិចីខាងក្រោម ចក្កវាឡទិសខាងត្បូង ហាក់ដូចជាបះឡើងទាល់គ្នានឹងភវគ្គព្រហ្មខាងលើ ។ ព្រះពោធិ-សត្វទ្រង់ព្រះតម្រិះថា ក្នុងទីនេះ ប្រហែលជាមិនមែនជាទីឲ្យសម្រេចព្រះសម្ពោធិញ្ញាណ ទើបទ្រង់ធ្វើប្រទក្សិណ ហើយយាងទៅកាន់ទិសខាងកើតទ្រង់ឈរបែរព្រះភក្ត្រទៅទិសខាងលិច ។ ក្នុងទិសខាងកើតជាទីតាំងនៃបល្ល័ង្ក

របស់ព្រះពុទ្ធទាំងពួង ទើបទីនោះមិនកម្រើកមិនញាប់ញ័រ ។ ព្រះពោធិសត្វទ្រង់ដឹងថា ទីនេះជាទីដែលព្រះពុទ្ធទាំងពួងទ្រង់មិនលះបង់ ជាទីមិនញាប់ញ័រ ជាទីកម្ចាត់ទ្រុង គឺកិលេស ទើបទ្រង់ចាប់ចុងស្មៅទាំងនោះរលាស់ ។ រំពេចនោះឯង បល្ល័ង្កកម្ពស់ ១៤ ហត្ថ ស្មៅទាំងនោះ ក៏ក្រាលដោយល្អ ដោយការក្រាលបែបនោះ សូម្បីជាងគំនូរ ឬជាងចម្លាក់ដ៏ឈ្លាស ក៏មិនអាចគូរ ឬឆ្លាក់បាន ។ ព្រះពោធិសត្វទ្រង់ធ្វើដើមពោធិ៍ឲ្យនៅពីក្រោយខ្នង បែរព្រះភក្ត្រទៅទិសខាងកើត ទ្រង់មានព្រះហឫទ័យមាំទាំ ទ្រង់គង់ពត់ភ្នែនលើអបរាជិត-បល្ល័ង្ក ដែលសូម្បីរន្ទះ ១០០ ដង ក៏មិនអាចទម្លាយ ដោយទ្រង់អធិដ្ឋានថា

ស្បែក សរសៃ ឆ្អឹង សូមឲ្យសល់នៅចុះ សាច់ និងឈាម
ក្នុងសរីរៈ ចូរហួតហែងទៅចុះ ។

អាត្មាអញមិនសម្រេចសម្មាសម្ពោធិញ្ញាណ នឹងមិនទម្លាយភ្នែននេះ ។ សម័យនោះ មារមានចិត្តបាបគិតថា សិទ្ធត្ថកុមារចង់កន្លងផុតអំណាចរបស់អញ ឥឡូវនេះ អញនឹងមិនឲ្យសិទ្ធត្ថកុមារនោះកន្លងផុតទៅបាន ទើបទៅកាន់សម្នាក់របស់ពលមារ ប្រាប់សេចក្តីនោះហើយ ឲ្យស្រែកជាសម្រែកមារ ហើយនាំពលមារចេញទៅ ។ សេនាមារនោះ ខាងមុខ ១២ យោជន៍ ខាងស្តាំ និងខាងឆ្វេង ១២ យោជន៍ ខាងក្រោយទល់គ្នានឹងកណ្តាប់ចក្កវាឡ ខាងលើ ៩ យោជន៍ ស្រែកហ៊ោមានសំឡេងដូចផែនដីស្រុត ឮរាប់ពាន់យោជន៍ ។ កាលនោះ ទេវបុត្តមារជិះដំរីគិរិមេខលៈកម្ពស់ ១៥០ យោជន៍ និម្មិតដៃ ១០០០ កាន់អាវុធគ្រប់ប្រភេទ ។ បរិស័ទមារដ៏សេសពីនោក់

ឡើងទៅដូចគ្នា កាន់អាវុធដូចគ្នាមិនមាន មានពណ៌សម្បុរផ្សេងគ្នា មានមុខផ្សេងគ្នា កាន់អាវុធខុសគ្នា ចូលមកចោមចាប់ព្រះពោធិសត្វ ។

ឯទេវតាក្នុងម៉ឺនចក្កវាឡបានឈរសរសើរព្រះមហាសត្វ សក្កទេវរាជឈរផ្លុំស័ង្ខ ឈ្មោះវិជយុត្តរ បានឮថា ស័ង្ខនោះមានប្រវែង ១២០ ហត្ថ កាលផ្លុំតែម្តង មានសំឡេងអស់ ៤ ខែ មិនទាន់អស់សំឡេង ស្តេចកាឡនាគឈរពណ៌នាគុណដោយគាថាច្រើនជាង ១០០ បទ មហាព្រហ្ម ឈរបាំងស្វេតច្ឆត្រ កាលពលមារចូលទៅជិតពោធិមណ្ឌល បណ្តាទេវតាទាំងនោះសូម្បីមួយអង្គ ក៏មិនអាចតាំងនៅបាន នាំគ្នាគេចទៅក្នុងចំពោះមុខ ។ ស្តេចកាឡនាគជ្រែកដីទៅកាន់នាគពិភពដ៏ស្រស់ស្អាត ដែលមានទំហំ ៥០០ យោជន៍ ដេកយកដៃទាំង ២ ខ្ទប់មុខ ។ សក្កទេវរាជ អូសស័ង្ខវិជយុត្តរទៅឈរត្រង់កណ្តាប់ចក្កវាឡ មហាព្រហ្ម ចាប់កំពូលស្វេតច្ឆត្រ ទៅកាន់ព្រហ្មលោកយ៉ាងរហ័ស ទេវតាមួយអង្គ ដែលអាចនៅបាន មិនមានឡើយ មានតែមហាបុរសឯកអង្គប៉ុណ្ណោះគង់នៅបាន ។

ឯមារ ពោលនឹងបរិស័ទរបស់ខ្លួនថា នែបាទាំងឡាយ បុរសដទៃស្មើដោយព្រះសិទ្ធត្ថ ឱរសរបស់ព្រះបាទសុទ្ធោទនៈមិនមានទេ ពួកយើងមិនអាចចូលពីមុខ ពួកយើងនឹងច្បាំងអំពីខាងក្រោយ ។

ឯព្រះពោធិសត្វទ្រង់សម្លឹងមើលទាំង ៣ បានឃើញតែកាពទទេ ព្រោះទេវតាទាំងពួងនាំគ្នារត់ទៅអស់ ទ្រង់ឃើញពលមារចោមរោមផ្នែកខាងលើទៀត ទើបទ្រង់ព្រះតម្រិះថា ជនមានប្រមាណប៉ុណ្ណោះ ធ្វើនូវសេចក្តី

ព្យាយាមធំ ព្រោះបំណងក្នុងអញតែម្នាក់ ក្នុងទីនេះ អញមិនមានបិតា មិនមានមាតា មិនមានបងប្អូន ឬញាតិដទៃ តែបារមី ១០ នេះ ជាបរិវារដែលអញចិញ្ចឹមអស់កាលយូរ ព្រោះដូច្នោះ អញគួរធ្វើបារមីនេះឯងឲ្យជាកំពូលនៃពួកពល យកសស្ត្រា គឺបារមីនេះឯងប្រហារ កម្ចាត់ពួកពលនេះ ដូច្នេះហើយ ទើបទ្រង់គន់ពិចារណាដល់បារមីទាំង ១០ ប្រការ ។

លំដាប់នោះ ទេវបុត្តមារគិតថា នឹងឲ្យព្រះសិទ្ធត្ថកុមារគេចទៅ ដោយខ្យល់ ទើបបណ្ដាលមណ្ឌលខ្យល់ឲ្យតាំងឡើង ។ ខណៈនោះឯង ខ្យល់ទាំងឡាយ មានខ្យល់ទិសខាងកើតជាដើមក៏តាំងឡើង អាចទម្លាយកំពូលភ្នំដែលមានប្រមាណកន្លះយោជន៍ មួយយោជន៍ ពីរយោជន៍ បីយោជន៍ក៏បាន ធ្វើនូវព្រៃ គុម្ពឈើ និងដើមឈើជាដើម ឲ្យមានឫសឡើងខាងលើក៏បាន ហើយធ្វើគាមនិគមដោយជុំវិញ ឲ្យល្អិតជាលម្អិតតូចធំក៏បាន តែមានអានុភាពត្រូវតេជះនៃបុណ្យរបស់ព្រះមហាបុរសកម្ចាត់ហើយ លុះមកដល់ព្រះពោធិសត្វ ក៏មិនអាចធ្វើសូម្បីជាយចីវររបស់ព្រះពោធិសត្វ ឲ្យកម្រើកបាន ។

លំដាប់នោះ ទើបទេវបុត្តមារគិតថា នឹងឲ្យទឹកលិចព្រះសិទ្ធត្ថស្លាប់ ទើបបណ្ដាលមហាភ្លៀងឲ្យតាំងឡើង ។ ដោយអានុភាពរបស់ទេវបុត្តមារនោះ ពពកច្រើនយ៉ាងមានពពក ១ រយស្រទាប់ ១ ពាន់ស្រទាប់ជាដើម តាំងឡើងត្រួតៗ គ្នា ហើយធ្លាក់ចុះមក ដោយកម្លាំងនៃធ្លាររបស់ទឹកភ្លៀង ផែនដីនឹងធ្លុះជាប្រហោងតូចធំ ។ មហាមេឃដែលអណ្ដែតមកចំណែកខាងលើនៃព្រៃ និងដើមឈើជាដើម មិនអាចឲ្យទឹក សូម្បីប៉ុនតំណក់ទឹកសន្សើម

ទទឹកចីវររបស់ព្រះមហាសត្វ ។

លំដាប់នោះ ក៏បណ្ដាលភ្លៀងថ្មឲ្យតាំងឡើង កំពូលភ្នំធំៗ ទង្គិចគ្នាបែកជាផ្សែង ឆេះជាភ្លើង ធ្លាក់មកតាមអាកាស លុះដល់ព្រះពោធិសត្វ ក៏ក្លាយជាផ្កាទិព្វ ។

លំដាប់នោះ ក៏បណ្ដាលភ្លៀងគ្រឿងប្រហារឲ្យតាំងឡើង គ្រឿងប្រហារទាំងឡាយ មានដាវ លំពែង និងព្រួញជាដើម មានមុខតែម្ខាង មានមុខសងខាង ដូចជាផ្សែងឆេះទ្រលោម អណ្ដែតមកតាមអាកាស លុះដល់ព្រះពោធិសត្វ ក៏ក្លាយជាផ្កាទិព្វ ។

លំដាប់នោះ ទើបបណ្ដាលភ្លៀងរងើកភ្លើងឲ្យតាំងឡើង រងើកភ្លើងទាំងឡាយ មានពណ៌ដូចផ្កាចារ អណ្ដែតមកតាមអាកាស លុះដល់ព្រះពោធិសត្វ ក៏ក្លាយជាផ្កាទិព្វ បាចសាចទៀបបាទមូលរបស់ព្រះពោធិសត្វ ។

លំដាប់នោះ ក៏បណ្ដាលភ្លៀងផេះក្ដៅឲ្យតាំងឡើង ផេះនោះមានពណ៌ដូចភ្លើងក្ដៅក្រៃលែង អណ្ដែតមកតាមអាកាស ហើយក្លាយជាលម្អិតខ្លឹមចន្ទន៍ធ្លាក់ចុះមកទៀបបាទមូលរបស់ព្រះពោធិសត្វ ។

គ្រានោះ ក៏បណ្ដាលភ្លៀងខ្សាច់ឲ្យតាំងឡើង ខ្សាច់ទាំងឡាយល្អិត ដូចផ្សែងដែលឆេះទ្រលោម អណ្ដែតមកតាមអាកាស ក៏ក្លាយជាផ្កាទិព្វ ធ្លាក់ចុះទៀបបាទមូលរបស់ព្រះមហាសត្វ ។

លំដាប់នោះ ក៏បណ្ដាលភ្លៀងភក់ឲ្យតាំងឡើង ភក់នោះដូចជាផ្សែងឆេះសន្ធោសន្ធៅ អណ្ដែតមកតាមអាកាស ក៏ក្លាយជាគ្រឿងលាប ដែលជាទិព្វ

ធ្លាក់ចុះទៀបបាទមូលរបស់ព្រះពោធិសត្វ ។

លំដាប់នោះ ទេវបុត្តមារក៏បណ្ដាលងងឹតឲ្យតាំងឡើង ដោយគិតថា អញនឹងធ្វើឲ្យព្រះសិទ្ធត្ថខ្លាចដោយងងឹតនេះហើយគេចទៅ ។ ងងឹតនោះជាការងងឹត ដូចងងឹតដែលប្រកបដោយអង្គ ៤ គឺថ្ងៃ ១៤ រោច ព្រៃជ្រៅ ពពកខ្មៅ និងកណ្ដាលយប់ លុះដល់ព្រះពោធិសត្វក៏អន្តរធានអស់ទៅ ដូចងងឹតដែលត្រូវកម្ចាត់ដោយពន្លឺព្រះអាទិត្យ ដូច្នោះ ។

មារនោះ កាលមិនអាចធ្វើឲ្យព្រះពោធិសត្វគេចទៅដោយខ្យល់ ភ្លៀង ភ្លៀងថ្ម ភ្លៀងគ្រឿងប្រហារ ភ្លៀងរងើកភ្លើង ភ្លៀងផេះ ភ្លៀងខ្សាច់ ភ្លៀងភក់ និងការងងឹតទាំង ៤ ប្រការនេះ ទើបបញ្ជាបរិស័ទរបស់ខ្លួនថា ពួកអ្នកឈប់ធ្វើអ្វី ចូរចាប់សិទ្ធត្ថកុមារនេះ ចូរសម្លាប់ ចូរបណ្ដេញទៅ ខ្លួនឯងក៏អង្គុយលើ-ករីគិរិមេខលៈ កាន់ចក្រាវុធ ចូលទៅជិតព្រះពោធិសត្វ ពោលថា នែសិទ្ធត្ថ ចូរអ្នកក្រោកឡើងចាកបល្ល័ង្កនេះៗ មិនគួរដល់អ្នក បល្ល័ង្កនេះគួរដល់យើង ។ ព្រះមហាសត្វបានស្ដាប់ពាក្យរបស់មារនោះហើយ ត្រាស់ថា នែមារ អ្នកមិនបានបំពេញបារមី ១០ មិនបានបំពេញឧបបារមី ១០ មិនបានបំពេញបរមត្ថបារមី ១០ ទាំងមិនបានធ្វើមហាបរិច្ចាគ ៥ អ្នកមិនបានបំពេញញាតត្ថចរិយា លោកត្ថចរិយា ពុទ្ធត្ថចរិយា ធម៌ទាំងអស់នោះ យើងប៉ុណ្ណោះបំពេញមកហើយ ព្រោះហេតុនោះ ទើបបល្ល័ង្កនេះ មិនគួរដល់អ្នក គួរដល់យើងប៉ុណ្ណោះ ។

មារក្រោធ អត់ធន់នឹងកម្លាំងសេចក្ដីក្រោធមិនបាន ក៏គ្រវែងចក្រាវុធ

សំដៅព្រះមហាបុរស ចក្រាវុធនោះ កាលព្រះមហាបុរសពិចារណាដល់បារមី ១០ នោះឯង បានក្លាយជាពិតានផ្កា តាំងនៅក្នុងចំណែកខាងលើ ។ បានឮថា ចក្រាវុធនោះមុតថ្វាពន់ពេក កាលណាមារក្រោធហើយ គប់វែងទៅក្នុងទីដទៃ អាចកាត់សសរថ្មដ៏ក្រាស់ឲ្យដាច់ទៅ ដូចកាត់ទំពាំងនោះឯង តែឥឡូវនេះ កាលចក្រាវុធនោះក្លាយជាពិតានផ្កា ទើបបរិស័ទរបស់មារដ៏សេសនាំគ្នាគប់វែងនូវកំពូលភ្នំធំៗ សំដៅមក ដោយគិតថា ព្រះសិទ្ធត្ថនឹងក្រោកចាកបល្ល័ង្កគេចទៅក្នុងកាលឥឡូវនេះ ។ កំពូលភ្នំទាំងនោះ កាលមហាបុរសពិចារណាដល់បារមី ១០ ក៏ក្លាយជាសំណុំផ្កាឈើធ្លាក់លើផែនដី ទេវតាទាំងឡាយ ដែលនៅក្នុងកណ្តាប់ចក្កវាឡ ក៏អើត-កមើល ដោយគិតថា ឱ ! អត្តភាពដល់នូវលម្អ ដោយព្រះរូបកាយរបស់ព្រះសិទ្ធត្ថកុមារវិនាសអន្តរធានហើយហ្ន៎ ព្រះសិទ្ធត្ថកុមារនោះ ទ្រង់នឹងធ្វើដូចម្តេចហ្ន៎ ។

លំដាប់នោះ ព្រះពោធិសត្វត្រាស់ថា បល្ល័ង្កដែលកើតឡើងក្នុងថ្ងៃត្រាស់ដឹងរបស់ព្រះពោធិសត្វទាំងឡាយ ដែលបានបំពេញបារមីមកហើយ រមែងគួរដល់អញ ទើបត្រាស់នឹងមារដែលកំពុងឈរថា នែមារ ក្នុងការៈដែលអ្នកបានឲ្យទាន អ្នកណាជាសាក្សី មារលាដៃទៅរកពល ដោយពោលថា ជនមានអម្បាលប្រមាណប៉ុណ្ណេះជាសាក្សី ។ ខណៈនោះ សំឡេងបរិស័ទរបស់មារ បានតាំងឡើងថា ខ្ញុំជាសាក្សី ខ្ញុំជាសាក្សី ហាក់បីដូចជាសំឡេងផែនដីស្រុត ។

គ្រានោះ មារពោលនឹងមហាបុរសថា នែសិទ្ធត្ថ ក្នុងកាលដែលអ្នក

បានឲ្យទាន អ្នកណាជាសាក្សី ព្រះមហាបុរសត្រាស់ថា ក្នុងកាលដែលអ្នកឲ្យទាន បុគ្គលមានចិត្តជាបន្ទាល់ ចំណែកយើង យើងមិនមានបុគ្គលណាមួយ ដែលមានចិត្តជាបន្ទាល់ឡើយ ក្នុងទីនេះ ទានដែលយើងឲ្យក្នុងអត្តភាពដទៃៗ លើកទុកចុះ តែក្នុងការៈដែលយើងតាំងនៅក្នុងអត្តភាពជាព្រះវេស្សន្តរ បានឲ្យសត្តសតកមហាទាន ប្រឹថពីដ៏ក្រាស់នេះ មិនមានចិត្តក៏ជាសាក្សីបាន ទើបទ្រង់ដកព្រះហស្តខាងស្តាំចេញអំពីស្រទាប់ចីវរ ហើយចង្អុលទៅកាន់មហាប្រឹថពី ដោយត្រាស់ថា ក្នុងកាលដែលយើងតាំងនៅក្នុងអត្តភាពជាព្រះវេស្សន្តរ បានឲ្យសត្តសតកមហាទាន អ្នកជាសាក្សី ឬមិនមែនជាសាក្សី ។ មហាប្រឹថពីបានបន្លឺឡើង ហាក់ដូចជាគ្របសង្កត់ពលមារដោយរយសំឡេង ពាន់សំឡេង សែនសំឡេងថា ក្នុងកាលនោះ ខ្ញុំជាសាក្សី ។

បន្ទាប់អំពីនោះ កាលព្រះមហាបុរសទ្រង់ពិចារណាដល់ទានដែលឲ្យក្នុងអត្តភាពជាព្រះវេស្សន្តរថា សិទ្ធត្ថ មហាទាន ឧត្តមទាន អ្នកបានឲ្យហើយដូច្នេះ ដំរីគិរិមេខលៈកម្ពស់ ១៥០ យោជន៍ លុតជង្គង់ចុះលើផែនដី បរិស័ទមារ នាំគ្នាគេចទៅកាន់ទិសានុទិស មារ ២ នាក់ ឈ្មោះថា គេចទៅដោយផ្លូវ ១ មិនមាន នាំគ្នាបោលអាភរណៈលើក្បាល និងសំពត់ដែលស្លៀកហើយរត់ទៅក្នុងទិសដែលមានត្រង់មុខនោះឯង ។

បន្ទាប់អំពីនោះ ពួកទេវតាឃើញពលមាររត់ទៅ ទើបប្រកាសដល់ពួកទេវតា ពួកនាគប្រកាសដល់ពួកនាគ ពួកគ្រុឌប្រកាសដល់ពួកគ្រុឌ ពួក

ព្រហ្ម ប្រកាសដល់ព្រហ្មថា បរាជ័យកើតដល់មារហើយ ជ័យជម្នះកើតដល់ព្រះសិទ្ធត្ថកុមារហើយ ពួកយើងនឹងធ្វើការបូជានូវជ័យជម្នះ ដូច្នេះ កាន់គ្រឿងក្រអូប និងកម្រងផ្កាជាដើម មកកាន់ពោធិបល្ល័ង្ក ដែលជាសម្នាក់នៃមហាបុរស ។

ក្នុងកាលនោះ ពួកទេវតាមានចិត្តត្រេកអរ ប្រកាសនូវជ័យ
ជម្នះរបស់ព្រះមហេសី ត្រង់ពោធិមណ្ឌលថា ព្រះពុទ្ធដ៏មាន
សិរី ទ្រង់មានជ័យជម្នះ មារមានចិត្តបាប ចាញ់ព្រះអង្គ
ហើយ ។

ក្នុងកាលនោះ ពួកនាគមានចិត្តត្រេកអរ ប្រកាសនូវជ័យ
ជម្នះរបស់ព្រះមហេសី ត្រង់ពោធិមណ្ឌលថា ព្រះពុទ្ធមានសិរី
ទ្រង់មានជ័យជម្នះ មារមានចិត្តបាប ចាញ់ព្រះអង្គហើយ ។

ក្នុងកាលនោះ ពួកគ្រុឌមានចិត្តត្រេកអរ ប្រកាសនូវជ័យជម្នះ
របស់ព្រះមហេសី ត្រង់ពោធិមណ្ឌលថា ព្រះពុទ្ធមានសិរី
ទ្រង់មានជ័យជម្នះ មារមានចិត្តបាប ចាញ់ព្រះអង្គហើយ ។

ក្នុងកាលនោះ ពួកព្រហ្មមានចិត្តត្រេកអរ ប្រកាសនូវជ័យ
ជម្នះរបស់ព្រះមហេសី ត្រង់ពោធិមណ្ឌលថា ព្រះពុទ្ធមានសិរី
ទ្រង់មានជ័យជម្នះ មារមានចិត្តបាប ចាញ់ព្រះអង្គហើយ ។

ទេវតាក្នុងម៉ឺនចក្កវាឡដ៏សេស បានបូជាដោយកម្រងផ្កា គ្រឿងក្រអូប និងគ្រឿងលាប បានពោលសរសើរច្រើនប្រការ ។ កាលព្រះអាទិត្យកំពុង

នៅវេលានោះឯង ព្រះមហាបុរសកម្ចាត់មារ និងសេនាបាន ត្រួយមហាពោធិ-ព្រឹក្ស បានធ្លាក់លើចីវរដូចស្រទាប់កែវប្រពាលក្រហមបូជា ទ្រង់រឭកនូវបុព្វេនិវាសញ្ញាណបានក្នុងបឋមយាម ទ្រង់ជម្រះទិព្វចក្ខុបានក្នុងមជ្ឈិមយាម ទ្រង់ញុំាំងព្រះញាណឲ្យធ្លាក់ចុះក្នុងបដិច្ចសមុប្បាទបានក្នុងបច្ឆិមយាម ។ កាលព្រះមហាបុរសពិចារណាបច្ចយាការ ដែលប្រកបដោយអង្គ ១២ ដោយអនុលោម និងបដិលោម ដោយអំណាចវដ្ដ និងវិវដ្ដ មុឺនលោកធាតុ បានញាប់ញ័រអស់ ១២ ដង ទល់គ្នានឹងទឹកទ្រផែនដី ។ កាលព្រះមហាបុរសញុំាំងមុឺនលោកធាតុឲ្យលាន់ឮហើយ ទ្រង់ធ្វើឲ្យជាក់ច្បាស់នូវព្រះសព្វញ្ញុ-តញ្ញាណក្នុងពេលអរុណរះ លោកធាតុមួយមុឺនក៏មានការតាក់តែងដូចគ្នា ។ ទង់ជ្វាលាដែលលើកឡើង ត្រង់កណ្ដាប់ចក្កវាឡទិសខាងកើត ទៅទល់គ្នានឹងកណ្ដាប់ចក្កវាឡទិសខាងលិច ។ម្យ៉ាងទៀត ទង់ជ្វាលាដែលលើកឡើងត្រង់កណ្ដាប់ចក្កវាឡទិសខាងលិច ក៏ទៅទល់គ្នានឹងកណ្ដាប់ចក្កវាឡទិសខាងកើត ។ ទង់ជ្វាលាដែលលើកឡើង ត្រង់កណ្ដាប់ចក្កវាឡទិសខាងត្បូង ទៅទល់គ្នានឹងកណ្ដាប់ចក្រវាលទិសខាងជើង ។ ទង់ជ្វាលា ដែលលើកឡើងត្រង់កណ្ដាប់ចក្កវាឡទិសខាងជើង ទៅទល់គ្នានឹងកណ្ដាប់ចក្កវាឡទិសាខាងត្បូង ។ ទង់ជ្វាលាដែលលើកឡើងត្រង់ផែនដី ទៅទល់គ្នានឹងព្រហ្មលោក ។ទង់ជ្វាលា ដែលលើកឡើងត្រង់ព្រហ្មលោក ក៏មកទល់គ្នានឹងផែនដី ។ ដើមឈើផ្កា ក្នុងមុឺនចក្កវាឡក៏ចេញផ្កា ដើមឈើផ្លែ ក៏ពេញទៅដោយចង្កោមផ្លែផ្កាឈូកដើមក៏ចេញផ្កាអំពីដើម ផ្កាឈូកមែកក៏ចេញផ្កាអំពីមែក ឈូកវល្លិ

ក៏ចេញផ្កាអំពីវល្លិ ឈូកសំយុងក្នុងអាកាស ក៏ចេញផ្កាក្នុងអាកាស ឈូកប្រភេទទង ក៏ទម្លាយផ្ទាំងថ្មដុះឡើងជាស្រទាប់ៗ ត្រួតគ្នាជា ១០០ ស្រទាប់ ។ ម៉ឺនលោកធាតុ ដេរដាសដោយផ្កា ដូចសំណុំផ្កាដែលរួមចូលគ្នាហើយបោះទៅ និងដូចកម្រាលផ្កាដែលគេក្រាលយ៉ាងល្អ ដូច្នោះ ។ លោកន្តរិកនរកទំហំ ៨០០០ យោជន៍ ត្រង់ចន្លោះចក្រវាឡទាំងឡាយមិនធ្លាប់ភ្លឺ សូម្បីពន្លឺព្រះអាទិត្យរះឡើង ៧ ក្នុងកាលនោះ ក៏មានពន្លឺដូចគ្នា ។ មហាសមុទ្រជម្រៅ ៨ ម៉ឺន ៤ ពាន់យោជន៍ ក៏ក្លាយជាទឹកផ្អែម ស្ទឹងទាំងឡាយមិនហូរ មនុស្សខ្វាក់អំពីកំណើតមើលឃើញរូប មនុស្សថ្លង់អំពីកំណើតបានឮសំឡេង មនុស្សខ្វិនអំពីកំណើតក៏ដើរបាន ចំណង គឺខ្នោះឃ្នាងជាដើម ក៏របើកទៅឯង ។

ព្រះមហាបុរសដែលទេវតា និងមនុស្សទាំងឡាយបូជាដោយសិរីសម្បត្តិមិនមានប្រមាណ ដោយប្រការយ៉ាងនេះ កាលអច្ឆរិយធម៌ទាំងឡាយ មានប្រការមិនមែនតិចប្រាកដហើយ ទ្រង់ចាក់ធ្លុះនូវសព្វញ្ញុតញ្ញាណហើយ ទើបទ្រង់បន្លឺឧទាន ដែលព្រះពុទ្ធទាំងពួងមិនបានលះបង់ថា

កាលតថាគតមិនទាន់បានជួបប្រទះ ( ពោធិញ្ញាណវល់តែ )
ស្វះស្វែងរកជាងផ្ទះ គឺតណ្ហា អ្នកធ្វើផ្ទះ គឺអត្តភាព ក៏អន្ទោល
ទៅកាន់សង្សារវដ្តមានជាតិដ៏ច្រើន សេចក្តីកើតជាទុក្ខរឿយៗ ។
នែជាងផ្ទះ អ្នកឯងធ្វើផ្ទះ គឺអត្តភាព តថាគតឃើញហើយ
អ្នកនឹងធ្វើផ្ទះ ( របស់តថាគត ) ទៀត មិនបានឡើយ
ធ្នឹមជំនីរ គឺកិលេសរបស់អ្នកទាំងអស់ តថាគតកាច់បំបាក់

អស់ហើយ ដំបូលផ្ទះ គឺអវិជ្ជា តថាគតកម្ចាត់ចោលហើយ ចិត្តរបស់តថាគតដល់ព្រះនិព្វាន ដែលមានសង្ខារប្រាស ហើយ តថាគតបានដល់ធម៌ ជាគ្រឿងក្ស័យតណ្ហាទាំងឡាយ ហើយ ដូច្នេះ ។

រយៈកាលចាប់អំពីតុសិតភព រហូតមកដល់សម្រេចសព្វញ្ញុតញ្ញាណ ត្រង់ពោធិមណ្ឌលនេះ គប្បីជ្រាបថា ឈ្មោះថា **អវិទូរេនិទាន** ដោយប្រការដូច្នេះ ។

**អវិទូរេនិទានចប់**

# សន្តិកេនិទានកថា

សន្តិកេនិទាន លោកពោលថា បានដល់ រឿងដែលកើតឡើងតែមួយរឿងក្នុងទីផ្សេងៗ ដូចពាក្យថា សម័យមួយ ព្រះមានព្រះភាគ ទ្រង់គង់នៅក្នុងវត្តជេតពន ដែលជាអារាមរបស់អនាថបិណ្ឌិកសេដ្ឋី ជិតក្រុងសាវត្ថី ដូច្នេះ និងថា ទ្រង់គង់នៅក្នុងកូដាគារសាលា ត្រង់ព្រៃមហាវ័ន ក្បែរក្រុងវេសាលី ដូច្នេះជាដើម លោកពោលយ៉ាងនេះក៏ពិត តែទោះជាយ៉ាងនោះគប្បីជ្រាបសន្តិកេនិទាននោះ តាំងអំពីដើមដូចតទៅ

ព្រះមានព្រះភាគ ទ្រង់គង់លើជយបល្ល័ង្ក ទ្រង់បន្លឺឧទានហើយ មានព្រះតម្រិះយ៉ាងនេះថា តថាគតអន្ទោលទៅអស់ ៤ អសង្ខេយ្យ និង ១ សែនកប្ប ព្រោះហេតុនៃបល្ល័ង្កនេះ ព្រោះហេតុនៃបល្ល័ង្កនេះទៀតនោះឯងតថាគតបានកាត់ក្បាល ដែលប្រដាប់ហើយ ត្រង់កឲ្យទៅជាទាន អស់កាលមានប្រមាណប៉ុណ្ណោះ តថាគតខ្វេះភ្នែកដែលបន្តក់ល្អហើយ និងពុះទ្រូង រួងយកហទយៈឲ្យទៅហើយ តថាគតឲ្យបុត្រ ដូចជាជាលីកុមារ ឲ្យធីតា ដូចជាកណ្ហាជិនាកុមារី និងឲ្យភរិយា ដូចព្រះនាងមទ្រីទេវី ដើម្បីជាខ្ញុំបម្រើរបស់អ្នកដទៃ បល្ល័ង្ករបស់តថាគតនេះ ជាបល្ល័ង្កជ័យ ជាបល្ល័ង្កមាំទាំ កាលតថាគតអង្គុយលើបល្ល័ង្កនេះ តម្រិះបានពេញបរិបូណ៌ តថាគតនឹងមិនចេញចាកបល្ល័ង្កនេះ ដូច្នេះ ទើបទ្រង់គង់ចូលសមាបត្តិច្រើនសែនកោដិ ត្រង់បល្ល័ង្កនោះឯងអស់ ៧ ថ្ងៃ ដែលលោកសំដៅដល់ថា គ្រានោះឯង ព្រះមានព្រះភាគ ទ្រង់គង់សោយវិមុត្តិសុខដោយភ្នែន ១ អស់ ១ សប្តាហ៍ជាដើម ។

កាលនោះ ទេវតាពួកខ្លះ កើតនូវបរិវិតក្កថា ថ្ងៃនេះ ព្រះសិទ្ធត្ថក៏នៅ

មានកិច្ចដែលត្រូវធ្វើពិត ព្រោះមិនអាចលះអាល័យក្នុងបល្ល័ង្ក ព្រះសាស្តាទ្រង់ជ្រាបបរិវិតក្ករបស់ទេវតាទាំងឡាយ ដើម្បីទ្រង់រម្ងាប់បរិវិតក្ករបស់ទេវតាទាំងនោះ ទើបហោះឡើងកាន់អាកាស សម្តែងយមកប្បាដិហារ្យ ។ ពិតហើយ បាដិហារ្យដែលទ្រង់ធ្វើត្រង់មហាពោធិមណ្ឌលក្តី បាដិហារ្យដែលទ្រង់ធ្វើក្នុងសមាគមព្រះញាតិក្តី បាដិហារ្យដែលទ្រង់ធ្វើក្នុងសមាគមអ្នកបាដលិបុត្តក្តី ទាំងអស់ ដូចគ្នានឹងយមកប្បាដិហារ្យ ដែលទ្រង់ធ្វើត្រង់គល់គណ្ឌាម្ពព្រឹក្ស ( គាល់ស្វាយ ) ។

ព្រះសាស្តា កាលទ្រង់រម្ងាប់វិតក្ករបស់ទេវតាទាំងឡាយ ដោយបាដិហារ្យនេះយ៉ាងនេះហើយ ទើបទ្រង់ឈរត្រង់ទិសខាងជើង ចៀងខាងកើតឆ្ងាយអំពីបល្ល័ង្កបន្តិច ទ្រង់ព្រះតម្រិះថា តថាគតត្រាស់ដឹងសព្វញ្ញុតញ្ញាណត្រង់បល្ល័ង្កនេះហ្ន៎ ទើបទ្រង់មិនប៉ប្រិចភ្នែកទតបល្ល័ង្ក និងដើមពោធិ៍ដែលជាទីសម្រេចផលនៃបារមីទាំងឡាយ ដែលទ្រង់បំពេញមកអស់ ៤ អសង្ខេយ្យ និង ១ សែនកប្ប ទ្រង់សម្ងំនៅអស់ ១ សប្តាហ៍ ទើបទីនោះ ឈ្មោះថា **អនិមិសចេតិយ ។**

លំដាប់នោះ ព្រះសាស្តាទ្រង់និម្មិតទីចង្រ្កមក្នុងរវាងបល្ល័ង្ក និងទីដែលទ្រង់ឈរទ្រង់ចង្រ្កមលើរតនចង្រ្កម ដែលលាតសន្ធឹងពីទិសខាងកើតទៅទិសខាងលិច ទ្រង់សម្ងំអស់មួយសប្តាហ៍ទីនោះ ឈ្មោះថា **រតនចង្កមចេតិយ ។**

ក្នុងសប្តាហ៍ទី ៤ ទេវតាទាំងឡាយ និម្មិតផ្ទះកែវត្រង់ទិសពាយ័ព្យអំពីដើមពោធិ៍ ព្រះមានព្រះភាគទ្រង់គង់ពត់ភ្នែនក្នុងផ្ទះកែវនោះ ទ្រង់ពិចារណា

អភិធម្មបិដក និងសមន្តប្បដ្ឋានអនន្តន័យ ក្នុងព្រះអភិធម្មបិដកនោះ ដោយពិសេសក្រៃលែងឡើង ឲ្យសប្តាហ៍ ១ កន្លងទៅ ។ ឯអ្នកអភិធម្មទាំងឡាយពោលថា ឈ្មោះថា ផ្ទះកែវ មិនមែនផ្ទះកែវដែលធ្វើដោយកែវ ៧ ប្រការទេ តែជាទីដែលទ្រង់ពិចារណាបករណ៍ទាំង ៧ ទើបហៅថា ផ្ទះកែវ ។ តែព្រោះហេតុដែលរឿងទាំង ២ នោះ ចូលគ្នាបានក្នុងទីនេះដោយបរិយាយ ព្រោះហេតុនោះ គួរកាន់យកទាំង ២ រឿងនោះឯង ។ ចាប់តាំងពីនោះមក ទើបទីនោះ ឈ្មោះថា **រតនឃរចេតិយ** ។

ព្រះសាស្តា ទ្រង់នៅសម្ងំ ៤ សប្តាហ៍ក្នុងបរិវេណ ជិតគល់ពោធិព្រឹក្សប៉ុណ្ណោះ ដោយប្រការយ៉ាងនេះ ក្នុងសប្តាហ៍ទី ៥ យាងចេញអំពីមណ្ឌលពោធិព្រឹក្ស ទៅកាន់អជបាលនិគ្រោធ ទ្រង់គង់ពិចារណាព្រះធម៌ និងសោយនូវវិមុត្តិសុខ ត្រង់ដើមអជបាលនិគ្រោធនោះ ។

សម័យនោះ មារមានចិត្តបាបគិតថា អាត្មាអញជាប់តាមអស់កាលមានប្រមាណប៉ុណ្ណោះ សូម្បីសម្លឹងមើលឱកាស ក៏មិនបានឃើញការភ្លាំងភ្លាត់ណាមួយរបស់សិទ្ធត្ថនេះ ឥឡូវនេះ សិទ្ធត្ថនេះឈានកន្លងផុតអំណាចរបស់អញហើយ ទើបដល់នូវសេចក្តីទោមនស្ស អង្គុយនៅក្នុងផ្លូវធំ គិតដល់ហេតុ ១៦ ប្រការ ទើបគូសគំនូស ១៦ លើផែនដី គឺគិតថា អញមិនបានបំពេញទានបារមី ដូចព្រះសិទ្ធត្ថនេះ ព្រោះហេតុនោះ ទើបអញមិនដូចព្រះសិទ្ធត្ថនេះ ដូច្នេះហើយ គូស ១ ។ បន្តទៀត គិតថា អញមិនបានបំពេញសីលបារមី ។បេ។ នេក្ខម្មបារមី បញ្ញាបារមី វីរិយបារមី ខន្តិបារមី សច្ចបារមី អធិដ្ឋាន-

បារមី មេត្តាបារមី ឧបេក្ខាបារមី ដូចសិទ្ធត្ថនេះ ព្រោះហេតុនោះ ទើបអញមិនដូចសិទ្ធត្ថនោះ ដូច្នេះហើយ ទើបគូសគំនូសទី ១០ ។ ជាបន្តទៀត គិតថា អញមិនបានបំពេញបារមី ១០ ដែលជាឧបនិស្ស័យ ដល់ការចាក់ធ្លុះនូវឥន្ទ្រិយបរោបរិយត្តិញាណ ដែលមិនទូទៅដល់អ្នកដទៃដូចសិទ្ធត្ថនេះ ព្រោះហេតុនោះ ទើបអញមិនបានដូចសិទ្ធត្ថនេះ ដូច្នេះហើយ គូសគំនូសទី ១១ ។ ជាបន្តទៀត គិតថា អញមិនបានបំពេញបារមី ១០ ដែលជាឧបនិស្ស័យដល់ការចាក់ធ្លុះអាសយានុសយញ្ញាណ ... មហាករុណាសមាបត្តិញ្ញាណ... យមកប្បាដិហារិយញ្ញាណ ... អនាវរណញ្ញាណ ... អញមិនបានបំពេញបារមី ១០ ដែលជាឧបនិស្ស័យដល់ការចាក់ធ្លុះសព្វញ្ញុតញ្ញាណ ដែលមិនទូទៅដល់អ្នកដទៃ ដូចសិទ្ធត្ថនេះ ព្រោះហេតុនោះ ទើបអញមិនដូចព្រះសិទ្ធត្ថនេះ ដូច្នេះហើយ គូសគំនូសទី ១៦ ។ មារអង្គុយគូសគំនូស ១៦ ត្រង់ផ្លូវធំព្រោះហេតុដូចពោលមកនេះ ដោយប្រការដូច្នេះ ។

សម័យនោះ ធីតារបស់មារ ៣ នាក់ គឺនាងតណ្ហា ១ នាងរាគា ១ នាងអរតី ១ គិតថា បិតារបស់ពួកយើងមិនប្រាកដ ឥឡូវនេះ នៅឯណាហ្ន៎ ទើបនាំគ្នារកមើល បានឃើញបិតាដល់នូវទោមនស្ស អង្គុយគូសផែនដី ទើបនាំគ្នាទៅកាន់សម្នាក់របស់បិតា ហើយសួរថា បពិត្របិតា ព្រោះហេតុអ្វី ទើបលោកឪពុកដល់នូវសេចក្តីទុក្ខកង្វល់ក្នុងចិត្ត ។ មារពោលថា នែកូន មហាសមណៈនេះ កន្លងផុតអំណាចរបស់បិតាហើយ បិតាឃ្លាំមើលអស់កាលមានប្រមាណប៉ុណ្ណេះ ក៏មិនឃើញឱកាស គឺទោសរបស់មហាសមណៈ

នេះទេ ព្រោះហេតុនោះ ទើបបិតាកើតទុក្ខកង្វល់ក្នុងចិត្ត ធីតាមារពោលថា បើដូច្នោះ បិតាកុំទោមនស្សឡើយ កូននឹងធ្វើឲ្យមហាសមណៈនោះ ធ្លាក់នៅក្នុងអំណាចរបស់ខ្លួន ហើយនាំមក ។ មារពោលថា នែកូន មហាសមណៈនេះ បុគ្គលណាមួយ មិនអាចធ្វើឲ្យនៅក្នុងអំណាចបានឡើយ បុរសនេះតាំងនៅក្នុងសទ្ធាដែលមិនញាប់ញ័រ ធីតាមារពោលថា បពិត្របិតា ពួកកូនឈ្មោះថាជាស្រី កូននឹងយកអន្ទាក់ គឺរាគៈជាដើម ចងមហាសមណៈនោះ នាំមកឥឡូវនេះឯង បិតាកុំគិតថ្វីឡើយ កាលពោលហើយ ទើបចូលទៅរកព្រះមានព្រះភាគទូលថា បពិត្រសមណៈ ពួកខ្ញុំនឹងបម្រើបាទារបស់ព្រះអង្គ ព្រះមានព្រះភាគទ្រង់មិនបានដាក់ចិត្តដល់ពាក្យរបស់ពួកនាង ទ្រង់មិនបើកព្រះនេត្រមើល ទ្រង់គង់សោយវិវេកសុខតែម្យ៉ាង ព្រោះទ្រង់បង្អោនព្រះហឫទ័យទៅក្នុងធម៌ ជាគ្រឿងអស់ទៅនូវឧបធិដ៏កំពូល ។

ធីតាមារគិតគ្នាថា បំណងរបស់ពួកបុរសមិនពិតប្រាកដឡើយ បុរសខ្លះ ស្រឡាញ់ស្រីក្មេង បុរសខ្លះ ស្រឡាញ់ស្រីនៅក្នុងបឋមវ័យ បុរសខ្លះ ស្រឡាញ់ស្រីនៅក្នុងមជ្ឈិមវ័យ បុរសខ្លះ ស្រឡាញ់ស្រីនៅក្នុងបច្ឆិមវ័យ បើដូច្នោះ ពួកយើងគួរយករូបផ្សេងៗ ចូលទៅលួងលោម ហើយចាប់យកទើបស្រីនីមួយៗ និម្មិតអត្តភាពរៀងៗ ខ្លួន ឲ្យជារូបស្រីក្មេងជាដើម គឺជារូបស្រីក្មេង ជាស្រីមិនទាន់ប្រសូត ជាស្រីប្រសូតម្តង ជាស្រីប្រសូត ២ ដង ជាស្រីកណ្តាលមនុស្ស ជាស្រីចំណាស់ ចូលទៅរកព្រះមានព្រះភាគ អស់ ៦ ដង ហើយទូលថា បពិត្រសមណៈ យើងខ្ញុំទាំងឡាយ នឹងបម្រើបាទា

របស់ព្រះអង្គ ដូច្នោះ ព្រះមានព្រះភាគ ទ្រង់មិនបានដាក់ព្រះហឫទ័យ ព្រោះទ្រង់បង្អោនព្រះហឫទ័យទៅក្នុងធម៌ ជាគ្រឿងអស់ទៅនូវឧបធិដ៏កំពូល ។

ឯអាចារ្យពួកខ្លះពោលថា ព្រះមានព្រះភាគ ទ្រង់ឃើញមារធីតាទាំងនោះ ចូលទៅរកដោយកាឡាខ្លួនជាស្រីចំណាស់ ទើបទ្រង់អធិដ្ឋានថា ស្រីទាំងនេះ ចូរជាមនុស្សធ្មេញបាក់ សក់ស្កូវ ។ ពាក្យរបស់អាចារ្យនោះ មិនគួរកាន់យក ព្រោះព្រះមានព្រះភាគ ទ្រង់មិនធ្វើអធិដ្ឋានបែបនោះ តែព្រះមានព្រះភាគត្រាស់ថា ចូរពួកនាងចៀសចេញទៅ ពួកនាងឃើញអ្វី ទើបព្យាយាមយ៉ាងនេះ គួរធ្វើកម្មបែបនេះ ខាងមុខរបស់ពួកបុគ្គលដែលមិនទាន់ប្រាសចាករាគៈជាដើម ឯតថាគតលះរាគៈ ទោសៈ មោហៈហើយ ទើបទ្រង់ប្រារព្ធដល់ការលះកិលេសរបស់ព្រះអង្គ ទ្រង់សម្តែងធម្មកថា ២ គាថា ក្នុងធម្មបទ ពុទ្ធវគ្គដូច្នេះថា

ជ័យជម្នះរបស់ព្រះពុទ្ធអង្គណា មិនត្រឡប់ចាញ់វិញ កិលេស
ណាមួយក្នុងលោក រមែងមិនជាប់តាមជ័យជម្នះរបស់ព្រះពុទ្ធ
អង្គនោះ នាងទាំងឡាយ នឹងប្រលោមព្រះពុទ្ធអង្គនោះ ដែល
មានគោចររកទីបំផុតគ្មាន មិនមានកិលេស ដូចស្នាមជើង
ដោយកិលេសដូចស្នាមជើង ម្តេចកើត ។
តណ្ហា ដែលមានបណ្តាញផ្សាយទៅក្នុងអារម្មណ៍ផ្សេងៗ មិន
មានដល់ព្រះពុទ្ធអង្គណា ដើម្បីនឹងនាំទៅក្នុងភពណាមួយ
នាងទាំងឡាយ នឹងប្រលោមព្រះពុទ្ធអង្គនោះ ដែលមាន

គោចរ រកទីបំផុតគ្មាន មិនមានកិលេសដូចស្នាមជើង ដោយ
កិលេសដូចស្នាមជើង ម្ដេចកើត ដូច្នេះ ។

មារធីតាទាំងនោះ នាំគ្នាពោលពាក្យជាដើមថា ពិតហើយ បិតារបស់ពួកយើងបានពោលថា ព្រះអរហន្តសុគតក្នុងលោក បុគ្គលណាមួយនឹងនាំទៅបានងាយៗ ដោយរាគៈមិនបានឡើយ ដូច្នេះជាដើម ហើយនាំគ្នាត្រឡប់មកកាន់សម្នាក់របស់បិតា ។

ឯព្រះមានព្រះភាគ ទ្រង់សម្រាំនៅត្រង់អជបាលនិគ្រោធនោះឯងអស់ ១ សប្ដាហ៍ បន្ទាប់អំពីនោះ បានយាងទៅកាន់គល់មុចលិន្ទ ។ ក្នុងទីនោះ ភ្លៀងក៏ធ្លាក់អស់ ៧ ថ្ងៃ ដើម្បីការពារនូវរងាជាដើម ស្ដេចនាគឈ្មោះមុចលិន្ទ យកខ្លួនព័ទ្ធជារង្វេលជុំវិញព្រះមានព្រះភាគ ៧ ជុំ ព្រះមានព្រះភាគ ហាក់ដូចប្រថាប់គង់ក្នុងព្រះគន្ធកុដិដែលមិនចង្អៀត សោយវិមុត្តិសុខអស់ ១ សប្ដាហ៍ ហើយយាងចូលទៅកាន់ដើមរាជាយតនៈ ( ដើមកែស ) ក្នុងទីនោះ ទ្រង់សោយវិមុត្តិសុខអស់ ១ សប្ដាហ៍ ។ ដោយលំដាប់ កាលមានប្រមាណប៉ុណ្ណេះ រួមជា ៧ សប្ដាហ៍ដោយបរិបូណ៌ ។

ក្នុងរវាងនេះ មិនមានការស្រង់ព្រះភក្ត្រ មិនមានកិច្ចបដិបត្តិព្រះសរីរៈ មិនមានកិច្ចដោយព្រះក្រយាហារ ទ្រង់សម្រាំដោយឈានសុខ និងផលសុខប៉ុណ្ណោះ ។

ក្នុងថ្ងៃទី ៤៩ ដែលជាថ្ងៃចុងក្រោយរបស់ ៧ សប្ដាហ៍នោះ កាលព្រះមានព្រះភាគគង់ត្រង់ដើមរាជាយតនៈនោះ ទ្រង់កើតនូវព្រះតម្រិះថា នឹង

ខ្ចីព្រះឱស្ឋ សក្កទេវរាជស្តេចទេវតា ទ្រង់បាននាំផ្លែសម៉ ដែលជាថ្នាំធម្មជាតិមកថ្វាយ ។ ព្រះសាស្តាទ្រង់សោយផ្លែសម៉នោះ ដោយផ្លែសម៉នោះទើបទ្រង់មានការបន្ទោបង់ព្រះឧច្ចារៈ ។ លំដាប់នោះ សក្កទេវរាជនោះឯងបានថ្វាយឈើស្ទន់ ឈ្មោះនាគលតា និងទឹកខ្ចីព្រះឱស្ឋដល់ព្រះអង្គ ។ ព្រះសាស្តាទ្រង់ទំពាឈើស្ទន់នោះហើយ ខ្ចីព្រះឱស្ឋ ដោយទឹកមកអំពីអនោតត្តស្រះ ស្រេចហើយ គង់ប្រថាប់ត្រង់គល់រាជាយតនៈនោះឯង ។

សម័យនោះ ពាណិជ ២ នាក់ ឈ្មោះតបុស្សៈ និងភល្លិកៈធ្វើដំណើរមកអំពីឧក្កលជនបទ នឹងទៅកាន់មជ្ឈិមបទេស ដោយរទេះ ៥០០ ត្រូវទេវតាជាញាតិសាលោហិតរបស់ខ្លួនក្នុងជាតិមុនរារាំងរទេះ បបួលឲ្យថ្វាយព្រះក្រយាហារដល់ព្រះសាស្តា ទើបកាន់យកសត្តុវជុំ និងនំដែលផ្សំដោយទឹកឃ្មុំ ហើយក្រាបទូលថា បពិត្រព្រះអង្គដ៏ចម្រើន សូមព្រះមានព្រះភាគទ្រង់អាស្រ័យសេចក្តីអនុគ្រោះ ទទួលព្រះក្រយាហាររបស់ខ្ញុំព្រះអង្គទាំងឡាយចុះ ដូច្នេះហើយ បង្អោនថ្វាយព្រះសាស្តាហើយឈរ ។ ព្រោះបាត្រដែលអន្តរធានទៅ ក្នុងថ្ងៃទទួលបាយាស ទើបព្រះមានព្រះភាគទ្រង់ព្រះតម្រិះថា ព្រះតថាគតទាំងឡាយ រមែងមិនទទួលដោយដៃទេ តថាគតទទួលដោយអ្វីហ្ន៎ លំដាប់នោះ មហារាជ ៤ អង្គ មកអំពីទិសទាំង ៤ ដឹងព្រះតម្រិះរបស់ព្រះមានព្រះភាគ ទើបបង្អោនថ្វាយនូវបាត្រទាំងឡាយ ដែលសម្រេចហើយដោយកែវឥន្ទនីល ព្រះមានព្រះភាគទ្រង់មិនទទួលបាត្រទាំងនោះ មហារាជទាំង ៤ ក៏បង្អោនបាត្រ ៤ ដែលសម្រេចហើយដោយថ្ម មានពណ៌

ដូចសណ្តែកបាយ កាលទ្រង់រក្សានូវសទ្ធារបស់មហារាជទាំង ៤ ទើបទ្រង់ទទួលបាត្រទាំង ៤ ទ្រង់ដាក់ត្រួតលើគ្នាហើយ អធិដ្ឋានថា ចូរជាបាត្រតែមួយ ទើបបាត្រទាំង ៤ រួមចូលគ្នាតែមួយ មានស្នាមប្រាកដត្រង់កណ្តាប់មាត់ ជាបាត្រខ្នាតកណ្តាល ។ ព្រះមានព្រះភាគ ទ្រង់ទទួលព្រះក្រយាហារត្រង់បាត្រដែលសម្រេចហើយដោយសិលា ដែលមានតម្លៃច្រើននោះ សោយហើយ បានធ្វើអនុមោទនា ។ ពាណិជពីរនាក់បងប្អូននោះ ដល់នូវព្រះពុទ្ធនិងព្រះធម៌ជាសរណៈ បានជាទ្វេវាចិកឧបាសក គឺឧបាសកដែលដល់សរណៈ ២ ។ លំដាប់នោះ កាលពាណិជទាំង ២ នោះ ក្រាបទូលថា បពិត្រព្រះអង្គដ៏ចម្រើន សូមទ្រង់ប្រទានឋានៈដែលគួរបតិបត្តិដល់ខ្ញុំព្រះអង្គទាំង ២ ចុះ ។ ព្រះមានព្រះភាគ យកព្រះហស្តស្តាំ ស្ទាបសីសៈរបស់ព្រះអង្គ ហើយបានប្រទានព្រះកេសធាតុទាំងឡាយ ។ ពាណិជទាំង ២ នោះ ដាក់ព្រះកេសធាតុទាំងនោះក្នុងប្រអប់មាស ប្រតិស្ឋានចេតិយទុកក្នុងនគររបស់ខ្លួន ។

ចាប់តាំងពីនោះ ព្រះសម្មាសម្ពុទ្ធយាងត្រឡប់ទៅកាន់ដើមអជបាលនិគ្រោធទៀត ហើយគង់ត្រង់គល់និគ្រោធ ។ កាលព្រះសម្មាសម្ពុទ្ធនោះ គង់ត្រង់គល់និគ្រោធនោះប៉ុណ្ណោះ ទ្រង់ពិចារណាឃើញថា ធម៌ដែលព្រះអង្គត្រាស់ដឹងហើយ ជាធម៌ជ្រាលជ្រៅ ការត្រិះរិះដែលព្រះពុទ្ធទាំងឡាយ ធ្លាប់ប្រព្រឹត្តមកដល់អាការ គឺការមិនបំណងនឹងសម្តែងធម៌ដល់ជនដទៃកើតឡើងថា ធម៌នេះ តថាគតសម្រេចបានដោយលំបាក ។

លំដាប់នោះ សហម្បតីព្រហ្មត្រិះរិះថា លោកដ៏ចម្រើនទាំងឡាយ លោកនឹងវិនាសហ្ន៎ លោកដ៏ចម្រើនទាំងឡាយ លោកនឹងវិនាសហ្ន៎ ទើបនាំសក្កទេវរាជ ស្តេចសុយាម ស្តេចសន្តុសិត ស្តេចនិម្មានរតី ស្តេចវសវត្តី និងមហាព្រហ្ម អំពីចក្កវាឡទាំង ១ ម៉ឺន មកកាន់សម្នាក់នៃព្រះសាស្តា ទូលអារាធនាឲ្យទ្រង់សម្តែងធម៌ ដោយន័យជាដើមថា បពិត្រព្រះអង្គដ៏ចម្រើន សូមព្រះមានព្រះភាគទ្រង់សម្តែងធម៌ចុះ ។

ព្រះសាស្តាទ្រង់ឲ្យបេ្តជ្ញាដល់សហម្បតីព្រហ្មនោះ ហើយទ្រង់ព្រះតម្រិះថា តថាគតគួរសម្តែងធម៌ដំបូងដល់អ្នកណាហ្ន៎ ទ្រង់ញុំាងព្រះតម្រិះឲ្យកើតឡើងថា អាឡារតាបសជាបណ្ឌិត នឹងដឹងធម៌នេះបានឆាប់រួសរាន់ ទើបទ្រង់ប្រមើលមើលទៀត ទ្រង់ក៏ជ្រាបថា អាឡារតាបសនោះធ្វើកាលកិរិយាបាន ៧ ថ្ងៃហើយ ទើបទ្រង់រំពឹងដល់ឧទកតាបស ទ្រង់ក៏ជ្រាបថា ឧទកតាបសនោះបានធ្វើកាលកិរិយាកាលពីព្រលប់ម្សិលមិញនេះ ទ្រង់ក៏មនសិការ ប្រារព្ធដល់បញ្ចវគ្គិយភិក្ខុថា បញ្ចវគ្គិយភិក្ខុមានឧបការៈច្រើនដល់តថាគត ទើបទ្រង់ព្រះតម្រិះថា ឥឡូវនេះ បញ្ចវគ្គិយភិក្ខុទាំងនោះ នៅក្នុងទីណាហ្ន៎ ទ្រង់ក៏ជ្រាបថា នៅត្រង់ព្រៃឥសិបតនមិគទាយវ័ន ក្រុងពារាណសី ទើបត្រាច់បិណ្ឌបាតក្នុងបរិវេណជុំវិញពោធិមណ្ឌល គង់ប្រថាប់ពីរបីថ្ងៃហើយ ទ្រង់ព្រះតម្រិះថា ក្នុងថ្ងៃ ១៥ កើត ខែអាសាឍ តថាគតនឹងទៅកាន់ក្រុងពារាណសី ប្រកាសធម្មចក្ក ទើបក្នុងតិថីទី ១៤ នៃបក្ខ វេលាបច្ចូសសម័យ កាលរាត្រីអស់ហើយ ព្រឹកឡើងទ្រង់កាន់បាត្រ និងចីវរ យាងទៅអស់ចម្ងាយផ្លូវ ១៨

យោជន៍ ក្នុងរវាងផ្លូវ ទ្រង់ជួបឧបកាជីវក ទើបត្រាស់ប្រាប់ថា ទ្រង់ជាព្រះពុទ្ធដល់ឧបកាជីវកនោះ ហើយយាងដល់ព្រៃឥសិបតនៈ ក្នុងវេលាល្ងាចថ្ងៃនោះឯង ។

បញ្ចវគ្គិយឃើញព្រះតថាគតយាងមកអំពីចម្ងាយ បានធ្វើកតិកាគ្នាថា នែអាវុសោទាំងឡាយ ព្រះសមណគោតមនេះ វិលមកដើម្បីភាពជាអ្នកប្រាថ្នាច្រើនក្នុងបច្ច័យ មានរាងកាយបរិបូណ៌ មានឥន្ទ្រិយផូរផង់ មានពណ៌ដូចមាស កំពុងយាងមក ពួកយើងនឹងមិនធ្វើសាមីចិកម្ម មានការថ្វាយបង្គំជាដើមដល់ព្រះសមណគោតមនេះ តែលោកប្រសូតក្នុងត្រកូលធំ គួររៀបចំអាសនៈ ដោយហេតុនោះ ពួកយើងក្រាលអាសនៈ ដើម្បីលោកក៏ល្មមគ្រប់គ្រាន់ ។

ព្រះមានព្រះភាគ ទ្រង់ពិចារណាថា បញ្ចវគ្គិយភិក្ខុទាំងនេះ គិតគ្នាដូចម្តេច ក៏បានជ្រាបវារចិត្តដោយព្រះញាណ ដែលអាចជ្រាបវារចិត្តនៃចិត្តរបស់លោក ព្រមទាំងទេវលោក ។ លំដាប់នោះ ទ្រង់សមោធានមេត្តាចិត្តដែលអាចផ្សាយទៅ ដោយអំណាចការផ្សាយទៅដោយមិនចំពោះក្នុងទេវតានិងមនុស្សទាំងឡាយ ហើយទ្រង់ផ្សាយមេត្តាចិត្តទៅក្នុងបញ្ចវគ្គិយទាំងនោះដោយអំណាចការផ្សាយដោយចំពោះ ។ បញ្ចវគ្គិយទាំងនោះ កាលព្រះមានព្រះភាគទ្រង់ឲ្យពាល់ត្រូវដោយមេត្តាចិត្តហើយ កាលព្រះសាស្តាយាងចូលទៅជិត មិនអាចតាំងនៅក្នុងកតិការបស់ខ្លួន នាំគ្នាក្រោកឡើង ធ្វើកិច្ចទាំងពួង មានការអភិវាទជាដើម តែមិនដឹងថា ព្រះមានព្រះភាគជាព្រះសម្មាសម្ពុទ្ធ

ទើបហៅព្រះអង្គដោយព្រះនាម និងដោយពាក្យថា អាវុសោ តាមដែលធ្លាប់ហៅមក ។

លំដាប់នោះ ព្រះមានព្រះភាគ ទ្រង់ឲ្យបញ្ចវគ្គិយទាំងនោះដឹងថា ទ្រង់ជាព្រះពុទ្ធដោយព្រះតម្រាស់ថា ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយកុំហៅតថាគតដោយឈ្មោះ និងដោយពាក្យថា អាវុសោឡើយ ម្នាលភិក្ខុទាំងឡាយ តថាគតជាព្រះអរហន្តសម្មាសម្ពុទ្ធហើយ ដូច្នេះហើយ ប្រថាប់គង់លើពុទ្ធាសនៈដ៏ប្រសើរដែលក្រាល កាលដល់នក្ខត្តឫក្សខែអាសាឍ ដែលព្រហ្ម ១៨ កោដិចោមរោមហើយ ទើបត្រាស់ហៅព្រះថេរៈដែលជាបញ្ចវគ្គិយមក ទ្រង់សម្ដែងព្រះធម្មចក្កប្បវត្តនសូត្រដ៏កំពូល លម្អដោយញាណ ៦ មានបរិវដ្ដ ៣ មានអាការ ១២ ។ បណ្ដាព្រះថេរៈដែលជាបញ្ចវគ្គិយទាំងនោះ ព្រះកោណ្ឌញ្ញត្ថេរបញ្ជូនញាណទៅតាមក្រសែនៃព្រះធម្មទេសនា ក្នុងកាលចប់ព្រះសូត្រ ក៏បានតាំងនៅក្នុងសោតាបត្តិផល មួយអន្លើដោយព្រហ្ម ១៨ កោដិ ។

ព្រះសាស្ដាទ្រង់ចូលវស្សាក្នុងព្រៃឥសិបតនមិគទាយវ័ននោះឯង ស្អែកឡើង ទ្រង់គង់ក្នុងទីសម្រាកប្រទានឱវាទដល់ព្រះវប្បត្ថេរ ព្រះថេរៈដ៏សេសទាំង ៤ រូប ត្រាច់បិណ្ឌបាត ។ ក្នុងវេលាព្រឹកនោះឯង ព្រះវប្បត្ថេរ ក៏សម្រេចសោតាបត្តិផល ដោយវិធីនោះឯង ទ្រង់ឲ្យព្រះថេរៈទាំងអស់ តាំងនៅក្នុងសោតាបត្តិផល គឺក្នុងថ្ងៃស្អែកឡើង ទ្រង់ឲ្យព្រះភទ្ទិយត្ថេរសម្រេចស្អែកឡើងទៀត ទ្រង់ឲ្យមហានាមត្ថេរសម្រេច ស្អែកឡើងទៀត ទ្រង់ឲ្យ

ព្រះអស្សជិត្ថេរសម្រេចក្នុងតិថីទី ៥ នៃបក្ខ ឲ្យព្រះថេរៈទាំង ៥ ប្រជុំគ្នាហើយ ទ្រង់សម្តែងអនត្តលក្ខណសូត្រ ក្នុងកាលចប់ទេសនា ព្រះថេរៈទាំង ៥ រូប តាំងនៅក្នុងអរហត្ត ។

កាលនោះ ព្រះសាស្តាទ្រង់ឃើញឧបនិស្ស័យ របស់យសកុលបុត្រ ទើបត្រាស់ហៅកុលបុត្រនោះ ដែលនឿយណាយក្នុងផ្ទះ ចេញទៅក្នុងកណ្តាល យប់ថា ម្នាលយស មកចុះ ទ្រង់ឲ្យកុលបុត្រនោះ តាំងនៅក្នុងសោតាបត្តិផល ក្នុងយប់នោះឯង ហើយឲ្យតាំងនៅក្នុងអរហត្ត ក្នុងថ្ងៃស្អែកឡើង ទ្រង់ឲ្យជន ៥៤ នាក់ទៀត ដែលជាសម្លាញ់របស់ព្រះយសនោះបព្វជ្ជា ដោយឯហិភិក្ខុ-ឧបសម្បទា ហើយទ្រង់ឲ្យសម្រេចអរហត្ត ។

កាលព្រះអរហន្ត ៦១ អង្គ កើតឡើងក្នុងលោកយ៉ាងនេះហើយ ព្រះសាស្តាទ្រង់ចេញវស្សា បវារណាហើយ ទ្រង់បញ្ជូនភិក្ខុ ៦០ រូប ទៅក្នុងទិសទាំងឡាយ ដោយព្រះតម្រាស់ថា ម្នាលភិក្ខុទាំងឡាយ ចូរពួកអ្នក ត្រាច់ចារិកទៅ ដូច្នេះជាដើម ឯព្រះអង្គយាងទៅកាន់ឧរុវេលាបទេស ក្នុងរវាងផ្លូវ ទ្រង់ទូន្មានភទ្ទវគ្គិយកុមារ ៣០ នាក់ ក្នុងព្រៃកប្បាស បណ្តាភទ្ទវគ្គិយ-កុមារទាំងនោះ បុគ្គលដែលទាបជាងគេ ជាព្រះសោតាបន្ន បុគ្គលដែលក្រៃលែងជាងគេ ជាព្រះអនាគាមី ទ្រង់ឲ្យភទ្ទវគ្គិយកុមារទាំងនោះបព្វជ្ជា ដោយឯហិភិក្ខុដូចគ្នា ហើយទ្រង់បញ្ជូនទៅក្នុងទិសទាំងឡាយ ហើយទ្រង់យាងមកឧរុវេលាបទេស ទ្រង់សម្តែងបាដិហារ្យ ៣៥០០ បាដិហារ្យ ទូន្មានជដិល ៣ នាក់ បងប្អូន មានឧរុវេលកស្សបៈជាដើម មានជដិល ១០០០

រូបជាបរិវារ ទ្រង់ឲ្យបព្វជ្ជាដោយភាពជាឯហិភិក្ខុ ហើយឲ្យអង្គុយប្រជុំគ្នាត្រង់គយាសីសប្រទេស ឲ្យតាំងនៅក្នុងអរហត្ត ដោយអាទិត្តបរិយាយទេសនា ដែលព្រះអរហន្ត ១០០០ អង្គចោមរោម ហើយបានយាងទៅកាន់ឧទ្យានលដ្ឋិវ័ន ក្នុងនគររាជគ្រឹះ ដោយបំណងថា នឹងដោះពាក្យបណ្ដាដែលឲ្យជាមួយព្រះបាទពិម្ពិសារ ។ ព្រះរាជា ទ្រង់ស្ដាប់ដំណឹងអំពីសម្នាក់របស់ឧទ្យានបាលថា ព្រះសាស្ដាយាងមក ទើបទ្រង់ចោមរោមដោយព្រាហ្មណ៍ និងគហបតី ១២ ម៉ឺននាក់ ទ្រង់ចូលទៅគាល់ព្រះសាស្ដា ទ្រង់ឱនព្រះសិរសាទៀបបាទារបស់ព្រះតថាគត ដែលមានផ្ទៃព្រះបាទវិចិត្រដោយរូបចក្រ កំពុងបញ្ចេញរស្មី ដូចពិតានដែលពាសដោយបន្ទះមាស ហើយប្រថាប់គង់ក្នុងចំណែកម្ខាង មួយអន្លើដោយបរិស័ទ ។

លំដាប់នោះ ព្រាហ្មណ៍ និងគហបតីទាំងនោះមានការគិតដូច្នេះថា ព្រះមហាសមណៈប្រព្រឹត្តព្រហ្មចរិយៈ ក្នុងឧរុវេលកស្សបៈ ឬឧរុវេលកស្សបៈប្រព្រឹត្តព្រហ្មចរិយៈក្នុងព្រះមហាសមណៈ ។ ព្រះមានព្រះភាគទ្រង់ជ្រាបនូវបរិវិតក្កនៃចិត្តរបស់ព្រាហ្មណ៍ និងគហបតីទាំងនោះដោយហាទយៈ ទើបត្រាស់នឹងព្រះឧរុវេលកស្សបៈ ដោយព្រះគាថាថា

អ្នកឯងនៅក្នុងឧរុវេលាប្រទេស ជាអ្នកប្រដៅពួកតាបស
តើអ្នកឃើញអ្វី បានជាលះបង់ការបូជាភ្លើងចោលចេញ ។
ម្នាលកស្សប តថាគតសួរសេចក្ដីនេះនឹងអ្នក កាលបូជា
ភ្លើង ដែលអ្នកលះបង់ហើយ តើព្រោះហេតុអ្វី ។

ឯព្រះថេរៈជ្រាបបំណងរបស់ព្រះមានព្រះភាគ ទើបពោលគាថានេះថា

ជនទាំងឡាយ តែងពោលសរសើរ ចំពោះនូវកាមទាំង
ឡាយ គឺរូប សំឡេង ព្រមទាំងរសផង នូវស្រីទាំងឡាយ
ផង ព្រោះការបូជា ខ្ញុំព្រះអង្គដឹងថា កាមគុណ មានរូប
ជាដើមនេះ ជាគ្រឿងសៅហ្មងក្នុងឧបធិទាំងឡាយ ព្រោះ
ហេតុដូច្នោះ ខ្ញុំព្រះអង្គមិនត្រេកអរក្នុងការបូជាធំ និងការ
បូជាតូច ( គឺការគោរពភ្លើងរាល់ថ្ងៃ ) ដូច្នេះ ។

ដើម្បីប្រកាសភាពដែលខ្លួនជាសាវ័ក ទើបឱនសីសៈត្រង់ខ្នងព្រះបាទ របស់ព្រះតថាគត ហើយក្រាបទូលថា បពិត្រព្រះអង្គដ៏ចម្រើន ព្រះមានព្រះភាគជាសាស្តារបស់ខ្ញុំព្រះអង្គ ខ្ញុំព្រះអង្គជាសាវ័ក ដូច្នេះហើយ ហោះឡើងទៅកាន់អាកាស ៧ ដង គឺ ១ ជួរដើមត្នោត ២ ជួរដើមត្នោត ៣ ជួរដើមត្នោត រហូតដល់ ៧ ជួរដើមត្នោត ហើយចុះមកថ្វាយបង្គំព្រះតថាគត អង្គុយក្នុងទីសមគួរនាចំណែកម្ខាង ។

មហាជនបានឃើញបាដិហារ្យដូច្នោះ ទើបពោលពាក្យសរសើរព្រះគុណរបស់ព្រះសាស្តាជាសំឡេងតែមួយថា គួរអស្ចារ្យ ព្រះពុទ្ធមានអានុភាពច្រើន សូម្បីឧរុវេលកស្សបៈ មានទិដ្ឋិខ្លាំងក្លាយ៉ាងនេះ សម្គាល់ខ្លួនថា ជាព្រះអរហន្ត ក៏ត្រូវព្រះតថាគតទូន្មាន ទម្លាយនូវសំណាញ់ គឺទិដ្ឋិ បានហើយ ។

ព្រះមានព្រះភាគត្រាស់ថា តថាគតមិនមែនទូន្មានឧរុវេលកស្សបៈ តែក្នុងកាលឥឡូវនេះប៉ុណ្ណោះទេ សូម្បីក្នុងអតីតកាល តថាគតក៏បានទូន្មាន

ឱរុវេលកស្សបៈនេះមកហើយ ព្រោះអត្ថុប្បត្តិហេតុនេះ ទើបត្រាស់មហានារទកស្សបជាតក ហើយទ្រង់ប្រកាសសច្ចៈ ៤ ។ ព្រះរាជា មួយអន្លើដោយបរិវារ ១១ ម៉ឺន តាំងនៅក្នុងសោតាបត្តិផល បរិវារ ១ ម៉ឺន ប្រកាសខ្លួនជាឧបាសក ព្រះរាជាប្រថាប់គង់ក្នុងសម្នាក់របស់ព្រះសាស្តានោះឯង ទ្រង់ក្រាបទូលឲ្យព្រះមានព្រះភាគជ្រាបនូវសេចក្តីប្រាថ្នា ៥ ប្រការ[1] ហើយទ្រង់ដល់នូវសរណៈ ទ្រង់និមន្តព្រះសាស្តាដើម្បីសោយក្នុងថ្ងៃស្អែក ហើយទ្រង់ក្រោកឡើងចាកអាសនៈ ធ្វើប្រទក្សិណព្រះមានព្រះភាគហើយ យាងត្រឡប់ទៅ ។

ស្អែកឡើង ពួកជនអ្នកនគររាជគ្រឹះទាំងមូលប្រមាណ ១៨ កោដិ ទាំងអ្នកបានឃើញ និងអ្នកមិនបានឃើញព្រះមានព្រះភាគ កាលពីម្សិលមិញ មានបំណងនឹងឃើញព្រះតថាគត ទើបនាំគ្នាចេញអំពីនគររាជគ្រឹះ ទៅកាន់លដ្ឋិវនឧទ្យានអំពីព្រលឹម ។ ក្នុងផ្លូវ ៣ គាវុត មិនល្មមនឹងធ្វើដំណើរ ។ លដ្ឋិវនឧទ្យានទាំងមូលកុះករ ។ មហាជនសូម្បីឃើញអត្តភាព ដែលដល់នូវលម្អដ៏ប្រសើរនៃព្រះរូបឆោមរបស់ព្រះទសពល ក៏មិនអាចធ្វើឲ្យឆ្អែត នេះជាពណ៌នាលម្អនៃព្រះឆវីវណ្ណ ( ដោយសង្ខេប ) ។ ពិតហើយ ក្នុងឋានៈបែបនេះគប្បីពណ៌នា លម្អនៃព្រះរូបកាយទាំងអស់ ដូចជាមហាបុរិស-

---

១- សេចក្តីប្រាថ្នា ៥ ប្រការ គឺសូមឲ្យបានទទួលអភិសេក ១ សូមឲ្យព្រះអរហន្ត-សម្មាសម្ពុទ្ធមកកាន់នគរ ១ សូមឲ្យបានចូលគាល់ ១ សូមឲ្យបានស្តាប់ធម៌ ១ សូមឲ្យបានយល់ធម៌នោះ ១ ។

លក្ខណៈនិងអនុព្យញ្ជនៈជាដើម នៃព្រះមានព្រះភាគផងដែរ ។ កាលឧទ្យាន និងផ្លូវដើរចង្អៀតដោយមហាជន ដែលមើលព្រះសរីរៈរបស់ព្រះទសពល ដែលដល់នូវលម្អដ៏ប្រសើរ ដោយព្រះរូបយ៉ាងនេះ សូម្បីភិក្ខុ ១ រូប ក៏មិនមានឱកាសនឹងចេញទៅបាន បានឮថា ថ្ងៃនោះ ព្រះមានព្រះភាគត្រូវដាច់ព្រះក្រយាហារ ព្រោះហេតុនោះ ទើបអាសនៈដែលសក្កទេវរាជគង់ប្រថាប់ សម្តែងអាការក្តៅ ដែលមានហេតុឲ្យដឹងថា សេចក្តីនោះ កុំបីកើតឡើងឡើយ ។ សក្កទេវរាជរំពឹងមើលដឹងហេតុនោះឯង ទើបនិម្មិតភេទជាមាណពតូច ពោលពាក្យសរសើរ ដែលប្រកបដោយព្រះពុទ្ធ ព្រះធម៌ ព្រះសង្ឃ ទៅអំពីខាងមុខព្រះទសពល វៃកផ្លូវឲ្យ ដោយទេវានុភាព យាងទៅខាងមុខ ពោលនូវគុណរបស់ព្រះសាស្តា ដោយគាថាទាំងនេះថា

ព្រះអង្គមានពណ៌ល្អដូចដុំមាសឈ្មោះសិង្គី ទ្រង់យាងចូល
ទៅកាន់ក្រុងរាជគ្រឹះ មួយអន្លើដោយពួកបុរាណជដិល
ដែលមានចិត្តផុតហើយ ( ចាកសេចក្តីសៅហ្មង ) ទាំង
មានចិត្តផុតស្រឡះហើយ ( ចាកអាសវធម៌ ) ។
ព្រះដ៏មានព្រះភាគ ទ្រង់ធ្វូង ( ចាកលោក ) ហើយ ទាំង
មានព្រះហឫទ័យផុតស្រឡះហើយ ( ចាកអាសវធម៌ )
ព្រះអង្គមានពណ៌ល្អដូចដុំមាស ឈ្មោះសិង្គី ទ្រង់យាង
ចូលទៅកាន់ក្រុងរាជគ្រឹះ មួយអន្លើដោយពួកបុរាណជដិល
ដែលធ្វូងហើយ ( ចាកលោក ) ទាំងមានចិត្តផុតស្រឡះ

ហើយ ( ចាកអាសវធម៌ ) ។

ព្រះដ៏មានព្រះភាគ មានព្រះហឫទ័យរម្ងាប់ហើយ ( ចាកអកុសលធម៌ ) ទាំងមានព្រះហឫទ័យផុតស្រឡះហើយ ( ចាកអាសវធម៌ ) ព្រះអង្គមានពណ៌ល្អដូចដុំមាស ឈ្មោះសិង្គី ទ្រង់យាងចូលទៅកាន់ក្រុងរាជគ្រឹះ មួយអន្លើដោយពួកបុរាណជដិលដែលមានចិត្តរម្ងាប់ហើយ ( ចាកអកុសលធម៌ ) ទាំងមានចិត្តផុតស្រឡះហើយ ( ចាកអាសវធម៌ ) ។

ព្រះដ៏មានព្រះភាគនោះ ទ្រង់មានអរិយវាស ១០ យ៉ាង ទ្រង់មានកម្លាំង ១០ ព្រះអង្គជ្រាបច្បាស់នូវធម៌ ( គឺកម្មបថ ) ១០ ប្រការ ទ្រង់ប្រកបដោយអង្គជារបស់នៃអសេក្ខបុគ្គល ១០ យ៉ាង មានភិក្ខុសង្ឃ ១ ពាន់ជាបរិវារ ទ្រង់យាងចូលទៅកាន់ក្រុងរាជគ្រឹះ ដូច្នេះ ។

ក្នុងកាលនោះ មហាជនឃើញលម្អនៃរូបរបស់មាណពតូចហើយ គិតថា មាណពតូចនេះរូបល្អក្រៃលែងហ្ន៎ ពួកយើងមិនធ្លាប់ឃើញឡើយ ទើបពោលថា មាណពតូចនេះមកអំពីណា ឬថា មាណពតូចនេះ ជាកូនចៅអ្នកណា ។ មាណពបានស្តាប់ដូច្នោះ ទើបពោលគាថាថា

អ្នកប្រាជ្ញណា ទូន្មានឥន្ទ្រិយទាំងអស់បានហើយ មានព្រះហឫទ័យស្អាត រកបុគ្គលប្រៀបមិនបាន ឆ្ងាយចាកសត្រូវ ពោល គឺកិលេស មានដំណើរល្អក្នុងលោក ខ្ញុំឯង ជាអ្នក

បម្រើអ្នកប្រាជ្ញនោះ ដូច្នេះ ។

ព្រះសាស្តាយាងតាមផ្លូវដែលសក្កៈទ្រង់ធ្វើឲ្យទំនេរ ដែលភិក្ខុ ១០០០ ចោមរោម យាងចូលក្រុងរាជគ្រឹះ ។ ព្រះរាជាទ្រង់ថ្វាយមហាទាន ដល់ភិក្ខុសង្ឃ មានព្រះពុទ្ធជាប្រធាន ហើយក្រាបទូលថា បពិត្រព្រះអង្គដ៏ចម្រើន ទូលបង្គំមិនអាចនៅដោយមិនមានព្រះរតនត្រ័យ ទូលបង្គំនឹងមកកាន់សម្នាក់នៃព្រះមានព្រះភាគក្នុងកាលខ្លះ មិនមែនកាលខ្លះ ឧទ្យានឈ្មោះលដ្ឋិវ័នឆ្ងាយពេក តែឧទ្យានឈ្មោះវេឡុវ័នរបស់ទូលបង្គំ មិនឆ្ងាយពេក មិនជិតពេក មានផ្លូវទៅមកបានស្រួល ជាសេនាសនៈសមគួរដល់ព្រះពុទ្ធ បពិត្រព្រះអង្គដ៏ចម្រើន សូមព្រះមានព្រះភាគទទួលឧទ្យានវេឡុវ័ន របស់ទូលបង្គំនេះចុះ ហើយទ្រង់យកព្រះសុវណ្ណភិង្គារផងទឹក ដែលមានពណ៌ដូចកែវមណី អប់ដោយផ្កាក្រអូប កាលទ្រង់បរិច្ចាគវេឡុវ័នឧទ្យាន ទើបទ្រង់ប្រួចទឹកលើព្រះហស្តរបស់ព្រះទសពល ។ កាលព្រះមានព្រះភាគទទួលវេឡុវ័នឧទ្យាននោះឯង មហាប្រឹថពីញាប់ញ័រ ដែលមានការឲ្យដឹងថា ឫសគល់ព្រះពុទ្ធ-សាសនាបានឈមចុះហើយ ។ ពិតហើយ ក្នុងផ្ទៃជម្ពូទ្វីប វៀរវេឡុវ័នចេញហើយ សេនាសនៈដទៃដែលទ្រង់ទទួលហើយ មហាប្រឹថពីកម្រើកមិនមានឡើយ ។ ក្នុងតម្ពបណ្ណិទ្វីប គឺកោះលង្កា វៀរមហាវិហារចេញហើយ ឈ្មោះថា សេនាសនៈដទៃដែលទទួលហើយ ផែនដីកម្រើក មិនមាន ។ ព្រះសាស្តាកាលទ្រង់ទទួលវេឡុវ័នារាមហើយ ទ្រង់ធ្វើអនុមោទនាដល់ព្រះរាជា ហើយទ្រង់ក្រោកឡើងចាកអាសនៈ ដែលភិក្ខុសង្ឃចោមរោម យាងទៅកាន់

វត្តវេឡុវ័ន ។

សម័យនោះឯង បរិព្វាជក ២ នាក់ គឺសារីបុត្រ និងមោគ្គល្លាន អាស្រ័យក្រុងរាជគ្រឹះ ស្វែងរកអមតធម៌ ។ ក្នុងបរិព្វាជក ២ រូបនោះ សារីបុត្តបរិព្វាជក ឃើញព្រះអស្សជិត្ថេរចូលទៅបិណ្ឌបាត មានចិត្តជ្រះថ្លា ទើបចូលទៅអង្គុយជិត ស្តាប់គាថា **យេ ធម្មា ហេតុប្បភវា** ដូច្នេះជាដើម បានតាំងនៅក្នុងសោតាបត្តិផល ហើយបានពោលគាថានោះឯង ដល់មោគ្គល្លានបរិព្វាជក ដែលជាសម្លាញ់របស់ខ្លួន សូម្បីមោគ្គល្លានបរិព្វាជកនោះ ក៏បានតាំងនៅក្នុងសោតាបត្តិផល ។ ទើបបរិព្វាជកទាំង ២ នោះ លាសញ្ជយបរិព្វាជក ទៅបួសក្នុងសម្នាក់របស់ព្រះមានព្រះភាគ មួយអន្លើដោយបរិស័ទរបស់ខ្លួន ។ បណ្តាកុលបុត្រទាំង ២ នោះ ព្រះមោគ្គល្លានសម្រេចអរហត្តក្នុងកាលកន្លងទៅ ៧ ថ្ងៃ ព្រះសារីបុត្រសម្រេចអរហត្តក្នុងកាលកន្លងកន្លះខែ ព្រះសាស្តាទ្រង់តាំងព្រះថេរៈទាំងពីររូបនោះ ក្នុងតំណែងអគ្គសាវក ក្នុងថ្ងៃដែលព្រះសារីបុត្តត្ថេរសម្រេចអរហត្តនោះឯង ទ្រង់បានធ្វើសន្និបាត គឺប្រជុំនូវសាវក ។

កាលព្រះតថាគត ទ្រង់គង់នៅក្នុងវេឡុវ័នឧទ្យាននោះឯង ព្រះបាទសុទ្ធោទនមហារាជទ្រង់បានដំណឹងថា បុត្ររបស់អញ ធ្វើទុក្ករកិរិយា ៦ ឆ្នាំ ទើបសម្រេចបរមាភិសម្ពោធិញ្ញាណ ហើយប្រកាសធម្មចក្កដ៏បវរ ចូលទៅអាស្រ័យក្រុងរាជគ្រឹះ ទ្រង់គង់នៅក្នុងវត្តវេឡុវ័ន ដូច្នេះ ទើបត្រាស់ហៅ

អមាត្យម្នាក់មក ត្រាស់ថា នែអ្នក ចូរអ្នកនាំបរិវារ ១០០០ ធ្វើដំណើរទៅនគររាជគ្រឹះ ពោលតាមពាក្យរបស់យើងថា ព្រះបាទសុទ្ធោទនមហារាជ ព្រះរាជ-បិតារបស់ព្រះអង្គមានបំណងនឹងជួប ដូច្នេះហើយ ចូរនាំកូនរបស់យើងមក ។

អមាត្យនោះ ទទួលព្រះរាជតម្រាស់របស់ព្រះរាជាថា ករុណាថ្លៃវិសេស ហើយមានបុរស ១០០០ ជាបរិវារ ប្រញាប់ធ្វើដំណើរទៅអស់ផ្លូវ ៦០ យោជន៍ ហើយចូលទៅកាន់ព្រះវិហារ ក្នុងកាលព្រះទសពលទ្រង់គង់សម្តែងធម៌កណ្តាលបរិស័ទ ៤ ។ អមាត្យនោះគិតថា ព្រះរាជសាសន៍របស់ព្រះរាជាដែលបញ្ជូនមកទុកសិនចុះ ទើបឈរខាងចុងបរិស័ទ ស្តាប់ព្រះធម្មទេសនារបស់ព្រះសាស្តា ទាំងកំពុងឈរនោះឯង បានសម្រេចអរហត្ត មួយអន្លើនឹងបុរស ១០០០ ទើបទូលសូមបព្វជ្ជា ។ ព្រះសាស្តា ទ្រង់លាព្រះហស្តត្រាស់ថា អ្នកទាំងឡាយ ចូរជាភិក្ខុចុះ រំពេចនោះឯង មនុស្សទាំងអស់ បានជាអ្នកទ្រទ្រង់បាត្រ និងចីវរដែលសម្រេចដោយឫទ្ធិ ដូចព្រះថេរៈមានវស្សា ៦០ ។

តាមធម្មតាព្រះអរិយៈទាំងឡាយ រមែងក្លាយជាបុគ្គលកណ្តាលៗ តាំងអំពីបានសម្រេចអរហត្ត ព្រោះហេតុនោះ ព្រះថេរៈដែលជាអមាត្យនោះ ក៏មិនបានក្រាបទូលទូលដំណឹងដែលព្រះរាជាបញ្ជូនមក ដល់ព្រះទសពល ។ ព្រះរាជាទ្រង់ព្រះតម្រិះថា អមាត្យដែលទៅមិនត្រឡប់មក ដំណឹងក៏មិនបានស្តាប់ ទើបបញ្ជូនអមាត្យដទៃទៅ ដោយទំនងនោះឯងថា នែអ្នក ចូរអ្នកទៅ ។ អមាត្យនោះទៅហើយ បានសម្រេចអរហត្ត មួយអន្លើដោយបរិស័ទ ក៏បាននៅស្ងៀម ដោយន័យមុននោះឯង ។ ព្រះរាជាទ្រង់បញ្ជូនអមាត្យដទៃទៅទៀត

៧ នាក់ ដោយទំនងនេះឯងថា នែអ្នក ចូរអ្នកទៅ ។ អមាត្យដែលព្រះរាជាទ្រង់បញ្ជូនទៅទាំងអស់ ៩ នាក់ មួយអន្លើដោយបរិវារ ៩០០០ នាក់ ធ្វើកិច្ចរបស់ខ្លួនស្រេចហើយ ជាអ្នកនៅស្ងៀម ក្នុងក្រុងរាជគ្រឹះនោះប៉ុណ្ណោះ ។

ព្រះរាជា ទ្រង់មិនបានអាមាត្យដែលជាអ្នកនាំដំណឹងមកប្រាប់បាន ទើបទ្រង់ព្រះតម្រិះថា ជនមានប្រមាណប៉ុណ្ណោះ មិនទាំមកសូម្បីតែដំណឹង ព្រោះមិនមានសេចក្តីស្រឡាញ់ក្នុងអញ អ្នកណាហ្ន៎ នឹងធ្វើតាមពាក្យរបស់អញ កាលទ្រង់ពិនិត្យមើលពលទាំងអស់ ក៏បានឃើញកាឡុទាយិអមាត្យ ។ បានឮថា កាឡុទាយិអមាត្យនោះ ជាអ្នកចាត់ចែងរាជកិច្ចទាំងពួង ជាមនុស្សខាងក្នុង ជាអមាត្យដែលមានការស្និទ្ធស្នាលក្រៃលែង កើតថ្ងៃតែមួយជាមួយនឹងព្រះពោធិសត្វ ជាសម្លាញ់លេងដីជាមួយគ្នា ។ លំដាប់នោះ ព្រះរាជាត្រាស់ហៅកាឡុទាយិអមាត្យនោះមកត្រាស់ថា នែកាឡុទាយី ខ្ញុំចង់ឃើញកូនរបស់ខ្ញុំ ទើបបញ្ជូនអមាត្យ ៩ នាក់ មួយអន្លើយដោយបរិវារ ៩០០០ ទៅ បណ្តាមនុស្សទាំងនោះ សូម្បីតែម្នាក់ ឈ្មោះថា មកប្រាប់ ត្រឹមតែដំណឹងក៏មិនមាន អន្តរាយនៃជីវិតរបស់ខ្ញុំដឹងបានលំបាក ខ្ញុំនៅមានជីវិត ប្រាថ្នានឹងឃើញបុត្រ អ្នកអាចបង្ហាញបុត្រដល់ខ្ញុំឬហ្ន៎ កាឡុទាយិអមាត្យក្រាបទូលថា ទូលបង្គំអាចបើទូលបង្គំបានបួស ។ ព្រះរាជាត្រាស់ថា នែបា បាបួសក្តី មិនបួសក្តី ចូរបង្ហាញបុត្រដល់ខ្ញុំ ។ កាឡុទាយិអមាត្យទទួលព្រះរាជបញ្ជាថា ករុណាថ្លៃវិសេស ហើយកាន់យករាជសាសន៍ទៅកាន់នគររាជគ្រឹះ ឈរនៅខាងចុងបរិស័ទ ក្នុងកាលដែលព្រះសាស្តាទ្រង់សម្តែងធម៌ ស្តាប់ធម៌ហើយ មួយអន្លើ

ដោយបរិវារ សម្រេចអរហត្តហើយ បួសដោយភាពជាឯហិភិក្ខុ ហើយសម្ងំនៅ ។

ព្រះសាស្តា បានត្រាស់ជាព្រះពុទ្ធហើយ ខាងក្នុងវស្សាដំបូង ទ្រង់គង់នៅត្រង់ឥសិបតនមិគទាយវ័ន ចេញវស្សា បវារណាហើយ យាងទៅកាន់តំបន់ឧរុវេលា ទ្រង់គង់នៅត្រង់ឧរុវេលានោះអស់ ៣ ខែ ទ្រង់ទូន្មានជដិល ៣ នាក់បងប្អូនហើយ មានភិក្ខុ ១០០០ ជាបរិវារ ក្នុងថ្ងៃពេញបូណ៌មី ខែបុស្ស ទ្រង់យាងទៅកាន់នគររាជគ្រឹះ ទ្រង់គង់នៅអស់ ២ ខែ ដោយលំដាប់កាលមានប្រមាណប៉ុណ្ណេះ ឈ្មោះថា ទ្រង់យាងចេញអំពីនគរពារាណសី មកហើយ ៥ ខែ ហេមន្តរដូវអស់ទៅហើយ តាំងពីថ្ងៃដែលកាឡុយិត្ថេរមកដល់ក្នុងកាលកន្លងទៅ ៧-៨ ថ្ងៃ ក្នុងថ្ងៃ ១៥ កើត ខែផល្គុណ ព្រះថេរៈគិតថា ឥឡូវនេះ ហេមន្តរដូវកន្លងទៅហើយ វស្សានរដូវកំពុងចូលមក ពួកមនុស្សដកសន្ទូងជាដើមបើកផ្លូវឲ្យហើយ ផែនដីក៏គ្របដណ្តប់ដោយស្មៅខៀវខ្ចី ដងព្រៃមានផ្ការីកស្គុសស្គាយ ផ្លូវសមគួរដល់ការដើរ ជាកាលដែលព្រះទសពលធ្វើនូវការសង្គ្រោះព្រះញាតិ ។ លំដាប់នោះ កាឡុទាយិត្ថេរ ក៏ចូលទៅគាល់ព្រះមានព្រះភាគ ពណ៌នាការយាងទៅកាន់នគរនៃរាជត្រកូលរបស់ព្រះទសពលដោយគាថាប្រមាណ ៦០ ថា

បពិត្រព្រះអង្គដ៏ចម្រើន ឥឡូវនេះ ពួកឈើ មានពណ៌ដូចរងើកភ្លើង ជិតផ្លែហើយ ជម្រុះស្លឹកចាស់ចោល ឈើទាំងនោះ រុងរឿងដូចជាអណ្តាតភ្លើង បពិត្រព្រះអង្គមានព្យាយាមធំ កាលនេះ ជា

កាលគួរបានចំណែកធម្មរសហើយ ។បេ។ បពិត្រព្រះអង្គដ៏ចម្រើន រដូវដែលមិនត្រជាក់ពេក មិនក្តៅពេក ជាសុខស្រួល គួរដើរទៅកាន់ផ្លូវឆ្ងាយបាន ។បេ។ ជាដើម ។

លំដាប់នោះ ព្រះសាស្តាត្រាស់នឹងកាឡុទាយិត្ថេរថា ម្នាលឧទាយី ព្រោះហេតុអ្វីហ្ន៎ ទើបពណ៌នាផ្លូវទៅដោយសំឡេងដ៏ពីរោះ ព្រះកាឡុទាយិត្ថេរក្រាបទូលថា បពិត្រព្រះអង្គដ៏ចម្រើន ព្រះបាទសុទ្ធោទនមហារាជ ព្រះបិតារបស់ព្រះអង្គ ទ្រង់មានបំណងនឹងជួបព្រះអង្គ សូមព្រះអង្គទ្រង់ធ្វើនូវសេចក្តីអនុគ្រោះដល់ញាតិទាំងឡាយចុះ ។ ព្រះសាស្តាត្រាស់ថា សាធុ ឧទាយី តថាគតនឹងធ្វើនូវការសង្គ្រោះព្រះញាតិទាំងឡាយ ចូរអ្នកប្រាប់ដល់ភិក្ខុសង្ឃ ភិក្ខុទាំងឡាយ នឹងបានធ្វើគមិកវត្ត គឺវត្តសម្រាប់អ្នកធ្វើដំណើរទៅឲ្យបរិបូណ៌ ព្រះថេរៈទទួលព្រះតម្រាស់ថា សាធុ ព្រះអង្គ ហើយប្រាប់ដល់ភិក្ខុទាំងឡាយនោះ ។

ព្រះមានព្រះភាគ ទ្រង់ចោមរោមដោយព្រះខីណាស្រព ២ ម៉ឺនអង្គ គឺភិក្ខុកុលបុត្រអ្នកអង្គៈ និងអ្នកមគធៈ ១ ម៉ឺនអង្គ ភិក្ខុកុលបុត្រអ្នកកបិលពស្តុ ១ ម៉ឺនអង្គ ចេញអំពីក្រុងរាជគ្រឹះ យាងទៅមួយថ្ងៃ ១ យោជន៍ ។ ព្រះមានព្រះភាគទ្រង់ព្រះតម្រិះថា ពីនគររាជគ្រឹះដល់នគរកបិលពស្តុ មានប្រមាណ ៦០ យោជន៍ តថាគតនឹងទៅដល់ដោយកាលប្រមាណ ២ ខែ ទើបទ្រង់យាងចារិក ដោយមិនប្រញាប់ប្រញាល់ ។ ឯព្រះថេរៈគិតថា អញនឹងក្រាបទូលថា ព្រះមានព្រះភាគយាងមកហើយដល់ព្រះរាជា ទើបហោះ

តាមអាកាស ទៅប្រាកដក្នុងព្រះរាជនិវេសន៍ ។

ព្រះរាជាទ្រង់ឃើញព្រះថេរៈហើយ មានព្រះហឫទ័យសោមនស្ស និមន្ត ឲ្យគង់លើបល្ល័ង្កដែលមានតម្លៃច្រើន ដាក់ភោជនមានរសដ៏ប្រសើរផ្សេងៗ ពេញបាត្រ ដែលគេត្រៀមដើម្បីព្រះអង្គហើយប្រគេន ។ ព្រះថេរៈសម្ដែងអាការក្រោកឡើង គិតនឹងទៅ ។ ព្រះរាជាត្រាស់ថា សូមគង់ឆាន់សិនចុះ ព្រះថេរៈទូលថា បពិត្រមហារាជ អាត្មានឹងទៅកាន់សម្នាក់របស់ព្រះសាស្ដា ហើយនឹងឆាន់ ។ ព្រះរាជាត្រាស់សួរថា ព្រះសាស្ដានៅទីណា ព្រះថេរៈក្រាបទូលថា បពិត្រមហារាជ ព្រះសាស្ដាមានភិក្ខុ ២ ម៉ឺនជាបរិវារ យាងចារិកមកហើយ ដើម្បីគាល់ព្រះអង្គ ។ ព្រះរាជាទ្រង់មានព្រះហឫទ័យសោមនស្ស ត្រាស់ថា សូមលោកម្ចាស់ឆាន់បិណ្ឌបាតនេះ ហើយនាំបិណ្ឌបាតអំពីទីនេះ ទៅថ្វាយព្រះឱរសនោះ ទម្រាំព្រះឱរសរបស់ខ្ញុំមកដល់នគរនេះ ។ ព្រះថេរៈទទួលព្រះតម្រាស់ហើយ ។

ព្រះរាជាទ្រង់អង្គាសព្រះថេរៈ ហើយឲ្យលាងបាត្រដោយលម្អិតគ្រឿងក្រអូប ដាក់បណីតភោជនពេញ តម្កល់ក្នុងដៃរបស់ព្រះថេរៈ ត្រាស់ថា សូមលោកម្ចាស់ថ្វាយដល់ព្រះតថាគត ។ ព្រះថេរៈ កាលមនុស្សទាំងឡាយកំពុងឃើញនោះឯង បោះបាត្រទៅក្នុងអាកាស ខ្លួនឯងក៏ហោះឡើងទៅកាន់អាកាស នាំបិណ្ឌបាតមកថ្វាយត្រង់ព្រះហស្ដរបស់ព្រះសាស្ដា ។ ព្រះសាស្ដា ទ្រង់សោយបិណ្ឌបាតនោះ ។ ព្រះថេរៈនាំបិណ្ឌបាតមក រាល់ៗ ថ្ងៃ ដោយឧបាយនេះឯង ។

ឯព្រះសាស្តា ក៏សោយបិណ្ឌបាត្ររបស់ព្រះរាជាប៉ុណ្ណោះក្នុងចន្លោះផ្លូវ ។ ក្នុងកាលស្រេចភត្តកិច្ចរាល់ៗ ថ្ងៃ ព្រះថេរៈក៏ពោលថា ថ្ងៃនេះ ព្រះសាស្តាយាងមកអស់ចម្ងាយផ្លូវ មានប្រមាណប៉ុណ្ណេះ ថ្ងៃនេះ មានប្រមាណប៉ុណ្ណេះ និងបានធ្វើរាជត្រកូលទាំងមូលឲ្យកើតនូវការជ្រះថ្លាក្នុងព្រះសាស្តា ទាំងមិនទាន់បានឃើញព្រះសាស្តា ដោយកថាដែលប្រកបដោយពុទ្ធគុណ ។ ព្រោះហេតុនោះឯង ទើបព្រះមានព្រះភាគ ទ្រង់ស្ថាបនាព្រះថេរៈឲ្យជាឯតទគ្គៈ ដោយព្រះតម្រាស់ថា ម្នាលភិក្ខុទាំងឡាយ បណ្តាពួកភិក្ខុអ្នកញុំាងត្រកូលឲ្យជ្រះថ្លាដែលជាសាវករបស់តថាគត ស្រេចនឹងកាឡុទាយីប្រសើរជាងគេ ។

ឯស្តេចសក្យៈទាំងឡាយ កាលព្រះមានព្រះភាគយាងមកដោយលំដាប់ គិតគ្នាថា យើងនឹងឃើញញាតិដ៏ប្រសើររបស់ពួកយើង ទើបប្រជុំគ្នា ពិចារណាទីគង់របស់ព្រះមានព្រះភាគ សម្រេចថា អារាមរបស់ព្រះបាទនិគ្រោធសក្យៈ គួរជាទីត្រេកអរ ទើបឲ្យធ្វើការជួសជុលគ្រប់យ៉ាង ក្នុងអារាមនោះ មានដៃកាន់គ្រឿងក្រអូប និងកម្រងផ្កា កាលនឹងធ្វើការទទួល ទើបបញ្ជូនកុមារ និងកុមារីអ្នកនគរដែលនៅក្មេងៗ តែងខ្លួនដោយគ្រឿងប្រដាប់គ្រប់យ៉ាងទៅមុន បន្ទាប់អំពីនោះ បញ្ជូនរាជកុមារ និងរាជកុមារីទៅ ខ្លួនឯងបូជាដោយគ្រឿងក្រអូប និងកម្រងផ្កាជាដើម បន្ទប់អំពីព្រះរាជកុមារ និងព្រះរាជកុមារីទាំងនោះ បាននាំព្រះមានព្រះភាគ ទៅកាន់និគ្រោធារាមនោះឯង ។ ក្នុងនិគ្រោធារាមនោះ ព្រះមានព្រះភាគ មានព្រះខីណាស្រព ២ ម៉ឺនអង្គចោមរោម ទ្រង់គង់លើបវរពុទ្ធាសនៈដែលគេក្រាល ។

ធម្មតាសក្យៈទាំងឡាយ មានជាតិមានះ ប្រកាន់ខ្លួនខ្លាំង ស្តេចសក្យៈទាំងនោះ គិតគ្នាថា សិទ្ធត្ថកុមារក្មេងជាងពួកយើង ជាព្រះអនុជ ជាព្រះភាគិនេយ្យ ជាព្រះឱរស ជាព្រះនត្តារបស់ពួកយើង ទើបត្រាស់នឹងរាជកុមារទាំងឡាយក្មេងៗ ថា ចូរពួកអ្នកនាំគ្នាថ្វាយបង្គំ ឯយើងទាំងឡាយ នឹងអង្គុយខាងក្រោយរបស់ពួកអ្នក ។ កាលសក្យៈទាំងឡាយមិនថ្វាយបង្គំ គង់យ៉ាងនោះ ព្រះមានព្រះភាគ ទ្រង់ប្រមើលមើលអធ្យាស្រ័យរបស់សក្យៈទាំងនោះ ទ្រង់ព្រះតម្រិះថា ព្រះញាតិទាំងឡាយមិនថ្វាយបង្គំតថាគត ណ្ហើយចុះ តថាគតនឹងឲ្យពួកទ្រង់ថ្វាយបង្គំក្នុងកាលឥឡូវនេះ ទើបទ្រង់ចូលចតុត្ថជ្ឈាន ដែលជាបាទនៃអភិញ្ញា ហើយចេញអំពីចតុត្ថជ្ឈាននោះ ហោះឡើងទៅកាន់អាកាសហាក់ដូចរោយនូវធូលីព្រះបាទលើសិរសារបស់សក្យៈទាំងនោះ ទ្រង់បានធ្វើបាដិហារ្យ ដូចគ្នានឹងយមកប្បាដិហារ្យ ត្រង់គល់គណ្ឌម្ពព្រឹក្ស ។ ព្រះរាជាទ្រង់ឃើញភាពអស្ចារ្យនោះ ក៏ទូលថា បពិត្រព្រះអង្គដ៏ចម្រើន ក្នុងថ្ងៃដែលទ្រង់ប្រសូត ខ្ញុំបានឃើញព្រះបាទរបស់ព្រះអង្គ ដែលគេនាំទៅដើម្បីឲ្យថ្វាយបង្គំកាលទេវិលតាបស ទៅប្រតិស្ឋានលើក្បាលរបស់ព្រាហ្មណ៍ ទើបថ្វាយបង្គំព្រះបាទរបស់ព្រះអង្គ នេះជាការថ្វាយបង្គំលើកទី ១ របស់ខ្ញុំ ។ ក្នុងថ្ងៃវប្បមង្គល កាលទ្រង់ផ្ទំលើសិរីសេយ្យាសនៈ ត្រង់ម្លប់ព្រីង ខ្ញុំបានឃើញស្រមោលដើមព្រីង មិនជ្រេទៅ ក៏បានថ្វាយបង្គំព្រះបាទរបស់ព្រះអង្គ នេះជាការថ្វាយបង្គំលើកទី ២ របស់ខ្ញុំ ។ ឥឡូវនេះ ខ្ញុំបានឃើញបាដិហារ្យដែលមិនធ្លាប់ឃើញនេះ ទើបថ្វាយបង្គំព្រះបាទរបស់ព្រះអង្គ នេះជាការថ្វាយបង្គំ

លើកទី ៣ របស់ខ្ញុំ ។

កាលព្រះរាជាថ្វាយបង្គំហើយ មិនមានស្តេចសក្យៈសូម្បីតែមួយអង្គ ដែលមិនថ្វាយបង្គំព្រះមានព្រះភាគ ស្តេចសក្យៈទាំងពួង នាំគ្នាថ្វាយបង្គំទាំងអស់ ។

ព្រះមានព្រះភាគ ទ្រង់ឲ្យព្រះញាតិទាំងឡាយថ្វាយបង្គំ ដោយប្រការដូច្នេះហើយ យាងចុះអំពីអាកាស ទ្រង់គង់លើអាសនៈដែលគេក្រាល ។ លុះព្រះមានព្រះភាគទ្រង់គង់ហើយ មានការប្រជុំព្រះញាតិដ៏កំពូល ស្តេចសក្យៈទាំងពួង មានឯកគ្គតាចិត្ត ប្រថាប់គង់ហើយ ។ លំដាប់នោះ មហាមេឃបាន ញុំាងភ្លៀងបោក្ខរព័ស្សឲ្យធ្លាក់ចុះមក ទឹកពណ៌ក្រហមស្រក់ចុះកាន់ផែនដី ពួកអ្នកត្រូវការឲ្យសើមប៉ុណ្ណោះ ទើបសើម បុគ្គលដែលមិនប្រាថ្នាឲ្យសើម ទឹកក៏មិនធ្លាក់ត្រូវរាងកាយ សូម្បីត្រឹមតែមួយតំណក់ ។ ស្តេចសក្យៈទាំងអស់ ឃើញដូច្នោះ កើតអស្ចារ្យក្នុងចិត្ត ទើបពោលឡើងថា ឱ ! គួរអស្ចារ្យ ឱ ! មិនធ្លាប់មាន ។

ព្រះសាស្តាត្រាស់ថា ភ្លៀងបោក្ខរព័ស្សធ្លាក់ចុះក្នុងសមាគមនៃព្រះញាតិរបស់តថាគត តែក្នុងកាលឥឡូវនេះប៉ុណ្ណោះក៏មិនមែន សូម្បីក្នុងអតីតកាលក៏ធ្លាក់ចុះមកហើយ ទើបត្រាស់វេស្សន្តរជាតក ព្រោះអត្ថុប្បត្តិហេតុនេះ ។ ស្តេចសក្យៈទាំងពួងបានស្តាប់ធម្មកថាហើយ ក្រោកឡើងថ្វាយបង្គំហើយ ចៀសចេញទៅ ។ ព្រះរាជា ឬមហាមាត្យរបស់ព្រះរាជាសូម្បីតែម្នាក់ ឈ្មោះថាក្រាបទូលថា សូមទ្រង់ទទួលភិក្ខារបស់យើងខ្ញុំ ដូច្នេះហើយ ត្រឡប់ទៅ ។

ស្អែកឡើង ព្រះសាស្តា មានភិក្ខុ ២ ម៉ឺនអង្គចោមរោម យាងទៅបិណ្ឌបាតកាន់ក្រុងកបិលពស្តុ មិនមានបុគ្គលណាមួយនិមន្តព្រះអង្គ ឬមិនមានបុគ្គលណាមួយទទួលបាត្រ ។ ព្រះសាស្តា ទ្រង់ឈរត្រង់សសរខឿននោះឯង ទ្រង់ពិចារណាថា ព្រះពុទ្ធទាំងឡាយ ក្នុងកាលមុន យាងបិណ្ឌបាតក្នុងនគររបស់ត្រកូលដូចម្តេចហ្ន៎ គឺយាងទៅកាន់ផ្ទះរបស់ពួកឥស្សរជន ដោយរំលងលំដាប់ ឬយាងទៅតាមលំដាប់ច្រក ។ លំដាប់នោះ ទ្រង់មិនបានឃើញព្រះពុទ្ធសូម្បីត្រឹមតែមួយអង្គ យាងទៅដោយរំលងលំដាប់ ទើបទ្រង់ព្រះតម្រិះថា ឥឡូវនេះ តថាគតក៏គួរផ្គងវង្សរបស់ព្រះពុទ្ធទាំងនោះទុកឲ្យបានតទៅ សាវ័កទាំងឡាយរបស់តថាគត នឹងបានបំពេញបិណ្ឌចារិកវត្តតាមតថាគត ហើយយាងបិណ្ឌបាតតាមលំដាប់ច្រក ផ្តើមតាំងអំពីផ្ទះ ដែលតាំងនៅខាងចុងស្រុកតទៅ ។ មហាជនជជែកគ្នាថា បានឮថា សិទ្ធត្ថកុមារ ជាអយ្យបុត្តត្រាច់ទៅដើម្បីដុំបាយ ទើបបើកបង្អួចក្នុងប្រាសាទជាន់ទី ២ និងជាន់ទី ៣ ជាដើម ព្យាយាមដើម្បីមើល ។

ឯព្រះទេវីរាហុលមាតាព្រះតម្រិះថា បានឮថា អយ្យបុត្តត្រាច់ទៅក្នុងនគរនេះឯង ដោយវិមាសជាដើម ដោយរាជានុភាពដ៏ក្រៃលែង ឥឡូវនេះកោរសក់ និងពុកមាត់ ដណ្តប់សំពត់កាសាវៈ កាន់អំបែងត្រាច់ទៅដើម្បីដុំបាយ ល្អដែរឬហ្ន៎ ទើបបើកបង្អួចទត បានឃើញព្រះមានព្រះភាគ ទ្រង់ញុំាងវិថីក្នុងព្រះនគរឲ្យភ្លឺស្វាងដោយព្រះរស្មីនៃព្រះសរីរៈ ដែលរុងរឿងដោយរស្មីផ្សេងៗ លម្អដោយពុទ្ធសិរី មិនអាចឧបមាបាន ប្រដាប់ដោយមហាបុរិស-

លក្ខណៈ ៣២ ប្រការ លម្អដោយអនុព្យញ្ជនៈ ៨០ ចោមរោមដោយព្រះរស្មី ប្រមាណ ១ ព្យាម ទើបព្រះនាងសរសើរចាប់តាំងអំពីឧណ្ហិស គឺចាប់ពីថ្ងាសចុះទៅ រហូតដល់ផ្ទៃព្រះបាត ដោយគាថាឈ្មោះនរសីហៈ ១០ គាថា យ៉ាងនេះថា

ព្រះនរសីហៈ មានកេសារល្អទន់ខ្មៅរលោង មានថ្ងាសទូលាយ ប្រាសចាកមន្ទិល ដូចព្រះអាទិត្យមានព្រះនាសាវែងខ្ពស់ ទន់សម មានបណ្ដាញរស្មី ផ្សាយចេញអំពីកាយ ដូច្នេះជាដើម ។

ហើយក្រាបទូលដល់ព្រះរាជាថា ព្រះឱរសរបស់ព្រះអង្គត្រាច់ទៅដើម្បីដុំបាយ ។ ព្រះរាជាទ្រង់សង្វេគយកដៃម្ខាងចាប់សំពត់សាដក ស្លៀកឲ្យរៀបរយ ប្រញាប់ប្រញាល់ចេញទៅ ទ្រង់យាងទៅឈរប្រថាប់ខាងមុខព្រះភក្ត្រព្រះដ៏មានព្រះភាគ ហើយត្រាស់ថា បពិត្រព្រះអង្គដ៏ចម្រើន ហេតុអ្វី ទើបទ្រង់ធ្វើឲ្យខ្ញុំខ្មាសគេ ទ្រង់មិនចាំបាច់ត្រាច់ទៅដើម្បីដុំបាយ ហេតុអ្វី ទើបទ្រង់ធ្វើសេចក្ដីសម្គាល់ថា ភិក្ខុមានប្រមាណប៉ុណ្ណេះ មិនអាចបានភត្តាហារ ។

ព្រះសាស្ដាត្រាស់ថា មហាបពិត្រ នេះជាការប្រព្រឹត្តតាមវង្សរបស់តថាគត ព្រះរាជាត្រាស់ថា បពិត្រព្រះអង្គ ឈ្មោះថា វង្សរបស់យើងទាំង-ឡាយ ជាវង្សរបស់មហាសម្មតរាជ ក្នុងវង្សនេះ មិនមានស្ដេច សូម្បីតែមួយអង្គ ដែលត្រាច់ទៅដើម្បីភិក្ខា ព្រះសាស្ដាត្រាស់ថា មហាបពិត្រ ឈ្មោះថា ខត្តិយវង្សនេះ ជាវង្សរបស់ព្រះអង្គ ឯពុទ្ធវង្ស គឺព្រះទីបង្ករ ព្រះកោណ្ឌញ្ញៈ

។បេ។ ព្រះកស្សបៈ ជាវង្សរបស់តថាគត ព្រះពុទ្ធទាំងឡាយនេះ និងអង្គដទៃៗ រាប់ពាន់ បានសម្រេចការចិញ្ចឹមព្រះជន្មជីព ដោយការត្រាច់កិក្ខាចារប៉ុណ្ណោះ ទាំងដែលប្រថាប់ឈរក្នុងរវាងផ្លូវនោះឯង បានត្រាស់ព្រះគាថា ( ក្នុងធម្មបទ ) នេះថា

បុគ្គលមិនគួរប្រមាទ ក្នុងដុំបាយ ដែលខ្លួនគប្បីក្រោកឡើង
ទទួល គប្បីប្រព្រឹត្តធម៌ឲ្យសុចរិត បុគ្គលអ្នកប្រព្រឹត្តធម៌ជា
ប្រកតី រមែងដេកជាសុខ ក្នុងលោកនេះផង ក្នុងលោកខាង
មុខផង ដូច្នេះ ។

ក្នុងវេលាចប់ទេសនា ព្រះរាជាតាំងនៅក្នុងសោតាបត្តិផល ។ ទ្រង់បានស្តាប់គាថា ( ក្នុងធម្មបទ ) នេះថា

បុគ្គលគួរប្រព្រឹត្តធម៌ឲ្យសុចរិត មិនគួរប្រព្រឹត្តធម៌នោះ ឲ្យ
ទុច្ចរិតឡើយ បុគ្គលប្រព្រឹត្តធម៌ជាប្រក្រតី រមែងដេកជាសុខ
ក្នុងលោកនេះផង ក្នុងលោកខាងមុខផង ដូច្នេះ ។

ហើយបានតាំងនៅក្នុងសកទាគាមិផល ទ្រង់បានស្តាប់មហាធម្មបាលជាតក បានតាំងនៅក្នុងអនាគាមិផល ក្នុងសម័យជិតសោយទិវង្គត ទ្រង់ផ្ទំលើព្រះសិរីសេយ្យាសនៈខាងក្រោមស្វេតច្ឆត្រនោះឯង បានសម្រេចអរហត្ត កិច្ចក្នុងការតាមប្រកបព្យាយាម ដោយការនៅព្រៃជាដើម មិនមានដល់ព្រះរាជា ។

ព្រះរាជាកាលទ្រង់ធ្វើឲ្យជាក់ច្បាស់នូវសោតាបត្តិផលហើយ ទ្រង់ទទួលបាត្ររបស់ព្រះមានព្រះភាគ ទ្រង់នាំព្រះមានព្រះភាគ ព្រមទាំងបរិស័ទ ឡើង

កាន់មហាប្រាសាទ ទ្រង់អង្គាសដោយខាទនីយាហារ ភោជនីយាហារដ៏ប្រណីត ក្នុងកាលស្រេចភត្តកិច្ច ស្នំទាំងពួងនាំគ្នាមកថ្វាយបង្គំព្រះមានព្រះភាគ វៀរតែរាហុលមាតា ។ រាហុលមាតានោះសូម្បីបរិវារជនក្រាបទូលថា សូមព្រះនាងយាងទៅថ្វាយបង្គំព្រះអយ្យបុត្ត ក៏ត្រាស់ថា បើគុណរបស់ខ្ញុំមាន ព្រះអយ្យបុត្តនឹងយាងមកកាន់សម្នាក់របស់ខ្ញុំ ដោយព្រះអង្គឯង កាលទ្រង់យាងមកនោះឯង ខ្ញុំនឹងថ្វាយបង្គំ ត្រាស់ដូច្នេះហើយ ក៏មិនបានយាងទៅ ។

ព្រះមានព្រះភាគទ្រង់ឲ្យព្រះរាជាទទួលបាត្រហើយ យាងទៅកាន់បន្ទប់ដ៏មានសិរីរបស់ព្រះរាជធីតា មួយអន្លើដោយអគ្គសាវកទាំង ២ ហើយត្រាស់ថា កាលព្រះរាជធីតាថ្វាយបង្គំ ចូរថ្វាយបង្គំតាមគាប់ចិត្ត បុគ្គលណាមួយមិនគួរតិះដៀល ហើយទ្រង់គង់លើអាសនៈ ដែលគេក្រាលថ្វាយ ។ ព្រះរាជ-ធីតាប្រញាប់យាងមក ហើយចាប់កព្រះបាទាដាក់សិរសា លើខ្នងព្រះបាទ ហើយថ្វាយបង្គំតាមព្រះអធ្យាស្រ័យ ។ ព្រះរាជាត្រាស់គុណដែលព្រះរាជធីតាមានសេចក្ដីស្រឡាញ់ និងការរាប់អានច្រើនជាដើម ក្នុងព្រះមានព្រះភាគឲ្យទ្រង់ជ្រាបថា បពិត្រព្រះអង្គ ធីតារបស់ខ្ញុំបានដំណឹងថា ទ្រង់ស្លៀកដណ្ដប់សំពត់កាសាវៈ តាំងពីនោះមក ក៏ជាអ្នកស្លៀកដណ្ដប់សំពត់កាសាវៈដែរ បានឮថា ទ្រង់សោយព្រះក្រយាហារមួយពេល ក៏ជាអ្នកមានភត្តមួយពេលដែរ បានឮថា ព្រះអង្គវៀរមហាសយនៈ ក៏ផ្ទំលើគ្រែតូច ដែលពាសដោយសំពត់ ដឹងថា ទ្រង់វៀរចាកកម្រងផ្កា និងគ្រឿងក្រអូបជាដើម ក៏វៀរចាកកម្រងផ្កា និងគ្រឿងក្រអូបដែរ កាលព្រះញាតិទាំងឡាយ បញ្ជូនដំណឹងមកថា

យើងខ្ញុំនឹងប្រណិប័តន៍ ក៏មិនបានសម្លឹងមើលព្រះញាតិទាំងនោះ សូម្បីតែមួយអង្គ បពិត្រព្រះអង្គដ៏ចម្រើន ព្រះធីតារបស់ខ្ញុំ ដល់ព្រមដោយគុណយ៉ាងនេះ ។ ព្រះសាស្តាត្រាស់ថា មហាបពិត្រ ការដែលព្រះរាជធីតាដែលទ្រង់រក្សាក្នុងឥឡូវនេះ រក្សាខ្លួនបានក្នុងកាលដែលញាណចាស់ក្លាហើយ មិនគួរអស្ចារ្យទេ ក្នុងកាលមុន ព្រះរាជធីតានេះ មិនមានការរក្សា ត្រាច់ទៅត្រង់ជើងភ្នំ ក៏គង់រក្សាខ្លួនបានក្នុងកាលញាណមិនទាន់ចាស់ក្លា ដូច្នេះហើយត្រាច់ ចន្ទកិន្នរីជាតក ហើយទ្រង់ក្រោកឡើងចាកអាសនៈយាងទៅ ។

ក្នុងថ្ងៃស្អែកឡើង កាលវិវាហមង្គល ទាក់ទងក្នុងការយាងចូលព្រះរាជ-ដំណាក់ អភិសេករបស់នន្ទរាជកុមារកំពុងប្រព្រឹត្តទៅ ព្រះសាស្តាយាងទៅកាន់ដំណាក់របស់ព្រះរាជកុមារនោះ ទ្រង់ឲ្យព្រះកុមារកាន់បាត្រ មានព្រះបំណងឲ្យបួស ត្រាស់មង្គលកថាហើយ ទ្រង់ក្រោកចាកអាសនៈយាងត្រឡប់ ។ នាងជនបទកល្យាណីឃើញព្រះរាជកុមារកំពុងយាងទៅ ទើបទូលថា បពិត្រអយ្យបុត្ត សូមទ្រង់ប្រញាប់ត្រឡប់មក ហើយអើតមើល ។ នន្ទកុមារនោះ មិនអាចទូលព្រះមានព្រះភាគថា សូមទ្រង់ទទួលបាត្រ ទើបយាងទៅកាន់វិហារដូចគ្នា ។ នន្ទកុមារមិនប្រាថ្នាឡើយ ព្រះមានព្រះភាគទ្រង់ឲ្យបួសហើយ ព្រះមានព្រះភាគ យាងទៅកាន់នគរកបិលពស្តុ ទ្រង់ឲ្យនន្ទបួសក្នុងថ្ងៃទី ៣ ដោយប្រការដូច្នេះ ។

ក្នុងថ្ងៃទី ៧ ព្រះមាតារបស់រាហុលព្រះនាងតាក់តែងព្រះរាជកុមារ រួចបញ្ជូនទៅកាន់សម្នាក់របស់ព្រះមានព្រះភាគថា នែកូន ចូរកូនមើលសមណៈ

នោះ ដែលមានពណ៌ដូចរូបព្រហ្ម មានសម្បុរដូចមាស ចោមរោមដោយសមណៈ ២ ម៉ឺនរូប សមណៈនេះជាបិតារបស់កូន សមណៈនេះមានកំណប់ទ្រព្យធំ ចាប់តាំងអំពីសមណៈនេះចេញបួសហើយ មាតាមិនឃើញកំណប់ទ្រព្យទាំងនោះ ចូរកូនទៅសូមមត៌កនឹងព្រះសមណៈនោះថា បពិត្រព្រះបិតា ខ្ញុំជាកុមារ បានទទួលអភិសេកហើយ នឹងបានជាស្តេចចក្រពត្តិ ខ្ញុំត្រូវការទ្រព្យ សូមទ្រង់ប្រទានទ្រព្យដល់ខ្ញុំ ព្រោះបុត្ត រមែងជាម្ចាស់របស់មត៌កនៃបិតា ។ ព្រះរាជកុមារក៏បានទៅកាន់សម្នាក់របស់ព្រះមានព្រះភាគនោះឯង បានកើតនូវសេចក្តីស្រឡាញ់ក្នុងឋានៈជាបិតា មានចិត្តរីករាយ ក្រាបទូលថា បពិត្រព្រះសមណៈ ម្លប់របស់ព្រះអង្គត្រជាក់ស្រួលណាស់ ហើយបានឈរពោលពាក្យដទៃៗ និងពាក្យដែលសមគួរជាច្រើន ។ ព្រះមានព្រះភាគទ្រង់ធ្វើភត្តកិច្ច ហើយត្រាស់អនុមោទនា ទ្រង់ក្រោកចាកអាសនៈ យាងត្រឡប់ទៅ ។ ឯព្រះរាជកុមារក្រាបទូលថា បពិត្រព្រះសមណៈ សូមទ្រង់ប្រទានទ្រព្យមត៌កដល់ខ្ញុំ បពិត្រព្រះសមណៈ សូមទ្រង់ប្រទានទ្រព្យមត៌កដល់ខ្ញុំ ហើយដើរតាមព្រះមានព្រះភាគទៅ ។ ព្រះមានព្រះភាគមិនឲ្យកុមារត្រឡប់ សូម្បីបរិវារជនក៏មិនអាចញ៉ាំងព្រះរាជកុមារដែលទៅជាមួយព្រះមានព្រះភាគ ឲ្យត្រឡប់បាន ។ ព្រះរាជកុមារនោះ បានទៅកាន់អារាមនោះ មួយអន្លើនឹងព្រះមានព្រះភាគដោយប្រការដូច្នេះ ។

លំដាប់នោះ ព្រះមានព្រះភាគទ្រង់ព្រះតម្រិះថា កុមារនេះ ប្រាថ្នាទ្រព្យដែលជារបស់បិតា ដែលប្រព្រឹត្តទៅតាមវដ្តៈ មានតែការចង្អៀតចង្អល់

ណេហ្ហ៍យចុះ តថាគតនឹងឲ្យអរិយទ្រព្យ ៧ ប្រការ ដែលតថាគតបានចំពោះត្រង់ពោធិមណ្ឌលដល់កុមារនេះ តថាគតនឹងធ្វើកុមារនេះឲ្យជាម្ចាស់ទ្រព្យមត៌កដែលជាលោកុត្តរ ទើបត្រាស់ហៅព្រះសារីបុត្រមកថា ម្នាលសារីបុត្រ បើដូច្នោះ ចូរអ្នកឲ្យរាហុលកុមារបួស ។

ព្រះថេរៈឲ្យរាហុលកុមារនោះបួសហើយ កាលព្រះរាជកុមារបួសហើយ សេចក្ដីទុក្ខមានប្រមាណក្រៃលែងកើតដល់ព្រះរាជា ។ ទ្រង់មិនអាចអត់សង្កត់សេចក្ដីទុក្ខនោះបាន ទើបយាងទៅគាល់ព្រះមានព្រះភាគ សូមពរថា បពិត្រព្រះអង្គដ៏ចម្រើន ខ្ញុំសូមឱកាស លោកម្ចាស់ទាំងឡាយ មិនគប្បីបំបួសកុលបុត្រដែលមាតាបិតាមិនទាន់អនុញ្ញាត ។ ព្រះមានព្រះភាគ ទ្រង់ប្រទានពរដល់ព្រះរាជា ក្នុងថ្ងៃស្អែកឡើង ទ្រង់ធ្វើភត្តកិច្ចក្នុងព្រះរាជនិវេសន៍ កាលព្រះរាជាគង់ប្រថាប់ក្នុងចំណែកម្ខាង ទូលថា បពិត្រព្រះអង្គដ៏ចម្រើន ក្នុងកាលដែលទ្រង់ធ្វើទុក្ករកិរិយា ទេវតាមួយអង្គមកប្រាប់ខ្ញុំថា ឱរសរបស់ព្រះអង្គសោយទិវង្គតហើយ ខ្ញុំមិនជឿពាក្យរបស់ទេវតានោះ បានឃាត់ទេវតានោះថា កូនរបស់ខ្ញុំ បើមិនទាន់សម្រេចសម្ពោធិញ្ញាណ នឹងមិនស្លាប់ឡើយ ដូច្នេះ ទើបព្រះមានព្រះភាគត្រាស់ថា ឥឡូវនេះ ទ្រង់ជឿបានដូចម្ដេច ក្នុងកាលមុនមនុស្សយកឆ្អឹងមកបង្ហាញ ហើយពោលថា កូនរបស់អ្នកស្លាប់ហើយ ទ្រង់ក៏នៅតែមិនជឿ ដូច្នេះ ហើយត្រាស់មហាធម្មបាលជាតក ព្រោះអត្ថុប្បត្តិហេតុនៃរឿងនេះ ក្នុងកាលចប់កថា ព្រះរាជាទ្រង់តាំងនៅក្នុងអនាគាមិផល ។

ព្រះមានព្រះភាគ ទ្រង់ឲ្យព្រះបិតាតាំងនៅក្នុងផលទាំង ៣ ដោយប្រការ

ដូច្នេះហើយ កាលពួកភិក្ខុបោមរោម ទ្រង់យាងទៅកាន់នគររាជគ្រឹះទៀត ទ្រង់គង់នៅត្រង់ព្រៃសីតវ័ន ។ សម័យនោះ អនាថបិណ្ឌិកគហបតី យករទេះ ៥០០ ផ្ទុកទំនិញទៅកាន់នគររាជគ្រឹះ បានទៅកាន់ផ្ទះរបស់សេដ្ឋី ដែលជាសម្លាញ់របស់ខ្លួន[១] បានស្តាប់ថា ព្រះមានព្រះភាគ កើតឡើងហើយ ទើបចូលទៅគាល់ព្រះសាស្តា តាមទ្វារដែលបើកដោយទេវានុភាព តាំងអំពីនៅងងឹត ស្តាប់ធម៌ហើយ តាំងនៅក្នុងសោតាបត្តិផល ។ ក្នុងថ្ងៃទី ២ បានថ្វាយមហាទានដល់សង្ឃ មានព្រះពុទ្ធជាប្រធាន បានក្រាបទូលសូមឲ្យព្រះសាស្តាទ្រង់ទទួលបដិញ្ញា ដើម្បីយាងមកកាន់នគរសាវត្ថី ក្នុងចន្លោះផ្លូវ ៤៥ យោជន៍ បានបរិច្ចាគទ្រព្យ ១ សែន សាងវិហារក្នុងទី ១ យោជន៍មួយៗ ហើយទិញឧទ្យានរបស់ព្រះអង្គម្ចាស់ជេត ដោយប្រាក់ ១៨ កោដិ ដោយយកប្រាក់រាប់កោដិ ក្រាលរហូតពេញ ហើយផ្តើមកសាង ។ អនាថបិណ្ឌិកគហបតីនោះ ឲ្យសាងវិហារដែលគួរជាទីត្រេកអរ ត្រង់ភូមិភាគដែលគួរជាទីត្រេកអរដោយបរិច្ចាគប្រាក់ ១៨ កោដិ គឺឲ្យសាងព្រះគន្ធកុដិ ដើម្បីព្រះទសពលនៅត្រង់កណ្តាល ឲ្យសាងសេនាសនៈដ៏សេស ដូចជាកុដិទោល កុដិភ្លោះ កុដិមូល សាលាវែង សាលាខ្លី និងបារាំជាដើម និងស្រះបោក្ខរណី ទីចង្រ្កម ទីសម្រាកពេលយប់ ព្រះគន្ធកុដិនោះ រួចស្រេចហើយ ទ្រង់បញ្ជូនទូតទៅនិមន្តព្រះទសពលឲ្យយាងមក ព្រះសាស្តាទ្រង់ស្តាប់ពាក្យរបស់ទូតនោះហើយ មានមហាភិក្ខុនិងទីសម្រាកពេលថ្ងៃ ក្នុងអាវាសដែលជាចំណែកផ្ទាល់ខ្លួន សម្រាប់ព្រះមហា-

---

១- ក្នុងវិនយបិដកសេនាសនក្ខន្ធកៈថា ទៅកាន់ផ្ទះរបស់រាជគហសេដ្ឋីដែលជាបងថ្លៃ ។

ថេរៈអង្គជុំវិញ ៨០ សង្ឃជាបរិវារ យាងចេញអំពីនគររាជគ្រឹះ ទៅកាន់នគរសាវត្ថី ដោយលំដាប់ ។

ឯមហាសេដ្ឋីក៏ត្រៀមបុណ្យឆ្លងវិហារ ក្នុងថ្ងៃដែលព្រះតថាគតយាងចូលវត្តជេតពន បានតែងខ្លួនកូនប្រុស ដោយគ្រឿងប្រដាប់គ្រប់យ៉ាង ហើយបញ្ជូនទៅ មួយអន្លើដោយកុមារ ៥០០ ដែលតាក់តែងដោយគ្រឿងប្រដាប់ដូចគ្នា បុត្តរបស់សេដ្ឋីនោះ ព្រមដោយបរិវារ កាន់ទង់ ៥០០ ដែលរុងរឿងដោយសំពត់មានពណ៌ ៥ អំពីខាងមុខព្រះទសពល ធីតារបស់សេដ្ឋី ២ នាក់ គឺនាងមហាសុភទ្ទា ១ នាងចូឡសុភទ្ទា ១ មួយអន្លើដោយកុមារី ៥០០ កាន់ក្អមពេញដោយទឹក ចេញដើរខាងក្រោយកុមារទាំងនោះ ភរិយារបស់សេដ្ឋីប្រដាប់ទៅដោយគ្រឿងអលង្ការទាំងពួង មួយអន្លើដោយស្ត្រី ៥០០ កាន់ថាសដែលមានបរិក្ខារពេញ ដើរទៅអំពីខាងក្រោយកុមារីទាំងនោះ ។

មហាសេដ្ឋីស្លៀកសំពត់ថ្មី មួយអន្លើដោយសេដ្ឋី ៥០០ នាក់ ដែលស្លៀកសំពត់ថ្មីដូចគ្នា ធ្វើដំណើរទៅរកព្រះមានព្រះភាគខាងក្រោយគេបង្អស់ព្រះមានព្រះភាគ ទ្រង់ធ្វើឧបាសកបរិស័ទនេះទុកអំពីខាងមុខ ដែលមហាភិក្ខុសង្ឃចោមរោម ទ្រង់ធ្វើជង់ព្រៃ ឲ្យដូចជាស្រោចដោយទឹកមាស ដោយព្រះរស្មីអំពីព្រះសរីរៈរបស់ព្រះអង្គ ទ្រង់យាងចូលវត្តជេតពនវិហារ ដោយពុទ្ធលីលា មិនមានទីបំផុត ដោយព្រះពុទ្ធសិរីប្រមាណមិនមាន ។

លំដាប់នោះ អនាថបិណ្ឌិកសេដ្ឋី បានទូលសួរព្រះមានព្រះភាគថា បពិត្រព្រះអង្គដ៏ចម្រើន ខ្ញុំព្រះអង្គនឹងបដិបត្តិក្នុងវិហារនេះដូចម្តេច ព្រះមាន

ព្រះភាគត្រាស់ថា ម្នាលគហបតី បើយ៉ាងនោះ ចូរអ្នកប្រតិស្ឋានវិហារនេះ ជារបស់ភិក្ខុសង្ឃដែលនៅក្នុងទិសទាំង ៤ ទាំងដែលមកហើយ និងមិនទាន់មកកាន់វិហារនេះ សេដ្ឋីទទួលពុទ្ធដីកាថា សាធុ ហើយកាន់យកឃ្នោកមាសប្រួចទឹកលើព្រះហស្តរបស់ព្រះទសពល ហើយថ្វាយដោយពាក្យថា ខ្ញុំព្រះអង្គសូមថ្វាយវត្តជេតពនវិហារនេះដល់ភិក្ខុសង្ឃ មានព្រះពុទ្ធជាប្រធាន ដែលនៅក្នុងទិសទាំង ៤ ដែលមកហើយ និងមិនទាន់បានមក ។ ព្រះសាស្តា ទ្រង់ទទួលព្រះវិហារហើយ កាលទ្រង់ធ្វើអនុមោទនា បានត្រាស់អានិសង្សការថ្វាយវិហារ ( ក្នុងវិនយបិដក ចុល្លវគ្គ ) ថា

( វិហារ គឺទីអាវាស ឬសេនាសនៈ ជាទីនៅនៃសង្ឃទាំងឡាយ ) រមែងការពាររងាផង ក្តៅផង ម្រឹគសាហាវទាំងឡាយផង ពស់តូច និងពស់ធំទាំងឡាយផង មូសទាំងឡាយផង ត្រជាក់ទាំងឡាយផង គ្រាប់ភ្លៀងទាំងឡាយផង ខ្យល់ និងកម្តៅថ្ងៃដ៏ក្លាខ្លាំង ដែលកើតឡើងហើយ រមែងបាត់ទៅវិញ ព្រោះវិហារនោះៗ ។ វិហារទាន គឺការឲ្យលំនៅ ( ដែលបុគ្គលបានឲ្យហើយ ) ដល់សង្ឃដើម្បីជាទីជ្រកកោនផង ដើម្បីនៅជាសុខផង ដើម្បីដុតបាបធម៌ផង ដើម្បីចម្រើនវិបស្សនាផង ព្រះពុទ្ធទាំងឡាយ តែងសរសើរថា ជាទានដ៏ប្រសើរ ។ ព្រោះហេតុនោះឯង បុរស ( ស្ត្រី ) ជាបណ្ឌិត កាលបើបានឃើញច្បាស់នូវប្រយោជន៍របស់ខ្លួន ក៏គួរសាង

ព្រះវិហារ គឺអាវាស ឬសេនាសនៈទាំងឡាយ ដ៏ជាទីគួរ
រីករាយ ហើយគួរនិមន្តលោក ដែលជាពហុស្សូត គឺលោក
អ្នកចេះដឹងច្រើនទាំងឡាយឲ្យនៅក្នុងទីនោះ ។ គួរមានចិត្ត
ជ្រះថ្លា ចំពោះលោកទាំងឡាយ ដែលមានចិត្តត្រង់ ហើយ
ប្រគេនបាយ ទឹក សំពត់ និងសេនាសនៈទាំងឡាយ ដល់
លោកទាំងនោះចុះ ។ លោកទាំងនោះ រមែងសម្ដែងធម៌ជា
គ្រឿងបន្ទោបង់ ឲ្យឃ្លាតចាកទុក្ខគ្រប់ប្រការដល់អ្នកនោះ លុះ
អ្នកនោះបានដឹងធម៌ណា ក្នុងព្រះពុទ្ធសាសនានេះហើយ ក៏ជា
អ្នកមិនមានអាសវៈ រមែងបរិនិព្វាន ដូច្នេះ ។

តាំងពីថ្ងៃទី ២ ជាដើមទៅ អនាថបិណ្ឌិកសេដ្ឋីផ្ដើមនូវការធ្វើវិហារ ។ ការធ្វើវិហាររបស់នាងវិសាខា ៤ ខែ ទើបស្រេច ឯការធ្វើវិហាររបស់អនាថ-បិណ្ឌិកសេដ្ឋី ៩ ខែ ទើបស្រេច ។ ក្នុងការធ្វើវិហារក៏អស់ទ្រព្យ ១៨ កោដិ ដូចគ្នា ។ ព្រះវិហារតែម្យ៉ាងប៉ុណ្ណោះ លោកបានបរិច្ចាគទ្រព្យរាប់បាន ៥៤ កោដិ ដោយប្រការដូច្នេះ ។

ក្នុងអតីតកាល ក្នុងសម័យព្រះមានព្រះភាគ ព្រះនាមវិបស្សី សេដ្ឋីឈ្មោះបុនព្វសុមិត្ត ទិញដីដែលក្រាលដោយឥដ្ឋមាស ធ្វើសង្ឃារាមប្រមាណ ១ យោជន៍ ក្នុងទីនោះដូចគ្នា ។

ក្នុងសម័យព្រះមានព្រះភាគ ព្រះនាមសិខី សេដ្ឋីឈ្មោះសិរិវឌ្ឍ ទិញដី ក្រាលដោយផាលមាសហើយឲ្យធ្វើសង្ឃារាម មានប្រមាណ ៣ គាវុត ក្នុងទីនោះដូចគ្នា ។

ក្នុងសម័យ ព្រះមានព្រះភាគ ព្រះនាមវេស្សភូ សេដ្ឋីឈ្មោះសោត្ថិយៈ ទិញដី ក្រាលដោយជើងដំរីមាស ហើយធ្វើសង្ឃារាម មានប្រមាណកន្លះយោជន៍ ក្នុងទីនោះដូចគ្នា ។ ក្នុងសម័យព្រះមានព្រះភាគព្រះនាមកកុសន្ធៈ សេដ្ឋីឈ្មោះអច្ចុតៈ ទិញដីដោយក្រាលឥដ្ឋមាស ហើយធ្វើសង្ឃារាម មានប្រមាណ ១ គាវុតក្នុងទីនោះដូចគ្នា ។

ក្នុងសម័យរបស់ព្រះមានព្រះភាគ ព្រះនាមកោនាគមនៈ សេដ្ឋីឈ្មោះឧគ្គៈ ទិញដី ក្រាលដោយអណ្តើកមាស ហើយធ្វើសង្ឃារាម មានប្រមាណកន្លះគាវុតក្នុងទីនោះដូចគ្នា ។

ក្នុងសម័យព្រះមានព្រះភាគ ព្រះនាមកស្សបៈ សេដ្ឋីឈ្មោះសុមង្គលៈ ទិញដី ក្រាលដោយឈើប្រចត់មាស ហើយធ្វើសង្ឃារាមប្រមាណ ១៦ ករីស ក្នុងទីនោះដូចគ្នា ។

តែក្នុងសម័យព្រះមានព្រះភាគនៃយើងទាំងឡាយ សេដ្ឋីឈ្មោះអនាថ-បិណ្ឌិក ទិញដី ក្រាលដោយទ្រព្យជាកហាបណៈ ១ កោដិ ហើយធ្វើសង្ឃារាម

មានប្រមាណ ៨ ករីស ក្នុងទីនោះដូចគ្នា ។ បានឮថា ទីនេះ ជាទីដែលព្រះពុទ្ធគ្រប់អង្គ មិនបានលះបង់ឡើយ ។

តាំងអំពីសម្រេចសព្វញ្ញុតញ្ញាណត្រង់មហាពោធិមណ្ឌល រហូតដល់គ្រែមហាបរិនិព្វាន ព្រះមានព្រះភាគ ទ្រង់គង់ក្នុងទីណា ទីនោះ គប្បីជ្រាបថា ឈ្មោះថា **សន្តិកេនិទាន** ដោយប្រការដូច្នេះ ។

**សន្តិកេនិទាន ចប់**

**និទានកថា ចប់**

# ពណ្ណនា អត្ថុប្បត្តិនិទាន

[ ១ ] សព្ទថា អថ ក្នុងគាថានេះថា

**អថ ពុទ្ធាបទានានិ សុណាថ សុទ្ធមានសា**
**តឹសបារមិសម្បុណ្ណា ធម្មរាជា អសង្ខិយា ។**(១)

លំដាប់នេះ លោកទាំងឡាយ ជាអ្នកមានចិត្តបរិសុទ្ធ ចូរស្ដាប់ពុទ្ធាបទានថា ព្រះតថាគតដែលជាព្រះរាជាហេតុធម៌ បរិបូណ៌ដោយបារមី ៣០ ដូច្នេះ ។

ជាបទនិបាត ប្រើក្នុងអត្ថថា សម្ដែងលំដាប់រឿង ។ ក្នុងនិបាត ២ យ៉ាង គឺនិបាតដែលប្រកបវិភត្តិ និងមិនប្រកបវិភត្តិ **អថ** សព្ទ ជានិបាត ប្រកបដោយវិភត្តិ ។ម្យ៉ាងទៀត **អថ** សព្ទ ប្រព្រឹត្តទៅក្នុងអត្ថថា អធិការ មង្គល សម្រេច អវធារណៈ ជាប់គ្នា និងអត្ថថា ប្រាសទៅ ។

ពិតហើយ ព្រោះលោកពោលថា

អធិការ រមែងចង្អុលបង្ហាញដល់កិច្ចដ៏ក្រៃលែង ឋានៈដ៏ក្រៃលែង និងអត្ថដ៏ក្រៃលែង លោកពោលព្រោះជាការៈប្រសើរបំផុត និងចម្រើនបំផុត ដូច្នេះ ។

ភ្ជាប់សេចក្ដីថា លោកទាំងឡាយ ចូរស្ដាប់អបទាន គឺហេតុដែលប្រកបដោយ **អថ** សព្ទ ដែលមានអធិការជាអត្ថ ដោយជាកិច្ចដ៏ក្រៃលែងនៃបារមីធម៌ ៣០ របស់ព្រះពុទ្ធទាំងឡាយ ដោយការៈដ៏ប្រសើរបំផុត និង

---

១- បិដកខ្មែរ គាថានេះ មានតែពីរបាទខាងចុង ឯពីរបាទខាងដើម លោកមិនបានលើកមក តែមានក្នុងនយលក្ខណៈ ( លេខយោង ) ។

បម្រើនបំផុត ភ្ជាប់សេចក្តីថា អ្នកទាំងឡាយ ចូរស្តាប់អបទាន ដែលប្រកប ដោយ **អដ្ឋ** សព្ទ មានមង្គលជាអត្ថ ដោយព្រះបាលីថា ការបូជាចំពោះបុគ្គលដែលគួរបូជាទាំងឡាយ ១ នេះជាមង្គលដ៏ឧត្តម ព្រោះការបូជាព្រះពោធិសត្វ ៣ ពួក ជាមង្គលដោយសការៈ ។

អ្នកទាំងឡាយ ចូរស្តាប់អបទាន ដែលប្រកបដោយ **អដ្ឋ** សព្ទ ដែលមានការសម្រេចជាអត្ថ ព្រោះកិច្ចនៃសម្បត្តិរបស់បុគ្គលដែលជាធំ មានព្រះពុទ្ធជាដើម សម្រេចត្រង់អរហត្តមគ្គ ។

អ្នកទាំងឡាយ ចូរស្តាប់អបទាន ដែលប្រកបដោយ **អដ្ឋ** សព្ទ ដែលមានអវធារណៈជាអត្ថ គឺមានការហាមជាអត្ថ ព្រោះព្រះពុទ្ធជាដើម មិនមានកុសលដទៃណាក្រៅអំពីកុសល មានអរហត្តមគ្គជាដើម ។

អ្នកទាំងឡាយ ចូរស្តាប់អបទាន ដែលប្រកបដោយ **អដ្ឋ** សព្ទ ដែលមានការជាប់តគ្នាជាអត្ថ ព្រោះលោកចងក្រងបន្តអំពីខុទ្ទកបាឋៈ ។

អ្នកទាំងឡាយ ចូរស្តាប់អបទាន ដែលប្រកបដោយ **អដ្ឋ** សព្ទ ដែលមានការប្រាសទៅជាអត្ថ បន្តអំពីខុទ្ទកបាឋៈនេះទៅ ។

ក្នុងបទថា **ពុទ្ធោ** នេះ មានវិគ្គហៈដូចតទៅ ឈ្មោះថា **ពុទ្ធ** ព្រោះត្រាស់ដឹងសច្ចៈទាំងឡាយ ឈ្មោះថា **ពុទ្ធ** ព្រោះញ៉ាំងពួកសត្វឲ្យត្រាស់ដឹង ឈ្មោះថា **ពុទ្ធ** ទ្រង់ជាអ្នកដឹងវត្ថុទាំងពួង ឈ្មោះថា **ពុទ្ធ** ព្រោះទ្រង់ឃើញវត្ថុទាំងពួង ឈ្មោះថា **ពុទ្ធ** ព្រោះទ្រង់មិនមានអ្នកដទៃទូន្មាន ព្រោះថា **ពុទ្ធ** ព្រោះទ្រង់ជាអ្នករីក ឈ្មោះថា **ពុទ្ធ** ព្រោះអស់អាសវៈហើយ ឈ្មោះថា **ពុទ្ធ**

ព្រោះប្រាសចាកឧបក្កិលេស ឈ្មោះថា **ពុទ្ធ** ព្រោះបព្វជ្ជា ឈ្មោះថា **ពុទ្ធ** ព្រោះអត្ថថា មិនមានបុគ្គលជាទី ២ ឈ្មោះថា **ពុទ្ធ** ព្រោះអត្ថថា លះតណ្ហាបាន ឈ្មោះថា **ពុទ្ធ** ព្រោះទ្រង់យាងទៅតាមផ្លូវឯក ឈ្មោះថា **ពុទ្ធ** ព្រោះទ្រង់ត្រាស់ដឹងសម្មាសម្ពោធិញ្ញាណ ដ៏កំពូលមួយព្រះអង្គឯង ឈ្មោះថា **ពុទ្ធ** ព្រោះទ្រង់បានចំពោះនូវការដឹង ជាហេតុកម្ចាត់ការមិនដឹង ។

បទទាំង ៣ គឺ **ពុទ្ធិ ពុទ្ធំ ពោធោ** នេះ មានអត្ថមិនផ្សេងគ្នា ។ សំពត់គេហៅថា សំពត់ខៀវ សំពត់ក្រហម ព្រោះប្រកបដោយពណ៌ខៀវជាដើមយ៉ាងណា ឈ្មោះថា **ពុទ្ធ** ព្រោះប្រកបដោយគុណរបស់ព្រះពុទ្ធក៏យ៉ាងនោះ ។

ម្យ៉ាងទៀត ញាណក្នុងមគ្គ ៤ ហៅថា **ពោធិ** ញាណដែលហៅថា **ពោធិ** ព្រោះដុតពួកកិលេស ១៥០០ ឲ្យអស់ទៅដោយញាណនោះមុនហើយសម្រេចព្រះនិព្វាន ។ សមង្គីបុគ្គលប្រកបដោយញាណនោះ ឈ្មោះថា ជាព្រះពុទ្ធ ។ សូម្បីព្រះបច្ចេកពុទ្ធ ក៏ដុតកិលេសទាំងពួងឲ្យអស់ទៅ ដោយញាណនោះដូចគ្នាមុន ហើយទើបសម្រេចព្រះនិព្វាន ។ ញាណនោះឯងជាអបទាន គឺជាហេតុនៃព្រះសម្ពុទ្ធទាំងនោះ ដោយជាញាណដ៏ក្រៃលែង ចំពោះរបស់ព្រះពុទ្ធទាំងឡាយ ទើបឈ្មោះថា **ពុទ្ធាបទាន** ព្រោះព្រះពុទ្ធទាំងឡាយទ្រង់បំពេញបារមីមក ៤ អសង្ខេយ្យ និង ១ សែនកប្ប ទើបបានសម្រេចពោធិញ្ញាណ ព្រោះទ្រង់សម្រេចសាធារណញ្ញាណ មានឥន្ទ្រិយបរោបរិយត្តញ្ញាណ មហាករុណាសមាបត្តិញ្ញាណ យមកប្បាដិហារិយញ្ញាណ សព្វញ្ញុតញ្ញាណ អនាវរណញ្ញាណ អាសយានុសយញ្ញាណជាដើម ១ ព្រោះទ្រង់

ឲ្យពួកសត្វរាប់មិនអស់ ផឹកនូវអមតធម៌ ដោយព្រះធម្មទេសនាត្រឹមតែមួយកណ្ឌ ហើយឲ្យសម្រេចនិព្វាន ១ ។

ពុទ្ធាបទាននោះ មាន ២ យ៉ាង គឺជាកុសល ១ អកុសល ១ តែព្រះបច្ចេកពុទ្ធទាំងឡាយ មិនអាចធ្វើយ៉ាងនោះបាន កាលនឹងធ្វើការសង្គ្រោះទាយកអ្នកថ្វាយបច្ច័យ មានបាយជាដើម ក៏សម្តែងធម៌ត្រឹមតែ ២ គាថាថា

ផលដែលអ្នកប្រាថ្នាត្រូវការ ចូរសម្រេចដោយរួសរាន់ ចូរការត្រិះរិះក្នុងចិត្ត ពេញបរិបូណ៌ ដូចព្រះចន្ទក្នុងថ្ងៃ ១៥ ដូច្នោះ ។

ផលដែលអ្នកប្រាថ្នាត្រូវការ ចូរសម្រេចដោយរួសរាន់ ចូរការត្រិះរិះក្នុងចិត្ត ពេញបរិបូណ៌ ដូចកែវមណី ឈ្មោះជោតិរស ដូច្នោះ ។

ព្រះបច្ចេកពុទ្ធទាំងឡាយ សូម្បីសម្តែងធម៌ ក៏មិនអាចធ្វើពួកសត្វរាប់មិនអស់ឲ្យត្រាស់ដឹងបាន ព្រោះហេតុនោះ ទើបឈ្មោះថា ព្រះបច្ចេកពុទ្ធ ព្រោះជាព្រះពុទ្ធដោយចំពោះ មិនដូចព្រះសព្វញ្ញុពុទ្ធ ។ អបទាន គឺហេតុនៃព្រះបច្ចេកពុទ្ធទាំងនោះ ទើបឈ្មោះថា **បច្ចេកពុទ្ធាបទាន** ។

ឈ្មោះថា **ថេរ** ព្រោះតាំងនៅយូរ ។ម្យ៉ាងទៀត ឈ្មោះថា **ថេរ** ព្រោះប្រកបដោយគុណ មានសីល អាចារ និង ការទន់ភ្លន់ជាដើម ដែលមាំទាំជាង ។ ម្យ៉ាងទៀត ឈ្មោះថា **ថេរ** ព្រោះប្រកបដោយគុណ គឺសីល សមាធិ បញ្ញា វិមុត្តិ និងវិមុត្តិញាណទស្សនៈដែលមាំទាំ និងប្រសើរ ។

ម្យ៉ាងទៀត ឈ្មោះថា **ថេរ** ព្រោះសម្រេចព្រះនិព្វាន គឺសន្តិ ដែលរាប់ថា មាំទាំជាង ប្រណីត និងប្រសើរ ។ អបទានរបស់ព្រះថេរៈទាំងឡាយ ឈ្មោះថា **ថេរាបទាន** ។

ឈ្មោះថា **ថេរី** ព្រោះប្រកបដោយគាទិគុណ ដូចព្រះថេរៈ អបទានរបស់ព្រះថេរីទាំងឡាយ ឈ្មោះថា **ថេរីបទាន** ។

ក្នុងអបទានទាំងនោះ ពុទ្ធាបទាន មាន ៥ អបទាន និង ៥ សូត្រ ដោយហេតុនោះ ទើបបុរាណាចារ្យពោលថា

អបទានទី ១ មាន ៥ អបទាន និង ៥ សូត្រ ហៅថា អបទាន ដោយអនុលោម ។

បច្ចេកពុទ្ធាបទាន មាន ៥ អបទាន និង ៥ សូត្រ ។ ដោយហេតុនោះ ទើបបុរាណាចារ្យពោលថា

អបទានទី ២ មាន ៥ អបទាន និង ៥ សូត្រ ហៅថា បច្ចេកពុទ្ធាបទាន ដោយអនុលោម ។

ថេរាបទាន មាន ៥១០ អបទាន ចែកជាវគ្គ មាន ៥១ វគ្គ ដោយហេតុនោះ ទើបបុរាណាចារ្យពោលថា

អបទានទី ៣ មាន ៥១០ អបទាន ចែកជាវគ្គ មាន ៥១ វគ្គ នេះ ឈ្មោះថា ថេរាបទាន ដោយអនុលោម ។

ថេរីអបទាន មាន ៤០ អបទាន ចែកជាវគ្គ មាន ៤ វគ្គ ដោយហេតុនោះ ទើបបុរាណាចារ្យពោលថា

អបទានទី ៤ មាន ៤០ អបទាន និងមាន ៤ វគ្គ ហៅថា ថេរីបទាន ដោយអនុលោម ។

**អបទាន** សព្ទ ក្នុងបទថា **អបទានំ** នេះ ប្រើក្នុងអត្ថច្រើនយ៉ាង ដូច **ការណ គរហណ អបគមន បដិបាដិ** និង **អក្កោសន** ។

ពិតហើយ **អបទាន** សព្ទនេះ ប្រើក្នុងអត្ថថា **ការណ** គឺហេតុ ដូចក្នុងប្រយោគជាដើមថា **ខត្តិយានំ អបទានំ** ហេតុ គឺប្រវត្តិរបស់ស្តេចទាំងឡាយ **ព្រាហ្មណានំ អបទានំ** ហេតុ គឺប្រវត្តិរបស់ព្រាហ្មណ៍ទាំងឡាយជាដើម ។

ប្រើក្នុងអត្ថថា **គរហណ** គឺការព្រមទទួល ដូចក្នុងប្រយោគជាដើមថា **ឧបាសកានំ អបទានំ** ការព្រមទទួលរបស់ឧបាសកទាំងឡាយ ។

ប្រើក្នុងអត្ថថា **អបគមន** គឺការចាកចេញទៅ ដូចក្នុងប្រយោគជាដើមថា **វាណិជានំ អបទានំ សុទ្ទានំ អបទានំ** កាលចេញទៅរបស់ពួកឈ្មួញនិងពួកសូទ្រៈទាំងនោះ គឺពួកគេគេចទៅអំពីទីនោះៗ ។

ប្រើក្នុងអត្ថថា **បដិបាដិ** គឺតាមលំដាប់ ដូចក្នុងប្រយោគជាដើមថា **បិណ្ឌបាតិកោ ភិក្ខុ សបទានចារិកេន បិណ្ឌាយ ចរតិ** ភិក្ខុអ្នកសមាទានបិណ្ឌបាតជាវត្ត រមែងត្រាច់ទៅដើម្បីដុំបាយ តាមលំដាប់ច្រក គឺតាមលំដាប់ផ្ទះ ។

ប្រើក្នុងអត្ថថា **អក្កោសន** គឺការជេរ ដូចក្នុងប្រយោគជាដើមថា **អបគតា ឥមេ សាមញ្ញា អបគតា ឥមេ ព្រហ្មញ្ញាតិ អបទានេតិ** កាព

ជាសមណៈ មិនមានដល់សមណៈទាំងនេះ ភាពជាព្រាហ្មណ៍ មិនមានដល់សមណៈទាំងនេះ អធិប្បាយថា រមែងជេរ រមែងបរិភាស ។

តែក្នុងទីនេះ ប្រើក្នុងអត្ថថា **ការណៈ** គឺហេតុ ព្រោះហេតុនោះ អបទានរបស់ព្រះពុទ្ធទាំងនោះ ឈ្មោះថា **ពុទ្ធាបទាន** អធិប្បាយថា ហេតុធ្វើឲ្យជាព្រះពុទ្ធ ។ គប្បីឃើញថា បារមី ៣០ មានទានបារមីជាដើម ជាហេតុឲ្យបានជាព្រះពុទ្ធទាំងឡាយមិនមែនតិច ឧបមាដូចគ្រាប់ខ្សាច់ក្នុងស្ទឹងគង្គារ មានការភ្ជាប់សេចក្ដីថា ឥឡូវនេះ អ្នកទាំងឡាយមានចិត្តបរិសុទ្ធ ចូរស្ដាប់អបទានដែលប្រើក្នុងអត្ថថា អធិការ គឺគុណដែលធ្វើក្រៃលែងជាដើម ។

បណ្ដាបទទាំងនោះ បទថា **សុទ្ធមានសា** សេចក្ដីថា លោកទាំងឡាយដែលជាព្រះខីណាស្រព ៥០០ ឈ្មោះថា ជាអ្នកមានចិត្តបរិសុទ្ធ គឺមានចិត្តផូរផង់ បានដល់ មានហទយៈស្អាត ព្រោះធ្វើកិលេស ១៥០០ ឲ្យអស់ទៅដោយអរហត្តមគ្គញាណ ហើយតាំងនៅ ចូរអង្គុយក្នុងធម្មសភា ចូរស្ដាប់ គឺចូរផ្ទៀងនូវសោតៈ ធ្វើទុកក្នុងចិត្ត ។

ក្នុងសេចក្ដីនេះ គប្បីជ្រាបថា ទោះបីមានការតាំងបច្ចេកពុទ្ធាបទាន ថេរាបទាន និងថេរីបទាន លោកក៏មិនប្រើពាក្យថា **អបទានានិ** ត្រឡប់ជាប្រើពាក្យថា **អថ ពុទ្ធាបទានានិ** ព្រោះជាប្រធាន និងព្រោះជាចំណែកខាងដើម ដូចកាលមានខន្ធយមកៈ អាយតនយមកៈ ធាតុយមកៈ សច្ចយមកៈ សង្ខារយមកៈ និងអនុសយយមកៈផងដែរ លោកក៏ប្រើពាក្យថា មូលយមកៈ ព្រោះជាប្រធាន និងព្រោះជាខាងដើម និងដូចកាលមានសង្ឃាទិសេស ១៣

អនិយត ២ និស្សគ្គិយ ៣០ ផងដែរ លោកប្រើពាក្យថា បារាជិកកណ្ឌ ព្រោះជាប្រធាន និងព្រោះជាខាងដើម ។

កាលគួរនឹងពោលថា **សម្មាសម្ពុទ្ធាបទានានិ** តែលោកធ្វើនូវការលុប បទនិបាតថា **សម្មា** ដែលចង្អុលប្រាប់អត្ថជាតតិយាវិភត្តិ និងបទឧបសគ្គថា **សំ** ដែលប្រាប់អត្ថនៃសព្ទថា **សយំ** ដោយនិរុត្តិន័យថា កាលផ្លាស់ ( និរុត្តិ ) មាន ៥ ប្រភេទ គឺជ្រែកអក្ខរៈ ។បេ។ ឬដោយសូត្រថា ក្នុងសន្ធិ មាន សន្ធិកិរិយោបករណ៍ គឺ **ក្វចិ** លុប ចុះតួអក្ខរៈ ធ្វើឲ្យខុសចាករបស់ដើម និងផ្លាស់ឲ្យខុសផ្សុយគ្នា ដូច្នេះហើយ ប្រើសព្ទថា **ពុទ្ធ** ដែលចង្អុលបង្ហាញ ថា **ជាកិតកៈ** ហើយពោលថា **ពុទ្ធាបទានានិ** ដើម្បីឲ្យងាយស្រួលក្នុងការ ចងគាថា ព្រោះហេតុនោះ ពាក្យថា **ពុទ្ធាបទានានិ** ទើបមានអត្ថថា អបទានរបស់ព្រះសម្មាសម្ពុទ្ធ ។

**ពណ៌នា អព្ភន្តរនិទាន ចប់**

# អដ្ឋកថា

## ពុទ្ធាបទានទី ១

ឥឡូវនេះ ព្រះថេរៈមានបំណងនឹងពោលអដ្ឋកថាអបទាន ក្នុងលំដាប់អព្ភន្តរនិទាន ទើបពោលថា

អបទាន គឺអបទានណា សម្ដែងន័យដ៏វិចិត្រ ព្រះអរហន្តទាំង
ឡាយ សង្គាយនាទុកក្នុងខុទ្ទកនិកាយ ឥឡូវនេះ ដល់លំដាប់
ពណ៌នាអត្ថនៃអបទាននោះហើយ ដូច្នេះ ។

ជាបឋម អបទាន ( ណា ) ក្នុងគាថានោះ ដល់នូវការសង្គ្រោះបាន ជារសតែមួយ ព្រោះលោកពោលថា ព្រះពុទ្ធវចនៈទាំងអស់ មានរសតែមួយ គឺវិមុត្តិ ក្នុងធម៌ ២ ពួក គឺធម៌ និងវិន័យ ចាត់នៅក្នុងពួកធម៌ ក្នុងបណ្ដាបឋមពុទ្ធវចនៈ មជ្ឈិមពុទ្ធវចនៈ និងបច្ឆិមពុទ្ធវចនៈ ចាត់ទុកក្នុងមជ្ឈិម-ពុទ្ធវចនៈ ក្នុងព្រះវិនយបិដក ព្រះសុត្តន្តបិដក និងព្រះអភិធម្មបិដក ចាត់ទុកក្នុងសុត្តន្តបិដក ក្នុងនិកាយ ៥ គឺទីឃនិកាយ មជ្ឈិមនិកាយ សំយុត្តនិកាយ អង្គុត្តរនិកាយ និងខុទ្ទកនិកាយ ចាត់ទុកក្នុងខុទ្ទកនិបាយ និកាយក្នុងនវង្គ-សត្ថុសាសនៈ គឺសុត្តៈ គេយ្យៈ វេយ្យាករណៈ គាថា ឧទាន ឥតិវុត្តកៈ ជាតក អព្ភូតធម៌ វេទល្លៈ ចាត់ទុកក្នុងគាថា ក្នុងធម្មក្ខន្ធ ៨៤០០០ ដែលព្រះអានន្ទពោលហើយយ៉ាងនេះថា

ខ្ញុំរៀនមកអំពីព្រះពុទ្ធ ៨២០០០ ព្រះធម្មក្ខន្ធ រៀនអំពីភិក្ខុ
២០០០ ព្រះធម្មក្ខន្ធ រួមជាធម្មក្ខន្ធ ដែលស្ទាត់រត់មាត់
៨៤០០០ ព្រះធម្មក្ខន្ធ ដូច្នេះ ។

អបទាន ចាត់ទុកក្នុងធម្មក្ខន្ធចំណែកបន្តិចបន្តួច ។

ឥឡូវនេះ កាលនឹងសម្ដែងអបទាននោះ ទើបលោកពោលថា ដែលជាព្រះរាជាហេតុធម៌ បរិបូណ៌ដោយបារមី ៣០ ជាដើម ។ ក្នុងបទទាំងនោះ មានវិនិច្ឆ័យដូចតទៅនេះថា

បារមី ១០ នោះឯង ចាត់ជាបារមី ៣០ គឺបារមី ១០ ឧបបារមី ១០ និងបរមត្ថបារមី ១០ ចាត់ជាយ៉ាងទាប យ៉ាងកណ្ដាល និងយ៉ាងខ្ពស់ ជាអ្នកបរិបូណ៌ល្អ គឺដល់ព្រម បានដល់ សម្បុរ ប្រកប ព្រមព្រៀង សម្រេច ប្រកបដោយបារមី ៣០ នោះ ព្រោះហេតុនោះ ទើបឈ្មោះថា បរិបូណ៌ដោយបារមី ៣០ ។

ឈ្មោះថា **រាជា** ព្រោះញ៉ាំងពួកសត្វ ដែលនៅក្នុងលោកទាំង ៣ ឲ្យត្រេកអរដោយចិត្តតែមួយ ឲ្យត្រេកអរដោយចិត្តតែមួយ ក្នុងកាយរបស់ខ្លួនដោយព្រហ្មវិហារសមាបត្តិ ៤ គឺមេត្តា ករុណា មុទិតា ឧបេក្ខា ឬដោយធម៌ជាគ្រឿងនៅ គឺផលសមាបត្តិ ។ ព្រះរាជាដោយធម៌ ឈ្មោះថា **ធម្មរាជា** ព្រះពុទ្ធទាំងឡាយមានសភាពយ៉ាងនេះ អធិប្បាយថា ព្រះពុទ្ធ ជាធម្មរាជាដែលកន្លងទៅហើយ គឺចេញទៅហើយ រលត់ហើយ ដល់នូវការតាំងនៅមិនបានហើយ រាប់មិនបាន គឺ រាប់មិនអស់ដោយចំនួន ១ រយ ១ ពាន់ ១ ម៉ឺន ១ សែន ១ លាន ១ កោដិ ១ បកោដិ ១ កោដិបកោដិ ១ នហុត ១ និន្នហុត ១ អក្ខោភិនី ១ ពិន្ទុ ១ អព្វុទៈ ១ និរព្វុទៈ ១ អហហៈ ១ អពពៈ ១ អដដៈ ១ សោគន្ធិកៈ ១ ឧប្បលៈ ១ កុមុទៈ ១ បុណ្ឌរិកៈ ១

បទុមៈ ១ កឋានៈ ១ មហាកឋានៈ និង ១ អសេង្ខយ្យ ។

ព្រះមានព្រះភាគ ដែលព្រះអានន្ទត្ថេរទូលសួរដល់អធិការ ដែលព្រះអង្គជាពោធិសត្វ ទ្រង់ធ្វើក្នុងអតីតព្រះពុទ្ធទាំងនោះ និងសម្ភារៈ ដែលព្រះអង្គជាស្តេចចក្រពត្តិទ្រង់ធ្វើហើយ ទើបត្រាស់ពាក្យជាដើមថា **សព្វញ្ញូ ពុទ្ធ-សេដ្ឋានំ** ចំពោះព្រះសព្វញ្ញុតញ្ញាណរបស់ព្រះពុទ្ធដ៏ប្រសើរទាំងឡាយ ដូច្នេះ មានអធិប្បាយថា ម្នាលអានន្ទ ចូរអ្នកស្តាប់អបទានរបស់តថាគត ក្លាប់សេចក្តីថា ម្នាលអានន្ទ ក្នុងកាលមុន គឺក្នុងកាលបំពេញពោធិសម្ភារៈ តថាគតជាស្តេចចក្រពត្តិ អភិវាទដោយសិរសា នូវព្រះសព្វញ្ញុតញ្ញាណ គឺចតុសច្ចមគ្គញ្ញាណ ឬព្រះសព្វញ្ញុតញ្ញាណ របស់ព្រះពុទ្ធទាំងឡាយដ៏ប្រសើរ គឺដែលចាក់ធ្លុះនូវសច្ចៈ ៤ ហើយ អធិប្បាយថា តថាគតយកម្រាមដៃ ១០ គឺបាតដៃទាំង ២ នមស្ការ គឺថ្វាយបង្គំព្រះពុទ្ធទាំងឡាយ ដែលជាលោក-នាយក គឺជាអ្នកជំក្នុងលោក ព្រមទាំងព្រះសង្ឃ គឺព្រមដោយសង្ឃសាវ័ក ហើយនមស្ការដោយសិរសា គឺត្បូង គឺធ្វើនូវការសរសើរហើយ ធ្វើការឱនលំទោន ដោយការពេញចិត្ត ។ បទថា **យាវតា ពុទ្ធក្ខេត្តេសុ** សេចក្តីថា រតនៈទាំង ៧ មានកែវពិទូរ្យជាដើម ដែលតាំងនៅក្នុងអាកាស គឺដែលនៅក្នុងអាកាស ដែលតាំងនៅលើផែនដី គឺដែលនៅលើផែនដីរាប់មិនអស់ គឺរាប់មិនបានថា នេះមានប្រមាណប៉ុនណា គឺមានប្រមាណត្រឹមណា ក្នុងពុទ្ធក្ខេត្តក្នុងម៉ឺនចក្កវាឡ តថាគតនឹក គឺប្រើចិត្តប្រមូលចិត្តមកនូវរតនៈទាំងអស់នោះ គឺអធិដ្ឋានចិត្ត នាំមកដោយល្អ អធិប្បាយថា តថាគតនឹងធ្វើឲ្យជាគំនរជុំវិញ

ប្រាសាទរបស់តថាគត ។

បទថា **តត្ថ រូបិយភូមិយំ** សេចក្តីថា និម្មិតផែនដីដែលសម្រេចដោយរូបិយ គឺសម្រេចដោយប្រាក់ ក្នុងប្រាសាទទាំងឡាយជាន់នោះ អធិប្បាយថា តថាគតនិម្មិតប្រាសាទច្រើនរយជាន់ ដែលសម្រេចដោយរតនៈ គឺសម្រេចដោយរតនៈ ៧ ខ្ពស់ឡើងទៅក្នុងអាកាស គឺរុងរឿងនៅក្នុងអាកាស ។

ព្រះមានព្រះភាគ កាលពណ៌នាប្រាសាទនោះ ទើបត្រាស់ថា **វិចិត្តថម្ភំ** ដូច្នេះជាដើម ក្នុងសេចក្តីថា ប្រាសាទលើកឡើង តាក់តែងយ៉ាងល្អ ដោយសសរ មានពណ៌ដូចកែវមកិតជាដើមច្រើនសសរ សាងហើយដោយល្អត្រូវលក្ខណៈ ចាត់ចែងរៀបរយដោយកម្ពស់ និងទំហំ ឈ្មោះថា មានតម្លៃច្រើន ព្រោះនិម្មិតសសរដែលមានតម្លៃច្រើនរយកោដិ ។ ប្រាសាទ វិសេសដូចម្តេចទៀត គឺប្រាសាទមានសសរ ដែលសម្រេចដោយមាស បានដល់ ប្រកបដោយធ្នឹម និងផ្តោងធ្វើអំពីមាស ប្រដាប់ហើយ គឺធ្វើឲ្យស្អាតហើយ ដោយសត្វក្រៀល និងឆត្រ ដែលលើកឡើងក្នុងប្រាសាទនោះ ។

កាលទ្រង់ពណ៌នាលម្អ របស់ប្រាសាទដោយចំពោះដដែលទៀត ទើបត្រាស់ថា ជាន់ទីមួយ ជាវិការនៃកែវពៃទូរ្យជាដើម សេចក្តីថា ប្រាសាទដែលមានផ្ទៃច្រើនរយជាន់នោះល្អ គឺគួរប្រាថ្នា គួរស្រឡាញ់ គួរពេញចិត្ត ដូចជុំពពក គឺដូចគ្នានឹងមេឃប្រាសចាកមន្ទិល គឺមិនមានមន្ទិល មានពណ៌ខៀវ សម្រេចដោយកែវពិទូរ្យ អធិប្បាយថា ជាន់ទីមួយ ដេរដាស គឺដល់ព្រមដោយផ្កាឈូក និងផ្កាបទុមដែលកើតក្នុងទឹក មានផ្ទៃសម្រេចអំពីមាស គឺជា

ផ្លែមាសដ៏ប្រសើរឧត្តម ។

អធិប្បាយថា ប្រាសាទនោះឯង ជាន់ខ្លះ មានពណ៌ដូចកែវប្រពាល គឺមានចំណែកនៃកែវប្រពាល មានពណ៌ដូចកែវប្រពាល ជាន់ខ្លះ មានពណ៌ក្រហម គឺមានពណ៌ក្រហម ជាន់ខ្លះ មានផ្ទៃស្អាត គឺជាទីត្រេកអរនៃចិត្ត មានពន្លឺដូចពណ៌មេភ្លៀង[១] ចាំងរស្មី ជាន់ខ្លះ ភ្លឺចេញទៅទាំង ១០ ទិស ។

ក្នុងប្រាសាទនោះ ជាន់ខ្លះ មានរបៀង គឺយ៉មុខ ដែលរៀបចំល្អហើយ គឺចាត់ចែងសមសួន បានដល់ ចាត់ជាចំណែកៗ និងមានសីហបញ្ជរ និងសីហទ្វារ ។ បទថា **ចតុរោ វេទិកា** សេចក្តីថា ផ្ទៃប្រាសាទ ជាទីត្រេកអរ គឺជាទីចាប់ចិត្ត ដោយវេទិកា ( ភ្នាក់ដៃ ) មានរាងជារង្វង់ ៤ ជាន់ និងដោយគោម និងសំណុំគ្រឿងក្រអូបសំយុងនៅ ។

ក្នុងប្រាសាទនោះឯង មានផ្ទះកំពូលប្រដាប់ដោយរតនៈ ៧ គឺលម្អទៅដោយរតនៈ ៧ ។ មានពណ៌ដូចម្តេច គឺមានពណ៌ខៀវ ពណ៌លឿង បានដល់ មានពណ៌លឿងដូចមាស ពណ៌ក្រហមដូចទន់ដែង ពណ៌ស ពណ៌ខ្មៅសុទ្ធ មានពណ៌ខ្មៅសុទ្ធ មិនលាយដោយពណ៌ដទៃ អធិប្បាយថា ប្រាសាទនោះប្រកបដោយផ្ទះកំពូល គឺប្រកបដោយផ្ទះកំពូល ដែលមានជហ្វាយ៉ាងល្អ ។

ក្នុងប្រាសាទនោះឯង មានផ្កាបទុមរីក គឺមានផ្កាតាំងឡើង បានដល់ មានផ្កាឈូករីកស្រស់ត្រកាល អធិប្បាយថា ប្រាសាទនោះលម្អដោយពួកសត្វសាហាវ មានសីហៈ និងខ្លាជាដើម និងលម្អដោយពួកបក្សី មានហង្ស

---

១- បាលីថា ឥន្ទគោបក បិដកខ្មែរ ប្រែថា អណ្តើកមាស ។

ក្រៀល ក្អែកជាដើម សេចក្តីថា ប្រាសាទនោះខ្ពស់សន្ធឹម ព្រោះទល់មេឃ ទើបដេរដាសដោយនក្ខត្តឫក្ស និងផ្កាយ ប្រដាប់ដោយព្រះចន្ទ ព្រះអាទិត្យ ។

អធិប្បាយថា ប្រាសាទរបស់ស្តេចចក្រពត្តិនោះឯង គ្របដណ្តប់ដោយបណ្តាញមាស សំយុង គឺប្រកបដោយបណ្តាញកណ្តឹងមាស សេចក្តីថា បណ្តាញមាស គឺជួរនៃផ្កាដែលជាទីត្រេកអរនៃចិត្ត គឺជាទីជាប់ចិត្ត រមែងបន្លឺសំឡេង គឺរមែងបញ្ចេញសំឡេង ព្រោះកម្លាំងខ្យល់ គឺព្រោះខ្យល់ប៉ះខ្ទប់ ។

ដោតទង់ដែលជ្រលក់ពណ៌ គឺប៉ាក់ដោយពណ៌ផ្សេងៗ គឺមានពណ៌មិនតែមួយ ជាទង់ពណ៌ហង្សបាទ ពណ៌ក្រហម គឺក្រហមដូចឈាម ពណ៌លឿង គឺមានពណ៌លឿង ដូចមាសជម្ពូនទ គឺមានពណ៌លឿងចាស់ បានដល់ មានពណ៌ដូចមាសជម្ពូនទ និងមានពណ៌លឿងខ្ចី គឺដោតទង់មានពណ៌ផ្សេងៗក្នុងប្រាសាទនោះ ។ ពាក្យថា **ធជមាលិនី** នេះ លោកប្រើជាលិង្គវិបល្លាស ឯសេចក្តី គឺប្រាសាទនោះ ប្រកបដោយរបៀបទង់ ។

កាលទ្រង់ពណ៌នាកម្រាលជាដើមក្នុងប្រាសាទនោះ ទើបត្រាស់ថា **ឆទំ ពហូ** ដូច្នេះជាដើម ក្នុងសេចក្តីនេះ អធិប្បាយថា ប្រាសាទនោះ មិនមានវត្ថុដែលមិនមានឡើយ ។ ទីដេក មានគ្រែ និងតាំងជាដើម វិចិត្រដោយសយនៈផ្សេងៗ គឺដោយកម្រាលមិនមែនតិច មានចំនួនច្រើនរយ គឺរាប់បានច្រើនរយ ។ សួរថា មានអ្វីខ្លះ ។ ឆ្លើយថា គឺ ទីដេកធ្វើដោយកែវផលិក[1]

---

១- បិដកច្បាប់ឆដ្ឋសង្គាយនា មានបាលីថា ផលិកា ប្រែថា កែវផលិក តែបិដកខ្មែរជា ផលកា ប្រែថា បន្ទះក្តារទៅវិញ ។

បានដល់ ធ្វើសម្រេចដោយកែវផលិក ធ្វើដោយប្រាក់ គឺសម្រេចដោយប្រាក់ ដោយកែវមណី គឺសម្រេចដោយកែវមណីខៀវ ធ្វើដោយកែវទទឹម គឺសម្រេចដោយកែវមណីមានពណ៌ក្រហមដោយកំណើត ធ្វើដោយកែវប្រពាល គឺធ្វើដោយកែវមណីប្រពាល បានដល់ កែវមកិត ក្រាលទៅដោយសំពត់កាសីសាច់ល្អ គឺក្រាលដោយសំពត់កាសីសាច់ម៉ដ្ឋទន់ ។

សំពត់ដណ្តប់ ឈ្មោះថា **ចាវុកា** ។ សួរថា សំពត់ដណ្តប់ដូចម្តេច គឺសំពត់រោមសត្វ បានដល់ សំពត់ដែលត្បាញអំពីរោមសត្វ សំពត់សូត្រ បានដល់ សំពត់ដែលត្បាញដោយសម្បកឈើ សំពត់ស្រុកចីនៈ បានដល់ សំពត់ដែលត្បាញក្នុងប្រទេសចីនៈ សំពត់ស្រុកបត្តុណ្ណៈ បានដល់ សំពត់ដែលត្បាញដោយសំឡីដែលកើតក្នុងស្រុកបត្តុណ្ណៈ សំពត់ស្រុកបណ្ឌុ បានដល់ សំពត់ពណ៌លឿង អធិប្បាយថា តថាគតឲ្យក្រាលនូវកម្រាលដ៏វិចិត្រ គឺទីដេកទាំងអស់ ដែលវិចិត្រដោយកម្រាល និងសំពត់ដណ្តប់ មិនមែនតិចដោយមនោ គឺ ដោយចិត្ត ( របស់តថាគត ) ។

កាលទ្រង់ពណ៌នាប្រាសាទនោះដដែលទៀត ទើបត្រាស់ថា **តាសុ តាស្វេវ ភូមីសុ** ដូច្នេះជាដើម ។ បណ្តាបទទាំងនោះ បទថា **រតនកូដលង្កតំ** សេចក្តីថា ប្រដាប់ គឺធ្វើឲ្យល្អ ដោយជហ្វារតនៈ គឺជហ្វាកែវ ។ បទថា **មណិវេរោចនា ឧក្កា** សេចក្តីថា គប់ភ្លើង គឺប្រទីបមានដង ធ្វើដោយកែវមណីដ៏រុងរឿង គឺកែវមណីក្រហម ។ បទថា **ធារយន្តា សុតិដ្ឋរេ** សេចក្តីថា មនុស្សច្រើនរយឈរកាន់ គឺកាន់ក្នុងអាកាសយ៉ាងស្អាត ។

កាលទ្រង់ពណ៌នាប្រាសាទនោះដដែលទៀត ទើបត្រាស់ពាក្យជាដើមថា **សោភន្តិ ឃសិកា ចម្មា** ដូច្នេះ ។ សសរដែលដោតត្រង់ទ្វារនគរ ដើម្បីឲ្យស្អាត ឈ្មោះថា **ឃសិកា ចម្ម** ក្នុងពាក្យថា **សោភន្តិ ឃសិកាចម្មា** នោះ ។ ខ្លោងទ្វារល្អ គឺគួរពេញចិត្ត ខ្លោងទ្វារជាវិការនៃមាស គឺសម្រេចដោយមាស ជាវិការនៃមាសជម្ពូនទ គឺសម្រេចដោយមាសជម្ពូនទ ជាវិការនៃឈើខ្លឹម គឺធ្វើដោយខ្លឹមគគីរ និងជាវិការនៃប្រាក់ អធិប្បាយថា សសររបង និងខ្លោងទ្វារ ធ្វើនូវប្រាសាទនោះឲ្យស្អាត ។

ក្នុងប្រាសាទនោះ ទាំងទីតំណាដ៏ច្រើនដែលចែកល្អ គឺវិចិត្រល្អ ដោយសន្ទះទ្វារ និងរនុកទ្វារ បិទបាំងទីតធ្វើឲ្យស្អាត ។ បទថា **ឧភតោ** បានដល់សងខាងប្រាសាទនោះ មានថ្នាំងពេញដោយទឹក គឺពេញដោយផ្កាឈូកក្រហមមិនមែនតិច និងឧប្បលមិនមែនតិច ធ្វើប្រាសាទនោះឲ្យល្អ ។

កាលទ្រង់ពណ៌នាលម្អរបស់ប្រាសាទយ៉ាងនេះហើយ កាលទ្រង់ប្រកាសប្រាសាទដែលធ្វើដោយរតនៈ សក្ការៈ និងការរាប់អាន ទើបត្រាស់ពាក្យជាដើមថា **អតីតេ សព្វពុទ្ធេ ច** ដូច្នេះ ។

បណ្ដាបទទាំងនោះ បទថា **អតីតេ** សេចក្ដីថា ក្នុងកាលដែលកន្លងទៅហើយ គឺផុតទៅហើយ តថាគតនិម្មិតព្រះពុទ្ធជាលោកនាយកគ្រប់អង្គមួយអន្លើដោយព្រះសង្ឃសាវ័ក គឺប្រព្រឹត្តទៅដោយពួកសាវ័កដែលកើតមានមកហើយ និងព្រះពុទ្ធ ព្រមទាំងសាវ័ក គឺមានសាវ័ក ដោយមានពណ៌សម្បុរ រូបឆោម និងទ្រង់ទ្រាយតាមប្រក្រតីដោយសភាវៈព្រះពុទ្ធ មួយអន្លើ

ដោយសាវ័ក យានចូលទៅកាន់ប្រាសាទតាមទ្វារនោះ ប្រថាប់គន់លើតាំង ដែលធ្វើដោយមាសសុទ្ធ គឺសម្រេចហើយដោយមាសទាំងអស់ ជាអរិយ-មណ្ឌល គឺជាពួកព្រះអរិយៈ អធិប្បាយថា ក្នុងឥឡូវនេះ គឺក្នុងបច្ចុប្បន្ន តថាគតបានឲ្យព្រះពុទ្ធដ៏ប្រសើរ គឺមិនមានអ្នកដទៃក្រៃលែងជាង ដែលមាន និងព្រះបច្ចេកពុទ្ធច្រើនរយអង្គ ដែលជាសយម្ភូ គឺជាអ្នកកើតឯង មិនមានអ្នកដទៃជាអាចារ្យ ជាអ្នកមិនចាលចាញ់ គឺជាបុគ្គលដែលខន្ធមារ កិលេសមារ អភិសង្ខារមារ មច្ចុមារ និងទេវបុត្តមារ ធ្វើឲ្យចាលចាញ់មិនបាន ជាអ្នកសម្រេចជ័យជម្នះ ឲ្យឆ្អែតស្កប់ស្កល់ហើយ ។ ព្រះពុទ្ធគ្រប់អង្គ ក្នុងអតីតកាល និងក្នុងបច្ចុប្បន្នកាល បានយាងឡើង គឺយាងឡើងយ៉ាងល្អ គឺដោយល្អហើយ ។

ភ្ជាប់សេចក្តីថា ដើមកប្បព្រឹក្សទាំងឡាយណាដែលជាទិព្វ គឺជារបស់ទិព្វ បានដល់ កើតក្នុងទេវលោក មានច្រើន និងដើមកប្បព្រឹក្សពួកណាដែលជារបស់មនុស្ស គឺកើតក្នុងមនុស្សមានច្រើន តថាគតនាំយកសំពត់ទាំងអស់អំពីដើមកប្បព្រឹក្សទាំងនោះ មកធ្វើជាត្រៃចីវរ ហើយឲ្យព្រះបច្ចេកពុទ្ធទាំងនោះ គ្រងត្រៃចីវរ ។

កាលព្រះបច្ចេកពុទ្ធទាំងនោះ ស្លៀកដណ្តប់ត្រៃចីវរ អង្គុយយ៉ាងនេះហើយ តថាគតនាំយករបស់ទំពា គឺរបស់ឯណាមួយ មានទំពាំងដើមដែលគួរទំពា ដែលដល់ព្រមហើយ គឺមានរសឆ្ងាញ់ របស់គួរបរិភោគ គឺអាហារដែលគួរបរិភោគដែលឆ្ងាញ់ របស់គួរលិទ្ធ គឺរបស់ដែលគួរលិទ្ធភក្សដ៏ឆ្ងាញ់ របស់ដែលគួរផឹក គឺទឹកបានៈ ៨ យ៉ាងដែលដល់ព្រម គឺឆ្ងាញ់ និងភោជន

គឺអាហារដែលគួរបរិភោគ ដាក់ពេញក្នុងបាត្រកែវមណី គឺធ្វើដោយថ្មដ៏ស្អាត គឺល្អ ហើយប្រគេន គឺនិមន្តឲ្យទទួលយកហើយ ។

អរិយមណ្ឌលទាំងអស់នោះ គឺពួកអរិយៈទាំងអស់នោះ ជាអ្នកមានទិព្វចក្ខុស្មើគ្នា ជាអ្នកស្អាតស្អំ អធិប្បាយថា ជាអ្នកដល់ព្រមដោយទិព្វចក្ខុ ជាបុគ្គលជ្រះស្រឡះ គឺជាអ្នកបរិសុទ្ធ គឺល្អ ព្រោះវៀរចាកកិលេសទាំងពួង ស្លៀកដណ្តប់ចីវរ គឺជាអ្នកដល់ព្រមដោយត្រៃចីវរ ជាបុគ្គលដែលតថាគតឲ្យឆ្អែតស្កប់ស្កល់ គឺឲ្យឆ្អែតក្រៃលែង ឲ្យបរិបូណ៌ដោយបង្អែម ស្ករក្រាម ប្រេង ទឹកឃ្មុំ ទឹកអំពៅ និងបាយដ៏ល្អ គឺលំដាប់ដែលល្អ ។

ពួកព្រះអរិយៈទាំងនោះ ដែលតថាគតឲ្យឆ្អែតស្កប់ស្កល់យ៉ាងនេះហើយ ចូលកាន់បន្ទប់កែវ គឺផ្ទះដែលមានបន្ទប់ ដែលធ្វើដោយរតនៈទាំង ៧ សម្រេចសីហសេយ្យាលើសយនៈមានតម្លៃច្រើន គឺលើគ្រែ ដែលមានតម្លៃកាត់ថ្លៃមិនបាន ដូចកេសររាជសីហ៍ក្នុងគុហា គឺដេកនៅក្នុងគុហា ដូច្នោះ អធិប្បាយថា សីហមិគរាជដេកផ្ទៀងស្តាំ ដាក់ជើងត្រួតលើជើង យកជើងស្តាំធ្វើជាខ្នើយ ជើងឆ្វេងសណ្តូកទៅត្រង់ យកកន្ទុយស៊កក្នុងរវាងភ្លៅ ដេកស្ងៀមមិនកម្រើកយ៉ាងណា ពួកព្រះអរិយៈទាំងឡាយក៏សម្រេច គឺការដេកក៏យ៉ាងនោះ ។

អធិប្បាយសេចក្តីថា ពួកព្រះអរិយៈទាំងនោះ កាលសម្រេចសីហសេយ្យាសនៈយ៉ាងនេះហើយ មានសតិសម្បជញ្ញៈ គឺសម្បូរដោយសតិសម្បជញ្ញៈ ក្រោកឡើងហើយ គឺក្រោកឡើងយ៉ាងរៀបរយ ហើយពត់ភ្នែនលើទីដេក គឺធ្វើការអង្គុយ ធ្វើភ្លៅឲ្យតាំងស៊ប់ជាប់គ្នា ។

បទថា **គោចរំ សព្វពុទ្ធានំ** សេចក្តីថា បំពេញសេចក្តីត្រេកអរក្នុងឈានជាអារម្មណ៍ គឺជាអ្នកឆ្អែតយ៉ាងល្អ បានដល់ ព្រមដោយការត្រេកអរក្នុងឈានដែលជាគោចរ គឺអារម្មណ៍របស់ព្រះពុទ្ធទាំងពួង ទាំងក្នុងអតីត និងអនាគត ។ បទថា **អញ្ញេ ឈានានិ ឆេសេន្តិ** សេចក្តីថា បណ្តាព្រះបច្ចេកពុទ្ធទាំងនោះ ព្រះបច្ចេកពុទ្ធមួយពួក គឺពួកខ្លះ សម្តែងធម៌ ពួកខ្លះ លេង គឺត្រេកអរដោយឫទ្ធិ គឺដោយការលេងឈាន មានបឋមជ្ឈានជាដើម ។

អធិប្បាយថា អន្លះខ្លះ គឺពួកខ្លះ ចម្រើនអភិញ្ញា គឺធ្វើអភិញ្ញា ៥ ឲ្យជំនាញ គឺធ្វើឲ្យស្ទាត់ រមែងដល់ គឺចូលអភិញ្ញាដែលទៅ គឺដល់ សម្រេចនូវការជំនាញដោយវសី ៥ យ៉ាង ក្នុងអភិញ្ញា ៥ ប្រការ ពោល គឺអាវជ្ជនៈ ការចូល ការចេញ អធិដ្ឋាន និងការពិចារណា អន្លះខ្លះ សម្តែងឫទ្ធិ គឺធ្វើការសម្តែងឫទ្ធិ គឺការឡាខ្លួន ដូចជាមនុស្សម្នាក់ ធ្វើឲ្យច្រើនពាន់នាក់ក៏បាន ច្រើននាក់ ធ្វើឲ្យជាម្នាក់ក៏បាន ។

បទថា **ពុទ្ធាបិ ពុទ្ធេ** សេចក្តីថា កាលព្រះបច្ចេកពុទ្ធទាំងឡាយប្រជុំគ្នាដូច្នេះហើយ ព្រះពុទ្ធទាំងឡាយ រមែងសួរព្រះពុទ្ធទាំងឡាយដល់ប្រស្នាដែលជាវិស័យ គឺជាអារម្មណ៍របស់ព្រះសព្វញ្ញុតញ្ញាណ ព្រះពុទ្ធទាំងនោះរមែងត្រាស់ដឹងពិត គឺត្រាស់ដឹងដោយវិសេស មិនមានចំណែកសេសសល់នូវឋានៈ គឺហេតុ ដែលឈ្មោះថា ដ៏ជ្រៅល្អិត ព្រោះជ្រៅដោយអត្ថ ដោយបញ្ញា ។

ក្នុងកាលនោះ សាវកទាំងឡាយ ដែលប្រជុំគ្នាក្នុងប្រាសាទរបស់តថាគត

ក៏ទូលសួរបញ្ហានឹងព្រះពុទ្ធទាំងឡាយៗ ក៏សួរបញ្ហានឹងសាវ័ក គឺសិស្សទាំងឡាយ ព្រះពុទ្ធ និងសាវ័កទាំងនោះ សួរបញ្ហាគ្នានិងគ្នា ព្យាករ គឺឆ្លើយបញ្ហាគ្នានិងគ្នា ។

កាលទ្រង់សម្ដែងព្រះពុទ្ធទាំងអស់នោះ នៅរួមគ្នាទៀត ទើបត្រាស់ពាក្យថា **ពុទ្ធា បច្ចេកពុទ្ធា ច** ជាដើម ។ ក្នុងពាក្យនោះ មានអធិប្បាយថា ព្រះពុទ្ធ បានដល់ ព្រះសម្មាសម្ពុទ្ធ ព្រះបច្ចេកពុទ្ធ សាវ័ក គឺសិស្ស និងអ្នកប្រណិប័តន៍ គឺនិស្សិតទាំងអស់នេះ ត្រេកអរដោយការត្រេកអររៀងៗ ខ្លួនពួនសម្ងំ អភិរម្យក្នុងប្រាសាទរបស់តថាគត ។

ព្រះបាទតិលោកវិជយចក្កពត្តិរាជនោះ កាលទ្រង់សម្ដែងអាចារសម្បត្តិនៃព្រះបច្ចេកពុទ្ធទាំងឡាយ ក្នុងពេជយ័ន្តប្រាសាទរបស់ព្រះអង្គយ៉ាងនេះហើយ ឥឡូវនេះ កាលទ្រង់សម្ដែងអានុភាពរបស់ព្រះអង្គ ទើបត្រាស់ពាក្យថា **ឆត្តា តិដ្ឋន្តុ រតនា** ដូច្នេះជាដើម ។ ក្នុងពាក្យនោះ មានអធិប្បាយថា ឆត្រកែវ គឺឆត្រដែលសម្រេចហើយដោយកែវ ៧ ប្រការ មានកម្រងមាសជាជួរ គឺមានបណ្ដាញមាសសំយុងជាប្រចាំ ។ ឆត្រទាំងឡាយព័ទ្ធព័ទ្ធដោយសំណាញ់កែវមុក្តា គឺពាសដោយសំណាញ់កែវមុក្តា ត្រឹមតែគិតថា ឆត្រគ្រប់ប្រភេទចូរបាំងលើសីសៈរបស់យើង ក៏ប្រាកដឡើងមួយរំពេច ។

ពិតានសំពត់វិចិត្រដោយរូបផ្កាយមាស គឺរំលេចដោយផ្កាយមាស ចូរមាន គឺចូរកើតឡើង អធិប្បាយថា ពិតានមិនមែនតិចគ្រប់ប្រភេទ វិចិត្រ គឺមានពណ៌ច្រើនយ៉ាង ដេរដាសដោយមាល័យ គឺផ្សាយទៅដោយផ្កា ចូរបាំង

លើសិរសា គឺចំណែកខាងលើទីអន្ទ្យ ។

ក្លាប់សេចក្ដីថា ស្រះបោក្ខរណីដេរដាស គឺចម្រុះដោយកម្រងគ្រឿងក្រអូប គឺកម្រងផ្កាក្រអូបច្រើនយ៉ាង លម្អដោយកម្រងគ្រឿងក្រអូប គឺកម្រងសុគន្ធជាតិ មានខ្លឹមចន្ទន៍ ( ឫស ) ស្បូវក្លាំង និងក្រស្នាជាដើម អធិប្បាយថា ស្រះបោក្ខរណីចម្រុះដោយផ្ទាំងសំពត់ គឺកម្រងសំពត់ដែលមានតម្លៃកាត់ថ្លៃមិនបាន មានសំពត់បត្តុណ្ណៈ និងសំពត់ចីនៈជាដើម ប្រដាប់តាក់តែងដោយកម្រងរតនៈ ៧ ប្រការ ដេរដាសដោយផ្កា គឺដេរដាសដោយផ្កាក្រអូប មានផ្កាចម្ប៉ា ផ្កាស្រល់ និងចន្ទុលណីជាដើម វិចិត្រដោយល្អ ។ សួរថា ស្រះបោក្ខរណី មានអ្វីខ្លះទៀត គឺស្រះបោក្ខរណី អប់ដោយសុគន្ធជាតិ មានក្លិនក្រអូប គួរពេញចិត្តក្រៃលែង ប្រោះព្រំដោយគ្រឿងក្រអូបដោយជុំវិញ គឺប្រដាប់ដោយគ្រឿងក្រអូប ដែលយកម្រាមទាំង ៥ លាបស្រះបោក្ខរណី មាននៅក្នុងទិសទាំង ៤ របស់ប្រាសាទ ប្រក់ដោយដំបូលមាស គឺប្រក់ដោយគ្រឿងប្រក់ដែលជាមាស និងពិតានមាស ដេរដាស ផ្សាយពេញទៅដោយផ្កាបទុម និងឧប្បល ចូរប្រាកដជាពណ៌មាសក្នុងរូបមាស ស្រះបោក្ខរណី ផ្សាយទៅដោយលម្អងនៃផ្កាឈូក គឺខ្វះខ្វាយទៅដោយលម្អងផ្កាឈូកដ៏ស្អាត ។

ជុំវិញពេជយ័ន្តប្រាសាទរបស់តថាគត មានដើមឈើ មានដើមចម្ប៉ាជាដើមចេញផ្កាគ្រប់ដើម នេះជាដើមឈើផ្កា ។ ផ្កាទាំងឡាយជ្រុះមកឯង ហើយអណ្ដែតទៅបាចសាចលើប្រាសាទ គឺចូររោយលើប្រាសាទ ។

មានអធិប្បាយថា ក្នុងពេជយ័ន្តប្រាសាទរបស់តថាគតនោះ ចូរក្ងោក

រាំពត់ពែន ពួកហង្សទិព្វ គឺហង្សទេវតា ចូរបញ្ចេញសំឡេង ពួកសត្វករវិក តាវៅដែលមានសំឡេងពីរោះ ចូរយំ គឺធ្វើការច្រៀង ហើយពួកបក្សីដទៃៗ ដែលមិនចេញឈ្មោះ ក៏ចូរយំដោយសំឡេងដ៏ពីរោះជុំវិញប្រាសាទ ។

ជុំវិញប្រាសាទ មានស្គរដែលពាសតែម្ខាង និងស្គរសម្ភោរជាដើម ទាំងអស់ ចូរតាំងឡើងឯង គឺវាយឯង ពិណទាំងអស់ដែលមានខ្សែមិនតែ ១ ចូរដេញឯង គឺបន្លឺសំឡេង ។ តន្ត្រីគ្រប់ប្រភេទ គឺច្រើនប្រការ ចូរប្រព្រឹត្ត ទៅ គឺចូរបន្លឺ អធិប្បាយថា ចូរប្រគំឡើង ។ ក្នុងពុទ្ធក្ខេត្តមានកំណត់ត្រឹមណា គឺក្នុងទីមានប្រមាណប៉ុន្មាន បានដល់ ក្នុងម៉ឺនចក្កវាឡ និងក្នុងចក្កវាឡដទៃ ក្រៅអំពីម៉ឺនចក្កវាឡនោះ បល្ល័ង្កមាស សម្បូរដោយពន្លឺ គឺសម្បូរដោយរស្មី មិនមានឱកាសទទេ គឺជំគ្រប់ផ្នែក ដោយរតនៈទាំង ៧ ចូរតាំងនៅ ។ ដើមឈើដែលញូរប្រទីប គឺជាតប្រទីប ដើមឈើដែលមានប្រេង ដើមឈើដែលឆេះសន្ធោសន្ធៅ គឺភ្លឺដោយប្រទីបជុំវិញប្រាសាទ ជាប់តគ្នាជាពន្លឺតែមួយរាប់ម៉ឺនប្រទីប គឺម៉ឺនប្រទីបជាប់តគ្នានឹងម៉ឺនប្រទីប ចូរជាប្រទីបរុងរឿងតែមួយ គឺដូចប្រទីប ១ ដួង អធិប្បាយថា ចូរឆេះសន្ធោសន្ធៅ ។

ស្រី<u>គណិកា</u> គឺស្រីរបាំអ្នកឈ្លាសក្នុងការរាំ និងការច្រៀង ស្រីអ្នកចម្រៀង គឺស្រីអ្នកធ្វើសំឡេងដោយមាត់ ចូររាំច្រៀងជុំវិញប្រាសាទ ។ ពួកស្រីអប្សរ គឺពួកស្រីសួគ៌ ចូររាំ ។ ទីលានរាំផ្សេងៗ គឺមណ្ឌលសម្រាប់រាំផ្សេងៗ មានពណ៌ជាច្រើនប្រការ ( អ្នករាំ ) ចូររាំដោយជុំវិញប្រាសាទ ឈ្មោះថា ចូរប្រាកដ គឺមើលឃើញ ។

អធិប្បាយថា ក្នុងកាលនោះ តថាគតជាស្តេចចក្កពត្តិ ឈ្មោះតិលោកវិជយ ឲ្យលើកទង់ទាំងពួងមានពណ៌ ៥ គឺដែលមាន ៥ ពណ៌ មានពណ៌ខៀវ និងពណ៌លឿងជាដើម វិចិត្រ គឺលម្អដោយពណ៌ជាច្រើនលើចុងឈើត្រង់ត្រួយឈើ លើកំពូលភ្នំ គឺលើកំពូលភ្នំហិមពាន្ត និងភ្នំកណ្តាប់ចក្កវាឡជាដើម លើកំពូលភ្នំសិនេរុ និងក្នុងទីទាំងពួង ក្នុងចក្កវាឡទាំងមូល ។

អធិប្បាយថា ពួកមនុស្ស គឺមនុស្សដែលនៅក្នុងលោក ពួកនាគអំពីស្ថាននាគ ពួកគន្ធព្វ និងពួកទេវតាអំពីទេវលោកទាំងអស់ សូមចូលមក ។ ពួកមនុស្សជាដើមទាំងនោះ ចូរថ្វាយបង្គំ គឺនមស្ការតថាគត ធ្វើអញ្ជលី គឺប្រណម្យម្រាម ១០ ចោមរោមពេជយ័ន្តប្រាសាទរបស់តថាគត ។

ព្រះបាទចក្កពត្តិ តិលោកវិជយនោះ កាលពណ៌នាអានុភាពប្រាសាទ និងអានុភាពនៃខ្លួន យ៉ាងនេះហើយ ឥឡូវនេះ កាលឲ្យពួកសត្វបានទទួលផលបុណ្យ ដែលមានក្នុងព្រះអង្គ ទើបពោលពាក្យថា **យំ កិញ្ចិ កុសលំ កម្មំ** ដូច្នេះជាដើម អធិប្បាយថា កិរិយា ពោល គឺកុសលកម្មឯណាមួយដែលគប្បីធ្វើមាន កុសលកម្មដែលគប្បីធ្វើទាំងអស់នោះ ដែលខ្ញុំធ្វើហើយដោយកាយ វាចា និងចិត្ត គឺដោយទ្វារ ៣ ឲ្យជាការដែលធ្វើល្អហើយ គឺធ្វើហើយ ល្អហើយ អធិប្បាយថា ធ្វើឲ្យគួរទៅកើតក្នុងស្ថានតាវត្តិង្ស ។

កាលឲ្យទទួល ( ផលបុណ្យ ) ទៀត ទើបត្រាស់ថា **យេ សត្តា សញ្ញិនោ** ដូច្នេះជាដើម ក្នុងពាក្យនោះ មានអធិប្បាយថា សត្វពួកណា ជាមនុស្ស ទេវតា ឬព្រហ្មក្តីដែលមានសញ្ញា គឺប្រកបដោយសញ្ញា មាន និង

សត្វពួកណា ដែលមិនមានសញ្ញា គឺប្រាសចាកសញ្ញា បានដល់ សត្វដែលមិនមានសញ្ញា មាន សត្វទាំងអស់នោះ ចូរជាអ្នកមានចំណែកផលបុណ្យដែលខ្ញុំបានធ្វើហើយ គឺចូរជាអ្នកមានបុណ្យ ។

ព្រះពោធិសត្វ កាលនឹងឲ្យកាន់យកទៀត ទើបត្រាស់ពាក្យថា **យេ តំ កតំ** ដូច្នេះជាដើម ។ អធិប្បាយថា បុណ្យដែលខ្ញុំធ្វើហើយ ដែលជន គឺ នាគ គន្ធព្វ និងទេវតាពួកណាដឹងហើយ គឺជ្រាបហើយ ខ្ញុំឲ្យផលបុណ្យដល់នរជនជាដើមនោះ នរជនជាដើមណា មិនដឹងថា ខ្ញុំឲ្យចំណែកបុណ្យដែលខ្ញុំធ្វើហើយនោះ សូមទេវតាទៅប្រាប់ឲ្យសត្វទាំងនោះបានដឹង អធិប្បាយថា ចូរប្រាប់ផលបុណ្យនោះដល់នរជនជាដើមនោះ ។

សត្វពួកណា ក្នុងលោកទាំងពួង ដែលអាស្រ័យអាហាររស់នៅ សត្វទាំងអស់នោះ ចូរបានអាហារដែលគាប់ចិត្តគ្រប់យ៉ាង ដោយចិត្តរបស់ខ្ញុំ គឺដោយចិត្តរបស់ខ្ញុំ អធិប្បាយថា ចូរបានដោយបុញ្ញឫទ្ធិរបស់ខ្ញុំ ។

ខ្ញុំឲ្យទានឲ្យដោយចិត្ត គឺដោយចិត្តដែលជ្រះថ្លា ខ្ញុំកាន់យក គឺញុំាងនូវសេចក្តីជ្រះថ្លាឲ្យកើតឡើងហើយ ក្នុងទាននោះដោយចិត្ត ។ ព្រះពុទ្ធគ្រប់អង្គ ព្រះបច្ចេកសម្ពុទ្ធ និងសាវករបស់ព្រះជិនស្រី ដែលតថាគតជាស្តេចចក្កពត្តិបូជាហើយ ។

ព្រោះកម្មដែលតថាគតធ្វើល្អហើយនោះ គឺដោយកុសលកម្មដែលតថាគតជឿហើយធ្វើ និងព្រោះការតាំងនូវចេតនា គឺដោយការប្រាថ្នា ដែលធ្វើដោយចិត្ត តថាគតលះ គឺលះរាងកាយមនុស្ស បានដល់ សរីរៈរបស់មនុស្ស

ហើយបានទៅកាន់តាវត្តិង្សទេវលោក អធិប្បាយថា តថាគតបានកើតឡើង ក្នុងតាវត្តិង្សទេវលោកនោះ ដូចដេកលក់ហើយ ភ្ញាក់ឡើង ដូច្នោះ ។ បន្ទាប់អំពីនោះ ស្តេចចក្កពត្តិតិលោកវិជ័យ ក៏បានសោយទិវង្គត បន្ទាប់អំពីនោះ តថាគតស្គាល់ ២ ភព គឺ ២ ជាតិដែលមកដល់ គឺជាទេវតា បានដល់អត្តភាពរបស់ទេវតា និងភាពជាមនុស្ស គឺអត្តភាពរបស់មនុស្ស ។ ក្រៅអំពី ២ ជាតិ តថាគតមិនស្គាល់ គឺមិនឃើញគតិដទៃ គឺបដិសន្ធិដទៃ ដែលជាផលនៃសេចក្តីប្រាថ្នាដោយចិត្ត គឺដោយហទយៈ អធិប្បាយថា ជាផលនៃសេចក្តីប្រាថ្នា ដែលតថាគតប្រាថ្នាហើយ ។

បទថា **ទេវានំ អធិកោ ហោមិ** សេចក្តីថា បើកើតក្នុងទេវតា តថាគតបានជាអ្នកក្រៃលែង គឺជាធំ បានដល់ ជាអ្នកប្រសើរបំផុតជាងទេវតាទាំង-ឡាយដោយអាយុ ពណ៌សម្បុរ កម្លាំង និងតេជះ បើកើតក្នុងមនុស្ស តថាគតរមែងជាធំក្នុងមនុស្ស គឺជាអធិបតី ជាធំជាងមនុស្សទាំងឡាយ ។ ម្យ៉ាងទៀត តថាគតជាព្រះរាជា សម្បុរ គឺ ដល់ព្រមដោយរូបដ៏ក្រៃលែង គឺដោយរូបសម្បត្តិ និងដោយលក្ខណៈ គឺកម្ពស់ និងទំហំ មិនមានបុគ្គលស្មើ គឺប្រាសចាកបុគ្គលដែលស្មើដោយបញ្ញា បញ្ញាជាគ្រឿងដឹងបរមត្ថ ក្នុងភពដែលកើតហើយ អធិប្បាយថា មិនមានបុគ្គលណាម្នាក់ស្មើតថាគត ។

ព្រោះផលបុណ្យដែលជាបុញ្ញសម្ភារ ដែលតថាគតធ្វើហើយ ភោជនដ៏ប្រសើរ គឺឆ្ងាញ់ គឺមានប្រការផ្សេងៗ រតនៈទាំង ៧ ជាច្រើន មានប្រមាណមិនតិច និងសំពត់បត្តុណ្ណៈ និងសំពត់កោសេយ្យជាដើម ច្រើនប្រភេទ គឺជា

អនេកប្បការ ធ្លាក់ចុះអំពីមេឃ គឺអាកាសមក គឺចូលមករកតថាគត បានដល់ មកកាន់សម្នាក់របស់តថាគតដោយរួសរាន់ ក្នុងភពដែលកើតហើយ ។

តថាគតលោ គឺចង្អុលដៃទៅកាន់ទីណា ទោះជាផែនដី លើភ្នំ លើអាកាស ក្នុងទឹក និងក្នុងព្រៃ ភិក្ខាទិព្វ គឺអាហារទិព្វរមែងចូលមក គឺចូលមករកតថាគត បានដល់ ចូលមកកាន់សម្នាក់របស់តថាគតអំពីទីនោះៗ អធិប្បាយថា ប្រាកដឡើង ។ ម្យ៉ាងទៀត រតនៈទាំងពួង គ្រឿងក្រអូប មានខ្លឹមចន្ទន៍ជាដើមគ្រប់យ៉ាង យាន គឺពាហនៈគ្រប់ប្រភេទ មាលា គឺផ្កាទាំងអស់ មានផ្កាចម្ប៉ា ផ្កាខ្ទឹង ផ្កាបុសនាគជាដើម គ្រឿងអលង្ការ គឺអាភរណៈគ្រប់ប្រភេទ ស្រីទិព្វកញ្ញាទាំងអស់ ទឹកឃ្មុំ ស្ករក្រាមគ្រប់យ៉ាង របស់ទំពា គឺរបស់គួរទំពា មាននំជាដើមគ្រប់ប្រភេទ រមែងចូលមក គឺរមែងចូលមករកតថាគត គឺមកកាន់សម្នាក់របស់តថាគតដោយលំដាប់ ។

បទថា **សម្ពោធិវរបត្តិយា** ប្រែថា ដើម្បីសម្រេចមគ្គញាណទាំង ៤ ដ៏ឧត្តម អធិប្បាយថា តថាគតបានធ្វើ គឺបំពេញឧត្តមទានណា ដោយឧត្តមទាននោះ តថាគតធ្វើភ្នំថ្មឲ្យលាន់ឮដូចគ្នាទាំងអស់ ញ៉ាំងភ្នំដែលក្រាស់ ឲ្យគ្រហឹម គឺឲ្យកើតសំឡេងខ្ទរខ្ទារ ញ៉ាំងលោក ព្រមទាំងទេវលោក បានដល់ មនុស្សលោក និងទេវលោកទាំងអស់ឲ្យត្រេកអរ គឺធ្វើឲ្យដល់សោមនស្ស នឹងបានជាព្រះពុទ្ធ ដែលមានកិលេសដូចដំបូលបើកហើយក្នុងលោក គឺក្នុងសកលលោកទាំង ៣ ។

បទថា **ទិសា ទសវិធា លោកេ** សេចក្ដីថា ក្នុងចក្កវាឡលោក មាន

ទិស ១០ គឺ ១០ ចំណែក ទីបំផុតរមែងមិនមានដល់អ្នកទៅ គឺអ្នកដើរទៅក្នុងចំណែកនោះ កាលជាស្តេចចក្កពត្តិ ក្នុងទីដែលតថាគតទៅហើយ ឬក្នុងទិសាភាគនោះ មានពុទ្ធក្ខេត្ត គឺពុទ្ធវិស័យរាប់មិនអស់ គឺរាប់មិនបាន ។

បទថា **បភា បកិត្តិតា** សេចក្តីថា ក្នុងកាលនោះ ក្នុងកាលជាស្តេចចក្កពត្តិ រស្មីរបស់តថាគត គឺពន្លឺរបស់ចក្ករតនៈ និងកែវមណីជាដើម បញ្ចេញរស្មីជាគូៗ គឺបញ្ចេញរស្មីប្រាកដចេញមក ។ ក្នុងរវាងនេះ គឺក្នុងរវាងម៉ឺនចក្កវាឡ មានបណ្តាញរស្មី គឺពួករស្មី មានពន្លឺច្រើន គឺទូលំទូលាយ ។

បទថា **ឯត្ថកេ លោកធាតុម្ហិ** សេចក្តីថា ក្នុងម៉ឺនចក្កវាឡ ជនទាំងឡាយ ចូរសម្លឹងមើល គឺឃើញតថាគត ។ ទេវតាទាំងពួង រហូតដល់ទេវលោក ចូរស្រេបតាមតថាគត គឺចូរអនុគ្រោះតថាគត ។

បទថា **វិសិដ្ឋមធុនាទេន** ប្រែថា ដោយសំឡេងដែលបន្លឺដ៏ពីរោះរណ្តំ ។ បទថា **អមតភេរិមាហនឹ** ប្រែថា តថាគតទូងអមតភេរី បានដល់ ស្គរដ៏ប្រសើរ ។ ជនទាំងពួងក្នុងរវាងនេះ គឺរវាងម៉ឺនចក្កវាឡនេះ ចូរស្តាប់ គឺចូរដាក់ចិត្តស្តាប់សំឡេងដ៏ពីរោះរបស់តថាគត កាលភ្លៀង គឺធម៌ធ្លាក់ចុះ គឺកាលភ្លៀង មានអត្ថដែលជាបរមត្ថ ជ្រាលជ្រៅ ពីរោះ សុខុម ដែលជាវោហាររបស់ព្រះធម្មទេសនានោះធ្លាក់ចុះមក ដោយការបន្លឺដែលសម្រេចហើយដោយព្រះធម្មទេសនា ភិក្ខុ និងភិក្ខុនីទាំងអស់ជាដើម ចូរជាអ្នកមិនមានអាសវៈ មិនមានកិលេស ដោយអានុភាពនៃព្រះសម្មាសម្ពុទ្ធ ។ បទថា **យេត្ថ បច្ឆិមកា សត្តា** មានអធិប្បាយថា បណ្តាសត្វ គឺបរិស័ទ ៤ ដែលជាពួកនេះ សត្វពួក

ណាបានគុណធម៌ទាបបំផុត គឺជាបុគ្គលទាបបំផុត ដោយអំណាចគុណសត្វទាំងអស់នោះ ចូរជាព្រះសោតាបន្ន ។

ក្នុងកាលនោះ គឺក្នុងកាលជាស្តេចចក្កពត្តិ តិលោកវិជ័យនោះ តថាគតបានឲ្យទានដែលគួរឲ្យ បំពេញសីលបារមី ដោយខ្វះខាត គឺដោយមិនសេសសល់ សម្រេចដល់បារមី គឺទីបំផុតក្នុងនេក្ខម្ម: គឺនេក្ខម្មបារមី គប្បីជាបុគ្គលសម្រេចសម្ពោធិញ្ញាណដ៏ឧត្តម គឺមគ្គញ្ញាណទាំង ៤ ។ តថាគតសាកសួរបណ្ឌិតទាំងឡាយ គឺអ្នកប្រាជ្ញដែលមានបញ្ញា គឺសួរថា លោកដ៏ចម្រើន អ្វីគួរធ្វើ អ្វីមិនគួរធ្វើ អ្វីជាកុសល អ្វីជាអកុសល បុគ្គលធ្វើអ្វី ទើបជាអ្នកមានចំណែក ២ យ៉ាង គឺចំណែកស្ថានសួគ៌ និងនិព្វាន អធិប្បាយថា បំពេញបញ្ញាបារមី ដោយប្រការដូច្នេះ ។ បទថា **កត្វា វីរិយមុត្តមំ** បានដល់ ធ្វើនូវសេចក្តីព្យាយាមដ៏ឧត្តម គឺប្រសើរបំផុត បានដល់ មិនដាច់ក្នុងការឈរនិងការអង្គុយជាដើម អធិប្បាយថា បំពេញវិរិយបារមី ។ តថាគតដល់នូវបារមី គឺទីបំផុតនៃអធិវាសនខន្តី ដែលបុគ្គលធ្វើខុសទូទៅមិនដាក់ចិត្ត គឺបានបំពេញខន្តិបារមីហើយ គប្បីសម្រេចពោធិញ្ញាណដ៏ឧត្តម គឺភាពជាព្រះពុទ្ធដ៏ឧត្តម ។

បទថា **កត្វា ទឡ្ហមធិដ្ឋានំ** សេចក្តីថា តថាគតធ្វើអធិដ្ឋានបារមីមាំទាំ ដោយមិនកម្រើកថា ទោះបីសរីរៈ និងជីវិតរបស់អញវិនាសទៅ អញមិនវៀរបុញ្ញកម្ម បំពេញទីបំផុតនៃសច្ចបារមីថា ទោះបីក្បាលនឹងដាច់ អញមិនពោលមុសាវាទ ដល់ទីបំផុតនៃមេត្តាបារមីដោយន័យជាដើមថា សត្វទាំងពួង

ចូរជាអ្នកមានសេចក្ដីសុខ មិនមានជំងឺតម្កាត់ ហើយសម្រេចសម្ពោធិញ្ញាណដ៏ឧត្ដម ។

តថាគតជាអ្នកស្មើ គឺមានចិត្តស្មើក្នុងអារម្មណ៍ទាំងពួង គឺក្នុងការបាននូវវត្ថុមានជីវិត និងមិនមានជីវិត ក្នុងការមិនបានវត្ថុទាំងនោះ ក្នុងសុខផ្លូវកាយនិងចិត្ត ក្នុងទុក្ខក៏ដូចគ្នា គឺដែលប្រព្រឹត្តទៅតាមកាយ និងចិត្ត ក្នុងការសរសើរនិងការមើលងាយ ដែលបុគ្គលជាប់ជំពាក់ធ្វើឡើង បំពេញឧបេក្ខាបារមីសម្រេច គឺដល់នូវសម្ពោធិញ្ញាណដ៏ឧត្ដម ។

លោកទាំងឡាយ ចូរឃើញ គឺចូរដឹងនូវការខ្ជិលច្រអូស គឺភាពជាអ្នកខ្ជិលច្រអូស ដោយភាពជាភ័យ គឺថា ជាភ័យ ថាមានចំណែកនៃអបាយទុក្ខ ចូរឃើញ គឺដឹងនូវការមិនខ្ជិលច្រអូស គឺភាពជាអ្នកមិនខ្ជិលច្រអូស ការប្រព្រឹត្តមិនធូរថយ ដែលហៅថា សេចក្ដីព្យាយាមដោយភាពជាធម៌ក្សេម គឺដោយអំណាចសេចក្ដីក្សេមថា ធ្វើឲ្យទៅកាន់និព្វាន ហើយចូរជាអ្នកប្រារព្ធព្យាយាម នេះជាអនុសាសនីរបស់ព្រះពុទ្ធ គឺនេះជាការប្រៀនប្រដៅរបស់ព្រះពុទ្ធទាំងឡាយ ។

បទថា **វិវាទំ ភយតោ ទិស្វា** សេចក្ដីថា អ្នកទាំងឡាយ ចូរឃើញនូវវិវាទ គឺការឈ្លោះថា ជាភ័យ ឃើញ គឺដឹងថា វិវាទ មានចំណែកឲ្យទៅអបាយ និងឃើញ គឺដឹងនូវការមិនវិវាទ គឺការវៀរចាកវិវាទ ថាជាហេតុឲ្យសម្រេចព្រះនិព្វាន ហើយចូរជាអ្នកព្រមព្រៀងស្រុះស្រួលនឹងគ្នាចុះ គឺមានចិត្តនឹងន៍ ពោលវាចាផ្អែមល្ហែម គឺពីរោះ ល្អដោយមេត្តា សមនឹងធុរកិច្ច ។

កថា គឺការចរចា បានដល់ ការពោលនេះ ជាអនុសាសនី គឺជាការឲ្យឱវាទរបស់ព្រះពុទ្ធទាំងឡាយ ។

អ្នកទាំងឡាយ ចូរឃើញ គឺចូរដឹងនូវអប្បមាទ គឺការនៅដោយប្រាសចាកសតិ ក្នុងការឈរ និងការអង្គុយជាដើម ដោយភាពជាភ័យថា ជាហេតុឲ្យប្រព្រឹត្តទៅដើម្បីសេចក្តីទុក្ខ ភាពជាអ្នកមានរូបអាក្រក់ និងភាពជាអ្នកមានបាយទឹកតិចជាដើម និងជាហេតុឲ្យទៅកាន់អបាយជាដើម ក្នុងទីដែលកើតហើយ ចូរឃើញ គឺចូរដឹងយ៉ាងជាក់ច្បាស់ដល់អប្បមាទ គឺការនៅដោយសតិក្នុងឥរិយាបថទាំងពួង ថាជាគុណដ៏ក្សេម គឺដោយសេចក្តីចម្រើនថា ជាហេតុសម្រេចព្រះនិព្វាន ហើយចូរអប់រំ គឺចូរចម្រើន ចូរដាក់ចិត្តដល់មគ្គមានអង្គ ៨ គឺមគ្គ បានដល់ ឧបាយជាគ្រឿងសម្រេចសម្មាសម្ពោធិញ្ញាណ ដែលមានអង្គប្រកប ៨ យ៉ាង គឺសម្មាទិដ្ឋិ សម្មាសង្កប្ប សម្មាវាចា សម្មាកម្មន្តៈ សម្មាអាជីវៈ សម្មាវាយាមៈ សម្មាសតិ សម្មាសមាធិ ។ កថា គឺការពោល បានដល់ ការចរចា ការបន្ទឺវាចា នេះជាអនុសាសនីរបស់ព្រះពុទ្ធ គឺជាការប្រៀនប្រដៅរបស់ព្រះពុទ្ធទាំងឡាយ ។

បទថា **សមាគតា ពហូ ពុទ្ធា** សេចក្តីថា ព្រះបច្ចេកពុទ្ធទាំងឡាយរាប់បានច្រើនសែន បានមកជួបជុំដោយសព្វគ្រប់ហើយ គឺប្រជុំគ្នាហើយ និងអរហន្តខីណាស្រពទាំងឡាយ បានមកជួបជុំដោយសព្វគ្រប់ហើយ គឺជាអ្នកប្រជុំគ្នាហើយ ដោយប្រការទាំងពួង បានដល់ គ្រប់ប្រការ ព្រោះហេតុនោះអ្នកទាំងឡាយ ចូរនមស្ការ គឺចូរថ្វាយបង្គំ ដោយការឱនលំទោន ដោយ

អវយវៈតូចធំ ដែលព្រះពុទ្ធនិងព្រះអរហន្តទាំងឡាយនោះ គួរដល់ការក្រាបថ្វាយបង្គំ ។

ដោយប្រការដូច្នេះ គឺដោយប្រការដូចខ្ញុំពោលមកហើយនេះ ព្រះពុទ្ធទាំងឡាយ ជាអចិន្តេយ្យ គឺបុគ្គលណាម្នាក់មិនអាចនឹងគិត ។ ធម៌ទាំងឡាយ គឺសតិប្បដ្ឋាន ៤ ។បេ។ មគ្គមានអង្គ ៨ ខន្ធ ៥ ហេតុប្បច្ច័យ អារម្មណប្បច្ច័យជាដើម ឈ្មោះថា ធម៌របស់ព្រះពុទ្ធ ។ មួយវិញទៀត សភាវៈនៃព្រះពុទ្ធទាំងឡាយជាអចិន្តេយ្យ គឺបុគ្គលណាម្នាក់មិនអាចដើម្បីនឹងគិត វិបាកពោល គឺទេវសម្បត្តិ មនុស្សសម្បត្តិ និងនិព្វានសម្បត្តិរបស់ទេវតា និងមនុស្សទាំងឡាយ ដែលជ្រះថ្លាក្នុងវត្ថុដែលជាអចិន្តេយ្យ គឺក្នុងវត្ថុដែលផុតចាកវិស័យនៃការគិត បុគ្គលណាម្នាក់មិនអាចគិត គឺកន្លងផុតចាកការរាប់ ។

ដោយលំដាប់ពាក្យមានប្រមាណប៉ុណ្ណេះ ជាការបញ្ចប់ពុទ្ធាបទានដោយអបទាន ដែលជាចំណែកកុសលហើយ ឧបមាដូចអ្នកដើរ ពោលថា ជួយប្រាប់ផ្លូវឲ្យខ្ញុំបន្តិច កាលមនុស្សត្រូវសួរប្រាប់ថា ចូរលះផ្លូវខាងឆ្វេង កាន់យកផ្លូវខាងស្តាំ ដូច្នេះហើយ ក៏ធ្វើកិច្ចដែលគួរធ្វើក្នុងគាមនិគម និងរាជធានីឲ្យសម្រេចដោយផ្លូវនោះ ទោះបីទៅផ្លូវថ្មីទៀត គឺទៅផ្លូវខាងឆ្វេងដែលគេលះ ក៏ធ្វើកិច្ចដែលគួរធ្វើ ក្នុងគាមនិគមជាដើម ឲ្យសម្រេចបានដូចគ្នា ដើម្បីឲ្យពុទ្ធាបទាននោះពិស្តារ ដោយអំណាចអបទានដែលជាអកុសលខ្លះ ទើបតាំងបញ្ហាដូច្នេះថា

ការធ្វើទុក្ករកិរិយា ១ ការពោលទោស ១ ការជេរ ១ ការចោទ

ប្រកាន់ ១ ការប្រមៀលថ្ម ១ ការសោយវេទនាអំពីអំបែងថ្ម ១ ។

ដំរីនាឡាគិរី ១ ការវះដោយសស្ត្រា ១ ការឈឺសីសៈ ១ ការបរិភោគអង្ករសំរូប ១ ការឈឺព្រះបិដ្ឋិ គឺខ្នង ១ ការចុះព្រះលោហិត ១ ទាំងនេះ មានអកុសលជាហេតុ ។

បណ្ដាមាតិកាទាំងនោះ មាតិកាទី ១ គប្បីជ្រាបការមកនៃរឿងដូចតទៅ ការធ្វើទុក្ករកិរិយាអស់ ៦ ឆ្នាំ ឈ្មោះថា ការធ្វើទុក្ករកិរិយា ក្នុងអតីតកាល ក្នុងសម័យនៃព្រះកស្សបសម្មាសម្ពុទ្ធ ព្រះពោធិសត្វកើតជាព្រាហ្មណមាណព ឈ្មោះជោតិបាល ព្រោះជាជាតិព្រាហ្មណ៍ ទើបមិនជ្រះថ្លាក្នុងសាសនា ព្រោះវិបាកកម្មចាស់នៃព្រះមានព្រះភាគអង្គនោះ ជោតិបាលបានឮថា ព្រះកស្សបៈមានព្រះភាគ ក៏បានពោលថា សមណៈត្រងោល នឹងមានការត្រាស់បានដូចម្ដេច ការត្រាស់ដឹងជារបស់បានដោយកម្រក្រៃលែង ព្រោះវិបាកនៃកម្មនោះ ព្រះពោធិសត្វក៏បានសោយទុក្ខ មាននរកជាដើមច្រើនរយជាតិ បន្ទាប់អំពីព្រះមានព្រះភាគអង្គនោះឯង ព្រះពោធិសត្វ ត្រូវប្រើកម្មដែលខ្លួនបានទទួលព្យាករនោះឯង អស់កាលដែលអន្ទោលទៅក្នុងសង្សារ ក្នុងគ្រាចុងក្រោយបានអត្តភាពជាព្រះវេស្សន្តរ ចុតិចាកអត្តភាពនោះហើយ កើតក្នុងស្ថានតុសិត ។

ចុតិចាកស្ថានតុសិតនោះ ដោយការអារាធនារបស់ពួកទេវតា កើតក្នុងសក្យត្រកូល ព្រោះញាណចាស់ក្លា ទើបលះបង់រាជសម្បត្តិ ក្នុងសកល-

ជម្ពូទ្វីប ហើយកាត់ព្រះកេសាឲ្យមានចុងស្មើគ្នាដោយដាវដែលសំលៀងល្អ ត្រង់ច្នៃរស្មីងអនោមានទី ទទួលបរិក្ខារ ៨ ដែលសម្រេចដោយឫទ្ធិ ដែលកើតក្នុងគុម្ពឈូក ក្នុងកាលដែលកប្បផ្ដើមកើតឡើង ដែលព្រហ្មនាំមកឲ្យ ហើយបព្វជ្ជា ជំបូងព្រោះញាណទស្សនៈ គឺព្រះពោធិញ្ញាណមិនទាន់ចាស់ក្លា ទើបមិនដឹងផ្លូវ និងមិនមែនផ្លូវដែលនាំឲ្យបានជាព្រះពុទ្ធ ជាអ្នកមានសរីរៈដូចគ្នានឹងប្រេត ប្រាសចាកសាច់ និងឈាម សល់តែឆ្អឹង ស្បែក និងសរសៃ ព្រោះបរិភោគអាហារត្រឹមតែមួយពេលមួយពំនូត នៅតែឯង ទៅតែឯង អង្គុយតែឯង បំពេញមហាបធាន គឺសេចក្ដីព្យាយាមធំ ជាវត្ថុដែលធ្វើបានដោយក្រ ត្រង់ឧរុវេលាជនបទ អស់កាល ៦ ឆ្នាំ ដោយន័យដែលពោលហើយ ក្នុងបធានសូត្រនោះឯង ។ ព្រះពោធិសត្វនោះ ពិចារណាដល់ទុក្ករកិរិយានេះថា មិនជាផ្លូវនៃការត្រាស់ដឹង ទើបបែរមកសោយអាហារប្រណីតអំពីគាមនិគម និងរាជធានី មានឥន្ទ្រិយផូរផង់ មានមហាបុរិសលក្ខណៈ ៣២ គ្រប់បរិបូណ៌ យាងចូលកាន់ពោធិមណ្ឌលដោយលំដាប់ ឈ្នះមារទាំង ៥ បានជាព្រះពុទ្ធ ។

ក្នុងភពមួយនោះ តថាគតកើតជាជោតិបាល បានផ្ដួញផ្ដាល់
ព្រះសុគត ព្រះនាមកស្សបៈថា ព្រោះអ្វី ក៏ថា ត្រាស់ដឹង
ពោធិញ្ញាណជាទីផូរផង់ គេរកបានដោយកម្រក្រៃលែង ។
ដោយវិបាកនៃកម្មនោះ តថាគតប្រព្រឹត្ត ទុក្ករកិរិយាជាច្រើន
ក្នុងឧរុវេលប្រទេស អស់ ៦ វស្សា ទើបបានត្រាស់ដឹងឡើង ។
តថាគត មិនបាននូវពោធិញ្ញាណដ៏ឧត្ដម ដោយផ្លូវនុ៎ះទេ

តថាគត ហេតុតែបុព្វកម្មនោះជាស់តឿន ក៏ស្វែងរកតាមផ្លូវខុស ។

តថាគតមានបុណ្យ និងបាបអស់រលីងហើយ បានវៀរបង់នូវកម្តៅទាំងពួង មិនមានសេចក្តីសោក មិនមានសេចក្តីចង្អៀតចង្អល់ មិនមានអាសវៈ នឹងបរិនិព្វាន ដូច្នេះ ។

គប្បីជ្រាបការមកដូចតទៅនេះថា

ការពោលទោសក្រៃលែង គឺការជេរ ឈ្មោះថា ការពោលទោស ។

បានឮថា ក្នុងអតីតកាល ព្រះពោធិសត្វកើតក្នុងត្រកូលសូទ្រៈ ជាអ្នកមិនមានកេរ្តិ៍ឈ្មោះ មិនមានជំនាញណាមួយ ជាអ្នកលេង ឈ្មោះ មុនាឡិ ។ កាលនោះ ព្រះបច្ចេកពុទ្ធព្រះនាមសុរភិ មានឫទ្ធិច្រើន មានអានុភាពច្រើន ទៅជិតលំនៅរបស់អ្នកលេងនោះ ដោយកិច្ចឯណានីមួយ ។ ព្រះពោធិសត្វឃើញព្រះបច្ចេកពុទ្ធនោះ បានជេរដោយពាក្យជាដើមថា សមណៈនេះទ្រុស្តសីល មានធម៌ដ៏លាមក ។ ព្រោះវិបាករបស់អកុសលនោះ ព្រះពោធិសត្វក៏បានសោយទុក្ខក្នុងនរកជាដើមច្រើនពាន់ឆ្នាំ ។ ក្នុងអត្តភាពចុងក្រោយនេះ មុនមានព្រះមានព្រះភាគ ព្រះពោធិសត្វគង់នៅក្នុងស្ថានតុសិត ពួកតិរ្ថិយមានឈ្មោះបោះសំឡេងត្រាច់សម្តែងទិដ្ឋិ ៦២ បោកបញ្ឆោតមហាជន ព្រះពោធិសត្វបានចុតិអំពីតុសិតបុរី កើតក្នុងសក្យត្រកូល ហើយបានត្រាស់ជាព្រះពុទ្ធដោយលំដាប់ ។ ពួកតិរ្ថិយសាបសូន្យលាភសក្ការៈ ដូចអំពិលអំពែកក្នុងពេលដែលព្រះអាទិត្យរះឡើង ទើបចងអាឃាតក្នុងព្រះមានព្រះភាគរឿយៗមក ។

សម័យនោះ សេដ្ឋីក្នុងក្រុងរាជគ្រឹះចងសំណាញ់ក្នុងស្ទឹងគង្គា ហើយលេងទឹក ឃើញពកខ្លឹមចន្ទន៍ក្រហម គិតថា ក្នុងផ្ទះរបស់យើងមានខ្លឹមចន្ទន៍សន្ធឹកសន្ធាប់ នឹងឲ្យជាងក្រឡឹង កំណត់ឈើចន្ទក្រហមនេះធ្វើជាបាត្រ ហើយចងព្យួរត្រង់ឫស្សីដែលតគ្នា ឲ្យវាយស្គរប្រកាសថា បុគ្គលណាអាចកាន់យកបាត្រនេះបានដោយឫទ្ធិ ខ្ញុំនឹងស្រឡាញ់រាប់អានចំពោះបុគ្គលនោះ ។

ក្នុងកាលនោះ ពួកតិរ្ថិយប្រឹក្សាគ្នាថា ឥឡូវនេះ ពួកយើងវិនាសហើយ ឥឡូវនេះ ពួកយើងវិនាសហើយ និគ្គណ្ឋនាដបុត្រពោលនឹងបរិស័ទរបស់ខ្លួនយ៉ាងនេះថា អញនឹងទៅក្បែរដើមឫស្សី ធ្វើអាការនឹងហោះឡើងក្នុងអាកាស ចូរពួកឯងចាប់អញ ហើយឃាត់ថា លោកម្ចាស់កុំធ្វើឫទ្ធិ ព្រោះអាស្រ័យបាត្រ ដែលធ្វើដោយឈើដុតខ្មោចឡើយ តិរ្ថិយទាំងនោះ នាំគ្នាទៅយ៉ាងនោះហើយ បានធ្វើដូច្នោះ ។

គ្រានោះ ព្រះបិណ្ឌោលភារទ្វាជៈ និងព្រះមោគ្គល្លានឈរលើកំពូលភ្នំថ្មប្រមាណ ៣ គាវុត កំពុងដណ្តប់ចីវរដើម្បីទៅទទួលបិណ្ឌបាត បានឮសំឡេងកោលាហលនោះ ។ បណ្តាព្រះថេរៈ ២ អង្គនោះ ព្រះមហាមោគ្គល្លាន បានពោលនឹងព្រះបិណ្ឌោលភារទ្វាជៈថា សូមលោកម្ចាស់ហោះទៅយកបាត្រនោះ ព្រះបិណ្ឌោលភារទ្វាជៈនោះពោលថា អាវុសោ លោកប៉ុណ្ណោះ ដែលព្រះមានព្រះភាគទ្រង់ស្ថាបនា ក្នុងតំណែងកំពូលខាងអ្នកមានឫទ្ធិទាំងឡាយ សូមលោកនោះឯង ទៅកាន់យកបាត្រមក ។ កាលបើដូច្នោះ លោកត្រូវព្រះមោគ្គល្លានប្រាប់ថា ខ្ញុំឲ្យលោកនោះឯង ទៅកាន់យកមក ទើបធ្វើភ្នំថ្មីប្រមាណ

៣ គាវុត ដែលខ្លួនជាន់ឲ្យជាប់ត្រង់បាតជើង ហើយហោះទៅ បាំងនគររាជគ្រឹះទាំងអស់ ដូចយកគម្របផ្ទាំង បិទផ្ទាំងបាយ ដូច្នោះ ។ កាលនោះ អ្នកនគរឃើញព្រះថេរៈ ដូចអំបោះក្រហមដែលដោតក្នុងក្អំកែវផលិក នាំគ្នាបន្លឺកថា ព្រះភារទ្វាជៈដ៏ចម្រើន សូមលោកម្ចាស់ថែរក្សាពួកខ្ញុំផង បានចង្អុរជាដើមបាំងលើក្បាល ។ ពេលនោះ ព្រះថេរៈលែងក្អំនោះឲ្យធ្លាក់ត្រង់ទីដើមហើយទៅដោយឫទ្ធិ កាន់យកបាត្រនោះមក ។ កាលនោះ អ្នកនគរក៏បានធ្វើនូវកោលាហលខ្លាំងឡើង ។

ព្រះមានព្រះភាគ ទ្រង់គង់នៅក្នុងវេឡុវនារាម ទ្រង់បានស្តាប់សំឡេងនោះ ទើបត្រាស់សួរព្រះអានន្ទថា ម្នាលអានន្ទ នុ៎ះសំឡេងអ្វី ព្រះអានន្ទទូលថា បពិត្រព្រះអង្គដ៏ចម្រើន ព្រះភារទ្វាជៈកាន់យកបាត្រមកបាន ទើបអ្នកនគរត្រេកអរ បានធ្វើសំឡេងហ៊ោកញ្ជ្រៀវ ។ កាលនោះ ព្រះមានព្រះភាគដើម្បីនឹងការពារ កុំឲ្យអ្នកដទៃតិះដៀលតទៅ ទើបទ្រង់ឲ្យនាំបាត្រនោះមក ឲ្យវាយហើយឲ្យធ្វើជាដន្ទាប់ល្អិត ដាក់ថ្នាំបន្តក់ភ្នែក ហើយទ្រង់ឲ្យចែកដល់ភិក្ខុទាំងឡាយ កាលទ្រង់ឲ្យចែកហើយ ទើបទ្រង់បញ្ញត្តសិក្ខាបទថា ម្នាលភិក្ខុទាំងឡាយ ភិក្ខុមិនគួរធ្វើនូវការសម្តែងឫទ្ធិ ភិក្ខុណាធ្វើ ភិក្ខុនោះត្រូវអាបត្តិទុក្កដ ។

លំដាប់នោះ តិរ្ថិយទាំងឡាយពោលថា បានឮថា ព្រះគោតមបញ្ញត្តសិក្ខាបទដល់សាវ័កទាំងឡាយ សាវ័កទាំងនោះ មិនហ៊ានកន្លងល្មើសសិក្ខាបទដែលបញ្ញត្តនោះ ព្រោះហេតុនៃជីវិត ពួកយើងនឹងធ្វើឥទ្ធិប្បាដិហារ្យ ទើបនាំគ្នាជាពួក ធ្វើនូវប្រកាសទៅតាមទីផ្សេងៗ ។ ក្នុងកាលនោះ ព្រះបាទពិម្ពិសារ

បានស្តាប់ដូច្នោះ ទើបយាងទៅគាល់ព្រះមានព្រះភាគ ទ្រង់ថ្វាយបង្គំហើយ ប្រថាប់គង់ក្នុងទីសមគួរ នាចំណែកម្ខាង ក្រាបទូលព្រះមានព្រះភាគយ៉ាងនេះថា បពិត្រព្រះអង្គដ៏ចម្រើន ពួកតិរ្ថិយប្រកាសថា នឹងធ្វើឥទ្ធិប្បាដិហារ្យ ។

ព្រះមានព្រះភាគត្រាស់ថា មហាបពិត្រ តថាគតនឹងធ្វើដែរ ព្រះរាជាត្រាស់សួរថា ទ្រង់បញ្ញត្តសិក្ខាបទដល់សាវកទាំងឡាយហើយ មិនមែនឬ ព្រះមានព្រះភាគត្រាស់ថា មហាបពិត្រ តថាគតសូមសួរព្រះអង្គខ្លះ ទ្រង់កំណត់ទោសដល់បុគ្គលដែលស៊ីផ្លែស្វាយជាដើម ក្នុងឧទ្យានរបស់ព្រះអង្គថា មានទោសប៉ុណ្ណេះ រួមយកទាំងព្រះអង្គផងដែរឬ ។ ព្រះរាជាក្រាបទូលថា មិនមានទោសសម្រាប់ខ្ញុំព្រះអង្គទេ ព្រះមានព្រះភាគត្រាស់ថា យ៉ាងនោះឯង មហាបពិត្រ សិក្ខាដែលតថាគតបញ្ញត្ត ក៏មិនធ្លាក់ដល់តថាគតទេ ។

ព្រះរាជាត្រាស់សួរថា បពិត្រព្រះអង្គដ៏ចម្រើន បាដិហារ្យនឹងមានក្នុងទីណា ព្រះមានព្រះភាគត្រាស់ថា ត្រង់គល់គណ្ឌម្ពព្រឹក្ស ជិតនគរសាវត្ថី ព្រះរាជាត្រាស់ថា សាធុ ព្រះអង្គ ខ្ញុំព្រះអង្គទាំងឡាយនឹងរង់ចាំមើលបាដិហារ្យនោះ ។

លំដាប់នោះ ពួកតិរ្ថិយបានស្តាប់ថា បានឮថា បាដិហារ្យនឹងមានត្រង់គល់គណ្ឌម្ពព្រឹក្ស ទើបឲ្យកាប់ដើមស្វាយទាំងអស់ជុំវិញព្រះនគរ ។ ពួកអ្នកនគរទាំងឡាយ នាំគ្នាចងគ្រែត្រួតលើគ្រែ និងធ្វើរោងជាដើម ក្នុងទីដែលជាលានធំ អ្នកជម្ពូទ្វីបចែកគ្នាជាក្រុមៗ ក្នុងទិសខាងកើត ចម្ងាយទៅដល់ ១២ យោជន៍ ក្នុងទិសដ៏សេស ក៏ប្រជុំគ្នាដោយអាការដែលសមគួរនឹងទីនោះ ។

ឯព្រះមានព្រះភាគ លុះដល់ពេលហើយ គឺក្នុងថ្ងៃ ១៥ កើត ខែអាសាឍ ទ្រង់ធ្វើកិច្ចដែលគួរធ្វើស្រេចបាច់អំពីព្រលឹម ហើយយាងទៅកាន់ទីនោះ គង់ប្រថាប់ ។ ខណៈនោះ អ្នកយាមឧទ្យាន ឈ្មោះគណ្ឌៈ ឃើញផ្លែស្វាយទុំល្អក្នុងសម្បុកអង្រ្កង ទើបគិតថា បើអញថ្វាយផ្លែស្វាយនេះដល់ព្រះរាជា ក៏នឹងបានទ្រព្យដែលជាសារៈ មានកហាបណៈជាដើម តែបើបង្អោនដល់ព្រះមានព្រះភាគ សម្បត្តិក្នុងលោកនេះ និងលោកខាងមុខ ក៏នឹងកើតមាន លុះគិតដូច្នេះហើយ ទើបបង្អោនថ្វាយដល់ព្រះមានព្រះភាគ ។ ព្រះមានព្រះភាគទ្រង់ទទួលស្វាយនោះហើយ ត្រាស់នឹងព្រះអានន្ទត្ថេរថា ម្នាលអានន្ទ ចូរអ្នកប្របាច់ស្វាយនេះ ធ្វើជាទឹកបានៈ ។ ព្រះថេរៈបានធ្វើតាមព្រះតម្រាស់ហើយ ។ ព្រះមានព្រះភាគទ្រង់សោយទឹកស្វាយហើយ ប្រទានគ្រាប់ដល់ឧទ្យានបាលត្រាស់ថា ចូរដាំស្វាយនេះ ។ នាយឧទ្យានបាលនោះ កាយខ្សាច់ហើយដាំស្វាយនោះ ព្រះអានន្ទត្ថេរយកកុណ្ឌីទឹកស្រោច ។ ខណៈនោះ ពន្លកស្វាយក៏ដុះឡើង ។ កាលមហាជនកំពុងឃើញនោះឯង ប្រាកដពេញទៅដោយមែកប្រគាប ផ្កា ផ្លែ និងស្លឹកខ្ចី ។ ផ្លែស្វាយដែលជ្រុះមក អ្នកជម្ពូទ្វីបទាំងមូលមិនអាចបរិភោគអស់បាន ។

លំដាប់នោះ ព្រះមានព្រះភាគទ្រង់និម្មិតរតនចង្រ្កម បណ្តោយអំពីចក្កវាឡ ទិសខាងកើតទៅទល់គ្នានឹងចក្កវាឡទិសខាងលិច នៅលើកំពូលភ្នំព្រះសុមេរុ ក្នុងចក្កវាឡនេះ កាលទ្រង់បន្លឺសីហនាទ កណ្តាលបរិស័ទមិនមែនតិច ទើបទ្រង់ធ្វើមហាឥទ្ធិប្បាដិហារ្យ ដោយន័យដូចពោលហើយ ក្នុង

អដ្ឋកថាធម្មបទ ទ្រង់ញាំញីពួកតិរ្ថិយ ធ្វើឲ្យពួកគេដល់នូវវិបរិតផ្សេងៗ ក្នុងពេលស្រេចបាដិហារ្យហើយ បានយាងទៅកាន់ស្ថានតាវត្តិង្ស តាមលំនាំដែលព្រះពុទ្ធក្នុងកាលមុនប្រព្រឹត្តមក ទ្រង់ចាំវស្សាក្នុងស្ថានតាវត្តិង្សនោះ ទ្រង់សម្តែងអភិធម្មជាប់តគ្នាអស់ ៣ ខែ ទ្រង់ធ្វើទេវតាមិនមែនតិច មានព្រះមាតាជាប្រធាន ឲ្យសម្រេចសោតាបត្តិមគ្គ ចេញវស្សាហើយ ទ្រង់ចុះអំពីទេវលោកដែលពួកទេវតា និងព្រហ្ម មិនមែនតិចចោមរោម យាងចុះត្រង់ទ្វារសង្កស្សនគរ ទ្រង់ធ្វើការអនុគ្រោះសត្វលោក ។ កាលនោះ ព្រះមានព្រះភាគ មានលាភសក្ការៈហូរជោរជន់ទូទៅទាំងជម្ពូទ្វីប ដូចស្ទឹងធំ ៥ ខ្សែ ដូច្នោះ ។

កាលនោះ ពួកតិរ្ថិយវិនាសចាកលាភសក្ការៈ កើតទុក្ខទោមនស្សអង្គុយមានកសំយុង មានមុខឱនចុះ ។ ក្នុងកាលនោះ ឧបាសិការបស់ពួកតិរ្ថិយទាំងនោះ ឈ្មោះចិញ្ចមាណវិកា ដល់នូវភាពជាអ្នកល្អលើស ដោយរូបឆោម ឃើញពួកតិរ្ថិយទាំងនោះអង្គុយយ៉ាងនោះ ទើបសួរថា បពិត្រលោកម្ចាស់ ព្រោះហេតុអ្វី ទើបលោកទាំងឡាយអង្គុយជាទុក្ខទោមនស្សយ៉ាងនេះ ពួកតិរ្ថិយពោលថា ម្នាលប្អូនស្រី ព្រោះហេតុអ្វី ទើបនាងមានសេចក្តីខ្វល់ខ្វាយតិច ។ នាងចិញ្ចមាណវិកាសួរថា មានហេតុអ្វី តិរ្ថិយពោលថា ម្នាលប្អូនស្រី តាំងពីព្រះសមណគោតមកើតឡើងមក ពួកយើងវិនាសចាកលាភសក្ការៈអស់ អ្នកនគរមិនសម្គាល់ពួកយើងឡើយ ។ នាងចិញ្ចមាណវិកាសួរថា ក្នុងរឿងនេះ ខ្ញុំគួរធ្វើដូចម្តេច តិរ្ថិយឆ្លើយថា នាងគួរធ្វើពាក្យនិន្ទាឲ្យកើតឡើងដល់ព្រះសមណគោតម ។ នាងចិញ្ចមាណវិកានោះ

ពោលថា សេចក្ដីនោះ មិនជាការទើសទាល់សម្រាប់ខ្ញុំឡើយ កាលធ្វើឧស្សាហ៍ក្នុងការណ៍នោះ ទើបទៅកាន់វត្តជេតពនវិហារ ក្នុងវេលាវិកាល ហើយនៅក្នុងសម្នាក់របស់ពួកតិរ្ថិយ ព្រឹកឡើង ក្នុងពេលដែលអ្នកនគរកាន់គ្រឿងក្រអូបជាដើម ដើម្បីទៅថ្វាយបង្គំព្រះមានព្រះភាគ ទើបចេញមក ធ្វើដូចចេញអំពីវត្តជេតពនវិហារ កាលត្រូវសួរថា នាងដេកឯណា ក៏ឆ្លើយថា ប្រយោជន៍អ្វី ដោយទីដេកដល់ពួកលោក ដូច្នេះហើយ ចៀសចេញទៅ ។ ពេលវេលាកន្លងទៅដោយលំដាប់ នាងត្រូវសួរហើយ ទើបឆ្លើយថា ខ្ញុំដេកក្នុងព្រះគន្ធកុដិជាមួយព្រះគោតម ហើយចេញមក ពួកបុថុជ្ជនល្ងង់ខ្លៅក៏ជឿតាមនោះ បណ្ឌិតទាំងឡាយ មានព្រះសោតាបន្នជាដើមមិនជឿឡើយ ។ ថ្ងៃមួយ នាងចងកំណាត់ឈើមូលត្រង់ពោះ ស្លៀកសំពត់ក្រហមពីលើ ហើយទៅពោលនឹងព្រះមានព្រះភាគ ដែលគង់សម្ដែងធម៌ដល់បរិស័ទ ព្រមទាំងព្រះរាជាយ៉ាងនេះថា ព្រះសមណៈដ៏ចម្រើន លោករវល់តែសម្ដែងធម៌ មិនស្វែងរកខ្ទឹមនិងម្រេចជាដើមឲ្យខ្ញុំ ទារកដែលកើតក្នុងគភ៌អាស្រ័យព្រះអង្គ ។ ព្រះមានព្រះភាគត្រាស់ថា ម្នាលប្អូនស្រី នាង និងតថាគតប៉ុណ្ណោះ ដឹងថា ការពិតដូចម្ដេច ។ នាងចិញ្ចមាណវិកាពោលថា យ៉ាងនោះឯង ក្នុងកាលប្រឡូកប្រឡំដោយមេថុន ក៏ដឹងត្រឹមតែ ២ នាក់ អ្នកដទៃមិនដឹងទេ ។

ខណៈនោះ បណ្ឌុកម្ពលសិលាអាសនៈរបស់សក្កៈសម្ដែងអាការក្ដៅ ។ សក្កៈទ្រង់ពិចារណា ទ្រង់ដឹងហេតុនោះ ទើបត្រាស់បញ្ជាទេវបុត្រ ២ អង្គថា បណ្ដាអ្នកទាំង ២ មួយអង្គ ចូរនិម្មិតជាសត្វកណ្ដុរ កាត់ចំណងដុំឈើមូល

របស់នាងឲ្យជាប់ មួយអន្ល ចូរបណ្ដាលមណ្ឌលខ្យល់ឲ្យតាំងឡើង បក់សំពត់ដណ្ដប់ឲ្យប៉ោងឡើងខាងលើ ។ ទេវបុត្រ ២ អង្គបានទៅធ្វើតាមនោះហើយ ។ កំណាត់ឈើមូលធ្លាក់ចុះមក ប៉ះខ្នងជើងរបស់នាងបែក ។ បុថុជ្ជនទាំងឡាយដែលប្រជុំគ្នាក្នុងធម្មសភាទាំងអស់ នាំគ្នាពោលថា វ៉ឺយហង់ ចោរកាច ហង់ធ្វើការមួលបង្កាច់បែបនេះ ដល់បុគ្គលដែលជាលោកនាយកក្នុងភព ៣ បែបនេះ ហើយក្រោកឡើង យកកណ្ដាប់ដៃប្រហារម្នាក់មួយដៃ ម្នាក់ពីរដៃ ដេញចេញអំពីទីប្រជុំ កាលនាងផុតទស្សនៈ គឺការឃើញរបស់ព្រះមានព្រះភាគ ផែនដីបានបើកឱកាស ។ ខណៈនោះ អណ្ដាតភ្លើងចេញអំពីអវិចីនរកតាំងឡើង ស្រោបនាង ដូចដណ្ដប់ដោយសំពត់កម្ពលក្រហម ដែលត្រកូលឲ្យ ហើយទាញទៅក្នុងអវិចីនរក ។ ព្រះមានព្រះភាគ ទ្រង់មានលាភសក្ការៈដ៏លើសលប់ ដោយហេតុនោះ សមដូចព្រះមានព្រះភាគត្រាស់ថា

មួយទៀត តថាគតពោលបង្កាច់សាវក ឈ្មោះនន្ទ[1] របស់ព្រះពុទ្ធ ទ្រង់គ្របសង្កត់នូវសត្វលោកទាំងពួង តថាគតបានអន្ទោលទៅក្នុងនរក អស់កាលដ៏យូរ ព្រោះការពោលបង្កាច់នូវសាវកនោះ ។

តថាគតបាន អន្ទោលទៅក្នុងនរក អស់កាលដ៏យូរ ចំនួនមួយម៉ឺនឆ្នាំ លុះតថាគតបានមកជាមនុស្ស ក៏បាននូវការពោល

---

១- សេចក្ដីខាងដើមថា បានជេរព្រះបច្ចេកពុទ្ធ ព្រះនាមសុរភិ សេចក្ដីនេះ បណ្ឌិតគប្បីពិចារណា ។

បន្ទាប់ជាច្រើន ។

ដោយសំណល់នៃកម្មនោះ នាងចិញ្ចមានវិកាមក ពោលបង្កាច់

តថាគត ក្នុងប្រជុំជន ដោយពាក្យមិនពិត ។

ក្នុងរឿងទី ៣ គប្បីជ្រាបកាលមកដូចតទៅនេះថា

ការពោលក្រៃលែង គឺការជេរ ឈ្មោះថា ការជេរ ។ បានឮថា ក្នុងអតីតកាលព្រះពោធិសត្វកើតជាមនុស្សមិនមានកេរ្តិ៍ឈ្មោះ ជាអ្នកលេង ឈ្មោះមុនាឡិ ព្រោះប្រឡូកប្រឡំជាមួយបុគ្គលពាល ទើបជេរព្រះបច្ចេកពុទ្ធ ព្រះនាមសុរភិថា ភិក្ខុនេះទ្រុស្តសីល មានធម៌ដ៏លាមក ព្រោះវចីកម្មដែលជាអកុសលនោះ ព្រះពោធិសត្វនោះឆេះក្នុងនរកច្រើនពាន់ឆ្នាំ ក្នុងអត្តភាពចុងក្រោយនេះបានជាព្រះពុទ្ធដោយកម្លាំងនៃបារមី ១០ ដល់នូវភាពជាអ្នកប្រសើរដោយលាភនិងយស ។ ពួកតិរ្ថិយកើតឧស្សាហ៍ឡើងម្តងទៀត គិតគ្នាថា ពួកយើងនឹងញ៉ាំងទោសដែលមិនមែនជាយស ឲ្យកើតដល់ព្រះសមណគោតម បានដូចម្តេចហ្ន៎ នាំគ្នាអង្គុយជាទុក្ខទោមនស្ស ។

កាលនោះ បរិព្វាជិកាម្នាក់ឈ្មោះសុន្ទរី ចូលទៅរកតិរ្ថិយទាំងនោះថ្វាយបង្គំ ហើយឈរ ឃើញតិរ្ថិយនៅស្ងៀម មិននិយាយអ្វី ទើបសួរថា ខ្ញុំមានកំហុសអ្វីឬ ពួកតិរ្ថិយពោលថា ពួកយើងត្រូវសមណគោតមបៀតបៀននាងបែរជាមានសេចក្តីខ្វល់ខ្វាយតិច នេះឯងជាទោសរបស់នាង ។ នាងសុន្ទរីពោលថា កាលបើដូច្នោះ ខ្ញុំនឹងធ្វើដូចម្តេចក្នុងសេចក្តីនោះ តិរ្ថិយទាំងឡាយពោលថា នាងអាចធ្វើនូវការតិះដៀលឲ្យកើតដល់ព្រះសមណគោតមបានដែរ

ឬ នាងសុន្ទរីពោលថា បាន លោកម្ចាស់ កាលពោលហើយ ចាប់តាំងពីនោះមក ក៏ប្រាប់ដល់ពួកជនដែលបានជួបថា ខ្ញុំទៅដេកក្នុងព្រះគន្ធកុដិជាមួយនឹងព្រះសមណគោតម ហើយទើបចេញមក ដោយន័យដូចពោលដូចពោលខាងដើម ហើយជេរបរិភាស ។ ចំណែកពួកតិរ្ថិយ ក៏ជេរបរិភាសថា អ្នកដ៏ចម្រើនទាំងឡាយ ចូរមើលកម្មរបស់ព្រះសមណគោតម សមដូចព្រះមានព្រះភាគត្រាស់ថា

កាលកពមុន ក្នុងជាតិដទៃ តថាគតជាអ្នកលេង ឈ្មោះ បុនាលិ បានពោលបង្កាច់នូវព្រះបច្ចេកពុទ្ធ ព្រះនាមសុរភី ព្រះអង្គជាបុគ្គលមិនប្រទូស្តឡើយ ។

ដោយវិបាកនៃកម្មនោះ តថាគតអន្ទោលទៅក្នុងនរក អស់កាលដ៏យូរ រងទុក្ខវេទនា អស់ពាន់នៃឆ្នាំដ៏ច្រើន ។ ដោយសំណល់នៃកម្មនោះ ក្នុងបច្ឆិមភពនេះ តថាគតបាននូវការពោលបង្កាច់ ព្រោះហេតុនៃនាងសុន្ទរិកា ដូច្នេះ ។

ក្នុងរឿងទី ៤ គប្បីជ្រាបការមកដូចតទៅនេះថា

ការជេរ ការបរិភាសដោយក្រៃលែង គឺដោយពិសេស ឈ្មោះថា ការចោទប្រកាន់ ។ បានឮថា ក្នុងអតីតកាល ព្រះពោធិសត្វកើតក្នុងត្រកូលព្រាហ្មណ៍ ជាអ្នកសិក្សារៀនសូត្រច្រើន មនុស្សជាច្រើនធ្វើនូវសក្ការបូជា បានបួសជាតាបស មានឫសឈើ និងផ្លែឈើក្នុងព្រៃជាអាហារ បង្រៀនមន្តពួកមាណពជាច្រើន សម្រេចការនៅក្នុងព្រៃហិមពាន្ត ។ តាបស ១ រូប

បានអភិញ្ញា ៥ និងសមាបត្តិ ៨ បានមកកាន់សម្នាក់របស់ព្រះពោធិសត្វនោះៗ គ្រាន់តែឃើញតាបសនោះ ត្រូវសេចក្តីប្រណែនគ្របសង្កត់ បានជេរឥសី ដែលមិនប្រទូស្តនោះថា ឥសីនេះ បោកប្រាស ជាអ្នកបរិភោគកាម ហើយ ប្រាប់សិស្សរបស់ខ្លួនថា ឥសីនេះ ជាអ្នកមិនមានអាចារបែបនេះៗ ។ ឯសិស្ស ទាំងនោះ ក៏នាំគ្នាជេរបរិភាសយ៉ាងនោះដូចគ្នា ។ ដោយវិបាកនៃអកុសលកម្ម នោះ ព្រះពោធិសត្វនោះ ក៏បានសោយទុក្ខក្នុងនរកច្រើនពាន់ឆ្នាំ ក្នុងអត្តភាព ចុងក្រោយនេះ បានជាព្រះពុទ្ធ ដល់នូវភាពជាអ្នកប្រសើរដោយលាភ និង ដោយយស ប្រាកដដូចព្រះចន្ទពេញវង់ ក្នុងអាកាស ដូច្នោះ ។

ដោយការជេរយ៉ាងនោះ ពួកតិរ្ថិយនៅមិនអស់ចិត្ត ទើបគិតជាមួយ នាងសុន្ទរីឲ្យធ្វើការពោលទោសទៀត ហៅអ្នកលេងសុរាមកឲ្យថ្លៃឈ្នួល រួច ប្រាប់ថា ចូរសម្លាប់នាងសុន្ទរីកប់ក្នុងគំនរផ្កា ក្នុងទីជិតទ្វារវត្តជេតពន ។ ពួក អ្នកលេងសុរាទាំងនោះ បានធ្វើយ៉ាងនោះ បន្ទាប់អំពីនោះ ពួកតិរ្ថិយក៏ក្រាប ទូលដល់ព្រះរាជាថា ទូលបង្គំទាំងឡាយមិនឃើញនាងសុន្ទរី ព្រះរាជាត្រាស់ ថា លោកម្ចាស់ទាំងឡាយ ចូរស្វែងរកមើល តិរ្ថិយទាំងនោះក៏អូសសពមក អំពីទីដែលខ្លួនឲ្យកប់ លើកឡើងដាក់លើគ្រែតូច នាំទៅឲ្យព្រះរាជាទ្រង់ទត ហើយត្រាច់ឃោសនានូវទោសរបស់ព្រះមានព្រះភាគ និងភិក្ខុសង្ឃ ក្នុងនគរ ទាំងមូលថា អ្នកដ៏ចម្រើនទាំងឡាយ ចូរមើលកម្មរបស់សមណគោតម និង ពួកសាវក ហើយដាក់នាងសុន្ទរីលើគ្រែ ក្នុងទីស្មសាន ។ ព្រះរាជាត្រាស់ថា ចូរអ្នកទាំងឡាយស៊ើបរកមនុស្ស ដែលសម្លាប់នាងសុន្ទរី ។

កាលនោះ ពួកអ្នកលេងផឹកស្រា ហើយឈ្លោះគ្នាថា ឯងសម្លាប់នាងសុន្ទរី ឯងសម្លាប់នាងសុន្ទរី ។ រាជបុរសទាំងឡាយ ក៏ចាប់ពួកអ្នកលេងទាំងនោះឲ្យព្រះរាជាៗ ត្រាស់សួរថា នែអ្នក ពួកអ្នកសម្លាប់នាងសុន្ទរីឬ អ្នកលេងទាំងនោះក្រាបទូលថា ករុណាថ្លៃវិសេស ។ ព្រះរាជាត្រាស់សួរថា អ្នកណាបញ្ជា អ្នកលេងក្រាបទូលថា ពួកតិរ្ថិយ ទើបព្រះរាជាឲ្យនាំពួកតិរ្ថិយមក ហើយឲ្យចង ត្រាស់បញ្ជាថា ពួកលោក ចូរត្រាច់ប្រកាសថា ពួកយើងឲ្យសម្លាប់នាងសុន្ទរីឯង ដើម្បីឲ្យកើតនូវការតិះដៀលព្រះពុទ្ធមានព្រះភាគ និងសាវកទាំងឡាយរបស់ព្រះអង្គ ព្រះសម្ពុទ្ធមិនមែនជាអ្នកធ្វើឡើយ ។ ពួកតិរ្ថិយបានធ្វើតាមនោះ អ្នកនគរទាំងមូល ក៏អស់សេចក្តីសង្ស័យ ។ ព្រះរាជាទ្រង់ឲ្យសម្លាប់ពួកតិរ្ថិយ និងពួកអ្នកលេង ហើយឲ្យចោលសាកសព ។ បន្ទាប់អំពីនោះ លាភសក្ការៈចម្រើនដុះដាល ដល់ព្រះមានព្រះភាគក្រៃលែងឡើង សមដូចព្រះមានព្រះភាគត្រាស់ថា

តថាគត ជាព្រាហ្មណ៍ រៀនចប់ហើយ ជាអ្នកមានមហាជន
ធ្វើសក្ការបូជា បានបង្រៀនមន្តដល់មាណព ៥០០ ក្នុងព្រៃធំ ។
តថាគត កើតជាព្រាហ្មណ៍ តែងជាអ្នកចេះមន្ត មានគេធ្វើ
សក្ការបូជា បង្ហាញមន្តដល់មាណព ៥០០ នាក់ក្នុងព្រៃធំ ។
ឥសីភិមៈ បានអភិញ្ញា ៥ មានឫទ្ធិច្រើន មកក្នុងទីនោះ តថាគត
បានឃើញឥសីនោះ លោកជាអ្នកមិនប្រទូស្ត និមន្តមក ក៏
បានពោលបង្កាច់ ។

លំដាប់នោះ តថាគតនិយាយនឹងពួកសិស្សថា ឥសីនេះ ជាអ្នកបរិភោគកាម កាលតថាគតនិយាយប្រាប់ ឯពួកមាណពក៏បានរីករាយតាម ។

លំដាប់នោះ មាណពទាំងអស់ ត្រាច់ទៅសូមក្នុងត្រកូលតូចធំ និយាយប្រាប់មហាជនថា ឥសីនេះ ជាអ្នកបរិភោគកាម ។ ដោយវិបាកនៃកម្មនោះ ភិក្ខុទាំងអស់ ចំនួន ៥០០ នេះ ក៏បានទូវការពោលបង្កាច់ ព្រោះហេតុនៃនាងសុន្ទរិកា ដូច្នេះ ។

ក្នុងរឿងទី ៥ គប្បីជ្រាបការមកដូចតទៅនេះថា

បុគ្គលមានចិត្ត ដែលទោសប្រទូស្តហើយ ប្រមៀលថ្មសង្កត់ ឈ្មោះថា ការប្រមៀលថ្ម ។ បានឮថា ក្នុងអតីតកាល ព្រះពោធិសត្វ និងប្អូនប្រុស[១] ជាកូនដែលមានឪពុករួមគ្នា កាលបិតាស្លាប់ទៅហើយ បងប្អូនទាំង ២ នោះ ធ្វើនូវការឈ្លោះគ្នា ព្រោះអាស្រ័យពួកទាសៈ ទើបគិតប្រទូស្តគ្នាទៅវិញទៅមក ព្រះពោធិសត្វចាប់សង្កត់ប្អូនប្រុស ដោយភាពដែលខ្លួនជាអ្នកមានកម្លាំង រួចយកដុំថ្មសង្កត់លើប្អូនប្រុសនោះ ព្រោះវិបាកនៃកម្មនោះ ព្រះពោធិសត្វ សោយទុក្ខក្នុងនរកជាដើម ច្រើនពាន់ឆ្នាំ ក្នុងអត្តភាពចុងក្រោយនេះ បានជាព្រះពុទ្ធ ។

ទេវទត្តភិក្ខុ ជាព្រះមាតុលារបស់ព្រះរាហុលកុមារ ក្នុងជាតិមុន បានជាឈ្មួញរួមផ្លូវជាមួយព្រះពោធិសត្វ ។ ក្នុងកាលជាឈ្មួញ ឈ្មោះសិរិពាណិជ្ជ

---

១- ពាក្យថា ប្អូនប្រុស មកពីបាលីអដ្ឋកថាថា កនិដ្ឋភាតា ។

ឈ្មួញទាំង ២ នោះ ទៅដល់ស្រុកដែលតាំងនៅជិតកំពង់ទឹកមួយកន្លែង ទើបសម្រេចគ្នាថា ចូរអ្នកកាន់យកផ្លូវ ១ ខ្ញុំនឹងកាន់យកផ្លូវ ១ រួចជនទាំង ២ ក៏ចូលទៅក្នុងស្រុក ។ ក្នុងផ្លូវទាំង ២ នោះ ផ្លូវដែលទេវទត្តចូលទៅ មានមនុស្ស ២ នាក់ គឺភរិយារបស់សេដ្ឋីបុរាណម្នាក់ និងចៅស្រីម្នាក់ ។ ជនទាំង ២ មានថាសមាសធំ ត្រូវមន្ទិលកាន់ក្នុងរវាងភាជនៈ ។ ភរិយារបស់សេដ្ឋីបុរាណនោះ មិនដឹងថា ជាភាជន៍មាស ទើបពោលនឹងឈ្មួញទេវទត្តនោះថា សូមលោកយកថាសនេះទៅ ហើយឲ្យគ្រឿងប្រដាប់មក ។ ទេវទត្តនោះ ចាប់ថាសនោះហើយ យកដែកស្រួចកូតមើល ដឹងថាជាថាសមាស គិតថា ពន្យាបន្តិចហើយ សឹមមកយក ទើបចៀសចេញទៅ ។

លំដាប់នោះ ចៅស្រីឃើញព្រះពោធិសត្វមកត្រង់ជិតទ្វារ ទើបពោលថា បពិត្រលោកយាយ សូមលោកយាយឲ្យគ្រឿងប្រដាប់ឈ្មោះកច្ឆបុដៈដល់ខ្ញុំ ភរិយាសេដ្ឋីនោះ ក៏ហៅព្រះពោធិសត្វនោះមក ឲ្យអង្គុយហើយ ក៏ហុចភាជន៍នោះឲ្យ ពោលថា ចូរអ្នកកាន់យកភាជន៍នេះ ហើយឲ្យគ្រឿងប្រដាប់ ឈ្មោះកច្ឆបុដៈដល់ចៅស្រីរបស់ខ្ញុំ ។ ព្រះពោធិសត្វចាប់ភាជន៍នោះ ដឹងថា ជាភាជន៍មាស និងដឹងថា ស្រីនោះ ត្រូវទេវទត្តបញ្ឆោត ទើបឲ្យប្រាក់ ៨ កហាបណៈ ដែលរក្សាក្នុងថង់របស់ខ្លួន និងទំនិញដ៏សេស ហើយប្រដាប់កច្ឆបុដៈត្រង់ដៃរបស់កុមារី ហើយក៏ទៅ ។ ឈ្មួញមុនវិញត្រឡប់មកសួរ ភរិយាសេដ្ឋីនោះពោលថា នែអ្នក អ្នកមិនយក កូនរបស់ខ្ញុំឲ្យវត្ថុនេះៗ យកថាសនោះទៅហើយ ។ ឈ្មួញនោះ លុះបានស្តាប់ដូច្នោះ មាន

ហទយៈស្ទើរបែក ទើបរត់តាមទៅ ។ ព្រះពោធិសត្វឡើងទូកចេញទៅហើយ ។ ឈ្មួញនោះពោលថា ឈប់ កុំគេចៗ ហើយបានធ្វើសេចក្តីប្រាថ្នាថា អាត្មាអញគប្បីធ្វើឲ្យវាវិនាសក្នុងភពដែលកើតហើយ ។

ដោយអំណាចសេចក្តីប្រាថ្នា ឈ្មួញនោះបៀតបៀនគ្នានិងគ្នាច្រើនសែនជាតិ ក្នុងអត្តភាពនេះ កើតក្នុងសក្យត្រកូល កាលព្រះមានព្រះភាគសម្រេចសព្វញ្ញុតញ្ញាណ គង់នៅក្នុងក្រុងរាជគ្រឹះដោយលំដាប់ បានទៅកាន់សម្នាក់ព្រះមានព្រះភាគ មួយអន្លើដោយអនុរុទ្ធជាដើម បួសហើយ បានឈាន មានកេរ្តិ៍ឈ្មោះ ទើបទូលសូមពរព្រះមានព្រះភាគថា បពិត្រព្រះអង្គដ៏ចម្រើន ភិក្ខុសង្ឃទាំងពួង ចូរសមាទានធុតង្គ ១៣ មានត្រាច់បិណ្ឌបាតជាវត្តជាដើម ភិក្ខុសង្ឃទាំងមូល ចូរជាភារៈរបស់ខ្ញុំព្រះអង្គ ។ ព្រះមានព្រះភាគទ្រង់មិនអនុញ្ញាត ទេវទត្តចងពៀរ ទើបសាបសូន្យចាកឈាន ចង់ផ្តាច់ព្រះជន្មព្រះមានព្រះភាគ ។ ថ្ងៃមួយ កាលព្រះមានព្រះភាគទ្រង់ឈរ ឈរត្រង់ជើងភ្នំវេភារៈ[១] ទេវទត្តភិក្ខុនៅខាងលើ ប្រមៀលកំពូលភ្នំចុះមក ។ ដោយអានុភាពព្រះមានព្រះភាគ កំពូលភ្នំដទៃមួយទៀត ទទួលកំពូលភ្នំដែលកំពុងរមៀលចុះមក អំបែងថ្មដែលកើតអំពីកំពូលភ្នំទាំងនោះប៉ះគ្នា ខ្ទាតមកប៉ះខ្នងព្រះបាទ[២] របស់ព្រះមានព្រះភាគ ។ សមដូចព្រះមានព្រះភាគត្រាស់ថា

កាលភពមុន តថាគតសម្លាប់បងប្រុសម្នាក់ មានមាតាផ្សេងគ្នា

---

១- ទីខ្វះថា ភ្នំគិជ្ឈកូដ ។

២- ពាក្យថា ខ្នងព្រះបាទ មកពីបាលីអដ្ឋកថាថា បាទបិដ្ឋិយំ ។

ព្រោះហេតុនៃទ្រព្យ ហើយបោះចោលទៅក្នុងជ្រោះភ្នំឲ្យប៉ះនឹងថ្ម ។

ដោយវិបាកនៃកម្មនោះ ទេវទត្តបានប្រមៀលថ្ម ដុំថ្ម ក៏រមៀល

មកប៉ះអង្គុដ្ឋបាទ ( មេជើង ) នៃតថាគត ដូច្នេះ ។

ក្នុងរឿងទី ៦ គប្បីជ្រាបការមកដូចតទៅនេះថា

បំណែកថ្មប៉ះខ្ទប់ ឈ្មោះថា ការសោយវេទនាអំពីអំបែងថ្ម បានឮថា ក្នុងអតីតកាល ព្រះពោធិសត្វកើតក្នុងត្រកូលមួយ ក្នុងកាលជាកុមារ កំពុងលេងត្រង់ផ្លូវធំ ឃើញព្រះបច្ចេកពុទ្ធត្រាច់បិណ្ឌបាតក្នុងផ្លូវ គិតថា សមណៈត្រងោលនេះទៅណា ហើយទាញយកដុំថ្មគប់ត្រង់ខ្នងជើងរបស់លោក ។ ខ្នងជើងបែក ឈាមក៏ហូរចេញ ។ ព្រោះកម្មដ៏អាក្រក់នោះ ព្រះពោធិសត្វនោះបានសោយទុក្ខដ៏ពន្លឹកក្នុងនរកច្រើនពាន់ឆ្នាំ បានជាព្រះពុទ្ធហើយ ក៏ពុះពោរព្រះលោហិត ព្រោះបំណែកថ្មប៉ះខ្ទប់ត្រង់ខ្នងព្រះបាទ ដោយអំណាចកម្មចាស់ ដោយហេតុនោះ ទើបព្រះមានព្រះភាគត្រាស់ថា

កាលពីជាតិមុន តថាគតជាទារក កំពុងលេងក្នុងផ្លូវធំ បាន

ឃើញព្រះបច្ចេកពុទ្ធ ក៏ដុតព្រៃទាំងមូល ក្បែរផ្លូវ ។

ដោយវិបាកនៃកម្មនោះ ក្នុងបច្ឆិមភពនេះ ទេវទត្តក៏ប្រើខ្មាន់ធ្នូ

ឲ្យសម្លាប់តថាគត ។

ក្នុងរឿងទី ៧ គប្បីជ្រាបការមកដូចតទៅនេះថា

ដំរីធនបាលកៈ ដែលគេបញ្ជូនទៅដើម្បីឲ្យសម្លាប់ ឈ្មោះដំរីនាឡាគិរី ។ បានឮថា ក្នុងអតីតកាល ព្រះពោធិសត្វកើតជាអ្នកចិញ្ចឹមដំរី ជិះដំរីត្រាច់ទៅ

ឃើញព្រះបច្ចេកពុទ្ធក្នុងផ្លូវធំ គិតថា សមណៈត្រងោលនេះមក អំពីណា មានចិត្តចង្អៀតចង្អល់ ដូចជាចម្រឹងដោតក្នុងចិត្ត ទើបពន្យុះដំរីឲ្យដេញជាន់ ដោយកម្មនោះ ព្រះពោធិសត្វបានសោយទុក្ខក្នុងអបាយច្រើនពាន់ឆ្នាំ ក្នុង អត្តភាពចុងក្រោយ កើតជាព្រះពុទ្ធ ទេវទត្តធ្វើព្រះបាទអជាតសត្រូវឲ្យជា សម្លាញ់ហើយ ធ្វើកតិកាគ្នាថា បពិត្រមហារាជ ទ្រង់ផ្តាច់ព្រះជន្មព្រះបិតា ហើយ ចូរជាព្រះរាជា អាត្មាសម្លាប់ព្រះពុទ្ធហើយ នឹងធ្វើជាព្រះពុទ្ធ ដូច្នេះ ។ ថ្ងៃមួយ ទៅកាន់រោងដំរី តាមដែលព្រះរាជាទ្រង់អនុញ្ញាត ហើយប្រាប់ហ្មដំរី ថា ស្អែកនេះ ចូរអ្នកឲ្យដំរីនាឡាគិរីផឹកស្រា ១៦ ក្អម ហើយចូរលែងទៅ ក្នុងកាលដែលព្រះមានព្រះភាគត្រាច់បិណ្ឌបាត ព្រះនគរទាំងមូលកើតនូវ កោលាហលធំ ។ ជនទាំងឡាយនិយាយគ្នាថា យើងនឹងមើលចម្បាំងរបស់ នាគ គឺដំរី និងនាគ គឺព្រះពុទ្ធ ដូច្នេះហើយ នាំគ្នាចង់គ្រែត្រួតគ្រែក្នុងផ្លូវធំ ទាំងសងខាង ហើយរង់ចាំអំពីព្រលឹម ។

ឯព្រះមានព្រះភាគ ទ្រង់ធ្វើកិច្ចបដិបត្តិព្រះសរីរៈហើយ កាលពួកភិក្ខុ ចោមរោម យាងចូលទៅបិណ្ឌបាតក្នុងក្រុងរាជគ្រឹះ ខណៈនោះ ពួកអ្នកចិញ្ចឹម ដំរី លែងដំរីនាឡាគិរី ដោយទំនងដែលពោលហើយនោះឯង ។ ដំរីនាឡាគិរី ដើរកាត់វិថី និងផ្លូវបែកជា ៤ ជាដើមមក ។ កាលនោះ ស្រីម្នាក់ពទារកដើរ ឆ្លងថ្នល់ ដំរីឃើញស្រីនោះ ទើបដេញតាម ។ ព្រះមានព្រះភាគត្រាស់ថា ម្នាល នាឡាគិរី គេមិនបានបញ្ជូនមកដើម្បីសម្លាប់ស្រីនោះ ចូរអ្នកមកផ្លូវនេះ ។ ដំរី នោះ បានស្តាប់សំឡេងនោះហើយ ក៏រត់បែរមុខទៅរកព្រះមានព្រះភាគ ។

ព្រះសាស្តាទ្រង់ផ្សាយមេត្តា ដែលគួរផ្សាយទៅក្នុងសត្វ ដែលមិនមានទីបំផុត ក្នុងចក្កវាឡដែលប្រមាណមិនបាន ដាក់ក្នុងដំរីនាឡាគិរីត្រឹមតែមួយប៉ុណ្ណោះ ។ ដំរីនាឡាគិរីនោះ ដែលព្រះមេត្តារបស់ព្រះមានព្រះភាគពាល់ត្រូវហើយ ក្លាយជាដំរីដែលមិនមានភ័យ ក្រាបចុះទៀបបាទមូលរបស់ព្រះមានព្រះភាគ ។ ព្រះមានព្រះភាគទ្រង់ដាក់ព្រះហស្តលើក្បាលរបស់ដំរីនាឡាគិរីនោះ ។ កាលនោះ ទេវតា និងព្រហ្មជាដើម កើតអស្ចារ្យក្នុងចិត្តដែលមិនធ្លាប់មាន នាំគ្នាបូជាដោយផ្កា និងកេសរផ្កាជាដើម ។ ក្នុងនគរទាំងមូល មានគំនរទ្រព្យប្រមាណត្រឹមជង្គង់ ។ ព្រះរាជាត្រាស់ឲ្យគ្រាប់វាយស្គរប្រកាសថា ទ្រព្យត្រង់ទ្វារទិសខាងលិច ចូរជារបស់អ្នកនគរ ទ្រព្យត្រង់ទ្វារទិសខាងកើត ចូរនាំចូលរាជឃ្លាំង ។ មនុស្សទាំងពួង ធ្វើតាមនោះ ។ ក្នុងកាលនោះ ដំរីនាឡាគិរីបានឈ្មោះថា ធនបាល ។ ព្រះមានព្រះភាគ បានយាងទៅកាន់វេឡុវនារាម ។ សមដូចព្រះមានព្រះភាគត្រាស់ថា

កាលពីជាតិមុន តថាគតកើតជាហ្មដំរី បានបរដំរីបំព្រេចព្រះ
បច្ចេកមុនីដ៏ឧត្តម ព្រះអង្គកំពុងត្រាច់ទៅដើម្បីបិណ្ឌបាត ។
ដោយវិបាកនៃកម្មនោះ ដំរីនាឡាគិរីចុះប្រេង កាចចូលមក
ព្រេចតថាគត ក្នុងគិរិព្វជបុរីដ៏ប្រសើរ ( រាជគហៈ ) ។

ក្នុងរឿងទី ៨ គប្បីជ្រាបការមកដូចតទៅនេះថា

ការវះដោយសស្ត្រា គឺកាត់ដោយសស្ត្រា ឈ្មោះថា ការវះដោយសស្ត្រា ។ បានឮថា ក្នុងអតីតកាល ព្រះពោធិសត្វបានជាព្រះរាជា ក្នុង

បច្ចន្តប្បទេស ព្រះពោធិសត្វនោះបានជាអ្នកលេង ដោយអំណាចការប្រឡូកប្រឡំដោយមនុស្សអាក្រក់ និងដោយអំណាចការនៅក្នុងបច្ចន្តប្បទេស ជាមនុស្សគ្រោតគ្រាត ។ ថ្ងៃមួយ កាន់ដាវ[១] ដើរជើងទទេ ត្រាច់ទៅក្នុងនគរ បានយកកាំបិត កាប់អ្នកដែលមិនមានកំហុសចៀសចេញទៅ ។ ដោយវិបាកនៃបាបកម្មនោះ ព្រះពោធិសត្វនោះ ឆេះក្នុងនរកច្រើនពាន់ឆ្នាំ សោយទុក្ខក្នុងទុគ្គតិ មានសត្តតិរច្ឆានជាដើម ដោយវិបាកដ៏សេស ក្នុងអត្តភាពចុងក្រោយបានត្រាស់ជាព្រះពុទ្ធ ក៏ពុះពោរព្រះលោហិត ព្រោះត្រូវបំណែកថ្ម ដែលទេវទត្តប្រមៀលចុះ ប៉ះខ្ទប់ដោយន័យដូចពោលហើយខាងដើម ។ ពេទ្យជីវកវះស្បែកដែលហើមនោះ ដោយមេត្តាចិត្ត ។ ការធ្វើព្រះលោហិតឲ្យពុះពោររបស់ទេវទត្ត ដែលគិតចង់ពៀរ ចាត់ជាអនន្តរិយកម្ម ។ ការវះស្បែកដែលប៉ោងឡើងរបស់ពេទ្យជីវក ដែលមានចិត្តមេត្តា ចាត់ជាបុណ្យដោយពិត ។ សមដូចព្រះមានព្រះភាគត្រាស់ថា

> តថាគតកើតជាស្តេច ឈ្មោះបត្តិកៈ បានយកលំពែងសម្លាប់បុរសទាំងឡាយ ដោយវិបាកនៃកម្មនោះ តថាគតឆេះក្នុងភ្លើងនរកក្លាខ្លាំង ។
>
> ដោយសំណល់នៃកម្មនោះ ក្នុងកាលឥឡូវនេះ កម្មវិបាកនោះក៏ធ្វើឲ្យរបកស្បែកជើងទាំងអស់របស់តថាគត ព្រោះថា កម្ម

---

១- ដាវ មកពីបាលីអដ្ឋកថាថា ខគ្គៈ តែក្នុងបិដកខ្មែរថា លំពែង ព្រោះបាលីថា សត្តិយា ។

នៅតែមិនទាន់វិនាស ដូច្នេះ ។

ក្នុងរឿងទី ៩ គប្បីជ្រាបការមកដូចតទៅនេះថា

អាពាធកើតត្រង់សីសៈ គឺវេទនាត្រង់សីសៈ ឈ្មោះថា ការឈឺសីសៈ ។ បានឮថា ក្នុងអតីតកាល ព្រះពោធិសត្វកើតជាអ្នកប្រមង់ ក្នុងស្រុកអ្នកប្រមង់ ។ ថ្ងៃមួយ ព្រះពោធិសត្វនោះ មួយអន្លើដោយពួកអ្នកប្រមង់ ទៅកាន់ទីសម្លាប់ត្រី ឃើញត្រីទាំងឡាយស្លាប់ បានធ្វើសោមនស្សឲ្យកើតឡើងក្នុងត្រីដែលស្លាប់នោះ បុរសអ្នកប្រមង់ដែលទៅជាមួយគ្នានោះ ក៏ធ្វើសោមនស្សឲ្យកើតឡើងយ៉ាងនោះដូចគ្នា ដោយអកុសលកម្មនោះ ព្រះពោធិសត្វបានសោយទុក្ខក្នុងអបាយទាំង ៤ ក្នុងអត្តភាពចុងក្រោយនេះ កើតក្នុងសក្យរាជត្រកូល មួយអន្លើដោយបុរសទាំងនោះ បានសម្រេចភាពជាព្រះពុទ្ធដោយលំដាប់ហើយ ក៏នៅតែបានសោយនូវអាពាធត្រង់សីសៈ ។ ស្តេចសក្យៈទាំងនោះ ដល់នូវសេចក្តីវិនាសទាំងអស់ ក្នុងសង្គ្រាមរបស់ស្តេចវិឌូឌភៈ ដោយន័យដូចពោលក្នុងអដ្ឋកថាធម្មបទ ។ សមដូចព្រះមានព្រះភាគត្រាស់ថា

តថាគតកើតជាទារកនៃព្រានត្រី ក្នុងកេវដ្តគ្រាម បានឃើញ
ពួកជនអ្នកសម្លាប់ត្រី ក៏កើតសោមនស្ស ។
ដោយវិបាកនៃកម្មនោះ ស្តេចវិដដុភៈសម្លាប់ពួកសក្យៈ ក្នុង
កាលណា ទុក្ខក្នុងក្បាល ក៏មានដល់តថាគត ( ក្នុងកាល
នោះ ) ព្រោះពួកសក្យៈត្រូវគេសម្លាប់ ដូច្នេះ ។

ក្នុងរឿងទី ១០ គប្បីជ្រាបការមកដូចតទៅនេះថា

កាលសោយអង្ករក្រហម ក្នុងក្រុងវេសាលី ឈ្មោះថា ការបរិភោគអង្ករសំរូប ។ បានឮថា ក្នុងអតីតកាល ព្រះពោធិសត្វកើតក្នុងត្រកូលមួយ ព្រោះអំណាចជាតិ និងព្រោះភាពជាអន្ធពាល ឃើញសាវ័កទាំងឡាយរបស់ព្រះមានព្រះភាគផុស្សៈឆាន់បាយទឹកដ៏ឆ្ងាញ់ និងភោជននៃស្រូវសាលីជាដើម ទើបជេរថា ថ្វីយ ពួកសមណៈត្រងោល ចូរពួកលោកស៊ីបាយក្រហមចុះ កុំស៊ីនូវភោជននៃស្រូវសាលីឡើយ ។ ព្រោះវិបាកនៃអកុសលកម្មនោះ ព្រះពោធិសត្វក៏សោយទុក្ខក្នុងអបាយទាំង ៤ ច្រើនពាន់ឆ្នាំ ក្នុងអត្តភាពចុងក្រោយនេះ ដល់នូវភាពជាព្រះពុទ្ធដោយលំដាប់ កាលទ្រង់ធ្វើសេចក្ដីអនុគ្រោះសត្វលោក ត្រាច់ទៅក្នុងគាមនិគម និងរាជធានីទាំងឡាយ ។ សម័យមួយយាងដល់គល់ស្ដៅ ដែលសម្បូរដោយមែក និងប្រគាបក្នុងទីជិតវេរញ្ជព្រាហ្មណគាម ។ វេរញ្ជព្រាហ្មណ៍ចូលទៅគាល់ព្រះមានព្រះភាគ កាលមិនអាចយកឈ្នះព្រះមានព្រះភាគបាន ដោយហេតុផលដែលនាំមកអាងច្រើនប្រការ បានជាព្រះសោតាបន្នហើយ ក្រាបទូលថា បពិត្រព្រះអង្គដ៏ចម្រើន ការចាំវស្សាក្នុងទីនេះឯង រមែងគួរ ។ ព្រះមានព្រះភាគទ្រង់ទទួលនិមន្តដោយតុណ្ហីភាព ។ ចាប់តាំងពីថ្ងៃរះឡើងទៅ មារមានចិត្តបាប បានធ្វើការបណ្ដាលចិត្តអ្នកស្រុកវេរញ្ជព្រាហ្មណគាមទាំងអស់ ។ ព្រោះមារបណ្ដាលចិត្ត ទើបមិនមានបុគ្គលសូម្បីត្រឹមតែម្នាក់ ថ្វាយកិច្ចាសូម្បីមួយវែកដល់ព្រះមានព្រះភាគ ដែលចូលទៅបិណ្ឌបាត ។ ព្រះមានព្រះភាគមានបាត្រទទេ ដែលភិក្ខុសង្ឃ

ចោមរោម យាងត្រឡប់មក ។ កាលព្រះមានព្រះភាគត្រឡប់មកយ៉ាងនោះ ពួកឈ្មួញសេះដែលនៅក្នុងទីនោះឯង បានថ្វាយទានក្នុងថ្ងៃនោះ ។ ចាប់ពីថ្ងៃនោះទៅ ពួកឈ្មួញសេះ បាននិមន្តព្រះមានព្រះភាគ មានភិក្ខុ ៥០០ ជាបរិវារ ហើយធ្វើការរំលែកអំពីអាហាររបស់សេះ ៥០០ យកមកបុកធ្វើជាបាយក្រហម ហើយដាក់ក្នុងបាត្ររបស់ភិក្ខុទាំងឡាយ ។ ទេវតាក្នុងពាន់ចក្កវាឡ នាំគ្នាដាក់ទិព្វឱជៈ ដូចក្នុងថ្ងៃដែលនាងសុជាតាចម្អិនបាយាស ។ ព្រះមានព្រះភាគសោយហើយ ទ្រង់សោយបាយក្រហមអស់ ៣ ខែ កាល ៣ ខែកន្លងទៅ មារឈប់បណ្តាលចិត្ត ក្នុងថ្ងៃបវារណា វេរញ្ជព្រាហ្មណ៍រឭកឡើងបាន ដល់នូវភាពសង្វេគយ៉ាងធំ ទើបថ្វាយមហាទានដល់ភិក្ខុសង្ឃ មានព្រះពុទ្ធជាប្រធាន ថ្វាយបង្គំហើយ សូមឲ្យទ្រង់អត់ទោស ។ សមដូចព្រះមានព្រះភាគត្រាស់ថា

តថាគតបានពោលផ្ទួនា នូវពួកសាវក ក្នុងសាសនានៃព្រះពុទ្ធ
ព្រះនាមផុស្សៈថា ចូរលោកទាំងឡាយ ទំពាស៊ី បរិភោគ
នូវបាយដំណើបចុះ កុំបរិភោគនូវបាយស្រូវសាលីឡើយ ។
ដោយវិបាកនៃកម្មនោះ ក្នុងកាលនោះ តថាគតនៅក្នុងស្រុក
វេរញ្ជា ព្រាហ្មណ៍និមន្ត ឲ្យឆាន់តែបាយដំណើបអស់ ៣ ខែ
ដូច្នេះ ។

ក្នុងរឿងទី ១១ គប្បីជ្រាបការមកដូចតទៅនេះថា

អាពាធត្រង់ខ្នង ឈ្មោះថា ការឈឺព្រះបិដ្ឋិ គឺខ្នង ។ បានឮថា ក្នុង

អតីតកាល ព្រះពោធិសត្វកើតក្នុងត្រកូលគហបតី សម្បូរដោយកម្លាំង តែជាមនុស្សតឿ ។ សម័យនោះ អ្នកប្រដាល់ម្នាក់ កាលដើរដាល់ក្នុងគាម-និគម និងរាជធានីទាំងឡាយ ក្នុងជម្ពូទ្វីបទាំងមូល បានធ្វើពួកបុរស ឲ្យដួលចុះ បានទទួលជ័យជម្នះ មកដល់នគរដែលព្រះពោធិសត្វរស់នៅដោយលំដាប់ បានធ្វើពួកមនុស្សក្នុងនគរនោះឲ្យដួលចុះហើយ គិតនឹងទៅ ។ គ្រានោះ ព្រះពោធិសត្វគិតថា បុរសនេះបានទទួលជ័យជម្នះក្នុងស្រុករបស់អញហើយនឹងទៅ ទើបមកកាន់ទីលានប្រយុទ្ធប្រចាំនគរក្នុងទីនោះ ទះដៃ ហើយពោលថា មកប្រកួតនឹងយើង ហើយសឹមទៅ ។ អ្នកប្រដាល់នោះសើចហើយពោលថា ពួកបុរសធំៗ គង់អញធ្វើឲ្យដួលបាន បុរសនេះជាមនុស្សតឿ មានធាតុជាមនុស្សតឿ មិនល្មមដល់ដៃម្ខាងរបស់អញ ទើបទះដៃគំរាម ដើរចូលមករក ។ ជនទាំង ២ នោះ ចាប់ដៃគ្នានិងគ្នា ព្រះពោធិសត្វចាប់អ្នកប្រដាល់នោះលើកឡើង បោះទៅក្នុងអាកាសឲ្យធ្លាក់ចុះលើផែនដី បានកាច់ឆ្អឹងខ្នងហើយ បោះឲ្យដួលចុះ ។ អ្នកនគរទាំងមូល ធ្វើនូវការហ៊ោកញ្ជ្រៀវ ទះដៃបូជាព្រះពោធិសត្វដោយសំពត់ និងអាភរណៈជាដើម ព្រះពោធិសត្វឲ្យអ្នកប្រដាល់នោះអង្គុយឲ្យត្រង់ ពត់ឆ្អឹងខ្នងឲ្យត្រង់ ហើយពោលថា ចូរអ្នកទៅចុះ តាំងអំពីថ្ងៃនេះទៅ កុំធ្វើបែបនេះ ហើយបញ្ជូនទៅ ។ ដោយវិបាកនៃកម្មនោះ ព្រះពោធិសត្វបានសោយទុក្ខត្រង់រាងកាយ និងសីសៈជាដើម ក្នុងភពដែលកើតហើយ ក្នុងអត្តភាពចុងក្រោយ បានជាព្រះពុទ្ធហើយ ក៏បានសោយទុក្ខ មានការឈឺឆ្អឹងខ្នងជាដើម ព្រោះហេតុនោះ កាលសេចក្តីទុក្ខ

ត្រង់ខ្នងកើតឡើងម្ដងម្កាល ទ្រង់ក៏ត្រាស់នឹងព្រះសារីបុត្រ ឬព្រះមោគ្គល្លាន ថា ចាប់ពីនេះទៅ ចូរពួកអ្នកសម្ដែងធម៌ ហើយទ្រង់លាតសុគតចីវរដោយព្រះអង្គឯងហើយផ្ទំ ។ ឈ្មោះថា កម្មចាស់ សូម្បីព្រះពុទ្ធក៏មិនរួចផុតបានឡើយ សមដូចព្រះមានព្រះភាគត្រាស់ថា

តថាគតបានហាមឃាត់[១] កូនអ្នកចំបាប់ ក្នុងកាលដែលគ្មានព្រះពុទ្ធត្រាស់ ដោយវិបាកនៃកម្មនោះ ជំងឺខ្នងក៏កើតឡើង ដល់តថាគត ។

ក្នុងរឿងទី ១២ គប្បីជ្រាបការមកដូចតទៅនេះថា

ការចុះឈាម ឈ្មោះថា ការចុះព្រះលោហិត ។ បានឮថា ក្នុងអតីតកាល ព្រះពោធិសត្វកើតក្នុងត្រកូលគហបតី ចិញ្ចឹមជីវិតដោយវេជ្ជកម្ម ព្រះពោធិសត្វនោះ កាលនឹងព្យាបាលបុត្ររបស់សេដ្ឋីម្នាក់ ដែលត្រូវរោគបៀតបៀន ទើបផ្សំថ្នាំព្យាបាល ។ សេដ្ឋីបុត្ត ព្រោះអាស្រ័យសេចក្ដីប្រមាទក្នុងការឲ្យទេយ្យធម៌ ទើបឲ្យឱសថមួយមុខទៀត ធ្វើឲ្យក្អួត និងរាក សេដ្ឋីបានឲ្យទ្រព្យជាច្រើន ។ ដោយវិបាកនៃកម្មនោះ ទើបព្រះពោធិសត្វ ត្រូវអាពាធដោយរោគចុះឈាម ក្នុងភពដែលកើតហើយរឿយៗ ក្នុងអត្តភាពចុងក្រោយនេះ ក្នុងបរិនិព្វានសម័យ ក៏មានការចុះព្រះលោហិត ក្នុងខណៈដែលសោយសូករមទ្ទវៈ ដែលនាយចុន្ទកម្មារបុត្តថ្វាយ មួយអន្លើដោយព្រះក្រយាហារដែលទេវតាក្នុងចក្កវាឡទាំងមូលដាក់ទិព្វឱជៈចូលទៅ ។ កម្លាំង

---

១- ច្បាស់ធជ្ជសន្តាយនា ជាបៀតបៀន ព្រោះបាលីថា និហេឋយឹ ។

ដីរ ១ សែនកោដិ ដល់នូវការអស់ទៅ ។ ក្នុងថ្ងៃ ១៥ កើត ខែពិសាខ ព្រះមានព្រះភាគយាងទៅ ដើម្បីបរិនិព្វានក្នុងនគរកុសិនារា ទ្រង់គង់ក្នុងទីប្រើនកន្លែង ទ្រង់ស្រេកទឹក ទ្រង់ផាន់ទឹក យាងដល់នគរកុសិនារា ដោយសេចក្ដីលំបាកពន់ពេក ហើយទ្រង់បរិនិព្វានក្នុងវេលាបច្ចូសសម័យថ្ងៃជិតរះ ។ ព្រះមានព្រះភាគជារបស់ត្រៃលោកបែបនេះ កម្មចាស់ ក៏មិនលះបង់ ។ សមដូចព្រះមានព្រះភាគត្រាស់ថា

តថាគតកើតជាពេទ្យ បានដាក់ថ្នាំបញ្ចុះសេដ្ឋីបុត្ត ដោយវិបាក
នៃកម្មនោះ ជំងឺចុះឈាម ក៏កើតឡើងដល់តថាគត ។
ព្រះជិនស្រី ទ្រង់ដល់នូវអភិញ្ញា និងពលទាំងពួង បានព្យាករ
ដោយសេចក្ដីពិស្ដារ ដល់ភិក្ខុសង្ឃ ជិតមហាស្រះឈ្មោះ
អនោតត្ត ដូចរៀបរាប់មកនេះឯង ដូច្នេះ ។

អបទានខាងអកុសល ឈ្មោះថា ចប់បរិបូណ៌ តាមមាតិកាដែលលោកឲ្យប្ដេជ្ញា ដោយប្រការដូច្នេះ ព្រោះហេតុនោះ ទើបលោកពោលថា **ឥត្ថំ សុទំ** ប្រែថា ដូច្នេះ គឺដោយប្រការដូច្នេះ បានដល់ ន័យដែលពោលហើយខាងដើម ។ សព្ទថា **សុទំ** ជានិបាត ចុះក្នុងអត្ថថា ធ្វើបទឲ្យពេញ ។

ព្រះមានព្រះភាគ ទ្រង់ដល់ព្រមដោយភាគធម៌ ជាព្រះមហាសត្វដែលបំពេញបារមីមកហើយ ទ្រង់ប្រកបដោយគុណយ៉ាងនេះ គឺ

ព្រះមានព្រះភាគ ទ្រង់មានជោគ ទ្រង់កាច់បំបាក់នូវកិលេស
ទ្រង់ប្រកបដោយភាគធម៌ទាំងឡាយ ទ្រង់ចែកធម៌ ជាអ្នកគប់រក

និងជាអ្នកខ្ជាក់ចោលនូវកិលេស ដែលជាគ្រឿងប្រព្រឹត្តទៅក្នុងភព ហេតុនោះ ទើបទ្រង់ព្រះនាមថា **ភគវា**។

ទ្រង់ជាទេវតា ក្រៃលែងជាងទេវតា ជាសក្កៈ ក្រៃលែងជាងសក្កៈ ទ្រង់ជាព្រហ្ម ក្រៃលែងជាងព្រហ្ម ទ្រង់ជាព្រះពុទ្ធក្រៃលែងជាងព្រះពុទ្ធ ព្រះមានព្រះភាគ ជាអ្នកមានមហាករុណាអង្គនោះ កាលឲ្យព្រះអានន្ទដឹង គឺកាលទ្រង់ធ្វើឲ្យប្រាកដនូវពុទ្ធចរិយា គឺហេតុដែលឲ្យបានជាព្រះពុទ្ធរបស់ព្រះអង្គ ទើបបានភាសិត គឺត្រាស់ធម្មបរិយាយ គឺព្រះសូត្រ គឺសុត្តន្តធម្មទេសនាឈ្មោះថា **ពុទ្ធាបទានិយ** គឺដែលឈ្មោះថាសូត្រប្រកាសហេតុនៃព្រះពុទ្ធដូច្នេះឯង ៕ល៚

## អដ្ឋកថាពុទ្ធាបទាន ចប់

# សុត្តន្តបិដក

## បច្ចេកពុទ្ធាបទានទី ២

អ្នកទាំងឡាយ ចូរស្តាប់បច្ចេកពុទ្ធាបទាន ដូចតទៅនេះ

[ ២ ] នតន្ទ: ជាអ្នកប្រាជ្ញ ជាបុត្តនៃនាងទេវី ក្នុងដែនវេទេហ: បានសួរព្រះតថាគត កាលគង់នៅក្នុងវត្តជេតពនថា ឮថា ព្រះបច្ចេកពុទ្ធទាំងឡាយ រមែងមាន តើព្រះបច្ចេកពុទ្ធ ជាអ្នកប្រាជ្ញទាំងនោះ រមែងកើតឡើងដោយហេតុដូចម្តេចខ្លះ ។ គ្រានោះ ព្រះសព្វញ្ញុពុទ្ធដ៏ប្រសើរ ព្រះអង្គស្វែងរកនូវគុណដ៏ធំ ទ្រង់បែរទៅត្រាស់នឹងព្រះអានន្ទដ៏ចម្រើន ដោយព្រះសូរសៀងដ៏ ពីរោះថា ពួកជនណា មានការកសាងបានធ្វើទុកហើយ ក្នុងសម្នាក់នៃព្រះពុទ្ធទាំងពួង តែមិនទាន់បានមោក្ខធម៌ ក្នុងសាសនានៃព្រះជិនស្រីទេ ។ ជនទាំងនោះ ជាអ្នកប្រាជ្ញ ជាអ្នកមានប្រាជ្ញាមុតថ្លា វៀរលែងតែព្រះពុទ្ធទាំងឡាយ រមែងបាននូវបច្ចេកពោធិញ្ញាណ ដោយប្រធាននៃសំវេគនោះផង ដោយអារម្មណ៍ដ៏ស្តើងស្តួចនោះផង ។ ក្នុងលោកទាំងមូល វៀរលែងតែតថាគតចេញ មិនមានបុគ្គលណាស្មើនឹងព្រះបច្ចេកពុទ្ធឡើយ តថាគតនឹងសម្តែងនូវគុណ ត្រឹមតែសង្ខេបនេះ របស់ព្រះបច្ចេកពុទ្ធទាំងឡាយនោះ ( អ្នកទាំងឡាយ ចូរស្តាប់នូវគុណ ) របស់ពួកព្រះបច្ចេកពុទ្ធ ជាមហាមុនី ដោយប្រពៃចុះ ។ អ្នកទាំងឡាយ កាលប្រាថ្នានូវភេសជ្ជៈដ៏ប្រសើរផុត គឺព្រះនិព្វាន ចូរមានចិត្តជ្រះថ្លាទាំងអស់គ្នា ស្តាប់នូវពាក្យដ៏ពីរោះ

ដូចជាទឹកឃ្មុំផ្អិត របស់ព្រះមហាឥសី ដែលត្រាស់ដឹងឯង ។ ព្រះបច្ចេកពុទ្ធទាំងឡាយ ដែលមកប្រជុំគ្នា មានព្យាករណ៍ មានទោស មានវត្ថុ នៃសេចក្តីសោយចិត្ត ទាំងមានហេតុដែលបានសម្រេចនូវពោធិញ្ញាណផ្សេងៗគ្នា ។ (ព្រះបច្ចេកពុទ្ធទាំងនោះ) មានសេចក្តីសម្គាល់ក្នុងការសោយចិត្ត ក្នុងវត្ថុដែលប្រកបដោយរាគៈ មានចិត្តសោយក្នុងលោក ដែលគេត្រេកត្រអាល លះបង់នូវបបញ្ចធម៌ និងកិលេសជាត ដែលញុំាងសត្វឲ្យអន្ទះសា ហើយបានសម្រេចនូវពោធិញ្ញាណក្នុងទីនោះឯង ។ បុគ្គលទម្លាក់ចោលនូវអាជ្ញា ចំពោះសត្វទាំងពួង មិនបៀតបៀននូវសត្វទាំងនោះ សូម្បីសត្វណាមួយទេ ទាំងជាអ្នកអនុគ្រោះ ចំពោះប្រយោជន៍ ដោយមេត្តាចិត្ត គប្បីប្រព្រឹត្តតែម្នាក់ឯង ដូចកុយរមាស ។ បុគ្គលទម្លាក់ចោលនូវអាជ្ញា ចំពោះពួកសត្វទាំងពួង មិនបៀតបៀនចំពោះសត្វទាំងនោះ សូម្បីសត្វណាមួយទេ មិនបានប្រាថ្នានូវបុត្ត ( ទៅហើយ ) តើនឹងប្រាថ្នានូវសម្លាញ់អំពីណា គប្បីប្រព្រឹត្តតែម្នាក់ឯង ដូចកុយរមាស ។ សេចក្តីស្រឡាញ់ របស់សត្វដែលនៅច្រឡូកច្រឡំគ្នា រមែងមានឯសេចក្តីទុក្ខនេះ មានឡើង ព្រោះអាស្រ័យសេចក្តីស្រឡាញ់ បុគ្គលកាលឃើញទោស ដែលកើតអំពីសេចក្តីស្រឡាញ់ គប្បីប្រព្រឹត្តតែម្នាក់ឯង ដូចកុយរមាស ។ បុគ្គលមានចិត្តជាប់ជំពាក់ កាលអនុគ្រោះចំពោះពួកមិត្ត និងសម្លាញ់ រមែងញុំាងប្រយោជន៍ឲ្យវិនាស

បុគ្គលកាលឃើញនូវភ័យ ក្នុងសេចក្តីស្និទ្ធស្នាលទុំះ គប្បីប្រព្រឹត្ត តែម្នាក់ឯង ដូចកុយរមាស ។ សេចក្តីស្រឡាញ់ក្នុងបុត្ត និងកិរិយា ដូចជាឫស្សីមានមែកចាក់កណ្តាញ់ បុគ្គលកាលមិនជាប់ជំពាក់ ដូច ជាទំពាំងឫស្សី គប្បីប្រព្រឹត្តតែម្នាក់ឯង ដូចកុយរមាស ។ ម្រឹគក្នុង ព្រៃ មិនជាប់ចំណង ដើរទៅរកចំណីតាមចំណង់បាន យ៉ាងណា វិញ្ញូជនកាល បើប្រាថ្នាសេរីភាព ( យ៉ាងនោះ ) គប្បីប្រព្រឹត្តតែម្នាក់ ឯង ដូចកុយរមាស ។ ការហៅរក រមែងមានក្នុងកណ្តាលនៃ សម្លាញ់ គឺក្នុងលំនៅ ក្នុងទីបម្រើ ក្នុងការដើរ ក្នុងការត្រាច់ចារិក បុគ្គលកាលប្រាថ្នានូវសេរីភាព ដែលពួកជនពាល មិនប្រាថ្នា គប្បី ប្រព្រឹត្តម្នាក់ឯង ដូចកុយរមាស ។ ល្បែង និងតម្រេក រមែងមានក្នុង កណ្តាលនៃសម្លាញ់ ទាំងសេចក្តីស្រឡាញ់ដ៏ធំទូលាយ រមែងមាន ក្នុងបុត្រទាំងឡាយ បុគ្គលកាលខ្ពើមរអើម ចំពោះការព្រាត់ប្រាស ចាកសត្វ និងសង្ខារជាទីស្រឡាញ់ គប្បីប្រព្រឹត្តតែម្នាក់ឯង ដូច កុយរមាស ។ បុគ្គលជាអ្នកនៅជាសុខ ក្នុងទិសទាំង ៤ មិនមាន ថ្នាំងថ្នាក់ចិត្ត ត្រេកអរក្នុងវត្ថុ តាមមានតាមបាន ជាអ្នកអត់ធន់ ចំពោះអន្តរាយ ជាអ្នកមិនតក់ស្លុត គប្បីប្រព្រឹត្តតែម្នាក់ឯង ដូចកុយ រមាស ។ បព្វជិតពួកខ្លះ ឬពួកគ្រហស្ថ ដែលនៅគ្រប់គ្រងផ្ទះខ្លះ គេ សង្គ្រោះបានដោយកម្រ បុគ្គលអ្នកមិនមានសេចក្តីខ្វល់ខ្វាយ ចំពោះ ពួកកូននៃបុគ្គលដទៃ គប្បីប្រព្រឹត្តតែម្នាក់ឯង ដូចកុយរមាស ។

វីរបុគ្គលលះបង់ នូវវត្ថុទាំងឡាយ ជាគ្រឿងប្រាកដរបស់គ្រហស្ថ កាត់បង់នូវចំណង របស់គ្រហស្ថទាំងឡាយ ដូចដើមរលួសផ្អុង ជម្រុះស្លឹក គប្បីប្រព្រឹត្តតែម្នាក់ឯង ដូចកុយរមាស ។ បើបុគ្គល បានសម្លាញ់ ជាអ្នកប្រាជ្ញ មានបញ្ញាខ្ជាប់ខ្ជួន ជាអ្នកប្រព្រឹត្តត្រូវគ្នា មានធម៌ជាគ្រឿងនៅដ៏ល្អ គប្បីជាអ្នកមានស្មារតី គ្របសង្កត់នូវ អន្តរាយទាំងពួង ហើយមានចិត្តរីករាយ ប្រព្រឹត្តជាមួយសម្លាញ់ នោះចុះ ។ បើបុគ្គលមិនបានសម្លាញ់ ជាអ្នកប្រាជ្ញ មានបញ្ញាខ្ជាប់ ខ្ជួន ជាអ្នកប្រព្រឹត្តត្រូវគ្នា មានធម៌ជាគ្រឿងនៅដ៏ល្អទេ គប្បីប្រព្រឹត្ត តែម្នាក់ឯង ដូចព្រះរាជាទ្រង់លះបង់នូវដែន ដែលទ្រង់ឈ្នះហើយ ឬដូចដំរីឈ្មោះមាតង្គៈ ( លះបង់នូវហ្វូងកាលត្រាច់ទៅ ) ក្នុងព្រៃ ។ តាមពិត យើងសរសើរ នូវការបរិបូណ៌ ដោយសម្លាញ់ហើយ តែ បុគ្គលគួរគប់រកសម្លាញ់ ដែលមានគុណប្រសើរជាងខ្លួន ឬសម្លាញ់ មានគុណស្មើនឹងខ្លួន បើរកមិនបាន ពួកសម្លាញ់ទាំងនុ៎ះទេ គប្បីជា អ្នកបរិភោគនូវបច្ចុប្បច្ច័យ ដែលមិនជាទោស ហើយប្រព្រឹត្តតែម្នាក់ ឯង ដូចកុយរមាស ។ បុគ្គលឃើញនូវកងមាសទាំងពីរ ដែលពួក ជាងមាសធ្វើសម្រេចល្អហើយ រណ្តំគ្នាត្រង់កដៃ គប្បីប្រព្រឹត្តតែ ម្នាក់ឯង ដូចកុយរមាស ។ ឯការច្រៀយច្រងដោយវាចាក្តី ការជាប់ ជំពាក់ក្តី ជាមួយនឹងបុគ្គលគម្រប់ពីររបស់អញ ដូចកងមាសមួយគូ មានយ៉ាងនុ៎ះ បុគ្គលកាលរំពឹងឃើញនូវភ័យនុ៎ះ ក្នុងកាលខាងមុខ

គប្បីប្រព្រឹត្តតែម្នាក់ឯង ដូចកុយរមាស ។ ពិតណាស់ កាមទាំងឡាយដ៏វិចិត្រ មានរសផ្អែម ជាទីរីករាយនៃចិត្ត រមែងញាំញីនូវចិត្ត ដោយសភាពដ៏ប្លែកៗ បុគ្គលឃើញទោស ក្នុងកាមគុណទាំងឡាយហើយ គប្បីប្រព្រឹត្តតែម្នាក់ឯង ដូចកុយរមាស ។ បុគ្គលឃើញនូវភ័យនុ៎ះ ក្នុងកាមគុណទាំងឡាយថា នេះជាចង្រៃ ជាបូស ជាឧបទ្រព ជារោគ ជាសរ ទាំងជាភ័យ របស់អញហើយ គប្បីប្រព្រឹត្តតែម្នាក់ឯង ដូចកុយរមាស ។ បុគ្គលគ្របសង្កត់ នូវសត្រូវទាំងអស់នុ៎ះ គឺត្រជាក់ ក្តៅ គម្លាន សម្រេក ខ្យល់ និងកម្តៅថ្ងៃ របោម និងសត្វលូនហើយ គប្បីប្រព្រឹត្តតែម្នាក់ឯង ដូចកុយរមាស ។ ដំរី មានខ្នងសមរម្យ មាំមួន មានសម្បុរដូចផ្កាឈូក កាលលះបង់ហ្វូងហើយ នៅក្នុងព្រៃ គួរដល់អធ្យាស្រ័យ យ៉ាងណា បុគ្គលគប្បីប្រព្រឹត្តតែម្នាក់ឯង ដូចកុយរមាស យ៉ាងនោះឯង ។ បុគ្គលបាននូវសាមយិកវិមុត្តិ ដោយហេតុណា ហេតុនោះមិនមែនជាទីតាំង នៃបុគ្គលអ្នកត្រេកអរក្នុងពួកទេ បុគ្គលពិចារណានូវពាក្យនៃព្រះពុទ្ធ ជាអាទិច្ចពន្ធុហើយ គប្បីប្រព្រឹត្តតែម្នាក់ឯង ដូចកុយរមាស ។ បុគ្គលកន្លងនូវចម្រូង គឺទិដ្ឋិ ដល់នូវធម៌ទៀង គឺមគ្គទី ១ មានមគ្គ ( ដ៏សេស ) បានហើយ មិនមានអ្នកដទៃដឹកនាំ ព្រោះដឹងថា អាត្មាអញមានញាណ កើតឡើងហើយ គប្បីប្រព្រឹត្តតែម្នាក់ឯង ដូចកុយរមាស ។ បុគ្គលមិនជាប់ចិត្ត ( ក្នុង

អាហារ ) មិនកុហក មិនស្រេកឃ្លាន មិនលុបគុណគេ កម្ចាត់បង់មោហៈ ដូចជាទឹកចត់ មិនមានទីអាស្រ័យនៅ គឺតណ្ហាក្នុងលោកទាំងពួងហើយ គប្បីប្រព្រឹត្តតែម្នាក់ឯង ដូចកុយរមាស ។ បុគ្គលគប្បីវៀរស្រឡះ នូវសម្លាញ់អាក្រក់ អ្នកមិនឃើញនូវសេចក្តីវិនាស អ្នកអាស្រ័យនៅក្នុងកម្មមិនស្មើ មិនគប្បីគប់រកនូវសម្លាញ់ដែលជាប់ជំពាក់ ដែលស្រវឹង ( ក្នុងកាមគុណ ) ដោយខ្លួនឯង គប្បីប្រព្រឹត្តតែម្នាក់ឯង ដូចកុយរមាស ។ បុគ្គលគប្បីគប់រកនូវបុគ្គល ជាពហូសូត អ្នកទ្រទ្រង់ធម៌ អ្នកប្រកបដោយគុណដ៏ក្រៃលែង មានប្រាជ្ញាវាងវៃ បុគ្គលដឹងច្បាស់ នូវប្រយោជន៍ទាំងឡាយ គួរបន្ទោបង់សេចក្តីសង្ស័យ គប្បីប្រព្រឹត្តតែម្នាក់ឯង ដូចកុយរមាស ។ បុគ្គលមិនអើពើ មិនអាឡោះអាល័យ នូវល្បែងផង តម្រេកផង កាមសុខក្នុងលោកផង ជាអ្នកវៀរស្រឡះចាកគ្រឿងស្អិតស្អាង អ្នកពោលនូវពាក្យសច្ចៈ គប្បីប្រព្រឹត្តតែម្នាក់ឯង ដូចកុយរមាស ។ បុគ្គលលះបង់នូវកាម ទាំងឡាយតាមចំណែក គឺបុត្រ ភរិយា បិតា មាតា ទ្រព្យសម្បត្តិ ស្រូវ អង្ករ និងផៅពង្សហើយ គប្បីប្រព្រឹត្តតែម្នាក់ឯង ដូចកុយរមាស ។ កាមគុណនេះជាគ្រឿងជាប់ជំពាក់ ឯសេចក្តីសុខ ក្នុងកាមនុ៎ះ មានប្រមាណតិច កាមគុណនុ៎ះ មានសេចក្តីត្រេកអរតិច បុគ្គលអ្នកមានគំនិតប្រាជ្ញាលុះដឹងច្បាស់ថា កាមគុណនុ៎ះ ដូចជាដំបៅពក ដូច្នេះហើយ គប្បី

ប្រព្រឹត្តតែម្នាក់ឯង ដូចកុយរមាស ។ បុគ្គលទម្លាយនូវសំយោជនៈ ដូចត្រីក្នុងទឹក ទម្លាយនូវសំណាញ់ មិនត្រឡប់មករកសំយោជនៈវិញ ដូចភ្លើងឆេះ ( មិនត្រឡប់វិញ ) គប្បីប្រព្រឹត្តតែម្នាក់ឯង ដូចកុយរមាស ។ បុគ្គលមានចក្ខុដាក់ចុះ មានជើងមិនរពឹស ជាអ្នកគ្រប់គ្រងឥន្ទ្រិយ រក្សាចិត្តទុក ( ដោយល្អ ) មិនជោកជាំ មិនរោលរាល ( ដោយកិលេស ) គប្បីប្រព្រឹត្តតែម្នាក់ឯង ដូចកុយរមាស ។ បុគ្គលលះ បង់នូវភេទគ្រហស្ថ ដូចដើមបារិច្ឆត្តព្រឹក្ស ដែលមានស្លឹកដាច់ហើយ មានសំពត់កាសាយៈ ចេញបួសហើយ គប្បីប្រព្រឹត្តតែម្នាក់ឯង ដូចកុយរមាស ។ បុគ្គលមិនធ្វើនូវសេចក្តីប្រាថ្នា ក្នុងរសទាំងឡាយ ជាអ្នកមិនល្មោភ មិនចិញ្ចឹមនូវបុគ្គលដទៃ ជាអ្នកត្រាច់ទៅសព្វច្រក មិនជាប់ចិត្ត ក្នុងត្រកូលមួយៗ គប្បីប្រព្រឹត្តតែម្នាក់ឯង ដូចកុយរមាស ។ បុគ្គលលះបង់ នូវហេតុជាគ្រឿងរាំង ៥ យ៉ាងរបស់ចិត្ត បន្ទោបង់នូវឧបក្កិលេសទាំងពួងទាំងមិនអាស្រ័យ ( ដោយតណ្ហា និងទិដ្ឋិ ) កាត់បង់នូវទោសនៃសេចក្តីស្រឡាញ់ហើយ គប្បីប្រព្រឹត្តតែម្នាក់ឯង ដូចកុយរមាស ។ បុគ្គលធ្វើនូវសុខ ទុក្ខ សោមនស្ស និងទោមនស្ស ក្នុងកាលមុនឲ្យនៅពីក្រោយខ្នង បាននូវឧបេក្ខា ជាសមថៈដ៏ស្អាត គប្បីប្រព្រឹត្តតែម្នាក់ឯង ដូចកុយរមាស ។ បុគ្គលប្រារព្ធព្យាយាម ដើម្បីដល់នូវព្រះនិព្វាន មានចិត្តមិនរួញរា មានការប្រព្រឹត្តមិនខ្ជិលច្រអូស

មានសេចក្តីប្រឹងប្រែងដ៏មាំមួន ប្រកបដោយកម្លាំងកាយ និងកម្លាំងបញ្ញាហើយ គប្បីប្រព្រឹត្តតែម្នាក់ឯង ដូចកុយរមាស ។ បុគ្គលកាលមិនលះបង់ នូវឈានដ៏ស្ងប់ស្ងាត់ ( ចាកសត្វ និងសង្ខារ ) ជាអ្នកប្រព្រឹត្តនូវធម៌ ដ៏សមគួរក្នុងធម៌ទាំងឡាយ អស់កាលជានិច្ច ពិចារណានូវទោសក្នុងភពទាំងឡាយហើយ គប្បីប្រព្រឹត្តតែម្នាក់ឯង ដូចកុយរមាស ។ បុគ្គលកាលប្រាថ្នា នូវការអស់តណ្ហា ជាអ្នកមិនប្រហែស មិនល្ងង់ មានការចេះដឹង មានស្មារតី មានធម៌ពិចារណាហើយ ជាបុគ្គលទៀង មានសេចក្តីខ្មីឃ្មាត គប្បីប្រព្រឹត្តតែម្នាក់ឯង ដូចកុយរមាស ។ បុគ្គល កាលមិនតក់ស្លុត ក្នុងលក្ខណៈមានមិនទៀងជាដើម ដូចសីហៈ មិនតក់ស្លុតក្នុងសំឡេងទាំងឡាយ មិនជាប់ជំពាក់ក្នុងធម៌ទាំងឡាយ មានខន្ធជាដើម ដូចខ្យល់មិនជាប់នឹងសំណាញ់ មិនប្រឡាក់ដោយលោកៈជាដើម ដូចស្លឹកឈូក មិនប្រឡាក់ដោយទឹក គប្បីប្រព្រឹត្តតែម្នាក់ឯង ដូចកុយរមាស ។ សីហៈ ជាស្តេចសត្វ មានចង្កូមជាកម្លាំង ប្រព្រឹត្តគ្របសង្កត់ កំហែងនូវពួកម្រឹគ យ៉ាងណា បុគ្គលគប់រកនូវសេនាសនៈដ៏ស្ងាត់ ( មានព្រៃជាគ្រឿងអាង ) ក៏យ៉ាងនោះដែរ គប្បីប្រព្រឹត្តតែម្នាក់ឯង ដូចកុយរមាស ។ បុគ្គលកាលចម្រើននូវមេត្តា ឧបេក្ខា ករុណា និងមុទិតា ជាហេតុរួចចាកកិលេស ក្នុងកាលដ៏គួរ មិនទាស់នឹងសព្វានឹងលោកទាំងពួង គប្បីប្រព្រឹត្តតែម្នាក់ឯង ដូចកុយ

រមាស ។ បុគ្គលលះបង់នូវរាគៈផង ទោសៈផង មោហៈផង ហើយ ទម្លាយចេញនូវសំយោជនៈ មិនតក់ស្លុត ក្នុងការអស់ទៅនៃជីវិតហើយ គប្បីប្រព្រឹត្តតែម្នាក់ឯង ដូចកុយរមាស ។ ពួកជនមានប្រយោជន៍ជាហេតុ ទើបគប់រកផង បម្រើផង ឯពួកមិត្តដែលឥតហេតុ គេរកបានដោយក្រ ក្នុងថ្ងៃនេះ ឯពួកមនុស្សអ្នកមានបញ្ញា ប្រាថ្នាប្រយោជន៍ផ្ទាល់ខ្លួន ឈ្មោះថា ជាមនុស្សមិនស្អាត បុគ្គលគប្បីប្រព្រឹត្តតែម្នាក់ឯង ដូចកុយរមាស ។ ពួកព្រះបច្ចេកពុទ្ធ មានសីលបរិសុទ្ធ មានប្រាជ្ញាបរិសុទ្ធល្អ មានចិត្តតម្កល់មាំ ប្រកបរឿយៗ នូវព្យាយាមជាគ្រឿងភ្ញាក់រឭក អ្នកពិចារណានូវសង្ខារ ឃើញនូវធម៌ដ៏វិសេស ដឹងច្បាស់នូវធម៌ ដែលជាអង្គនៃមគ្គ និងពោជ្ឈង្គ ។ ពួកជន ជាអ្នកប្រាជ្ញណា ចម្រើននូវសុញ្ញតវិមោក្ខ អប្បណិហិតវិមោក្ខ និងអនិមិត្តវិមោក្ខ ក្នុងសាសនានៃព្រះជិនស្រីហើយ តែមិនសម្រេចនូវភាពជាសាវ័កទេ ពួកជនជាអ្នកប្រាជ្ញនោះ គង់បានជាព្រះបច្ចេកពុទ្ធ ត្រាស់ដឹងឯង ។ ពួកជននោះ ជាអ្នកមានធម៌ដ៏ច្រើន មានធម្មកាយដ៏សម្បូណ៌ មានចិត្តជាធំ ឆ្លងនូវទុក្ខនិងឱឃៈទាំងពួង មានចិត្តខ្ពង់ខ្ពស់ផុត ជាអ្នកឃើញ នូវប្រយោជន៍ដ៏ក្រៃលែង គឺព្រះនិព្វាន មានឧបមាដូចសីហៈ ( តែងប្រព្រឹត្តតែម្នាក់ឯង ) ដូចកុយរមាស ។ ព្រះបច្ចេកពុទ្ធទាំងឡាយ ជាបុគ្គលមានឥន្ទ្រិយស្ងប់ មានចិត្តស្ងប់ស្ងាត់ មានចិត្តជាសមាធិ

ប្រព្រឹត្តដោយប្រាជ្ញា ចំពោះសត្វក្នុងទីបំផុតដែន ដូចប្រទីបចុះបំភ្លឺក្នុងលោកខាងមុខ និងលោកនេះ ជាអ្នកប្រតិបត្តិដើម្បីប្រយោជន៍ដល់ពួកសត្វ ។ ព្រះបច្ចេកពុទ្ធទាំងឡាយ ជាធំជាងជន លះកិលេស ជាគ្រឿងរារាំងទាំងពួងហើយ ជាប្រទីបនៃលោក មានរស្មីដូចមាសដុំ ជាទក្ខិណេយ្យបុគ្គលដ៏ល្អ របស់សត្វលោកដោយឥតសង្ស័យ ជាបុគ្គលសម្រេចដោយនិរោធសមាបត្តិ ជារឿយៗ ។ សុភាសិតរបស់ព្រះបច្ចេកពុទ្ធទាំងឡាយ រមែងប្រព្រឹត្តទៅក្នុងមនុស្សលោក ព្រមទាំងទេវលោក ពួកជនពាលណា ស្ដាប់ហើយ តែមិនបានធ្វើតាមសុភាសិត មានសភាពដូច្នោះទេ ពួកជនពាលនោះឯង រមែងធ្លាក់ទៅវដ្ដទុក្ខទាំងឡាយរឿយៗ ។ សុភាសិតរបស់ព្រះបច្ចេកពុទ្ធទាំងឡាយ ផ្អែមល្ហែម ដូចទឹកឃ្មុំផ្អិតដែលហូរចុះ ពួកជនណា បានស្ដាប់ហើយ ប្រកបនូវសេចក្ដីប្រតិបត្តិតាមយ៉ាងនោះ ពួកជននោះ ប្រកបដោយប្រាជ្ញា រមែងឃើញនូវសច្ចធម៌ ។ គាថាដ៏ខ្ពង់ខ្ពស់ណា ដែលព្រះបច្ចេកពុទ្ធទាំងឡាយ ជាអ្នកឈ្នះកិលេស សម្ដែងហើយនោះ ព្រះសម្ពុទ្ធជាសីហៈ ក្នុងសក្យវង្សទ្រង់ខ្ពង់ខ្ពស់ជាងជន ទ្រង់ចេញបព្វជ្ជាហើយ បានប្រកាសទុក

ដើម្បីការដឹងច្បាស់នូវធម៌ ។ សុភាសិតទាំងនេះ ដែលព្រះបច្ចេក-ពុទ្ធទាំងនោះ សម្តែងផ្សេងៗ គ្នា ដើម្បីអនុគ្រោះ ដល់សត្វលោក ព្រះសយម្ភូ ដូចជាសីហៈ ទ្រង់ប្រកាសទុកហើយ ដើម្បីញុំាង សំវេគធម៌ សង្គហធម៌ និងឧបាយប្រាជ្ញា ឲ្យចម្រើនឡើង ។

បច្ចេកពុទ្ធាបទាន ចប់

# អដ្ឋកថា

## បច្ចេកពុទ្ធាបទានទី ២

[ ២ ] ព្រះអានន្ទត្ថេរ កាលសំដែងនូវអបទាន បន្ទាប់អំពីពុទ្ធាបទាន នោះតទៅ កាលព្រះមហាកស្សបត្ថេរសួរថា នែអាវុសោអានន្ទ បច្ចេកពុទ្ធាបទាន ព្រះមានព្រះភាគទ្រង់បញ្ញត្តក្នុងទីណា ទើបពោលថា អ្នកទាំងឡាយ ចូរស្តាប់បច្ចេកពុទ្ធាបទានដូចតទៅជាដើម ។ អត្ថ របស់ពាក្យថា អបទានរបស់ព្រះបច្ចេកសម្ពុទ្ធទាំងនោះ បានពោលហើយខាងដើមនោះឯង ។

ព្រះថេរៈកាលប្រកាសបទដែលពោលថា **សុណាថ** ដោយអំណាចនៃអត្ថុប្បត្តិហេតុ ទើបពោលពាក្យថា **តថាគតំ ជេតវនេ វសន្តំ** ដូច្នេះជាដើម ។ ក្នុងបទទាំងនោះ បទថា **វសន្តំ** ប្រែថា ដែលគង់នៅក្នុងវត្ត ដែលមានឈ្មោះបែបនោះ តាមព្រះនាមរបស់ជេតរាជកុមារ ដោយឥរិយាបថវិហារទាំង ៤ ឬដោយទិព្វវិហារ ព្រហ្មវិហារ និងអរិយវិហារ ។ ព្រះពុទ្ធទាំងឡាយដែលមានក្នុងកាលមុន មានព្រះវិបស្សីជាដើម ទ្រង់បំពេញបារមី ៣០ ហើយយាងមកដោយប្រការណា ព្រះមានព្រះភាគនៃយើងទាំងឡាយ ក៏យាងមកហើយដោយប្រការនោះ ព្រោះហេតុនោះ ទើបឈ្មោះថា **តថាគត** ភ្ជាប់សេចក្តីថា ព្រះតថាគតអង្គនោះ ប្រថាប់នៅក្នុងវត្តជេតពនវិហារ ។

បទថា **វេទេហមុនី** សេចក្តីថា ព្រះទេវីដែលកើតក្នុងដែនវេទេហៈ ទើបឈ្មោះថា **វេទេហី** ឱរសរបស់ព្រះនាងវេទេហី ទើបឈ្មោះថា **វេទេហិបុត្ត** ។

ញាណ លោកហៅថា **មោន** អ្នកទៅ គឺដើរទៅ បានដល់ ប្រកប

ដោយមោនៈនោះ ព្រោះហេតុនោះ ទើបឈ្មោះថា **មុនិ** ។ ព្រះអានន្ទនោះ ជាបុត្តរបស់ព្រះនាងវេទេហីផង ជាមុនីផង ព្រោះហេតុនោះ ទើបឈ្មោះថា **វេទេហមុនិ** ព្រោះកាលគួរពោលថា **វេទេហិបុត្តមុនិ**ដោយព្រោះផ្លាស់ **ឥ** ជា **អ** និងលុប **បុត្ត** សព្ទចេញ ដោយនិរុត្តិន័យថា ចុះតួអក្ខរៈប្ញីជាដើម ភ្ជាប់សេចក្ដីថា ព្រះអានន្ទដែលព្រះមានព្រះភាគ ទ្រង់តាំងទុកក្នុងឯតទគ្គៈថា ម្នាលភិក្ខុទាំងឡាយ បណ្ដាពួកភិក្ខុអ្នកចេះដឹងច្រើន ពួកភិក្ខុអ្នកមានស្មារតី ពួកភិក្ខុអ្នកមានគតិ ពួកភិក្ខុអ្នកមានប្រាជ្ញា ពួកភិក្ខុជាឧបដ្ឋាក ដែលជាសាវករបស់តថាគត ស្រេចនឹងអានន្ទប្រសើរជាងគេ ដូច្នេះ បង្អោនកាយចុះ គឺបង្អោនចំណែករបស់កាយចុះ ធ្វើអញ្ជលី បានទូលសួរថា បពិត្រព្រះអង្គដ៏ចម្រើន ឈ្មោះថា ព្រះបច្ចេកសម្ពុទ្ធទាំងឡាយ ដូចម្ដេច ព្រះបច្ចេកសម្ពុទ្ធទាំងនោះ រមែងមាន គឺរមែងកើតឡើង ដោយហេតុអ្វី ព្រះថេរៈហៅព្រះមានព្រះភាគថា **វីរ**(១) ។

១- បិដកខ្មែរជា ធីរ ។

ខាងមុខអំពីនោះ ព្រះអានន្ទត្ថេរ កាលសម្ដែងអាការដែលព្រះមានព្រះភាគទ្រង់វិសជ្ជនា ទើបពោលពាក្យថា គ្រានោះ ព្រះសព្វញ្ញុពុទ្ធដ៏ប្រសើរជាដើម ។ ឈ្មោះថា **សព្វញ្ញូ** ព្រោះទ្រង់ដឹងវត្ថុទាំងពួង ដូចជាវត្ថុដែលជាអតីតជាដើម ដូចផ្លែកន្ទួតព្រៃក្នុងដៃ ។ ឈ្មោះថា **សព្វញ្ញុវរោ** ព្រោះព្រះសព្វញ្ញូអង្គនោះប្រសើរ និងឧត្ដម ។ ឈ្មោះថា **មហេសី** ព្រោះស្វែងរកគុណ គឺសីល សមាធិ បញ្ញា វិមុត្តិ និងវិមុត្តិញាណទស្សនៈដ៏ធំ ភ្ជាប់សេចក្ដីថា

ក្នុងកាលនោះ គឺក្នុងកាលដែលត្រូវសួរនោះ ព្រះមានព្រះភាគត្រាស់ប្រាប់ គឺត្រាស់ប្រាប់ព្រះអានន្ទត្ថេរដោយព្រះសូរសៀងដ៏ពីរោះ អធិប្បាយថា ម្នាលអានន្ទដ៏ចម្រើន ជនពួកណា គឺព្រះបច្ចេកសម្ពុទ្ធពួកណា សន្សំបុញ្ញាធិការ គឺធ្វើនូវបុញ្ញសម្ភារ ក្នុងសម្នាក់នៃព្រះពុទ្ធទាំងពួង គឺក្នុងអតីតពុទ្ធទាំងឡាយកាលមុន តែមិនទាន់បានមោក្ខធម៌ក្នុងសាសនានៃព្រះជិនស្រីទេ គឺមិនទាន់សម្រេចព្រះនិព្វាន ជនទាំងនោះ គឺព្រះបច្ចេកពុទ្ធទាំងអស់ជាអ្នកប្រាជ្ញ ធ្វើបុគ្គលណាម្នាក់ឲ្យជាប្រធាន ដោយសេចក្តីសង្វេគ ទើបបានជាព្រះបច្ចេកពុទ្ធក្នុងលោកនេះ ។ បុគ្គលមានបញ្ញាមុតថ្លាល្អ គឺមានបញ្ញារឹងប៉ឹងដោយល្អ ទោះបីមិនមានព្រះពុទ្ធទាំងឡាយ គឺទោះបីវៀរចាកឱវាទានុសាសនីរបស់ព្រះពុទ្ធទាំងឡាយ ក៏រមែងសម្រេច គឺរមែងដឹងច្បាស់នូវបច្ចេកពោធិញ្ញាណ គឺពោធិចំពោះមួយអង្គឯង បានដល់ ពោធិ ដែលនៅក្នុងរវាងរបស់ព្រះសម្មាសម្ពុទ្ធទាំងឡាយ ដោយអារម្មណ៍បន្តិចបន្តួច គឺមានប្រមាណតិច ។

ក្នុងលោកទាំងមូល គឺក្នុងត្រៃលោកទាំងមូល វៀរលែងតែតថាគត គឺវៀរនូវតថាគតចេញ មិនមានបុគ្គលណាស្មើនឹងព្រះបច្ចេកពុទ្ធឡើយ បានដល់ មិនមានបុគ្គលដូច ។ តថាគតនឹងសម្តែង អធិប្បាយថា នឹងប្រាប់នូវគុណនេះ គឺគុណសម្បត្តិនេះ របស់ព្រះបច្ចេកសម្ពុទ្ធដែលជាមហាមុនីទាំងនោះ ត្រឹមតែសង្ខេបនេះ គឺត្រឹមចំណែកសង្ខេបដោយល្អ គឺយ៉ាងល្អ ដល់អ្នកទាំងឡាយ ។

អ្នកទាំងឡាយកាលប្រាថ្នា គឺត្រូវការព្រះនិព្វាន ដែលជាភេសជ្ជៈ គឺជា

ថ្នាំដ៏ប្រសើរបំផុត គឺមិនមានវត្ថុដែលក្រៃលែងជាង ចូរមានចិត្តជ្រះថ្លា គឺចូរមានចិត្តថ្លាស្អាត ចូរស្តាប់ គឺចូរដាក់ចិត្តនូវពាក្យ គឺពាក្យឧទានដ៏ពីរោះ គឺផ្អែមដូចទឹកឃ្មុំ គឺដូចទឹកឃ្មុំតូចរបស់ព្រះបច្ចេកពុទ្ធ អ្នកស្វែងរកគុណធំ ក្នុងវាងឥសីទាំងឡាយ ជាអ្នកមិនមានអាចារ្យ ដែលត្រាស់ដឹងឯង គឺដឹងច្បាស់ដោយខ្លួនឯង ។

បទថា **បច្ចេកពុទ្ធានំ សមាគតានំ** បានដល់ ព្រះបច្ចេកសម្ពុទ្ធទាំងឡាយដែលរួមគ្នាជាក្រុម គឺកើតឡើងហើយ អធិប្បាយថា ការព្យាករណ៍បន្តៗ គ្នាមក គឺចំពោះមួយអន្លៗ ទាំងឡាយណា ដែលជាអបទានរបស់បច្ចេកសម្ពុទ្ធ ១០០ អន្ល គឺអរិដ្ឋៈ ឧបរិដ្ឋៈ តគរសិខី យសស្សី សុទស្សនៈ បីយទស្សី គន្ធារៈ បិណ្ឌោល ឧបាសកៈ និថៈ តថៈ សុតវា ភាវិតត្តៈ សុម្ភៈ សុភៈ មេថុលៈ អដ្ឋមៈ សុមេធៈ អនីឃៈ សុទាឋៈ ហិង្គុ ហិង្គៈ ទ្វេជាលិនៈ អដ្ឋកៈ កោសលៈ សុពាហុ ឧបនេមិសៈ សន្តចិត្តៈ សច្ចៈ តថៈ វិរជៈ បណ្ឌិតៈ កាលៈ ឧបកាលៈ វិជិតៈ ជិតៈ អង្គៈ បង្គៈ គុត្តិជិតៈ បស្សី ជហី ឧបធិ ទុក្ខមូលៈ អបរាជិតៈ សរភង្គៈ លោមហំសៈ ឧច្ចង្គមាយៈ អសិតៈ អនាសវៈ មនោមយៈ មានច្ឆិទៈ ពន្ធុមៈ តទាធិមុត្តៈ វិមលៈ កេតុមា កេតុម្ពរង្គៈ មាតង្គៈ អរិយៈ អច្ចុតៈ អច្ចុតគាមី ព្យាមកៈ សុមង្គលៈ ទិព្វិលៈជាដើម ។ ម្យ៉ាងទៀត អាទីនវៈ គឺទោសណា វិភវវត្ថុ គឺវត្ថុនៃសេចក្តីសោយចិត្តណា ព្រះបច្ចេកសម្ពុទ្ធទាំងឡាយ ដែលសម្រេចនូវពោធិញាណ គឺធ្វើមគ្គញាណ ៤ ឲ្យប្រចក្សបានដោយប្រការណា គឺដោយ

ហេតុណា ព្រះបច្ចេកពុទ្ធទាំងនោះ មានសេចក្តីសម្គាល់ ក្នុងការសោយចិត្ត ក្នុងវត្ថុដែលប្រកបដោយរាគៈថា ប្រាសចាករាគៈ គឺសញ្ញាក្នុងវិរាគៈ ក្នុងវត្ថុដែលមានរាគៈ គឺក្នុងវត្ថុដែលគប្បីប្រកាន់ស្អិត បានដល់ ក្នុងវត្ថុកាម និងកិលេសកាមទាំងឡាយ មានចិត្តសោយក្នុងលោក ដែលគេត្រេកត្រអាល គឺក្នុងលោកដែលមានសភាវៈជាគ្រឿងប្រកាន់ លះនូវធម៌ជាគ្រឿងយឺតយូរ គឺលះកិលេស ពោល គឺគ្រឿងយឺតយូរ បានដល់ គ្រឿងយឺតយូរ គឺរាគៈ គ្រឿងយឺតយូរ គឺទោសៈ គ្រឿងយឺតយូរ គឺកិលេសទាំងពួង ឈ្មោះនូវទិដ្ឋិដែលជាហេតុឲ្យអន្ទះអន្ទែង គឺឈ្មោះទិដ្ឋិ ៦២ ដែលអន្ទះអន្ទែង ហើយបានសម្រេចនូវពោធិញ្ញាណយ៉ាងនោះ គឺធ្វើបច្ចេកពោធិញ្ញាណឲ្យប្រចក្សយ៉ាងនោះ គឺដោយហេតុនោះ ។

បទថា **សព្វេសុ ភូតេសុ និធាយ ទណ្ឌំ** សេចក្តីថា ដាក់ គឺវៀរចាកការសម្លុតគំរាម ការទម្វាយ ការសម្លាប់ និងការចង មិនបៀតបៀនសត្វណាមួយ គឺសត្វណាសូម្បីតែមួយ ក្នុងរវាងសត្វទាំងពួងនោះ គឺមិនធ្វើឲ្យលំបាក មានចិត្តប្រកបដោយមេត្តា គឺមានចិត្តសហគតៈដោយមេត្តាថា សត្វទាំងពួង ចូរមានសេចក្តីសុខ ទាំងជាអ្នកអនុគ្រោះចំពោះប្រយោជន៍ដោយចិត្ត គឺមានសេចក្តីអនុគ្រោះ ដោយប្រយោជន៍ដែលជាសភាវៈ ។ ម្យ៉ាងទៀត បទថា **សព្វេសុ** នេះ ក្នុងបទថា **សព្វេសុ ភូតេសុ និធាយ ទណ្ឌំ** ជាបទចង្អុលបង្ហាញ គឺការរួមយកទាំងអស់ មិនសេសសល់ ។ ក្នុងបទថា **ភូតេសុ** គប្បីជ្រាបដូច្នេះថា សត្វដែលតក់ស្លុត និងសត្វដែលមិនតក់ស្លុត ហៅថា

**ភូត** ។ សត្វទាំងឡាយណា លះនូវតណ្ហា ដែលធ្វើឲ្យតក់ស្លុតមិនបាន ទាំងលះនូវភ័យ និងការខ្លាចមិនបាន សត្វទាំងនោះ ឈ្មោះថា តក់ស្លុត ព្រោះហេតុអ្វី ទើបហៅថា តក់ស្លុត សត្វពួកណា រមែងតក់ស្លុត គឺតក់ស្លុតឡើងតក់ស្លុតជុំវិញ រមែងខ្លាច រមែងដល់នូវការតក់ស្លុតព្រម ព្រោះហេតុនោះទើបសត្វទាំងនោះ លោកហៅថា ជាអ្នកតក់ស្លុត សត្វពួកណា លះនូវតណ្ហា ដែលធ្វើឲ្យតក់ស្លុតបាន ទាំងលះភ័យ និងការខ្លាចបាន សត្វទាំងនោះឈ្មោះថា ជាអ្នកមិនតក់ស្លុត ព្រោះហេតុអ្វី ទើបហៅថា ជាអ្នកមិនតក់ស្លុត សត្វពួកណា រមែងមាំទាំ គឺមិនតក់ស្លុត មិនតក់ស្លុតឡើង មិនតក់ស្លុតដោយជុំវិញ មិនខ្លាច មិនដល់នូវការតក់ស្លុតព្រម ព្រោះហេតុនោះ ទើបសត្វទាំងនោះ លោកហៅថា ជាអ្នកមិនតក់ស្លុត ។

អាជ្ញាមាន ៣ យ៉ាង គឺកាយអាជ្ញា វចីអាជ្ញា និងមនោអាជ្ញា ។ កាយទុច្ចរិត ៣ ឈ្មោះថា កាយអាជ្ញា វចីទុច្ចរិត ៤ ឈ្មោះថា វចីអាជ្ញា មនោទុច្ចរិត ៣ ឈ្មោះថា មនោអាជ្ញា ។ ដាក់ គឺទម្លាក់ចុះ លើកចុះ លើកចុះព្រម ដាក់ទុក គឺរម្ងាប់អាជ្ញា ៣ យ៉ាងនោះក្នុងភូត គឺសត្វទាំងពួង គឺទាំងអស់ បានដល់ មិនកាន់យកអាជ្ញាដើម្បីបៀតបៀន ព្រោះហេតុនោះ ទើបឈ្មោះថា ដាក់ចុះនូវអាជ្ញាក្នុងសត្វទាំងពួង ។ បទថា **អវិហេឋយំ អញ្ញតរម្បិ តេសំ** សេចក្តីថា មិនបៀតបៀនសូម្បីសត្វមួយដោយបាតដៃ ឬដុំដី ដំបងសស្ត្រា ខ្នោះ ខ្សែ មិនបៀតបៀនសត្វគ្រប់ប្រភេទ ដោយបាតដៃ ដុំដីដំបង សស្ត្រា ខ្នោះ ខ្សែ គឺមិនបៀតបៀន សត្វទាំងនោះ សូម្បីតែមួយ ។

សព្វថា **ន** ក្នុងបទថា **ន បុត្តមិច្ឆេយ្យ កុតោ សហាយំ** ជាពាក្យបដិសេធ ។ ក្នុងបទថា **បុត្តំ** សេចក្តីថា កូនមាន ៤ ប្រភេទ គឺកូនដែលកើតក្នុងខ្លួន ១ កូនដែលកើតក្នុងខេត្ត ១ កូនដែលគេឲ្យ ១ កូន គឺអន្តេវាសិក ១ ។

ក្នុងបទថា **សហាយំ** គប្បីជ្រាបថា ការមក ការទៅ ការឈរ ការអង្គុយ ការហៅរក ការចរចា ការសន្ទនាជាមួយបុគ្គលណា ជាផាសុកបុគ្គលនោះ លោកហៅថា សម្លាញ់ ។ បទថា **ន បុត្តមិច្ឆេយ្យ កុតោ សហាយំ** សេចក្តីថា សូម្បីបុត្តក៏មិនចង់បាន មិនត្រេកអរ មិនប្រាថ្នា មិនត្រូវការ មិនចង់មាន ធ្វើម្តេចចង់បាន ត្រេកអរ ប្រាថ្នា ត្រូវការ ចង់មានមិត្តបុគ្គលដែលស្និទ្ធស្នាល បុគ្គលដែលទើបតែស្និទ្ធស្នាល ឬសម្លាញ់នោះ ព្រោះហេតុនោះ ឈ្មោះថា មិនប្រាថ្នាសូម្បីតែបុត្ត តើនឹងត្រូវការសម្លាញ់មកអំពីណា ។

បទថា **ឯកោ ចរេ ខគ្គវិសាណកប្បោ** សេចក្តីថា ព្រះបច្ចេកពុទ្ធនោះឈ្មោះថា ជាបុគ្គលម្នាក់ឯង ព្រោះចំណែកបព្វជ្ជា ជាបុគ្គលម្នាក់ឯង ព្រោះអត្ថថា មិនមានបុគ្គលជាគម្រប់ពីរ ជាបុគ្គលម្នាក់ឯង ព្រោះអត្ថថា លះបង់តណ្ហា ជាបុគ្គលម្នាក់ឯង ព្រោះហេតុប្រាសចាករាគៈ ដោយដាច់ខាត ជាបុគ្គលម្នាក់ឯង ព្រោះហេតុប្រាសចាកទោសៈ ដោយដាច់ខាត ជាបុគ្គលម្នាក់ឯង ព្រោះហេតុប្រាសចាកមោហៈ ដោយដាច់ខាត ជាបុគ្គលម្នាក់ឯង ព្រោះហេតុមិនមានកិលេស ដោយដាច់ខាត ជាបុគ្គលម្នាក់ឯង ព្រោះហេតុទៅកាន់

ផ្លូវជាទីទៅតែម្នាក់ឯង ជាបុគ្គលម្នាក់ឯង ព្រោះហេតុត្រាស់ដឹងនូវបច្ចេកសម្ពោធិដ៏ប្រសើរ តែម្នាក់ឯង ។

ព្រះបច្ចេកសម្ពុទ្ធនោះ ឈ្មោះថា ជាបុគ្គលម្នាក់ឯង ព្រោះចំណែកបព្វជ្ជា តើដូចម្ដេច ។ ព្រះបច្ចេកសម្ពុទ្ធនោះ ទ្រង់កាត់បលិពោធក្នុងឃរាវាស កាត់បលិពោធក្នុងបុត្ត និងភរិយា កាត់បលិពោធក្នុងញាតិ កាត់បលិពោធក្នុងការសន្សំ កោរសក់ ពុកមាត់ និងពុកចង្កា ស្លៀកដណ្ដប់សំពត់កាសាយៈ ចេញចាកផ្ទះចូលទៅកាន់ផ្នួស ដល់នូវភាពមិនមានកង្វល់ ជាបុគ្គលម្នាក់ឯង ចរទៅ ត្រាច់ទៅ ប្រព្រឹត្ត រក្សា យាត្រា ឲ្យយាត្រាទៅ ហេតុនោះ ព្រះបច្ចេកសម្ពុទ្ធនោះ ឈ្មោះថា ជាបុគ្គលម្នាក់ឯង ព្រោះចំណែកបព្វជ្ជាយ៉ាងនេះ ។

ព្រះបច្ចេកសម្ពុទ្ធនោះ ជាបុគ្គលម្នាក់ឯង ព្រោះអត្ថថា មិនមានបុគ្គលជាគម្រប់ពីរ តើដូចម្ដេច ។ ព្រះបច្ចេកសម្ពុទ្ធនោះ កាលបួសយ៉ាងនេះហើយ ជាបុគ្គលម្នាក់ឯង គប់រកសេនាសនៈដ៏ស្ងាត់ គឺព្រៃរបោះ និងព្រៃញាតស្បាត ជាទីមិនមានសំឡេង មិនមានសំឡេងគឹកកង ប្រាសចាកខ្យល់ដែលកើតអំពីសរីរៈមនុស្ស ជាទីស្ងាត់កំបាំងរបស់មនុស្ស សមគួរដល់ទីពួនសម្ងំ លោកដើរទៅម្នាក់ឯង ឈរនៅម្នាក់ឯង អង្គុយម្នាក់ឯង សម្រេចសេយ្យាម្នាក់ឯង ចូលទៅកាន់ស្រុក ដើម្បីបិណ្ឌបាតម្នាក់ឯង ត្រឡប់មកវិញម្នាក់ឯង អង្គុយក្នុងទីស្ងាត់ម្នាក់ឯង អធិដ្ឋានចង្រ្កមម្នាក់ឯង ចរ ត្រាច់ទៅ ប្រព្រឹត្ត រក្សា យាត្រា ឲ្យយាត្រាទៅតែម្នាក់ឯង ហេតុនោះ ព្រះបច្ចេកសម្ពុទ្ធនោះ ឈ្មោះថា ជាបុគ្គលម្នាក់ឯង ព្រោះអត្ថថា មិនមានបុគ្គលជាគម្រប់ពីរយ៉ាងនេះ ។

ព្រះបច្ចេកសម្ពុទ្ធនោះ ជាបុគ្គលម្នាក់ឯង ព្រោះអត្ថថា លះបង់តណ្ហា តើដូចម្តេច ។ ព្រះបច្ចេកសម្ពុទ្ធនោះ ជាបុគ្គលម្នាក់ឯង ឥតមានបុគ្គលជាគម្រប់ពីរ យ៉ាងនេះហើយ ជាអ្នកមិនប្រហែស មានព្យាយាមដុតកម្តៅកិលេស មានចិត្តស្ទុង ( ទៅកាន់ព្រះនិព្វាន ) ផ្គងព្យាយាមធំ កម្ចាត់បង់មារ ព្រមទាំងសេនា ដែលមិនដោះលែង ជាផៅពង្សនៃបុគ្គលប្រហែស គឺថា លះបង់ បន្ទោបង់ ធ្វើឲ្យវិនាស ញុំាំងតណ្ហាដូចជាបណ្តាញ ដែលហូរទៅ ផ្សាយទៅ ឲ្យដល់នូវការមិនកើតមាន ។

បុរស មានតណ្ហាជាគម្រប់ពីរ កាលអន្ទោលទៅកាន់សង្សារ
អស់កាលដ៏វែង រមែងមិនកន្លងនូវសង្សារវដ្ត ដែលមាន
សភាពយ៉ាងនេះ និងយ៉ាងដទៃបានឡើយ ភិក្ខុ ដឹងនូវតណ្ហា
នេះ ថាជាទោស ជាដែនកើតនៃទុក្ខហើយ ជាអ្នកប្រាសចាក
តណ្ហា មិនមានសេចក្តីប្រកាន់ ជាអ្នកមានសតិ គប្បីវៀរបង់
ចោលចេញ ដូច្នេះ ។

ព្រះបច្ចេកសម្ពុទ្ធនោះ ជាបុគ្គលម្នាក់ឯង ព្រោះអត្ថថា លះបង់តណ្ហា យ៉ាងនេះ ។

ព្រះបច្ចេកសម្ពុទ្ធនោះ ជាបុគ្គលម្នាក់ឯង ព្រោះហេតុប្រាសចាករាគៈដោយដាច់ខាត តើដូចម្តេច ។ ជាបុគ្គលម្នាក់ឯង ព្រោះហេតុប្រាសចាករាគៈ ដោយដាច់ខាត ព្រោះលោកលះរាគៈហើយ ។ ជាបុគ្គលម្នាក់ឯង ព្រោះហេតុប្រាសចាកទោសៈដោយដាច់ខាត ព្រោះលោកលះទោសៈហើយ ។ ជាបុគ្គលម្នាក់ឯង

ព្រោះហេតុប្រាសចាកមោហៈដោយដាច់ខាត ព្រោះលោកលះមោហៈហើយ ។ ជាបុគ្គលម្នាក់ឯង ព្រោះហេតុមិនមានកិលេសដោយដាច់ខាត ព្រោះលោកលះកិលេសទាំងឡាយហើយ ។ ព្រះបច្ចេកសម្ពុទ្ធនោះ ជាបុគ្គលម្នាក់ឯង ព្រោះហេតុប្រាសចាករាគៈដោយដាច់ខាតយ៉ាងនេះ ។

ព្រះបច្ចេកសម្ពុទ្ធនោះ ជាបុគ្គលម្នាក់ឯង ព្រោះហេតុទៅកាន់ផ្លូវជាទីទៅម្នាក់ឯង តើដូចម្តេច ។ សតិប្បដ្ឋាន ៤ សម្មប្បធាន ៤ ឥទ្ធិបាទ ៤ ឥន្ទ្រិយ ៥ ពល ៥ ពោជ្ឈង្គ ៧ អរិយមគ្គប្រកបដោយអង្គ ៨ លោកហៅថា ផ្លូវជាទីទៅម្នាក់ឯង ។

> ព្រះមានព្រះភាគ មានប្រក្រតីឃើញនូវទីបំផុតនៃធម៌ ជាគ្រឿងអស់ទៅនៃជាតិ មានសេចក្តីអនុគ្រោះដោយប្រយោជន៍ ទ្រង់ជ្រាបច្បាស់នូវផ្លូវជាទីទៅនៃបុគ្គលម្នាក់ឯង ជនទាំងឡាយក្នុងកាលមុន បានឆ្លងហើយ តាមផ្លូវនោះ ជនទាំងឡាយបម្រុងនឹងឆ្លង ជនទាំងឡាយ កំពុងឆ្លងនូវឱឃៈ ( ក៏ឆ្លងតាមផ្លូវនោះ ) ដូច្នេះ ។

ព្រះបច្ចេកសម្ពុទ្ធនោះ ជាបុគ្គលម្នាក់ឯង ព្រោះហេតុទៅកាន់ផ្លូវជាទីទៅម្នាក់ឯង យ៉ាងនេះ ។

ព្រះបច្ចេកសម្ពុទ្ធនោះ ជាបុគ្គលម្នាក់ឯង ព្រោះហេតុត្រាស់ដឹងនូវបច្ចេកសម្ពោធិដ៏ប្រសើរតែម្នាក់ឯង តើដូចម្តេច ។ ញាណ បញ្ញា បញ្ញិន្ទ្រិយ បញ្ញាពល ធម្មវិចយសម្ពោជ្ឈង្គ វីមំសា វិបស្សនា សម្មាទិដ្ឋិក្នុងមគ្គទាំង ៤

ហៅថា ពោធិ ។ ព្រះបច្ចេកសម្ពុទ្ធនោះ ត្រាស់ដឹងហើយនូវសច្ចៈទាំងឡាយ ដោយបច្ចេកពុទ្ធញ្ញាណ ត្រាស់ដឹងហើយថា សង្ខារទាំងពួង មិនទៀង ត្រាស់ដឹងហើយថា សង្ខារទាំងពួង ជាទុក្ខ ត្រាស់ហើយថា ធម៌ទាំងពួង ជាអនត្តា ត្រាស់ដឹងហើយថា សង្ខារទាំងឡាយ ( កើតមាន ) ព្រោះអវិជ្ជាជាបច្ច័យ ត្រាស់ដឹងហើយថា វិញ្ញាណ ( កើតមាន ) ព្រោះសង្ខារជាបច្ច័យ ត្រាស់ដឹងហើយថា នាម និងរូប ( កើតមាន ) ព្រោះវិញ្ញាណជាបច្ច័យ ត្រាស់ដឹងហើយថា អាយតនៈ ៦ ( កើតមាន ) ព្រោះនាមរូបជាបច្ច័យ ត្រាស់ដឹងហើយថា ផស្សៈ ( កើតមាន ) ព្រោះអាយតនៈ ៦ ជាបច្ច័យ ត្រាស់ដឹងហើយថា វេទនា ( កើតមាន ) ព្រោះផស្សៈជាបច្ច័យ ត្រាស់ដឹងហើយថា តណ្ហា ( កើតមាន ) ព្រោះវេទនាជាបច្ច័យ ត្រាស់ដឹងហើយថា ឧបាទាន ( កើតមាន ) ព្រោះតណ្ហាជាបច្ច័យ ត្រាស់ដឹងហើយថា ភព ( កើតមាន ) ព្រោះឧបាទានជាបច្ច័យ ត្រាស់ដឹងហើយថា ជាតិ ( កើតមាន ) ព្រោះភពជាបច្ច័យ ត្រាស់ដឹងហើយថា ជរា និងមរណៈ ( កើតមាន ) ព្រោះជាតិជាបច្ច័យ ត្រាស់ដឹងហើយថា ការរលត់សង្ខារ ព្រោះការរលត់ទៅនៃអវិជ្ជា ត្រាស់ដឹងហើយថា ការរលត់វិញ្ញាណ ព្រោះការរលត់សង្ខារ ។បេ។ ការរលត់ជាតិ ព្រោះការរលត់ភព ត្រាស់ដឹងហើយថា ការរលត់ជរាមរណៈ ព្រោះការរលត់ជាតិ ត្រាស់ដឹងហើយថា នេះទុក្ខ ត្រាស់ដឹងហើយថា នេះការកើតទុក្ខ ត្រាស់ដឹងហើយថា នេះការរលត់ទុក្ខ ត្រាស់ដឹងហើយថា នេះបដិបទាជាដំណើរទៅកាន់ការរលត់ទុក្ខ ត្រាស់ដឹងហើយថា ទាំងនេះអាសវៈ ត្រាស់ដឹងហើយថា នេះ

ការកើតអាសវៈ ។បេ។ ត្រាស់ដឹងថា នេះទុក្ខនិរោធ គាមិនីបដិបទា ។ ត្រាស់ដឹងថា ធម៌ទាំងនេះ គួរកំណត់ដឹង ត្រាស់ដឹងថា ធម៌ទាំងនេះ គួរលះ ត្រាស់ដឹងថា ធម៌ទាំងនេះ គួរធ្វើឲ្យជាក់ច្បាស់ ត្រាស់ដឹងថា ធម៌ទាំងនេះ គួរចម្រើន ត្រាស់ដឹងហើយ នូវការកើតឡើងផង ការវិនាសផង គុណផង ទោសផង ការរលាស់ចេញនូវផស្សាយតនៈ ៦ ផង ត្រាស់ដឹងហើយ នូវការកើតឡើងផង ។បេ។ ការរលាស់ចេញនូវឧបាទានក្ខន្ធ ៥ ផង ត្រាស់ដឹងហើយ នូវការកើតឡើងផង ការវិនាសផង គុណផង ទោសផង ការរលាស់ចេញនូវមហាភូតរូប ៤ ផង ត្រាស់ដឹងហើយថា ធម្មជាតណាមួយ មានការកើតឡើងជាធម្មតា ធម្មជាតទាំងអស់នោះ មានការរលត់ទៅវិញជាធម្មតា គឺថា ត្រាស់ដឹង ត្រាស់ដឹងតាម ត្រាស់ដឹងឯង ប៉ះពាល់ ធ្វើឲ្យជាក់ច្បាស់ នូវធម៌ដែលត្រូវត្រាស់ដឹង ដែលត្រូវត្រាស់ដឹងតាម ដែលត្រូវត្រាស់ដឹងឯង ដែលត្រូវប៉ះពាល់ ដែលត្រូវធ្វើឲ្យជាក់ច្បាស់ទាំងអស់ ដោយបច្ចេកពោ-ធិញ្ញាណនោះ ហេតុនោះ ព្រះបច្ចេកសម្ពុទ្ធនោះ ជាបុគ្គលម្នាក់ឯង ព្រោះហេតុត្រាស់ដឹងនូវបច្ចេកសម្ពោធិដ៏ប្រសើរម្នាក់ឯង យ៉ាងនេះ ។

បទថា **ចរេ** សេចក្តីថា ចរិយា មាន ៨ គឺឥរិយាបថចរិយា ១ អាយតនចរិយា ១ សតិចរិយា ១ សមាធិចរិយា ១ ញាណចរិយា ១ មគ្គចរិយា ១ បត្តិចរិយា ១ លោកត្ថចរិយា ១ ។

ចរិយាក្នុងឥរិយា ៤ ឈ្មោះថា ឥរិយាបថចរិយា ។ ចរិយាក្នុងអាយតនៈខាងក្នុង ៦ និងខាងក្រៅ ៦ ឈ្មោះថា អាយតនចរិយា ។ ចរិយាក្នុង

សតិប្បដ្ឋាន ៤ ឈ្មោះថា សតិចរិយា ។ ចរិយាក្នុងឈាន ៤ ឈ្មោះថា សមាធិចរិយា ។ ចរិយាក្នុងអរិយសច្ចៈ ៤ ឈ្មោះថា ញាណចរិយា ។ ចរិយាក្នុងអរិយមគ្គ ៤ ឈ្មោះថា មគ្គចរិយា ។ ចរិយាក្នុងសាមញ្ញផល ៤ ឈ្មោះថា បត្តិចរិយា ។ កាលប្រព្រឹត្តប្រយោជន៍ដល់លោក ក្នុងព្រះតថាគតអរហន្តសម្មាសម្ពុទ្ធ ក្នុងបច្ចេកសម្ពុទ្ធដោយចំណែកខ្លះ ក្នុងសាវកទាំងឡាយដោយចំណែកខ្លះ ឈ្មោះថា លោកត្ថចរិយា ។

ចរិយារបស់បុគ្គលដែលដល់ព្រមដោយការតម្កល់ខ្លួនប្រពៃ ឈ្មោះថា ឥរិយាបថចរិយា ។ ចរិយារបស់បុគ្គលដែលគ្រប់គ្រងទ្វារ ក្នុងឥន្ទ្រិយទាំងឡាយ ឈ្មោះថា អាយតនចរិយាយ ។ ចរិយារបស់បុគ្គលដែលមានប្រក្រតីនៅដោយការមិនប្រមាទ ឈ្មោះថា សតិចរិយា ។ ចរិយារបស់បុគ្គលដែលប្រកបរឿយៗ ក្នុងអធិចិត្ត ឈ្មោះថា សមាធិចរិយា ។ ចរិយារបស់បុគ្គលដែលសម្បូរដោយបញ្ញាជាគ្រឿងត្រាស់ដឹង ឈ្មោះថា ញាណចរិយា ។ ចរិយារបស់បុគ្គលដែលបដិបត្តិដោយប្រពៃ ឈ្មោះថា មគ្គចរិយា ។ ចរិយារបស់បុគ្គលដែលសម្រេចផលហើយ ឈ្មោះថា បត្តិចរិយា និងចរិយារបស់ព្រះតថាគតអរហន្តសម្មាសម្ពុទ្ធ របស់ព្រះបច្ចេកសម្ពុទ្ធចំណែកខ្លះ របស់សាវកទាំងឡាយចំណែកខ្លះ ឈ្មោះថា លោកត្ថចរិយា នេះជាចរិយា ៨ ប្រការ ។

ចរិយា ៨ ដទៃទៀត គឺបុគ្គលកាលបង្អោនចិត្តជឿ រមែងប្រព្រឹត្តដោយសទ្ធា ១ កាលផ្គង រមែងប្រព្រឹត្តដោយព្យាយាម ១ កាលចូលទៅតាំងមាំ រមែងប្រព្រឹត្តដោយសតិ ១ កាលធ្វើនូវការមិនរាយមាយ រមែង

ប្រព្រឹត្តដោយសមាធិ ១ កាលឃើញច្បាស់ រមែងប្រព្រឹត្តដោយបញ្ញា ១ កាលដឹងច្បាស់ រមែងប្រព្រឹត្តដោយវិញ្ញាណ ១ កាលមនសិការថា កុសលធម៌ទាំងឡាយ រមែងប្រព្រឹត្តទូទៅដល់អ្នកបដិបត្តិយ៉ាងនេះ រមែងប្រព្រឹត្តដោយអាយតនចរិយា ១ កាលមនសិការថា អ្នកបដិបត្តិយ៉ាងនេះ រមែងសម្រេចគុណវិសេស រមែងប្រព្រឹត្តដោយវិសេសចរិយា ១ នេះជាចរិយា ៨ ប្រការ ។

ចរិយា ៨ ដទៃទៀត គឺចរិយាក្នុងសម្មាទិដ្ឋិ ឈ្មោះថា ទស្សនចរិយា គឺចរិយាក្នុងការឃើញ ១ ចរិយាក្នុងសម្មាសង្កប្ប ឈ្មោះថា អភិនិរោបនចរិយា គឺចរិយាក្នុងការលើកចិត្ត ១ ចរិយាក្នុងសម្មាវាចា ឈ្មោះថា បរិគ្គហចរិយា គឺចរិយាក្នុងការកំណត់ ១ ចរិយាក្នុងសម្មាកម្មន្តៈ ឈ្មោះថា សមុដ្ឋានចរិយា គឺចរិយាក្នុងការប្រឹងប្រែង ១ ចរិយាក្នុងសម្មាអាជីវៈ ឈ្មោះថា វោទានចរិយា គឺចរិយាក្នុងសេចក្ដីផូរផង់ ១ ចរិយាក្នុងសម្មាវាយាមៈ ឈ្មោះថា បគ្គហចរិយា គឺចរិយាក្នុងការផ្គង ១ ចរិយាក្នុងសម្មាសតិ ឈ្មោះថា ឧបដ្ឋានចរិយា គឺចរិយាក្នុងការប្រុងប្រយ័ត ១ ចរិយាក្នុងសម្មាសមាធិ ឈ្មោះថា អវិក្ខេបចរិយា គឺ ចរិយាក្នុងការមិនរាយមាយ ១ នេះជាចរិយា ៨ ប្រការ ។

បទថា **ខគ្គវិសាណកប្បោ** សេចក្ដីថា ធម្មតារមាសមានកុយតែមួយប៉ុណ្ណោះ មិនមានកុយជាគម្រប់ ២ យ៉ាងណា ព្រះបច្ចេកសម្ពុទ្ធនោះ ក៏ដូច្នោះដូចគ្នា ដូចកុយរមាសនោះ ដូចគ្នាតែមួយនឹងកុយរមាសនោះ មាន

ចំណែកប្រៀបដោយកុយរមាសនោះ ។ វត្ថុមានរសប្រៃក្រៃលែង អ្នកផងតែង និយាយថា ដូចអំបិល វត្ថុមានរសល្វីងក្រៃលែង អ្នកផងតែងនិយាយថា ដូចម្រះ វត្ថុមានរសផ្អែមក្រៃលែង អ្នកផងតែងនិយាយថា ដូចទឹកឃ្មុំ កម្តៅដ៏ក្រៃលែង អ្នកផងតែងនិយាយថាដូចភ្លើង វត្ថុត្រជាក់ក្រៃលែង អ្នកផងតែង និយាយថា ដូចព្រិល ( ឬទឹកកក ) ជារនៃទឹកច្រើន អ្នកផងតែងនិយាយថា ដូចសមុទ្រ សាវកដែលដល់នូវកម្លាំងអភិញ្ញាដ៏ច្រើន អ្នកផងតែងនិយាយថា ដូចព្រះសាស្តា យ៉ាងណាមិញ ព្រះបច្ចេកសម្ពុទ្ធ ដូចកុយរមាសនោះ ប្រាកដស្មើដោយកុយរមាសនោះ មានការប្រៀបដោយកុយរមាសនោះ ជាបុគ្គលឯក មិនមានបុគ្គលជាគម្រប់ពីរ របួតចាកចំណងហើយ តែងចរ ត្រាច់ទៅ ប្រព្រឹត្ត រក្សា យាត្រា ឲ្យយាត្រាទៅក្នុងលោកដោយប្រពៃ ក៏យ៉ាងនោះដែរ ព្រោះហេតុនោះ ទើបឈ្មោះថា គប្បីប្រព្រឹត្តតែម្នាក់ឯង ដូចកុយរមាស ។ ដោយហេតុនោះ ទើបព្រះបច្ចេកសម្ពុទ្ធទាំងឡាយពោលថា

បុគ្គលទម្លាក់ចោល នូវអាជ្ញាចំពោះសត្វទាំងពួង មិនបៀតបៀន នូវសត្វទាំងនោះ សូម្បីសត្វណាមួយទេ ទាំងជាអ្នកអនុគ្រោះ ចំពោះប្រយោជន៍ដោយមេត្តាចិត្ត គប្បីប្រព្រឹត្តតែម្នាក់ឯង ដូចកុយរមាស ។

បុគ្គលទម្លាក់ចោលនូវអាជ្ញា ចំពោះពួកសត្វទាំងពួង មិនបៀតបៀន ចំពោះសត្វទាំងនោះ សូម្បីសត្វណាមួយទេ មិនបានប្រាថ្នានូវបុត្ត ( ទៅហើយ ) តើនឹងប្រាថ្នានូវសម្លាញ់អំពីណា គប្បីប្រព្រឹត្តតែម្នាក់ឯង ដូចកុយរមាស ។

( ព្រះបច្ចេកសម្ពុទ្ធមួយអង្គពោលថា )

សេចក្ដីស្រឡាញ់ របស់សត្វដែលនៅប្រឡូកប្រឡំគ្នា រមែងមាន ឯសេចក្ដីទុក្ខនេះ មានឡើង ព្រោះអាស្រ័យសេចក្ដីស្រឡាញ់ បុគ្គលកាលឃើញទោស ដែលកើតអំពីសេចក្ដីស្រឡាញ់ គប្បីប្រព្រឹត្តតែម្នាក់ឯង ដូចកុយរមាស ។

( ព្រះបច្ចេកសម្ពុទ្ធមួយអង្គពោលថា )

បុគ្គលមានចិត្តជាប់ជំពាក់ កាលអនុគ្រោះចំពោះពួកមិត្ត និងសម្លាញ់ រមែងញុំាងប្រយោជន៍ឲ្យវិនាស បុគ្គលកាលឃើញនូវភ័យ ក្នុងសេចក្ដីស្និទ្ធស្នាលនុ៎ះ គប្បីប្រព្រឹត្តតែម្នាក់ឯង ដូចកុយរមាស ។

( ព្រះបច្ចេកសម្ពុទ្ធមួយអង្គពោលថា )

សេចក្ដីស្រឡាញ់ ក្នុងបុត្ត និងភរិយា ដូចជាឫស្សីមានមែក ចាក់កណ្ដាញ់ បុគ្គល កាលមិនជាប់ជំពាក់ ដូចជាទំពាំងឫស្សី គប្បីប្រព្រឹត្តតែម្នាក់ឯង ដូចកុយរមាស ។

( ព្រះបច្ចេកសម្ពុទ្ធមួយអង្គពោលថា )

ម្រឹគក្នុងព្រៃ មិនជាប់ចំណង ដើរទៅរកចំណីតាមចំណង់បាន យ៉ាងណា វិញ្ញូជនកាល បើប្រាថ្នាសេរីភាព ( យ៉ាងនោះ ) គប្បីប្រព្រឹត្តតែម្នាក់ឯង ដូចកុយរមាស ។

( ព្រះបច្ចេកសម្ពុទ្ធមួយអង្គពោលថា )

ការហៅរក រមែងមាន ក្នុងកណ្ដាលនៃសម្លាញ់ គឺក្នុងលំនៅ ក្នុងទីបម្រើ

ក្នុងការដើរ ក្នុងការត្រាច់ចារិក បុគ្គល កាលប្រាថ្នានូវសេរីភាព ដែលពួកជនពាលមិនប្រាថ្នា គប្បីប្រព្រឹត្តម្នាក់ឯង ដូចកុយរមាស ។

( ព្រះបច្ចេកសម្ពុទ្ធមួយអង្គពោលថា )

ល្បែង និងតម្រេក រមែងមានក្នុងកណ្តាលនៃសម្លាញ់ ទាំងសេចក្តីស្រឡាញ់ដ៏ធំទូលាយ រមែងមានក្នុងបុត្រទាំងឡាយ បុគ្គល កាលខ្ពើមរអើមចំពោះការព្រាត់ប្រាសចាកសត្វ និងសង្ខារជាទីស្រឡាញ់ គប្បីប្រព្រឹត្តតែម្នាក់ឯង ដូចកុយរមាស ។

( ព្រះបច្ចេកសម្ពុទ្ធមួយអង្គពោលថា )

បុគ្គលជាអ្នកនៅជាសុខ ក្នុងទិសទាំង ៤ មិនមានថ្នាំងថ្នាក់ចិត្ត ត្រេកអរក្នុងវត្ថុ តាមមាន តាមបាន ជាអ្នកអត់ធន់ចំពោះអន្តរាយ ជាអ្នកមិនតក់ស្លុត គប្បីប្រព្រឹត្តតែម្នាក់ឯង ដូចកុយរមាស ។

( ព្រះបច្ចេកសម្ពុទ្ធមួយអង្គពោលថា )

បព្វជិតពួកខ្លះ ឬពួកគ្រហស្ថ ដែលនៅគ្រប់គ្រងផ្ទះខ្លះ គេសង្គ្រោះបានដោយកម្រ បុគ្គលអ្នកមិនមានសេចក្តីខ្វល់ខ្វាយ ចំពោះពួកកូននៃបុគ្គលដទៃ គប្បីប្រព្រឹត្តតែម្នាក់ឯង ដូចកុយរមាស ។

( ព្រះបច្ចេកសម្ពុទ្ធមួយអង្គពោលថា )

វីរបុគ្គល លះបង់នូវវត្ថុទាំងឡាយ ជាគ្រឿងប្រាកដរបស់គ្រហស្ថ កាត់បង់នូវចំណងរបស់គ្រហស្ថទាំងឡាយ ដូចដើមរលួសផ្អុងជម្រុះស្លឹក គប្បីប្រព្រឹត្តតែម្នាក់ឯង ដូចកុយរមាស ។

( ព្រះបច្ចេកសម្ពុទ្ធមួយអង្គពោលថា )

បើបុគ្គលបានសម្លាញ់ ជាអ្នកប្រាជ្ញ មានបញ្ញាខ្ជាប់ខ្ជួន ជាអ្នកប្រព្រឹត្តត្រូវគ្នា មានធម៌ជាគ្រឿងនៅដ៏ល្អ គប្បីជាអ្នកមានស្មារតី គ្របសង្កត់នូវអន្តរាយទាំងពួង ហើយមានចិត្តរីករាយ ប្រព្រឹត្តជាមួយ សម្លាញ់នោះចុះ ។

( ព្រះបច្ចេកសម្ពុទ្ធមួយអង្គពោលថា )

បើបុគ្គលមិនបានសម្លាញ់ ជាអ្នកប្រាជ្ញ មានបញ្ញាខ្ជាប់ខ្ជួន ជាអ្នកប្រព្រឹត្តត្រូវគ្នា មានធម៌ជាគ្រឿងនៅដ៏ល្អទេ គប្បីប្រព្រឹត្តតែម្នាក់ឯង ដូចព្រះរាជា ទ្រង់លះបង់នូវដែន ដែលទ្រង់ឈ្នះហើយ ឬដូចដំរីឈ្មោះមាតង្គៈ ( លះបង់នូវហ្វូងកាលត្រាច់ទៅ ) ក្នុងព្រៃ ។

( ព្រះបច្ចេកសម្ពុទ្ធមួយអង្គពោលថា )

តាមពិត យើងសរសើរនូវការបរិបូណ៌ ដោយសម្លាញ់ហើយ តែបុគ្គលគួរគប់រកសម្លាញ់ ដែលមានគុណប្រសើរជាងខ្លួន ឬសម្លាញ់មានគុណស្មើនឹងខ្លួន បើរកមិនបានពួកសម្លាញ់ទាំងនុ៎ះទេ គប្បីជាអ្នកបរិភោគ នូវចតុប្បច្ច័យដែលមិនជាទោស ហើយប្រព្រឹត្តតែម្នាក់ឯង ដូចកុយរមាស ។

( ព្រះបច្ចេកសម្ពុទ្ធមួយអង្គពោលថា )

បុគ្គលឃើញនូវកងមាសទាំងពីរ ដែលពួកជាងមាសធ្វើសម្រេចល្អហើយ រណ្តំគ្នាត្រង់កដៃ គប្បីប្រព្រឹត្តតែម្នាក់ឯង ដូចកុយរមាស ។

( ព្រះបច្ចេកសម្ពុទ្ធមួយអង្គពោលថា )

ឯការឆ្លើយឆ្លងដោយវាចាក្តី ការជាប់ជំពាក់ក្តី ជាមួយនឹងបុគ្គលគម្រប់ពីរ

របស់អញ ដូចកងមាសមួយគូ មានយ៉ាងនុ៎ះ បុគ្គល កាលរំពឹងឃើញនូវភ័យនុ៎ះ ក្នុងកាលខាងមុខ គប្បីប្រព្រឹត្តតែម្នាក់ឯង ដូចកុយរមាស ។

( ព្រះបច្ចេកសម្ពុទ្ធមួយអង្គពោលថា )

ពិតហើយ កាមទាំងឡាយដ៏វិចិត្រ មានរសផ្អែម ជាទីរីករាយនៃចិត្ត រមែងញាំញីនូវចិត្ត ដោយសភាពដ៏ប្លែកៗ បុគ្គលឃើញទោសក្នុងកាមគុណទាំងឡាយហើយ គប្បីប្រព្រឹត្តតែម្នាក់ឯង ដូចកុយរមាស ។

( ព្រះបច្ចេកសម្ពុទ្ធមួយអង្គពោលថា )

បុគ្គលឃើញនូវភ័យនុ៎ះ ក្នុងកាមគុណទាំងឡាយថា នេះជាចង្រៃ ជាបូស ជាឧបទ្រព ជារោគ ជាសរ ទាំងជាភ័យ របស់អញហើយ គប្បីប្រព្រឹត្តតែម្នាក់ឯង ដូចកុយរមាស ។

( ព្រះបច្ចេកសម្ពុទ្ធមួយអង្គពោលថា )

បុគ្គលគ្របសង្កត់ នូវសត្រូវទាំងអស់នុ៎ះ គឺត្រជាក់ ក្តៅ គម្លាន សម្រេក ខ្យល់ និងកម្តៅថ្ងៃ របោម និងសត្វលូនហើយ គប្បីប្រព្រឹត្តតែម្នាក់ឯង ដូចកុយរមាស ។

( ព្រះបច្ចេកសម្ពុទ្ធមួយអង្គពោលថា )

ដំរី មានខ្នងសមរម្យ មាំមួន មានសម្បុរដូចផ្កាឈូក កាលលះបង់ហ្វូងហើយ នៅក្នុងព្រៃ គួរដល់អធ្យាស្រ័យ យ៉ាងណា បុគ្គលគប្បីប្រព្រឹត្តតែម្នាក់ឯង ដូចកុយរមាសយ៉ាងនោះឯង ។

( ព្រះបច្ចេកសម្ពុទ្ធមួយអង្គពោលថា )

បុគ្គលបាននូវសាមយិកវិមុត្តិ ដោយហេតុណា ហេតុនោះ មិនមែនជាទីតាំងនៃបុគ្គលអ្នកត្រេកអរក្នុងពួកទេ បុគ្គលពិចារណានូវពាក្យនៃព្រះពុទ្ធជាអាទិច្ចពន្ធុហើយ គប្បីប្រព្រឹត្តតែម្នាក់ឯង ដូចកុយរមាស ។

( ព្រះបច្ចេកសម្ពុទ្ធមួយអង្គពោលថា )

បុគ្គល កន្លងនូវចម្រូង គឺទិដ្ឋិ ដល់នូវធម៌ទៀង គឺមគ្គទី ១ មានមគ្គ ( ដ៏សេស ) បានហើយ មិនមានអ្នកដទៃដឹកនាំ ព្រោះដឹងថា អាត្មាអញមានញាណកើតឡើងហើយ គប្បីប្រព្រឹត្តតែម្នាក់ឯង ដូចកុយរមាស ។

( ព្រះបច្ចេកសម្ពុទ្ធមួយអង្គពោលថា )

បុគ្គលមិនជាប់ចិត្ត ( ក្នុងអាហារ ) មិនកុហក មិនស្រេកឃ្លាន មិនលុបគុណគេ កម្ចាត់បង់មោហៈ ដូចជាទឹកចត់ មិនមានទីអាស្រ័យនៅ គឺតណ្ហា ក្នុងលោកទាំងពួងហើយ គប្បីប្រព្រឹត្តតែម្នាក់ឯង ដូចកុយរមាស ។

( ព្រះបច្ចេកសម្ពុទ្ធមួយអង្គពោលថា )

បុគ្គលគប្បីវៀរស្រឡះ នូវសម្លាញ់អាក្រក់ អ្នកមិនឃើញនូវសេចក្តីវិនាស អ្នកអាស្រ័យនៅ ក្នុងកម្មមិនស្មើ មិនគប្បីគប់រកនូវសម្លាញ់ ដែលជាប់ជំពាក់ ដែលស្រវឹង ( ក្នុងកាមគុណ ) ដោយខ្លួនឯង គប្បីប្រព្រឹត្តតែម្នាក់ឯង ដូចកុយរមាស ។

( ព្រះបច្ចេកសម្ពុទ្ធមួយអង្គពោលថា )

បុគ្គលគប្បីគប់រកនូវបុគ្គលជាពហុស្សូត អ្នកទ្រទ្រង់ធម៌ អ្នកប្រកបដោយគុណដ៏ក្រៃលែង មានប្រាជ្ញាវាងវៃ បុគ្គលដឹងច្បាស់នូវប្រយោជន៍ទាំង

ឡាយ គួរបន្ទោបង់សេចក្តីសង្ស័យ គប្បីប្រព្រឹត្តតែម្នាក់ឯង ដូចកុយរមាស ។

( ព្រះបច្ចេកសម្ពុទ្ធមួយអង្គពោលថា )

បុគ្គលមិនអើពើ មិនអាឡោះអាល័យ នូវល្បែងផង តម្រេកផង កាមសុខក្នុងលោកផង ជាអ្នកវៀរស្រឡះ ចាកគ្រឿងស្អិតស្អាង អ្នកពោលនូវពាក្យសច្ចៈ គប្បីប្រព្រឹត្តតែម្នាក់ឯង ដូចកុយរមាស ។

( ព្រះបច្ចេកសម្ពុទ្ធមួយអង្គពោលថា )

បុគ្គលលះបង់នូវកាមទាំងឡាយតាមចំណែក គឺបុត្រ ភរិយា បិតា មាតា ទ្រព្យសម្បត្តិ ស្រូវ អង្ករ និងផៅពង្សហើយ គប្បីប្រព្រឹត្តតែម្នាក់ឯង ដូចកុយរមាស ។

( ព្រះបច្ចេកសម្ពុទ្ធមួយអង្គពោលថា )

កាមគុណនេះ ជាគ្រឿងជាប់ជំពាក់ ឯសេចក្តីសុខ ក្នុងកាមនុ៎ះ មានប្រមាណតិច កាមគុណនុ៎ះ មានសេចក្តីត្រេកអរតិច បុគ្គលអ្នកមានគំនិតប្រាជ្ញា លុះដឹងច្បាស់ថា កាមគុណនុ៎ះ ដូចជាដំបៅពក ដូច្នេះហើយ គប្បីប្រព្រឹត្តតែម្នាក់ឯង ដូចកុយរមាស ។

( ព្រះបច្ចេកសម្ពុទ្ធមួយអង្គពោលថា )

បុគ្គលទម្លាយនូវសំយោជនៈ ដូចត្រីក្នុងទឹកទម្លាយនូវសំណាញ់ មិនត្រឡប់មករកសំយោជនៈវិញ ដូចភ្លើងឆេះ ( មិនត្រឡប់វិញ ) គប្បីប្រព្រឹត្តតែម្នាក់ឯង ដូចកុយរមាស ។

( ព្រះបច្ចេកសម្ពុទ្ធមួយអង្គពោលថា )

បុគ្គលមានចក្ខុដាក់ចុះ មានជើងមិនរពឹស ជាអ្នកគ្រប់គ្រងឥន្ទ្រិយ រក្សាចិត្តទុក ( ដោយល្អ ) មិនជោកជាំ មិនរោលរាល ( ដោយកិលេស ) គប្បីប្រព្រឹត្តតែម្នាក់ឯង ដូចកុយរមាស ។

( ព្រះបច្ចេកសម្ពុទ្ធមួយអង្គពោលថា )

បុគ្គលលះបង់នូវភេទគ្រហស្ថ ដូចដើមបារិច្ឆត្តព្រឹក្ស ដែលមានស្លឹកដាច់ហើយ មានសំពត់កាសាយៈ ចេញបួសហើយ គប្បីប្រព្រឹត្តតែម្នាក់ឯង ដូចកុយរមាស ។

( ព្រះបច្ចេកសម្ពុទ្ធមួយអង្គពោលថា )

បុគ្គលមិនធ្វើនូវសេចក្ដីប្រាថ្នា ក្នុងរសទាំងឡាយ ជាអ្នកមិនល្មោភ មិនចិញ្ចឹមនូវបុគ្គលដទៃ ជាអ្នកត្រាច់ទៅសព្វប្រេក មិនជាប់ចិត្តក្នុងត្រកូលមួយៗ គប្បីប្រព្រឹត្តតែម្នាក់ឯង ដូចកុយរមាស ។

( ព្រះបច្ចេកសម្ពុទ្ធមួយអង្គពោលថា )

បុគ្គលលះបង់នូវហេតុជាគ្រឿងរារាំង ៥ យ៉ាង របស់ចិត្ត បន្ទោបង់នូវឧបក្កិលេសទាំងពួង ទាំងមិនអាស្រ័យ ( ដោយតណ្ហា និងទិដ្ឋិ ) កាត់បង់នូវទោសនៃសេចក្ដីស្រឡាញ់ហើយ គប្បីប្រព្រឹត្តតែម្នាក់ឯង ដូចកុយរមាស ។

( ព្រះបច្ចេកសម្ពុទ្ធមួយអង្គពោលថា )

បុគ្គលធ្វើនូវសុខ ទុក្ខ សោមនស្ស និងទោមនស្ស ក្នុងកាលមុន ឲ្យនៅពីក្រោយខ្នង បាននូវឧបេក្ខាជាសមថៈដ៏ស្អាត គប្បីប្រព្រឹត្តតែម្នាក់ឯង ដូចកុយរមាស ។

( ព្រះបច្ចេកសម្ពុទ្ធមួយអង្គពោលថា )

បុគ្គលប្រារព្ធព្យាយាម ដើម្បីដល់នូវព្រះនិព្វាន មានចិត្តមិនរួញរា មានការប្រព្រឹត្តមិនខ្ជិលច្រអូស មានសេចក្តីប្រឹងប្រែងដ៏មាំមួន ប្រកបដោយកម្លាំងកាយ និងកម្លាំងបញ្ញាហើយ គប្បីប្រព្រឹត្តតែម្នាក់ឯង ដូចកុយរមាស ។

( ព្រះបច្ចេកសម្ពុទ្ធមួយអង្គពោលថា )

បុគ្គលកាលមិនលះបង់នូវឈានដ៏ស្ងប់ស្ងាត់ ( ចាកសត្វ និងសង្ខារ ) ជាអ្នកប្រព្រឹត្តនូវធម៌ដ៏សមគួរក្នុងធម៌ទាំងឡាយ អស់កាលជានិច្ច ពិចារណានូវទោសក្នុងភពទាំងឡាយហើយ គប្បីប្រព្រឹត្តតែម្នាក់ឯង ដូចកុយរមាស ។

( ព្រះបច្ចេកសម្ពុទ្ធមួយអង្គពោលថា )

បុគ្គលកាលប្រាថ្នា នូវការអស់តណ្ហា ជាអ្នកមិនប្រហែស មិនល្ងង់ មានការចេះដឹង មានស្មារតី មានធម៌ពិចារណាហើយ ជាបុគ្គលទៀង មានសេចក្តីខ្មីឃ្មាត គប្បីប្រព្រឹត្តតែម្នាក់ឯង ដូចកុយរមាស ។

( ព្រះបច្ចេកសម្ពុទ្ធមួយអង្គពោលថា )

បុគ្គលកាលមិនតក់ស្លុត ក្នុងលក្ខណៈមានមិនទៀងជាដើម ដូចសីហៈមិនតក់ស្លុត ក្នុងសំឡេងទាំងឡាយ មិនជាប់ជំពាក់ក្នុងធម៌ទាំងឡាយ មានខន្ធជាដើម ដូចខ្យល់មិនជាប់នឹងសំណាញ់ មិនប្រឡាក់ដោយលោភៈជាដើម ដូចស្លឹកឈូក មិនប្រឡាក់ដោយទឹក គប្បីប្រព្រឹត្តតែម្នាក់ឯង ដូចកុយរមាស ។

( ព្រះបច្ចេកសម្ពុទ្ធមួយអង្គពោលថា )

សីហៈ ជាស្តេចសត្វ មានចង្កូមជាកម្លាំង ប្រព្រឹត្តគ្របសង្កត់ កំហែង

នូវពួកម្រឹគ យ៉ាងណា បុគ្គលគប់រកនូវសេនាសនៈដ៏ស្ងាត់ ( មានព្រៃជាគ្រឿងអាង ) ក៏យ៉ាងនោះដែរ គប្បីប្រព្រឹត្តតែម្នាក់ឯង ដូចកុយរមាស ។

( ព្រះបច្ចេកសម្ពុទ្ធមួយអង្គពោលថា )

បុគ្គលកាលចម្រើននូវមេត្តា ឧបេក្ខា ករុណា និងមុទិតាជាហេតុ រួចចាកកិលេស ក្នុងកាលដ៏គួរ មិនទើងសម្បានឹងលោកទាំងពួង គប្បីប្រព្រឹត្តតែម្នាក់ឯង ដូចកុយរមាស ។

( ព្រះបច្ចេកសម្ពុទ្ធមួយអង្គពោលថា )

បុគ្គលលះបង់នូវរាគៈផង ទោសៈផង មោហៈផងហើយ ទម្លាយចេញនូវសំយោជនៈ មិនតក់ស្លុត ក្នុងការអស់ទៅនៃជីវិតហើយ គប្បីប្រព្រឹត្តតែម្នាក់ឯង ដូចកុយរមាស ។

( ព្រះបច្ចេកសម្ពុទ្ធមួយអង្គពោលថា )

ពួកជនមានប្រយោជន៍ជាហេតុ ទើបគប់រកផង បម្រើផង ឯពួកមិត្តដែលឥតហេតុ គេរកបានដោយក្រ ក្នុងថ្ងៃនេះ ឯពួកមនុស្សអ្នកមានបញ្ញាប្រាថ្នាប្រយោជន៍ផ្ទាល់ខ្លួន ឈ្មោះថា ជាមនុស្សមិនស្អាត បុគ្គលគប្បីប្រព្រឹត្តតែម្នាក់ឯង ដូចកុយរមាស ។

# អដ្ឋកថា

## បច្ចេកពុទ្ធាបទានគាថាទី ១

## (ខគ្គវិសាណគាថា)

ក្នុងគាថានោះ បទថា **សព្វេសុ ភូតេសុ** ជាសូត្រនៃបច្ចេកពុទ្ធាបទាន ដែលពោល ( ប្រៀបធៀប ) ថា ដូចកុយរមាស ( ខគ្គវិសាណសូត្រ ) ។

សូត្រនោះ មានអត្ថុប្បត្តិហេតុដូចម្តេច ។ សូត្រទាំងពួង មានហេតុកើតឡើង ៤ យ៉ាង គឺ កើតដោយអធ្យាស្រ័យនៃព្រះអង្គឯង ១ កើតដោយអធ្យាស្រ័យរបស់អ្នកដទៃ ១ កើតដោយអត្ថុប្បត្តិហេតុ ១ កើតដោយអំណាចនៃការសួរ ១ ។

ក្នុងហេតុកើត ៤ យ៉ាងនោះ ពោលដោយទូទៅ ខគ្គវិសាណសូត្រកើតឡើងដោយអំណាចការសួរដោយមិនពិសេស តែបើពោលដោយពិសេស ព្រោះហេតុដែលគាថាខ្លះ ក្នុងសូត្រនេះ ព្រះបច្ចេកសម្ពុទ្ធអង្គនោះៗ ត្រូវសួរទើបពោល គាថាខ្លះមិនត្រូវសួរ តែលោកបន្លឺចេញមកជាឧទាន ដែលសមគួរដល់ន័យក្នុងមគ្គដែលខ្លួនបានសម្រេច ទើបពោល ព្រោះហេតុនោះ ទើបគាថាខ្លះ កើតឡើងដោយអំណាចការសួរ គាថាខ្លះ កើតឡើងដោយអធ្យាស្រ័យរបស់ខ្លួន ។ ក្នុងហេតុកើត ៤ យ៉ាងនោះ ហេតុកើតដោយអំណាចការសួរដោយមិនពិសេសនោះ គប្បីជ្រាបការផ្តើមរឿងដូចតទៅ

សម័យមួយ ព្រះមានព្រះភាគ គង់នៅក្នុងនគរសាវត្ថី កាលនោះព្រះអានន្ទនៅក្នុងទីសម្ងំ កើតបរិវិតក្កក្នុងចិត្តយ៉ាងនេះថា សេចក្តីប្រាថ្នា និងអភិនីហាររបស់ព្រះពុទ្ធទាំងឡាយ រមែងប្រាកដច្បាស់ របស់សាវកទាំងឡាយ

ក៏ប្រាកដដូចគ្នា តែរបស់ព្រះបច្ចេកសម្ពុទ្ធទាំងឡាយ មិនប្រាកដច្បាស់ បើដូច្នោះ អញគប្បីចូលទៅគាល់ព្រះមានព្រះភាគ ហើយទូលសួរ ។ ព្រះអានន្ទនោះ ក៏ចេញពីទីសម្ងំ ទូលសួរដល់រឿងនោះ ដោយលំដាប់ ។

លំដាប់នោះ ទើបព្រះមានព្រះភាគ បានត្រាស់បុព្វយោគាវចរសូត្រដល់ព្រះអានន្ទនោះថា

ម្នាលអានន្ទ អានិសង្ស ៥ ប្រការ ក្នុងការចម្រើនសេចក្តីព្យាយាមដែលជាចំណែកខាងដើម គឺធ្វើឲ្យឆាប់សម្រេចអរហត្តផលក្នុងបច្ចុប្បន្ន ១ បើមិនយ៉ាងនោះ រមែងឲ្យសម្រេចអរហត្តផលក្នុងវេលាជិតស្លាប់ ១ បើមិនយ៉ាងនោះ នឹងជាទេវបុត្ត ហើយសម្រេចអរហត្តផល ១ បើមិនយ៉ាងនោះ នឹងជាខិប្បាភិញ្ញាត្រាស់ដឹងបានរហ័សចំពោះព្រះភក្ត្រព្រះពុទ្ធទាំងឡាយ ១ បើមិនជាយ៉ាងនោះ នឹងបានត្រាស់ជាព្រះបច្ចេកពុទ្ធ ក្នុងកាលចុងក្រោយ ១ ។

កាលត្រាស់យ៉ាងនេះហើយ ទើបត្រាស់បន្តថា ម្នាលអានន្ទ ធម្មតាព្រះបច្ចេកសម្ពុទ្ធទាំងឡាយ ជាអ្នកបរិបូណ៌ដោយអភិនីហារ ធ្វើសេចក្តីនូវព្យាយាមមកអំពីមុន ព្រោះហេតុនោះ ព្រះបច្ចេកសម្ពុទ្ធ និងសាវករបស់ព្រះពុទ្ធទាំងឡាយ ក៏ត្រូវប្រាថ្នា និងត្រូវធ្វើអភិនីហារ ( ការតាំងចិត្តពិត ) ។

ព្រះអានន្ទទូលថា បពិត្រព្រះអង្គដ៏ចម្រើន សេចក្តីប្រាថ្នារបស់ព្រះពុទ្ធទាំងឡាយ គួរប្រើពេលយូរប៉ុនណា ព្រះសាស្តាត្រាស់ថា ម្នាលអានន្ទ សេចក្តីប្រាថ្នានៃព្រះពុទ្ធទាំងឡាយ ដោយកំណត់យ៉ាងទាប រមែងប្រព្រឹត្តទៅ ៤ អសង្ខេយ្យ និង ១ សែនកប្ប កំណត់យ៉ាងកណ្តាល រមែងប្រព្រឹត្ត

ទៅ ៨ អសង្ខេយ្យ និង ១ សែនកប្ប កំណត់យ៉ាងខ្ពស់ រមែងប្រព្រឹត្តទៅ ១៦ អសង្ខេយ្យ និង ១ សែនកប្ប ។

ការផ្សេងគ្នាទាំងនេះ គប្បីជ្រាបដោយអំណាចព្រះពុទ្ធដែលជាបញ្ញាធិក សទ្ធាធិក និងវីរិយាធិក ។

ពិតហើយ ព្រះពុទ្ធដែលជាបញ្ញាធិក មានសទ្ធាទន់ខ្សោយ មានបញ្ញាខ្លាំងក្លា ព្រះពុទ្ធដែលជាសទ្ធាធិក មានបញ្ញាជាកណ្តាល មានសទ្ធាខ្លាំងក្លា ព្រះពុទ្ធដែលជាវីរិយាធិក មានសទ្ធា និងបញ្ញាទន់ខ្សោយ មានសេចក្តីព្យាយាមខ្លាំងក្លា ។

ក្នុងករណី កាលឲ្យទានរាល់ៗ ថ្ងៃ ដូចការឲ្យទានរបស់ព្រះវេស្សន្តរ និងការសន្សំបារមីធម៌ មានសីលជាដើម ដែលសមគួរដល់ទាននោះ បើមិនទាន់ដល់ ៤ អសង្ខេយ្យ និង ១ សែនកប្បទេ ក៏មិនបានជាព្រះពុទ្ធក្នុងរវាងចន្លោះនេះ គឺប្រព្រឹត្តទៅមិនបាន ។ សួរថា ព្រោះហេតុអ្វី ឆ្លើយថា ព្រោះញាណមិនទាន់តាំងគភ៌ មិនទាន់ដល់នូវភាពបរិបូណ៌ មិនទាន់ដល់នូវភាពចាស់ក្លា ។ ឧបមាដូចសម្ទូងដែលឲ្យផល ក្នុងកាលកន្លងទៅ ៣ ខែ ៤ ខែ និង ៥ ខែ មិនទាន់ដល់ពេលនោះ ទោះបីប្របាច់ក្តី យកទឹកស្រោចក្តី មួយថ្ងៃ ១០០ ដង ១០០០ ដង មិនអាចឲ្យផលក្នុងមួយបក្ខ ឬមួយខែ ក្នុងចន្លោះបែបនេះបានឡើយ សួរថា ព្រោះហេតុអ្វី ឆ្លើយថា ព្រោះសម្ទូងមិនទាន់ផើម និងមិនទាន់ដល់នូវភាពបរិបូណ៌ មិនទាន់ចាស់ យ៉ាងណា ឋានៈនេះ បើមិនទាន់ដល់ ៤ អសង្ខេយ្យ និង ១ សែនកប្ប នឹងបានជាព្រះ

សម្មាសម្ពុទ្ធដូច្នេះ រមែងមិនមាន យ៉ាងនោះដូចគ្នា ។ ព្រោះហេតុនោះ គប្បីធ្វើនូវការបំពេញបារមីសព្វកាល តាមដែលពោលហើយនោះឯង ដើម្បីឲ្យញាណចាស់ក្លាសិន ។

ម្យ៉ាងទៀត បុគ្គលប្រាថ្នាភាពជាព្រះពុទ្ធ ដោយកាលមានប្រមាណប៉ុណ្ណេះ ក៏ចាំបាច់ប្រាថ្នាសម្បត្តិ ៨ ក្នុងការធ្វើអភិនីហារ ។ ពិតហើយ សេចក្តីប្រាថ្នាដ៏ធំក្រៃលែង រមែងសម្រេចព្រោះសមោធានធម៌ ៨ ប្រការគ្រប់គ្រាន់ គឺ

ភាពជាមនុស្ស ១ ដល់ព្រមដោយភេទ ១ មានហេតុ ១
បានជួបព្រះសាស្តា ១ កាន់យកភេទបព្វជ្ជា ១ មាន
គុណសម្បត្តិ ១ បានធ្វើអធិការ ១ មានឆន្ទៈ ១ ។

ពាក្យថា សេចក្តីប្រាថ្នាដ៏ធំក្រៃលែងនេះ ជាឈ្មោះនៃការប្រាថ្នា ផ្តើមដំបូង ។ ក្នុងធម៌ ៨ ប្រការនោះ ការកើតជាមនុស្ស ឈ្មោះថា ភាពជាមនុស្ស ព្រោះក្រៅអំពីកំណើតមនុស្សហើយ សេចក្តីប្រាថ្នា រមែងមិនសម្រេចដល់បុគ្គលដែលតាំងនៅក្នុងកំណើតដ៏សេស សូម្បីតែកំណើតទេវតា ។ បុគ្គលដែលតាំងនៅក្នុងកំណើតដទៃនោះ កាលប្រាថ្នាភាពជាព្រះពុទ្ធ ត្រូវធ្វើបុញ្ញកម្មមានទានជាដើម ហើយប្រាថ្នាចំពោះភាពជាមនុស្សសិន កាលតាំងនៅក្នុងភាពជាមនុស្សហើយ សឹមធ្វើសេចក្តីប្រាថ្នា ។ កាលធ្វើយ៉ាងនេះឯង ទើបសេចក្តីប្រាថ្នាសម្រេច ។

ភាពជាបុរស ឈ្មោះថា ដល់ព្រមដោយភេទ ។ ពិតហើយ មាតុគ្រាម

ឡើយ និងមនុស្សភេទ ២ សូម្បីតាំងនៅក្នុងកំណើតមនុស្ស សេចក្តីប្រាថ្នាក៏មិនសម្រេច បុគ្គលតាំងនៅក្នុងភេទស្រីជាដើមនោះ កាលប្រាថ្នាភាពជាព្រះពុទ្ធ គប្បីធ្វើបុញ្ញកម្ម មានទានជាដើម ប្រាថ្នាចំពោះភាពជាបុរសជាមុនសិន កាលបានតាំងនៅក្នុងភាពជាបុរសហើយ សឹមប្រាថ្នាភាពជាព្រះពុទ្ធ ព្រោះសេចក្តីប្រាថ្នា រមែងសម្រេចបានដោយវិធីនេះ ។

ការដល់ព្រមដោយឧបនិស្ស័យនៃអរហត្ត ឈ្មោះថា មានហេតុ ។ បើបុគ្គលណា អាចសម្រេចអរហត្ត ក្នុងអត្តភាពនោះបាន កាលប្រើសេចក្តីព្យាយាម សេចក្តីប្រឹងប្រែង សេចក្តីប្រាថ្នារបស់បុគ្គលនោះ រមែងសម្រេច សេចក្តីប្រាថ្នារបស់បុគ្គលក្រៅពីនេះ រមែងមិនសម្រេច ដូចសុមេធបណ្ឌិត ។ ពិតហើយ សុមេធបណ្ឌិតនោះ បើបួសទៀបបាទមូលរបស់ព្រះពុទ្ធទីបង្ករ ក៏អាចសម្រេចអរហត្តបានក្នុងអត្តភាពនោះ ។

ការបានជួបព្រះភក្ត្ររបស់ព្រះពុទ្ធទាំងឡាយ ឈ្មោះថា បានជួបព្រះសាស្តា ។ ព្រោះសេចក្តីប្រាថ្នានឹងសម្រេចបានដោយវិធីនេះ មិនមែនដោយវិធីដទៃ ដូចគ្នានឹងសុមេធបណ្ឌិត ។ ព្រោះលោកបានជួបនឹងព្រះពុទ្ធទីបង្ករចំពោះព្រះភក្ត្រហើយ តាំងនូវសេចក្តីប្រាថ្នា ។

ភាពជាអ្នកមិនមានផ្ទះ ឈ្មោះថា កាន់យកភេទបព្វជ្ជា។ ភាពជាបុគ្គលមិនមានផ្ទះនោះ រមែងធ្វើក្នុងព្រះសាសនា ឬក្នុងនិកាយនៃតាបស និងបរិព្វាជក ដែលជាកម្មវាទី និងកិរិយវាទី ទើបសម្រេចបាន ដូចសុមេធ-បណ្ឌិត ។ ពិតហើយ សុមេធបណ្ឌិតនោះ បួសជាតាបសឈ្មោះសុមេធ

ទើបតាំងសេចក្តីប្រាថ្នា ។

ការបានចំពោះគុណ មានឈានជាដើម ឈ្មោះថា មានគុណសម្បត្តិ ។ ពិតហើយ កាលបួសហើយ ត្រូវមានគុណប៉ុណ្ណោះ ទើបសេចក្តីប្រាថ្នាសម្រេច សម្រាប់បុគ្គលក្រៅអំពីនេះ មិនសម្រេចឡើយ ដូចសុមេធបណ្ឌិត ។ ពិតហើយ សុមេធបណ្ឌិតនោះ ជាអ្នកមានអភិញ្ញា ៥ និងជាអ្នកបានសមាបត្តិ ៨ ហើយ ទើបប្រាថ្នា ។

ការធ្វើដ៏ក្រៃលែង អធិប្បាយថា ការបរិច្ចាគ ឈ្មោះថា ធ្វើអធិការ ។ ពិតហើយ កាលបុគ្គលបរិច្ចាគជីវិតជាដើម ហើយប្រាថ្នានោះឯង សេចក្តីប្រាថ្នាទើបសម្រេច មិនសម្រេចដល់បុគ្គលក្រៅអំពីនេះ ដូចសុមេធបណ្ឌិត ។ ពិតហើយ សុមេធបណ្ឌិតនោះ ធ្វើនូវការបរិច្ចាគខ្លួន ហើយតាំងនូវសេចក្តីប្រាថ្នាយ៉ាងនេះថា

> សូមព្រះពុទ្ធ ព្រមទាំងពួកសិស្ស ជាន់អាត្មាអញ យាងទៅចុះ សូមកុំជាន់ភក់ឡើយ ការមិនជាន់លើភក់នោះ នឹងជាប្រយោជន៍ដល់អាត្មាអញ ដូច្នេះហើយ ទើបប្រាថ្នា ។

ភាពជាអ្នកប្រាថ្នាដើម្បីធ្វើ ឈ្មោះថា មានឆន្ទៈ ។ បុគ្គលណា មានឆន្ទៈខ្លាំងក្លា សេចក្តីប្រាថ្នា រមែងសម្រេចដល់បុគ្គលនោះ បើបុគ្គលណាមួយពោលថា អ្នកណានៅក្នុងនរកអស់ ៤ អសង្ខេយ្យ និង ១ សែនកប្បបាន ហើយប្រាថ្នាភាពជាព្រះពុទ្ធ ដូច្នេះ បុគ្គលណា បានស្តាប់ពាក្យនោះហើយ ហ៊ានប្រាប់ថា ខ្ញុំ ខ្ញុំ ដូច្នេះ គប្បីជ្រាបថា ឆន្ទៈរបស់បុគ្គលនោះខ្លាំងក្លា ។

ម្យ៉ាងទៀត បើមានបុគ្គលណាពោលថា អ្នកណាជាន់ចក្កវាឡទាំងមូលដែលពេញទៅដោយរងើកភ្លើង ប្រាសចាកអណ្តាតបាន ហើយសឹមប្រាថ្នាភាពជាព្រះពុទ្ធ បុគ្គលណាជាន់ចក្កវាឡទាំងមូល ដែលច្រងប្រាងដោយលំពែង និងចម្រូងផុតទៅបាន ហើយសឹមប្រាថ្នាភាពជាព្រះពុទ្ធ បុគ្គលណាឆ្លងចក្កវាឡទាំងមូល ដែលមានទឹកពេញប្រៀបទៅបាន ហើយសឹមប្រាថ្នាភាពជាព្រះពុទ្ធ បុគ្គលណាដើរជាន់ចក្កវាឡទាំងមូល ដែលពេញដោយគុម្ពឫស្សី មិនមានចន្លោះផុតទៅបាន ហើយសឹមប្រាថ្នាភាពជាព្រះពុទ្ធ ដូច្នេះ បុគ្គលណាបានស្តាប់ពាក្យនោះហើយ ហ៊ានពោលថា ខ្ញុំ ខ្ញុំ គប្បីជ្រាបថា បុគ្គលនោះជាអ្នកមានឆន្ទៈខ្លាំងក្លា ។ សុមេធបណ្ឌិតប្រកបដោយឆន្ទៈ ដែលធ្វើដូចដែលពោលមក ទើបប្រាថ្នា ។

ព្រះពោធិសត្វមានអភិនីហារ ដែលសម្រេចហើយយ៉ាងនេះ រមែងមិនចូលដល់អភព្វដ្ឋាន គឺឋានៈដែលមិនគួរ ១៨ ប្រការ គឺចាប់តាំងអំពីសម្រេចអភិនីហារហើយ ព្រះពោធិសត្វនោះ មិនជាមនុស្សខ្វាក់អំពីកំណើត ១ មិនជាមនុស្សថ្លង់អំពីកំណើត ១ មិនជាមនុស្សឆ្កួត ១ មិនជាមនុស្សគ ១ មិនជាមនុស្សខ្វិន ១ មិនកើតឡើងក្នុងពួកមិលក្ខ គឺមនុស្សព្រៃ ១ មិនកើតក្នុងផ្ទៃនាងទាសី ១ មិនជានិយតមិច្ឆាទិដ្ឋិ ១ មិនត្រឡប់ភេទ ( ជាស្រី ) ១ មិនធ្វើអនន្តរិយកម្មប្រាំ ១ មិនជាមនុស្សឃ្លង់ ១ ក្នុងកំណើតតិរច្ឆាន មិនមានរាងកាយតូចជាងចាប ១ មិនធំជាងដំរី ១ មិនកើតក្នុងខុប្បិបាសិកប្រេត និងនិជ្ឈាមតណ្ហិកប្រេត ១ មិនកើតក្នុងពួកកាឡកញ្ជិកាសុរ ១ មិនកើតក្នុង

អវិចីនរក ១ មិនកើតក្នុងលោកន្តរនរក ១ ក្នុងកាមាវចរ មិនកើតជាមារ ក្នុងរូបាវចរ មិនកើតក្នុងអសញ្ញីភព មិនកើតក្នុងជាន់សុទ្ធាវាស មិនកើតក្នុងអរូបភព មិនកើតក្នុងចក្កវាឡដទៃ ១ ។

ព្រះពោធិសត្វជាអ្នកប្រកបដោយពុទ្ធភូមិ ៤ គឺឧស្សាហ៍ ១ ឧម្មង្គៈ គឺបញ្ញា ១ អវត្ថានៈ គឺការតាំងចិត្តមាំ ១ ហិតចរិយា គឺការប្រព្រឹត្តប្រយោជន៍ ១ ក្នុងពុទ្ធភូមិ ៤ ប្រការនោះ គប្បីជ្រាបថា

សេចក្តីព្យាយាម ហៅថា ឧស្សាហៈ បញ្ញា ហៅថា ឧម្មង្គៈ
អធិដ្ឋាន ហៅថា អវត្ថានៈ មេត្តាភាវនា ហៅថា ហិតចរិយា ។

ម្យ៉ាងទៀត អជ្ឈាសយ ៦ ប្រការ គឺអធ្យាស្រ័យក្នុងនេក្ខម្មៈ ១ អធ្យាស្រ័យក្នុងវិវេក ១ អធ្យាស្រ័យក្នុងអលោភៈ ១ អធ្យាស្រ័យក្នុងអទោសៈ ១ អធ្យាស្រ័យក្នុងអមោហៈ ១ អធ្យាស្រ័យក្នុងនិស្សរណៈ គឺការលោស់ចេញចាកភព ១ រមែងប្រព្រឹត្តទៅដើម្បីបន្ទុំពោធិញ្ញាណ ។ ព្រោះប្រកបដោយអធ្យាស្រ័យពួកណា ទើបលោកហៅព្រះពោធិសត្វទាំងឡាយថា ជាអ្នកមានអធ្យាស្រ័យក្នុងនេក្ខម្មៈ ឃើញទោសក្នុងកាមទាំងឡាយ ហៅថា អ្នកមានអធ្យាស្រ័យក្នុងវិវេក ឃើញទោសក្នុងការច្រឡូកច្រឡំ ហៅថា អ្នកមានអធ្យាស្រ័យក្នុងអលោភៈ ឃើញទោសក្នុងការចង់បាន ហៅថា អ្នកមានអធ្យាស្រ័យក្នុងអទោសៈ ឃើញទោសក្នុងទោសៈ ហៅថា អ្នកមានអធ្យាស្រ័យក្នុងអមោហៈ ឃើញទោសក្នុងមោហៈ ហៅថា អ្នកមានអធ្យាស្រ័យក្នុងនិស្សរណៈ ឃើញទោសក្នុងភពទាំងពួង ។ ព្រះពោធិសត្វ

ដែលសម្រេចធ្វើអភិនីហារហើយ រមែងជាអ្នកប្រកបដោយអធ្យាស្រ័យទាំងនោះផងដែរ ។

សួរថា ការប្រាថ្នារបស់ព្រះបច្ចេកសម្ពុទ្ធ រមែងប្រព្រឹត្តទៅយូរប៉ុនណា ឆ្លើយថា សេចក្តីប្រាថ្នានៃព្រះបច្ចេកពុទ្ធទាំងឡាយ រមែងប្រព្រឹត្តទៅ ២ អសង្ខេយ្យ និង ១ សែនកប្ប មិនអាចតិចជាងនោះ គប្បីជ្រាបហេតុក្នុងការប្រាថ្នានោះ ដោយន័យដូចពោលខាងដើមនោះឯង ។ បុគ្គលប្រាថ្នាភាពជាព្រះបច្ចេកពុទ្ធ ដោយប្រើពេលដូចកំណត់នេះហើយ ត្រូវប្រើគុណសម្បត្តិ ៥ ក្នុងការធ្វើអភិនីហារ ( ការតាំងសេចក្តីប្រាថ្នា ) ។ ពិតហើយ ព្រះបច្ចេកសម្ពុទ្ធទាំងនោះ

ហេតុដែលធ្វើឲ្យអភិនីហារ របស់ព្រះបច្ចេកពុទ្ធទាំងនោះសម្រេច
គឺជាមនុស្ស ១ ដល់ព្រមដោយភេទ ១ បានជួបលោកអ្នក
ប្រាសចាកអាសវៈ ១ ធ្វើអធិការទុក ១ មានឆន្ទៈ ១ ។

បណ្តាពាក្យទាំងនោះ ពាក្យថា បានជួបលោកអ្នកប្រាសចាកអាសវៈ បានដល់ បានឃើញព្រះពុទ្ធ ព្រះបច្ចេកសម្ពុទ្ធ និងសាវករបស់ព្រះពុទ្ធណាមួយ ។ ពាក្យដ៏សេស មានន័យដូចពោលហើយនោះឯង ។

កាលបើដូច្នោះ សួរថា ការប្រាថ្នារបស់សាវកទាំងឡាយ ប្រព្រឹត្តទៅយូរប៉ុនណា ឆ្លើយថា សេចក្តីប្រាថ្នារបស់អគ្គសាវក ប្រព្រឹត្តទៅ ១ អសង្ខេយ្យ និង ១ សែនកប្ប របស់ព្រះអសីតិមហាសាវក ប្រព្រឹត្តទៅ ១ សែនកប្បប៉ុណ្ណោះ ។ សេចក្តីប្រាថ្នារបស់ពុទ្ធបិតា ពុទ្ធមាតា ពុទ្ធុបដ្ឋាក និង

ពុទ្ធបុត្រ ក៏ ១ សែនកប្បដូចគ្នា ព្រោះហេតុនោះ ទើបមិនអាចតិចជាងនោះ ហេតុក្នុងសេចក្ដីប្រាថ្នានោះ មានន័យដូចពោលហើយនោះឯង ។

តែសាវកទាំងនេះគ្រប់អង្គ ប្រើអភិនីហារត្រឹមយ៉ាង ២ គឺធ្វើអធិការ ១ មានឆន្ទៈ ១ ។

ព្រះពុទ្ធទាំងឡាយ កាលបំពេញបារមីទាំងឡាយ អស់កាលតាមដែលពោលហើយ ដោយសេចក្ដីប្រាថ្នានេះ និងដោយអភិនីហារនេះ យ៉ាងនេះហើយ កាលនឹងកើតឡើងក្នុងលោក រមែងកើតឡើងក្នុងត្រកូលក្សត្រ ឬត្រកូលព្រាហ្មណ៍ ។

ព្រះបច្ចេកពុទ្ធទាំងឡាយ រមែងកើតក្នុងត្រកូលក្សត្រ ត្រកូលព្រាហ្មណ៍ ឬត្រកូលគហបតី ត្រកូលណាមួយ ។

ឯអគ្គសាវក រមែងកើតឡើងចំពោះក្នុងត្រកូលក្សត្រ និងត្រកូលព្រាហ្មណ៍ ដូចព្រះពុទ្ធ ។

ព្រះពុទ្ធគ្រប់អង្គ មិនកើតឡើងក្នុងសំវដ្ដកប្ប គឺកប្បវិនាស រមែងកើតឡើងក្នុងវិវដ្ដកប្ប គឺកប្បចម្រើន ។ ព្រះបច្ចេកសម្ពុទ្ធទាំងឡាយក៏ដូចគ្នា ។

ម្យ៉ាងទៀត ព្រះបច្ចេកសម្ពុទ្ធទាំងឡាយ មិនកើតឡើងក្នុងកាលដែលព្រះពុទ្ធទាំងឡាយកើតឡើង ។ ព្រះពុទ្ធទាំងឡាយត្រាស់ដឹងដោយព្រះអង្គឯង និងញ៉ាំងឲ្យអ្នកដទៃដឹងបានផង ។ ព្រះបច្ចេកសម្ពុទ្ធទាំងឡាយត្រាស់ដឹងចំពោះខ្លួនឯង តែមិនញ៉ាំងអ្នកដទៃឲ្យត្រាស់ដឹង ។ ព្រះបច្ចេកសម្ពុទ្ធ រមែងចាក់ធ្លុះនូវអត្ថរសប៉ុណ្ណោះ មិនចាក់ធ្លុះនូវធម្មរស ។ ព្រោះព្រះបច្ចេកសម្ពុទ្ធទាំងនោះ

មិនអាចលើកលោកុត្តរធម៌ឡើងជាបទបញ្ញត្តិ ហើយសម្តែងទេ ។ ព្រះបច្ចេកសម្ពុទ្ធទាំងនោះ មានការត្រាស់ដឹងធម៌ដូចមនុស្សគ យល់សប្តិ និងដូចព្រានព្រៃ ភ្លក្សរសម្ហូបក្នុងនគរ ដូច្នោះ ។ លោកសម្រេចធម៌គ្រប់ប្រភេទ ដូចជាឥទ្ធិឫទ្ធិ សមាបត្តិ និងបដិបទាជាដើម ដោយភាពស្រស់ស្អាតនៃគុណវិសេសលោកជាអ្នកទាបជាងព្រះពុទ្ធ ខ្ពស់ជាងសាវ័ក លោកជាអ្នកឲ្យអ្នកដទៃបួសមិនបាន តែឲ្យសិក្សាអភិសមាចារិកវត្តបាន ធ្វើឧបោសថបាន ដោយមាតិកានេះថា គប្បីជុសខាត់ចិត្ត មិនគប្បីលះបង់ ឬធ្វើឧបោសថ ដោយត្រឹមតែពោលថា ថ្ងៃនេះ ជាថ្ងៃឧបោសថ កាលធ្វើឧបោសថ រមែងប្រជុំគ្នាធ្វើត្រង់រោងកែវ ត្រង់គល់មញ្ជូសកៈ គឺ ដើមឪលោក លើភ្នំគន្ធមាទន៍ ។

ព្រះមានព្រះភាគត្រាស់ប្រាប់សេចក្តីប្រាថ្នា និងអភិនីហារដែលបរិបូណ៌ដោយអាការទាំងពួងរបស់ព្រះបច្ចេកពុទ្ធទាំងឡាយ ដល់ព្រះអានន្ទយ៉ាងនេះហើយ ឥឡូវនេះ ដើម្បីត្រាស់ប្រាប់ព្រះបច្ចេកសម្ពុទ្ធនោះៗ ដែលប្រព្រឹត្តទៅព្រមដោយការប្រាថ្នានេះ និងដោយអភិនីហារនេះ ទើបត្រាស់ខគ្គវិសាណសូត្រនេះ ដោយន័យថា **សព្វេសុ ភូតេសុ និធាយ ទណ្ឌំ** ដូច្នេះជាដើម ។ នេះជាអត្ថុប្បត្តិហេតុនៃខគ្គវិសាណសូត្រ ដោយអំណាចការសួរ ដោយមិនពិសេស ។

ឥឡូវនេះ នឹងពោលការកើតឡើងនៃខគ្គវិសាណសូត្រ ចំពោះព្រះអង្គ ( ព្រះបច្ចេកពុទ្ធ ) ។ ក្នុងសេចក្តីនោះ គប្បីជ្រាបការកើតឡើងនៃគាថានេះយ៉ាងនេះ

បានឮថា ព្រះបច្ចេកសម្ពុទ្ធអង្គនេះ ឈមចុះកាន់ភូមិបច្ចេកពោធិសត្វ បំពេញបារមី ២ អសង្ខេយ្យ និង ១ សែនកប្ប បួសក្នុងសាសនាព្រះមានព្រះភាគកស្សបៈ ជាអ្នកសមាទានការនៅព្រៃជាវត្ត បំពេញគតបច្ចាគតវត្តឲ្យបរិបូណ៌ បានធ្វើសមណធម៌ហើយ ។ បានឮថា បុគ្គលមិនបំពេញវត្តដូចពោលនេះឲ្យបរិបូណ៌ នឹងសម្រេចបច្ចេកពោធិញ្ញាណមិនបាន ។ វត្តឈ្មោះគតបច្ចាគតវត្ត គឺអ្វី បានដល់ ការនាំទៅ និងនាំត្រឡប់មក ។ ខ្ញុំនឹងពោលរឿងជាការអធិប្បាយវត្តនោះឲ្យជាក់ច្បាស់ ដូច្នោះ ។

ភិក្ខុរូបខ្លះ ក្នុងសាសនានេះ នាំទៅ តែមិននាំត្រឡប់មក រូបខ្លះ នាំត្រឡប់មក តែមិននាំទៅ រូបខ្លះ មិននាំទៅ មិននាំត្រឡប់មក រូបខ្លះ នាំទៅផង នាំត្រឡប់មកផង ។ បណ្តាភិក្ខុទាំងនោះ ភិក្ខុណាក្រោកឡើងអំពីព្រឹមធ្វើវត្តត្រង់លានព្រះចេតិយ និងលានពោធិព្រឹក្ស ស្រោចទឹកត្រង់ដើមពោធិ៍ យកក្អមដងទឹករហូតពេញ នាំមកតម្កល់ក្នុងរោងទឹកផឹក ធ្វើអាចរិយវត្ត និងឧបជ្ឈាយវត្ត សមាទានខន្ធកវត្ត ៨២ និងមហាវត្ត ១៤ ហើយប្រព្រឹត្ត ។ ភិក្ខុនោះ ជម្រះរាងកាយហើយ ចូលកាន់សេនាសនៈ សម្ងំក្នុងទីអង្គុយដ៏ស្ងាត់ រហូតដល់ពេលភិក្ខាចារ ដឹងថា បានហើយ ស្លៀកស្បង់ ចងវត្តពន្ធ ដណ្តប់ចីវរធៀងស្មា យកសង្ឃាដីដាក់លើស្មា ស្ពាយបាត្រត្រង់ចង្កេះស្មា ដាក់ចិត្តដល់កម្មដ្ឋាន ដើរទៅត្រង់លានចេតិយ ថ្វាយបង្គំព្រះចេតិយ និងពោធិព្រឹក្ស ហើយដណ្តប់ចីវរក្នុងទីជិតស្រុក កាន់បាត្រចូលស្រុក ដើម្បីបិណ្ឌបាត ភិក្ខុដែលចូលទៅហើយយ៉ាងនេះ ជាអ្នកមានលាភ មានបុណ្យដែលពួកឧបាសក

ឧបាសិកាធ្វើសក្ការគោរព ត្រឡប់មកត្រង់ត្រកូលរបស់ឧបដ្ឋាក ឬរោងសម្នាក់ ដណ្តប់ចីវរពេលត្រឡប់ ត្រូវពួកឧបាសក និងឧបាសិកា សួរបញ្ហានោះៗ រមែងលះមនសិការនោះ ចេញអំពីស្រុកទៅ ព្រោះឆ្លើយបញ្ហារបស់ឧបាសក ឧបាសិកាទាំងនោះ និងព្រោះការវាយមាយ ដែលកើតអំពីការសម្តែងធម៌ មកកាន់វិហារ ត្រូវពួកភិក្ខុសួរបញ្ហា ក៏ត្រូវឆ្លើយបញ្ហាខ្លះ ពោលនូវធម៌ខ្លះ ដល់នូវការខ្វល់ខ្វាយក្នុងរឿងដទៃៗ ខ្លះ ខាតពេលជាមួយភិក្ខុទាំងនោះ ដោយប្រការយ៉ាងនេះ អស់កាលក្រោយកត្ត ទាំងបឋមយាម និងមជ្ឈិមយាម ត្រូវកាពគ្រោតគ្រាតផ្លូវកាយគ្របសង្កត់ ក្នុងបច្ឆិមយាមក៏ដេក មិនដាក់ចិត្តដល់កម្មដ្ឋាន ។ ភិក្ខុនេះ ហៅថា នាំទៅ តែមិននាំត្រឡប់មក ។

ឯភិក្ខុណា ជាអ្នកមានជំងឺច្រើន ឆាន់កត្តហើយ ក្នុងពេលជិតភ្លឺ អាហារមិនរលួយល្អ ក្នុងពេលព្រឹក មិនអាចក្រោកឡើងធ្វើវត្តតាមដែលពោលបាន ឬមិនអាចមនសិការកម្មដ្ឋានបាន តែត្រូវការបបរ របស់ទំពា ភេសជ្ជៈ ឬកត្ត គ្រាន់តែបានពេលប៉ុណ្ណោះ ក៏កាន់យកបាត្រ និងចីវរចូលស្រុក បាននូវបបរ របស់ទំពា ភេសជ្ជៈ ឬកត្តក្នុងស្រុកនោះហើយ នាំបាត្រចេញមក ធ្វើកត្តកិច្ចស្រេចហើយ អង្គុយលើអាសនៈដែលក្រាល ធ្វើទុកក្នុងចិត្តនូវកម្មដ្ឋាន សម្រេចគុណវិសេស ឬមិនសម្រេចក៏ដោយ ត្រឡប់មកកាន់វិហារ នៅតែមនសិការនោះឯង ភិក្ខុនេះ ហៅថា នាំត្រឡប់មក តែមិនបាននាំទៅ ។ ពិតហើយ ភិក្ខុបែបនេះ ឆាន់បបរហើយ ចម្រើនវិបស្សនា សម្រេចអរហត្តក្នុងព្រះពុទ្ធសាសនា មានរាប់មិនអស់ ក្នុងកោះសីហឡៈ អាសនៈតាមរោងឆាន់

ក្នុងស្រុកនោះៗ ដែលភិក្ខុទាំងឡាយអង្គុយឆាន់បបរហើយ មិនសម្រេចអរហត្ត មិនមានឡើយ ។

ឯភិក្ខុណា ជាអ្នកច្រើនដោយសេចក្តីប្រមាទ ដាក់នូវធុរៈ ទម្លាយវត្តទាំងពួង មានចិត្តចងដោយចំណង ដូចចេតោខីល ៥ យ៉ាង មិនធ្វើទុកក្នុងចិត្តនូវកម្មដ្ឋាន ចូលទៅបិណ្ឌបាតក្នុងស្រុក ក៏ឃើតឃូរ ដោយការជជែកនឹងពួកគ្រហស្ថ ជាមនុស្សទទេចាកចេញ ភិក្ខុនេះ ហៅថា មិននាំទៅ ទាំងមិននាំត្រឡប់មក ។

ឯភិក្ខុណា ក្រោកឡើងអំពីព្រលឹម ធ្វើវត្តគ្រប់យ៉ាងឲ្យគ្រប់បរិបូណ៌ដោយន័យដែលមានក្នុងកាលមុននោះឯង ពត់ក្អែន មនសិការដល់កម្មដ្ឋានរហូតដល់វេលាភិក្ខាចារ ។ ធម្មតាកម្មដ្ឋាន មាន ២ យ៉ាង គឺសព្វត្ថកម្មដ្ឋាន កម្មដ្ឋានដែលប្រើគ្រប់ស្ថាន និងបារិហារិយកម្មដ្ឋាន កម្មដ្ឋានដែលត្រូវបរិហារ ។ ក្នុងកម្មដ្ឋាន ២ យ៉ាងនោះ មេត្តា និងមរណានុស្សតិ ឈ្មោះថា សព្វត្ថកម្មដ្ឋាន ព្រោះកម្មដ្ឋានដូចពោលនេះ ចាំបាច់ក្នុងទីគ្រប់កន្លែង ព្រោះហេតុនោះ ទើបហៅថា សព្វត្ថកម្មដ្ឋាន ។ ធម្មតាមេត្តា ចាំបាច់ក្នុងទីទាំងពួង មានក្នុងអាវាសជាដើម ។ ពិតហើយ ភិក្ខុដែលមានប្រក្រតីនៅដោយមេត្តាក្នុងអាវាសទាំងឡាយ រមែងជាទីស្រឡាញ់ ជាទីពេញចិត្តរបស់សព្រហ្មចារីទាំងឡាយ ដោយមេត្តានោះ ធ្វើឲ្យនៅយ៉ាងផាសុក មិនខ្ទាំងខ្ទប់គ្នា ។ ភិក្ខុមានប្រក្រតីនៅដោយមេត្តាក្នុងទេវតាទាំងឡាយ និងជាបុគ្គលដែលពួកទេវតារក្សាគ្រប់គ្រងនៅជាសុខ ។ ភិក្ខុមានប្រក្រតីនៅដោយមេត្តាក្នុងព្រះរាជា និង

មហាមាត្យរបស់ព្រះរាជាជាដើម ជាបុគ្គលដែលព្រះរាជា និងមហាមាត្យទាំងនោះស្រឡាញ់រាប់អានទៅជាសុខ ។ ភិក្ខុអ្នកមានប្រក្រតីនៅដោយមេត្តាក្នុងគាម និងនិគមជាដើម ជាបុគ្គលដែលមនុស្សទាំងឡាយក្នុងទីគ្រប់កន្លែង មានទីត្រាច់ភិក្ខាចារជាដើម ធ្វើសក្ការៈ គោរព រមែងនៅជាសុខ ។ ដោយការចម្រើនមរណានុស្សតិ ភិក្ខុ រមែងលះនូវការជាប់ជំពាក់ក្នុងជីវិត ជាអ្នកនៅដោយមិនប្រមាទ ។

ឯកម្មដ្ឋានដែលត្រូវបរិហារសព្វកាល ជាកម្មដ្ឋានដែលរៀនយក តាមសមគួរដល់ចរិត ជាកម្មដ្ឋានណាមួយ ក្នុងបណ្ដាអសុភ ១០ កសិណ ១០ និងអនុស្សតិ ១០ ឬចតុធាតុវវដ្ឋាន ហៅថា បារិហារិយកម្មដ្ឋាន ព្រោះចាំបាច់ត្រូវបរិហារ ចាំបាច់ត្រូវរក្សា និងចាំបាច់ត្រូវចម្រើនសព្វកាល ។ បារិ-ហារិយកម្មដ្ឋាននោះឯង ហៅថា មូលកម្មដ្ឋានក៏បាន ។

កុលបុត្រណាប្រាថ្នាប្រយោជន៍ បួសក្នុងសាសនា នៅរួមគ្នា ១០ ឆ្នាំខ្លះ ២០ ឆ្នាំខ្លះ ៣០ ឆ្នាំខ្លះ ៤០ ឆ្នាំខ្លះ ៥០ ឆ្នាំខ្លះ ១០០ ឆ្នាំខ្លះ ធ្វើកតិកាវត្តថា អាវុសោទាំងឡាយ អ្នកទាំងឡាយមិនមែនបួស ព្រោះជាកូនបំណុល មិនមែនបួសព្រោះមានភ័យ មិនមែនបួសដើម្បីចិញ្ចឹមជីវិត តែបំណងនឹងរួចផុតចាកទុក្ខ ទើបបានបួសក្នុងសាសនានេះ ព្រោះហេតុនោះ កិលេសកើតក្នុងពេលដើរ អ្នកទាំងឡាយ ចូរសង្កត់សង្កិនក្នុងពេលដើរនោះឯង កិលេសដែលកើតក្នុងពេលឈរ ចូរសង្កត់សង្កិនក្នុងពេលឈរនោះឯង កិលេសដែលកើតក្នុងពេលអង្គុយ ចូរសង្កត់សង្កិនក្នុងពេលអង្គុយនោះឯង កិលេសដែល

កើត ក្នុងពេលដេក ចូរសង្កត់សង្កិនក្នុងពេលដេកនោះឯង ។

កុលបុត្រទាំងនោះ កាលធ្វើកតិកាវត្តយ៉ាងនេះហើយ ខណៈដើរទៅបិណ្ឌបាតក្នុងរវាងកន្ទះឧសភ មួយឧសភ កន្ទះគាវុត និងមួយគាវុត មានថ្មទំនេរ ក៏យកដុំថ្មនោះ ជាទីចំណាំ ធ្វើទុកក្នុងចិត្តដល់កម្មដ្ឋានដើរទៅ ។ បើក្នុងពេលដើរទៅ កិលេសកើតឡើងដល់បុគ្គលណា បុគ្គលនោះ រមែងសង្កត់កិលេសនោះ ក្នុងពេលដើរនោះឯង បើធ្វើយ៉ាងនោះមិនបាន ក៏ឈប់ហើយឈរ កាលភិក្ខុនិមន្តមកតាមក្រោយ ក៏ឈប់ដូចគ្នា ។ បុគ្គលនោះនឹងចោទខ្លួនឯងឡើងថា ភិក្ខុនេះ ដឹងនូវការត្រិះរិះដែលកើតឡើងហើយដល់អ្នក សេចក្ដីនេះ មិនសមគួរដល់អ្នក ដូច្នេះហើយ ចម្រើនវិបស្សនា រមែងឈានចុះកាន់អរិយភូមិក្នុងគ្រាឈរនោះឯង កាលមិនអាចធ្វើយ៉ាងនោះ ទើបអង្គុយ កាលភិក្ខុនិមន្តមកតាមក្រោយទាន់គ្នា ក៏អង្គុយដែរ បែបនេះរឿយៗ ទៅ កាលមិនអាចឈានចុះកាន់អរិយភូមិ ក៏សង្កត់កិលេសនោះហើយ ដាក់ចិត្តដល់កម្មដ្ឋានប៉ុណ្ណោះ ដើរទៅ បើមានចិត្តឃ្លាតចាកកម្មដ្ឋាន កុំលើកជើង បើលើកជើង ត្រូវត្រឡប់មកឈរក្នុងទីដើមសិន ដូចព្រះមហាផុស្សទេវត្ថេរនៅក្នុងអាលិន្ទកៈ ។

បានឮថា ព្រះថេរៈនោះបំពេញគតបច្ចាគតវត្តយ៉ាងមាំទាំ អស់ ១៩ ឆ្នាំ ឯមនុស្សទាំងឡាយ ភ្ជួរស្រែ ព្រោះស្រូវ ដកសំណាប ធ្វើការងារក្នុងវាងផ្លូវ ឃើញព្រះថេរៈដើរទៅយ៉ាងនោះ ទើបនិយាយគ្នាថា ព្រះថេរៈដើរត្រឡប់ទៅត្រឡប់មក គង់វង្វេងផ្លូវ ឬភ្លេចអ្វីមួយ ។ ព្រះថេរៈមិនដាក់ចិត្ត

ក្នុងវាចានោះ មានចិត្តប្រកបដោយកម្មដ្ឋានតែម្យ៉ាង ធ្វើនូវសមណធម៌ ខាងក្នុង ២០ ឆ្នាំ ក៏បានសម្រេចអរហត្ត ។ ក្នុងថ្ងៃដែលព្រះថេរៈនោះ សម្រេចអរហត្តនោះឯង ទេវតាដែលអាស្រ័យត្រង់ចុងចង្រ្កម បានឈរយកម្រាមដៃទាំងឡាយ ធ្វើពន្លឺឲ្យភ្លឺឡើង ស្តេចមហារាជទាំង ៤ សក្កទេវរាជ និងសហម្បតីព្រហ្ម ក៏នាំគ្នាមកកាន់ទីបម្រើ ។ ព្រះមហាតិស្សត្ថេរដែលនៅក្នុងព្រៃ បានឃើញពន្លឺនោះក្នុងថ្ងៃទី ២ ទើបសួរថា ក្នុងពេលយប់មានពន្លឺក្នុងសម្នាក់របស់អាវុសោ ពន្លឺនោះ គឺពន្លឺអ្វី ព្រះថេរៈកាលធ្វើនូវកាលបន្ទប់ ទើបពោលពាក្យយ៉ាងនេះថា ធម្មតាពន្លឺ ជាពន្លឺរបស់ប្រទីបក៏មាន ជាពន្លឺរបស់កែវមណីក៏មាន ព្រះថេរៈចាប់ចំណុចបានថា លោកម្ចាស់បិទបាំងឬ ទើបទទួលថា ករុណា ហើយប្រាប់ ។

ដូចព្រះមហានាគត្ថេរ អ្នកនៅក្នុងកាឡវល្លិមណ្ឌប បានឮថា ព្រះថេរៈនោះ កាលបំពេញគតបច្ចាគតវត្ត ទើបគិតថា ខាងដើម អញនឹងបូជាព្រះមហាបធានរបស់ព្រះមានព្រះភាគ ហើយអធិដ្ឋានការឈរ និងការចង្រ្កម ប៉ុណ្ណោះ អស់ ៧ ឆ្នាំ បានបំពេញគតបច្ចាគតវត្ត ១៦ ឆ្នាំ ទើបសម្រេចអរហត្ត ។ ព្រះថេរៈមានចិត្តមាំក្នុងកម្មដ្ឋានយ៉ាងនេះឯង ទើបលើកជើង កាលលើកជើងឡើង ចិត្តប្រាសចាកកម្មដ្ឋាន ទើបបែរត្រឡប់មក លោកទៅរហូតជិតស្រុកហើយ ឈរក្នុងទីដែលអ្នកស្រែគួរសង្ស័យថា ជាគោ ឬជាបព្វជិតហ្ន៎ ទើបដណ្តប់សង្ឃាដី កាន់បាត្រទៅដល់ទ្វារស្រុក ហើយយកទឹកអំពីកុណ្ឌីដែលត្បៀតត្រង់កន្ទោះក្លៀកមកបៀមហើយ ទើបចូលស្រុក ដោយគិតថា

អាត្មាអញកុំបីលះបង់កម្មដ្ឋាន ដោយហេតុត្រឹមតែពោលនឹងពួកមនុស្សដែលចូលទៅរក ដើម្បីប្រគេនភិក្ខា ឬដើម្បីថ្វាយបង្គំថា ចូរមានអាយុវែងចុះ ។ បើពួកគេសួរដល់ថ្ងៃថា បពិត្រលោកម្ចាស់ ថ្ងៃនេះជាថ្ងៃ ៧ ឬថ្ងៃ ៨ លោកខ្ពាក់ទឹកហើយ ទើបប្រាប់ បើមិនមានបុគ្គលសួរដល់ថ្ងៃក្នុងពេលចេញទៅ លោកខ្ពុរមាត់ត្រង់ទ្វារស្រុកហើយ ដើរទៅ ។

និងដូចភិក្ខុ ៥០ រូប ចាំវស្សាក្នុងកលម្ពតិត្ថវិហារ ក្នុងកោះសីហឡ ។ បានឮថា ក្នុងថ្ងៃឧបោសថ ជិតចូលវស្សា ភិក្ខុទាំងនោះ បានធ្វើកតិកាគ្នាថា យើងទាំងឡាយ បើមិនសម្រេចអរហត្ត នឹងមិននិយាយគ្នា ។ កាលចូលស្រុកដើម្បីបិណ្ឌបាត ក៏បៀមទឹកត្រង់ទ្វារស្រុកហើយ ទើបចូលទៅ ។ កាលគេសួរដល់ថ្ងៃ ក៏ខ្ពាក់ទឹកហើយ ទើបប្រាប់ កាលមិនមានអ្នកសួរ ក៏ខ្ពុរចោលត្រង់ទ្វារស្រុក ហើយត្រឡប់មកកាន់វិហារ ។ មនុស្សទាំងឡាយក្នុងទីនោះ ឃើញស្នាមទឹកដែលខ្ពុរក៏ដឹងបានថា ថ្ងៃនេះ មកមួយរូប ថ្ងៃនេះ មកពីររូប នាំគ្នាគិតយ៉ាងនេះថា ភិក្ខុទាំងនេះ មិននិយាយជាមួយពួកយើង ឬមិននិយាយគ្នានិងគ្នា បើមិននិយាយដល់គ្នា គង់កើតជម្លោះពិត ណ្ហើយចុះ ពួកយើងនឹងឲ្យភិក្ខុទាំងនោះ ខមាទោសដល់គ្នានិងគ្នា មនុស្សទាំងឡាយក៏នាំគ្នាទៅកាន់វិហារ កាលភិក្ខុ ៥០ រូបនៅក្នុងវិហារនោះ ចូលវស្សា មិនឃើញភិក្ខុ ២ រូប ក្នុងទីតែមួយ ។ លំដាប់នោះ បណ្តាមនុស្សទាំងនោះ បុរសមានភ្នែកល្អពោលយ៉ាងនេះថា លោកដ៏ចម្រើនទាំងឡាយ ឱកាសនៃអ្នកទាស់ទែងគ្នាមិនដូច្នេះឡើយ លានព្រះចេតិយ លានពោធិព្រឹក្ស ស្អាតបាត អំបោស

ក៏រក្សាបានរៀបរយ ទឹកផឹក ទឹកប្រើប្រាស់ ក៏តម្កល់បានល្អ បន្ទាប់អំពីនោះ មនុស្សទាំងនោះក៏នាំគ្នាត្រឡប់ ។ ខាងក្នុងវស្សានោះឯង ភិក្ខុទាំងនោះចម្រើនវិបស្សនា បានសម្រេចអរហត្ត ក្នុងថ្ងៃមហាបវារណា ទើបបវារណាជាវិសុទ្ធិប្បវារណា ។

ភិក្ខុដូចគ្នានឹងព្រះមហានាគត្ថេរ ដែលនៅក្នុងកាឡវល្លិមណ្ឌប និងដូចភិក្ខុដែលនៅចាំវស្សា ក្នុងកលម្ពតិត្ថវិហារយ៉ាងនេះហើយ ភិក្ខុមានចិត្តប្រកបដោយកម្មដ្ឋានតែម្យ៉ាង ឈានជើងទៅ កាលចូលទៅក្បែរ ទើបបៀមទឹកកំណត់ផ្លូវ ដែលមិនមានបុគ្គលចាំរករឿង មានអ្នកលេងសុរាជាដើម ឬដីរកាច សេះកាចជាដើម ហើយដើរទៅតាមផ្លូវនោះ ។ កាលត្រាច់បិណ្ឌបាតក្នុងផ្លូវនោះ កុំប្រញាប់ប្រញាល់ទៅ ។ ឈ្មោះថា ធុតង្គរបស់ភិក្ខុដែលត្រាច់បិណ្ឌបាត ដើរដោយរហ័ស មិនមាន នឹងដើរត្រង់ៗ ដូចរទេះផ្ទុកពេញ ធ្លងទីមិនរាបស្មើ ។ ដល់លំដាប់ស្រុកហើយ រង់ចាំកាល ដែលសមគួរជាមុនដើម្បីមើលថា មានមនុស្សពេញចិត្តប្រគេន ឬមិនប្រគេន ទទួលភិក្ខាមកហើយ អង្គុយក្នុងទីដែលសមគួរ កាលដាក់ចិត្តក្នុងកម្មដ្ឋាន ឲ្យចម្រើនអាហារេបដិកូលសញ្ញា ពិចារណាដោយប្រៀបធៀបដោយប្រេងបន្តក់ភ្លៅរទេះ ថ្នាំលាបដំបៅ និងសាច់កូន បរិភោគអាហារ ដែលប្រកបដោយអង្គ ៨ គឺមិនមែនដើម្បីលេង មិនមែនដើម្បីស្រវឹង ។បេ។ និងបរិភោគហើយ ធ្វើកិច្ចដោយទឹក បន្ទោបង់នូវសេចក្តីលំបាកព្រោះភត្តមួយស្របក់ ហើយធ្វើទុកក្នុងចិត្តនូវកម្មដ្ឋានអស់កាលខាងក្រោយភត្ត អស់បឋមយាម និងបច្ឆិមយាម

ដូចកាលមុនកត្ត ។ ភិក្ខុនេះ ហៅថា នាំទៅផង នាំត្រឡប់មកផង ។ ការនាំទៅ និងការនាំត្រឡប់មកនេះ យ៉ាងនេះ ហៅថា **គតបច្ចាគតវត្ត។**

ភិក្ខុបំពេញវត្តនេះ បើជាអ្នកដល់ព្រមដោយឧបនិស្ស័យ រមែងសម្រេចអរហត្តក្នុងបឋមវ័យនោះឯង បើមិនសម្រេចក្នុងបឋមវ័យ ក៏នឹងសម្រេចក្នុងមជ្ឈិមវ័យ បើមិនសម្រេចក្នុងមជ្ឈិមវ័យ ក៏សម្រេចក្នុងពេលជិតស្លាប់ បើមិនសម្រេចក្នុងពេលជិតស្លាប់ បានជាទេវបុត្រហើយ នឹងសម្រេច បើជាទេវបុត្រមិនសម្រេច ក៏នឹងបានជាព្រះបច្ចេកពុទ្ធ ហើយបរិនិព្វាន ។ បើមិនបានជាព្រះបច្ចេកសម្ពុទ្ធបរិនិព្វាន ក៏នឹងបានជាខិប្បាភិញ្ញា ក្នុងកាលបានជួបព្រះភក្ត្រព្រះពុទ្ធទាំងឡាយ ដូចព្រះពាហិយត្ថេរ ឬនឹងជាអ្នកមានបញ្ញាច្រើនដូចព្រះសារីបុត្តត្ថេរ ។

បច្ចេកពោធិសត្វអង្គនេះ បួសក្នុងសាសនារបស់កស្សបព្រះមានព្រះភាគជាអ្នកសមាទានការនៅព្រៃជាវត្ត បំពេញគតបច្ចាគតវត្តនេះអស់ ២ ម៉ឺនឆ្នាំធ្វើកាលកិរិយាហើយ កើតក្នុងកាមាវចរទេវលោក ។ ចុតិអំពីនោះហើយបដិសន្ធិក្នុងគភ៌នៃអគ្គមហេសីរបស់ព្រះបាទពារាណសី ។ ស្ត្រីទាំងឡាយដែលជាអ្នកឈ្លាស រមែងដឹងនូវការតាំងគភ៌ក្នុងថ្ងៃនោះឯង ។ អគ្គមហេសីនោះក៏ជាស្ត្រីមួយអង្គ ក្នុងចំនួនស្ត្រីទាំងនោះ ព្រោះហេតុនោះ អគ្គមហេសីនោះក៏ក្រាបទូលនូវការតាំងគភ៌ដល់ព្រះរាជា ។ កាលសត្វអ្នកមានបុណ្យកើតឡើងក្នុងគភ៌ ស្ត្រី រមែងបាននូវការបរិហារគភ៌នោះ សេចក្តីនេះ ជាធម្មតា ព្រោះហេតុនោះ ទើបព្រះរាជាបានប្រទាននូវការបរិហារគភ៌ ដល់អគ្គមហេសី

នោះ ។ ចាប់តាំងអំពីនោះ ព្រះនាងមិនបានបរិភោគរបស់ដែលក្តៅខ្លាំង ត្រជាក់ខ្លាំង ជូរខ្លាំង ប្រៃខ្លាំង ហឹរខ្លាំង និងល្វីងខ្លាំង ។ ព្រោះកាលមាតាបរិភោគរបស់ក្តៅខ្លាំង សត្វដែលកើតក្នុងគភ៌ រមែងដូចនៅក្នុងលោហកុម្ភីនរក កាលបរិភោគរបស់ត្រជាក់ពេក រមែងដូចនៅក្នុងលោកន្តរនរក កាលបរិភោគនូវរបស់ជូរពេក ប្រៃពេក ហឹរពេក ល្វីងពេក អវយវៈរបស់ទារកដល់នូវវេទនាដ៏ខ្លាំងក្លា ដូចត្រូវកាត់ដោយកាំបិត ស្រោចដោយទឹកក្បុងជាដើម ។ អ្នកបរិហារគភ៌ទាំងឡាយ ទើបហាមព្រះនាងដោយការដើរច្រើន ឈរច្រើន អង្គុយច្រើន និងដេកច្រើន ដោយបំណងថា ទារកនៅក្នុងគភ៌ កុំលំបាកព្រោះការកម្រើកឡើយ ។ ព្រះនាងបានទទួលអនុញ្ញាតឲ្យដើរទៅមកជាដើម យ៉ាងគ្រប់គ្រាន់ លើទីដែលក្រាលដោយកម្រាលដ៏ទន់ បានសោយបាយ និងទឹកដែលសមគួរ ឆ្ងាញ់ បរិបូណ៌ដោយពណ៌ និងក្លិនជាដើម អ្នកថែរក្សា ចាំផ្គងឲ្យព្រះនាងយាង គង់ និងក្រោកឡើង ។

ព្រះនាងដែលគេបរិហារយ៉ាងនេះ ក្នុងពេលព្រះគភ៌ចាស់ យាងចូលផ្ទះប្រសូត ក្នុងពេលជិតភ្លឺ ប្រសូតព្រះឱរស ដូចគ្នានឹងដុំមនោសិលា ដែលលាបដោយប្រេងដែលចម្រាញ់ហើយ ប្រកបដោយធញ្ញលក្ខណៈ និងបុញ្ញលក្ខណៈ ។ ក្នុងថ្ងៃទី ៥ បន្ទាប់អំពីថ្ងៃនោះ ព្រះញាតិទាំងឡាយ ក៏នាំព្រះរាជឱរស ដែលតាក់តែងគ្រឿងអលង្ការហើយ ទៅថ្វាយព្រះរាជាទត ។ ព្រះរាជាទ្រង់សប្បាយព្រះហឫទ័យ ឲ្យទំនុកបម្រុងដោយមេដោះ ៦៦ នាក់ ។ ព្រះរាជឱរសនោះចម្រើនដោយសម្បត្តិទាំងពួង មិនយូរប៉ុន្មាន ទ្រង់ក៏សម្រេច

កាពជាអ្នកជីនក្តី ព្រះរាជា ទ្រង់អភិសេកព្រះរាជឱរស ដែលមានព្រះជន្ម ១៦ វស្សានោះ ដោយរាជសម្បត្តិ និងឲ្យបម្រើដោយអ្នករបាំផ្សេងៗ ព្រះរាជឱរសអភិសេកហើយ មានព្រះនាមថា ព្រហ្មទត្ត គ្រងរាជសម្បត្តិក្នុងនគរ ២ ម៉ឺន ក្នុងសកលជម្ពូទ្វីប ។ បានឮថា ជម្ពូទ្វីបក្នុងកាលមុន មាននគរ ៨៤០០០ នគរទាំងនោះវិនាសទៅ សល់ត្រឹមតែ ៦ ម៉ឺននគរ បន្ទាប់អំពីនោះវិនាសទៅនៅសល់ត្រឹមតែ ៤ ម៉ឺននគរ ក្នុងពេលចុងក្រោយនៅសល់ត្រឹមតែ ២ ម៉ឺននគរ ។ ព្រះបាទព្រហ្មទត្តនេះ កើតឡើងក្នុងពេលនគរវិនាសអស់ ព្រោះហេតុនោះ ទើបព្រះបាទព្រហ្មទត្ត មាននគរ ២ ម៉ឺន មានប្រាសាទ ២ ម៉ឺន មានពលដំរី ២ ម៉ឺន មានពលសេះ ២ ម៉ឺន មានរថ ២ ម៉ឺន មានពលថ្មើរជើង ២ ម៉ឺន មានស្នំ និងអ្នករបាំ ២ ម៉ឺន មានអមាត្យ ២ ម៉ឺននាក់ ។

ព្រះបាទព្រហ្មទត្តនោះ ទ្រង់គ្រងមហារាជសម្បត្តិនោះឯង ទ្រង់ធ្វើនូវកសិណបរិកម្ម ទ្រង់ធ្វើអភិញ្ញា ៥ និងសមាបត្តិ ៨ ឲ្យកើតឡើងបាន ។ ព្រោះថា ព្រះរាជាដែលអភិសេកហើយ ត្រូវគង់ប្រថាប់ក្នុងសាលជាប្រចាំ ព្រោះហេតុនោះ ព្រឹកថ្ងៃមួយ សោយព្រះក្រយាហារព្រឹកហើយ គង់ប្រថាប់ក្នុងទីវិនិច្ឆ័យ ។ ក្នុងទីនោះ ពួកមនុស្សបានធ្វើសំឡេងអឺងកង ទ្រង់ព្រះតម្រិះថា សំឡេងនេះ ជាឧបក្កិលេសនៃសមាបត្តិ ទើបឡើងកាន់ប្រាសាទ គង់ប្រថាប់ បំណងនឹងចូលសមាបត្តិ ក៏មិនអាចចូលបាន ព្រោះក្រវល់ក្រវាយនិងការគ្រប់គ្រងរាជ្យ ទើបសមាបត្តិវិនាស ។

លំដាប់នោះ ទើបទ្រង់ព្រះតម្រិះថា រាជសម្បត្តិប្រសើរ ឬសមណធម៌

ប្រសើរ បន្ទាប់អំពីនោះ ទ្រង់ជ្រាបថា សេចក្តីសុខក្នុងរាជសម្បត្តិបន្តិចបន្តួច មានទោសច្រើន តែសេចក្តីសុខក្នុងសមណធម៌ទូលំទូលាយ មានអានិសង្ស មិនមែនតិច បុរសដ៏ឧត្តមសេពហើយ ទើបទ្រង់បញ្ជាអមាត្យម្នាក់ថា ចូរអ្នក គ្រប់គ្រងរាជសម្បត្តិនេះដោយធម៌ស្មើ កុំគ្រប់គ្រងដោយអធម៌ ដូច្នេះហើយ ទ្រង់ប្រគល់រាជសម្បត្តិទាំងពួងឲ្យដល់អមាត្យនោះ ហើយឡើងកាន់ប្រាសាទ ទ្រង់ឲ្យពេលវេលាកន្លងទៅដោយសេចក្តីសុខក្នុងសមាបត្តិ បុគ្គលណាម្នាក់ ចូលទៅគាល់មិនបាន វៀរលែងតែអ្នកថ្វាយទឹកលុបព្រះភក្ត្រ និងឈើស្ទន់ និងអ្នកនាំព្រះក្រយាហារទៅថ្វាយជាដើម ។

តមក ក្នុងកាលកន្លងទៅកន្លះខែ ព្រះមហេសីត្រាស់សួរថា មិនឃើញ ព្រះរាជាក្នុងទីណាមួយ ក្នុងការយាងទៅប្រពាតឧទ្យាន ការត្រួតពល និង ការមើលស្រីរបាំជាដើម ព្រះរាជាទ្រង់យាងទៅណា ។ អាមាត្យទាំងឡាយ ក៏ក្រាបទូលសេចក្តីនោះ ដល់ព្រះមហេសី ។ ព្រះនាងបញ្ជូនដំណឹងទៅប្រាប់ អមាត្យថា កាលអ្នកទទួលរាជសម្បត្តិ សូម្បីខ្ញុំក៏ឈ្មោះថា អ្នកទទួលដែរ ចូរអ្នកមកសម្រេចការនៅរួមជាមួយខ្ញុំ ។ អមាត្យនោះបិទត្រចៀកទាំង ២ បដិសេធថា សេចក្តីនេះ ធ្វើមិនបាន ។ ព្រះនាងក៏បញ្ជូនដំណឹងទៅទៀតអស់ វារៈ ២-៣ ដង ឲ្យគំរាមអមាត្យនោះដែលមិនប្រាថ្នាថា បើអ្នកមិនធ្វើ យើង នឹងដកតំណែង នឹងឲ្យផ្តាច់ជីវិតលោក អមាត្យនោះខ្លាច គិតថា ធម្មតា មាតុគ្រាម ជាអ្នកចិត្តដាច់ ជួនកាល អាចឲ្យធ្វើដូចព្រះសវនីយ៍នោះ ថ្ងៃមួយ ទៅកាន់ទីស្ងាត់ សម្រេចការនៅរួមជាមួយព្រះនាង លើព្រះសិរីសយនាសនៈ ។

ព្រះនាងជាស្រីមានបុណ្យ មានសម្ផស្សទន់ អមាត្យនោះ ត្រេកអរហើយ ដោយតម្រេកក្នុងសម្ផស្សរបស់ព្រះនាង រង្គៀសផង សង្វៀយផងនោះឯង ក៏បានទៅក្នុងទីនោះរឿយៗ តមក អស់សេចក្តីរង្គៀស ចេញចូលដូចខ្លួនជាម្ចាស់ផ្ទះ ។

លំដាប់នោះ មនុស្សរបស់ព្រះរាជាបានក្រាបទូលរឿងនោះដល់ព្រះរាជា ព្រះរាជាទ្រង់មិនជឿ ទើបនាំគ្នាក្រាបទូលអស់វារៈ ២ ដង ។ គ្រានោះ ព្រះរាជាទ្រង់លបទៅ បានឃើញដោយព្រះអង្គឯង ទើបត្រាស់ឲ្យប្រជុំអមាត្យទាំងអស់ ហើយប្រាប់ឲ្យជ្រាប ។ អមាត្យទាំងនោះ ក្រាបទូលថា អមាត្យនេះ ខុសចំពោះព្រះរាជា គួរកាត់ដៃកាត់ជើងដាក់ទោសផ្លូវកាយគ្រប់ប្រភេទ រហូតដល់ការដោតដោយលំពែង ។ ព្រះរាជាត្រាស់ថា ក្នុងការសម្លាប់ ការចង និងការវាយបុរសនេះ វិហិង្សា ក៏គប្បីកើតឡើងដល់យើង ក្នុងការផ្តាច់ជីវិត បាណាតិបាតក៏គប្បីកើត ក្នុងការរឹបអូសយកទ្រព្យ អទិន្នាទានគប្បីកើតឡើង មិនគួរធ្វើកម្មបែបនេះ ចូរពួកអ្នកបណ្តេញអមាត្យនេះចេញអំពីអាណាចក្ររបស់យើង ។ អមាត្យទាំងឡាយ បានធ្វើអាមាត្យនោះឲ្យជាមនុស្សមិនមានទីពឹង ។ បុរសនោះក៏នាំយកទ្រព្យ ភរិយា និងបុត្ររបស់ខ្លួនដែលល្មមនាំយកទៅបាន ទៅកាន់ដែននៃព្រះរាជាដទៃ ។ ព្រះរាជាក្នុងដែននោះទ្រង់ជ្រាប ទើបត្រាស់សួរថា អ្នកមកធ្វើអ្វី អមាត្យនោះក្រាបទូលថា បពិត្រព្រះសម្មតិទេព ខ្ញុំព្រះអង្គប្រាថ្នាចង់បម្រើព្រះអង្គ ព្រះរាជានោះក៏ទទួល ។ លុះកន្លងទៅ ២-៣ ថ្ងៃ អមាត្យបានស្និទ្ធស្នាលហើយ បាន

ក្រាបទូលពាក្យនេះ នឹងព្រះរាជានោះថា បពិត្រមហារាជ ទូលបង្គំឃើញឃ្មុំ ដែលមិនមានមេ អ្នកបរិភោគទឹកឃ្មុំនោះ ក៏មិនមាន ។ ព្រះរាជាទ្រង់ព្រះតម្រិះថា បុរសនេះ និយាយបែបនោះគង់និយាយលេង ទើបទ្រង់មិនស្តាប់ ។ អមាត្យនោះបានឱកាស ក៏ពណ៌នាក្រាបទូលឲ្យល្អក្រៃលែងឡើងទៀត ព្រះរាជាត្រាស់សួរថា ទឹកឃ្មុំនោះ គឺអ្វី អមាត្យនោះក្រាបទូលថា បពិត្រព្រះសម្មតិទេព រាជសម្បត្តិក្នុងនគរពារាណសី ។ ព្រះរាជាត្រាស់ថា លោកបំណងនាំយើងឲ្យទៅស្លាប់ឬ អមាត្យនោះក្រាបទូលថា បពិត្រព្រះសម្មតិទេព ទ្រង់កុំត្រាស់យ៉ាងនោះ បើទ្រង់មិនជឿ សូមទ្រង់បញ្ជូនមនុស្សទៅស៊ើបមើល ។ ព្រះរាជាក៏ទ្រង់បញ្ជូនមនុស្សទាំងឡាយទៅ មនុស្សទាំងនោះ ទៅដល់ហើយ ទើបជីកខ្លោងទ្វារ ហើយផុសឡើងក្នុងដំណាក់ត្រង់ទីបន្ទំរបស់ព្រះរាជា ព្រះរាជាទ្រង់ឃើញហើយ ទើបត្រាស់សួរថា ពួកអ្នកមកធ្វើអ្វី មនុស្សទាំងនោះក្រាបទូលថា ទូលបង្គំទាំងឡាយជាចោរ ព្រះរាជាបានឲ្យទ្រព្យដល់អ្នកទាំងនោះហើយ ទូន្មានថា ពួកអ្នកកុំធ្វើយ៉ាងនេះទៀត ហើយដោះលែងទៅ ពួកមនុស្សទាំងនោះ ក៏មកក្រាបទូលឲ្យព្រះរាជាអង្គនោះទ្រង់ជ្រាប ។ ព្រះរាជានោះទ្រង់ពិសោធយ៉ាងនោះឯង ២ ដងថែមទៀត ទ្រង់ជ្រាបថា ព្រះរាជាទ្រង់មានសីល ទើបលើកកងទ័ពដែលមានអង្គ ៤ ចូលទៅជិតនគរ ត្រង់ចន្លោះព្រំដែន ហើយបញ្ជូនដំណឹងដល់អមាត្យក្នុងនគរនោះថា ឲ្យនគរដល់យើងឬច្បាំង ។ ទើបអមាត្យនោះឲ្យមនុស្សក្រាបទូលរឿងនោះ ដល់ព្រះបាទព្រហ្មទត្តថា សូមទ្រង់បញ្ជាមកថា ច្បាំង ឬក៏លើកនគរឲ្យគេ ព្រះរាជាទ្រង់

បញ្ជូនដំណឹងទៅថា មិនចាំបាច់ច្បាំង ចូរអ្នកឲ្យនគរ ហើយមកនៅក្នុងទីនេះ ។ អមាត្យនោះបានធ្វើតាមបញ្ជាយ៉ាងនោះ ឯព្រះរាជា ដែលជាសត្រូវដណ្តើមយកនគរនោះបានហើយ ទ្រង់បញ្ជូនទូតទៅកាន់នគរដ៏សេសយ៉ាងនោះឯង អមាត្យទាំងនោះ ក៏ក្រាបទូលដល់ព្រះបាទព្រហ្មទត្តយ៉ាងនោះដូចគ្នា កាលព្រះបាទព្រហ្មទត្តនោះត្រាស់ថា មិនចាំបាច់ច្បាំង គប្បីមកក្នុងទីនេះ ទើបនាំគ្នាមកកាន់នគរពារាណសី ។

លំដាប់នោះ ទើបអមាត្យទាំងឡាយក្រាបទូលព្រះរាជាព្រហ្មទត្តថា បពិត្រមហារាជ ពួកខ្ញុំព្រះអង្គនឹងច្បាំងជាមួយព្រះរាជាអង្គនោះ ព្រះរាជាទ្រង់ឃាត់ថា បាណាតិបាតនឹងមានដល់យើង អមាត្យទាំងឡាយក្រាបទូលថា បពិត្រមហារាជ ពួកទូលបង្គំនឹងចាប់ព្រះរាជានោះ ទាំងនៅមានព្រះជន្មហើយនាំមកក្នុងទីនេះឲ្យបាន ប្រើឧបាយផ្សេងៗ ឲ្យព្រះរាជាទ្រង់អនុញ្ញាតហើយក្រាបទូលថា បពិត្រមហារាជ សូមទ្រង់យាង ដូច្នេះហើយ ផ្តើមនឹងទៅ ព្រះរាជាត្រាស់ថា បើអ្នកទាំងឡាយមិនធ្វើការសម្លាប់សត្វ មិនវាយ មិនប្លន់ យើងក៏នឹងទៅ ។ អមាត្យទាំងឡាយក្រាបទូលថា បពិត្រព្រះសម្មតិទេព ពួកទូលបង្គំនឹងមិនធ្វើ ពួកទូលបង្គំនឹងធ្វើឲ្យភ័យ ហើយឲ្យគេចទៅ ដូច្នេះហើយ ទើបប្រមូលចតុរង្គិនីសេនា ដាក់ប្រទីបក្នុងថ្នាំង ដើរទៅទាំងកណ្តាលរាត្រី ។ ថ្ងៃនោះ ព្រះរាជាដែលជាសត្រូវដណ្តើមនគរ ក្នុងទីជិតនគរពារាណសីបានហើយ ទ្រង់ព្រះតម្រិះថា ឥឡូវនេះ គង់មិនមានអ្វីក្នុងពេលរាត្រី ទើបឲ្យដោះគ្រោះ ជាអ្នកប្រមាទ នាំគ្នាឈានចុះកាន់និទ្រា មួយអន្លើដោយពួកពល ។

លំដាប់នោះ អមាត្យទាំងឡាយបាននាំព្រះបាទព្រហ្មទត្តទៅដល់បន្ទាយរបស់ព្រះរាជាដែលជាសត្រូវ ទើបឲ្យនាំប្រទីបចេញអំពីផ្ទាំងទាំងអស់ ធ្វើឲ្យរុងរឿងទូទៅ ហើយធ្វើនូវការស្រែកហ៊ោ អមាត្យរបស់ព្រះរាជាដែលជាសត្រូវ ឃើញពួកពលច្រើនក៏ខ្លាច ទើបចូលទៅគាល់ព្រះរាជារបស់ខ្លួន រួចក្រាបទូលដោយខ្លាំងថា សូមទ្រង់ក្រោកឡើង សោយទឹកឃ្មុំដែលមិនមានមេចុះ សូម្បីមនុស្សទី ២ មនុស្សទី ៣ ក៏បានធ្វើយ៉ាងនោះ ។ ព្រះរាជាជាសត្រូវភ្ញាក់ឡើង ព្រោះសំឡេងនោះ កើតនូវការខ្លាចតក់ស្លុត ។ សំឡេងហ៊ោកញ្ជ្រៀវរាប់រយ លាន់ឮទៅហើយ ។ ព្រះរាជាទ្រង់ព្រះតម្រិះថា យើងជឿពាក្យរបស់អ្នកដទៃ ទើបធ្លាក់ក្នុងកណ្តាប់ដៃសត្រូវ ទ្រង់រវើរវាយបែបនោះអស់រាត្រី ក្នុងថ្ងៃស្អែកឡើង ទ្រង់ព្រះតម្រិះថា ព្រះរាជាទ្រង់តាំងនៅក្នុងធម៌ គង់មិនធ្វើអន្តរាយ អញនឹងឲ្យទ្រង់អត់ទោស ទើបចូលទៅគាល់ព្រះរាជាលុតជង្គង់ចុះ ហើយក្រាបទូលថា បពិត្រមហារាជ សូមទ្រង់អត់ទោសដល់ខ្ញុំផងចុះ ព្រះរាជាទ្រង់ទូន្មានព្រះរាជាដែលជាសត្រូវ ហើយត្រាស់ថា ចូរក្រោកឡើងចុះ ខ្ញុំអត់ទោសដល់ទ្រង់ ។ ព្រះរាជាជាសត្រូវនោះ កាលព្រះរាជាត្រាស់យ៉ាងនោះប៉ុណ្ណោះ ក៏បាននូវការក្សេមព្រះហឫទ័យក្រៃលែង បានគ្រប់គ្រងរាជសម្បត្តិក្នុងជនបទជិតខាងនគរ របស់ព្រះបាទពារាណសីនោះឯង ព្រះរាជាទាំង ២ អង្គនោះ បានជាសម្លាញ់នឹងគ្នា ។ លំដាប់នោះ ព្រះបាទព្រហ្មទត្តទ្រង់ទតសេនាទាំង ២ ចំណែក ត្រេកអររាក់ទាក់រកគ្នា ទើបទ្រង់ព្រះតម្រិះថា ព្រោះអាត្មាអញតែម្នាក់ តាមរក្សាចិត្ត ទើបមិនមានតំណក់ឈាម

ត្រឹមតែមួយចម្អែតរុយកើត ឡើងក្នុងពួកមហាជននេះ ឱ ! ល្អពិតហ្ន៎ ឱ ! ល្អពិតហ្ន៎ សត្វទាំងឡាយទាំងពួង ចូរមានសេចក្តីសុខ កុំបីមានពៀរ កុំបៀតបៀនគ្នា ហើយទ្រង់ធ្វើមេត្តាឈានឲ្យកើតឡើង ទ្រង់ធ្វើមេត្តាឈាននោះឯងឲ្យជាបាទ ពិចារណាសង្ខារទាំងឡាយ ធ្វើឲ្យជាក់ច្បាស់នូវបច្ចេកពោធិញ្ញាណ សម្រេចភាពជាព្រះសយម្ភូ ។ អាមាត្យទាំងឡាយថ្វាយបង្គំហើយ ក្រាបទូលព្រះបាទព្រហ្មទត្ត ដែលមានសេចក្តីសុខដោយសុខក្នុងមគ្គនិងផល ដែលប្រថាប់គង់លើកដំរីថា បពិត្រមហារាជ បានពេលដែលទ្រង់យាងត្រឡប់ហើយ គប្បីធ្វើសក្ការៈដល់ពួកពលដែលឈ្នះ គប្បីឲ្យស្បៀងគឺភត្តដល់ពួកពលដែលចាញ់ ។ ព្រះបាទព្រហ្មទត្តនោះត្រាស់ថា នែអ្នកយើងមិនមែនជាព្រះរាជា យើងជាព្រះបច្ចេកពុទ្ធ ។ អមាត្យទាំងឡាយក្រាបទូលថា បពិត្រព្រះអង្គដ៏ប្រសើរ ទ្រង់ត្រាស់ថ្វី ព្រះបច្ចេកសម្ពុទ្ធទាំងឡាយមិនមែនដូច្នេះទេ ។ ព្រះរាជាត្រាស់ថា អ្នកទាំងឡាយ ព្រះបច្ចេកសម្ពុទ្ធទាំងឡាយដូចម្តេច អមាត្យទាំងឡាយក្រាបទូលថា ធម្មតាព្រះបច្ចេកសម្ពុទ្ធ ជាអ្នកមានសក់ និងពុកមាត់ ២ ធ្នាប់ មានបរិក្ខារ ៨ ទើបព្រះរាជាយកព្រះហស្តស្តាំស្ទាបព្រះសិរសា រំពេចនោះ ឃរាវាសភេទ ក៏អន្តរធានទៅ ភេទបព្វជិត ក៏ប្រាកដឡើង ។ ព្រះអង្គមានព្រះកេសា និងព្រះមស្សុ ប្រមាណ ២ ធ្នាប់ មានបរិក្ខារ ៨ ដូចគ្នានឹងព្រះថេរៈមានវស្សា ១០០ ។ ព្រះរាជាទ្រង់ចូលចតុត្ថជ្ឈាន ហោះពីកដំរីទៅកាន់អាកាស គង់លើផ្កាឈូក អមាត្យទាំងឡាយថ្វាយបង្គំហើយ ទូលសួរថា បពិត្រព្រះអង្គ អ្វីជាកម្មដ្ឋានទ្រង់

សម្រេចបានដូចម្តេច ព្រោះទ្រង់មានកម្មដ្ឋាន មានមេត្តាឈានជាអារម្មណ៍ ទ្រង់ឃើញច្បាស់មេត្តានោះ ជាវិបស្សនា ទើបបានសម្រេច ហេតុនោះ កាលទ្រង់សម្តែងសេចក្តីនោះ ទើបត្រាស់គាថានេះ ដែលជាគាថាឧទាន ជាគាថាព្យាករថា **សព្វេសុ ភូតេសុ និធាយ ទណ្ឌំ** ដូច្នេះជាដើម ។

បណ្តាបទទាំងនោះ បទថា **សព្វេសុ** ប្រែថា មិនមានសេសសល់ ។ បទថា **ភូតេសុ** បានដល់ ក្នុងសត្វទាំងឡាយ ។ ក្នុងទីនេះ មានសេចក្តីសង្ខេបប៉ុណ្ណេះ ឯសេចក្តីពិស្តារ ខ្ញុំនឹងពោលក្នុងអដ្ឋកថារតនសូត្រ ។ បទថា **និធាយ** ប្រែថា ដាក់ហើយ ។ បទថា **ទណ្ឌំ** បានដល់ អាជ្ញាផ្លូវកាយ វាចា និងចិត្ត ។ ពាក្យនេះ ជាឈ្មោះនៃកាយទុច្ចរិតជាដើម ។ ពិតហើយ កាយ-ទុច្ចរិត ឈ្មោះថា អាជ្ញា ព្រោះត្រូវដាក់ទោស អធិប្បាយថា បៀតបៀន គឺធ្វើឲ្យដល់នូវសេចក្តីវិនាស វចីទុច្ចរិត និងមនោទុច្ចរិតក៏ដូចគ្នា ។ ម្យ៉ាងទៀត អាជ្ញា បានដល់ អាជ្ញា គឺការប្រហារ អធិប្បាយថា ដាក់នូវអាជ្ញា គឺការប្រហារនោះ ដូច្នេះក៏មាន ។ បទថា **អវិហេឋយំ** ប្រែថា មិនបៀតបៀន ។ បទថា **អញ្ញតរម្បិ** បានដល់ សត្វណាមួយ គឺសូម្បីតែម្នាក់ តែមួយ ។ បទថា **តេសំ** សំដៅដល់ សត្វទាំងពួងនោះ ។ បទថា **ន បុត្តមិច្ឆេយ្យ** សេចក្តីថា មិនគប្បីប្រាថ្នាបុត្តប្រភេទណាមួយ ក្នុងបណ្តាបុត្ត ៤ ពួក គឺបុត្តដែលកើតអំពីខ្លួន ១ បុត្តដែលកើតក្នុងខេត្ត ១ បុត្តដែលគេឲ្យ ១ អន្តេ-វាសិក គឺកូនសិស្ស ១ ។ បទថា **កុតោ សហាយំ** ពាក្យថា គួរប្រាថ្នាសម្លាញ់ នឹងមានអំពីណា ។

បទថា **ឯកោ** សេចក្តីថា ឈ្មោះថា ជាបុគ្គលម្នាក់ឯង ព្រោះចំណែកបព្វជ្ជា ឈ្មោះថា ជាបុគ្គលម្នាក់ឯង ព្រោះអត្ថថា មិនមានបុគ្គលជាគម្រប់ពីរ ឈ្មោះថា ជាបុគ្គលម្នាក់ឯង ព្រោះអត្ថថា លះបង់តណ្ហា ឈ្មោះថា ជាបុគ្គលម្នាក់ឯង ព្រោះអត្ថថា ប្រាសចាកកិលេសៈដោយដាច់ខាត ឈ្មោះថា ជាបុគ្គលម្នាក់ឯង ព្រោះហេតុមិនមានកិលេសដោយដាច់ខាត ឈ្មោះថា ជាបុគ្គលម្នាក់ឯង ព្រោះត្រាស់ដឹងបច្ចេកសម្ពោធិញ្ញាណម្នាក់ឯង ពិតហើយ ព្រះបច្ចេកសម្ពុទ្ធ សូម្បីនៅក្នុងចំណោមសមណៈ ១០០០ រូប ក៏ឈ្មោះថាម្នាក់ឯង ព្រោះកាត់នូវការជាប់ជំពាក់ជាមួយគ្រហស្ថហើយ ឈ្មោះថា ជាបុគ្គលម្នាក់ឯង ព្រោះចំណែកបព្វជ្ជា ដោយប្រការយ៉ាងនេះ ។

ឈ្មោះថា ជាបុគ្គលម្នាក់ឯង មិនមានបុគ្គលជាគម្រប់ពីរ យ៉ាងនេះ គឺ ជាបុគ្គលឈរម្នាក់ឯង ដើរម្នាក់ឯង អង្គុយម្នាក់ឯង ដេកម្នាក់ឯង ផ្លាស់ប្តូរឥរិយាបថម្នាក់ឯង ។

ឈ្មោះថា ជាបុគ្គលម្នាក់ឯង មិនមានបុគ្គលជាគម្រប់ពីរដោយប្រការយ៉ាងនេះ គឺ

> បុរស មានតណ្ហាជាគម្រប់ពីរ កាលអន្ទោលទៅកាន់សង្សារ
> អស់កាលដ៏វែង រមែងមិនកន្លងនូវសង្សារវដ្ត ដែលមាន
> សភាពយ៉ាងនេះ និងយ៉ាងដទៃបានឡើយ ភិក្ខុដឹងនូវតណ្ហានេះ
> ថា ជាទោស ជាដែនកើតនៃទុក្ខហើយ ជាអ្នកប្រាសចាក
> តណ្ហា មិនមានសេចក្តីប្រកាន់ ជាអ្នកមានសតិ គប្បីវៀរបង់

បោលចេញ ។

ឈ្មោះថា ជាបុគ្គលម្នាក់ឯង ព្រោះអត្ថថា ប្រាសចាកកិលេស ដោយចំណែកមួយយ៉ាងនេះ គឺកិលេសទាំងពួង ដែលលោកលះបានហើយ មានឫសគល់ដាច់ហើយ ធ្វើឲ្យដូចជាត្នោតកំបុតក ធ្វើឲ្យមិនមាន ធ្វើមិនឲ្យកើតឡើងតទៅទៀតជាធម្មតា ។

ឈ្មោះថា ជាបុគ្គលម្នាក់ឯង ព្រោះត្រាស់ដឹងបច្ចេកសម្ពោធិញ្ញាណម្នាក់ឯងយ៉ាងនេះ គឺលោកមិនមានអាចារ្យ ជាសយម្ភូ ត្រាស់ដឹងព្រះបច្ចេក-សម្ពោធិញ្ញាណដោយខ្លួនឯង ។

បទថា **ចរេ** សេចក្តីថា ចរិយាទាំង ៨ ណា គឺឥរិយាបថចរិយា ក្នុងឥរិយាបថ ៤ របស់បុគ្គលដែលបរិបូណ៌ដោយបណិធិ ( ការតម្កល់ខ្លួន ) ។ អាយតនចរិយា ក្នុងអាយតនៈខាងក្នុង ៦ របស់បុគ្គលដែលគ្រប់គ្រងទ្វារក្នុងឥន្ទ្រិយទាំងឡាយ ។ សតិចរិយាក្នុងសតិប្បដ្ឋាន ៤ របស់បុគ្គលដែលមានប្រក្រតីនៅដោយសេចក្តីមិនប្រមាទ ។ សមាធិចរិយាក្នុងឈាន ៤ នៃបុគ្គលដែលប្រកបរឿយៗ ក្នុងអធិចិត្ត ។ ញាណចរិយាក្នុងអរិយសច្ច ៤ នៃបុគ្គលដែលបរិបូណ៌ដោយពុទ្ធិ គឺបញ្ញា ។ មគ្គចរិយាក្នុងអរិយសច្ច ៤ នៃបុគ្គលដែលបដិបត្តិប្រពៃ ។ បត្តិចរិយាក្នុងសាមញ្ញផល ៤ របស់អ្នកត្រាស់ដឹងនូវផល ។ លោកត្ថចរិយា ក្នុងសព្វសត្វរបស់ព្រះពុទ្ធ ៣ ពួក ។ បណ្តាចរិយាទាំងនោះ ជាចរិយារបស់ព្រះបច្ចេកសម្ពុទ្ធ និងសាវ័ករបស់ព្រះសម្មាសម្ពុទ្ធដោយចំណែកខ្លះ ដូចលោកពោល ( ខុទ្ទកនិកាយ បដិសម្ភិទាមគ្គ )

ថា ពាក្យថា ការប្រព្រឹត្ត បានដល់ ការប្រព្រឹត្ត គឺចរិយា ៨ គឺឥរិយាបថ-ចរិយា ១ ... ដូច្នេះ ។ គប្បីធ្វើពិស្តារ ។ គប្បីជាអ្នកប្រកបដោយចរិយាទាំងនោះ ។

ចរិយា ៨ ដទៃទៀត គឺបុគ្គលកាលចុះចិត្តស៊ប់ ឈ្មោះថា ប្រព្រឹត្តដោយសទ្ធា ១ កាលផ្គងឡើង ឈ្មោះថា ប្រព្រឹត្តដោយវិរិយៈ ១ កាលប្រុងប្រយ័ត្ន ឈ្មោះថា ប្រព្រឹត្តដោយសតិ ១ កាលធ្វើមិនឲ្យរាយមាយ ឈ្មោះថា ប្រព្រឹត្តដោយសមាធិ ១ កាលដឹងច្បាស់ ឈ្មោះថា ប្រព្រឹត្តដោយប្រាជ្ញា ១ ការដឹងផ្សេងៗ ឈ្មោះថា ប្រព្រឹត្តដោយវិញ្ញាណ ១ បុគ្គលប្រតិបត្តិយ៉ាងនេះ រមែងបាននូវគុណវិសេស ហេតុនោះ ឈ្មោះថា ប្រព្រឹត្តដោយវិសេសចរិយា ១ កុសលធម៌ទាំងឡាយ របស់បុគ្គលដែលប្រតិបត្តិយ៉ាងនេះ រមែងប្រព្រឹត្តក្បៀវក្លា ហេតុនោះ ឈ្មោះថា ប្រព្រឹត្តដោយអាយតនចរិយា ១[១] នេះឈ្មោះថា ចរិយា ៨ ។

ក្នុងពាក្យថា **ខគ្គវិសាណកប្បោ** នេះ ស្នែងរបស់រមាស ឈ្មោះថា កុយរមាស ។ អត្ថនៃ **កប្ប** សព្ទ ខ្ញុំនឹងប្រកាសក្នុងអដ្ឋកថាមង្គលសូត្រ ។ តែក្នុងទីនេះ **កប្ប** សព្ទនេះ គប្បីជ្រាបថា មានអត្ថថា ដូច ។ ដូចក្នុងប្រយោគជាដើមថា **សត្ថុកប្បេន វត ភោ កិរ**[២] **សាវកេន សទ្ធឹ មន្តយមានា** ឱ ! ពុទ្ធោអើយ យើងបានប្រឹក្សាជាមួយនឹងសាវក ដែលទុកស្មើនឹងព្រះ

---

១- ក្នុងអដ្ឋកថា លោកតាំងអាយតនចរិយាត្រង់លេខរៀងទី ៧ វិសេសចរិយា លោកតាំងត្រង់លេខរៀងទី ៨ ។ ២- បិដកខ្មែរជា វត កិរ ភោ ។

សាស្តាផងតើ ។ បទថា **ខគ្គវិសាណកប្បោ** ទើបមានពាក្យអធិប្បាយថា ដូចកុយរមាស ។ អធិប្បាយអត្ថនៃបទក្នុងទីនេះ មានប្រមាណប៉ុណ្ណេះ ។

តែកាលពោលដោយពាក្យអធិប្បាយ ដែលទាក់ទងគ្នា គប្បីជ្រាបយ៉ាងនេះ អាជ្ញាមានប្រការដូចពោលនេះ ដែលបុគ្គលឲ្យប្រព្រឹត្តទៅក្នុងសត្វទាំងឡាយ រមែងមិនជាប្រយោជន៍ ខ្ញុំដាក់ចុះនូវអាជ្ញានោះ ក្នុងសត្វទាំងអស់ដោយមិនឲ្យអាជ្ញាប្រព្រឹត្តទៅក្នុងសត្វទាំងនោះ និងដោយនាំចូលទៅនូវប្រយោជន៍ដល់សត្វដទៃ ដោយមេត្តាដែលជាចំណែកផ្ទុយជាមួយអាជ្ញានោះ និងព្រោះជាអ្នកលែងចោលនូវអាជ្ញាហើយ ទើបមិនបៀតបៀន ដោយប្រការដែលពួកសត្វមិនទាន់ដាក់ចុះនូវអាជ្ញា រមែងបៀតបៀនសត្វទាំងឡាយដោយដំបង សស្ត្រា បាតដៃ ឬដុំដី អាស្រ័យមេត្តាកម្មដ្ឋាននេះ សូម្បីតែមួយបណ្តាព្រហ្មវិហារទាំង ៤ នោះ ឃើញច្បាស់នូវវេទនា សញ្ញា សង្ខារ និងវិញ្ញាណក្នុងកម្មដ្ឋាននោះ ម្យ៉ាងទៀត កាលឃើញធម៌នោះ និងសង្ខារដទៃអំពីនោះ តាមគន្លងនៃវេទនា សញ្ញា សង្ខារ និងវិញ្ញាណនោះហើយ ទើបបានសម្រេចបច្ចេកសម្ពោធិញ្ញាណ នេះជាអធិប្បាយខាងដើម ។

ចំណែករឿងតទៅ មានដូច្នេះ កាលព្រះរាជាត្រាស់យ៉ាងនេះហើយ អមាត្យទាំងឡាយក្រាបទូលថា បពិត្រព្រះអង្គ ឥឡូវនេះ ទ្រង់យាងទៅណា ។ លំដាប់នោះ កាលព្រះបច្ចេកសម្ពុទ្ធពិចារណាថា ព្រះបច្ចេកសម្ពុទ្ធទាំងឡាយក្នុងកាលមុន នៅទីណាហ្ន៎ កាលទ្រង់ជ្រាបហើយ ទើបទ្រង់ត្រាស់ថា អាត្មានឹងទៅកាន់ភ្នំគន្ធមាទន៍ ទើបអមាត្យទាំងឡាយក្រាបទូល

ទៀតថា បពិត្រព្រះអង្គ ឥឡូវនេះ ទ្រង់លះបង់ពួកខ្ញុំទៅ មិនប្រាថ្នាពួកខ្ញុំហើយឬ ។ លំដាប់នោះ ព្រះបច្ចេកសម្ពុទ្ធក៏ត្រាស់ពាក្យទាំងពួងថា **ន បុត្ត-មិច្ឆេយ្យ** ដូច្នេះជាដើម ។ ក្នុងពាក្យនោះ មានអធិប្បាយថា ឥឡូវនេះ អាត្មាមិនប្រាថ្នាសូម្បីតែបុត្តប្រភេទណានីមួយ មានបុត្តកើតអំពីខ្លួនជាដើម នឹងប្រាថ្នាសម្លាញ់ អម្បាលពួកអ្នកដូចម្តេចកើត ។ ព្រោះហេតុនោះ បណ្តាពួកអ្នក អ្នកណាចង់ទៅជាមួយអាត្មា ឬចង់ដូចដូចអាត្មា បុគ្គលនោះ គប្បីជាបុគ្គលម្នាក់ឯង ត្រាច់ទៅ ដូចកុយរមាស ។ម្យ៉ាងទៀត កាលអមាត្យទាំងនោះក្រាបទូលថា បពិត្រព្រះអង្គ ឥឡូវនេះ ទ្រង់លះបង់ពួកខ្ញុំ មិនត្រូវការពួកខ្ញុំទេឬ ។ ព្រះបច្ចេកសម្ពុទ្ធនោះក៏ត្រាស់ថា បុគ្គលមិនប្រាថ្នាកូន នឹងប្រាថ្នាសម្លាញ់អំពីណាកើត បានឃើញគុណនៃការត្រាច់ទៅម្នាក់ឯង ដោយអត្ថតាមដែលពោលហើយ ទើបត្រេកអរ កើតនូវបីតិសោមនស្ស បន្លឺឧទាននេះថា គប្បីប្រព្រឹត្តទៅតែម្នាក់ឯង ដូចកុយរមាស ដូច្នេះ ។ លុះត្រាស់យ៉ាងនេះហើយ កាលមហាជនកំពុងឃើញនោះឯង ក៏ហោះទៅកាន់ភ្នំគន្ធមាទន៍តាមផ្លូវអាកាស ។

ឈ្មោះថា ភ្នំគន្ធមាទន៍នេះ នៅត្រង់ហិមវន្តប្បប្រទេស រំលងភ្នំ ៧ ទៅ គឺចូឡកាលបព៌ត ១ មហាកាឡបព៌ត ១ នាគបលិវេឋនបព៌ត ១ ចន្ទគព្ភបព៌ត ១ សុរិយគព្ភបព៌ត ១ សុវណ្ណបស្សបព៌ត ១ ហិមវន្តបព៌ត ១ ។ ត្រង់ភ្នំគន្ធមាទន៍ មានញកភ្នំ ឈ្មោះថា នន្ទមូលកៈ ជាលំនៅរបស់ព្រះបច្ចេកសម្ពុទ្ធទាំងឡាយ និងមានគុហា ៣ គឺសុវណ្ណគុហា ១ មណិគុហា ១

រជតគុហា ១ បណ្ដាគុហាទាំង ៣ នោះ ត្រង់ទ្វារមណិគុហា មានដើមឈើឈ្មោះមញ្ជូសកៈ ( ដើមឪលោក ) កម្ពស់ ១ យោជន៍ ទំហំ ១ យោជន៍ ។ ដើមឈើនោះ មាននៅក្នុងទឹក ឬលើគោកទូទៅ ដោយចំពោះ ក្នុងថ្ងៃដែលព្រះបច្ចេកសម្ពុទ្ធនិមន្តមកដល់ ។ បន្ទាប់អំពីដើមឈើនោះទៅ មានផ្ទះកែវគ្រប់ប្រភេទ ក្នុងផ្ទះកែវនោះ ខ្យល់ដែលធ្វើការបោស ក៏បោសសំរាមយកទៅចោល ខ្យល់ដែលធ្វើឲ្យផ្ទៃដីរាប ក៏កៀរខ្សាច់ដែលសម្រេចហើយដោយរតនៈឲ្យរាបស្មើ ខ្យល់ដែលស្រោចទឹក ក៏នាំទឹកមកអំពីអនោតត្តស្រះមកស្រោច ខ្យល់ដែលធ្វើក្លិនក្រអូប ក៏នាំក្លិនក្រអូបរបស់ដើមឈើមកអំពីព្រៃហិមពាន្ត ខ្យល់ដែលរោយ ក៏រោយផ្កាទាំងឡាយឲ្យធ្លាក់ចុះមក ខ្យល់ដែលក្រាល ក៏ក្រាលកម្រាលក្នុងទីទាំងពួង ហើយក្នុងរោងនោះ ក្រាលអាសនៈរៀបរយជាប្រចាំ សម្រាប់ជាទីដែលព្រះបច្ចេកសម្ពុទ្ធទាំងពួងគង់ប្រជុំ ក្នុងថ្ងៃដែលព្រះបច្ចេកសម្ពុទ្ធកើតឡើង និងក្នុងថ្ងៃឧបោសថ នេះជាប្រក្រតីក្នុងទីនោះ ។ ព្រះបច្ចេកសម្ពុទ្ធអង្គនេះ ទៅក្នុងទីនោះហើយ គង់លើអាសនៈដែលក្រាល ។ លំដាប់នោះ បើក្នុងពេលនោះ មានព្រះបច្ចេកសម្ពុទ្ធដទៃៗ ព្រះបច្ចេកសម្ពុទ្ធទាំងនោះក៏មកប្រជុំគ្នា គង់លើអាសនៈដែលក្រាលមួយរំពេច កាលគង់ហើយនាំគ្នាចូលសមាបត្តិខ្លះ ហើយចេញអំពីសមាបត្តិ បន្ទាប់អំពីនោះ ដើម្បីឲ្យព្រះបច្ចេកសម្ពុទ្ធទាំងពួងអនុមោទនា ព្រះសង្ឃត្ថេរក៏សួរកម្មដ្ឋាន ដល់ព្រះបច្ចេកសម្ពុទ្ធដែលមកថ្មីយ៉ាងនេះថា លោកម្ចាស់សម្រេចដូចម្ដេច ។ ក្នុងកាលនោះ ព្រះបច្ចេកសម្ពុទ្ធដែលទើបមកថ្មី ក៏ពោលឧទានគាថា និងព្យាករ

*គាថារបស់ខ្លួននោះឯង ។ ព្រះមានព្រះភាគ ត្រូវព្រះអានន្ទសួរ ក៏ត្រាស់គាថានោះឯងដដែលទៀត ព្រះអានន្ទក៏ពោលគាថានោះឯង ក្នុងកាលសង្គាយនារួមសេចក្តីថា គាថានីមួយៗ មានការពោល ៤ ដង គឺក្នុងទីត្រាស់ដឹងបច្ចេក-សម្ពោធិញ្ញាណ ១ ក្នុងរោងក្បែរដើមមញ្ជូសកៈ ១ ក្នុងពេលដែលព្រះអានន្ទទូលសួរ ១ ក្នុងពេលសង្គាយនា ១ ដោយប្រការដូច្នេះ ៕*

## អដ្ឋកថា គាថាទី ១ ចប់

# អដ្ឋកថា

## សំសគ្គគាថា

គាថាថា **សំសគ្គជាតស្ស** ដូច្នេះជាដើម មានអត្ថុប្បត្តិហេតុដូចម្ដេច ។ ព្រះបច្ចេកពោធិសត្វអង្គនេះ ក៏បានធ្វើសមណធម៌មកក្នុងសាសនានៃព្រះមានព្រះភាគ ព្រះនាមកស្សបៈអស់ ២ ម៉ឺនឆ្នាំ ដោយន័យក្នុងរឿងមុននោះឯង ធ្វើកសិណបរិកម្មដ្ឋាន ញុំាងបឋមជ្ឈានឲ្យកើតហើយ កំណត់នាម និងរូប ពិចារណាត្រៃលក្ខណ៍ តែមិនទាន់សម្រេចអរិយមគ្គ កើតក្នុងព្រហ្មលោក ។ ព្រះបច្ចេកពោធិសត្វនោះ ចុតិអំពីព្រហ្មលោកនោះហើយ កើតក្នុងគភ៌របស់អគ្គមហេសីនៃព្រះបាទពារាណសី ចម្រើនវ័យឡើង ដោយន័យមុននោះឯង តាំងអំពីដឹងការផ្សេងគ្នាថា នេះជាស្រី នេះជាប្រុសហើយ មិនគាប់ចិត្តនៅក្នុងដៃរបស់ពួកស្រី មិនត្រេកអរ សូម្បីត្រឹមតែការអប់ ការងូត និងការប្រដាប់ជាដើម បុរសប៉ុណ្ណោះចិញ្ចឹម ព្រះបច្ចេកពោធិសត្វនោះ ក្នុងកាលឲ្យបៅដោះ ។ ស្នំទាំងឡាយក្លែងភេទជាបុរសឲ្យបៅ ព្រះបច្ចេកពោធិសត្វនោះ បានក្លិន ឬបានឮសំឡេងរបស់ស្រីក៏យំ ទោះបីដឹងក្ដីហើយ ក៏មិនប្រាថ្នានឹងឃើញស្រី ដោយហេតុនោះ ទើបមនុស្សទាំងឡាយ ថ្វាយព្រះនាមបច្ចេក-ពោធិសត្វនោះថា **អនិត្ថិគន្ធកុមារ** ( អ្នកមិនប្រាថ្នាក្លិនស្រី ) ។ កាលអនិត្ថិគន្ធកុមារនោះមានព្រះជន្ម ១៦ វស្សា ព្រះរាជាទ្រង់តម្រិះថា នឹងឲ្យតាំងវង្សត្រកូល ទើបនាំស្ត្រីក្រមុំដែលសមគួរដល់ព្រះរាជកុមារនោះមកឲ្យ ទ្រង់បញ្ជាអមាត្យនោះថា ចូរធ្វើឲ្យព្រះរាជកុមារត្រេកអរ អមាត្យមានបំណងឲ្យព្រះរាជកុមារនោះត្រេកអរដោយឧបាយ ទើបឲ្យបាំងវាំងនន ក្នុងទីមិនឆ្ងាយពី

ព្រះរាជកុមារនោះ ហើយឲ្យពួកស្រីរបាំច្រៀងរាំក្នុងវាំងនន ។ ព្រះរាជកុមារបានស្តាប់សំឡេងច្រៀង និងសំឡេងប្រគំតន្ត្រី ទើបត្រាស់សួរថា នេះសំឡេងរបស់អ្នកណា អមាត្យក្រាបទូលថា នេះជាសំឡេងរបស់ពួកស្រីរបាំរបស់ព្រះអង្គ អ្នកមានបុណ្យទាំងឡាយ ទើបមានស្រីរបាំបែបនេះ បពិត្រព្រះសម្មតិទេព សូមទ្រង់ត្រេកអរក្រៃលែងចុះ ទ្រង់មានបុណ្យច្រើន ។ ព្រះរាជកុមារបានឲ្យវាយអមាត្យនោះដោយដំបង ហើយឲ្យអូសចេញទៅ អមាត្យនោះ ក៏ក្រាបទូលដល់ព្រះរាជាៗ យាងទៅ មួយអន្លើដោយព្រះជននីរបស់ព្រះរាជកុមារ ឲ្យព្រះរាជកុមារខមាទោស ហើយត្រាស់នឹងអមាត្យទៀត ។ ព្រះរាជកុមារត្រូវបិតាជាដើមនោះរំអុកពេក ទើបឲ្យមាស ដែលមានសាច់ល្អ ហើយត្រាស់នឹងពួកជាងមាសថា ចូរពួកអ្នកធ្វើរូបស្រីឲ្យស្អាត ១ ។ ជាងមាសទាំងនោះ ធ្វើរូបស្រី ប្រដាប់ដោយគ្រឿងអលង្ការសព្វយ៉ាង ដូចវិស្សកម្មទេវបុត្រនិម្មិត ហើយឲ្យព្រះរាជកុមារទត ។ ព្រះរាជកុមារទ្រង់ឃើញហើយ ទ្រង់ងក់ព្រះសិរសៈ ដោយការចម្លែកព្រះហឫទ័យ ហើយបញ្ជូនមនុស្សឲ្យទៅក្រាបទូលព្រះជនក និងព្រះជននីថា បើខ្ញុំបានស្ត្រីបែបនេះ នឹងទទួល ។ ព្រះជនក និងព្រះជននីត្រាស់ថា កូនរបស់យើងមានបុណ្យច្រើន គង់រកទារិកាត្រឹមតែម្នាក់ ដែលបានធ្វើបុណ្យរួមជាមួយបុត្តរបស់យើងនោះ ដែលកើតមកក្នុងលោកបានយ៉ាងពិតប្រាកដ ទើបឲ្យលើករូបមាសនោះដាក់លើរថ ប្រាប់ដល់អមាត្យថា អ្នកទាំងឡាយ ចូរទៅស្វែងរកទារិកាដូចរូបមាសនេះ ។ អមាត្យទាំងនោះ នាំរូបមាសនោះ ត្រាច់ទៅក្នុងជនបទធំៗ ១៦ ជនបទ ទៅ

ដល់ស្រុកនោះៗ ឃើញពួកជនក្នុងទីណាមួយ មានកំពង់ទឹកជាដើម ក៏យករូបមាសដូចទេវតា តម្កល់ទុកក្នុងទីនោះៗ ធ្វើនូវការបូជាដោយផ្កា សំពត់ និងគ្រឿងប្រដាប់ផ្សេងៗ ចងពិតាន ហើយឈរក្នុងចំណែកម្ខាង ដោយអន្ទឹងថា បើបុគ្គលណាម្នាក់ធ្លាប់ឃើញទារិកាមានរូបបែបនេះ គេនឹងនិយាយឡើង ។ អមាត្យទាំងឡាយត្រាច់ទៅហើយ គ្រប់ជនបទដោយឧបាយនោះ វៀរតែមទ្ទរដ្ឋ មើលងាយដែនមទ្ទរដ្ឋនោះថា ជាដែនតូច ដំបូង ទើបមិនទៅក្នុងដែននោះ នាំគ្នាត្រឡប់ ។

លំដាប់នោះ អមាត្យទាំងនោះបាននូវការគិតដូច្នេះថា ពួកយើងនឹងទៅដែនមទ្ទរដ្ឋជាមុន ពួកយើងទៅដល់នគរពារាណសីហើយ ព្រះរាជានឹងមិនបញ្ជូនយើងមកទៀត កាលគិតដូច្នេះហើយ អមាត្យទាំងនោះ ក៏បានទៅកាន់សាគលនគរ ក្នុងដែនមទ្ទរដ្ឋ ។ ក្នុងសាគលនគរ មានព្រះរាជាព្រះនាមមទ្ទៈ ធីតារបស់ព្រះអង្គព្រះជន្មាយុបាន ១៦ វស្សា មានព្រះរូបល្អ ពួកនាងវណ្ណ-ទាសីរបស់ព្រះរាជធីតានោះ នាំគ្នាទៅកាន់កំពង់ទឹកដើម្បីងូតទឹក ឃើញរូបមាសដែលពួកអមាត្យតម្កល់ទុកត្រង់កំពង់ទឹកនោះអំពីចម្ងាយ នាំគ្នាពោលថា ព្រះរាជបុត្រីបញ្ជូនពួកយើងមកងូតទឹក ហេតុអ្វី ក៏យាងមកឯង ទើបទៅជិតហើយពោលថា នេះមិនមែនព្រះនាងៗ របស់ពួកយើងមានរូបស្អាតជាងនេះ អមាត្យទាំងឡាយបានស្តាប់ដូច្នោះ ទើបចូលទៅគាល់ព្រះរាជា ហើយទូលសូមទារិកា ដោយន័យដែលសមគួរ ព្រះរាជាក៏ប្រទានឲ្យ ។ អមាត្យទាំងនោះក៏បញ្ជូនដំណឹងទៅក្រាបទូលដល់ព្រះបាទពារាណសីថា បពិត្រព្រះសម្មតិទេព

ទូលបង្គំទាំងឡាយ បាននាងកុមារិកាហើយ ទ្រង់យាងមកឯង ឬឲ្យទូលបង្គំទាំងឡាយនាំមក ព្រះរាជាទ្រង់បញ្ជូនរាជសាសន៍ទៅថា កាលយើងមកសេចក្ដីលំបាក ព្រោះជនបទនឹងកើតមាន ពួកលោកនោះឯង ចូរនាំមក ។

ឯអមាត្យទាំងឡាយ នាំទារិកាចេញអំពីនគរ ហើយបញ្ជូនដំណឹងដល់ព្រះរាជកុមារថា បានកុមារិកាដូចរូបមាសហើយ ។ ព្រះរាជកុមារបានស្ដាប់ប៉ុណ្ណោះ ត្រូវរាគៈគ្របសង្កត់ សាបសូន្យចាកបឋមជ្ឈាន ព្រះរាជកុមារនោះក៏បញ្ជូនដំណឹងទៅបណ្ដើរៗ ថា ចូរពួកអ្នកប្រញាប់នាំមក ចូរពួកអ្នកប្រញាប់នាំមក ។ ពួកអមាត្យទាំងនោះ ក៏មកដល់ក្រុងពារាណសី ដោយសម្រាកក្នុងទីគ្រប់កន្លែងត្រឹមមួយយប់ ទើបបញ្ឈប់ខាងក្រៅព្រះនគរ បញ្ជូនដំណឹងទៅថ្វាយព្រះរាជាថា គួរចូលទៅថ្ងៃនេះឬ ។ ព្រះរាជាត្រាស់ថា កុមារិកានាំមកអំពីត្រកូលដ៏ប្រសើរ ពួកយើងធ្វើមង្គលកិរិយាហើយ នាំចូលទៅដោយសក្ការៈធំ អ្នកទាំងឡាយ ចូរនាំនាងទៅកាន់ឧទ្យានសិន អមាត្យទាំងនោះបានធ្វើតាមពាក្យបញ្ជានោះ ។ កុមារិកានោះ ជាស្រីសុខុមាលជាត អស់កម្លាំងព្រោះយានរលាក់ កើតរោគខ្យល់ ព្រោះលំបាកក្នុងផ្លូវឆ្ងាយ ដូចផ្កាស្រពោនទើបស្លាប់ក្នុងកណ្ដាលរាត្រី អមាត្យទាំងឡាយ នាំគ្នាបរិទេវនាការថា ពួកយើងជាអ្នកប្រាសចាកសក្ការៈហើយ ព្រះរាជា និងអ្នកនគរក៏កន្ទក់កន្ទេញថាត្រកូលវង្សវិនាសហើយ ។ អ្នកនគរទាំងមូល បានកើតកោលាហល ព្រោះត្រឹមតែស្ដាប់ដំណឹងប៉ុណ្ណោះ សេចក្ដីសោកដ៏ខ្លាំងក្លា ក៏កើតឡើងដល់ព្រះរាជកុមារ ។

លំដាប់នោះ ព្រះរាជកុមារផ្តើមជីកឫសគល់របស់សេចក្តីសោក ទ្រង់ព្រះតម្រិះយ៉ាងនេះថា ឈ្មោះថា សេចក្តីសោកនេះ រមែងមិនមានដល់អ្នកមិនកើត តែសម្រាប់បុគ្គលដែលកើតមកហើយ រមែងមានសេចក្តីសោក ព្រោះហេតុនោះ សេចក្តីសោកមានព្រោះអាស្រ័យជាតិ ជាតិមានព្រោះអាស្រ័យអ្វី ទ្រង់ដឹងថា ជាតិមានព្រោះអាស្រ័យភព ។ កាលទ្រង់មនសិការដោយឧបាយដោយអានុភាពនៃការអប់រំការទាក្នុងកាលមុន ដោយវិធីនេះ ទ្រង់បានឃើញបដិច្ចសមុប្បាទ ទាំងអនុលោម និងបដិលោម កាលត្រឡប់ពិចារណាសង្ខារទាំងឡាយដោយអនុលោមទៀត គង់ប្រថាប់ក្នុងទីនោះឯង បានធ្វើឲ្យជាក់ច្បាស់នូវបច្ចេកសម្ពោធិញ្ញាណ ។ អមាត្យទាំងឡាយឃើញព្រះរាជកុមារនោះមានសេចក្តីសុខ ដោយសុខក្នុងមគ្គ និងផល មានឥន្ទ្រិយស្ងប់ មានចិត្តស្ងប់ប្រថាប់គង់ ទើបថ្វាយបង្គំ ហើយក្រាបទូលថា បពិត្រព្រះសម្មតិទេព សូមទ្រង់កុំសោយសោកឡើយ ជម្ពូទ្វីបធំ ទូលបង្គំទាំងឡាយនឹងនាំកញ្ញាដទៃដែលស្អាតជាងនេះមកថ្វាយ ។

ព្រះបច្ចេកសម្ពុទ្ធនោះ ត្រាស់ថា អាត្មាមិនសោក អាត្មាអស់សេចក្តីសោក ជាព្រះបច្ចេកពុទ្ធហើយ ។ ខាងមុខអំពីនេះទៅ រឿងទាំងពួងដូចគ្នានឹងគាថាដំបូង ដែលពោលមកហើយនោះឯង វៀរពណ៌នាគាថា ។ ឯពណ៌នាគាថា គប្បីជ្រាបដូចតទៅនេះ បទថា **សំសគ្គជាតស្ស** ប្រែថា ដែលកើតនូវការប្រឡូកប្រឡំ ។ ក្នុងបទថា **សំសគ្គជាតស្ស** នោះ **សំសគ្គ** ( ការប្រឡូកប្រឡំ ) មាន ៥ យ៉ាង គឺប្រឡូកប្រឡំដោយការឃើញ ១ ប្រឡូក

ប្រឡូំដោយការស្តាប់ ១ ប្រឡូកប្រឡូំដោយកាយ ១ ប្រឡូកប្រឡូំដោយការចរចា ១ ប្រឡូកប្រឡូំដោយការបរិភោគរួម ១ ។ ក្នុងការប្រឡូកប្រឡូំ ៥ យ៉ាងនោះ រាគៈកើតតាមចក្ខុវិញ្ញាណវិថី ព្រោះឃើញគ្នានិងគ្នា ឈ្មោះថា **ទស្សនសំសគ្គ** ( ប្រឡូកប្រឡូំដោយការឃើញ ) ។ ក្នុងទស្សនសំសគ្គៈនេះ មានឧទាហរណ៍ដូចជា ធីតារបស់កុដុម្ពិកៈអ្នកកាឡទីឃវាបី ក្នុងកោះសីហឡ ឃើញភិក្ខុកំលោះអ្នកពោលទីឃនិកាយ នៅក្នុងកល្យាណវិហារ ដែលកំពុងត្រាច់បិណ្ឌបាត មានចិត្តប្រតិព័ទ្ធ មិនបានភិក្ខុកំលោះនោះ ដោយឧបាយណាមួយ ក៏ស្លាប់ទៅ ភិក្ខុកំលោះរូបនោះឯង ឃើញកំណាត់សំពត់ដណ្តប់របស់នាង គិតថា អញមិនបាននៅរួមជាមួយនាង ដែលស្លៀកដណ្តប់សំពត់បែបនេះ មានហទយៈបែកធ្លាយ ក៏ស្លាប់ជាគំរូ ។

រាគៈកើតតាមផ្លូវសោតវិញ្ញាណវិថី ព្រោះបានស្តាប់រូបសម្បត្តិជាដើម ដែលអ្នកដទៃពោល ឬបានស្តាប់សំឡេងសើច សំឡេងចរចា និងសំឡេងច្រៀងដោយខ្លួនឯង ឈ្មោះថា **សវនសំសគ្គ** ( ប្រឡូកប្រឡូំដោយការស្តាប់ ) ។ ក្នុងសវនសំសគ្គៈនេះ មានភិក្ខុកំលោះឈ្មោះតិស្សៈ អ្នកនៅក្នុងគុហាបញ្ចគ្គឡៈ កំពុងហោះទៅតាមអាកាស បានឮសំឡេងរបស់កូនស្រីជាងមាស ដែលនៅក្នុងគិរិគាម ទៅកាន់ស្រះឈូក មួយអន្លើដោយកុមារិកា ៥ នាក់ ងូតទឹក បេះផ្កា ហើយច្រៀង ដោយសំឡេងដ៏ពីរោះ ទើបវិនាសចាកគុណវិសេស ព្រោះកាមរាគៈ ដល់នូវសេចក្តីវិនាសជាគំរូ ។

រាគៈកើតឡើង ព្រោះការស្ទាបអង្អែលអវយវៈនៃគ្នានិងគ្នា ឈ្មោះថា

**កាយសំសគ្គ** ( ប្រឡូកប្រឡំដោយកាយ ) ។ មានភិក្ខុកំលោះអ្នកពោលធម៌ និងព្រះរាជធីតាជាគំរូក្នុងសេចក្ដីនេះ ។ បានឮថា ភិក្ខុកំលោះ ក្នុងមហាវិហារពោលធម៌ មហាជននាំគ្នាមកក្នុងវិហារនោះ ព្រះរាជា អគ្គមហេសី និងព្រះរាជធីតា ក៏បានយាងមកផងដែរ ។ បន្ទាប់អំពីនោះ ព្រោះអាស្រ័យរូប និងសំឡេងរបស់ភិក្ខុកំលោះនោះ រាគៈដ៏ខ្លាំងក្លា បានកើតឡើងដល់ព្រះរាជធីតាផង កើតដល់ភិក្ខុកំលោះនោះផង ។ ព្រះរាជាទតឃើញដូច្នោះ ទ្រង់កំណត់ដឹង ទើបឲ្យបាំងរាំងននទ ។ ជនទាំង ២ ប៉ះពាល់ឱបក្រសោបគ្នានិងគ្នា ។ មនុស្សទាំងឡាយ យករាំងននទចេញ សម្លឹងមើល ក៏បានឃើញជនទាំង ២ ស្លាប់ហើយ ។

រាគៈកើតឡើង ព្រោះការសន្ទនា ប្រាស្រ័យគ្នា ឈ្មោះថា **សមុល្លបនសំសគ្គ** ( ប្រឡូកប្រឡំដោយការចរចា ) ។ រាគៈដែលកើតឡើង ព្រោះធ្វើការប្រើប្រាស់រួមគ្នាជាមួយភិក្ខុនីទាំងឡាយ ឈ្មោះថា **សម្ភោគសំសគ្គ** ( ប្រឡូកប្រឡំដោយការបរិភោគរួម ) ។ ក្នុងសំសគ្គទាំង ២ នេះ មានភិក្ខុនិងភិក្ខុនីដែលត្រូវអាបត្តិបារាជិកជាគំរូ ។ បានឮថា ក្នុងកាលឆ្លងមហាវិហារឈ្មោះមរិចវដ្ដិ ព្រះបាទទុដ្ឋគាមណីអភ័យ ទ្រង់ត្រៀមមហាទាន ហើយអង្គាសព្រះសង្ឃទាំង ២ ចំណែក កាលគេថ្វាយយាគូក្ដៅ ក្នុងមហាទាននោះ សាមណេរីបួសថ្មីក្នុងសង្ឃ បានប្រគេនវង្វេលភ្លុកដល់សាមណេរ ដែលបួសថ្មីក្នុងសង្ឃជាទម្របាត្រ ហើយធ្វើការចរចាប្រាស្រ័យគ្នា ។ អ្នកទាំង ២ នោះបានឧបសម្បទាហើយ មានវស្សា ៦០ ទៅកាន់ត្រើយដទៃ បាននូវសញ្ញាក្នុង

កាលមុន ព្រោះការចរចាប្រាស្រ័យគ្នានិងគ្នា វេលានោះឯង ក៏កើតសេចក្ដីស្នេហា បានកន្លងល្មើសសិក្ខាបទ ត្រូវអាបត្តិបារាជិក ។

សេចក្ដីស្នេហា រមែងមានដល់បុគ្គលដែលកើតនូវការប្រឡូកប្រឡំ ដោយការប្រឡូកប្រឡំណាមួយ ក្នុងបណ្ដាសំសគ្គ ៥ យ៉ាង ដោយប្រការដូច្នេះ ។ រាគៈដ៏ខ្លាំងក្លាដែលមានរាគៈខាងដើមជាបច្ច័យ រមែងកើតឡើង ។ បន្ទាប់អំពីនោះ សេចក្ដីទុក្ខនេះមានឡើង ព្រោះអាស្រ័យសេចក្ដីស្រឡាញ់ រមែងមានមក គឺសេចក្ដីទុក្ខនេះ មានប្រការផ្សេងៗ មានសោក និងបរិទេវៈជាដើម ដែលប្រព្រឹត្តទៅក្នុងបច្ចុប្បន្ន និងប្រព្រឹត្តទៅក្នុងសម្បរាយភព ដែលជាប់តាមសេចក្ដីស្រឡាញ់នោះឯង រមែងមាន គឺរមែងមានទូទៅ បានដល់ រមែងកើតឡើង ។

អាចារ្យពួកដទៃពោលថា ការបណ្ដោយចិត្តទៅក្នុងអារម្មណ៍ ឈ្មោះថា **សំសគ្គ** សេចក្ដីស្រឡាញ់ បន្ទាប់អំពីសំសគ្គៈនោះ ចាត់ជាទុក្ខ ដែលកើតអំពីសេចក្ដីស្រឡាញ់នេះ ដូច្នេះ ។ ព្រះបច្ចេកសម្ពុទ្ធនោះ ពោលដល់កន្លះគាថានេះ ដែលមានអត្ថយ៉ាងនេះហើយ ទើបពោលថា ព្រះបច្ចេកសម្ពុទ្ធនេះជីកនូវឫសគល់របស់ទុក្ខ ដែលទៅតាមសេចក្ដីស្រឡាញ់ ដែលពោលថា សេចក្ដីទុក្ខនេះមានឡើង ព្រោះអាស្រ័យសេចក្ដីស្រឡាញ់ ដូចជា ទុក្ខកើតអំពីសេចក្ដីសោកជាដើមនោះឯង បានសម្រេចបច្ចេកពោធិញ្ញាណហើយ ។

កាលព្រះរាជាត្រាស់យ៉ាងនេះហើយ អមាត្យទាំងនោះ ក្រាបទូលថា បពិត្រព្រះអង្គ ឥឡូវនេះ ទូលបង្គំទាំងឡាយគួរធ្វើដូចម្ដេច ។ លំដាប់នោះ

ព្រះបច្ចេកសម្ពុទ្ធពោលថា អ្នកទាំងឡាយ ឬអ្នកឯណាមួយ ដែលបំណងនឹងផុតចាកទុក្ខនេះ អ្នកទាំងអស់នោះ គប្បីឃើញទោសដែលកើតអំពីសេចក្ដីស្រឡាញ់ គប្បីត្រាច់ទៅតែម្នាក់ឯង ដូចកុយរមាស ដូច្នោះ ។ ក្នុងទីនេះ គប្បីជ្រាបថា លោកសំដៅយកពាក្យដែលពោលថា សេចក្ដីទុក្ខនេះ មានឡើង ព្រោះអាស្រ័យសេចក្ដីស្រឡាញ់នោះឯង ទើបពោលថា បុគ្គលកាលឃើញទោស ដែលកើតអំពីសេចក្ដីស្រឡាញ់ ដូច្នេះ ។

ម្យ៉ាងទៀត ភ្ជាប់សេចក្ដីយ៉ាងនេះថា សេចក្ដីស្រឡាញ់ រមែងមានដល់បុគ្គលដែលច្រឡូកច្រឡំដោយការសំសគ្គៈ តាមដែលពោលហើយ ទុក្ខប្រព្រឹត្តទៅតាមសេចក្ដីស្រឡាញ់នេះមានច្រើន អាត្មាឃើញទោស ដែលកើតអំពីសេចក្ដីស្រឡាញ់ តាមសេចក្ដីពិតយ៉ាងនេះ ទើបសម្រេចហើយ គប្បីជ្រាបថា ព្រះបច្ចេកសម្ពុទ្ធពោលបាទទី ៤ ដោយអំណាចសេចក្ដីស្រឡាញ់ ដោយន័យដូចពោលហើយខាងដើម ។ ខាងមុខអំពីនេះទៅ បទទាំងពួងដូចគ្នាតាមដែលពោលហើយ ក្នុងគាថាទី ១ ដូច្នេះ ។

## អដ្ឋកថា សំសគ្គគាថា ចប់

# អដ្ឋកថា

## មិត្តសុហជ្ជគាថា

គាថាថា **មិត្តេ សុហជ្ជេ** ដូច្នេះជាដើម មានអត្ថុប្បត្តិហេតុដូចម្តេច មានអត្ថុប្បត្តិហេតុដូច្នេះ

ព្រះបច្ចេកពោធិសត្វអង្គនេះ កើតឡើងហើយ ដោយន័យដូចពោលក្នុងគាថាទី ១ នោះឯង គ្រងរាជសម្បត្តិនៅក្នុងនគរពារាណសី ធ្វើបឋមជ្ឈានឲ្យកើតឡើងហើយ ចង់ពិសោធថា សមណធម៌ប្រសើរ ឬរាជសម្បត្តិប្រសើរ ទើបប្រគល់រាជសម្បត្តិដល់អមាត្យទាំងឡាយ ហើយបានធ្វើសមណធម៌ ។ អមាត្យទាំងឡាយ ទោះព្រះបច្ចេកពោធិសត្វត្រាស់ថា ចូរពួកអ្នកកាត់ក្តីដោយធម៌ស្មើ ក៏សុំសំណូកហើយកាត់ក្តី មិនប្រកបដោយធម៌ ។ អមាត្យទាំងនោះទទួលសំណូកហើយ ធ្វើម្ចាស់ទ្រព្យឲ្យចាញ់ ។ គ្រាមួយ ធ្វើរាជវល្លភៈ ( អ្នកស្និទ្ធស្នាលជាមួយព្រះរាជា ) ម្នាក់ឲ្យចាញ់ ។ រាជវល្លភៈនោះចូលទៅគាល់ មួយអន្លើដោយពួកអ្នកចម្អិនក្រយាហាររបស់ព្រះរាជា ហើយក្រាបទូលរឿងទាំងពួងឲ្យទ្រង់ជ្រាប ។ ក្នុងថ្ងៃទី ២ ទើបព្រះរាជាបានយាងទៅកាន់ទីវិនិច្ឆ័យដោយព្រះអង្គឯង ។ លំដាប់នោះ ពួកមហាជន ក៏បន្លឺសំឡេងអឺងកងថា បពិត្រព្រះសម្មតិទេព ពួកអមាត្យកាត់ក្តី ធ្វើម្ចាស់ទ្រព្យមិនឲ្យជាម្ចាស់ទ្រព្យ ហើយបានធ្វើអកប្បកិរិយា ដូចមហាចម្បាំង ។ លំដាប់នោះ ព្រះរាជាក្រោកឡើងចាកទីវិនិច្ឆ័យ ហើយយាងឡើងកាន់ប្រាសាទ គង់ប្រថាប់ចូលសមាបត្តិ មានចិត្តរាយមាយ ព្រោះសំឡេងនោះ មិនអាចចូលសមាបត្តិបាន ។ ព្រះរាជានោះ ទ្រង់ព្រះតម្រិះថា ប្រយោជន៍អ្វី ដោយរាជសម្បត្តិ

សម្រាប់អញ សមណធម៌ប្រសើរជាង ទើបទ្រង់លះបង់រាជសម្បត្តិ ធ្វើសមាបត្តិឲ្យកើតឡើងទៀត ហើយចម្រើនវិបស្សនា ដោយន័យដូចពោលខាងដើមនោះឯង ធ្វើឲ្យជាក់ច្បាស់នូវព្រះបច្ចេកពោធិញ្ញាណ ត្រូវព្រះសង្ឃត្ថេរសួរកម្មដ្ឋាន ទើបបានពោលគាថានេះ ។

បណ្តាមិត្ត និងសម្លាញ់នោះ ឈ្មោះថា មិត្ត ព្រោះនាំមកនូវមេត្រីចិត្ត ឈ្មោះថា សម្លាញ់ ព្រោះជាអ្នកមានចិត្តល្អ ។ បុគ្គលពួកខ្លះ ត្រឹមតែជាមិត្ត ព្រោះជាអ្នកប្រាថ្នាប្រយោជន៍តែម្យ៉ាង មិនជាសម្លាញ់ ។ ពួកខ្លះ ត្រឹមតែជាសម្លាញ់ ដោយធ្វើសេចក្តីសុខចិត្តឲ្យកើត ក្នុងការទៅ ការមក ការឈរ ការអង្គុយនិងការប្រាស្រ័យតែមិនបានជាមិត្ត ។ ពួកខ្លះ ជាសម្លាញ់ផង ជាមិត្តផង ព្រោះប្រព្រឹត្តទៅបានទាំង ២ យ៉ាង ។

មិត្តនោះ មាន ២ ពួក គឺអគារិយមិត្ត និងអនគារិយមិត្ត ។ បណ្តាមិត្ត ២ ពួកនោះ អគារិយមិត្ត មាន ៣ គឺមិត្តមានឧបការៈ ១ មិត្តរួមសុខទុក្ខ ១ មិត្តមានសេចក្តីឈឺឆ្អាល ១ ។ អនគារិយមិត្ត ជាអ្នកប្រាប់នូវប្រយោជន៍ដោយពិសេសឲ្យពិត ។

មិត្តទាំងនោះ ជាអ្នកប្រកបដោយអង្គ ៤ ដូចព្រះតម្រាស់ថា

ម្នាលគហបតិបុត្ត មិត្តមានឧបការៈ ជាមិត្តមានសន្តានល្អ អ្នកត្រូវដឹងដោយស្ថាន ៤ យ៉ាង គឺរក្សាមិត្តដែលធ្វេសប្រហែស ១ រក្សាសម្បត្តិរបស់មិត្តដែលធ្វេសប្រហែស ១ ជាទីពឹងពំនាក់នៃមិត្ត ដែលមានសេចក្តីភិតភ័យ ១ កាលបើ

កិច្ចដែលត្រូវធ្វើកើតឡើងហើយ តែងជួយផ្តល់ភោគៈ ជាទ្វិគុណជាងទ្រព្យដែលមិត្តត្រូវការនោះ ១ ដូច្នេះ ។

ម្យ៉ាងទៀត ដូចព្រះតម្រាស់ថា

ម្នាលគហបតិបុត្ត មិត្តរួមសុខទុក្ខ ជាមិត្តមានសន្តានល្អ អ្នកត្រូវដឹងដោយស្ថាន ៤ យ៉ាង គឺប្រាប់នូវអាថ៌កំបាំងរបស់ខ្លួនដល់មិត្ត ១ ជួយបិទបាំងនូវអាថ៌កំបាំងរបស់មិត្ត ១ មិនបោះបង់គ្នាក្នុងគ្រាមានវិបត្តិ ១ សូម្បីជីវិតក៏ហ៊ានលះបង់ដើម្បីប្រយោជន៍ដល់មិត្ត ( ស៊ូប្តូរជីវិត ) ១ ដូច្នេះ ។

ម្យ៉ាងទៀត ដូចព្រះតម្រាស់ថា

ម្នាលគហបតិបុត្ត មិត្តមានសេចក្តីឈឺឆ្អាល ជាមិត្តមានសន្តានល្អ អ្នកត្រូវដឹងដោយស្ថាន ៤ យ៉ាង គឺជួយព្រួយចិត្តពីព្រោះមិត្តបានសេចក្តីវិនាស ១ ជួយត្រេកអរ ព្រោះមិត្តបានសេចក្តីចម្រើន ១ ទទឹងទាស់នឹងមនុស្សដែលពោលទោសមិត្ត ១ សរសើរតែមនុស្សដែលពណ៌នាគុណមិត្ត ១ ដូច្នេះ ។

ម្យ៉ាងទៀត ដូចព្រះតម្រាស់ត្រាស់ថា

ម្នាលគហបតិបុត្ត មិត្តប្រាប់ប្រយោជន៍ ជាមិត្តមានសន្តានល្អ អ្នកត្រូវដឹងដោយស្ថាន ៤ យ៉ាង គឺហាមមិត្តឲ្យឃ្លាតចាកអំពើអាក្រក់ ១ ដឹកនាំឲ្យមិត្ត តម្កល់នៅតែក្នុងអំពើល្អ ១ ឲ្យបានឮពាក្យ ដែលមិនធ្លាប់បានឮ ១ ប្រាប់ផ្លូវស្ថានសួគ៌ ១

ដូច្នេះ ។

បណ្ដាមិត្ត ២ ពួកនោះ ក្នុងទីនេះ បំណងយកអគារិយមិត្ត តែដោយសេចក្ដី រមែងរួមយកមិត្តទាំងអស់ ។ បទថា **មិត្តេ សុហជ្ជេ អនុកម្បមានោ** បានដល់ អាណិតអាសូរមិត្តសម្លាញ់ទាំងនោះ គឺត្រូវការនាំសុខចូលទៅឲ្យមិត្តទាំងនោះ និងត្រូវកម្ចាត់ទុក្ខចោលទៅ ។

បទថា **ហាបេតិ អត្ថំ** សេចក្ដីថា រមែងធ្វើប្រយោជន៍ ៣ គឺទិដ្ឋធម្មិកត្ថប្រយោជន៍ សម្បរាយិកត្ថប្រយោជន៍ និងបរមត្ថប្រយោជន៍ឲ្យវិនាស ។ ម្យ៉ាងទៀត រមែងធ្វើប្រយោជន៍ ៣ គឺប្រយោជន៍ខ្លួន ប្រយោជន៍អ្នកដទៃ និងប្រយោជន៍របស់ខ្លួនផងអ្នកដទៃផងឲ្យវិនាស គឺឲ្យវិនាសទៅដោយចំណែកទាំង ២ គឺធ្វើវត្ថុដែលបានហើយឲ្យវិនាសទៅ ១ ធ្វើវត្ថុដែលមិនទាន់កើត មិនឲ្យកើតឡើង ១ បុគ្គលមានចិត្តជាប់ជំពាក់ គឺដាក់ខ្លួនក្នុងឋានៈដែលទាបយ៉ាងនេះថា វៀរបុគ្គលនេះចេញ អាត្មាអញរស់នៅមិនបាន បុគ្គលនេះ ជាគតិ ជាអ្នកនាំមុខរបស់អញដូច្នេះក្ដី ឈ្មោះថា បុគ្គលមានចិត្តជាប់ជំពាក់ ។ ឬដាក់ខ្លួនក្នុងឋានៈដែលខ្ពស់យ៉ាងនេះថា មនុស្សទាំងនេះប្រាសចាកអញហើយ ជាអ្នករស់នៅមិនបាន អញជាគតិ ជាអ្នកនាំមុខរបស់មនុស្សទាំងនោះដូច្នេះក្ដី ឈ្មោះថា បុគ្គលមានចិត្តជាប់ជំពាក់ ។ ក្នុងទីនេះ លោកបំណងយកបុគ្គលដែលមានចិត្តជាប់ជំពាក់យ៉ាងនេះ ។

បទថា **ឯតំ ភយំ** បានដល់ ភ័យ គឺការធ្វើប្រយោជន៍ឲ្យវិនាស ។ ពាក្យនេះ ព្រះរាជាត្រាស់សំដៅដល់ការសោបសួនឲ្យចាកសមាបត្តិរបស់ព្រះអង្គ ។

*បទថា* **សង្គេ** *សេចក្តីថា សង្គៈ មាន ៣ យ៉ាង គឺតណ្ហាសង្គៈ ១ ទិដ្ឋិសង្គៈ ១ មិត្តសង្គៈ ១ ។ ក្នុងសង្គៈ ៣ យ៉ាងនោះ តណ្ហាទាំង ១០៨ ឈ្មោះថា តណ្ហាសង្គៈ ទិដ្ឋិ ៦២ ឈ្មោះថា ទិដ្ឋិសង្គៈ ការអនុគ្រោះមិត្ត ដោយភាពជាអ្នកមានចិត្តជាប់ជំពាក់ ឈ្មោះថា មិត្តសង្គៈ ។ បណ្តាសង្គៈ ៣ នោះ ក្នុងទីនេះ បំណងយកមិត្តសង្គៈនោះ ។ ពិតហើយ សមាបត្តិរបស់ព្រះរាជានោះវិនាស ព្រោះមិត្តសង្គៈនោះ ដោយហេតុនោះ ទើបព្រះបច្ចេកសម្ពុទ្ធត្រាស់ថា បុគ្គលកាលឃើញនូវភ័យ ក្នុងសេចក្តីស្និទ្ធស្នាលនុ៎ះ ទើបត្រាស់ដឹង ពាក្យដ៏សេស មានន័យដូចពោលហើយនោះឯង ។*

## អដ្ឋកថា មិត្តសុហជ្ជគាថា ចប់

# អដ្ឋកថា

## វិសត្តធីរគាថា

គាថាថា **វិសោ វិសាលោ** ដូច្នេះជាដើម មានអត្ថុប្បត្តិហេតុដូចម្តេច ។ បានឮថា ក្នុងកាលមុន ព្រះបច្ចេកពោធិសត្វ ៣ អង្គ បួសក្នុងសាសនានៃព្រះមានព្រះភាគកស្សបៈ បំពេញគតបច្ចាគតវត្តអស់ ២ ម៉ឺនឆ្នាំ ហើយកើតឡើងក្នុងទេវលោក ចុតិអំពីទេវលោកនោះហើយ បណ្តាបច្ចេកពោធិសត្វទាំងនោះ បច្ចេកពោធិសត្វច្បង កើតក្នុងរាជត្រកូលរបស់ព្រះបាទពារាណសី បច្ចេកពោធិសត្វ ២ អង្គទៀត កើតក្នុងរាជត្រកូលជាយដែន ។ ព្រះបច្ចេក-ពោធិសត្វទាំង ២ អង្គនោះ រៀនកម្មដ្ឋានហើយ លះបង់រាជសម្បត្តិ ចេញបួស បានជាព្រះបច្ចេកសម្ពុទ្ធដោយលំដាប់ នៅត្រង់ញកភ្នំនន្ទមូលកៈ ថ្ងៃមួយចេញអំពីសមាបត្តិ ហើយអាវជ្ជនៈថា យើងទាំងឡាយធ្វើកម្មអ្វី ទើបសម្រេចលោកុត្តរសុខនេះដោយលំដាប់ ពិចារណាក៏បានឃើញចរិយារៀងៗ ខ្លួន ក្នុងកាលនៃព្រះកស្សបសម្ពុទ្ធ បន្ទាប់អំពីនោះ ទើបអាវជ្ជនៈថា អង្គទី ៣ នៅឯណា ក៏បានដឹងថា ក្នុងនគរពារាណសី រឭកដល់គុណទាំងឡាយរបស់ព្រះបច្ចេកពោធិសត្វអង្គនោះ គិតថា ព្រះបច្ចេកពោធិសត្វនោះ តាមប្រក្រតី ជាអ្នកប្រកបដោយគុណ មានការប្រាថ្នាតិចជាដើម ជាអ្នកឲ្យឱវាទ ប្រៀនប្រដៅចំពោះពួកយើង អត់ធន់ចំពោះពាក្យសម្តី មានប្រក្រតីតិះដៀលបាប ណ្ហើយចុះ យើងនឹងសម្តែងអារម្មណ៍នោះឲ្យដឹង ។ រង់ចាំឱកាស ថ្ងៃមួយ ឃើញព្រះរាជានោះប្រដាប់ដោយគ្រឿងអលង្ការទាំងពួង យាងទៅកាន់ឧទ្យាន ទើបមកតាមអាកាស ឈរត្រង់គុម្ពឫស្សី ក្បែរទ្វារឧទ្យាន ។ មហាជនមិនឆ្អែត

ក្នុងការមើលព្រះរាជា សម្លឹងមើលតែព្រះរាជា ។ លំដាប់នោះ ព្រះរាជាទ្រង់ព្រះតម្រិះថា មានឬទេហ្ន៎ បុគ្គលណាមួយ មិនធ្វើនូវការខ្វល់ខ្វាយក្នុងការមើលអញ ទើបពិនិត្យមើល ក៏បានឃើញព្រះបច្ចេកសម្ពុទ្ធទាំង ២ អង្គ ទ្រង់ក៏កើតសេចក្តីស្រឡាញ់ក្នុងព្រះបច្ចេកសម្ពុទ្ធទាំង ២ អង្គនោះ មួយរំពេច ។ ព្រះរាជាក៏យាងចុះអំពីកដំរី ចូលទៅរកដោយមារយាទដ៏ស្ងប់ ហើយត្រាស់សួរថា បពិត្រលោកម្ចាស់ៗ ទាំងឡាយ ឈ្មោះអ្វី ព្រះបច្ចេកសម្ពុទ្ធទាំង ២ អង្គទូលថា បពិត្រមហារាជ អាត្មាឈ្មោះ **អសជ្ជមាន** ។ ព្រះរាជាត្រាស់សួរថា បពិត្រលោកម្ចាស់ ពាក្យថា **អសជ្ជមាន** នេះ មានសេចក្តីដូចម្តេច ព្រះបច្ចេកសម្ពុទ្ធទូលថា មានសេចក្តីថា មិនជាប់ជំពាក់ ។

លំដាប់នោះ ព្រះបច្ចេកសម្ពុទ្ធក៏ចង្អុលបង្ហាញគុម្ពឫស្សី ហើយទូលថា បពិត្រមហារាជ គុម្ពឫស្សីនេះ ឫស ដើម មែកធំ និងមែកតូច ចាក់ស្រែះគ្នា ដោយប្រការទាំងពួង បុរសមានដាវក្នុងដៃ កាលកាត់ឫស ហើយទាញចេញមក ក៏មិនអាចទាញចេញមកបានយ៉ាងណា ព្រះអង្គក៏យ៉ាងនោះដូចគ្នាត្រូវព្រៃស្លុកខាងក្នុង និងខាងក្រៅ ធ្វើឲ្យជាប់ជំពាក់ចាក់ស្រែះក្នុងអារម្មណ៍នោះ ម្យ៉ាងទៀត ទំពាំងឫស្សីនេះ ទោះបីនៅត្រង់កណ្តាលគុម្ពឫស្សីនោះ ក៏មិនជាប់ជំពាក់ ព្រោះមិនមានមែក បុគ្គលណាម្នាក់ ក៏អាចកាត់ចុង ឬកាត់គល់ ហើយទាញចេញមកបាន យ៉ាងណា អាត្មាទាំងឡាយ ក៏យ៉ាងនោះដូចគ្នា មិនជាប់ក្នុងវត្ថុណាមួយ ទៅបានគ្រប់ទិស កាលពោលដូច្នេះហើយ ទើបចូលចតុត្ថជ្ឈានមួយរំពេច កាលព្រះរាជាកំពុងទតនោះឯង បានទៅកាន់ញកភ្នំ

ឈ្មោះនន្ទមូលកៈ តាមផ្លូវអាកាស ។

លំដាប់នោះ ព្រះរាជាទ្រង់ព្រះតម្រិះថា ក្នុងកាលណាហ្ន៎ អាត្មាអញ គប្បីជាអ្នកមិនជាប់ជំពាក់យ៉ាងនេះ ទាំងដែលប្រថាប់ឈរនោះឯង ទ្រង់ឃើញច្បាស់ បានធ្វើឲ្យជាក់ច្បាស់នូវបច្ចេកពោធិញ្ញាណហើយ ។ ព្រះបច្ចេកសម្ពុទ្ធត្រូវសួរដល់កម្មដ្ឋាន ដោយន័យដែលមានក្នុងកាលមុននោះឯង ទើបពោលគាថានេះ ។

ឫស្សី ឈ្មោះថា **វំស** ក្នុងគាថានេះ ។ បទថា **វិសាលោ** បានដល់ផ្សាយចេញទៅ ។ **វ** អក្ខរៈ មានអត្ថថា ឃាត់នូវអត្ថដទៃ ។ ម្យ៉ាងទៀត **វ** អក្ខរៈនេះ គឺ **ឯវ** អក្ខរៈ ។ ក្នុងទីនេះ **ឯ** អក្សរៈ បាត់ទៅ ដោយអំណាចសន្ធិ **ឯ** អក្ខរៈនោះ ភ្ជាប់ចូលជាមួយបទខាងក្រោយ ។ ខ្ញុំនឹងអធិប្បាយសេចក្តីនោះខាងក្រោយ ។ បទថា **យថា** ប្រើក្នុងការប្រៀបធៀប ។ បទថា **វិសត្តោ** បានដល់ ជាប់ចាក់ស្រែះគ្នា ។ បទថា **បុត្តេសុ ទារេសុ ច** បានដល់ ក្នុងកូនប្រុស កូនស្រី និងភរិយា ។ បទថា **យា អបេក្ខា** បានដល់ ចំណង់ណា គឺសេចក្តីស្រឡាញ់ឯណា ។ បទថា **វំសក្កឡីរោវ អសជ្ជមានោ** សេចក្តីថា មិនជាប់ ដូចទំពាំងឫស្សី ។ លោកអធិប្បាយដូចម្តេច លោកអធិប្បាយថា ឫស្សីផ្សាយ រមែងជារបស់ចាក់ស្រែះគ្នាទាំងអស់ យ៉ាងណា ការជាប់ជំពាក់ក្នុងបុត្ត ធីតា និងភរិយានោះ ក៏យ៉ាងនោះ ឈ្មោះថា ជាប់ជំពាក់ព្រោះចាក់ស្រែះដោយវត្ថុទាំងពួងនោះ ។ អាត្មានោះ មានការជាប់ជំពាក់ ដោយការជាប់ជំពាក់នោះ ទើបជាប់ជំពាក់ ដូចឫស្សីដែល

*ផ្សាយទៅ ដូច្នោះ ព្រោះហេតុនោះ អាត្មាឃើញទោសក្នុងការជាប់ជំពាក់យ៉ាងនេះ ទើបកាត់នូវការជាប់ជំពាក់នោះ ដោយមគ្គញ្ញាណ មិនជាប់ជំពាក់ដោយតណ្ហា មានះ ទិដ្ឋិ ក្នុងអារម្មណ៍ មានរូបជាដើម ក្នុងវត្ថុដែលគួរប្រាថ្នាមានលាភជាដើម ឬក្នុងភព មានកាមភពជាដើម ដូចទាំងនេះ ទើបសម្រេចបច្ចេកពោធិញ្ញាណ ។ ពាក្យដ៏សេស គប្បីជ្រាបដោយន័យមុននោះឯង ។*

**អដ្ឋកថា វិសណ្ណធម្មគាថា ចប់**

# អដ្ឋកថា

## មិគោអរញ្ញគាថា

គាថាថា **មិគោ អរញ្ញម្ហិ** ដូច្នេះជាដើម មានអត្ថុប្បត្តិហេតុដូចម្តេច ។

បានឮថា ភិក្ខុមួយរូប ជាព្រះយោគាវចរ ក្នុងសាសនារបស់ព្រះមានព្រះភាគកស្សបៈ ធ្វើកាលកិរិយាហើយ កើតក្នុងត្រកូលសេដ្ឋី នៅក្នុងនគរពារាណសីដែលជាត្រកូលស្តុកស្តម្ភ មានទ្រព្យច្រើន មានភោគៈច្រើន កុលបុត្តនោះ ជាអ្នកមានរូបស្អាត ព្រោះហេតុនោះ ទើបធ្វើខុសចំពោះភរិយារបស់អ្នកដទៃ ស្លាប់ហើយ ទៅកើតក្នុងនរក ឆេះក្នុងនរកនោះ ដោយវិបាកនៃកម្មដ៏សេស ទើបបដិសន្ធិជាស្រីក្នុងផ្ទៃរបស់ភរិយាសេដ្ឋី ។ សត្វដែលមកអំពីនរក រមែងមានរាងកាយក្តៅ ដោយហេតុនោះ ភរិយារបស់សេដ្ឋីមានគភ៌ក្តៅ ទ្រទ្រង់នូវគភ៌នោះដោយលំបាក ហើយប្រសូតទារិកាតាមកំណត់ ។ ទារិកានោះ ចាប់តាំងពីថ្ងៃដែលកើតមក ជាទីស្អប់ខ្ពើមរបស់មាតាបិតា និងរបស់ពួកញាតិ មួយអន្លើដោយបរិវារជន លុះចម្រើនវ័យហើយ បានជាទីស្អប់ខ្ពើម មិនជាទីស្រឡាញ់ មិនជាទីពេញចិត្ត របស់ស្វាមី ឪពុកក្មេក និងម្តាយក្មេក ក្នុងត្រកូលដែលលើកនាងឲ្យ ។ កាលមហាជនប្រកាសបុណ្យនក្ខត្តឫក្ស សេដ្ឋីបុត្តមិនប្រាថ្នានឹងដើរលេងជាមួយទារិកានោះ ទើបនាំស្រីគណិកាមកដើរលេង ។ ទារិកានោះ បានឮដំណឹងនោះ អំពីសម្នាក់ពួកទាសី ទើបចូលទៅរកសេដ្ឋីបុត្ត រៀបរាប់ដោយប្រការផ្សេងៗ ថា បពិត្រអយ្យបុត្ត ធម្មតាស្រី ទោះបីជាប្អូនស្រីរបស់ព្រះរាជា ១០ អង្គ ឬជាបុត្រីរបស់ស្តេចចក្រពត្តិ ក៏ត្រូវធ្វើការបម្រើប្តី កាលប្តីមិនហៅរក រមែងសោយទុក្ខ ដូចចាក់

ដោយលំពែង បើខ្ញុំគួរដល់ការអនុគ្រោះ ក៏គួរអនុគ្រោះ បើមិនគួរអនុគ្រោះ ក៏គួរដោះលែង ខ្ញុំនឹងទៅកាន់ផ្ទះញាតិរបស់ខ្ញុំ ។ សេដ្ឋីបុត្តពោលថា ណ្ហើយចុះ នាង នាងកុំទោមនស្សឡើយ ចូរត្រៀមការលេងចុះ ពួកយើងនឹងលេងនក្ខត្តឫក្ស ។ ត្រឹមតែវាចាប៉ុណ្ណោះ ធីតាសេដ្ឋីកើតឧស្សាហ៍មួយរំពេច គិតថា នឹងលេងនក្ខត្តឫក្សស្អែកនេះ ទើបរៀបចំរបស់ទំពា និងរបស់បរិភោគសន្ធឹកសន្ធាប់ ។ ក្នុងថ្ងៃទី ២ សេដ្ឋីបុត្តមិនបានប្រាប់ឡើយ បានទៅកាន់ទីលេង ។ ទារិកាអង្គុយចាំមើលផ្លូវ ដោយទន្ទឹងក្នុងចិត្តថា ប្តីអញនឹងបញ្ជូនមនុស្សមកក្នុងកាលឥឡូវនេះ ឃើញព្រះអាទិត្យរះខ្ពស់ហើយ ទើបបញ្ជូនមនុស្សទៅមើលមនុស្សទាំងនោះ ត្រឡប់មកហើយប្រាប់ថា បុត្តរបស់សេដ្ឋីទៅហើយ សេដ្ឋីធីតានោះ ក៏កាន់យករបស់ទាំងអស់ ដែលត្រៀមស្រេចបាច់ហើយ លើកឡើងដាក់យាន ទៅកាន់ឧទ្យាន គ្រានោះ ព្រះបច្ចេកសម្ពុទ្ធនៅត្រង់ញកភ្នំនន្ទមូលកៈ ក្នុងថ្ងៃទី ៧ ចេញអំពីនិរោធសមាបត្តិ ទំពាឈើស្ទន់ ឈ្មោះនាគលតា លុបមុខត្រង់អនោតត្តស្រះហើយ ពិចារណាថា ថ្ងៃនេះ អាត្មាអញនឹងត្រាច់បិណ្ឌបាតក្នុងទីណា បានឃើញធីតារបស់សេដ្ឋីនោះ ដឹងថា កម្មនោះរបស់សេដ្ឋីធីតានេះ នឹងដល់នូវការអស់ទៅ ព្រោះបានធ្វើនូវសក្ការៈដោយសទ្ធាក្នុងអាត្មាអញ ទើបឈរត្រង់ផ្ទៃមនោសិលា ដែលមានទំហំ ៦០ យោជន៍ ក្នុងទីជិតញកភ្នំ កាន់បាត្រ និងចីវរ ចូលឈាន មានអភិញ្ញាជាបាទហើយមកតាមអាកាស ចុះត្រង់ផ្លូវដែលនាងធ្វើដំណើរមក បែរមុខទៅកាន់នគរពារាណសី ។ ពួកទាសីឃើញព្រះបច្ចេកសម្ពុទ្ធនោះ ក៏ប្រាប់ដល់សេដ្ឋីធីតា

នាងក៏ចុះចាកយាន ថ្វាយបង្គំដោយគោរព ដាក់បាត្រឲ្យពេញដោយរបស់គួរទំពា របស់គួរបរិភោគ ដែលសម្បូរដោយរសផ្សេងៗ ហើយយកផ្កាឈូកគ្រប យកដៃមួយកាន់ផ្កាឈូក ដោយឲ្យផ្កាឈូកនៅខាងក្រោមបាត្រ ប្រគេនបាត្រក្នុងដៃរបស់ព្រះបច្ចេកសម្ពុទ្ធហើយ ថ្វាយបង្គំហើយ ដៃកាន់បាច់ផ្កាឈូកបានធ្វើសេចក្តីប្រាថ្នាថា បពិត្រលោកម្ចាស់ ខ្ញុំកើតក្នុងភពណាៗ គប្បីជាទីស្រឡាញ់ ជាទីពេញចិត្តរបស់មហាជនក្នុងភពនោះៗ ដូចផ្កាឈូកនេះ ។ លុះប្រាថ្នាយ៉ាងនេះហើយ ទើបប្រាថ្នាទី ២ ថា បពិត្រលោកម្ចាស់ ការនៅក្នុងគភ៌ជាការលំបាក ខ្ញុំគប្បីបដិសន្ធិក្នុងផ្កាឈូកប៉ុណ្ណោះ កុំកើតក្នុងផ្ទៃឡើយ ហើយប្រាថ្នាទី ៣ ថា មាតុគ្រាមគួររង្កៀស សូម្បីជាបុត្រីរបស់ស្តេចចក្រពត្តិ ក៏ត្រូវនៅក្នុងអំណាចរបស់អ្នកដទៃ ព្រោះហេតុនោះ ខ្ញុំកុំបានចូលដល់ភាពជាស្រីឡើយ គប្បីជាបុរស ។ លើកទី ៤ ក៏ប្រាថ្នាថា បពិត្រលោកម្ចាស់ ខ្ញុំគប្បីកន្លងផុតសង្សារទុក្ខនេះ ក្នុងទីបំផុតគប្បីសម្រេចអមតធម៌ ដែលលោកម្ចាស់បានសម្រេចហើយនេះ នាងធ្វើសេចក្តីប្រាថ្នា ៤ ប្រការយ៉ាងនេះហើយ ធ្វើការបូជាផ្កាឈូកមួយក្តាប់នោះ ហើយថ្វាយបង្គំដោយបញ្ចង្គប្រតិស្ឋាន បានធ្វើសេចក្តីប្រាថ្នាទី ៥ ដូច្នេះថា សូមក្លិន និងពណ៌សម្បុររបស់ខ្ញុំ ដូចផ្កានោះឯង ។

លំដាប់នោះ ព្រះបច្ចេកសម្ពុទ្ធទទួលបាត្រ និងបាច់ផ្កាហើយ ឈរក្នុងអាកាស ធ្វើអនុមោទនាដល់សេដ្ឋីធីតាដោយគាថានេះថា

**ឥច្ឆិតំ បត្ថិតំ តុយ្ហំ ខិប្បមេវ សមិជ្ឈតុ**

**សព្វេ បូរេន្តុ សង្កប្បា ចន្ទោ បន្នរសោ យថា ។**

ផលដែលអ្នកត្រូវការប្រាថ្នា ចូរសម្រេចដោយឆាប់រហ័ស ការត្រិះរិះទាំងពួង ចូរពេញ ដូចព្រះចន្ទក្នុងថ្ងៃ ១៥ កើត ។

ហើយអធិដ្ឋានថា ខណៈអាត្មាអញទៅ សេដ្ឋីធិតា ចូរឃើញអាត្មាអញ ហើយទៅកាន់ញកភ្នំនន្ទមូលកៈតាមអាកាស ។ កាលធីតារបស់ សេដ្ឋីឃើញដូច្នោះ កើតនូវបីតិច្រើន ។ អកុសលកម្មដែលនាងធ្វើក្នុងវាងកពអស់ទៅ ព្រោះមិនមានឱកាស ។ នាងជាសត្វបរិសុទ្ធ ដូចភាជន៍មាស ដែលខាត់ដោយម្ជូរអំពិល ដូច្នោះ ។ រំពេចនោះឯង ជនទាំងពួងក្នុងត្រកូលស្វាមីនិងត្រកូលញាតិរបស់នាងត្រេកអរហើយ បញ្ជូនពាក្យដែលគួរស្រឡាញ់ និងបណ្ណាការទៅថា ពួកយើងនឹងធ្វើអ្វីខ្លះ ។ សូម្បីប្ដីក៏បញ្ជូនមនុស្សទៅថា ចូរនាំសេដ្ឋីធីតាមកកាន់ឧទ្យានដោយឆាប់រហ័ស ដំបូងខ្ញុំក្លេចនាង ។ ចាប់តាំងអំពីនោះមក មហាជនស្រឡាញ់រាប់អាន មើលថែនាង ដូចលម្អិតខ្ទឹមចន្ទន៍ដែលលាបត្រង់ទ្រូង ដូចកែវមុក្ដាហារដែលពាក់ និងដូចកម្រងផ្កា ដូច្នោះ ។ នាងសោយសុខដែលប្រកបដោយភាពជាធំ និងភោគទ្រព្យដរាបដល់អស់អាយុ ស្លាប់ទៅ កើតក្នុងផ្កាឈូកនាស្ថានទេវលោក ដោយភេទជាបុរស ។ ទេវបុត្តនោះ កាលដើរ ក៏ដើរក្នុងផ្កាឈូកប៉ុណ្ណោះ ឈរក្ដី ដេកក្ដី អង្គុយក្ដី ក៏ឈរ អង្គុយ ដេក ក្នុងផ្កាឈូកដូចគ្នា ទេវតាទាំងឡាយនាំគ្នាហៅទេវបុត្តនោះថា មហាបទុមទេវបុត្ត ។ មហាបទុមទេវបុត្តនោះ អន្ទោលទៅអន្ទោល

មកតែក្នុងទេវលោក ៦ ជាន់ប៉ុណ្ណោះ ដោយឥទ្ធានុភាពនោះ ដោយប្រការដូច្នេះ ។

សម័យនោះ ព្រះបាទពារាណសីមានស្រ្តី ២ ម៉ឺន បណ្តាស្រ្តីទាំងនោះ សូម្បីតែស្រ្តីម្នាក់ ក៏គ្មានបុត្ត ។ អមាត្យទាំងឡាយក៏ក្រាបទូលឲ្យព្រះរាជាទ្រង់ច្បាស់ថា បពិត្រព្រះសម្មតិទេព សូមទ្រង់ប្រាថ្នាព្រះឱរស ដើម្បីរក្សាវង្សត្រកូល កាលព្រះឱរសកើតក្នុងទ្រង់មិនមាន ព្រះឱរសដែលកើតក្នុងខេត្ត ក៏ជាអ្នកទ្រទ្រង់នូវវង្សត្រកូលបាន ។ លំដាប់នោះ ទើបព្រះរាជាត្រាស់ថា ស្រ្តីដទៃ វៀរលែងតែអគ្គមហេសី ចូរធ្វើនូវការរាំ ប្រកបដោយធម៌អស់ ៧ ថ្ងៃ ហើយឲ្យត្រាច់ទៅខាងក្រៅព្រះរាជវាំងបាន តាមសេចក្តីប្រាថ្នា ។ ទោះបីយ៉ាងនោះ ក៏មិនបានព្រះរាជឱរស ។ ទើបអមាត្យទាំងឡាយក្រាបទូលទៀតថា បពិត្រមហារាជ ធម្មតាព្រះមហេសី ជាបុគ្គលប្រសើរជាងស្រីទាំងពួង ដោយបុណ្យ និងបញ្ញា ទ្រង់នឹងបានព្រះរាជឱរសក្នុងគភ៌របស់ព្រះនាង ។ ព្រះរាជាក៏ប្រាប់សេចក្តីនោះដល់ព្រះមហេសី ។ ព្រះមហេសីក្រាបទូលថា បពិត្រមហារាជ ស្រ្តីអ្នកមានសីល មានប្រក្រតីពោលពាក្យសច្ចៈ ទើបបានបុត្ត ស្រ្តីដែលប្រាសចាកហិរិឱត្តប្បៈ នឹងបានបុត្តដូចម្តេចកើត ទើបឡើងកាន់ប្រាសាទ សមាទានសីល ៥ ហើយពិចារណារឿយៗ កាលព្រះរាជធីតាអ្នកមានសីល ពិចារណាដល់សីល ៥ តាំងព្រះហឫទ័យប្រាថ្នាបុត្ត អាសនៈរបស់ព្រះឥន្ទ្រក៏ញាប់ញ័រ ។

លំដាប់នោះ សក្កទេវរាជទ្រង់ពិចារណាមើល ទ្រង់ឃើញច្បាស់នូវ

រឿងនោះហើយ មានព្រះតម្រិះថា អញនឹងឲ្យបុត្តដ៏ប្រសើរដល់ព្រះរាជធីតា អ្នកមានសីល ទើបយាងមកតាមអាកាស ប្រថាប់ឈរត្រង់មុខព្រះទេវី រួចត្រាស់ថា បពិត្រព្រះទេវី នាងប្រាថ្នាអ្វី ព្រះទេវីទូលថា បពិត្រមហារាជ ខ្ញុំប្រាថ្នាព្រះរាជឱរស សក្កទេវរាជត្រាស់ថា នែព្រះទេវី ខ្ញុំនឹងឲ្យព្រះរាជឱរសដល់ព្រះនាងៗ កុំគិតថ្វីឡើយ ហើយយាងទៅកាន់ទេវលោក ពិចារណាថា ទេវបុត្តដែលអស់អាយុក្នុងទេវលោកនេះ មានឬហ្ន៎ ទ្រង់ជ្រាបថា មហាបទុមទេវបុត្តនេះ ជាអ្នកប្រាថ្នាទៅកាន់ទេវលោកខាងលើ ទើបទៅកាន់វិមានរបស់មហាបទុមទេវបុត្តនោះ ហើយអង្វរថា នែមហាបទុម ចូរអ្នកទៅកាន់មនុស្សលោកចុះ ។ មហាបទុមទេវបុត្តក្រាបទូលថា បពិត្រមហារាជ ទ្រង់កុំត្រាស់យ៉ាងនេះ ខ្ញុំខ្ពើមមនុស្សលោក ។ សក្កទេវរាជត្រាស់ថា នែបា អ្នកធ្វើបុណ្យក្នុងមនុស្សលោកទេតើ ទើបកើតក្នុងទេវលោកនេះ អ្នកតាំងនៅក្នុងមនុស្សលោកនោះឯង អាចបំពេញបារមីបាន នែបា ចូរអ្នកទៅចុះ ។ មហាបទុមទេវបុត្តក្រាបទូលថា បពិត្រមហារាជ ការនៅក្នុងផ្ទៃជាទុក្ខ ខ្ញុំមិនអាចនៅក្នុងផ្ទៃនោះ កាលសក្កទេវរាជត្រាស់ហើយត្រាស់ទៀតថា នែបា ការនៅក្នុងផ្ទៃមិនមានដល់បាឡើយ ព្រោះបាបានធ្វើកម្មដោយប្រការដែលកើតចំពោះក្នុងផ្កាឈូកប៉ុណ្ណោះ នែបា ចូរទៅចុះ ទេវបុត្រក៏ទទួលពាក្យ ។ មហាបទុមទេវបុត្តនោះ ចុតិអំពីទេវលោកហើយ កើតក្នុងផ្កាឈូក ក្នុងស្រះបោក្ខរណីដែលដេរដាសដោយផ្ទាំងថ្ម ក្នុងឧទ្យានរបស់ព្រះបាទពារាណសី យប់នោះក្នុងវេលាជិតភ្លឺ ព្រះមហេសីទ្រង់សុបិនថា ព្រះនាងចោមរោមដោយស្ត្រី ២

ម៉ឺន យាងទៅកាន់ឧទ្យាន បានព្រះរាជឱរសក្នុងផ្កាឈូក នាស្រះបោក្ខរណី ដែលដេរដាសទៅដោយថ្ម ។ កាលរាត្រីអស់ហើយ ព្រះនាងទ្រទ្រង់សីល បានយាងទៅកាន់ព្រះរាជឧទ្យាននោះ ឃើញផ្កាឈូកមួយ ផ្កាឈូកនោះនៅមាត់ប្រាំងផង ក្នុងទីមិនជ្រៅផង ។ ដំណាលគ្នានឹងនាងទតឃើញប៉ុណ្ណោះ សេចក្តីស្រឡាញ់ដូចកូន កើតឡើងក្នុងផ្កាឈូកនោះ ព្រះនាងចុះឯង កាច់យកផ្កាឈូកនោះមក ផ្កាឈូកកាលព្រះនាងចាប់ពាល់ប៉ុណ្ណោះ ត្របកទាំងឡាយក៏រីក ព្រះនាងបានឃើញទារកល្អដូចបដិមាមាសក្នុងផ្កាឈូកនោះ ។ គ្រាន់តែឃើញប៉ុណ្ណោះ ព្រះនាងទ្រង់បន្លឺព្រះសូរសៀងថា ខ្ញុំបានរាជបុត្តហើយ ។ មហាជនបានបន្លឺសាធុការរាប់ពាន់ដង ហើយបញ្ជូនដំណឹងដល់ព្រះរាជា ។ ព្រះរាជាទ្រង់ស្តាប់ហើយត្រាស់សួរថា បានក្នុងទីណា ទ្រង់បានស្តាប់ដល់ទីដែលបាន ទើបត្រាស់ថា ឧទ្យាន និងផ្កាឈូកជារបស់យើង ព្រោះហេតុនោះ បុត្តនេះ ឈ្មោះថា បុត្តដែលកើតក្នុងខេត្ត ព្រោះកើតក្នុងដែនរបស់យើង ទើបឲ្យបួលមកកាន់នគរ ឲ្យស្ត្រី ២ ម៉ឺនាក់ ធ្វើកិច្ចជាមេដោះ ។ ស្ត្រីណាដឹងថា ព្រះរាជកុមារពេញចិត្តរបស់ណា ឲ្យព្រះរាជកុមារសោយរបស់ទំពា ដែលទ្រង់ចង់សោយ ស្ត្រីនោះ នឹងបានទ្រព្យ ១០០០ ។ នគរពារាណសីទាំងមូល កក្រើករំពើក ជនទាំងពួងបានបញ្ជូនបណ្ណាការរាប់ពាន់ថ្វាយព្រះរាជកុមារ ។ ព្រះរាជកុមារ ទ្រង់មិនដាក់ព្រះហឫទ័យដល់បណ្ណាការនោះៗ កាលពួកមេដោះទូលថា សូមទ្រង់ទំពារបស់នេះ សូមទ្រង់សោយរបស់នេះ ទ្រង់ធុញទ្រាន់ក្នុងព្រះក្រយាហារ ក៏យាងទៅកាន់ខ្លោងទ្វារ ទ្រង់

លេនឃ្មុំ ដែលធ្វើដោយដុំល័ខ ។

ក្នុងកាលនោះ មានព្រះបច្ចេកសម្ពុទ្ធមួយអង្គ អាស្រ័យនគរពារាណសី នៅត្រង់ឥសិបតនៈ ក្រោកអំពីព្រហាម ធ្វើកិច្ចទាំងពួង មានសេនាសនវត្ត បរិកម្មរាងកាយ និងមនសិការកម្មដ្ឋានជាដើមហើយ ចេញអំពីទីសម្ងំ ពិចារណាថា ថ្ងៃនេះ អាត្មាអញនឹងទទួលភិក្ខាក្នុងទីណា បានឃើញគុណរបស់ព្រះរាជកុមារ ទើបពិចារណាថា ព្រះរាជកុមារនេះ ក្នុងជាតិមុន បានធ្វើកម្មអ្វី បានជ្រាបថា ព្រះរាជកុមារនេះ បានឲ្យបិណ្ឌបាតដល់បុគ្គលដូចគ្នានឹងអាត្មាអញ ហើយប្រាថ្នា ៤ យ៉ាង ក្នុងការប្រាថ្នា ៤ យ៉ាងនោះ ៣ យ៉ាង សម្រេចហើយ សេចក្តីប្រាថ្នាមួយទៀត មិនទាន់សម្រេច អាត្មាអញនឹងឲ្យអារម្មណ៍ដល់ព្រះរាជកុមារនោះដោយឧបាយ គិតហើយ ក៏ទៅកាន់សម្នាក់របស់ព្រះរាជកុមារនោះ ដោយការត្រាច់បិណ្ឌបាត ។ ព្រះរាជកុមារ ឃើញព្រះបច្ចេកសម្ពុទ្ធនោះហើយ ត្រាស់ថា បពិត្រសមណៈ លោកកុំមកទីនេះឡើយ ព្រោះមនុស្សទាំងនេះ នឹងពោលជាមួយលោកថា ចូរទំពារបស់នេះ ចូរបរិភោគរបស់នេះ ។ ដោយការពោលពាក្យត្រឹមមួយមាត់ ព្រះបច្ចេកសម្ពុទ្ធក៏និមន្តត្រឡប់អំពីទីនោះ ទៅកាន់សេនាសនៈរបស់ខ្លួន ព្រះរាជកុមារក៏ពោលនឹងបរិវារថា សមណៈនេះគ្រាន់តែយើងពោលប៉ុណ្ណោះ ក៏ត្រឡប់ទៅ លោកខឹងនឹងយើងទេដឹង ។ ព្រះរាជកុមារនោះ កាលពួកបរិវារជនទូលថា ធម្មតាបព្វជិតទាំងឡាយ មិនឈមមុខទៅរកសេចក្តីក្រោធទេ បុគ្គលដទៃមានចិត្តជ្រះថ្លា ឲ្យនូវរបស់ណា ក៏ញុំាំងអត្តភាព ឲ្យប្រព្រឹត្តទៅដោយរបស់នោះ ។

ព្រះរាជកុមារទ្រង់ព្រះតម្រិះថា សមណៈបែបនេះ ក្រោធហើយ អញនឹងឲ្យលោកអត់ទោស ទើបក្រាបទូលដល់ព្រះជនកព្រះជននី ហើយឡើងដំរីទៅកាន់ព្រៃឥសិបតនៈ ដោយរាជានុភាពធំ ទតឃើញហ្វូងម្រឹគ ត្រាស់សួរថា សត្វទាំងនេះ ឈ្មោះអ្វី បរិវារជនទូលថា បពិត្រអយ្យបុត្ត សត្វទាំងនេះឈ្មោះថា ម្រឹគ ព្រះរាជកុមារត្រាស់ថា ពួកជនទាំងឡាយពោលដល់ម្រឹគទាំងនេះថា ចូរស៊ីរបស់នេះ ចូរបរិភោគ ចូរភ្លក្សរបស់នេះ ហើយប្រណិ-ប័តន៍មានឬ ។ បរិវារជនទូលថា បពិត្រព្រះអង្គ មិនមានទេ ម្រឹគទាំងនេះនៅក្នុងទីដែលមានស្មៅ និងមានទឹករកបានងាយ ។ ព្រះរាជកុមារទ្រង់ព្រះតម្រិះថា កាលណាហ្ន៎ អញនឹងនៅដូចម្រឹគទាំងនេះ មិនមានអ្នកណារក្សានៅក្នុងទីដែលប្រាថ្នា ហើយកាន់យករឿងនេះឲ្យជាអារម្មណ៍ ។ ឯព្រះបច្ចេក-សម្ពុទ្ធដឹងថា ព្រះរាជកុមារយាងមក ក៏បោសផ្លូវទៅកាន់សេនាសនៈ និងទីចង្ក្រម ធ្វើឲ្យស្អាត ហើយដើរចង្ក្រម ១-២-៣ ជំហាន សម្តែងស្នាមជើង ហើយបោសទីសម្រាកពេលថ្ងៃ និងសាលាស្លឹក ធ្វើឲ្យស្អាត ទុកស្នាមជើងចូលទៅ មិនបង្ហាញស្នាមជើងចេញមក ហើយទៅកាន់ទីដទៃ ។ ព្រះរាជ-កុមារយាងដល់ទីនោះ ទ្រង់ឃើញទីនោះបោសស្អាត ទ្រង់ស្តាប់បរិវារជនពោលថា ព្រះបច្ចេកសម្ពុទ្ធអង្គនោះ ប្រហែលជានៅក្នុងទីនេះ ទើបត្រាស់ថា សមណៈនោះ កាលពីព្រឹកក៏ក្រោធ បើមកឃើញទីរបស់ខ្លួន ត្រូវដំរី និងសេះជាដើមជាន់ ក៏រឹងរឹតតែក្រោធ ចូរពួកអ្នកឈប់ក្នុងទីនេះឯង ហើយយាងចុះអំពីកដំរី មួយអង្គឯង ចូលទៅកាន់សេនាសនៈ ទ្រង់ឃើញស្នាមជើងក្នុង

ទីដែលបោសយ៉ាងល្អ ដោយត្រឹមត្រូវតាមវត្ត ទើបទ្រង់ព្រះតម្រិះថា ឥឡូវនេះ សមណៈនោះនឹងចង្ក្រមក្នុងទីនេះ មិនគិតរឿងការលក់ដូរជាដើម សមណៈនេះ ប្រហែលជាគិតតែប្រយោជន៍ខ្លួនតែម្យ៉ាង មានព្រះហឫទ័យជ្រះថ្លា ឡើងកាន់ទីចង្ក្រម ទ្រង់ធ្វើវិតក្កដ៏មាំ ឲ្យចេញទៅឆ្ងាយ យាងទៅប្រថាប់គង់លើផ្ទាំងថ្ម ទ្រង់កើតនូវឯកគ្គតាចិត្ត ចូលទៅកាន់សាលាស្ទឹក ត្រាស់ដឹងបច្ចេកពោធិញ្ញាណ ត្រូវបុរោហិតសាកសួរដល់កម្មដ្ឋាន ដោយន័យមុននោះឯង ទើបគង់ប្រថាប់នៅលើអាកាស ត្រាស់ព្រះគាថានេះ ។

បណ្តាបទទាំងនោះ បទថា **មិគោ** បានដល់ ម្រឹគ ២ ប្រភេទ គឺ ទ្រាយ ១ ប្រើស ១ ។ ម្យ៉ាងទៀត ពាក្យថា **មិគោ** នេះ ជាឈ្មោះរបស់សត្វចតុប្បាទដែលនៅក្នុងព្រៃគ្រប់ប្រភេទ ។ តែក្នុងទីនេះ អាចារ្យមួយពួកបំណងយកប្រើស ។ បទថា **អរញ្ញម្ហិ** សេចក្តីថា វៀរស្រុក និងឧចារៈរបស់ស្រុក ក្រៅអំពីនោះ ចាត់ជាព្រៃ តែក្នុងទីនេះ បំណងយកឧទ្យាន ព្រោះហេតុនោះ ទើបមានន័យថា ក្នុងឧទ្យាន ។ សព្ទថា **យថា** ប្រើក្នុងអត្ថប្រៀបធៀប ។ បទថា **អពទ្ធោ** ប្រែថា មិនត្រូវចងដោយចំណង គឺខ្សែជាដើម ។ ដោយពាក្យនេះ លោកសម្តែងដល់អាកប្បកិរិយា ដែលមិនគួរគួររង្កៀស ។ បទថា **យេនិច្ឆកំ គច្ឆតិ គោចរាយ** សេចក្តីថា ទៅរកចំណីដោយទិសាភាគដែលខ្លួនប្រាថ្នានឹងទៅ សមដូចព្រះមានព្រះភាគត្រាស់ ( ក្នុងខុទ្ទកនិកាយ ចូឡនិទ្ទេស ) ថា

ម្នាលភិក្ខុទាំងឡាយ ដូចម្រឹគដែលនៅក្នុងព្រៃ ត្រាច់ទៅក្នុងព្រៃធំ រមែង

ដើរឥតរង្កៀស ឈរឥតរង្កៀស អង្គុយឥតរង្កៀស ដេកឥតរង្កៀស ដំណើរនោះ ព្រោះហេតុអ្វី ម្នាលភិក្ខុទាំងឡាយ ព្រោះម្រឹគនុ៎ះ មិននៅក្នុងគន្លងរបស់ព្រាន យ៉ាងណាមិញ ម្នាលភិក្ខុទាំងឡាយ ភិក្ខុស្ងាត់ចាកកាមទាំងឡាយ ។បេ។ ហើយចូលបឋមជ្ឈាន ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុនេះតថាគត ហៅថា បានធ្វើមារឲ្យខ្វាក់ សម្លាប់មិនឲ្យមានស្នាមជើង ដល់នូវការមិនឃើញដោយភ្នែកនៃមារដែលមានចិត្តបាប ។ គប្បីធ្វើឲ្យពិស្តារ ។

បទថា **សេរិតំ** បានដល់ ការប្រព្រឹត្ត ការពេញចិត្ត ឬមិនទាក់ទងដោយអ្នកដទៃ លោកអធិប្បាយថា ម្រឹគ មិនត្រូវចងក្នុងព្រៃ រមែងទៅរកចំណីតាមប្រាថ្នា យ៉ាងណា កាលណាហ្ន៎ អាត្មាអញ គប្បីកាត់ចំណង គឺតណ្ហា ត្រាច់ទៅយ៉ាងនោះ ហេតុនោះ វិញ្ញូជន គឺបុគ្គលដែលជាបណ្ឌិតប្រាថ្នាសេរីភាព គប្បីត្រាច់ទៅតែម្នាក់ឯង ដូច្នោះ ។៤៕

## អដ្ឋកថា មិគោអរញ្ញគាថា ចប់

# អដ្ឋកថា

## អាមន្តនាគាថា

គាថាថា **អាមន្តនា ហោតិ** ដូច្នេះជាដើម មានអត្ថុប្បត្តិហេតុដូចម្តេច ។

បានឮថា អមាត្យទាំងឡាយ ចូលទៅគាល់ក្នុងសម័យបម្រើធំ របស់ព្រះបាទពារាណសី បណ្តាអមាត្យទាំងនោះ អមាត្យម្នាក់ក្រាបទូលថា បពិត្រព្រះសម្មតិទេព មានវត្ថុដែលគួរស្តាប់ ក៏ទូលឲ្យទ្រង់យាងទៅក្នុងចំណែកម្ខាង ព្រះរាជាទ្រង់ក្រោកចាកអាសនៈ ហើយយាងទៅ ។ អមាត្យម្នាក់ទៀតក្រាបទូលសូមឲ្យប្រថាប់គង់ក្នុងទីបម្រើធំទៀត ។ អមាត្យម្នាក់ទៀត ទូលសូមឲ្យប្រថាប់គង់លើកដំរី អមាត្យម្នាក់ទៀត ទូលសូមឲ្យប្រថាប់គង់លើខ្នងសេះ អមាត្យម្នាក់ទៀត ទូលសូមឲ្យប្រថាប់គង់ក្នុងរថមាស អមាត្យម្នាក់ទៀតទូលសូមឲ្យប្រថាប់គង់ក្នុងវយានទៅឧទ្យាន ។ ព្រះរាជាចុះអំពីវនោះយាងទៅ ។ អមាត្យម្នាក់ទៀត ទូលសូមឲ្យទ្រង់យាងទៅប្រពាសជនបទ ។ ព្រះរាជាទ្រង់ស្តាប់ពាក្យរបស់អមាត្យនោះ ទើបចុះពីកដំរី ហើយយាងទៅក្នុងចំណែកម្ខាង ។ កាលបើដូច្នោះ ទ្រង់នឿយណាយក្នុងពួកអមាត្យទាំងនោះ ទើបទ្រង់បួសអមាត្យទាំងឡាយ ក៏ចង់បានជាភាពធំក្រៃលែង ។ បណ្តាអមាត្យទាំងនោះ អមាត្យម្នាក់ ទៅក្រាបទូលព្រះរាជាថា បពិត្រមហារាជ សូមទ្រង់ប្រទានជនបទឈ្មោះនោះ ដល់ទូលបង្គំ ព្រះរាជាទ្រង់ត្រាស់នឹងអមាត្យនោះថា បុគ្គលឈ្មោះនោះ បរិភោគ ( គ្រប់គ្រង ) ។ អមាត្យនោះ មិនអើពើនឹងព្រះតម្រាស់របស់ព្រះរាជា ក្រាបទូលថា បពិត្រព្រះអង្គ ទូលបង្គំនឹងទៅដណ្តើមយកជនបទនោះគ្រប់គ្រង ដូច្នេះហើយ ទៅកាន់ជនបទនោះ បង្កនូវ

ជម្លោះ ។ ជនទាំង ២ នាំគ្នាមកកាន់សម្នាក់របស់ព្រះរាជាទៀត ហើយក្រាបទូលទោសនៃគ្នានិងគ្នា ។ ព្រះរាជាទ្រង់ព្រះតម្រិះថា អញមិនអាចឲ្យពួកអមាត្យទាំងនេះត្រេកអរបាន ទ្រង់ឃើញទោសក្នុងសេចក្ដីលោភរបស់អមាត្យទាំងនោះ ទ្រង់ចម្រើនវិបស្សនា បានធ្វើឲ្យជាក់ច្បាស់នូវបច្ចេកពោធិញ្ញាណ ។ ទ្រង់បានពោលឧទាននេះ ដោយន័យដែលមានមកក្នុងកាលមុន ។

អត្ថនៃគាថានោះ មានដូច្នេះថា បុគ្គលតាំងនៅក្នុងកណ្ដាលសម្លាញ់ រមែងមានការហៅរកផ្សេងៗ ដោយន័យជាដើមថា ចូរស្ដាប់រឿងនេះរបស់ខ្ញុំ ចូរឲ្យវត្ថុនេះដល់ខ្ញុំ ទាំងក្នុងសម្រាក ពោល គឺការសម្រាកពេលថ្ងៃ ក្នុងទីឈរ ពោល គឺក្នុងទីបម្រើធំ ក្នុងទីដើរ ពោល គឺការទៅកាន់ឧទ្យាន និងក្នុងទីប្រពាស ពោល គឺការត្រាច់ទៅក្នុងជនបទ ព្រោះហេតុនោះ ទើបខ្ញុំនឿយណាយក្នុងសេចក្ដីនោះ ។ ការគប់រកអរិយជននេះ មានអានិសង្ស មិនមែនតិច ជាសុខដោយចំណែកមួយ កាលបើយ៉ាងនោះ បុគ្គលអាក្រក់ គ្រប់គ្នា ដែលត្រូវលោភៈគ្របសង្កត់ ទើបមិនប្រាថ្នាបព្វជ្ជា ខ្ញុំឃើញការមិនលោភនោះ និងការប្រព្រឹត្តតាមពេញចិត្តរបស់ខ្លួន ព្រោះជាកព្វបុគ្គល ដោយមិនធ្លាក់ក្នុងអំណាចនៃអ្នកដទៃ ផ្ដើមចម្រើនវិបស្សនាហើយ ទើបសម្រេចបច្ចេក-ពោធិញ្ញាណដោយលំដាប់ ។ ពាក្យដ៏សេស មានន័យដូចពោលហើយនោះឯង ។

## អដ្ឋកថា អាមន្តនាគាថា ចប់

# អដ្ឋកថា

## ចិន្តារតិគាថា

គាថាថា **ចិន្តា រតិ** ដូច្នេះជាដើម មានអត្ថុប្បត្តិហេតុដូចម្តេច ។

បានឮថា ក្នុងនគរពារាណសី មានព្រះរាជាព្រះនាមឯកបុត្តកព្រហ្មទត្ត ព្រះរាជាអង្គនោះ មានព្រះរាជឱរសតូចមួយអង្គ ជាទីស្រឡាញ់ពេញព្រះរាជហឫទ័យ ស្មើដោយជីវិត ។ ព្រះរាជាទ្រង់នាំយកព្រះរាជឱរសតូចយាងទៅគ្រប់ឥរិយាបថ ថ្ងៃមួយ ទ្រង់យាងទៅកាន់ព្រះរាជឧទ្យាន ទ្រង់យាងទៅដោយមិននាំព្រះរាជឱរសទៅផង ។ ឯព្រះរាជកុមារ ក៏អស់ព្រះជន្ម ព្រោះព្យាធិដែលកើតឡើងក្នុងថ្ងៃនោះឯង អមាត្យទាំងឡាយប្រឹក្សាគ្នាថា ហទយៈរបស់ព្រះរាជានឹងបែក ព្រោះសេចក្តីស្រឡាញ់ក្នុងព្រះរាជឱរស ទើបមិនក្រាបទូលឲ្យទ្រង់ជ្រាប នាំគ្នាបូជាភ្លើងព្រះរាជកុមារនោះ ។ ព្រះរាជា ទ្រង់ស្រវឹងទឹកចណ្ឌក្នុងព្រះរាជឧទ្យាន មិនបាននឹកដល់ព្រះរាជឱរស ក្នុងថ្ងៃទី ២ ក៏ដូចគ្នា ក្នុងពេលស្រង់ និងក្នុងពេលសោយក៏មិនបានរឭកដល់ ។ តមកព្រះរាជាសោយហើយ ប្រថាប់គង់ ទ្រង់រឭកបាន ទើបត្រាស់ថា ចូរនាំកូនមកឲ្យយើង អមាត្យទាំងឡាយក៏ទូលរឿងនោះដល់ព្រះរាជា ដោយពិធីដ៏សមគួរ ។ លំដាប់នោះ ព្រះរាជាត្រូវសេចក្តីសោកគ្របសង្កត់ ប្រថាប់គង់ទ្រង់ធ្វើទុកក្នុងព្រះហឫទ័យដោយឧបាយយ៉ាងនេះថា កាលធម៌នេះមាន ធម៌នេះក៏មាន ព្រោះធម៌នេះកើត ធម៌នេះក៏កើត ទ្រង់ពិចារណាបដិច្ចសមុប្បាទទាំងអនុលោម និងបដិលោម ដោយលំដាប់យ៉ាងនេះ ទ្រង់ធ្វើឲ្យជាក់ច្បាស់នូវបច្ចេកសម្ពោធិញ្ញាណ ។ ពាក្យដ៏សេស ដូចគ្នាតាមដែលបានពោលហើយ

ក្នុងសំសគ្គគាថានោះឯង វៀរតែពណ៌នាគាថា ។ ឯពណ៌នាគាថា មាន សេចក្តីដូច្នេះ ការលេង ឈ្មោះថា **ខិឌ្ឌា** ។ ការលេងនោះ មាន ២ យ៉ាង គឺលេងផ្លូវកាយ ១ លេងផ្លូវវាចា ១ ។ បណ្តាការលេង ២ យ៉ាងនោះ ការលេងយ៉ាងនេះ គឺលេងដំរីខ្លះ លេងសេះខ្លះ លេងរថខ្លះ លេងធ្នូខ្លះ លេងដាវខ្លះជាដើម ឈ្មោះថា លេងផ្លូវកាយ ។ ការលេងយ៉ាងនេះ គឺការច្រៀង ការពោលកំណាព្យ ការលេងស្គរមាត់ជាដើម ឈ្មោះថា ការលេងផ្លូវវាចា ។ ការត្រេកអរក្នុងកាមគុណ ៥ ឈ្មោះថា **រតិ** ។ បទថា **វិបុលំ** បានដល់ត្រេកអរពេញអត្តភាព រហូតដល់ខួរក្នុងឆ្អឹង ។ ពាក្យដ៏សេស ប្រាកដច្បាស់ហើយ ។ សូម្បីវាចាប្រកបសេចក្តីតាមលំដាប់ ក្នុងគាថានេះ ក៏គប្បីជ្រាបដោយន័យដែលពោលហើយ ក្នុងសំសគ្គគាថានោះឯង ។ រឿងទាំងអស់បន្ទាប់អំពីនេះទៅ ក៏មានន័យដូចគ្នា ៕

## អដ្ឋកថា ខិឌ្ឌារតិគាថា ចប់

# អដ្ឋកថា

## ចាតុទ្ទិសគាថា

គាថាថា **ចាតុទ្ទិសោ** ដូច្នេះជាដើម មានអត្ថុប្បត្តិហេតុដូចម្តេច ។

បានឮថា ក្នុងកាលមុន បច្ចេកពោធិសត្វ ៥ អង្គ បួសក្នុងសាសនារបស់ព្រះមានព្រះភាគកស្សបៈ បំពេញគតបច្ចាគតវត្ត អស់ ២ ម៉ឺនឆ្នាំ ហើយកើតក្នុងទេវលោក ចុតិចាកទេវលោកនោះហើយ បណ្តាបច្ចេកពោធិសត្វទាំងនោះ បច្ចេកពោធិសត្វអង្គធំ បានជាព្រះបាទពារាណសី បច្ចេកពោធិសត្វដ៏សេស បានជាបទេសរាជា ។ ឯព្រះរាជា ៤ អង្គនោះ រៀនកម្មដ្ឋានហើយ ទ្រង់លះរាជសម្បត្តិចេញបួស បានជាព្រះបច្ចេកសម្ពុទ្ធដោយលំដាប់ ហើយនៅត្រង់ញកភ្នំនន្ទមូលកៈ ថ្ងៃមួយ ចេញចាកសមាបត្តិហើយពិចារណាដល់កម្ម និងសម្ភាញ់របស់ខ្លួន ដោយន័យដូចពោលហើយ ក្នុងវិសក្កន្ធគាថា កាលដឹងហើយ ទើបរកឱកាសដើម្បីសម្តែងអារម្មណ៍ដល់ព្រះបាទពារាណសីដោយឧបាយ ។ ព្រះរាជានោះ ស្ដុតព្រះហឫទ័យក្នុងពេលយប់ អស់វារៈ ៣ ដង ទ្រង់ខ្លាច ទើបទ្រង់ស្រែកដោយសំឡេងខ្លាំង ទ្រង់ស្ទុះទៅកាន់ល្វែងធំ កាលត្រូវបុរោហិតដែលក្រោកឡើងអំពីព្រលឹម ក្រាបទូលសួរដល់ការផ្ទុំជាសុខ ទើបត្រាស់ថា លោកអាចារ្យ យើងមានសេចក្តីសុខអំពីណា ហើយទ្រង់ប្រាប់រឿងទាំងអស់នោះ ។ ឯបុរោហិតគិតថា រោគនេះបុគ្គលណាម្នាក់ មិនអាចព្យាបាលដោយភេសជ្ជកម្មណាមួយ មានការដាក់ថ្នាំធ្វើឲ្យក្អួតជាដើម តែឧបាយសម្រាប់បរិភោគកើតឡើងដល់អញហើយ ទើបក្រាបទូលថា បពិត្រមហារាជ នេះជាបុព្វនិមិត្តនៃការវិនាសរាជសម្បត្តិ

និងអន្តរាយនៃព្រះជន្មជាដើម ធ្វើឲ្យព្រះរាជាតក់ស្លុតខ្លាំងឡើង ហើយក្រាបទូលថា ដើម្បីឲ្យបុព្វនិមិត្តនេះស្ងប់ ទ្រង់គប្បីប្រទានដំរី សេះ និងរថជាដើម មានប្រមាណប៉ុណ្ណេះៗ មួយអន្លើដោយប្រាក់ និងមាសឲ្យជាទក្ខិណាបូជាយញ្ញ ហើយឲ្យចាត់ចែងការបូជាយញ្ញ ។

គ្រានោះ ព្រះបច្ចេកសម្ពុទ្ធទាំងឡាយ ឃើញសត្វមានជីវិតច្រើនពាន់ ដែលគេប្រមូលមកដើម្បីជាប្រយោជន៍ដល់យញ្ញ ទើបគិតថា កាលព្រះរាជាធ្វើកម្មនេះ ទ្រង់នឹងជាបុគ្គលដែលបុគ្គលណាម្នាក់ ឲ្យត្រាស់ដឹងបានលំបាកណ្ហើយចុះ យើងទាំងឡាយប្រញាប់ទៅគាល់ព្រះរាជានោះ ទើបនិមន្តមកត្រាច់បិណ្ឌបាត បានទៅកាន់ទីលានព្រះរាជវាំងតាមលំដាប់ ដោយន័យដូចពោលហើយ ក្នុងវិសក្កឡីរគាថា ។ ព្រះរាជាប្រថាប់ឈរត្រង់សីហបញ្ជរទតលានព្រះរាជវាំង បានឃើញព្រះបច្ចេកសម្ពុទ្ធទាំងនោះ ដំណាលគ្នានឹងការឃើញនោះឯង សេចក្តីស្រឡាញ់បានកើតឡើងដល់ព្រះអង្គ ។ គ្រានោះទើបត្រាស់ឲ្យនិមន្តព្រះបច្ចេកសម្ពុទ្ធទាំងនោះមក និមន្តឲ្យគង់លើអាសនៈដែលក្រាលហើយ ក្នុងទីកណ្តាលវាល និមន្តឲ្យឆាន់ដោយគោរព ហើយត្រាស់សួរព្រះបច្ចេកសម្ពុទ្ធដែលធ្វើភត្តកិច្ចស្រេចហើយថា លោកម្ចាស់ទាំងឡាយជានរណា ព្រះបច្ចេកសម្ពុទ្ធឆ្លើយថា បពិត្រមហារាជ ពួកអាត្មា ឈ្មោះចាតុទ្ទិស ។ ព្រះរាជាត្រាស់សួរថា បពិត្រលោកម្ចាស់ ពាក្យថា ចាតុទ្ទិសនេះ មានន័យដូចម្តេច ព្រះបច្ចេកសម្ពុទ្ធឆ្លើយថា បពិត្រមហារាជ ពួកអាត្មា មិនមានការខ្លាច ឬការតក់ស្លុតក្នុងទីណា អំពីទីណាមួយ ក្នុងទិសទាំង ៤

ឡើយ ។ ព្រះរាជាត្រាស់សួរថា បពិត្រលោកម្ចាស់ ព្រោះហេតុអ្វី ទើបការខ្លាចមិនមានដល់លោកម្ចាស់ទាំងឡាយ ។ ព្រះបច្ចេកសម្ពុទ្ធ ថ្វាយព្រះពរថា បពិត្រមហារាជ អាត្មាទាំងឡាយចម្រើនមេត្តា ករុណា មុទិតា ឧបេក្ខា ដោយហេតុនោះ ទើបការខ្លាចនោះមិនមានដល់អាត្មា ដូច្នេះហើយ ក្រោកចាកអាសនៈ ទៅកាន់លំនៅរបស់ខ្លួន ។

លំដាប់នោះ ព្រះរាជាទ្រង់ព្រះតម្រិះថា សមណៈទាំងនេះ នាំគ្នាពោលថា មិនមានការខ្លាច ព្រោះចម្រើនមេត្តាជាដើម តែពួកព្រាហ្មណ៍នាំគ្នាសរសើរការសម្លាប់សត្វច្រើនពាន់ ពាក្យរបស់អ្នកណាហ្ន៎ ជាពាក្យពិត ។ គ្រានោះ ទ្រង់មានព្រះតម្រិះដូច្នេះថា សមណៈទាំងឡាយ លាងរបស់មិនស្អាតដោយរបស់ស្អាត តែព្រាហ្មណ៍លាងរបស់មិនស្អាត ដោយរបស់មិនស្អាត បុគ្គលណាម្នាក់ មិនអាចលាងរបស់មិនស្អាត ដោយរបស់មិនស្អាតបានទេ ពាក្យរបស់បព្វជិតនោះឯង ជាពាក្យពិត ដូច្នេះហើយ ទ្រង់ចម្រើនព្រហ្មវិហារទាំង ៤ មានមេត្តាជាដើម ដោយន័យជាដើមថា សូមសត្វទាំងពួង បាននូវសេចក្តីសុខចុះ ទ្រង់មានព្រះហឫទ័យផ្សាយនូវប្រយោជន៍ ទ្រង់ប្រាប់អមាត្យទាំងឡាយថា ចូរពួកអ្នកលែងសត្វទាំងអស់ សត្វទាំងអស់ ចូរផឹកទឹកត្រជាក់ ស៊ីស្មៅពណ៌ខៀវ ខ្យល់ត្រជាក់ ចូរបក់សត្វទាំងនោះ អមាត្យទាំងនោះ បានធ្វើតាមព្រះរាជបញ្ជាសព្វប្រការ ។

លំដាប់នោះ ព្រះរាជាទ្រង់ព្រះតម្រិះថា អញផុតចាកបាបកម្ម ព្រោះពាក្យរបស់កល្យាណមិត្ត ប្រថាប់គង់ក្នុងទីនោះឯង ចម្រើនវិបស្សនា បានធ្វើ

ឲ្យជាក់ច្បាស់នូវបច្ចេកពោធិញ្ញាណ ក្នុងកាលនោះ ពួកអមាត្យទូលថា បពិត្រមហារាជ សូមទ្រង់សោយចុះ ដល់កាលហើយ ។ ព្រះរាជាត្រាស់ពាក្យទាំងពួងដោយន័យមុននោះឯងថា អាត្មាមិនមែនព្រះរាជា ដូច្នេះជាដើម ហើយបានត្រាស់ឧទានគាថា និងព្យាករគាថានេះ ។

បណ្តាបទទាំងនោះ បទថា **ចាតុទ្ទិសោ** សេចក្តីថា មានប្រក្រតីនៅជាសុខក្នុងទិសទាំង ៤ ។ មួយវិញទៀត ឈ្មោះថា **ចាតុទ្ទិសោ** ព្រោះមានទិសទាំង ៤ ផ្សាយទៅដោយព្រហ្មវិហារភាវនា ដោយន័យជាដើមថា ផ្សាយទៅកាន់ទិស ១ ។ ឈ្មោះថា **អប្បដិឃោ** ព្រោះមិនបៀតបៀនសត្វ ឬសង្ខារក្នុងទីណាមួយ ក្នុងទិសទាំង ៤ នោះ ព្រោះការខ្លាច ។ បទថា **សន្តុស្សមានោ** បានដល់ ជាអ្នកសន្តោសដោយអំណាចសន្តោស ១២ យ៉ាង ។ បទថា **ឥតរីតរេន** បានដល់ ដោយបច្ច័យល្អ និងមិនល្អ ។ ក្នុងបទថា **បរិស្សយានំ សហិតា អឆម្ភី** នេះ មានវិនិច្ឆ័យដូច្នេះ ឈ្មោះថា **បរិស្សយ** ព្រោះបៀតបៀនកាយ និងចិត្ត ឬញុំាងសម្បត្តិនៃកាយ និងចិត្តឲ្យវិនាសទៅជុំវិញ ឬអាស្រ័យកាយ និងចិត្តនោះដេក ។ បទថា **បរិស្សយ** នេះ ជាឈ្មោះនៃឧបទ្ទវន្តរាយផ្លូវកាយ និងចិត្ត ដែលជាខាងក្រៅ មានសីហៈ និងខ្លាធំជាដើម ដែលជាខាងក្នុង មានកាមច្ឆន្ទៈជាដើម ។ ឈ្មោះថា **សហិតា** ព្រោះអត់សង្កត់អន្តរាយទាំងនោះ ដោយអធិវាសនខន្តី និងដោយធម៌ទាំងឡាយ មានវីរិយៈជាដើម ។ ឈ្មោះថា **អឆម្ភី** ព្រោះមិនមានការខ្លាច ដែលធ្វើឲ្យខ្លួនរឹង ។ លោកអធិប្បាយដូចម្តេច លោកអធិប្បាយថា សន្តោសដោយ

បច្ច័យតាមមានតាមបាន ដូចសមណៈ ៤ អង្គនោះ តាំងនៅក្នុងសន្តោស ដែលជាបទដ្ឋាននៃកិច្ចបដិបត្តិនេះ ឈ្មោះថា **ចាតុទ្ទិស** ព្រោះចម្រើនមេត្តា ជាដើមក្នុងទិសទាំង ៤ និងឈ្មោះថា **អប្បដិឃ** ព្រោះមិនមានការភ័យខ្លាច អំពីការបៀតបៀន ក្នុងសត្វ និងសង្ខារទាំងឡាយ ។ បុគ្គលនោះ ឈ្មោះថា **បរិស្សយានំ សហិតា** ព្រោះជាអ្នកនៅតាមសប្បាយក្នុងទិសទាំង ៤ និងឈ្មោះថា **អឆម្ភី** ព្រោះភាពជាអ្នកមិនមានអាក់អន់ ខ្ញុំឃើញគុណនៃកិច្ចបដិបត្តិយ៉ាងនេះ ដោយប្រការដូច្នេះ ទើបបដិបត្តិដោយឧបាយ បានសម្រេចបច្ចេកពោធិញ្ញាណហើយ ។ម្យ៉ាងទៀត លោកអធិប្បាយថា ខ្ញុំដឹងថា បុគ្គលដែលសន្តោសដោយបច្ច័យតាមមានតាមបាន ជាអ្នកនៅតាមសប្បាយក្នុងទិស ៤ ដោយន័យដូចពោលហើយ ដូចសមណៈទាំងនោះ ទើបប្រាថ្នាជាអ្នកនៅតាមសប្បាយក្នុងទិស ៤ យ៉ាងនោះ ។ បដិបត្តិដោយឧបាយទើបបានសម្រេច ព្រោះហេតុនោះ បុគ្គលដទៃ ប្រាថ្នាឋានៈដូច្នេះ គប្បីជាអ្នកគ្របសង្កត់អន្តរាយ ដោយភាពជាអ្នកផ្សាយមេត្តាទៅក្នុងទិស ៤ និងជាអ្នកមិនតក់ស្លុត ដោយភាពជាអ្នកមិនអាក់អន់ ត្រាច់ទៅម្នាក់ឯង ដូចកុយរមាស ។ ពាក្យដ៏សេស មានន័យដូចពោលហើយនោះឯង ។៚

**អដ្ឋកថា ចាតុទ្ទិសគាថា ចប់**

# អដ្ឋកថា

## ឆុស្សន្ទ្ធហាគាថា

គាថាថា **ឆុស្សន្ទ្ធហា** ដូច្នេះជាដើម មានអត្ថុប្បត្តិហេតុដូចម្តេច ។

បានឮថា អគ្គមហេសីរបស់ព្រះបាទពារាណសីសោយព្រះទិវង្គត បន្ទាប់អំពីនោះ កាលថ្ងៃសោយសោកកន្លងទៅហើយ ថ្ងៃមួយ អមាត្យទាំងឡាយទូលអង្វរថា ធម្មតាព្រះរាជាទាំងឡាយ ចាំបាច់ប្រាថ្នាអគ្គមហេសីក្នុងរាជកិច្ចផ្សេងៗ ដោយខានមិនបាន ទូលបង្គំទាំងឡាយសូមឱកាស សូមព្រះសម្មតិទេពទ្រង់នាំព្រះទេវីអង្គដទៃមក ។ ព្រះរាជាត្រាស់ថា នែអ្នក បើដូច្នោះ ចូរអ្នកទាំងឡាយដឹងចុះ ។ ខណៈដែលអមាត្យទាំងនោះកំពុងស្វែងរកព្រះរាជាក្នុងរាជអាណាចក្រជិតខាងសោយទិវង្គត ព្រះទេវីរបស់ព្រះរាជានោះគ្រប់គ្រងរាជសម្បត្តិ និងមានព្រះគភ៌ អមាត្យទាំងឡាយដឹងថា ព្រះទេវីនេះសមគួរដល់ព្រះរាជា ទើបអង្វរព្រះនាង ។ ព្រះនាងត្រាស់ថា ធម្មតាស្រីមានគភ៌ រមែងមិនជាទីគាប់ចិត្តរបស់មនុស្សទាំងឡាយ បើអ្នកបង្អង់ទម្រាំយើងប្រសូត ក៏នឹងល្អ បើរង់ចាំមិនបាន ក៏ចូរពួកអ្នករកស្រីដទៃចុះ ។ អមាត្យទាំងឡាយ ក៏ក្រាបទូលសេចក្តីនោះដល់ព្រះរាជា ។ ព្រះរាជាត្រាស់ថា ទោះបីព្រះនាងមានគភ៌ ក៏ចូរនាំមកចុះ អមាត្យទាំងនោះក៏នាំមក ។ ព្រះរាជាទ្រង់អភិសេកព្រះទេវីនោះហើយ បានប្រទានគ្រឿងប្រើប្រាស់សម្រាប់ព្រះមហេសីសព្វយ៉ាង ទ្រង់សង្គ្រោះព្រះនាង និងបរិវារជន ដោយគ្រឿងបណ្ណាការគ្រប់ប្រភេទ ។ ព្រះមហេសីនោះ ប្រសូតព្រះឱរសតាមកាល ព្រះរាជាទ្រង់បី-ពព្រះរាជឱរសរបស់ព្រះនាងនោះ លើភ្លៅ និងដើមទ្រូង ក្នុងឥរិយាបថទាំងពួង

ដូចឱរសរបស់ព្រះអង្គ ។ កាលនោះ បរិវារជនរបស់ព្រះទេវីនោះ នាំគ្នាគិតថា ព្រះរាជាទ្រង់សង្គ្រោះយ៉ាងក្រៃលែង ទ្រង់ធ្វើនូវការស្និទ្ធស្នាលបំផុតក្នុងព្រះរាជកុមារ ណ្ហើយចុះ ពួកយើងនឹងញុះញង់ព្រះរាជកុមារនោះឲ្យបែកអំពីព្រះអង្គ ។

បន្ទាប់អំពីនោះ ក៏នាំគ្នាទូលព្រះរាជកុមារថា បពិត្រអយ្យបុត្ត ទ្រង់ជាឱរសនៃព្រះរាជារបស់ទូលបង្គំទាំងឡាយ មិនមែនជាព្រះរាជឱរសរបស់ព្រះរាជាអង្គនេះ ទ្រង់កុំទុកព្រះហឫទ័យក្នុងព្រះរាជាអង្គនេះ ។ ពេលនោះ ព្រះរាជកុមារ កាលព្រះរាជាត្រាស់ថា មកបុត្ត ដូច្នេះក្តី យកព្រះហស្តទាញមកក្តី ក៏មិនឱបព្រះរាជាដូចកាលមុន ព្រះរាជាទ្រង់ពិចារណាថា ហេតុអ្វី ទ្រង់ក៏ជ្រាបរឿងនោះ ទ្រង់នឿយណាយថា មនុស្សទាំងនេះ ទោះបីអញសង្គ្រោះក៏នៅតែប្រព្រឹត្តិបរិតនោះឯង ទើបទ្រង់លះរាជសម្បត្តិចេញបួស ។ ឯអមាត្យនិងបរិវារជនទាំងឡាយជ្រាបថា ព្រះរាជាទ្រង់ព្រះផ្នួស ក៏នាំគ្នាបួសជាច្រើន ។ ព្រះរាជា មួយអន្លើនឹងបរិវារជនសូម្បីបួសហើយ មនុស្សទាំងឡាយ ក៏នៅតែនាំបច្ច័យប្រណីតទៅប្រគេន ។ ព្រះរាជាទ្រង់ឲ្យបច្ច័យដ៏ប្រណីតតាមលំដាប់មនុស្សដល់បុគ្គលដែលចាស់ជាង ។ បណ្តាជនទាំងនោះ មនុស្សដែលបានរបស់ល្អ ក៏នាំគ្នាត្រេកអរ មនុស្សដែលបានរបស់មិនល្អ ក៏នាំគ្នាពោលថា ពួកយើងបោសបរិវេណជាដើម ធ្វើកិច្ចទាំងពួង ក៏បានកត្តាហារសៅហ្មង និងសំពត់ចាស់ ។ ព្រះរាជាទ្រង់ជ្រាបដូច្នោះ ទើបទ្រង់ព្រះតម្រិះថា ជនទាំងនេះសូម្បីអញឲ្យតាមលំដាប់បុគ្គលដែលជាថេរៈ ក៏គង់ពោលទោស ឱ! បរិស័ទ

*សង្គ្រោះបានលំបាកហ្ន៎ ទើបទ្រទ្រង់កាន់បាត្រ និងចីវរ មួយអន្លងឯង ចូលកាន់ព្រៃ ផ្តើមចម្រើនវិបស្សនា បានធ្វើឲ្យជាក់ច្បាស់នូវបច្ចេកពោធិញ្ញាណ ។ ត្រូវជនដែលមកក្នុងទីនោះសួរដល់កម្មដ្ឋាន ទើបត្រាស់គាថានេះ ។ គាថានោះដោយអត្ថប្រាកដច្បាស់ហើយ តែមានពាក្យអធិប្បាយប្រកបដូច្នេះថា សូម្បីបព្វជិតពួកខ្លះ ដែលត្រូវអសន្តោសគ្របសង្កត់ ក៏សង្គ្រោះបានដោយក្រម្យ៉ាងទៀត គ្រហស្ថអ្នកគ្រប់គ្រងផ្ទះ ក៏យ៉ាងនោះដូចគ្នា ខ្ញុំស្អប់ខ្ពើមភាពជាអ្នកសង្គ្រោះលំបាកនេះ ទើបផ្តើមចម្រើនវិបស្សនា បានសម្រេចហើយ ។ ពាក្យដ៏សេស គប្បីជ្រាបដោយន័យមុននោះឯង ៕*

**អដ្ឋកថា ទុស្សង្គហគាថា ចប់**

# អដ្ឋកថា

## កោវិឡារគាថា

គាថាថា **ឱរោបយិត្វា** ដូច្នេះជាដើម មានអត្ថុប្បត្តិហេតុដូចម្តេច ។

បានឮថា ក្នុងនគរពារាណសី មានព្រះរាជា ព្រះនាមចាតុមាសិក-ព្រហ្មទត្ត យាងទៅព្រះរាជឧទ្យាន ក្នុងខែដំបូងនៃគិម្ហន្តរដូវ ទ្រង់ឃើញដើមរលួសផ្អុង ពេញទៅដោយស្លឹកពណ៌ខៀវ និងក្រាស់ ក្នុងភូមិភាគដែលគួរជាទីត្រេកអរ ក្នុងព្រះរាជឧទ្យាននោះ ទើបត្រាស់ថា ចូរក្រាលទីបន្ទំដល់យើងត្រង់គល់រលួសផ្អុង ហើយទ្រង់ក្រសាលក្នុងព្រះរាជឧទ្យាន ពេលល្ងាចទ្រង់សម្រេចការផ្ទំទៀបគល់រលួសផ្អុងនោះ ។

ក្នុងខែកណ្តាលនៃគិម្ហន្តរដូវ បានយាងទៅកាន់ព្រះរាជឧទ្យាននោះទៀត ក្នុងកាលនោះ ដើមរលួសផ្អុងកំពុងចេញផ្កា ក្នុងកាលនោះ ទ្រង់ក៏ធ្វើយ៉ាងនោះដូចគ្នា ។ ក្នុងខែខាងចុងគិម្ហន្តរដូវបានយាងទៅម្តងទៀត ក្នុងកាលនោះ ដើមរលួសផ្អុងក៏ជ្រុះស្លឹក ដូចជាដើមឈើងាប់ ។ ក្នុងកាលនោះ ព្រះរាជាទ្រង់មិនទាន់មើលដើមឈើនោះ ដ្បិតធ្លាប់ស្និទ្ធស្នាលក្នុងកាលមុន ទើបត្រាស់ឲ្យក្រាលកម្រាលដែលជាទីបន្ទំ ត្រង់គល់រលួសផ្អុងនោះទៀត ។ អមាត្យទាំងឡាយទោះបីដឹង ក៏ក្រាលទីបន្ទំត្រង់គល់រលួសផ្អុងនោះ តាមពាក្យរបស់ព្រះរាជា ។ ទ្រង់ក្រសាលក្នុងព្រះរាជឧទ្យាន លុះពេលល្ងាច កាលផ្ទំក្នុងទីនោះ ទ្រង់ឃើញដើមឈើនោះ ទើបទ្រង់ព្រះតម្រិះថា អាក្រក់ពិតហ្ន៎ ដើមឈើនេះ កាលមុនពេញដោយស្លឹក ជាដើមឈើស្អាត គួរមើល ដូចសម្រេចដោយកែវមណី បន្ទាប់អំពីនោះ មានសម្រស់គួរមើល ដោយផ្កាទាំងឡាយ

ដូចគ្នានឹងពន្លកកែវប្រពាល ដែលដាក់ក្នុងវាំងមែក មានពណ៌ក្រហមដូចកែវមណី និងភូមិភាគខាងក្រោមដើមឈើនេះ ក៏ក្រាលដោយដីខ្សាច់ ដូចគ្នានឹងបណ្ដាញកែវមុក្តា ដេរដាសដោយផ្កាដែលជ្រុះចាកទង ដូចជាក្រាលដោយសំពត់កម្ពលក្រហម ថ្ងៃនេះ ដើមឈើនេះ ដូចដើមឈើងាប់ សល់ត្រឹមតែមែក ហើយនឹងដើម ឱ ! ដើមរលួសផ្អុង ក៏ត្រូវជរាប្រទូស្តហើយ ទ្រង់បានចំពោះនូវអនិច្ចសញ្ញាថា វត្ថុដែលមិនមានវិញ្ញាណគ្រប់គ្រង ក៏គង់ជរាបៀតបៀន នឹងពោលថ្វីដោយវត្ថុដែលមានវិញ្ញាណ ទ្រង់ឃើញច្បាស់នូវសង្ខារទាំងពួងដោយភាពជាទុក្ខ និងដោយភាពជាអនត្តា ដោយទំនងដូចគ្នា ទ្រង់ប្រាថ្នាថា ឱហ្ន៎ ! អាត្មាអញ ក៏គប្បីជាអ្នកប្រាសចាកគ្រឿងសម្គាល់របស់គ្រហស្ថ ដូចដើមរលួសផ្អុងជ្រុះស្លឹក ដូច្នោះ ទ្រង់ផ្ចំដោយបង្អៀងស្ដាំត្រង់ទីបន្ទំនោះដោយលំដាប់ ចម្រើនវិបស្សនា ទ្រង់ធ្វើឲ្យជាក់ច្បាស់នូវបច្ចេកពោធិញ្ញាណហើយ ។ ក្នុងពេលយាងចេញអំពីទីនោះ កាលពួកអមាត្យក្រាបទូលថា បពិត្រព្រះសម្មតិទេព ដល់កាលយាងត្រឡប់ហើយ ទើបត្រាស់ពាក្យជាដើមថា យើងមិនមែនព្រះរាជា ហើយត្រាស់គាថានេះ ដោយន័យមុននោះឯង ។

បណ្ដាបទទាំងនោះ បទថា **ឱរោបយិត្វា** បានដល់ នាំចេញទៅ ។ បទថា **គិហិព្យញ្ជនានិ** បានដល់ សក់ ពុកមាត់ សំពត់ស គ្រឿងប្រដាប់ផ្កា គ្រឿងក្រអូប គ្រឿងលាប បុត្ត ភរិយា ទាសី និងទាសៈជាដើម វត្ថុទាំងនេះធ្វើឲ្យភាពជាគ្រហស្ថប្រាកដ ព្រោះហេតុនោះ ទើបហៅថា **គិហិ-**

**ព្យញ្ជនានិ** ។ *បទថា* **សញ្ឆិន្នបត្តោ** *ប្រែថា មានស្លឹកជ្រុះទៅហើយ ។ បទថា* **ឆេត្វាន** *បានដល់ កាត់ដោយមគ្គញ្ញាណ ។ បទថា* **វីរោ** *បានដល់ ប្រកបដោយសេចក្តីព្យាយាមក្នុងមគ្គ ។ បទថា* **គិហិព្យញ្ជនានិ** *បានដល់ គ្រឿងចង គឺកាម ។ ពិតហើយ កាមទាំងឡាយ ជាគ្រឿងចងរបស់គ្រហស្ថ អត្ថនៃបទ មានត្រឹមប៉ុណ្ណេះសិន ។ ឯពាក្យអធិប្បាយមានដូច្នេះ ព្រះរាជាទ្រង់ព្រះតម្រិះយ៉ាងនេះថា ឱហ្ន៎ ! សូម្បីអញ ក៏គប្បីដាក់នូវគ្រឿងសម្គាល់របស់គ្រហស្ថ គប្បីដូចដើមរលួសផ្អុងដែលជ្រុះស្លឹក ដូច្នោះ ទ្រង់ចម្រើនវិបស្សនាបានសម្រេច ។ ពាក្យដ៏សេស គប្បីជ្រាបដោយន័យដែលពោលមុននោះឯង ។*

**អដ្ឋកថា កោវិឡារគាថា ចប់**

# អដ្ឋកថា

## សហាយគាថា

គាថាថា **សចេ លភេថ** ដូច្នេះជាដើម មានអត្ថុប្បត្តិហេតុដូចម្ដេច ។

បានឮថា ក្នុងកាលមុន បច្ចេកពោធិសត្វ ២ អង្គ បួសក្នុងសាសនារបស់ព្រះមានព្រះភាគ ព្រះនាមកស្សបៈ បំពេញគតបច្ចាគតវត្តអស់ ២ ម៉ឺនឆ្នាំ កើតឡើងក្នុងទេវលោក ។ ចុតិអំពីទេវលោកនោះហើយ បណ្ដាបច្ចេកពោធិសត្វទាំងនោះ បច្ចេកពោធិសត្វអង្គធំ បានជាឱរសរបស់ព្រះបាទពារាណសី បច្ចេកពោធិសត្វអង្គតូច បានជាបុត្តរបស់បុរោហិត ។ បច្ចេកពោធិសត្វទាំង ២ នោះ បដិសន្ធិក្នុងថ្ងៃតែមួយ ចេញអំពីឧទរមាតាក្នុងថ្ងៃតែមួយ បានជាសម្លាញ់លេងដីជាមួយគ្នា ។ កូនបុរោហិតជាអ្នកមានបញ្ញា ក្រាបទូលព្រះរាជបុត្តថា បពិត្រសម្លាញ់ អំណឹះឥតអំពីព្រះរាជបិតាទៅ ទ្រង់នឹងបានរាជសម្បត្តិ ឯខ្ញុំនឹងបានតំណែងបុរោហិត បុគ្គលសិក្សាល្អហើយ ទើបអាចគ្រប់គ្រងរាជសម្បត្តិបាន មកពួកយើងនឹងរៀនសិល្បសាស្ត្រ ។ បន្ទាប់អំពីនោះ ជនទាំង ២ ពាក់អំបោះ ទ្រង់ក្លែងភេទជាព្រាហ្មណ៍ ត្រាច់បិណ្ឌបាតទៅក្នុងគាម និងនិគមជាដើម ដល់បច្ចន្តជនបទ ។ ព្រះបច្ចេកពុទ្ធ ៥ អង្គចូលទៅកាន់ស្រុកនោះ ក្នុងពេលភិក្ខាចារ ជនទាំងឡាយក្នុងស្រុកនោះ ឃើញព្រះបច្ចេកសម្ពុទ្ធទាំងឡាយហើយ កើតនូវឧស្សាហ៍ នាំគ្នាក្រាលអាសនៈបង្អោនរបស់ទំពា និងរបស់បរិភោគដ៏ប្រណីតចូលទៅបូជា ។ ជនទាំង ២ នោះគិតដូច្នេះថា ឈ្មោះថា បុគ្គលមានត្រកូលខ្ពស់ដូចពួកយើង មិនមានម្យ៉ាងទៀត ជនទាំងនេះ បើត្រូវការក៏នឹងឲ្យភិក្ខាដល់ពួកយើង បើមិនត្រូវការ

ក៏មិនឲ្យ គេធ្វើសក្ការៈបែបនេះ ដល់បព្វជិតទាំងនេះ បព្វជិតទាំងនេះ រមែងចេះសិប្បសាស្ត្រណាមួយពិត ណ្ហើយចុះ ពួកយើងនឹងរៀនសិល្បសាស្ត្រក្នុងសម្នាក់នៃបព្វជិតទាំងនេះ កាលពួកមនុស្សត្រឡប់ទៅហើយ ជនទាំង ២ នោះបានឱកាស ទើបពោលអង្វរថា លោកដ៏ចម្រើន សូមលោកទាំងឡាយឲ្យពួកខ្ញុំសិក្សាសិល្បសាស្ត្រ ដែលលោកទាំងឡាយចេះមកផងចុះ ។ ព្រះបច្ចេកសម្ពុទ្ធទាំងឡាយពោលថា ពួកអាត្មាមិនអាចឲ្យមនុស្សដែលមិនបានបួសសិក្សា ។ ជនទាំង ២ នោះ ក៏សូមបួសហើយ ។ លំដាប់នោះ ព្រះបច្ចេកសម្ពុទ្ធទាំងឡាយ ក៏ប្រាប់អភិសមាចារិកវត្តដល់ជនទាំង ២ ដោយន័យជាដើមថា អ្នកទាំងឡាយ គប្បីស្លៀកយ៉ាងនេះ គប្បីដណ្តប់យ៉ាងនេះ ហើយពោលថា សេចក្តីត្រេកអរក្នុងភាពជាបុគ្គលម្នាក់ឯង ជាការសម្រេចនៃសិល្បសាស្ត្រនេះ ព្រោះហេតុនោះ គប្បីអង្គុយម្នាក់ឯង គប្បីចង្រ្កមម្នាក់ឯង គប្បីឈរម្នាក់ឯង គប្បីដេកម្នាក់ឯង ហើយប្រគល់បណ្ណសាលាឲ្យម្នាក់មួយ ។ បន្ទាប់អំពីនោះ បព្វជិតទាំង ២ នោះ ក៏ចូលទៅកាន់បណ្ណសាលារៀងៗ ខ្លួនហើយអង្គុយ ។ បុត្តបុរោហិតបាននូវឯកគ្គតាចិត្ត បានឈានតាំងអំពីពេលដែលអង្គុយ ។ មួយសន្ទុះ ព្រះរាជបុត្តអផ្សុក ទើបមកកាន់សម្នាក់របស់កូនបុរោហិត ។ កូនបុរោហិតនោះឃើញដូច្នោះ ទើបសួរថា អ្វីសម្លាញ់ ព្រះរាជបុត្តពោលថា ខ្ញុំអផ្សុក ។ កូនបុរោហិតពោលថា បើដូច្នោះ សូមទ្រង់គង់ទីនេះ ។ ព្រះរាជបុត្តនោះគង់ក្នុងទីនោះ បានមួយស្របក់ ក៏ពោលថា នៃសម្លាញ់ បានឮថា ការត្រេកអរក្នុងភាពជាបុគ្គលម្នាក់ឯង ជាការសម្រេចនៃ

សិល្បសាស្ត្រនេះ មិនមែនឬ ។ កូនបុរោហិតពោលថា យ៉ាងនោះឯងសម្លាញ់ បើដូច្នោះ សូមទ្រង់ទៅកាន់ទីអន្ទ្ធិយរបស់ទ្រង់នោះឯង យើងនឹងរៀនសិល្បសាស្ត្រនេះឲ្យសម្រេច ។ ព្រះរាជបុត្តនោះក៏យាងទៅ មួយអន្ទាំស្វាប៉ុណ្ណោះ ក៏កើតអផ្សុកទៀត ត្រឡប់មកដោយន័យមុននោះឯង អស់វារៈ ៣ ដង ។

លំដាប់នោះ កូនបុរោហិតក៏បញ្ជូនព្រះរាជបុត្តនោះទៅដូចមុន កាលរាជបុត្តនោះទៅហើយ ក៏គិតថា រាជបុត្តនេះ ធ្វើកម្មរបស់ខ្លួន និងកម្មរបស់អញឲ្យវិនាស មកក្នុងទីនេះរឿយៗ ។ កូនបុរោហិតនោះ ក៏ចេញអំពីបណ្ណសាលា ចូលក្នុងព្រៃ ។ ឯរាជបុត្តអង្គុយក្នុងបណ្ណសាលានោះឯង មួយសម្មុះក៏អផ្សុក ទើបមកកាន់សម្នាក់របស់កូនបុរោហិត រកដោយជុំវិញ ក៏មិនឃើញកូនបុរោហិតនោះ ទើបគិតថា បុគ្គលណាក្នុងគ្រាជាគ្រហស្ថ នាំគ្រឿងបណ្ណាការមករក ក៏មិនបានជួបអញ ឥឡូវនេះ បុគ្គលនោះ កាលអញមករក ក៏មិនចង់ជួប លបចៀសចេញទៅ ឱ ! ចិត្តអាក្រក់ ឯងមិនមានខ្មាស ឲ្យអញមកទីនេះអស់វារៈ ៤ ដង ឥឡូវនេះ អញនឹងមិនធ្លាក់ក្នុងអំណាចរបស់ឯងដោយពិត អញនឹងឲ្យឯងនោះឯង ប្រព្រឹត្តទៅក្នុងអំណាចរបស់អញ ដូច្នេះហើយ ចូលទៅកាន់សេនាសនៈរបស់ខ្លួន ចម្រើនវិបស្សនា ធ្វើឲ្យជាក់ច្បាស់នូវបច្ចេកពោធិញ្ញាណ ហើយទៅកាន់ញកភ្នំនន្ទមូលកៈ តាមអាកាស ។ ឯកូនបុរោហិត ចូលព្រៃហើយ ផ្តើមវិបស្សនា ធ្វើឲ្យជាក់ច្បាស់នូវបច្ចេកពោធិញ្ញាណហើយ បានទៅទីនោះដូចគ្នា ព្រះបច្ចេកសម្ពុទ្ធទាំង ២ នោះ គង់លើផ្ទាំងមនោសិលា បានពោលឧទានគាថាទាំងនេះ មួយអង្គមួយគាថា ។

បណ្ដាបទទាំងនោះ បទថា **និបកំ** បានដល់ ជាអ្នកមានបញ្ញារក្សាខ្លួនតាមប្រក្រតី គឺជាបណ្ឌិត បានដល់ ជាអ្នកឈ្លាសក្នុងការបរិកម្មកសិណជាដើម ។ បទថា **សាធុវិហារី** បានដល់ ប្រកបដោយវិហារធម៌ដ៏នឹងធឹង ឬដោយវិហារធម៌យ៉ាងស៊ប់ ។ បទថា **ធីរំ** គឺជាអ្នកបរិបូណ៌ដោយបញ្ញាជាគ្រឿងទ្រទ្រង់ចាំ ក្នុងសេចក្ដីនោះ លោកពោលសំដៅដល់ធិតិសម្បទា ការដល់ព្រមដោយបញ្ញាជាគ្រឿងទ្រទ្រង់ចាំ ដោយភាពជាអ្នកមានបញ្ញារក្សាខ្លួន ។ តែក្នុងទីនេះ សំដៅសេចក្ដីថា ជាអ្នកបរិបូណ៌ដោយធិតិប៉ុណ្ណោះ ។ ការព្យាយាមមិនធូរថយ ឈ្មោះថា **ធិតិ** ។ ពាក្យនេះ ជាឈ្មោះនៃសេចក្ដីព្យាយាមដែលប្រព្រឹត្តទៅយ៉ាងនេះថា **កាមំ តចោ ច ន្ហារុ ច** សូមឲ្យស្បែកសរសៃ ... ជាដើម ។ ម្យ៉ាងទៀត ឈ្មោះថា **ធីរ** ព្រោះខ្ពើមរអើមនូវបាបដូច្នេះក៏មាន ។ បទថា **រាជាវ រដ្ឋំ វិជិតំ បហាយ** សេចក្ដីថា គប្បីលះនូវសម្លាញ់ដែលជាបុគ្គលពាល ត្រាច់ទៅម្នាក់ឯង ដូចព្រះរាជាតាមប្រក្រតីទ្រង់ដឹងថា ដែនដែលអញឈ្នះហើយ នាំសេចក្ដីវិនាសមកឲ្យ ទើបលះរាជសម្បត្តិ ត្រាច់ទៅមួយអង្គឯង ដូច្នោះ ។ ម្យ៉ាងទៀត បទថា **រាជាវ រដ្ឋំ** នោះ មានសេចក្ដីដូចតទៅនេះថា ជាបុគ្គលម្នាក់ឯងត្រាច់ទៅ ដូចព្រះបាទសុត្តសោមទ្រង់លះនូវដែនដែលឈ្នះហើយ ត្រាច់ទៅមួយអង្គឯង និងដូចព្រះមហាជនក ដូច្នោះ ពាក្យដ៏សេស អាចដឹងតាមគន្លងដែលពោលហើយ ព្រោះហេតុនោះ ទើបមិនចាំបាច់ពោលឲ្យពិស្ដារ ដូច្នេះឯង ។

**អដ្ឋកថាសហាយគាថា ចប់**

# អដ្ឋកថា

## អន្ធាបសំសាគាថា

គាថាថា **អន្ធា បសំសាម** ដូច្នេះជាដើម មានអត្ថុប្បត្តិហេតុដូចគ្នានឹងអត្ថុប្បត្តិហេតុរបស់ **ចាតុទ្ទិសគាថា** ទៅទល់គ្នានឹងព្រះបច្ចេកសម្ពុទ្ធទាំងឡាយអង្គុយលើអាសនៈ ដែលក្រាលក្នុងទីវាល ។ ឯសេចក្តីប្លែកគ្នា មានដូចតទៅ

ព្រះរាជាអង្គនេះមិនតក់ស្លុត ដូចព្រះរាជាអង្គនោះ ដែលតក់ស្លុតក្នុងវេលាយប់អស់វារៈ ៣ ដង ។ ព្រះរាជាអង្គនេះទ្រង់មិនបានត្រៀមការបូជាយញ្ញ ទ្រង់និមន្តឲ្យព្រះបច្ចេកសម្ពុទ្ធទាំងឡាយ អង្គុយលើអាសនៈដែលគេក្រាលក្នុងទីវាល រួចត្រាស់ថា លោកម្ចាស់ទាំងឡាយជានរណា ព្រះបច្ចេក-សម្ពុទ្ធទាំងឡាយទូលថា មហាបពិត្រ ពួកអាត្មាឈ្មោះអនវជ្ជភោជី ។ ព្រះរាជាត្រាស់សួរថា លោកដ៏ចម្រើន ពាក្យថា **អនវជ្ជភោជី** នេះ មានសេចក្តីដូចម្តេច ព្រះបច្ចេកសម្ពុទ្ធទាំងឡាយទូលថា បពិត្រមហារាជ ពួកអាត្មាបានរបស់ល្អ ឬមិនល្អ ក៏ឆាន់បាន ដោយមិនសម្តែងអាការខុសប្រក្រតី ។ ព្រះរាជាបានស្តាប់ដូច្នោះ ទើបមានព្រះតម្រិះដូច្នេះថា បើដូច្នោះ អញគួរពិសោធមើលលោកម្ចាស់ទាំងនេះ ជាបុគ្គលដូច្នេះ ឬមិនមែន ។ ថ្ងៃនោះ ទ្រង់ក៏អង្គាសដោយបាយចុងអង្ករ មានទឹកជ្រក់ជាគម្រប់ ២ ព្រះបច្ចេកសម្ពុទ្ធទាំងឡាយ មិនមានអាកាសខុសប្លែក ឆាន់បាយចុងអង្ករនោះដូចអមតភោជន ។ ព្រះរាជាទ្រង់ព្រះតម្រិះថា លោកទាំងនេះ ជាអ្នកមិនមានអាការខុសប្រក្រតី ក្នុងមួយថ្ងៃ ព្រោះបដិជ្ញាហើយ ស្អែកនេះ អញនឹងដឹង

ទើបនិមន្តដើម្បីឆាន់ក្នុងថ្ងៃស្អែក ។ ក្នុងថ្ងៃទី ២ ក៏ទ្រង់ធ្វើយ៉ាងនោះ ។ ព្រះបច្ចេកពុទ្ធទាំងនោះក៏ឆាន់យ៉ាងនោះ ។

លំដាប់នោះ ព្រះរាជាទ្រង់ព្រះតម្រិះថា អញនឹងថ្វាយរបស់ល្អសាកមើល ទើបនិមន្តទៀត ទ្រង់ធ្វើមហាសក្ការៈអស់ ២ ថ្ងៃ ទ្រង់អង្គាសដោយរបស់ទំពា របស់ឆាន់ដ៏ប្រណីតក្រៃលែង ។ ព្រះបច្ចេកសម្ពុទ្ធទាំងនោះក៏មិនសម្តែងអាការខុសប្រក្រតីឆាន់យ៉ាងនោះឯង ពោលមង្គលដល់ព្រះរាជាហើយក៏ចៀសចេញទៅ ។ កាលព្រះបច្ចេកសម្ពុទ្ធទាំងនោះ ចៀសចេញទៅមិនយូរប៉ុន្មាន ព្រះរាជាទ្រង់ព្រះតម្រិះថា លោកទាំងនេះ ជាអនវជ្ជភោជី ឱហ្ន៎ ! សូម្បីអាត្មាអញ ក៏គួរជាអនវជ្ជភោជីដែរ ទើបលះរាជសម្បត្តិធំ កាន់យកភេទបព្វជា ចម្រើនវិបស្សនាហើយ បានជាព្រះបច្ចេកសម្ពុទ្ធ កាលចង្អុលបង្ហាញអារម្មណ៍របស់ខ្លួន ក្នុងកណ្តាលព្រះបច្ចេកសម្ពុទ្ធទាំងឡាយ ត្រង់គល់មញ្ជូសកៈ បានពោលគាថានេះ ។ គាថានោះ ដោយអត្ថជាក់ច្បាស់ហើយ តែក្នុងបទថា **សហាយសម្បទំ** នេះ គប្បីជ្រាបថា សម្លាញ់ដែលដល់ព្រមដោយសីលក្ខន្ធជាដើម ដែលជាអសេក្ខៈប៉ុណ្ណោះ ទើបចាត់ជាសហាយ-សម្បទា ។

ឯពាក្យប្រកបសេចក្តីក្នុងបទថា **សហាយសម្បទំ** នេះ មានដូចតទៅនេះ ខ្ញុំសរសើរសហាយសម្បទា ដែលពោលហើយនោះដោយពិតអធិប្បាយថា ខ្ញុំសរសើរដោយចំណែកមួយ សរសើរដូចម្តេច សរសើរថាគួរគប់រកសម្លាញ់ ដែលមានគុណប្រសើរជាងខ្លួន ឬសម្លាញ់មានគុណស្មើ

នឹងខ្លួន ។ ព្រោះហេតុអ្វី ព្រោះកាលបុគ្គលគប់រកបុគ្គលដែលប្រសើរជាង ដោយគុណ មានសីលជាដើមរបស់ខ្លួន ធម៌ទាំងឡាយ មានសីលជាដើម ដែលមិនទាន់កើត រមែងកើតឡើង និងដែលកើតហើយ រមែងដល់នូវសេចក្តី ចម្រើនដុះដាលបរិបូណ៌ ។ កាលគប់រកបុគ្គលដែលស្មើ ធម៌ដែលបានហើយ ក៏មិនវិនាស ព្រោះស្មើគ្នានិងគ្នា និងព្រោះបន្ទោបង់នូវការក្តៅក្រហាយចិត្តបាន កុលបុត្តដែលប្រាថ្នាប្រយោជន៍ បើមិនបាននូវសម្លាញ់ដែលប្រសើរជាង និង ស្មើគ្នាទាំងនោះ គប្បីលះមិច្ឆាជីវៈ មានការបោកបញ្ឆោតជាដើម បរិភោគ ភោជនដែលកើតឡើងដោយធម៌ ដោយស្មើ នឹងមិនធ្វើសេចក្តីត្រេកអរ មិន ត្រេកអរឲ្យកើតឡើងក្នុងភោជននោះ ជាអ្នកមានប្រក្រតីបរិភោគ ដោយមិន មានទោស ត្រាច់ទៅតែម្នាក់ឯង ដូចកុយរមាស ដូច្នោះ ខ្ញុំប្រព្រឹត្តយ៉ាងនេះ ទើបបានសម្រេចសម្បត្តិនេះ ។ ១៣ ។

## អដ្ឋកថា អគ្គាបសំសាគាថា ចប់

# អដ្ឋកថា

## សុវណ្ណវលយគាថា

គាថាថា **ធិស្វា សុវណ្ណស្ស** ដូច្នេះជាដើម មានអត្ថុប្បត្តិហេតុដូចម្ដេច ។

បានឮថា ព្រះរាជាក្នុងនគរពារាណសីមួយអង្គ បានយាងចូលព្រះបន្ទំ ពេលថ្ងៃក្នុងរដូវក្ដៅ នាងវណ្ណទាសីក្នុងសម្នាក់របស់ព្រះរាជានោះ កំពុងបុកខ្លឹមចន្ទន៍ក្រហម ត្រង់ដៃម្ខាងរបស់នាងវណ្ណទាសីនោះ មានកងដៃមាស ១ ត្រង់ដៃម្ខាងទៀតមាន ២ ។ កងមាស ២ នោះទង្គិចគ្នា កងមាស ១ ក្រៅអំពីនោះមិនប៉ះជាមួយអ្វីឡើយ ។ ព្រះរាជាទ្រង់ឃើញដូច្នោះ ទើបទ្រង់ព្រះតម្រិះថា ព្រោះការនៅជាគណៈយ៉ាងនេះឯង ទើបមានការប៉ះទង្គិចគ្នា ព្រោះការនៅម្នាក់ឯង ទើបមិនមានការប៉ះទង្គិចគ្នា ហើយទតមើលនាងទាសីរឿយៗ ។ សម័យនោះ ព្រះទេវីប្រដាប់ដោយគ្រឿងអលង្ការសព្វយ៉ាង ឈរបក់ផ្លិត ព្រះទេវីនោះមានព្រះតម្រិះថា ព្រះរាជាប្រហែលជាមានព្រះហឫទ័យប្រតិព័ទ្ធនាងវណ្ណទាសី ទើបឲ្យនាងវណ្ណទាសីក្រោកឡើង ហើយបុកខ្លឹមចន្ទន៍ដោយខ្លួនឯង កាលនោះ ត្រង់ព្រះពាហាទាំង ២ របស់ព្រះនាង មានកងដៃមាសជាច្រើន កងមាសទាំងនោះ ក៏ប៉ះទង្គិចគ្នា ធ្វើឲ្យកើតសំឡេងខ្លាំង ។ ព្រះរាជាកាលទ្រង់នឿយណាយខ្លាំងឡើង ទើបទ្រង់ផ្ទំដោយព្រះបង្អៀងស្ដាំនោះឯង ទ្រង់ចម្រើនវិបស្សនាហើយ ធ្វើឲ្យជាក់ច្បាស់នូវបច្ចេកពោធិញ្ញាណ ។ ព្រះទេវីកាន់ខ្លឹមចន្ទន៍ចូលទៅរកព្រះរាជានោះ ដែលផ្ទំដោយសុខដ៏ក្រៃលែង ក្រាបទូលថា បពិត្រមហារាជ សូមទ្រង់លាប ។ ព្រះរាជានោះត្រាស់ថា ចៀសចេញទៅ កុំលាបឡើយ ព្រះទេវីក្រាលទូលថា បពិត្រមហារាជ ខ្ញុំនឹងលាប

ឲ្យនរណា ព្រះរាជាត្រាស់ថា យើងមិនមែនព្រះរាជា ។ អមាត្យទាំងឡាយបានស្តាប់ពាក្យប្រាស្រ័យរបស់ព្រះរាជា និងព្រះទេវីនោះយ៉ាងនោះ ទើបនាំគ្នាចូលទៅគាល់ ។ ព្រះបច្ចេកសម្ពុទ្ធសួរមន្ត្រីអមាត្យទាំងនោះ ទូលដោយវាទៈថា ព្រះរាជាក៏ត្រាស់ថា យើងមិនមែនព្រះរាជាទេ ។ ពាក្យដ៏សេស មានន័យដូចពោលហើយ ក្នុងគាថា ទី ១ នោះឯង ។

ឯពណ៌នាគាថា មានដូចតទៅនេះ បណ្តាបទទាំងនោះ បទថា **ទិស្វា** បានដល់ ទ្រង់មើលហើយ ។ បទថា **សុវណ្ណស្ស** បានដល់ មាស ។ លោកឲ្យបន្ថែមពាក្យដែលមិនមាន គឺពាក្យថា **វលយានិ**ចូលមក ។ ព្រោះអត្ថត្រូវមានពាក្យដែលមិនមាន ( គឺពាក្យដែលបន្ថែមចូលមក ) ផងដែរ ។ បទថា **បភស្សរានិ** បានដល់ មានពន្លឺចាំងចែងជាប្រក្រតី អធិប្បាយថារុងរឿង ។ ពាក្យដ៏សេស មានអត្ថងាយយល់ហើយ ចំណែកវាចាប្រកបសេចក្តីមានដូចតទៅនេះ ខ្ញុំឃើញកងមាសត្រង់ដៃ ទើបគិតយ៉ាងនេះថា កាលមានការនៅជាគណៈ ការប៉ះទង្គិចគ្នារមែងមាន ការនៅម្នាក់ឯង ក៏មិនមានការប៉ះខ្ទប់គ្នា ទើបផ្តើមចម្រើនវិបស្សនា បានសម្រេចហើយ ។ ពាក្យដ៏សេស មានអត្ថងាយយល់ហើយនោះឯង ៕

## អដ្ឋកថា សុវណ្ណវលយគាថា ចប់

# អដ្ឋកថា

## អាយតិភយគាថា

គាថាថា **ឯវំ ធុតិយេន** ដូច្នេះជាដើម មានអត្ថុប្បត្តិហេតុដូចម្តេច ។

បានឮថា ស្តេចពារាណសីមួយអង្គនៅក្មេង មានបំណងចង់បួស ទើបត្រាស់នឹងអមាត្យទាំងឡាយថា អ្នកទាំងឡាយ ចូរនាំព្រះទេវីមក ហើយឲ្យព្រះនាងបរិហាររាជសម្បត្តិ យើងនឹងបួស ។ អមាត្យទាំងឡាយទូលឲ្យព្រះរាជាជ្រាបថា បពិត្រមហារាជ ទូលបង្គំទាំងឡាយ មិនអាចរក្សារាជសម្បត្តិដែលឥតព្រះរាជាៗ ក្បែរខាងទាំងឡាយ នឹងនាំគ្នាមកប្លន់ដណ្តើមយក សូមទ្រង់បង្អង់ ទម្រាំព្រះរាជឱរសមួយអង្គកើតឡើង ។

ព្រះរាជាទ្រង់មានព្រះហឫទ័យទន់ភ្លន់ ទើបទទួលពាក្យ ។ លំដាប់នោះព្រះទេវីទ្រង់តាំងគភ៌ ព្រះរាជាទ្រង់ត្រាស់នឹងអមាត្យទាំងនោះទៀតថា ព្រះទេវីមានព្រះគភ៌ហើយ អ្នកទាំងឡាយ ចូរអភិសេកព្រះរាជឱរសដែលប្រសូតហើយក្នុងរាជសម្បត្តិ ហើយចូរបរិហារ គឺគ្រប់គ្រងរាជសម្បត្តិ យើងនឹងបួស ។ អមាត្យទាំងឡាយទូលព្រះរាជាឲ្យទ្រង់ជ្រាបទៀតថា បពិត្រមហារាជកាលដែលព្រះទេវីប្រសូតព្រះរាជឱរស ឬព្រះរាជធីតានោះ ដឹងបានលំបាកព្រោះហេតុនោះ សូមទ្រង់រង់ចាំកាលប្រសូតិសិន ។ ពេលនោះ ព្រះទេវីបានប្រសូតព្រះរាជបុត្ត ។ គ្រានោះ ព្រះរាជាទ្រង់ក៏ត្រាស់នឹងអមាត្យទាំងឡាយយ៉ាងនោះទៀត អមាត្យទាំងឡាយ នាំគ្នាទូលព្រះរាជាឲ្យទ្រង់យល់ព្រមដោយហេតុផលជាច្រើនទៀតថា បពិត្រមហារាជ សូមទ្រង់បង្អង់សិន ទម្រាំព្រះឱរសមានសមត្ថភាព ។ លំដាប់នោះ កាលព្រះរាជកុមារ ជាអ្នកមាន

សមត្ថភាពហើយ ព្រះរាជាត្រាស់ឲ្យអមាត្យទាំងឡាយប្រជុំគ្នា ហើយត្រាស់ថា ឥឡូវនេះ ព្រះរាជកុមារនេះជាអ្នកមានសមត្ថភាពហើយ អ្នកទាំងឡាយចូរអភិសេកព្រះរាជកុមារនោះ ក្នុងរាជសម្បត្តិ ហើយប្រណិប័តន៍ចុះ កាលត្រាស់ហើយ មិនឲ្យឱកាសដល់ពួកអមាត្យ ឲ្យនាំបរិក្ខារទាំងពួង មានសំពត់កាសាវៈជាដើមមកអំពីរានផ្សារ ទ្រង់បួសខាងក្នុងបុរីនោះឯង រួចយាងចេញទៅ ដូចព្រះមហាជនក ។ បរិវារជនទាំងពួងនាំគ្នាកន្ទក់កន្ទេញ មានប្រការផ្សេងៗ ជាប់តាមព្រះរាជាទៅ ។ ព្រះរាជាយាងទៅអស់វេជ្ជសីមារបស់ព្រះអង្គហើយយកឈើប្រត់គូស ត្រាស់ថា កុំឈានកន្លងស្នាមគំនូសនេះ មហាជនក្រាបចុះលើផែនដី ធ្វើក្បាលទុកត្រង់ស្នាមគំនូស កន្ទក់កន្ទេញពោលថា បពិត្រព្រះរាជកុមារ ឥឡូវនេះ អាជ្ញារបស់ព្រះរាជាធ្វើអ្វីដល់ព្រះអង្គបាន ទើបឲ្យព្រះរាជកុមារឈានកន្លងគំនូសទៅ ។ ព្រះរាជកុមារទូលថា បពិត្របិតា បពិត្របិតា ហើយរត់ទៅទាន់ព្រះរាជា ។ ព្រះរាជាទ្រង់ឃើញព្រះរាជកុមារហើយទ្រង់ព្រះតម្រិះថា អញគ្រងរាជសម្បត្តិ គ្រប់គ្រងមហាជននេះមកហើយ ឥឡូវនេះ គ្រប់គ្រងទារកម្នាក់មិនបានឬ ទើបនាំព្រះរាជកុមារចូលព្រៃ ទ្រង់ឃើញបណ្ណសាលាដែលព្រះបច្ចេកពុទ្ធទាំងឡាយមុនៗ ធ្លាប់នៅហើយ ក្នុងព្រៃនោះទើបអាស្រ័យនៅជាមួយព្រះរាជឱរស ។

លំដាប់នោះ ព្រះរាជកុមារធ្លាប់ស្និទ្ធស្នាល នឹងទីដេកយ៉ាងល្អជាដើមកាលមកដេកលើកម្រាលដែលធ្វើដោយស្មៅ ឬគ្រែខ្សែ ទ្រង់ក៏ព្រះកន្សែង ។ កាលត្រូវរងា និងខ្យល់ជាដើម ក៏ទូលថា បពិត្របិតា ខ្ញុំក្តៅ បពិត្របិតា

មួសខាំ បពិត្របិតា ខ្ញុំឃ្លាន បពិត្របិតា ខ្ញុំស្រេក ។ ព្រះរាជាអំពល់តែលួងលោមព្រះរាជកុមារនោះឯង ធ្វើឲ្យពេលវេលាកន្លងទៅអស់រាត្រី សូម្បីពេលថ្ងៃ ទ្រង់ក៏ត្រាច់បិណ្ឌបាត ហើយនាំកត្តាហារចូលទៅឲ្យព្រះរាជកុមារនោះ ។ អាហារជាអាហារលាយគ្នា ច្រើនទៅដោយថ្កៅ ស្កួយ និងសណ្តែកបាយជាដើម សូម្បីមិនពេញចិត្ត ក៏ត្រូវសោយកត្តាហារនោះ ព្រោះការឃ្លានលុះកន្លងទៅ ២-៣ ថ្ងៃ ក៏ទ្រង់ស្គមស្គាំង ដូចផ្កាឈូក ដែលដាក់ក្នុងទីក្តៅឯព្រះរាជាទ្រង់មិនមានអាការខុសប្រក្រតី សោយបាន ដោយអំណាចការពិចារណា ។ លំដាប់នោះ ព្រះរាជាកាលទ្រង់ឲ្យព្រះរាជកុមារព្រមសោយទើបត្រាស់ថា នែបា ក្នុងនគរ រមែងរកអាហារប្រណីតបាន ពួកយើងទៅក្នុងនគរចុះ ។ ព្រះរាជកុមារទទួលថា សាធុ បិតា ។ បន្ទាប់អំពីនោះ ព្រះរាជាទ្រង់ឲ្យព្រះរាជកុមារទៅមុន ហើយត្រឡប់មកកាន់នគរ តាមផ្លូវដែលមកហើយនោះឯង ។ ឯព្រះជននីរបស់ព្រះរាជកុមារ ទ្រង់ព្រះតម្រិះថា ឥឡូវនេះព្រះរាជាគង់មិននាំព្រះរាជកុមារ ទៅនៅព្រៃអស់កាលយូរ ត្រឹមតែ ២-៣ ថ្ងៃក៏នឹងត្រឡប់មក ទើបធ្វើរបងក្នុងទីដែលព្រះរាជាយកឈើច្រត់គូសនោះឯងហើយសម្រេចការនៅ ។ ព្រះរាជាប្រថាប់ឈរ ក្នុងទីមិនឆ្ងាយអំពីរបងរបស់ព្រះទេវីនោះ ហើយទ្រង់បញ្ជូនព្រះរាជកុមារទៅថា នែបា មាតារបស់កូនអង្គុយនៅក្នុងទីនោះ បាទៅចុះ ។ ព្រះអង្គបានប្រថាប់ឈរមើលរហូតព្រះរាជ-កុមារដល់ទីនោះ ដោយតាំងព្រះហឫទ័យថា បុគ្គលណាម្នាក់ កុំបីធ្វើអន្តរាយដល់ព្រះរាជកុមារឡើយ ។ ព្រះរាជកុមារបានរត់ទៅរកព្រះមាតា ។

ពួកបុរសធ្វើការរក្សា ឃើញព្រះរាជកុមារនោះយាងមក ទើបក្រាបទូលព្រះទេវី ។ ព្រះទេវីចោមរោមដោយស្រីរបាំ ២ ម៉ឺននាក់ ធ្វើការទទួលព្រះរាជកុមារ ហើយត្រាស់សួរដល់ការប្រព្រឹត្តទៅរបស់ព្រះរាជា ព្រះនាងបានស្តាប់ថា ទ្រង់យាងមកឯក្រោយ ទើបបញ្ជូនមនុស្សទៅចាំទទួល ។ ឯព្រះរាជាបានយាងត្រឡប់ទៅកាន់លំនៅរបស់ព្រះអង្គ ក្នុងវេលានោះឯង ។ មនុស្សទាំងឡាយមិនជួបព្រះរាជា ទើបនាំគ្នាត្រឡប់មក ។ លំដាប់នោះ ព្រះទេវីអស់សង្ឃឹម ទើបនាំព្រះរាជឱរសទៅកាន់នគរ អភិសេកទុកក្នុងរាជសម្បត្តិ ។ ឯព្រះរាជា ប្រថាប់គង់ក្នុងលំនៅរបស់ព្រះអង្គ ទ្រង់ចម្រើនវិបស្សនា រហូតបានសម្រេចពោធិញ្ញាណ ហើយបានពោលឧទានគាថានេះ ក្នុងកណ្តាលព្រះបច្ចេកសម្ពុទ្ធទាំងឡាយ ត្រង់គល់មញ្ជូសកព្រឹក្ស ។ ឧទានគាថានោះ ដោយអត្ថងាយយល់ហើយ ។

ក្នុងឧទានគាថានោះ មានអធិប្បាយដូចតទៅនេះថា ការបន្ទឺវាចាសន្ទនា ឬវាចាជាគ្រឿងជាប់ជំពាក់ ដោយអំណាចសេចក្តីស្រឡាញ់ក្នុងកុមារនោះ កើតហើយដល់ខ្ញុំ មានព្រះរាជកុមារម្នាក់ជាសម្លាញ់ រង់ចាំរំអុករឿងរ៉ាវ ក្តៅជាដើម បើខ្ញុំមិនលះបង់កុមារនោះសោត តមកអំពីនោះ ការបន្ទឺវាចាសន្ទនា ឬវាចាដោយពាក្យស្និទ្ធស្នាលជាមួយបុគ្គល ដែលនៅជាមួយ ក៏នឹងមានយ៉ាង

នោះ រហូតដល់ឥឡូវនេះ ។ ខ្ញុំសម្លឹងឃើញភ័យនេះតទៅខាងមុខថា ការបន្ទឺវាចាសន្ទនា និងវាចាជាគ្រឿងជាប់ជំពាក់ទាំង ២ នេះ នឹងធ្វើអន្តរាយចំពោះការសម្រេចគុណវិសេស ទើបលះបង់កុមារនោះ ហើយបដិបត្តិដោយឧបាយបានសម្រេចបច្ចេកពោធិញ្ញាណហើយ ។ ពាក្យដ៏សេស មានន័យដូចពោលហើយនោះឯង ៕៚

## អដ្ឋកថា អាយតិភយគាថា ចប់

# អដ្ឋកថា

## កាមគាថា

គាថាថា **កាមា ហិ ចិត្រា** ដូច្នេះជាដើម មានអត្ថុប្បត្តិហេតុដូចម្តេច ។

បានឮថា សេដ្ឋីបុត្តក្នុងនគរពារាណសីបានតំណែងសេដ្ឋី តាំងអំពីក្មេងនោះឯង ។ សេដ្ឋីបុត្តនោះ បានទទួលការបម្រើដោយសម្បត្តិទាំងពួង ដូចទេវកុមារ ។ កាលនោះ សេដ្ឋីបុត្តនោះនៅក្មេងនោះឯង គិតថា នឹងបួស ទើបលាមាតាបិតា ។ មាតាបិតាក៏ហាមឃាត់ សេដ្ឋីបុត្តនោះ ក៏រំអុករឿយៗ ។ មាតាបិតាក៏ហាមឃាត់ទៀត ដោយប្រការផ្សេងៗ ថា នែបា បាជាមនុស្សសុខុមាលជាតិ បព្វជ្ជាធ្វើបានដោយក្រ ដូចការដើរទៅមកលើមុខកាំបិតកោរ ។ សេដ្ឋីបុត្តនោះ ក៏នៅតែរំអុកយ៉ាងនោះឯង ទើបមាតាបិតាគិតថា បើកូននេះបួស ពួកយើងក៏មានទោមនស្ស បើឲ្យនៅ កូនយើងក៏កើតទោមនស្ស សូមឲ្យទោមនស្សកើតដល់ពួកយើងចុះ កុំបីមានដល់កូនយើងឡើយ ទើបអនុញ្ញាតឲ្យបួស ។ បន្ទាប់អំពីនោះ សេដ្ឋីបុត្តនោះ មិនដាក់ចិត្តដល់បរិវារជន ដែលកំពុងបរិទេវនាការ ទៅកាន់ព្រៃឥសិបតនៈ បួសក្នុងសម្នាក់របស់ព្រះបច្ចេកសម្ពុទ្ធទាំងឡាយ សេនាសនៈដ៏ប្រសើរ មិនដល់លំដាប់កុលបុត្តនោះ ទើបកុលបុត្តនោះលាតកន្ទេលផែងលើគ្រែតូច ហើយសិង ។ កុលបុត្តនោះ ធ្លាប់ស្និទ្ធស្នាលក្នុងដំណេកយ៉ាងល្អមកអំពីមុន ទើបមានសេចក្តីលំបាកក្រៃលែងអស់មួយយប់ទល់ភ្លឺ កាលរាត្រីអស់ហើយ កុលបុត្តនោះ ធ្វើបរិកម្មសរីរៈ ហើយកាន់បាត្រ និងចីវរចូលទៅបិណ្ឌបាត មួយអន្លើដោយព្រះបច្ចេកសម្ពុទ្ធទាំងឡាយ ។ បណ្តាព្រះបច្ចេកសម្ពុទ្ធទាំងនោះ ព្រះបច្ចេកសម្ពុទ្ធដែល

ចាស់ជាង បាននូវសេនាសនៈដ៏ប្រសើរ និងភោជនដ៏ប្រសើរ ។ ព្រះបច្ចេក-សម្ពុទ្ធដែលជានវក បាននូវសេនាសនៈ និងភោជនដ៏សៅហ្មងតាមមានតាមបាន ។ កុលបុត្តនោះ បានទទួលសេចក្តីទុក្ខយ៉ាងក្រៃលែង ព្រោះភោជនសៅហ្មងនោះ ។ លុះកន្លងទៅ ២-៣ ថ្ងៃ ប៉ុណ្ណោះ កុលបុត្តនោះក៏ស្គាំងស្គមមានពណ៌សម្បុរសៅហ្មង នឿយណាយក្នុងសមណធម៌ មិនដល់នូវការចាស់ក្លា ។ បន្ទាប់អំពីនោះ ក៏ប្រាប់ទូតឲ្យជម្រាបដល់មាតាបិតា ហើយសឹក ។ លុះកន្លងទៅ ២-៣ ថ្ងៃ កុលបុត្តនោះមានកម្លាំងហើយ ទើបចង់បួសទៀត ។ បន្ទាប់អំពីនោះ ទើបបួសជាលើកទី ២ ហើយសឹកទៀត ។ ក្នុងលើកទី ៣ កុលបុត្តនោះបួសទៀត បដិបត្តិដោយប្រពៃ ចម្រើនវិបស្សនារហូតធ្វើឲ្យជាក់ច្បាស់ហើយនូវបច្ចេកពោធិញ្ញាណ ហើយពោលឧទានគាថានេះ បានពោលព្យាករគាថានេះឯងដដែលទៀត ក្នុងកណ្តាលព្រះបច្ចេកសម្ពុទ្ធទាំងឡាយ ។

បណ្តាបទទាំងនោះ បទថា **កាមា** បានដល់ កាម ២ យ៉ាង គឺវត្ថុកាម ១ កិលេសកាម ១ ។ ក្នុង ២ យ៉ាងនោះ ធម៌ គឺអារម្មណ៍ ដូចជា បិយរូបជាដើម ឈ្មោះថា **វត្ថុកាម** រាគៈគ្រប់ប្រភេទឈ្មោះថា **កិលេសកាម ។** តែក្នុងទីនេះ បំណងយកវត្ថុកាម ។ កាមទាំងឡាយជារបស់វិចិត្រ ព្រោះមានច្រើនយ៉ាង មានរូបជាដើម ។ ឈ្មោះថា មានរសផ្អែម ព្រោះជាទីពេញចិត្តរបស់សត្វលោក ។ ឈ្មោះថា ជាទីរីករាយនៃចិត្ត ព្រោះធ្វើចិត្តរបស់ពាលបុថុជ្ជនឲ្យត្រេកអរ ។ ឈ្មោះថា មានសភាពដ៏ប្លែកៗ បានដល់ ដោយសភាពផ្សេងៗ លោកអធិប្បាយថា ដោយសភាវៈផ្សេងៗ ។ ពិតហើយ កាម

ទាំងនោះ វិចិត្រល្អដោយអំណាចរូបជាដើម មានរូបផ្សេងៗ ច្រើនប្រភេទ ដោយអំណាចពណ៌ខៀវជាដើមក្នុងរូបជាដើម អធិប្បាយថា កាមទាំងឡាយ សម្តែងនូវការពេញចិត្ត ដោយប្រការនោះៗ ដោយរូបផ្សេងៗ នោះៗ យ៉ាងនេះ រមែងញាំញីនូវចិត្ត គឺមិនឲ្យត្រេកអរក្នុងការបួស ។ ពាក្យដ៏សេស ក្នុងគាថានេះ ប្រាកដច្បាស់ហើយ សូម្បីបទសរុប ក៏គប្បីជ្រាបដោយន័យដូចពោលហើយ ក្នុងគាថាទី ១ នោះឯង ដោយរួម ២ ឬ ៣ បទ ( គាថា ) ប្រកបគ្នា ។៤៩៩

**អដ្ឋកថា កាមគាថា ចប់**

# អដ្ឋកថា
# ឡិតិគាថា

គាថាថា **ឡិតី** ៩ ដូច្នេះជាដើម មានអត្ថុប្បត្តិហេតុដូចម្តេច ។

បានឮថា ក្នុងនគរពារាណសី បូសកើតឡើងដល់ព្រះរាជា ។ វេទនាដ៏ខ្លាំងក្លាបានបន្ថែមច្រើនឡើង គ្រូពេទ្យទាំងឡាយទូលថា វៀរសត្ថកម្ម គឺការវះកាត់ នឹងមិនមានផាសុក ព្រះរាជាទ្រង់ឲ្យអភ័យដល់ពេទ្យទាំងនោះ ហើយឲ្យធ្វើការវះកាត់ ពេទ្យទាំងនោះវះបូសនោះហើយ នាំខ្ទុះ និងឈាមចេញអស់នូវការឈឺចាប់ ហើយយកសំពត់រុំ និងថ្វាយដំបូន្មានព្រះរាជាឲ្យសោយព្រះក្រយាហារ ដែលផ្សំដោយសាច់សៅហ្មង ។ ព្រះរាជាទ្រង់មានព្រះសរីរៈស្គាំងស្គមព្រោះភោជនសៅហ្មង បូសរបស់ព្រះរាជានោះក៏ក្រៀមទៅ ។ ព្រះរាជាទ្រង់មានសញ្ញាថា ទ្រង់មានផាសុក ទើបសោយព្រះក្រយាហារដ៏ប្រសើរ ដោយហេតុនោះ ទើបទ្រង់មានកម្លាំង សោយព្រះក្រយាហារដូចមុនទៀត ។ បូសរបស់ព្រះរាជានោះត្រឡប់កើតដូចមុនទៀត កាលបើយ៉ាងនោះ ទើបទ្រង់ឲ្យធ្វើការវះកាត់ រហូតដល់ ៣ ដង ត្រូវគ្រូពេទ្យទាំងឡាយវៀរហើយចាកការរក្សា ទើបទ្រង់នឿយណាយ លះមហារាជសម្បត្តិចេញបួស ចូលព្រៃប្រារព្ធវិបស្សនា អស់ ៧ ឆ្នាំ ធ្វើឲ្យជាក់ច្បាស់នូវបច្ចេកពោធិញ្ញាណ បានពោលឧទានគាថានេះហើយ ទៅកាន់ភ្នំនន្ទមូលកៈ ។

ដែលឈ្មោះថា **ឡិតី** ក្នុងគាថានោះ ព្រោះអត្ថថា មក ពាក្យថា **ឡិតី** នេះ ជាឈ្មោះរបស់ហេតុនៃសេចក្តីវិនាស ដែលជាចំណែកនៃអកុសលដែលចរមក ។ ព្រោះហេតុនោះ កាមគុណទាំងនេះ ទើបឈ្មោះថា ចង្រៃ ព្រោះ

អត្ថថា នាំមកនូវការវិនាសមិនមែនតិច និងព្រោះអត្ថថា ជាទីប្រជុំនៃសេចក្តីវិនាស ។ បូសក៏ហូរចេញនូវរបស់មិនស្អាតមក ជារបស់ប៉ោងឡើង ទុំ និងបែក ព្រោះហេតុនោះ ទើបកាមគុណទាំងនេះ ឈ្មោះថា ជាបូស ព្រោះហូរនូវរបស់មិនស្អាត គឺកិលេសចេញមក និងព្រោះមានភាវៈប៉ោងឡើងទុំ និងបែក ដោយការកើតឡើង ការគ្រាំគ្រា និងការបែកធ្លាយទៅ ។ ឈ្មោះថា ឧបទ្ទវ ព្រោះអត្ថថា បៀតបៀន អធិប្បាយថា ធ្វើនូវសេចក្តីវិនាសឲ្យកើតហើយគ្របសង្កត់ លិចលង់ ។ ពាក្យថា ឧបទ្ទវ នេះ ជាឈ្មោះនៃបូស គឺរាគៈជាដើម ព្រោះហេតុនោះ កាមគុណទាំងនេះ ក៏ឈ្មោះថា ឧបទ្ទវ ព្រោះនាំមកនូវសេចក្តីវិនាស គឺការមិនដឹងច្បាស់នូវព្រះនិព្វានជាហេតុ និងព្រោះជាវត្ថុដែលតាំងដោយជុំវិញនៃឧបទ្ទវកម្មគ្រប់ប្រភេទ ។ ព្រោះហេតុដែលកាមគុណទាំងនេះ ធ្វើនូវការសោប់សេល់ ព្រោះកិលេសឲ្យកើត ធ្វើនូវការមិនមានរោគ ពោល គឺសីល ឬសេចក្តីលោភឲ្យកើតឡើង ប្លន់យកនូវការមិនមានរោគ ដែលជាសភាវៈប្រក្រតី ដូច្នោះ ទើបកាមគុណទាំងនោះ ឈ្មោះថា ជារោគ ព្រោះអត្ថថា ប្លន់នូវការមិនមានរោគនេះ ។ ម្យ៉ាងទៀត ឈ្មោះថា ជាសរ ព្រោះអត្ថថា មុតចូលទៅខាងក្នុង ព្រោះអត្ថថា ដោតចូលទៅខាងក្នុង និងព្រោះអត្ថថា ដកចេញបានលំបាក ។ ឈ្មោះថា ជាភ័យ ព្រោះនាំមកនូវភ័យក្នុងបច្ចុប្បន្ន និងភ័យក្នុងភពខាងមុខ ។ បទថា **មេតំ** កាត់បទជា **មេ ឯតំ** ។ ពាក្យដ៏សេសក្នុងគាថានេះ ប្រាកដច្បាស់ហើយ ។ សូម្បីពាក្យសរុប ក៏គប្បីជ្រាបដោយន័យដូចពោលហើយនោះឯង ។៚

# អដ្ឋកថា

## សីតាលុកគាថា

គាថាថា **សីតញ្ច** ដូច្នេះជាដើម មានអត្ថុប្បត្តិហេតុដូចម្ដេច ។

បានឮថា ក្នុងនគរពារាណសី មានព្រះរាជាព្រះនាមសីតាលុកព្រហ្មទត្ត ព្រះរាជាអង្គនោះ ទ្រង់បួសហើយ នៅក្នុងកុដិ ដែលប្រក់ដោយស្មៅក្នុងព្រៃ ក្នុងទីនោះ ក្នុងរដូវរងា ក៏រងាខ្លាំង ក្នុងរដូវក្ដៅ ក៏ក្ដៅខ្លាំង ព្រោះជាទីស្រឡះ ។ ក្នុងគោចរគាមក៏មិនបានភិក្ខាសូម្បីត្រឹមតែល្មមតាមត្រូវការ ទឹកផឹកក៏រកបានដោយលំបាក ។ ខ្យល់ក្ដី កម្ដៅថ្ងៃក្ដី របោម និងសត្វលូនវារក្ដី ក៏បៀតបៀន ។ ព្រះរាជានោះមានព្រះតម្រិះថា ក្នុងទីប្រមាណកន្លះយោជន៍អំពីនេះ មានទីដទៃដែលសម្បូរអន្តរាយ ដែលបៀតបៀនទាំងនោះគ្រប់ប្រភេទ ក៏មិនមានក្នុងទីនោះ បើដូច្នោះ អញគប្បីទៅក្នុងទីដទៃនោះ អាត្មាអញនៅផាសុក អាចបានសម្រេចសេចក្ដីសុខ ។ ទ្រង់ព្រះតម្រិះបន្តទៀតថា ធម្មតាបព្វជិតទាំងឡាយ រមែងមិនជាបុគ្គលប្រាថ្នាច្រើនក្នុងបច្ច័យ រមែងបង្គាប់ចិត្តបែបនេះឲ្យនៅក្នុងអំណាចរបស់ខ្លួនបាន រមែងមិនធ្លាក់នៅក្នុងអំណាចរបស់ចិត្ត អញនឹងមិនទៅ កាលពិចារណាយ៉ាងនេះហើយ ទើបមិនយាងទៅ ។ ទ្រង់ពិចារណាចិត្តដែលកើតឡើងយ៉ាងនេះ អស់វារៈ ៣ ដង ធ្វើចិត្តឲ្យត្រឡប់ ។ បន្ទាប់អំពីនោះ ទ្រង់ក៏ប្រថាប់នៅក្នុងទីដើមនោះឯង ដល់ទៅ ៧ ឆ្នាំ បដិបត្តិប្រពៃ ធ្វើឲ្យជាក់ច្បាស់នូវបច្ចេកសម្ពោធិញ្ញាណ ត្រាស់ឧទានគាថានេះ ហើយបានទៅកាន់ញកភ្នំនន្ទមូលកៈ ។

បណ្តាបទទាំងនោះ បទថា **សីតញ្ច** សេចក្តីថា រងា មាន ២ យ៉ាង គឺរងាមានធាតុខាងក្នុងកម្រើកជាបច្ច័យ ១ រងាមានធាតុខាងក្រៅកម្រើកជាបច្ច័យ ១ ។ កម្តៅ មាន ២ យ៉ាងដូចគ្នា ។ រុយពណ៌ខ្មោត ឈ្មោះថា រោមម ។ បទថា **សរីសបា** បានដល់ ទីឃជាតិប្រភេទណាមួយ ដែលលូនវារទៅ ។ ពាក្យដ៏សេស ប្រាកដច្បាស់ហើយ ។ សូម្បីបទសរុបគប្បីជ្រាបដោយន័យដូចពោលហើយនោះឯង ។ល។

## អដ្ឋកថា សីតាលុកគាថា ចប់

# អដ្ឋកថា

## ឆាគគាថា

គាថាថា **ឆាគោរ** ជាដើម មានអត្ថុប្បត្តិហេតុដូចម្តេច ។

បានឮថា ក្នុងនគរពារាណសី មានព្រះរាជាមួយអង្គគ្រងរាជសម្បត្តិ ២០ ឆ្នាំ សោយទិវង្គតហើយ ត្រូវឆេះក្នុងនរក ២០ ឆ្នាំ ដូចគ្នា ហើយមកកើតក្នុងកំណើតដំរី ក្នុងហិមវន្តប្បទេស មានសកលកាយទាំងមូល ពណ៌ដូចផ្កាឈូក ជាដំរីមេហ្វូងដ៏ប្រសើរ ។ កូនដំរីទាំងឡាយ រមែងស៊ីមែកឈើបាក់ ដែលដំរីនោះកាច់ឲ្យហើយ ក្នុងការចុះកាន់ទឹក ពួកដំរីញី ក៏យកភក់មកលាបដំរីនោះ ។ រឿងទាំងអស់ដូចគ្នានឹងរឿងរបស់ដំរីបាលិលេយ្យកៈ ។ ដំរីនោះនឿយណាយ ទើបចៀសចេញចាកហ្វូង បន្ទាប់អំពីនោះ ហ្វូងដំរីក៏នាំគ្នាទៅតាមដំរីនោះ តាមស្នាមជើង ។ ដំរីនោះ ទោះបីគេចចេញយ៉ាងនោះ អស់វារៈ ៣ ដង ហ្វូងដំរីក៏នៅតែជាប់តាមអស់ វារៈ ៣ ដង ។ លំដាប់នោះដំរីនោះគិតថា ឥឡូវនេះ ចៅរបស់អញគ្រងរាជសម្បត្តិ ក្នុងនគរពារាណសី បើដូច្នោះ អញគប្បីទៅកាន់ឧទ្យានក្នុងជាតិមុនរបស់អញ ចៅនោះ នឹងរក្សាអញក្នុងឧទ្យាននោះ ។ លំដាប់នោះ កាលហ្វូងដំរីនាំគ្នាដេកលក់ក្នុងពេលយប់ដំរីនោះក៏លះបង់ហ្វូង ចូលទៅកាន់ឧទ្យាននោះឯង ។ អ្នករក្សាឧទ្យានឃើញដំរីនោះ ទើបក្រាបទូលដល់ព្រះរាជា ។ ព្រះរាជាទ្រង់ចោមរោមដោយសេនាបំណងថា នឹងចាប់ដំរី ។ ដំរីបែរមុខឆ្ពោះទៅរកព្រះរាជា ។ ព្រះរាជាទ្រង់ព្រះតម្រិះថា ដំរីបែរមុខមករកអញ ទើបផ្ចាប់ព្រួញ ប្រថាប់ឈរ លំដាប់នោះដំរីគិតថា ព្រះរាជានេះគង់នឹងបាញ់អញ ទើបពោលដោយភាសាមនុស្សថា

បពិត្រព្រហ្មទត្ត ទ្រង់កុំបាញ់ខ្ញុំឡើយ ខ្ញុំជាអយ្យការបស់ទ្រង់ ។ ព្រះរាជាត្រាស់ថា ឯងនិយាយអ្វី ហើយត្រាស់សួររឿងទាំងពួង ។ ឯដំរីក៏ក្រាបទូលរឿងទាំងពួងទាក់ទងនឹងរាជសម្បត្តិ ទាក់ទងនឹងនរក និងទាក់ទងក្នុងកំណើតដំរីឲ្យទ្រង់ជ្រាប ។ ព្រះរាជាត្រាស់ថា សាធុ អ្នកកុំខ្លាច និងកុំឲ្យបុគ្គលណាមួយខ្លាច ហើយឲ្យតម្កល់ស្បៀងចាត់មនុស្សឲ្យរក្សា និងកណ្ឌៈសម្រាប់ដំរី ។ ថ្ងៃមួយ ព្រះរាជាប្រថាប់គង់លើកដំរីដ៏ប្រសើរ ទ្រង់ព្រះតម្រិះថា អយ្យកានេះគ្រងរាជ្យ ២០ ឆ្នាំ ហើយត្រូវឆេះក្នុងនរក មកកើតក្នុងកំណើតតិរច្ឆាន ព្រោះវិបាកកម្មដែលសេសសល់ កើតក្នុងកំណើតជាដំរី ក៏អត់សង្កត់នូវការប៉ះខ្ទប់ក្នុងពួកគណៈមិនបាន ទើបមកទីនេះ ។ ឱ ! ការនៅជាពួក ជាគណៈ លំបាកហ្ន៎ ។ តែកាពជាបុគ្គលម្នាក់ឯងនោះឯង ជាសុខពិត ទើបទ្រង់ផ្តើមវិបស្សនាលើកដំរីនោះឯង បានធ្វើឲ្យជាក់ច្បាស់នូវបច្ចេកពោធិញ្ញាណហើយ ។ ព្រះរាជានោះ ទ្រង់មានសេចក្តីសុខ ដោយលោកុត្តរសុខ ពួកអមាត្យចូលទៅក្រាបទូលថា បពិត្រមហារាជ កាលនេះ ជាកាលគួរយាងត្រឡប់ហើយ លំដាប់នោះ ព្រះរាជាត្រាស់ថា យើងមិនមែនជាព្រះរាជាហើយបានត្រាស់គាថានេះ ដោយន័យដែលមានពោលក្នុងខាងដើមនោះឯង ។ គាថានោះ មានអត្ថនៃបទប្រាកដច្បាស់ហើយ ។

តែក្នុងទីនេះ មានពាក្យអធិប្បាយប្រកបសេចក្តីដូច្នេះ គាថានោះ លោកពោលរឿងពិត មិនមែនពោលតាមដែលបានស្តាប់មក ។ ដំរីនេះ ឈ្មោះថានាគ ព្រោះមិនមកកាន់ភូមិដែលខ្លួនមិនបានទូន្មាន ព្រោះទូន្មានហើយក្នុងសីល

ដែលជាទីស្រឡាញ់របស់ព្រះអរិយៈក៏បាន ព្រោះជាអ្នកមានរាងកាយធំក៏បាន យ៉ាងណា ចំណែកអញជានាគរហូត ព្រោះមិនមកកាន់ភូមិ ដែលមិនមានបានទទួលការទូន្មាន ដែលទូន្មានហើយក្នុងសីល ដែលជាទីស្រឡាញ់របស់ព្រះអរិយៈ ព្រោះមិនធ្វើបាបក៏បាន ព្រោះមិនត្រឡប់មកកាន់ភាពជាយ៉ាងនេះទៀតក៏បាន ឬព្រោះមានរាងកាយ គឺគុណវិសេសធំក៏បាន យ៉ាងនោះ ។ ម្យ៉ាងទៀត ដំរីនេះ លះបង់ហ្វូង ហើយនៅក្នុងព្រៃ គួរដល់អធ្យាស្រ័យដោយសេចក្ដីសុខក្នុងភាពជាបុគ្គលម្នាក់ឯង ត្រាច់ទៅ បុគ្គលគប្បីប្រព្រឹត្តតែម្នាក់ឯង ដូចកុយរមាស យ៉ាងណា សូម្បីអាត្មាអញ ក៏យ៉ាងនោះសព្វកាល វៀរពួកគណៈ នៅក្នុងព្រៃ តាមគាប់ចិត្ត ដោយសេចក្ដីសុខក្នុងការនៅម្នាក់ឯង គឺអាស្រ័យនៅក្នុងព្រៃអស់សព្វកាលដែលប្រាថ្នា ដោយប្រការដែលនឹងកើតសេចក្ដីសុខដល់ខ្លួន គប្បីជាបុគ្គលម្នាក់ឯង ត្រាច់ទៅដូចកុយរមាស អធិប្បាយថា គប្បីជាបុគ្គលម្នាក់ឯង ត្រាច់ទៅ ។ ម្យ៉ាងទៀត ដំរីនេះ ឈ្មោះថា មានខ្លួនសមរម្យ មាំមួន ព្រោះមានដងខ្លួនធំសព្វកាល យ៉ាងណា អាត្មាអញយ៉ាងនោះ ជាបុគ្គល ឈ្មោះថា មានដងខ្លួនសមសួន ព្រោះជាអ្នកមានដងខ្លួន គឺគំនរនៃសីល ដែលជារបស់ព្រះសេក្ខៈដ៏ធំក្រៃលែង ។ ម្យ៉ាងទៀត ដំរីនេះ ឈ្មោះថា មានសម្បុរដូចផ្កាឈូក ព្រោះមានខ្លួនដូចគ្នានឹងផ្កាឈូក ឬព្រោះកើតក្នុងត្រកូលដំរីបទុមសព្វកាល

យ៉ាងណា អាត្មាអញ ក៏យ៉ាងនោះ ជាបុគ្គល ឈ្មោះថា មានសម្បុរដូច ផ្កាឈូក ព្រោះជាបុគ្គលស្មោះត្រង់ ដូចគ្នានឹងផ្កាឈូក ឬព្រោះជាអ្នកកើត ក្នុងផ្កាឈូក គឺអរិយជាតិ ។ ម្យ៉ាងទៀត ដំរីនេះ ជាដំរីធំ និងថាមពល ជាដើមសព្វកាល យ៉ាងណា សូម្បីអាត្មាអញ ក៏យ៉ាងនោះ គប្បីជាអ្នកធំ ដោយភាពជាអ្នកមានកាយសមាចារដ៏បរិសុទ្ធជាដើម ឬដោយសីល សមាធិ និងបញ្ញា ជាគ្រឿងទម្លាយកិលេសជាដើម ។ ខ្ញុំគិតយ៉ាងនេះ ទើបផ្តើម ចម្រើនវិបស្សនា បានសម្រេចបច្ចេកពោធិញ្ញាណ ដោយប្រការដូច្នេះ ។ល។

**អដ្ឋកថា ឆាគគាថា ចប់**

# អដ្ឋកថា

## អដ្ឋានគាថា

គាថាថា **អដ្ឋានតំ** ជាដើម មានអត្ថុប្បត្តិហេតុដូចម្ដេច ។

បានឮថា ឱរសរបស់ព្រះបាទពារាណសី ទ្រង់នៅក្មេងនោះឯង មានបំណងនឹងបួស ទើបទូលសូមព្រះមាតាបិតា ។ ព្រះមាតាបិតាទ្រង់ឃាត់រាជឱរសនោះ ។ ព្រះរាជឱរសនោះសូម្បីត្រូវឃាត់ក៏នៅតែរំអុកដូចមុនថា នឹងបួស បន្ទាប់អំពីនោះ ព្រះជនកព្រះជននីបានត្រាស់ពាក្យទាំងពួង ដូចគ្នានឹងមាតាបិតា និយាយនឹងសេដ្ឋីបុត្តដែលពោលមកហើយ ហើយទ្រង់អនុញ្ញាត ។ ទ្រង់ឲ្យព្រះរាជឱរសប្ដេជ្ញាថា បួសហើយ ត្រូវនៅក្នុងឧទ្យានប៉ុណ្ណោះ ។ ព្រះរាជឱរសនោះ បានធ្វើតាមនោះ ។ ព្រះមាតារបស់ព្រះអង្គ ព្រះនាងចោមរោមដោយស្រីរបាំ ២ ម៉ឺននាក់ យាងទៅកាន់ឧទ្យានអំពីព្រឹក ឲ្យព្រះរាជឱរសធាន់បបរក្នុងរាងកត្ត ព្រះនាងក៏ឲ្យទំពារបស់ដែលគួរទំពាជាដើម ព្រះនាងសន្ទនាជាមួយព្រះរាជឱរសនោះ រហូតដល់ថ្ងៃត្រង់ ទើបយាងចូលព្រះនគរ ។ ឯព្រះបិតាក៏យាងមកក្នុងពេលថ្ងៃត្រង់ ឲ្យព្រះរាជឱរសនោះសោយ ទ្រង់ក៏សោយដែរ ទ្រង់សន្ទនាជាមួយព្រះរាជឱរសនោះ អស់ពេលថ្ងៃ ក្នុងពេលល្ងាច ទ្រង់ដាក់អ្នកប្រណិប័តន៍ ហើយយាងចូលព្រះនគរ ។ ព្រះរាជឱរសនោះ មិនស្ងាត់អស់កាលទាំងថ្ងៃ ទាំងយប់ ដោយប្រការយ៉ាងនេះ ។

សម័យនោះ ព្រះបច្ចេកសម្ពុទ្ធព្រះនាមអាទិច្ចពន្ធុ នៅត្រង់ញកភ្នំនន្ទមូលកៈ ព្រះបច្ចេកសម្ពុទ្ធអង្គនោះ ទ្រង់ពិចារណា បានឃើញព្រះរាជកុមារនោះថា កុមារនេះ បួសបាន តែមិនអាចកាត់នូវព្រៃស្តុកបាន ។ ព្រះបច្ចេក-

សមុទ្ទ ពិចារណាបន្តទៀតថា ព្រះរាជកុមារ នឹងនឿយណាយដោយធម្មតាៗ របស់ខ្លួនឬហ្ន៎ ។ លំដាប់នោះ លោកក៏ជ្រាបថា ព្រះរាជកុមារ បើទ្រង់នឿយណាយដោយខ្លួនឯង ក៏ប្រើវេលាយូរ ទើបលោកត្រិះរិះថា អាត្មាអញនឹងឲ្យអារម្មណ៍ដល់ព្រះរាជកុមារនោះ ដូច្នេះហើយ មកអំពីផ្ទាំងមនោសិលាដោយន័យមុន ឈរក្នុងឧទ្យាន ។ បរិស័ទរបស់ព្រះរាជាឃើញហើយ ក៏ក្រាបទូលថា បពិត្រមហារាជ ព្រះបច្ចេកសមុទ្ទនិមន្តមក ព្រះរាជាទ្រង់មានព្រះហឫទ័យប្រកបដោយបាមោជ្ជថា ឥឡូវនេះ កូនរបស់អញ នឹងមិនអផ្សុកនឹងនៅជាមួយព្រះបច្ចេកសមុទ្ទ ទើបទ្រង់ឧបដ្ឋាកព្រះបច្ចេកសមុទ្ទដោយគោរពនិមន្តឲ្យនៅក្នុងឧទ្យាននោះ ត្រាស់ឲ្យធ្វើវត្ថុគ្រប់យ៉ាង មានបណ្ណសាលា ទីសម្រាកពេលថ្ងៃ និងទីចង្ក្រមជាដើម ស្រេចហើយ និមន្តឲ្យគង់ ។ ព្រះបច្ចេកសមុទ្ទនោះ នៅក្នុងទីនោះ ថ្ងៃមួយ បានឱកាស ទើបសួរព្រះរាជកុមារថា លោកជាអ្វី ព្រះរាជកុមារត្រាស់ថា ខ្ញុំជាបព្វជិត ព្រះបច្ចេកសមុទ្ទពោលថា ធម្មតាបព្វជិតទាំងឡាយ មិនមានសភាពដូច្នេះ ។

លំដាប់នោះ កាលព្រះរាជកុមារសួរថា លោកម្ចាស់ដ៏ចម្រើន បព្វជិតទាំងឡាយជាបុគ្គលដូចម្តេច មានអ្វីមិនសមគួរដល់ខ្ញុំឬ ព្រះបច្ចេកសមុទ្ទក៏ត្រាស់ថា លោកមិនពិចារណាមើលវត្ថុ ដែលមិនសមគួររបស់លោក ព្រះមាតារបស់លោកយាងមកក្នុងពេលព្រឹកជាមួយនឹងពួកស្ត្រី ២ ម៉ឺននាក់ ធ្វើឧទ្យានមិនឲ្យស្ងប់ស្ងាត់ ម្យ៉ាងទៀត ព្រះបិតារបស់លោក ក៏យាងមកជាមួយមហាពល ធ្វើមិនឲ្យស្ងប់ស្ងាត់ក្នុងពេលល្ងាច បរិស័ទអ្នកប្រណិប័តន៍ ធ្វើឲ្យ

មិនស្ងប់ស្ងាត់អស់រាត្រីទាំងមូល ជម្ពូតាបព្វជិតទាំងឡាយ មិនមានសភាព ដូចលោក តែលោកជាបុគ្គលមានសភាពយ៉ាងនេះ ។ ហើយសម្តែងឫទ្ធិឲ្យ ព្រះរាជកុមារ ដែលនៅក្នុងឧទ្យាននោះឯងឃើញវិហារ ១ ក្នុងហិមវន្តប្បទេស ។ ព្រះរាជកុមារឃើញព្រះបច្ចេកសម្ពុទ្ធទាំងឡាយ ក្នុងហិមវន្តប្បទេស នោះ ឈរផ្អែកបន្ទះក្តារខ្លះ កំពុងចង្រ្កមខ្លះ កំពុងធ្វើការជ្រលក់ និងការដេរ ជាដើមខ្លះ ទើបព្រះរាជកុមារសាកសួរថា លោកទាំងនោះមិនមកនៅក្នុងទីនេះ ឬ លោកម្ចាស់អនុញ្ញាតឲ្យលោកទាំងនោះបួសឬ ។ ព្រះបច្ចេកសម្ពុទ្ធពោល ថា ត្រូវហើយ លោកទទួលអនុញ្ញាតបួស ចាប់តាំងអំពីកាលដែលបួស ហើយ ឈ្មោះថា សមណៈទាំងឡាយ គួរធ្វើឲ្យខ្លួនឯងចេញចាកទុក្ខ និងទៅ កាន់ទីដែលត្រូវការ ដែលប្រាថ្នា គួរធ្វើត្រឹមប៉ុណ្ណោះឯង កាលពោលហើយ ឈរក្នុងអាកាស ពោលកន្លះគាថានេះថា បុគ្គលបាននូវសាមយិកវិមុត្តិ ដោយហេតុណា ហេតុនោះ មិនមែនជាទីតាំងនៃបុគ្គលអ្នកត្រេកអរក្នុងពួកទេ ដូច្នេះ កាលមនុស្សកំពុងឃើញនោះឯង បានទៅកាន់ញកភ្នំនន្ទមូលកៈ តាម អាកាស ។ កាលព្រះបច្ចេកសម្ពុទ្ធ និមន្តទៅយ៉ាងនោះហើយ ព្រះរាជកុមារ នោះចូលទៅកាន់បណ្ណសាលារបស់ខ្លួន ហើយក៏សិង ។ ឯបុរសអ្នករក្សា ប្រហែសធ្វេសថា ព្រះរាជកុមារផ្ទុំហើយ នឹងទៅណាបាន ទើបចុះកាន់និទ្រា ។ ព្រះរាជកុមារដឹងថា បុរសនោះប្រមាទហើយ ទើបកាន់យកបាត្រ និងចីវរ ចូលព្រៃ ។ ព្រះរាជកុមារនៅក្នុងព្រៃនោះ ផ្តើមចម្រើនវិបស្សនា ធ្វើឲ្យជាក់ ច្បាស់នូវបច្ចេកសម្ពោធិញ្ញាណ ហើយទៅកាន់លំនៅរបស់ព្រះបច្ចេកសម្ពុទ្ធ ។

ក្នុងទីនោះ ត្រូវសួរថា សម្រេចបានដូចម្តេច ទើបពោលកន្ទះគាថា ដែលព្រះអាទិច្ចពន្ធុបច្ចេកពុទ្ធពោល ឲ្យគ្រប់បរិបូណ៌ ។

សេចក្តីនៃគាថានោះថា បទថា **អដ្ឋាន តំ** កាត់បទជា **អដ្ឋានំ តំ** មានសេចក្តីស្មើគ្នានឹង **អការណំ តំ** ប្រែថា សេចក្តីនោះមិនមែនជាហេតុ ។ លោកលុបនិគ្គហិតចេញ ដូចក្នុងពាក្យថា **អរិយសច្ចាន ទស្សនំ** ដូច្នេះជាដើម ។ បទថា **សង្គណិការតស្ស** ប្រែថា ជាអ្នកត្រេកអរក្នុងពួកគណៈ ។ បទថា **យំ** ជាពាក្យប្រាប់ហេតុ ដូចក្នុងប្រយោគជាដើមថា **យំ ហិរីយតិ ហិរីយិតព្វេន** ប្រែថា ត្រង់ដែលបុគ្គលខ្មាស ដោយវត្ថុដែលគួរខ្មាស ។ បទថា **ផស្សយេ** បានដល់ គប្បីត្រាស់ដឹង ។ បទថា **សាមយិកំ វិមុត្តឹ** បានដល់ លោកិយសមាបត្តិ ។ ពិតហើយ សមាបត្តិដែលជាលោកិយនោះ លោកហៅថា សាមយិកវិមុត្តិ ព្រោះរួចផុតចាកសត្រូវទាំងឡាយ ក្នុងសម័យដែលចិត្តជាឯកគ្គតាប៉ុណ្ណោះ ។ នូវសាមយិកវិមុត្តិនោះ ។ ព្រះបច្ចេកសម្ពុទ្ធពោលថា បុគ្គលពិចារណានូវពាក្យនៃព្រះពុទ្ធជាព្រះអាទិច្ចពន្ធុហើយ បុគ្គលគប្បីសម្រេចវិមុត្តិដោយហេតុណា ហេតុនោះ មិនមែនឋានៈ គឺហេតុនោះមិនមានដល់បុគ្គលដែលត្រេកអរក្នុងការប្រឡូកប្រឡំ ដូច្នេះ ទើបលះនូវការត្រេកអរក្នុងការប្រឡូកប្រឡំ បដិបត្តិដោយឧបាយ ទើបបានសម្រេច ។ ពាក្យដ៏សេសមាន ន័យដូចពោលហើយនោះឯង ។៚

**អដ្ឋកថា អដ្ឋានគាថា ចប់**

**វគ្គទី ២ ចប់**

# អដ្ឋកថា

## ទិដ្ឋីវិសូកគាថា

ពាក្យថា **ទិដ្ឋីវិសូកានិ** ដូច្នេះជាដើម មានអត្ថុប្បត្តិហេតុដូចម្តេច ។

បានឮថា ព្រះបាទពារាណសីមួយអង្គ នៅក្នុងទីស្ងាត់ ទ្រង់ព្រះតម្រិះថា ការក្តៅជាដើម ដែលកម្ចាត់រងាជាដើមមាន យ៉ាងណា វិវដ្តៈ ដែលកម្ចាត់វដ្តៈ នឹងមានដូច្នោះឬហ្ន៎ ទើបទ្រង់ត្រាស់សួរអមាត្យទាំងឡាយថា ពួកអ្នកស្គាល់វិវដ្តៈដែរឬទេ អមាត្យទាំងនោះក្រាបទូលថា បពិត្រមហារាជ ស្គាល់ព្រះអង្គ ។ ព្រះរាជាត្រាស់សួរថា វិវដ្តៈនោះ គឺអ្វី បន្ទាប់អំពីនោះ អមាត្យទាំងឡាយ ក៏ពោលដល់ការទៀង និងការដាច់សូន្យ ដោយន័យជាដើមថា លោកមានទីបំផុត ។ ព្រះរាជាទ្រង់ព្រះតម្រិះថា អមាត្យទាំងនេះមិនដឹង អមាត្យទាំងអស់នេះ ជាមិច្ឆាទិដ្ឋិ ទ្រង់ឃើញភាពដែលព្រះអង្គឯង ជំទាស់ និងចូលមិនបាន ជាមួយអាមាត្យទាំងនោះហើយ ទ្រង់ព្រះតម្រិះថា វិវដ្តៈដែលកម្ចាត់វដ្តៈមានពិត គួរស្វែងរកវិវដ្តៈនោះ ទើបទ្រង់លះរាជសម្បត្តិចេញបួស ចម្រើនវិបស្សនា បានធ្វើឲ្យជាក់ច្បាស់នូវបច្ចេកសម្ពោធិញ្ញាណហើយ ។ បានត្រាស់ឧទានគាថា និងព្យាករគាថា ក្នុងកណ្តាលព្រះបច្ចេកសម្ពុទ្ធទាំងឡាយ ។

សេចក្តីនៃគាថានោះថា បទថា **ទិដ្ឋីវិសូកានិ** បានដល់ ទិដ្ឋិ ៦២ ។ ពិតហើយ ទិដ្ឋិទាំងនោះ ឈ្មោះថា ចម្រូង ព្រោះអត្ថថា ជាសត្រូវ ព្រោះអត្ថថា ជាគ្រឿងចាក់ដោត និងព្រោះអត្ថថា ជាបដិបក្ខចំពោះមគ្គសម្មាទិដ្ឋិ កាលបើដូច្នោះ សត្រូវរបស់ទិដ្ឋិ ឬទិដ្ឋិនោះឯងជាសត្រូវ ឈ្មោះថា ចម្រូង គឺទិដ្ឋិ ។ បទថា **ឧបាតិវត្តោ** ប្រែថា ឈានកន្លងហើយដោយមគ្គ គឺ

ទស្សនៈ ។ បទថា **បត្តោ និយាមំ** សេចក្តីថា សម្រេចដល់និយតភាវៈ ដោយភាពជាបុគ្គលមិនធ្លាក់ទៅជាធម្មតា និងដោយភាព ជាបុគ្គលមាន សម្ពោធិញ្ញាណជាទីទៅខាងមុខ ឬបានសម្រេចបឋមមគ្គ ដែលហៅថា សម្មត្តនិយាម ។ លោកពោលការសម្រេចកិច្ចក្នុងបឋមមគ្គ និងការបាន ចំពោះនូវបឋមមគ្គនោះ ដោយលំដាប់ពាក្យមានប្រមាណប៉ុណ្ណេះ ។ ឥឡូវ នេះ លោកសម្តែងការបានចំពោះនូវមគ្គដ៏សេស ដោយពាក្យថា **បដិលទ្ធ-មគ្គោ** ដូច្នេះ ។ បទថា **ឧប្បន្នញាណោម្ហិ** ប្រែថា ខ្ញុំជាបុគ្គល មានព្រះ បច្ចេកសម្ពោធិញ្ញាណកើតឡើងហើយ លោកសម្តែងផល ដោយបទថា **ឧប្បន្នញាណោម្ហិ** នេះ ។ បទថា **អនញ្ញនេយ្យោ** សេចក្តីថា ដែលបុគ្គល ដទៃមិនចាំបាច់ដឹកនាំពិតថា នេះជាសច្ចៈជាដើម ។ លោកសម្តែងភាពជាព្រះ សយម្ភូ ដោយបទថា **អនញ្ញនេយ្យោ** នេះ ម្យ៉ាងទៀត សម្តែងដល់ភាពជា អ្នកជំនាញឯង ព្រោះមិនមានភាពជាបុគ្គលដទៃត្រូវដឹកនាំ ក្នុងបច្ចេកសម្ពោ-ធិញ្ញាណដែលបានសម្រេចហើយ ។ ម្យ៉ាងទៀត សេចក្តីថា ប្រព្រឹត្តកន្លង សត្រូវ គឺទិដ្ឋិ ដោយសមថៈ និងវិបស្សនា សម្រេចដល់ភាពទៀងដោយមគ្គ ខាងដើម មានមគ្គដែលបានហើយ ដោយមគ្គដ៏សេសទាំងឡាយ មាន ញាណកើតឡើងហើយ ដោយផលញ្ញាណ ឈ្មោះថា មិនមានអ្នកដទៃដឹកនាំ ព្រោះបានត្រាស់ដឹងធម៌ទាំងអស់នោះ ដោយខ្លួនឯង ។ ពាក្យដ៏សេស គប្បីជ្រាបដោយន័យដូចបានពោលហើយនោះឯង ។៚

**អដ្ឋកថា ខគ្គវិសាណគាថា ចប់**

# អដ្ឋកថា

## ឆិន្នោលុបគាថា

គាថាថា **ឆិន្នោលុទោ** ជាដើម មានអត្ថុប្បត្តិហេតុដូចម្ដេច ។

បានឮថា ចុងភៅរបស់ព្រះបាទពារាណសី ចម្អិនព្រះស្ងោយក្នុងចន្ទោះ ឃើញថា គួរពេញចិត្ត មានរសឆ្ងាញ់ ទើបបង្អោនចូលទៅថ្វាយ ដោយបំណងថា ធ្វើដូចម្ដេចហ្ន៎ ព្រះរាជាប្រទានទ្រព្យឲ្យដល់អញខ្លះ ។ ព្រះក្រយាហារនោះគ្រាន់តែក្លិនប៉ុណ្ណោះ ក៏ធ្វើឲ្យព្រះរាជាចង់សោយ ធ្វើឲ្យកើតទឹកមាត់ក្នុងព្រះឱស្ឋ លុះដាក់ពំនូតបាយ ១ មាត់ដំបូង ចូលក្នុងព្រះឱស្ឋ សរសៃ ១៧០០០ បីដូចទឹកអម្រឹតពាល់ត្រូវហើយ ចុងភៅគិតថា នឹងប្រទានដល់អញក្នុងកាលឥឡូវនេះ នឹងប្រទានដល់អញក្នុងកាលឥឡូវនេះ ចំណែកព្រះរាជាទ្រង់ព្រះតម្រិះថា ចុងភៅសមគួរដល់សក្ការៈ ហើយទ្រង់ព្រះតម្រិះថា បើអញបានភ្លក្សរសហើយ ឲ្យសក្ការៈ កិត្តិសព្ទមិនល្អក៏នឹងផ្សាយទៅថា ព្រះរាជាអង្គនេះ ជាមនុស្សល្មោភក្នុងរស ដូច្នេះ ទើបមិនត្រាស់ពាក្យណាមួយ ។ តែទោះជាដូច្នោះ បុរសចុងភៅនោះ ក៏នៅតែគិតថា នឹងប្រទានឥឡូវនេះ នឹងប្រទានឥឡូវនេះ រហូតដល់សោយស្រេច ។ ចំណែកព្រះរាជាក៏មិនបានត្រាស់ពាក្យណាមួយ ព្រោះខ្លាចចំពោះការតិះដៀល លំដាប់នោះ ចុងភៅគិតថា ជិវ្ហាវិញ្ញាណរបស់ព្រះរាជានេះ ប្រហែលជាមិនមាន ក្នុងថ្ងៃទី ២ ក៏បង្អោនព្រះក្រយាហារដែលមានរសមិនឆ្ងាញ់ចូលទៅថ្វាយ ។ ព្រះរាជាលុះបានសោយទ្រង់ក៏ជ្រាបថា អ្នកដ៏ចម្រើន ថ្ងៃនេះ ចុងភៅគួរដល់ការតិះដៀលហ្ន៎ តែទ្រង់ពិចារណាដូចក្នុងកាលមុន ទើបមិនបានត្រាស់ពាក្យណាមួយ ព្រោះខ្លាចត្រូវ

តិះដៀល ។ លំដាប់នោះ ចុងភៅគិតថា ព្រះរាជាល្អក៏មិនជ្រាប មិនល្អក៏មិនជ្រាប ទើបកាន់យកគ្រឿងចម្អិនគ្រប់ប្រភេទជារបស់ខ្លួន ប្រើគ្រឿងចម្អិនតាមមានតាមបាន ថ្វាយព្រះរាជា ។ ព្រះរាជាទ្រង់ព្រះតម្រិះថា ឱ ! សេចក្តីលោភអាត្មាអញបរិភោគ គឺគ្រប់គ្រងនូវនគរហូតដល់ ២ ម៉ឺន ក៏មិនបានត្រឹមតែបាយ ព្រោះសេចក្តីលោភរបស់អ្នកជាំស្ងនេះ ទ្រង់នឿយណាយ ទើបលះរាជសម្បត្តិចេញបួស ចម្រើនវិបស្សនា បានធ្វើឲ្យជាក់ច្បាស់នូវបច្ចេកសម្ពោធិញ្ញាណ ហើយពោលគាថានេះ ដោយន័យមុននោះឯង ។

បណ្តាបទទាំងនោះ បទថា **និល្លោលុបោ** ប្រែថា មិនមានសេចក្តីលោភ ។ ពិតហើយ បុគ្គលណាត្រូវចំណង់ក្នុងរសគ្របសង្កត់ បុគ្គលនោះរមែងលោភខ្លាំង លោភហើយលោភទៀត ព្រោះហេតុនោះ ទើបលោកពោលថា **លោលុប** គឺបុគ្គលលោភ ។ ព្រោះហេតុនោះ ព្រះបច្ចេកសម្ពុទ្ធអង្គនេះ កាលបដិសេធថា ព្រះអង្គមិនជាបុគ្គលលោភ ទើបត្រាស់ថា **និល្លោលុប** គឺបុគ្គលមិនមានសេចក្តីលោភ ។ ក្នុងបទថា **និក្កុហោ** នេះ មានអធិប្បាយដូចតទៅនេះថា ហេតុដែលធ្វើឲ្យបោកបញ្ឆោត ៣ យ៉ាង មិនមានដល់បុគ្គលណា បុគ្គលនោះ លោកហៅថា បុគ្គលមិនកុហក ពិតហើយ ទោះជាយ៉ាងនោះ ក្នុងគាថានេះ ឈ្មោះថា មិនកុហក ព្រោះមិនមានការត្រេកអរក្នុងភោជនដែលជាទីពេញចិត្តជាដើម ។ ក្នុងបទថា **និប្បិបាសោ** នេះ ការចង់ផឹក ឈ្មោះថា ការស្រេក ឈ្មោះថា ជាអ្នកមិនស្រេក ព្រោះមិនមានការចង់ផឹកនោះ អធិប្បាយថា ជាអ្នកវៀរចាកបំណង និងបរិភោគ ព្រោះ

លោកក្នុងវេសន្តរ ។ ក្នុងបទថា **និម្មក្ខោ** នេះ ឈ្មោះថា ជាអ្នកមិន លុបគុណគេ ព្រោះមិនមានមក្ខៈ គឺការលុបគុណ ដែលមានការទម្លាយគុណ របស់អ្នកដទៃជាលក្ខណៈ ។ ព្រះបច្ចេកសម្ពុទ្ធ ពោលសំដៅយកការមិនមាន ការលុបគុណអ្នកដាំស្ល ក្នុងកាលដែលទ្រង់នៅជាគ្រហស្ថ ។ ក្នុងបទថា **និទ្ធន្ត-កសាវមោហោ** នេះ ធម៌ ៦ ប្រការ គឺកិលេស ៣ មានរាគៈជាដើម និង ទុច្ចរិត ៣ មានកាយទុច្ចរិតជាដើម គប្បីជ្រាបថា **កសាវ** គឺកិលេសដូច ទឹកចត់ ព្រោះអត្ថថា មិនផូរផង់ ដូចពេលកើត ព្រោះអត្ថថា ធ្វើឲ្យលះភាវៈ របស់ខ្លួនហើយ កាន់យកភាវៈដទៃ និងព្រោះអត្ថថា អាក្រក់គួរខ្ពើម ។ ដូច លោកពោល ( ក្នុងអភិធម្មវិភង្គ ) ថា

> បណ្តាធម៌ទាំងនោះ ទឹកចត់ ៣ តើដូចម្តេច ។ ទឹកចត់ គឺ រាគៈ ១ ទឹកចត់ គឺទោសៈ ១ ទឹកចត់ គឺមោហៈ ១ នេះ ទឹកចត់ ៣ ។
>
> បណ្តាធម៌ទាំងនោះ ទឹកចត់ ៣ ដទៃទៀត តើដូចម្តេច ទឹក ចត់ គឺកាយ ១ ទឹកចត់ គឺវាចា ១ ទឹកចត់ គឺចិត្ត ១ នេះ ទឹកចត់ ៣ ដូច្នេះ ។

បណ្តាកិលេសដូចទឹកចត់ទាំងនោះ ឈ្មោះថា កម្ចាត់បង់មោហៈ ដូច ជាទឹកចត់ ព្រោះជាអ្នកកម្ចាត់កិលេសដូចទឹកចត់ ៥ យ៉ាង វៀរមោហៈ និង ព្រោះជាអ្នកកម្ចាត់មោហៈ ដែលជាមូលរបស់កិលេស ដូចទឹកចត់ ទាំងអស់ នោះ ម្យ៉ាងទៀត ឈ្មោះថា កម្ចាត់បង់មោហៈ ដូចជាទឹកចត់ ព្រោះជាអ្នក

កម្ចាត់ កិលេសដូចទឹកចត់ផ្លូវកាយ វាចា ចិត្ត ៣ នោះឯង និងឈ្មោះថា កម្ចាត់បង់មោហៈ ដូចជាទឹកចត់ ព្រោះជាអ្នកកម្ចាត់មោហៈហើយ ។ ក្នុងកិលេសដូចទឹកចត់ក្រៅពីនេះ កិលេសដូចទឹកចត់ គឺរាគៈ ឈ្មោះថា ត្រូវកម្ចាត់ ដោយការមិនមានលោភៈជាដើម កិលេសដូចទឹកចត់ គឺទោសៈត្រូវកម្ចាត់ ដោយការមិនលុបគុណ ។ បទថា **និរាសយោ** ប្រែថា ជាអ្នកមិនមានតណ្ហា ។ បទថា **សព្វលោកេ ភវិត្វា** សេចក្ដីថា ជាអ្នកវៀរចាកតណ្ហា និងវិភវតណ្ហា ក្នុងលោកទាំងមូល គឺក្នុងភពទាំង ៣ ឬក្នុងអាយតនៈ ១២ ។ ពាក្យដ៏សេស គប្បីជ្រាបដោយន័យដូចពោលហើយនោះឯង ។ ម្យ៉ាងទៀត គួរលើកបាទទាំង ៣ មកភ្ជាប់មួយ សេចក្ដីថា ក្នុងបាទទី ៤ នេះថា ពាក្យថា **ឯកោ ចរេ** គឺអាចត្រាច់ទៅម្នាក់ឯង ដូច្នេះផង ។៚

## អដ្ឋកថា និល្លោលុបគាថា ចប់

# អដ្ឋកថា

## ទាបសហាយគាថា

គាថាថា **ទាបំ សហាយំ** ជាដើម មានអត្ថុប្បត្តិហេតុដូចម្តេច ។

បានឮថា ព្រះរាជាមួយអង្គ ក្នុងនគរពារាណសី ទ្រង់ធ្វើប្រទក្សិណព្រះនគរដោយរាជានុភាពធំ ទ្រង់ឃើញមនុស្សទាំងឡាយនាំយកស្រូវចាស់ជាដើម ចេញអំពីជង្រុកទៅខាងក្រៅ ទើបត្រាស់សួរអមាត្យថា នែអ្នក នេះជាអ្វី ពួកអមាត្យក្រាបទូលថា បពិត្រមហារាជ ឥឡូវនេះ ស្រូវថ្មីជាដើមកើតឡើង ទើបមនុស្សទាំងនេះយកស្រូវចាស់ជាដើមចេញ ដើម្បីនឹងមានទីទំនេរសម្រាប់ស្រូវថ្មីជាដើមនេះ ។ ព្រះរាជាត្រាស់ថា នែបា ស្បៀងរបស់ពួកពលក្នុងជំណាក់ និងស្រីស្នំជាដើម ពេញបរិបូណ៌ឬ ។ ពួកអមាត្យក្រាបទូលថា បពិត្រមហារាជ នៅពេញបរិបូណ៌ព្រះអង្គ ។ ព្រះរាជាត្រាស់ថា នែបា បើយ៉ាងនោះ លោកទាំងឡាយ ចូរសាងរោងទាន យើងនឹងឲ្យទាន ស្រូវទាំងនេះ កុំបីវិនាសទទេ ដោយឥតប្រយោជន៍ ។ លំដាប់នោះ អមាត្យដែលមានការយល់ខុសម្នាក់ ក៏ក្រាបទូលថា បពិត្រមហារាជ ទានដែលឲ្យហើយ មិនមានផល ដូច្នេះហើយ ទើបក្រាបទូលដល់ព្រះរាជាថា បុគ្គលទាំងឡាយ ទោះបីជាពាលក្តី បណ្ឌិតក្តី ស្មុះទៅ អន្ទោលទៅ នឹងធ្វើទីបំផុតនៃទុក្ខបានឯង ដូច្នេះហើយ ទូលហាម ។ ព្រះរាជាទ្រង់ឃើញជង្រុក ត្រូវជញ្ជូនស្រូវចេញលើកទី ២ លើកទី ៣ ក៏ត្រាស់ដូចមុន ។ ទោះបីក្នុងលើកទី ៣ អមាត្យដែលមានគតិក្នុងការឃើញខុសនោះ ក៏នៅពោលពាក្យជាដើមថា បពិត្រមហារាជ ទាននេះ បុគ្គលល្ងង់បញ្ញត្ត ហើយទូលហាមព្រះរាជានោះ ។ ព្រះ

រាជាត្រាស់ថា នែបា សូម្បីរបស់ខ្ញុំ ក៏មិនបានដើម្បីនឹងឲ្យឬ បាបមិត្តទាំងនេះមានប្រយោជន៍អ្វី ទ្រង់នឿយណាយ ទើបលះរាជសម្បត្តិចេញបួស ចម្រើនវិបស្សនា បានធ្វើឲ្យជាក់ច្បាស់នូវបច្ចេកសម្ពោធិញ្ញាណហើយ កាលទ្រង់តិះដៀលបាបមិត្តនោះ ទើបត្រាស់ឧទានគាថានេះ ។

សេចក្ដីដោយសង្ខេបនៃឧទានគាថានោះ មានដូចតទៅនេះ សម្លាញ់នេះឈ្មោះថា អាក្រក់ ព្រោះជាអ្នកប្រកបដោយទិដ្ឋិលាមក ដែលមានវត្ថុ ១០ ប្រការ ឈ្មោះថា អ្នកមិនឃើញនូវសេចក្ដីវិនាស ព្រោះចង់ឃើញនូវការវិនាសរបស់មនុស្សពួកដទៃ និងជាបុគ្គលតាំងមាំនៅក្នុងធម៌ដែលមិនស្មើ មានកាយទុច្ចរិតជាដើម កុលបុត្តអ្នកប្រាថ្នាប្រយោជន៍ បុគ្គលគប្បីវៀរស្រឡះនូវសម្លាញ់អាក្រក់ អ្នកមិនឃើញនូវសេចក្ដីវិនាស អ្នកអាស្រ័យនៅក្នុងកម្មមិនស្មើ ។ បទថា **សយំ ន សេវេ** បានដល់ មិនគប្បីសេពសម្លាញ់នោះតាមសេចក្ដីត្រូវការរបស់ខ្លួន អធិប្បាយថា ព្រោះបើធ្លាក់នៅក្នុងអំណាចរបស់បុគ្គលដទៃហើយ នឹងធ្វើអ្វីបាន ។ បទថា **បសុតំ** បានដល់ ជាអ្នកបណ្ដែតបណ្ដោយខ្លួន អធិប្បាយថា ជាអ្នកជាប់នៅក្នុងអារម្មណ៍នោះៗ ដោយអំណាចទិដ្ឋិ ។ បទថា **បមត្តំ** បានដល់ ជាអ្នកបណ្ដោយចិត្តទៅក្នុងកាមគុណ ៥ ។ ម្យ៉ាងទៀត បានដល់ ជាអ្នកវៀរចាកកុសលភាវនា មិនគប្បីសេព មិនគប្បីគប់រក មិនគប្បីចូលទៅអង្គុយជិតសម្លាញ់នោះ គឺបុគ្គលបែបនោះ ផ្ទុយគ្នា គប្បីជាបុគ្គលម្នាក់ឯង ត្រាច់ទៅដូចកុយរមាស ដូច្នោះ ។

**អដ្ឋកថា ចាបសហាយគាថា ចប់**

# អដ្ឋកថា

## ពហុស្សុតគាថា

គាថាថា **ពហុស្សុតំ** ដូច្នេះជាដើម មានអត្ថុប្បត្តិហេតុដូចម្ដេច ។

ពាក្យទាំងពួង មានពាក្យថា បានឮថា ក្នុងកាលមុន ព្រះបច្ចេកពោធិ-សត្វ ៨ អង្គ បួសក្នុងសាសនារបស់ព្រះមានព្រះភាគកស្សបៈ បំពេញគត-បច្ចាគតវត្ត ហើយកើតឡើងក្នុងទេវលោក ដូច្នេះ ដូចគ្នានឹងពាក្យពោល ហើយ ក្នុងអនវជ្ជភោជីគាថានោះឯង ឯសេចក្ដីប្លែកគ្នាមានដូចតទៅ ព្រះរាជានិមន្តឲ្យព្រះបច្ចេកសម្ពុទ្ធទាំងឡាយ គង់ហើយ ទើបត្រាស់សួរថា លោកទាំងឡាយ ជានរណា ព្រះបច្ចេកសម្ពុទ្ធទាំងនោះទូលថា បពិត្រមហារាជ អាត្មាទាំងឡាយ ឈ្មោះថា ពហុស្សុតៈ ព្រះរាជាទ្រង់ព្រះតម្រិះថា អាត្មាអញ ឈ្មោះថា សុតព្រហ្មទត្ត មិនឆ្អែតក្នុងការស្ដាប់ ណ្ហើយចុះ អញនឹងស្ដាប់ធម្មទេសនាដែលមានន័យដ៏វិចិត្រ ក្នុងសម្នាក់របស់បច្ចេកសម្ពុទ្ធទាំងនោះ កាលទ្រង់ព្រះតម្រិះហើយ ទ្រង់ពេញព្រះហឫទ័យ ថ្វាយទឹកទក្ខិណោទក រួចទ្រង់អង្គាស ក្នុងកាលស្រេចភត្តកិច្ច បានប្រថាប់គង់ក្នុងទីជិតព្រះសង្ឃត្ថេរ ហើយត្រាស់ថា លោកដ៏ចម្រើន សូមលោកម្ចាស់ពោលធម្មកថាចុះ ។ ព្រះបច្ចេកសម្ពុទ្ធពោលថា បពិត្រមហារាជ សូមទ្រង់មានសេចក្ដីក្សេមសម្រាន្ត សូមមានការអស់ទៅនូវរាគៈចុះ ហើយក្រោកឡើង ព្រះរាជាទ្រង់ព្រះតម្រិះថា លោកម្ចាស់អង្គនេះ មិនមែនជាពហុសូត លោកម្ចាស់អង្គទី ២ គង់ជាពហុសូត ស្អែកនេះ អញនឹងបានស្ដាប់ធម្មទេសនាដ៏វិចិត្រ ក្នុងសម្នាក់របស់លោក ទើបនិមន្តឆាន់ក្នុងថ្ងៃស្អែក ។ ព្រះរាជា ទ្រង់និមន្តព្រះបច្ចេកសម្ពុទ្ធ

គ្រប់អន្តតាមលំដាប់ ដោយប្រការយ៉ាងនេះ ព្រះបច្ចេកពុទ្ធទាំងអស់នោះ ក៏ពោលបទដ៏សេសដូចគ្នានឹងអន្តទី ១ ផ្សេងគ្នាត្រឹមតែបទយ៉ាងនេះថា សូមអស់នូវទោសៈចុះ សូមអស់នូវមោហៈចុះ សូមអស់នូវគតិចុះ សូមអស់នូវភពចុះ សូមអស់នូវវដ្តៈចុះ សូមអស់នូវឧបធិចុះ សូមអស់នូវតណ្ហាចុះ ហើយក្រោកទៅ ។ លំដាប់នោះ ព្រះរាជា ទ្រង់ព្រះតម្រិះថា លោកទាំងនេះពោលថា ពួកយើងជាពហុស្សូត តែលោកទាំងនោះ មិនមានគាថាវិចិត្រសោះ លោកទាំងនោះពោលដល់អ្វី ទើបទ្រង់ផ្តើមពិចារណាអត្ថរបស់វាថា នៃព្រះបច្ចេកសម្ពុទ្ធទាំងនោះ កាលទ្រង់ពិចារណាអត្ថរបស់ពាក្យថា សូមអស់នូវរាគៈចុះ ក៏ទ្រង់ជ្រាបថា កាលរាគៈអស់ទៅ ទោសៈក្តី មោហៈក្តី កិលេសដទៃៗក្តី ឈ្មោះថា អស់ទៅដែរ ទ្រង់ពេញព្រះហឫទ័យថា សមណៈទាំងនេះ ជាពហុស្សូតដោយពិត ដូចបុរសយកម្រាមដៃចង្អុលមហាប្រឹថពី ឬអាកាសចង្អុលត្រឹមតែចំណុច ១ ធ្នាប់ ក៏មិនមែន តែស្មើគ្នានឹងចង្អុលមហាប្រឹថពីទាំងមូល ចង្អុលអាកាសទាំងមូលនោះឯង យ៉ាងណា សមណៈទាំងនេះ ក៏យ៉ាងនោះ កាលចង្អុលបង្ហាញអត្ថនីមួយៗ រមែងចង្អុលបង្ហាញអត្ថទាំងឡាយដែលមិនមានប្រមាណ ។ បន្ទាប់អំពីនោះ ទ្រង់ព្រះតម្រិះថា ឈ្មោះថា សូម្បីអាត្មាអញក៏នឹងជាពហុស្សូតយ៉ាងនោះឲ្យបាន កាលទ្រង់ប្រាថ្នាភាពជាពហុស្សូតបែបនោះ ទើបទ្រង់លះរាជសម្បត្តិចេញបួស ចម្រើនវិបស្សនា បានធ្វើឲ្យជាក់ច្បាស់បច្ចេកសម្ពោធិញ្ញាណ ហើយបានពោលឧទានគាថានេះ ។

សេចក្តីសង្ខេបក្នុងឧទានគាថានេះ មានដូចតទៅ

បទថា **ពហុស្សុតំ** សេចក្តីថា ពហូសូតមាន ២ យ៉ាង គឺបរិយត្តិ-ពហូសូត ដែលជំនាញក្នុងព្រះត្រៃបិដក ១ បដិវេធពហូសូត ដែលចាក់ធ្លុះមគ្គ ផល វិជ្ជា និងអភិញ្ញា ១ ។ បុគ្គលមានអាគមដែលមកហើយ ឈ្មោះថា **ធម្មធរោ** ។ ម្យ៉ាងទៀត បុគ្គលប្រកបដោយកាយកម្ម វចីកម្ម និងមនោកម្មដ៏ក្រៃលែង ឈ្មោះថា **ឧឡារោ** ។ បុគ្គលមានយុត្តបដិភាណ ( ឈ្លាសក្នុងការសួរ) មានមុត្តប្បដិភាណ ( ឈ្លាសក្នុងការឆ្លើយ ) និងមានយុត្តមុត្តបដិភាណ ឈ្មោះថា **បដិភាណវា** ។ ម្យ៉ាងទៀត គប្បីជ្រាបបុគ្គលអ្នកមានបដិភាណ ៣ យ៉ាង គឺបរិយត្តិ បរិបុច្ឆា និងអធិគម ។ ពិតហើយ បរិយត្តិរមែងជាក់ច្បាស់ដល់បុគ្គលណា បុគ្គលនោះ ជាអ្នកមានបរិយត្តិប្បដិភាណ គឺឈ្លាសក្នុងបរិយត្តិ ។ ការសាកសួរ ទាក់ទងនឹងអត្ថ ញាណ លក្ខណៈ ឋានៈ និងអដ្ឋានៈ ជាក់ច្បាស់ដល់បុគ្គលណា បុគ្គលនោះជាអ្នកមានបរិបុច្ឆាបដិភាណ គឺឈ្លាសក្នុងការសួរ ។ មគ្គជាដើម ដែលបុគ្គលណាចាក់ធ្លុះហើយ បុគ្គលនោះ ជាអ្នកមានអធិគមប្បដិភាណ គឺឈ្លាសក្នុងការសម្រេច ។ បុគ្គលគប្បីសេពគប់មិត្តនោះ គឺបែបនោះ ដែលជាពហូសូតទ្រទ្រង់នូវធម៌ អ្នកប្រកបដោយគុណដ៏ក្រៃលែង អ្នកមានបដិភាណ ។ បន្ទាប់អំពីនោះ គប្បីស្គាល់ប្រយោជន៍ច្រើនយ៉ាង គឺប្រយោជន៍របស់ខ្លួន ប្រយោជន៍

អ្នកដទៃ និងប្រយោជន៍ទាំង ២ ឬដូចជាទិដ្ឋធម្មិកត្ថប្រយោជន៍ សម្បរាយិកត្ថប្រយោជន៍ និងបរមត្ថប្រយោជន៍ ដោយអានុភាពរបស់មិត្តនោះ បន្ទាប់អំពីនោះ បន្ទោបង់នូវសេចក្តីសង្ស័យ គឺបន្ទោបង់ បានដល់ កម្ចាត់ចោលនូវការសន្ទិះសង្ស័យក្នុងឋានៈ ដែលជាទីតាំងនៃសេចក្តីសង្ស័យ មានជាដើមថា ក្នុងអតីតកាលដ៏យូរលង់ អាត្មាអញមានហើយឬហ្ន៎ជាដើម ជាអ្នកធ្វើកិច្ចទាំងពួងស្រេចហើយ យ៉ាងនេះ ឈ្មោះថា គប្បីជាអ្នកត្រាច់ទៅតែម្នាក់ឯង ដូចកុយរមាស ដូច្នោះ ។ល។

## អដ្ឋកថា ពហុស្សុតគាថា ចប់

# អដ្ឋកថា

## វិក្ខសដ្ឋានគាថា

គាថាថា **ទិដ្ឋំ រតី** ដូច្នេះជាដើម មានអត្ថុប្បត្តិហេតុដូចម្ដេច ។

បានឮថា ព្រះរាជាព្រះនាមវិក្ខសកព្រហ្មទត្ត ក្នុងនគរពារាណសី សោយយាគូ គឺព្រះក្រយាហារអំពីព្រលឹមហើយ ឲ្យជាងប្រដាប់ព្រះកាយដោយគ្រឿងអលង្ការច្រើនប្រភេទ ទ្រង់មើលព្រះសរីរៈទាំងមូល ក្នុងកញ្ចក់ធំ មិនពេញចិត្តវត្ថុណា ក៏យកវត្ថុនោះចេញ ហើយឲ្យប្រដាប់ដោយគ្រឿងអលង្ការដទៃ ។ ថ្ងៃមួយ កាលព្រះអង្គទ្រង់ធ្វើតាមទម្លាប់ ដល់ពេលសោយព្រះក្រយាហារថ្ងៃត្រង់ល្មម ។ ទ្រង់ផ្អាកការតាក់តែង ទើបយកសំពត់ព័ទ្ធព័ន្ធព្រះសិសៈ សោយហើយ ទ្រង់ចូលផ្ទំពេលថ្ងៃ ។ កាលទ្រង់ក្រោកឡើង ទ្រង់ធ្វើយ៉ាងនោះដដែលទៀត ព្រះអាទិត្យក៏លិច ក្នុងថ្ងៃទី ២ ក្នុងថ្ងៃទី ៣ ក៏យ៉ាងនោះ កាលទ្រង់ខ្វល់ខ្វាយតែក្នុងការប្រដាប់យ៉ាងនោះ រោគត្រង់បិដ្ឋិ គឺខ្នងក៏កើតឡើង ទ្រង់មានព្រះតម្រិះថា ឱ ! អញប្រើកម្លាំងទាំងអស់មកប្រដាប់ ក៏មិនពេញចិត្តក្នុងសំពត់គ្រឿងប្រដាប់នេះ ត្រឡប់ធ្វើឲ្យលោភៈ ឈ្មោះថា សេចក្ដីលោភ ជាធម៌ឲ្យទៅអបាយ ណ្ហើយចុះ អញនឹងសង្កត់នូវលោភៈ ទើបទ្រង់លះរាជសម្បត្តិចេញបួស ចម្រើនវិបស្សនា បានធ្វើឲ្យច្បាស់នូវបច្ចេកសម្ពោធិញ្ញាណ ហើយបានត្រាស់ឧទានគាថានេះ

ល្បែង និងតម្រេកក្នុងឧទានគាថានោះ បានពោលមកហើយ ( ក្នុងទិព្វារតិគាថា ) ខាងដើម ។ បទថា **កាមសុខំ** បានដល់ សេចក្ដីសុខក្នុងវត្ថុកាម ។ ពិតហើយ វត្ថុកាមទាំងឡាយ លោកក៏ហៅថា សុខ ព្រោះជា

អារម្មណ៍ជាដើមរបស់សេចក្តីសុខ ដូចលោកពោលថា រូបជាសុខ ធ្លាក់ទៅតាមសេចក្តីសុខ មាន ដូច្នេះ ។ កាលបើយ៉ាងនោះ ទើបលោកមិនធ្វើអើពើ គឺមិនប្រាប់ថា សម នូវការលេង ការត្រេកអរ និងសេចក្តីសុខនេះ ក្នុងលោកនេះ បានដល់ មិនកាន់យ៉ាងនេះថា ការលេងជាដើមនោះ ជាទីឆ្អែតនៃចិត្ត ឬថា ជាសារៈ ។ បទថា **អនបេក្ខមានោ** បានដល់ ជាអ្នកមានប្រក្រតីមិនសម្លឹង គឺមិនប្រាថ្នាច្រើន មិនមាននូវការចង់បាន ព្រោះការមិនធ្វើឲ្យពេញចិត្តនោះ ក្នុងពាក្យថា **វិភូសដ្ឋានា វិរតោ សច្ចវាទី** នោះ ការប្រដាប់ មាន ២ យ៉ាង គឺការប្រដាប់របស់គ្រហស្ថ ១ ការប្រដាប់របស់បព្វជិត ១ ការប្រដាប់ដោយសំពត់ដណ្តប់ សំពត់ជូតក្បាល ផ្កាកម្រង និងគ្រឿងក្រអូបជាដើម ឈ្មោះថា ការប្រដាប់របស់គ្រហស្ថ ។ ការប្រដាប់ ដូចជាតាក់តែងបាត្រជាដើម ឈ្មោះថា ការប្រដាប់របស់បព្វជិត ។ ឋានៈនៃការស្អិតស្អាង គឺការប្រដាប់នោះឯង ។ ព្រោះហេតុនោះ ទើបព្រះបច្ចេកសម្ពុទ្ធវៀរចាកឋានៈនៃការប្រដាប់តាក់តែងនោះ ដោយវិរតិ ៣ យ៉ាង ។ គប្បីជ្រាបអត្ថយ៉ាងនេះថា ឈ្មោះថា អ្នកពោលនូវពាក្យសច្ចៈ ព្រោះពោលនូវពាក្យពិត ៗ។

## អដ្ឋកថា វិភូសដ្ឋានគាថា ចប់

# អដ្ឋកថា

## បុត្តទារគាថា

គាថាថា **បុត្តញ្ច ទារំ** ដូច្នេះជាដើម មានអត្ថុប្បត្តិហេតុដូចម្តេច ។

បានឮថា ឱរសរបស់ព្រះបាទពារាណសីបានទទួលអភិសេកគ្រងរាជសម្បត្តិ ក្នុងកាលនៅក្មេងនោះឯង ទ្រង់សោយសិរិរាជសម្បត្តិ ដូចព្រះបច្ចេកពោធិសត្វដែលពោលហើយក្នុងគាថាទី ១ ថ្ងៃមួយ ទ្រង់ព្រះតម្រិះថា អញគ្រងរាជសម្បត្តិ បង្ករសេចក្តីទុក្ខឲ្យដល់ជនជាច្រើន អញធ្វើបាបនេះដើម្បីអាហារមួយពេលធ្វើអ្វី ណ្ហើយចុះ អញនឹងធ្វើសេចក្តីសុខឲ្យកើតឡើង ទើបទ្រង់លះរាជសម្បត្តិចេញបួស ចម្រើនវិបស្សនា ធ្វើឲ្យជាក់ច្បាស់នូវបច្ចេកសម្ពោធិញ្ញាណហើយ បានពោលឧទានគាថានេះ ។

បណ្តាបទទាំងនោះ បទថា **ធនានិ** បានដល់ រតនៈទាំងឡាយ មានកែវមុក្តា កែវមណី កែវពិទូរ្យ ស័ង្ខ សិលា កែវប្រពាល ប្រាក់ និងមាសជាដើម ។ បទថា **ធញ្ញានិ** បានដល់ បុព្វណ្ណជាតិ ៧ ប្រភេទ មានស្រូវសាលី ស្រូវខ្សាយ ស្រូវជំណើប ស្រងែ ល្ពៅ ស្កួយ និងស្មៅគេលលកជាដើម និងអបរណ្ណជាតិដ៏សេស ។ បទថា **ពន្ធវានិ** បានដល់ ផៅពង្ស ៤ យ៉ាង គឺផៅពង្ស គឺញាតិ ១ ផៅពង្ស គឺគោត្រ ១ ផៅពង្ស គឺមិត្ត ១ ផៅពង្ស គឺអ្នករួមរៀនសិប្ប: ១ ។ បទថា **យថោធិកានិ** បានដល់ ដែលតាំងនៅតាមព្រំដែនរៀងៗ ខ្លួន ។ ពាក្យដ៏សេស មានន័យដូចពោលហើយនោះឯង ។៚

**អដ្ឋកថា បុត្តទារគាថា ចប់**

# អដ្ឋកថា

## សង្គគាថា

គាថាថា **សង្កោ ឃរេសោ** ដូច្នេះជាដើម មានអត្ថុប្បត្តិហេតុដូចម្តេច ។

បានឮថា ក្នុងនគរពារាណសី មានព្រះរាជាព្រះនាម បាទលោលព្រហ្មទត្ត ទ្រង់សោយយាគូ និងព្រះក្រយាហារអំពីព្រលឹម ហើយទតរបាំ ៣ យ៉ាង ក្នុងប្រាសាទទាំង ៣ ។ របាំ មាន ៣ យ៉ាង គឺរបាំដែលមានមកអំពីព្រះរាជាអង្គមុនៗ ១ របាំដែលមានមកអំពីព្រះរាជាបន្ទាប់មក ១ របាំដែលតាំងឡើងក្នុងសម័យរបស់ខ្លួន ១ ។ ថ្ងៃមួយ ទ្រង់យាងទៅកាន់ប្រាសាទ ដែលមានស្រីរបាំវ័យក្មេងអំពីព្រលឹម ស្រីរបាំទាំងនោះគិតថា នឹងធ្វើព្រះរាជាឲ្យត្រេកអរ ទើបនាំគ្នាប្រកបការរាំ ការច្រៀង និងការប្រគំ គួរឲ្យចាប់ចិត្តក្រៃលែង ដូចទេពអប្សរ រាំថ្វាយដល់សក្កទេវរាជ ដូច្នោះ ។ ព្រះរាជាទ្រង់មិនត្រេកអរ ទ្រង់ព្រះតម្រិះថា អ្នករបាំវ័យក្មេង មិនគួរមើល ទើបយាងទៅកាន់ប្រាសាទដែលមានស្រីរបាំវ័យកណ្តាល ស្រីរបាំទាំងនោះ ក៏បានធ្វើយ៉ាងនោះឯង ទ្រង់ក៏មិនត្រេកអរក្នុងស្រីរបាំវ័យកណ្តាលនោះដូចគ្នា ទើបយាងទៅកាន់ប្រាសាទដែលមានស្រីរបាំវ័យចំណាស់ ។ ស្រីរបាំទាំងនោះ ក៏បានធ្វើយ៉ាងនោះ ព្រះរាជាទ្រង់ឃើញការរាំ ដូចរាងឆ្អឹងកំពុងលេង ទ្រង់បានស្តាប់ការច្រៀងមិនពីរោះ ព្រោះស្រីរបាំទាំងនោះ កន្លងព្រះរាជា ២-៣ រជ្ជកាលមកហើយ ទើបជាមនុស្សចាស់ ទើបទ្រង់យាងទៅកាន់ប្រាសាទដែលមានស្រីក្មេងម្តងទៀត រួចយាងទៅកាន់ប្រាសាទ ដែលមានស្រីវ័យកណ្តាលម្តងទៀត ទ្រង់យាងទៅយ៉ាងនេះ ដោយប្រការដូច្នេះ ទ្រង់ក៏មិនត្រេកអរក្នុងប្រាសាទណាមួយ ទ្រង់ក៏ព្រះ

តម្រិះថា ស្រីរបាំទាំងនេះ បំណងនឹងញ៉ាំងអញឲ្យត្រេកអរ ទើបយកកម្លាំងទាំងអស់ប្រកបការរាំ ការច្រៀង និងការប្រគំ ដូចទេពអប្សរទាំងឡាយបំណងនឹងឲ្យសក្កទេវរាជទ្រង់ត្រេកអរ ពេលណា ខ្ញុំនោះមិនសន្ដោស ( ខ្ញុំ ) នឹងញ៉ាំងលោភៈឲ្យចម្រើនឡើង ។ ឈ្មោះថា លោភៈនេះ ជាធម៌ធ្វើឲ្យទៅកាន់អបាយ ណ្ហើយចុះ អញនឹងសង្កត់លោភៈ ទើបលះនូវរាជសម្បត្តិ ហើយទ្រង់ព្រះផ្នួស ចម្រើនវិបស្សនា ធ្វើឲ្យជាក់ច្បាស់នូវបច្ចេកពោធិញ្ញាណ ទើបត្រាស់ឧទានគាថានេះ ។

អត្ថនៃឧទានគាថានោះថា ព្រះរាជាទ្រង់ចង្អុលបង្ហាញនូវគ្រឿងប្រើប្រាស់របស់ព្រះអង្គ ដោយបទថា **សង្គោ ឯសោ** ដូច្នេះជាដើម ។ ព្រោះគ្រឿងប្រើប្រាស់នោះ ឈ្មោះថា **សង្គ** ព្រោះជាទីជាប់ជំពាក់របស់សត្វទាំងឡាយដូចដំរីជាប់ក្នុងភក់ ដូច្នោះ ។ ក្នុងបទថា **បរិត្តមេត្ថ សោខ្យំ** នេះ សេចក្ដីសុខ ឈ្មោះថា បន្តិចបន្តួច ព្រោះអត្ថថា ថោកទាប ព្រោះឲ្យកើតនូវការយល់ខុសក្នុងកាលប្រើប្រាស់កាមគុណ ៥ ឬព្រោះទាក់ទងក្នុងធម៌ ដែលជាកាមាវចរ គឺជារបស់មួងម្កាល ដូចសេចក្ដីសុខក្នុងការមើលរបាំ ដោយពន្លឺនៃផ្លេកបន្ទោរ អធិប្បាយថា ប្រព្រឹត្តទៅមួយជួរខណៈ ។ ក្នុងបទថា **អប្បស្សាទោ ទុក្ខមេវេត្ថ ភិយ្យោ** នេះ សេចក្ដីត្រេកអរណា ដែលត្រាស់ ( ក្នុងមជ្ឈិមនិកាយ មូលបណ្ណាសក ) ថា ម្នាលភិក្ខុទាំងឡាយ សេចក្ដីសុខសោមនស្សកើតឡើង ព្រោះអាស្រ័យកាមគុណ ៥ ប្រការនេះ នេះឯងជាតម្រេករបស់កាមទាំងឡាយ សេចក្ដីត្រេកអរនោះ ត្រាស់ថា ជាទុក្ខក្នុង

ការជាប់ជំពាក់នេះដោយន័យថា ម្នាលភិក្ខុទាំងឡាយ ចុះអ្វីជាទោសរបស់កាមទាំងឡាយ ម្នាលភិក្ខុទាំងឡាយ កុលបុត្តក្នុងលោកនេះ ចិញ្ចឹមជីវិតដោយសេចក្តីប្រឹងប្រែង ដោយសិល្បសាស្រ្តណាមួយ ទោះបីដោយការរាប់ម្រាមដៃទទេក្តី ដោយការរាប់លេខនព្វន្តក្តី ដូច្នេះជាដើម ប្រៀបធៀបហើយ វត្ថុណា គួរពេញចិត្ត វត្ថុនោះ មានតិច ប្រមាណប៉ុនតំណក់ទឹកដោយពិត ទុក្ខនោះឯងមានច្រើនក្រៃលែងជាង ដូចទឹកក្នុងមហាសមុទ្រទាំង ៤ ដោយហេតុនោះ ទើបលោកពោលថា **អប្បស្សាទោ ទុក្ខមេវេត្ថ ភិយ្យោ** ដូច្នេះ ។ បទថា **គណ្ឌោ ឯសោ** សេចក្តីថា ការជាប់ជំពាក់ គឺកាមគុណ ៥ នេះ ប្រៀបដូចសន្ទូច ព្រោះធ្វើឲ្យត្រេកអរ ហើយអូសទាញមក ។ បទថា **ឥតិ ញត្វា មតិមា** សេចក្តីថា បុរសដែលមានការដឹង គឺបណ្ឌិត ដឹងយ៉ាងនេះហើយ គប្បីលះការជាប់ជំពាក់ទាំងអស់នោះ ហើយត្រាច់ទៅតែម្នាក់ឯងដូចកុយរមាស ដូច្នោះ ។ល។

**អដ្ឋកថា សង្គគាថា ចប់**

# អដ្ឋកថា

## សន្ទាលគាថា

គាថាថា **សន្ទាលយិត្វាន** ដូច្នេះជាដើម មានអត្ថុប្បត្តិហេតុដូចម្ដេច ។

បានឮថា ក្នុងនគរពារាណសី មានព្រះរាជាព្រះនាមអនិវត្តព្រហ្មទត្ត ព្រះរាជានោះ បើចូលកាន់សង្គ្រាមហើយ ផ្ដើមធ្វើការកិច្ចដទៃ បើមិនឈ្នះ ឬទ្រង់ផ្ដើមធ្វើការងារដទៃមិនសម្រេច ទ្រង់មិនត្រឡប់ ព្រោះហេតុនោះ ទើបជនទាំងឡាយស្គាល់ទ្រង់យ៉ាងនោះ ។ ថ្ងៃមួយ ទ្រង់យាងទៅកាន់ព្រះរាជ-ឧទ្យាន ។

សម័យនោះ ភ្លើងព្រៃកើតឡើង ភ្លើងនោះឆេះឈើស្ងួត និងស្មៅស្រស់ជាដើម រាលទៅមិនត្រឡប់ឡើយ ។ ព្រះរាជាទ្រង់ឃើញដូច្នោះ ទើបកើតនិមិត្ត ដែលមានភ្លើងព្រៃនោះ ជាគ្រឿងប្រៀបធៀបថា ភ្លើងព្រៃនេះ យ៉ាងណា ភ្លើង ១១ កង[១] ក៏ដូច្នោះដូចគ្នា ឆេះសត្វទាំងពួង រាលទៅមិនត្រឡប់បន្តឲ្យកើតសេចក្ដីទុក្ខធំ បើដូច្នោះ ដើម្បីឲ្យទុក្ខនេះអស់ អញក៏គួរដុតកិលេសទាំងឡាយមិនឲ្យត្រឡប់មក ដោយភ្លើង គឺអរិយមគ្គញាណ ដូចភ្លើងនេះឲ្យបាន ។

បន្ទាប់អំពីនោះ ទ្រង់យាងទៅបន្តិចទៀត បានឃើញអ្នកប្រមង់ កំពុងចាប់ត្រីក្នុងទឹក ត្រីធំមួយចូលទៅខាងក្នុងសំណាញ់របស់អ្នកប្រមង់ទាំងនោះ

---

១- ភ្លើង ១១ កង ភ្លើង គឺរាគៈ ភ្លើង គឺទោសៈ ភ្លើង គឺមោហៈ ភ្លើង គឺជាតិ ភ្លើង គឺជរា ភ្លើង គឺមរណៈ ភ្លើង គឺសោក ភ្លើង គឺបរិទេវៈ ភ្លើង គឺទុក្ខ ភ្លើង គឺទោមនស្ស និងភ្លើង គឺឧបាយាស ។

*បានទម្លាយសំណាញ់គេចទៅ ។ អ្នកប្រមង់ទាំងនោះ ក៏នាំគ្នាបញ្ចេញសំឡេងថា ត្រីទម្លាយសំណាញ់គេចទៅហើយ ព្រះរាជាទ្រង់បានស្តាប់ពាក្យនោះ ទើបទ្រង់កើតនិមិត្តដែលមានត្រីនោះឲ្យជាគ្រឿងប្រៀបធៀបថា បើដូច្នោះ អាត្មាអញគួរទម្លាយសំណាញ់ គឺតណ្ហា និងទិដ្ឋិ គេចទៅ ដោយជាប់ជំពាក់ដោយអរិយមគ្គញាណឲ្យបាន ។ ទើបទ្រង់លះរាជសម្បត្តិបួស ចម្រើនវិបស្សនា បានធ្វើឲ្យជាក់ច្បាស់នូវបច្ចេកពោធិញ្ញាណ ហើយបានពោលឧទានគាថានេះ ។*

*ក្នុងបទទី ២ របស់គាថានោះ វត្ថុដែលធ្វើដោយអំបោះ ហៅថា* **ជាល** *ទឹក ហៅថា* **អម្ពុ។** *ឈ្មោះថា* **អម្ពុចារី** *ព្រោះត្រាច់ទៅក្នុងទឹកនោះ ។ ពាក្យថា* **អម្ពុចារី** *នោះ ជាឈ្មោះនៃត្រី ។ ត្រីក្នុងទឹក ឈ្មោះថា* **សលិលម្ពុចារី** *អធិប្បាយថា ដូចត្រីទម្លាយសំណាញ់គេចទៅក្នុងទឹក ដូច្នោះ ។ ក្នុងបាទទី ៣ ទីដែលត្រូវភ្លើងឆេះ ហៅថា* **ឧឌ្ឍ** *អធិប្បាយថា ភ្លើងរមែងមិនវិលត្រឡប់មកកាន់ទីដែលឆេះហើយ គឺមកកើតត្រង់នោះទៀតមិនបាន យ៉ាងណា អញក៏មិនវិលត្រឡប់មកកាន់ស្ថានទី គឺកាមគុណ ដែលត្រូវដុតដោយភ្លើង គឺមគ្គញាណ គឺមិនមករកកាមគុណនោះទៀត ដូច្នោះ ។ ពាក្យដ៏សេស មានន័យដូចពោលហើយនោះឯង ។*

**អដ្ឋកថា សង្ឃាលគាថា ចប់**

# អដ្ឋកថា

## ឱក្ខិត្តចក្ខុគាថា

គាថាថា **ឱក្ខិត្តចក្ខុ** ដូច្នេះជាដើម មានអត្ថុប្បត្តិហេតុដូចម្តេច ។

បានឮថា ក្នុងនគរពារាណសី ព្រះរាជាព្រះនាមចក្ខុលោលព្រហ្មទត្ត ជាអ្នកខ្វល់ខ្វាយក្នុងការមើលរបាំ ដូចព្រះបាទបាទលោលព្រហ្មទត្តដែរ ឯសេចក្តីប្លែកគ្នាមានដូចតទៅ

ព្រះបាទបាទលោលព្រហ្មទត្តនោះ ជាអ្នកមិនពេញព្រះហឫទ័យ យាងទៅតាមប្រាសាទផ្សេងៗ ឯព្រះបាទចក្ខុលោលព្រហ្មទត្តអង្គនេះ ទតរបាំនោះៗ ទ្រង់ត្រេកអរក្រៃលែង ទ្រង់បន្ថែមនូវចំណង់ ដោយផ្លាស់ប្តូរការទតការសម្តែងរបាំនោះ ។ បានឮថា ទ្រង់ឃើញកិរិយារបស់កុដុម្ពិកៈម្នាក់ ដែលមកមើលការសម្តែង បានញ៉ាំងតម្រេកឲ្យកើតឡើង ។ បន្ទាប់អំពីនោះ ទ្រង់ដល់នូវសេចក្តីសង្វេគ ទើបព្រះតម្រិះថា ឱ! អញចម្រើនតណ្ហា នឹងជាអ្នកពេញក្នុងអបាយណ្ហើយចុះ អញនឹងសង្កត់តណ្ហានោះ ទើបចេញបួស ចម្រើនវិបស្សនា បានធ្វើឲ្យជាក់ច្បាស់នូវបច្ចេកពោធិញាណ កាលទ្រង់ពិចារណាកិច្ចបដិបត្តិដំបូងរបស់ព្រះអង្គ ទើបទ្រង់ត្រាស់ឧទានគាថានេះ ដែលសម្តែងគុណដែលជាបដិបក្ខចំពោះកិច្ចបដិបត្តិនោះ ។ បណ្តាបទទាំងនោះ បទថា **ឱក្ខិត្តចក្ខុ** បានដល់ ជាអ្នកមានចក្ខុដាក់ចុះទៅក្រោយ លោកអធិប្បាយថា ដាក់ចុះនូវឆ្អឹងក ៧ កំណាត់ដោយលំដាប់ សម្លឹងមើលមួយជួរនឹម ដើម្បីនឹងមើលវត្ថុដែលគួរវៀរ និងវត្ថុដែលគួរកាន់យក តែមិនមែនយកឆ្អឹងចង្ការ មកទល់នឹងឆ្អឹងដើមទ្រូង ព្រោះកាលបើយ៉ាងនោះ ក៏មិនជាសមណសារុប្បៈ ។

បទថា **ន ច ចាគលោលោ** សេចក្តីថា មិនដូចបុគ្គលមានជើងរមាស់ ព្រោះចង់ដើរចូលទៅរកពួកជនដោយអាការយ៉ាងនេះ មានបុគ្គលម្នាក់ ទៅឲ្យបានគម្រប់ ២ មានបុគ្គលពីរ ទៅឲ្យបានគម្រប់ ៣ គឺវៀរចាកការត្រាច់ចារិកទៅយូរ និងត្រាច់ចារិកទៅមិនត្រឡប់ ។

បទថា **គុត្តិន្ទ្រិយោ** សេចក្តីថា ជាអ្នកមានឥន្ទ្រិយគ្រប់គ្រង ដោយអំណាចគ្រប់គ្រងឥន្ទ្រិយដ៏សេសអំពីដែលពោលហើយ ព្រោះបណ្តាឥន្ទ្រិយទាំង ៦ ក្នុងទីនេះ លោកចែកមនិន្ទ្រិយដោយឡែក ។

បទថា **រក្ខិតមានសានោ** សេចក្តីថា **មានសានំ** គឺ **មានសំ** នោះឯង ។ ឈ្មោះថា **រក្ខិត** ព្រោះរក្សាចិត្តនោះបាន ។ លោកអធិប្បាយថា ជាអ្នករក្សាចិត្តបានដោយប្រការដែលមិនត្រូវកិលេសប្លន់ ។ បទថា **អនវស្សុតោ** សេចក្តីថា ជាអ្នកវៀរចាកការត្រូវកិលេសលិចស្រោច ក្នុងអារម្មណ៍នោះៗ ដោយកិច្ចបដិបត្តិនេះ ។

បទថា **អបរិឌយ្ហមានោ** បានដល់ មិនត្រូវភ្លើងកិលេសដុត ។ ម្យ៉ាងទៀត បានដល់ មិនត្រូវកិលេសលិចស្រោចខាងក្រៅ មិនត្រូវភ្លើងកិលេសដុតខាងក្នុង ។ ពាក្យដ៏សេស មានន័យដូចពោលហើយនោះឯង ៕

**អដ្ឋកថា ឱក្ខិត្តចក្ខុគាថា ចប់**

# អដ្ឋកថា

## ចារិច្ចត្តកគាថា

គាថាថា **ឱហារយិត្វា** ដូច្នេះជាដើម មានអត្ថុប្បត្តិហេតុដូចម្ដេច ។

បានឮថា ក្នុងនគរពារាណសី មានព្រះរាជាមួយអង្គ ព្រះនាមចាតុមាសិកព្រហ្មទត្ត ទ្រង់យាងទៅប្រពាតឧទ្យានរៀងរាល់ ៤ ខែម្ដង ។ ថ្ងៃមួយ ទ្រង់យាងចូលទៅកាន់ឧទ្យានក្នុងខែកណ្ដាលនៃគិម្ហរដូវ ទ្រង់ឃើញដើមរលួសផ្អុង ដេរដាសដោយស្លឹក មានមែក និងប្រគាប ប្រដាប់ដោយផ្កាត្រង់ទ្វារឧទ្យាន ទ្រង់កាន់យកផ្កាមួយ ហើយយាងចូលទៅកាន់ឧទ្យាន ។ លំដាប់នោះ អមាត្យម្នាក់នៅលើ-កដំរី គិតថា ព្រះរាជាទ្រង់កាន់យកផ្កាដ៏ប្រសើរទៅហើយ ទើបកាន់យកផ្កាមួយដូចគ្នា ។ ពួកពលទាំងអស់ បានកាន់យកដោយឧបាយដូចគ្នា ពួកអ្នកដែលមិនចូលចិត្តផ្កា ក៏បេះស្លឹកកាន់យកទៅ ។ ដើមឈើនោះ អស់ស្លឹក និងផ្កា មានត្រឹមតែដើមប៉ុណ្ណោះ ។ ពេលល្ងាច ព្រះរាជាយាងចេញអំពីឧទ្យាន ទ្រង់ឃើញដូច្នោះ ទើបទ្រង់ព្រះតម្រិះថា ហេតុអ្វី ទើបមនុស្សធ្វើដើមឈើនេះ ( ឲ្យមានសភាពយ៉ាងនេះ ) ពេលដែលអញមកដើមឈើនេះ នៅល្អដោយផ្កា ដូចគ្នានឹងកែវប្រពាល ក្នុងរវាងមែកដែលមានពណ៌ដូចកែវមណី ឥឡូវនេះ បែរជាមិនមានស្លឹក និងផ្កា កាលទ្រង់កំពុងត្រិះរិះ ក៏បានទតឃើញដើមឈើមិនមានផ្កា មានស្លឹកត្រសាយត្រសុំ ក្នុងទីមិនឆ្ងាយអំពីដើមរលួសផ្អុងនោះ កាលទ្រង់ឃើញហើយ មានព្រះតម្រិះដូច្នេះថា ដើមឈើនេះ ព្រោះមែកមានផ្កា ទើបធ្វើឲ្យមនុស្សជាច្រើនចង់បាន ដោយហេតុនោះ ទើបដល់នូវសេចក្ដីវិនាសត្រឹមមួយសម្ទុះ ( ប៉ុណ្ណោះ ) ចំណែក

ដើមឈើមួយទៀត តាំងនៅដដែល ព្រោះមនុស្សមិនចង់បាន ឯរាជសម្បត្តិនេះសោត ក៏មានមនុស្សប្រចង់បាន ដូចដើមឈើមានផ្កា ដូច្នោះ ឯភិក្ខុភាវៈមិនមានមនុស្សប្រចង់បាន ដូចដើមឈើដែលមិនមានផ្កា ព្រោះហេតុនោះ ដរាបណា ដែលរាជសម្បត្តិនេះ មិនទាន់ត្រូវដណ្តើម ដូចដើមឈើនេះ ដរាបនោះ អាត្មាអញនឹងស្លៀកដណ្តប់សំពត់កាសាវៈបួស ដូចដើមល្ហុសផ្អុងដទៃ ដែលមានស្លឹកត្រសាយត្រសុំ ដូច្នោះ ទើបទ្រង់លះរាជសម្បត្តិបួស ចម្រើនវិបស្សនា បានធ្វើឲ្យជាក់ច្បាស់នូវបច្ចេកពោធិញ្ញាណហើយ បានត្រាស់ឧទានគាថានេះ ។

បណ្តាបទទាំងនោះ បាទគាថាថា **កាសាយវត្ថោ អភិនិក្ខមិត្វា** នេះ គប្បីជ្រាបអត្ថយ៉ាងនេះថា ទ្រង់ចេញចាកដំណាក់ ជាអ្នកស្លៀកដណ្តប់សំពត់កាសាវៈ ។ ពាក្យដ៏សេស អាចដឹងច្បាស់បានដោយន័យដូចពោលហើយនោះឯង ព្រោះហេតុនោះ ទើបមិនចាំបាច់ពោលឲ្យពិស្តារឡើយ ។ល។

**អដ្ឋកថា ចារិច្ចត្តកគាថា ចប់**

**វគ្គទី ៣ ចប់**

# អដ្ឋកថា

## រសគេធគាថា

គាថាថា **រសេសុ** ដូច្នេះជាដើម មានអត្ថុប្បត្តិហេតុដូចម្ដេច ។

បានឮថា ព្រះបាទពារាណសីមួយអង្គ មានបុត្តអមាត្យទាំងឡាយចោមរោមក្នុងឧទ្យាន ទ្រង់ក្រសាលក្នុងស្រះបោក្ខរណី ដែលក្រាលដោយផ្ទាំងថ្ម ។ អ្នកដាំស្លរបស់ព្រះអង្គយករសសាច់គ្រប់ប្រភេទមកចម្អិន ក្នុងអន្តរកត្តដែលផ្សំល្អក្រៃលែង ដូចអមតរស ហើយបង្អោនចូលទៅថ្វាយ ។ ទ្រង់ជាប់ក្នុងរសនោះ មិនប្រទានដល់បុគ្គលណា សោយតែមួយព្រះអង្គឯងប៉ុណ្ណោះ ។ ទ្រង់លេងទឹក ទើបយាងត្រឡប់ចេញទៅក្នុងពេលព្រលប់ ហើយប្រញាប់ប្រញាល់សោយ ។ ព្រះអង្គទ្រង់មិននឹកដល់បុគ្គលណាម្នាក់ ដែលធ្លាប់រួមសោយមកអំពីមុន ។ ខាងក្រោយ ទ្រង់ធ្វើការពិចារណា ទ្រង់ជ្រាបថា ឱ ! អញត្រូវចំណង់ក្នុងរសគ្របសង្កត់ ភ្លេចជនទាំងពួង បរិភោគម្នាក់ឯងប៉ុណ្ណោះ បានធ្វើកម្មដ៏លាមកហើយ ណ្ហើយចុះ អញនឹងសង្កត់ចំណង់ក្នុងរសនោះ កាលទ្រង់ត្រិះរិះហើយ ទើបលះរាជសម្បត្តិចេញបួស ចម្រើនវិបស្សនា ធ្វើឲ្យជាក់ច្បាស់នូវបច្ចេកពោធិញ្ញាណ កាលទ្រង់តិះដៀលនូវបដិបត្តិ ដែលមានក្នុងកាលមុនរបស់ព្រះអង្គ ទើបពោលឧទានគាថានេះ ដែលសម្ដែងគុណផ្ទុយនឹងការបដិបត្តិនោះ ។

បណ្ដាបទទាំងនោះ បទថា **រសេសុ** បានដល់ ក្នុងរបស់គួរលិទ្ធភក្ស មានរសជូរ រសផ្អែម រសល្វីង រសហឹរ រសប្រៃ រសខារ រសចត់ជាដើម ។ បទថា **គេធំ អករំ** ប្រែថា មិនធ្វើនូវការចង់បាន អធិប្បាយថា មិនញ៉ាំងនូវតណ្ហាឲ្យកើតឡើង ។

បទថា **អលោលោ** បានដល់ មិនវង្វេងក្នុងការឆ្ងាញ់នៃរសទាំងឡាយ យ៉ាងនេះថា អញនឹងលិទ្ធភក្សវត្ថុនេះ អញនឹងលិទ្ធភក្សវត្ថុនេះ ។

បទថា **អនញ្ញបោសី** បានដល់ មិនឲ្យសទ្ធិវិហារិក ដែលត្រូវចិញ្ចឹមជាដើម អធិប្បាយថា ជាអ្នកសន្ដោសដោយហេតុ ត្រឹមតែទ្រទ្រង់រាងកាយ ។ ម្យ៉ាងទៀត អធិប្បាយថា ឈ្មោះថា **អនញ្ញបោសី** ព្រោះមិនដូចកាលមុន គឺក្នុងឧទ្យាន ដែលខ្ញុំមានប្រក្រតីធ្វើនូវចំណង់ក្នុងរសទាំងឡាយ ឲ្យអ្នកដទៃចិញ្ចឹម លះតណ្ហាដែលជាហេតុឲ្យលោភៈធ្វើចំណង់ក្នុងរសទាំងឡាយ មិនឲ្យអ្នកដទៃចិញ្ចឹម ដោយមិនធ្វើឲ្យកើតអត្តភាពដទៃ ដែលមានតណ្ហាជាឫសគល់ ។ ម្យ៉ាងទៀត ក្នុងបទនេះ មានអត្ថដូចតទៅនេះ កិលេសទាំងឡាយហៅថា **អញ្ញ** ព្រោះអត្ថថា ញ៉ាំងអត្តភាពឲ្យកើត ឈ្មោះថា **អនញ្ញបោសី** ព្រោះមិនចិញ្ចឹមកិលេសទាំងនោះ ។

*បទថា* **សបទានចារី** *បានដល់ មានប្រក្រតីត្រាច់ទៅ មិនគេច ចេញក្រៅផ្លូវ គឺមានប្រក្រតីត្រាច់ទៅដោយលំដាប់ អធិប្បាយថា មិនលះនូវ លំដាប់ផ្ទះ ចូលទៅបិណ្ឌបាតជាប់តគ្នាទៅ ទាំងត្រកូលស្តុកស្តម្ភ និងត្រកូល ក្រីក្រ ។*

*បទថា* **កុលេ កុលេ អប្បដិពទ្ធចិត្តោ** *បានដល់ មានចិត្តមិនជាប់ ជំពាក់ក្នុងត្រកូលក្សត្រជាដើម ត្រកូលណាមួយ ដោយអំណាចកិលេស អធិប្បាយថា ជាអ្នកថ្មីជានិច្ច ឧបមាដូចព្រះចន្ទ ។ ពាក្យដ៏សេស មានន័យ ដូចបានពោលហើយនោះឯង ។ល។*

**អដ្ឋកថា សេគេឍគាថា ចប់**

# អដ្ឋកថា

## អាវរណាគាថា

គាថាថា **បហាយ បញ្ចាវរណានិ** ដូច្នេះជាដើម មានអត្ថុប្បត្តិហេតុដូចម្តេច ។

បានឮថា ព្រះរាជាមួយអង្គ ក្នុងនគរពារាណសី ជាអ្នកបានបឋមជ្ឈាន កាលទ្រង់រក្សាឈាននោះ ទើបទ្រង់លះរាជសម្បត្តិចេញបួស ចម្រើនវិបស្សនា ទ្រង់សម្រេចបច្ចេកពោធិញ្ញាណ កាលសម្តែងបដិបទាក្នុងកិច្ចបដិបត្តិរបស់ព្រះអង្គ ទើបពោលឧទានគាថានេះ ។

បណ្តាបទទាំងនោះ បទថា **បញ្ចាវរណានិ** បានដល់ នីវរណៈ ៥ នោះឯង ។ នីវរណៈ ៥ នោះ ដោយអត្ថ បានពោលហើយក្នុងឧរគសូត្រ ( ក្នុងខុទ្ទកនិកាយ សុត្តនិបាត ) ព្រោះនីវរណៈទាំងនោះរារាំងចិត្ត ដូចពពកជាដើមបិទបាំងព្រះចន្ទ និងព្រះអាទិត្យ ដូច្នោះ ទើបហៅថា ជាគ្រឿងរារាំងចិត្ត អធិប្បាយថា គប្បីលះ គឺលះផ្តាច់នូវនីវរណៈទាំងនោះ ដោយឧបចារសមាធិ ឬអប្បនាសមាធិ ។

បទថា **ឧបក្កិលេសេ** បានដល់ អកុសលធម៌ដែលចូលទៅបៀតបៀនចិត្ត ។ម្យ៉ាងទៀត បានដល់ អភិជ្ឈាជាដើម ដែលពោលក្នុងវត្ថូបមសូត្រ ( វត្ថូបមសូត្រ ) ជាដើម ។

បទថា **ព្យបនុជ្ជ** បានដល់ បន្ទោបង់ អធិប្បាយថា លះដោយវិបស្សនា និងមគ្គ ។ បទថា **សព្វេ** បានដល់ មិនមានសេសសល់ ។ បុគ្គលដល់ព្រមដោយសមថៈ និងវិបស្សនាយ៉ាងនេះ ឈ្មោះថា ដែលតណ្ហា

*និងទិដ្ឋិមិនអាស្រ័យ ព្រោះលះទិដ្ឋិនិស្ស័យបានហើយដោយបឋមមគ្គ ។ កាត់បង់នូវទោស គឺសេចក្តីស្រឡាញ់ អធិប្បាយថា តណ្ហា និងរាគៈដែលប្រព្រឹត្តទៅក្នុងធាតុទាំង ៣ ដោយមគ្គដ៏សេស ។ ពិតហើយ សេចក្តីស្រឡាញ់នោះឯង លោកហៅថា សិនេហទោសៈ ព្រោះជាបដិបក្ខចំពោះគុណ ។ ពាក្យដ៏សេស មានន័យដូចបានពោលហើយនោះឯង ៕*

**អដ្ឋកថា អាវរណគាថា ចប់**

# អដ្ឋកថា

## វិបិដ្ឋិគាថា

គាថាថា **វិបិដ្ឋិកត្វាន** ដូច្នេះជាដើម មានអត្ថុប្បត្តិហេតុដូចម្ដេច ។

បានឮថា ព្រះរាជាមួយអង្គ ក្នុងនគរពារាណសី ជាអ្នកបានចតុត្ថជ្ឈាន ព្រះរាជានោះ ដើម្បីរក្សាឈាន ក៏ទ្រង់លះរាជសម្បត្តិចេញបួស ចម្រើនវិបស្សនា ទ្រង់ធ្វើឲ្យជាក់ច្បាស់នូវបច្ចេកពោធិញ្ញាណ កាលសម្ដែងបដិបទាក្នុងកិច្ចបដិបត្តិរបស់ព្រះអង្គ ទើបពោលឧទានគាថានេះ ។

បណ្ដាបទទាំងនោះ បទថា **វិបិដ្ឋិកត្វាន** ប្រែថា ធ្វើទុកខាងក្រោយ អធិប្បាយថា ចោល គឺលះ ។ បទថា **សុខញ្ច ទុក្ខំ** បានដល់ ដោយសុខនិងទុក្ខផ្លូវកាយ ។ បទថា **សោមនស្សទោមនស្សំ** បានដល់ សេចក្ដីសុខនិងសេចក្ដីទុក្ខផ្លូវចិត្ត ។ បទថា **ឧបេក្ខំ** បានដល់ ឧបេក្ខាក្នុងចតុត្ថជ្ឈាន ។ បទថា **សមថំ** បានដល់ សមាធិក្នុងចតុត្ថជ្ឈាននោះឯង ។ បទថា **វិសុទ្ធំ** សេចក្ដីថា ឈ្មោះថា បរិសុទ្ធក្រៃលែង ព្រោះផុតចាកធម៌ដែលជាសត្រូវ ៩ ប្រការ គឺនីវរណៈ ៥ និងវិតក្ក វិចារៈ បីតី សុខ អធិប្បាយថា ប្រាសចាកឧបក្កិលេស ដូចមាសដែលខាត់ហើយ ។

ឯពាក្យអធិប្បាយប្រកបសេចក្ដី មានដូចតទៅនេះ លះសុខ និងទុក្ខក្នុងកាលមុននោះឯងទុកខាងក្រោយ អធិប្បាយថា លះទុក្ខទុកខាងក្រោយ ក្នុងឧបចារៈនៃបឋមជ្ឈាន ធ្វើនូវសុខទុកខាងក្រោយក្នុងឧបចារៈនៃតតិយជ្ឈាន ។ នាំ ច អក្ខរៈដែលនៅជាមួយពាក្យដើម មកទុកខាងក្រោយផង សម្រេចរូបជា **សោមនស្សំ ទោមនស្សញ្ច វិបិដ្ឋិកត្វាន បុព្វេវ** ធ្វើនូវសោមនស្ស

និងទោមនស្សមុនៗ ទុកខាងក្រោយ ដូច្នេះ ។ ដោយហេតុនោះ ទើបលោកសម្តែងថា ធ្វើសោមនស្សទុកខាងក្រោយក្នុងឧបចារៈនៃចតុត្ថជ្ឈាន និងធ្វើទោមនស្សទុកខាងក្រោយក្នុងឧបចារៈនៃទុតិយជ្ឈាន ។ ពិតហើយ ឈានទាំងនោះ ជាគ្រឿងទ្រុសម្រាប់លះសោមនស្ស និងទោមនស្សដោយអម តែបើពោលដោយត្រង់ បឋមជ្ឈាន ជាបាទសម្រាប់លះនូវទុក្ខ ទុតិយជ្ឈានជាបាទសម្រាប់លះនូវទោមនស្ស តតិយាជ្ឈាន ជាបាទសម្រាប់លះសុខ ចតុត្ថជ្ឈាន ជាបាទសម្រាប់លះនូវសោមនស្ស ។ ដូចលោកពោលថា ពាក្យទាំងពួងថា ព្រះយោគីចូលដល់បឋមជ្ឈាន ទុក្ខិន្ទ្រិយដែលកើតឡើងហើយក្នុងបឋមជ្ឈាននេះ រមែងរលត់ដោយឥតសេសសល់ ដូច្នេះជាដើម លោកពោលហើយក្នុងអដ្ឋកថា ធម្មសង្គហៈ ឈ្មោះអដ្ឋសាលិនី ។ លះបង់ធ្វើទុក្ខទោមនស្ស និងសុខទុកអំពីខាងក្រោយក្នុងឈាន ៣ មានបឋមជ្ឈានដើមដែលហៅថា ក្នុងកាលមុន យ៉ាងណា ក្នុងទីនេះក៏យ៉ាងនោះ លះបង់សោម-នស្សទុកខាងក្រោយ ក្នុងចតុត្ថជ្ឈាន បាននូវឧបេក្ខា និងសមថៈដ៏បរិសុទ្ធដោយបដិបទានេះហើយ គប្បីត្រាច់ទៅតែម្នាក់ឯង ។ ពាក្យដ៏សេស មានន័យដូចពោលហើយនោះឯង ៗ។

## អដ្ឋកថា ខគ្គវិសាណគាថា ចប់

# អដ្ឋកថា

## អារទ្ធវីរិយគាថា

គាថាថា **អារទ្ធវីរិយោ** ដូច្នេះជាដើម មានអត្ថុប្បត្តិហេតុដូចម្ដេច ។

បានឮថា ព្រះរាជាបច្ចន្តប្បទេសមួយអង្គ មានទាហានជាពលនិកាយ ១០០០ នាក់ ជាអ្នកមានរាជសម្បត្តិតូចតាច តែជាអ្នកមានបញ្ញាច្រើន ។ ថ្ងៃមួយ ទ្រង់ព្រះតម្រិះថា អាត្មាអញជាអ្នកមានរាជសម្បត្តិតិចក៏ពិត តែមនុស្សមានបញ្ញា អាចដណ្ដើមយកជម្ពូទ្វីបទាំងមូលបាន ទើបទ្រង់បញ្ជូនទូតទៅកាន់ព្រះរាជាក្បែរខាងថា ខាងក្នុង ៧ ថ្ងៃ ចូរប្រគល់រាជសម្បត្តិឲ្យយើង ឬធ្វើការច្បាំង ។

បន្ទាប់អំពីនោះ ទ្រង់ប្រជុំពួកអមាត្យរបស់ព្រះអង្គ ហើយត្រាស់ថា យើងមិនបានប្រាប់អ្នកទាំងឡាយ ធ្វើកម្មដោយរហ័ស យើងបញ្ជូនសារយ៉ាងនេះទៅឲ្យព្រះរាជានោះហើយ គួរធ្វើដូចម្ដេច ពួកអមាត្យក្រាបទូលថា បពិត្រមហារាជ ទ្រង់ឲ្យទូតនោះត្រឡប់មិនបានឬ ព្រះរាជាត្រាស់ថា មិនបាន ព្រោះទូតទៅហើយ ។ អមាត្យក្រាបទូលថា បើយ៉ាងនោះ ទ្រង់បានធ្វើពួកទូលបង្គំឲ្យវិនាសហើយ ព្រោះការស្លាប់ដោយសស្ត្រារបស់អ្នកដទៃលំបាក ណ្ហើយចុះពួកទូលបង្គំនឹងសម្លាប់គ្នានិងគ្នាឲ្យស្លាប់ សម្លាប់ខ្លួន ចងក និងបរិភោគថ្នាំពិសឲ្យស្លាប់ ។ បណ្ដាអមាត្យទាំងនោះ អមាត្យម្នាក់ៗ ពណ៌នាចំពោះសេចក្ដីស្លាប់ប៉ុណ្ណោះ ដោយប្រការដូច្នេះ ។

លំដាប់នោះ ទើបព្រះរាជាត្រាស់ថា យើងមានប្រយោជន៍អ្វី ដោយអមាត្យទាំងនេះ ទាហានទាំងឡាយរបស់យើងមាន លំដាប់នោះ ទាហាន ១

ពាន់នាក់ក្រោកឡើងក្រាបទូលថា បពិត្រមហារាជ ទូលបង្គំជាទាហាន បពិត្រមហារាជ ទូលបង្គំជាទាហាន ព្រះរាជាទ្រង់ព្រះតម្រិះថា អញនឹងពិសោធទាហានទាំងនេះ ទើបត្រាស់ឲ្យរៀបចំជើងថ្ករធំ ហើយត្រាស់ថា នែអ្នករឿងនេះ យើងធ្វើទៅហើយដោយរួសរាន់ អមាត្យទាំងឡាយជំទាស់យើងក្នុងរឿងនោះ យើងនឹងចូលក្នុងជើងថ្ករ អ្នកណាចូលទៅជាមួយយើងខ្លះ អ្នកណាលះបង់ជីវិតដើម្បីយើងខ្លះ កាលត្រាស់យ៉ាងនេះហើយ ទាហាន ៥០០ ក៏ក្រោកឡើងទូលថា បពិត្រមហារាជ ពួកទូលបង្គំនឹងចូលទៅ ។

លំដាប់នោះ ទើបព្រះរាជាត្រាស់នឹងទាហាន ៥០០ ដ៏សេសថា នែអ្នកទាំងឡាយ ឥឡូវនេះ អ្នកទាំងឡាយដូចម្ដេច ។ ទាហានទាំងនោះក្រាបទូលថា បពិត្រមហារាជ នេះមិនមែនការធ្វើរបស់កូនប្រុស នេះជាការធ្វើរបស់មនុស្សស្រី ម្យ៉ាងទៀត មហារាជក៏បញ្ជូនទូតទៅកាន់ព្រះរាជាដែលជាសត្រូវហើយ ពួកទូលបង្គំនឹងច្បាំងជាមួយព្រះរាជានោះរហូតដល់ស្លាប់ បន្ទាប់អំពីនោះ ទើបព្រះរាជាត្រាស់ថា ពួកអ្នកលះបង់ជីវិតដើម្បីយើង ទើបរៀបចំកងទ័ពដែលប្រកបដោយអង្គ ៤ មានទាហាន ១០០០ នាក់នោះចោមរោម យាងទៅប្រថាប់គង់ក្នុងដែននៃរាជអាណាចក្រ ។

ព្រះរាជាជាសត្រូវនោះ បានស្ដាប់រឿងនោះ ទ្រង់ព្រះពិរោធថា ព្រះរាជាតូចតាចនេះ មិនល្មម ( ប្រយុទ្ធ ) ជាមួយនឹងទាសៈរបស់អញ ទើបនាំពួកពលទាំងអស់ចេញទៅដើម្បីច្បាំង ។

ព្រះរាជាតូចនោះ ឃើញព្រះរាជាដែលជាសត្រូវចេញមក ទើបត្រាស់

នឹងពួកពលថា នែបាទាំងឡាយ ពួកអ្នកមិនមានច្រើន អ្នកទាំងឡាយ ចូររួមគ្នាកាន់ដាវ និងខែល ប្រញាប់តម្រង់ទៅកាន់ព្រះរាជានោះ ទាហានទាំងនោះបានធ្វើយ៉ាងនោះ ។

ពេលនោះ កងទ័ពរបស់ព្រះរាជានោះ បានញែកគ្នាជា ២ ចំណែកឲ្យចន្លោះដល់ទាហានទាំងនោះ ទើបចាប់ព្រះរាជានោះបាន ហើយនាំមកថ្វាយដល់ព្រះរាជារបស់ខ្លួនដែលយាងមក ដោយព្រះបំណងថា នឹងសម្លាប់ព្រះរាជានោះ ។ ព្រះរាជាដែលជាសត្រូវទូលសូមអភ័យនឹងព្រះរាជាតូចនោះ ។ ព្រះរាជាទ្រង់ឲ្យអភ័យដល់ព្រះរាជាដែលជាសត្រូវ ហើយឲ្យធ្វើការស្បថ ទ្រង់ធ្វើឲ្យនៅក្នុងអំណាចរបស់ព្រះអង្គហើយ បែរមុខទៅរកព្រះរាជាអង្គដទៃ ជាមួយព្រះរាជាដែលជាសត្រូវនោះ ទ្រង់បោះព្រះពន្លាត្រង់ព្រំដែន នៃរាជអាណាចក្ររបស់ព្រះរាជានោះ ទ្រង់បញ្ជូនសារទៅថា ឲ្យរាជសម្បត្តិដល់យើង ឬច្បាំង ព្រះរាជានោះបញ្ជូនសារមកថា ខ្ញុំមិនអាចច្បាំងម្នាក់ឯងបាន ហើយប្រគល់រាជសម្បត្តិ ។ ព្រះរាជាតូចចាប់ព្រះរាជាទាំងពួងបានដោយឧបាយនេះ ហើយបានចាប់ព្រះបាទពារាណសីក្នុងព្រះរាជវាំង ។

ព្រះរាជាតូចនោះ ដែលព្រះរាជា ១០១ អង្គចោមរោម ទ្រង់គ្រងរាជសម្បត្តិក្នុងជម្ពូទ្វីបទាំងមូល ទើបទ្រង់ព្រះតម្រិះថា កាលមុនអញជាព្រះរាជាតូច តែឥឡូវនេះ អញជាព្រះរាជាធំនៃមណ្ឌលក្នុងជម្ពូទ្វីបទាំងមូល ព្រោះញាណសម្បត្តិរបស់ខ្លួន តែញាណរបស់អញនោះឯង ប្រកបដោយសេចក្តីព្យាយាមដែលជាលោកិយ រមែងមិនប្រព្រឹត្តទៅដើម្បីការនឿយណាយ ដើម្បី

ប្រាសចាកតម្រេក បើដូច្នោះ អញគប្បីស្វែងរកលោកុត្តរធម៌ដោយញាណនេះ ។

លំដាប់នោះ ទើបទ្រង់ប្រគល់រាជសម្បត្តិដល់ព្រះបាទពារាណសី ឲ្យបុត្ត និងព្រះជាយាទៅនៅក្នុងជនបទ ( ដើម ) របស់ព្រះអង្គ ទ្រង់លះវត្ថុទាំងពួងចេញបួស ចម្រើនវិបស្សនា ធ្វើឲ្យជាក់ច្បាស់នូវបច្ចេកពោធិញ្ញាណកាលសម្ដែងវីរិយសម្បត្តិរបស់ព្រះអង្គ ទើបពោលឧទានគាថានេះ ។

ក្នុងឧទានគាថានោះ គប្បីជ្រាបពាក្យអធិប្បាយដូចតទៅនេះ ឈ្មោះថាជាអ្នកប្រារព្ធសេចក្ដីព្យាយាម ព្រោះមានសេចក្ដីព្យាយាមប្រារព្ធហើយ ។ ដោយបទនេះ លោកសម្ដែងថា លោកជាបុគ្គលមានសេចក្ដីព្យាយាមធំក្រៃលែង ។ ព្រះនិព្វាន លោកហៅថា **បរមត្ថ** ការសម្រេចនិព្វាននោះឈ្មោះថា **បរមត្ថបត្តិ ។** ដើម្បីសម្រេចនិព្វានដែលឈ្មោះថា **បរមត្ថ** នោះ ។ ដោយបទនេះ លោកសម្ដែងដល់ផលដែលគប្បីសម្រេច ដោយការប្រារព្ធសេចក្ដីព្យាយាមនោះ ។

បទថា **អលីនចិត្តោ** នេះ លោកសម្ដែងដល់ការមិនរួញរារបស់ចិត្ត និងចេតសិកដែលមានសេចក្ដីព្យាយាមជាគ្រឿងឧបត្ថម្ភ ដោយបទថា **អកុសីតវុត្តិ** នេះ លោកសម្ដែងដល់ការមិនលិចចុះនៃកាយក្នុងការឈរ និងការចង្រ្កមជាដើម ។

ដោយបទថា **ទឡ្ហនិក្កមោ** នេះ លោកសម្ដែងដល់សេចក្ដីព្យាយាមដែលផ្ដើមតម្កល់ទុកដែលប្រព្រឹត្តទៅយ៉ាងនេះថា **កាមំ តចោ ច ន្ហារុ ច**

ស្បែក សរសៃ សូមឲ្យសល់នៅចុះ ដូច្នេះជាដើម បុគ្គលដែលផ្ដើមតាំងទុកក្នុងអនុបុព្វសិក្ខាជាដើម លោកហៅថា ធ្វើឲ្យជាក់ច្បាស់នូវបរមត្ថសច្ចៈដោយកាយ ម្យ៉ាងទៀត ដោយបទថា **ឧដ្ឋនិក្កមោ** នេះ លោកសម្ដែងដល់សេចក្ដីព្យាយាម ដែលសម្បយុត្តដោយមគ្គ ។ សេចក្ដីព្យាយាមនោះ ឈ្មោះថា **ឧដ្ឋ** ព្រោះដល់នូវភាពបរិបូណ៌នៃការអប់រំ ឈ្មោះថា **និក្កម** ព្រោះចេញចាកសត្រូវ ដោយប្រការទាំងពួង ព្រោះហេតុនោះ បុគ្គលដែលដល់ព្រមដោយសេចក្ដីព្យាយាមនោះ លោកហៅថា **ឧដ្ឋនិក្កម** ព្រោះមានសេចក្ដីព្យាយាមជាគ្រឿងឈានចេញដ៏មាំ ។

បទថា **ថាមពលូបបន្នោ** បានដល់ បុគ្គលដែលប្រកបដោយកម្លាំងនៃកាយ និងកម្លាំងញាណក្នុងខណៈមគ្គ ។ ម្យ៉ាងទៀត បានដល់ បុគ្គលប្រកបដោយពលដែលជាកម្លាំង អធិប្បាយថា ជាអ្នកប្រកបដោយកម្លាំងញាណដ៏មាំទាំ ។

ដោយបទថា **ថាមពលូបបន្នោ** នេះ លោកសម្ដែងដល់ការប្រកបព្រមដោយវិបស្សនាញាណនៃសេចក្ដីព្យាយាមនោះ ទើបធ្វើបធាន គឺសេចក្ដីព្យាយាមជាគ្រឿងប្រកបឲ្យសម្រេច ។ ម្យ៉ាងទៀត គប្បីប្រកបបទទាំង ៣ ដោយសេចក្ដីព្យាយាមដែលជាខាងដើម កណ្ដាល និងឧក្រិដ្ឋ ។ ពាក្យដ៏សេស មានន័យដូចបានពោលហើយនោះឯង ។៙

**អដ្ឋកថា អារទ្ធវីរិយគាថា ចប់**

# អដ្ឋកថា

## បដិសល្លានគាថា

គាថាថា **បដិសល្លានំ** ដូច្នេះជាដើម មានអត្ថុប្បត្តិហេតុដូចម្តេច ។

ការកើតឡើងនៃគាថានេះ ដូចអាវរណគាថា មិនមានសេចក្តីផ្សេងគ្នាណាឡើយ ឯពណ៌នាអត្ថនៃគាថានេះ មានដូចតទៅនេះថា ការត្រឡប់ចាកពួកសត្វ និងសង្ខារនោះៗ ពួនសម្ងំ ឈ្មោះថា **បដិសល្លាន** បានដល់ ភាពជាអ្នកនៅក្នុងសមគួរ នាចំណែកម្ខាង គឺភាពជាបុគ្គលម្នាក់ឯង បានដល់កាយវិវេក ។

ចិត្តវិវេក លោកហៅថា **ឈាន** ព្រោះដុតកិលេស ដូចសត្រូវ និងព្រោះចូលទៅសម្ងឹងដោយអារម្មណូបនិជ្ឈាន និងលក្ខណូបនិជ្ឈាន ។

ក្នុងពាក្យថា **ឈាន** នោះ សមាបត្តិ ៨ ហៅថា **ឈាន** ព្រោះដុតកិលេស ដូចសត្រូវ មាននីវរណៈជាដើម និងព្រោះចូលទៅសម្ងឹងអារម្មណ៍មានកសិណជាដើម ។ វិបស្សនា មគ្គ ផល ក៏ហៅថា ឈាន ព្រោះដុតកិលេសដូចជាសត្រូវ មានសត្តសញ្ញា សម្គាល់ថា សត្វជាដើម និងព្រោះចូលទៅសម្ងឹងលក្ខណៈ ។ តែក្នុងទីនេះ លោកបំណងយកអារម្មណូបនិជ្ឈានប៉ុណ្ណោះ ។

មិនលះ គឺមិនបោះបង់ បានដល់ មិនលះបង់នូវការពួនសម្ងំ និងឈាននោះ ដោយអាការយ៉ាងនោះ ។ បទថា **ធម្មេសុ** បានដល់ ក្នុងធម៌ គឺបញ្ចក្ខន្ធជាដើមដែលឲ្យចូលដល់វិបស្សនា ។ បទថា **និច្ចំ** បានដល់ ជាប់ត គឺរឿយៗ បានដល់ ប្រឡូកប្រឡំ ។

បទថា **អនុធម្មចារី** បានដល់ ប្រព្រឹត្តវិបស្សនាធម៌ដែលទៅហើយរឿយៗ ដោយប្រារព្ធធម៌នោះៗ ប្រព្រឹត្តទៅ ។ ម្យ៉ាងទៀត ក្នុងបទថា **ធម្មេសុ** នេះ លោកុត្តរធម៌ ៩ ឈ្មោះថា **ធម៌** ។ ឈ្មោះថា អនុធម៌ ព្រោះជាធម៌ដែលអនុលោមដល់ធម៌ទាំងនោះ ។ ពាក្យថា អនុធម្មចារី នេះ ជាឈ្មោះនៃវិបស្សនា ។ ក្នុងគាថានោះ កាលគួរនឹងពោលថា **ធម្មានំ និច្ចំ អនុធម្មចារី** តែបែរជាពោលថា **ធម្មេសុ ( និច្ចំ អនុធម្មចារី )** ដើម្បីងាយស្រួលក្នុងការចងគាថា ព្រោះលោកជាអ្នកឈ្លាសក្នុងវិភត្តិ ។ ក្នុងបទថា **អាទីនវំ សម្មសិតា ភវេសុ** នេះ គប្បីជ្រាបវាចាប្រកបសេចក្តីយ៉ាងនេះ ពិចារណាឃើញទោសមានការមិនទៀងជាដើមក្នុងភពទាំង ៣ ដោយវិបស្សនា ពោល គឺភាពជាអ្នកមានប្រក្រតីប្រព្រឹត្តដ៏សមគួរដល់ធម៌នោះ គប្បីពោលថា ជាអ្នកសម្រេចដោយបដិបទា គឺវិបស្សនាដែលដល់កំពូលនៃកាយវិវេក និងចិត្តវិវេកនេះ ដោយអាការយ៉ាងនេះ គប្បីជាបុគ្គលម្នាក់ឯង ត្រាច់ទៅ ៕ ១០

## អដ្ឋកថា បដិសល្លានគាថា ចប់

# អដ្ឋកថា

## តណ្ហាក្ខយគាថា

គាថាថា **តណ្ហាក្ខយំ** ដូច្នេះជាដើម មានអត្ថុប្បត្តិហេតុដូចម្តេច ។

បានឮថា ព្រះបាទពារាណសីមួយអង្គ ធ្វើប្រទក្សិណព្រះនគរ ដោយរាជានុភាពធំ មនុស្សទាំងឡាយ ជាអ្នកជាប់ចិត្តក្នុងការស្អាតនូវព្រះរូបរបស់ព្រះរាជានោះ សូម្បីដើរទៅខាងមុខក៏គង់ត្រឡប់មកសម្លឹងមើលព្រះអង្គ សូម្បីដើរទៅខាងក្រោយក្តី ទៅដោយចំហៀងទាំង ២ ក្តី ក៏នៅតែងាកមកមើលព្រះអង្គ ។ តាមប្រក្រតីសត្វលោកមិនឆ្អែតក្នុងការមើលព្រះពុទ្ធ និងក្នុងការមើលព្រះចន្ទពេញវង់ សមុទ្រ និងព្រះរាជា ។

កាលនោះ ភរិយារបស់កុដុម្ពិកៈម្នាក់ នៅក្នុងប្រាសាទជាន់លើ បានបើកបង្អួចឈរមើល ព្រះរាជាទ្រង់ឃើញស្ត្រីនោះ មានព្រះហឫទ័យប្រតិព័ទ្ធ ក៏ត្រាស់នឹងអមាត្យថា នែអ្នក ចូរទៅស៊ើបមើលថា ស្រីនោះ មានប្តី ឬមិនមានប្តី ។ អមាត្យនោះដឹងហើយ ទើបក្រាបទូលថា បពិត្រព្រះអង្គ ស្រីនោះមានប្តីហើយ ។

ពេលនោះ ព្រះរាជាទ្រង់ព្រះតម្រិះថា ស្រីស្នំ ២ ម៉ឺននាក់ ប្រៀបដូចទេពអប្សរ ញុំាងអញម្នាក់ប៉ុណ្ណោះឲ្យអភិរម្យ ឥឡូវនេះ អញមិនត្រេកអរក្នុងស្រីទាំងនេះ មកធ្វើតណ្ហាឲ្យកើតឡើងក្នុងស្រីរបស់បុរសដទៃ តណ្ហានោះកើតឡើងហើយ រមែងអូសទៅកាន់អបាយតែម្យ៉ាង ដូច្នេះ ទ្រង់ឃើញទោសនៃតណ្ហាហើយ ទ្រង់ព្រះតម្រិះថា នឹងសង្កត់តណ្ហានោះ ទើបលះរាជសម្បត្តិបួស ចម្រើនវិបស្សនា ធ្វើឲ្យជាក់ច្បាស់នូវបច្ចេកពោធិញ្ញាណ ហើយបាន

ពោលឧទានគាថានេះ ។

បណ្តាបទទាំងនោះ បទថា **តណ្ហក្ខយំ** បានដល់ ព្រះនិព្វាន ម្យ៉ាងទៀត បានដល់ ការមិនប្រព្រឹត្តទៅនៃតណ្ហាដែលមានទោស ដែលប្រាកដ ដែលប្រាកដច្បាស់នោះ ។

បទថា **អប្បមត្តោ** បានដល់ មានប្រក្រតីធ្វើជាប់ត គឺមានប្រក្រតីធ្វើដោយគោរព ។

បទថា **អនេលមូគោ** បានដល់ ជាអ្នកមិនមានទឹកមាត់ត្រង់មាត់ ។ ម្យ៉ាងទៀត បានដល់ មិនជាមនុស្សឆ្កួត និងមនុស្សគ អធិប្បាយថា ជាបណ្ឌិត ជាអ្នកមុតស្រួច ។

ឈ្មោះថា **សុតវា** ព្រោះមានសុតៈ ដែលញ៉ាំងហិតសុខឲ្យដល់ព្រម អធិប្បាយថា ជាអ្នកសម្បូរដោយបរិយត្តិ ។

បទថា **សតីមា** បានដល់ ជាអ្នករឭកដល់វត្ថុដែលធ្វើយូរជាដើមបាន ។ បទថា **សង្ខាតធម្មោ** បានដល់ ជាអ្នកមានធម៌កំណត់ដឹង ដោយការចូលទៅពិចារណាធម៌ ។ បទថា **និយតោ** បានដល់ ជាអ្នកដល់នូវភាពជាអ្នកទៀង ដោយអរិយមគ្គ ។ បទថា **បធានវា** បានដល់ ជាអ្នកដល់ព្រមដោយការព្យាយាមជាគ្រឿងតាំងទុកដោយប្រពៃ ។ គប្បីប្រកបបាឋៈនេះ ខាងមុខដោយក្រៅលំដាប់ គឺ ( មុនពាក្យដទៃ ) ។

បុគ្គលប្រកបដោយធម៌ មានការមិនប្រមាទជាដើមនោះ ដោយប្រការយ៉ាងនេះ ជាអ្នកមានសេចក្តីខ្មីឃ្មាត ដោយសេចក្តីព្យាយាម ដោយដែលឲ្យ

ដល់នូវភាពទៀង ជាបុគ្គលទៀង ដោយការទៀងដែលដល់ព្រមដោយសេចក្ដីព្យាយាមនោះ បន្ទាប់អំពីនោះ ឈ្មោះថា ជាអ្នកមានធម៌ពិចារណាហើយ ព្រោះបានសម្រេចអរហត្ត ពិតហើយ ព្រះអរហន្តទាំងឡាយ លោកហៅថា ជាអ្នកមានធម៌ដែលពិចារណាស្រេចហើយ ព្រោះមិនមានធម៌ ដែលត្រូវពិចារណាទៀត ។ ដូចលោកពោល ( ក្នុងខុទ្ទកនិកាយ សុត្តនិបាត ) ថា ពួកអសេក្ខបុគ្គល អ្នកមានធម៌ពិចារណាហើយ និងពួកសេក្ខបុគ្គល ជាច្រើនណា ក្នុងសាសនានេះ ដូច្នេះ ។ ពាក្យដ៏សេស មានន័យដូចពោលហើយនោះឯង ៕

**អដ្ឋកថា តណ្ហាក្ខយគាថា ចប់**

# អដ្ឋកថា

## សីហានិគាថា

គាថាថា **សីហោវ** ដូច្នេះជាដើម មានអត្ថុប្បត្តិហេតុដូចម្ដេច ។

បានឮថា ព្រះបាទពារាណសីមួយអង្គ មានឧទ្យាននៅក្នុងទីឆ្ងាយ ទ្រង់តើនឡើងអំពីព្រលឹម យាងទៅកាន់ឧទ្យាន ក្នុងរវាងផ្លូវ ទ្រង់ចុះអំពីយាន ចូលទៅកាន់ទីដែលមានទឹក ដោយបំណងថា នឹងលុបព្រះភក្ត្រ ។ ក្នុងទីនោះ មានសីហៈញីកើតកូន ហើយក៏ចេញទៅរកចំណី ។ រាជបុរសឃើញកូនសីហៈនោះហើយ ទើបក្រាបទូលថា បពិត្រព្រះសម្មតិទេព នេះកូនសីហៈ ព្រះរាជាទ្រង់ព្រះតម្រិះថា បានឮថា សីហៈមិនខ្លាចនរណា ដើម្បីសាកល្បងកូនសីហៈនោះ ទើបឲ្យវាយស្គរជាដើម កូនសីហៈសូម្បីបានឮសំឡេងនោះ ក៏នៅដេកបែបនោះ កាលបើដូច្នោះ ទើបព្រះរាជាទ្រង់ឲ្យវាយស្គរលើកទី ៣ ក្នុងលើកទី ៣ កូនសីហៈនោះអើតក្បាលឡើង មើលបរិស័ទទាំងអស់ ហើយក៏ដេកយ៉ាងនោះឯង ។

លំដាប់នោះ ព្រះរាជាត្រាស់ថា ចូរពួកយើងគេចទៅមុន ទាន់មេរបស់វាមិនទាន់មក ខណៈយាងទៅ ទ្រង់ព្រះតម្រិះថា កូនសីហៈ សូម្បីកើតក្នុងថ្ងៃនោះ ក៏មិនតក់ស្លុត មិនខ្លាច កាលណាហ្ន៎ អញគប្បីលះបង់នូវការខ្លាច គឺតណ្ហា និងទិដ្ឋិ ហើយមិនតក់ស្លុត មិនខ្លាច ។

ព្រះរាជាកាន់យករឿងនោះឲ្យជាអារម្មណ៍យាងទៅ ទ្រង់ឃើញអ្នកប្រមង់ចាប់ត្រី ហើយហាលសំណាញ់ត្រង់មែកឈើ ខ្យល់បក់មក មិនជាប់ត្រង់សំណាញ់ដែលសន្ទឹង ទ្រង់បានកាន់យកនិមិត្តក្នុងរឿងនោះទៀតថា បើដូច្នោះ

អញគួរហែកសំណាញ់ គឺតណ្ហា ទិដ្ឋិ និងមោហៈ ហើយមិនជាប់ជំពាក់យ៉ាងនោះ ហើយទៅ ។

កាលនោះ ព្រះរាជាទ្រង់យាងទៅកាន់ឧទ្យាន ប្រថាប់គង់ត្រង់ប្រាំងស្រះបោក្ខរណី មានផ្ទាំងថ្ម ទ្រង់ឃើញផ្កាឈូកដែលត្រូវខ្យល់ប៉ះខ្ទប់ ទើបឱនទៅក្នុងទឹក ហើយផុសមកវិញ ក្នុងកាលដែលប្រាសចាកខ្យល់ មិនសើមដោយទឹក ទ្រង់បានកាន់យកនិមិត្តក្នុងសេចក្ដីនោះថា បើដូច្នោះ អាត្មាអញកើតមកហើយក្នុងលោក ក៏គួរតាំងនៅដោយមិនឲ្យលោកបូកលាបបាន ដូចឈូកទាំងនេះ កើតក្នុងទឹក តែតាំងនៅដោយទឹកប្រឡាក់មិនបាន ។

ទ្រង់ព្រះតម្រិះរឿយៗ ថា អាត្មាអញ គប្បីជាអ្នកមិនតក់ស្លុត មិនជាប់ជំពាក់មិនត្រូវបូកលាប ដូចសីហៈ ខ្យល់ និងផ្កាឈូក ទើបទ្រង់លះរាជ-សម្បត្តិបួស ចម្រើនវិបស្សនា ធ្វើឲ្យជាក់ច្បាស់នូវបច្ចេកពោធិញ្ញាណហើយបានពោលឧទានគាថានេះ ។

ឈ្មោះថា **សីហា** ក្នុងគាថានោះ សីហៈមាន ៤ ពួក គឺតិណសីហៈ ១ បណ្ឌុសីហៈ ១ កាឡសីហៈ ១ កេសរសីហៈ ១ ។ បណ្ដាសីហៈទាំងនោះ កេសរសីហៈ លោកពោលថា ប្រសើរ កេសរសីហៈនោះ លោកបំណងយកក្នុងទីនេះ ។ ខ្យល់មានច្រើនយ៉ាង ដូចជាខ្យល់ទិសខាងកើតជាដើម ។ ផ្កាឈូកមានច្រើនយ៉ាង ដូចជាផ្កាឈូកពណ៌ក្រហម និងពណ៌សជាដើម ។ បណ្ដាខ្យល់ និងផ្កាឈូកទាំងនោះ ខ្យល់ប្រភេទណាមួយ និងឈូកប្រភេទណាមួយ ក៏គួរនោះឯង ។ ព្រោះហេតុថា បណ្ដាការតក់ស្លុតជាដើមនោះ ឈ្មោះ

ថា ការតក់ស្លុត មាន ព្រោះស្រឡាញ់ខ្លួន ដែលជម្មតា ការស្រឡាញ់ខ្លួន ជាការប្ញុកលាបដោយតណ្ហា មាន ក៏ព្រោះសេចក្តីលោភ ដែលប្រកបដោយទិដ្ឋិខ្វះ ប្រាសចាកទិដ្ឋិខ្វះ សេចក្តីស្រឡាញ់ខ្លួននោះ គឺតណ្ហានោះឯង ។

ម្យ៉ាងទៀត ការជាប់ជំពាក់រមែងមានដល់បុគ្គល ដែលខ្វះការពិចារណាជាដើមក្នុងអារម្មណ៍នោះ ព្រោះមោហៈ ។ មោហៈ គឺអវិជ្ជានោះឯង ។ ក្នុងតណ្ហា និងអវិជ្ជា នោះ លះតណ្ហាដោយសមថៈ លះអវិជ្ជាដោយវិបស្សនា ។

ព្រោះហេតុនោះ គប្បីលះសេចក្តីស្រឡាញ់ខ្លួនដោយសមថៈ ហើយមិនតក់ស្លុតក្នុងលក្ខណៈទាំងឡាយ មានអនិច្ចលក្ខណៈ និងទុក្ខលក្ខណៈជាដើម ដូចសីហៈ មិនតក់ស្លុតក្នុងសំឡេងទាំងឡាយ លះមោហៈដោយវិបស្សនា មិនជាប់ក្នុងខន្ធ និងអាយតនៈជាដើម ដូចខ្យល់មិនជាប់នឹងសំណាញ់ លះលោភៈ និងទិដ្ឋិដែលប្រកបដោយលោភៈ ដោយសមថៈដូចគ្នា មិនប្រឡាក់ដោយលោភៈ ក្នុងភវសម្បត្តិទាំងពួង ដូចផ្កាឈូក មិនប្រឡាក់ដោយទឹក ដូច្នោះ ។

បណ្តាធម៌ទាំងនេះ សីលជាបទដ្ឋាននៃសមថៈ សមថៈជាបទដ្ឋាននៃសមាធិ សមាធិជាបទដ្ឋាននៃវិបស្សនា រួមសេចក្តីថា កាលធម៌ ២ ប្រការសម្រេចហើយ ខន្ធ គឺគុណទាំង ៣ រមែងជាការសម្រេចបានពិត បណ្តាខន្ធគឺគុណទាំងនោះ បុគ្គលរមែងជាអ្នកក្លៀវក្លាដោយសីលក្ខន្ធ ។

បុគ្គលនោះ រមែងមិនតក់ស្លុត ដូចសីហៈ មិនតក់ស្លុតក្នុងសំឡេងទាំងឡាយ ព្រោះសីហៈនោះ ចូលចិត្តក្រោធក្នុងសំឡេងដែលជាអាឃាតវត្ថុ

*បុគ្គលដែលមានសភាវៈដែលចាក់ធ្លុះ ហើយដោយបញ្ញាខន្ធ រមែងមិនជាប់ជំពាក់ក្នុងប្រភេទនៃធម៌ មានខន្ធជាដើម ដូចខ្យល់ មិនជាប់ក្នុងសំណាញ់ ជាបុគ្គលមានរាគៈទៅប្រាសហើយ ដោយសមាធិក្ខន្ធ រមែងមិនប្រឡាក់ដោយរាគៈ ដូចផ្កាឈូក មិនប្រឡាក់ដោយទឹក ដូច្នោះ ។*

*កាលបើយ៉ាងនោះ បណ្ឌិតគប្បីជ្រាបបុគ្គលដែលមិនតក់ស្លុត មិនជាប់ និងមិនប្រឡាក់ ដោយអំណាចការលះតណ្ហា អវិជ្ជា និងអកុសលមូល ៣ ដែលមានដោយសមថៈ និងវិបស្សនា និងដោយសីលក្ខន្ធ សមាធិក្ខន្ធ និងបញ្ញាក្ខន្ធ ។ ពាក្យដ៏សេស មានន័យដូចពោលហើយនោះឯង ។៚*

**អដ្ឋកថា សីហាទិគាថា ចប់**

# អដ្ឋកថា

## ឆាបពលីគាថា

គាថាថា **សីហោ យថា** ដូច្នេះជាដើម មានអត្ថុប្បត្តិហេតុដូចម្តេច ។

បានឮថា ព្រះបាទពារាណសីមួយអង្គ ដើម្បីនឹងញ៉ាំងជនបទជាយដែន ដែលកម្រើកឲ្យស្ងប់ ទើបទ្រង់រៀបការធ្វើដំណើរតាមលំដាប់នៃស្រុក យាង តាមផ្លូវកាត់ក្នុងព្រៃ ដែលជាផ្លូវត្រង់ យាងទៅដោយកងទ័ពធំ ។

សម័យនោះ ត្រង់ជើងភ្នំមួយកន្លែង មានរាជសីហ៍ដេកយកកម្តៅព្រះ អាទិត្យដែលស្រទន់ ។ រាជបុរសទាំងឡាយឃើញរាជសីហ៍នោះ ក៏ក្រាបទូល ដល់ព្រះរាជា ។ ព្រះរាជាទ្រង់ព្រះតម្រិះថា បានឮថា រាជសីហ៍មិនតក់ស្លុត ទើបឲ្យធ្វើសំឡេង មានសំឡេងស្គរធំ និងស្គរតូចជាដើម រាជសីហ៍ក៏នៅតែ ដេកដដែល ទ្រង់ឲ្យធ្វើសំឡេងលើកទី ២ រាជសីហ៍ក៏នៅតែដេកដដែល ទ្រង់ឲ្យធ្វើសំឡេងលើកទី ៣ ។ កាលនោះ រាជសីហ៍គិតថា គង់មានសត្រូវ ទើបឈរយ៉ាងមាំដោយជើងទាំង ៤ ហើយបន្លឺសីហនាទ ។ ហ្មដំរីជាដើម បានស្តាប់សំឡេងសីហនាទនោះ ក៏ចុះពីកដំរីជាដើម គេចចូលទៅពួនត្រង់គុម្ព ស្មៅ ។ ពួកសេះ និងដំរីផ្សេងៗ រត់ខ្ចាយខ្ចាយទៅគ្រប់ទិស ដំរីរបស់ព្រះ រាជា ក៏នាំព្រះរាជាវែកពួកឈើ និងព្រៃគេចទៅ ព្រះរាជាមិនអាចគង់លើដំរី នោះបាន ទ្រង់តោងមែកឈើ ហើយទម្លាក់ខ្លួនមកលើផែនដី យាងទៅតាមផ្លូវ ដែលដើរបានតែម្នាក់ ដល់ទីដែលជាលំនៅរបស់ព្រះបច្ចេកសម្ពុទ្ធទាំងឡាយ ទ្រង់បានត្រាស់សួរព្រះបច្ចេកសម្ពុទ្ធទាំងឡាយ ក្នុងទីនោះថា បពិត្រលោក ម្ចាស់ៗ ទាំងឡាយ បានឮសំឡេងខ្លះដែរឬទេ ព្រះបច្ចេកសម្ពុទ្ធទាំងឡាយ

ទូលថា សូមថ្វាយព្រះពរ បានឮព្រះរាជាត្រាស់ថា បពិត្រលោកម្ចាស់ សំឡេងអ្វី ព្រះបច្ចេកសម្ពុទ្ធត្រាស់ថា ដំបូងជាសំឡេងស្គរ និងសំឡេងស័ង្ខជាដើម ក្រោយមក ជាសំឡេងរាជសីហ៍ ។ ព្រះរាជាត្រាស់ថា បពិត្រលោកម្ចាស់ៗ ទាំងឡាយមិនខ្លាចទេឬ ព្រះបច្ចេកសម្ពុទ្ធទាំងឡាយពោលថា បពិត្រមហារាជ អាត្មាទាំងឡាយ មិនខ្លាចចំពោះសំឡេងណាមួយឡើយ ។ ព្រះរាជាត្រាស់ថា បពិត្រលោកម្ចាស់ៗ អាចធ្វើខ្ញុំឲ្យជាបុគ្គលបែបនោះបានដែរឬទេ ព្រះបច្ចេកសម្ពុទ្ធទាំងឡាយពោលថា អាច បើទ្រង់បួស ព្រះរាជាត្រាស់ថា បពិត្រលោកម្ចាស់ ខ្ញុំនឹងបួស ។ លំដាប់នោះ ព្រះបច្ចេកសម្ពុទ្ធទាំងឡាយ ឲ្យព្រះរាជាបួសហើយ ឲ្យសិក្សាអភិសមាចារិកវត្ត ដោយន័យដូចពោលហើយខាងដើមនោះឯង ព្រះរាជាចម្រើនវិបស្សនា ដោយន័យដូចពោលហើយក្នុងកាលមុនដូចគ្នា ធ្វើឲ្យជាក់ច្បាស់នូវបច្ចេកពោធិញ្ញាណហើយ បានពោលឧទានគាថានេះ ។

ដែលឈ្មោះថា **សីហា** ក្នុងគាថានោះ ព្រោះអត់ធន់ ព្រោះសម្លាប់ និងព្រោះស្ទុះទៅដោយរហ័ស ។ ក្នុងទីនេះ បំណងយកកេសរសីហៈដូចគ្នា ។ ឈ្មោះថា **ទាឋពលី** ព្រោះសីហៈនោះ មានចង្កូមជាកម្លាំង ។

២ បទ គឺ **បសយ្ហ អភិភុយ្យ** គប្បីប្រកបជាមួយសព្ទ **ចារី** ជា **បសយ្ហចារី អភិភុយ្យចារី** ។ ក្នុង ២ បទនោះ ឈ្មោះថា **បសយ្ហចារី** ព្រោះប្រព្រឹត្តសង្កត់សង្កិន គឺញាំញី ។ ឈ្មោះថា **អភិភុយ្យចារី** ព្រោះប្រព្រឹត្តគ្របសង្កត់ គឺធ្វើឲ្យតក់ស្លុត បានដល់ ធ្វើឲ្យនៅក្នុងអំណាច ។

រាជសីហ៍នោះ មានប្រក្រតីប្រព្រឹត្តសង្កត់សង្កិនដោយកម្លាំងកាយ និងមានប្រក្រតីប្រព្រឹត្តគ្របសង្កត់ដោយតេជះ ។

ក្នុងសេចក្តីនោះ បើបុគ្គលណាម្នាក់សួរថា រាជសីហ៍ មានប្រក្រតីប្រព្រឹត្តសង្កត់សង្កិន គ្របសង្កត់អ្វី ។ ព្រោះហេតុនោះ ឆដ្ឋីវិភត្តិ ដែលថា **មិគានំ** ទើបគួរប្រើក្នុងអត្ថទុតិយាវិភត្តិ ហើយឆ្លើយថា មានប្រក្រតីប្រព្រឹត្តសង្កត់សង្កិន គ្របសង្កត់ម្រឹគទាំងឡាយ ។

បទថា **បន្តានិ** បានដល់ នូវឆ្ងាយ ។ បទថា **សេនាសនានិ** បានដល់ទីលំនៅ ។ ពាក្យដ៏សេស អាចដឹងបានដោយន័យដូចពោលហើយនោះឯង ព្រោះហេតុនោះ ទើបមិនចាំបាច់ឲ្យពិស្តារ ។

## អដ្ឋកថា ឆាថពលីគាថា ចប់

# អដ្ឋកថា

## អប្បមញ្ញាគាថា

គាថាថា **មេត្តំ ឧបេក្ខំ** ដូច្នេះជាដើម មានអត្ថុប្បត្តិហេតុដូចម្ដេច ។

បានឮថា ព្រះរាជាមួយអង្គ ទ្រង់បានមេត្តាឈានជាដើម ទ្រង់ព្រះតម្រិះថា រាជសម្បត្តិ ជាអន្តរាយចំពោះសុខក្នុងឈាន ដើម្បីទ្រង់រក្សាឈាន ទើបលះរាជសម្បត្តិចេញបួស ចម្រើនវិបស្សនា ធ្វើឲ្យជាក់ច្បាស់នូវបច្ចេកពោធិញ្ញាណ ហើយបានពោលឧទានគាថានេះ ។

ក្នុងគាថានោះ ភាពជាអ្នកប្រាថ្នា នាំចូលទៅនូវហិតសុខ ដោយន័យជាដើមថា សត្វទាំងឡាយទាំងពួង ចូរជាអ្នកមានសេចក្ដីសុខចុះ ដូច្នេះឈ្មោះថា **មេត្តា** ។

ភាពជាអ្នកប្រាថ្នាដើម្បីបំបាត់វត្ថុដែលមិនមែនប្រយោជន៍ និងទុក្ខ ដោយន័យជាដើមថា ឱហ្ន៎ ! សត្វទាំងឡាយគប្បីផុតចាកទុក្ខនេះ ដូច្នេះ ឈ្មោះថា **ករុណា** ។ ភាពជាអ្នកប្រាថ្នាដើម្បីមិនឲ្យព្រាត់ប្រាសចាកហិតសុខ ដោយន័យជាដើមថា សត្វទាំងឡាយដ៏ចម្រើន ចូរត្រេកអរហ្ន៎ ចូរត្រេកអរដោយល្អដូច្នេះ ឈ្មោះថា **មុទិតា** ។

ការព្រងើយក្នុងសុខ និងទុក្ខ ដោយន័យជាដើមថា សត្វទាំងឡាយនឹងប្រាកដតាមកម្មរបស់ខ្លួន ដូច្នេះ ឈ្មោះថា **ឧបេក្ខា** ។

តែដើម្បីងាយស្រួលក្នុងការចងគាថា លោកពោលមេត្តា ហើយពោលឧបេក្ខា និងមុទិតា ឯក្រោយ ដោយផ្លាស់លំដាប់គ្នា ។

បទថា **វិមុត្តឹ** សេចក្ដីថា អប្បមញ្ញាទាំង ៤ នេះ ឈ្មោះថា **វិមុត្តិ**

ព្រោះផុតចាកធម៌ ដែលជាសត្រូវរបស់ខ្លួន ដោយហេតុនោះ ទើបលោកពោលថា គប្បីចម្រើនមេត្តា ឧបេក្ខា ករុណា និងមុទិតា ជាហេតុរួចចាកកិលេសសព្វកាល ។

បណ្តាបទទាំងនោះ បទថា **អាសេវមានោ** សេចក្តីថា ចម្រើនមេត្តា ករុណា មុទិតាទាំង ៣ ដោយអំណាចតិកជ្ឈាន និងចតុក្កជ្ឈាន ចម្រើនឧបេក្ខា ដោយអំណាចចតុក្កជ្ឈាន ។

បទថា **កាលេ** សេចក្តីថា ចម្រើនមេត្តា ចេញចាកមេត្តានោះហើយ ចម្រើនករុណា ចេញចាកករុណាហើយ ចម្រើនមុទិតា ចេញចាកករុណា ឬចាកឈានដែលមិនមានបីតិក្រៅអំពីនេះ ហើយចម្រើនឧបេក្ខានោះឯង លោកហៅថា ចម្រើនក្នុងកាលដ៏គួរ ម្យ៉ាងទៀត បានដល់ ចម្រើនក្នុងកាលដែលមានផាសុក ។

បទថា **សព្វេន លោកេន អវិរុជ្ឈមានោ** សេចក្តីថា មិនទាស់សម្បានឹងសត្វលោកទាំងពួង ក្នុងទិសទាំង ១០ ។ ពិតហើយ សត្វទាំងឡាយមិនវិកវរ ព្រោះចម្រើនមេត្តាជាដើម បដិឃៈដែលជាតួសត្រូវក្នុងសត្វទាំងឡាយរមែងស្ងប់រម្ងាប់ ។ ដោយហេតុនោះ ទើបលោកពោលថា មិនទាស់សម្បានឹងសត្វលោកទាំងពួង ។

សេចក្តីសង្ខេបក្នុងទីនេះ មានប្រមាណប៉ុណ្ណេះ ឯសេចក្តីពិស្តារនៃគាថាពោលដោយមេត្តាជាដើម ពោលហើយក្នុងអដ្ឋកថាធម្មសង្គហៈ ឈ្មោះថា អដ្ឋសាលិនី ។ ពាក្យដ៏សេសមានន័យដូចលោកពោលហើយនោះឯង ៕

# អដ្ឋកថា

## ជីវិតសង្ខេយគាថា

គាថាថា **រាគញ្ច ទោសញ្ច** ដូច្នេះជាដើម មានអត្ថុប្បត្តិហេតុដូចម្តេច ។

បានឮថា ព្រះបច្ចេកសម្ពុទ្ធព្រះនាមមាតង្គៈ អាស្រ័យនគររាជគ្រឹះ ជាព្រះបច្ចេកសម្ពុទ្ធអង្គចុងក្រោយ ក្នុងចំនួនព្រះបច្ចេកសម្ពុទ្ធទាំងឡាយ ។

គ្រានោះ ព្រះពោធិសត្វនៃយើងទាំងឡាយកើតឡើងហើយ ទេវតាទាំងឡាយមកដើម្បីបូជាព្រះពោធិសត្វ ឃើញព្រះមាតង្គបច្ចេកសម្ពុទ្ធក៏ពោលថា លោកនិទ្ទុក្ខ លោកនិទ្ទុក្ខ ព្រះពុទ្ធកើតឡើងហើយក្នុងលោក មាតង្គបច្ចេកសម្ពុទ្ធនោះ កំពុងចេញចាកនិរោធ បានឮដូច្នោះ ដឹងថា ខ្ទនអស់ជីវិត ក៏ហោះទៅកាន់ភ្នំឈ្មោះមហាបបាតៈ ក្នុងហិមវន្តប្បទេស ដែលជាទីបរិនិព្វានរបស់ព្រះបច្ចេកសម្ពុទ្ធទាំងឡាយ ហើយបោះឆ្អឹងរបស់ព្រះបច្ចេកសម្ពុទ្ធដែលបរិនិព្វានហើយ ចូលទៅក្នុងជ្រោះខ្ទួនឯង ក៏អង្គុយលើផ្ទាំងសិលា បានពោលឧទានគាថានេះ ។

រាគៈ ទោសៈ មោហៈ ក្នុងគាថានោះ បានពោលហើយក្នុងឧរគសូត្រ ( ក្នុងខុទ្ទកនិកាយ សុត្តនិបាត ) ។ បទថា **សំយោជនានិ** បានដល់សំយោជនៈ ១០ ។ ទម្លាយសំយោជនៈទាំង ១០ នោះ ដោយមគ្គនោះៗ ។

បទថា **អសន្តសំ ជីវិតសង្ខយម្ហិ** សេចក្តីថា ការបែកធ្លាយដោយជុំវិញនៃចុតិចិត្ត ហៅថា ការអស់ទៅនៃជីវិត ។ ឈ្មោះថា ជាអ្នកមិនតក់ស្លុតក្នុងការអស់ជីវិតនោះ ព្រោះលះសេចក្តីស្រឡាញ់ក្នុងជីវិតបានហើយ ។

ព្រះបច្ចេកសម្ពុទ្ធសម្តែងសឧបាទិសេសនិព្វានរបស់លោក ដោយពាក្យមានប្រមាណប៉ុណ្ណោះឯង ក្នុងវេលាចប់គាថា បានបរិនិព្វានដោយអនុបាទិសេសនិព្វានធាតុ ដូច្នេះឯង ៕

**អដ្ឋកថា ជីវិតសង្ខយគាថា ចប់**

# អដ្ឋកថា

## គាថាដ៏សេស

គាថាថា **ភជន្តិ** ដូច្នេះជាដើម មានអត្ថុប្បត្តិហេតុដូចម្ដេច ។

បានឮថា ព្រះរាជាមួយអង្គ ក្នុងនគរពារាណសី គ្រប់គ្រងអាណាចក្រ ដែលទូលំទូលាយ មានប្រការដូចពោលហើយខាងដើមនោះឯង អាពាធជាទម្ងន់កើតឡើងដល់ទ្រង់ ទុក្ខវេទនាទាំងឡាយកំពុងប្រព្រឹត្តទៅ ។ ស្ត្រីពីរម៉ឺនចោមរោមព្រះអង្គ ធ្វើនូវការប្រេបាច់ព្រះហស្ត និងព្រះបាទជាដើម ។

ពួកអមាត្យគិតគ្នាថា ព្រះរាជានឹងសោយទិវង្គតក្នុងកាលឥឡូវនេះ ណ្ហើយចុះ ពួកយើងនឹងស្វែងរកទីពឹងឲ្យខ្លួនឯង ទើបគេចទៅកាន់សម្នាក់របស់ព្រះរាជាមួយអង្គ ទូលសូមបម្រើ ។ អមាត្យទាំងនោះទទួលបម្រើក្នុងទីនោះ មិនបានរបស់ណាមួយ ។ ព្រះរាជាទ្រង់ជាអំពីប្រឈួនហើយ ត្រាស់សួរថា អមាត្យឈ្មោះនេះៗ ទៅណា បន្ទាប់អំពីនោះ ទ្រង់បានស្តាប់រឿងនោះ ទ្រង់គ្រវីព្រះសីសៈ ហើយនៅស្ងៀម ។

ឯអមាត្យទាំងនោះ បានដឹងដំណឹងថា ព្រះរាជាទ្រង់ជាអំពីប្រឈួនហើយ មិនបានអ្វីក្នុងទីនោះ ត្រូវសេចក្ដីវិនាសធំបៀតបៀន ទើបត្រឡប់មកវិញ ថ្វាយបង្គំព្រះរាជាហើយ ឈរក្នុងទីបំផុតនៃចំណែកម្ខាង ត្រូវព្រះរាជាត្រាស់សួរថា នែបាទាំងឡាយ ពួកអ្នកទៅណា ទើបនាំគ្នាក្រាបទូលថា ទូលបង្គំទាំងឡាយឃើញព្រះសម្មតិទេពទុព្វល ទើបនាំគ្នាទៅកាន់ជនបទឈ្មោះនោះ ព្រោះការខ្លាចដែលកើតអំពីការចិញ្ចឹមជីវិត ។ ព្រះរាជាទ្រង់គ្រវីសីសៈ រួចទ្រង់ព្រះតម្រិះថា បើដូច្នោះ អញនឹងសម្ដែងអាការអាពាធនោះទៀត ពួក

អមាត្យនឹងធ្វើយ៉ាងនោះទៀតដែរឬទេ ។ ព្រះរាជា កាលទ្រង់សម្ដែងវេទនាខ្លាំងក្លា ដូចរោគពាល់ត្រូវហើយក្នុងកាលមុន ទើបទ្រង់ធ្វើពុតជាឈឺ ។ ពួកស្ត្រីនាំគ្នាចោមរោម បានធ្វើកិច្ចដូចកាលមុននោះឯង ។

ឯពួកអមាត្យក៏នាំមនុស្សច្រើនជាងមុន ចៀសចេញទៅទៀតយ៉ាងនោះឯង ព្រះរាជាទ្រង់ធ្វើកម្មគ្រប់យ៉ាងដូចកាលមុន រហូតដល់លើកទី ៣ ដោយអាការយ៉ាងនេះ ឯអមាត្យទាំងនោះ ក៏នាំគ្នាចៀសចេញទៅយ៉ាងនោះឯង ។ បន្ទាប់អំពីនោះ ព្រះរាជាទ្រង់ឃើញអមាត្យទាំងនោះ ត្រឡប់មកលើកទី ៤ ទ្រង់ព្រះតម្រិះថា ឱ ! ពួកអមាត្យលះបង់អញដែលជាអ្នកមានជំងឺ មិនអាឡោះអាល័យចៀសចេញទៅ ជនទាំងនេះ ធ្វើកម្មដែលធ្វើបានដោយក្រ ទើបទ្រង់នឿយណាយ លះនូវរាជសម្បត្តិបួស ចម្រើនវិបស្សនា ធ្វើឲ្យជាក់ច្បាស់នូវបច្ចេកពោធិញ្ញាណ ទើបពោលឧទានគាថានេះ ។

បណ្ដាបទទាំងនោះ បទថា **ភជន្តិ** សេចក្ដីថា ចូលទៅអង្គុយជិតខ្លួន ។ បទថា **សេវន្តិ** សេចក្ដីថា យកចិត្តយកថ្លើម ដោយការថ្វាយបង្គំជាដើម ដើម្បីរង់ចាំស្ដាប់ថា តើឲ្យធ្វើអ្វី ។ ឈ្មោះថា **ការណត្ថា** ព្រោះមានប្រយោជន៍ជាហេតុ ។ អធិប្បាយថា ការគប់រកមិនមានហេតុដទៃ ប្រយោជន៍ប៉ុណ្ណោះជាហេតុនៃបុគ្គលទាំងនោះ ជនទាំងឡាយគប់រកគ្នា ព្រោះប្រយោជន៍ជាហេតុ ។

បទថា **និក្ការណា ទុល្លភា អជ្ជ មិត្តា** សេចក្ដីថា ឈ្មោះថា **និក្ការណា** ព្រោះប្រយោជន៍ ដែលខ្លួនបានយ៉ាងនេះថា ពួកយើងគង់បានអ្វី

អំពីមនុស្សនេះខ្លះ ។ មិត្តដែលប្រកបដោយភាពជាមិត្តដ៏ប្រសើរ ដែលត្រាស់ ( ក្នុងសិង្គាលកសូត្រ ) យ៉ាងនេះថា

មិត្តដែលមានឧបការៈ សម្លាញ់ដែលរួមសុខទុក្ខ មិត្តដែល
ប្រាប់ប្រយោជន៍ មិត្តដែលមានសេចក្ដីឈឺឆ្អាល បណ្ឌិត
ស្គាល់ជាក់នូវបុគ្គលទាំង ៤ ពួកនុ៎ះ ថាជាមិត្តមែនទែន ដូច្នេះ
សព្វថ្ងៃនេះ រកបានដោយក្រ ។

បទថា **អត្តដ្ឋបញ្ញា** សេចក្ដីថា ជនទាំងនេះ មានបញ្ញាក្នុងខ្លួន អធិប្បាយថា ឃើញដល់ខ្លួន មិនឃើញដល់អ្នកដទៃ ។ បាលីថា **អត្តត្ថ-បញ្ញា** ដូច្នេះក៏មាន បាលីនោះមានសេចក្ដីថា ឃើញតែប្រយោជន៍របស់ខ្លួនប៉ុណ្ណោះ មិនឃើញប្រយោជន៍របស់អ្នកដទៃ ។ បានឮថា បាលីបុរាណជា **ទិដ្ឋត្ថបញ្ញា** បាលីនោះ មានសេចក្ដីថា ជនទាំងនោះ មានបញ្ញាក្នុងប្រយោជន៍មួយនេះ គឺក្នុងបច្ចុប្បន្ន មិនមានបញ្ញាក្នុងអនាគត អធិប្បាយថា ឃើញដល់ប្រយោជន៍បច្ចុប្បន្ន មិនឃើញដល់ប្រយោជន៍ខាងមុខ ។

បទថា **អសុចី** បានដល់ ដែលប្រកបដោយកាយកម្ម វចីកម្ម និងមនោកម្ម ដែលមិនស្អាត គឺមិនប្រសើរ ។

បទថា **ខគ្គវិសាណកប្បា** សេចក្ដីថា ឈ្មោះថា **ខគ្គវិសាណា** ព្រោះរមាសយកកុយរបស់ខ្លួនត្រាច់ធ្វើឲ្យភ្នំជាដើម ឲ្យជាលម្អិតតូចធំ ដូចបុគ្គលយកដាវកាត់ដើមឈើ ដូច្នោះ ។ ឈ្មោះថា **វិសាណា** ព្រោះមានអំណាចដូចគ្នានឹងថ្នាំពិស ។ ឈ្មោះថា **ខគ្គ** ព្រោះដូចដាវ ។ ម្រឹគណា

មានស្នែងដូចដាវ ម្រឹគនោះ ឈ្មោះថា **ខគ្គវិសាណា** ។ កុយរបស់ម្រឹគដែលមានស្នែងដូចដាវនោះ ឈ្មោះថា **ខគ្គវិសាណកប្បា** អធិប្បាយថា ព្រះបច្ចេកសម្ពុទ្ធប្រៀបដូចកុយរមាស ជាបុគ្គលម្នាក់ឯង មិនមានមិត្ត មិនមានសម្លាញ់ ត្រាច់ទៅ គឺនៅ ប្រព្រឹត្តទៅ ដើរទៅ ឲ្យដើរទៅ ។

បទថា **វិសុទ្ធសីលា** ប្រែថា ជាអ្នកមានសីលបរិសុទ្ធដោយពិសេស គឺជាអ្នកមានសីលបរិសុទ្ធដោយបរិសុទ្ធ ៤ ប្រការ ។

បទថា **សុវិសុទ្ធបញ្ញា** ប្រែថា ជាអ្នកមានបញ្ញាបរិសុទ្ធដោយល្អ គឺឈ្មោះថា មានបញ្ញា គឺការបែកធ្លាយក្នុងមគ្គ និងផលដ៏បរិសុទ្ធ ព្រោះវៀរចាករាគៈជាដើម ។

បទថា **សមាហិតា** ប្រែថា តាំងមាំល្អ គឺដោយល្អ បានដល់ មានចិត្តតាំងនៅជាមួយខ្លួន ។

បទថា **ជាគរិយានុយុត្តា** សេចក្តីថា ការភ្ញាក់រឭក ឈ្មោះថា **ជាគរ** ការមិនដេកលក់ ភាពជាអ្នកភ្ញាក់ ឈ្មោះថា **ជាគរិយ** បុគ្គលព្យាយាមប្រកបក្នុងការភ្ញាក់ ឈ្មោះថា **អនុយុត្តា** ។

បទថា **វិបស្សកា** បានដល់ ជាអ្នកមានប្រក្រតីឃើញដោយពិសេសថា **អនិច្ចំ ទុក្ខំ អនត្តា** អធិប្បាយថា ផ្តើមតាំងវិបស្សនា ។

បទថា **ធម្មវិសេសទស្សី** ប្រែថា ជាអ្នកមានប្រក្រតីឃើញដោយពិសេសនូវកុសលធម៌ ១០ នូវសច្ចៈ ៤ ឬលោកុត្តរធម៌ ៩ ។

បទថា **មគ្គង្គពោជ្ឈង្គគតេ** បានដល់ អរិយធម៌ដែលទៅ គឺប្រកប

ដោយអង្គនៃមគ្គ មានសម្មាទិដ្ឋិជាដើម និងដោយពោជ្ឈង្គ មានសតិ-សម្ពោជ្ឈង្គជាដើម ។

បទថា **វិជញ្ញា** ប្រែថា ដឹង អធិប្បាយថា ដឹងដោយពិសេស ។ បទថា **សុញ្ញតាប្បណិហិតញ្ញានិមិត្តំ** បានដល់ នូវសុញ្ញតវិមោក្ខដោយអនត្តា-នុបស្សនា នូវអប្បណិហិតវិមោក្ខ ដោយទុក្ខានុបស្សនា និងនូវអនិមិត្តវិមោក្ខ ដោយអនិច្ចានុបស្សនា ។

បទថា **អាសេវយិត្វា** បានដល់ ចម្រើនហើយ ។ ពីរជនទាំងឡាយណាធ្វើបុញ្ញសម្ភារ មិនទាន់ដល់ គឺមិនទាន់សម្រេចនូវភាពជាសាវក ក្នុងសាសនានៃព្រះជិនស្រី ពីរជនទាំងនោះ ដែលបានធ្វើបុញ្ញសម្ភារហើយ រមែងជាព្រះបច្ចេកសម្ពុទ្ធជិនស្រី គឺជាព្រះបច្ចេកសម្ពុទ្ធដែលជាសយម្ភូ បានដល់ជាអ្នកកើតឯង ។

សួរថា លោកកើតដូចម្តេច ឆ្លើយថា លោកជាអ្នកមានធម៌ដ៏ច្រើន គឺមានបុញ្ញសម្ភារធំ ដែលបានបំពេញមកហើយ មានធម្មកាយសម្បូណ៌ គឺមានសភាវធម៌មិនមែនតិច ជារាងកាយ ។ សួរថា លោកកើតដូចម្តេចទៀត ឆ្លើយថា លោកមានចិត្តជាធំ គឺមានចិត្តជាគតិ អធិប្បាយថា ដល់ព្រមដោយឈាន ។

ពួកជននោះឆ្លងនូវទុក្ខ និងឱឃៈទាំងពួង គឺឆ្លង បានដល់ ឈានកន្លងឱឃៈ គឺសង្សារទាំងមូល មានចិត្តត្រេកអរ គឺមានចិត្តសោមនស្ស អធិប្បាយថា មានចិត្តស្ងប់ ព្រោះវៀរចាកកិលេស មានកោធៈ និងមានះជាដើម ។

ជាអ្នកឃើញនូវប្រយោជន៍ដ៏ក្រៃលែង គឺមានប្រក្រតីឃើញនូវប្រយោជន៍ក្រៃលែង គឺប្រយោជន៍ដ៏ឧត្តម ដូចជាខន្ធ ៥ អាយតនៈ ១២ អាការ ៣២ សច្ចៈ ៤ និងបដិច្ចសមុប្បាទ ។ ឧបមាដូចសីហៈ អធិប្បាយថា ដូចរាជសីហ៍ ព្រោះអត្ថថា មិនញាប់ញ័រ និងមិនតក់ស្លុត ។ មានឧបមាដូចកុយរមាស អធិប្បាយថា ឈ្មោះថា ដូចគ្នានឹងកុយរបស់រមាស ព្រោះមិនមានការប្រឡូកប្រឡំដោយពួកគណៈ ។

បទថា **សន្តិន្ទ្រិយា** បានដល់ ជាអ្នកមានឥន្ទ្រិយ មានសភាវៈស្ងប់ ព្រោះចក្ខុន្ទ្រិយជាដើម មិនប្រព្រឹត្តទៅក្នុងអារម្មណ៍រៀងៗ ខ្លួន ។

បទថា **សន្តមនា** ប្រែថា មានចិត្តស្ងប់ អធិប្បាយថា មាននូវការត្រិះរិះនៃចិត្ត មានសភាវៈស្ងប់ហើយ ព្រោះជាអ្នកអស់នូវកិលេស ។

បទថា **សមាធី** បានដល់ ជាអ្នកមានចិត្តជាឯកគ្គតាដោយល្អ ។

បទថា **បច្ចន្តសត្តេសុ បតិប្បវាចា** សេចក្តីថា មានប្រក្រតីប្រព្រឹត្តដោយការអាណិត និងសេចក្តីករុណាជាដើមក្នុងពួកសត្វ ក្នុងបច្ចន្តជនបទ ។

បទថា **ទីបា បរត្ថ ឥធ វិជ្ជលន្តា** សេចក្តីថា ជាដូចប្រទីប គឺដូចគ្នានឹងប្រទីបដែលឆេះសន្ធោសន្ធៅក្នុងលោកខាងមុខ និងលោកនេះ ដោយការធ្វើសេចក្តីអនុគ្រោះដល់សត្វលោកទាំងមូល ។

បទថា **បច្ចេកសម្ពុទ្ធា សតតំ ហិតាមេ** សេចក្តីថា ព្រះបច្ចេកសម្ពុទ្ធទាំងនេះ បដិបត្តិដើម្បីជាប្រយោជន៍ដល់លោកទាំងមូលជាប់តគ្នាមិនដាច់ គឺសព្វកាល ។

បទថា **បហីនសព្វាវរណា ជនិន្ទា** សេចក្តីថា ព្រះបច្ចេកសម្ពុទ្ធទាំងនោះជាធំ គឺឧត្តមជាងពួកជន ឈ្មោះថា លះកិលេសជាគ្រឿងរាំងទាំងពួងហើយ ព្រោះជាអ្នកលះគ្រឿងរាំងទាំង ៥ ប្រការ មានកាមច្ឆន្ទនីវរណៈជាដើម ។

បទថា **ឃនកញ្ចនាភា** សេចក្តីថា ជាបុគ្គលមានរស្មីដូចគ្នានឹងពន្លឺមាសឈ្មោះរត្តៈ និងមាសឈ្មោះជម្ពូនទ ។

បទថា **និស្សំសយំ លោកសុទក្ខិណេយ្យា** បានដល់ ជាបុគ្គលគួរ គឺសមគួរទទួលទក្ខិណាយ៉ាងល្អ គឺទានដ៏ប្រសើររបស់សត្វលោកដោយចំណែកមួយ អធិប្បាយថា ឈ្មោះថា ជាអ្នកគួរទទួលសុន្ទរទាន ព្រោះជាអ្នកមិនមានកិលេស ។

បទថា **បច្ចេកពុទ្ធា សតតប្បិតាមេ** សេចក្តីថា ព្រះពុទ្ធដែលជាអ្នកសម្រេចបច្ចេកញ្ញាណទាំងនេះ ជាបុគ្គលឆ្អែត គឺស្កប់ស្កល់បរិបូណ៌ជានិច្ច គឺសព្វកាល អធិប្បាយថា ទោះមិនមានអាហារ ៧ ថ្ងៃ ក៏បរិបូណ៌បានដោយអំណាចនៃនិរោធសមាបត្តិ និងផលសមាបត្តិ ។

ព្រះបច្ចេកសម្ពុទ្ធទាំងឡាយជាបុគ្គលមួយដោយឡែក គឺផ្សេង បានដល់ មិនដូចបុគ្គលដទៃ មិនប្រៀបធៀបបានជាមួយព្រះសម្មាសម្ពុទ្ធ ម្យ៉ាងទៀត ព្រោះ **បតិ** សព្ទ ជាឧបសគ្គ ចំពោះភាពជាឯក ព្រោះលោកពោលថា

> សព្ទទាំង ៣ គឺឧបសគ្គ និបាត និងបច្ច័យ អ្នកនិរុត្តិសាស្ត្រ
> ទាំងឡាយពោលថា មានវិស័យនៃអត្ថមិនមែនតិច ។

ទើបលោកជាធំ គឺជាប្រធាន ជាម្ចាស់ទ្រព្យ ព្រោះទទួលអាហារមានប្រមាណតិចនៃពួកទាយកសន្ទឹកសន្ទាប់ ហើយធ្វើឲ្យចូលទៅកាន់ស្ថានសួគ៌ និងនិព្វានបាន ។ ពិតហើយ ព្រះបច្ចេកសម្ពុទ្ធជាធំ ជាប្រធាន ដោយធ្វើឲ្យកើតទ្រព្យរាប់កោដិ ដល់អ្នករែកស្មៅឈ្មោះអន្នភារៈ ដោយទទួលកត្តដែលជាចំណែកបែងចែករបស់អន្នភារៈ កាលអន្នភារៈកំពុងសម្លឹងមើលនោះឯង ឆាន់ឲ្យឃើញ ញុំាងពួកទេវតាឲ្យបន្លឺសាធុការ ហើយនាំនាយអន្នភារៈដែលជាជនទុគ៌តឲ្យបានទទួលតំណែងសេដ្ឋីក្នុងថ្ងៃនោះឯង ។ ដោយការធ្វើឲ្យកើតសោមនស្ស ក្នុងខទិរង្គារជាតក លោកទទួលបិណ្ឌបាតដែលព្រះពោធិសត្វប្រគេន ដោយជាន់ផ្កាឈូក ដែលផុសឡើងពីរណ្តៅរងើកភ្លើងគគីរ ដែលមារនិម្មិតឡើង កាលព្រះពោធិសត្វកំពុងឃើញនោះឯង ហោះទៅក្នុងអាកាស ។ ដោយការធ្វើឲ្យកើតសោមនស្សម្តងទៀត ដល់មហាជនកពោធិសត្វ និងព្រះទេវី ដោយការដែល ( ព្រះបច្ចេកសម្ពុទ្ធ ) ជាឱរសរបស់អគ្គមហេសីបទុមវតី ហោះមកអំពីភ្នំគន្ធមាទន៍ ហើយទទួលទានដោយការអារាធនារបស់ព្រះទេវី នៃព្រះមហាជនក ដោយការធ្វើឲ្យកើតបាយ ដូចមានរឿងតទៅនេះថា ក្នុងកាលដែលព្រះពុទ្ធមិនទាន់កើតឡើង កាលឆាតកភ័យកើតឡើងក្នុងជម្ពូទ្វីបទាំងមូល ពារាណសីសេដ្ឋីបរិភោគស្រូវក្នុងជង្រុក ៦ ម៉ឺន ដែលដាក់ស្រូវឲ្យពេញរក្សាទុកឲ្យអស់ទៅ ព្រោះអាស្រ័យឆាតកភ័យ បរិភោគស្រូវដែលកប់ក្នុងផែនដី និងស្រូវដែលដាក់ក្នុងពាង ៦ ម៉ឺនឲ្យអស់ទៅ និងបរិភោគស្រូវដែលច្របាច់ជាមួយដីឥដ្ឋ ហើយបូកលាប

គ្រាន់ជញ្ជាំងប្រាសាទទាំងមូលឲ្យអស់ទៅ ក្នុងគ្រានោះ សល់ត្រឹមអង្ករមួយនាឡិប៉ុណ្ណោះ ក៏ដេកធ្វើការគិតឲ្យកើតឡើងថា ពួកយើងបរិភោគបាយនេះហើយ គង់ស្លាប់ក្នុងថ្ងៃនេះ ។ ព្រះបច្ចេកសម្ពុទ្ធមួយអង្គ មកអំពីភ្នំគន្ធមាទន៍បានឈរត្រង់ទ្វារផ្ទះ ។ សេដ្ឋីឃើញ កើតសេចក្តីជ្រះថ្លា ព្រមបរិច្ចាគជីវិតទើបដាក់កក្តាហារក្នុងបាត្រនៃព្រះបច្ចេកសម្ពុទ្ធ ។ ព្រះបច្ចេកសម្ពុទ្ធ ក៏និមន្តទៅកាន់លំនៅ ខណៈដែលសេដ្ឋីកំពុងមើលឃើញដោយអានុភាពរបស់លោកនោះឯង បានធាន់មួយអន្ទើដោយព្រះបច្ចេកពុទ្ធ ៥០០ អង្គ ។ ក្នុងកាលនោះ លោកសេដ្ឋី និងភរិយាបានបិទឆ្នាំងបាយតម្កល់ទុក ។

លុះសេចក្តីស្រេកឃ្លានកើតឡើងដល់សេដ្ឋី ដែលកំពុងដេកលក់ ទើបគាត់ក្រោកឡើងពោលនឹងភរិយាថា នាងដ៏ចម្រើន ចូរនាងមើល ថាតើមានត្រឹមតែបាយក្តាំងដែរឬទេ ។ ភរិយាជាអ្នកមានការសិក្សាល្អ មិនប្រាប់ថាបាយឲ្យទានអស់ហើយមិនមែនឬ បើកនូវគម្របឆ្នាំង ( មើល ) ។ រំពេចនោះ ឆ្នាំងបាយបានពេញដោយកក្តាំនៃស្រូវសាលី មានក្លិនក្រអូប ដូចគ្នានឹងផ្កាម្លិះក្រពុំ ។ នាង និងសេដ្ឋីត្រេកអរខ្ទួនឯង មនុស្សដែលនៅក្នុងផ្ទះទាំងអស់ និងអ្នកនគរទាំងអស់នាំគ្នាបរិភោគ ក្នុងទីដែលប្រើវែកដួសចេញ បាយក៏ពេញដូចដើម ។ ស្រូវសាលីមានក្លិនក្រអូបពេញក្នុងជង្រុកទាំង ៦ ម៉ឺន អ្នកជម្ពូទ្វីបបានស្រូវអំពីផ្ទះរបស់សេដ្ឋីនោះឯង មានសេចក្តីសុខ ។ ព្រះពុទ្ធជាធំគឺជាម្ចាស់ក្នុងការធ្វើឲ្យពួកសត្វ ដូចពោលមកនេះជាដើម ឈានចុះកាន់សេចក្តីសុខ ជួយបរិបាលរក្សា និងការឲ្យដល់ស្ថានសួគ៌ និងព្រះនិព្វាន ព្រោះហេតុ

នោះ ទើបឈ្មោះថា បច្ចេកសម្ពុទ្ធ ។

បទថា **បច្ចេកពុទ្ធានំ សុភាសិតានិ** បានដល់ ពាក្យដែលព្រះបច្ចេកសម្ពុទ្ធទាំងឡាយពោលល្អហើយ គឺដោយដើម្បីឲ្យផុតចាកអបាយទាំង ៤ ។ ពាក្យនោះដូចម្តេច ដូចទឹកឃ្មុំដែលកំពុងស្រក់ គឺកំពុងហូរចេញ អធិប្បាយថា ជាពាក្យផ្អែមល្ហែមដូចទឹកឃ្មុំ សេចក្តីថា ជនជាបណ្ឌិតពួកណា ដែលប្រកបដោយកិច្ចបដិបត្តិ បដិបត្តិក្នុងបដិបទាទាំងឡាយ តាមគន្លងដែលពោលហើយ បានស្តាប់ពាក្យដ៏ពីរោះមានសភាពបែបនោះហើយ ធ្វើតាម បណ្ឌិតទាំងនោះ រមែងឃើញសច្ចធម៌ គឺមានប្រក្រតីឃើញសច្ចៈទាំង ៤ ជាអ្នកប្រកបដោយប្រាជ្ញា គឺប្រព្រឹត្តទៅដោយបញ្ញា ។

បទថា **បច្ចេកពុទ្ធេហិ ជិនេហិ ភាសិតា** សេចក្តីថា ឈ្មោះថា **ជិន** ព្រោះឈ្នះ គឺបានឈ្នះកិលេស កថាដែលព្រះជិនបច្ចេកសម្ពុទ្ធទាំងនោះពោល គឺភាសិត ពោលជាពាក្យដ៏ខ្ពង់ខ្ពស់ គឺមានឱជៈប្រាកដ គឺប្រព្រឹត្តទៅ ។ ភ្ជាប់សេចក្តីថា កថាទាំងនោះ ដែលព្រះសក្យសីហៈ បានដល់ ព្រះតថាគតដែលជាគោតមជាសីហៈ ក្នុងវង្សនៃសក្យរាជ ដែលចេញបួសហើយ បានជាព្រះសម្ពុទ្ធ ជានរៈដ៏ឧត្តម គឺជាបុគ្គលដ៏ឧត្តមប្រសើរជាងនរជនទាំងឡាយ ទ្រង់សម្តែងហើយ គឺទ្រង់ធ្វើឲ្យប្រាកដ បានដល់ ត្រាស់ទេសនាហើយ ដើម្បីនឹងឆ្លើយពាក្យសួរថា ទ្រង់ប្រកាសដើម្បីអ្វី ទើបត្រាស់ថា ដើម្បីការដឹងច្បាស់នូវធម៌ អធិប្បាយថា ដើម្បីឲ្យដឹងលោកុត្តរធម៌ ៩ ដោយពិសេស ។

*បទថា* **លោកានុកម្បាយ ឥមានិ តេសំ** *សេចក្ដីថា ព្រោះភាពជាអ្នកអនុគ្រោះលោក គឺព្រោះអាស្រ័យសេចក្ដីអនុគ្រោះដល់សត្វលោក ព្រះបច្ចេកសម្ពុទ្ធទាំងនោះ ក៏បានពោលពាក្យទាំងនេះ គឺគាថាទាំងនេះយ៉ាងពិសេស គឺសម្ដែង ពោលដោយពិសេស ។*

*បទថា* **សំវេគសង្គមតិវឌ្ឍនត្ថំ** *សេចក្ដីថា ដើម្បីចម្រើននូវសំវេគ ដើម្បីចម្រើននូវការមិនច្រឡូកច្រឡំ គឺដើម្បីចម្រើននូវភាពជាបុគ្គលម្នាក់ឯង និងដើម្បីចម្រើននូវការដឹង គឺដើម្បីចម្រើននូវបញ្ញា ព្រះគោតមសម្មាសម្ពុទ្ធ ដែលជាសយម្ភូសីហៈ គឺជាបុគ្គលមិនមានអាចារ្យ កើតហើយ កើតឡើងហើយ ចាក់ធ្លុះហើយចំពោះព្រះអង្គឯង ដូចសីហៈដែលជាសត្វមិនតក់ស្លុត ទ្រង់បានប្រកាសពាក្យទាំងនេះ អធិប្បាយថា ប្រកាស បើក ធ្វើឲ្យរាក់នូវសេចក្ដីទាំងនេះហើយ ។*

*សព្ទថា* **ឥតិ** *ជានិបាត ចុះក្នុងអត្ថបញ្ចប់សេចក្ដី ។*

**អដ្ឋកថា បច្ចេកពុទ្ធាបទាន ចប់**

# សុត្តន្តបិដក

## សារីបុត្តត្ថេរាបទានទី ៣

អ្នកទាំងឡាយចូរស្តាប់ថេរាបទាន ដូចតទៅនេះ

[ ៣ ] មានភ្នំមួយ ឈ្មោះលម្ពកៈ នៅក្នុងទីមិនឆ្ងាយអំពីភ្នំហិមពាន្ត គេបានសង់អាស្រម សាងបណ្ណសាលាឲ្យខ្ញុំ ។ ស្ទឹងមានច្រាំងដ៏រាក់ មានកំពង់ល្អ ជាទីគាប់ចិត្ត ដ៏ដេរដាសដោយផ្នូកខ្សាច់ដ៏ស្អាត មានក្នុងទីមិនឆ្ងាយអំពីអាស្រមខ្ញុំ ។ ស្ទឹង ( នោះ ) មិនមានក្រួសរវាន មិនចោត មានទឹកដ៏ឆ្ងាញ់ មិនមានក្លិនអាក្រក់ តែងហូរទៅក្នុងទីនោះ ជាលម្អដល់អាស្រមខ្ញុំ ។ មានក្រពើ មករ ឆ្លាម អណ្តើក លេងក្នុងស្ទឹងនុ៎ះ ហែបហែលក្នុងស្ទឹងនោះ ជាលម្អដល់អាស្រមខ្ញុំ ។ មានទាំងត្រីស្លាត ត្រីសណ្តាយ ត្រីក្រាញ់ ត្រីក្រពុលបាយ ត្រីឆ្ពិន ត្រីខ្ជឹង តែងហែលធ្មៀលធ្មាត់ទៅមក ជាលម្អដល់អាស្រមខ្ញុំ ។ នៅត្រើយស្ទឹងទាំងសងខាង មានដើមឈើដ៏សម្បូរដោយផ្កា និងផ្លែសំយុងចុះ មកអំពីត្រើយស្ទឹងទាំងសងខាង ជាលម្អដល់អាស្រមខ្ញុំ ។ ស្វាយ សាលព្រឹក្ស ដង្កៀបក្តាម ប្រទៀងឈើភ្លើង មានផ្ការីក ផ្សាយក្លិន ផ្សាយក្លិនដូចជាទិព្វ ក្នុងអាស្រមខ្ញុំ ។ ចំបក់ ស្រល់ ក្តុល ខ្ទឹង បុន្នាគ រំចេក មានផ្ការីក ផ្សាយក្លិនដូចជាទិព្វ ក្នុងអាស្រមខ្ញុំ ។ រំដួល អសោក នួនស្រី មានផ្ការីក អង្កោល វល្លិបាស មានផ្ការីក ផ្សាយក្លិនទៅក្នុងអាស្រមខ្ញុំ ។ រំចេក ចេក ខ្ទញ ម្ទិះរួត ផ្សាយក្លិនដូចជាទិព្វ ក្នុងអាស្រមខ្ញុំ ។ ឈើជា

ច្រើន គឺកណិការ កណ្ណិការ ឆ្នង់ អញ្ចាន់ ផ្សាយក្លិនដូចជាទិព្វ ជាលម្អនៃអាស្រមខ្ញុំ ។ មានក្រូចឆ្មារ ក្រូច ភ្ញា រលួស មានផ្ការីក ផ្សាយក្លិនដូចជាទិព្វ ជាលម្អនៃអាស្រមខ្ញុំ ។ ឈើជាច្រើនយ៉ាង គឺ រាជព្រឹក្ស ខ្ទឹងគន់ កុម្ភ ពកុល ផ្សាយក្លិនដូចជាទិព្វ ជាលម្អនៃ អាស្រមខ្ញុំ ។ អាឡកព្រឹក្ស សណ្តែកក្រហម ចេក ក្រូចថ្លុង តែងលូតលាស់ ដោយទឹកដ៏មានក្លិន ឈើទាំងនោះ ទ្រទ្រង់ផ្លែ (ជានិច្ច) ។ ឈូក ខ្លះកំពុងផ្កា ខ្លះកំពុងបញ្ចេញកេសរ ខ្លះជម្រុះផ្កា រីកស្គុះស្គាយ ក្នុងស្រះក្នុងកាលនោះ ។ ពួកឈូកកំពុងលេចពន្លក មានក្រអៅ កំពុងលូតលាស់ ដេរដាសដោយត្របកផ្កា និងស្លឹក លម្អក្នុងស្រះ ក្នុងកាលនោះ ។ គុម្ពផ្កានយិតាផង អម្ពគណ្ឋីផង ឧត្តរាហិផង ពន្ទុជីវកៈផង មានផ្ការីក ផ្សាយក្លិនដូចជាទិព្វ ទៀប ស្រះ ក្នុងកាលនោះ ។ ពួកត្រីស្លាត ត្រីសណ្តាយ ត្រីក្រាញ់ ត្រី ក្រពុលបាយ ត្រីឆ្ពិន ត្រីចង្វា ត្រីផ្ទោងនៅក្នុងស្រះ ក្នុងកាលនោះ ។ ក្រពើ ឆ្លាម តន្តិគ្គាហៈ អារក្សទឹក ឱគាហៈ ថ្លាន់ នៅក្នុងស្រះ ក្នុងកាលនោះ ។ ព្រាប ព្រហិត ចាក្រពាក ក្អែកទឹក តាវៅ សេក និងសារិកា តែងអាស្រ័យរស់នៅទីស្រះនោះ ។ មានបក្សី ខ្វែក ក្តាម មាន់ព្រៃ ត្រដេវវិច សេក អាស្រ័យរស់នៅ ទីស្រះនោះ ។ ពួកបក្សី គឺហង្ស ក្រៀល ក្ងោក តាវៅ មាន់ទោ ចង្កៀលខ្យង ប៉ោលតោក តែងអាស្រ័យរស់នៅទីស្រះនោះ ។ ពួកបក្សីជាច្រើន

គឺមៀម ខ្ទិងស្រោក លលក ខ្ទិង អន្កត់ខ្មៅ តែងអាស្រ័យរស់នៅនឹងស្រះនោះ ។ ពួកម្រឹគជាច្រើន គឺបសទម្រឹគ ជ្រូក ឆ្កែព្រៃ រមាំង ប្រើស រមាស តែងអាស្រ័យរស់នៅនឹងស្រះនោះ ។ សីហៈ ខ្លាធំ ខ្លាដំបង ខ្លាឃ្មុំ ឆ្កែព្រៃ ខ្លាត្រី ដំរីចុះប្រេង តែងអាស្រ័យរស់នៅនឹងស្រះនោះ ។ ពួកកិន្នរ ពានរ ឬពួកមនុស្សអ្នកធ្វើការក្នុងព្រៃ មនុស្សអ្នកបម្រើ ព្រានព្រៃ តែងអាស្រ័យរស់នៅនឹងស្រះនោះ ។ ដើមទន្លាប់ ដើមទន្លា ដើមស្រគំ ពជ្រ ទ្រទ្រង់ផ្លែអស់កាលជានិច្ច ក្នុងទីមិនឆ្ងាយអំពីអាស្រមខ្ញុំ ។ ដើមស្រល ដើមស្រល់ ដើមកុម្ព ប្រកបដោយខ្លឹម និងផ្លែ តែងទ្រទ្រង់ផ្លែជានិច្ច ក្នុងទីមិនឆ្ងាយអំពីអាស្រមខ្ញុំ ។ ដើមសម៉ កន្ទួតព្រៃ ស្វាយ ព្រីង សម៉ពិភេទក៍ ស្តៅ រក់ ខ្នៅ ញ្ញៅ តែងទ្រទ្រង់ផ្លែជានិច្ច ។ ដំឡូងស្រំ ដំឡូងដូង ដំឡូងដៃខ្លា និងដំឡូងឈាមមាន់ ទាំងឈើជាថ្នាំ ក៏មានច្រើន នៅជិតអាស្រមខ្ញុំ ។ ស្រះដែលធម្មតានិម្មិតល្អហើយ ក៏មាននៅក្នុងទីមិនឆ្ងាយអំពីអាស្រមខ្ញុំ មានទឹកថ្លា មានទឹកត្រជាក់ មានកំពង់រាបទាបល្អ គួរជាទីរីករាយចិត្ត ។ ស្រះនោះ សឹងដ៏បរិបូណ៌ដោយឈូក និងឧប្បល ប្រកបដោយឈូកសព្រោងព្រាត ដោយស្គន់ មានក្លិនដូចជាទិព្វ រមែងផ្សាយទៅ ។ ក្នុងកាលនោះ ខ្ញុំតែងនៅក្នុងអាស្រម ជាទីត្រេកអរ ដែលធម្មតាធ្វើទុកល្អហើយ ក្នុងព្រៃដែលមានផ្កា និងផ្លែ បរិបូណ៌ដោយអង្គគ្រប់សព្វយ៉ាងនេះ ។ ខ្ញុំ

ជាតាបស ឈ្មោះសុរុចិ ជាអ្នកមានសីល បរិបូណ៌ដោយវត្ត មានឈាន ត្រេកអរក្នុងឈាន ដល់នូវកម្លាំងនៃអភិញ្ញាទាំង ៥ គ្រប់កាលទាំងពួង ។ ពួកព្រាហ្មណ៍ទាំងអស់នុ៎ះ ជាសិស្សរបស់ខ្ញុំ ចំនួន ២៤ ពាន់នាក់ ជាអ្នកមានជាតិ មានយស នៅចាំបម្រើខ្ញុំ ។ ( ពួកព្រាហ្មណ៍ទាំងនោះ ) ជាអ្នកចេះបទ ចេះវេយ្យាករណ៍ ដល់នូវត្រើយនៃវិជ្ជា ក្នុងសទ្ធម្ម គឺលក្ខណសាស្ត្រ ឥតិហាសសាស្ត្រ ព្រមទាំងនិឃណ្ឌុសាស្ត្រ និងកេដុភសាស្ត្រ ។ ពួកសិស្សរបស់ខ្ញុំ ជាអ្នកឈ្លាសវៃ ក្នុងឧត្បាត ក្នុងនិមិត្ត និងលក្ខណៈទាំងឡាយ បានសិក្សាល្អក្នុងផែនដី ក្នុងទី ក្នុងអាកាស ។ ពួកសិស្សទាំងនុ៎ះ ជាអ្នកប្រាថ្នាតិច មានប្រាជ្ញាខ្ជាប់ខ្ជួន មានអាហារតិច មិនល្មោភ សន្តោសដោយលាភ និងឥតលាភ តែងចោមរោមខ្ញុំ សព្វកាល ។ ពួកសិស្សទាំងនុ៎ះ ជាអ្នកប្រាជ្ញ មានឈាន ត្រេកអរក្នុងឈាន មានចិត្តស្ងប់រម្ងាប់ មានសមាធិ ប្រាថ្នានូវការមិនមានកង្វល់ តែងចោមរោមខ្ញុំ សព្វកាល ។ ពួកសិស្សទាំងនុ៎ះ ជាអ្នកប្រាជ្ញ ដល់នូវត្រើយនៃអភិញ្ញា ត្រេកអរក្នុងគោចរ ជាកេរ្តិ៍នៃបិតា ត្រាច់ទៅក្នុងអាកាសបាន តែងចោមរោមខ្ញុំ សព្វកាល ។ ពួកសិស្សខ្ញុំនោះ ជាអ្នកប្រាជ្ញ សង្រួមក្នុងទ្វារ ៦ មិនមានតណ្ហា ជាគ្រឿងញាប់ញ័រ មានឥន្ទ្រិយរក្សាហើយ មិនច្រឡូកច្រឡំ ( ដោយពួកគណៈ ) ដែលគេគ្របសង្កត់បានដោយក្រ ។ ពួកសិស្សរបស់ខ្ញុំទាំងនោះ ដែលគេគ្រប

សង្កត់បានដោយក្រ រមែងញុំាងរាត្រីឲ្យកន្លងទៅ ដោយការអង្គុយ ផ្គត់ភ្នែន ការឈរ និងការចង្ក្រម ។ ពួកសិស្សរបស់ខ្ញុំ ដែលគេគ្របសង្កត់បានដោយក្រ រមែងមិនត្រេកត្រអាលក្នុងអារម្មណ៍ ដែលគួរត្រេកអរ មិនខឹង ក្នុងអារម្មណ៍ដែលគួរខឹង មិនវង្វេង ក្នុងអារម្មណ៍ដែលគួរវង្វេង ។ ពួកសិស្សទាំងនោះ កាលល្បងឫទ្ធិ រមែងប្រព្រឹត្តអស់កាលជានិច្ច ពួកសិស្សទាំងនោះ តែងញុំាងផែនដីឲ្យញាប់ញ័រ ជាបុគ្គលដែលគេមិនងាយគ្របសង្កត់បាន ដោយការប្រណាំងប្រជែង ។ ពួកសិស្សទាំងនោះ កាលបើលេង រមែងលេងតែឈាន តែងយកផ្លែព្រីង អំពីដើមព្រីង ពួកសិស្សរបស់ខ្ញុំ ជាបុគ្គលដែលគេគ្របសង្កត់បានដោយក្រ ។ ពួកខ្លះ ទៅគោយានទ្វីប ពួកខ្លះ ទៅបុព្វវិទេហទ្វីប ពួកខ្លះ ទៅកាន់ឧត្តរកុរុទ្វីប ពួកសិស្សខ្ញុំគេគ្របសង្កត់បានដោយក្រ ។ ពួកសិស្សទាំងនោះ រមែងបញ្ជូននូវអម្រែកទៅមុន ពួកសិស្សទាំងនោះ រមែងទៅខាងក្រោយ ទាំងផ្ទៃអាកាស ក៏សឹងតែបិទបាំងដោយពួកតាបស ២៤ ពាន់រូប ។ ( ពួកសិស្សរបស់ខ្ញុំ ខ្លះបរិភោគ ) ផ្លែឈើដែលចម្អិនដោយភ្លើង ( ខ្លះបរិភោគ ) ផ្លែឈើមិនបាច់ចម្អិនដោយភ្លើង ខ្លះទំពាដោយធ្មេញ ខ្លះបុកក្នុងត្បាល់ ខ្លះដំដោយថ្ម ខ្លះបរិភោគ ផ្លែឈើជ្រុះឯង ។ ពួកខ្លះទៀត ចុះត្រាំទឹក ក្នុងវេលាល្ងាចព្រឹក ជាអ្នកត្រេកអរ ក្នុងអំពើដ៏ស្អាត ប្រព្រឹត្តស្រោចស្រពដោយទឹក ពួកសិស្សរបស់ខ្ញុំ គេគ្រប

សង្កត់បានដោយក្រ ។ ជាអ្នកមានរោមក្លៀក និងក្រចកដុះវែង មានធ្មេញ ប្រកបដោយមន្ទិល មានក្បាលប្រឡាក់ដោយធូលី ក្រអូបដោយក្លិននៃសីល ពួកសិស្សរបស់ខ្ញុំ គេគ្របសង្កត់បានដោយក្រ ។ ពួកជដិលប្រជុំគ្នាក្នុងវេលាព្រឹក មានតបៈដ៏ខ្លាំង សម្តែងនូវលាភធំ និងលាភតូច ហើយទៅក្នុងអាកាស ក្នុងកាលនោះ ។ កាលពួកតាបសទាំងនុ៎ះ ចៀសចេញទៅ សូរសព្ទខ្លាំង ក៏លាន់ឮឡើង ពួកទេវតាក៏រីករាយ ដោយសូរសព្ទស្បែកខ្លា ( របស់ពួកតាបសទាំងនោះ ) ។ ពួកឥសី ជាអ្នកត្រាច់ទៅក្នុងអាកាស តែងចេញទៅកាន់ទិសតូច ទិសធំ ឥសីទាំងនោះ ជាអ្នករឹងប៉ឹងដោយកម្លាំងរបស់ខ្លួនទៅកាន់ទីតាមប្រាថ្នា ។ ពួកឥសីទាំងអស់នុ៎ះឯង ជាអ្នកញុំាងផែនដីឲ្យកម្រើក ត្រាច់ទៅក្នុងអាកាស ជាអ្នកមានតេជៈខ្លាំង គេគ្របសង្កត់បានដោយក្រ មិនញាប់ញ័រ ប្រៀបដូចសាគរ ។ ពួកខ្លះ ជាអ្នកកាន់វត្តឈរចង្ក្រម ពួកខ្លះទៀត កាន់វត្តអង្គុយ ពួកខ្លះ បរិភោគផ្លែឈើដែលជ្រុះឯង ពួកសិស្សខ្ញុំ គេគ្របសង្កត់បានដោយក្រ ។ ពួកឥសីទាំងនុ៎ះ ជាអ្នកនៅដោយមេត្តាធម៌ ជាអ្នកស្វែងរកប្រយោជន៍ដល់ពួកសត្វទាំងពួង ពួកឥសីទាំងអស់នោះ ជាអ្នកមិនលើកខ្លួនឯង មិនបង្អាប់បុគ្គលណាមួយ ។ ពួកឥសីទាំងនោះ ជាអ្នកមិនញាប់ញ័រ ដូចស្តេចសីហៈ មានកម្លាំងដូចស្តេចដំរី ឬដូចខ្លាធំ ដែលគេគ្របសង្កត់បានដោយក្រ រមែងមកកាន់ទីជិតនៃខ្ញុំជានិច្ច ។ ពួកវិជ្ជាធរ

និងទេវតា នាគ គន្ធព្វ អារក្សទឹក កុម្ភណ្ឌ អសុរ គ្រុឌ ក៏មកអាស្រ័យរស់នៅទីងស្រះនោះ ។ ពួកឥសីទាំងនោះ ជាអ្នកទ្រទ្រង់ផ្នួងសក់ និងបរិក្ខារ ស្លៀកដណ្តប់នូវសំពត់ ដែលធ្វើដោយស្បែកខ្លា អាចត្រាច់ទៅក្នុងអាកាសបាន ក៏មកអាស្រ័យរស់នៅទីងស្រះនោះ ។ ពួកឥសីទាំងនុ៎ះ មានការប្រព្រឹត្តដ៏សមគួរ ប្រកបដោយសេចក្តីគោរព ដល់គ្នានិងគ្នា ទាំងសម្តីទ្រគោះរកគ្នារបស់ពួកឥសីទាំង ២៤ ពាន់រូប ក៏មិនមានក្នុងកាលនោះ ។ ពួកឥសីទាំងអស់នោះ កាលទីងដាក់ជើង ក្នុងពេលឈានជើង មានសំឡេងតិចៗសង្រួមដោយល្អ ចូលមកជិតថ្វាយបង្គំខ្ញុំដោយត្បូង ។ ខ្ញុំមានឈានត្រេកអរក្នុងឈាន ត្រូវពួកសិស្សទាំងនោះ ដែលជាអ្នកស្ងប់ មានតបៈចោមរោមហើយ នៅក្នុងអាស្រមនោះ ។ អាស្រមក្រអូបដោយក្លិនរបស់ពួកឥសី និងក្លិនទាំងពីរ គឺក្លិនផ្កា និងក្លិនផ្លែឈើ របស់ឈើដែលមានផ្លែ ។ខ្ញុំមិនស្គាល់យប់ថ្ងៃ ខ្ញុំមិនមានសេចក្តីអផ្សុក ខ្ញុំកាលទូន្មានពួកសិស្សរបស់ខ្ញុំ តែងបាននូវសេចក្តីរីករាយយ៉ាងក្រៃលែង ។ ក្លិនទាំងឡាយ របស់ផ្កាឈើ ដែលកំពុងផ្កា និងផ្លែដែលកំពុងទុំ ក៏មានក្លិនដូចជាទិព្វ រមែងផ្សព្វផ្សាយទៅ ញុំាងអាស្រមរបស់ខ្ញុំឲ្យរុងរឿង ។ ខ្ញុំជាអ្នកមានព្យាយាមដុតកិលេស មានបញ្ញាខ្ជាប់ខ្ជួន ចេញអំពីសមាធិហើយ តែងកាន់យកនូវការៈ គឺអម្រែក ដើរទៅក្នុងព្រៃ ។ ខ្ញុំជាអ្នកសិក្សាល្អហើយ ក្នុងឧត្បាត

យល់សប្តិ និងលក្ខណៈទាំងឡាយ ចេះចាំនូវបទមន្តដែលគេនិយម ក្នុងកាលនោះ ។ ព្រះសម្ពុទ្ធមានជោគ ព្រះនាមអនោមទស្សី ជាចម្បងក្នុងលោក ជានរាសភៈ ទ្រង់ប្រាថ្នាវិវេកធម៌ បានស្តេចមកកាន់ហិមវន្តប្រទេស ។ លុះព្រះមុនីដ៏ខ្ពង់ខ្ពស់ ប្រកបដោយករុណាជាបុរសដ៏ឧត្តម ស្តេចចូលមកកាន់ហិមវន្តប្រទេសហើយ ទ្រង់គង់ផ្គត់ព្រះភ្នែន ( ទៀបអាស្រមរបស់ខ្ញុំ ) ។ ខ្ញុំបានឃើញព្រះសម្ពុទ្ធនោះ ប្រកបដោយពន្លឺ ជាទីត្រេកអរនៃចិត្ត រុងរឿង ដូចផ្ការាជព្រឹក្សឬក៏ដូចគំនរភ្លើងឆេះ នូវគ្រឿងយញ្ញដែលគេដុត ។ លុះខ្ញុំបានឃើញព្រះសម្ពុទ្ធ ជានាយកនៃលោក ព្រះអង្គរុងរឿង ដូចដើមឈើប្រចាំទ្វីប ឬដូចផ្លេកបន្ទោរក្នុងអាកាស ឬក៏ដូចសាលរាជព្រឹក្សមានផ្ការីកដ៏ល្អ ។ ខ្ញុំរំពឹងថា ព្រះមុនីដ៏ប្រសើរនេះ ជាមហាវីរបុរសទ្រង់ធ្វើនូវទីបំផុតទុក្ខ បុគ្គលអាស្រ័យការឃើញនេះ រមែងរួចចាកទុក្ខទាំងពួង ។ លុះខ្ញុំឃើញព្រះសម្ពុទ្ធ ជាទេវតារបស់ទេវតាហើយក៏ពិនិត្យមើលលក្ខណៈថា ព្រះពុទ្ធមែនឬហ្ន៎ ឬក៏មិនមែនជាព្រះពុទ្ធទេអេះ បើដូច្នោះ អាត្មាអញនឹងសង្កេតមើលនូវព្រះសម្ពុទ្ធ ព្រះអង្គមានចក្ខុ ។ ចក្រទាំងឡាយ មានកាំមួយពាន់ ក៏ប្រាកដក្នុងផ្ទៃព្រះបាទាដ៏ប្រសើរ លុះខ្ញុំឃើញលក្ខណៈ របស់ព្រះសម្ពុទ្ធនោះហើយក៏ដល់នូវសេចក្តីចូលចិត្ត ចំពោះព្រះតថាគត ។ ក្នុងគ្រានោះ ខ្ញុំចាប់យកអំបោស មកបោសលំនៅ រួចហើយ ប្រមូលយកផ្កា ៨

ក្តាប់មកបូជា ចំពោះព្រះសម្ពុទ្ធដ៏ប្រសើរ ។ លុះខ្ញុំបូជា ចំពោះព្រះពុទ្ធអង្គនោះ ជាបុគ្គលធ្ងន់ឱឃៈ មិនមានអាសវៈហើយ ទើបធ្វើនូវស្បែកខ្លាធៀងស្មាម្ខាង រួចទមស្ការចំពោះព្រះសម្ពុទ្ធ ជានាយកនៃសត្វលោក ។ ព្រះសម្ពុទ្ធ ព្រះអង្គមិនមានអាសវៈ សម្រេចដោយញាណណា ខ្ញុំនឹងសម្តែងនូវញាណរបស់ព្រះអង្គនោះ សូមអ្នកទាំងឡាយ ស្តាប់ខ្ញុំសម្តែងចុះ ។ បពិត្រព្រះអង្គ ជាព្រះសយម្ភូ មានករុណាមិនមានប្រមាណ សូមព្រះអង្គស្រង់សត្វលោកនេះឲ្យទាន ដ្បិតពួកសត្វ នឹងធ្លងនូវខ្សែទឹក គឺសេចក្តីសង្ស័យបាន ព្រោះអាស្រ័យនូវការជួបប្រទះនឹងព្រះអង្គ ។ ព្រះអង្គ ជាសាស្តាចារ្យផង ទុកដូចជាទង់ផង ដូចជាទង់ជ័យផង ដូចជាប្រាសាទរបស់ពួកសត្វ ព្រះអង្គជាអ្នកដឹកនាំផង ជាទីពឹងផង ជាពំនាក់ផង ជាបុគ្គលប្រសើរជាងសត្វជើងពីរផង ។ ទឹកក្នុងសមុទ្រ គេអាចវាល់ដោយអាឡ្ហកៈបាន សព្វញ្ញុតញ្ញាណរបស់ព្រះអង្គ គេមិនអាចវាល់បានឡើយ ។ គេអាចដាក់ដីក្នុងមណ្ឌលនៃជញ្ជីង ហើយថ្លឹងបាន ឯសព្វញ្ញុតញ្ញាណរបស់ព្រះអង្គ គេមិនអាចនឹងថ្លឹងបានឡើយ ។ គេអាចវាស់អាកាសដោយខ្សែ ឬដោយម្រាមដៃបាន ឯសព្វញ្ញុ-តញ្ញាណរបស់ព្រះអង្គ គេមិនអាចនឹងវាស់បានឡើយ ។ បុគ្គលគប្បីធ្វើទឹកក្នុងមហាសមុទ្រ និងផែនដី ឲ្យស្មើបាន តែមិនគប្បីយកពុទ្ធញាណ មកប្រកបដោយឧបមាបានឡើយ ។ ចិត្តរបស់សត្វ

ទាំងឡាយណា ប្រព្រឹត្តទៅក្នុងលោក ព្រមទាំងទេវលោក បពិត្រព្រះអង្គមានចក្ខុ សត្វទាំងឡាយទុំះ តាំងនៅខាងក្នុងនៃសំណាញ់ញាណរបស់ព្រះអង្គ ។ ព្រះអង្គ បានដល់នូវពោធិញ្ញាណដ៏ឧត្តមដោយសព្វគ្រប់ ដោយញាណណា បពិត្រព្រះសព្វញ្ញូ ព្រះអង្គរមែងញាំញីតិត្ថិយដទៃ ដោយញាណនោះ ។ តាបសឈ្មោះសុរុចិនោះសរសើរដោយគាថានេះហើយ ក៏ក្រាលនូវស្បែកខ្លា ទើបអង្គុយលើផែនដី ។ ភ្នំដែលលិចចុះទៅក្នុងមហាសមុទ្រ អស់ប្រមាណ ៨ ហ្មឺន ៤ ពាន់យោជន៍ ខ្ពស់ឡើងក៏ប៉ុណ្ណោះដែរ គេហៅថាស្ដេចភ្នំ ។ កម្ពស់ក្ដី បណ្ដោយក្ដី ទទឹងក្ដី នៃភ្នំសិនេរុនោះ មានប្រមាណមួយសែនកោដិយោជន៍ ដោយចំណែកនៃការរាប់ដ៏ល្អិត ។ ខ្នាច់ដែលគេតាំងទុក ខ្នាច់នោះ ក៏ដល់នូវការអស់ទៅ ឯសព្វញ្ញុតញ្ញាណរបស់ព្រះអង្គ គេមិនអាចរាប់បានឡើយ ។ បុគ្គលណាព័ទ្ធព័ទ្ធទឹកដោយសំណាញ់មានក្រឡាញឹក ពួកសត្វណាមួយ ក្នុងទឹក គប្បីតាំងនៅខាងក្នុងសំណាញ់ យ៉ាងណាមិញ ។ បពិត្រព្រះអង្គ ជាមហាវីរបុរស ពួកតិត្ថិយជាច្រើនណាមួយ ស្ទុះទៅកាន់ទីសាំញ៉ាំ គឺទិដ្ឋិដែលវង្វេងហើយ ដោយការប្រកាន់មាំ ក៏យ៉ាងនោះដែរ ។ ពួកសត្វទាំងអស់ទុំះ តាំងនៅក្នុងខាងក្នុងសំណាញ់ញាណដ៏បរិសុទ្ធរបស់ព្រះអង្គ ជាគ្រឿងឃើញ មិនមានអ្វីរាំងបាន រមែងមិនកន្លងនូវញាណរបស់ព្រះអង្គបានឡើយ ។ គាប់ជួន សម័យនោះ

ព្រះមានព្រះភាគជិនសិរី ព្រះនាមអនោមទស្សី ព្រះអង្គមានយសធំ ( ទ្រង់ឈ្មះមារ ) ចេញអំពីសមាធិ ហើយទ្រង់ប្រមើលមើលទិស ។ សាវកឈ្មោះនិសភៈរបស់ព្រះមុនី ព្រះនាមអនោមទស្សី មានពួកព្រះខីណាស្រពមួយសែនអង្គ ជាអ្នកមានចិត្តស្ងប់រម្ងាប់ មិនញាប់ញ័រដោយលោកធម៌ អ្នកបរិសុទ្ធ មានអភិញ្ញា ៦ មានចិត្តនឹងធឹងចោមរោមហើយ បានដឹងព្រះហឫទ័យរបស់ព្រះពុទ្ធ ក៏ចូលមកគាល់ព្រះសម្ពុទ្ធ ជាលោកនាយក ។ ពួកសាវកទាំងនោះ ស្ថិតនៅឰដ៏អាកាស ធ្វើប្រទក្សិណក្នុងទីនោះ ផ្គងអញ្ជលីនមស្ការ ចុះមកក្នុងសម្នាក់ព្រះពុទ្ធ ។ ព្រះមានព្រះភាគ ព្រះនាមអនោមទស្សី ជាចម្បងក្នុងលោក ជានរាសភៈ ព្រះអង្គឈ្នះមារ ទ្រង់គង់ត្រង់កណ្តាលពួកភិក្ខុ ហើយធ្វើនូវការញញឹមឲ្យប្រាកដ ។ ( លំដាប់នោះ ) ភិក្ខុអ្នកបម្រើ ឈ្មោះវរុណៈ របស់ព្រះសាស្តា ព្រះនាមអនោមទស្សី ធ្វើនូវចីវរឆៀងស្មាម្ខាង ហើយទូលសួរព្រះសម្ពុទ្ធ ជានាយកនៃលោកថា បពិត្រព្រះមានព្រះភាគ អ្វីជាហេតុនៃការញញឹម របស់ព្រះសាស្តា ព្រោះថា ព្រះពុទ្ធទាំងឡាយ មិនដែលធ្វើនូវការញញឹមឲ្យប្រាកដ ដោយឥតហេតុទេ ។ ព្រះមានព្រះភាគ ព្រះនាមអនោមទស្សី ជាចម្បងក្នុងលោក ជានរាសភៈ ទ្រង់គង់ក្នុងកណ្តាលពួកភិក្ខុ បានពោលគាថានេះថា តាបសណា បូជាតថាគត ដោយផ្កាផង សរសើរនូវញាណផង តថាគតនឹងសម្តែងចំពោះតាបស

នោះ ហេតុនេះ អ្នកទាំងឡាយ ចូរស្តាប់តថាគតសម្តែងចុះ ។ ពួកទេវតាទាំងអស់នោះ ព្រមទាំងមនុស្ស ចង់ស្តាប់ព្រះសទ្ធម្ម ទើបនាំគ្នាចូលមកគាល់ព្រះសម្ពុទ្ធ ព្រោះដឹងច្បាស់នូវព្រះវាចា របស់ព្រះពុទ្ធ ។ ពួកទេវតាមានឫទ្ធិច្រើន ក្នុងលោកធាតុទាំង ១០ ចង់ស្តាប់ព្រះសទ្ធម្ម ក៏ចូលមកគាល់ព្រះសម្ពុទ្ធ ។ សេនាមានអង្គ ៤ គឺ សេនាដំរី ១ សេនាសេះ ១ សេនារថ ១ សេនាថ្មើរជើង ១ នឹងចោមរោមតាបសនេះ អស់កាលជានិច្ច នេះជាផលនៃពុទ្ធបូជា ។ ពួកតូរ្យតន្ត្រី ៦០ ពាន់ ស្គរទាំងឡាយដែលតាក់តែងល្អ នឹងបម្រើតាបសនេះ អស់កាលជានិច្ច នេះជាផលនៃពុទ្ធបូជា ។ ពួកស្ត្រី ១៦ ពាន់ ពួកនារីដែលតាក់តែងល្អ មានសំពត់ និងគ្រឿងប្រដាប់ដ៏វិចិត្រ ពាក់កុណ្ឌល ជាវិការនៃកែវមណី ពួកនារីទាំងនោះ មានមុខទូលាយ ស្រស់ស្រាយ មានសញ្ញាដ៏ល្អ មានដងខ្លួនពាក់កណ្តាលដ៏វៀវ នឹងចោមរោមតាបសនេះ អស់កាលជានិច្ច នេះជាផលនៃពុទ្ធបូជា ។ ( សុរុចិតាបស ) នឹងរីករាយក្នុងទេវលោកអស់មួយសែនកប្ប នឹងបានជាស្តេចចក្រពត្តិក្នុងដែនអស់មួយពាន់ដង ។ បានជាព្រះឥន្ទ្រសោយរាជ្យ ក្នុងស្ថានទេវតាអស់មួយពាន់ដង នឹងសោយរាជ្យ ក្នុងប្រទេសដ៏ទូលាយ មិនអាចរាប់បាន ។ តាបសនេះ នឹងទៅកាន់អត្តភាពជាមនុស្ស ក្នុងកាលដែលដល់នូវបច្ឆិមភព នឹងទៅកើតក្នុងផ្ទៃ នៃនាងព្រាហ្មណី ឈ្មោះសារី ។

តាបសនេះ នឹងបានជាអ្នកមានបញ្ញាមុតថ្លា មាននាមថា សារីបុត្ត តាមនាម និងគោត្ររបស់មាតា ។ តាបសនេះ ជាអ្នកមិនមានកង្វល់ នឹងលះបង់នូវទ្រព្យ ៨០ កោដិ ហើយចេញបួស ស្វែងរកនូវសន្តិបទ គឺព្រះនិព្វាន នឹងត្រាច់មកកាន់ផែនដីនេះ ។ ព្រះសាស្តាព្រះនាមគោតម កើតក្នុងត្រកូលក្សត្រិយ៍ ឈ្មោះឱក្កាកៈ ក្នុងកប្បដែលប្រមាណមិនបាន អំពីកប្បនេះ នឹងកើតឡើងក្នុងលោក ។ តាបសនេះ នឹងបានជាឱរស ជាអ្នកទទួលមត៌កក្នុងធម៌ទាំងឡាយរបស់ព្រះសាស្តាអង្គនោះ ជាធម្មនិម្មិត ជាអគ្គសាវ័ក មានឈ្មោះសារីបុត្ត ។ ស្ទឹងឈ្មោះភាគីរសីនេះ ដែលបែកចេញមក អំពីភ្នំហិមពាន្ត រមែងហូរចុះទៅកាន់មហាសមុទ្រ ញុំាងមហាសមុទ្រឲ្យឆ្អែត យ៉ាងណាមិញ ។ ព្រះសារីបុត្តនេះ ជាបុគ្គលអង់អាចក្លៀវក្លាក្នុងការបែកធ្លាយ ៣ យ៉ាង ដល់នូវបញ្ញាបារមី នឹងញុំាងពួកសត្វឲ្យឆ្អែត ក៏យ៉ាងនោះដែរ ។ គំនរខ្សាច់ណាក្នុងចន្លោះនេះ រាប់យកទាំងភ្នំហិមពាន្ត និងមហាសមុទ្រសាគរ គំនរខ្សាច់នោះ គេមិនគប្បីរាប់បានឡើយ ។ តែបើការរាប់នូវគ្រាប់ខ្សាច់នោះ បុគ្គលអាចរាប់ដោយមិនសល់បាន យ៉ាងណា ទីបំផុតនៃប្រាជ្ញារបស់ព្រះសារីបុត្ត នឹងមិនមែនយ៉ាងនោះទេ ។ កាលបើគេដាក់ខ្នាច់គ្រាប់ខ្សាច់ក្នុងស្ទឹងគង្គា គប្បីអស់ទៅ ឯទីបំផុតនៃប្រាជ្ញារបស់ព្រះសារីបុត្ត នឹងមិនអស់ដូច្នោះទេ ។ រលកក្នុងមហាសមុទ្រ ដែលគេ

មិនគប្បីរាប់បាន ដោយការរាប់ យ៉ាងណា ទីបំផុតនៃប្រាជ្ញារបស់ព្រះសារីបុត្ត ក៏គេនឹងមិនអាចរាប់បាន យ៉ាងនោះ ។ តាបសនេះនឹងសម្រេចបញ្ញាបារមី បានជាអគ្គសាវក ញុំាងព្រះសម្ពុទ្ធព្រះនាមគោតមជាធ្ងើម ក្នុងពួកសត្វ ឲ្យត្រេកអរ នឹងបង្អុរនូវភ្លៀង គឺធម៌ ដោយប្រពៃ ប្រព្រឹត្តតាមធម្មចក្ក ដែលព្រះសម្ពុទ្ធ ជាសក្យបុត្តព្រះអង្គ ជាបុគ្គលនឹងធឹង ឲ្យប្រព្រឹត្តទៅហើយ ។ ព្រះសម្ពុទ្ធព្រះនាមគោតមជាធ្ងើម ក្នុងពួកសក្យៈ ទ្រង់ជ្រាបច្បាស់នូវហេតុទាំងនុ៎ះ ទ្រង់គង់ក្នុងកណ្ដាលនៃពួកភិក្ខុហើយ នឹងតាំង ( ព្រះសារីបុត្ត ) ក្នុងទីជាអគ្គសាវក ។

ឱហ្ន៎ ខ្ញុំបានធ្វើអធិការ ចំពោះព្រះសាស្ដា ព្រះនាមអនោមទស្សីអង្គណា ហើយបានសម្រេចបារមីក្នុងទីទាំងពួង អំពើដែលខ្ញុំធ្វើចំពោះព្រះសាស្ដាអង្គនោះ ចំជាត្រូវល្អ ។ កម្មដែលខ្ញុំធ្វើហើយក្នុងកាលប្រមាណមិនបាន ឲ្យផលហើយក្នុងជាតិនេះ ខ្ញុំរួចស្រឡះហើយ ដូចជាសម្ទុះនៃសរ ដុតបំផ្លាញហើយ នូវកិលេសទាំងឡាយ ។ ខ្ញុំនុ៎ះ កាលស្វែងរកនូវអសង្ខតធម៌ គឺព្រះនិព្វាន ជាផ្លូវមិនកម្រើក កាលពិនិត្យមើលនូវពួកតិរ្ថិយទាំងអស់ បានអន្ទោលទៅក្នុងភព ។ បុរសអ្នកមានព្យាធិ ស្វែងរកឱសថ ជ្រើសរើសនូវទ្រព្យទាំងអស់ ដើម្បីសះស្បើយចាកព្យាធិ យ៉ាងណាមិញ ។ បុគ្គលស្វែងរកផ្លូវនៃអមតនិព្វាន ជាអសង្ខតធម៌ បួសជាឥសី មិន

ដែលដាច់ អស់ ៥០០ ជាតិ ក៏យ៉ាងនោះដែរ ។ ខ្ញុំពេញហើយដោយការៈ គឺផ្នួងសក់ ស្លៀកដណ្ដប់នូវស្បែកខ្លាដ៏ប្រសើរ ដល់នូវអភិញ្ញាបារមី ហើយបានទៅកើតក្នុងព្រហ្មលោក ។ ការបរិសុទ្ធក្នុងសាសនាខាងក្រៅ វៀរលែងសាសនានៃព្រះជិនសិរី មិនមានទេ ពួកសត្វណាមួយ ជាអ្នកមានប្រាជ្ញា រមែងបរិសុទ្ធក្នុងសាសនានៃព្រះជិនសិរី ។ ខ្ញុំមិនទាន់យល់ច្បាស់នៅឡើយថា ដំណើរនុ៎ះ ជាកិច្ចប្រាថ្នានូវប្រយោជន៍របស់ខ្ញុំ ទើបខ្ញុំស្វែងរកអសទ្ធម្មតធម៌ អន្ទោលទៅកាន់លទ្ធិដ៏អាក្រក់ ។ បុរសអ្នកត្រូវការខ្លឹម កាត់ ពុះដើមចេកមិនគប្បីបានខ្លឹម ក្នុងដើមចេកនោះទេ ពិតណាស់ បុរសនោះ ជាអ្នកទទេចាកខ្លឹម យ៉ាងណាមិញ ។ ពួកជនជាច្រើននាក់ ជាតិរ្ថិយមានទិដ្ឋិផ្សេងៗ គ្នា ក្នុងលោក ជាអ្នកទទេសោះចាកអសទ្ធម្មតធម៌ក៏យ៉ាងនោះដែរ ដូចជាបុរសកាត់ដើមចេក ទទេចាកខ្លឹម ។ ក្នុងកាលដែលដល់នូវភពទីបំផុត ខ្ញុំបានកើតជាព្រាហ្មណ៍ លះបង់ភោគសម្បទជាច្រើន ហើយចូលទៅកាន់ផ្នួស ។

## ភាណវារទី ១ ចប់

ព្រាហ្មណ៍ ឈ្មោះសញ្ជ័យ ជាអ្នកបង្រៀនមន្ត ចេះចាំមន្ត ចេះចប់ត្រៃវេទ ខ្ញុំនៅក្នុងសម្នាក់ព្រាហ្មណ៍នោះ ។ បពិត្រព្រះអង្គ មានព្យាយាមធំ ព្រាហ្មណ៍ឈ្មោះអស្សជិ ដែលគេគ្របសង្កត់បានដោយក្រ មានតេជះខ្ពង់ខ្ពស់ ជាសាវ័ករបស់ព្រះអង្គ ត្រាច់ទៅបិណ្ឌបាត

ក្នុងកាលនោះ ។ ខ្ញុំព្រះអង្គ បានឃើញព្រះអស្សជិនោះ ជាមុនី ប្រកបដោយបញ្ញា ខ្ជាប់ខ្ជួនក្នុងញាណ មានចិត្តស្ងប់រម្ងាប់ ជាមហានាគ ( លោករីកពេញដោយគុណ ) ដូចផ្កាឈូករីក ។ លុះខ្ញុំឃើញព្រះអស្សជិ មានឥន្ទ្រិយទូន្មានល្អ មានចិត្តល្អ ដូចឧសភៈលោកប្រសើរ មានព្យាយាម ខ្ញុំក៏គិតថា ស្រមណ៍នេះ ប្រាកដជាព្រះអរហន្ត ទើបមានរូបល្អ សង្រួមល្អ គួរជាទីជ្រះថ្លា ទូន្មានឥន្ទ្រិយ ដែលគួរទូន្មានដ៏ប្រសើរ ប្រាកដជាឃើញនូវព្រះនិព្វានឈ្មោះអមតៈ ។ បើដូច្នោះ មានតែអាត្មាអញ សួរអត្ថដ៏ឧត្តម នឹងស្រមណ៍ជាអ្នកមានចិត្តរីករាយ ប្រសិនបើអញសួរទៅហើយ លោកនឹងតបបាន អាត្មាអញនឹងសូមសួរលោកតទៅទៀតក្នុងវេលានោះ ។ កាលព្រះអស្សជិ កំពុងនិមន្តទៅបិណ្ឌបាត ខ្ញុំក៏បានដើរតាមពីក្រោយ រិះរកឱកាស ដើម្បីសួរនូវអមតបទ ។ ខ្ញុំបានចូលទៅសួរព្រះអស្សជិត្ថេរ ដែលនិមន្តដល់ត្រង់ចន្លោះថ្នល់ថា បពិត្រលោកមានព្យាយាម លោកជាគោត្រអ្វី បពិត្រលោកនិរទុក្ខ លោកជាសិស្សរបស់គ្រូណា ។ ព្រះអស្សជិត្ថេរនោះ កាលបើខ្ញុំសួរហើយក៏បានដោះស្រាយថា ម្នាលអាវុសោ ព្រះសម្ពុទ្ធ ដូចកេសររាជសីហ៍មិនចេះខ្លាច កើតហើយក្នុងលោក អាត្មាជាសិស្សរបស់ព្រះសម្ពុទ្ធនោះ ។ បពិត្រលោកមានព្យាយាមធំ ជាអនុជាត មានយសធំ ចុះពាក្យប្រដៅនៃព្រះសម្ពុទ្ធរបស់លោក តើដូចម្ដេច សូមលោក

សម្តែងធម៌ គឺពាក្យប្រដៅ ( របស់ព្រះសម្ពុទ្ធនោះ ) ដល់ខ្ញុំ ។ ព្រះអស្សជិត្ថេរនោះ កាលបើខ្ញុំសួរហើយ ទើបសម្តែងនូវសាសនធម៌ទាំងពួង ដែលល្អិតជ្រាលជ្រៅ ជាចំណែក ( និព្វាន ) ជាគុណកម្ចាត់បង់នូវសរ គឺតណ្ហា ដែលបន្ទោបង់នូវកងទុក្ខទាំងពួងថា ធម៌ទាំងឡាយណា មានហេតុជាដែនកើតមុន ព្រះតថាគត បានសម្តែងនូវហេតុរបស់ធម៌ទាំងនោះផង នូវការរលត់នៃធម៌ទាំងនោះផង ព្រះមហាសមណៈ តែងពោលយ៉ាងនេះ ។ កាលព្រះអស្សជិត្ថេរ បានដោះស្រាយបញ្ហាហើយ ខ្ញុំក៏បានសម្រេចផលជាបឋម បានប្រាសចាកធូលី ប្រាសចាកមន្ទិល ព្រោះបានស្តាប់ពាក្យប្រដៅរបស់ព្រះជិនស្រី ។ លុះខ្ញុំបានស្តាប់ព្រះពុទ្ធដីការបស់ព្រះមុនីហើយ ឃើញនូវធម៌ដ៏ឧត្តម ទាំងមានចិត្តចុះស៊ប់ស្ងួន ក្នុងព្រះសទ្ធម្មហើយ បានពោលនូវគាថានេះថា ធម៌នេះ ជាគន្លងនៃសេចក្តីជាក់ច្បាស់ មិនមានសោក ដែលខ្ញុំមិនទាន់ឃើញ កន្លងទៅយូរហើយ ដោយសែននៃកប្បជាច្រើន ។ កាលខ្ញុំស្វែងរកធម៌ បានត្រាច់ទៅហើយ ក្នុងលទ្ធិអាក្រក់ ឥឡូវប្រយោជន៍នោះ ខ្ញុំបានសម្រេចហើយ វេលានេះ ជាកាលគួរខ្ញុំមិនប្រមាទ ។ ខ្ញុំដែលបានព្រះអស្សជិត្ថេរ ប្រោសប្រាណហើយ ក៏បានសម្រេចអចលបទ គឺព្រះនិព្វាន ទើបទៅស្វែងរកជួបនឹងសម្លាញ់ ក៏បានទៅឯអាស្រម ។ សម្លាញ់របស់ខ្ញុំ ជាអ្នកសិក្សាល្អ បរិបូណ៌ដោយឥរិយាបថ បានឃើញខ្ញុំអំពីចម្ងាយ ក៏សួរខ្ញុំថា

អ្នកមានមុខ និងភ្នែកដ៏ស្រស់បស់ មានភាពជាអ្នកប្រាជ្ញ អ្នកប្រហែលជាបានសម្រេច នូវចំណែកនៃព្រះនិព្វាន ឈ្មោះអមតៈ ជាធម៌មិនច្យុតហើយឬ នៃព្រាហ្មណ៍ អ្នកមានសភាពល្អ បានដើរមក អ្នកទូន្មានខ្លួនក្នុងធម៌ ដែលគប្បីទូន្មានរបស់អ្នកទូន្មានហើយ មានចិត្តស្ងប់រម្ងាប់ ដូចដំរីដែលគេបង្ហាត់ មិនឲ្យញាប់ញ័រ ។ ខ្ញុំប្រាប់សម្លាញ់ថា ព្រះនិព្វាន ឈ្មោះអមតៈ ជាគុណ បន្ទោបង់នូវសរគឺសេចក្ដីសោក ខ្ញុំបានសម្រេចហើយ អ្នកចូរសម្រេចព្រះនិព្វាននោះចុះ យើងនឹងនាំគ្នាទៅកាន់សម្នាក់ព្រះពុទ្ធ ។ សម្លាញ់របស់ខ្ញុំនោះជាអ្នកសិក្សាល្អ បានទទួលពាក្យថា ប្រពៃហើយ រួចចាប់ដៃគ្នាដើរចូលមកសម្នាក់ព្រះអង្គ ក្រាបទូលថា បពិត្រព្រះសក្យបុត្ត ខ្ញុំព្រះអង្គទាំងពីរនាក់ នឹងបួសក្នុងសម្នាក់នៃព្រះអង្គ ជាអ្នកមិនមានអាសវៈ ព្រោះបានអាស្រ័យនូវសាសនធម៌របស់ព្រះអង្គហើយ ។ កោលិតជាបុគ្គលប្រសើរ ដោយឫទ្ធិ ឯខ្ញុំព្រះអង្គ ជាបុគ្គលដល់នូវត្រើយនៃបញ្ញា យើងខ្ញុំទាំងពីរនាក់ បានញុំាងសាសនធម៌ឲ្យល្អដូចគ្នា ។ កាលដែលខ្ញុំព្រះអង្គ មានបំណងមិនទាន់បានសម្រេចនៅឡើយ បានត្រាច់ទៅក្នុងលទ្ធិអាក្រក់ លុះបានមកជួបប្រទះនឹងព្រះអង្គ ទើបបំណងរបស់ខ្ញុំព្រះអង្គ ពេញបរិបូណ៌ឡើង ។ ឈើទាំងឡាយ ដែលដុះលើផែនដី រមែងមានផ្ការីកក្នុងរដូវ ក្លិនទាំងឡាយជាទិព្វ រមែងផ្សាយទៅ ញុំាងពួកសត្វទាំងពួង ឲ្យត្រេកអរ

បាន ( យ៉ាងណាមិញ ) ។ បពិត្រព្រះអង្គ មានព្យាយាមធំ ជាសក្យបុត្ត មានយសធំ ខ្ញុំព្រះអង្គតាំងនៅក្នុងសាសនារបស់ព្រះអង្គ ខំស្វែងរក ( នូវសម័យ ) ដើម្បីផ្កា ខ្ញុំស្វែងរកផ្កា គឺវិមុត្តិ ជាគ្រឿងរួចចាកកវសង្សារ តែងធ្វើពួកសត្វទាំងពួងឲ្យត្រេកអរ ដោយការបាននូវផ្កា គឺវិមុត្តិ ក៏យ៉ាងនោះដែរ ។ បពិត្រព្រះអង្គមានបញ្ញាចក្ខុ ក្នុងពុទ្ធក្ខេត្តទាំងប៉ុន្មាន លើកលែងតែព្រះមហាមុនីចេញ មិនមានបុគ្គលណា នឹងប្រហែលដោយប្រាជ្ញានៃបុត្តរបស់ព្រះអង្គទេ ។ ពួកសិស្សរបស់ព្រះអង្គ បានទូន្មានល្អហើយផង ពួកបរិស័ទសិក្សាល្អហើយផង គប្បីទូន្មានឥន្ទ្រិយដ៏ប្រសើរ លោកទាំងនោះ មានឥន្ទ្រិយទូន្មានហើយ តែងចោមរោមព្រះអង្គ សព្វៗ កាល ។ ពួកបរិស័ទដែលមានឈាន ត្រេកអរក្នុងឈាន មានប្រាជ្ញា មានចិត្តស្ងប់រម្ងាប់ មានចិត្តតម្កល់មាំ ជាមុនី បរិបូណ៌ដោយញាណ តែងចោមរោមព្រះអង្គ សព្វៗ កាល ។ ពួកបរិស័ទ ដែលជាអ្នកប្រាថ្នាតិច មានបញ្ញាឆ្អិន មានបញ្ញាជាគ្រឿងទ្រទ្រង់ មានអាហារតិច មិនល្មោភ ជាអ្នកសន្តោសតាមមានតាមបាន តែងចោមរោមព្រះអង្គ សព្វៗ កាល ។ ពួកបរិស័ទ ដែលជាអ្នកប្រព្រឹត្តនៅក្នុងព្រៃ ត្រេកអរក្នុងការកម្ចាត់បង់នូវកិលេស មានឈាន មានចីវរសៅហ្មង ត្រេកអរតែក្នុងទីស្ងាត់ មានប្រាជ្ញាជាគ្រឿងចងចាំ តែងចោមរោមព្រះអង្គ សព្វៗ កាល ។ ពួកសេក្ខបុគ្គល កំពុងប្រតិបត្តិខ្ជះ ស្ថិតនៅ

ក្នុងផលខ្ទះ និងព្រះអរហន្ត បរិបូណ៌ដោយផលខ្ទះ ជាអ្នកស្វែងរកប្រយោជន៍ដ៏ខ្ពង់ខ្ពស់ តែងចោមរោមព្រះអង្គ សព្វៗ កាល ។ ពួកសោតាបន្នបុគ្គល មិនមានធម៌ជាមន្ទិលផង សកទាគាមិបុគ្គលផង អនាគាមិបុគ្គលផង អរហន្តផង តែងចោមរោម ព្រះអង្គសព្វៗ កាល ។ ពួកសាវ័កជាច្រើនរបស់ព្រះអង្គ ជាអ្នកឈ្លាសវៃ ក្នុងសតិប្បដ្ឋាន ត្រេកអរក្នុងការចម្រើនពោជ្ឈង្គ តែងចោមរោមព្រះអង្គសព្វៗ កាល ។ ពួកសាវ័ក អ្នកឈ្លាសវៃក្នុងឥទ្ធិបាទ ត្រេកអរក្នុងការចម្រើនសមាធិ ប្រកបនូវសម្មប្បធាន តែងចោមរោមព្រះអង្គសព្វៗ កាល ។ ពួកសាវ័កអ្នកបាននូវត្រៃវិជ្ជាផង បានអភិញ្ញា ៦ ផង ដល់នូវត្រើយនៃឫទ្ធិផង ដល់នូវត្រើយនៃប្រាជ្ញាផង តែងចោមរោមព្រះអង្គសព្វៗ កាល ។ បពិត្រព្រះអង្គមានព្យាយាមធំ ពួកសិស្សរបស់ព្រះអង្គបែបនេះ បានសិក្សាល្អ កម្របុគ្គលគ្របសង្កត់បាន មានតេជះខ្ពង់ខ្ពស់ តែងចោមរោមព្រះអង្គ សព្វៗ កាល ។ ព្រះអង្គត្រូវពួកសិស្សទាំងនោះ ដែលជាអ្នកសង្រួម មានតបៈចោមរោមហើយ ទ្រង់មិនខ្លាច ដូចស្តេចម្រឹគ រុងរឿងដូចព្រះចន្ទ្រ ។ ឈើទាំងឡាយដុះនៅលើផែនដី តែងលូតលាស់ចម្រើនឡើង ឈើទាំងនោះ តែងបញ្ចេញផ្លែ ។ បពិត្រព្រះសក្យបុត្ត មានយសធំ ព្រះអង្គដូចផែនដី ពួកសាវ័កតាំងនៅក្នុងសាសនធម៌របស់ព្រះអង្គហើយ តែងបាននូវផ្លែ គឺអមតមហានិព្វាន ។ សាគរទទួលទឹក

របស់ស្ទឹងទាំងនុ៎ះ គឺសិន្ធុ សរស្សតី ចន្ទភាគា គង្គា យមុនា សរភូ និងមហី ដែលហូរមក ។ ទឹកស្ទឹងទាំងនោះ តែងលះបង់ឈ្មោះដើមចោលចេញ គេដឹងថា ជាសាគរតែម្យ៉ាង ( យ៉ាងណាមិញ ) ។ វណ្ណៈទាំង ៤ នេះ លុះបួសក្នុងសម្នាក់របស់ព្រះអង្គហើយ តែងលះឈ្មោះដើមចោលចេញ គេដឹងថា ជាពុទ្ធបុត្រតែម្យ៉ាង ក៏យ៉ាងនោះដែរ ។ មួយទៀត ព្រះចន្ទប្រាសចាកមន្ទិលអណ្តែតទៅក្នុងអាកាសធាតុ មានពន្លឺរុងរឿង កន្លងនូវពួកផ្កាយទាំងអស់ ក្នុងលោក យ៉ាងណាមិញ ។ បពិត្រព្រះអង្គ មានព្យាយាមធំ ព្រះអង្គមានពួកទេវតា និងមនុស្សចោមរោមហើយ ទ្រង់រុងរឿងកន្លងនូវពុទ្ធក្ខេត្ត សព្វកាល ក៏យ៉ាងនោះដែរ ។ រលកដែលតាំងឡើងក្នុងទឹកជ្រៅ មិនប្រព្រឹត្តកន្លងនូវច្រាំង រលកទាំងនោះ រមែងមកផ្ទប់នឹងច្រាំងទាំងអស់ សឹងបែកខ្ទេចខ្ទី រោយរាយទៅ ( យ៉ាងណាមិញ ) ។ ពួកតិរ្ថិយជាច្រើន មានទិដ្ឋិផ្សេងៗគ្នាក្នុងលោក មានប្រាថ្នាដើម្បីនឹងឆ្លងនូវធម៌របស់ព្រះអង្គ ក៏មិនប្រព្រឹត្តកន្លងនូវព្រះអង្គជាមុនីឡើយ ក៏យ៉ាងនោះដែរ ។ បពិត្រព្រះអង្គ មានបញ្ញាចក្ខុ ប្រសិនបើពួកតិរ្ថិយទាំងនោះ មកដល់ព្រះអង្គដោយលំដាប់ នៃវាទៈទាំងឡាយ លុះចូលមកកាន់សម្នាក់ព្រះអង្គហើយ រមែងខ្ទេចខ្ទី ។ មួយទៀត ដើមកុមុទ និងចង្កុលណីជាច្រើនកើតឡើងក្នុងទឹក តែងទទឹកដោយទឹកផង ប្រឡាក់ដោយភក់ និង

ល្បាប់ផង យ៉ាងណាមិញ ។ ពួកសត្វជាច្រើន តែងកើតឡើង ចម្រើនឡើងក្នុងលោក ជាសត្វទទឹកដោយរាគៈ និងទោសៈ ដូចកុមុទក្នុងភក់ ក៏យ៉ាងនោះដែរ ។ ឈូកដែលដុះឡើងក្នុងទឹក រមែងរុងរឿងក្នុងកណ្ដាលទឹក ឈូកនោះ មិនជាប់ដោយទឹក នៅជាឈូកមានកេសរដ៏បរិសុទ្ធ យ៉ាងណាមិញ ។ បពិត្រព្រះអង្គ មានព្យាយាមធំ ជាមហាមុនី ព្រះអង្គកើតឡើងក្នុងលោក ព្រះអង្គមិនជាប់ជំពាក់ដោយលោក ដូចឈូក ( មិនជាប់ ) ដោយទឹក ក៏យ៉ាងនោះដែរ ។ ពួកវារិជាតិជាច្រើន តែងរីកក្នុងខែជាទីត្រេកអរ ( ខែកត្តិក ) មិនកន្លងខែនោះទៅបានឡើយ ព្រោះខែនោះ ជាសម័យរីក យ៉ាងណាមិញ ។ បពិត្រព្រះសក្យបុត្ត ព្រះអង្គរីកហើយ ដោយវិមុត្តិ ពួកសាវកទាំងនោះ រមែងមិនប្រព្រឹត្តកន្លងនូវសាសនាឡើយ ដូចផ្កាឈូករីកដោយទឹក ។ ស្ដេចសាលព្រឹក្សមានផ្ការីកហើយ តែងផ្សាយនូវក្លិនដូចជាទិព្វ ស្ដេចសាលព្រឹក្ស មានពួកសាលព្រឹក្សដទៃចោមរោម តែងល្អដោយនាមជាសាលព្រឹក្ស យ៉ាងណាមិញ ។ បពិត្រព្រះអង្គ មានព្យាយាមធំ ព្រះអង្គរីកហើយ ដោយពុទ្ធញ្ញាណ មានភិក្ខុសង្ឃចោមរោមហើយ រុងរឿងដូចជាស្ដេចសាលព្រឹក្ស ក៏យ៉ាងនោះដែរ ។ មួយទៀត ភ្នំហិមពាន្ត ជាឱសថរបស់សត្វទាំងអស់ផង ជាទីនៅនៃពួកនាគ អសុរ និងពួកទេវតាផង យ៉ាងណាមិញ ។ បពិត្រព្រះអង្គ មានព្យាយាមធំ ព្រះអង្គដូចជាឱសថនៃពួក

សត្វដែលបានត្រៃវិជ្ជា បានឆឡភិញ្ញា ដល់ហើយនូវបារមីនៃឫទ្ធិផង ក៏យ៉ាងនោះដែរ ។ បពិត្រព្រះអង្គ មានព្យាយាមធំ សត្វទាំងនោះ ដែលព្រះអង្គ មានព្រះហឫទ័យករុណា ទ្រង់ប្រដៅហើយ តែងរីករាយដោយតម្រេកធម៌ តែងនៅក្នុងសាសនានៃព្រះអង្គ ។ សីហៈជាមិគរាជ ចេញអំពីទីអាស្រ័យហើយ តែងក្រឡេកមើលទិសទាំង ៤ ទើបបន្ទឺឡើង ៣ ដង ។ កាលមិគរាជបន្ទឺឡើង ពួកម្រឹគទាំងអស់ តែងតក់ស្លុតយ៉ាងខ្លាំង ព្រោះតែស្តេចម្រឹគនុ៎ះ ជាសត្វមានជាតិខ្ពស់ តែងធ្វើសត្វឲ្យតក់ស្លុត សព្វៗ កាល ( យ៉ាងណាមិញ ) ។ បពិត្រព្រះអង្គ មានព្យាយាមធំ កាលព្រះអង្គមានបន្ទូល ផែនដីនេះកម្រើក ពួកសត្វដែលគួរត្រាស់ដឹង រមែងត្រាស់ដឹង ពួកមារតែងតក់ស្លុត ។ បពិត្រព្រះមហាមុនី កាលបើព្រះអង្គទ្រង់បន្ទឺឡើង ពួកតិរ្ថិយទាំងអស់ តែងតក់ស្លុត ដូចពួកក្អែក និងខ្វែង ដែលភ្ញាក់ផ្អើល ឬដូចជាពួកម្រឹគ ដែលភ្ញាក់ផ្អើល ដោយសារស្តេចម្រឹគ ។ ពួកមេគណៈណា ដែលគេហៅថា សាស្តាក្នុងលោក មេគណៈទាំងនោះ តែងសម្តែងប្រាប់បរិស័ទ នូវធម៌ដែលនាំមកតៗ គ្នា ។ បពិត្រព្រះអង្គ មានព្យាយាមធំ ឯព្រះអង្គមិនសម្តែងធម៌ដល់ពួកសត្វដូច្នោះទេ ព្រោះត្រាស់ដឹងនូវសច្ចធម៌ទាំងឡាយ ដោយព្រះអង្គឯង ព្រមទាំងត្រាស់ដឹងនូវពោធិបក្ខិយធម៌ទាំងអស់ ដោយព្រះអង្គឯង ។ ព្រះអង្គទ្រង់ជ្រាបនូវអាសយានុសយៈ នូវឥន្ទ្រិយទាំងឡាយ

នូវពល និងមិនមែនពល ទ្រង់ជ្រាបច្បាស់នូវពួកសត្វដែលមានភ័ព្វ និងឥតភ័ព្វ ហើយទ្រង់សម្តែងធម៌ ដូចមហាមេឃ ( គំរាមហើយ ) ។ បរិស័ទអង្គុយក្នុងទីបំផុតនៃចក្រវាឡ មានទិដ្ឋិផ្សេងៗ គ្នា តែងត្រិះរិះនូវធម៌នោះ ដើម្បីនឹងផ្តាច់បង់សេចក្តីសង្ស័យ ។ ព្រះមុនី ទ្រង់ឈ្លាសវៃក្នុងបទឧបមា បានជ្រាបនូវចិត្តរបស់សត្វទាំងអស់ ទ្រង់សម្តែងតែបញ្ហាមួយ ក៏បានកាត់បង់នូវសេចក្តីសង្ស័យ របស់ពួកសត្វបាន ។ ផែនដីដែលពេញដោយមនុស្ស ប្រកបដោយរាគាទិក្កិលេស មនុស្សទាំងអស់នោះ នាំគ្នាប្រណម្យអញ្ជលី សរសើរគុណព្រះនាយក ។ ម្យ៉ាងទៀត មនុស្សទាំងនោះ កាលសរសើរគុណ គប្បីសរសើរដោយគុណផ្សេងៗ អស់មួយកប្ប ក៏មិនគប្បីសម្រេចនូវការរាប់បានឡើយ ( ព្រោះ ) ព្រះតថាគត មានគុណគេមិនគប្បីរាប់បាន ។ ព្រះជិនស្រីដ៏ប្រសើរ ដែលមនុស្ស និងទេវតាសរសើរហើយ ដោយកម្លាំងរបស់ខ្លួនយ៉ាងនោះ មនុស្សទាំងឡាយ កាលសរសើរ គប្បីសរសើរយ៉ាងនេះឯង អស់កោដិនៃកប្ប ។ ប្រសិនបើ បុគ្គលណាមួយ ទោះជាទេវតា ឬមនុស្សដែលសិក្សាល្អហើយ គប្បីកំណត់ដើម្បីនឹងរាប់ ( នូវធារទឹកក្នុងសមុទ្រ ) បុគ្គលនោះ នឹងបានតែសេចក្តីលំបាក ។ បពិត្រព្រះសក្យបុត្ត មានយសធំ ខ្ញុំព្រះអង្គ ស្ថិតនៅហើយក្នុងសាសនារបស់ព្រះអង្គ ដល់នូវបញ្ញាបារមី ជាបុគ្គលមិនមានអាសវៈ ។ ថ្ងៃនេះ ខ្ញុំព្រះអង្គជា

ធម្មសេនាបតី ក្នុងសាសនារបស់ព្រះសក្យបុត្ត បានញុំាញពួកតិរ្ថិយ ញុំាងសាសនានៃព្រះជិនស្រី ឲ្យប្រព្រឹត្តទៅ ។ អំពើដែលខ្ញុំធ្វើហើយ អស់កប្បប្រមាណមិនបាន ឲ្យផលដល់ខ្ញុំ ក្នុងជាតិនេះ ខ្ញុំព្រះអង្គ បានផុតស្រឡះហើយចាកកិលេស ដូចកម្លាំងសរ ( ដែលផុតចាកធ្នូ ) ទាំងបានដុតបំផ្លាញ នូវកិលេសអស់ហើយ ។ មនុស្សណាមួយ បាននាំទៅនូវភារៈលើក្បាល សព្វៗ កាល ( មនុស្សនោះ ) ក៏ដល់នូវសេចក្តីទុក្ខដោយភារៈ ព្រោះភារៈជារបស់ធ្ងន់ ។ ឯខ្ញុំព្រះអង្គ ត្រូវភ្លើងកិលេសទាំង ៣ គឺលោភៈ ទោសៈ មោហៈ ដុតពេលហើយ បានអន្ទោលទៅក្នុងភពទាំងឡាយ សឹងតែធ្ងន់ហើយដោយទម្ងន់ គឺភព ដូចជាគេដកយកភ្នំសិនេរុ ( មកទូលលើក្បាល ) ។ ភារៈនោះ ខ្ញុំព្រះអង្គ បានទម្លាក់ចោលហើយ ភពទាំងឡាយ ខ្ញុំព្រះអង្គ ក៏បានទម្លាយចោលហើយ កិច្ចទាំងពួងដែលគួរធ្វើក្នុងសាសនា របស់ព្រះសក្យបុត្ត ខ្ញុំព្រះអង្គបានធ្វើរួចហើយ ។ ពុទ្ធក្ខេត្ត មានកំណត់ត្រឹមណា វៀរលែងតែព្រះអង្គ ជាបុគ្គលប្រសើរ ក្នុងសក្យត្រកូលចេញ ខ្ញុំព្រះអង្គ ជាបុគ្គលប្រសើរដោយប្រាជ្ញា នឹងរកបុគ្គលណា ឲ្យស្មើនឹងខ្ញុំព្រះអង្គពុំបាន ។ ខ្ញុំព្រះអង្គឈ្លាសវៃចំណាប់ ក្នុងសមាធិ ដល់នូវបារមីញាណ ដោយឫទ្ធិ ថ្ងៃនេះ ( បើ ) ខ្ញុំព្រះអង្គប្រាថ្នា ( នឹងធ្វើឫទ្ធិ ) ក៏គប្បីនិម្មិតប្រមាណ ១ ពាន់ឫទ្ធិបាន ។ ព្រះមហាមុនី ទ្រង់ស្ទាត់ស្ទាញខាង

អនុបុព្វវិហារធម៌ បានសម្តែងនូវសាសនធម៌ ដល់ខ្ញុំព្រះអង្គ ឯព្រះនិព្វាន ជាគ្រឿងរម្ងាប់ទុក្ខ ជាដំណេករបស់ខ្ញុំព្រះអង្គ ។ ទិព្វចក្ខុរបស់ខ្ញុំព្រះអង្គស្អាតហើយ ខ្ញុំព្រះអង្គជាបុគ្គលឈ្លាសវៃក្នុងសមាធិ បានប្រកបក្នុងសម្មប្បធាន ត្រេកអរក្នុងការចម្រើននូវពោជ្ឈង្គ ។ កិច្ចណា ដែលសាវកគួរដល់ កិច្ចទាំងអស់នោះ ខ្ញុំព្រះអង្គធ្វើស្រេចហើយ វៀរលែងតែព្រះលោកនាថចេញ នឹងរកបុគ្គលណា ឲ្យស្មើនឹងខ្ញុំព្រះអង្គ ពុំបានឡើយ ។ ខ្ញុំព្រះអង្គ ជាបុគ្គលឈ្លាសវៃក្នុងសមាបត្តិ ជាអ្នកបាននូវឈាន និងវិមោក្ខយ៉ាងរហ័ស ត្រេកអរក្នុងការចម្រើននូវពោជ្ឈង្គ ដល់ហើយនូវបារមីញាណ នៃសាវកគុណ ។ ចិត្ត ( របស់ខ្ញុំព្រះអង្គ ) ដែលសង្គ្រោះដោយសទ្ធា ក្នុងពួកសព្រហ្មចារី សព្វៗ កាល ព្រោះសេចក្តីគោរពចំពោះបុរសប្រសើរដោយប្រាជ្ញា ដោយការបាននូវសាវកគុណ ។ ខ្ញុំព្រះអង្គមានសេចក្តីឆោត គឺមានះដាក់ចុះហើយ ដូចពស់ មានចង្កូមគេដកហើយ ពុំនោះសោត ដូចគោមានស្នែងបាក់ ខ្ញុំព្រះអង្គ ចូលមកកាន់ទីប្រជុំសង្ឃ ដោយសេចក្តីគោរពក្រៃពេក ។ ឯបញ្ញារបស់ខ្ញុំព្រះអង្គ ប្រសិនបើ មានរូប គប្បីស្មើនឹងស្តេចផែនដីក៏បាន នេះជាផលនៃការសរសើរនូវញាណ របស់ព្រះមានព្រះភាគ ទ្រង់ព្រះនាមអនោមទស្សី ។ ធម្មចក្រដែលព្រះសក្យបុត្ត ជាតាទិបុគ្គលទ្រង់ឲ្យប្រព្រឹត្តទៅហើយ ខ្ញុំព្រះអង្គ ឲ្យប្រព្រឹត្តទៅតាម ដោយ

ប្រពៃ នេះជាផលនៃការសរសើរនូវញាណ ។ ( មួយទៀត ) បុគ្គល អ្នកមានសេចក្តីប្រាថ្នាលាមក ជាបុគ្គលខ្ជិល មានព្យាយាមថោក ថយ មិនចេះដឹង ប្រព្រឹត្តអនាចារ កុំឲ្យមកជួបប្រទះនឹងខ្ញុំព្រះអង្គ ក្នុងទីណាមួយបានឡើយ ។ បុគ្គល ជាអ្នកចេះដឹងច្រើន អ្នកមាន ប្រាជ្ញា អ្នកមានចិត្តតម្កល់មាំ ក្នុងសីល និងអ្នកប្រកបរឿយៗ នូវ ចេតោសមថៈ សូមចូលមកតម្កល់នៅលើក្បាល ( របស់ខ្ញុំ ) ។ ព្រោះហេតុនោះ ខ្ញុំសូមពោលនឹងលោកទាំងឡាយ សូមអំពើដ៏ ចម្រើន ( មាន ) ដល់លោកទាំងឡាយទាំងអស់ ដែលបានមកជួប ជុំ ក្នុងទីនេះ សូមលោកទាំងឡាយ មានប្រាថ្នាតិច សន្តោស នាំ គ្នាឲ្យទាន សព្វៗ កាលចុះ ។ ខ្ញុំបានជួបនូវអាចារ្យអង្គណាជាដំបូង ហើយបានប្រាសចាកធូលី ប្រាសចាកមន្ទិល អាចារ្យខ្ញុំនោះ ជាអ្នក ប្រាជ្ញ ជាសាវ័ក ឈ្មោះអស្សជិ ។ ខ្ញុំជាអ្នកស្តាប់ពាក្យនៃព្រះអស្សជិ អង្គនោះបានជាធម្មសេនាបតី បានដល់នូវបារមី ក្នុងទីទាំងពួងហើយ ជាអ្នកមិនមានអាសវៈ ។ ព្រះសាវ័កឈ្មោះអស្សជិ ជាអាចារ្យ របស់ខ្ញុំគង់ ក្នុងទិសណា ខ្ញុំធ្វើទីក្បាលដំណេក ទៅក្នុងទិសនោះ ។ ព្រះគោតម ជាបុគ្គលប្រសើរក្នុងសក្យត្រកូល ទ្រង់រឭកឃើញនូវ

អំពើរបស់ខ្ញុំ ទ្រង់គង់ក្នុងកណ្តាលជំនុំសង្ឃ ហើយតម្កល់ទុកនូវខ្ញុំក្នុងទីដ៏ប្រសើរ ។ បដិសម្ភិទា ៤ វិមោក្ខ ៨ និង អភិញ្ញា ៦ នេះ ខ្ញុំបានធ្វើឲ្យជាក់ច្បាស់ហើយ ទាំងសាសនា របស់ព្រះសម្ពុទ្ធ ខ្ញុំក៏បានប្រតិបត្តិហើយ ។

បានឮថា ព្រះសារីបុត្តត្ថេរមានអាយុ បានសម្តែងនូវគាថាទាំងនេះ ដោយប្រការដូច្នេះ ។

**សារីបុត្តត្ថេរាបទាន ចប់**

# អដ្ឋកថា
# ថេរាបទាន

## សារីបុត្តត្ថេរាបទាន

[ ៣ ] បន្ទាប់អំពីនោះ ដើម្បីពណ៌នាគាថាថេរាបទាន ទើបលោក ( ព្រះអានន្ទ ) ពោលថា **អថ ថេរាបទានំ សុណាថ** ដូច្នេះ ។

អត្ថនៃ **អថ** សព្ទ និង **អបទាន** សព្ទ បានពោលមកហើយខាងដើម បណ្តាសព្ទទាំងនេះ **ថេរ** សព្ទ ប្រព្រឹត្តទៅក្នុងអត្ថមិនមែនតិច មានអត្ថថា កាល មាំទាំ បញ្ញត្តិ ឈ្មោះ ធំ ជាដើម ។

ពិតហើយ **ថេរ** សព្ទ មកក្នុងអត្ថថា **កាល** ដូចក្នុងប្រយោគជាដើមថា **ថេរោវស្សិកានិ បូតីនិ ចុណ្ណកជាតានិ**[១] ប្រែថា កន្ទងទៅ ១ ឆ្នាំ ហើយពុកផុយ ខ្ទេចខ្ទីជាលម្អិតតូចលម្អិតធំ ។ អធិប្បាយថា កន្ទងឆ្នាំទាំងឡាយអស់កាលយូរ គឺអស់កាលយូរ ។

មកក្នុងអត្ថថា **មាំទាំ** ដូចក្នុងប្រយោគជាដើមថា **ថេរោបិ តាវ មហា** ប្រែថា ត្រឹមតែជាអ្នកមាំទាំ ជាធំ សេចក្តីថា ជាអ្នកមានសីលមាំទាំ ។

មកក្នុងអត្ថថា **បញ្ញត្តិ** ដូចក្នុងប្រយោគជាដើមថា **ថេរកោអយមាយស្មាមហល្លកោ** ប្រែថា អ្នកមានអាយុ នេះជាមនុស្សចាស់ សេចក្តីថា ត្រឹមតែជាឈ្មោះដែលសត្វលោកដាក់ឲ្យ ។

---

១- បិ.ខ្មែរសតិបដ្ឋានសូត្រថា តេរោវស្សិកានិ ... អដ្ឋិកានិ បូតីនិ ចុណ្ណកជាតានិ ។

មកក្នុងអត្ថថា **ឈ្មោះ** ដូចក្នុងប្រយោគជាដើមថា **ចុន្ទត្ថេរោ ផុស្សត្ថេរោ** ប្រែថា ព្រះចុន្ទត្ថេរ និងព្រះផុស្សត្ថេរ សេចក្ដីថា គេដាក់ឈ្មោះយ៉ាងនេះ ។

មកក្នុងអត្ថថា **ធំ** ដូចក្នុងប្រយោគជាដើមថា **ថេរោ ចាយំ កុមារោ មម បុត្តេសុ** ប្រែថា បណ្ដាកូនរបស់ខ្ញុំ កុមារនេះជាធំ សេចក្ដីថា ជាកូនច្បង ។

តែក្នុងទីនេះ **ថេរ** សព្ទនេះ ប្រើក្នុងអត្ថថា **កាល** និង **មាំទាំ** ព្រោះហេតុនោះ ឈ្មោះថា **ថេរ** ព្រោះតាំងនៅអស់កាលយូរ ។ មួយវិញទៀតលោកប្រកបដោយគុណ មានសីល អាចារ និងមទ្ទវ ( ការទន់ភ្លន់ ) ដ៏មាំទាំក្រៃលែង ហៅថា **ថេរ** ព្រះថេរៈ និងថេរៈ ព្រោះហេតុនោះ ទើបឈ្មោះថា ព្រះថេរៈទាំងឡាយ **អបទាន** គឺហេតុនៃព្រះថេរៈទាំងឡាយឈ្មោះថា **ថេរាបទាន** ភ្ជាប់សេចក្ដីថា អ្នកទាំងឡាយ ចូរស្ដាប់នូវថេរា-បទាននោះ ។

បទថា **ហិមវន្តស្ស អវិទូរេ លម្ពកោ នាម បព្វតោ** ដូច្នេះជាដើម ជាអបទានរបស់ព្រះសារីបុត្រ ។ រឿងរបស់លោកមានអាយុនោះ និងរបស់ព្រះមហាមោគ្គល្លានត្ថេរ គប្បីជ្រាបយ៉ាងនេះ ។

បានឮថា ក្នុងអតីតកាល ក្នុងទីបំផុត ១ អសង្ខេយ្យ និង ១ សែនកប្ប ព្រះសារីបុត្រកើតក្នុងត្រកូលព្រាហ្មណមហាសាល ឈ្មោះសរទមាណពព្រះមហាមោគ្គល្លាន កើតក្នុងត្រកូលគហបតីមហាសាល ឈ្មោះសិរិវឌ្ឍន-កុដុម្ពិកៈ ។ ជនទាំង ២ នោះ ជាសម្លាញ់លេងដីជាមួយគ្នា បណ្ដាជនទាំង

២ នោះ សរទមាណព កាលបិតាស្លាប់ទៅហើយ បានគ្រប់គ្រងទ្រព្យដែលជារបស់ត្រកូល ថ្ងៃមួយ នៅក្នុងទីស្ងាត់ គិតថា ឈ្មោះថា ការស្លាប់នៃសត្វទាំងនោះ ជារបស់ពិតប្រាកដ ព្រោះហេតុនោះ អញគួរកាន់យកការបួសណាមួយ ស្វែងរកផ្លូវរួចផុត ទើបចូលទៅរកសម្លាញ់ ហើយពោលថា នែសម្លាញ់ ខ្ញុំចង់បួស តើឯងបួសដែរឬទេ កាលសម្លាញ់នោះពោលថា មិនអាច ទើបពោលថា ណ្ហើយចុះ ខ្ញុំនឹងបួសម្នាក់ឯង ហើយឲ្យបើកឃ្លាំងរតនៈ ឲ្យនូវមហាទានដល់មនុស្សកំព្រា និងអ្នកដំណើរជាដើម ហើយទៅកាន់ជើងភ្នំ បួសជាឥសី ។ កាលសរទមាណពនោះបួស មានកូនព្រាហ្មណ៍ប្រមាណ ៧៤០០០ នាក់ បួសតាម ។ សរទតាបសនោះ ធ្វើអភិញ្ញា ៥ និងសមាបត្តិ ៨ ឲ្យកើតឡើងហើយ ទើបប្រាប់កសិណបរិកម្មដល់ជដិលទាំងនោះ ។ ជដិលទាំងអស់នោះ ធ្វើអភិញ្ញា ៥ និងសមាបត្តិ ៨ ឲ្យកើតឡើង ។

សម័យនោះ ព្រះសម្មាសម្ពុទ្ធព្រះនាមអនោមទស្សី ទ្រង់កើតឡើងក្នុងលោក ទ្រង់ប្រកាសព្រះធម្មចក្រដ៏ប្រសើរ បានញុំាងពួកសត្វឲ្យឆ្លងចាកមហាឱឃសង្សារ ។ ថ្ងៃមួយ មានបំណងនឹងសង្គ្រោះសរទតាបស និងពួកអន្តេវាសិក មួយអង្គឯងមិនមានសម្លាញ់ ទ្រង់កាន់បាត្រ និងចីវរ យាងទៅតាមអាកាស ទ្រង់ព្រះតម្រិះថា តាបសនេះ ចូរដឹងថា តថាគតជាព្រះពុទ្ធ កាលសរទតាបសនោះកំពុងឃើញនោះឯង ក៏យាងចុះអំពីអាកាស ទ្រង់ឈរលើផែនដី ។

សរទតាបសពិចារណាមហាបុរិសលក្ខណៈ ក្នុងព្រះសរីរៈរបស់ព្រះ

សាស្តាហើយ សន្និដ្ឋានថា បុរសនេះជាសព្វញ្ញុពុទ្ធដោយចំណែកមួយ ទើបធ្វើនូវការទទួល ក្រាលអាសនៈថ្វាយ ព្រះមានព្រះភាគ គង់លើអាសនៈដែលក្រាលហើយ សរទតាបសអង្គុយក្នុងចំណែកម្ខាង ក្នុងសម្នាក់របស់ព្រះសាស្តា ។

សម័យនោះ ជដិលប្រមាណ ៧៤០០០ នាក់ ដែលជាអន្តេវាសិករបស់តាបសនោះ នាំផ្លែឈើតូចធំដ៏ប្រណីតជាច្រើន មានរសឆ្ងាញ់ ត្រឡប់មក បានឃើញព្រះសាស្តា កើតនូវសេចក្តីជ្រះថ្លា សម្លឹងមើលការអង្គុយនៃអាចារ្យរបស់ខ្លួន និងរបស់ព្រះសាស្តា ទើបពោលថា លោកអាចារ្យកាលមុន ពួកខ្ញុំសម្គាល់ថា មិនមានបុគ្គលណាមួយដែលជាធំជាងលោក បុរសនេះ ប្រហែលជាធំជាងលោកទេដឹង ។ សរទតាបសពោលថា អ្នកទាំងឡាយពួកអ្នកនិយាយអ្វី ពួកអ្នកប្រាថ្នានឹងប្រៀបធៀបភ្នំសិនេរុ ដែលមានកម្ពស់ ១៦៨០០០ យោជន៍ ឲ្យប៉ុននឹងគ្រាប់ស្ពៃយ៉ាងនោះឬ ពួកអ្នកកុំនាំយើងទៅប្រៀបធៀបនឹងព្រះសព្វញ្ញុពុទ្ធឡើយ ។ លំដាប់នោះ តាបសនោះ បានស្តាប់ពាក្យរបស់អាចារ្យហើយ នាំគ្នាគិតថា បុគ្គលនេះជាឧត្តមបុរស ធំក្រៃលែងពិត ទើបជនទាំងអស់ក្រាបចុះទៀបបាទា ថ្វាយបង្គំព្រះសាស្តា ។

គ្រានោះ អាចារ្យក៏ពោលនឹងពួកសិស្សនោះថា នែអ្នកទាំងឡាយទេយ្យធម៌របស់ពួកយើង ដែលសមគួរដល់ព្រះសាស្តា មិនមាន ព្រះសាស្តាក៏យាងមកក្នុងទីនេះ ក្នុងពេលភិក្ខាចារ ណ្ហើយចុះ ពួកយើងនឹងថ្វាយទេយ្យធម៌ តាមកម្លាំង ផលាផលប្រណីតៗ ឯណា ដែលពួកអ្នកបាននាំមក

ចូរពួកអ្នកនាំផលាផលនោះមក កាលឲ្យនាំមកហើយ ទើបលាងដៃទាំង ២ ដាក់ផលាផលក្នុងបាត្ររបស់ព្រះតថាគតដោយខ្លួនឯង លុះព្រះសាស្តា ទ្រង់ទទួលផលាផល ទេវតាទាំងឡាយបានដាក់ទិព្វឱជាចូលទៅ ។ សូម្បីទឹក តាបស ក៏បានត្រងថ្វាយដោយខ្លួនឯងដូចគ្នា ។

បន្ទាប់អំពីនោះ កាលព្រះសាស្តាទ្រង់ធ្វើកិច្ចដោយភោជនស្រេចហើយ ប្រថាប់គង់ តាបសហៅអន្តេវាសិកទាំងអស់មក ហើយអង្គុយពោលសារាណីយកថា ក្នុងសម្នាក់របស់ព្រះសាស្តា ។ ព្រះសាស្តា ទ្រង់ព្រះតម្រិះថា អគ្គសាវកទាំង ២ ចូរមកព្រមគ្នា មួយអន្លើដោយពួកភិក្ខុ ។ រំពេចនោះ អគ្គសាវក មានព្រះខីណាស្រពមួយសែនជាបរិវារ បានមកថ្វាយបង្គំព្រះមានព្រះភាគ ហើយឈរក្នុងចំណែកម្ខាង ។

លំដាប់នោះ សរទតាបសក៏ហៅពួកអន្តេវាសិកមកពោលថា បាទាំងឡាយ គួរធ្វើការបូជាដោយអាសនៈផ្កា ដល់ព្រះសាស្តា និងភិក្ខុសង្ឃ ព្រោះហេតុនោះ ចូរពួកអ្នកទៅនាំផ្កាមក ។ រំពេចនោះ ពួកអន្តេវាសិកក៏នាំផ្កាទាំងឡាយ ដែលសម្បូរដោយពណ៌ និងក្លិនមកដោយឫទ្ធិ ហើយក្រាលអាសនៈផ្កាប្រមាណ ១ យោជន៍ដល់ព្រះពុទ្ធ ក្រាលអាសនៈផ្កាប្រមាណ ៣ គាវុតដល់អគ្គសាវកទាំង ២ ក្រាលអាសនៈផ្កាកន្លះយោជន៍ជាដើម ដល់ភិក្ខុដ៏សេស ក្រាលអាសនៈផ្កាប្រមាណ ១ ឧសភដល់សង្ឃនវកភិក្ខុ ។

កាលក្រាលអាសនៈទាំងឡាយយ៉ាងនេះហើយ សរទតាបសបានផ្គងអញ្ជលីចំពោះព្រះភក្ត្រព្រះតថាគត ហើយក្រាបទូលថា បពិត្រព្រះអង្គដ៏ចម្រើន

សូមទ្រង់យាងឡើងកាន់អាសនៈផ្កានេះ ដើម្បីអនុគ្រោះខ្ញុំព្រះអង្គផងចុះ ។ ព្រះមានព្រះភាគគង់លើអាសនៈផ្កា កាលព្រះសាស្តាប្រថាប់គង់ហើយ អគ្គ-សាវកទាំង ២ និងភិក្ខុដ៏សេស ក៏អង្គុយលើអាសនៈដែលសមគួរដល់ខ្លួន ។

ព្រះសាស្តាទ្រង់ចូលនិរោធសមាបត្តិ ដោយបំណងថា ចូរផលធំមានដល់តាបសទាំងនេះ ។ ឯអគ្គសាវកទាំង ២ និងភិក្ខុដ៏សេស ដឹងថា ព្រះសាស្តាទ្រង់ចូលនិរោធសមាបត្តិ ទើបនាំគ្នាចូលនិរោធសមាបត្តិផងដែរ ។ តាបសបានឈរបាំងឆត្រផ្កាថ្វាយព្រះសាស្តាមិនមានចន្លោះអស់កាល ៧ ថ្ងៃ ។ តាបសដ៏សេស បរិភោគផ្លែឈើមើមឈើក្នុងព្រៃហើយ ក្នុងកាលដ៏សេសបានឈរផ្គងអញ្ជលី ។

លុះកន្លងទៅបាន ៧ ថ្ងៃ ព្រះសាស្តាទ្រង់ចេញអំពីនិរោធសមាបត្តិ រួចត្រាស់ហៅព្រះនិសភត្ថេរអគ្គសាវកថា ចូរអ្នកធ្វើអនុមោទនាអាសនៈផ្កាដល់តាបសទាំងឡាយ ។ ព្រះថេរៈតាំងនៅក្នុងសាវកបារមីញាណ បានធ្វើអនុ-មោទនាអាសនៈផ្កាដល់តាបសទាំងឡាយនោះ លុះចប់ទេសនារបស់ព្រះនិសភៈនោះ ព្រះសាស្តាត្រាស់ហៅព្រះអនោមត្ថេរទុតិយសាវក ត្រាស់ថា ចូរអ្នកសម្តែងធម៌ដល់តាបសទាំងនេះ ។ ឯព្រះអនោមត្ថេរពិចារណាពុទ្ធវចនៈ គឺព្រះត្រៃបិដក ហើយពោលធម៌ដល់តាបសទាំងនោះ ។ ដោយទេសនារបស់អគ្គសាវកទាំង ២ មិនមានបុគ្គលណាបានត្រាស់ដឹងធម៌ ។

លំដាប់នោះ ព្រះសាស្តាទ្រង់តាំងនៅក្នុងពុទ្ធវិស័យ ហើយទ្រង់ផ្តើមព្រះធម្មទេសនា ។ ក្នុងកាលចប់ទេសនា ជដិល ៧៤០០០ នាក់ដ៏សេស វៀរ

សរទតាបស សម្រេចអរហត្តហើយ ។ ព្រះសាស្តា ទ្រង់លាព្រះហស្ត ចេញមកត្រាស់នឹងជដិលទាំងនោះថា អ្នកទាំងឡាយ ចូរមកជាភិក្ខុចុះ ។ គ្រានោះ ជដិលទាំងនោះ មានភេទតាបសអន្តរធានទៅ ជាអ្នកទ្រទ្រង់បរិក្ខារ ៨ ដូចព្រះថេរៈមានវស្សា ៦០ ដូច្នោះ ។

ឯសរទតាបស ព្រោះភាពដែលខ្លួនកើតបរិវិតក្ក ក្នុងវេលាសម្តែងធម៌ឱ្យថា អញក៏គប្បីជាសាវ័ករបស់ព្រះពុទ្ធមួយអង្គក្នុងអនាគត ដូចព្រះនិសភៈនេះ មានចិត្តភាវែក ទើបមិនអាចធ្វើឲ្យជាក់ច្បាស់នូវមគ្គផល ។ លំដាប់នោះ សរទតាបស ក៏ថ្វាយបង្គំព្រះសាស្តា ហើយបានធ្វើសេចក្តីប្រាថ្នាតាមនោះ ។ ព្រះសាស្តាទ្រង់ឃើញថា ការប្រាថ្នានឹងសម្រេចដោយមិនមានអន្តរាយ ទើបទ្រង់ព្យាករថា កន្លងទៅមួយអសង្ខេយ្យ និងមួយសែនកប្ប បន្ទាប់អំពីកប្បនេះទៅ អ្នកនឹងបានជាអគ្គសាវ័ក មានឈ្មោះសារីបុត្ត របស់ព្រះគោតមសម្មាសម្ពុទ្ធ ហើយត្រាស់ធម្មកថា មានភិក្ខុសង្ឃជាបរិវារ ទ្រង់ហោះឡើងកាន់អាកាស ។

ឯសរទតាបស ក៏បានទៅកាន់សម្នាក់របស់សិរិវឌ្ឍកុដុម្ពិកៈដែលជាសម្លាញ់ ហើយពោលថា នែសម្លាញ់ ខ្ញុំប្រាថ្នាតំណែងអគ្គសាវ័ករបស់ព្រះគោតមសម្មាសម្ពុទ្ធ ដែលនឹងកើតឡើងក្នុងអនាគត ទៀបបាទមូលរបស់ព្រះមានព្រះភាគ ព្រះនាមអនោមទស្សី ចូរអ្នកប្រាថ្នាតំណែងទុតិយសាវ័ករបស់ព្រះគោតមសម្មាសម្ពុទ្ធនោះ ។

សិរិវឌ្ឍកុដុម្ពិកៈបានស្តាប់ពាក្យណែនាំដូច្នោះ ទើបឲ្យពង្រាបផែនដីក្នុងទី

ប្រមាណ ៨ ករីស ត្រង់ទ្វារនិវេសន៍របស់ខ្លួន ឲ្យរៀបស្មើហើយ រោយផ្កាមានលាជជាគម្រប់ ៥ ឲ្យសាងមណ្ឌប ប្រក់ដោយឧប្បលខៀវ ឲ្យក្រាលអាសនៈសម្រាប់ព្រះពុទ្ធ ឲ្យក្រាលអាសនៈសម្រាប់ភិក្ខុទាំងឡាយ ហើយត្រៀមគ្រឿងសក្ការៈ និងគ្រឿងបូជាជាច្រើន ហើយឲ្យសរទតាបសទៅនិមន្តព្រះសាស្តាមក ញុំាងមហាទានឲ្យប្រព្រឹត្តទៅអស់ ៧ ថ្ងៃ ហើយឲ្យភិក្ខុសង្ឃមានព្រះពុទ្ធជាប្រធាន ស្លៀកដណ្តប់សំពត់ទាំងឡាយ ដែលមានតម្លៃច្រើន ហើយបានធ្វើសេចក្តីប្រាថ្នា ដើម្បីភាពជាទុតិយសាវក ។

ព្រះសាស្តាទ្រង់ឃើញថា ការប្រាថ្នានឹងសម្រេចដោយមិនមានអន្តរាយ ទើបទ្រង់ព្យាករដោយន័យដូចពោលហើយ ទ្រង់ធ្វើអនុមោទនាភត្ត ហើយចៀសចេញទៅ ។ សិរិវឌ្ឍកុដុម្ពិកៈត្រេកអរ ធ្វើកុសលកម្មដរាបដល់អស់អាយុ ហើយកើតក្នុងកាមាវចរទេវលោក ក្នុងវារចិត្តទី ២ សរទតាបសចម្រើនព្រហ្មវិហារ ៤ ហើយកើតក្នុងព្រហ្មលោក ។

ចាប់តាំងអំពីនោះ លោកមិនពោលដល់កម្មក្នុងរវាងភពរបស់សម្លាញ់ទាំង ២ ។ សរទតាបសបដិសន្ធិក្នុងគភ៌របស់នាងរូបសារីព្រាហ្មណី ក្នុងឧបតិស្សគ្រាម មិនឆ្ងាយអំពីនគររាជគ្រឹះ មុនការកើតឡើងរបស់ព្រះមានព្រះភាគនៃយើងទាំងឡាយ ។ ក្នុងថ្ងៃនោះឯង សម្លាញ់របស់សរទតាបសនោះ ក៏បដិសន្ធិក្នុងគភ៌របស់នាងមោគ្គល្លីព្រាហ្មណី ក្នុងកោលិតគាម មិនឆ្ងាយអំពីនគររាជគ្រឹះដូចគ្នា ។

ព្រោះហេតុនោះ ទើបកុលបុត្តនោះឈ្មោះថា មោគ្គល្លាន ព្រោះជាកូន

នៃនាងមោគ្គលីព្រាហ្មណី ។ម្យ៉ាងទៀត ឈ្មោះថា មោគ្គល្លាន ព្រោះកើតដោយមោគ្គលីគោត្រ ។ ម្យ៉ាងទៀត ក្នុងកាលដែលមាតានៅជាកុមារិកា មាតាបិតារបស់កុមារិកានោះ ហៅឈ្មោះថា មុគ្គលី ព្រោះកាន់យកពាក្យថា **មា ឧគ្គលិ មា ឧគ្គលិ** ប្រែថា កុំលេប កុំលេប ។ ឈ្មោះថា មោគ្គល្លាន ព្រោះជាបុត្តរបស់នាងមុគ្គលីនោះ ។ ម្យ៉ាងទៀត ឈ្មោះថា មោគ្គល្លាន ព្រោះជាអ្នកអាច គឺអាចក្នុងបាន ក្នុងការកាន់យក ក្នុងការដឹងច្បាស់នូវមគ្គមានសោតាបត្តិមគ្គជាដើម ។

បានឮថា ត្រកូលទាំង ២ នោះ ជាសម្លាញ់ដែលរាប់អានគ្នាមក ៧ ជួរត្រកូល ។ មាតាបិតាបានឲ្យនូវការបរិហារគភ៌ដល់ជនទាំង ២ នោះ ក្នុងថ្ងៃតែមួយ កាលទារកកើតមក ក្រោយអំពីនៅក្នុងផ្ទៃបាន ១០ ខែ មាតាបិតាក៏រកមេដោះ ៦៦ នាក់មកឲ្យ ។ ក្នុងថ្ងៃដាក់ឈ្មោះ មាតាបិតា បានដាក់ឈ្មោះបុត្តរបស់នាងរូបសារីព្រាហ្មណីថា ឧបតិស្សៈ ព្រោះជាបុត្តរបស់ត្រកូលដែលជាប្រធាន ក្នុងឧបតិស្សគ្រាម តាំងឈ្មោះរបស់បុត្តក្រៅអំពីនោះថា កោលិតៈ ព្រោះជាបុត្តរបស់ត្រកូលដែលជាប្រធានក្នុងកោលិតគ្រាម ។ ជនទាំង ២ នោះ ចម្រើនមក មួយអន្លើដោយបរិវារច្រើន កាលចម្រើនវ័យហើយ ដល់នូវការសម្រេចក្នុងសិប្បៈទាំងពួង ។

ថ្ងៃមួយ ជនទាំង ២ នោះ កំពុងមើលមហោស្រពលើកំពូលភ្នំ ក្នុងនគររាជគ្រឹះ ឃើញមហាជនប្រជុំគ្នាកុះករ ព្រោះញាណដល់នូវភាពចាស់ក្លាទើបកើតនូវការគិតឡើងដោយឧបាយ បាននូវសេចក្តីសង្វេគថា មនុស្សទាំង

អស់នេះ ខាងក្នុង ១០០ ឆ្នាំប៉ុណ្ណោះ ក៏ចូលទៅកាន់មាត់របស់មច្ចុរាជ ទើបធ្វើនូវការសម្រេចចិត្តថា យើងទាំងពីរ គួរស្វែងរកមោក្ខធម៌ កាលស្វែងរកមោក្ខធម៌នោះ គួរកាន់យកបព្វជ្ជាឯណានីមួយ ទើបនាំគ្នាបួសក្នុងសម្នាក់របស់សញ្ជយបរិព្វាជក មួយអន្លើដោយមាណព ៥០០ នាក់ ។

ចាប់តាំងពីជនទាំង ២ បួសហើយ សញ្ជយបរិព្វាជក ជាអ្នកដល់នូវលាភដ៏ប្រសើរ និងយសដ៏ប្រសើរ ក្នុង ២-៣ ថ្ងៃប៉ុណ្ណោះ ជនទាំង ២ នោះ ក៏រៀនលទ្ធិរបស់សញ្ជ័យបានទាំងអស់ មិនឃើញសារៈក្នុងលទ្ធិនោះនឿយណាយក្នុងលទ្ធិនោះ ក៏សួរបញ្ហានឹងសមណព្រាហ្មណ៍ ដែលគេសន្មតថាជាបណ្ឌិតក្នុងទីផ្សេងៗ សមណព្រាហ្មណ៍ទាំងនោះ ត្រូវអ្នកទាំង ២ សួរហើយ ឆ្លើយបញ្ហាមិនបាន ផ្ទុយមកវិញជនទាំង ២ នោះឯង នាំគ្នាឆ្លើយបញ្ហាដល់សមណព្រាហ្មណ៍ទាំងនោះ ។ កាលបើដូច្នោះ ជនទាំង ២ នោះកាលនឹងស្វែងរកមោក្ខធម៌ ទើបធ្វើកតិកាថា ក្នុងយើងទាំង ២ អ្នកណាសម្រេចអមតៈមុន អ្នកនោះ ចូរប្រាប់ដល់បុគ្គលម្នាក់ទៀត ។

សម័យនោះ កាលព្រះសាស្តានៃយើងទាំងឡាយ ទ្រង់សម្រេចព្រះបឋមាភិសម្ពោធិញ្ញាណហើយ ទ្រង់ប្រកាសព្រះធម្មចក្រដ៏បវរ បន្ទាប់មកទ្រង់ទូន្មានជដិល ១០០០ នាក់ មានឧរុវេលកស្សបៈជាដើម គង់នៅក្នុងនគររាជគ្រឹះ ។ ថ្ងៃមួយ ឧបតិស្សបរិព្វាជក ខណៈដើរត្រឡប់ទៅកាន់បរិព្វាជការាមឃើញព្រះអស្សជិត្ថេរត្រាច់បិណ្ឌបាតក្នុងនគររាជគ្រឹះ គិតថា អញមិនធ្លាប់ឃើញបព្វជិត ដែលសម្បូរដោយមារយាទបែបនេះមកអំពីមុន ឈ្មោះថា ធម៌

ល្អិត គប្បីមានក្នុងបព្វជិតនេះ ទើបកើតសេចក្ដីជ្រះថ្លា សម្ងឹងមើលព្រះថេរៈដើរតាមអំពីខាងក្រោយដើម្បីសួរបញ្ហា ។

ចំណែកព្រះថេរៈបានបិណ្ឌបាតហើយទៅកាន់ទីកន្លែងដែលសមគួរដើម្បីនឹងឆាន់ ។ បរិព្វាជកបានលាតតាំងបរិព្វាជករបស់ខ្លួនប្រគេន ក្នុងកាលស្រេចភត្តកិច្ច បានប្រគេនទឹកក្នុងឃ្នោករបស់ខ្លួនដល់ព្រះថេរៈ ។ បរិព្វាជកនោះ ធ្វើអាចរិយវត្តយ៉ាងនេះហើយ បានធ្វើបដិសណ្ឋារៈជាមួយព្រះថេរៈដែលធ្វើភត្តកិច្ចស្រេចហើយ ទើបសួរថា អ្នកណាជាសាស្ដារបស់លោក លោកគាប់ចិត្តក្នុងធម៌របស់អ្នកណា ព្រះថេរៈអាងដល់ព្រះសម្មាសម្ពុទ្ធ កាលបរិព្វាជកនោះសួរទៀតថា សាស្ដារបស់លោកមានវាទៈដូចម្ដេច ក៏គិតថា អញនឹងសម្ដែងឲ្យដឹងថា ព្រះសាសនានេះ ជារបស់ជ្រាលជ្រៅ ទើបប្រាប់ឲ្យដឹងថា ខ្លួនដែលជាអ្នកបួសថ្មី កាលនឹងសម្ដែងធម៌ក្នុងព្រះសាសនា ដល់បរិព្វាជកនោះដោយសង្ខេប ក៏ពោលគាថាថា **យេ ធម្មា ហេតុប្បភវា** ជាដើម ។

បរិព្វាជកបានស្ដាប់ ២ បទដំបូងប៉ុណ្ណោះ ក៏តាំងនៅក្នុងសោតាបត្តិមគ្គនិងសោតាបត្តិផល ដែលសម្បូរដោយន័យ ១០០០ ពីរបទក្រោយបញ្ចប់ក្នុងកាលដែលកុលបុត្តនោះបានជាព្រះសោតាបន្នហើយ ។ ក្នុងកាលចប់គាថាកុលបុត្តនោះជាព្រះសោតាបន្ន កាលគុណវិសេសខាងលើមិនទាន់កើតឡើងកុលបុត្តនោះកំណត់ថា ក្នុងសេចក្ដីនេះនឹងមានហេតុ ទើបសាកសួរព្រះថេរៈថា បពិត្រលោកម្ចាស់ សូមលោកម្ចាស់កុំពង្រីកធម្មទេសនាឲ្យខ្ពស់ឡើយ

ប៉ុណ្ណោះគ្រប់គ្រាន់ហើយ ព្រះសាស្តារបស់យើងទាំងឡាយ គង់នៅឯណា ព្រះអស្សជិពោលថា នៅត្រង់វត្តវេឡុវ័ន បរិព្វាជកពោលថា បពិត្រលោកម្ចាស់ សូមលោកម្ចាស់ទៅមុន ខ្ញុំនឹងដោះបេ្តជ្ញាដែលធ្វើដល់សម្លាញ់របស់ខ្ញុំ ហើយនឹងនាំសម្លាញ់នោះទៅដែរ ហើយថ្វាយបង្គំដោយបញ្ចង្គប្រតិស្ឋាន ធ្វើប្រទក្សិណ បញ្ជូនព្រះថេរៈទៅ ហើយត្រឡប់ទៅកាន់បរិព្វាជការាម ។

កោលិតបរិព្វាជកឃើញឧបតិស្សបរិព្វាជកនោះ កំពុងមកអំពីចម្ងាយ គិតថា ទឹកមុខមិនដូចថ្ងៃដទៃ ឧបតិស្សៈនេះនឹងសម្រេចអមតធម៌ពិត ដើម្បីឲ្យប្រាកដក្នុងចិត្តថា ឧបតិស្សៈសម្រេចគុណវិសេស ទើបសួរដល់ការសម្រេចអមតធម៌ ឯឧបតិស្សៈនោះ ក៏ប្រាប់ដល់កោលិតៈនោះថា អាវុសោ ខ្ញុំសម្រេចអមតធម៌ហើយ ទើបពោលគាថានោះដដែលទៀត ។

ក្នុងពេលចប់គាថា កោលិតៈតាំងនៅក្នុងសោតាបត្តិផល ហើយពោលថា ព្រះសាស្តារបស់ពួកយើងនៅឯណា ឧបតិស្សៈពោលថា នៅត្រង់វត្តវេឡុវ័ន ។ កោលិតៈពោលថា អាវុសោ បើដូច្នោះ មក យើងនឹងទៅគាល់ព្រះសាស្តា ។

ឧបតិស្សៈជាបុគ្គលបូជាអាចារ្យអស់សព្វកាល ព្រោះហេតុនោះ ទើបចង់ប្រកាសគុណរបស់ព្រះសាស្តាដល់សញ្ជ័យ ហើយនាំសញ្ជ័យនោះទៅកាន់សម្នាក់ព្រះសាស្តាផង ។

សញ្ជយបរិព្វាជកនោះ ត្រូវសេចក្តីប្រាថ្នាច្រើនក្នុងលាភគ្របសង្កត់ មិនចង់ធ្វើជាសិស្ស ទើបបដិសេធថា ខ្ញុំជាពាងហើយ មិនអាចជាពែងទឹក

បានទេ ជនទាំង ២ នោះ កាលមិនអាចឲ្យសញ្ជ័យបរិព្វាជកនោះយល់ព្រម បាន ដោយហេតុច្រើនប្រការ ទើបទៅកាន់វត្តវេឡុវ័ន មួយអន្លើដោយ អន្តេវាសិក ២៥០ នាក់ ដែលធ្វើតាមឱវាទរបស់ខ្លួន ។

ព្រះសាស្តា ទ្រង់ឃើញជនទាំងនោះមកអំពីចម្ងាយ ទើបត្រាស់ថា នេះនឹងជាគូសាវ័ករបស់តថាគត ជាគូសាវ័កដ៏ប្រសើរ ហើយទ្រង់សម្តែងធម៌ តាមចរិតនៃបរិស័ទរបស់ជនទាំង ២ នោះ ឲ្យតាំងនៅក្នុងអរហត្តហើយ បាន ប្រទានឧបសម្បទា ដោយភាពជាឯហិភិក្ខុ បាត្រ និងចីវរដែលសម្រេចដោយ ឫទ្ធិបានកើតឡើងដល់អគ្គសាវ័ក ដូចកើតមានដល់ភិក្ខុទាំងនោះ ។ តែកិច្ចនៃ មគ្គ ៣ ខាងលើរបស់អគ្គសាវ័កមិនទាន់សម្រេច ព្រោះហេតុអ្វី ព្រោះ សាវកបារមីញាណ ជាគុណដ៏ធំក្រៃលែង ។

បណ្តាអគ្គសាវ័កនោះ ព្រះមហាមោគ្គល្លាន ក្នុងថ្ងៃទី ៧ បន្ទាប់ពីបួស ហើយ ធ្វើសមណធម៌ត្រង់ស្រុកកាលវាលគ្រាម ក្នុងមគធរដ្ឋ កាលថីនមិទ្ធៈ គ្របសង្កត់ ត្រូវព្រះសាស្តាឲ្យសង្វេគហើយ បន្ទោបង់នូវថីនមិទ្ធៈបាន ខណៈ ស្តាប់ធាតុកម្មដ្ឋាននោះឯង បានសម្រេចមគ្គខាងលើ ៣ ទៀត ដល់នូវទី បំផុតនៃសាវកបារមីញាណ ។

ឯព្រះសារីបុត្តកន្លងទៅបានកន្លះខែ បន្ទាប់អំពីបួស នៅក្នុងគុហា សូករខាតា ក្នុងនគររាជគ្រឹះជាមួយព្រះសាស្តា កាលព្រះសាស្តា ទ្រង់សម្តែង វេទនាបរិគ្គហសូត្រ ដល់ទីឃនខបរិព្វាជកជាក្មួយរបស់ខ្លួន បញ្ជូនញាណទៅ តាមព្រះធម្មទេសនា បានដល់ទីបំផុតនៃសាវកបារមីញាណ ដូចបុគ្គលបរិភោគ

កត្តដែលគេជួសមកដើម្បីអ្នកដទៃ ដូច្នោះ សាវកបារមីញាណរបស់អគ្គសាវក ទាំង ២ បានដល់នូវទីបំផុត ក្នុងទីជិតព្រះសាស្តានោះឯង ។

ព្រះសារីបុត្ត សម្រេចសាវកបារមីញាណយ៉ាងនេះហើយ ទើបពិចារណា ថា សម្បត្តិនេះ អញបានដោយកម្មអ្វី បានដឹងកម្មនោះហើយ កាលបន្លឺនូវ ឧទានដោយអំណាចបីតិសោមនស្ស ទើបពោលពាក្យជាដើមថា **ហិមវន្តស្ស អវិទូរេ** ជាដើម ដោយហេតុនោះ ទើបលោកពោលថា

មានភ្នំមួយ ឈ្មោះលម្ពកៈ នៅក្នុងទីមិនឆ្ងាយ អំពីភ្នំហិមពាន្ត
គេបានសង់អាស្រម សាងបណ្ណសាលាឲ្យខ្ញុំ ។

បណ្តាបទទាំងនោះ បទថា **ហិមវន្តស្ស** សេចក្តីថា ដែលឈ្មោះថា **ហិមវា** ព្រោះប្រទេសនោះមានសន្សើម នៅក្នុងទីមិនឆ្ងាយ គឺក្នុងទីជិតហិម-វន្តប្បទេសនោះ អធិប្បាយថា ក្នុងព្រៃដែលទាក់ទងដោយភ្នំហិមាល័យ ។

បទថា **លម្ពកោ ឆាម បព្វតោ** បានដល់ ភ្នំលាយដោយដីដែល មានឈ្មោះយ៉ាងនោះ ។

បទថា **អស្សមោ សុកតោ មយ្ហំ** សេចក្តីថា អាស្រម គឺអារញ្ញវាស ដែលធ្វើដើម្បីខ្ញុំ គឺដើម្បីប្រយោជន៍ដល់ខ្ញុំ ត្រង់ភ្នំឈ្មោះលម្ពកៈនោះ ឈ្មោះ ថា អាស្រម ព្រោះរាបស្មើដោយជុំវិញ ។ មួយវិញទៀត ឈ្មោះថា អាស្រម ព្រោះជាទីដែលមិនមានការហត់នឿយ គឺសេចក្តីក្រវល់ក្រវាយ ដល់បុគ្គល ដែលចូលទៅ ។ អារញ្ញវាសយ៉ាងនេះ ត្រូវធ្វើល្អហើយ គឺត្រូវសាងដោយ អាការដ៏ល្អ ដូចជាទីសម្រាកពេលយប់ ទីសម្រាកពេលថ្ងៃ កុដិ និងបារាំ

ជាដើម ។

បទថា **បណ្ណសាលា** បានដល់ សាលាសម្រាប់ជាទីអាស្រ័យនៅ ប្រក់ដោយស្លឹកឈើ មានស្បូវក្លាំង និងស្មៅយាប្លងជាដើម ។

ស្ទឹងមានច្រាំងដ៏រាក់ មានកំពង់ល្អ ជាទីគាប់ចិត្ត ដ៏ដេរដាស
ដោយផ្លូកខ្សាច់ដ៏ស្អាត មានក្នុងទីមិនឆ្ងាយ អំពីអាស្រមខ្ញុំ ។

បណ្ដាបទទាំងនោះ បទថា **ឧត្តានកូលា** បានដល់ ស្ទឹងដែលមិនជ្រៅ ។ បទថា **សុបតិត្ថា** ប្រែថា មានកំពង់ល្អ ។ បទថា **មនោរមា** បានដល់ ជាទីត្រេកអរនៃចិត្ត គឺជាទីញុំាងចិត្តឲ្យត្រេកអរ ។ បទថា **សុសុទ្ធបុលិនាកិណ្ណា** បានដល់ ដេរដាសដោយខ្សាច់ ហាក់បីដូចជាស្រទាប់កែវមុក្តាពណ៌សសុទ្ធ អធិប្បាយថា ជាផ្លូកខ្សាច់ ។

អធិប្បាយថា ស្ទឹង គឺស្ទឹងតូចដែលជារបស់យ៉ាងនេះ មានក្នុងទីមិនឆ្ងាយ គឺក្នុងទីជិតអាស្រមរបស់ខ្ញុំ ។ បទថា **អស្សមំ** គប្បីជ្រាបថា ជាទុតិយាវិភត្តិ ចុះក្នុងអត្ថនៃសត្តមីវិភត្តិ ។

ស្ទឹង ( នោះ ) មិនមានក្រួសរវាន មិនចោត
មានទឹក ដ៏ឆ្ងាញ់ មិនមានក្លិនអាក្រក់ តែងហូរទៅក្នុងទីនោះ
ជាលម្អ ដល់អាស្រមខ្ញុំ ។

បណ្ដាបទទាំងនោះ បទថា **អសក្ខរា** សេចក្ដីថា ឈ្មោះថា **អសក្ខរា** គឺប្រាសចាកក្រួស ព្រោះលោកពោលថា ដេរដាសដោយផ្លូកខ្សាច់ ។

បទថា **អបព្ភារា** ប្រែថា មិនមានជ្រុង គឺច្រាំងមិនជ្រៅ ។

បទថា **សាធុ អប្បដិគន្ធិកា** សេចក្ដីថា ស្ទឹង គឺស្ទឹងតូច មានទឹកសេចក្ដាញ់ វៀរចាកក្លិនស្អុយ ហូរទៅ គឺប្រព្រឹត្តទៅ ធ្វើអាស្រមរបស់ខ្ញុំឲ្យស្អាត ។

មានក្រពើ មករ ថ្លាម អណ្ដើក លេងក្នុងស្ទឹងនុ៎ះ ហែប
ហែលក្នុងស្ទឹងនោះ ជាលម្អដល់អាស្រមខ្ញុំ ។

ក្នុងគាថានោះ ភ្ជាប់សេចក្ដីថា ក្រពើ មករ ថ្លាម គឺ សត្វកាច និងអណ្ដើក បានលេងក្នុងស្ទឹងនេះ ភ្ជាប់សេចក្ដីថា ស្ទឹង គឺ ស្ទឹងតូចហូរទៅធ្វើឲ្យអាស្រមរបស់ខ្ញុំស្អាត ។

មានទាំងត្រីស្វាត ត្រីសណ្ដាយ ត្រីក្រាញ់ ត្រីក្រពុលបាយ
ត្រីឆ្ពិន ត្រីខ្ទឹង តែងហែលធ្វៀលធ្វាត់ទៅមក ជាលម្អដល់
អាស្រមខ្ញុំ ។

អធិប្បាយថា ត្រីស្វាត ត្រីសណ្ដាយ ត្រីក្រាញ់ ត្រីក្រពុលបាយ ត្រីឆ្ពិន ត្រីខ្ទឹង មច្ឆជាតិទាំងអស់នេះ លោតទៅក្នុងទិសផ្សេងៗ គឺហែលទៅជាមួយស្ទឹង ធ្វើឲ្យអាស្រមរបស់ខ្ញុំស្អាត ។

នៅត្រើយស្ទឹងទាំងសងខាង មានដើមឈើ ដ៏សម្បូរដោយផ្កា
និងផ្លែ សំយុងចុះមកអំពីត្រើយស្ទឹងទាំងសងខាង ជាលម្អដល់
អាស្រមខ្ញុំ ។

បណ្ដាបទទាំងនោះ បទថា **ឧភោ កូលេសុ** សេចក្ដីថា ត្រង់សងខាងស្ទឹងទាំង ២ នោះ មានដើមឈើ ដែលមានផ្កាប្រចាំ មានផ្លែប្រចាំ សំយុង

ចុះទាំងសងខាងប្រាំង គឺបង្អោនចុះខាងក្រោម ត្រង់ប្រាំងសងខាងស៊ីង ធ្វើឲ្យអាស្រមរបស់ខ្ញុំស្អាត ។

ស្វាយ សាលព្រឹក្ស ដង្កៀបក្តាម ប្រទៀង ឈើភ្លើង មាន
ផ្ការីក ផ្សាយក្លិនដូចជាទិព្វ ក្នុងអាស្រមខ្ញុំ ។

បណ្តាបទទាំងនោះ បទថា **អម្ពា** ជាដើម សេចក្តីថា ស្វាយជាចង្កោមមានរសផ្អែមឆ្ងាញ់ ដើមរាំងភ្នំ ដើមដង្កៀបក្តាម ដើមប្រទៀង និងដើមឈើភ្លើង ដើមឈើទាំងនេះ មានផ្កាជានិច្ច មានក្លិនក្រអូប ដូចក្លិនទិព្វ ផ្សាយទៅ គឺផ្សាយត្រឡប់ទៅដោយជុំវិញអាស្រមរបស់ខ្ញុំ ។

ចម្ប៉ា[១] ស្រល់ ក្តុល ខ្ទឹង បុន្នាគ រំចេក មានផ្ការីក ផ្សាយ
ក្លិនដូចជាទិព្វ ក្នុងអាស្រមខ្ញុំ ។

ក្នុងគាថានោះ មានអធិប្បាយថា ដើមចម្ប៉ា ស្រល់ ក្តុល មានផ្កាដូចកម្រងមាស ដើមខ្ទឹង ដើមបុសនាគ និងដើមរំចេក ឈើទាំងអស់នេះ មានផ្ការីក គឺរីកស្គុះស្គាយ មានក្លិនក្រអូប គឺផ្សាយក្លិនក្រអូបទៅក្នុងអាស្រមរបស់ខ្ញុំ ដូចក្លិនទិព្វ ។

រំដួល អសោក ទួនស្រី មានផ្ការីក អង្កោល វល្លិបាស
មានផ្ការីក ផ្សាយក្លិនទៅក្នុងអាស្រមខ្ញុំ ។

ក្នុងគាថានោះ ភ្ជាប់សេចក្តីថា ដើមរំដួលមានផ្ការីក ដើមអសោកមានផ្ការីក ដើមទួនស្រីមានផ្ការីក ដើមអង្កោលមានផ្ការីក និងវល្លិបាសមានផ្ការីក

១- បិដកខ្មែរជាដើមចំបក់ ។

ឈើទាំងនេះ រីកស្គុះស្គាយ ក្បែរអាស្រមរបស់ខ្ញុំ ។

រំចេក ចេក ខ្ទញ្ញ ម្ទិះរួត ផ្សាយក្លិនដូចជាទិព្វ ក្នុងអាស្រមខ្ញុំ ។

បណ្តាបទទាំងនោះ បទថា **កោសកា** បានដល់ គុម្ពសុគន្ធ គឺផ្កាំរំចេក អធិប្បាយថា ដើមចេក ដើមខ្ទញ្ញ ម្ទិះរួត រុក្ខជាតិទាំងអស់នេះ ចោលក្លិនក្រអូបឈ្ងុយ ធ្វើឲ្យអាស្រមរបស់ខ្ញុំល្អទូទៅ ។

ឈើជាច្រើន គឺកណិការ កណ្ណិការ ធ្នង់ អញ្ចាន់ ផ្សាយក្លិន

ដូចជាទិព្វ ជាលម្អនៃអាស្រមខ្ញុំ ។

ភ្ជាប់សេចក្តីថា ឈើទាំងឡាយ មានកណិការជាដើមនេះ ធ្វើអាស្រមខ្ញុំឲ្យស្អាតទូទៅ ចោលក្លិនក្រអូបឈ្ងុយ ។

មានក្រូចធ្លារ ក្រូចភ្លា រលួស មានផ្កាំរីក ផ្សាយក្លិនដូចជាទិព្វ

ជាលម្អនៃអាស្រមខ្ញុំ ។

អធិប្បាយថា ដើមឈើទាំងឡាយ មានក្រូចធ្លារជាដើម ចោលក្លិនក្រអូប ធ្វើឲ្យអាស្រមរបស់ខ្ញុំស្អាត ។

ឈើជាច្រើនយ៉ាង គឺរាជព្រឹក្ស ខ្វែងគង់ កូម្ព ពកុល ផ្សាយ

ក្លិនដូចជាទិព្វ ជាលម្អនៃអាស្រមខ្ញុំ ។

ភ្ជាប់សេចក្តីថា ដើមឈើទាំងឡាយ មានដើមរាជព្រឹក្សជាដើម ចោលក្លិនក្រអូប ធ្វើឲ្យអាស្រមរបស់ខ្ញុំស្អាត ។

អាឡវកព្រឹក្ស សណ្តែកក្រហម ចេក ក្រូចថ្លុង តែង

លូតលាស់ ដោយទឹកដ៏មានក្លិន ឈើទាំងនោះ ទ្រទ្រង់ផ្លែ

( ជានិច្ច ) ។

ក្នុងគាថានោះ មានអត្ថថា សណ្ដែកខ្មៅជាដើមនេះ ចម្រើនដោយទឹកក្រអូប នៃគ្រឿងក្រអូប មានចន្ទន៍ជាដើម ទ្រទ្រង់ផ្លែដូចមាស ធ្វើឲ្យអាស្រមរបស់ខ្ញុំស្អាត ។

ឈូកខ្លះកំពុងផ្កា ខ្លះកំពុងបញ្ចេញកេសរ ខ្លះជម្រុះផ្កា រីកស្គុះ

ស្គាយក្នុងស្រះ ក្នុងកាលនោះ ។

បណ្ដាបទទាំងនោះ បទថា **អញ្ញេ បុប្ផន្តិ បទុមា** សេចក្ដីថា ក្នុងបឹងក្នុងទីមិនឆ្ងាយអំពីអាស្រមរបស់ខ្ញុំ បទុមណាទីមួយ គឺគុម្ពឈូកខ្លះកំពុងផ្កា គុម្ពឈូកខ្លះកំពុងបញ្ចេញកេសរ គឺកំពុងកើត ឈូកគុម្ពខ្លះកំពុងជម្រុះផ្កា គឺមានកេសរក្នុងត្របកពោយទៅ ។

ពួកឈូកកំពុងលេចពន្លក មានក្រអៅ កំពុងលូតលាស់

ដេរដាសដោយត្របកផ្កា និងស្លឹកល្អក្នុងស្រះ ក្នុងកាលនោះ ។

បណ្ដាបទទាំងនោះ បទថា **គព្ភំ គណ្ហន្តិ បទុមា** សេចក្ដីថា ក្នុងកាលនោះ គឺក្នុងសម័យដែលខ្ញុំជាតាបស ឈូកខ្លះកំពុងចេញផ្កាក្រពុំខាងក្នុងបឹងឬសឈូក គឺក្រអៅឈូកកំពុងលូតទៅ គឺលូតទៅខាងក្នុងកក់ ដូចក្អកដីរី សេចក្ដីថា ក្រចាប់ទាំងឡាយដុះជាគុម្ព ដេរដាសដោយស្លឹក និងផ្កាដ៏ល្អ ។

គុម្ពផ្កានយិតាផង អម្ពគណ្ឋីផង ឧត្តាបាហិផង ពន្ធជីវកៈផង

មានផ្ការីក ផ្សាយក្លិនដូចជាទិព្វ ទៀបស្រះ ក្នុងកាលនោះ ។

អធិប្បាយថា ក្នុងកាលនោះ គឺក្នុងសម័យដែលខ្ញុំនៅក្បែរស្រះ គុម្ព

ក្អែកខ្វា គុម្ពចន្ទលណី គុម្ពឧត្តក ( វល្លិឆ្វេង ) និងគុម្ពប្បារ ឈើទាំងអស់នេះ រីកស្គុះស្គាយ គឺចេញផ្កា ជះក្លិនក្រអូបមក ធ្វើស្រះឲ្យស្អាត ។

ពួកត្រីស្វាត ត្រីសណ្តាយ ត្រីក្រាញ់ ត្រីក្រពុលបាយ ត្រីឆ្ពិន
ត្រីចង្វា ត្រីផ្ទោង នៅក្នុងស្រះ ក្នុងកាលនោះ ។

ភ្ជាប់សេចក្តីថា ក្នុងកាលនោះ គឺក្នុងសម័យដែលខ្ញុំនៅ ពួកត្រីមានត្រីស្វាតជាដើម មិនខ្វាចអាស្រ័យនៅក្នុងបឹង ។

ក្រពើ ឆ្លាម តន្តិគ្គាហៈ អារក្សទឹក ឱគាហៈ ថ្លាន់ នៅក្នុង
ស្រះ ក្នុងកាលនោះ ។

ភ្ជាប់សេចក្តីថា ក្នុងកាលនោះ គឺក្នុងសម័យដែលខ្ញុំនៅ ហ្វូងត្រីមានក្រពើជាដើមទាំងនោះមិនមានភ័យ មិនមានអន្តរាយ អាស្រ័យនៅក្នុងស្រះ ក្បែរអាស្រមរបស់ខ្ញុំ ។

ព្រាប ព្រហីត ចាក្រពាក ក្អែកទឹក តាវៅ សេក និងសារិកា
តែងអាស្រ័យរស់នៅទីងស្រះនោះ ។

ក្នុងគាថានោះ ភ្ជាប់សេចក្តីថា ព្រាប ប្រវឹក ចាក្រពាក ក្អែកទឹក តាវៅ សេក សារិកា អាស្រ័យស្រះក្បែរអាស្រមរបស់ខ្ញុំ គឺអាស្រ័យស្រះនោះរកស៊ី ។

មានបក្សីខ្វែក ក្តាម មាន់ព្រៃ ត្រដេវវិច សេក
អាស្រ័យរស់នៅទីងស្រះនោះ ។

បណ្តាបទទាំងនោះ បទថា **កុក្កុត្ថកា** បានដល់ បក្សីដែលមានឈ្មោះ

យ៉ាងនោះ ( ខ្វែក ) ។ បទថា **កុធ្បីរកា** បានដល់ បក្សីដែលមានឈ្មោះ យ៉ាងនោះ[១] ក្មាប់សេចក្តីថា មាន់ព្រៃ ត្រដេវវិច និងសេក សត្វទាំងអស់ នេះ នៅអាស្រ័យស្រះ ក្បែរអាស្រមរបស់ខ្ញុំនោះរកស៊ី ។

ពួកបក្សី គឺហង្ស ក្រៀល ក្ងោក តាវៅ មាន់ទោ ចង្កៀលខ្យង
ប៉ោលតោក តែងអាស្រ័យរស់នៅទីងស្រះនោះ ។

អធិប្បាយថា ហ្វូងបក្សី មានហង្សជាដើមទាំងអស់នេះ អាស្រ័យ ស្រះនោះ រស់នៅ គឺចិញ្ចឹមជីវិត ។

ពួកបក្សីជាច្រើន គឺមៀម ខ្វែងស្រោក លលក ខ្វែង អន្តត់ខ្មៅ
តែងអាស្រ័យរស់នៅទីងស្រះនោះ ។

ក្នុងគាថានោះ មានអធិប្បាយថា មៀម ខ្វែងស្រោក លលក ខ្វែង និងអន្តត់ខ្មៅ និងសត្វជាច្រើន ដែលជាសត្វគោក រមែងរស់នៅ គឺសម្រេច ការរកស៊ីនៅក្នុងស្រះនោះ គឺក្នុងទីជិតស្រះនោះ ។

ពួកម្រឹគជាច្រើន គឺបសទម្រឹគ ជ្រូក ឆ្កែព្រៃ រមាំង ប្រើស
រមាស តែងអាស្រ័យរស់នៅទីងស្រះនោះ ។

ក្នុងគាថានោះ មានអត្ថថា ម្រឹគទាំងនោះ មានបសទម្រឹគជាដើម រកស៊ី ក្នុងស្រះនោះ គឺជិតស្រះនោះ ។ បទថា **សរំ** ជាទុតិយាវិភត្តិ ចុះក្នុងអត្ថ នៃសត្តមីវិភត្តិ ។

---

១- បទថា កុឡីរកា បិដកខ្មែរប្រែថា ក្តាម តែអដ្ឋកថា ប្រាប់ថាជាឈ្មោះរបស់បក្សី ។

សីហៈ ខ្លាធំ ខ្លាដំបង ខ្លាឃ្មុំ ឆ្កែព្រៃ ខ្លាត្រី ដំរីចុះប្រេង
តែងអាស្រ័យរស់នៅទីនស្រះនោះ ។

ភ្នាប់សេចក្តីថា សត្វចតុប្បាទ មានសីហៈជាដើមនេះ មិនមានអន្តរាយ រកស៊ីជិតស្រះនោះ ។

ពួកកិន្នរ ពានរ ឬពួកមនុស្សអ្នកធ្វើការក្នុងព្រៃ មនុស្សអ្នក
បម្រើ ព្រានព្រៃ តែងអាស្រ័យរស់នៅទីនស្រះនោះ ។

ក្នុងគាថានោះ មានសេចក្តីថា សត្វទាំងនេះ ដែលរៀបរាប់ឈ្មោះហើយនោះ មានកិន្នរជាដើម អាស្រ័យនៅជិតស្រះនោះ ។

ដើមទន្ទាប់ ដើមទន្លា ដើមស្រគំ ពង្រ ទ្រទ្រង់ផ្លែអស់
កាលជានិច្ច ក្នុងទីមិនឆ្ងាយអំពីអាស្រមខ្ញុំ ។

ក្នុងគាថានោះ ភ្នាប់សេចក្តីថា ឈើទាំងឡាយ មានទន្ទាប់ជាដើមនោះ ចេញផ្លែមានរសឆ្ងាញ់ ក្នុងទីមិនឆ្ងាយអំពីអាស្រមរបស់ខ្ញុំ អស់រដូវទាំង ៣ គឺរដូវរងា រដូវក្តៅ និងរដូវភ្លៀងជាប្រចាំ ។

ដើមស្រូល ដើមស្រល់ ដើមក្ទម្ព ប្រកបដោយខ្ទឹម និងផ្លែ
តែងទ្រទ្រង់ផ្លែជានិច្ច ក្នុងទីមិនឆ្ងាយអំពីអាស្រមខ្ញុំ ។

ក្នុងគាថានោះ មានសេចក្តីថា ដើមឈើទាំងឡាយ មានដើមស្រូលជាដើមនេះ មានផ្លែរយោង មានផ្លែឆ្ងាញ់ មានផ្លែប្រសើរ ស្អកស្កះ គឺប្រកបព្រមដោយល្អ បានដល់ ដល់ព្រម ចេញផ្លែគ្រប់រដូវកាល ស្អាតក្បែរអាស្រមរបស់ខ្ញុំ ។

ដើមសម៉ កន្ទួតព្រៃ ស្វាយ ព្រីង សម៉ពិភេទក៍ ក្របៅ[១]

រាក់ខ្មៅ ញ្ញា តែងទ្រទ្រង់ផ្លែជានិច្ច ។

១- បាលីថា កោលា បិដកខ្មែរប្រែថា ដើមស្តៅ ។

ភ្លាប់សេចក្តីថា ដើមសម៉ជាដើមនោះ កើតក្នុងទីជិតអាស្រមរបស់ខ្ញុំ ចេញផ្លែជានិច្ច ។

ដំឡូងស្រំ ដំឡូងដួង ដំឡូងដៃខ្លា និងដំឡូងឈាមមាន់

ទាំងឈើជាថ្នាំ ក៏មានច្រើន នៅជិតអាស្រមខ្ញុំ ។

ភ្លាប់សេចក្តីថា មូលផលទាំងឡាយ មានដំឡូងស្រំជាដើមនោះ ផ្អែមមានរសឆ្ងាញ់ មានជាច្រើនក្នុងទីមិនឆ្ងាយអំពីអាស្រមរបស់ខ្ញុំ ។

ស្រះដែលធម្មតានិម្មិតល្អហើយ ក៏មាននៅក្នុងទីមិនឆ្ងាយ អំពី

អាស្រមខ្ញុំ មានទឹកថ្លា មានទឹកត្រជាក់ មានកំពង់រាបទាប ល្អ

គួរជាទីរីករាយចិត្ត ។

ក្នុងគាថានោះ មានសេចក្តីថា ក្នុងទីជិតអាស្រម មានស្រះដែលធម្មតានិម្មិតល្អហើយ មានទឹកថ្លា គឺមានទឹកថ្លាឆ្វេង ជាទឹកត្រជាក់ មានកំពង់រាបស្មើ គឺមានកំពង់ល្អ ជាទីត្រេកអរនៃចិត្ត គឺធ្វើឲ្យកើតសោមនស្ស ។

ស្រះនោះ សឹងដ៏បរិបូណ៌ដោយឈូក និងឧប្បល ប្រកប

ដោយឈូក-ស ព្រោងព្រាតដោយស្គន់ មានក្លិនដូចជាទិព្វ

រមែងផ្សាយទៅ ។

ក្នុងគាថានោះ មានសេចក្តីថា ស្រះទាំងឡាយដេរដាស គឺបរិបូណ៌

ដោយឈូកក្រហម និងឧប្បលប្រកប គឺដល់ព្រមដោយឈូក-ស ដេរដាស ជាពួកៗ ដោយស្គន់ ជះក្លិនក្រអូបឈ្ងុយឈ្ងប គឺផ្សាយទៅដោយជុំវិញ ។

ក្នុងកាលនោះ ខ្ញុំតែងនៅក្នុងអាស្រម ជាទីត្រេកអរ ដែលធម្មតាធ្វើទុកល្អហើយ ក្នុងព្រៃដែលមានផ្កា និងផ្លែ បរិបូណ៌ ដោយអង្គគ្រប់សព្វយ៉ាងនេះ ។

បណ្ដាបទទាំងនោះ បទថា **ឯវំ សព្វង្គសម្បន្នេ** សេចក្ដីថា ក្នុងកាលនោះ គឺក្នុងកាលជាតាបស នៅក្នុងអាស្រម គឺក្នុងអរញ្ញវាស ដែលគួរជាទីត្រេកអរ ដែលសាងយ៉ាងល្អក្នុងព្រៃ ដែលជាព្រៃស្ដុកដោយដើមឈើផ្កា និងផ្លែបរិបូណ៌ បរិបូណ៌ដោយអង្គប្រកប មានស្មឹងគ្រប់ប្រភេទជាដើម ។

ព្រះសារីបុត្តត្ថេរ កាលសម្ដែងសម្បត្តិនេះហើយ ឥឡូវនេះ កាលសម្ដែងគុណ មានសីលសម្បត្តិរបស់ខ្លួនជាដើម ទើបពោលថា

ខ្ញុំជាតាបស ឈ្មោះសុរុចិ ជាអ្នកមានសីល បរិបូណ៌ដោយវត្ត មានឈាន ត្រេកអរក្នុងឈាន ដល់នូវកម្លាំងនៃអភិញ្ញាទាំង ៥ គ្រប់កាលទាំងពួង ។

បណ្ដាបទទាំងនោះ បទថា **សីលវា** សេចក្ដីថា ដល់ព្រមដោយសីល ៥ ដូចបារិសុទ្ធិសីល ៤ ដែលប្រកបព្រមដោយឈាន ។

បទថា **វត្តសម្បន្នោ** សេចក្ដីថា បរិបូណ៌ដោយការសមាទានវត្តថា តាំងអំពីនេះទៅ ខ្ញុំមិនសេពយកវាស និងកាមគុណ ៥ ។ បទថា **ឈាយី** បានដល់ ជាអ្នកមានប្រក្រតីសម្លឹង គឺមានការសម្លឹងជាប្រក្រតី ដោយ

លក្ខណូបនិជ្ឈាន និងអារម្មណូបនិជ្ឈាន ។

បទថា **ឈានរតោ** សេចក្តីថា ត្រេកអរហើយ គឺពួនសម្ងំ បានដល់បរិបូណ៌សព្វកាល ក្នុងឈានទាំងឡាយនេះ ។

បទថា **បញ្ចាភិញ្ញាពលប្បត្តោ** សេចក្តីថា សម្បូរដោយពល បរិបូណ៌ដោយអភិញ្ញា គឺបញ្ញាពិសេស ៥ ប្រការ បានដល់ ឥទ្ធិវិធ ១ ទិព្វសោត ១ បរចិត្តវិជ្ជានន ១ បុព្វេនិវាសានុស្សតិ ១ ទិព្វចក្ខុ ១ ក្នុងសេចក្តីថា ខ្ញុំជាតាបស ឈ្មោះថា សុរុចិ ។

កាលសម្តែងគុណសម្បត្តិរបស់ខ្លួន ដោយពាក្យប្រមាណប៉ុណ្ណេះហើយ កាលនឹងសម្តែងបរិស័ទសម្បត្តិ ទើបពោលពាក្យជាដើមថា

ពួកព្រាហ្មណ៍ទាំងអស់នុ៎ះ ជាសិស្សរបស់ខ្ញុំ ចំនួន ២៤ ពាន់នាក់ ជាអ្នកមានជាតិ មានយស នៅចាំបម្រើខ្ញុំ ។

ក្នុងគាថានោះ ក្នុងសេចក្តីថា សិស្សរបស់ខ្ញុំទាំងអស់នេះ ជាព្រាហ្មណ៍ ២៤០០០ នាក់ ជាអ្នកមានជាតិ គឺសម្បូរដោយជាតិកំណើត មានយស គឺសម្បូរដោយបរិវារបម្រើខ្ញុំ ។

( ពួកព្រាហ្មណ៍ទាំងនោះ ) ជាអ្នកចេះបទ ចេះវេយ្យាករណ៍ ដល់នូវត្រើយនៃវិជ្ជា ក្នុងសទ្ទម្ហ គឺលក្ខណសាស្ត្រ ឥតិហាសសាស្ត្រ ព្រមទាំងនិឃណ្ឌុសាស្ត្រ និងកេដុភសាស្ត្រ ។

បណ្តាបទទាំងនោះ បទថា **លក្ខណេ** បានដល់ ក្នុងតម្រាទាយលក្ខណៈរមែងដឹងលក្ខណៈនៃស្ត្រី និងបុរសដែលជាលោកិយជនទាំងពួងថា បុគ្គល

*ប្រកបដោយលក្ខណៈទាំងនេះ ជាអ្នកមានទុក្ខ បុគ្គលប្រកបដោយលក្ខណៈទាំងនេះ ជាអ្នកមានសុខ ។ តម្រាដែលទាយលក្ខណៈនោះ ឈ្មោះថា លក្ខណៈ ។ ក្នុងតម្រាទាយលក្ខណៈនោះ ។*

*បទថា* **ឥតិហាសេ** *បានដល់ ក្នុងតម្រាដែលសម្តែងលំដាប់របស់រឿងដែលពោលថា* **ឥតិហាស ឥតិហាស** *រឿងនេះកើតមកយ៉ាងនេះ រឿងនេះកើតមកយ៉ាងនេះ ភ្ជាប់សេចក្តីថា ដល់នូវការពេញ គឺទីបំផុតក្នុងតម្រាទាយលក្ខណៈ និងតម្រាឥតិហាសៈ ។*

*តម្រាប្រាប់ឈ្មោះដើមឈើ និងភ្នំជាដើម ហៅថា និឃណ្ឌុ ។ បទថា* **កេដុភេ** *បានដល់ តម្រាពោលដោយការកំណត់ប្រើពាក្យកិរិយា ដែលជាប្រយោជន៍ដល់កវីទាំងឡាយ ។ ឈ្មោះថា* **សនិឃណ្ឌុ** *ព្រោះប្រព្រឹត្តទៅដោយគម្ពីរនិឃណ្ឌុ ។ ឈ្មោះថា* **សកេដុភ** *ព្រោះប្រព្រឹត្តទៅ ដោយគម្ពីរកេដុភៈ ភ្ជាប់សេចក្តីថា ដល់នូវការសម្រេចក្នុងត្រៃវេទ ដែលប្រព្រឹត្តទៅដោយគម្ពីរនិឃណ្ឌុ និងកេដុភៈនោះ ។*

*បទថា* **បទកា** *បានដល់ ជាអ្នកឈ្លាសក្នុងបទ នាម សមាស តទ្ធិត អាខ្យាត និងកិតកៈជាដើម ។*

*បទថា* **វេយ្យាករណា** *បានដល់ ជាអ្នកឈ្លាសក្នុងវេយ្យាករណ៍ មាន ចន្ទបាណិនីយកលាបៈជាដើម ។*

*បទថា* **សធម្មេ ធារមី គតា** *សេចក្តីថា ដល់ គឺសម្រេចនូវការពេញ គឺទីបំផុតក្នុងធម៌របស់ខ្លួន គឺក្នុងធម៌របស់ព្រាហ្មណ៍ បានដល់ ត្រៃវេទ ។*

ពួកសិស្សរបស់ខ្ញុំ ជាអ្នកឈ្លាសវៃក្នុងឧត្បាត ក្នុងនិម្មិត និង
លក្ខណៈទាំងឡាយ បានសិក្សាល្អក្នុងផែនដី ក្នុងទឹកក្នុង
អាកាស ។

គប្បីជ្រាបវិនិច្ឆ័យក្នុងគាថានោះដូចតទៅ ជាអ្នកឈ្លាស គឺឈ្លាសក្នុងជោគល្អ ជោគអាក្រក់ មានឧត្បាត គឺភ្លើងធ្លាក់ និងផែនដីកម្រើកជាដើមក្នុងនិមិត្តល្អ និងនិមិត្តអាក្រក់ និងក្នុងឥត្ថីលក្ខណៈ បុរិសលក្ខណៈ និងមហាបុរិសលក្ខណៈ ។

សិស្សទាំងឡាយរបស់ខ្ញុំ សិក្សាល្អហើយ ក្នុងវត្ថុទាំងពួង គឺក្នុងផែនដីក្នុងទឹកនៃ្វង និងក្នុងសកលលោក និងក្នុងអាកាស ។

សិស្សទាំងនុ៎ះ ជាអ្នកប្រាថ្នាតិច មានប្រាជ្ញាខ្ជាប់ខ្ជួន មាន
អាហារតិច មិនល្មោភ សន្តោសដោយលាភ និងការឥត
លាភ តែងចោមរោមខ្ញុំសព្វកាល ។

បណ្តាបទទាំងនោះ បទថា **អប្បិច្ឆា** បានដល់ ជាអ្នកញុំាងអត្តភាពឲ្យប្រព្រឹត្តទៅដោយអាហារមានចំនួនតិច ។

បទថា **និបកា** គឺដែលប្រកបដោយបញ្ញា ពោល គឺបញ្ញាជាគ្រឿងរក្សាខ្លួន ។

បទថា **អប្បាហារា** បានដល់ មានអាហារមួយពេល អធិប្បាយថាបរិភោគភត្តមួយពេល ។

បទថា **អលោលុបា** បានដល់ ជាអ្នកមិនប្រព្រឹត្តទៅដោយតណ្ហា គឺ

ការបង់បាន ។

បទថា **លាភាលាភេន** សេចក្ដីថា សិស្សទាំងឡាយរបស់ខ្ញុំនេះ ត្រេកអរ គឺមានការពេញចិត្តដោយលាភ និងការមិនមានលាភចោមរោម គឺបម្រើខ្ញុំសព្វកាល គឺជានិច្ចកាល ។

ពួកសិស្សទាំងនុ៎ះ ជាអ្នកប្រាជ្ញ មានឈាន ត្រេកអរក្នុងឈាន
មានចិត្តស្ងប់រម្ងាប់ មានសមាធិ ប្រាថ្នានូវការមិនមានកង្វល់
តែងចោមរោមខ្ញុំ សព្វកាល ។

បណ្ដាបទទាំងនោះ បទថា **ឈាយី** គឺប្រកបដោយលក្ខណូបនិជ្ឈាន និងអារម្មណូបនិជ្ឈាន ។ ម្យ៉ាងទៀត ប្រែថា ជាអ្នកមានប្រក្រតីសម្លឹង ។

បទថា **ឈានរតា** បានដល់ ជាអ្នកត្រេកអរ គឺចុះស៊ប់ក្នុងឈានទាំងនោះ ។ បទថា **ធីរា** បានដល់ សម្បូរដោយបញ្ញាជាគ្រឿងទ្រទ្រង់ចាំ ។ បទថា **សន្តចិត្តា** បានដល់ ជាអ្នកមានចិត្តស្ងប់ ។ បទថា **សមាហិតា** បានដល់ ជាអ្នកមានឯកគ្គតាចិត្ត ។ បទថា **អាកិញ្ចញ្ញំ** បានដល់ ជាអ្នកមិនមានបលិពោធ ។ បទថា **បត្ថយន្តា** បានដល់ ប្រាថ្នា ភ្ជាប់សេចក្ដីថា សិស្សទាំងឡាយរបស់ខ្ញុំ ដល់នូវភាពយ៉ាងនេះ ចោមរោមខ្ញុំសព្វកាល ។

ពួកសិស្សទាំងនុ៎ះ ជាអ្នកប្រាជ្ញដល់នូវត្រើយនៃអភិញ្ញា ត្រេកអរ
ក្នុងគោចរ ជាកេរ្តិ៍នៃបិតា ត្រាច់ទៅក្នុងអាកាសបាន តែង
ចោមរោមខ្ញុំ សព្វកាល ។

បណ្ដាបទទាំងនោះ បទថា **អភិញ្ញាបារមិប្បត្តា** សេចក្ដីថា សម្រេច

បរិបូណ៌ គឺដល់នូវទីបំផុតនៃអភិញ្ញា ៥ បានដល់ ធ្វើឲ្យបរិបូណ៌ហើយ ។

បទថា **បេត្តិកេ គោចរេ រតា** សេចក្តីថា ត្រេកអរហើយក្នុងអាហារ ដែលបានដោយការមិនធ្វើវិញ្ញត្តិ ដែលជាពុទ្ធានុញ្ញាត ។

បទថា **អន្តលិក្ខចរា** សេចក្តីថា ទៅ និងមកក្នុងអាកាស ។

បទថា **ធីរា** សេចក្តីថា ជាអ្នកមាំទាំ គឺមានសភាវៈមិនញាប់ញ័រក្នុង អន្តរាយ មានសីហៈ និងខ្លាធំជាដើម អធិប្បាយថា ពួកតាបសរបស់ខ្ញុំ ជាបុគ្គលយ៉ាងនេះ ចោមរោមខ្ញុំ សព្វកាល ។

ពួកសិស្សខ្ញុំនោះ ជាអ្នកប្រាជ្ញ សង្រួមក្នុងទ្វារ ៦ មិនមាន
តណ្ហាជាគ្រឿងញាប់ញ័រ មានឥន្ទ្រិយរក្សាហើយ មិនប្រឡូក
ប្រឡំ (ដោយពួកគណៈ) ដែលគេគ្របសង្កត់បានដោយក្រ ។

ក្នុងគាថានោះ មានសេចក្តីថា សង្រួម គឺរារាំងហើយ បានដល់ បិទ ហើយក្នុងទ្វារ ៦ មានចក្ខុទ្វារជាដើម និងក្នុងអារម្មណ៍ ៦ មានរូបារម្មណ៍ ជាដើម អធិប្បាយថា ជាអ្នករក្សាគ្រប់គ្រងទ្វារ ។

បទថា **ទុរាសទា** បានដល់ ចូលដល់លំបាក អធិប្បាយថា មិនអាច គឺមិនសមគួរចូលទៅជិត គឺប៉ះខ្ទប់ ។

ពួកសិស្សរបស់ខ្ញុំទាំងនោះ ដែលគេគ្របសង្កត់បាន ដោយក្រ
រមែងញុំាងរាត្រីឲ្យកន្លងទៅ ដោយការអង្គុយផ្គត់ភ្នែន ការ
ឈរ និងការចង្ក្រម ។

ក្នុងគាថានោះ ភ្ជាប់សេចក្តីថា សិស្សទាំងឡាយរបស់ខ្ញុំ ញុំាងរាត្រី

ទាំងមូលឲ្យកន្ទ្រង់ទៅ គឺឲ្យឈានកន្ទ្រង់ដោយពិសេស ដោយការអន្ទ្រយពត់ក្អែន គឺអន្ទ្រយឲ្យជើងត្រួតគ្នា វៀរការដេក ដោយការឈរ និងដោយការចង្ក្រម ។

ពួកសិស្សរបស់ខ្ញុំ ដែលគេគ្របសង្កត់បានដោយក្រ រមែងមិន
ត្រេកត្រអាលក្នុងអារម្មណ៍ ដែលគួរត្រេកអរ មិនខឹងក្នុង
អារម្មណ៍ដែលគួរខឹង មិនវង្វេងក្នុងអារម្មណ៍ ដែលគួរវង្វេង ។

អធិប្បាយសេចក្តីក្នុងគាថានោះថា ពួកសិស្សរបស់ខ្ញុំ គឺតាបសទាំងនោះ ដែលដល់នូវអាការយ៉ាងនេះ រមែងមិនត្រេកអរ គឺមិនធ្វើនូវតម្រេកឲ្យកើតឡើងក្នុងធម៌ជាទីតាំងនៃតម្រេក គឺការវង្វេង មិនខឹង គឺមិនធ្វើនូវការអាក់អន់ក្នុងវត្ថុដែលគួរអាក់អន់ គឺដឹកនាំឲ្យកើតការអាក់អន់ មិនវង្វេង គឺមិនធ្វើនូវការវង្វេងក្នុងធម៌ដែលជាទីតាំងនៃសេចក្តីវង្វេង គឺដឹកនាំឲ្យវង្វេង អធិប្បាយថា ជាអ្នកប្រកបព្រមដោយបញ្ញា ។

ពួកសិស្សទាំងនោះ កាលល្បងឫទ្ធិ រមែងប្រព្រឹត្តអស់កាល
ជានិច្ច ពួកសិស្សទាំងនោះ តែងញុំាងផែនដីឲ្យញាប់ញ័រ ជា
បុគ្គលដែលគេមិនងាយគ្របសង្កត់បាន ដោយការប្រណាំង
ប្រជែង ។

ភ្លាប់សេចក្តីថា សិស្សរបស់ខ្ញុំទាំងនោះ ល្បងបដិបត្តិជានិច្ចកាល នូវការសម្តែងឫទ្ធិ ដូចជាធ្វើមនុស្សម្នាក់ ឲ្យទៅជាច្រើននាក់ក៏បាន មនុស្សច្រើននាក់ ឲ្យជាមនុស្សតែម្នាក់ក៏បាន អធិប្បាយថា សិស្សរបស់ខ្ញុំទាំងនោះ និម្មិត

ផែនដីក្នុងអាកាសខ្លះ ក្នុងទឹកខ្លះ ហើយសម្រេចឥរិយាបថ ។

បទថា **សារម្ភេន** សេចក្តីថា មិនគួរមើលងាយ ដោយការប្រណាំងប្រជែង ឬដោយការធ្វើនូវជម្លោះ ។

ពួកសិស្សទាំងនោះ កាលបើលេង រមែងលេងតែឈាន
តែងយកផ្លែព្រីងអំពីដើមព្រីង ពួកសិស្សរបស់ខ្ញុំ ជាបុគ្គល
ដែលគេគ្របសង្កត់បានដោយក្រ ។

អធិប្បាយថា សិស្សរបស់ខ្ញុំទាំងនោះ កាលលេង ក៏លេង បានដល់ត្រេកអរក្នុងការលេងបឋមជ្ឈានជាដើម ។

បទថា **ជម្ពុតោ ផលមានេត្វា** សេចក្តីថា ទៅដោយឫទ្ធិ ហើយនាំយកមកនូវផ្លែព្រីងទំហំប៉ុនក្អម អំពីដើមព្រីងដែលមានកម្ពស់ ១០០ យោជន៍ក្នុងហិមវន្តប្បទេស ។

ពួកខ្លះ ទៅគោយានទ្វីប ពួកខ្លះ ទៅបុព្វវិទេហទ្វីប ពួកខ្លះ
ទៅកាន់ឧត្តរកុរុទ្វីប ពួកសិស្សខ្ញុំ គេគ្របសង្កត់បានដោយ
ក្រ ។

ក្តាប់សេចក្តីក្នុងគាថានោះថា រវាងសិស្សរបស់ខ្ញុំទាំងនោះ សិស្សមួយពួក គឺមួយពួកទៀត ទៅកាន់គោយានទ្វីប គឺអបរគោយានទ្វីប មួយពួកទៅកាន់បុព្វវិទេហទ្វីប មួយពួកទៅកាន់ឧត្តរកុរុទ្វីប សិស្សទាំងនោះ បុគ្គលគ្របសង្កត់បានដោយក្រ ដោយស្វែងរក គឺដោយការស្វះស្វែងរក បានដល់ស្វែងរកបច្ច័យក្នុងទីទាំងនេះ ។

ពួកសិស្សទាំងនោះ រមែងបញ្ជូនទូវអម្រែកទៅមុន ពួកសិស្ស
ទាំងនោះ រមែងទៅខាងក្រោយ ទាំងផ្ទៃអាកាសក៏សឹងតែបិទ
បាំងដោយពួកតាបស ២៤ ពាន់រូប ។

សេចក្ដីក្នុងគាថាថា សិស្សរបស់ខ្ញុំទាំងនេះ កាលទៅតាមអាកាស បញ្ជូនអម្រែក គឺល្អីដែលដាក់បរិក្ខារតាបស កាលបញ្ជូនអម្រែកនោះ ទៅមុនហើយ ខ្លួនឯងក៏ទៅខាងក្រោយអម្រែកនោះ ។

ភ្ជាប់សេចក្ដីថា ផ្ទៃមេឃ គឺផ្ទៃអាកាសត្រូវតាបស ២៤០០០ ដែលទៅយ៉ាងនោះបិទបាំង គឺបិទ ។

( ពួកសិស្សរបស់ខ្ញុំខ្លះបរិភោគ ) ផ្លែឈើដែលចម្អិនដោយ
ភ្លើង ( ខ្លះបរិភោគ ) ផ្លែឈើមិនបាច់ចម្អិនដោយភ្លើង ខ្លះ
ទំពាដោយធ្មេញ ខ្លះបុកក្នុងត្បាល់ ខ្លះដំដោយថ្ម ខ្លះបរិភោគ
ផ្លែឈើជ្រុះឯង ។

ក្នុងគាថានោះ មានការភ្ជាប់សេចក្ដីថា សិស្សរបស់ខ្ញុំពួកខ្លះ គឺរូបខ្លះចម្អិនដោយភ្លើង គឺដុតផ្លែឈើតូចធំ និងបន្លែជាដើម ហើយទើបបរិភោគ ពួកខ្លះ មិនអាំងដោយភ្លើង គឺមិនអាំងឲ្យឆ្អិនដោយភ្លើង បរិភោគទាំងឆៅ ពួកខ្លះ យកធ្មេញនោះឯង កកេរសម្បកបរិភោគ ពួកខ្លះ បុកនឹងត្បាល គឺប្រើត្បាលបុកបរិភោគ ពួកខ្លះ ដំដោយថ្ម គឺយកថ្មវាយបរិភោគ ពួកខ្លះ បរិភោគផ្លែឈើ ដែលជ្រុះឯង ។

ពួកខ្លះទៀត ចុះត្រាំទឹកក្នុងវេលាល្ងាច ព្រឹក ជាអ្នកត្រេកអរ

ក្នុងអំពើដ៏ស្អាត ប្រព្រឹត្តស្រោចស្រពដោយទឹក ពួកសិស្ស
របស់ខ្ញុំ គេគ្របសង្កត់បានដោយក្រ ។

សេចក្តីរបស់គាថាថា សិស្សទាំងឡាយរបស់ខ្ញុំ គេគ្របសង្កត់បាន ដោយក្រ ពួកខ្លះ ចូលចិត្តការស្អាត គឺត្រូវការភាពបរិសុទ្ធ ចុះងូតទឹក គឺ ចូលទៅក្នុងទឹក ទាំងព្រឹក ទាំងល្ងាច ពួកខ្លះ យកទឹកស្រោចខ្លួន អធិប្បាយ ថា ធ្វើកម្មត្រង់ខ្លួនដោយទឹក ។

ជាអ្នកមានរោមក្លៀក និងក្រចកដុះវែង មានធ្មេញប្រកប
ដោយមន្ទិល មានក្បាលប្រឡាក់ដោយធូលី ក្រអូបដោយក្លិន
នៃសីល ពួកសិស្សរបស់ខ្ញុំ គេគ្របសង្កត់បានដោយក្រ ។

សេចក្តីក្នុងគាថានោះ មានអធិប្បាយថា សិស្សរបស់ខ្ញុំទាំងនោះ បុគ្គល គ្របសង្កត់បានដោយក្រ មានក្រចក និងរោមវែង គឺកើតត្រង់ក្លៀកទាំង ២ ដៃ និងជើង អធិប្បាយថា មិនប្រដាប់តាក់តែង ព្រោះវៀរចាកខុរកម្ម គឺការ កោរដោយកាំបិតកោរ ។

បទថា **បង្កទន្តា** សេចក្តីថា មានធ្មេញប្រកបដោយមន្ទិល ព្រោះមិន បានធ្វើឲ្យសដោយកម្ទេចឥដ្ឋ កម្ទេចថ្មទឹកដោះ ។

បទថា **រជស្សិរា** បានដល់ មានសីសៈប្រឡាក់ធូលី ព្រោះវៀរចាក ការលាបប្រេងជាដើម ។

បទថា **គន្ធិតា សីលគន្ធេន** សេចក្តីថា ជាអ្នកមានក្លិនក្រអូបក្នុងទីគ្រប់ អន្លើ ដោយក្លិនលោកិយសីល ព្រោះជាអ្នកដល់ព្រមដោយសីលដែលប្រកប

ដោយឈាន សមាធិ និងសមាបត្តិទាំងឡាយ ។

ក្នុងបទថា **មម សិស្សា ឩុរាសណា** សេចក្តីថា សិស្សទាំងឡាយរបស់ខ្ញុំ បុគ្គលណាម្នាក់មិនអាចចូលដល់ គឺការខ្វាំងខ្ទប់បាន ព្រោះជាអ្នកប្រកបដោយគុណ មានប្រការដូចពោលហើយនេះ ។

ពួកជដិល ប្រជុំគ្នាក្នុងវេលាព្រឹក មានតបៈដ៏ខ្លាំង សម្តែងនូវ
លាភធំ និងលាភតូច ហើយទៅក្នុងអាកាស ក្នុងកាលនោះ ។

បណ្តាបទទាំងនោះ បទថា **ចាតោវ សន្និបតិត្វា** នេះ **តោ** បច្ច័យ ចុះក្នុងអត្ថនៃសត្តមីវិភត្តិ អធិប្បាយថា ជាពួកជាមួយគ្នាក្នុងសម្នាក់របស់ខ្ញុំ ក្នុងពេលព្រឹកនោះឯង ។

ជដិល គឺតាបស ដែលជាអ្នកពាក់ជដា មានតបៈដ៏ខ្លាំង គឺមានតបៈប្រាកដ បានដល់ មានតបៈផ្សាយទៅហើយ ។ ជដិល គឺ តាបសអ្នកចងជដា ។

ភ្ជាប់សេចក្តីក្នុងទីនេះថា ជដិលទាំងឡាយប្រកាសថា ទីណាមានលាភតិច ទីណាមិនមានតិច គឺប្រាប់លាភតិច និងលាភធំ ឲ្យដឹងក្នុងកាលនោះ គឺក្នុងពេលនោះ ទើបទៅក្នុងលម្ហ គឺផ្ទៃអាកាស ។

សុរុចិតាបស កាលប្រកាសគុណទាំងឡាយនៃតាបសទាំងនោះ ទើបពោលពាក្យថា **ឯតេសំ បក្ខម្ពន្នានំ** ដូច្នេះជាដើម ។ ក្នុងពាក្យនោះ មានសេចក្តីថា សំឡេងខ្លាំងដែលកើតអំពីសំពត់ស្បូវក្លាំងរបស់តាបសទាំងនេះដែលហោះទៅ គឺដែលទៅក្នុងអាកាស ឬលើគោក រមែងតាំងឡើង ។

ក្នុងបទថា **មុទិតា ហោន្តិ ទេវតា** នេះ ភ្នាប់សេចក្តីថា កាលពួកតាបសដែលធ្វើសំឡេងខ្លាំង ឲ្យសោត់ទៅយ៉ាងនោះ ទេវតាទាំងឡាយពេញចិត្តក្នុងស្បែកខ្លា កើតនូវសោមនស្សថា សាធុ សាធុ លោកម្ចាស់ទាំងឡាយ ជាអ្នកត្រេកអរ គឺជាអ្នកពេញចិត្ត ។

ក្នុងបទថា **ទិសោ ទិសំ** នេះ ភ្នាប់សេចក្តីថា ឥសីទាំងនោះទៅក្នុងវេហាស៍ គឺត្រាច់ទៅក្នុងអាកាសជាប្រក្រតី ហោះទៅ គឺទៅកាន់ទិសធំ និងទិសតូច ។

ក្នុងបទថា **សកេ ពលេនុបត្ថទ្ធា** នេះ ភ្នាប់សេចក្តីថា ជាអ្នកប្រកបដោយកម្លាំងរាងកាយ និងកម្លាំងឈានរបស់ខ្លួន ចង់ទៅទីណា ក៏ទៅតាមប្រាថ្នា ។

កាលប្រកាសអានុភាពរបស់តាបសទាំងនោះទៀត ទើបពោលពាក្យថា **បឋវី កម្បកា ឯតេ** ដូច្នេះ ជាដើម ។

ក្នុងកាលនោះ តាបសទាំងនោះ ត្រូវការត្រាច់ទៅក្នុងទីសព្វអន្លើ ជាអ្នកញ៉ាំងផែនដីឲ្យកម្រើក គឺធ្វើផែនដីឲ្យញាប់ញ័រ ត្រាច់ទៅក្នុងអាកាស គឺមានប្រក្រតីត្រាច់ទៅក្នុងអាកាស ។

បទថា **ឧគ្គតេជា** ជាដើម សេចក្តីថា មានតេជះខ្ពង់ខ្ពស់ គឺតេជះផ្សាយទៅ គេគ្របសង្កត់បានដោយក្រ គឺមិនអាចញ៉ាំញី គ្របសង្កត់ឲ្យប្រព្រឹត្តទៅ ( ក្នុងអំណាច ) បាន ព្រោះហេតុនោះ ទើបឈ្មោះថា គេគ្របសង្កត់បានដោយក្រ ។

ក្នុងបទថា **សាគរោវ អក្ខោភិយា** នេះ ភ្ជាប់សេចក្តីថា ជាបុគ្គលដែលអ្នកដទៃឲ្យរញ្ជួយមិនបាន គឺមិនអាចឲ្យញាប់ញ័របាន ប្រៀបដូចសាគរ គឺដូចសមុទ្រដែលអ្នកដទៃឲ្យញាប់ញ័រមិនបាន គឺឲ្យល្អក់មិនបាន ។

ក្នុងបទថា **ឋានចង្កមិនោ កេចិ** នេះ ភ្ជាប់សេចក្តីថា ក្នុងរវាងសិស្សរបស់ខ្ញុំទាំងនោះ ឥសីពួកខ្លះ ដល់ព្រមដោយឥរិយាបថឈរ និងឥរិយាបថចង្ក្រម ឥសីពួកខ្លះមិនដេក គឺដល់ព្រមដោយឥរិយាបថអង្គុយ ឥសីពួកខ្លះបរិភោគស្លឹកឈើដែលជ្រុះឯង ឈ្មោះថា គេគ្របសង្កត់បានដោយក្រ ព្រោះជាអ្នកប្រកបដោយគុណទាំងឡាយបែបនេះ ។

កាលសរសើរតាបសទាំងអស់នោះ ទើបពោលពាក្យថា **មេត្តាវិហារិនោ** ដូច្នេះជាដើម ។

ពាក្យនោះ មានអត្ថថា សិស្សរបស់ខ្ញុំទាំងនេះ ឈ្មោះថា ជាអ្នកនៅដោយមេត្តាធម៌ ព្រោះផ្សាយមេត្តាដែលមានសេចក្តីស្រឡាញ់ជាលក្ខណៈដោយន័យជាដើមថា សត្វមិនមានប្រមាណ ក្នុងចក្កវាឡដែលប្រមាណមិនបាន ចូររស់នៅជាសុខចុះ ដូច្នេះហើយ នៅ គឺញ៉ាំងអត្តភាពឲ្យប្រព្រឹត្តទៅ អធិប្បាយថា ឥសីទាំងអស់នោះ ជាអ្នកស្វែងរកប្រយោជន៍ គឺស្វែងរកប្រយោជន៍ដល់សព្វសត្វ គឺសត្វទាំងពួង ជាអ្នកមិនលើកខ្លួនឯង គឺមិនប្រកាន់ខ្លួន មិនបង្អាប់បុគ្គលណាម្នាក់ គឺអ្នកណាម្នាក់ បានដល់ មិនសម្គាល់ខ្លួនដោយធ្វើខ្លួនឲ្យទាបជាង ។

ភ្ជាប់សេចក្តីថា សិស្សរបស់ខ្ញុំទាំងនោះជាអ្នកមិនញាប់ញ័រ គឺមិនខ្លាច

ដូចរាជសីហ៍ ព្រោះជាអ្នកប្រកបដោយគុណ គឺសីល សមាធិ និងសមាបត្តិ មានកម្លាំង គឺដល់ព្រមដោយកម្លាំងកាយ និងកម្លាំងឈាន ដូចគជសារ គឺដូចស្តេចដំរី ដែលគេគ្របសង្កត់បានដោយក្រ គឺមិនអាចប៉ះពាល់ និងដូចស្តេចខ្លាធំ រមែងមកកាន់សម្នាក់របស់ខ្ញុំ ។

លំដាប់នោះ តាបសកាលប្រកាសអានុភាពរបស់ខ្លួន ឲ្យដឹងដោយអមទើបពោលពាក្យថា **វិជ្ជាធរា** ដូច្នេះជាដើម ។ ក្នុងពាក្យនោះ មានការភ្ជាប់សេចក្តីថា វិជ្ជាធរ មានឫទ្ធិ ដោយការទន្ទេញមន្តជាដើមក្តី កុម្ភទេវតាដែលនៅត្រង់ដើមឈើ និងភ្នំជាដើមក្តី នាគដែលតាំងនៅក្នុងផែនដី និងតាំងនៅលើគោកក្តី គន្ធព្វទេវតាក្តី អារក្សទឹកដែលកាចក្តី កុម្ភណ្ឌទេវតាក្តី ទានវ-ទេវតាក្តី និងគ្រុឌដែលអាចនិម្មិតវត្ថុផ្សេងតាមប្រាថ្នាក្តី តែចូលទៅអាស្រ័យស្រះនោះចិញ្ចឹមជីវិត អធិប្បាយថា នៅត្រង់ស្រះនោះ គឺក្នុងទីជិតស្រះ ។

កាលនឹងពណ៌នាគុណទាំងឡាយរបស់ពួកតាបស ដែលជាសិស្សរបស់ខ្លួននោះឯង ទើបពោលពាក្យថា **តេ ជដា ខារិភរិតា** ដូច្នេះជាដើម ។ ពាក្យទាំងអស់នោះ មានអត្ថងាយយល់ហើយ ។ បទថា **ខារិភារំ** បានដល់បរិក្ខាររបស់តាបស មានត្រឡោកទឹក និងកុណ្ឌីទឹកជាដើម ។

កាលនឹងប្រកាសគុណទាំងឡាយរបស់ខ្លួនទៀត ទើបពោលពាក្យថា **ឧប្បាតេ សុបិនេ ចាបិ** ដូច្នេះជាដើម ។ ក្នុងពាក្យនោះ ភ្ជាប់សេចក្តីថា ព្រោះដល់នូវការសម្រេចក្នុងសិប្បៈរបស់ព្រាហ្មណ៍ និងព្រោះជាអ្នកឈ្លាសក្នុងរឿងរបស់នក្ខត្តឫក្ស កាលត្រូវសួរដល់លក្ខណៈ ខ្ញុំត្រូវបុគ្គលណាម្នាក់

ស្ទួរដល់ការប្រព្រឹត្តទៅក្នុងលក្ខណៈនៃឧត្បាត និងក្នុងសុបិនថា ទក្ខត្តឫក្ស ដែលរាជកុមារនោះកើត តើល្អ ឬមិនល្អ ខ្ញុំជាអ្នកសិក្សាមកល្អហើយ ក្នុងការទាយយល់សប្តិថា សុបិននេះល្អ សុបិននេះមិនល្អ និងក្នុងការប្រាប់លក្ខណៈ ដៃ ជើង របស់ស្ត្រី និងបុរសទាំងពួង ទើបឈ្មោះថា ទ្រទ្រង់នូវមន្តបទ គឺកោដ្ឋាសរបស់មន្តទាយនូវលក្ខណៈគ្រប់យ៉ាង ដែលប្រព្រឹត្តទៅក្នុងជម្ពូទ្វីបទាំងមូល ។

កាលប្រកាសនូវការបានទទួលព្យាកររបស់ខ្លួនដែលមានគុណ សរសើរពុទ្ធគុណទៅខាងមុខ ទើបព្រះថេរៈពោលពាក្យថា **អនោមឧស្សី** ដូច្នេះជាដើម ។ ក្នុងពាក្យនោះ ភ្ជាប់សេចក្តីថា ដែលឈ្មោះថា **អនោម** ព្រោះមិនថោកថយ ។ ការឃើញសព្វសត្វទាំងឡាយ ដោយមំសចក្ខុ ទិព្វចក្ខុ សមន្តចក្ខុ ធម្មចក្ខុ និងពុទ្ធចក្ខុ ឈ្មោះថា ទស្សនៈ ។ ទស្សនៈរបស់ព្រះមានព្រះភាគអង្គណា មិនថោកថយ ព្រះមានព្រះភាគអង្គនោះ ឈ្មោះថា **អនោមឧស្សី** ។ ឈ្មោះថា **ភគវា** ព្រោះហេតុទាំងឡាយ មានភាពជាអ្នកមានភាគ្យ គឺបុណ្យជាដើម ។ ឈ្មោះថា **លោកជេដ្ឋោ** ព្រោះជាអ្នកចម្រើនបំផុត និងប្រសើរបំផុតនៃលោក ។

គោដ៏ប្រសើរ មាន ៣ ពួក គឺគោឧសភៈ ១ គោនិសភៈ ១ គោអាសភៈ ១ ក្នុងគោ ៣ ពួកនោះ គោដែលជាមេហ្វូងនៃគោ ១០០ ឈ្មោះថា **ឧសភ** គោដែលជាមេហ្វូងនៃគោ ១០០០ ឈ្មោះថា និសភៈ គោដែលជាមេហ្វូងនៃគោ ១០០០០ ឈ្មោះថា **អាសភ** ។ បុគ្គលដែលធំជាងនរៈ

ទាំងឡាយ ឈ្មោះថា **ឆកាសភ** បុគ្គលដែលចាក់ធ្លុះនូវធម៌ទាំងពួង ឈ្មោះថា **សម្មាសម្ពុទ្ធ** បុគ្គលដែលប្រាថ្នានូវភាពជាបុគ្គលម្នាក់ឯង ឈ្មោះថា **វិវេកកាម** ទ្រង់យាងចូលទៅកាន់ព្រៃហិមពាន្ត គឺភ្នំហិមាល័យ ។

បទថា **អជ្ឈោគាហេត្វា ហិមវន្តំ** សេចក្តីថា ឈមចុះ គឺយាងចូលទៅជិតភ្នំហិមពាន្ត ។ ពាក្យដ៏សេស មានអត្ថងាយយល់ហើយ ។

ភ្ជាប់សេចក្តីថា ខ្ញុំបានឃើញព្រះលោកនាយកទ្រង់គង់ រុងរឿង គឺរុងរឿងដូចផ្កាឈូកខៀវ ដូចទៀនសម្រាប់បូជា ដូចគំនរភ្លើង រុងរឿងដូចផ្លេកបន្ទោរក្នុងអាកាស គឺក្នុងលម្ហ និងដូចសាលរាជព្រឹក្ស ចេញផ្ការីកស្គុះស្គាយ ។

ទេវតានៃទេវតាទាំឡាយ ឈ្មោះថា **ទេវទេវោ** ព្រោះបានឃើញព្រះមានព្រះភាគអង្គនោះជាទេវតារបស់ទេវតា ទើបខ្ញុំពិនិត្យ គឺពិចារណាព្រះលក្ខណៈ គឺ ហេតុជាគ្រឿងឲ្យដឹងមហាបុរិសលក្ខណៈ ៣២ ប្រការ របស់ព្រះអង្គថា ជាព្រះពុទ្ធ ឬមិនមែនជាព្រះពុទ្ធហ្ន៎ ភ្ជាប់សេចក្តីថា ខ្ញុំឃើញព្រះជិនស្រី មានចក្ខុ គឺ មានចក្ខុ ៥ ដោយហេតុណា ។

ឃើញចក្រទាំងឡាយមានកាំ ១០០០ គឺចក្កលក្ខណៈ ដែលប្រាកដត្រង់ផ្ទៃព្រះបាតដ៏ប្រសើរ គឺត្រង់ផ្ទៃព្រះបាតដ៏ឧត្តម ខ្ញុំបានឃើញលក្ខណៈទាំងនោះនៃព្រះមានព្រះភាគអង្គនោះហើយ ទើបសន្និដ្ឋាន គឺសម្រេចអធិប្បាយថា ជាអ្នកអស់នូវសង្ស័យក្នុងព្រះតថាគត ។ ពាក្យដ៏សេស មានអត្ថងាយយល់ហើយ ។

សេចក្តីក្នុងគាថានេះថា ព្រះសយម្ភូ គឺលោកអ្នកត្រាស់ដឹងឯង ។ បទ

ថា **អមិតោទយ** បានដល់ បុគ្គលជាដែនកើតនៃព្រះគុណរាប់មិនបាន គឺជាដែនកើតឡើង បានដល់ ជាបាទ គឺជាទីតាំងឡើងនៃព្រះគុណទាំងឡាយប្រមាណមិនបាន គឺរាប់មិនបាន ។ ទាំង ២ បទនេះ ជាអាលបនៈទាំងអស់ ព្រះអង្គទ្រង់ជញ្ជូនសត្វលោកនេះ គឺសត្វលោកនេះដោយល្អ គឺទ្រង់ជញ្ជូនឡើងចាកសង្សារឲ្យដល់លើគោក គឺនិព្វាន ។

ក្នុងសេចក្ដីថា ពួកសត្វទាំងនោះ មកកាន់ទស្សនៈរបស់ព្រះអង្គហើយនឹងឆ្លង គឺឈានកន្លងខ្សែទឹក គឺសេចក្ដីសង្ស័យបានដល់ ឱឃៈធំ គឺវិចិកិច្ឆា ។

តាបសកាលសរសើរព្រះមានព្រះភាគ ទើបពោលពាក្យថា **តុវំ សត្ថា** ដូច្នេះជាដើម ។ ក្នុងគាថានោះ ក្នុងសេចក្ដីថា បពិត្រព្រះសព្វញ្ញូដ៏ចម្រើន ទ្រង់ជាសាស្ដា គឺជាអាចារ្យនៃសត្វលោក ព្រមទាំងទេវលោក ទ្រង់ប៉ុណ្ណោះឈ្មោះថា **កេតុ** គឺជារបស់ខ្ពស់ ព្រោះអត្ថថា ឧត្តម ទ្រង់ប៉ុណ្ណោះ ឈ្មោះថា **កេជ** ព្រោះអត្ថថា ប្រាកដក្នុងលោកទាំងមូល ទ្រង់ប៉ុណ្ណោះ ឈ្មោះថា **យូប** គឺដូចគ្នានឹងសសរដែលដោត ព្រោះខ្ពស់ក្នុងលោកទាំង ៣ ទ្រង់ប៉ុណ្ណោះឈ្មោះថា **ជាទាណភិន** គឺជាឋានៈដែលកាន់យកថា ដ៏ឧត្តមរបស់សត្វទាំងឡាយ គឺរបស់សព្វសត្វ ទ្រង់ប៉ុណ្ណោះជាទីពឹង គឺជាឋានៈដែលគប្បីពឹង ទ្រង់ប៉ុណ្ណោះឈ្មោះថា **ទីប** គឺដូចប្រទីបប្រេង ព្រោះកម្ចាត់ងងឹត គឺមោហៈរបស់សត្វលោក ជាបុគ្គលឧត្តមជាងទេវតា និងមនុស្សទាំងឡាយ គឺជាបុគ្គលឧត្តមជាងពួកទេវតា ព្រហ្ម និងមនុស្ស ដែលមានជើង ២ ។

កាលសរសើរចំពោះព្រះមានព្រះភាគទៀត ទើបពោលពាក្យថា **សព្វញ្ញា**

**សមុទ្ទេ ឧទកំ** ដូច្នេះជាដើម ។ ក្នុងគាថានោះ មានអធិប្បាយថា បុគ្គលណាម្នាក់អាចប្រមាណ គឺរាប់ទឹក វាល់ទឹកក្នុងមហាសមុទ្រដែលមានជម្រៅ ៨៤០០០ យោជន៍ បានដោយរង្វាល់ បពិត្រព្រះសព្វញ្ញូដ៏ចម្រើន ព្រះញាណរបស់ទ្រង់ បុគ្គលណាម្នាក់ក៏មិនអាចប្រមាណបាន គឺរាប់បានថា មានប្រមាណប៉ុណ្ណោះ ។

ក្តាប់សេចក្តីថា បុគ្គលណាម្នាក់អាចដាក់ប្រើថពីត្រង់ថាសជញ្ជីង គឺត្រង់ក្អែកជញ្ជីងហើយថ្លឹងបាន បពិត្រព្រះសព្វញ្ញូដ៏ចម្រើន ព្រះញាណរបស់ព្រះអង្គ បុគ្គលណាម្នាក់មិនអាចថ្លឹងបានឡើយ ។

សេចក្តីក្នុងគាថានេះថា បពិត្រព្រះសព្វញ្ញូដ៏ចម្រើន អាកាស គឺវេហាស៍ទាំងមូល បុគ្គលណាម្នាក់អាចវាស់បានដោយខ្សែ ឬម្រាមដៃ តែញាណបានដល់ អាកាស គឺញាណរបស់ព្រះអង្គ បុគ្គលណាម្នាក់មិនអាចប្រមាណ គឺវាស់មិនបានឡើយ ។

ក្នុងបទថា **មហាសមុទ្ទេ ឧទកំ** នេះ សេចក្តីថា គប្បីលះ គឺចោលបានដល់ ឈានកន្លងនូវទឹកទាំងមូល ក្នុងសាគរដែលមានជម្រៅ ៨៤០០០ យោជន៍ និងផែនដីទាំងមូល ដែលមានកម្រាស់ ២ សែន ៤ ម៉ឺនយោជន៍ គឺគប្បីធ្វើការថ្លឹង តែមិនគួរនាំយកព្រះញាណរបស់ព្រះពុទ្ធមកថ្លឹង គឺមកប្រៀបធៀប មិនគួរធ្វើដោយការប្រៀបធៀប គឺដោយអំណាចឧបមា ព្រោះព្រះញាណប៉ុណ្ណោះ ជាគុណជាតដ៏ធំក្រៃលែង ។

បពិត្រព្រះអង្គមានចក្ខុ គឺបពិត្រព្រះអង្គមានចក្ខុ ដោយចក្ខុ ៥ ពាក្យ

នេះ ជាអាលបនៈ គឺជាពាក្យហៅ ។ ពាក្យថា លោកប្រព្រឹត្តក្នុងលោក ព្រមទាំងទេវលោក ដោយទេវតាទាំងឡាយ ពាក្យនេះ ជាឆដ្ឋីវិភត្តិ ចុះក្នុងអត្ថនៃសត្តមីវិភត្តិ ។ ក្ឋាប់សេចក្តីថា ចិត្តរបស់សត្វទាំងឡាយពួកណា គឺមានប្រមាណប៉ុនណា រមែងប្រព្រឹត្តទៅក្នុងរវាងលោក និងព្រមទាំងទេវលោក សត្វទាំងឡាយដែលមានចិត្តទាំងនោះ គឺមានប្រមាណប៉ុណ្ណោះ តាំងនៅខាងក្នុងនៃសំណាញ់ញាណរបស់ព្រះអង្គ គឺចូលទៅខាងក្នុងសំណាញ់ គឺព្រះញាណ អធិប្បាយថា ទ្រង់ឃើញសព្វសត្វទាំងឡាយដោយសំណាញ់ គឺព្រះញាណ ។

ក្ឋាប់សេចក្តីក្នុងគាថានេះថា បពិត្រព្រះសព្វញ្ញូ គឺបពិត្រអ្នកដឹងនូវធម៌ទាំងពួងដ៏ចម្រើន ទ្រង់សម្រេច គឺដល់ព្រះពោធិញ្ញាណ គឺព្រះនិព្វានដ៏ឧត្តមទាំងមូលដោយព្រះញាណណាដែលសម្បយុត្តដោយមគ្គ ទ្រង់ញាំញី គឺគ្របសង្កត់តិរិយ គឺអនុត្តិរិយទាំងឡាយ ដោយព្រះញាណនោះ ។

ព្រះធម្មសង្គាហកត្ថេរទាំងឡាយ កាលនឹងប្រកាសអាការដែលតាបសនោះសរសើរ ទើបពោលពាក្យជាដើមថា **ឥមា គាថា ថវិត្វាន** ដូច្នេះ ។ បណ្តាបទទាំងនោះ បទថា **ឥមា គាថា** សេចក្តីថា តាបសឈ្មោះថា សុរុចិតាមឈ្មោះ តែមកក្នុងអដ្ឋកថាដ៏សេស ឈ្មោះថា សរទមាណពសរសើរ គឺធ្វើនូវការសរសើរដោយគាថាទាំងឡាយនេះ ។ ( ឈ្មោះតាបស ) សូមកាន់យកបាលីតាមអដ្ឋកថាន័យនោះជាគោល ។ ម្យ៉ាងទៀត ឈ្មោះថា សុរុចិ ព្រោះមានការពេញចិត្ត គឺអធ្យាស្រ័យស្អាត បានដល់ មានការអាឡោះអាល័យក្នុងព្រះនិព្វាន ។ ឈ្មោះថា សរទៈ ព្រោះស្មុះ គឺទៅ បានដល់

ប្រព្រឹត្តទៅក្នុងការទូន្មានឥន្ទ្រិយ ដូច្នោះ ឈ្មោះទាំង ២ ទើបជាឈ្មោះរបស់តាបសដូចគ្នា ។ សុរុចិតាបសនោះក្រាលស្បែកខ្លាហើយ អង្គុយលើផែនដី អធិប្បាយថា សរទតាបសអង្គុយវៀរទោសនៃការអង្គុយទាំង ៦ ប្រការ មានជិតពេកជាដើម ។

តាបសអង្គុយក្នុងទីនោះហើយ កាលសរសើរព្រះញាណរបស់ព្រះមានព្រះភាគនោះទៀត ទើបពោលពាក្យថា **ចុល្លាសីតិសហស្សានិ** ដូច្នេះជាដើម ។

ក្នុងគាថានោះមានការភ្ជាប់សេចក្តីថា ស្តេចភ្នំ គឺស្តេចភ្នំសិនេរុឈមចុះបានដល់ ចាក់ឫសទៅក្នុងមហាសមុទ្រ គឺក្នុងសាគរជម្រៅ ៨៤០០០ យោជន៍ កម្ពស់ឡើងលើ ៨៤០០០ យោជន៍ គឺមានប្រមាណប៉ុណ្ណោះ ដែលពោលក្នុងឥឡូវនេះ ។

ភ្នំនេរុកម្ពស់ត្រឹមនោះ គឺខ្ពស់យ៉ាងនោះ ភ្នំមហានេរុនោះ គឺភ្នំនេរុធំយ៉ាងនោះ ដោយចំណែកបណ្តោយ ចំណែកកម្ពស់ និងចំណែកទទឹង ជាភ្នំត្រូវបុកឲ្យល្អិត គឺត្រូវធ្វើឲ្យបែកល្អិតដល់មួយសែនកោដិ ដោយចំណែកនៃការរាប់ ។

ភ្ជាប់សេចក្តីថា បពិត្រព្រះសព្វញ្ញូដ៏ចម្រើន ព្រះញាណរបស់ព្រះអង្គកាលដាក់ខ្ទាច់រាប់ គឺកំណត់ជាមួយរយ មួយពាន់ ឬមួយសែន ឲ្យជាមួយចំណែកៗ ហើយតាំងទុកក្នុងព្រះញាណ កម្ទេចនៃភ្នំនេរុធំនោះឯង គប្បីរាប់អស់បាន ព្រះញាណរបស់ព្រះអង្គ បុគ្គលណាម្នាក់ មិនអាចប្រមាណ គឺធ្វើ

ការរាប់បានឡើយ ។

អធិប្បាយសេចក្តីក្នុងគាថានេះថា បុគ្គលណាគប្បីព័ទ្ធ គឺគប្បីធ្វើការព័ទ្ធ ដោយជុំវិញនូវទឹកក្នុងមហាសមុទ្រទាំងមូល ដោយសំណាញ់ដែលមានក្រឡាញឹក គឺមានក្រឡាល្អិត កាលបុគ្គលនោះព័ទ្ធទឹកយ៉ាងនេះ សត្វពួកណាមួយដែលកើតក្នុងទឹក សត្វទាំងអស់នោះ នឹងត្រូវបង្ខាំងនៅក្នុងសំណាញ់ ។

តាបសកាលសម្តែងសេចក្តីឧបមេយ្យនោះ ទើបពោលពាក្យថា **តថេវ ហិ** ដូច្នេះជាដើម ។ ក្នុងគាថានោះ គប្បីជ្រាបដូច្នេះថា សត្វទាំងឡាយដែលកើតក្នុងទឹក រមែងចូលទៅខាងក្នុងសំណាញ់ យ៉ាងណា បពិត្រព្រះអង្គជាមហាវីរបុរស គឺដែលធ្វើសេចក្តីព្យាយាមដើម្បីសម្រេចព្រះមហាពោធិញ្ញាណក៏ដូច្នោះដូចគ្នា ។ តិរ្ថិយ គឺមេលទ្ធិខុសពួកណាមួយជាច្រើន គឺមិនមែនតិចស្ទុះទៅកាន់ទីសាំញ៉ាំ គឺទិដ្ឋិ គឺចូលទៅកាន់ការប្រកាន់ ពោល គឺទិដ្ឋិ ដែលវង្វេងហើយដោយការប្រកាន់មាំ បានដល់ ត្រូវទិដ្ឋិដែលមានលក្ខណៈបបោសអង្អែលវត្ថុដទៃថា មាន ។ ធ្វើឲ្យវង្វេង គឺបិទបាំង ។

ភ្ជាប់សេចក្តីក្នុងគាថានេះថា តិរ្ថិយទាំងអស់ តាំងនៅខាងក្នុងសំណាញ់ ឬចូលទៅខាងក្នុងសំណាញ់ គឺព្រះញាណ ដោយព្រះញាណដ៏បរិសុទ្ធ គឺមិនមានកិលេសរបស់ព្រះអង្គ មិនមានអ្វីរាំងបាន គឺឃើញធម៌ទាំងពួង ប្រាសចាកគ្រឿងរាំងជាប្រក្រតី ក៏យ៉ាងនោះដូចគ្នា ។ បទថា **ញាណំ តេ នាតិវត្តរេ** សេចក្តីថា ពួកតិរ្ថិយទាំងនោះ មិនកន្លងផុតព្រះញាណរបស់ព្រះអង្គទៅបានឡើយ ។

ក្នុងខាងចុងនៃការសរសើរតាមដែលពោលមកហើយនេះ ដើម្បីសម្តែងការផ្តើមព្យាករឲ្យដល់ខ្លួន ទើបព្រះថេរៈពោលពាក្យថា **ភគវា តម្ហិ សមយេ** ដូច្នេះជាដើម ។ ក្នុងពាក្យនោះ ក្នុងសម័យណា តាបសសរសើរព្រះមានព្រះភាគ ក្នុងសម័យនោះ គឺវេលាសម្រេចនូវការសរសើរព្រះមានព្រះភាគ ព្រះនាមអនោមទស្សី ឈ្មោះថា ព្រះអង្គមានយសធំ ព្រោះទ្រង់មានបរិវារកន្លងផុតនូវការរាប់ ឈ្មោះថា ព្រះមានព្រះភាគជិនសិរី ព្រោះទ្រង់ឈ្នះកិលេសមារជាដើម ទ្រង់ចេញអំពីសមាធិ គឺចាកអប្បនាសមាធិ ទ្រង់ប្រមើលមើលសកលជម្ពូទ្វីបដោយទិព្វចក្ខុ ។

ក្នុងសេចក្តីក្នុងគាថានេះថា ព្រះសាវកឈ្មោះនិសភៈ របស់ព្រះមានព្រះភាគព្រះនាមអនោមទស្សីនោះដ៏ជាមុនី គឺជាអ្នកប្រកបដោយព្រះញាណពោល គឺមោនៈ ទ្រង់ចោមរោមដោយព្រះខីណាស្រពមួយសែនរូប ជាអ្នកមានចិត្តស្ងប់ គឺមានកិលេសក្នុងចិត្តដែលស្ងប់រម្ងាប់ មិនញាប់ញ័រដោយលោកធម៌ ឈ្មោះថា ជាអ្នកមិនញាប់ញ័រ ព្រោះជាបុគ្គលមានសភាវៈមិនញាប់ញ័រ ក្នុងវត្ថុដែលគួរប្រាថ្នា និងមិនគួរប្រាថ្នា ជាអ្នកបរិសុទ្ធ គឺប្រកបដោយកាយកម្មជាដើមដ៏បរិសុទ្ធ មានអភិញ្ញា ៦ ជាតាទិបុគ្គល គឺមានសភាវៈមិនញាប់ញ័រ ដោយលោកធម៌ ៨ ដឹង គឺជ្រាបព្រះតម្រិះរបស់ព្រះពុទ្ធ ក៏ចូលទៅគាល់ព្រះលោកនាយក គឺបានទៅកាន់ទីជិតក្នុងវេលានោះឯង ។

លោកទាំងនោះ ជាអ្នកមកហើយយ៉ាងនោះ ក្នុងទីនោះ គឺក្នុងទីជិតព្រះមានព្រះភាគ ស្ថិតនៅឰដ៏អាកាស គឺក្នុងលម្ហ បានធ្វើប្រទក្សិណព្រះមាន

ព្រះភាគហើយ ។ ក្ជាប់សេចក្ដីថា លោកទាំងនោះ ផ្គងអញ្ជលីនមស្ការ ចុះអំពីអាកាស មកក្នុងសម្នាក់របស់ព្រះសម្ពុទ្ធ ។

តាបស កាលនឹងប្រកាសហេតុខាងដើមនៃពាក្យព្យាករទៀត ទើបពោលពាក្យថា **សិតំ ចាតុការិ** ដូច្នេះជាដើម ។ ពាក្យទាំងអស់នោះ មានអត្ថងាយយល់ហើយ ។

បទថា **យោ មំ បុប្ផេន** សេចក្ដីថា តាបសណាញ៉ាំងចិត្តឲ្យជ្រះថ្លាក្នុងតថាគត ហើយបូជាដោយផ្កាមិនមែនតិច និងសរសើរ គឺសរសើរញាណរបស់តថាគតម្ដងហើយម្ដងទៀតៗ គឺរឿយៗ ។ បទថា **តមហំ** សេចក្ដីថា តថាគតនឹងព្យាករ គឺនឹងធ្វើតាបសនោះឲ្យប្រាកដ អ្នកទាំងឡាយ ចូរស្ដាប់ គឺចូរធ្វើឲ្យជាអារម្មណ៍ក្នុងការស្ដាប់ គឺចូរដាក់ចិត្តក្នុងពាក្យដែលតថាគតពោល ។

ព្រះមានព្រះភាគ កាលទ្រង់ប្រទានការព្យាករណ៍ ទើបត្រាស់ថា **បច្ឆិមេ ភវសម្បត្តេ** ដូច្នេះ ។ ក្នុងពាក្យនោះ មានអធិប្បាយថា កាលភពដែលមានក្នុងទីបំផុត គឺជាទីបំផុតមកដល់តាបសនេះ នឹងទៅកាន់អត្តភាពជាមនុស្ស គឺទៅកើតជាមនុស្ស បានដល់ កើតឡើងក្នុងមនុស្សលោក ព្រាហ្មណីឈ្មោះសារី ព្រោះជាអ្នកមានសារៈ ដោយសារៈទាំងឡាយ ដូចជាសារៈ គឺរូបសារៈទ្រព្យ សារៈត្រកូល សារៈភោគទ្រព្យ និងសារៈ គឺបុណ្យជាដើម និងតាំងគភ៌ ។

ព្រះមានព្រះភាគ ទ្រង់ផ្ដើមមូលព្យាករថា **អបរិមេយ្យេ ឥតោ កប្បេ**

ដូច្នេះ ។ ក្នុងមូលព្យាករនេះ គប្បីឃើញថា អគ្គសាវក ២ រូប បំពេញបារមី ១ អសង្ខេយ្យ និង ១ សែនកប្ប តែដើម្បីការងាយស្រួល ក្នុងការចងគាថា ទើបត្រាស់ដូច្នោះ ព្រោះរាប់អន្តរកប្បចូលផង ។

ព្រះមានព្រះភាគ បានប្រទានព្យាករថា នឹងបានជាអគ្គសាវក ឈ្មោះសារីបុត្រ ។ ព្រះមានព្រះភាគអង្គនោះ កាលប្រទានព្យាករហើយ ត្រាសរសើរតាបសនោះ ទើបត្រាស់ពាក្យថា **អយំ ភាគីរថី** ដូច្នេះជាដើម អធិប្បាយថា រវាងស្ទឹង ៥ ខ្សែនេះ គឺគង្គា យមុនា សរភូ មហី អចិរវតី ស្ទឹងធំមួយខ្សែ ឈ្មោះភាគីរថីនេះ ជាស្ទឹងសំខាន់ខ្សែដំបូង ហូរមកអំពីព្រៃហិមពាន្ត គឺមកអំពីភ្នំហិមពាន្ត កើតអំពីអនោតត្តស្រះ ហូរទៅដល់មហាសមុទ្រ គឺអន្លង់ទឹកធំហូរទៅកាន់ គឺទៅកាន់មហាសមុទ្រ គឺមហាសាគរ យ៉ាងណា សារីបុត្រនេះ ក៏យ៉ាងនោះដូចគ្នា ជាអ្នកអាចហ៊ាន ជាអ្នកក្លៀវក្លាក្នុងវេទទាំង ៣ គឺជាអ្នកក្លាហាន មានញាណមិនភ្លាំងភ្លាត់ គឺមានញាណផ្សាយទៅក្នុងវេទទាំង ៣ ដែលប្រព្រឹត្តទៅតាមត្រកូលរបស់ខ្លួន ដល់នូវបញ្ញាបារមី គឺដល់នូវទីបំផុតនៃសាវកញ្ញាណរបស់ខ្លួន និងញុំាងពួកសត្វ គឺសត្វទាំងអស់ឲ្យឆ្អែត គឺឲ្យឆ្អែតស្កប់ស្កល់ បានដល់ នឹងធ្វើឲ្យកើតនូវការឆ្អែតស្កប់ស្កល់ ។

បទថា **ហិមវន្តមុបាទាយ** សេចក្តីថា រាប់យកភ្នំហិមាល័យជាចំណុចចាប់ផ្តើម ហើយរាប់យកអន្លង់ទឹកធំ គឺមហាសមុទ្រ បានដល់ សាគរដែលមានទឹកពេញ ឲ្យជាចំណុចចុងក្រោយ ក្នុងរវាងនេះ គឺក្នុងកណ្តាលភ្នំ និងសាគរនេះ គំនរខ្សាច់ណា គឺគំនរខ្សាច់ប្រមាណប៉ុនណា មានដោយការរាប់

គឺដោយអំណាចការគណនាខ្សាច់នោះ រាប់មិនអស់ គឺកន្លងនូវការរាប់ ។

បទថា **តម្បិ សក្កា អសេសេន** សេចក្ដីថា ខ្សាច់នោះក៏អាច គឺគប្បីអាចរាប់អស់ ក្នុងបាប់សេចក្ដីថា ការរាប់នោះ រមែងមានដោយប្រការណា ទីបំផុត គឺទីបញ្ចប់នៃបញ្ញារបស់ព្រះសារីបុត្រមិនមានឡើយ ដោយប្រការនោះ ។

បទថា **លក្ខេ ។បេ។ ភវិស្សតិ** សេចក្ដីថា កាលតាំង បានដល់ ការរាប់ដោយញាណ ទុកក្នុងពេលមួយ ខ្សាច់ក្នុងស្ទឹងគង្គាគប្បីអស់ទៅ គឺដល់នូវការអស់ទៅ ។

ក្នុងបទថា **មហាសមុទ្ទេ** នេះ ក្នុងបាប់សេចក្ដីថា រលក គឺក្រុមរលកទំហំមួយគាវុតជាដើម ក្នុងមហាសមុទ្រទាំង ៤ ដែលមានជម្រៅ ៨៤០០០ យោជន៍ដោយការរាប់ រាប់មិនអស់ គឺរាប់មិនអស់ យ៉ាងណា ទីបំផុត គឺចុងបញ្ចប់នៃបញ្ញារបស់ព្រះសារីបុត្រ ក៏មិនមានយ៉ាងនោះ ។

ក្នុងបាប់សេចក្ដីក្នុងគាថានេះថា ព្រះសារីបុត្រនោះ មានបញ្ញាយ៉ាងនេះ នឹងធ្វើព្រះសម្ពុទ្ធព្រះនាមគោតម ព្រោះជាគោតមគោត្រ ជាធំក្នុងសក្យត្រកូល ជាសក្យៈដ៏ប្រសើរ ឲ្យទ្រង់ប្រោសប្រាណ គឺធ្វើនូវការត្រេកអរនៃចិត្ត ដោយវត្តបដិបត្តិ គឺសីល និងអាចារជាដើមដល់ទីបំផុត គឺចំណុចចុងក្រោយនៃសាវកញ្ញាណដោយបញ្ញា និងបានជាអគ្គសាវករបស់ព្រះមានព្រះភាគអង្គនោះ ។

អធិប្បាយសេចក្ដីក្នុងគាថានេះថា ព្រះសារីបុត្រនោះ បានទទួលតំណែងអគ្គសាវកយ៉ាងនេះហើយ នឹងបង្វិលនូវធម្មចក្រ គឺព្រះសទ្ធម្ម ដែលព្រះមាន

ព្រះភាគសក្យបុត្រ ឲ្យប្រព្រឹត្តទៅហើយ គឺទ្រង់ធ្វើឲ្យប្រាកដហើយ ដោយសភាវៈដែលមិនញាប់ញ័រក្នុងឥដ្ឋារម្មណ៍ និងអនិដ្ឋារម្មណ៍ គឺទ្រទ្រង់មិនឲ្យវិនាស និងបន្លឺនូវភ្លៀង គឺធម៌ បានដល់ ភ្លៀង គឺធម្មទេសនាឲ្យធ្លាក់ចុះ បានដល់ នឹងសម្តែង ប្រកាស បើកផ្សាយ ចែក និងធ្វើឲ្យរាក់ ឲ្យប្រព្រឹត្តទៅ ។

ភ្ជាប់សេចក្តីថា ព្រះមានព្រះភាគគោតមសក្យៈដ៏ប្រសើរ ទ្រង់ដឹងក្រៃលែងនូវវត្ថុទាំងអស់នោះ គឺទ្រង់ដឹងដោយញាណវិសេស ទ្រង់គង់ក្នុងកណ្តាលនៃពួកភិក្ខុហើយ គឺក្នុងកណ្តាលព្រះអរិយបុគ្គល ទ្រង់នឹងតែងតាំងព្រះសារីបុត្រក្នុងទីជាអគ្គសាវក គឺក្នុងតំណែងដ៏ឧត្តម ដែលជាទីអភិរម្យនៃគំនរគុណ មានបញ្ញាទាំងអស់ជាដើម ។

តាបសនោះ បានទទួលព្យាករយ៉ាងនេះហើយ ដល់នូវសោមនស្សកាលនឹងបន្លឺឧទាន ដោយអំណាចបីតិសោមនស្ស ទើបពោលពាក្យថា **អហោ មេ សុកតំ កម្មំ** ដូច្នេះជាដើម ។

បណ្តាបទទាំងនោះ សព្ទថា **អហោ** ជានិបាត ចុះក្នុងអត្ថថា គួរអស្ចារ្យ អធិប្បាយថា កម្ម គឺគំនរបុណ្យ ដែលខ្ញុំធ្វើហើយ គឺធ្វើដោយល្អហើយ បានដល់ ជឿហើយ ធ្វើក្នុងព្រះមានព្រះភាគដែលជាសាស្តា គឺដែលជាគ្រូ ព្រះនាមអនោមទស្សី ជាកម្មគួរអស្ចារ្យ គឺគួរកាន់កាំង មានអនុភាពជាអចិន្តេយ្យ ។

ភ្ជាប់សេចក្តីថា ខ្ញុំបានធ្វើអធិការ គឺបុញ្ញសម្ភារក្នុងព្រះមានព្រះភាគអង្គណា ខ្ញុំបានសម្រេចបារមី គឺទីបំផុត បានដល់ ដល់ព្រមនូវទីបំផុតដ៏កំពូល

ក្នុងធម៌ទាំងពួង គឺក្នុងគំនរគុណទាំងមូល ព្រះមានព្រះភាគអង្គនោះ ជាបុគ្គលគួរអស្ចារ្យ គឺគួរកាន់កាំង ។

គាថាថា **អបរិមេយ្យេ** ជាដើម អធិប្បាយថា ព្រះមានព្រះភាគទ្រង់សម្តែងកុសលកម្មដែលធ្វើហើយ ក្នុងកាលដែលរាប់មិនអស់ថា មានផល គឺវិបាក ក្នុងអត្តភាពចុងក្រោយនេះដល់ខ្ញុំ ។ ខ្ញុំផុតកិលេសទាំងឡាយហើយ ដោយផលនៃបុណ្យនោះ ដូចកម្លាំងនៃសរ ដែលរួចស្រឡះហើយ គឺផុតទៅល្អហើយ បានដល់ ដែលនាយខ្មាន់ធ្នូ អ្នកឈ្លាសបាញ់ទៅហើយ ។ ព្រះសារីបុត្រ កាលប្រកាសសេចក្តីព្យាយាមរបស់ខ្លួន ទើបពោលពាក្យថា **អសង្ខតំ** ដូច្នេះជាដើម ។

បណ្តាបទទាំងនោះ បទថា **អសង្ខតំ** បានដល់ តាក់តែងមិនបាន អធិប្បាយថា ដែលបច្ច័យទាំងឡាយប្រជុំធ្វើមិនបាន ភ្ជាប់សេចក្តីថា ខ្ញុំនោះកាលស្វែងរក គឺស្វះស្វែងរកនិព្វានដែលបច្ច័យតាក់តែងមិនបាននោះ ដែលឈ្មោះថា មិនកម្រើក ព្រោះមិនមានភាពបដិកូលដោយកិលេស ឈ្មោះថាបទ ( ផ្លូវ ) ព្រោះជាទីតាំងនៃបុញ្ញសម្ភារដែលធ្វើហើយ ពិនិត្យមើល គឺពិចារណានូវពួកលទ្ធិទាំងអស់ គឺបុគ្គលដែលនាំឲ្យកើតទិដ្ឋិ ទើបបានអន្ទោលទៅ គឺវិលវល់ក្នុងភព មានកាមភពជាដើម ។

កាលប្រកាសបំណងរបស់ខ្លួន ទើបពោលពាក្យថា **យថាបិ ព្យាធិតោ រោសោ** ដូច្នេះជាដើម ។

ក្នុងគាថានោះ ភ្ជាប់សេចក្តីថា បទថា **ព្យាធិតោ** សេចក្តីថា បុគ្គល គឺ

គឺបុរស ត្រូវព្យាធិបៀតបៀន គប្បីស្វែងរកឱសថ យ៉ាងណា អាត្មាអញ ក៏ដូច្នោះ កាលស្វែងរកអមតបទ គឺនិព្វានដែលបច្ច័យតាក់តែងមិនបាន ទើបបួសជាឥសី ៥០០ ជាតិ គឺក្នុងអត្តភាព ៥០០ ដែលជាប់តគ្នា គឺមិនដាច់ខ្សែ ជាប់តគ្នាទៅ ។

បទថា **កុតិត្ថេ សញ្ចរឹ អហំ** សេចក្តីថា ខ្ញុំអន្ទោលទៅក្នុងកំពង់ គឺផ្លូវទៅដ៏លាមក ។ បុរសអ្នកត្រូវការខ្លឹម គឺបុរសដែលស្វែងរកខ្លឹមឈើ ។ បទថា **កទលឹ ឆេត្វាន ផាលយេ** សេចក្តីថា គប្បីកាត់នូវដើមចេក ហើយពុះជា ២ ចំណែក ។ បទថា **ន តត្ថ សារំ វិន្ទេយ្យ** សេចក្តីថា កាលពុះចេញហើយ ក៏មិនជួប គឺមិនបាននូវខ្លឹមត្រង់ដើមចេកនោះ ភ្ជាប់សេចក្តីថា បុរសនោះ ជាបុគ្គលទទេ គឺសូន្យចាកខ្លឹម ។

ភ្ជាប់សេចក្តីថា ដើមចេកទទេ គឺទទេចាកខ្លឹម យ៉ាងណា ពួកតិរ្ថិយ គឺជនជាច្រើន ដែលមានទិដ្ឋិផ្សេងៗ ក្នុងលោក ក៏ដូច្នោះដូចគ្នា ជាបុគ្គលទទេ គឺទទេចាកព្រះនិព្វានដែលជាអសង្ខតៈ ។ សព្ទថា **សេ** ត្រឹមតែជានិបាត ។

អធិប្បាយក្នុងគាថានេះថា ក្នុងភពទីបំផុត គឺក្នុងជាតិចុងក្រោយ ខ្ញុំបានកើតជាព្រាហ្មណ៍ គឺកើតក្នុងត្រកូលព្រាហ្មណ៍ ។ បទថា **មហាភោគំ ឆឌ្ឌេត្វាន** សេចក្តីថា ខ្ញុំលះគំនរទ្រព្យធំ ដូចដុំទឹកមាត់ ចូលទៅកាន់ផ្នួស គឺបដិបត្តិជាបព្វជិត បានដល់ ជាអ្នកវៀរចាកកម្ម មានកសិណកម្ម និងពាណិជ្ជកម្មជាដើម គឺបួសជាតាបស ។

**ពណ៌នាបឋមភាណវារៈ ចប់**

បទថា **អជ្ឈាយកោ ។បេ។ មុនី មោនេ សមាហិតំ** សេចក្ដីថា ញាណ ហៅថា **មោន** បុគ្គលប្រកបដោយមោនៈនោះ ឈ្មោះថា **មុនី** ។ បុគ្គលមានចិត្តតម្កល់ស្មើ គឺតាំងចុះដោយប្រពៃ ឈ្មោះថា តាំងមាំក្នុងមោនៈនោះ ។ ឈ្មោះថា **នាគ** ព្រោះមិនធ្វើបាប គឺទោស បានដល់ ព្រះអស្សជិព្រះមហានាគនោះ ដែលរុងរឿងដូចផ្កាឈូកដែលរីកល្អហើយ ។

បទថា **ធិស្វា មេ ។បេ។ បុច្ឆិតុំ អមតំ បទំ** មានអត្ថងាយយល់ហើយ ។

បទថា **វិជិន្តរេ** ក្ដាប់សេចក្ដីថា ខ្ញុំបានចូលទៅ គឺទៅជិតព្រះថេរៈនោះ ដែលនៅ គឺមកដល់ បានដល់ ដល់ក្នុងវាងផ្លូវ ហើយទើបសួរ ។

បទថា **កីទិសំ តេ មហាវីរ** ក្ដាប់សេចក្ដីថា បពិត្រមហាវីរៈអ្នកបានសម្រេចអរហត្ត ក្នុងការប្រកាសព្រះធម្មចក្កគ្រាដំបូង ក្នុងវាងព្រះអរហន្តទាំងឡាយ ក្នុងសាសនារបស់បុរសអ្នកមានបញ្ញាទ្រទ្រង់ចាំទាំងអស់ បពិត្រលោកអ្នកមានយស ព្រោះជាអ្នកច្រើនទៅដោយបរិវារដែលកើតតាមមក គ្រូរបស់លោក មានពាក្យប្រៀបប្រដៅ គឺសាសនា ពោល គឺធម្មទេសនាដូចម្ដេច អធិប្បាយថា លោកដ៏ចម្រើន គឺលោកដែលមានមុខផូរផង់ សូមលោកសម្ដែង គឺសូមពោលនូវពាក្យប្រៀនប្រដៅដែលល្អ គឺចម្រើនដល់ខ្ញុំផងចុះ ។

លំដាប់នោះ ព្រះសារីបុត្រ កាលនឹងសម្ដែងអាការដែលសួរ ទើបពោលពាក្យថា **សោ មេ បុដ្ឋោ** ដូច្នេះជាដើម ។

បណ្ដាបទទាំងនោះ បទថា **សោ** សំដៅដល់ អស្សជិត្ថេរ ក្ដាប់សេចក្ដី

ថា ព្រះអស្សជិត្ថេរ ដែលខ្ញុំសួរហើយ គឺពោលថា ពាក្យប្រៀនប្រដៅដូចម្ដេច ទើបពោលពាក្យទាំងអស់ ។ ពាក្យប្រៀបប្រដៅទាំងអស់ ឈ្មោះថា ជ្រាលជ្រៅ ព្រោះជ្រៅដោយអត្ថ ឈ្មោះថា ជ្រាលជ្រៅ ព្រោះជ្រៅដោយទេសនា ធម្មៈ និងបដិវេធ ជាបទដែលល្អិត គឺជាព្រះនិព្វាន ព្រោះប្រកាសបរមត្ថសច្ចជាដើម ជាគុណកម្ចាត់បង់នូវសរ គឺតណ្ហា បានដល់ ធ្វើឲ្យវិនាស ដែលបន្ទោបង់នូវកងទុក្ខទាំងពួង គឺជាធម៌ ធ្វើនូវការអស់ទៅនៃសង្សារទុក្ខទាំងពួង ។

កាលសម្ដែងអាការដែលព្រះអស្សជិពោល ទើបពោលពាក្យថា **យេ ធម្មា** ដូច្នេះជាដើម ក្នុងសេចក្ដីថា ធម៌ទាំងឡាយណា គឺសភាវធម៌ពួកណា ព្រមទាំងបច្ច័យ មានហេតុជាដែនកើត គឺឧប្បត្តិក កើត ផុសឡើង កើតព្រម កើតឡើង កើតឡើងចំពោះអំពីហេតុ មាន មានព្រម រកបាន ព្រះតថាគតត្រាស់ហេតុនៃធម៌ទាំងនោះ ។ បទថា **តេសញ្ច យោ និរោធោ** បានដល់ ការរលត់ គឺសភាវៈនៃការរលត់ឯណា នៃធម៌ដែលមានហេតុទាំងនោះ ។ បទថា **ឯវំ វាទី មហាសមណោ** សេចក្ដីថា ព្រះមានព្រះភាគឈ្មោះថា មហាសមណៈ ព្រោះជាធំដោយបរិវា គឺគុណ មានសីល សមាធិ បញ្ញាជាដើម និងព្រោះជាអ្នកកម្ចាត់បាបបានហើយ តែងពោលយ៉ាងនេះ គឺត្រាស់ប្រាប់ការរម្ងាប់ហេតុជាដើមជាប្រក្រតី ។

កាលស្ដាប់ធម៌ដែលព្រះថេរៈពោលហើយ បន្ទាប់អំពីនោះ កាលនឹងសម្ដែងប្រការដែលខ្លួនធ្វើឲ្យប្រចក្ស ទើបពោលពាក្យថា **សោហំ** ដូច្នេះ

ជាដើម ។ ពាក្យនោះ មានអត្ថងាយយល់ហើយ ។

បទថា **ឯសេវ ធម្មោ យទិ តាវទេវ** សេចក្តីថា បើមិនមានធម៌ក្រៃលែងជាងនេះហើយ ប៉ុណ្ណោះក៏ល្មម គឺចំពោះសោតាបត្តិផលនេះប៉ុណ្ណោះ សេចក្តីថា បើយ៉ាងនោះ ប៉ុណ្ណោះឯង ចាត់ជាធម៌ ។ លោកឃើញប្រចក្ស គឺនិព្វានបទ ដែលមិនសោយសោក ។ បទនេះ ឈ្មោះថា ខ្ញុំមិនធ្លាប់ឃើញអស់កាលច្រើនម៉ឺនកប្ប ។

បទថា **យ្វាហំ ធម្មំ គវេសន្តោ** ជាដើម សេចក្តីថា ខ្ញុំណាកាលស្វែងរក គឺស្វែងរកធម្មសន្តិបទ បានវង្វេង គឺវិលវល់ក្នុងលទ្ធិខុស គឺលទ្ធិគួរខ្ពើម បានដល់ លទ្ធិដែលគួរតិះដៀល ។ បទថា **សោ មេ អត្ថោ អនុប្បត្តោ** សេចក្តីថា ប្រយោជន៍ដែលគួរស្វែងរកនោះ ខ្ញុំបានសម្រេចហើយ គឺដល់ព្រមហើយ ឥឡូវនេះ ជាកាលដែលខ្ញុំមិនប្រមាទ គឺជាអ្នកមិនប្រមាទ អធិប្បាយថា ខ្ញុំដែលព្រះអស្សជិត្ថេរឲ្យត្រេកអរហើយ គឺធ្វើនូវសោមនស្សឲ្យហើយ ដល់ គឺសម្រេចនិព្វានបទ ដែលមិនញាប់ញ័រ គឺមិនឃ្លៀងឃ្លាត កាលបបួល គឺទៅរកសម្លាញ់ ឈ្មោះកោលិតមាណព ទើបទៅកាន់អាស្រមបទ ។

បទថា **ទូរតោវ មមំ ទិស្វា** សេចក្តីថា សម្លាញ់របស់ខ្ញុំសិក្សាល្អហើយ ឃើញខ្ញុំមកអំពីចម្ងាយអំពីអាស្រមបទ សម្លាញ់នោះ ជាអ្នកដល់ព្រម គឺដល់ព្រមដោយឥរិយាបថ មានការឈរ និងការអង្គុយជាដើម បានពោល គឺពោលពាក្យតទៅខាងនេះ បានដល់ ពាក្យដែលនឹងពោលតទៅខាងមុខនេះ ។

អធិប្បាយថា នែសម្លាញ់ដ៏ចម្រើន អ្នកមានមុខ និងភ្នែកដ៏ស្រស់បស់ គឺជាអ្នកប្រកបដោយមុខ និងភ្នែកផូរផង់ គឺល្អ បានដល់ រុងរឿង ហាក់ដូចជាមុនី អ្នកមានសភាពយ៉ាងនេះ បានសម្រេចនិព្វានហើយឬ ខ្ញុំសូមសួរអ្នកថា អ្នកបានសម្រេចបទ គឺព្រះនិព្វានដែលមិនចុតិហើយឬ ។

គាថាថា **សុភាន្វយោ អាយាសិ** សេចក្ដីថា អ្នកជាបុគ្គលសមគួរដល់ភាពល្អ គឺវណ្ណៈដែលផូរផង់ដើរមក ។ ដោយបទថា **អាកេញ្ចការិតោ វិយ** នេះ កោលិតមាណពសួរថា នែអ្នក បុគ្គល ឈ្មោះថា ព្រាហ្មណ៍ ព្រោះជាអ្នកបន្សាត់បាបហើយ អ្នកដូចជាបុគ្គលដែលទូន្មានមកហើយ គឺដូចបានសិក្សាយ៉ាងល្អមកហើយ ៣ ខែ ដូចដំរីចាក់ដោយលំពែងជាដើម ក៏មិនញាប់ញ័រ បុគ្គលមានការទូន្មានហើយ គឺមានសិក្ខាបទដែលបានសិក្សាហើយ អ្នកចូលដល់បទដ៏ស្ងប់ហើយឬ ។

ឧបតិស្សមាណពត្រូវកោលិតមាណពនោះសួរ ទើបពោលពាក្យថា **អមតំ មយា** ដូច្នេះជាដើម ។ ពាក្យនោះ មានអត្ថងាយយល់ហើយ ។

បទថា **អបរិយោសិតសង្កប្បា** ជាដើម សេចក្ដីថា ជាអ្នកមានការត្រិះរិះមិនដល់ទីបំផុតនៃសេចក្ដីប្រាថ្នា ដែលប្រាថ្នាថា ខ្ញុំគប្បីជាអគ្គសាវករបស់ព្រះពុទ្ធមួយអង្គក្នុងអនាគត ។ ខ្ញុំវង្វេង គឺវិលទៅក្នុងលទ្ធិដែលខុស គឺក្នុងផ្លូវដែលមិនគួរទៅ អធិប្បាយថា បពិត្រព្រះអង្គដ៏ចម្រើន គឺបពិត្រព្រះគោតម ទ្រង់ជាបុគ្គលចម្រើនបំផុតក្នុងលោក ព្រោះបានអាស្រ័យ គឺព្រោះបានសម្រេចទស្សនៈរបស់ព្រះអង្គ សេចក្ដីត្រិះរិះរបស់ខ្ញុំព្រះអង្គ គឺការប្រាថ្នា

របស់ខ្ញុំព្រះអង្គទើបពេញ គឺបរិបូណ៌ហើយ ដោយការសម្រេចអរហត្តមគ្គ គឺដោយការសម្រេចសាវកបារមីញាណ ។ បទថា **បថវិយំ បតិដ្ឋាយ** សេចក្តីថា ដើមឈើដែលកើតលើផែនដី រមែងរីក គឺរីកតាមរដូវកាល គឺក្នុងហេមន្តរដូវ បញ្ចូនក្លិនក្រអូប គឺបញ្ចូនក្លិនផ្សាយទៅ គឺផ្សាយឈ្មុយឈ្មុបទៅ រមែងញ៉ាំងសត្វទាំងពួង គឺញ៉ាំងទេវតា និងមនុស្សទាំងពួងឲ្យត្រេកអរ គឺធ្វើឲ្យប្រកបដោយសោមនស្ស យ៉ាងណា ។

ក្នុងគាថាថា **តវេវាហំ មហាវីរ** ក្តាប់សេចក្តីថា បពិត្រព្រះអង្គ អ្នកមានព្យាយាមធំ គឺជាអ្នកមានបរិវារច្រើន ដែលកើតក្នុងសក្យត្រកូល ខ្ញុំព្រះអង្គតាំងនៅ គឺតាំងនៅក្នុងសាសនារបស់ព្រះអង្គ ទើបស្វែងរក គឺស្វែងរកសម័យ គឺកាលដើម្បីរីក គឺដើម្បីនឹងរីកដោយអរហត្តមគ្គញាណ ដូច្នោះដូចគ្នា ។

គាថាថា **វិមុត្តិបុប្ផំ** សេចក្តីថា ឈ្មោះថា **វិមុត្តិ** ព្រោះផុត ឬរលាស់ចាកកិលេសទាំងពួង ។ ស្វែងរក គឺរកផ្កា ពោល គឺអរហត្តផលវិមុត្តិដែលជាទីផុតចាកភវសង្សារនោះ គឺដែលអន្ទោលទៅ ស៊ុះទៅ ក្នុងភពមានកាមភពជាដើម ដែលផុតចាកភវសង្សារនោះ ឈ្មោះថា **ភវសំសារ-មោចនំ**។ បទថា **វិមុត្តិបុប្ផលាភេន** សេចក្តីថា ឈ្មោះថា **វិមុត្តិ** ព្រោះរួចផុត ម្យ៉ាងទៀត ឈ្មោះថា **វិមុត្តិ** ព្រោះជាគ្រឿងរួចផុតនៃបុគ្គលដែលមានបុញ្ញសម្ភារដែលធ្វើហើយ បានដល់ ផលដ៏ប្រសើរ គឺអរហត្តផល ។ ឈ្មោះថា **បុប្ផំ** ព្រោះជាគ្រឿងរីក គឺរីកនៃវេនេយ្យសត្វ ។ ផ្កា គឺវិមុត្តិ ឈ្មោះថា

**វិមុត្តិបុប្ផ** ។ ការបាន ឈ្មោះថា **លាភ** ការបានទូវផ្កា គឺវិមុត្តិ ឈ្មោះថា **វិមុត្តិបុប្ផលាភេន** ខ្ញុំព្រះអង្គញ៉ាំងពួកសត្វទាំងពួង គឺសព្វសត្វឲ្យត្រេកអរ គឺឲ្យដល់នូវសោមនស្ស ដោយការបានផ្កា គឺវិមុត្តិ បានដល់ ដោយការសម្រេចនោះ ។

ក្នុងបទថា **យាវតា ពុទ្ធក្ខេត្តម្ហិ** ដូច្នេះជាដើម ភ្ជាប់សេចក្តីថា បពិត្រព្រះអង្គទ្រង់មានចក្ខុ គឺមានចក្ខុ ៥ ។ ខេត្ត គឺអានុភាពរបស់ព្រះបរិត្ត មានរតនសូត្រជាដើម រមែងប្រព្រឹត្តទៅក្នុងទីប្រមាណប៉ុនណា ក្នុងពុទ្ធក្ខេត្ត ពោលគឺក្នុងទីមួយសែនកោដិចក្កវាឡមានប្រមាណប៉ុណ្ណោះ លើកលែងតែព្រះមហាមុនីចេញ គឺវៀរចាកព្រះសម្មាសម្ពុទ្ធ បណ្តាសត្វទាំងឡាយដ៏សេស មិនមានបុគ្គលដទៃណាមួយស្មើ គឺប្រៀបផ្ទឹមស្មើនឹងបញ្ញានៃបុត្ររបស់ព្រះអង្គ គឺខ្ញុំព្រះអង្គដែលជាបុត្តរបស់ទ្រង់ ។ ពាក្យដ៏សេស មានអត្ថងាយយល់ហើយ ។

បទថា **បដិបន្នា** សេចក្តីថា ព្រះអរិយភិក្ខុទាំង ៨ ពួកនេះ គឺលោកអ្នកដែលដល់ព្រមដោយមគ្គ ៤ លោកអ្នកដែលតាំងនៅក្នុងផល គឺតាំងនៅក្នុងអរហត្តផល និងព្រះសេក្ខៈដែលដល់ព្រមដោយផល គឺលោកអ្នកដែលប្រកបដោយផលទាំង ៣ ខាងក្រោម ប៉ុនប៉ង គឺស្វែងរកប្រយោជន៍ដ៏ខ្ពង់ខ្ពស់ គឺព្រះនិព្វាន តែងចោមរោម គឺគប់រក ចូលទៅអង្គុយជិតព្រះអង្គដែលមានបញ្ញាសព្វៗ កាល គឺអស់កាលទាំងពួង ។

ពួកសាវកជាអ្នកឈ្លាសវៃ គឺជាអ្នកឈ្លាសក្នុងសតិប្បដ្ឋាន ៤ ពោលគឺកាយានុបស្សនា ១ វេទនានុបស្សនា ១ ចិត្តានុបស្សនា ១ ធម្មានុបស្សនា ១

ត្រេកអរ គឺព្យាយាមក្នុងការចម្រើនភាវនា គឺការចម្រើនពោជ្ឈង្គ ៧ មានសតិសម្ពោជ្ឈង្គជាដើម ។

ទ្រង់រុងរឿងដូចព្រះចន្ទ្រ គឺដូចស្តេចនៃផ្កាយ ។

ឈ្មោះថា ផែនដី ( ធរណី ) ព្រោះទ្រទ្រង់នូវដើមឈើ ភ្នំ រតនៈ និងសត្វជាដើម ដើមឈើទាំងឡាយ ឈ្មោះថា **ធរណីរុហា** ព្រោះដុះឡើង គឺកើត និងចម្រើនលើធរណី ។ ដើមឈើទាំងឡាយ តាំងនៅលើផែនដី រមែងដុះដាល់ គឺរមែងដល់នូវការចម្រើនដុះដាល់ ។ ឈ្មោះថា តែងលូតលាស់ចម្រើនឡើង គឺភាពបរិបូណ៌ ដើមឈើទាំងនោះ តែងបញ្ចេញផ្កា គឺរមែងមានផ្លែដោយលំដាប់ ។

កាលទីងសរសើរព្រះមានព្រះភាគទៀត ទើបព្រះថេរៈពោលពាក្យជាគាថាថា **សិន្ធុ សរស្សតី** ដូច្នេះជាដើម ។

គប្បីជ្រាបវិនិច្ឆ័យក្នុងពាក្យនោះដូចតទៅ បទថា **សិន្ធុ** ជាដើម បានដល់ ស្ទឹងឈ្មោះសរស្សតី ស្ទឹងឈ្មោះនន្ទិយៈ ស្ទឹងឈ្មោះចន្ទភាគា ស្ទឹងឈ្មោះគង្គា ស្ទឹងឈ្មោះយមុនា ស្ទឹងឈ្មោះសរភូ និងស្ទឹងឈ្មោះមហី ។ សាគរ គឺមហាសមុទ្រប៉ុណ្ណោះ រមែងទទួល គឺទទួលយក បានដល់ ទ្រទ្រង់នូវទឹកទាំងនេះ ដែលហូរទៅ គឺហូរចូលទៅ ។ ក្នុងកាលនោះ ស្ទឹងទាំងអស់នេះ តែងលះបង់ គឺបោះបង់ឈ្មោះដើម បានដល់ ឈ្មោះ និងបញ្ញត្តិ-វោហារដើម មានស្ទឹងសិន្ធុជាដើមប្រាកដ គឺគេដឹងថា ជាសាគរដូចគ្នា យ៉ាងណា វណ្ណៈទាំង ៤ នេះ គឺត្រកូល ៤ បានដល់ ក្សត្រ ព្រាហ្មណ៍ វេស្សៈ

និងសូទ្រ: ក៏យ៉ាងនោះដូចគ្នា បួស គឺទ្រទ្រង់បាត្រ និងសំពត់កាសាវ: បដិបត្តិ គឺក្នុងសម្នាក់ បានដល់ ក្នុងទីជិតព្រះអង្គ រមែងលះ គឺរមែងលះឈ្មោះដើម គឺបញ្ញត្តិវោហារដែលមានឈ្មោះថា ក្សត្រជាដើមប្រាកដ គឺគេដឹងថា ជាពុទ្ធបុត្ត គឺជាពុទ្ធឱរស ។

ព្រះចន្ទ គឺចន្ទមណ្ឌល ឈ្មោះថា ប្រាសចាកមន្ទិល គឺមានមន្ទិលទៅប្រាសហើយ បានដល់ មិនមានមន្ទិល ព្រោះប្រាសចាកគ្រឿងសៅហ្មង ៥ ប្រការ គឺពពក ទឹកសន្សើម ធូលី ផ្សែង និងរាហុ គោចរទៅក្នុងអាកាសធាតុ គឺលម្ហ ញុំាញីនូវពួកផ្កាយទាំងអស់ដោយរស្មី រមែងរុងរឿង គឺភ្លឺស្វាងក្នុងលោក យ៉ាងណា ទ្រង់ក៏យ៉ាងនោះ គឺបែបនោះដូចគ្នា ។បេ។

ឈូក-ស និងកុមុទកើតក្នុងទឹក គឺចម្រើនក្នុងទឹក មានច្រើន គឺកន្ទង ផុតការរាប់ មិនប្រឡាក់ គឺមិនជាប់ដោយទឹក ភក់ និងល្បាប់ យ៉ាងណា ពួកសត្វជាច្រើន គឺសត្វមិនមានប្រមាណ ក៏យ៉ាងនោះដូចគ្នា តែងកើតឡើង គឺចម្រើនក្នុងលោក ដែលរាគ: និងទោស:បៀតបៀន គឺរឹតរុំ រមែងដុះដាល ដូចកុមុទដុះដាល គឺកើតក្នុងភក់ ដូច្នោះ ។ ពាក្យថា **កេសរី** ស្មើគ្នានឹងពាក្យថា **បទុមំ** ។

បទថា **រម្មកេ មាសេ** បានដល់ ក្នុងខែកត្តិក ព្រោះលោកពោលថា ក្នុងថ្ងៃ ១៥ កើត នៃខែទី ៤ ដែលជារដូវរីកនៃ ( រដូវ ) ជាថ្ងៃរីកនៃផ្កាកុមុទ ។

ភ្ជាប់សេចក្តីថា ផ្កាជាច្រើនកើតក្នុងទឹក បានដល់ ផ្កាឈូកជាដើម រមែង

រីក គឺរីកស្គុះស្គាយ ផ្កាដែលកើតក្នុងទឹក រមែងរលងខែនោះ គឺខែកត្តិកនោះទៅមិនបាន ។ បទថា **សមយោ បុប្ផនាយ សោ** សេចក្ដីថា ខែកត្តិកនោះ ជាសម័យ គឺពេលនៃផ្ការីក គឺលានូវត្របក ។ ផ្កាទាំងឡាយ រមែងរីក យ៉ាងណា បពិត្រព្រះសក្យបុត្រ ទ្រង់ជាអ្នករីក គឺរីកហើយដូច្នោះដូចគ្នា ។ បទថា **បុប្ផិតោ តេ វិមុត្តិយា** សេចក្ដីថា ភិក្ខុទាំងឡាយជាសិស្សរបស់ព្រះអង្គ ធ្វើនូវបុញ្ញសម្ភារហើយ ជាអ្នករីកហើយ គឺជាអ្នករីកស្គុះស្គាយហើយដោយវិមុត្តិ គឺដោយញាណក្នុងអរហត្តផល អធិប្បាយថា ឈូកដែលកើតក្នុងទឹក រមែងមិនផុតពេលដែលរីក យ៉ាងណា សត្វទាំងនោះ រមែងមិនកន្លង គឺមិនកន្លងផុតពាក្យប្រៀនប្រដៅ គឺឱវាទានុសាសនីរបស់ព្រះអង្គ ក៏យ៉ាងនោះ ។

បទថា **យថាបិ សេលោ ហិមវា** អធិប្បាយថា ភ្នំ ដែលសម្រេចហើយដោយថ្ម ឈ្មោះថា ហិមពាន្ត ។ ភ្នំហិមពាន្តនោះ ជាទីកើតឱសថ គឺមានឱសថរបស់ពួកសត្វ គឺសម្រាប់សត្វដែលមានជំងឺទាំងអស់ ជាលំនៅ គឺជាស្រុកទេសរបស់ពួកនាគ អសុរ និងទេវតាទាំងពួង យ៉ាងណា បពិត្រមហាវីរៈ ទ្រង់ក៏ដូច្នោះ ទ្រង់ដូចទីកើតឱសថ ព្រោះដោះនូវសត្វទាំងពួងឲ្យផុតចាកជរា ព្យាធិ និងមរណៈជាដើម ។ ភ្ជាប់សេចក្ដីថា ភ្នំហិមពាន្តនោះ ជាលំនៅរបស់ពួកនាគជាដើម យ៉ាងណា សត្វទាំងឡាយដែលសម្រេច គឺដល់នូវការពេញ គឺទីបំផុតនៃវិជ្ជា ៣ អភិញ្ញា ៦ និងឥទ្ធិឫទ្ធិ ក៏រមែងអាស្រ័យព្រះអង្គ ដូច្នោះ ។ ដោយឧបមា និងឧបមេយ្យ មុន និងក្រោយ

ធ្វើឲ្យយល់អត្ថរបស់គាថាបានងាយហើយ ។

ក្នុងបទថា **អាសយានុសយំ ញត្វា** នេះ គប្បីជ្រាបដូច្នេះ **អាសយ** គឺអធ្យាស្រ័យ បានដល់ ចរិយា កិលេសដ៏ខ្លាំងក្លា ឈ្មោះថា អនុស័យ អធិប្បាយថា ទ្រង់ជ្រាបអធ្យាស្រ័យ និងអនុស័យ គឺការប្រព្រឹត្តទៅនៃកិលេស ដោយន័យជាដើមថា បុគ្គលនេះជារាគចរិត បុគ្គលនេះជាទោសចរិត បុគ្គលនេះជាមោហចរិត ។ បទថា **ឥន្ទ្រិយានំ ពលាពលំ** សេចក្តីថា ទ្រង់ដឹងនូវឥន្ទ្រិយ ៥ មានសទ្ធិន្ទ្រិយជាដើមថាមានកម្លាំង និងមិនមានកម្លាំងយ៉ាងនេះថា បុគ្គលនេះមានឥន្ទ្រិយចាស់ក្លា មានឥន្ទ្រិយទន់ខ្សោយ មានអាការល្អ មានអាការមិនល្អ ឲ្យត្រាស់ដឹងបានងាយ ឲ្យត្រាស់ដឹងបានដោយក្រ ។ បទថា **ភព្វាភព្វេ វិទិត្វាន** សេចក្តីថា បពិត្រព្រះសព្វញ្ញូដ៏ចម្រើន ទ្រង់ជ្រាប គឺទ្រង់ឃើញប្រចក្សថា បុគ្គលនេះ គួរ គឺអាច បុគ្គលនេះ មិនគួរត្រាស់ដឹងនូវធម៌ដែលតថាគតសម្តែងហើយ ទើបទ្រង់គ្រហឹម គឺទ្រង់ធ្វើចក្រវាលទាំងមូលឲ្យខ្ទរខ្ទារ ដោយការគ្រហឹម ដែលមិនតក់ស្លុត ដោយការគ្រហឹមដូចសីហៈ ក្នុងការសម្តែងធម៌ ដូចមហាមេឃដែលតាំងឡើងក្នុងទ្វីបទាំង ៤ គ្រហឹម ដូច្នោះ ។ បទថា **ចក្កវាឡបរិយន្តា** សេចក្តីថា បរិស័ទគប្បីអង្គុយពេញចក្កវាឡដោយជុំវិញ ពួកគេអង្គុយយ៉ាងនោះ មានទិដ្ឋិផ្សេងៗ គ្នា គឺមានការកាន់យកទស្សនៈមិនមែនតិច ពោលផ្សេងៗ គ្នា កើតនូវការសង្ស័យវិវាទគ្នា ដើម្បីនឹងផ្តាច់បង់សេចក្តីសង្ស័យ គឺដើម្បីកាត់នូវមិច្ឆាញាណរបស់ពួកគេ ទ្រង់ជាមុនី ទ្រង់ឈ្លាសក្នុងឧបមា គឺទ្រង់មានជំនាញក្នុងឧបមាឧបមេយ្យ

ទ្រង់បានជ្រាបនូវចិត្ត គឺទ្រង់ជ្រាបការទៅនៃចិត្តរបស់សត្វទាំងពួង ទ្រង់សម្ដែងតែមួយបញ្ហា ក៏កាត់នូវការសង្ស័យនៃសត្វទាំងឡាយ ដែលអន្ទយក្នុងល្វែងនៃចក្កវាឡទាំងមូលបាន គឺទ្រង់ធ្វើឲ្យអស់សេចក្ដីសង្ស័យ ដោយការត្រាស់ ១ បញ្ហាប៉ុណ្ណោះ ។

បទថា **ឧបធិសសធិសោហោវ** នេះ គប្បីជ្រាបដូចតទៅ ឈ្មោះថា **ឧបធិស** ព្រោះមើលឃើញ គឺជារបស់ប្រាកដលើទឹក បានដល់ ពួកចក ។ ដូចគ្នានឹងចក បានដល់ ពួកជនដែលដូចគ្នានឹងចក ដូចឧបសទិសៈ គឺចកទាំងឡាយ ធ្វើទឹកមិនឲ្យប្រាកដ ផ្សាយលើទឹកនោះ យ៉ាងណា ពសុធា គឺផែនដី ក៏យ៉ាងនោះ គប្បីពេញដោយពួកមនុស្ស ដូចគ្នានឹងចកនោះឯង នៅពេញទាំងអស់ ទាំងអស់នោះ ពេញផែនដី ផ្គងអញ្ជលី គឺផ្គងអញ្ជលីលើសិរសា សរសើរទ្រង់ដែលជាលោកនាយក គឺគប្បីពោលគុណរបស់ព្រះសម្ពុទ្ធ ដែលជាលោកនាយក ។

ទេវតា និងមនុស្សទាំងឡាយនោះសរសើរ គឺនឹងពោលគុណអស់មួយកប្ប គឺអស់កប្បទាំងមូល ក៏គប្បីប្រកាសដោយគុណផ្សេងៗ គឺដោយព្រះគុណមានប្រការផ្សេងៗ ទោះជាយ៉ាងនោះ ទេវតា និងមនុស្សទាំងអស់នោះ ក៏មិនគប្បីសម្រេចនូវការរាប់បានឡើយ គឺឲ្យដល់ព្រម គឺមិនអាចធ្វើឲ្យអស់បាន ដើម្បីនឹងរាប់ចំនួន គឺដើម្បីពោលចំនួនព្រះគុណបាន ។ ព្រះតថាគតមានគុណគេមិនគប្បីរាប់បានឡើយ គឺព្រះសម្មាសម្ពុទ្ធមានព្រះគុណក្រៃលែង រហូតរាប់ប្រមាណមិនបាន ។ លោកសម្ដែងថា ព្រះពុទ្ធជាបុគ្គល

មានគុណដ៏ក្រៃលែង ដោយបទថា **អប្បមេយ្យា** នេះ ។

អធិប្បាយក្នុងគាថានេះថា ព្រះពុទ្ធទ្រង់ឈ្នះហើយ គឺទ្រង់ឈ្នះកិលេស ជាបុគ្គលដែលខ្ញុំសរសើរហើយ គឺលើកតម្កើងហើយដោយកម្លាំងរបស់ខ្លួន គឺដោយកម្លាំងរបស់ខ្លួន ដោយឧបមា ឧបមេយ្យខាងដើម យ៉ាងណា ទេវតានិងមនុស្សទាំងពួង កាលសរសើរអស់កោដិកប្បក្តី រយកោដិកប្បក្តី ក៏គប្បីសរសើរ គឺគប្បីពោលយ៉ាងនោះដូចគ្នា ។

ដើម្បីសម្តែងគុណទាំងឡាយ ប្រមាណមិនបានដដែលទៀត ទើបព្រះថេរៈពោលថា **សចេ ហិ កោចិ ទេវោ វា** ដូច្នេះជាដើម ។ បទថា **បូរិតំ បរិកឌ្ឍយ្យ** សេចក្តីថា បុគ្គលណា គប្បីបាចទឹកដែលពេញក្នុងមហាសមុទ្រដោយជុំវិញ បុគ្គលនោះ គប្បីបាន គឺគប្បីដល់នូវការលំបាក គឺសេចក្តីទុក្ខប៉ុណ្ណោះ ។

បទថា **វត្តេមិ ជិនសាសនំ** សេចក្តីថា ខ្ញុំឲ្យប្រព្រឹត្តបដិបត្តិទៅ គឺរក្សាព្រះត្រៃបិដកទាំងមូលដែលព្រះជិនស្រីត្រាស់ហើយ ។ បទថា **ធម្មសេនាបតិ** សេចក្តីថា ឈ្មោះថា ជាធម្មសេនាបតី ព្រោះជាធំ គឺជាប្រធានក្នុងបរិស័ទ ពោល គឺបរិស័ទ ៤ របស់ព្រះមានព្រះភាគដោយធម៌ គឺដោយបញ្ញា អធិប្បាយថា ក្នុងសាសនារបស់ព្រះសក្យបុត្ត គឺរបស់ព្រះមានព្រះភាគ ខ្ញុំនឹងរក្សាព្រះពុទ្ធសាសនាទាំងមូលក្នុងថ្ងៃនេះ គឺក្នុងកាលដែលកំពុងប្រព្រឹត្តទៅនេះ ដូចជេដ្ឋឱរស គឺកូនច្បងរបស់ស្តេចចក្រពត្តិ ដូច្នោះ ។

កាលនឹងសម្តែងការរីលរវល់ ទៅក្នុងសង្សាររបស់ខ្លួន ទើបពោលពាក្យ

ថា **យោ កោចិ មនុជោ ភារំ** ដូច្នេះជាដើម ។ ក្នុងសេចក្ដីក្នុងពាក្យនេះថា មនុស្សណាមួយគប្បីដាក់ភារៈ គឺទ្រទ្រង់ដោយក្បាល ទុកលើក្បាល គឺអំបែងក្បាល ហើយទូល គឺគប្បីនាំទៅ មនុស្សនោះគប្បីមានសេចក្ដីទុក្ខដោយភារៈ គឺគប្បីជាអ្នកត្រូវរបស់ធ្ងន់នោះបៀតបៀនគ្របសង្កត់ សព្វៗ កាល គឺគ្រប់កាល ។ ភារៈ បានដល់ ភារៈដែលរែកដោយស្មា ខ្ញុំរែកហើយ គឺរែកច្រើនក្រៃលែង ។ ឯខ្ញុំព្រះអង្គ ត្រូវភ្លើងកិលេសទាំង ៣ គឺខ្ញុំ ពោល គឺរាគគ្គិ ទោសគ្គិ មោហគ្គិ ដុតយ៉ាងនោះ គឺដោយប្រការនោះ អំរែក គឺជាទុក្ខដោយភារៈ គឺកព បានដល់ ភារៈ គឺការចូលដល់កវសង្សារ ដូចរែកភ្នំសិនេរុ គឺដូចដកយក គឺលើកយកភ្នំមហានេរុបពិតដាក់លើក្បាល អន្ទោលទៅ គឺវិលទៅជុំវិញក្នុងភពទាំងឡាយ ។

បទថា **ឱរោបិតោ ច មេ ភារោ** សេចក្ដីថា ឥឡូវនេះ ខ្ញុំដាក់ គឺទម្លាក់ភារៈ គឺភពនោះ តាំងអំពីកាលដែលបួសហើយ ។ បទថា **ភវា ឧគ្ឃាដិតា មយា** សេចក្ដីថា ភពថ្មីគ្រប់ភព ខ្ញុំកម្ចាត់ហើយ ។ កិច្ចទាំងពួងដែលគួរធ្វើ គឺការងារកម្ចាត់កិលេសដោយលំដាប់ មគ្គដែលត្រូវធ្វើឯណា មានក្នុងសាសនារបស់ព្រះសក្យបុត្រ គឺព្រះមានព្រះភាគ កិច្ចដែលគួរធ្វើទាំងអស់នោះ ខ្ញុំធ្វើស្រេចហើយ ។

កាលនឹងសម្ដែងគុណវិសេសរបស់ខ្លួនទៀត ទើបព្រះថេរៈពោលបទថា **យាវតា ពុទ្ធក្ខេត្តម្ហិ** ដូច្នេះជាដើម ។ ក្នុងពាក្យនោះ លោកសម្ដែងថា ក្នុងពុទ្ធក្ខេត្ត ពោល គឺម៉ឺនចក្កវាឡមានកំណត់ត្រឹមណា គឺមានប្រមាណប៉ុនណា

វៀរលែងព្រះអង្គជាបុគ្គលដ៏ប្រសើរក្នុងសក្យត្រកូលចេញ គឺព្រះមានព្រះភាគ ដែលចម្រើនបំផុតក្នុងសក្យត្រកូល បណ្តាសត្វដ៏សេសទាំងឡាយ មិនមាន សត្វណាមួយដែលស្មើខ្ញុំដោយបញ្ញា ។ ដោយហេតុនោះ ទើបព្រះថេរៈពោល ថា ខ្ញុំព្រះអង្គជាបុគ្គលប្រសើរដោយប្រាជ្ញា នឹងរកបុគ្គលណាមួយ ឲ្យស្មើនឹង ខ្ញុំព្រះអង្គពុំបាន ជាបុគ្គលក្រៃលែង ដូច្នេះ ។

កាលនឹងសម្តែងអានុភាពរបស់ខ្លួនទៀត ទើបព្រះថេរៈពោលគាថាថា **សមាធិម្හි** ដូច្នេះជាដើម ។ ពាក្យនោះ មានអត្ថងាយយល់ហើយ ។

បទថា **ឈានវិមោក្ខានខិប្បបដិលាភី** សេចក្តីថា ជាអ្នកបានឈាន ដោយឆាប់រួសរាន់ នូវឈាន មានបឋមជ្ឈានជាដើម និងវិមោក្ខដែលជា លោកុត្តរ ៨ ដែលបានឈ្មោះថា វិមោក្ខ ព្រោះផុតចាកលោក ឈ្មោះថា សម្រេចបានរហ័ស ។

កាលនឹងប្រកាសថា ទោះខ្លួនមានអានុភាពច្រើនយ៉ាងនោះ ក៏ជាអ្នក មានការគោរព រាប់អានច្រើន ក្នុងសព្រហ្មចារីទាំងឡាយ ទើបពោលបទថា **ឧទ្ធតវិសោវ** ដូច្នេះជាដើម ។ ក្នុងពាក្យនោះ មានអធិប្បាយដូចតទៅថា ឥឡូវនេះ ខ្ញុំព្រះអង្គមានសេចក្តីធោត គឺមានះដាក់ចុះហើយ គឺជាបុគ្គលមាន ការតម្កើងខ្លួនដោយមានះ មានការស្រវឹងព្រោះគោត្រជាដើម បោះបង់ចោល ហើយ ដូចពស់ដែលមានចង្កូមគេដកហើយ គឺមានពិសដ៏ខ្លាំងក្លា ខ្ចាក់ចោល ហើយ ដូចឧសភកាត់ស្នែងហើយ គឺត្រូវកាត់ស្នែងចោលហើយ ចូលទៅរក គឺចូលមកកាន់ទីប្រជុំសង្ឃ គឺសម្នាក់សង្ឃ ដោយការគោរពពន់ពេក គឺ

ដោយការរាប់អានច្រើន ដោយការពេញចិត្ត ។

ឥឡូវនេះ ដើម្បីប្រកាសថា លោកជាអ្នកមានបញ្ញាច្រើន ទើបព្រះថេរៈពោលបទថា **យថាបិ** ដូច្នេះជាដើម អធិប្បាយថា បញ្ញាធំរបស់ខ្ញុំព្រះអង្គបែបនេះ ជារបស់មិនមានរូបរាង បើគប្បីមានរូបរាង ក្នុងកាលនោះ បញ្ញារបស់ខ្ញុំ ក៏នឹងស្មើ គឺគប្បីស្មើនឹងស្ដេចផែនដីក៏បាន គឺព្រះរាជាជាធំក្នុងផែនដី ។ កាលសម្ដែងថា លោកជាអ្នកមានបញ្ញាច្រើនយ៉ាងនេះហើយ បន្ទាប់អំពីនោះ បានរឭកដល់បុព្វកម្ម ដោយបុព្វេនិវាសានុស្សតិញ្ញាណ ទើបពោលពាក្យថា **អនោមទស្សិស្ស** ដូច្នេះជាដើម ។ ក្នុងពាក្យនោះ មានអធិប្បាយថា ភាពជាធំនៃបញ្ញារបស់ខ្ញុំនេះ ជាផលនៃការសរសើរព្រះញាណ ដែលខ្ញុំធ្វើហើយ ដល់ព្រះពុទ្ធព្រះនាមអនោមទស្សី ។

ចក្ក សព្ទ ក្នុងពាក្យថា **បវត្តិតំ ធម្មចក្កំ** នេះ រមែងប្រព្រឹត្តទៅក្នុងអត្ថថា **ពាហន** ដូចក្នុងប្រយោគជាដើមថា **ចតុចក្កយានំ** ប្រែថា យានមានកង់ ៤ ។

ប្រព្រឹត្តទៅក្នុងអត្ថថា **ទេសនា** ដូចក្នុងប្រយោគជាដើមថា **បវត្តិតេ ច បន ភគវតា ធម្មចក្កេ** ប្រែថា កាលបើធម្មចក្រដែលព្រះដ៏មានព្រះភាគឲ្យប្រព្រឹត្តទៅ ។

ប្រព្រឹត្តទៅក្នុងអត្ថថា **បុញ្ញកិរិយាវត្ថុ** គឺទានមយ ដូចក្នុងប្រយោគជាដើមថា **ចក្កំ វត្តយ សព្វបាណិនំ** ប្រែថា សូមព្រះអង្គញុំាងចក្កធម៌ ឲ្យប្រព្រឹត្តទៅដល់សត្វទាំងពួង ។

ប្រព្រឹត្តទៅក្នុងអត្ថថា **ឥរិយាបថ** ដូចក្នុងប្រយោគជាដើមថា **ចក្កំ វត្តេតិ អហោរត្តំ** ប្រែថា រមែងញ៉ាំងចក្រ គឺឥរិយាបថឲ្យប្រព្រឹត្តទៅអស់ថ្ងៃនិងយប់ ប្រព្រឹត្តទៅក្នុងអត្ថថា **ខុរចក្ក** ដូចក្នុងប្រយោគជាដើមថា **ឥច្ឆាហតស្ស ពោសស្ស ចក្កំ ភមតិ មត្ថកេ** ប្រែថា ចក្រវិលកិនអំបែងក្បាលបុគ្គលដែលឥស្សាគ្របសង្កត់ហើយ ប្រព្រឹត្តទៅក្នុងអត្ថថា **ចក្ករតន** ដូចក្នុងប្រយោគជាដើមថា **រាជា វត្តវត្តី ចក្កានុភាវេន វត្តនកោ** ប្រែថា ព្រះបាទចក្រពត្តិ យាងទៅដោយអានុភាពនៃចក្រ ។

ក្នុងទីនេះ **ចក្ក** សព្ទនេះ ប្រព្រឹត្តទៅក្នុងទេសនា ភ្ជាប់សេចក្តីថា ខ្ញុំប្រកាសតាម គឺប្រកាសទៅតាមបានដោយប្រពៃ គឺដោយមិនខុស បានដល់សំដែង គឺធ្វើការសំដែងព្រះធម្មចក្រ ពោល គឺព្រះត្រៃបិដកដែលព្រះសក្យបុត្រ គឺព្រះគោតមសម្ពុទ្ធដែលជាតាទិបុគ្គល គឺដែលប្រកបដោយតាទិគុណដែលធ្វើឲ្យមាំទាំ ទ្រង់ឲ្យប្រព្រឹត្តទៅហើយ គឺទ្រង់សំដែងហើយ ។ កាលប្រកាសតាម គឺការទៅតាមធម្មចក្រដែលទ្រង់សំដែងហើយនេះ ហើយសំដែងតាមក្រោយ ជាផលនៃការសរសើរព្រះញាណ ដែលខ្ញុំធ្វើហើយ ដល់ព្រះសម្ពុទ្ធអង្គមុន ។

បន្ទាប់អំពីនោះ កាលនឹងសំដែងផលនៃបុណ្យ មានការចូលទៅអាស្រ័យសប្បុរស និងយោនិសោមនសិការជាដើម ទើបព្រះថេរៈពោលពាក្យថា **មា មេ កទាចិ បាបិច្ឆោ** ដូច្នេះជាដើម ។ ក្នុងពាក្យនោះ ភ្ជាប់សេចក្តីថា អ្នកមានសេចក្តីប្រាថ្នាលាមក គឺអ្នកប្រកបដោយការចង់បានដ៏លាមក បានដល់

មានប្រក្រតីប្រព្រឹត្តលាមក ជាអ្នកខ្ជិលប្រអូស ក្នុងការធ្វើវត្តបដិបត្តិ ក្នុងការឈរ និងការអង្គុយជាដើម ជាអ្នកមានព្យាយាមធូរថយ ក្នុងការចម្រើនឈាន សមាធិ និងមគ្គជាដើម ឈ្មោះថា ជាអ្នកមិនចេះដឹង ព្រោះវៀរចាកគន្ថធុរៈ និងវិបស្សនាធុរៈ និងឈ្មោះថា ជាអ្នកអនាចារ ព្រោះវៀរចាកអាចារក្នុងអាចារ្យ និងឧបជ្ឈាយ៍ជាដើម កុំឲ្យមកជួបប្រទះ គឺរួមជាមួយខ្ញុំក្នុងទីណាមួយ ក្នុងកាលណាមួយឡើយ ។

បទថា **ពហុស្សុតោ** បានដល់ បុគ្គលជាពហូសូត ២ យ៉ាងដោយអំណាចបរិយត្តិ និងបដិវេធ ។ បទថា **មេធាវី** បានដល់ ប្រកបដោយមាធាគឺបញ្ញា ។ បទថា **សីលេសុ សុសមាហិតោ** សេចក្តីថា តាំងមាំហើយ គឺមានចិត្តតាំងមាំហើយ ក្នុងបារិសុទ្ធិសីល ៤ សីលដែលសម្បយុត្តដោយមគ្គ និងឧបោសថសីលមានអង្គ ៨ ជាដើម ។ បទថា **ចេតោសមថានុយុត្តោ** បានដល់ បុគ្គលប្រកបឯកីភាវៈនៃចិត្ត អធិប្បាយថា បុគ្គលបែបនេះ ចូរតាំងនៅលើសិរសាដោយពិត គឺចូរតាំងនៅលើសីសៈដែលជាអំបែងក្បាលរបស់ខ្ញុំនោះឯង ។ ព្រះសារីបុត្តត្ថេរកាលពោលផលានិសង្ស ដែលខ្លួនបានហើយ កាលនឹងដឹកនាំអ្នកដទៃក្នុងសេចក្តីនោះ ទើបពោលពាក្យថា **តំ ភោ វទាមិ ភទ្ទន្តេ** ដូច្នេះជាដើម ។ ពាក្យនោះ មានអត្ថងាយយល់ហើយ ។

បទថា **យមហំ** សេចក្តីថា ព្រះអស្សជិត្ថេរអង្គណា ខ្ញុំឃើញមកអំពីមុន គឺគ្រាដំបូង បានជាអ្នកប្រាសចាកមន្ទិល គឺវៀរចាកមន្ទិល ព្រោះលះកិលេសទាំងឡាយ មានសក្កាយទិដ្ឋិជាដើម ដោយការបានទូវសោតាបត្តិមគ្គ

ព្រះអស្សជិត្ថេរនោះជាអាចារ្យខ្ញុំ គឺជាអ្នកឲ្យសិក្សានូវលោកុត្តរធម៌ ខ្ញុំបានជាធម្មសេនាបតីក្នុងថ្ងៃនេះ ព្រោះការបានស្តាប់ គឺព្រោះការប្រៀនប្រដៅរបស់ព្រះអស្សជិត្ថេរនោះ ។ ខ្ញុំដល់នូវបារមី គឺដល់នូវទីបំផុតដ៏កំពូល គឺក្នុងទីទាំងពួង គឺក្នុងគុណទាំងពួង ជាអ្នកមិនមានអាសវៈ គឺមិនមានកិលេស ។

កាលនឹងសម្តែងការមានសេចក្តីគោរពក្នុងអាចារ្យរបស់ខ្លួន ទើបព្រះថេរៈពោលពាក្យថា **យោ មេ អាចរិយោ** ដូច្នេះជាដើម ។ ក្នុងសេចក្តីថា ព្រះថេរៈណាឈ្មោះអស្សជិ ជាសាវ័ករបស់ព្រះសាស្តា បានជាអាចារ្យរបស់ខ្ញុំ ព្រះថេរៈនោះ គង់ក្នុងទិសណា គឺក្នុងចំណែកនៃទិសណា ខ្ញុំធ្វើចំណែកនៃទិសនោះទុកលើសិរសារបស់ខ្ញុំ គឺចំណែកខាងលើនៃសិរសា ។

បន្ទាប់អំពីនោះ កាលសម្តែងថា លោកបានទទួលតំណែង ទើបព្រះថេរៈពោលពាក្យថា **មម កម្មំ** ដូច្នេះជាដើម ។ ក្នុងសេចក្តីថា ព្រះគោតម គឺព្រះមានព្រះភាគជាសក្យៈដ៏ប្រសើរ គឺជាកំពូលរបស់សក្យត្រកូល ទ្រង់រឭក គឺទ្រង់ជ្រាបនូវកម្មដែលធ្វើក្នុងកាលមុនរបស់ខ្ញុំ ដោយព្រះសព្វញ្ញុតញ្ញាណ គង់ប្រថាប់ក្នុងកណ្តាលភិក្ខុសង្ឃ ទ្រង់តម្កល់នូវខ្ញុំក្នុងទីដ៏ប្រសើរ គឺតំណែងអគ្គសាវ័ក ។

បដិសម្ភិទាទាំង ៤ នេះ គឺអត្ថប្បដិសម្ភិទា ធម្មប្បដិសម្ភិទា និរុត្តិប្បដិសម្ភិទា បដិភាណប្បដិសម្ភិទា និងការផ្សេងគ្នានៃបដិសម្ភិទាទាំងនោះ លោកបានពោលហើយក្នុងបដិសម្ភិទាមគ្គ ។

វិមោក្ខ ៨ ពោលដោយមគ្គ ៤ និងផល ៤ ឬពោលដោយរូបជ្ឈាន

*និងអរូបជ្ឈាន បានដល់ ធម៌ជាគ្រឿងរួចផុតចាកសង្សារ និងអភិញ្ញា ៦ មាន ឥទ្ធិវិធជាដើម ខ្ញុំបានធ្វើឲ្យជាក់ច្បាស់ហើយ គឺធ្វើឲ្យប្រចក្សហើយ ។ បទថា* **កតំ ពុទ្ធស្ស សាសនំ** *សេចក្ដីថា ពាក្យទូន្មាន បានដល់ ពាក្យប្រៀនប្រដៅ ពោល គឺឱវាទរបស់ព្រះពុទ្ធ ខ្ញុំក៏បានបដិបត្តិហើយ គឺធ្វើឲ្យសម្រេចហើយ ដោយអរហត្តមគ្គញាណ ។*

*សព្ទថា* **ឥត្ថំ** *ក្នុងពាក្យថា* **ឥត្ថំ សុទំ** *នេះ ជានិបាត ប្រើក្នុងអត្ថថា ចង្អុលបង្ហាញ សេចក្ដីថា ដោយប្រការដូច្នេះ ។ ដោយពាក្យនោះ លោក សំដៅដល់ អបទានរបស់ព្រះសារីបុត្រទាំងមូល ។ សព្ទថា* **សុទំ** *ជានិបាត ប្រើក្នុងអត្ថថា ធ្វើបទឲ្យពេញ ។ បទថា* **អាយស្មា** *ជាពាក្យហៅដោយ សេចក្ដីគោរពជាគ្រូ ។ បទថា* **សារិបុត្តោ** *បានដល់ ព្រះថេរៈដែលគេហៅ តាមឈ្មោះរបស់មាតា ។ បទថា* **ឥមា គាថាយោ** *សេចក្ដីថា បានភាសិត គឺពោលគាថាដោយអបទានរបស់ព្រះសារីបុត្តត្ថេរទាំងអស់នេះ ។* **ឥតិ** *សព្ទ ជានិបាត ចុះក្នុងអត្ថថា ចប់បរិបូណ៌ អធិប្បាយថា អបទានរបស់ព្រះ សារីបុត្រទាំងមូល ចប់ហើយ ៕*

## អដ្ឋកថា សារីបុត្តត្ថេរាបទាន ចប់

# សុត្តន្តបិដក

## មហាមោគ្គល្លានត្ថេរាបទានទី ៤

[ ៤ ] ព្រះមានព្រះភាគ ព្រះនាមអនោមទស្សី ជាច្បងក្នុងលោក ជានរាសភៈ មានពួកទេវតាចោមរោម ទ្រង់គង់នៅក្នុងព្រៃហិមពាន្ត ។ គ្រានោះ ខ្ញុំកើតជាស្តេចនាគ ឈ្មោះវរុណៈ នៅក្នុងមហាសមុទ្រចេះប្លែងរូបបានតាមសេចក្តីប្រាថ្នា ។ វេលានោះ ខ្ញុំបានលះបង់នូវពួកនាគជាបរិវារ ហើយបានផ្តើមប្រគំតូរ្យតន្ត្រី ឯពួកស្រីអប្សរ ( នាងនាគមានវិកា ) ក៏ចោមរោមប្រគំ ថ្វាយព្រះសម្ពុទ្ធដែរ ។ កាលមានតូរ្យតន្ត្រីរបស់ពួកនាគហើយ ពួកទេវតាក្នុងចាតុម្មហារាជិកា ក៏បានប្រគំនូវតូរ្យតន្ត្រីទិព្វ ឯព្រះសម្ពុទ្ធ ទ្រង់ឮ ទ្រង់ជ្រាបច្បាស់នូវសំឡេងនៃតូរ្យតន្ត្រីទាំងពីរពួកនោះ ។ បន្ទាប់មក ខ្ញុំបាននិមន្តព្រះសម្ពុទ្ធ ហើយវិលត្រឡប់ចូលទៅកាន់ពិភពរបស់ខ្លួនវិញ បានក្រាលអាសនៈ រួចហើយ ទៅក្រាបបង្គំទូលកត្តកាល ។ ព្រះលោកនាយក មានពួកព្រះខីណាស្រពមួយពាន់ចោមរោម ទ្រង់ផ្សាយនូវពន្លឺស្មើសព្វទិស ហើយស្តេចចូលទៅកាន់លំនៅរបស់ខ្ញុំ ។ វេលានោះ ខ្ញុំបានអង្គាសព្រះពុទ្ធមានព្យាយាមធំ ទ្រង់ជាទេវតា ប្រសើរជាងទេវតា ជានរាសភៈ និងភិក្ខុសង្ឃដែលចូលទៅក្នុងលំនៅនៃខ្ញុំឲ្យឆ្អែតស្កប់ស្កល់ ដោយបាយនិងទឹក ។

ព្រះសយម្ភូ ជាអគ្គបុគ្គល មានព្យាយាមធំ លុះទ្រង់ធ្វើអនុមោទនារួចហើយ ទើបទ្រង់គង់ក្នុងកណ្តាលនៃភិក្ខុសង្ឃ ហើយទ្រង់

សម្ដែងនូវព្រះគាថាទាំងឡាយនេះថា នាគរាជនេះ បានបូជាព្រះពុទ្ធ ជាលោកនាយកផង ព្រះសង្ឃផង ដោយចិត្តជ្រះថ្លានោះ នឹងបាន ទៅកើតក្នុងទេវលោក ។ នាគរាជនេះ នឹងសោយទេវរជ្ជសម្បត្តិ អស់ ៧៧ ដង នឹងគ្រប់គ្រងរាជ្យលើផែនដីអស់ ១០៨ ដង ។ នឹងបានជាស្ដេចចក្រពត្តិ អស់ ៥៥ ដង ឯទ្រព្យសម្បត្តិរាប់មិន អស់ នឹងកើតឡើង សម្រាប់ស្ដេចចក្រពត្តិនោះ ក្នុងកាលនោះ ។ ក្នុងកប្បរាប់មិនបានអំពីកប្បនេះ នឹងមានព្រះពុទ្ធមួយអង្គ ព្រះនាម គោតម កើតក្នុងត្រកូលក្សត្រឱក្កាកៈ នឹងបានជាសាស្ដាក្នុងលោក ។ វរុណនាគរាជនោះ នឹងឃ្លាតចេញអំពីនរក មកកើតជាមនុស្ស មានឈ្មោះថាកោលិត ជាជាតិព្រាហ្មណ៍ ។ លុះខាងក្រោយមក កោលិតមាណពនោះ ត្រូវកុសលមូលដាស់តឿន ក៏បានចេញបួស នឹងបានជាទុតិយសាវក របស់ព្រះមានព្រះភាគ ព្រះនាមគោតម លោកផ្គងសេចក្ដីព្យាយាម មានចិត្តស្ទុងចុះទៅរកព្រះនិព្វាន លោក ដល់នូវបារមីដោយឫទ្ធិ កំណត់ដឹងនូវអាសវធម៌ទាំងពួង ជាអ្នក មិនមានអាសវធម៌ នឹងបរិនិព្វាន ។

ខ្ញុំលុះក្នុងអំណាចនៃកាមរាគ ព្រោះអាស្រ័យនឹងបាបមិត្ត មានចិត្ត ប្រទូស្ត ក៏បានសម្លាប់មាតា និងបិតា ។ ខ្ញុំចូលទៅយកកំណើត ណាៗ ទោះបីជានរកគ្តី ជាមនុស្សគ្តី ស៊ីងបរិបូណ៌ដោយបាបកម្ម ស្លាប់តែនឹងដាច់ក្បាល ។ ជាតិនេះ ជាបច្ឆិមជាតិរបស់ខ្ញុំ ភពជា

ខាងក្រោយ ប្រព្រឹត្តទៅហើយ ក្នុងពេលនេះ ខ្ញុំនឹងធ្វើមរណកាល បែបនេះទៀត ។ ខ្ញុំប្រកបរឿយៗ ក្នុងវិវេក ត្រេកអរក្នុងការចម្រើនសមាធិ កំណត់ដឹងនូវអាសវធម៌ទាំងពួង ទាំងជាអ្នកមិនមានអាសវធម៌ ។ ខ្ញុំបានដល់នូវបារមីនៃឫទ្ធិ ហើយញ៉ាំងព្រះធរណីដ៏ជ្រៅ និងក្រាស់ ដែលបុគ្គលមិនអាចឲ្យកម្រើកបាន ឲ្យកម្រើកបាន ដោយចុងម្រាមជើងឆ្វេង ។ ខ្ញុំមិនដែលឃើញអស្មិមានះ មានះរបស់ខ្ញុំ មិនដែលមានទេ ខ្ញុំធ្វើចិត្តគោរពចំពោះសមណៈតាំងពីសាមណេរទៅ ។ ក្នុងកប្បរាប់មិនបាន រហូតមកដល់កប្បនេះ ខ្ញុំបានបំពេញនូវបុញ្ញកម្មណាៗ ក៏បានសម្រេចនូវសាវកភូមិនោះ ទាំងបានដល់នូវអាសវក្ខយ ។ បដិសម្ភិទា ៤ វិមោក្ខ ៨ និងអភិញ្ញា ៦ នេះ ខ្ញុំបានធ្វើឲ្យជាក់ច្បាស់ហើយ ទាំងសាសនារបស់ព្រះសម្ពុទ្ធ ខ្ញុំក៏បានប្រតិបត្តិហើយ ។

បានឮថា ព្រះមហាមោគ្គល្លានត្ថេរមានអាយុ បានសម្តែងនូវគាថាទាំងនេះ ដោយប្រការដូច្នេះ ។

មហាមោគ្គល្លានត្ថេរាបទាន ចប់

# អដ្ឋកថា

## មហាមោគ្គល្លានត្ថេរាបទាន

[ ៤ ] *អបទានរបស់ព្រះមហាមោគ្គល្លានត្ថេរ មានពាក្យផ្ដើមថា* **អនោមទស្សី ភគវា** *ដូច្នេះជាដើម ។*

*មានលំនាំដើមថា ព្រះថេរៈនេះ ជាអ្នកមានអធិការដែលធ្វើហើយក្នុងព្រះអង្គមុន សន្សំបុណ្យទាំងឡាយ ដែលឧបនិស្ស័យនៃព្រះនិព្វាន ក្នុងភពនោះៗ ក្នុងកាលនៃព្រះមានព្រះភាគព្រះនាមអនោមទស្សី ដូច្នេះ បានពោលហើយក្នុងរឿងរបស់ព្រះធម្មសេនាបតីសារីបុត្តត្ថេរ ។*

*សេចក្ដីតមក មានដូច្នេះថា ចាប់តាំងអំពីថ្ងៃដែលបួសហើយ ក្នុងថ្ងៃទី ៧ ព្រះថេរៈទៅអាស្រ័យស្រុកកល្លវាលគ្រាម ក្នុងដែនមគធៈ បំពេញសមណធម៌ កាលថីនមិទ្ធៈ គឺការងោកងុយគ្របសង្កត់ ដែលព្រះសាស្ដាទ្រង់ឲ្យសង្វេគ ដោយព្រះតម្រាស់ជាដើមថា ម្នាលមោគ្គល្លាន សេចក្ដីព្យាយាមរបស់អ្នក កុំឥតផលឡើយ កាលបានស្ដាប់ធាតុកម្មដ្ឋានទេសនាដែលព្រះមានព្រះភាគទ្រង់បន្ទោបង់នូវការងងុយ ហើយត្រាស់ឲ្យស្ដាប់ បានសម្រេចមគ្គ ៣ ខាងលើ ដោយលំដាប់នៃវិបស្សនា ដល់នូវទីបំផុតនៃសាវកញ្ញាណ ក្នុងខណៈសម្រេចអរហត្តផល ។*

*ព្រះមហាមោគ្គល្លានត្ថេរ កាលបានសម្រេចភាពជាទុតិយសាវក បន្ទាប់អំពីព្រះសារីបុត្តត្ថេរយ៉ាងនេះហើយ បានរឭកដល់បុព្វកម្មរបស់ខ្លួន កាលប្រកាសអបទានដែលជាបុព្វចរិយាដោយអំណាចសោមនស្ស ទើបពោលពាក្យថា* **អនោមទស្សី ភគវា** *ដូច្នេះជាដើម ។*

ក្នុងពាក្យនោះ ដែលឈ្មោះថា **អនោមទស្សី** ព្រោះមានទស្សនៈ គឺការឃើញមិនថោកថយ គឺមិនអាក្រក់ ។ ពិតហើយ ទ្រង់ធ្វើឲ្យមិនធុញទ្រាន់ក្នុងការមើល បុគ្គលដែលសម្លឹងមើលព្រះអង្គ អស់កាល ១ ថ្ងៃ អស់កាល ១ ខែ អស់កាល ១ ឆ្នាំ អស់កាល ១ សែនឆ្នាំ ( ក៏មិនទៀយណាយ ) ព្រោះទ្រង់មានព្រះសរីរៈប្រដាប់ដោយមហាបុរិសលក្ខណៈ ៣២ ប្រការ ព្រោះហេតុនោះ ទើបឈ្មោះថា **អនោមទស្សី** ។ ម្យ៉ាងទៀត ឈ្មោះថា **អនោមទស្សី** ព្រោះមានប្រក្រតីឃើញព្រះនិព្វានដែលមិនថោកថយ គឺមិនអាក្រក់ ព្រះមានព្រះភាគបានឈ្មោះថា **អនោមទស្សី** ជាព្រះមានព្រះគាគ ព្រោះហេតុជាអ្នកមានភាគ្យជាដើម ។ បទថា **លោកជេដ្ឋោ** បានដល់ ជាធំ គឺជាប្រធាននៃសត្វលោកទាំងមូល ។ ឈ្មោះថា **អាសភ** ព្រោះដូចគ្នានឹងគោអាសភៈ ។ ជាអាសភៈជាងនរៈ ឈ្មោះថា **នរាសភ** ។ ព្រះមានព្រះភាគអនោមទស្សី ជាលោកជេដ្ឋៈ ជាបុគ្គលធំក្រៃលែងជាងនរៈអង្គនោះ ដែលពួកទេវតាចោមរោម គឺដែលពួកទេវតាទាំងឡាយចោមរោមហើយ ភ្ជាប់សេចក្តីថា គង់នៅត្រង់ក្នុំហិមពាន្ត ។

អធិប្បាយថា ក្នុងគ្រាដែលធ្វើសេចក្តីប្រាថ្នាក្នុងវារៈទី ២ ដើម្បីជាទុតិយសាវកនោះ ខ្ញុំបានកើតជានាគរាជ មានឈ្មោះវរុណៈ ដោយហេតុនោះទើបពោលថា គ្រានោះ ខ្ញុំកើតជានាគរាជ មានឈ្មោះវរុណៈ ដូច្នេះ ។ បទថា **កាមរូបី** បានដល់ និម្មិតវត្ថុដែលត្រូវការបានតាមប្រាថ្នា ។ បទថា **វិកុព្វាមិ** ប្រែថា ធ្វើនូវការសម្តែងឫទ្ធិផ្សេងៗ បាន ។ បទថា **មហោទធិ–**

**និវាសហំ** សេចក្តីថា ក្នុងពួកនាគទាំងនេះ គឺមញ្ជេរិកនាគ ១ នាគដែលនៅលើផែនដី ១ នាគដែលនៅលើភ្នំ ១ នាគដែលនៅក្នុងស្ទឹង ១ នាគដែលនៅក្នុងសមុទ្រ ១ ខ្ញុំជានាគនៅក្នុងសមុទ្រ អាស្រ័យនៅ គឺសម្រេចការនៅក្នុង អន្លង់ទឹកធំ គឺក្នុងសមុទ្រ ។

បទថា **សង្គណិយំ គណំ ហិត្វា** សេចក្តីថា លះ គឺលះបង់ពួកនាគដែលជាបរិវារប្រចាំ គឺដែលជាបរិវាររបស់ខ្លួន ។ បទថា **តុរិយំ បដ្ឋបេសហំ** សេចក្តីថា ខ្ញុំផ្តើមតាំងគ្រឿងតន្ត្រី អធិប្បាយថា ឲ្យប្រគំតន្ត្រី ។ បទថា **សម្ពុទ្ធំ បរិវារេត្វា** សេចក្តីថា ក្នុងកាលនោះ ពួកស្រីទេពអប្សរ គឺនាងនាគមាណវិកាទាំងឡាយ ចោមរោមព្រះអនោមទស្សីសម្ពុទ្ធ ប្រគំ គឺច្រៀងដោយពាក្យដ៏ពីរោះ បន្ទឺដោយកំណាព្យជាដើម បានដល់ បន្ទឺតាមភាពសមគួរនឹងវត្ថុដែលខ្លួនមាន ។

បទថា **វជ្ជមានេសុ តុរិយេសុ** សេចក្តីថា កាលតន្ត្រីរបស់មនុស្ស និងតន្ត្រីយរបស់នាគ ដែលប្រកបដោយអង្គ ៥ កំពុងប្រគំ ។ បទថា **ទេវ-តុរិយានិ វជ្ជយុំ** សេចក្តីថា ទេវតាជាន់ចាតុម្មហារាជក៏ប្រគំ គឺប្រគំទិព្វតន្ត្រី ។ បទថា **ឧភិន្នំ សទ្ទំ សុត្វាន** សេចក្តីថា ទ្រង់បានស្តាប់សំឡេងស្គរទេវតា និងមនុស្សទាំង ២ ចំណែក អធិប្បាយថា ព្រះពុទ្ធទ្រង់ស្មើដោយគ្រូនៃលោកទាំង ៣ ក៏ទ្រង់ជ្រាប គឺទ្រង់ដឹង ទ្រង់ស្តាប់ ។

បទថា **និមន្តេត្វាន សម្ពុទ្ធំ** សេចក្តីថា និមន្ត គឺសូមព្រះសម្ពុទ្ធ ព្រមទាំងពួកសាវកដើម្បីសោយក្នុងថ្ងៃស្អែក ។ បទថា **សកភវនំ** បានដល់ ចូល

ទៅកាន់នាគពិភពរបស់ខ្លួន ។ បទថា **អាសនំ បញ្ញបេត្វាន** សេចក្តីថា ក្រាល គឺត្រៀមទីសម្រាកពេលយប់ ទីសម្រាកពេលថ្ងៃ កុដិ មណ្ឌប ទីដេក និងទីអង្គុយ ។ បទថា **កាលមារោចយឹ អហំ** សេចក្តីថា ខ្ញុំធ្វើវិធីខាងដើម យ៉ាងនេះហើយ ក្រាបទូល គឺឲ្យទ្រង់ជ្រាបកាលថា បានកាល ពេលព្រះអង្គ កត្តាហារសម្រេច ។

បទថា **ខីណាសវ សហស្សេហិ** សេចក្តីថា ក្នុងកាលនោះ ព្រះមាន ព្រះភាគអង្គនោះ ដែលព្រះអរហន្ត ១០០០ រូប ចោមរោមហើយ ជាលោក-នាយក ទ្រង់ញ៉ាំងទិសទាំងពួងឲ្យភ្លឺ យាងចូលទៅ គឺយាងមក គឺយាងដល់ ភពរបស់ខ្ញុំ ។

កាលនឹងសម្តែងអាការដែលព្រះមានព្រះភាគ ចូលទៅកាន់ភពរបស់ ខ្លួន ឲ្យសោយ ទើបពោលពាក្យថា **ឧបវដ្ឋំ មហាវីរំ** ដូច្នេះជាដើម ។ ពាក្យនោះ មានអត្ថងាយយល់ហើយ ។

បទថា **ឱក្កាកកុលសម្ភវោ** សេចក្តីថា ព្រះសាស្តា ព្រះនាមគោតម ដោយគោត្រ គឺដោយអំណាចនៃគោត្រ ទ្រង់កើតក្នុងរាជត្រកូល ដែលបន្ត មកអំពីព្រះបាទឱក្កាករាជ ឬកើតក្នុងរាជត្រកូលដែលប្រាកដក្នុងជម្ពូទ្វីបទាំង មូល និងកើតមានក្នុងមនុស្សលោក ។ ដោយបទថា **សោ បច្ឆា បព្វជិត្វាន** នេះ ព្រះសាស្តាទ្រង់ធ្វើការព្យាករណ៍ថា នាគរាជនោះ ដែលកុសលមូល គឺ កុសលមូលដាស់តឿន គឺបញ្ជូនក្នុងកាលខាងក្រោយ គឺភពចុងក្រោយ នឹង បួសក្នុងសាសនា នឹងបានជាទុតិយសាវ័ក របស់ព្រះមានព្រះភាគ ព្រះនាម

គោតម ។

បទថា **អារទ្ធវីរិយោ** បានដល់ មានសេចក្តីព្យាយាមក្នុងឥរិយាបថទាំងឡាយ មានការឈរ និងការអង្គុយជាដើម ។ បទថា **បហិតត្តោ** បានដល់ មានចិត្តបញ្ជូនទៅហើយក្នុងព្រះនិព្វាន ។ បទថា **ឥទ្ធិយា ចារមឹ គតោ** សេចក្តីថា ដល់ គឺសម្រេចដល់នូវការពេញ គឺទីបំផុតក្នុងអធិដ្ឋានឫទ្ធិ វិកុព្វនឫទ្ធិ កម្មវិបាកជឫទ្ធិជាដើម ដោយព្រះតម្រាស់ថា ម្នាលភិក្ខុទាំងឡាយ បណ្តាពួកភិក្ខុអ្នកមានឫទ្ធិ ស្រេចនឹងមហាមោគ្គល្លាន ដូច្នេះ ។ បទថា **សព្វាសវេ** សេចក្តីថា កំណត់ដឹង គឺដឹងទូទៅហើយ ធម៌ គឺកាម ភវ ភព ទិដ្ឋិ និងអវិជ្ជាទាំងអស់ ដែលបានឈ្មោះថា អាសវៈ ព្រោះហូរទៅ គឺប្រព្រឹត្តទូទៅ គឺជុំវិញ ជាអ្នកមិនមានអាសវធម៌ គឺជាអ្នកមិនមានកិលេស ។ បទថា **ឆិព្វាយិស្សតិ** ភ្ជាប់សេចក្តីថា នឹងនិព្វានដោយកិលេសបរិនិព្វាន និងខន្ធបរិនិព្វាន ។

ព្រះថេរៈកាលពោលដល់ការព្យាករណ៍ ដែលបានដោយអំណាចបុណ្យរបស់ខ្លួនយ៉ាងនេះហើយ កាលប្រកាសចរិយាដ៏លាមក ទើបពោលពាក្យថា **ចាបមិត្តោ បនិស្សាយ** ដូច្នេះជាដើម ។ ក្នុងពាក្យនោះ មានអធិប្បាយថា ចូលទៅអាស្រ័យបាបមិត្ត គឺមិត្តអាក្រក់ គឺមិត្តថោកទាប គឺយកជាទីពឹង បានដល់ ទាក់ទងនឹងមិត្តអាក្រក់ទាំងនោះ ។

ក្នុងសេចក្តីនោះ មានអនុបុព្វីកថាដូចតទៅ សម័យមួយ ពួកតិរ្ថិយប្រជុំគ្នាប្រឹក្សាគ្នាថា អាវុសោទាំងឡាយ ពួកអ្នកដឹងទេ ព្រោះហេតុអ្វី ទើប

លាភសក្ការៈកើតឡើងច្រើន ដល់ព្រះសមណគោតម ។ ពួកតិរ្ថិយពោលថា ពួកខ្ញុំមិនដឹង ពួកលោកដឹងឬ ពួកតិរ្ថិយពោលថា អើ ខ្ញុំដឹង លាភសក្ការៈកើតឡើង ព្រោះអាស្រ័យភិក្ខុមួយរូប ឈ្មោះមោគ្គល្លាន ព្រោះថា ព្រះមោគ្គល្លាននោះទៅកាន់ទេវលោក សួរដល់កម្មដែលពួកទេវតាធ្វើ ហើយចុះមកប្រាប់ដល់ពួកមនុស្សថា ពួកគេធ្វើកម្មឈ្មោះនេះ ទើបបានសម្បត្តិបែបនេះ និងសួរកម្មរបស់អ្នកដែលកើតក្នុងនរក ហើយត្រឡប់មកប្រាប់ដល់ពួកមនុស្សថា ពួកគេធ្វើកម្មឈ្មោះនេះ ទើបបានសោយទុក្ខបែបនេះ ។

មនុស្សទាំងឡាយបានស្ដាប់ពាក្យរបស់ព្រះមហាមោគ្គល្លានហើយ ទើបនាំទៅចំពោះនូវលាភសក្ការៈធំ តិរ្ថិយទាំងអស់ មានឆន្ទៈដូចគ្នាថា បើពួកយើងសម្លាប់ព្រះមោគ្គល្លាននោះបាន លាភសក្ការៈនោះនឹងកើតឡើង ដល់ពួកយើង ឧបាយនេះមានប្រយោជន៍ ហើយគិតគ្នាថា ពួកយើងនឹងធ្វើឧបាយណាមួយ សម្លាប់ព្រះមោគ្គល្លាននោះចោល ទើបបបួល ( រៃអង្គាស ) ពួកឧបដ្ឋាករបស់ខ្លួន បានកហាបណៈ ១០០០ ហើយឲ្យហៅចោរអ្នកសម្លាប់មនុស្សមកហើយ ពោលថា ឈ្មោះថា ព្រះមហាមោគ្គល្លានត្ថេរ ជាសាវ័ករបស់ព្រះមានព្រះភាគសមណគោតម នៅត្រង់កាលសិលាបទេស ចូរអ្នកទៅក្នុងទីនោះ ហើយសម្លាប់ព្រះមោគ្គល្លាននោះចោល កាលពោលហើយបានឲ្យកហាបណៈ ១០០០ ដល់ចោរទាំងនោះ ។

ពួកចោរទទួលពាក្យ ព្រោះបានទ្រព្យ ទើបទៅដោយបំណងថា ពួកយើងនឹងសម្លាប់ព្រះថេរៈ ព័ទ្ធលំនៅរបស់ព្រះថេរៈនោះ ។ ព្រះថេរៈដឹងថា

ពួកចោរទាំងនោះកំពុងចោមព័ទ្ធ ទើបគេចចេញតាមប្រហោងសោ ។ ពួកចោរមិនឃើញព្រះថេរៈក្នុងថ្ងៃនោះ ទើបនាំគ្នាចោមរោមលំនៅព្រះថេរៈនោះក្នុងថ្ងៃស្អែក ។ ព្រះថេរៈដឹងហើយ ក៏ទម្លាយមណ្ឌលហោជាង ហើយហោះទៅតាមអាកាស ។ កាលបើយ៉ាងនោះ ពួកចោរទាំងនោះក៏មិនអាចចាប់ព្រះថេរៈក្នុងដើមខែ និងកណ្តាលខែ លុះចុងខែ ព្រះថេរៈដឹងថា កម្មដែលខ្លួនធ្វើអូសទាញមក ទើបមិនគេច ។ ពួកចោរប្រហារព្រះថេរៈ វាយបំបែកឆ្អឹងរហូតបែក ឲ្យមានទំហំប៉ុនៗ គ្រាប់អង្ករ ។ ពេលនោះ ពួកចោរសម្គាល់ព្រះថេរៈនោះថា ស្លាប់ហើយ ទើបបោះទៅលើគុម្ពឈើមួយកន្លែង ហើយនាំគ្នាចៀសចេញទៅ ។ ព្រះថេរៈគិតថា អញនឹងគាល់ព្រះសាស្តា ថ្វាយបង្គំហើយ នឹងបរិនិព្វាន ហើយផ្សារនូវអត្តភាពដោយគ្រឿងផ្សារ គឺឈាន រួចហោះទៅកាន់សម្នាក់ព្រះសាស្តា ថ្វាយបង្គំព្រះសាស្តាហើយ ក្រាបទូលថា បពិត្រព្រះអង្គដ៏ចម្រើន ខ្ញុំព្រះអង្គនឹងបរិនិព្វាន ។ ព្រះសាស្តាត្រាស់ថា ម្នាលមោគ្គល្លាន អ្នកនឹងបរិនិព្វានឬ ព្រះថេរៈក្រាបទូលថា ព្រះករុណាព្រះអង្គ ។ ព្រះសាស្តាត្រាស់ថា អ្នកទៅបរិនិព្វានក្នុងទីណា ព្រះថេរៈទូលថា នឹងទៅកាន់កាលសិលាបទេស ព្រះសាស្តាត្រាស់ថា ម្នាលមោគ្គល្លាន បើយ៉ាងនោះអ្នកពោលធម៌ដល់តថាគតហើយ សឹមទៅចុះ ព្រោះតាំងពីនេះទៅ តថាគតលែងបានឃើញសាវកដូចអ្នកទៀតហើយ ។

ព្រះថេរៈក្រាបទូលថា បពិត្រព្រះអង្គដ៏ចម្រើន ខ្ញុំព្រះអង្គនឹងធ្វើយ៉ាងនោះ ថ្វាយបង្គំព្រះសាស្តាហើយ ហោះទៅកាន់អាកាស ធ្វើឫទ្ធិមានប្រការ

ផ្សេងៗ ដូចព្រះសារីបុត្តត្ថេរ ធ្វើក្នុងថ្ងៃបរិនិព្វាន ហើយពោលធម៌ ថ្វាយបង្គំលាព្រះសាស្តា ទៅកាន់កាលសិលាបទេស ហើយបរិនិព្វាន ។ រឿងនេះល្បីថា ពួកចោរសម្លាប់ព្រះថេរៈ បានផ្សាយទៅក្នុងជម្ពូទ្វីបទាំងមូល ។

ព្រះបាទអជាតសត្រូវ ទ្រង់ចាត់ពួកចារបុរស ដើម្បីស៊ើបរកពួកចោរ កាលចោរទាំងនោះផឹកស្រាក្នុងតៀមស្រា ស្រវឹងហើយ ចោរម្នាក់ វាយខ្នងចោរម្នាក់ឲ្យដួលចុះ ចោរនោះ កាលគំរាមចោរដែលវាយខ្លួន ទើបពោលថា នែមនុស្សប្រដៅក្រ ហេតុអ្វី ទើបអាប្រហារខ្នងរបស់អញ ធ្វើឲ្យដួល រឺយចោរកាច ព្រះមោគ្គល្លានត្ថេរ អាប្រហារមុនឬ ។ ចោរដែលវាយ ពោលថា ឯងមិនដឹងថា អញប្រហារលោកមុនទេឬ ចោរទាំងនោះក៏ជជែកគ្នាយ៉ាងនេះថា អញប្រហារមុន អញប្រហារមុន ដូច្នេះ ។ ពួកចារបុរសទាំងនោះបានស្តាប់ហើយ ទើបចាប់ចោរទាំងអស់ ហើយក្រាបទូលព្រះរាជា ឲ្យទ្រង់ជ្រាប ។ ព្រះរាជាត្រាស់ឲ្យហៅចោរទាំងនោះមកហើយ ត្រាស់សួរថា ពួកអ្នកសម្លាប់ព្រះថេរៈឬ ពួកចោរក្រាបទូលថា ករុណាថ្លៃវិសេស ។ ព្រះរាជាត្រាស់ថា អ្នកណាបញ្ជូនពួកអ្នក ពួកចោរពោលថា បពិត្រព្រះអង្គ ពួកសមណៈអាក្រាត ។ ព្រះរាជាត្រាស់ឲ្យចាប់ពួកសមណៈអាក្រាតទាំង ៥០០ នាក់ ហើយឲ្យកប់ក្នុងរណ្តៅប្រមាណត្រឹមផ្ចិត ត្រង់លានព្រះរាជវាំង មួយអន្លើដោយពួកចោរទាំង ៥០០ ហើយឲ្យយកចំបើងគ្រប ហើយដុតដោយភ្លើង កាលទ្រង់ជ្រាបថា អ្នកទាំងនោះត្រូវដុតហើយ បានឲ្យយកនង្គ័លដែកភ្ជួរ ឲ្យធ្វើមនុស្សទាំងអស់ជាកំណាត់តូចធំ ។ ក្នុងកាលនោះ ភិក្ខុទាំងឡាយ

សន្ទនាគ្នាក្នុងធម្មសភាថា ព្រះមហាមោគ្គល្លានដល់នូវការស្លាប់ មិនសមគួរដល់ខ្លួន ។ ព្រះសាស្តាយាងមក ត្រាស់សួរថា ម្នាលភិក្ខុទាំងឡាយ អម្បាញ់មិញនេះ ពួកអ្នកអង្គុយសន្ទនាគ្នាអំពីរឿងអ្វី កាលភិក្ខុទាំងឡាយក្រាបទូលថា បពិត្រព្រះអង្គ ដោយរឿងឈ្មោះនេះ ទើបព្រះមានព្រះភាគត្រាស់ថា ម្នាលភិក្ខុទាំងឡាយ ការស្លាប់របស់មោគ្គល្លាន មិនសមសម្រាប់អត្តភាពនេះដោយពិត តែសមគួរដល់កម្មដែលមោគ្គល្លាននោះធ្វើក្នុងជាតិមុន កាលភិក្ខុទាំងឡាយទូលសួរថា បពិត្រព្រះអង្គ បុព្វកម្មរបស់ព្រះថេរៈនោះដូចម្តេចទើបទ្រង់ត្រាស់បុព្វកម្មនោះដោយពិស្តារថា

ម្នាលភិក្ខុទាំងឡាយ ក្នុងអតីតកាល មានកុលបុត្រម្នាក់ នៅក្នុងនគរពារាណសី ធ្វើការងារ មានបុកអង្ករ និងដាំបាយជាដើមដោយខ្លួនឯង បដិបត្តិមាតាបិតា ។ កាលនោះ ទើបមាតាបិតាពោលថា នែកូន អ្នកម្នាក់ឯង ធ្វើការងារទាំងក្នុងស្រុក ក្នុងព្រៃ ត្រូវលំបាក យើងនឹងនាំកុមារិកាម្នាក់មកឲ្យទោះបីត្រូវកុលបុត្រនោះឃាត់ថា បពិត្រលោកឪពុក និងអ្នកម្តាយ លោកទាំង ២ នៅមានជីវិតដរាបណា កូននឹងបម្រើលោកឪពុក និងអ្នកម៉ែដោយដៃរបស់ខ្លួនឯងដរាបនោះ ដូច្នេះ ក៏នៅតែអង្វររឿយៗ ហើយនាំកុមារិកាមកឲ្យ ។ កុមារិកានោះបម្រើមាតាបិតារបស់កុលបុត្រនោះ បានត្រឹម ២-៣ ថ្ងៃប៉ុណ្ណោះក្រោយមក មិនប្រាថ្នានឹងមើលជនទាំង ២ នោះ ដ្បិតធុញទ្រាន់ ទើបលើកទោសថា ខ្ញុំមិនអាចនៅក្នុងទីជាមួយនឹងមាតាបិតារបស់អ្នក កាលកុលបុត្រនោះមិនជឿពាក្យរបស់ខ្លួន ក្នុងកាលកុលបុត្រនោះចេញទៅខាងក្រៅ ទើប

យកចម្រៀកសម្បកឆ្នៃ និងពពុះបបរមករោយក្នុងទីផ្សេងៗ កាលកុលបុត្រនោះមកហើយ សួរថា នេះជាអ្វី ទើបនាងពោលថា នេះជាការធ្វើរបស់មនុស្សចាស់ខ្វាក់ទាំងនេះ មនុស្សនោះ ត្រាច់ធ្វើឲ្យស្មោកគ្រោកពេញផ្ទះ ខ្ញុំមិនអាចនៅក្នុងទីតែមួយជាមួយមនុស្សទាំងនេះ កាលនាងពោលរឿយៗ យ៉ាងនេះ សត្វដែលបានបំពេញបារមីមកហើយបែបនេះ ក៏បែកចិត្តពីមាតាបិតា ។ កុលបុត្រនោះក៏ពោលថា ណ្ហើយចុះ អញនឹងដឹងកម្មដែលគួរធ្វើដល់មនុស្សទាំងនេះ ទើបឲ្យមាតាបិតាបរិភោគ ហើយពោលថា បពិត្រលោកឪពុក អ្នកម៉ែ ពួកញាតិរបស់លោក នៅក្នុងទីឈ្មោះនោះ ទន្ទឹងការមក ពួកយើងនឹងទៅក្នុងទីនោះ ដូច្នេះហើយ លើកមាតាបិតាឡើងយានតូច នាំទៅ លុះដល់កណ្តាលព្រៃក៏ពោលថា បពិត្រលោកឪពុក សូមលោកកាន់ខ្សែ ពួកគោនឹងដើរទៅតាមការបញ្ជា ក្នុងទីនេះ មានពួកចោរ ខ្ញុំនឹងចុះដើរទៅ ហើយដាក់ខ្សែក្នុងដៃរបស់បិតា ខ្លួនឯងចុះដើរទៅ បានប្តូរសំឡេង ធ្វើដូចជាសំឡេងពួកចោរមក មាតាបិតាបានឮសំឡេង យល់ថា ចោរមក ទើបពោលថា នែបា ពួកចោរមកហើយ ពួកយើងចាស់ហើយ ចូរបារក្សាខ្លួនឯងចុះ ។ ទាំងមាតាបិតាកំពុងយំរៀបរាប់ កុលបុត្រនោះ ក៏ធ្វើសំឡេងចោរ វាយឲ្យស្លាប់ ហើយបោះចោលក្នុងព្រៃ ត្រឡប់មក ។

ព្រះសាស្តា កាលត្រាស់បុព្វកម្មនេះរបស់ព្រះថេរៈហើយ ទើបត្រាស់ថា ម្នាលភិក្ខុទាំងឡាយ មោគ្គល្លានធ្វើកម្ម មានប្រមាណប៉ុណ្ណោះ ឆេះក្នុងនរក ច្រើនសែនឆ្នាំ ត្រឹមតែសេសសល់ផលកម្ម ជាអ្នកបែកខ្ទេចខ្ទី ព្រោះ

វាយបែបនោះឯង ដល់នូវការស្លាប់អស់ ១ រយអត្តភាព មោគ្គល្លានបាន ទទួលនូវការស្លាប់ សមគួរដល់កម្មរបស់ខ្លួនយ៉ាងនេះឯង ឯតិរ្ថិយ ៥០០ និង ចោរ ៥០០ ប្រទូស្តបុត្ររបស់តថាគតដែលជាអ្នកមិនប្រទូស្ត ក៏បានដល់នូវ ការស្លាប់សមគួរដូចគ្នា ព្រោះបុគ្គលប្រទូស្តក្នុងអ្នកមិនប្រទូស្ត រមែងដល់នូវ សេចក្ដីវិនាសព្រោះហេតុ ១០ ប្រការនោះឯង កាលទ្រង់បន្តអនុសន្ធិសម្ដែង ធម៌ ទើបត្រាស់គាថាទាំងនេះថា

> បុគ្គលណា ប្រទូស្តដោយអាជ្ញា ចំពោះបុគ្គលទាំងឡាយ ដែលមិនមានអាជ្ញា មិនប្រទូស្ត បុគ្គលនោះ រមែងដល់នូវ ហេតុនៃសេចក្ដីទុក្ខណាមួយ ក្នុងហេតុ ១០ យ៉ាង ដោយ ទាន់ហន់ គឺគប្បីដល់នូវវេទនាដ៏អាក្រក់ ១ សេចក្ដីវិនាស ទ្រព្យ ១ បែកធ្លាយសរីរៈ ១ អាពាធជាទម្ងន់ ១ ក្រឡក ចិត្ត ( ឆ្កួត ) ១ រឹបជាន់អំពីស្ដេច ១ ពោលពាក្យបង្កាច់ ដ៏អាក្រក់ ១ អស់ពួកញាតិរលីង ១ ពុកផុយភោគសម្បត្តិ ទាំងឡាយ ១ ទាំងភ្លើងនឹងឆេះបំផ្លាញនូវផ្ទះរបស់បុគ្គលនោះ ១ បុគ្គលមិនមានប្រាជ្ញានោះ លុះបែកធ្លាយរាងកាយ រមែង ទៅកើតក្នុងនរក ។

បទថា **បរិវេកមនុយុត្តោ** សេចក្ដីថា ប្រកបរឿយៗ គឺប្រកបហើយ បានដល់ ប្រកបតាម ប្រកបទូទៅហើយនូវការស្ងាត់ងាយជុំវិញ គឺភាពជា បុគ្គលម្នាក់ឯង ។ បទថា **សមាធិភាវនារតោ** សេចក្ដីថា ត្រេកអរហើយ

គឺជាប់ហើយ ក្នុងការចម្រើនបឋមជ្ឈានជាដើម ភ្ជាប់សេចក្តីថា នឹងកំណត់ដឹង គឺជ្រាប បានដល់ លះហើយនូវអាសវៈទាំងពួង បានដល់ កិលេសទាំងមូល ជាអ្នកមិនមានអាសវៈ គឺមិនមានកិលេស ។

ឥឡូវនេះ កាលសម្តែងបុព្វកម្ម ដែលប្រព្រឹត្តមកក្នុងកាលមុន ដោយអំណាចបុញ្ញសម្ភាររបស់ខ្លួន ទើបពោលពាក្យថា **ធរណិម្ហិ សុគម្ភីរំ** ដូច្នេះជាដើម ។

ក្នុងពាក្យនោះ មានអនុបុព្វីកថាដូចតទៅ បទថា **ពុទ្ធេន ចោទិតោ** សេចក្តីថា ដែលព្រះសម្ពុទ្ធទ្រង់ដាស់តឿនហើយ គឺទ្រង់បញ្ជូនទៅហើយ ។ បទថា **ភិក្ខុសង្ឃស្ស បេក្ខតោ** សេចក្តីថា កាលមហាភិក្ខុសង្ឃកំពុងឃើញ ។ បទថា **មិគារមាតុបាសាទំ បាទង្គុដ្ឋេន កម្បយិ** សេចក្តីថា ខ្ញុំធ្វើមហាប្រាសាទដែលប្រកបដោយសសរ ១០០០ ដែលនាងវិសាខាមហាឧបាសិកាឲ្យសាងក្នុងបុព្វារាម ឲ្យញាប់ញ័រដោយម្រាមមេជើងរបស់ខ្លួន ។ គ្រាមួយ កាលព្រះមានព្រះភាគគង់នៅក្នុងប្រាសាទ តាមដែលពោលហើយក្នុងបុព្វារាម ពួកភិក្ខុជាច្រើនអង្គុយក្នុងប្រាសាទជាន់លើ មិនគិតដល់សូម្បីតែព្រះសាស្តា ផ្តើមពោលតិរច្ឆានកថា ព្រះមានព្រះភាគទ្រង់ស្តាប់ដូច្នោះ ទ្រង់បំណងឲ្យភិក្ខុទាំងនោះសង្វេគ ហើយត្រឡប់ជាភាជនៈ ទទួលព្រះធម្មទេសនារបស់ព្រះអង្គ ទើបត្រាស់ហៅព្រះមហាមោគ្គល្លានត្ថេរមកថា ម្នាលមោគ្គល្លាន ចូរអ្នកមើលពួកភិក្ខុដែលបួសថ្មី ដែលវង្វេងក្នុងការពោលតិរច្ឆានកថា ។ ព្រះថេរៈបានស្តាប់ព្រះតម្រាស់នោះ ជ្រាបព្រះអធ្យាស្រ័យរបស់ព្រះសាស្តា ទើប

ចូលចតុត្ថជ្ឈាន មានអាបោកសិណជាអារម្មណ៍ មានអភិញ្ញាជាបាទ ហើយចេញចាកចតុត្ថជ្ឈាន អធិដ្ឋានថា ឱកាសដែលប្រាសាទតាំងនៅ ចូរជាទឹក ហើយយកម្រាមមេជើងក្ដិះកំពូលប្រាសាទ ។ ប្រាសាទបានផ្អៀងទៅម្ខាង ព្រះថេរៈសង្កត់ម្ដងទៀត ប្រាសាទក៏ផ្អៀងទៅម្ខាងទៀត ភិក្ខុទាំងនោះ ភិតភ័យភ្ញាក់ផ្អើល ព្រោះប្រាសាទរលំ ទើបចេញអំពីប្រាសាទនោះ ហើយឈរក្នុងទីជិតព្រះមានព្រះភាគ ។ ព្រះសាស្ដា ទ្រង់ប្រមើលមើលអធ្យាស្រ័យរបស់ភិក្ខុទាំងនោះហើយ ទ្រង់សម្ដែងធម៌ ។ ព្រោះបានស្ដាប់ព្រះធម៌នោះ បណ្ដាភិក្ខុទាំងនោះ ពួកខ្លះ តាំងនៅក្នុងសោតាបត្តិផល ពួកខ្លះ តាំងនៅក្នុងសកទាគាមិផល ពួកខ្លះ តាំងនៅក្នុងអនាគាមិផល ពួកខ្លះ តាំងនៅក្នុងអរហត្តផល ។ សេចក្ដីនេះ គប្បីសម្ដែងដោយសូត្រដែលពោលអំពីប្រាសាទកម្រើក ។

បទថា **វេជយន្តបាសាទំ** សេចក្ដីថា វេជយន្តប្រាសាទនោះកម្ពស់ ១ ពាន់យោជន៍ ប្រដាប់ដោយប៉ម និងផ្ទះកំពូលច្រើនពាន់ផុសឡើង ក្នុងកាលសក្កទេវរាជឈ្នះពួកអសុរ ក្នុងទេវាសុរសង្គ្រាម ហើយទ្រង់គង់នៅក្នុងកណ្ដាលនគរ ក្នុងស្ថានតាវត្តិង្ស ជាប្រាសាទដែលបានឈ្មោះថា វេជយន្ត ព្រោះកើតក្នុងទីបំផុតនៃជ័យជម្នះ លោកសំដៅយកប្រាសាទនោះ ទើបពោលថា **វេជយន្តបាសាទំ**[១] ដូច្នេះ ។ ព្រះថេរៈធ្វើវេជយន្តប្រាសាទនោះឲ្យញាប់ញ័រដោយម្រាមមេជើង ។ សម័យមួយ ព្រះមានព្រះភាគទ្រង់គង់នៅក្នុងបុព្វារាម សក្ក-

---

១- បទនេះ លោកពន្យល់ក្នុងចូឡតណ្ហាសង្ខយសូត្រ ។

ទេវរាជចូលទៅគាល់ហើយ ទូលសួរដល់វិមុត្តិ គឺធម៌ជាគ្រឿងអស់តណ្ហា ព្រះមានព្រះភាគ ទ្រង់វិសជ្ជនាដល់សក្កៈ ។ សក្កទេវរាជទ្រង់ស្តាប់ដូច្នោះ ទ្រង់ត្រេកអរ ទ្រង់អភិវាទហើយ ធ្វើប្រទក្សិណយាងទៅកាន់ទេវលោករបស់ព្រះអង្គមួយរំពេច ។

កាលនោះ ព្រះមោគ្គល្លានគិតយ៉ាងនេះថា សក្កទេវរាជចូលទៅគាល់ព្រះមានព្រះភាគ ហើយទូលសួរបញ្ហាដែលប្រកបដោយព្រះនិព្វានដ៏ជ្រាលជ្រៅបែបនេះ ព្រះមានព្រះភាគក៏បានឆ្លើយបញ្ហាហើយ សក្កទេវរាជជ្រាបហើយ ទើបយាងទៅ ឬថា ទ្រង់មិនជ្រាបហើយយាងទៅ បើដូច្នោះ អញគួរទៅកាន់ទេវលោក ហើយដឹងសេចក្តីនោះ ។

ក្នុងរំពេចនោះ ព្រះថេរៈបានទៅកាន់តាវត្តិង្សទូលសួរសេចក្តីនោះនឹងសក្កទេវរាជ ។ សក្កៈជាអ្នកប្រមាទក្នុងទិព្វសម្បត្តិ ទើបបានធ្វើឲ្យរាយមាយ ។ ដើម្បីឲ្យកើតសេចក្តីសង្វេគដល់សក្កៈ ព្រះថេរៈក៏ធ្វើវេជយន្តប្រាសាទឲ្យញាប់ញ័រដោយមេជើង ដោយហេតុនោះ ទើបលោកពោល ( ក្នុងមារតជ្ជនីយសូត្រ ) ថា

ភិក្ខុណា បានធ្វើវេជយន្តប្រាសាទឲ្យញាប់ញ័រ ដោយចុងម្រាមជើងបាន ជាអ្នកមាំមួនដោយកម្លាំងឫទ្ធិ អាចធ្វើទេវតាទាំងឡាយឲ្យសង្វេគបាន ដូច្នេះ ។

អត្ថនេះ គប្បីសម្តែងដោយចូឡតណ្ហាសង្ខយវិមុត្តិសូត្រ ។ អាការដែលប្រាសាទញាប់ញ័រ បានពោលហើយខាងដើមដូចគ្នា ។ បទថា **សក្កំ**

**សោ បរិបុច្ឆតិ** លោកពោលសំដៅយកអាការដែលព្រះថេរៈសួរវិមុត្តិ គឺធម៌ធ្វើឲ្យអស់តណ្ហា តាមដែលពោលហើយនោះឯង ។ ដោយហេតុនោះ ទើបលោកពោលថា អាវុសោ ទ្រង់ជ្រាបតណ្ហាសង្ខយវិមុត្តិឬទេ សក្កទេវរាជបានពិតឲ្យព្រះថេរៈជ្រាប ។ ពាក្យនេះ លោកសំដៅដល់កាលដែលព្រះថេរៈធ្វើប្រាសាទឲ្យញាប់ញ័រហើយ សក្កទេវរាជសង្វេគទ្រង់លះសេចក្តីប្រមាទ ហើយទ្រង់ដាក់ចិត្តដោយឧបាយ ទើបទ្រង់ព្យាករបញ្ហា ។ ក្នុងកាលនោះ សក្កទេវរាជបានត្រាស់តាមទំនងដូចព្រះសាស្តាទ្រង់ទេសនានោះឯង ដោយហេតុនោះ ទើបលោកពោលថា សក្កទេវរាជ ត្រូវព្រះថេរៈសួរហើយ ទើបព្យាករបញ្ហាតាមសេចក្តីពិត ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **សក្កំ សោ បរិបុច្ឆតិ** សេចក្តីថា ព្រះមហាមោគ្គល្លានត្ថេរទូលសក្កទេវរាជថា តណ្ហាសង្ខយវិមុត្តិ ដែលព្រះសាស្តាទ្រង់សម្តែងហើយ ទ្រង់ចាំមកត្រឹមត្រូវដែរឬទេ ពាក្យនេះ ជាបច្ចុប្បន្នកាលប្រើក្នុងអត្ថជាអតីតកាល ។ បទថា **អបាវុសោ ជានាសិ** សេចក្តីថា អាវុសោ ទ្រង់ជ្រាបឬទេ គឺទ្រង់ជ្រាបឬ ។ ដោយបទថា **តណ្ហាក្ខយវិមុត្តិយោ** នេះ ព្រះថេរៈទូលត្រូវសួរថា ព្រះសាស្តាទ្រង់សម្តែងតណ្ហាសង្ខយវិមុត្តិដល់ព្រះអង្គ ទ្រង់ជ្រាបតាមនោះឬ ។ ម្យ៉ាងទៀត ដោយបទថា **តណ្ហាក្ខយ-វិមុត្តិយោ** នេះ ព្រះថេរៈទូលសួរដល់ការសម្តែងតណ្ហាសង្ខយវិមុត្តិសូត្រ ។

បទថា **ព្រហ្មានំ** បានដល់ មហាព្រហ្ម ។ បទថា **សុធម្មាយាភិតោ សភំ** បានដល់ ក្នុងសុធម្មាសភា ។ សុធម្មាសភានេះ ជាសុធម្មាសភាក្នុង

ព្រហ្មលោក មិនមែនក្នុងស្ថានតាវត្តិង្ស ។ ជម្ពូតាទេវលោក វៀរចាក សុធម្មាសភា មិនមាន ។ បទថា **អជ្ជាបិ តេ អាវុសោ សា ទិដ្ឋិ យា តេ ទិដ្ឋិ បុរេ អហុ** សេចក្តីថា មិនមានសមណៈ ឬព្រាហ្មណ៍ណាមួយ ដែលអាចមកដល់ព្រហ្មលោកនេះបាន ក្នុងកាលមុន តែព្រះសាស្តាយាងមកក្នុងទីនេះ ទិដ្ឋិណាមានហើយដល់លោក ហេតុអ្វីថ្ងៃនេះ គឺឥឡូវនេះ ទើបទិដ្ឋិមិនប្រាសទៅ ។

បទថា **បស្សសិ វីតិវត្តន្តំ ព្រហ្មលោកេ បភស្សរំ** សេចក្តីថា លោកឃើញឱកាសរបស់ព្រះមានព្រះភាគ ព្រមទាំងសាវកដែលសាវកទាំងឡាយមានព្រះមហាកប្បិន និងព្រះមហាកស្សបៈជាដើមចោមរោម ទ្រង់គង់ចូលតេជោធាតុផ្សាយទៅក្នុងព្រហ្មលោកដែរឬទេ ។

សម័យមួយ ព្រះមានព្រះភាគជ្រាបការគិតរបស់ព្រហ្ម ដែលអង្គុយប្រជុំក្នុងសុធម្មាសភា ក្នុងព្រហ្មលោកដែលកំពុងគិតថា សមណៈ ឬព្រាហ្មណ៍ណាមួយ ដែលមានឫទ្ធិយ៉ាងនេះមានឬហ្ន៎ សមណៈ ឬព្រាហ្មណ៍នោះ គប្បីមកក្នុងទីនេះបាន ទើបទ្រង់យាងទៅព្រហ្មលោកនោះ គង់ប្រថាប់ក្នុងអាកាសខាងលើសិរសារបស់ព្រហ្ម ទ្រង់ចូលតេជោធាតុ បញ្ចេញនូវឱកាស ទ្រង់ត្រិះរិះឲ្យព្រះមហាមោគ្គល្លានជាដើមមក ។ ព្រះមហាមោគ្គល្លានជាដើមនោះ ក៏បានទៅក្នុងទីនោះ ដំណាលគ្នានឹងព្រះតម្រិះ ថ្វាយបង្គំព្រះសាស្តា ដឹងនូវអធ្យាស្រ័យរបស់ព្រះសាស្តា ទើបអង្គុយចូលតេជោធាតុមួយទិស មួយអង្គហើយផ្សាយឱកាសទៅ ។ ព្រហ្មលោកទាំងមូល មានឱកាសតែមួយ ។ ព្រះ

សាស្តាទ្រង់ជ្រាបថា ព្រហ្មជាអ្នកមានចិត្តគួរទទួលធម៌ ទើបទ្រង់សម្តែងធម៌ប្រកាសសច្ចៈ ៤ ។

ក្នុងកាលចប់ទេសនា ព្រហ្មច្រើនពាន់ បានតាំងនៅក្នុងមគ្គ និងផល ។ លោកសំដៅដល់សេចក្តីនោះ កាលនឹងទាក់ទង ទើបពោលគាថាថា **អដ្ឋាបិតេ អាវុសោ សា ទិដ្ឋិ** ដូច្នេះជាដើម ។ សេចក្តីនេះ គប្បីសម្តែងដោយពកព្រហ្មសូត្រ សមដូចលោកពោលថា

ខ្ញុំបានស្តាប់មកយ៉ាងនេះ ។ សម័យមួយ ព្រះមានព្រះភាគទ្រង់គង់នៅក្នុងវត្តជេតពន របស់អនាថបិណ្ឌិកគហបតី ទៀបក្រុងសាវត្ថី ។ សម័យនោះឯង ព្រហ្មមួយអង្គ មានទិដ្ឋិអាក្រក់ មានសភាពយ៉ាងនេះ កើតឡើងថា បុគ្គលដែលមកក្នុងលោកនេះ គ្មានជាសមណៈ ជាព្រាហ្មណ៍ទេ ។

គ្រានោះ ព្រះមានព្រះភាគ ទ្រង់ជ្រាបនូវបរិវិតក្កក្នុងចិត្តរបស់ព្រហ្មនោះ ដោយប្រពៃហើយ ក៏ដូចបុរសមានកម្លាំង ។បេ។ ទៅប្រាកដក្នុងព្រហ្មលោកនោះ ។ ទើបព្រះមានព្រះភាគ ទ្រង់ចូលតេជោធាតុគង់ផ្គត់ព្រះភ្នែនព្ធដ៏អាកាសខាង លើព្រហ្មនោះ ។

គ្រានោះ ព្រះមហាមោគ្គល្លានមានអាយុ មានសេចក្តីត្រិះរិះយ៉ាងនេះថា ឥឡូវនេះ ព្រះមានព្រះភាគ គង់ក្នុងទីណាហ្ន៎ ។ ព្រះមហាមោគ្គល្លានមានអាយុ ក៏បានឃើញនូវព្រះមានព្រះភាគ ដោយទិព្វចក្ខុដ៏បរិសុទ្ធ កន្លងបង់នូវចក្ខុជារបស់មនុស្សធម្មតា ដែល

ព្រះអង្គចូលតេជោធាតុ គង់ផ្គត់ព្រះភ្នែនព្ធដ៏អាកាស អំពីខាងលើនៃព្រហ្មនោះ លុះឃើញហើយ ក៏បាត់អំពីវត្តជេតពន ទៅប្រាកដក្នុងព្រហ្មលោកនោះ ដោយឆាប់រហ័ស ដូចបុរសមានកម្លាំងលាចេញនូវដៃដែលបត់ចូល ឬបត់ចូលនូវដៃដែលលាចេញ ។ លំដាប់នោះ ព្រះមហាមោគ្គល្លានមានអាយុ អាស្រ័យនៅទិសខាងកើត ចូលតេជោធាតុ អង្គុយផ្គត់ភ្នែនព្ធដ៏អាកាស ខាងលើព្រហ្មនោះ ទាបជាងព្រះមានព្រះភាគ ។

គ្រានោះ ព្រះមហាកស្សបៈមានអាយុ មានសេចក្តីត្រិះរិះយ៉ាងនេះថា ឥឡូវនេះ ព្រះមានព្រះភាគ ទ្រង់គង់ក្នុងទីណាហ្ន៎ ។ ព្រះមហាកស្សបៈមានអាយុ បានឃើញព្រះមានព្រះភាគ ដោយទិព្វចក្ខុ ។បេ។ លុះឃើញហើយ ក៏ដូចបុរសមានកម្លាំង ។បេ។ បាត់អំពីវត្តជេតពន ទៅប្រាកដក្នុងព្រហ្មលោកនោះ ដោយឆាប់រហ័ស ។ លំដាប់នោះ ព្រះមហាកស្សបៈមានអាយុ អាស្រ័យនៅទិសខាងត្បូង ចូលតេជោធាតុ អង្គុយផ្គត់ភ្នែនព្ធដ៏អាកាស ខាងលើព្រហ្មនោះ ទាបជាងព្រះមានព្រះភាគ ។

គ្រានោះ ព្រះមហាកប្បិនមានអាយុ មានសេចក្តីត្រិះរិះយ៉ាងនេះថា ឥឡូវនេះ ព្រះមានព្រះភាគ ទ្រង់គង់ក្នុងទីណាហ្ន៎ ។ គ្រានោះ ព្រះមហាបក្បិនមានអាយុ ឃើញព្រះមានព្រះភាគ ដោយទិព្វចក្ខុ ។បេ។ លុះឃើញហើយ ក៏ដូចបុរសមានកម្លាំង ។បេ។ បាត់អំពី

វត្តជេតពន ទៅប្រាកដក្នុងព្រហ្មលោកនោះ ដោយឆាប់រហ័ស ។ លំដាប់នោះ ព្រះមហាបក្សិនមានអាយុ អាស្រ័យនៅទិសខាងលិច ចូលតេជោធាតុ អង្គុយផ្គត់ភ្នែនព្ពដ៏អាកាស ខាងលើព្រហ្មនោះ ទាបជាងព្រះមានព្រះភាគ ។

គ្រានោះ ព្រះអនុរុទ្ធមានអាយុ មានសេចក្តីត្រិះរិះយ៉ាងនេះថា ឥឡូវនេះ ព្រះមានព្រះភាគ ទ្រង់គង់ក្នុងទីណាហ្ន៎ ។ ទើបព្រះអនុរុទ្ធមានអាយុបានឃើញ ។បេ។ លុះឃើញហើយ ក៏ដូចជាបុរសមានកម្លាំង ។បេ។ ទៅប្រាកដក្នុងព្រហ្មលោកនោះ ដោយឆាប់រហ័ស ។ លំដាប់នោះ ព្រះអនុរុទ្ធមានអាយុ អាស្រ័យនៅទិសខាងជើង ចូលតេជោធាតុ អង្គុយផ្គត់ភ្នែនព្ពដ៏អាកាស ខាងលើព្រហ្មនោះ ទាបជាងព្រះមានព្រះភាគ ។

គ្រានោះ ព្រះមហាមោគ្គល្លានមានអាយុ បានពោលគាថានឹងព្រហ្មថា ម្នាលអាវុសោ ទិដ្ឋិណារបស់អ្នក មានហើយក្នុងកាលមុន ទិដ្ឋិរបស់អ្នកនោះ មានក្នុងថ្ងៃនេះទៀត អ្នកឃើញនូវរស្មីរបស់ព្រះពុទ្ធ ដែលប្រព្រឹត្តកន្លងនូវរស្មីឯទៀត ក្នុងព្រហ្មលោកដែរឬ ។ ព្រហ្មតបថា បពិត្រលោកនិរទុក្ខ ទិដ្ឋិរបស់ខ្ញុំណាមានហើយ ក្នុងកាលមុន ទិដ្ឋិរបស់ខ្ញុំនោះ មិនមានទេ ខ្ញុំឃើញនូវព្រះរស្មីដែលប្រព្រឹត្តកន្លងនូវរស្មីឯទៀត ក្នុងព្រហ្មលោកដែរ ឥឡូវនេះ ខ្ញុំនឹងពោលដោយប្រការដូចម្តេច ព្រោះថា ខ្ញុំជាបុគ្គលទៀង ជាបុគ្គល

មាននៅ សព្វៗ កាល ។

គ្រានោះ ព្រះមានព្រះភាគ ញុំាងព្រហ្មនោះឲ្យសង្វេគហើយ ក៏បាត់អំពីព្រហ្មលោកនោះ មកប្រាកដក្នុងវត្តជេតពន ដោយឆាប់រហ័ស ដូចបុរសមានកម្លាំងលាចេញនូវដៃដែលបត់ចូល ឬបត់ចូលនូវដៃដែលលាចេញ លំដាប់នោះ ព្រហ្មក៏ហៅព្រហ្មជាបរិសទ្យមួយអង្គមកថា ម្នាលអ្នកនិរទុក្ខ អ្នកចូរមក អ្នកទៅរកព្រះមហាមោគ្គល្លានមានអាយុ លុះចូលទៅដល់ហើយ ចូរពោលយ៉ាងនេះ នឹងព្រះមហាមោគ្គល្លានមានអាយុថា បពិត្រព្រះមោគ្គល្លាន អ្នកនិរទុក្ខ សាវកទាំងឡាយដទៃទៀត របស់ព្រះមានព្រះភាគនោះ ដែលមានឫទ្ធិច្រើនយ៉ាងនេះ មានអានុភាពច្រើនយ៉ាងនេះ ដូចជាព្រះមហាមោគ្គល្លាន ព្រះកស្សបៈ ព្រះកប្បិន ព្រះអនុរុទ្ធដ៏ចម្រើន នៅមានទៀតដែរឬទេ ។ ព្រហ្មជាបរិសទ្យនោះ ទទួលពាក្យព្រហ្មនោះថា អើ លោកអ្នកនិរទុក្ខ ដូច្នេះហើយក៏បាត់អំពីព្រហ្មលោកនោះ មកប្រាកដក្នុងទីចំពោះមុខព្រះមហា-មោគ្គល្លានមានអាយុ ដោយឆាប់រហ័ស ដូចបុរសមានកម្លាំង ។បេ។ លំដាប់នោះ ព្រហ្មជាបរិសទ្យនោះ ក្រាបថ្វាយបង្គំព្រះមហា-មោគ្គល្លានមានអាយុហើយ ស្ថិតនៅក្នុងទីដ៏សមគួរ ។ ព្រហ្មជាបរិសទ្យនោះ លុះស្ថិតនៅក្នុងទីសមគួរហើយ បានពោលពាក្យនេះនឹងព្រះមហាមោគ្គល្លានមានអាយុថា បពិត្រលោកអ្នកនិរទុក្ខ ។បេ។

ព្រះអនុរុទ្ធ ។

គ្រានោះ ព្រះមាហាមោគ្គល្លានមានអាយុ បានពោលគាថា នឹងព្រហ្មជាបរិសទ្យថា

សាវ័កទាំងឡាយរបស់ព្រះពុទ្ធ នៅមានច្រើនអង្គ ជាអ្នកមានវិជ្ជា ៣ ផង សម្រេចដោយឫទ្ធិផង ឈ្លាសក្នុងវារៈនៃចិត្តផង ជាព្រះអរហន្តខីណាស្រពផង ។

លំដាប់នោះ ព្រហ្មជាបរិសទ្យនោះ ត្រេកអររីករាយនឹងភាសិតរបស់ព្រះមហាមោគ្គល្លានមានអាយុហើយ ក៏ចូលទៅរកព្រហ្មនោះលុះចូលទៅដល់ហើយ បានពោលពាក្យនេះ នឹងព្រហ្មនោះថា បពិត្រអ្នកនិរទុក្ខ ព្រះមហាមោគ្គល្លានមានអាយុ មានថេរវាចាយ៉ាងនេះថា

សាវ័កទាំងឡាយរបស់ព្រះពុទ្ធ នៅមានច្រើនអង្គ ជាអ្នកមានវិជ្ជា ៣ ផង សម្រេចដោយឫទ្ធិផង ឈ្លាសក្នុងវារៈនៃចិត្តផង ជាព្រះអរហន្តខីណាស្រពផង ។

ព្រហ្មជាបរិសទ្យ បានពោលពាក្យនេះហើយ ចំណែកខាងព្រហ្មជាអ្នកមានសេចក្តីត្រេកអរ ក៏ត្រេកអរនឹងភាសិតរបស់ព្រហ្មជាបរិសទ្យនោះ ។

លោកសំដៅដល់រឿងដូចពោលនេះ ទើបពោលថា សេចក្តីនេះ គប្បីសម្តែងពកព្រហ្មសូត្រ ។

ដោយបទថា **មហានេរុនោ កូដំ**[១] នេះ លោកពោលដល់ស្តេចសិនេរុទាំងមូលនោះឯង ក្នុងចំណុចដែលប្រាកដ គឺកំពូល ។

បទថា **វិមោក្ខេន អបស្សយិ** អធិប្បាយថា ឃើញហើយដោយវិមោក្ខដែលសម្បយុត្តដោយឈាន មានអភិញ្ញាដែលជាទីអាស្រ័យ ។

បទថា **វនំ** បានដល់ ជម្ពូទ្វីប ។ ពិតហើយ ជម្ពូទ្វីបនោះ ហៅថា **វន** ព្រោះមានព្រៃជាច្រើន ។ ដូចលោកពោលថា **ជម្ពុមណ្ឌស្ស ឥស្សរោ** បុគ្គលជាធំនៃផ្ទៃជម្ពូទ្វីប ។

បទថា **បុព្វវិទេហានំ** បានដល់ ដែលនៅក្នុងបុព្វវិទេហទ្វីប ឈ្មោះថា អ្នកបុព្វវិទេហៈ ។ បទថា **យេ ច ភូមិសយា នរា** សេចក្តីថា ពួកមនុស្សអ្នកអបរគោយានទ្វីប និងឧត្តរកុរុទ្វីប ឈ្មោះថា នរៈអ្នកដេកលើផែនដី ។ ពិតហើយ នរៈទាំងនោះ លោកហៅថា **ភូមិសយ** អ្នកដេកលើផែនដី ព្រោះមិនមានផ្ទះ ភ្ជាប់សេចក្តីថា នរជនទាំងអស់នោះមិនឃើញអត្ថនេះ គប្បីសម្តែងដោយការទូន្មាននន្ទោបនន្ទនាគរាជ ។

បានឮថា សម័យមួយ អនាថបិណ្ឌិកគហបតី ស្តាប់ព្រះធម្មទេសនារបស់ព្រះមានព្រះភាគ ទើបទូលនិមន្តថា បពិត្រព្រះអង្គដ៏ចម្រើន សូមទ្រង់ទទួលភិក្ខាហារក្នុងផ្ទះរបស់ខ្ញុំព្រះអង្គ មួយអន្លើដោយភិក្ខុសង្ឃ ៥០០ ក្នុងថ្ងៃស្អែកនេះ ដូច្នេះហើយ ចៀសចេញទៅ ។ ក្នុងថ្ងៃនោះ កាលព្រះមានព្រះភាគទ្រង់ប្រមើលមើលមុនលោកធាតុ ក្នុងវេលាទៀបភ្លឺ នាគរាជឈ្មោះ

---

១- បទនេះ លោកអធិប្បាយក្នុងមារតជ្ជនីយសូត្របន្តទៀត ។

នន្ទោបនន្ទមកកាន់គន្លងក្នុងមុខនៃព្រះញាណ ។ ព្រះមានព្រះភាគ ទ្រង់ពិចារណាថា នាគរាជនេះ មកកាន់គន្លងចំពោះញាណ ។ ទើបព្រះមានព្រះភាគ ទ្រង់ពិចារណាថា នាគរាជនេះ មកកាន់គន្លងចំពោះព្រះញាណរបស់តថាគត មានហេតុអ្វីឬហ្ន៎ ទ្រង់ក៏បានឃើញឧបនិស្ស័យនៃសរណគមន៍ ទ្រង់ពិចារណាថា ជាមិច្ឆាទិដ្ឋិ មិនជ្រះថ្លាក្នុងព្រះរតនត្រ័យ អ្នកណាហ្ន៎ អាចដោះនាគរាជនេះ អំពីមិច្ឆាទិដ្ឋិបាន ដូច្នេះ ទ្រង់ក៏បានឃើញព្រះមហាមោគ្គល្លាន ។

លំដាប់នោះ កាលរាត្រីអស់ហើយ ទ្រង់ធ្វើកិច្ចបដិបត្តិសរីរៈហើយ ត្រាស់ហៅព្រះអានន្ទដ៏មានអាយុមកត្រាស់ថា ម្នាលអានន្ទ ចូរអ្នកប្រាប់ភិក្ខុ ៥០០ ថា ព្រះតថាគតយាងចារិកទៅកាន់ទេវលោក ។ ថ្ងៃនោះ ពួកនាគចាត់ចែងទីសម្រាប់ផឹកស៊ីសម្រាប់នន្ទោបនន្ទនាគរាជ ។ នាគរាជនោះ ត្រូវបាំងដោយស្វេតច្ឆត្រទិព្វលើរតនបល្ល័ង្កទិព្វ ដែលនាគរបាំ ៣ ប្រភេទ និងនាគបរិស័ទចោមរោម កំពុងអង្គុយមើលបាយ និងទឹក ដែលដាក់ក្នុងភាជន៍ទិព្វ ។ កាលនោះ ព្រះមានព្រះភាគទ្រង់ធ្វើឲ្យស្ដេចនាគមើលឃើញ ទ្រង់បែរព្រះភក្ត្រទៅកាន់តាវត្តិង្សទេវលោក លើវិមានមាសរបស់នាគរាជនោះឯងមួយអន្លើដោយភិក្ខុ ៥០០ រូប ។

សម័យនោះ នន្ទោបនន្ទនាគរាជកើតនូវទិដ្ឋិដ៏លាមកបែបនេះថា ពួកសមណៈត្រងោលទាំងនេះ ចូលទៅខ្លះ ត្រឡប់ចេញមកខ្លះ អំពីភពរបស់ទេវតាជាន់តាវត្តិង្សក្ដី រំលងលើភពរបស់អញ ឥឡូវនេះ តាំងអំពីនេះទៅ អញមិនឲ្យពួកសមណៈត្រងោលទាំងនេះ ជម្រុះធូលីដែលជាប់នឹងជើងលើ

អំបែងក្បាលរបស់អញហើយទៅ ទើបក្រោកឡើង ទៅកាន់ដើងភ្នំសិនេរុ លះអត្តភាពនោះ យករង្វេលព័ទ្ធភ្នំសិនេរុ ៧ ជុំ បើកពពារអំពីខាងលើ ហើយយកពពារគ្របស្ថានតាវត្តិង្ស ធ្វើឲ្យមើលមិនឃើញ ។

កាលនោះឯង ព្រះរដ្ឋបាលបានក្រាបទូលព្រះមានព្រះភាគដូច្នេះថា បពិត្រព្រះអង្គដ៏ចម្រើន កាលមុន ខ្ញុំព្រះអង្គឈរត្រង់បទេសនេះ ឃើញភ្នំសិនេរុ និងឃើញភ្នំសត្តបរិភណ្ឌ ឃើញស្ថានតាវត្តិង្ស ឃើញវេជយន្តប្រាសាទ ឃើញទង់ខាងលើវេជយន្តប្រាសាទ បពិត្រព្រះអង្គដ៏ចម្រើន អ្វីហ្ន៎ជាហេតុ អ្វីហ្ន៎ជាបច្ច័យដែលធ្វើខ្ញុំព្រះអង្គមើលមិនឃើញភ្នំសិនេរុ ។បេ។ មិនឃើញទង់ខាងលើវេជយន្តប្រាសាទក្នុងឥឡូវនេះ ។ ព្រះសាស្តាត្រាស់ថា ម្នាលរដ្ឋបាល នាគរាជឈ្មោះនន្ទោបនន្ទ ក្រោធនឹងពួកអ្នក ទើបយករង្វេលព័ទ្ធភ្នំសិនេរុ ៧ ជុំ យកពពារបិទខាងលើធ្វើឲ្យងងឹត ។ ព្រះរដ្ឋបាលក្រាបទូលថា បពិត្រព្រះអង្គដ៏ចម្រើន ខ្ញុំព្រះអង្គទូន្មាននាគរាជនោះ ព្រះមានព្រះភាគទ្រង់មិនអនុញ្ញាតដល់ព្រះរដ្ឋបាលនោះ ។ កាលនោះឯង ភិក្ខុទាំងពួង គឺព្រះភទ្ទិយៈ ព្រះរាហុល ក្រោកឡើងដោយលំដាប់ ។ ព្រះមានព្រះភាគទ្រង់មិនអនុញ្ញាត ។

ក្នុងទីបំផុត ព្រះមហាមោគ្គល្លានត្ថេរក្រាបទូលថា បពិត្រព្រះអង្គដ៏ចម្រើន ខ្ញុំព្រះអង្គសូមទូន្មាននាគរាជនោះ ។ ព្រះមានព្រះភាគ ទ្រង់អនុញ្ញាតថា ម្នាលមោគ្គល្លាន ចូរអ្នកទូន្មាន ។ ព្រះថេរៈលះអត្តភាពដើម ហើយនិម្មិតភេទជានាគរាជធំ យករង្វេលរឹតរុំនន្ទោបនន្ទនាគរាជ ១៤ ជុំ ហើយដាក់ពពាររបស់ខ្លួនលើពពាររបស់នាគរាជនោះ ហើយរួតផ្ទប់នឹងភ្នំសិនេរុ ។ នាគរាជ

បន្ហុយផ្សែង ។ ចំណែកព្រះថេរៈក៏ពោលថា ផ្សែង មិនមែនមានតែក្នុងសរីរៈរបស់អ្នកទេ សូម្បីរបស់យើងក៏មាន ទើបបន្ហុយផ្សែង ។ ផ្សែងរបស់នាគរាជមិនបៀតបៀនព្រះថេរៈ តែផ្សែងរបស់ព្រះថេរៈបៀតបៀននាគរាជ លំដាប់នោះ នាគរាជក៏បន្ហុយភ្លើង ឯព្រះថេរៈក៏ពោលថា មិនមែនមានភ្លើងតែក្នុងសរីរៈរបស់អ្នកប៉ុណ្ណោះទេ របស់យើងក៏មាន ហើយព្រួសភ្លើង ។ ភ្លើងរបស់នាគរាជមិនបៀតបៀនព្រះថេរៈ តែភ្លើងរបស់ព្រះថេរៈបៀតបៀននាគ-រាជ ។ នាគរាជគិតថា សមណៈនេះ រួតអញផ្ចប់នឹងភ្នំសិនេរុ បន្ហុយផ្សែងនិងភ្លើង ទើបសាកសួរថា លោកដ៏ចម្រើន លោកជានរណា ព្រះថេរៈឆ្លើយថា ម្នាលនន្ទៈ អាត្មាជាមោគ្គល្លាន ។ នាគរាជពោលថា លោកដ៏ចម្រើនសូមលោកម្ចាស់ ត្រឡប់ភេទជាភិក្ខុដូចដើមចុះ ។

ព្រះថេរៈលះអត្តភាពនោះហើយ ចូលទៅកាន់ប្រហោងត្រចៀកខាងស្ដាំរបស់នាគរាជនោះ ហើយចេញតាមប្រហោងត្រចៀកឆ្វេង ចូលតាមប្រហោងត្រចៀកឆ្វេង ហើយចេញតាមប្រហោងត្រចៀកស្ដាំ ។ មា៉ងទៀត ចូលតាមរន្ធច្រមុះស្ដាំ ហើយចេញតាមរន្ធច្រមុះឆ្វេង ចូលតាមរន្ធច្រមុះឆ្វេង ហើយចេញតាមរន្ធច្រមុះស្ដាំ ។ លំដាប់នោះ នាគរាជហាមាត់ ព្រះថេរៈក៏ចូលតាមមាត់ ដើរចង្ក្រមក្នុងពោះ ពីទិសខាងកើតទៅទិសខាងលិច ។ ព្រះមានព្រះភាគត្រាស់ថា ម្នាលមោគ្គល្លាន ចូរអ្នកមនសិការឲ្យល្អ នាគមានឫទ្ធិ ព្រះថេរៈក្រាបទូលថា បពិត្រព្រះអង្គដ៏ចម្រើន ឥទ្ធិបាទ ៤ ខ្ញុំព្រះអង្គចម្រើនហើយ ធ្វើឲ្យច្រើនហើយ ធ្វើឲ្យដូចជាយានហើយ ធ្វើឲ្យដូចជាវត្ថុទីតាំងហើយ បដិបត្តិ

ហើយ សន្សំហើយ ផ្ដើមល្អហើយ បពិត្រព្រះអង្គដ៏ចម្រើន នន្ទោបនន្ទនាគរាជ សូមស្ងេះទុកចុះ នាគរាជដូចនន្ទោបនន្ទ ១០០ ក្ដី ១០០០ ក្ដី ខ្ញុំព្រះអង្គក៏ទូន្មានបាន ។

នាគរាជគិតថា ខាងដើម កាលសមណៈនេះមក អញមិនឃើញ ពេលនេះ ក្នុងកាលដែលចេញមក អញនឹងដាក់សមណៈនោះ ក្នុងរវាងចង្កូម ហើយទំពាស៊ី កាលគិតហើយ ទើបពោលថា បពិត្រលោកម្ចាស់ សូមលោកម្ចាស់ចេញមកចុះ កុំដើរចង្រ្កមទៅមកៗ ខាងក្នុងផ្ទៃ ធ្វើឲ្យខ្ញុំលំបាកឡើយ ។ ព្រះថេរៈបានចេញមកឈរខាងក្រៅ នាគរាជឃើញថា នេះ គឺសមណៈ ទើបបញ្ចេញខ្យល់តាមច្រមុះ ព្រះថេរៈចូលចតុត្ថជ្ឈាន សូម្បីរោមរបស់ព្រះថេរៈ ខ្យល់ក៏មិនអាចធ្វើឲ្យញាប់ញ័របាន ។ បានឮថា ភិក្ខុទាំងឡាយដ៏សេស អាចធ្វើបាដិហារ្យគ្រប់យ៉ាង ចាប់តាំងអំពីដំបូងបាន តែដល់ដំណាក់កាលនេះ មិនមានអ្នកណាអាចចូលឈានបានរហ័ស មាំទាំបែបនេះ ព្រោះហេតុនោះ ទើបព្រះមានព្រះភាគមិនអនុញ្ញាតឲ្យភិក្ខុទាំងនោះទូន្មាននាគរាជ ។

នាគរាជគិតថា អញមិនអាចធ្វើសូម្បីតែរន្ធរោមរបស់សមណៈនេះ ឲ្យកម្រើកដោយខ្យល់ច្រមុះ សមណៈនេះមានឫទ្ធិច្រើន ព្រះថេរៈប្ដូរអត្តភាពនោះ ហើយនិម្មិតជាគ្រុឌ កាលនឹងឲ្យស្គាល់ខ្យល់របស់គ្រុឌ ទើបដេញតាមនាគរាជ ។ នាគរាជផ្លាស់អត្តភាពនោះ និម្មិតភេទជាមាណពពោលថា លោកដ៏ចម្រើន ខ្ញុំសូមដល់លោកជាសរណៈ ដូច្នេះហើយ ថ្វាយបង្គំបាទាទាំង ២ របស់ព្រះថេរៈ ។

ព្រះថេរៈពោលថា ននូៈ ព្រះសាស្តារបស់យើងយាងមក ចូរអ្នកមក យើងទៅទាំងអស់គ្នា ទូន្មាននាគរាជធ្វើឲ្យអស់ព្យសន៍ហើយ នាំទៅកាន់សម្នាក់ ព្រះមានព្រះភាគ ។ នាគរាជថ្វាយបង្គំព្រះមានព្រះភាគហើយ ក្រាបទូលថា បពិត្រព្រះអង្គដ៏ចម្រើន ខ្ញុំព្រះអង្គសូមដល់ទ្រង់ជាសរណៈ ។ ព្រះមាន ព្រះភាគត្រាស់ថា ម្នាលនាគរាជ ចូរអ្នកនៅជាសុខចុះ កាលភិក្ខុសង្ឃ ចោមរោម បានយាងទៅកាន់និវេសន៍របស់អនាថបិណ្ឌិកសេដ្ឋី ។

អនាថបិណ្ឌិកសេដ្ឋីក្រាបទូលថា បពិត្រព្រះអង្គដ៏ចម្រើន ហេតុអ្វី ទើប ទ្រង់យាងមកយឺត ព្រះសាស្តាត្រាស់ថា ព្រោះមានសង្គ្រាមរបស់មោគ្គ-ល្លាន និងននទោបននទនាគរាជ អនាថបិណ្ឌិកសេដ្ឋីទូលសួរថា អ្នកណាឈ្នះ អ្នកណាបរាជ័យ ព្រះមានព្រះភាគត្រាស់ថា មោគ្គល្លានឈ្នះ ននូៈបរាជ័យ ។ អនាថបិណ្ឌិកសេដ្ឋីក្រាបទូលថា បពិត្រព្រះអង្គដ៏ចម្រើន សូមព្រះមានព្រះភាគ ទ្រង់ទទួលភត្តាហារដោយលំដាប់ អស់ ៧ ថ្ងៃ ខ្ញុំព្រះអង្គនឹងធ្វើសក្ការៈដល់ ព្រះថេរៈ អស់ ៧ ថ្ងៃ ដូច្នេះហើយ ឲ្យធ្វើសក្ការៈធំដល់ភិក្ខុ ៥០០ រូប មានព្រះពុទ្ធជាព្រះប្រធានអស់ ៧ ថ្ងៃ ដោយហេតុនោះ ទើបលោកពោលថា គប្បីសម្តែងសេចក្តីនេះ ដោយការទូន្មាននន្ទោបនន្ទនាគរាជ ដូច្នេះ ។

សម័យមួយ ព្រះមានព្រះភាគ គង់នៅក្នុងប្រាសាទដែលប្រដាប់ដោយ បន្ទប់ ១០០០ ដែលនាងវិសាខាឧបាសិកាសាងក្នុងបុព្វារាម ។បេ។ និងឲ្យ ទេវតាទាំងឡាយសង្វេគហើយ ដោយហេតុនោះ ទើបលោកពោលថា

ហើយញ៉ាំងព្រះធរណីដ៏ជ្រៅ និងក្រាស់ ដែលបុគ្គលមិនអាចឲ្យកម្រើក

បាន ឲ្យកម្រើកបានដោយចុងម្រាមជើងឆ្វេង ។

បណ្ដាបទទាំងនោះ បទថា **ឥទ្ធិយា ចាបមឹ គតោ** សេចក្ដីថា ដល់ គឺសម្រេចដល់ទីបំផុតនៃឫទ្ធិ មានសម្ដែងឫទ្ធិបានផ្សេងៗ ជាដើម ។ បទថា **អស្មិមានំ** សេចក្ដីថា ខ្ញុំមិនឃើញ គឺមិនជួបអស្មិមានះដូចអាត្មាអញ ជាអ្នកដល់ព្រមដោយបញ្ញា សីល និងសមាធិ កាលនឹងសម្ដែងសេចក្ដីនោះ ទើបព្រះថេរៈពោលថា **មានោ មយ្ហំ ន វិជ្ជតិ** ដូច្នេះជាដើម ។

បទថា **សាមណេរេ ឧបាទាយ** សេចក្ដីថា ខ្ញុំធ្វើសេចក្ដីកោតក្រែងយ៉ាងខ្លាំងក្លា ធ្វើចិត្តគោរព បានដល់ ធ្វើនូវការរាប់អានច្រើន ដោយអើពើក្នុងភិក្ខុសង្ឃទាំងមូល តាំងអំពីសាមណេរឡើងទៅ ។

បទថា **អបរិមេយ្យេ ឥតោ កប្បេ** សេចក្ដីថា ក្នុងទីបំផុត ១ អសង្ខេយ្យ និង ១ សែនកប្ប រាប់មិនបានអំពីកប្បដែលកើតហើយនេះ រួមទាំងអន្តរកប្បជាដើមផង ។ បទថា **យំ កម្មមភិនីហរឹ** សេចក្ដីថា ខ្ញុំបំពេញបុញ្ញសម្បត្តិ ដែលជាហេតុឲ្យដល់នូវភាពជាអគ្គសាវក ។

បទថា **តាហំ ភូមិមនុប្បត្តោ** សេចក្ដីថា ខ្ញុំជាបុគ្គលដល់ដោយលំដាប់នូវសាវកភូមិនោះ គឺជាអ្នកដល់នូវព្រះនិព្វាន ពោល គឺការអស់អាសវៈ ។

បដិសម្ភិទា ៤ មានអត្ថប្បដិសម្ភិទាជាដើម វិមោក្ខ ៨ មានសោតាបត្តិមគ្គជាដើម អភិញ្ញា ៦ មានឥទ្ធិវិធជាដើម ខ្ញុំបានធ្វើឲ្យជាក់ច្បាស់ហើយ គឺធ្វើឲ្យប្រចក្សហើយ សាសនា ពោល គឺឱវាទានុសាសនីរបស់ព្រះសម្ពុទ្ធ គឺរបស់ព្រះមានព្រះភាគ ខ្ញុំធ្វើស្រេចហើយ អធិប្បាយថា ឲ្យសម្រេចហើយ

*ដោយការញុំាងបដិបទាក្នុងសីលឲ្យសម្រេច ។*

*បទថា* **ឯត្ថំ** *ប្រែថា ដោយប្រការនេះ គឺដោយលំដាប់ ដូចពោលខាងដើម ។ ព្រះមហាមោគ្គល្លានត្ថេរបានទទួលព្យាករ ក្នុងសម្នាក់ព្រះអនោមទស្សី-សម្ពុទ្ធមួយអន្ត ២ ដង ដោយប្រការដូច្នេះ ។ សួរថា រឿងកើតដូចម្ដេច ឆ្លើយថា ជាសេដ្ឋីបានទទួលព្យាករក្នុងសម្នាក់ព្រះមានព្រះភាគនោះ ដោយន័យដូចពោលហើយខាងដើម ។ ចុតិចាកអត្តភាពនោះ កើតក្នុងនាគពិភពដែលនៅក្នុងសមុទ្រ បានធ្វើការបូជាក្នុងសម្នាក់ព្រះមានព្រះភាគអង្គនោះទៀត ព្រោះជាសម័យដែលមនុស្សមានអាយុវែង បាននិមន្តឲ្យសោយ ហើយធ្វើនូវមហាបូជា ។ ក្នុងកាលនោះ ព្រះមានព្រះភាគ ក៏បានត្រាស់ព្យាករឲ្យផងដែរ ។ សព្ទថា* **សុទំ** *ជានិបាត ចុះក្នុងអត្ថថា ធ្វើបាទឲ្យពេញ ។*

*បទថា* **អាយស្មា** *ជាពាក្យហៅដោយសេចក្ដីស្រឡាញ់ គឺជាពាក្យហៅដោយសេចក្ដីគោរពពន់ពេក ។ ព្រះមហាមោគ្គល្លានត្ថេរបានភាសិត គឺពោលអបទានគាថាទាំងនេះ ។ សព្ទថា* **ឥតិ** *ជានិបាត ចុះក្នុងអត្ថថា ចប់សេចក្ដី ។៚*

**អដ្ឋកថា មហាមោគ្គល្លានត្ថេរាបទាន ចប់**

# សុត្តន្តបិដក

## មហាកស្សបត្ថេរាបទានទី ៩

[ ៥ ] កាលព្រះមានព្រះភាគ ទ្រង់ព្រះនាមបទុមុត្តរៈ ជាច្បង ក្នុងលោក ទ្រង់មិនញាប់ញ័រដោយលោកធម៌ ជាទីពឹងនៃសត្វលោក ទ្រង់បរិនិព្វានទៅ ពួកជននាំគ្នាធ្វើការបូជាព្រះសាស្តាអង្គនោះ ។ ប្រជុំជនមានចិត្តខ្ពស់ មានចិត្តសប្បាយរីករាយ កាលញាតិ និងមិត្ត នៃខ្ញុំទាំងនោះ កំពុងកើតសង្វេគ បីតិកើតឡើងដល់ខ្ញុំ ។ ខ្ញុំប្រជុំ ញាតិ និងមិត្តទាំងឡាយ ទើបពោលពាក្យនេះថា ព្រះលោកនាថ មានព្យាយាមធំ ទ្រង់បរិនិព្វានហើយ បើដូច្នោះ យើងនឹងធ្វើការ បូជា ។ ញាតិ និងមិត្តទាំងនោះទទួលស្តាប់ថា ប្រពៃហើយ ក៏ ញុំាងសេចក្តីរីករាយឲ្យកើតដល់ខ្ញុំដោយច្រើន ខ្ញុំបានធ្វើនូវការសន្សំ បុណ្យ ក្នុងព្រះពុទ្ធជាទីពឹង នៃសត្វលោកអង្គនោះ ។ ខ្ញុំបានសង់ វិមាន មានកម្ពស់ ១០០ ហត្ថ មានទំហំ ១៥០ ហត្ថ ខ្ពស់ទើស អាកាស ជាវិមានមានតម្លៃ ដែលរចនាយ៉ាងល្អ ។ ខ្ញុំសង់វិមាន ដ៏មានតម្លៃ វិចិត្រដោយគំនរកុសលទាំងឡាយ ក្នុងទីនោះហើយ បានញុំាងចិត្តរបស់ខ្លួនឲ្យជ្រះថ្លា បានបូជានូវចេតិយដ៏ប្រសើរ ។ ឯ ចេតិយនោះ រុងរឿង ដូចគំនរភ្លើង ឬដូចស្តេចសាលព្រឹក្ស មាន ផ្ការីក ភ្លឺស្វាងក្នុងទិសទាំង ៤ ដូចឥន្ទធនូ ក្នុងអាកាស ។ ខ្ញុំញុំាង ចិត្តឲ្យជ្រះថ្លាក្នុងធាតុចេតិយនោះ ហើយធ្វើកុសលដ៏ច្រើន ខ្ញុំបាន ទៅកើតក្នុងស្ថានតាវត្តិង្ស ព្រោះរឭកនូវបុព្វកម្មនោះ ។ ខ្ញុំជិះយាន

ទិព្វ ទីមដោយសេះមួយពាន់ ឯវិមាន ៧ ជាន់ដ៏ខ្ពស់ កើតឡើង សម្រាប់ខ្ញុំ ។ ផ្ទះមានកំពូលមួយពាន់ ជាវិការនៃមាសសុទ្ធ រុងរឿង ជានិច្ច ទិសទាំងពួង ស៊ីងតែភ្លឺដោយតេជះរបស់ខ្លួន ។ ផ្ទះខាងមុខ ដទៃទៀត ជាវិការនៃកែវក្រហម មានក្នុងកាលនោះ ផ្ទះទាំងនោះ ភ្លឺរន្ទាល ដោយរស្មី ទៅកាន់ទិសទាំង ៤ ដោយជុំវិញ ។ ផ្ទះមាន កំពូលទាំងឡាយ កើតឡើង ដោយបុញ្ញកម្មដ៏តាក់តែងល្អ ជាវិការ នៃកែវមណី តែងភ្លឺប្រាល ទៅកាន់ទិសតូចទិសធំដោយជុំវិញ ។ ផ្ទះកំពូលទាំងនោះ កាលភ្លឺឡើង រស្មីធំទូលាយ ខ្ញុំគ្របសង្កត់នូវ ទេវតាទាំងពួង នេះជាផលនៃបុញ្ញកម្ម ។ ក្នុងកប្ប ៦ ហ្មឺន អំពី កប្បនេះ ខ្ញុំកើតជាស្តេចចក្រពត្តិ ព្រះនាមឧព្វិទ្ធៈ មានសមុទ្រទាំង ៤ ជាព្រំដែន ជាស្តេចឈ្នះលើផែនដី គ្រប់គ្រងផែនដី ។ ក្នុង កទ្ទុកប្បនេះ ខ្ញុំកើតជាស្តេចចក្រពត្តិមានកម្លាំងច្រើន អស់ ៣០ ដង ខ្ញុំបានប្រារព្ធនូវកម្មរបស់ខ្លួន ( ប្រព្រឹត្តខ្ជាប់ដោយរាជធម៌ ១០ ) ។ ខ្ញុំបរិបូណ៌ដោយកែវទាំង ៧ ជាឥស្សរៈក្នុងទ្វីបទាំង ៤ ប្រាសាទ របស់ខ្ញុំ ខ្ពស់ ភ្លឺផ្លេកដូចផ្លេកបន្ទោរ ក្នុងរជ្ជកាលនៃស្តេចចក្រពត្តិ នោះ ។ទីក្រុងឈ្មោះរម្មកៈមានបណ្តោយ ២៤ យោជន៍ ទទឹង ១២ យោជន៍ មានកំពែង និងខ្លោងទ្វារដ៏មាំ ។ ឯកំពែងនោះ មាន បណ្តោយ ៥០០ យោជន៍ មានទទឹង ២៥០ យោជន៍ កុះករ ដោយពួកជនទាំងឡាយ ដូចជាបុរីនៃទេវតា ក្នុងជាន់ត្រៃត្រិង្ស ។

ម្ហូលមានចំនួន ២៥ ដែលគេយកទៅប្រកក្នុងបំពង់ម្ហូលពេញណែនរមែងកកិតជិតជាប់គ្នា យ៉ាងណាមិញ ។ ទីក្រុងរបស់ខ្ញុំ កុះករដោយដំរី សេះ រថ ទីក្រុងនោះ ច្រើនដោយពួកមនុស្ស ជាក្រុងវិសេសគួរជាទីត្រេកអរ ក៏យ៉ាងនោះដែរ ។ ខ្ញុំបរិភោគ ( ភោជន ) ផងផឹកទឹកផង ក្នុងបុរីនោះ រួចហើយ ទៅកាន់អត្តភាពជាទេវតាទៀតក្នុងបច្ឆិមភព ខ្ញុំបរិបូណ៌ដោយត្រកូលខ្ពង់ខ្ពស់ ។ ខ្ញុំកើតក្នុងត្រកូលព្រាហ្មណ៍ ជាអ្នកសម្បូរដោយរតនៈច្រើន បានលះបង់ហិរញ្ញចំនួន ៨០ កោដិ ហើយចេញបួស ។ បដិសម្ភិទា ៤ វិមោក្ខ ៨ និងអភិញ្ញា ៦ នេះ ខ្ញុំបានធ្វើឲ្យជាក់ច្បាស់ហើយ ទាំងសាសនារបស់ព្រះពុទ្ធ ខ្ញុំក៏បានប្រតិបត្តិហើយ ។

បានឮថា ព្រះមហាកបស្សត្ថេរមានអាយុ បានសម្តែងនូវគាថាទាំងនេះ ដោយប្រការដូច្នេះ ។

## មហាកស្សបត្ថេរាបទាន ចប់

# អដ្ឋកថា

## មហាកស្សបត្ថេរាបទាន

[ ៥ ] *អបទានរបស់ព្រះមហាកសប្បត្ថេរ មានពាក្យថា* **បទុមុត្តរស្ស ភគវតោ** *ដូច្នេះ ។*

*ព្រះមហាកស្សបត្ថេរនេះ ក៏មានអធិការបានធ្វើហើយ ក្នុងព្រះពុទ្ធអង្គមុនៗ សន្សំបុណ្យទាំងឡាយ ដែលជាឧបនិស្ស័យនៃព្រះនិព្វានក្នុងភពនោះៗ ក្នុងសាសនានៃព្រះមានព្រះភាគ ព្រះនាមបទុមុត្តរៈ បានជាកុដុម្ពិកៈ មានទ្រព្យសម្បត្តិ ៨០ កោដិ មាននាមថា វេទេហៈ នៅក្នុងនគរហង្សវតី ។*

*កុដុម្ពិកៈនោះជាឧបាសក ដែលរាប់អានព្រះពុទ្ធ ព្រះធម៌ ព្រះសង្ឃ ថាជារបស់ខ្លួន ក្នុងថ្ងៃឧបោសថមួយ បរិភោគភោជនជនដ៏ល្អអំពីព្រលឹម អធិដ្ឋានអង្គឧបោសថ ហើយកាន់យកគ្រឿងក្រអូប និងផ្កាទៅកាន់វិហារ បូជាព្រះសាស្តា នមស្ការ ហើយអង្គុយក្នុងចំណែកម្ខាង ។*

*ខណៈនោះ ព្រះសាស្តាទ្រង់តាំងសាវ័កទី ៣ នាមថា មហានិសភត្ថេរ ក្នុងតំណែងឯតទគ្គៈថា ម្នាលភិក្ខុទាំងឡាយ និសភៈនេះជាកំពូលនៃសាវ័កទាំងឡាយរបស់តថាគត ជាអ្នកទ្រទ្រង់នូវធុតង្គ និងពោលទូន្មានរឿងធុតង្គ ។ ឧបាសកបានស្តាប់ដូច្នោះក៏ជ្រះថ្លា ក្នុងកាលចប់ធម្មកថា កាលមហាជនក្រោកទៅហើយ ក៏ថ្វាយបង្គំព្រះសាស្តា ទូលនិមន្តថា បពិត្រព្រះអង្គដ៏ចម្រើន សូមទ្រង់ទទួលភិក្ខារបស់ខ្ញុំព្រះអង្គក្នុងថ្ងៃស្អែកនេះ ។ ព្រះសាស្តាត្រាស់ថា ម្នាលឧបាសក ភិក្ខុសង្ឃមានច្រើន ។ ឧបាសកទូលសួរថា ភិក្ខុសង្ឃមានប្រមាណប៉ុន្មាន ព្រះសាស្តាត្រាស់ថា មានភិក្ខុប្រមាណ ៦ លាន ៨ សែន ។*

ឧបាសកក្រាបទូលថា បពិត្រព្រះអង្គដ៏ចម្រើន សូមទ្រង់ទទួលភិក្ខារបស់ខ្ញុំព្រះអង្គ កុំឲ្យសេសសល់សូម្បីត្រឹមតែសាមណេរមួយរូប ។ ព្រះសាស្តាទ្រង់ទទួលនិមន្តហើយ ។ ឧបាសកដឹងថា ព្រះសាស្តាទ្រង់ទទួលនិមន្តហើយ ត្រឡប់ទៅផ្ទះ ត្រៀមនូវមហាទាន ក្នុងថ្ងៃស្អែកឡើង ប្រើមនុស្សទៅក្រាបទូលវេលាសោយភត្តាហារដល់ព្រះសាស្តា ។ ព្រះសាស្តា ទ្រង់កាន់បាត្រនិងចីវរ មានភិក្ខុសង្ឃចោមរោម យាងទៅកាន់ផ្ទះរបស់ឧបាសក គង់លើអាសនៈដែលគេក្រាលហើយ ក្នុងវេលាស្រេចការថ្វាយទឹកទក្ខិណោទក ទ្រង់ទទួលយាគូជាដើមហើយ ទ្រង់ផ្អាកការសោយភត្តាហារ ។ ឧបាសកក៏អង្គុយក្នុងទីជិតព្រះសាស្តា ។

ក្នុងរវាងនោះ ព្រះមហានិសភត្ថេរត្រាច់បិណ្ឌបាត បាននិមន្តទៅកាន់ផ្លូវនោះដូចគ្នា ។ ឧបាសកឃើញ ទើបក្រោកទៅថ្វាយបង្គំព្រះថេរៈ ហើយពោលថា បពិត្រលោកម្ចាស់ សូមលោកម្ចាស់ឲ្យបាត្រ ។ ព្រះថេរៈក៏ឲ្យបាត្រ ។ ឧបាសកពោលថា បពិត្រលោកម្ចាស់ សូមលោកម្ចាស់ ចូលទៅក្នុងទីនេះចុះ ព្រះសាស្តាក៏ប្រថាប់គង់ក្នុងផ្ទះ ។ ព្រះថេរៈពោលថា មិនគួរទេ ឧបាសក ។ ឧបាសកក៏កាន់បាត្ររបស់ព្រះថេរៈ ដាក់ពេញដោយបិណ្ឌបាត ហើយប្រគេន បន្ទាប់អំពីនោះ ឧបាសកនោះក៏តាមជូនដំណើរព្រះថេរៈ ហើយត្រឡប់មកអង្គុយជិតព្រះសាស្តា ក្រាបទូលយ៉ាងនេះថា បពិត្រព្រះអង្គដ៏ចម្រើន ព្រះមហានិសភត្ថេរ កាលខ្ញុំព្រះអង្គពោលថា សូម្បីព្រះសាស្តាក៏គង់ក្នុងផ្ទះ ដូច្នេះ ក៏មិនប្រាថ្នានឹងចូលមក ព្រះមហានិសភត្ថេរនេះ មានគុណក្រៃលែងជាង

គុណរបស់ព្រះអង្គឬ ធម្មតាវណ្ណមច្ឆរិយៈ ការកំណាញ់គុណ រមែងមិនមានដល់ព្រះពុទ្ធទាំងឡាយ ព្រោះហេតុនោះ ទើបព្រះសាស្ដាត្រាស់យ៉ាងនេះថា ម្នាលឧបាសក យើងទាំងឡាយ អង្គុយវង់ចាំភិក្ខាក្នុងផ្ទះ ភិក្ខុនោះមិនអង្គុយវង់ចាំភិក្ខាយ៉ាងនេះ យើងទាំងឡាយ នៅក្នុងសេនាសនៈក្បែរស្រុក ភិក្ខុនោះនៅតែក្នុងព្រៃប៉ុណ្ណោះ យើងទាំងឡាយ នៅក្នុងទីប្រក់បាំង ភិក្ខុនោះនៅតែក្នុងទីវាលប៉ុណ្ណោះ ។ ព្រះមានព្រះភាគ ត្រាស់គុណរបស់ព្រះនិសភត្ថេរថា គុណរបស់លោកបែបនេះ បែបនេះ ហាក់បីដូចធ្វើនូវមហាសមុទ្រឲ្យពេញ ។

ឯឧបាសក ជាអ្នកជ្រះថ្លាក្រៃលែង ដូចប្រទីបដែលឆេះសន្ធោសន្ធៅតាមប្រក្រតី ត្រូវស្រោចដោយប្រេង ដូច្នោះ ទើបគិតថា អញមិនត្រូវការដោយសម្បត្តិដទៃ បើដូច្នោះ អញនឹងធ្វើសេចក្ដីប្រាថ្នាដើម្បីភាពជាឯតទគ្គៈជាងភិក្ខុទាំងឡាយ ដែលទ្រទ្រង់នូវធុតង្គ និងប្រៀនប្រដៅក្នុងធុតង្គ ក្នុងសម្នាក់របស់ព្រះពុទ្ធអង្គណាមួយ ក្នុងអនាគតកាល កុលបុត្រនោះ ក៏និមន្តព្រះសាស្ដាម្ដងទៀត ហើយថ្វាយមហាទាន ដោយទំនងនោះឯង អស់ ៧ ថ្ងៃ ក្នុងថ្ងៃទី ៧ ថ្វាយត្រៃចីវរដល់មហាភិក្ខុសង្ឃ មានព្រះពុទ្ធជាប្រធាន ហើយក្រាបចុះទៀបបាទារបស់ព្រះសាស្ដា ក្រាបទូលយ៉ាងនេះថា បពិត្រព្រះដ៏ចម្រើន កាលខ្ញុំព្រះអង្គថ្វាយទានអស់ ៧ ថ្ងៃ ចូលទៅតាំងនូវមេត្តាកាយកម្ម មេត្តាវចីកម្ម មេត្តាមនោកម្មឯណា ដោយមេត្តាកាយកម្ម មេត្តាវចីកម្ម មេត្តាមនោកម្មនេះ ខ្ញុំព្រះអង្គមិនប្រាថ្នាសម្បត្តិដទៃ ជាទេវសម្បត្តិ ឬសក្កសម្បត្តិ មារសម្បត្តិ និងព្រហ្មសម្បត្តិទេ តែសូមឲ្យកម្មរបស់ខ្ញុំព្រះអង្គនេះ ជាអធិការ

ដើម្បីភាពជាកំពូលនៃភិក្ខុទាំងឡាយ ខាងទ្រទ្រង់ធុតង្គ ១៣ ដើម្បីបានតំណែងដែលព្រះមហានិសភត្ថេរបានហើយ ក្នុងសម្នាក់របស់ព្រះពុទ្ធមួយអង្គ ក្នុងអនាគតកាល ។ ព្រះសាស្តា ទ្រង់ប្រមើលមើលថា ឧបាសកនេះ ប្រាថ្នាតំណែងធំកន្លង នឹងសម្រេចឬហ្ន៎ ទ្រង់ឃើញថា សម្រេច ទើបត្រាស់ព្យាករថា អ្នកប្រាថ្នាតំណែងដែលជាទីត្រេកអរ ក្នុងអនាគតកាល ក្នុងទីបំផុតមួយសែនកប្ប ព្រះពុទ្ធព្រះនាមគោតមនឹងកើតឡើង អ្នកនឹងបានជាសាវកទី ៣ របស់ព្រះពុទ្ធអង្គនោះ នឹងជាបុគ្គលឈ្មោះថា មហាកស្សបត្ថេរ ឧបាសកបានស្តាប់ដូច្នោះ ទើបមនសិការថា ធម្មតាព្រះពុទ្ធទាំងឡាយ មិនមានព្រះតម្រាស់បែកជា ២ បានសម្គាល់ហាក់ដូចជាបានសម្បត្តិនោះក្នុងថ្ងៃស្អែក ។ កុលបុត្រនោះឲ្យទាន សមាទានសីល ហើយរក្សាជរាបដល់អស់អាយុ ធ្វើនូវបុញ្ញកម្មមានប្រការផ្សេងៗ ធ្វើកាលកិរិយាហើយ កើតក្នុងស្ថានសួគ៌ ។ ចាប់តាំងពីនោះ ឧបាសកនោះសោយសម្បត្តិក្នុងទេវតា និងមនុស្សទាំងឡាយ ក្នុងកប្បទី ៩១ អំពីកប្បនេះ កាលព្រះវិបស្សីសម្មាសម្ពុទ្ធយាងចូលទៅអាស្រ័យពន្ធុមតីនគរ ប្រថាប់នៅក្នុងខេមមិគទាយវ័ន កុលបុត្តនោះ ចុតិចាកទេវ-លោក មកកើតក្នុងត្រកូលព្រាហ្មណ៍ចាស់ជរាមួយ ។

ក្នុងកាលនោះ ព្រះមានព្រះភាគព្រះនាមវិបស្សី ត្រាស់នូវធម៌ក្នុងឆ្នាំទី ៧ មានកោលាហលយ៉ាងធំ ។ ពួកទេវតាក្នុងជម្ពូទ្វីបទាំងមូលប្រាប់គ្នាថា ព្រះសាស្តានឹងត្រាស់ធម៌ ។ ព្រាហ្មណ៍បានឮដំណឹងនោះដែរ ។ ព្រាហ្មណ៍នោះមានសំពត់សាដកសម្រាប់ស្លៀកមួយផ្ទាំង ព្រាហ្មណី ក៏មានសំពត់សាដក

សម្រាប់ស្លៀកមួយផ្ទាំងដូចគ្នា ។ ជនទាំង ២ មានសំពត់ដណ្ដប់តែមួយផ្ទាំងប៉ុណ្ណោះ ព្រាហ្មណ៍នោះក៏ប្រាកដក្នុងនគរទាំងមូលថា ឯកសាដកព្រាហ្មណ៍ ។

ព្រាហ្មណ៍នោះ កាលមានការប្រជុំពួកព្រាហ្មណ៍ ដោយកិច្ចឯណានីមួយ ឲ្យព្រាហ្មណីនៅផ្ទះ ចំណែកខ្លួនឯង ដណ្ដប់សំពត់មួយផ្ទាំងនោះទៅ ។ កាលមានការប្រជុំពួកព្រាហ្មណី ខ្លួនឯងក៏នៅក្នុងផ្ទះ ព្រាហ្មណីក៏ដណ្ដប់សំពត់នោះទៅ ។ ក្នុងថ្ងៃនោះ ព្រាហ្មណ៍នោះ ពោលនឹងព្រាហ្មណីថា នែនាងនាងស្ដាប់ធម៌ពេលយប់ ឬពេលថ្ងៃ ព្រាហ្មណីពោលថា ខ្ញុំជាមាតុគ្រាមមានជាតិជាអ្នកខ្លាច មិនអាចស្ដាប់ធម៌ក្នុងពេលយប់បាន ខ្ញុំនឹងស្ដាប់ក្នុងពេលថ្ងៃ ទើបឲ្យព្រាហ្មណ៍នោះនៅផ្ទះ ដណ្ដប់សំពត់នោះទៅវិហារ មួយអន្លើនឹងពួកឧបាសិកា ថ្វាយបង្គំព្រះសាស្ដាហើយ អង្គុយក្នុងចំណែកម្ខាង ស្ដាប់ធម៌ហើយ ត្រឡប់មកទៅជាមួយពួកឧបាសិកា ។ ពេលនោះ ទើបព្រាហ្មណ៍ឲ្យព្រាហ្មណីនៅផ្ទះ ហើយដណ្ដប់សំពត់នោះ ទៅវិហារ ។

សម័យនោះ ព្រះសាស្ដាទ្រង់គង់លើធម្មាសនៈ ដែលប្រដាប់តាក់តែងហើយ ក្នុងកណ្ដាលបរិស័ទ ទ្រង់ចាប់ផ្ចិតដ៏វិចិត្រ ត្រាស់ធម្មកថា ដូចធ្វើអាកាសគង្គាឲ្យធ្លាក់ចុះ និងដូចធ្វើភ្នំសិនេរុឲ្យជាត្បាល់កូរនូវសមុទ្រ ដូច្នោះ ។ កាលព្រាហ្មណ៍អង្គុយខាងចុងបរិស័ទស្ដាប់ធម៌ ក្នុងបឋមយាមនោះ បីតិមានពណ៌ ៥ ប្រការកើតឡើពេញរាងកាយ ។ កុលបុត្រនោះ ក៏បត់សំពត់ដែលដណ្ដប់ ហើយគិតថា នឹងថ្វាយដល់ព្រះទសពល ។ កាលនោះ សេចក្ដីកំណាញ់ដែលសម្ដែងទោសរាប់ពាន់ កើតដល់ព្រាហ្មណ៍នោះ ។ ព្រាហ្មណ៍

នោះ គិតថា ព្រាហ្មណី និងអញ មានសំពត់ដណ្តប់តែមួយប៉ុណ្ណោះ សំពត់ដណ្តប់ដទៃមិនមាន បើមិនដណ្តប់សំពត់ ក៏ត្រាច់ទៅខាងក្រៅបានមិនបាន ដូច្នេះ ទើបមិនចង់ថ្វាយសំពត់ដោយប្រការទាំងពួង ។ កាលបឋមយាមកន្លងទៅ ក្នុងមជ្ឈិមយាម បីតិក៏កើតដល់កុលបុត្រនោះយ៉ាងនោះឯង ។ កុលបុត្រនោះ គិតយ៉ាងនោះ មិនចង់ថ្វាយយ៉ាងនោះដូចគ្នា ។ កាលមជ្ឈិម-យាមកន្លងទៅ បីតិកើតឡើងដល់ព្រាហ្មណ៍នោះ សូម្បីក្នុងបច្ឆិមយាមក៏កើតបីតិយ៉ាងនោះឯង ។ ក្នុងកាលនោះ កុលបុត្រនោះ ឈ្នះសេចក្តីកំណាញ់ បត់សំពត់ហើយ ដាក់ទៀបព្រះបាទារបស់ព្រះសាស្តា បន្ទាប់អំពីនោះ ទើបលើកដៃច្វេង យកដៃស្តាំទះ ៣ ដងព្រមទាំងពោលថា **ជិតំ មេ ជិតំ មេ** ខ្ញុំឈ្នះហើយ ខ្ញុំឈ្នះហើយ ។

សម័យនោះ ព្រះបាទពន្ធុមរាជប្រថាប់គង់ស្តាប់ធម៌ ខាងក្នុងវាំងននក្រោយធម្មាសនៈ ធម្មតាព្រះរាជាទ្រង់មិនពេញចិត្តនឹងសំឡេងថា **ជិតំ មេ** ខ្ញុំឈ្នះហើយ ។ ព្រះរាជាក៏បញ្ជូនរាជបុរសទៅថា នែអ្នក ចូរអ្នកទៅសួរព្រាហ្មណ៍នោះថា ព្រាហ្មណ៍ពោលអ្វី ។ ព្រាហ្មណ៍កាលត្រូវបុរសនោះមកសួរ ទើបប្រាប់ថា មនុស្សដទៃៗ ដែលឡើងយាន គឺដំរីជាដើម កាន់ដាវនិងខែលជាដើម យកឈ្នះសេនារបស់សត្រូវដទៃ សេចក្តីនោះ មិនគួរអស្ចារ្យ ចំណែកខ្ញុំឈ្នះចិត្តកំណាញ់ បានថ្វាយសំពត់ដណ្តប់ដល់ព្រះទសពល ដូចបុគ្គលយកដំបងវាយក្បាលគោកាច ដែលដើរតាមពីក្រោយ ធ្វើឲ្យវាគេចទៅដូច្នោះ ។ កាលដែលខ្ញុំយកឈ្នះសេចក្តីកំណាញ់ បានជាវត្ថុគួរអស្ចារ្យ ។

បុរសនោះ ក៏ត្រឡប់មកក្រាបទូលរឿងនោះដល់ព្រះរាជា ។ ព្រះរាជាត្រាស់ថា នែអ្នក យើងទាំងឡាយ មិនដឹងថា វត្ថុណា សមគួរដល់ព្រះទសពល ព្រាហ្មណ៍ដឹង ។ ទ្រង់ជ្រះថ្លាក្នុងព្រាហ្មណ៍នោះ ទើបបញ្ជូនសំពត់ទៅឲ្យមួយគូ ។

ព្រាហ្មណ៍ឃើញដូច្នោះ គិតថា ដំបូង កាលអញអង្គុយស្ងៀមៗ ព្រះរាជាមិនព្រះរាជប្រទានរបស់ណាមួយ កាលអញពោលគុណទាំងឡាយរបស់ព្រះសាស្តា ទើបព្រះរាជទាន សំពត់គូនេះកើតឡើង ព្រោះគុណទាំងឡាយរបស់ព្រះសាស្តា ទើបសមគួរដល់ព្រះសាស្តាប៉ុណ្ណោះ កាលគិតហើយ បានថ្វាយគូសំពត់នោះដល់ព្រះទសពល ព្រះរាជាត្រាស់សួរថា ព្រាហ្មណ៍ធ្វើអ្វី ទ្រង់ស្តាប់ថា គាត់ថ្វាយគូសំពត់នោះដល់ព្រះតថាគតទៀត ទើបបញ្ជូនសំពត់ ២ គូទៅឲ្យ ។ ព្រាហ្មណ៍ក៏បានថ្វាយគូសំពត់នោះ ដល់ព្រះសាស្តាទៀត ។ ព្រះរាជាទ្រង់បញ្ជូនសំពត់ ៤ គូដទៃទៀតទៅឲ្យ រួមសេចក្តីថា ត្រាស់យ៉ាងនោះហើយ ទ្រង់ឲ្យបញ្ជូនគូសំពត់ទៅឲ្យរហូតដល់ ៣២ គូ ។

លំដាប់នោះ ព្រាហ្មណ៍គិតថា ការធ្វើដូច្នេះនឹងបន្ថែមច្រើនឡើងៗ ទើបទទួលយក គឺទទួលយកសំពត់ ២ គូ ១ គូដើម្បីខ្លួន ១ គូដើម្បីព្រាហ្មណី ហើយបានថ្វាយចំពោះព្រះតថាគត ៣០ គូ តាំងអំពីនោះ ព្រាហ្មណ៍នោះក៏ជាអ្នកស្និទ្ធស្នាលនឹងព្រះសាស្តា ។

ថ្ងៃមួយ ក្នុងរដូវរងា ព្រះរាជាទ្រង់ទតឃើញព្រាហ្មណ៍នោះ ស្តាប់ធម៌ក្នុងសម្នាក់របស់ព្រះសាស្តា ទើបព្រះរាជទានសំពត់កម្ពលក្រហម ដែលមាន

តម្លៃ ១០០០០ ដែលទ្រង់ដណ្ដប់ ឲ្យព្រាហ្មណ៍ ហើយត្រាស់ថា តាំងអំពីនេះទៅ ចូរអ្នកដណ្ដប់សំពត់កម្ពលនេះស្ដាប់ធម៌ ព្រាហ្មណ៍គិតថា ប្រយោជន៍អ្វីសម្រាប់អញដែលប្រើសំពត់កម្ពលនេះ ដណ្ដប់កាយស្អុយនេះ ទើបធ្វើជាពិតានខាងលើគ្រែរបស់ព្រះតថាគត ខាងក្នុងព្រះគន្ធកុដិ ហើយទៅ ។

ថ្ងៃមួយ ព្រះរាជាយាងទៅកាន់ព្រះវិហារអំពីព្រលឹម គង់ប្រថាប់ក្នុងសម្នាក់របស់ព្រះសាស្ដា ខាងក្នុងព្រះគន្ធកុដិ ខណៈនោះ ព្រះពុទ្ធរស្មី មានពណ៌ ៦ ប៉ះត្រង់សំពត់កម្ពល សំពត់កម្ពលក៏មានពណ៌ល្អក្រៃលែង ព្រះរាជាទ្រង់សម្លឹងមើល ទ្រង់ស្គាល់ ទើបត្រាស់ថា បពិត្រព្រះអង្គដ៏ចម្រើននេះសំពត់កម្ពល របស់ដែលខ្ញុំព្រះអង្គឲ្យដល់ឯកសាដកព្រាហ្មណ៍ ព្រះសាស្ដាត្រាស់ថា មហាបពិត្រ ទ្រង់បូជាព្រាហ្មណ៍ ព្រាហ្មណ៍បូជាតថាគត ។

ព្រះរាជាទ្រង់ព្រះតម្រិះថា ព្រាហ្មណ៍ដឹងវត្ថុដែលគួរ អញមិនដឹង ទើបទ្រង់ជ្រះថ្លា ទ្រង់បែងចែកវត្ថុដែលជាប្រយោជន៍ ដល់ពួកមនុស្សជា ៨ ពួកមួយពួក ៨ មុខ ទ្រង់ឲ្យទាន ឈ្មោះថា សព្វដ្ឋកទាន ហើយទ្រង់តាំងព្រាហ្មណ៍ទុកក្នុងតំណែងបុរោហិត ។ ឯព្រាហ្មណ៍នោះរៀបចំសលាកភត្ត ៦៤ សម្រាប់ គឺមួយមុខ ៨ សម្រាប់ ជា ៦៤ សម្រាប់ ហើយឲ្យទាន រក្សាសីលដរាបដល់អស់ជីវិត ចុតិចាកអត្តភាពនោះហើយ កើតក្នុងស្ថានសួគ៌ ។

បន្ទាប់មក ចុតិចាកស្ថានសួគ៌នោះ ក្នុងកប្បនេះ កើតក្នុងត្រកូលកុដុម្ពិកៈក្នុងនគរពារាណសី ចន្លោះព្រះពុទ្ធ ២ អង្គ គឺព្រះមានព្រះភាគ ព្រះនាមកោនាមគនៈ និងព្រះមានព្រះភាគព្រះនាមកស្សបៈ ។ កុលបុត្រនោះ ចម្រើន

វិយនៅគ្រប់គ្រងផ្ទះ ថ្ងៃមួយ ត្រាច់លេងក្នុងព្រៃ ។ សម័យនោះ ព្រះបច្ចេកសម្ពុទ្ធ ធ្វើការដេរចីវរត្រង់ឆ្នេរស្ទឹង កាលសំពត់អនុវាតមិនគ្រប់គ្រាន់ ទើបផ្ដើមបត់ទុក ។ កុលបុត្រនោះឃើញដូច្នោះ ទើបពោលថា លោកម្ចាស់ដ៏ចម្រើន ព្រោះហេតុអ្វី ទើបលោកម្ចាស់បត់ទុក ព្រះបច្ចេកសម្ពុទ្ធពោលថា សំពត់អនុវាតមិនគ្រប់គ្រាន់ ទើបកុលបុត្រនោះពោលថា បពិត្រលោកម្ចាស់ សូមលោកម្ចាស់ធ្វើដោយសំពត់នេះ ហើយប្រគេនសំពត់ដណ្ដប់ បានតាំងសេចក្ដីប្រាថ្នាថា សេចក្ដីវិនាសណាមួយ កុំបីមានដល់ខ្ញុំ ក្នុងទីដែលកើតហើយ ។

កាលភរិយា និងប្អូនស្រីបង្កូនវដម្មោះ ព្រះបច្ចេកពុទ្ធចូលទៅបិណ្ឌបាតក្នុងផ្ទះរបស់កុលបុត្រនោះ ។ កាលនោះ ប្អូនស្រីរបស់កុលបុត្រនោះ បានថ្វាយបិណ្ឌបាតដល់ព្រះបច្ចេកសម្ពុទ្ធ តាំងសេចក្ដីប្រាថ្នាសំដៅដល់ភរិយារបស់កុលបុត្រនោះថា ខ្ញុំគប្បីនៅឆ្ងាយស្រីពាលនេះ ១០០ យោជន៍ ។ នាងឈរត្រង់លានផ្ទះ បានឮ ទើបគិតថា ព្រះបច្ចេកសម្ពុទ្ធ សូមកុំបរិភោគភត្តដែលស្រីនេះថ្វាយ ទើបកញ្ឆក់យកបាត្រ ចាក់ភត្តចោល ហើយយកភក់ដាក់ឲ្យពេញប្រគេន ។ ប្អូនស្រីរបស់កុលបុត្រនោះឃើញ ទើបពោលថា នែស្រីពាល នាងជេរ ឬប្រហារខ្ញុំ ក៏តាមចិត្តចុះ មិនគួរចាក់ភត្តអំពីបាត្ររបស់ព្រះបច្ចេកសម្ពុទ្ធ ដែលបានបំពេញបារមីមក ២ អសង្ខេយ្យបែបនេះ ហើយយកភក់ដាក់ជំនួសឡើយ ។

កាលនោះ ភរិយារបស់កុលបុត្រនោះ បាននូវស្មារតី ទើបពោលថា

សូមលោកម្ចាស់មេត្តាឈប់សិន ហើយចាក់កក់ចោល លាងបាត្រ ខាត់ដោយគ្រឿងប្រអប់ ដាក់កត្តដ៏ប្រណីត និងដោយមធុរស ៤ យ៉ាង[១] រហូតពេញ ហើយដាក់បាត្រដែលចាំងចែងដោយសប្បិ មានពណ៌ដូចត្របកបទុមអំពីខាងលើ ដាក់ក្នុងដៃរបស់ព្រះបច្ចេកសម្ពុទ្ធ បានធ្វើសេចក្តីប្រាថ្នាថា បិណ្ឌបាតនេះកើតនូវពន្លឺ យ៉ាងណា រាងកាយរបស់ខ្ញុំ សូមមានពន្លឺយ៉ាងនោះចុះ ព្រះបច្ចេកសម្ពុទ្ធអនុមោទនាហើយ ហោះឡើងទៅកាន់អាកាស ។

ជនទាំង ២ គឺស្វាមី និងភរិយានោះ តាំងនៅដរាបដល់អស់អាយុ ចុតិចាកអត្តភាពនោះហើយ កើតក្នុងស្ថានសួគ៌ ។ ចុតិអំពីស្ថានសួគ៌នោះ កើតជាឧបាសកក្នុងត្រកូលដែលសម្បូរដោយសម្បត្តិ ៨០ កោដិ ក្នុងពារាណសីនគរ ក្នុងកាលនៃព្រះកស្សបសម្មាសម្ពុទ្ធ ។ ឯភរិយាកើតជាធីតារបស់សេដ្ឋីមានសម្បត្តិដូចគ្នា ។ លុះចម្រើនវ័យហើយ មាតាបិតាក៏នាំសេដ្ឋីធីតានោះមកជាភរិយា ។ ដោយអានុភាពនៃកម្មដ៏លាមក ដែលមានវិបាកមិនគួរប្រាថ្នាក្នុងជាតិមុន គ្រាន់តែនាងចូលទៅកាន់ត្រកូលស្វាមី ផ្ទះទាំងមូល តាំងអំពីធរណីទ្វារទៅ ក៏មានក្លិនស្អុយ ដូចបើករណ្តៅលាមកចេញ ។ កុមារសួរថា នេះក្លិនរបស់អ្នកណា បានស្តាប់ថា ជាក្លិនសេដ្ឋីធីតា ទើបពោលថា ចូរនាំចេញទៅ ហើយបញ្ជូនទៅកាន់ផ្ទះត្រកូលរបស់នាងមួយរំពេច នាងត្រឡប់ទៅ ត្រឡប់មក ដោយទំនងនោះឯង អស់ ៧ ដង ។

សម័យនោះ ព្រះកស្សបទសពលបរិនិព្វានហើយ ជនទាំងឡាយ

---

១- មធុរស ៤ យ៉ាង គឺទធិ ១ ទឹកឃ្មុំ ១ សប្បិ ១ ដុំស្ករអំពៅ ១ ។

កសាងចេតិយរបស់ព្រះអគ្គ កម្ពស់មួយយោជន៍ដោយឥដ្ឋមាស ដែលមានតម្លៃមួយសែន ។ កាលគេកំពុងនាំគ្នាសាងចេតិយនោះ ធីតាសេដ្ឋីនោះ គិតថា អញត្រឡប់ហើយ ៧ ដង ប្រយោជន៍អ្វីដោយការរស់នៅ ទើបឲ្យជុំគ្រឿងប្រដាប់របស់ខ្លួនធ្វើជាឥដ្ឋមាស បណ្តោយ ១ ហត្ថ ទទឹង ១ ចំអាមកម្រាស់ ៤ ធ្នាប់ ។ បន្ទាប់អំពីនោះ ទើបកាន់យកដុំហរតាល និងមនោសិលា ហើយកាន់យកផ្កាឧប្បល ៨ ក្តាប់ ទៅកាន់ទីធ្វើព្រះចេតិយ ។ ខណៈនោះ ជួររបស់ឥដ្ឋមួយដុំដែលតម្រៀបមក ខ្វះឥដ្ឋសម្រាប់តមួយដុំ ទើបស្រេច ។ ធីតាសេដ្ឋីក៏ពោលនឹងមេជាងថា សូមលោកដាក់ឥដ្ឋរបស់ខ្ញុំមួយដុំនេះ ក្នុងទីនេះ ។ នាយជាងពោលថា អើ នាង នាងមកទាន់ពេលល្មម ចូរនាងដាក់ដោយខ្លួនឯងចុះ ។ ទើបនាងឡើងទៅ យកប្រេងលាយនឹងកម្ទេចហរតាល និងមនោ-សិលា ហើយបិទភ្ជាប់នឹងឥដ្ឋជាគ្រឿងភ្ជាប់ភ្ជិត ហើយធ្វើការបូជាដោយផ្កាឈូក ៨ ក្តាប់ ខាងលើឥដ្ឋនោះ ថ្វាយបង្គំហើយ ធ្វើសេចក្តីប្រាថ្នាថា ក្នុងទីដែលខ្ញុំកើតហើយ សូមក្លិនខ្លឹមចន្ទន៍ផ្សាយចេញអំពីកាយរបស់ខ្ញុំ សូមក្លិនឧប្បលផ្សាយចេញអំពីមាត់ ស្រេចហើយ ថ្វាយបង្គំព្រះចេតិយ ធ្វើប្រទក្សិណហើយ ត្រឡប់ទៅផ្ទះ ។

ខណៈនោះឯង សេដ្ឋីបុត្តដែលនាំនាងទៅកាន់ផ្ទះក្នុងកាលមុន នឹកភ្នកដល់នាង ។ ក្នុងនគរ មានការប្រកាសនក្ខត្តឫក្ស ។ សេដ្ឋីបុត្រនោះ ពោលនឹងអ្នកបម្រើថា ធីតាសេដ្ឋីដែលនាំមកក្នុងទីនេះ នៅឯណា ។ ពួកបម្រើពោលថា នៅឯផ្ទះរបស់ត្រកូល ។ សេដ្ឋីបុត្រពោលថា ចូរពួកអ្នកនាំនាង

មក យើងនឹងលេងនក្ខត្តឫក្ស អ្នកបម្រើទាំងនោះទៅដល់សំពះនាង ហើយឈរ កាលនាងសួរថា នែអ្នកទាំងឡាយ ពួកអ្នកមកធ្វើអ្វី ទើបនាំគ្នាប្រាប់ការមកឲ្យនាងជ្រាប នាងពោលថា អ្នកទាំងឡាយ ខ្ញុំយកគ្រឿងប្រដាប់បូជាព្រះចេតិយហើយ ខ្ញុំមិនមានគ្រឿងប្រដាប់ អ្នកបម្រើទាំងនោះក៏ត្រឡប់ទៅប្រាប់ដល់សេដ្ឋីបុត្រ ។ សេដ្ឋីបុត្រពោលថា ចូរពួកអ្នកនាំនាងមកចុះ នាងនឹងបានគ្រឿងប្រដាប់ ។ អ្នកបម្រើទាំងនោះក៏នាំនាងមក ដំណាលគ្នានឹងនាងចូលកាន់ផ្ទះ ក្លិនខ្លឹមចន្ទន៍ និងក្លិនឧប្បលផ្សាយទៅពេញផ្ទះ ។ សេដ្ឋីបុត្រសួរនាងថា នាងដ៏ចម្រើន ដំបូង ក្លិនស្អុយផ្សាយចេញអំពីរាងកាយរបស់នាង តែឥឡូវនេះ ក្លិនចន្ទន៍ផ្សាយចេញអំពីកាយរបស់នាង ក្លិនឧប្បលផ្សាយចេញអំពីមាត់ តើមានរឿងអ្វី នាងក៏ប្រាប់កម្មដែលខ្លួនធ្វើតាំងអំពីដើម ។ សេដ្ឋីបុត្រក៏គិតថា ព្រះពុទ្ធសាសនា ជាគ្រឿងនាំចេញចាកទុក្ខហ្ន៎ ទើបជ្រះថ្លា ឲ្យយកសំពត់ធ្វើជាសំពត់ដណ្តប់ចេតិយមាស ដែលមានកម្ពស់ ១ យោជន៍ ហើយបានប្រដាប់ដោយផ្កាឈូកមាស ទំហំប៉ុនកង់រថក្នុងទីនោះៗ ផ្កាឈូកមាស ( នោះ ) ដែលសំយុងចុះមកប្រមាណ ១២ ហត្ថ ។

សេដ្ឋីបុត្រនោះ តាំងនៅក្នុងអត្តភាពនោះដរាបដល់អស់អាយុ ច្យុតិចាកអត្តភាពនោះ កើតក្នុងស្ថានសួគ៌ ច្យុតិចាកស្ថានសួគ៌នោះទៀត មកកើតក្នុងត្រកូលអមាត្យមួយ ឆ្ងាយអំពីនគរពារាណសី ប្រមាណ ១ យោជន៍ ។ ឯភរិយារបស់គេ ច្យុតិអំពីទេវលោក មកកើតជារាជធីតាទោលក្នុងរាជត្រកូល កាលជនទាំង ២ នោះ ដល់នូវការចម្រើនវ័យហើយ គេប្រកាសលេង

នក្ខត្តឫក្ស ក្នុងស្រុកដែលកុមារនៅ ។ កុមារនោះពោលនឹងមាតាថា បពិត្រអ្នកម៉ែ សូមម៉ែឲ្យសំពត់សាដកដល់ខ្ញុំមួយផ្ទាំង ខ្ញុំនឹងលេងនក្ខត្តឫក្ស ។ មាតាក៏បាននាំសំពត់ដែលបោកហើយមកឲ្យ កុមារពោលថា បពិត្រអ្នកម៉ែ សំពត់នេះគ្រោតគ្រាត ទើបមាតានាំសំពត់ដទៃមកឲ្យ ។ សំពត់ផ្ទាំងនោះ ក៏កុលបុត្រនោះបដិសេធ គ្រានោះ មាតាក៏ពោលថា នែកូន ពួកយើងកើតក្នុងផ្ទះបែបនេះ ពួកយើងមិនមានបុណ្យ ដើម្បីបានសំពត់សាច់ម៉ដ្ឋជាងនេះ កុមារពោលថា បពិត្រអ្នកម៉ែ បើយ៉ាងនោះ ខ្ញុំក៏នឹងទៅកាន់ទីដែលនឹងបាន ។ មាតាពោលថា នែកូន ម៉ែចង់ឲ្យកូនបានរាជសម្បត្តិ ក្នុងនគរពារាណសីក្នុងថ្ងៃនេះឯង ។ កុមារថ្វាយបង្គំមាតាហើយ ពោលថា ខ្ញុំទៅហើយ មាតាពោលថា នែកូន ទៅចុះ កុមារនោះចេញអំពីផ្ទះ ទៅតាមកំណត់នៃបុណ្យដល់នគរពារាណសីហើយ ដេកទទូរលើផ្ទាំងថ្មដែលជាមង្គលក្នុងឧទ្យាននោះ ។ ថ្ងៃនោះ ជាថ្ងៃទី ៧ ដែលព្រះបាទពារាណសីសោយទិវង្គត ។

អមាត្យទាំងឡាយ ធ្វើនូវការថ្វាយព្រះភ្លើងហើយ អង្គុយត្រង់លានព្រះរាជវាំង ប្រឹក្សាគ្នាថា ព្រះរាជាមានតែធីតាមួយអង្គ មិនមានព្រះរាជឱរសរាជសម្បត្តិដែលមិនមានព្រះរាជានឹងវិនាស អ្នកណាគួរជាព្រះរាជា ។ ពួកអមាត្យពោលថា គឺលោកៗ ។ បុរោហិតពោលថា កុំពិចារណាច្រើន ពួកយើងនឹងផ្សងបុស្សរថ ។ អមាត្យទាំងនោះ ក៏ទឹមសេះសិន្ធព ៤ មានពណ៌ដូចផ្កាកោមុទ ហើយដាក់រាជកកុធភណ្ឌ ៥ យ៉ាង និងស្វេតច្ឆត្រ លើបុស្សរថនោះ ហើយលែងរថទៅ ឲ្យប្រគំតន្ត្រីតាមក្រោយ រថចេញតាមទ្វារទិសខាង

កើតបែរមុខទៅកាន់ឧទ្យាន ។ អមាត្យពួកខ្លះពោលថា រថបែរមុខទៅកាន់ឧទ្យាន ព្រោះសេចក្តីស្និទ្ធស្នាល ចូរពួកយើងឲ្យរថត្រឡប់ ។ បុរោហិតពោលថា ពួកលោកកុំឲ្យរថត្រឡប់ឡើយ ។ រថធ្វើប្រទក្សិណកុមារ ហើយឈប់ ធ្វើអាការនឹងឲ្យកុមារឡើង ហើយតាំងនៅ ។ បុរោហិតវែកជាយសំពត់ដណ្តប់ ពិនិត្យមើលបាតជើង ពោលថា ទ្វីបនេះ ចូរស្ទះទុក បុគ្គលនេះ សមគួរគ្រងរាជសម្បត្តិក្នុងមហាទ្វីបទាំង ៤ មានទ្វីបតូច ២០០០ ជាបរិវារ ហើយពោលថា អ្នកទាំងឡាយ ចូរប្រគំតន្ត្រី ហើយឲ្យប្រគំតន្ត្រី ៣ ដង ។

លំដាប់នោះ កុមារបើកមុខសម្លឹងមើល ពោលថា អ្នកទាំងឡាយនាំគ្នាមកដោយកិច្ចអ្វី ។ អមាត្យទាំងឡាយពោលថា បពិត្រទេវៈ រាជសម្បត្តិដល់ព្រះអង្គហើយ ។ កុមារពោលថា ព្រះរាជាពួកអ្នកទៅណា ពួកអមាត្យពោលថា ព្រះរាជាយាងទៅកាន់ភាពជាទេវតាហើយ ។ កុមារពោលថា ទ្រង់សោយទិវង្គតប៉ុន្មានថ្ងៃហើយ ។ អមាត្យពោលថា ថ្ងៃនេះជាថ្ងៃទី ៧ កុមារពោលថា ព្រះឱរស ឬព្រះធីតាមិនមានទេឬ ។ ពួកអមាត្យពោលថា បពិត្រទេវៈ មានតែព្រះរាជធីតា ព្រះរាជឱរសមិនមានឡើយ កុមារពោលថា បើយ៉ាងនោះ យើងនឹងគ្រប់គ្រងរាជសម្បត្តិ ។ អមាត្យទាំងនោះ ក៏ឲ្យសាងមណ្ឌបសម្រាប់អភិសេកក្នុងវេលានោះ ហើយប្រដាប់តាក់តែងព្រះរាជធីតាដោយគ្រឿងអលង្ការទាំងពួង នាំទៅកាន់ឧទ្យាន បានធ្វើការអភិសេកដល់កុមារ ។ លំដាប់នោះ អមាត្យទាំងឡាយ ក៏នាំសំពត់ដែលមានតម្លៃមួយសែន

ចូលទៅដើម្បីកុមារដែលធ្វើការអភិសេកហើយ ។ ព្រះរាជកុមារត្រាស់ថា អ្នកទាំងឡាយ នេះជាអ្វី ពួកអមាត្យក្រាបទូលថា បពិត្រព្រះសម្មតិទេព នេះសំពត់សម្រាប់ស្លៀក ព្រះរាជកុមារត្រាស់ថា បាទាំងឡាយ សំពត់នេះសាច់គ្រោតគ្រាត មិនមែនឬ ពួកអមាត្យក្រាបទូលថា បពិត្រព្រះសម្មតិទេព បណ្តាសំពត់សម្រាប់ប្រើប្រាស់របស់មនុស្ស សំពត់ដែលមានសាច់ទន់ជាងនេះ មិនមាន ព្រះរាជកុមារពោលថា ព្រះរាជារបស់អ្នកទាំងឡាយ ទ្រង់ស្លៀកសំពត់បែបនេះឬ ។ ពួកអមាត្យក្រាបទូលថា ករុណាថ្លៃវិសេស ព្រះរាជកុមារត្រាស់ថា ព្រះរាជារបស់អ្នកទាំងឡាយ ប្រហែលជាមិនមានបុណ្យហើយឲ្យនាំឃ្លោកមាសមក ដោយព្រះតម្រាស់ថា ចូរអ្នកទាំងឡាយ នាំព្រះសុវណ្ណភិង្គាមក យើងនឹងបានសំពត់ ហើយទ្រង់ក្រោកឡើង លាងព្រះហស្តខ្ពុរព្រះឱស្ឋ យកព្រះហស្តជួសទឹកបាចទៅទិសខាងកើត ដើមកប្បព្រឹក្ស ៨ ដើម ជ្រែកផែនដីដ៏រឹងផុសឡើង ។ ទ្រង់ជួសទឹក ប្រោះទៅទិសខាងត្បូង ទិសខាងលិច និងទិសខាងជើងទៀត រួមសេចក្តីថា ទ្រង់ប្រោះទៅទិសទាំង ៤ ដើមកប្បព្រឹក្ស ៣២ ដើមផុសឡើងគ្រប់ទិស មួយទិស ៨ ដើម ។ ព្រះរាជកុមារនោះ ទ្រង់ស្លៀកសំពត់ទិព្វមួយផ្ទាំង ទ្រង់ដណ្តប់មួយផ្ទាំង ហើយត្រាស់ថា ចូរអ្នកទាំងឡាយ ត្រាច់វាយស្គរប្រកាសយ៉ាងនេះថា ក្នុងដែនរបស់ព្រះបាទនន្ទរាជ ស្ត្រីទាំងឡាយអ្នករវៃអំបោះ កុំរវៃអំបោះឡើយ ហើយឲ្យលើកឆត្រ ប្រដាប់តាក់តែងព្រះអង្គហើយ ប្រថាប់គង់លើគជីវដ៏ប្រសើរយាងចូលកាន់ព្រះនគរ ឡើងកាន់ប្រាសាទសោយមហាសម្បត្តិ ។

ពេលវេលាប្រព្រឹត្តទៅយ៉ាងនេះ ព្រះទេវីឃើញសម្បត្តិរបស់ព្រះរាជាហើយ ព្រះនាងសម្តែងអាការដោយករុណាថា ឱ ! គួរអាណិតហ្ន៎ លោកអ្នកមានតបៈ ព្រះរាជាត្រាស់សួរថា នែព្រះទេវី តើនាងនិយាយអ្វី ទើបក្រាបទូលថា បពិត្រព្រះសម្មតិទេព សម្បត្តិរបស់ទ្រង់ធំក្រៃលែង ជាផលនៃកល្យាណកម្ម ដែលទ្រង់ជឿព្រះពុទ្ធទាំងឡាយ ហើយបានធ្វើក្នុងអតីត តែឥឡូវនេះ ទ្រង់មិនធ្វើបុណ្យ ដែលជាបច្ច័យដល់អនាគត ព្រះរាជាត្រាស់ថា យើងនឹងឲ្យដល់អ្នកណា បើអ្នកមានសីលមិនមាន ។ ព្រះទេវីក្រាបទូលថា បពិត្រព្រះសម្មតិទេព ជម្ពូទ្វីប មិនសាបសូន្យចាកព្រះអរហន្តទាំងឡាយឡើយ សូមទ្រង់ត្រៀមទាន ខ្ញុំម្ចាស់នឹងបានព្រះអរហន្ត ។

ស្អែកឡើង ព្រះរាជាទ្រង់ឲ្យត្រៀមទានត្រង់ទ្វារទិសខាងកើត ។ ព្រះទេវីទ្រង់អធិដ្ឋានអង្គឧបោសថអំពីព្រលឹម ក្រាបបែរមុខទៅកាន់ទិសខាងកើតក្នុងប្រាសាទជាន់លើ ហើយពោលថា បើព្រះអរហន្តទាំងឡាយ មានក្នុងទិសនេះ ស្អែកនេះ សូមមកទទួលកិច្ចារបស់ពួកខ្ញុំទាំងឡាយផងចុះ ។ ក្នុងទិសនោះ មិនមានព្រះអរហន្ត ទើបឲ្យសក្ការៈនោះដល់មនុស្សកំព្រា និងយាចកទាំងឡាយ ។

ស្អែកឡើង ទ្រង់ត្រៀមទានត្រង់ទ្វារទិសខាងត្បូង ក៏មិនបានទក្ខិ-ណេយ្យបុគ្គលយ៉ាងនោះឯង ។ ស្អែកឡើង ទ្រង់ត្រៀមទាន ត្រង់ទ្វារទិសខាងលិច ក៏មិនបានទក្ខិណេយ្យបុគ្គលយ៉ាងនោះដូចគ្នា តែក្នុងថ្ងៃដែលត្រៀមត្រង់ទ្វារទិសខាងជើង កាលព្រះទេវីនិមន្តយ៉ាងនោះឯង ព្រះមហាបទុមបច្ចេក-

សមុទ្ទ ជាបងប្រុសរបស់ព្រះបច្ចេកសមុទ្ទ ៥០០ អង្គ ជាឱរសរបស់ព្រះនាងបទុមវតី ដែលនៅក្នុងហិមវន្តប្បទេស ហៅព្រះបច្ចេកសមុទ្ទដែលជាប្អូនប្រុសមកថា លោកនិទ៌ុក្ខទាំងឡាយ ព្រះបាទនន្ទរាជ និមន្តលោកទាំងឡាយ ចូរលោកទាំងឡាយទទួលនិមន្តរបស់ព្រះរាជាចុះ ព្រះបច្ចេកសមុទ្ទទាំងនោះទទួលនិមន្តហើយ ស្អែកឡើង លុបមុខត្រង់អនោតត្តស្រះ ហើយហោះមកតាមអាកាស ចុះត្រង់ទ្វារទិសខាងជើង ។ មនុស្សទាំងឡាយឃើញហើយទើបទៅក្រាបទូលដល់ព្រះរាជាថា បពិត្រព្រះសម្មតិទេព ព្រះបច្ចេកសមុទ្ទ ៥០០ អង្គនិមន្តមកហើយ ។

ព្រះរាជា មួយអន្លើដោយព្រះទេវី នាំគ្នាទៅថ្វាយបង្គំ ហើយនិមន្តឡើងកាន់ប្រាសាទ ថ្វាយទានដល់ព្រះបច្ចេកសមុទ្ទទាំងនោះក្នុងប្រាសាទ ក្នុងវេលាស្រេចភត្តកិច្ច ព្រះរាជាទ្រង់ក្រាបចុះទៀបបាតជើងរបស់ព្រះសង្ឃត្ថេរ ព្រះទេវីក្រាបចុះទៀបបាតជើងរបស់ព្រះសង្ឃនវក ហើយត្រាស់ថា បពិត្រលោកម្ចាស់ដ៏ចម្រើន លោកម្ចាស់ទាំងឡាយ កុំលំបាកដោយបច្ច័យឡើយ យើងខ្ញុំទាំងឡាយ កុំបីសាបសូន្យចាកបុណ្យ សូមលោកម្ចាស់ទាំងឡាយឲ្យប្តេជ្ញាដល់យើងខ្ញុំ ដើម្បីនៅក្នុងទីនេះ ដរាបដល់អស់អាយុ ឲ្យព្រះបច្ចេកសមុទ្ទទាំងនោះ ធ្វើប្តេជ្ញាហើយ ធ្វើនូវទីអាស្រ័យប្រគេន មួយអន្លើដោយរបស់គ្រប់យ៉ាង គឺបណ្ណសាលា ៥០០ ទីចង្ក្រម ៥០០ ក្នុងព្រះរាជឧទ្យាន ហើយនិមន្តឲ្យនៅក្នុងទីនោះ ។

ពេលវេលាកន្លងទៅយ៉ាងនេះ កាលបច្ចន្តជនបទរបស់ព្រះរាជាកើត

ចលាចល ព្រះរាជាត្រាស់ថា យើងនឹងទៅបង្រ្កាបបច្ចន្តជនបទឲ្យស្ងប់រម្ងាប់ នាងកុំប្រមាទក្នុងព្រះបច្ចេកសម្ពុទ្ធទាំងឡាយ ទ្រង់ទូន្មានព្រះទេវីហើយ យាងទៅ ។ កាលព្រះរាជាមិនទាន់ត្រឡប់មក អាយុសង្ខាររបស់ព្រះបច្ចេកសម្ពុទ្ធក៏អស់ទៅ ។ ព្រះបច្ចេកសម្ពុទ្ធទាំងអស់នោះឯង បរិនិព្វាន ដោយប្រការដូច្នេះ គឺព្រះមហាបទុមបច្ចេកសម្ពុទ្ធ លេងឈានអស់យាម ៣ នៃរាត្រី ក្នុងពេលទៀបភ្លឺ បានឈរគោងបន្ទះក្តារសម្រាប់ផ្អែក បរិនិព្វានដោយអនុបាទិសេសនិព្វានធាតុ ឯព្រះបច្ចេកសម្ពុទ្ធទាំងឡាយដ៏សេស ក៏បរិនិព្វានដោយឧបាយនោះ ។ ស្អែកឡើង ព្រះទេវីរៀបចំទីអង្គុយសម្រាប់ព្រះបច្ចេកសម្ពុទ្ធទាំងឡាយ ហើយរោយផ្កាអប់នូវធូប ប្រថាប់គង់រង់ចាំការមករបស់ព្រះបច្ចេកសម្ពុទ្ធទាំងនោះ កាលមិនឃើញ ទើបបញ្ជូនពួកបុរសទៅ ដោយព្រះតម្រាស់ថា នែបាទាំងឡាយ អ្នកទាំងឡាយ ចូរទៅ ចូរដឹងលោកម្ចាស់ទាំងឡាយ មិនផាសុកដូចម្តេច ។ បុរសទាំងនោះនាំគ្នាទៅហើយ បើកទ្វារបណ្ណសាលារបស់ព្រះមហាបទុម កាលមិនឃើញក្នុងទីនោះ ទើបទៅកាន់ទីចង្រ្កម ឃើញលោកឈរផ្អែកបន្ទះក្តារសម្រាប់ផ្អែក ទើបពោលថា លោកម្ចាស់ដ៏ចម្រើន បានកាលហើយ ។ សរីរៈរបស់លោកដែលបរិនិព្វានហើយ នឹងនិយាយបានដូចម្តេច ។ បុរសទាំងនោះពោលថា ប្រហែលជាសិងលក់ ទើបយកដៃស្ទាបត្រង់ខ្នងជើង ដឹងថា បរិនិព្វានហើយ ព្រោះជើងទាំង ២ ត្រជាក់ និងរឹង ទើបទៅកាន់សម្នាក់របស់ព្រះបច្ចេកសម្ពុទ្ធអង្គទី ២ ដឹងបានយ៉ាងនោះដូចគ្នា ទើបទៅកាន់សម្នាក់របស់ព្រះបច្ចេកសម្ពុទ្ធអង្គទី ៣ រឿយៗ

ទៅយ៉ាងនេះ ដឹងថា លោកបរិនិព្វានគ្រប់អង្គ ទើបនាំគ្នាត្រឡប់មកកាន់រាជ-ត្រកូល កាលព្រះទេវីត្រាស់សួរថា នែបាទាំងឡាយ ព្រះបច្ចេកសម្ពុទ្ធទៅណា ទើបក្រាបទូលថា បរិនិព្វានហើយ ព្រះទេវីទ្រង់ព្រះកន្សែង យាងចេញទៅក្នុងទីនោះ មួយអន្លើដោយអ្នកនគរ ព្រះនាងឲ្យធ្វើសាធុកីឡា រួចព្រះនាងឲ្យធ្វើឈាបនកិច្ចសរីរៈរបស់ព្រះបច្ចេកសម្ពុទ្ធទាំងឡាយ ហើយឲ្យយកព្រះធាតុទាំងឡាយ តម្កល់ទុកក្នុងព្រះចេតិយ ។

ព្រះរាជាទ្រង់បង្ក្រាបបច្ចន្តជនបទឲ្យស្ងប់ហើយ យាងត្រឡប់មក ត្រាស់សួរព្រះទេវីដែលយាងមកទទួលថា នាងដ៏ចម្រើន នាងមិនប្រមាទក្នុងព្រះបច្ចេកសម្ពុទ្ធទាំងឡាយទេឬ ព្រះបច្ចេកសម្ពុទ្ធទាំងឡាយ មានផាសុកឬ ។ ព្រះទេវីក្រាបទូលថា បពិត្រព្រះសម្មតិទេព លោកម្ចាស់ទាំងឡាយ បរិ-និព្វានហើយ ។ ព្រះរាជាទ្រង់បានស្តាប់ដូច្នោះ ទ្រង់ព្រះតម្រិះថា ការស្លាប់គង់កើតឡើងដល់បណ្ឌិតទាំងឡាយ ដែលមានសភាពបែបនេះ ពួកយើងនឹងផុតចាកសេចក្តីស្លាប់បានដូចម្តេច មិនយាងចូលព្រះនគរ យាងទៅកាន់ព្រះឧទ្យានមួយរំពេច ត្រាស់ឲ្យហៅបុត្រច្បងមក ទ្រង់ប្រគល់រាជសម្បត្តិ ដល់ព្រះរាជឱរសនោះហើយ ទ្រង់បួសជាសមណៈដោយព្រះអង្គឯង ឯព្រះទេវីព្រះតម្រិះថា កាលព្រះរាជាទ្រង់បួសហើយ អញនៅធ្វើអ្វី ទើបបួសក្នុងឧទ្យានដូចគ្នា ជនទាំង ២ ធ្វើឈានឲ្យកើត ចុតិចាកអត្តភាពនោះហើយ ទៅកើតក្នុងព្រហ្មលោក ។

កាលជនទាំង ២ គឺព្រះរាជា និងព្រះទេវីនោះ នៅក្នុងព្រហ្មលោក

នោះឯង ព្រះសាស្តានៃយើងទាំងឡាយ កើតឡើងក្នុងលោក ទ្រង់ប្រកាសព្រះធម្មចក្រដ៏បវរ ហើយយាងដល់នគររាជគ្រឹះដោយលំដាប់ ។ កាលព្រះសាស្តានៅអាស្រ័យក្នុងនគររាជគ្រឹះនោះ បិប្ផលិមាណពនេះ កើតក្នុងផ្ទៃករិយាកបិលព្រាហ្មណ៍ ក្នុងព្រាហ្មណគ្រាម ឈ្មោះមហាតិត្ថ ។ នាងភទ្ទកាបិលានីនេះ កើតក្នុងផ្ទៃករិយាព្រាហ្មណ៍កោសិយគោត្រ ក្នុងសាគលនគរ ដែនមទ្ទរដ្ឋ ។ កាលជនទាំង ២ ចម្រើនវ័យដោយលំដាប់ កាលបិប្ផលិមាណពមានវ័យ ២០ ឆ្នាំ នាងភទ្ទាមានអាយុ ១៦ ឆ្នាំ មាតាសម្លឹងមើលបុត្រហើយ រំអុកថា នែបា កូនចម្រើនវ័យហើយ សមគួរនឹងតាំងវង្សត្រកូល មាណពពោលថា លោកឪពុក អ្នកម្តាយ កុំពោលពាក្យបែបនេះ ក្នុងគន្លងនៃសោតៈរបស់ខ្ញុំឡើយ ខ្ញុំនឹងបដិបត្តិ ដរាបដែលលោកឪពុក អ្នកម្តាយ នៅមានជីវិត កាលលោកឪពុក អ្នកម្តាយស្លាប់ទៅហើយ ខ្ញុំនឹងចេញបួស ។ កន្លងទៅបាន ២-៣ ថ្ងៃ មាតាបិតាក៏ពោលទៀត ។ ឯមាណពក៏បដិសេធទៀត ។ បន្ទាប់អំពីនោះ មាតាក៏នៅពោលរឿយៗ នោះឯង ។

មាណពគិតថា អញនឹងឲ្យមាតាយល់ ទើបប្រគល់មាស ១០០០ ដុំ ឲ្យពួកជាងមាសធ្វើរូបស្ត្រី ក្នុងពេលសម្រេចការងារ មានការដំ និងខាត់រូបនោះជាដើម ទើបស្លៀកសំពត់ក្រហមឲ្យរូបនោះ ប្រដាប់ដោយផ្កា និងគ្រឿងអលង្ការផ្សេងៗ ដែលដល់ព្រមទៅដោយមាស ហើយពោលថា បពិត្រអ្នកម៉ែ បើខ្ញុំបានអារម្មណ៍បែបនេះ ទើបនៅគ្រប់គ្រងផ្ទះ បើមិនបាន ក៏មិននៅ ។ ព្រាហ្មណីមានបញ្ញា គិតថា កូនរបស់អញមានបុណ្យ បានឲ្យទាន បានសាង

អភិនីហារហើយ កាលធ្វើបុណ្យទាំងឡាយក្នុងជាតិមុន គង់មិនបានធ្វើម្នាក់ឯង ។ គង់មានស្រីដែលធ្វើបុណ្យរួមជាមួយបុត្ររបស់អញ នឹងជាស្រីមានរូបដូចមាសពិតៗ ។ ទើបនាងឲ្យអញ្ជើញព្រាហ្មណ៍ ៨ នាក់មក ប្រគល់ភោគៈគ្រប់យ៉ាង រហូតឲ្យស្កប់ស្កល់ ឲ្យលើករូបមាសដាក់ឡើងរថ បញ្ជូនទៅ ដោយពាក្យថា បាទាំងឡាយ ចូរនាំគ្នាទៅ បើឃើញទារិកាបែបនេះ ក្នុងត្រកូលដែលមានជាតិ គោត្រ និងភោគៈជាដើមស្មើគ្នា នឹងយើងទាំងឡាយក្នុងទីណា ចូរឲ្យរូបមាសនេះឯង ជាគ្រឿងបណ្ណាការក្នុងទីនោះ ។

ព្រាហ្មណ៍ទាំងនោះនាំគ្នាទៅដោយគិតថា នេះជាការងាររបស់ពួកយើង ហើយប្រឹក្សាគ្នាថា ពួកយើងនឹងទៅរកក្នុងទីណា ឈ្មោះថា មទ្ទរដ្ឋជាប្រភពស្រីស្អាត ពួកយើងនឹងទៅកាន់មទ្ទរដ្ឋមុន ហើយបានទៅកាន់សាគលនគរក្នុងមទ្ទរដ្ឋ តាំងរូបមាសនោះ ត្រង់កំពង់សម្រាប់ងូតទឹក ក្នុងដែនមទ្ទរដ្ឋនោះ រួចអង្គុយក្នុងទីបំផុតនាចំណែកម្ខាង ។ លំដាប់នោះ មេដោះរបស់នាងភទ្ទាឲ្យនាងភទ្ទាងូតទឹក តែងខ្លួនហើយ ខ្លួនឯងទៅកាន់កំពង់ទឹក ដើម្បីងូតទឹក ឃើញរូបមាស ទើបគិតថា នាងភទ្ទានេះ ប្រដៅក្រ មកឈរទីនេះដើម្បីអ្វី ទើបវាយត្រង់ខ្នង ដឹងថា ជារូបមាស ទើបពោលថា អញធ្វើការសម្គាល់ឲ្យកើតឡើងថា ជាអយ្យធីតារបស់យើង ស្រីនេះ ទោះបីស្លៀកសំពត់ ក៏មិនដូចអយ្យធីតា ។

លំដាប់នោះ ព្រាហ្មណ៍ទាំងនោះ ក៏សួរមេដោះនោះថា បានឮថា ធីតារបស់នាងបែបនេះឬ មេដោះនោះពោលថា អយ្យធីតារបស់ខ្ញុំ មានរូបស្អាត

ជានរូបមាសនេះ ១០០ ដង ១០០០ ដង ពិតហើយ នាងអង្គុយក្នុងបន្ទប់ប្រមាណ ១២ ហត្ថ សូម្បីមិនមានប្រទីប ក៏កម្ចាត់ងងឹតបានដោយពន្លឺចេញអំពីរាងកាយ ។ ពួកព្រាហ្មណ៍ពោលថា បើយ៉ាងនោះ យើងទាំងឡាយនឹងទៅកាន់សម្នាក់មាតាបិតារបស់នាង ហើយលើករូបមាសដាក់ឡើងរថ ធ្វើដំណើរតាមមេដោះនោះទៅ ឈរត្រង់ទ្វារផ្ទះ ឲ្យប្រាប់ថា ពួកខ្លួនមករក ។

ព្រាហ្មណ៍ធ្វើបដិសណ្ឋារៈហើយ សួរថា អ្នកទាំងឡាយ មកអំពីណា ព្រាហ្មណ៍ទាំងនោះពោលថា យើងទាំងឡាយមកអំពីផ្ទះរបស់កបិលព្រាហ្មណ៍ ក្នុងស្រុកមហាតិត្ថគាម ដែនមគធៈ ដោយហេតុឈ្មោះនេះ ។ ព្រាហ្មណ៍ពោលថា សាធុ ព្រាហ្មណ៍នោះមានជាតិ គោត្រ និងទ្រព្យសម្បត្តិស្មើយើង យើងនឹងឲ្យទារិកា ហើយទទួលគ្រឿងបណ្ណាការ ។ ព្រាហ្មណ៍ទាំងនោះក៏បញ្ជូនដំណឹងដល់កបិលព្រាហ្មណ៍ថា ទារិកាឈ្មោះភទ្ទា ពួកយើងរកបានហើយ សូមលោកដឹងកិច្ចដែលគួរធ្វើតទៅ ។ មាតាបិតា បានស្តាប់ដំណឹងនោះហើយ ទើបប្រាប់ដល់បិប្ផលិមាណពថា បានទារិកាហើយ ។ បិប្ផលិមាណពគិតថា អញគិតថា មិនបាន ព្រាហ្មណ៍ទាំងនោះ បញ្ជូនដំណឹងមកថា បានហើយ អញមិនត្រូវការ នឹងបញ្ជូនសំបុត្រទៅប្រាប់ ចូលទៅកាន់ទីស្ងាត់ចារឹកអក្សរថា ភទ្ទា ចូរនាងបានប្តីដែលសមគួរដល់ជាតិ គោត្រ និងភោគទ្រព្យរបស់ខ្លួនចុះ ខ្ញុំនឹងចេញបួស នាងកុំក្តៅក្រហាយចិត្តក្នុងកាលជាខាងក្រោយឡើយ ឯនាងភទ្ទាបានស្តាប់ថា បានឮថា មាតាបិតាបំណងលើកអញឲ្យបុរសនោះ ទើបចូលទៅក្នុងទីស្ងាត់ ចារឹកអក្សរថា សូមអយ្យបុត្របានទារិកា ដែល

សមគួរដល់ជាតិ គោត្រ និងភោគទ្រព្យរបស់ខ្លួន ខ្ញុំនឹងបួស លោកកុំបីក្តៅក្រហាយចិត្តក្នុងកាលជាក្រោយឡើយ ។ សំបុត្រទាំង ២ មកជួបគ្នាត្រង់កណ្តាលផ្លូវ ។ មនុស្សរបស់នាងកញ្ញាសួរថា នេះសំបុត្ររបស់អ្នកណា មនុស្សរបស់បិប្ផលិមាណពឆ្លើយថា សំបុត្រនេះ បិប្ផលិមាណពបញ្ជូនទៅឲ្យនាងកញ្ញា កាលពួកបិប្ផលិមាណពពោលថា នេះសំបុត្ររបស់អ្នកណា កាលមនុស្សរបស់នាងកញ្ញាពោលថា សំបុត្រនេះ នាងកញ្ញាបញ្ជូនទៅឲ្យបិប្ផលិ-មាណព ទើបមនុស្សទាំងនោះអានសុំត្រទាំង ២ ច្បាប់ ហើយពោលថា អ្នកទាំងឡាយ ចូរមើលការធ្វើរបស់ក្មេងៗ ដូច្នេះហើយ ហែកបោះចោលក្នុងព្រៃសរសេរសាជាថ្មី ផ្លាស់សេចក្តីសំបុត្រហើយបញ្ជូនទៅទាំងសងខាង ។ ហេតុនោះ សំបុត្ររបស់កុមារ និងកុមារិកា ទើបជាសំបុត្រឧបការៈទាក់ទងដោយផ្លូវលោកនោះឯង ព្រោះហេតុនោះ ជនទាំង ២ សូម្បីមិនត្រូវការ ក៏ត្រូវនៅរួមគ្នា ។

ក្នុងថ្ងៃនោះឯង បិប្ផលិមាណព ឲ្យកម្រងផ្កាដល់នាងកញ្ញាមួយកម្រង ។ ឯនាងកញ្ញាក៏ដាក់ផ្កានោះត្រង់កណ្តាលដំណេក ជនទាំង ២ នាក់ បរិភោគអាហារល្ងាចហើយ ផ្តើមចូលដេក ។ ក្នុងជនទាំង ២ នោះ មាណពឡើងខាងស្តាំ នាងកញ្ញាឡើងខាងឆ្វេង ហើយពោលថា ពួកយើងនឹងដឹងថា ផ្កាខាងរបស់បុគ្គលណាស្វិតស្រពោន រាគចិត្តកើតឡើងហើយដល់អ្នកនោះបុគ្គលណាមួយ មិនគប្បីប៉ះកម្រងផ្កានេះ ។ ជនទាំង ២ នោះ ដេកមិនលក់អស់រាត្រី ព្រោះខ្លាចពាល់ត្រូវរាងកាយគ្នានិងគ្នា ក្នុងពេលថ្ងៃ ក៏មិនធ្វើ

សូម្បីត្រឹមតែការញញឹម ។ ជនទាំង ២ មិនប្រឡូកប្រឡំដោយលោកាមិស មិនចាត់ចែងទ្រព្យ ប្រាក់មាស ដរាបណាមាតាបិតានៅមានជីវិត កាលមាតាបិតាធ្វើកាលកិរិយាហើយ ទើបចាត់ចែង ។ សម្បត្តិរបស់មាណពមានច្រើន កម្ទេចមាសដែលគេដុសខាត់រាងកាយ ហើយបោះចោល ក្នុងមួយថ្ងៃប្រមាណ ១២ នាឡិមគធៈ មាណពមានបឹងធំ ដែលបំពាក់ដោយគ្រឿងយន្ត ៦០ កន្លែង មានកសិដ្ឋាន ១២ យោជន៍ មានស្រុក ១៤ ប្រមាណប៉ុនអនុរាធបុរី មានពលដំរី ១៤ កង ពលសេះ ១៤ កង និងពលរថ ១៤ កង ។

ថ្ងៃមួយ មាណពជិះសេះដែលប្រដាប់ហើយ ដែលមហាជនចោមរោម ទៅកាន់ទីធ្វើការ ឈរត្រង់ចុងស្រែ ឃើញពួកបក្សីមានក្អែកជាដើមចឹកសត្វទាំងឡាយ មានជន្លេនជាដើម អំពីគន្លងនង្គ័ល ទើបសួរថា បាទាំងឡាយ សត្វទាំងនេះស៊ីអ្វី ជនជាបរិវារប្រាប់ថា បពិត្រលោកម្ចាស់ ស៊ីជន្លេន មាណពពោលថា បាបដែលពួកបក្សីធ្វើមានដល់នរណា បរិវារជនឆ្លើយថា មានដល់លោកម្ចាស់ ។ មាណពគិតថា បើបាបដែលបក្សីទាំងនោះធ្វើ មានដល់អញ ទ្រព្យ ៨៧ កោដិ នឹងធ្វើអ្វីកើត កសិដ្ឋាន ១២ យោជន៍ នឹងធ្វើអ្វីកើត បឹងបំពាក់ដោយគ្រឿងយន្តនឹងធ្វើអ្វីកើត ស្រុកសួយ ១៤ នឹងធ្វើអ្វីកើត អញនឹងប្រគល់សម្បត្តិទាំងអស់នេះដល់នាងភទ្ទាកាបិលានី ហើយចេញបួស ។

ខណៈនោះ នាងភទ្ទាកាបិលានី ហាលល្ង ៣ ក្អម ក្នុងទីវាល ពួកមេដោះកំពុងអង្គុយចោមរោម ឃើញពួកក្អែកស៊ីសត្វក្នុងគ្រាប់ល្ង ទើបសួរថា នាងទាំងឡាយ ក្អែកទាំងនេះស៊ីអ្វី ពួកមេដោះពោលថា ស៊ីសត្វ ។ នាង

កទ្ទាសួរថា អកុសលមានដល់អ្នកណា ពួកមេដោះឆ្លើយថា មានដល់នាងម្ចាស់ ។ នាងគិតថា អញបានសំពត់ ៤ ហត្ថ និងកត្តត្រឹមតែបាយមួយនាឡិរមែងគួរ បើអកុសលដែលសត្វទាំងនេះធ្វើ ជារបស់អញ សូម្បី ១០០០ កព អញក៏មិនអាចងើបក្បាលឡើងអំពីវដ្តៈបាន កាលអយ្យបុត្រមកដល់ប៉ុណ្ណោះ អញនឹងប្រគល់សម្បត្តិទាំងអស់ដល់អយ្យបុត្រ ហើយចេញបួស ។

មាណពត្រឡប់មកងូតទឹក ឡើងកាន់ប្រាសាទ អង្គុយលើបល្ល័ង្កដែលមានតម្លៃច្រើន ។ លំដាប់នោះ បរិវារជននាំភោជនដែលសមគួរដល់ស្តេចចក្រពត្តិ បង្អោនដល់មាណព ។ ជនទាំង ២ បរិភោគ កាលបរិវារជនចេញទៅហើយ ទើបទៅក្នុងទីស្ងាត់ អង្គុយក្នុងទីដែលជាផាសុក ។

លំដាប់នោះ មាណពក៏ពោលនឹងនាងកទ្ទាថា នែកទ្ទា កាលនាងមកកាន់ផ្ទះនេះ នាំទ្រព្យមានប្រមាណប៉ុនណាមក នាងកទ្ទាពោលថា បពិត្រអយ្យបុត្រ ៥ ម៉ឺន ៥ ពាន់រទេះ មាណពពោលថា ទ្រព្យទាំងអស់នោះ និងសម្បត្តិទាំងឡាយ ដូចជាទ្រព្យ ៨៧ កោដិជាដើមក្នុងផ្ទះនេះ និងបឹងដែលបំពាក់ដោយគ្រឿងយន្ត ៦០ បឹងដែលមានទាំងអស់នោះ ខ្ញុំសូមប្រគល់ដល់នាងតែម្នាក់ ។ នាងកទ្ទាពោលថា បពិត្រអយ្យបុត្រ លោកទៅណា មាណពពោលថា ខ្ញុំនឹងបួស ។ នាងកទ្ទាពោលថា បពិត្រអយ្យបុត្រ ខ្ញុំអង្គុយទន្ទឹងការមករបស់លោក ឯខ្ញុំក៏នឹងបួស ។ ភពទាំង ៣ ប្រាកដដល់ជនទាំង ២ នោះ ដូចខ្ទមស្លឹកដែលត្រូវភ្លើងឆេះ ពាសពេញហើយ ដូច្នោះ ។ ជនទាំង ២ នោះពោលថា យើងទាំង ២ នឹងបួស ទើបឲ្យមនុស្សទៅនាំចីវរដែលជ្រលក់

ដោយទឹកម្ទេស និងបាត្រដីមកអំពីរានផ្សារ ហើយកោរសក់ឲ្យដល់គ្នានិងគ្នា ពោលថា ព្រះអរហន្តអង្គណា មានក្នុងលោក យើងទាំងឡាយ បួសឧទ្ទិស ព្រះអរហន្តទាំងនោះ ដូច្នេះហើយ បួស ដាក់បាត្រក្នុងស្បោក ពាក់ត្រង់ចង្កូយស្មាហើយ ចុះអំពីប្រាសាទ ។ បណ្តាទាសៈ និងកម្មករក្នុងផ្ទះ មិនមានអ្នកមួយចាំបាន ។

កាលនោះ អ្នកទាំង ២ នោះចេញអំពីស្រុកព្រាហ្មណ៍ ទៅកាន់ទ្វារស្រុករបស់ទាសៈ ពួកទាសៈចាំបានដោយកប្បកិរិយា ទាសៈទាំងនោះទ្រហោយំ ក្រាបចុះទៀបបាតជើង ហើយពោលថា បពិត្រអយ្យបុត្រ ហេតុអ្វី ទើបលោកទាំងឡាយ ធ្វើពួកខ្ញុំឲ្យជាមនុស្សអនាថា មិនមានទីពឹង ។ ជនទាំង ២ ពោលថា នែអ្នកទាំងឡាយ យើងទាំង ២ បួស ដោយឃើញថា ភពទាំង ៣ ដូចបណ្ណសាលាដែលភ្លើងឆេះទូទៅ បើយើងដោះឲ្យជាអ្នកជាម្នាក់ម្តងៗ សូម្បី ១០០ ឆ្នាំក៏មិនអស់ អ្នកទាំងឡាយ ចូរមកកក់សីសៈ ហើយចូរជាអ្នកជា ចិញ្ចឹមជីវិតចុះ កាលទាសៈទាំងនោះកំពុងយំនោះឯង បានចៀសចេញទៅ ។

ព្រះថេរៈដើរទៅខាងមុខ ងាកមកសម្លឹងមើល គិតថា នាងភទ្ទាកាបិលានីនេះ ជាស្ត្រីមានតម្លៃ គួរដល់ជម្ពូទ្វីបទាំងមូល ដើរមកតាមក្រោយអញ បុគ្គលណាមួយ គប្បីគិតយ៉ាងនេះថា ជនទាំងនេះ សូម្បីបួសហើយ ក៏មិនអាចបែកគ្នា ធ្វើកម្មដែលមិនសមគួរ ។ កើតការគិតឡើងថា បើបុគ្គលណាមួយ មានចិត្តថោកទាប គិតប្រទូស្តបែបនេះ គប្បីពេញក្នុងអបាយ កាល

ដើរទៅមុខ ឃើញផ្លូវបែកជា ២ ទើបឈប់ត្រង់ផ្លូវនោះ ឯនាងកទ្ទាមក ដល់ថ្វាយបង្គំ ហើយឈរ ។

លំដាប់នោះ ព្រះថេរៈពោលនឹងនាងកទ្ទាថា នែកទ្ទា មហាជនឃើញស្រី ដើរតាមពីក្រោយយើង មានចិត្តគិតប្រទូស្តក្នុងពួកយើងថា អ្នកទាំងនេះ សូម្បីបួសហើយ ក៏មិនអាចបែកគ្នា គប្បីពេញក្នុងអបាយ ផ្លូវបែកជា ២ នេះ ចូរនាងកាន់យកផ្លូវមួយ ខ្ញុំនឹងទៅដោយផ្លូវមួយ ។ នាងកទ្ទាពោលថា ករុណាលោកម្ចាស់ មាតុគ្រាមជាបលិពោធរបស់បព្វជិតទាំងឡាយ មនុស្ស ទាំងឡាយគប្បីពោលទោសពួកយើងថា អ្នកទាំងនេះ បួសហើយ ក៏មិនបែក គ្នា ដូច្នេះហើយ ធ្វើប្រទក្សិណ ៣ ដង ថ្វាយបង្គំដោយបញ្ចង្គប្រតិស្ឋាន ក្នុង ទីទាំង ៤ អន្លើ ហើយផ្គងអញ្ជលីដ៏រុងរឿង ដោយការប្រជុំនៃម្រាម ១០ ហើយពោលថា ការស្និទ្ធស្នាលដោយភាពជាមិត្រ ដែលបានធ្វើក្នុងកាលយូរ ប្រមាណមួយសែនកប្ប បែកគ្នាក្នុងថ្ងៃនេះ លោកម្ចាស់នោះឯង ឈ្មោះថា ជាទក្ខិណា ផ្លូវខាងស្តាំគួរដល់លោកម្ចាស់ ខ្ញុំឈ្មោះថា មាតុគ្រាម ជាអ្នកមាន ជាតិខាងឆ្វេង ផ្លូវខាងឆ្វេងគួរដល់ខ្ញុំ ដូច្នេះ ទើបថ្វាយបង្គំ ហើយធ្វើដំណើរ ទៅ ។ ក្នុងកាលដែលជនទាំង ២ នោះបែកផ្លូវគ្នា មហាប្រឹថពីបានកម្រើក រំពើក ហាក់បីដូចជាពោលថា ខ្ញុំអាចទ្រភ្នំកណ្តាប់ចក្កវាឡនិងភ្នំសិនេរុជាដើម បាន តែមិនអាចទ្រទ្រង់នូវគុណទាំងឡាយរបស់លោកទាំង ២ បានទេ សំឡេងដូចរន្ទះតាំងនៅក្នុងអាកាស ភ្នំកណ្តាប់ចក្កវាឡក៏លាន់ឮ ។

ឯព្រះសម្មាសម្ពុទ្ធ គង់នៅក្នុងព្រះគន្ធកុដិ ក្នុងវត្តវេឡុវនមហាវិហារ

ទ្រង់ស្តាប់សំឡេងផែនដីញាប់ញ័រ ទ្រង់អាវជ្ជនះថា ប្រឹថពីញាប់ញ័រព្រោះអ្នកណាហ្ន៎ ទ្រង់ជ្រាបថា បិប្ផលិមាណព និងនាងភទ្ទកាបិលានី លះសម្បត្តិប្រមាណមិនបាន បួសឧទ្ទិសតថាគត ព្រោះកម្លាំងនៃគុណរបស់ជនទាំង ២ ការញាប់ញ័រនៃប្រឹថពីនេះ កើតក្នុងទីដែលជនទាំង ២ នោះបែកផ្លូវគ្នា ។ តថាគតក៏គួរធ្វើនូវការសង្គ្រោះដល់ជនទាំង ២ នោះ ទើបចេញចាកព្រះគន្ធកុដិ ទ្រទ្រង់នូវបាត្រ និងចីវរ មិនប្រាប់ដល់បុគ្គលណាមួយ ក្នុងបណ្តាមហាថេរៈ ៨០ អង្គ ទ្រង់ធ្វើការទទួលអស់ចម្ងាយផ្លូវ ៣ គាវុត ទ្រង់គង់ពត់ភ្នែន ត្រង់គល់ពហុបុត្តកនិគ្រោធ ក្នុងចន្លោះក្រុងរាជគ្រឹះ និងស្រុកនាលន្ទា ។ ទ្រង់គង់មិនបានគង់ដូចភិក្ខុដែលសមាទានបង្សុកូល ជាវត្តអង្គណាមួយ ទ្រង់កាន់យកភេទរបស់ព្រះពុទ្ធ គង់បញ្ចេញព្រះពុទ្ធរស្មី មានប្រមាណ ៨០ ហត្ថ ។ គ្រានោះ ព្រះពុទ្ធរស្មី មានទំហំប៉ុនឆត្រស្លឹក ឈើប៉ុនកង់រទេះ ប៉ុនផ្ទះកំពូលជាដើម ផ្សាយជារង្វង់ដោយជុំវិញ ធ្វើឲ្យដូចកាលដែលព្រះចន្ទ ១០០០ និងព្រះអាទិត្យ ១០០០ រះឡើង ធ្វើដូវព្រៃនោះឲ្យមានពន្លឺតែមួយ ។ ដូវព្រៃរុងរឿងដោយសិរីនៃព្រះមហាបុរិសលក្ខណៈ ៣២ ប្រការ ដូចផ្ទៃមេឃរុងរឿងដោយពួកផ្កាយដែលរុងរឿង និងដូចទឹករុងរឿងដោយគុម្ពឈូកដែលរីកស្គុសស្គាយ ដូច្នោះ ។ តាមប្រក្រតីដើមនិគ្រោធពណ៌ស ស្លឹកមានពណ៌ខៀវ ផ្លែពណ៌ក្រហម តែថ្ងៃនោះ ដើមនិគ្រោធ មានពណ៌ដូចមាសទាំងអស់ ។

ព្រះមហាកស្សបត្ថេរឃើញដូច្នោះ គិតថា បុគ្គលនេះនឹងជាព្រះសាស្តារបស់អញ អញបួសឧទ្ទិសព្រះសាស្តាអង្គនេះ ទើបបង្អោនខ្លួន ដើរចូលទៅ

តាំងអំពីទីដែលខ្លួនឃើញហើយ ថ្វាយបង្គំក្នុងទី ៣ កន្លែង ក្រាបទូលថា បពិត្រព្រះអង្គដ៏ចម្រើន ព្រះមានព្រះភាគជាសាស្តារបស់ខ្ញុំព្រះអង្គ ខ្ញុំព្រះអង្គជាសាវ័ក បពិត្រព្រះអង្គដ៏ចម្រើន ព្រះមានព្រះភាគ ជាសាស្តារបស់ខ្ញុំព្រះអង្គ ខ្ញុំព្រះអង្គជាសាវ័ក ដូច្នេះ ។ លំដាប់នោះ ព្រះមានព្រះភាគត្រាស់នឹងព្រះមហាកស្សបត្ថេរនោះថា ម្នាលកស្សបៈ បើអ្នកធ្វើសេចក្តីគោរពនេះដល់ផែនដី ផែនដីនោះ ក៏មិនអាចទ្រទ្រង់បាន តែការគោរពដែលអ្នកដឹងថា ព្រះតថាគតមានគុណច្រើនធ្វើមកហើយនេះ មិនអាចធ្វើសូម្បីរោមរបស់តថាគតឲ្យញាប់ញ័រ ម្នាលកស្សបៈ ចូរអ្នកអង្គុយ តថាគតនឹងឲ្យមត៌កដល់អ្នក ។

លំដាប់នោះ ព្រះមានព្រះភាគ បានប្រទានឧបសម្បទាដល់ព្រះមហាកស្សបត្ថេរនោះដោយឱវាទ ៣ កាលឲ្យហើយ ទើបយាងចេញចាកគល់ពហុបុត្តនិគ្រោធ ទ្រង់ធ្វើព្រះថេរៈឲ្យជាបច្ឆាសមណៈ ហើយទ្រង់ធ្វើដំណើរទៅ ។ ព្រះសរីរៈរបស់ព្រះអង្គ លម្អដោយមហាបុរិសលក្ខណៈ ៣២ ប្រការ ឯសរីរៈរបស់ព្រះមហាកស្សបៈ លម្អដោយមហាបុរិសលក្ខណៈ ៧ ប្រការ ព្រះថេរៈជាប់តាមក្រោយព្រះសាស្តាទៅ ដូចកូនទូកមាសទៅតាមក្រោយទូកមាសធំ ដូច្នោះ ព្រះសាស្តាយាងទៅតាមផ្លូវបានបន្តិច ហើយទ្រង់គេចចេញអំពីផ្លូវ ទ្រង់សម្តែងអាការគន់ប្រថាប់ត្រង់គល់ឈើមួយកន្លែង ព្រះថេរៈដឹងថា ព្រះសាស្តាបំណងនឹងគង់ ទើបបត់សង្ឃាដីចាស់របស់ខ្លួន ធ្វើជា ៤ ជាន់ក្រាបថ្វាយ ។

ព្រះសាស្តាគង់លើសង្ឃាដីនោះ យកព្រះហស្តស្ទាបសំពត់ រួចត្រាស់

ថា ម្នាលកស្សបៈ សង្ឃាដីចាស់របស់អ្នកនេះទន់ល្អ ។ ព្រះថេរៈដឹងថា ព្រះសាស្តាត្រាស់ថា សង្ឃាដីរបស់អញទន់ គង់បំណងនឹងដណ្តប់ ទើបក្រាបទូលថា បពិត្រព្រះអង្គដ៏ចម្រើន សូមព្រះមានព្រះភាគទ្រង់ដណ្តប់នូវសំពត់សង្ឃាដីចុះ ព្រះសាស្តាត្រាស់ថា ម្នាលកស្សបៈ អ្នកដណ្តប់អ្វី ព្រះថេរៈក្រាបទូលថា បពិត្រព្រះអង្គដ៏ចម្រើន បើខ្ញុំព្រះអង្គបានសំពត់ដណ្តប់របស់ទ្រង់ ក៏នឹងដណ្តប់សំពត់នោះ ។ ព្រះសាស្តាត្រាស់ថា ម្នាលកស្សបៈ អ្នកអាចទ្រទ្រង់សំពត់បង្សុកូលដ៏ចាស់ ព្រោះការប្រើប្រាស់នេះបានឬ ព្រោះថា ក្នុងថ្ងៃដែលតថាគតកាន់យកសំពត់បង្សុកូលនេះ មហាប្រឹថពីញាប់ញ័រ រហូតដល់ទឹកទ្រផែនដី ធម្មតាចីវរចាស់ដែលព្រះពុទ្ធប្រើប្រាស់ហើយនេះ បុគ្គលដែលមានគុណតិចតួច មិនអាចទ្រទ្រង់បាន ចីវរនេះ ដែលភិក្ខុមានជាតិជាអ្នកសមាទានបង្សុកូលជាវត្ត ជាអ្នកឈ្លាស អាចក្នុងការបំពេញបដិបត្តិប៉ុណ្ណោះ ទើបសមគួរគ្រងសំពត់នេះ ដូច្នេះ ហើយ ទ្រង់ប្តូរចីវរជាមួយព្រះថេរៈ ។

កាលទ្រង់ប្តូរចីវរយ៉ាងនេះហើយ ព្រះមានព្រះភាគទ្រង់ដណ្តប់ចីវររបស់ព្រះថេរៈៗ ដណ្តប់ចីវររបស់ព្រះសាស្តា ។ ខណៈនោះ មហាប្រឹថពីនេះសូម្បីមិនមានចិត្ត ក៏ញាប់ញ័ររហូតដល់ទឹកទ្រផែនដីជាទីបំផុត ហាក់បីដូចជាពោលថា បពិត្រព្រះអង្គដ៏ចម្រើន ទ្រង់ធ្វើនូវវត្តដែលធ្វើបានដោយក្រ ឈ្មោះថា ការប្តូរចីវរដែលទ្រង់ប្រើហើយ ជាមួយសាវ័ក មិនធ្លាប់មានឡើយ ខ្ញុំមិនអាចទ្រទ្រង់នូវគុណរបស់ព្រះអង្គបានឡើយ ។ ឯព្រះថេរៈ មិនបានធ្វើនូវមានះថា អញបានចីវរដែលជាគ្រឿងបរិភោគប្រើប្រាស់របស់ព្រះពុទ្ធ ឥឡូវ

នេះ អញនឹងធ្វើឲ្យក្រៃលែងឡើង ទើបបានសមាទានធុតង្គគុណ ១៣ ក្នុងសម្នាក់របស់ព្រះសាស្ដាមួយរំពេច លោកនៅជាបុថុជ្ជនប្រមាណ ៧ ថ្ងៃ ក្នុងថ្ងៃទី ៨ បានក៏សម្រេចអរហត្ត មួយអន្លើដោយបដិសម្ភិទា ។

លំដាប់នោះ ព្រះសាស្ដាទ្រង់សរសើរព្រះថេរៈនោះ ដោយន័យ ( ក្នុងសំយុត្តនិកាយ និទានវគ្គ ) យ៉ាងនេះថា ម្នាលភិក្ខុទាំងឡាយ កស្សបៈ មានឧបមាដូចព្រះចន្ទ្រ តែងដកកាយ ដកចិត្តចេញ ធ្វើដូចជាអាគន្តុកភិក្ខុ មិនឃ្នើសឃ្នងក្នុងត្រកូលទាំងឡាយ ហើយចូលទៅកាន់ត្រកូល ដូច្នេះជាដើម ។ ក្នុងកាលតមក កាលគង់នៅក្នុងកណ្ដាលពួកព្រះអរិយៈ ទ្រង់តាំងព្រះថេរៈក្នុងតំណែងឯតទគ្គៈ នៃភិក្ខុទាំងឡាយខាងទ្រទ្រង់ធុតង្គ និងពោលប្រៀនប្រដៅធុតង្គថា ម្នាលភិក្ខុទាំងឡាយ បណ្ដាពួកភិក្ខុអ្នកពោលពាក្យកម្ចាត់បង់កិលេស ស្រេចនឹងមហាកស្សបៈប្រសើរជាងគេ ដូច្នេះ ។

ព្រះមហាកស្សបៈ ដែលព្រះមានព្រះភាគទ្រង់តាំងទុកក្នុងតំណែងឯតទគ្គៈយ៉ាងនេះហើយ បានទទួលភាពជាមហាសាវកហើយ រឭកដល់បុព្វកម្មរបស់ខ្លួន កាលប្រកាសអបទានដែលធ្លាប់ប្រព្រឹត្តមកក្នុងជាតិមុនដោយសោមនស្ស ទើបពោលពាក្យថា **បទុមុត្តរស្ស ភគវតោ** ដូច្នេះជាដើម ។

បណ្ដាបទទាំងនោះ បទថា **បទុមុត្តរស្ស ភគវតោ** សេចក្ដីថា បានឮថា ចាប់តាំងពីកាលដែលព្រះមានព្រះភាគអង្គនោះ យាងចេញចាកព្រះគភ៌របស់ព្រះមាតា ក្នុងពេលឈានព្រះបាទ ផ្កាឈូកដែលមានត្របកមួយសែនទម្លាយផែនដីផុសឡើង ទ្រព្រះបាទដែលទ្រង់ឈានហើយ ព្រោះហេតុនោះ

ពាក្យថា **បទុមុត្តរស្ស** នោះ ទើបបានជាព្រះនាមរបស់ព្រះមានព្រះភាគអង្គនោះ ។ ឈ្មោះថា **ភគវតោ** ក្នុងសត្វនីមួយៗ បណ្តាសត្វនិកាយទាំងមូល ធ្វើបុណ្យម្នាក់ ១០០ ដង ទ្រង់ធ្វើបុណ្យបាន ១០០ គុណនៃបុណ្យនោះ ( ១ ម៉ឺនដង ) ។

បទថា **លោកជេដ្ឋស្ស តាទិនោ** សេចក្តីថា ទ្រង់ជាប្រធាននៃសត្វលោក ឈ្មោះថា **តាទិនោ** ព្រោះទ្រង់ដល់នូវភាពជាអ្នកមិនញាប់ញ័រក្នុងឥដ្ឋារម្មណ៍ និងអនិដ្ឋារម្មណ៍ ។

បទថា **និព្វុតេ លោកនាថម្ហិ** សេចក្តីថា កាលព្រះមានព្រះភាគជាទីពឹងនៃសត្វលោកបរិនិព្វានហើយ ដោយខន្ធបរិនិព្វាន អធិប្បាយថា យាងទៅកាន់ទីមើលមិនឃើញ ។

ដោយបទថា **បូជំ កុព្វន្តិ សត្ថុនោ** នេះ ភ្ជាប់សេចក្តីថា លេងសាធុកីឡា ធ្វើនូវការបូជាដល់ព្រះមានព្រះភាគ ដែលបាននាមថា **សត្ថុ** នោះ ព្រោះទ្រង់ទូន្មានសត្វលោក ព្រមទាំងទេវលោក ។

ដោយបទថា **អគ្គឹ ចិនន្តិ ជនតា** នេះ ភ្ជាប់សេចក្តីថា ពួកជនបង្កាត់ភ្លើងធ្វើឲ្យជាគំនរដើម្បីថ្វាយព្រះភ្លើង ត្រេកអរីករាយដោយទូទៅ គឺដោយជុំវិញ ត្រេកអរីករាយ ដោយប្រការផ្សេង ៗ ធ្វើការបូជា ។

បទថា **តេសុ សំវេគជាតេសុ** សេចក្តីថា កាលពួកជនទាំងនោះដល់នូវសេចក្តីសង្វេគ បាននូវការតក់ស្លុត បីតិ គឺការត្រេកអរកើតឡើង គឺប្រាកដដល់ខ្ញុំ ។

បទថា **ញាតិមិត្តេ សមានេត្វា** សេចក្តីថា ប្រជុំផៅពង្ស និងសម្លាញ់របស់ខ្ញុំ គឺរួមជាក្រុម ភ្ជាប់សេចក្តីថា ខ្ញុំបានពោល គឺពោលពាក្យនេះថា ព្រះមានព្រះភាគជាអ្នកមានព្យាយាមធំបរិនិព្វានហើយ គឺបានយាងទៅកាន់ទីដែលមិនឃើញហើយ ។

សព្ទថា **ហន្ទ** ក្នុងពាក្យថា **ហន្ទ បូជំ ករោម សេ** នេះ ជានិបាតប្រាប់នូវអត្ថបបួល អធិប្បាយថា ព្រោះហេតុនោះ ពួកយើងគ្រប់គ្នា ដែលមកប្រជុំគ្នា ចូរធ្វើនូវការបូជា ។ សព្ទថា **សេ** ជានិបាត ។

បទថា **សាធូតិ តេ បដិស្សុត្វា** សេចក្តីថា ញាតិ និងមិត្តរបស់ខ្ញុំទាំងនោះស្តាប់ចំពោះហើយ គឺទទួលពាក្យរបស់ខ្ញុំថា សាធុ គឺប្រពៃ បានដល់ ចម្រើន ធ្វើឲ្យត្រេកអរ គឺបីតិយ៉ាងក្រៃលែង គឺយ៉ាងលើសលប់ គឺឲ្យកើតឡើងហើយដល់ខ្ញុំ ។

បន្ទាប់អំពីនោះ កាលនឹងសម្តែងការកសាងបុណ្យដែលខ្លួនបានធ្វើ ទើបពោលពាក្យថា **ពុទ្ធស្ស លោកនាថស្ស** ដូច្នេះជាដើម ។ ក្នុងពាក្យនោះ ភ្ជាប់សេចក្តីថា ខ្ញុំសាងឯង និងឲ្យអ្នកដទៃសាងចេតិយដែលខ្ពស់ឡើង គឺកម្ពស់ ១០០ ហត្ថ ទទឹង ១៥០ ហត្ថ ខ្ពស់ឡើងទៅក្នុងលម្ហ គឺក្នុងអាកាសដូចវិមាន ជាការសាងយ៉ាងល្អ គឺជាការសាងដោយអាការដ៏ល្អ មានតម្លៃហើយធ្វើការសន្សំបុណ្យ គឺគំនរបុណ្យ ។

បទថា **កត្វាន អគ្ឃិយំ តត្ថ** សេចក្តីថា ធ្វើឯង និងឲ្យអ្នកដទៃធ្វើឲ្យមានតម្លៃវិចិត្រ គឺល្អ ដោយជួរនៃដើមត្នោត គឺដោយជួរនៃដើមត្នោត ញ៉ាំង

ចិត្តរបស់ខ្លួនឲ្យជ្រះថ្លា បូជាព្រះចេតិយដ៏ឧត្តម ។ ដោយបទថា **ចេតិយំ បូជយុត្តមំ** ក្លាប់សេចក្តីថា ខ្ញុំបូជាចេតិយដ៏ឧត្តម គឺដែលគេបញ្ចុះព្រះធាតុរបស់ព្រះសម្មាសម្ពុទ្ធ ។

កាលសម្តែង ភាពធំមហិមារបស់ចេតិយនោះ ទើបពោលពាក្យថា **អគ្គិក្ខន្ធោវ** ដូច្នេះជាដើម ។

បណ្តាបទទាំងនោះ បទថា **អគ្គិក្ខន្ធោវ** ក្លាប់សេចក្តីថា ព្រះចេតិយនេះ រមែងបញ្ចេញពន្លឺដោយរតនៈ ៧ ប្រការ ដូចគំនរភ្លើង រុងរឿងក្នុងអាកាស ភ្លឺរន្ទាល គឺរុងរឿងសព្វទិស គឺក្នុងទិសទាំង ៤ ដូចស្តេចសាល-ព្រឹក្សរីក គឺមានផ្ការីក និងដូចឥន្ទធនូក្នុងអាកាស ។

បទថា **តត្ថ ចិត្តំ បសាទេត្វា** ក្លាប់សេចក្តីថា ខ្ញុំញុំាងចិត្ត គឺឲ្យចិត្តជ្រះថ្លា គឺធ្វើនូវសោមនស្សក្នុងបន្ទប់ ដែលបញ្ចុះព្រះធាតុដ៏រុងរឿងនោះ រួចសាងកុសល គឺបុណ្យជាច្រើន គឺមានប្រការផ្សេងៗ ដោយការជ្រះថ្លានៃចិត្តនោះ បានរឭកដល់បុញ្ញកម្មយ៉ាងនេះថា ខ្ញុំបានធ្វើបុណ្យមានប្រមាណប៉ុណ្ណេះក្នុងបន្ទប់បញ្ចុះព្រះធាតុ និងក្នុងព្រះសាសនា ស្លាប់ហើយចូលដល់ គឺកើតក្នុងស្ថានត្រៃត្រិង្ស គឺភពតាវត្តិង្ស ដូចដេកលក់ហើយភ្ញាក់ឡើង ដូច្នោះ ។

កាលប្រកាសសម្បត្តិក្នុងទេវលោក ដែលខ្លួនទៅកើត ទើបពោលថា **សហស្សយុត្តំ** ដូច្នេះជាដើម ។ ក្នុងពាក្យនោះ មានអធិប្បាយថា ខ្ញុំឡើងយានដែលទឹមដោយសេះ គឺរថពិទ្យដែលទឹមដោយសេះសិន្ធពមួយពាន់ ។ ខ្ញុំមានវិមានកម្ពស់ត្រកាល ៧ ជាន់ ។

អធិប្បាយថា ក្នុងវិមាននោះ មានប្រាសាទ ១០០០ សម្រេចដោយមាសទាំងអស់ ។ ក្តាប់សេចក្តីថា ដោយតេជះរបស់ខ្លួន គឺដោយអានុភាពរបស់ខ្លួន ខ្ញុំរមែងរុងរឿង គឺរុងរឿងធ្វើទិសទាំងពួង គឺទិសទាំង ១០ ឲ្យភ្លឺ ។

ក្នុងវិមានដែលប្រាកដដល់ខ្ញុំនោះ មានយ៉មុខ គឺសាលាខាងមុខ ។ សាលាខាងមុខដូចម្តេច ក្តាប់សេចក្តីថា ក្នុងកាលនោះ យ៉មុខទាំងនោះសម្រេចដោយកែវទទឹម គឺសម្រេចដោយកែវមណីក្រហម សព្វទិសទាំងទាំង ៤ ដោយរស្មី គឺភ្លឺ ។

អធិប្បាយថា ខ្ញុំគ្របសង្កត់ទេវតាទាំងពួង គឺទេវតាក្នុងទេវលោក ៦ ជាន់ទាំងមូល ។ បើមានអ្នកសួរថា ជាផលនៃអ្វី សូមឆ្លើយថា នេះជាផលនៃបុញ្ញកម្ម ដែលខ្ញុំបានធ្វើហើយ ។

បន្ទាប់អំពីនោះ កាលសម្តែងមនុស្សសម្បត្តិ ទើបព្រះថេរៈពោលថា **សដ្ឋិកប្បសហស្សម្ហិ** ដូច្នេះជាដើម ។ ក្នុងពាក្យនោះ ក្តាប់សេចក្តីថា ក្នុងខាងចុងកប្បទី ៦០០០០ អំពីកប្បនេះទៅ ខ្ញុំជាស្តេចចក្រពត្តិព្រះនាមឧព្វិទ្ធៈ មានមហាសមុទ្រ ៤ ជាព្រំប្រទល់ គឺមានមហាទ្វីប ៤ ជាទីបំផុត ជាអ្នកឈ្នះ គឺឈ្នះសត្រូវទាំងពួង គ្រប់គ្រងផែនដី គឺគ្រងរាជសម្បត្តិ ។

បទថា **តថេវ ភទ្ទកេ កប្បេ** គឺក្នុងកប្បឈ្មោះភទ្ទកៈ ព្រោះជាកប្បដែលមានព្រះពុទ្ធ ៥ អង្គ ក្តាប់សេចក្តីថា ខ្ញុំបានជាស្តេចចក្រពត្តិ ជាធំ ជាប្រធានក្នុងទ្វីបទាំងបួន ៣០ ដង គឺ ៣០ ជាតិ បរិបូណ៌ គឺដល់ព្រមដោយរតនៈ ៧ ប្រការ មានចក្ករតន៍ជាដើម ប្រារព្ធនូវកម្មរបស់ខ្លួន គឺត្រេកអរ

បានដល់ កាន់យកក្នុងកម្មរបស់ខ្លួន បានដល់ ទសពិធរាជធម៌ ។

កាលនឹងសម្តែងសម្បត្តិដែលសោយ ក្នុងកាលដែលខ្លួនជាស្តេចចក្រពត្តិ ទើបពោលថា **តត្ថាសិ ភវនំ មយ្ហំ** ដូច្នេះជាដើម ។ ក្នុងពាក្យនោះ ក្តាប់សេចក្តីថា ក្នុងកាលជាស្តេចចក្រពត្តិនោះ ប្រាសាទរបស់ខ្ញុំ រុងរឿងក្នុងអាកាស ដូចផ្ទេកបន្ទោរ គឺខ្ពស់ទៅ ចែកជា ៧ ជាន់ជាដើម ពោលដោយចំណែកបណ្តោយ និងកម្ពស់ ២៤ យោជន៍ ពោលដោយចំណែកទទឹង ១២ យោជន៍ ។

អធិប្បាយថា មាននគរឈ្មោះរម្មណៈ ព្រោះជាទីពេញចិត្តរបស់ជនទាំងពួង ។ លោកសម្តែងថា នគរដែលសម្បូរដោយកំពែង និងរបងមាំទាំ កម្ពស់ប្រមាណ ១២ ឬ ៣០ ហត្ថ ។

បទថា **តទឌ្ឍកំ** កាត់បទជា **តតោ អឌ្ឍកំ** សេចក្តីថា ប្រមាណ ២៥០ យោជន៍ ។ បទថា **បក្កិណ្ណា បណ្ណវីសតិ** សេចក្តីថា រៀបចំរានលក់ដូរ ២០ រានជាប់គ្នា មិនរៀវផ្លូវដើរ ក្នុងចន្លោះឡើយ ។ បទថា **ព្រហ្មញ្ញ-កុលសម្ភូតោ** ប្រែថា កើតក្នុងត្រកូលព្រាហ្មណ៍ ។ ពាក្យដ៏សេស មានអត្ថងាយយល់ហើយ ព្រោះមានន័យដូចពោលហើយនោះឯង ។

## អដ្ឋកថា មហាកស្សបត្ថេរាបទាន ចប់

# សុត្តន្តបិដក

## អន្នុរុទ្ធត្ថេរាបទានទី ៦

[ ៦ ] ខ្ញុំបានឃើញព្រះមានព្រះភាគ ទ្រង់ព្រះនាមសុមេធៈ ជាច្បង ក្នុងលោក ជានរាសភៈ ជាលោកនាយក ទ្រង់ចេញចាកគណៈ ហើយគង់នៅតែមួយអង្គឯង ។ ទើបខ្ញុំចូលទៅជិត ព្រះសុមេធ-សម្ពុទ្ធ ជាលោកនាយក ហើយផ្គងអញ្ជលីអារាធនាព្រះសម្ពុទ្ធ ដ៏ប្រសើរថា បពិត្រព្រះអង្គ ទ្រង់មានព្យាយាមធំ ជាច្បងក្នុងលោក ជានរាសភៈ សូមព្រះអង្គអនុគ្រោះ ខ្ញុំព្រះអង្គសូមថ្វាយប្រទីបដល់ ព្រះអង្គដែលទ្រង់ចម្រើនឈាន ក្បែរគល់ឈើ ។ ព្រះសយម្ភូ ជាអ្នកប្រាជ្ញ ប្រសើរជាងពួកអ្នកប្រាជ្ញនោះ ទ្រង់បានទទួលហើយ ក្នុងវេលានោះ ខ្ញុំបានទម្លុះឈើទាំងឡាយ ដើម្បីប្រកបនូវប្រទីប ។ មិនតែប៉ុណ្ណោះ ខ្ញុំបានថ្វាយប្រឆេះចង្កៀងមួយពាន់ ដល់ព្រះសម្ពុទ្ធ ជាលោកពន្ធុ ឯប្រទីបទាំងឡាយ ក៏ឆេះរុងរឿងឡើង អស់ ៧ ថ្ងៃ ហើយទើបរលត់ទៅវិញ ។ លុះខ្ញុំលះរាងកាយ ជារបស់មនុស្ស ហើយ ទៅកើតក្នុងវិមាន ( ស្ថានសួគ៌ ) ដោយចិត្តជ្រះថ្លានោះផង ដោយការតាំងចេតនានោះផង ។ កាលដែលខ្ញុំទៅកើត ជាទេវតា ហើយ មានប្រាសាទដែលបុញ្ញកម្ម តាក់តែងដោយល្អ ភ្លឺរុងរឿង ដោយជុំវិញ នេះជាផលនៃការថ្វាយនូវប្រទីប ។ ខ្ញុំកើតជាស្តេច ចក្រពត្តិអស់ ២៨ ដង បានឃើញរូបចម្ងាយ ១ យោជន៍ជុំវិញ ទាំងថ្ងៃទាំងយប់ក្នុងកាលនោះ ។ ខ្ញុំតែងធ្វើនូវទិសទាំងពួង ចម្ងាយ

១ យោជន៍ដោយជុំវិញ ឲ្យភ្លឺរុងរឿង ក្នុងកាលនោះ ខ្ញុំគ្របសង្កត់ទេវតាទាំងអស់ នេះជាផលនៃការថ្វាយប្រទីប ។ ខ្ញុំជាធំជាងទេវតាបានសោយរាជ្យក្នុងពួកទេវតាអស់ ៣០ កប្ប ឥតមានពួកទេវតាណា មើលងាយខ្ញុំបានឡើយ នេះជាផលនៃការថ្វាយនូវប្រទីប ។ ខ្ញុំបានសម្រេចទិព្វចក្ខុ ក្នុងសាសនានៃព្រះសាស្ដា តែងឃើញលោកធាតុមួយពាន់ដោយញាណ នេះជាផលនៃការថ្វាយនូវប្រទីប ។ ព្រោះតែខ្ញុំបានថ្វាយប្រទីប ដោយចិត្តជ្រះថ្លាដល់ព្រះសម្ពុទ្ធ ព្រះនាមសុមេធៈ ទ្រង់កើតក្នុងកាល ៣០ ពាន់កប្បនោះ បដិសម្ភិទា ៤ វិមោក្ខ ៨ និងអភិញ្ញា ៦ នេះ ខ្ញុំបានធ្វើឲ្យជាក់ច្បាស់ហើយ ទាំងសាសនារបស់ព្រះពុទ្ធ ខ្ញុំក៏បានប្រតិបត្តិហើយ ។

បានឮថា ព្រះអនុរុទ្ធត្ថេរមានអាយុ បានសម្ដែងនូវគាថាទាំងនេះដោយប្រការដូច្នេះ ។

## អនុរុទ្ធត្ថេរាបទាន ចប់

# អដ្ឋកថា

## អនុរុទ្ធត្ថេរាបទាន

[ ៦ ] *អបទានរបស់ព្រះអនុរុទ្ធត្ថេរ មានពាក្យថា* **សុមេធំ ភគវន្តាហំ** *ដូច្នេះជាដើម ។*

*ព្រះអនុរុទ្ធត្ថេរនេះ ជាអ្នកមានអធិការបានធ្វើហើយ ក្នុងព្រះពុទ្ធអង្គមុនៗ សន្សំបុណ្យទាំងឡាយ ដែលជាឧបនិស្ស័យនៃព្រះនិព្វានក្នុងភពនោះៗ ក្នុងកាលនៃព្រះមានព្រះភាគព្រះនាមបទុមុត្តរៈ កើតក្នុងត្រកូលព្រាហ្មណ៍ ដែលសម្បូរដោយទ្រព្យសម្បត្តិ លុះចម្រើនវ័យហើយ ថ្ងៃមួយ ទៅកាន់វិហារ ស្តាប់ធម៌ក្នុងសម្នាក់របស់ព្រះសាស្តា ឃើញភិក្ខុមួយរូប ដែលព្រះសាស្តាទ្រង់តែងតាំងក្នុងតំណែងឯតទគ្គៈជាងភិក្ខុទាំងឡាយ ដែលមានទិព្វចក្ខុ ខ្លួនឯងក៏ប្រាថ្នាតំណែងនោះ ទើបថ្វាយមហាទានអស់ ៧ ថ្ងៃ ដល់ព្រះមានព្រះភាគ ដែលមានភិក្ខុមួយសែនរូបជាបរិវារ ក្នុងថ្ងៃទី ៧ បានថ្វាយសំពត់ដ៏ឧត្តមដល់ព្រះមានព្រះភាគ និងភិក្ខុសង្ឃ ហើយបានធ្វើសេចក្តីប្រាថ្នា ។ ឯព្រះសាស្តាទ្រង់ឃើញថា សេចក្តីប្រាថ្នារបស់កុលបុត្តនោះ សម្រេចដោយមិនមានអន្តរាយ ទើបទ្រង់ព្យាករថា អ្នកនឹងបានជាបុគ្គលដ៏កំពូលជាងភិក្ខុដែលមានទិព្វចក្ខុ ក្នុងសាសនារបស់ព្រះគោតមសម្មាសម្ពុទ្ធ ក្នុងអនាគតកាល ។ កុលបុត្រនោះ ក៏ធ្វើបុណ្យទាំងឡាយក្នុងព្រះសាសនានោះទៀត កាលព្រះសាស្តាបរិនិព្វានហើយ បានធ្វើការបូជាដោយប្រទីបដ៏ឱឡារ ត្រង់ស្តូបមាសកម្ពស់ ៧ យោជន៍ ដោយប្រទីបមានជង ប្រទីបភាជនៈ និងថាសសំរឹទ្ធជាច្រើន ដោយអធិដ្ឋានថា សូមជាឧបនិស្ស័យដល់ទិព្វចក្ខុញាណ*

កុលបុត្រនោះធ្វើបុណ្យទាំងឡាយ ដរាបដល់អស់ជីវិត ដោយប្រការយ៉ាងនេះ អន្ទោលទៅក្នុងទេវតា និងមនុស្ស ក្នុងកាលនៃព្រះមានព្រះភាគព្រះនាមកស្សបៈ កើតក្នុងផ្ទះរបស់កុដុម្ពិកៈ ក្នុងនគរពារាណសី ដល់នូវភាពជាអ្នកដឹងក្តីហើយ កាលព្រះសាស្តាបរិនិព្វាន គេសាងស្តូបមាសទំហំ ១ យោជន៍សម្រេចហើយ បាននាំកាជនៈសំរឹទ្ធជាច្រើន មកដាក់ឲ្យពេញដោយសប្បិថ្លាបរិសុទ្ធរបស់ពេញថាស និងឲ្យដាក់ដុំស្កររអំពៅត្រង់កណ្តាលមួយដុំមួយថាស ដាក់ប្រទេះក្នុងថាសនីមួយៗ ឲ្យជាប់តគ្នាតម្កល់ជុំវិញព្រះចេតិយ ។ ចំណែកថាសដែលជារបស់ខ្លួន ដាក់សប្បិដែលថ្លាបរិសុទ្ធរហូតពេញ ដាក់ប្រទេះ ១០០០ អុជភ្លើង ទូលលើក្បាល ដើរប្រទក្សិណព្រះចេតិយអស់មួយរាត្រី ។

ក្នុងអត្តភាពនោះ ក៏បានធ្វើកុសលយ៉ាងនោះ ដរាបដល់អស់ជីវិត ហើយទៅកើតក្នុងទេវលោក តាំងនៅក្នុងទេវលោកនោះ ដរាបដល់អស់អាយុ ចុតិចាកទេវលោកនោះ កាលព្រះពុទ្ធមិនទាន់កើតឡើង បានកើតក្នុងត្រកូលក្រីក្រ ក្នុងនគរពារាណសីនោះឯង មានឈ្មោះអន្នភារៈ ។ អន្នភារៈនោះធ្វើការងារចិញ្ចឹមជីវិតក្នុងផ្ទះរបស់សេដ្ឋីឈ្មោះសុមនៈ ។ ថ្ងៃមួយ កុលបុត្រនោះ ឃើញព្រះបច្ចេកសម្ពុទ្ធព្រះនាមឧបរិដ្ឋៈ ចេញអំពីនិរោធសមាបត្តិហោះមកអំពីភ្នំគន្ធមាទន៍ ចុះត្រង់ទ្វារក្រុងពារាណសី ដណ្តប់ចីវរ ហើយត្រាច់បិណ្ឌបាតក្នុងនគរ មានចិត្តជ្រះថ្លា ទទួលយកបាត្រហើយ ដាក់កត្តដែលជាចំណែករបស់ខ្លួន ផ្តើមនឹងប្រគេនដល់ព្រះបច្ចេកសម្ពុទ្ធ តាមដែលតាំងចិត្ត ឯកិរិយារបស់កុលបុត្រនោះ ក៏ដាក់កត្តដែលជាចំណែករបស់ខ្លួនក្នុងបាត្រដូចគ្នា

កុលបុត្រនោះ ក៏នាំបាត្រទៅដាក់ក្នុងដៃរបស់ព្រះបច្ចេកសម្ពុទ្ធ ។ ព្រះបច្ចេកសម្ពុទ្ធទទួលយកបាត្រនោះ ធ្វើអនុមោទនាហើយ ចៀសចេញទៅ ។

ថ្ងៃនោះ ទេវតាដែលអាស្រ័យនៅត្រង់ឆត្ររបស់សុមនសេដ្ឋី អនុមោទនាដោយសំឡេងខ្លាំងថា ឱ ! ទាននេះ ជាទានយ៉ាងក្រៃលែង អន្នភារៈប្រតិស្ឋានល្អហើយក្នុងព្រះបច្ចេកសម្ពុទ្ធឧបរិដ្ឋៈ ។ សុមនសេដ្ឋីបានស្តាប់ដូច្នោះ គិតថា ទានត្រឹមតែប៉ុណ្ណោះ ទេវតាគង់អនុមោទនាយ៉ាងនេះ ត្រូវជាទានដ៏ឧត្តម ទើបសូមនូវចំណែកបុណ្យក្នុងទាននោះ ។

ឯអន្នភារៈឲ្យចំណែកបុណ្យដល់សុមនសេដ្ឋីនោះ សុមនសេដ្ឋីមានសេចក្តីពេញចិត្ត ទើបឲ្យទ្រព្យ ១០០០ ហើយពោលថា ចាប់អំពីនេះទៅ អ្នកមិនចាំបាច់ធ្វើការងារដោយដៃរបស់ខ្លួន ចូរអ្នកធ្វើផ្ទះឲ្យសមរម្យ ក្នុងទីនេះ រហូតទៅ ។

ព្រោះហេតុដែលបិណ្ឌបាត ដែលបុគ្គលថ្វាយដល់ព្រះបច្ចេកសម្ពុទ្ធ ដែលចេញអំពីនិរោធសមាបត្តិ រមែងមានវិបាកដ៏ឱឡារ ក្នុងថ្ងៃនោះឯង ព្រោះហេតុនោះ សុមនសេដ្ឋី កាលទៅគាល់ព្រះរាជា បាននាំអន្នភារៈនោះទៅផង ឯព្រះរាជាបានទតនាយអន្នភារៈនោះដោយអើពើ ។ សេដ្ឋីក្រាបទូលថា បពិត្រមហារាជ នាយអន្នភារៈនេះ ជាបុគ្គលគួរសម្តីងមើលនោះឯង ហើយក្រាបទូលកម្មដែលនាយអន្នភារៈធ្វើក្នុងគ្រានោះ និងភាពដែលខ្លួនបានឲ្យទ្រព្យ ១០០០ ដល់មាណព ។ ព្រះរាជាបានស្តាប់ដូច្នោះ ទ្រង់ត្រេកអរ បានប្រទានទ្រព្យ ១០០០ ហើយទ្រង់កំណត់ទីសាងផ្ទះឲ្យមាណពថា ចូរធ្វើផ្ទះក្នុងទីនោះ ។

កាលនាយអន្នភារៈនោះឲ្យជម្រះទីនោះ ឆ្នាំងទ្រព្យធំៗ ច្រើនឆ្នាំងផុសឡើងមក ។ មាណពឃើញដូច្នោះ ក៏ក្រាបទូលដល់ព្រះរាជា ។ ព្រះរាជាត្រាស់ឲ្យជញ្ជូនទ្រព្យទាំងអស់មក ទ្រង់ឃើញទ្រព្យ ដែលគេនាំមកគរ ទើបត្រាស់សួរថា ក្នុងនគរនេះ ផ្ទះអ្នកណាមានទ្រព្យប៉ុណ្ណេះឬទេ មហាជនក្រាបទូលថា បពិត្រព្រះសម្មតិទេព ក្នុងផ្ទះរបស់បុគ្គលណាមិនមានប៉ុណ្ណេះឡើយ ។ ព្រះរាជាត្រាស់ថា បើដូច្នោះ អន្នភារៈនេះ ចូរជាសេដ្ឋី ឈ្មោះអន្នភារសេដ្ឋីក្នុងនគរនេះ ហើយទ្រង់ឲ្យលើកឆត្រសេដ្ឋីដល់មាណពក្នុងថ្ងៃនោះឯង ។

អន្នភារៈបានជាសេដ្ឋីហើយ ធ្វើកល្យាណកម្ម ដរាបដល់អស់អាយុ ហើយកើតក្នុងទេវលោក អន្ទោលទៅក្នុងទេវតា និងមនុស្សទាំងឡាយ អស់កាលយូរ ក្នុងកាលព្រះមានព្រះភាគនៃយើងទាំងឡាយទ្រង់កើតឡើង កុលបុត្តនោះ បដិសន្ធិក្នុងរាជវាំងរបស់ព្រះបាទសុក្កោទនសក្យៈ ក្នុងនគរកបិលពស្តុ ។ កាលកើតមក ព្រះញាតិទាំងឡាយបានថ្វាយព្រះនាមថា អនុរុទ្ធ ។ ព្រះអនុរុទ្ធកុមារនោះ ជាព្រះកនិដ្ឋភាតារបស់ព្រះមហានាមសក្យៈ ដែលជាឱរសរបស់ឪពុកមានៃព្រះមានព្រះភាគ ជាសុខុមជាតិក្រៃលែង ជាអ្នកមានបញ្ញាច្រើន ព្រះក្រយាហាររបស់ព្រះអង្គកើតឡើងចំពោះក្នុងថាសមាសប៉ុណ្ណោះ ។

ថ្ងៃមួយ ព្រះមាតារបស់ព្រះអង្គទ្រង់ព្រះតម្រិះថា បុត្ររបស់អញ មិនស្គាល់ពាក្យថា មិនមាន អញនឹងឲ្យកូនអញដឹង ទើបយកថាសមាសមួយគ្របលើថាសមាសទទេមួយ ហើយបញ្ជូនទៅឲ្យដល់ព្រះអង្គ ក្នុងរវាងផ្លូវ

ទេវតាទាំងឡាយ ធ្វើថាសមាសនោះឲ្យពេញដោយទំនិញ ព្រះអនុរុទ្ធនោះមានបុណ្យច្រើនយ៉ាងនេះ ដែលស្រីបម្រើប្រដាប់តាក់តែងហោមរោម សោយសម្បត្តិធំ ក្នុងប្រាសាទ ៣ ដែលសមគួរដល់រដូវ ៣ ដូចទេវតា ។

ព្រះពោធិសត្វនៃយើងទាំងឡាយ ចុតិចាកតុសិតបុរីក្នុងសម័យនោះ កើតក្នុងព្រះគភ៌របស់ព្រះអគ្គមហេសីរបស់សុទ្ធោទនមហារាជ ទ្រង់ចម្រើនវ័យដោយលំដាប់ ប្រថាប់នៅកណ្តាលផ្ទះអស់ ២៩ វស្សា ហើយចេញមហាភិនេស្ក្រមណ៍ ទ្រង់ចាក់ធ្លុះនូវសព្វញ្ញុតញ្ញាណដោយលំដាប់ ទ្រង់ញុំាងពេលវេលាឲ្យកន្លងទៅក្នុងពោធិមណ្ឌលដ្ឋាន ៧ សប្តាហ៍ ហើយទ្រង់ប្រកាសធម្មចក្រ ត្រង់ព្រៃឥសិបតនមិគទាយវ័ន កាលទ្រង់ធ្វើការអនុគ្រោះសត្វលោកទើបយាងទៅកាន់នគររាជគ្រឹះ ទ្រង់គង់នៅក្នុងវត្តវេឡុវ័ន ។ ក្នុងកាលនោះព្រះបាទសុទ្ធោទនមហារាជទ្រង់បញ្ជូនអមាត្យ ១០ នាក់ មានបរិវារម្នាក់ ១០០០ ទៅដោយព្រះតម្រាស់ថា បានឮថា បុត្ររបស់យើង ដល់នគររាជគ្រឹះដោយលំដាប់ហើយ នែបា បាទាំងឡាយ ចូរទៅនាំបុត្ររបស់យើងមក ។ អមាត្យទាំងអស់នោះ នាំគ្នាបួសដោយឯហិភិក្ខុបព្វជ្ជា ។ ព្រះមានព្រះភាគ ដែលព្រះឧទាយិត្ថេរក្នុងចំនួនអមាត្យទាំងនោះទូលអារាធនា សូមឲ្យយាងចារិកទៅ ទ្រង់ហោមរោមដោយព្រះខីណាស្រព ២ ម៉ឺនអង្គ ចេញអំពីនគររាជគ្រឹះ ដល់កបិលពស្តុបុរី ហើយទ្រង់សម្តែងបាដិហារ្យមិនមែនតិចក្នុងសមាគមព្រះញាតិ ហើយត្រាស់ធម្មទេសនាដ៏វិចិត្រ លម្អទៅដោយបាដិហារ្យ ញុំាងមហាជនឲ្យផឹកនូវអមតៈហើយ ក្នុងថ្ងៃទី ២ ទ្រង់កាន់បាត្រ និងចីវរ

ទ្រង់ឈរត្រង់ទ្វារនគរ ទ្រង់អាវជ្ជនៈថា ព្រះពុទ្ធគ្រប់អង្គ យាងមកដល់នគររបស់ត្រកូលហើយ ទ្រង់ប្រព្រឹត្តដូចម្តេចហ្ន៎ ទ្រង់ជ្រាបថា ប្រព្រឹត្តបិណ្ឌបាតទៅតាមលំដាប់ច្រក ទើបត្រាច់បិណ្ឌបាតតាមលំដាប់ច្រក ។ ព្រះរាជាទ្រង់ជ្រាបថា ព្រះរាជឱរសរបស់ព្រះអង្គត្រាច់បិណ្ឌបាត ទើបប្រញាប់យាងមកទ្រង់បានស្តាប់ធម៌ក្នុងវាំងថ្នល់ ទើបនិមន្តឲ្យយាងចូលក្នុងនិវេសន៍របស់ព្រះអង្គ ទ្រង់បានធ្វើសមានធំក្រៃលែង ។ ព្រះមានព្រះភាគ ទ្រង់ធ្វើការអនុគ្រោះព្រះញាតិដែលគប្បីធ្វើក្នុងទីនោះ ហើយទ្រង់ឲ្យរាហុលកុមារបព្វជ្ជា យាងចេញអំពីនគរកបិលពស្តុ ចារិកទៅមល្លរដ្ឋ ក្នុងកាលមិនយូរប៉ុន្មាន យាងដល់អនុបិយម្ពវ័ន ។

សម័យនោះ ព្រះបាទសុទ្ធោទនមហារាជត្រាស់ឲ្យប្រជុំពួកសក្យរាជ ហើយត្រាស់ថា បើបុត្ររបស់យើងគ្រប់គ្រងផ្ទះ នឹងបានជាស្តេចចក្រពត្តិសម្បូរដោយរតនៈ ៧ ប្រការ មានពួកក្សត្រជាបរិវារ សូម្បីរាហុលកុមារចៅរបស់យើង ក៏នឹងបានត្រាច់ចោមរោមបុត្ររបស់យើង មួយអន្លើដោយពួកក្សត្រ អ្នកទាំងឡាយក៏ដឹងរឿងនេះស្រាប់ហើយ ឥឡូវនេះ បុត្ររបស់យើងត្រាស់ដឹងជាព្រះពុទ្ធហើយ ក្សត្រទាំងឡាយនោះ ចូរជាបរិវារនៃបុត្ររបស់យើង អ្នកទាំងឡាយ ចូរឲ្យទារកមួយត្រកូលម្នាក់ កាលព្រះបាទសុទ្ធោទនមហារាជត្រាស់យ៉ាងនេះហើយ ពួកខត្តិកុមារ ៨ ម៉ឺន ២ ពាន់នាក់ ចេញបួសព្រមគ្នា ។

សម័យនោះ មហានាមសក្យៈទ្រង់ជាធំក្នុងទ្រព្យសម្បត្តិ ទ្រង់ចូលទៅ

រកអនុរុទ្ធសក្យៈដែលជាប្អូនប្រុសរបស់ព្រះអង្គ ហើយបានត្រាស់ពាក្យនេះថា ប្អូនអនុរុទ្ធ ឥឡូវនេះ សក្យកុមារមានកេរ្តិ៍ឈ្មោះប្រាកដច្រើនព្រះអង្គ បួសតាមព្រះមានព្រះភាគហើយ នរណាមួយអំពីត្រកូលរបស់យើង ដែលចេញពីផ្ទះ បួសជាបព្វជិត មិនមាន បើយ៉ាងនោះ ប្អូនឯងបួស ឬបងបួស អនុរុទ្ធបានស្តាប់ដូច្នោះ មិនត្រេកអរក្នុងការគ្រប់គ្រងផ្ទះ ទើបចេញអំពីផ្ទះ បួសជាបុគ្គលគម្រប់ ៧ ។ ប្រវត្តិនៃការបួសរបស់ព្រះអនុរុទ្ធនោះ មានក្នុងសង្ឃភេទក្ខន្ធកៈនោះឯង ។ បណ្តាស្តេចសក្យៈទាំងនោះ ទៅកាន់អនុបិយម្ពវ័នហើយបួសយ៉ាងនោះ ព្រះភទ្ទិយត្ថេរ សម្រេចបានអរហត្តខាងក្នុងវស្សានោះឯង ព្រះអនុរុទ្ធត្ថេរធ្វើទិព្វចក្ខុឲ្យកើត ទេវទត្តធ្វើសមាបត្តិ ៨ ឲ្យកើត ព្រះអានន្ទត្ថេរតាំងនៅក្នុងសោតាបត្តិផល ព្រះភគុត្ថេរ និងព្រះកិម្ពិលត្ថេរសម្រេចអរហត្ត ក្នុងកាលខាងក្រោយ ។ អភិនីហារនៃសេចក្តីប្រាថ្នាក្នុងជាតិមុនរបស់ព្រះថេរៈទាំងអស់នោះ នឹងមានច្បាស់ក្នុងការពោលដល់ប្រវត្តិរបស់ខ្លួន ។ ព្រះអនុរុទ្ធត្ថេរនោះ រៀនព្រះកម្មដ្ឋានក្នុងសម្នាក់របស់ព្រះធម្មសេនាបតី ហើយទៅកាន់បាចីនវង្សទាយវ័ន ក្នុងចេតិយរដ្ឋ បំពេញសមណធម៌ ត្រិះរិះក្នុងមហាបុរិសវិតក្ក ៧ ទាក់ទើរក្នុងមហាបុរិសវិតក្កទី ៨ ព្រះសាស្តាទ្រង់ជ្រាបថា ព្រះអនុរុទ្ធទាក់ទើរក្នុងមហាបុរិសវិតក្កទី ៨ ទើបទ្រង់ព្រះតម្រិះថា តថាគតនឹងធ្វើការត្រិះរិះរបស់អនុរុទ្ធឲ្យបរិបូណ៌ ទើបយាងទៅក្នុងទីនោះ ទ្រង់គង់លើបវរពុទ្ធាសនៈដែលគេក្រាល ត្រាស់អរិយវង្សប្រដិបទាដែលប្រដាប់ដោយការចម្រើនសន្តោសក្នុងបច្ច័យ ៤ ជាទីមកត្រេកអរ ទ្រង់ធ្វើមហាបុរិសវិតក្កទី ៨

ឲ្យបរិបូណ៌ ហើយហោះទៅក្នុងអាកាស ទៅកាន់ភេសកលាវ័ននោះឯង ។

ព្រះថេរៈកាលព្រះសាស្តាយាងត្រឡប់ទៅ បានជាព្រះមហាខីណាស្រព មានវិជ្ជា ៣ គិតថា ព្រះសាស្តាទ្រង់ជ្រាបចិត្តរបស់អញ ទើបយាងមកប្រទាន មហាបុរិសវិតក្កទី ៨ ឲ្យបរិបូណ៌ មានោរថរបស់អញដល់ទីបំផុតហើយ បាន ប្រារព្ធព្រះធម្មទេសនារបស់ព្រះពុទ្ធ និងបដិវេធធម៌របស់ខ្លួន ទើបបានពោល ឧទានគាថាទាំងនេះថា

ព្រះសាស្តា ជាបុគ្គលប្រសើរក្នុងលោក ព្រះអង្គទ្រង់ជ្រាប ច្បាស់នូវសេចក្តីត្រិះរិះរបស់អាត្មាអញ ទ្រង់មានកាយសម្រេច ដោយចិត្ត ទ្រង់ស្តេចចូលមកដោយឫទ្ធិ តម្រិះរបស់អាត្មា អញ កើតមានយ៉ាងណា ព្រះអង្គក៏ទ្រង់សម្តែងនូវធម៌ដ៏លើស លុបយ៉ាងនោះ ព្រះពុទ្ធទ្រង់ត្រេកអរក្នុងនិប្បបញ្ចធម៌ ក៏ទ្រង់ សម្តែងនូវនិប្បបញ្ចធម៌ អាត្មាអញបានដឹងច្បាស់នូវធម៌របស់ ព្រះអង្គ ក៏ត្រេកអរក្នុងសាសនា វិជ្ជាទាំង ៣ អាត្មាអញ ក៏បានសម្រេចហើយ សាសនារបស់ព្រះពុទ្ធ អាត្មាអញក៏ បានធ្វើហើយ ដូច្នេះ ។

ក្នុងកាលតមក ព្រះសាស្តាទ្រង់គង់នៅក្នុងវត្តជេតពនមហាវិហារ ទ្រង់ តាំងព្រះអនុរុទ្ធត្ថេរនោះក្នុងតំណែងឯតទគ្គៈថា អនុរុទ្ធជាកំពូលជាងភិក្ខុទាំង ឡាយខាងមានទិព្វចក្ខុ ។

ព្រះអនុរុទ្ធត្ថេរនោះ កាលបានតំណែងឯតទគ្គៈជាងភិក្ខុ ដែលមានទិព្វចក្ខុ

*អំពីសម្នាក់របស់ព្រះសាស្តាយ៉ាងនេះហើយ រឭកដល់បុព្វកម្មរបស់ខ្លួន កាល ប្រកាសអបទានដែលប្រព្រឹត្តមកក្នុងកាលមុន ដោយអំណាចសោមនស្ស ទើបពោលពាក្យថា* **សុមេធំ ភគវន្តាហំ** *ដូច្នេះជាដើម ។ ក្នុងគាថានោះ ក្ឬាប់សេចក្តីថា* **មេធា** *ពោល គឺបញ្ញាក្នុងការជួយឧបការៈ បញ្ញាក្នុងមគ្គ ផល បញ្ញានៅក្នុងវិបស្សនា និងបដិសម្ភិទាជាដើមដែលល្អ មានដល់ព្រះ មានព្រះភាគអង្គណា ព្រះមានព្រះភាគអង្គនោះ ឈ្មោះថា សុមេធៈ ខ្ញុំបាន ឃើញព្រះសុមេធៈនោះ ។ ឈ្មោះថា* **ភគវន្តំ** *ព្រោះទ្រង់ដល់ព្រមដោយភាគ គឺបុណ្យ ជាជេដ្ឋបុរសនៃលោក គឺប្រសើរបំផុត បានដល់ ជាធំក្នុងលោក គឺទ្រង់ចេញចាកសង្សារ ជានរាសភ ៣ គឺទៅខាងមុខនៃនរជនទាំងឡាយ ទ្រង់ ចេញចាកគណៈ គឺជាអ្នកស្ងាត់ បានដល់ ដែលនៅដោយមិនមានការត្រេកអរ ក្នុងការប្រឡូកប្រឡំដោយពួកគណៈ សេចក្តីថា ចូលទៅក្បែរព្រះមានព្រះ ភាគ ដែលឈ្មោះថា ព្រះសុមេធសម្ពុទ្ធ ព្រោះត្រាស់ដឹងធម៌ទាំងពួង ដោយ ព្រះអង្គឯង ។ បទថា* **អញ្ជលឹ បគ្គហេត្វាន** *សេចក្តីថា ប្រណម្យម្រាមទាំង ១០ ដាក់លើសិរសា ។ ពាក្យដ៏សេសមានអត្ថងាយយល់ហើយ ។ បទថា* **ទិវា រត្តិញ្ច បស្សាមិ** *សេចក្តីថា ក្នុងកាលនោះ គឺក្នុងកាលកើតឡើងក្នុង ទេវលោក និងមនុស្សលោក ខ្ញុំរមែងមើលឃើញបាន ១ យោជន៍ដោយ ជុំវិញ ដោយមំសចក្ខុ ។*

បទថា **សហស្សលោកំ ញាណេន** សេចក្ដីថា ខ្ញុំឃើញ ១០០០ ចក្កវាឡដោយបញ្ញាចក្ខុ ។ បទថា **សត្ថុសាសនេ** បានដល់ ក្នុងសាសនានៃព្រះមានព្រះភាគព្រះនាមគោតម ក្នុងឥឡូវនេះ ។ នេះគឺជាផលនៃការថ្វាយប្រទីប គឺបូជាដោយប្រទីប អធិប្បាយថា ដោយផលនេះ ទើបខ្ញុំសម្រេច គឺបានធ្វើទិព្វចក្ខុឲ្យកើតឡើង ។៚

**អដ្ឋកថា អនុរុទ្ធត្ថេរាបទាន ចប់**

# សុត្តន្តបិដក

## បុណ្ណមន្តានីបុត្តត្ថេរាបទានទី៧

[ ៧ ] ខ្ញុំជាអ្នកបង្រៀនមន្ត ចេះចាំមន្ត សម្រេចត្រៃវេទ មានពួកសិស្សចោមរោមហើយ បានចូលទៅគាល់ព្រះសម្មាសម្ពុទ្ធដ៏ប្រសើរជាងនរជន ។ ព្រះមហាមុនីព្រះនាមបទុមុត្តរៈ ទ្រង់ជ្រាបច្បាស់នូវសត្វលោក ព្រះអង្គជាអ្នកគួរទទួលគ្រឿងបូជា បានសម្តែងនូវកម្មរបស់ខ្ញុំ ដោយសង្ខេប ។ ខ្ញុំបានស្តាប់ធម៌នោះហើយ ក៏ផ្គងអញ្ជលី ថ្វាយបង្គំព្រះសាស្តា ហើយបែរមុខឆ្ពោះទៅកាន់ទិសទក្សិណ ដើរចេញទៅ ។ ខ្ញុំបានស្តាប់ដោយសង្ខេបទេ តែអាចសម្តែងដោយពិស្តារបាន ពួកសិស្សទាំងអស់ បានស្តាប់ភាសិតដែលខ្ញុំសម្តែង ក៏មានចិត្តរីករាយគ្រប់ៗ គ្នា ។ ពួកសិស្សទាំងនោះ លះបោលនូវទិដ្ឋិរបស់ខ្លួនហើយ ធ្វើចិត្តឲ្យជ្រះថ្លាក្នុងព្រះពុទ្ធ ខ្ញុំសម្តែងដោយសង្ខេបក៏បាន ដោយពិស្តារយ៉ាងនោះក៏បាន ។ ខ្ញុំឈ្លាសវៃក្នុងន័យព្រះអភិធម្ម ឈ្លាសវៃក្នុងវិសុទ្ធិ ក្នុងកថាវត្ថុ ញុំាងជនជាបណ្ឌិតទាំងពួងឲ្យត្រាស់ដឹង ទាំងជាអ្នកមិនមានអាសវៈ ។ ក្នុងកប្បទី ៥០០ អំពីភទ្ទកប្បនេះទៅ ខ្ញុំកើតជាស្តេចចក្រពត្តិ ៤ ដង មានកេរ្តិ៍ឈ្មោះល្បីល្បាញទូទៅ បរិបូណ៌ដោយកែវទាំង ៧ ប្រការ

ជាឥស្សរៈក្នុងទីប ៤ ។ បដិសម្ភិទា ៤ វិមោក្ខ ៨ និងអភិញ្ញា ៦ នេះ ខ្ញុំបានធ្វើឲ្យជាក់ច្បាស់ហើយ ទាំងសាសនារបស់ព្រះពុទ្ធ ខ្ញុំក៏បានប្រតិបត្តិហើយ ។

បានឮថា ព្រះបុណ្ណមន្តានីបុត្តត្ថេរមានអាយុ បានសម្តែងនូវគាថាទាំងនេះ ដោយប្រការដូច្នេះ ។

បុណ្ណមន្តានីបុត្តត្ថេរាបទាន ចប់

# អដ្ឋកថា

## បុណ្ណមន្តានីបុត្តត្ថេរាបទាន

[ ៧ ] អបទានរបស់ព្រះបុណ្ណមន្តានីបុត្តត្ថេរ ពាក្យជាដើមថា **អជ្ឈាយកោ មន្តធរោ** ដូច្នេះ ។

ព្រះថេរៈនេះ ក៏មានអធិការបានធ្វើហើយ ក្នុងព្រះពុទ្ធអង្គមុនៗ សន្សំបុណ្យទាំងឡាយដែលជាឧបនិស្ស័យនៃព្រះនិព្វាន ក្នុងភពនោះៗ មុនព្រះមានព្រះភាគព្រះនាមបទុមុត្តរៈកើតឡើង កើតក្នុងត្រកូលព្រាហ្មណមហាសាល ក្នុងនគរហង្សវតី ដល់នូវភាពជាអ្នកដឹងក្តីដោយលំដាប់ ក្នុងកាលតមក គ្រាព្រះមានព្រះភាគបទុមុត្តរៈកើតឡើងហើយ ទ្រង់សម្តែងធម៌ដល់ពួកសត្វដែលគួរដល់ការត្រាស់ដឹង ចូលទៅកាន់ព្រះវិហារ មួយអន្លើដោយមហាជនដោយន័យដូចពោលហើយខាងដើមនោះឯង អង្គុយខាងចុងបរិស័ទ ស្តាប់ធម៌ ឃើញព្រះសាស្តាទ្រង់តាំងភិក្ខុមួយរូប ក្នុងតំណែងដ៏ប្រសើរជាងភិក្ខុទាំងឡាយដែលជាធម្មកថិក ទើបគិតថា សូម្បីអញក៏គួរជាបុគ្គលបែបនេះក្នុងអនាគត ។ ក្នុងកាលចប់ទេសនា កាលបរិស័ទក្រោកឡើងហើយ ទើបចូលទៅគាល់ព្រះសាស្តា ទូលនិមន្តហើយ ធ្វើមហាសក្ការៈ ដោយន័យដូចពោលហើយខាងដើម ហើយក្រាបទូលព្រះមានព្រះភាគយ៉ាងនេះថា បពិត្រព្រះអង្គដ៏ចម្រើន ដោយការធ្វើដ៏ក្រៃលែងនេះ ខ្ញុំព្រះអង្គមិនបានប្រាថ្នាសម្បត្តិដទៃ ភិក្ខុដែលទ្រង់តែងតាំងក្នុងតំណែងដ៏ប្រសើរជាងភិក្ខុទាំងឡាយ ដែលជាធម្មកថិក ក្នុងទីបំផុតនៃថ្ងៃទី ៧ យ៉ាងណា ខ្ញុំព្រះអង្គក៏គប្បីជាបុគ្គលប្រសើរជាងភិក្ខុទាំងឡាយ ដែលជាធម្មកថិក ក្នុងសាសនារបស់ព្រះពុទ្ធអង្គណាមួយ ក្នុងអនា-

គតកាលយ៉ាងនោះចុះ ហើយបានតាំងសេចក្តីប្រាថ្នាទុកហើយ ។ ព្រះសាស្តាទ្រង់ប្រមើលមើលអនាគត ទ្រង់ឃើញការប្រាថ្នារបស់កុលបុត្រនោះសម្រេច ទើបទ្រង់ព្យាករថា ក្នុងអនាគតកាល ក្នុងទីបំផុតមួយសែនកប្ប ព្រះមានព្រះភាគព្រះនាមគោតមនឹងកើតឡើង អ្នកនឹងបួសក្នុងសាសនារបស់ព្រះគោតមសម្ពុទ្ធនោះ នឹងបានជាកំពូលជាងភិក្ខុទាំងឡាយ ដែលជាព្រះធម្មកថិក ។

កុលបុត្រនោះ ធ្វើកល្យាណកម្មដរាបដល់អស់អាយុ ចុតិចាកអត្តភាពនោះហើយ សន្សំបុញ្ញសម្ភារ ១ សែនកប្ប អន្ទោលទៅក្នុងទេវតា និងមនុស្សទាំងឡាយ ក្នុងកាលនៃព្រះមានព្រះភាគរបស់យើងទាំងឡាយ បានទៅកើតជាក្មួយរបស់ព្រះអញ្ញាកោណ្ឌញ្ញត្ថេរ ក្នុងត្រកូលព្រាហ្មណមហាសាលក្នុងស្រុកព្រាហ្មណ៍ ឈ្មោះថា ទោណវត្ថុ មិនឆ្ងាយអំពីនគរកបិលពស្តុ ញាតិទាំងឡាយបានដាក់ឈ្មោះថា បុណ្ណៈ កាលព្រះសាស្តាសម្រេចអភិសម្ពោធិញ្ញាណហើយ ទ្រង់ប្រកាសធម្មចក្រដ៏បវរ ចូលទៅអាស្រ័យនគររាជគ្រឹះ គង់នៅដោយលំដាប់ បុណ្ណមាណពក៏បួសក្នុងសម្នាក់របស់ព្រះអញ្ញាកោណ្ឌញ្ញៈ បានឧបសម្បទាហើយ ប្រកបសេចក្តីព្យាយាម គិតថា អញធ្វើកិច្ចនៃបព្វជិតទាំងពួង ឲ្យដល់ទីបំផុតសិន សឹមទៅគាល់ព្រះទសពល ទើបធ្វើដំណើរទៅកាន់សម្នាក់របស់ព្រះសាស្តា មួយអន្លើដោយព្រះថេរៈដែលជាឪពុកធំ សម្រាកក្បែរៗ បរិវេណ ជិតនគរកបិលពស្តុ ធ្វើកម្មក្នុងយោនិសោមនសិការ ខ្វល់ខ្វាយក្នុងវិបស្សនា ហើយបានសម្រេចអរហត្ត ក្នុងកាលមិនយូរប៉ុន្មានឡើយ ។

ព្រះបុណ្ណត្ថេរនោះ មានកុលបុត្រ ៥០០ បួសក្នុងសម្នាក់ព្រះថេរៈ ពោលទូន្មានកុលបុត្រទាំងនោះ ដោយកថាវត្ថុ ១០ ប្រការ ។ កុលបុត្រទាំងនោះ បានទទួលពាក្យប្រៀនប្រដៅ ដោយកថាវត្ថុ ១០ ហើយ តាំងនៅក្នុងឱវាទរបស់ព្រះបុណ្ណៈនោះ ក៏បានសម្រេចអរហត្ត កាលដឹងថា កិច្ចនៃបព្វជិតរបស់ខ្លួនដល់ទីបំផុតហើយ ទើបចូលទៅរកព្រះឧបជ្ឈាយ៍ ហើយពោលថា បពិត្រលោកម្ចាស់ ពួកខ្ញុំដល់នូវទីបំផុតនៃកិច្ចរបស់បព្វជិតកិច្ចហើយ នឹងជាអ្នកមានប្រក្រតីបាននូវកថាវត្ថុ ១០ ឥឡូវនេះ ជាសម័យដែលពួកខ្ញុំគួរចូលគាល់ព្រះទសពល ។ ព្រះថេរៈបានស្តាប់ពាក្យរបស់ភិក្ខុទាំងនោះហើយ ទើបគិតថា ព្រះសាស្តាទ្រង់ជ្រាបថា អាត្មាអញជាអ្នកបានកថាវត្ថុ ១០ អញកាលសម្តែងធម៌ ក៏មិនសម្តែងក្រៅអំពីវត្ថុ ១០ នោះ បើអញទៅភិក្ខុទាំងអស់នោះនឹងចោមរោមអញ កាលបើដូច្នោះ អញមិនគួរទៅគាល់ព្រះទសពល មួយអន្លើដោយគណៈ ភិក្ខុទាំងនេះ ចូលទៅគាល់ព្រះទសពលមុន ។ លំដាប់នោះ ព្រះថេរៈក៏ពោលនឹងភិក្ខុទាំងនោះយ៉ាងនេះថា អាវុសោទាំងឡាយ ចូរពួកអ្នកទៅគាល់ព្រះទសពល ចូរថ្វាយបង្គំព្រះបាទារបស់ព្រះតថាគតតាមពាក្យរបស់ខ្ញុំ ឯខ្ញុំក៏នឹងទៅតាមផ្លូវដែលពួកអ្នកទៅ ព្រះថេរៈទាំងអស់នោះនៅក្នុងរដ្ឋដែលជាជាតិភូមិរបស់ព្រះទសពលទាំងអស់ ជាព្រះខីណាស្រពទាំងអស់ បានកថាវត្ថុ ១០ ទទួលឱវាទរបស់ឧបជ្ឈាយ៍ ថ្វាយបង្គំព្រះថេរៈហើយត្រាច់ទៅដោយលំដាប់ ឆ្លងកាត់ផ្លូវ ៦០ យោជន៍ ទៅកាន់វេឡុវនវិហារ ក្នុងនគររាជគ្រឹះ ថ្វាយបង្គំបាទាព្រះទសពល ហើយអង្គុយក្នុងចំណែក

ម្ចាស់ ។ ការប្រាស្រ័យជាមួយអាគន្តុកភិក្ខុទាំងឡាយនេះ ព្រះមានព្រះភាគទាំងឡាយ ទ្រង់ប្រព្រឹត្តបន្តគ្នាមក ព្រោះហេតុនោះ ទើបព្រះមានព្រះភាគទ្រង់ធ្វើបដិសណ្ឋារៈដោយពាក្យដ៏ពីរោះជាមួយភិក្ខុទាំងនោះ ដោយន័យជាដើមថា ម្នាលភិក្ខុទាំងឡាយ ពួកអ្នកល្មមអត់ធន់បានដែរឬ ដូច្នេះហើយ ត្រាស់សួរថា ម្នាលភិក្ខុទាំងឡាយ ពួកអ្នកមកអំពីទីណា កាលភិក្ខុទាំងនោះក្រាបទូលទៀតថា មកអំពីជាតិភូមិ ទើបត្រាស់ដល់ភិក្ខុដែលបាននូវកថាវត្ថុ ១០ ថា ម្នាលភិក្ខុទាំងឡាយ ក្នុងជាតិភូមិ មានភិក្ខុរូបណា បានទទួលការលើកតម្កើងអំពីសព្រហ្មចារីយ៉ាងនេះថា ខ្លួនជាអ្នកប្រាថ្នាតិច ហើយដឹកនាំភិក្ខុទាំងឡាយ ឲ្យប្រាថ្នាតិចផង ។ ភិក្ខុទាំងនោះ ក៏ក្រាបទូលថា បពិត្រព្រះអង្គលោកមានអាយុឈ្មោះបុណ្ណៈ កូនរបស់នាងមន្តានី ។

ចំណែកព្រះសារីបុត្រ បានស្តាប់ពាក្យរបស់ភិក្ខុទាំងនោះ មានបំណងនឹងឃើញព្រះថេរៈ ។ បន្ទាប់អំពីនោះ ព្រះសាស្តាបានយាងអំពីនគររាជគ្រឹះទៅកាន់នគរសាវត្ថី ព្រះបុណ្ណត្ថេរក៏បានជ្រាបថា ព្រះទសពលយាងទៅក្នុងនគរសាវត្ថី ទើបទៅដោយបំណងថា បានចូលគាល់ព្រះសាស្តា ខាងក្នុងព្រះគន្ធកុដិនោះឯង ។ ព្រះសាស្តាទ្រង់សម្តែងធម៌ដល់ព្រះថេរៈៗ ស្តាប់ធម៌ហើយថ្វាយបង្គំព្រះទសពល ដើម្បីពួនសម្ងំ ទើបទៅកាន់ព្រៃអន្ធវ័ន អង្គុយសម្រាកក្នុងពេលថ្ងៃ ត្រង់គល់ឈើមួយដើម ឯព្រះសារីបុត្របានដឹងថា ព្រះបុណ្ណៈនិមន្តមក ទើបដើរតាមអំពីខាងក្រោយ ល្មមមើលក្បាលឃើញ រង់ចាំឱកាសហើយចូលទៅរកព្រះថេរៈ ដែលអង្គុយត្រង់គល់ឈើនោះ ប្រាស្រ័យជាមួយ

ព្រះថេរៈហើយ ក៏សួរលំដាប់នៃវិសុទ្ធិ ឯព្រះថេរៈក៏ព្យាករបញ្ហាដែលសួរហើយដល់ព្រះសារីបុត្រ គ្រប់ប្រស្នាដោយការប្រៀបធៀបដោយរថ ៧ គ្រឿង ធ្វើឲ្យព្រះសារីបុត្រពេញចិត្តក្រៃលែង ។ ព្រះថេរៈទាំង ២ រូប អនុមោទនាភាសិតនៃគ្នានិងគ្នា ។

ក្នុងកាលតមក ព្រះសាស្ដាទ្រង់គង់នៅក្នុងកណ្ដាលភិក្ខុសង្ឃ ទ្រង់តែងតាំងព្រះថេរៈក្នុងតំណែងឯតទគ្គៈថា ម្នាលភិក្ខុទាំងឡាយ បណ្ដាពួកភិក្ខុអ្នកជាធម្មកថិក ដែលជាសាវ័ករបស់តថាគត ស្រេចនឹងបុណ្ណមន្តានីបុត្ត ប្រសើរជាងគេ ។ ព្រះថេរៈនោះ រឭកដល់កម្មក្នុងកាលមុនរបស់ខ្លួន កាលនឹងប្រកាសអបទាន គឺការប្រព្រឹត្តក្នុងកាលមុន ដោយសោមនស្ស ទើបពោលពាក្យថា **អជ្ឈាយកោ** ដូច្នេះជាដើម ។

បណ្ដាបទទាំងនោះ បទថា **អជ្ឈាយកោ** បានដល់ ប្រាប់ គឺបង្រៀនពួកព្រាហ្មណ៍មិនមែនតិច ។ បទថា **មន្តធរោ** បានដល់ ជាអ្នកទ្រទ្រង់នូវមន្ត លោកពោលអធិប្បាយថា ចាំនូវវេទទី ៤ ពោលគឺគម្ពីរវេទ ដោយការទន្ទេញ ការស្ដាប់ និងការបង្រៀន ។ បទថា **តិណ្ណំ វេទាន** សេចក្ដីថា ជាអ្នកដល់ត្រើយ គឺក្នុងទីបំផុតក្នុងគម្ពីរវេទទាំង ៣ ដែលបាននាមថា វេទៈ ព្រោះជាអ្នកទ្រទ្រង់នូវវេទទាំង ៣ គឺឥរុព្វវេទ យជុរវេទ និងសាមវេទ ដោយញាណ ។ បទថា **បុរក្ខតោម្ហិ សិស្សេហិ** សេចក្ដីថា ខ្ញុំជាបុគ្គលដែលពួកសិស្សជាបរិវាររបស់ខ្ញុំចោមរោម ។ បទថា **ឧបគច្ឆឹ នរុត្តមំ** សេចក្ដីថា ខ្ញុំចូលទៅគាល់ព្រះមានព្រះភាគ ជាបុគ្គលដ៏ឧត្តមជាងនរជន អធិប្បាយថា

ចូលទៅក្បែរ ។ ពាក្យដ៏សេសមានអត្ថងាយយល់ហើយ ។

បទថា **អភិធម្មនយញ្ញូហំ** សេចក្តីថា ក្នុងកាលនោះ គឺក្នុងកាលរបស់ព្រះពុទ្ធអង្គនោះ ខ្ញុំជាអ្នកឈ្លាសក្នុងអភិធម្មន័យ ។ បទថា **កថាវត្ថុវិសុទ្ធយា** បានដល់ ជាអ្នកឈ្លាសដោយសេចក្តីបរិសុទ្ធ ក្នុងកថាវត្ថុប្បករណ៍ ម្យ៉ាងទៀត សេចក្តីថា ជាអ្នកឈ្លាសក្នុងកថាវត្ថុ ១០ មានកថាពោលដោយការប្រាថ្នាតិច និងសន្តោសជាដើម ។ ខ្ញុំញ៉ាំងជនជាបណ្ឌិតទាំងពួង គឺបណ្ឌិតសម្រួមឥន្ទ្រិយ ឲ្យដឹងច្បាស់ គឺត្រាស់ដឹងដោយបរិសុទ្ធ ក្នុងកថាវត្ថុនោះ ជាអ្នកមិនមានអាសវៈ គឺមិនមានកិលេស បានដល់ សម្រេចការនៅ ។

បទថា **ឥតោ បញ្ចសតេ កប្បេ** សេចក្តីថា ក្នុង ៥០០ កប្បបន្ទាប់ពីភទ្ទកប្បនេះ ដែលមានព្រះពុទ្ធ ៥ ព្រះអង្គ ខ្ញុំបានជាស្តេចចក្រពត្តិ ៤ ដងជាជនដែលគេស្គាល់យ៉ាងល្អ គឺជាអ្នកប្រាកដដោយល្អ ទ្រង់សម្បូរដោយរតនៈ ៧ មានចក្ករ័តន៍ជាដើម ទ្រង់ជាឥស្សរៈ គឺជាប្រធានក្នុងទ្វីបទាំង ៤ មានជម្ពូទ្វីបជាដើម ។ ពាក្យដ៏សេសមានន័យដូចពោលហើយនោះឯង ។

## អដ្ឋកថា បុណ្ណាមន្តានិបុត្តត្ថេរាបទាន ចប់

# សុត្តន្តបិដក

## ឧទាលិត្ថេរាបទានទី ៨

[ ៨ ] ខ្ញុំកើតជាព្រាហ្មណ៍ ឈ្មោះសុជាត ក្នុងក្រុងហង្សវតី ជាអ្នកសន្សំនូវទ្រព្យសម្បត្តិ ចំនួន ៨០ កោដិ មានទ្រព្យ និងស្រូវជាច្រើន ។ ខ្ញុំជាអ្នកបង្រៀនមន្ត ចេះចាំមន្ត សម្រេចត្រៃវេទ ដល់នូវត្រើយក្នុងធម៌របស់ខ្លួន គឺក្បួនទាយលក្ខណៈ និងក្បួនឈ្មោះឥតិ-ហាសៈ ។ ក្នុងគ្រានោះ ពួកបរិព្វាជក អ្នកមានផ្នួងសក់មួយ ពួកពុទ្ធសាវករបស់ព្រះគោតម និងពួកតាបសអ្នកប្រព្រឹត្តតបៈ តែងនាំគ្នាត្រាច់ទៅលើផែនដី ។ ពួកទាំងនោះ តែងចោមរោមខ្ញុំ ពួកជនជាច្រើនតែងបូជាខ្ញុំ ដោយសម្គាល់ថាជាព្រាហ្មណ៍ មានកិត្តិសព្ទល្បីល្បាញ ខ្ញុំមិនបូជាជនណាមួយ ។ វេលានោះ ខ្ញុំជាមនុស្សរឹងត្អឹងដោយមានះ មិនឃើញបុគ្គលគួរបូជា ទាំងពាក្យថា ព្រះពុទ្ធ ក៏មិនដែលមាន ព្រោះព្រះជិនស្រី ទ្រង់មិនទាន់កើតឡើងនៅឡើយ ។ លុះកន្លងថ្ងៃ និងយប់ទៅ ព្រះពុទ្ធទ្រង់ព្រះនាមបទុមុត្តរៈ ទ្រង់មានបញ្ញាចក្ខុ កម្ចាត់បង់នូវងងឹតទាំងពួង ទ្រង់កើតឡើងក្នុងលោក ។ កាលបើពួកជនជាអ្នកប្រាជ្ញ មានចំនួនច្រើនផ្សាយទៅផង សាសនារីកក្រាស់ក្រែលផង គ្រានោះ ព្រះសម្ពុទ្ធស្តេចចូលទៅកាន់ក្រុងហង្សវតី ។ ព្រះពុទ្ធមានបញ្ញាចក្ខុនោះ ទ្រង់សម្តែងធម៌ដើម្បីប្រយោជន៍ដល់ព្រះបិតាក្នុងវេលានោះ ពួកបរិស័ទប្រមាណមួយយោជន៍ដោយជុំវិញ ( មកគាល់ព្រះអង្គ ) តាមកាលដ៏គួរនោះ ។

គ្រានោះ តាបសឈ្មោះសុនន្ទៈ ដែលពួកមនុស្សរាប់អាន បានបិទបាំងពុទ្ធបរិស័ទទាំងអស់ ដោយផ្កាទាំងឡាយ ។ កាលព្រះសម្មាសម្ពុទ្ធ ទ្រង់ប្រកាសសច្ចៈទាំង ៤ ក្នុងមណ្ឌប ដ៏ហើយដោយផ្កាដ៏ប្រសើរ ពួកបរិស័ទមួយសែនកោដិ ក៏បានសម្រេចធម្មាភិសម័យ ។ ព្រះសម្ពុទ្ធ ទ្រង់បង្អុរភ្លៀង គឺព្រះធម៌អស់ ៧ យប់ ៧ ថ្ងៃ លុះដល់ថ្ងៃទី ៨ ព្រះជិនស្រី ក៏ទ្រង់បានទំនាយនូវតាបសឈ្មោះសុនន្ទៈថា សុនន្ទតាបសនេះ កាលអន្ទោលទៅក្នុងភព គឺទេវលោក ឬមនុស្សលោក នឹងបានជាអ្នកប្រសើរជាងទេវតា ទាំងជាងមនុស្សទាំងអស់ នឹងអន្ទោលទៅក្នុងភពទាំងឡាយ ។ លុះដល់រវាងមួយសែនកប្ប នឹងមានព្រះសម្ពុទ្ធ ព្រះនាមគោតម កើតឡើងក្នុងត្រកូលឱក្កាកៈ នឹងបានជាសាស្តាក្នុងលោក ។ សុនន្ទតាបសនេះ នឹងបានជាទាយាទក្នុងធម៌ ជាឱរស ជាធម្មនិម្មិត ជាសាវក ឈ្មោះបុណ្ណៈ ជាបុត្តនៃនាងមន្តានីរបស់ព្រះសាស្តានោះ ។ លុះព្រះសម្ពុទ្ធ បានព្យាករសុនន្ទតាបសយ៉ាងនេះហើយ បានញុំាងជនទាំងពួងឲ្យរីករាយ ទ្រង់សម្តែងតាមកម្លាំងរបស់ព្រះអង្គ ។ វេលានោះ ពួកបរិស័ទ បានប្រណម្យអញ្ជលីនមស្ការចំពោះសុនន្ទតាបស សុនន្ទតាបស ក៏ធ្វើសក្ការបូជាចំពោះព្រះសម្ពុទ្ធ រួចហើយ ទើបធ្វើគតិរបស់ខ្លួនឲ្យស្អាត ។ ខ្ញុំបានស្តាប់ព្រះពុទ្ធដីការបស់ព្រះមុនី ( ព្រះនាមបទុមុត្តរៈ ) ក៏មានបំណង ក្នុងវេលានោះថា អាត្មាអញនឹង

បានឃើញព្រះគោតមយ៉ាងណា នឹងធ្វើសក្ការបូជាយ៉ាងនោះ ។ លុះខ្ញុំគិតយ៉ាងនេះរួចហើយ ទើបគិតរកបុញ្ញកិរិយាវត្ថុ ដែលខ្ញុំគួរធ្វើថា អាត្មាអញនឹងប្រព្រឹត្តអំពើអ្វីហ្ន៎ ក្នុងបុញ្ញក្ខេត្តដ៏ប្រសើរ ។ ឯភិក្ខុជាអ្នកសូត្រអង្គនេះ ព្រះមានព្រះភាគបានតាំងថា ជាអ្នកប្រសើរខាងព្រះវិន័យ ជាងភិក្ខុអ្នកសូត្រទាំងពួង ក្នុងសាសនា ដូច្នេះ អាត្មាអញនឹងប្រាថ្នាយកតំណែងនោះ ។ ទ្រព្យរបស់អាត្មាអញនេះច្រើនណាស់ រាប់មិនអស់ ឧបមាដូចសាគរ បុគ្គលមិនអាចនឹងឲ្យញាប់ញ័របានឡើយ ហេតុនេះ អាត្មាអញគួរសាងអារាម ថ្វាយព្រះសម្ពុទ្ធ ដោយទ្រព្យនោះ ។ ខ្ញុំបានសាងអារាមមួយ ឈ្មោះសោភនៈនៅខាងមុខទីក្រុង ឲ្យជាអារាមសម្រាប់សង្ឃ អស់ចំនួនមួយសែនកហាបណៈ ។ ខ្ញុំបានសាងផ្ទះ មានកំពូលផង ប្រាសាទវែងផង មណ្ឌបផង ប្រាសាទមានជំបូលរលីងផង គុហាផង ទីចង្ក្រមដ៏ល្អផង ក្នុងអារាមរបស់សង្ឃ ។ មួយទៀត ខ្ញុំបានសាងរោងកម្តៅកាយ រោងភ្លើង រោងទឹក បន្ទប់សម្រាប់ស្រង់ទឹក ថ្វាយចំពោះព្រះភិក្ខុសង្ឃ ។ ខ្ញុំបានថ្វាយជើងម៉ា តាំង គ្រឿងប្រើប្រាស់ ភាជន៍ ភេសជ្ជៈ ទាំងអស់នុ៎ះ សម្រាប់អារាម ។ ខ្ញុំបានតម្កល់ទុកបុគ្គលអ្នករក្សា ឲ្យគេធ្វើកំពែងយ៉ាងមាំ ( ការពារ ) កុំឲ្យមានសត្រូវណាមួយ មកបៀតបៀនព្រះអង្គ ទ្រង់ជាតាទិបុគ្គល មានព្រះហឫទ័យស្ងប់រម្ងាប់ ។ ខ្ញុំបានឲ្យគេសាងអាវាស ជាអារាមសម្រាប់សង្ឃ អស់ចំនួនទ្រព្យ

មួយសែន លុះសាងអារាម មានសភាពស្អុកស្កម្ភ រួចហើយ ក៏បានបង្អោនថ្វាយដល់ព្រះសម្មាសម្ពុទ្ធថា បពិត្រព្រះមុនី អារាម ខ្ញុំបានឲ្យគេសាងស្រេចហើយ សូមព្រះអង្គទទួលយក បពិត្រព្រះធីរៈ ខ្ញុំព្រះអង្គនឹងថ្វាយទាន ចំពោះព្រះអង្គ បពិត្រព្រះអង្គមានចក្ខុ សូមព្រះអង្គទ្រង់ទទួលនិមន្ត ។ ព្រះលោកនាយក ព្រះនាមបទុមុត្តរៈ ទ្រង់ជ្រាបច្បាស់នូវសត្វលោក ទ្រង់គួរទទួលយកនូវគ្រឿងបូជា ទ្រង់ទទួលនិមន្តហើយ ព្រោះទ្រង់ជ្រាបនូវបំណងរបស់ខ្ញុំ ។ លុះខ្ញុំបានដឹងថា ព្រះអង្គទ្រង់ទទួលនិមន្តហើយ ទើបចាត់ចែងនូវភោជនាហារបម្រុងថ្វាយដល់ព្រះសព្វញ្ញូ ទ្រង់ស្វែងរកគុណដ៏ធំ រួចហើយ ទើបក្រាបទូលកត្តកាល ។ លុះខ្ញុំក្រាបទូលនូវកត្តកាលរួចហើយ ទើបព្រះលោកនាយកព្រះនាមបទុមុត្តរៈ ស្តេចមកកាន់អារាមរបស់ខ្ញុំ ( មួយអន្លើ ) ដោយព្រះខីណាស្រព ប្រមាណមួយពាន់អង្គ ។ ខ្ញុំដឹងនូវវេលាដែលព្រះអង្គ ទ្រង់គង់ស៊ប់ហើយ ក៏បានញ៉ាំងព្រះអង្គឲ្យឆ្អែតស្កប់ស្កល់ ដោយបាយ និងទឹក លុះខ្ញុំដឹងនូវវេលាដែលព្រះអង្គសោយស្រេចហើយ ទើបក្រាបបង្គំទូលនូវពាក្យនេះថា បពិត្រព្រះមហាមុនី ខ្ញុំព្រះអង្គបានជាវទីដី អស់តម្លៃមួយសែនកហាបណៈ បានឲ្យគេសាងអារាម ឈ្មោះសោភនៈ ដោយតម្លៃកហាបណៈប៉ុណ្ណោះដែរ សូមព្រះអង្គទ្រង់ទទួល ។ ដោយការថ្វាយភូមិនេះផង ដោយការតម្កល់ចេតនាទាំងនេះផង ខ្ញុំព្រះអង្គកាលទៅ

កើតក្នុងភព ( ណាៗ ) សូមឲ្យបានសម្រេច តាមដែលខ្ញុំព្រះអង្គប្រាថ្នា ។

ព្រះសម្ពុទ្ធ ទ្រង់បានទទួលសង្ឃារាម ដែលខ្ញុំបានសាងល្អហើយ ព្រះអង្គគង់កណ្ដាលនៃជំនុំភិក្ខុសង្ឃ ហើយទ្រង់ត្រាស់នូវព្រះពុទ្ធដីកានេះថា បុគ្គលណា បានថ្វាយសង្ឃារាម ដែលខ្លួនបានសាងល្អហើយ ដល់ព្រះពុទ្ធ តថាគតនឹងព្យាករបុគ្គលនោះ អ្នកទាំងឡាយចូរស្ដាប់តថាគតសម្ដែងចុះ ។ សេនាមានអង្គ ៤ គឺដំរី សេះ រថពលថ្មើរជើង រមែងចោមបុគ្គលនេះជានិច្ច នេះជាផលនៃសង្ឃារាម ។ តូរ្យតន្ត្រី ៦០ ពាន់ និងស្គរប្រដាប់ល្អហើយ រមែងចោមរោមបុគ្គលនេះជានិច្ច នេះជាផលនៃសង្ឃារាម ។ ពួកនារីចំនួន ៨៦ ពាន់ ស្អិតស្អាងល្អហើយ សឹងស្លៀកសំពត់ និងគ្រឿងអាភរណៈដ៏វិចិត្រ ពាក់កុណ្ឌលជាវិការនៃកែវមណី ។ ( នារីទាំងនោះ ) មានមុខស្រស់រីករាយ មានសរីរៈល្អ មានចង្កេះរៀវ រមែងចោមរោមបុគ្គលនេះជានិច្ច នេះផលនៃសង្ឃារាម ។ បុគ្គលនេះ នឹងត្រេកអរក្នុងទេវលោក អស់ ៣០ ពាន់កប្ប បានជាធំជាងទេវតាសោយទេវរាជ្យ អស់ចំនួនមួយពាន់ដង ។ នឹងបានសម្បត្តិទាំងពួងដែលទេវរាជគប្បីបាន ជាអ្នកមានភោគៈមិនខ្វះខាត ហើយសោយរាជ្យក្នុងស្ថានទេវលោក ។ នឹងបានជាស្ដេចចក្រពត្តិក្នុងដែន អស់មួយពាន់ដង នឹងបានជាស្ដេចផែនដីដ៏ស្ដុកស្ដម្ភ គណនារាប់មិនបាន ។

លុះដល់មួយសែនកប្បទៀត ព្រះគោតមបរមគ្រូ កើតក្នុងត្រកូលឱក្កាកៈ នឹងបានជាសាស្តាក្នុងលោក ។ បុគ្គលនេះ នឹងបានជាឱរសជាទាយាទក្នុងធម៌ ជាធម្មនិម្មិត មាននាមថាឧបាលិ នឹងបានជាសាវ័ក នៃព្រះសាស្តាអង្គនោះ ។ នឹងដល់នូវត្រើយ ក្នុងព្រះវិន័យផង ឈ្លាសវៃក្នុងហេតុ និងមិនមែនហេតុផង ទ្រទ្រង់នូវសាសនារបស់ព្រះជិនស្រី ទាំងជាបុគ្គលមិនមានអាសវៈ ។ ព្រះគោតមជាបុគ្គលប្រសើរ ក្នុងសក្យត្រកូល ទ្រង់ជ្រាបជំណើរនុ៎ះ សព្វគ្រប់ហើយ ទ្រង់តាំងក្នុងកណ្តាលនៃភិក្ខុសង្ឃ ហើយនឹងតាំងឧបាលិនុ៎ះក្នុងឋានៈជាឯតទគ្គៈ ។

ខ្ញុំប្រាថ្នានូវសាសនា គឺពាក្យប្រៀនប្រដៅរបស់ព្រះអង្គ អាស្រ័យនូវកប្បរាប់មិនបាន ប្រយោជន៍ គឺការអស់ទៅ នៃសញ្ញោជនៈទាំងពួងនោះ ខ្ញុំក៏បានសម្រេចហើយ ។ បុរសជាប់ក្នុងដែកអណ្តាតត្រូវរាជទណ្ឌគំរាមហើយ មិនបានស្រួលក្នុងដែកអណ្តាត ប្រាថ្នាចង់ឲ្យរួចវិញ ដូចម្តេចមិញ ។ បពិត្រព្រះអង្គមានព្យាយាមធំ ខ្ញុំព្រះអង្គត្រូវអាជ្ញា គឺភពគំរាមហើយ ជាប់នៅហើយ ក្នុងដែកអណ្តាត គឺកម្ម ស្ថិតនៅហើយ ដោយកម្លាំងវេទនា គឺសេចក្តីស្រេកឃ្លាន ។ មិនបានស្រួលក្នុងភព ក្តៅក្រហាយដោយភ្លើងទាំង ៣ ស្វែងរកឧបាយ ដើម្បីនឹងរួចស្រឡះ ដូចបុរសដែលប្រាថ្នាដើម្បីរួចចាករាជទណ្ឌយ៉ាងនោះ ។ មួយទៀត បុរសអ្នកក្មៀវក្លា

ត្រូវពិសបៀតបៀនហើយ គេក៏គប្បីស្វែងរកនូវឱសថ ជាឧបាយ ដើម្បីបន្សាបនូវពិស ។ កាលស្វែងរក ក៏បានឃើញនូវឱសថ ដែលជាគ្រឿងបន្សាបនូវពិស ក៏ផឹកនូវឱសថនោះ ហើយក៏បាន សេចក្ដីសុខ ព្រោះរួចផុតអំពីពិស យ៉ាងណាមិញ ។ បពិត្រព្រះអង្គ មានព្យាយាមដ៏ធំ ខ្ញុំព្រះអង្គ ក៏ដូចជាជនអ្នកលង់នៅក្នុងពិស ត្រូវ អវិជ្ជាបៀតបៀនហើយ បានស្វែងរកឱសថ គឺព្រះសទ្ធម្ម ។ កាល ស្វែងរកឱសថ គឺធម៌ ក៏ប្រទះនូវសាសនារបស់ព្រះសក្យមុនីសម្ពុទ្ធ ជាឱសថ គឺសច្ចៈដ៏ប្រសើរបំផុត ជាថ្នាំសម្រាប់បន្ទោបង់នូវសរ ទាំងពួង ។ ខ្ញុំព្រះអង្គបានផឹកឱសថ គឺធម៌ ហើយដកនូវពិសទាំង ពួងចោលចេញ ក៏បានឃើញព្រះនិព្វាន ជាគុណឥតមានចាស់ ស្លាប់ មានសភាពត្រជាក់ ក៏យ៉ាងនោះដែរ ។ បុរសត្រូវខ្មោច គំរាមហើយ ត្រូវគ្រោះថ្នាក់ គឺខ្មោចបៀតបៀនហើយ គប្បីស្វែង រកពេទ្យ សម្រាប់ចាប់ខ្មោច ដើម្បីឲ្យរួចផុតអំពីខ្មោច ។ បុរស នោះកំពុងតែស្វែងរក ក៏បានឃើញបុគ្គលអ្នកឈ្លាសវៃ ក្នុងវិជ្ជា ចាប់ខ្មោច បុគ្គលនោះ ក៏បានបំបរបង់ខ្មោច ព្រមទាំងធ្វើឫសគល់ ឲ្យវិនាស អំពីបុរសនោះចេញ យ៉ាងណាមិញ ។ បពិត្រព្រះអង្គ មានព្យាយាមធំ ខ្ញុំព្រះអង្គត្រូវគ្រោះថ្នាក់ គឺងងឹតបៀតបៀនហើយ ក៏ខំស្វែងរកពន្លឺ គឺញាណ ដើម្បីឲ្យផុតអំពីងងឹត ក៏បានប្រទះ ឃើញព្រះសក្យមុនី ទ្រង់ជម្រះងងឹត គឺកិលេសរួចហើយ ព្រះអង្គ

ទ្រង់កម្ចាត់ងងឹតរបស់ខ្ញុំព្រះអង្គ ដូចជាពេទ្យចាប់ខ្មោច បានបណ្តេញបង់នូវខ្មោចចេញ ។ ខ្ញុំព្រះអង្គបានផ្តាច់បង់នូវខ្សែ គឺសង្សារ ហាមឃាត់នូវខ្សែ គឺតណ្ហា ដកចោលនូវភពទាំងអស់ ប្រៀបដូចពេទ្យចាប់ខ្មោច ( បៀតបៀនខ្មោច ) ឲ្យអស់ឫសគល់ ក៏យ៉ាងនោះដែរ ។ សត្វគ្រុឌ ឆាបយកពួកនាគ ជាចំណីរបស់ខ្លួន ធ្វើមហាស្រះទំហំ ១០០ យោជន៍ដោយជុំវិញ ឲ្យរំភើបញាប់ញ័រ ។ លុះគ្រុឌនោះ ឆាបយកនាគ ធ្វើឲ្យមានក្បាលចុះក្រោម ឲ្យបានសេចក្តីលំបាក ហើយនាំយកទៅកាន់ទីតាមសេចក្តីប្រាថ្នារបស់ខ្លួន យ៉ាងណាមិញ ។ បពិត្រព្រះអង្គមានព្យាយាមធំ ខ្ញុំព្រះអង្គ មានកម្លាំងខ្លាំង ដូចគ្រុឌ ខ្ញុំព្រះអង្គកំពុងស្វែងរកអសង្ខតធម៌ គឺព្រះនិព្វានហើយ បានខ្ជាក់ទោសចោលចេញអស់ហើយ ។ ខ្ញុំព្រះអង្គបានឃើញព្រះធម៌ ដ៏ប្រសើរ ជាចំណែកនៃសេចក្តីស្ងប់រម្ងាប់ មិនមានគុណជាតដទៃប្រសើរលើស ហើយកាន់យកនូវធម៌នោះ ដូចគ្រុឌឆាបយកនាគ ក៏យ៉ាងនោះដែរ ។ វល្លិឈ្មោះអាសាវតី កើតក្នុងចិត្តលតាវ័ន កន្លងទៅមួយពាន់ឆ្នាំ វល្លិនោះ ក៏កើតផ្លែមួយឡើង ។ ពួកទេវតា ( ក្នុងស្ថានតាវត្តិង្ស ) តែងនាំគ្នាចូលទៅអង្គុយជិតវល្លិនោះ ដែលមានផ្លែយូរៗ ម្តង តាមពិត វល្លិឈ្មោះអាសាវតីនោះ មានផ្លែដ៏ឧត្តម ជាទីពេញចិត្តរបស់ពួកទេវតា យ៉ាងនេះ ។ ចំណែកខាងខ្ញុំព្រះអង្គ ខំបម្រើព្រះមុនីអង្គនោះ រាប់សែនកប្ប ( ប៉ុណ្ណោះ ) តែងនមស្ការ

រាល់ព្រឹកល្ងាច ដូចជាពួកទេវតា តែងចូលទៅអង្គុយជិតវល្លិ៍អាសាវតី ។ ការបម្រើ ( របស់ខ្ញុំព្រះអង្គ ) មិនឥតអំពើ ទាំងការនមស្ការក៏មិនជាមោឃៈ ពុទ្ធុប្បាទក្ខណៈ ក៏មិនបានប្រព្រឹត្តកន្លងនូវខ្ញុំព្រះអង្គ អស់កាលជាយូរអង្វែង ។ ឥឡូវនេះ ខ្ញុំព្រះអង្គត្រិះរិះទៅ មិនឃើញបដិសន្ធិ ក្នុងភពថ្មីទៀតទេ ខ្ញុំព្រះអង្គមិនមានឧបធិក្កិលេស រួចស្រឡះចាកសង្សារ មានចិត្តស្ងប់រម្ងាប់ ។ ធម្មតាផ្កាឈូក តែងរីក ដោយសាររស្មីនៃព្រះអាទិត្យ យ៉ាងណាមិញ បពិត្រព្រះអង្គមានព្យាយាមធំ ខ្ញុំព្រះអង្គបានរីក ដោយសាររស្មីព្រះពុទ្ធ ក៏យ៉ាងនោះដែរ ។ កំណើតកុកស មិនមានឈ្មោលសព្វៗកាលទេ កាលបើមេឃគំរាម ( ផ្គរលាន់ ) កុកទាំងនោះ ក៏កាន់យកនូវគភ៌សព្វៗ កាល ។ កុកទាំងនោះ ទ្រទ្រង់គភ៌អស់កាលដ៏យូរដរាបទាល់តែមេឃលែងគំរាម ទាល់តែមេឃបង្អុរភ្លៀង ទើបកុកទាំងនោះ រួចផុតចាកភារៈ យ៉ាងណាមិញ ។ កាលព្រះពុទ្ធព្រះនាមបទុមុត្តរៈ ទ្រង់គំរាមដោយមេឃ គឺធម៌ ខ្ញុំព្រះអង្គបានកាន់យកនូវគភ៌ គឺធម៌ ដោយសំឡេងនៃមេឃ គឺធម៌ ។ ខ្ញុំព្រះអង្គទ្រទ្រង់នូវគភ៌ គឺបុណ្យ រាប់សែនកប្ប មេឃ គឺធម៌ មិនគំរាម ( ដរាបណា ) ខ្ញុំក៏មិនបានរួចចាកភារៈធ្ងន់ ( ដរាបនោះ ) ។ បពិត្រព្រះសក្យមុនី ពេលណា ព្រះអង្គទ្រង់គំរាមដោយមេឃ គឺធម៌ ក្នុងក្រុងកបិលពស្តុដែលជាទីត្រេកអរ ខ្ញុំព្រះអង្គក៏បានរួចចាកភារៈដ៏ធ្ងន់ យ៉ាងនោះ

ដែរ ។ ខ្ញុំព្រះអង្គ ( បានទាំងធ្វើឲ្យជាក់ច្បាស់ ) នូវសុញ្ញតវិមោក្ខផង អនិមិត្តវិមោក្ខផង អប្បណិហិតវិមោក្ខផង ត្រាស់ដឹងនូវធម៌ទាំងពួង គឺផលទាំង ៤ ផង ទម្លាយនូវធម៌ គឺបណ្តាញនោះផង ។

**ទុតិយភាណវារ ចប់**

ខ្ញុំព្រះអង្គ ប្រាថ្នានូវសាសនា របស់ព្រះអង្គ រាប់កប្បប្រមាណមិនបាន ប្រយោជន៍ គឺចំណែកនៃសេចក្តីស្ងប់ដ៏ប្រសើរបំផុត ខ្ញុំព្រះអង្គបានសម្រេចហើយ ។ ខ្ញុំព្រះអង្គដល់នូវត្រើយក្នុងព្រះវិន័យ ដូចភិក្ខុអ្នកស្វែងរកនូវគុណ អ្នកសូត្រ ( ក្នុងជំនាន់សាសនាព្រះពុទ្ធព្រះនាមបទុមុត្តរៈនោះដែរ ) ភិក្ខុជាអ្នកមានគុណស្មើ នឹងខ្ញុំព្រះអង្គមិនមានឡើយ ខ្ញុំព្រះអង្គទ្រទ្រង់សាសនា ។ សេចក្តីសង្ស័យរបស់ខ្ញុំព្រះអង្គ ក្នុងវិន័យទុំៈផង ក្នុងខន្ធកវិន័យផង ក្នុងតិកច្ឆេទៈផង ក្នុងបញ្ចកៈផង សូម្បីតែអក្ខរៈមួយ ឬក៏ព្យញ្ជនៈមួយមិនមានឡើយ ។ ខ្ញុំព្រះអង្គដល់នូវត្រើយ ក្នុងព្រះវិន័យទាំងពួង វាងវៃក្នុងការសង្កត់សង្កិនភិក្ខុបាបផង ក្នុងបដិកម្ម គឺការសម្តែងអាបត្តិផង ក្នុងហេតុដ៏គួរនិងមិនគួរផង ក្នុងឱសារណកម្ម គឺហៅភិក្ខុចូលកាន់ទីប្រជុំសង្ឃក្នុងកាលញ៉ាំងភិក្ខុឲ្យចេញចាកអាបត្តិផង ។ ខ្ញុំព្រះអង្គ បានរៀបទុកដាក់នូវចំណែកក្នុងវិន័យផង ក្នុងខន្ធកៈផង ក្នុងឧភតោវិភង្គផង ហើយគប្បីឲ្យប្រជុំចុះ ដោយកិច្ចបាន ។ ខ្ញុំព្រះអង្គជាអ្នកឈ្លាសវៃក្នុងវោហារផង វាងវៃក្នុងហេតុចម្រើន និងហេតុមិនចម្រើនផង

សកាលដែលខ្ញុំព្រះអង្គ មិនចេះដឹង ( នោះ ) មិនមានឡើយ ខ្ញុំព្រះអង្គ ជាភិក្ខុខ្ពស់ឯក ក្នុងសាសនារបស់ព្រះសាស្តា ។ ក្នុងថ្ងៃនេះ ខ្ញុំព្រះអង្គជាបុគ្គលយល់រូប ក្នុងសាសនានៃព្រះពុទ្ធជាសក្យបុត្ត ហើយបន្ទោបង់នូវកង្ខាទាំងពួង កាត់បង់នូវសង្ស័យទាំងអស់បាន ។ ខ្ញុំព្រះអង្គ ( ដឹងច្បាស់ ) នូវបទផង អនុបទផង អក្ខរៈផង ព្យញ្ជនៈផង ឈ្លាសវៃក្នុងហេតុសព្វអន្ទើ គឺហេតុជាទីតាំង ( ខាងដើម ) និងហេតុជាទីតាំងខាងចុង ( នៃសិក្ខាបទ ) ។ ព្រះរាជាមានកម្លាំង ទ្រង់សង្កត់សង្កិន នូវពួកស្តេចជាសត្រូវ លុះទ្រង់ឈ្នះសង្គ្រាមហើយ ទើបសាងទីក្រុងក្នុងដែន ដែលទ្រង់ឈ្នះហើយនោះ ។ ទ្រង់ឲ្យជាងធ្វើកំពែង ស្នាមភ្លោះ សសរខឿន ខ្លោងទ្វារ និងប៉មទាំងឡាយផ្សេងៗ ជាច្រើនក្នុងនគរ ។ ទ្រង់ឲ្យជាងធ្វើនូវផ្លូវត្រឡែងកែង ផ្លូវថ្នល់ រានផ្សារជាចន្លោះ ដែលតាក់តែងល្អ ព្រមទាំងសភាសម្រាប់វិនិច្ឆ័យ នូវសេចក្តីចម្រើន និងសេចក្តីមិនចម្រើនក្នុងនគរនោះ ។ ព្រះរាជាអង្គនោះ ទ្រង់តាំងសេនាមាត្យដើម្បីឲ្យសង្កត់សង្កិននូវពួកសត្រូវ ឲ្យស្គាល់ទោស និងមិនមែនទោស ដើម្បីរក្សានូវពួកពល ។ ព្រះរាជាអង្គនោះ ទ្រង់តាំងបុរសអ្នករក្សានូវកណ្ឌៈ ជាអ្នកឈ្លាសវៃក្នុងការទុកដាក់ ដើម្បីប្រយោជន៍រក្សានូវកណ្ឌៈដោយព្រះរាជបំណងថា កុំឲ្យកណ្ឌៈរបស់អាត្មាអញវិនាសទៅបានឡើយ ។ បុរសនោះ ជាអ្នកមានចិត្តស្វាមីភក្តិចំពោះព្រះរាជា ព្រោះ

ព្រះរាជា ប្រាថ្នាការចម្រើន ដល់បុរសណា ទ្រង់ក៏ព្រះរាជទាន នូវឥស្សរៈ ក្នុងការវិនិច្ឆ័យអធិករណ៍ដល់បុរសនោះ ដើម្បីប្រតិបត្តិ កុំឲ្យបែកមិត្ត ។ ព្រះរាជានោះ ទ្រង់តាំងបុរសអ្នកវាងវៃ ក្នុងឧប្បាទហេតុទាំងឡាយផង ក្នុងនិមិត្តទាំងឡាយផង ក្នុងលក្ខណៈទាំងឡាយផង ជាអ្នកបង្រៀនមន្ត្រ បេះចាំមន្ត្រ ក្នុងឋានៈជាបុរោហិត ។ ព្រះរាជាបរិបូណ៌ដោយអង្គទាំងឡាយនុ៎ះហើយ ទើបហៅថាក្សត្រិយ៍ បុរសទាំងនោះ តែងរក្សាព្រះរាជានោះសព្វៗ កាល ដូចសត្វចាក-ក្រពាក រក្សាក្រុមញាតិ ដែលដល់សេចក្តីទុក្ខ ។ បពិត្រព្រះអង្គមានព្យាយាមធំ អ្នកផងតែងហៅព្រះអង្គថា ធម្មរាជរបស់សត្វលោក ព្រមទាំងទេវលោក ដូចក្សត្រិយ៍ ដែលកម្ចាត់សត្រូវហើយ ដូច្នោះដែរ ។ ព្រះធម្មរាជនោះ ទ្រង់ញាំញីនូវពួកតិរ្ថិយទាំងឡាយផង នូវមារ ព្រមទាំងសេនាផង ទ្រង់ទម្លាយមោហន្ធការដ៏ងងឹត រួចហើយ កសាងធម្មនគរ ។ បពិត្រព្រះអង្គមានបញ្ញាជាគ្រឿងទ្រទ្រង់ ឯក្នុងធម្មនគរនោះ មានសីលជាកំពែង មានញាណរបស់ព្រះអង្គជាខ្លោងទ្វារ មានសទ្ធារបស់ព្រះអង្គ ជាសសរខឿន មានការសង្រួម ជានាយឆ្មាំទ្វារ ។ បពិត្រព្រះមុនី សតិប្បដ្ឋាន ជាប៉មបញ្ញារបស់ព្រះអង្គ ជាផ្លូវថ្នល់ ឥទ្ធិបាទ ជាផ្លូវត្រឡែងកែង ថ្នល់គឺពោធិបក្ខិយធម៌ទាំង ៣៧ ព្រះអង្គទ្រង់និម្មិតទុកល្អហើយ ។ ព្រះសូត្រ ព្រះអភិធម្ម និងព្រះវិន័យ ពុទ្ធវចនៈមានអង្គ ៩ ទាំងអស់

ន្ទុំះ ជាធម្មសការបស់ព្រះអង្គ ។ សុញ្ញតវិហារ អនិមិត្តវិហារ អប្បណិហិតវិហារ ការមិនមានតណ្ហា ជាគ្រឿងញាប់ញ័រ និងការរម្ងត់ទុក្ខ នេះជាធម្មកុដិរបស់ព្រះអង្គ ។ ព្រះថេរៈជាបុគ្គលប្រសើរ ខាងប្រាជ្ញា ដែលព្រះអង្គតាំងទុកហើយ ជាអ្នកវាងវៃក្នុងប្រាជ្ញា មានឈ្មោះថាសារីបុត្ត ជាធម្មសេនាបតីរបស់ព្រះអង្គ ។ បពិត្រព្រះមុនី ព្រះថេរៈដែលឈ្លាសវៃក្នុងចុតូបបាតញ្ញាណ គឺប្រាជ្ញាដែលដឹងនូវចុតិ និងបដិសន្ធិរបស់សត្វ ដល់នូវត្រើយនៃឫទ្ធិ មានឈ្មោះថាកោលិតៈ ជាបុរោហិតរបស់ព្រះអង្គ ។ បពិត្រព្រះមុនី ព្រះថេរៈឈ្មោះកស្សបៈ អ្នកទ្រទ្រង់វង្សបុរាណ មានតេជៈដ៏ខ្ពង់ខ្ពស់ ដែលគេគ្របសង្កត់បានដោយក្រ ប្រសើរក្នុងគុណ មានការកម្ចាត់បង់នូវទោសជាដើម គឺទ្រទ្រង់ធុតង្គទាំង ១៣ ជាអ្នកសម្រាប់ពិភាក្សារបស់ព្រះអង្គ ។ បពិត្រព្រះមុនី ព្រះថេរៈជាពហុស្សូត អ្នកទ្រទ្រង់ធម៌ ចេះចាំពុទ្ធវចនៈទាំងអស់ក្នុងសាសនា មាននាមថាអានន្ទ ជាអ្នករក្សាធម៌របស់ព្រះអង្គ ។ ព្រះមានព្រះភាគរបស់ខ្ញុំ ជាអ្នកស្វែងរកគុណដ៏ធំ ទ្រង់ប្រទានការវិនិច្ឆ័យក្នុងវិន័យ ដែលវិញ្ញូភិក្ខុទាំងឡាយសម្តែងហើយ ដល់ខ្ញុំព្រះអង្គ រំលងព្រះថេរៈទាំងអស់ន្ទុំះ ។ ពុទ្ធសាវកណាមួយ សួរបញ្ហាក្នុងវិន័យ ( នឹងខ្ញុំព្រះអង្គ ) ខ្ញុំព្រះអង្គមិនបាច់គិតក្នុងបញ្ហានោះទេ ខ្ញុំព្រះអង្គប្រាប់សេចក្តីនោះតែម្តង ។ ពុទ្ធក្ខេត្ត កំណត់ត្រឹមណា វៀរលែងតែព្រះមហាមុនីចេញ មិនមាន

ភិក្ខុណា នឹងស្មើដោយខ្ញុំព្រះអង្គ ក្នុងវិន័យ តើនឹងមានភិក្ខុប្រសើរ លើសខ្ញុំព្រះអង្គពីណា ។ ព្រះគោតម ទ្រង់គង់ក្នុងកណ្ដាលជំនុំភិក្ខុសង្ឃ ហើយទ្រង់ប្រកាសយ៉ាងនេះថា ភិក្ខុណាមួយ ជាអ្នកស្មើដោយឧបាលិ ក្នុងវិន័យ និងខន្ធកៈ មិនមានឡើយ ។ សត្ថុសាសនាមានអង្គ ៩ ដែលព្រះពុទ្ធសម្ដែងហើយ ទាំងអម្បាលម៉ាន ខ្ញុំព្រះអង្គជាអ្នកឃើញឫសគល់របស់វិន័យ ( កាត់បង់ ) នូវសេចក្ដីជាប់ជំពាក់ទាំងពួង ដែលព្រះអង្គសម្ដែងហើយ ក្នុងវិន័យ ។ ព្រះគោតមជាបុគ្គលប្រសើរ ក្នុងសក្យត្រកូល ទ្រង់រឭកឃើញនូវអំពើរបស់ខ្ញុំ ហើយគង់ក្នុងភិក្ខុសង្ឃ ទ្រង់តម្កល់ខ្ញុំក្នុងទីជាឯតទគ្គៈ ។ ខ្ញុំបានប្រាថ្នាយកនូវតំណែងនេះ រាប់សែនកប្បមកហើយ ឥឡូវនេះប្រយោជន៍នោះ ខ្ញុំបានសម្រេចហើយ ខ្ញុំបានដល់នូវត្រើយ ក្នុងព្រះវិន័យហើយ ។ កាលពីដើម ខ្ញុំជានាយខ្មាន់ព្រះកេស ជាអ្នកបណ្ដុះសេចក្ដីត្រេកអរដល់ពួកសក្យៈ លះបង់កំណើតនោះចោលចេញ បានមកជាបុត្តរបស់ព្រះមហេសីសម្ពុទ្ធវិញ ។ ក្នុងកប្បទី ២ រាប់អំពីកទ្រកប្បនេះទៅ មានក្សត្រិយ៍ឈ្មោះអញ្ជសៈ មានតេជះរកទីបំផុតគ្មាន មានយសរាប់មិនបាន ជាម្ចាស់ផែនដី មានទ្រព្យច្រើន ។ ខ្ញុំជាព្រះរាជបុត្តរបស់ព្រះរាជានោះ ជាក្សត្រិយ៍ឈ្មោះចន្ទនៈ ជាអ្នករឹងត្អឹង ដោយស្រវឹងព្រោះជាតិផង ដោយស្រវឹងព្រោះយសសក្តិ និងភោគៈផង ។ មានពួកដំរីមាតង្គៈ ចំនួន ១ សែន

សុទ្ធតែចុះប្រេង ដោយហេតុ ៣ ប្រការ ដ៏ប្រដាប់ដោយគ្រឿងអលង្ការទាំងពួង ចោមរោមខ្ញុំសព្វៗ កាល ។ វេលានោះ ខ្ញុំមានពួកពលរបស់ខ្លួនចោមរោមហើយ ប្រាថ្នាទៅកាន់ឧទ្យាន ឡើងជិះដំរីឈ្មោះសិរិកៈ ចេញអំពីនគរទៅ ។ ស្រាប់តែមានព្រះបច្ចេកសម្ពុទ្ធព្រះនាមរេវតៈ ទ្រង់បរិបូណ៌ដោយចរណៈ មានទ្វារគ្រប់គ្រង សង្រួមល្អ បាននិមន្តមកចំពោះមុខខ្ញុំ ។ វេលានោះ ខ្ញុំបានបរដំរីឈ្មោះសិរិកៈ ទៅឲ្យបៀតបៀនព្រះសម្ពុទ្ធ លំដាប់នោះ ដំរីក៏ក្រោធខឹងមិនលើកជើង ។ លុះខ្ញុំឃើញដំរីមានចិត្តខឹង ក៏ក្រេវក្រោធនឹងព្រះពុទ្ធជាម្ចាស់ បៀតបៀនព្រះសម្ពុទ្ធហើយ ក៏ទៅក្នុងឧទ្យាន ។ ខ្ញុំមិនបានទូវសេចក្តីសុខស្រួល ក្នុងឧទ្យាននោះ ក្បាល ( របស់ខ្ញុំ ) ហាក់ដូចជាភ្លើងឆេះ ខ្ញុំក្តៅអន្ទះអន្ទែង ដោយសេចក្តីក្រហល់ក្រហាយដូចត្រីជាប់សន្ទូច ។ ផែនដីដែលមានសាគរជាទីបំផុត ហាក់ដូចជាដុតកម្តៅខ្ញុំ ទើបខ្ញុំចូលទៅកាន់សម្នាក់នៃព្រះបិតា ហើយក្រាបបង្គំទូលថា យើងខ្ញុំបៀតបៀនព្រះពុទ្ធសយម្ភូណា ដូចបុគ្គលបៀតបៀនអាសិរពិស ដែលកំពុងក្រោធ ឬដូចបុគ្គលបៀតបៀនគំនរភ្លើងដែលឆេះរាលមក ឬក៏ដូចបុគ្គលបៀតបៀនដំរីមានភ្លុក ដែលចុះប្រេង ។ ព្រះពុទ្ធជាម្ចាស់អង្គនោះ មានតបៈដ៏ខ្ពង់ខ្ពស់ ក្លៀវក្លា ជាព្រះជិនស្រី យើងខ្ញុំបៀតបៀនហើយ យើងខ្ញុំទាំងអស់គ្នា នឹងវិនាស យើងខ្ញុំនឹងញុំាងព្រះសយម្ភូ ជាមុនីអង្គនោះ ឲ្យអត់ទោស ។

ប្រសិនបើយើងខ្ញុំ នឹងមិនបានញ៉ាំងព្រះពុទ្ធ ដែលមានខ្ជួនទូន្មាន ហើយ មានព្រះហឫទ័យខ្ជាប់ខ្ជួននោះ ឲ្យអត់ទោសទេ ដែនរបស់យើងខ្ញុំ មុខជាវិនាស ថយពីថ្ងៃទី ៧ ទៅមិនខាន ។ ក្សត្រិយ៍ ៤ ព្រះអង្គ ព្រះនាមសុមេខលៈ ១ កោសេយ្យៈ ១ សិគ្គវៈ ១ សត្តកៈ ១ ជាមួយនឹងពួកសេនានោះ បានបៀតបៀនឥសីទាំងឡាយ ហើយដល់នូវសេចក្ដីវិនាស ។ ពួកឥសីអ្នកសង្រួម ប្រព្រឹត្តព្រហ្មចរិយធម៌ ក្រោធខឹងក្នុងកាលណា រមែងធ្វើសត្វលោក ព្រមទាំងទេវលោក ទាំងសមុទ្រ និងភ្នំ ឲ្យវិនាសទៅបាន ។ ខ្ញុំបានប្រជុំពួកបុរសក្នុងទី ៣ ពាន់យោជន៍ បានចូលទៅគាល់ព្រះសយម្ភូ ដើម្បីនឹងសម្ដែងទោស ។ ពួកបុរសទាំងពួង ស្លៀកសំពត់ទទឹក មានក្បាលទទឹក ធ្វើក្រពុំម្រាមដៃ ក្រាបទៀបព្រះពុទ្ធ ហើយទូលថា បពិត្រព្រះអង្គ មានព្យាយាមធំ សូមព្រះអង្គអត់ទោស ( ព្រោះ ) ជនសូមទោសនឹងព្រះអង្គ សូមព្រះអង្គរម្ងាប់ក្រវល់ក្រវាយ សូមព្រះអង្គកុំធ្វើដែន ( របស់យើងខ្ញុំ ) ឲ្យវិនាសឡើយ ។ ( ប្រសិនបើព្រះអង្គមិនអនុគ្រោះទេ ) ពួកបុរសទាំងអស់ ព្រមទាំងទេវតា និងមនុស្ស ទាំងអ្នកធ្វើទាន ទាំងអ្នកថែរក្សា គេនឹងយកញញួរដែកមកទម្លាយអំបែងក្បាលយើងខ្ញុំ សព្វៗ កាល ។ ( ព្រះសម្ពុទ្ធទ្រង់ត្រាស់ថា ) ភ្លើងមិនស្ថិតនៅក្នុងទឹក ពូជមិនដុះលើថ្មភ្នំ ដង្កូវមិនស្ថិតនៅក្នុងឱសថ សេចក្ដីក្រោធមិនកើតក្នុងព្រះពុទ្ធ ។ ផែនដីមិនកម្រើក

សមុទ្រសាគរប្រមាណមិនបាន អាកាសរកទីបំផុតគ្មាន យ៉ាងណាមិញ ព្រះពុទ្ធទាំងឡាយ មានព្រះហឫទ័យ មិនរញ្ជួយញាប់ញ័រក៏យ៉ាងនោះដែរ ។ ព្រះពុទ្ធទាំងឡាយ មានព្យាយាមធំ មានខ្ជួនទូន្មាន ទ្រង់អត់ធន់ មានតបៈ ពួកបុគ្គលអ្នកអំណត់អត់ធន់ មិនមានការលុះក្នុងអគតិ ។ ព្រះបច្ចេកសម្ពុទ្ធ ទ្រង់ពោលដូច្នេះហើយទើបរម្ងាប់ក្រវល់ក្រវាយរបស់ខ្ញុំ ហើយហោះទៅតាមអាកាស ក្នុងទីចំពោះមុខមហាជន ក្នុងកាលនោះ ។ បពិត្រព្រះអង្គ មានព្យាយាមព្រោះអំពើនោះហើយ បានជាខ្ញុំព្រះអង្គចូលទៅកាន់ ភាពជាអ្នកថោកទាប លុះកន្លងជាតិនោះមកហើយ ក៏បានចូលទៅកាន់អភយបុរី គឺព្រះនិព្វាន ។ បពិត្រព្រះអង្គ មានព្យាយាមធំ វេលានោះ ព្រះពុទ្ធបានញុំាងខ្ញុំព្រះអង្គ ដែលកំពុងក្តៅក្រហាយ នៅមិនទាន់រលត់ ឲ្យបន្ទោបង់ក្រវល់ក្រវាយចេញ ខ្ញុំព្រះអង្គបានញុំាងព្រះសយម្ភូឲ្យអត់ទោស ។ បពិត្រព្រះអង្គមានព្យាយាមធំ ក៏ក្នុងថ្ងៃនេះព្រះអង្គបានញុំាងខ្ញុំព្រះអង្គ ដែលកំពុងក្តៅក្រហាយ ដោយភ្លើងទាំង ៣ ឲ្យរលត់ផង ញុំាងភ្លើងទាំង ៣ ឲ្យរលត់ផង ឥឡូវនេះ ខ្ញុំព្រះអង្គបានដល់នូវភាពត្រជាក់ហើយ ។ លោកទាំងឡាយណាមានការតម្កល់នូវសោតប្រសាទ លោកទាំងនោះ ចូរស្តាប់ខ្ញុំចុះ ខ្ញុំនឹងប្រាប់ប្រយោជន៍ដល់អ្នក ដូចជាចំណែកដែលខ្ញុំបានឃើញ ។ ខ្ញុំបានមើលងាយព្រះសយម្ភូនោះ ដែលមានព្រះហឫទ័យស្ងប់រម្ងាប់

មានព្រះហឫទ័យខ្ជាប់ខ្ជួន ដោយកម្មនោះហើយ បានជាក្នុងថ្ងៃនេះ ខ្ញុំមកកើតក្នុងកំណើតថោកទាប ។ អ្នកទាំងឡាយ កុំឲ្យខណៈឃ្លាតទៅទេ ព្រោះបុគ្គលដែលខណៈកន្លងហើយ រមែងសោកសៅ អ្នកទាំងឡាយ គប្បីព្យាយាម ក្នុងប្រយោជន៍របស់ខ្លួន ( ព្រោះ ) ខណៈប្រាកដដល់អ្នកទាំងឡាយហើយ ។ ជនពួកខ្លះ បានថ្នាំក្អួត ជនពួកខ្លះ បានថ្នាំបញ្ចុះ ជនពួកខ្លះ បានថ្នាំពិសដែលខ្លាំង ជនពួកខ្លះ បានឱសថ ។ ថ្នាំក្អួតសម្រាប់ពួកបុគ្គល អ្នកប្រតិបត្តិ ( នូវមគ្គ ) ថ្នាំបញ្ចុះ សម្រាប់ពួកបុគ្គលអ្នក ស្ថិតនៅក្នុងផល ឱសថសម្រាប់ពួកបុគ្គលអ្នកបាននូវផល ជាអ្នកស្វែងរកបុញ្ញក្ខេត្ត ។ ពិសដែលខ្លាំងសម្រាប់បុគ្គល អ្នកប្រតិបត្តិខុសចាកសាសនា អាសិរពិសដែលមានពិសកាច តែងដុតនរៈនោះតែមួយជង ។ ពិសដ៏ខ្លាំងដែលបុគ្គលផឹកហើយ បៀតបៀនជីវិតបានតែមួយជង ឯបុគ្គលអ្នកប្រតិបត្តិខុសចាកសាសនា រមែងក្តៅក្រហាយ អស់កោដិនៃកប្ប ។ គេតែងឆ្លងចាកលោក ព្រមទាំងទេវលោក ដោយការអត់ធន់ ១ ដោយការមិនបៀតបៀន ១ ដោយមានចិត្តមេត្តា ១ ហេតុនោះ បុគ្គលមិនគប្បីឲ្យត្អាំត្អូង នឹងព្រះពុទ្ធទាំងនោះ ។ ព្រះពុទ្ធទាំងឡាយមាន ព្រះហឫទ័យស្មើដោយផែនដី មិនជាប់ជំពាក់ក្នុងលាភ និងអលាភ ក្នុងការរាប់អាន ក្នុងការមើលងាយ ហេតុនោះ បុគ្គលមិនគប្បីឲ្យត្អាំត្អូងនឹងព្រះពុទ្ធទាំងនោះ ។ ព្រះមុនី មានហឫទ័យស្មើ

ចំពោះសត្វទាំងពួង គឺទេវទត្ត ខ្មាន់ធ្នូ ចោរអង្គុលិមាល រាហុល និងដំរីធនបាល ។ ព្រះពុទ្ធមិនមានសេចក្តីស្អប់ជនទាំងនុ៎ះ មិនមានសេចក្តីស្រឡាញ់ជនទាំងនុ៎ះទេ មានព្រះហឫទ័យស្មើ ចំពោះជនទាំងអស់ គឺចំពោះខ្មាន់ធ្នូ និងចំពោះឱរស ។ បុគ្គលបើឃើញសំពត់កាសាវៈ ជាទង់ជ័យរបស់ព្រះពុទ្ធ ដែលប្រឡាក់ដោយលាមក ដែលគេចោលហើយក្នុងផ្លូវ គប្បីធ្វើអញ្ជលី ថ្វាយបង្គំដោយត្បូង ។ ព្រះសម្ពុទ្ធទាំងឡាយ ដែលកន្លងទៅហើយក្តី ក្នុងបច្ចុប្បន្ននេះក្តី ក្នុងអនាគតក្តី តែងបរិសុទ្ធដោយទង់ជ័យនេះ ព្រោះហេតុនោះ ព្រះសម្ពុទ្ធទាំងនុ៎ះ បុគ្គលគប្បីនមស្ការ ។ ខ្ញុំចាំវិន័យដោយប្រពៃ គួរតាមអធ្យាស្រ័យរបស់ព្រះសាស្តា ដោយហឫទ័យខ្ញុំតែងនមស្ការវិន័យនោះសព្វៗ កាល ។ វិន័យ ជាទីអាស្រ័យវិន័យ ជាទីឈរ ទាំងជាទីចង្រ្កមរបស់ខ្ញុំ ខ្ញុំតែងដេកនៅក្នុងវិន័យវិន័យ ជាទីគោចររបស់ខ្ញុំ ។ បពិត្រព្រះអង្គមានព្យាយាមធំ ឧបាលិដល់នូវត្រើយក្នុងវិន័យផង ឈ្លាសវៃក្នុងសមថៈផង តែងថ្វាយបង្គំនូវព្រះបាទារបស់ព្រះសាស្តា ។ ខ្ញុំព្រះអង្គនោះ នឹងត្រាច់ទៅអំពីស្រុកមួយ ទៅកាន់ស្រុកមួយ អំពីបុរីមួយទៅកាន់បុរីមួយ ហើយនមស្ការនូវព្រះសម្ពុទ្ធផង នូវភាពនៃធម៌ជាធម៌ល្អផង ។ ខ្ញុំព្រះអង្គដុតកិលេសទាំងឡាយហើយ ដកចោលនូវភពទាំងអស់ហើយ អាសវៈទាំងពួង អស់រលីងហើយ ឥឡូវនេះ ភពថ្មីមិនមានទេ ។

ឱ ! ដំណើរ ដែលខ្ញុំមកក្នុងសម្នាក់របស់ព្រះពុទ្ធដ៏ប្រសើរ ( នេះ ) ជាដំណើរមកដោយល្អ វិជ្ជាទាំង ៣ ខ្ញុំព្រះអង្គបានសម្រេចហើយ សាសនារបស់ព្រះសម្ពុទ្ធ ខ្ញុំព្រះអង្គក៏បានប្រតិបត្តិហើយ ។ បដិ-សម្ភិទា ៤ វិមោក្ខ ៨ និងអភិញ្ញា ៦ នេះ ខ្ញុំបានធ្វើឲ្យជាក់ច្បាស់ហើយទាំងសាសនារបស់ព្រះសម្ពុទ្ធ ខ្ញុំក៏បានប្រតិបត្តិហើយ ។

បានឮថា ព្រះឧបាលិត្ថេរមានអាយុ បានសម្ដែងនូវគាថាទាំងនេះដោយប្រការដូច្នេះ ។

ឧបាលិត្ថេរាបទាន ចប់

# អដ្ឋកថា

## ឧបាលិត្ថេរាបទាន

[ ៨ ] អបទានរបស់ព្រះឧបាលិត្ថេរ មានពាក្យផ្ដើមថា **នគរេ ហំសវតិយា** ដូច្នេះ ។

ព្រះថេរៈនេះ មានអធិការដែលធ្វើហើយក្នុងព្រះសម្ពុទ្ធ សន្សំបុណ្យទាំងឡាយដែលជាឧបនិស្ស័យនៃព្រះនិព្វានក្នុងភពនោះៗ ។ ក្នុងកាលនៃព្រះមានព្រះភាគព្រះនាមបទុមុត្តរៈ កើតក្នុងត្រកូលព្រាហ្មណ៍ សម្បូរដោយទ្រព្យសម្បត្តិ ក្នុងនគរហង្សវតី ។ ថ្ងៃមួយ ស្ដាប់ធម៌ក្នុងសម្នាក់របស់ព្រះសាស្ដា ឃើញព្រះសាស្ដាទ្រង់ស្ថាបនាភិក្ខុមួយរូប ក្នុងតំណែងឯតទគ្គៈ ជាងភិក្ខុទាំងឡាយ ខាងទ្រទ្រង់ព្រះវិន័យ ទើបធ្វើអធិការដល់ព្រះសាស្ដា ហើយប្រាថ្នាតំណែងនោះ ។

កុលបុត្រនោះ ធ្វើកុសលដរាបដល់អស់ជីវិត អន្ទោលទៅក្នុងទេវតានិងមនុស្សទាំងឡាយ ក្នុងពុទ្ធុប្បាទកាលនេះ កើតក្នុងផ្ទះជាងកោរកាត់ ញាតិទាំងឡាយដាក់ឈ្មោះថា ឧបាលិ ។ ឧបាលីនោះចម្រើនវ័យហើយ បានជាសម្លាញ់ជាទីស្រឡាញ់នៃស្ដេច ៦ អង្គ មានស្ដេចអនុរុទ្ធជាដើម កាលព្រះតថាគតទ្រង់គង់នៅក្នុងអនុបិយម្ពវ័ន បានចេញបួស មួយអន្លើដោយក្សត្រទាំង ៦ អង្គ ដែលយាងចេញបួស ។ វិធីបព្វជ្ជារបស់ព្រះឧបាលីនោះ មានមកក្នុងព្រះបាលីនោះឯង ។

ព្រះឧបាលីនោះបព្វជ្ជាឧបសម្បទាហើយ រៀនព្រះកម្មដ្ឋានក្នុងសម្នាក់របស់ព្រះសាស្ដា ហើយក្រាបទូលថា បពិត្រព្រះអង្គដ៏ចម្រើន សូមទ្រង់

អនុញ្ញាតការនៅព្រៃដល់ខ្ញុំព្រះអង្គចុះ ។ ព្រះសាស្តាត្រាស់ថា ម្នាលភិក្ខុ ការនៅព្រៃនឹងបានធុរៈតែម្យ៉ាង តែការនៅក្នុងសម្នាក់របស់តថាគត វិបស្សនាធុរៈ និងគន្ថធុរៈ នឹងបរិបូណ៌ ។

ព្រះឧបាលីនោះ ទទួលព្រះតម្រាស់របស់ព្រះសាស្តាហើយ ធ្វើកម្មក្នុងវិបស្សនា មិនយូរប៉ុន្មាន ក៏បានសម្រេចអរហត្ត ។ ព្រះសាស្តា ទ្រង់ឲ្យព្រះឧបាលីនោះ រៀនព្រះវិនយបិដកទាំងអស់ដោយព្រះអង្គឯង ។ ក្នុងកាលតមក លោកបានវិនិច្ឆ័យរឿង ៣ គឺរឿងភារុកច្ឆៈ ១ រឿងអជ្ជុកៈ ១ រឿងកុមារកស្សបៈ ១ ។ ព្រះសាស្តា ទ្រង់ប្រទានសាធុការក្នុងការវិនិច្ឆ័យតែមួយរឿង ទ្រង់លើកយកការវិនិច្ឆ័យទាំង ៣ ឲ្យជាអត្ថុប្បត្តិហេតុ ទើបទ្រង់តែងតាំងព្រះថេរៈក្នុងតំណែងឯតទគ្គៈ ជាងភិក្ខុទាំងឡាយខាងទ្រទ្រង់ព្រះវិន័យ ។

ព្រះថេរៈកាលបានតំណែងឯតទគ្គៈយ៉ាងនេះហើយ រឭកដល់បុព្វកម្មរបស់ខ្លួន កើតសោមនស្ស កាលនឹងប្រកាសអបទាន គឺការប្រព្រឹត្តក្នុងកាលមុននោះ ទើបពោលពាក្យថា **នគរេ ហំសវតិយា** ដូច្នេះជាដើម ។

បណ្តាបទទាំងនោះ បទថា **ហំសវតិយា** សេចក្តីថា របង គឺកំពែងដោយអាការដូចហង្ស មានក្នុងនគរណា នគរនោះមានឈ្មោះថាហង្សវតី ។ ម្យ៉ាងទៀត ពួកហង្សរាប់មិនអស់ នៅអាស្រ័យនៅក្នុងបឹង ស្រះឈូក និងភក់ជាដើម ហើរត្រឡប់ដោយជុំវិញក្នុងនគរនោះ ព្រោះហេតុនោះ ទើបនគរនោះ ឈ្មោះថា ហង្សវតី ។ ក្នុងនគរហង្សវតីនោះ ។

បទថា **សុជាតោ នាម ព្រាហ្មណោ** សេចក្តីថា ឈ្មោះថា សុជាត

ព្រោះកើតល្អ អធិប្បាយថា កើតមកជាអ្នកមិនត្រូវតិះដៀលដោយពាក្យថា មិនត្រូវតិះដៀល មិនត្រូវមើលងាយ ។ បទថា **អសីតិកោដិនិចយោ** ក្ដាប់សេចក្ដីថា ព្រាហ្មណ៍ឈ្មោះសុជាតិ មានគំនរទ្រព្យ ៨០ កោដិ ឈ្មោះថា មានទ្រព្យ និងស្រូវសន្ទឹកសន្ធាប់ គឺមានទ្រព្យ និងស្រូវរាប់មិនអស់ ។

កាលនឹងសម្ដែងថា សុជាតព្រាហ្មណ៍នោះឯង ជាបុគ្គលធំ ទើបពោលពាក្យថា **អជ្ឈាយកោ** ដូច្នេះជាដើម ។ បណ្ដាបទទាំងនោះ បទថា **អជ្ឈាយកោ** សេចក្ដីថា ជាអ្នកប្រាប់ត្រៃវេទជាដើមដល់មនុស្សដទៃ ។ បទថា **មន្តធរោ** សេចក្ដីថា បញ្ញា លោកហៅថា **មន្ត** ជាអ្នកមានបញ្ញា ដឹងនូវការព្យាករណ៍មានអថព្វនវេទជាដើម ។ បទថា **តិណ្ណំ វេទាន បារគូ** សេចក្ដីថា ដល់នូវទីបំផុត គឺជាអ្នករៀនចប់នូវត្រៃវេទ ពោល គឺឥរុវេទ យជុវេទ និងសាមវេទ ។ បទថា **លក្ខណេ** បានដល់ គម្ពីរទាយលក្ខណៈ អធិប្បាយថា ក្នុងគម្ពីរទាយលក្ខណៈដែលមានក្នុងដៃ និងជើងជាដើមរបស់បុរសដែលជាពុទ្ធៈ ព្រះបច្ចេកពុទ្ធ និងស្ដេចចក្រពត្តិទាំងឡាយ ។ បទថា **ឥតិហាសេ** បានដល់ ក្នុងគម្ពីរដែលប្រកាសរឿងក្នុងគ្រាបុរាណថា **ឥតិហអាស ឥតិហអាស** យ៉ាងនេះ យ៉ាងនេះ ។ បទថា **សធម្មេ** សេចក្ដីថា ដល់នូវការសម្រេច គឺ ដល់ទីបំផុត គឺ ចុងបញ្ចប់ ក្នុងធម៌របស់ខ្លួន គឺ ធម៌របស់ព្រាហ្មណ៍ ។

បទថា **បរិព្វាជា** ក្ដាប់សេចក្ដីថា សាវករបស់និគ្គណ្ឋទាំងអស់ មានទិដ្ឋិផ្សេងគ្នា ក្នុងកាលនោះ នាំគ្នាត្រាច់ទៅលើផែនដី គឺលើផ្ទៃប្រឹថពី

អធិប្បាយថា ព្រះជិនស្រីមិនទាន់កើតឡើងដរាបណា គឺអស់កាលមានប្រមាណប៉ុនណា ពាក្យថា **តាវេ** ក៏មិនទាន់ដរាបនោះ គឺអស់កាល មានប្រមាណប៉ុណ្ណោះ ។

បទថា **អច្ចយេន អហោរត្តំ** សេចក្តីថា ថ្ងៃ និងយប់ ឈ្មោះថា **អហោរត្ត** អធិប្បាយថា ដោយឆ្នាំកន្លងទៅជាច្រើន ពាក្យដ៏សេស មានអត្ថងាយយល់ហើយ ។

បទថា **មន្តាណិបុត្តោ** សេចក្តីថា កូនរបស់កូនស្រីជាងកោរកាត់ឈ្មោះមន្តាណី[1] បានឈ្មោះថា បុណ្ណៈ ព្រោះគ្រប់ខែ គ្រប់ថ្ងៃ ភ្ជាប់សេចក្តីថា នឹងបានជាសាវករបស់ព្រះសាស្តាអង្គនោះ ។

បទថា **ឯវំ កិត្តយិ សោ តាវេ** សេចក្តីថា ព្រះមានព្រះភាគព្រះនាមបទុមុត្តរៈនោះទ្រង់ប្រកាស គឺទ្រង់បានព្យាករនូវសុនន្ទតាបស ដែលឲ្យនូវសោមនស្ស ដោយអាការដ៏ល្អយ៉ាងនេះ គឺដោយប្រការនេះ ភ្ជាប់សេចក្តីថា ទ្រង់ញុំាងជនទាំងពួង គឺពួកជនទាំងអស់ឲ្យត្រេកអរដោយល្អ គឺធ្វើឲ្យកើតសោមនស្ស កាលទ្រង់សម្តែងកម្លាំងរបស់ខ្លួន គឺកាលទ្រង់ធ្វើឲ្យប្រាកដ ។

លំដាប់បន្ទាប់ពីនោះ កាលសម្តែងអានុភាពរបស់ខ្លួន ដោយអាងដល់អ្នកដទៃ ទើបពោលពាក្យថា **កតញ្ជលី** ដូច្នេះជាដើម ភ្ជាប់សេចក្តីថា ក្នុងកាលមុន គឺក្នុងកាលមុនព្រះពុទ្ធកើតឡើងនោះ ជនទាំងពួង ធ្វើក្រពុំអញ្ជលីនមស្ការសុនន្ទតាបស ។ បទថា **តាវេ ការំ ករិត្វាន** សេចក្តីថា សុនន្ទ-

[1] បិដកខ្មែរ ជាមន្តានី ។

តាបសនោះ ជាបុគ្គលដែលជនទាំងពួងបូជាហើយយ៉ាងនេះ ក៏មិនប្រកាន់ខ្លួនថា ជាបុគ្គលដែលគេបូជា បានធ្វើកិច្ចដ៏ក្រៃលែង ក្នុងព្រះពុទ្ធសាសនា ធ្វើគតិ គឺការកើតរបស់ខ្លួនឲ្យបរិសុទ្ធ គឺធ្វើឲ្យបរិសុទ្ធ ។

បទថា **សុត្វាន មុនិនោ វចំ** បានដល់ ព្រះវាចារបស់ព្រះសម្មាសម្ពុទ្ធអង្គនោះ ដើម្បីងាយស្រួលក្នុងការចងគាថា ទើបលោកប្រើពាក្យថា **វចំ** ដោយរស្សៈ **អា** ជា **អ** ភ្ជាប់សេចក្តីថា ខ្ញុំមានតម្រិះ គឺមានមនសិការយ៉ាងពិតប្រាកដថា ព្រោះបានស្តាប់ព្រះតម្រាស់របស់ព្រះមុនីដូច្នេះថា ក្នុងអនាគតកាលដ៏វែងឆ្ងាយ ព្រះសាស្តាព្រះនាមគោតមដោយព្រះនាម នឹងកើតមានក្នុងលោក ខ្ញុំនឹងឃើញព្រះមានព្រះភាគព្រះនាមគោតម ដោយប្រការណា នឹងធ្វើសក្ការៈ គឺកិច្ចដ៏ក្រៃលែង បានដល់ បុញ្ញសម្ភារ ដោយប្រការនោះ ។

បទថា **យាហំ ចិន្តយិត្វាន** បានដល់ គិតយ៉ាងនេះថា ខ្ញុំនឹងធ្វើសក្ការៈ ។ បទថា **កិរិយំ ចិន្តយឹ មម** សេចក្តីថា ខ្ញុំគិតដល់បុញ្ញកិរិយា គឺកិច្ចដែលគប្បីធ្វើថា អញគប្បីធ្វើបុណ្យដូចម្តេចហ្ន៎ ។ បទថា **ក្យាហំ កម្មំ អាចរាមិ** សេចក្តីថា ខ្ញុំនឹងប្រព្រឹត្ត គឺបំពេញបុញ្ញកម្មដូចម្តេច ។ បទថា **បុញ្ញក្ខេត្តេ អនុត្តរេ** សេចក្តីថា ក្នុងព្រះរតនត្រ័យដែលមិនមានវត្ថុក្រៃលែងជាង គឺជាភាជនៈនៃបុណ្យទាំងមូល ។

បទថា **អយញ្ច បាឋិកោ ភិក្ខុ** សេចក្តីថា ភិក្ខុនេះ ជាភិក្ខុដែលបាននាមថា **បាឋិក** ព្រោះសូធ្យព្រះបាលីក្នុងគម្ពីរ គឺពោលដោយអំណាចសរភញ្ញ

ព្រះសាស្តាទ្រង់តែងតាំងក្នុងតំណែងឯតទគ្គៈ គឺទ្រង់ស្ថាបនាថា ជាបុគ្គលដ៏ប្រសើរក្នុងរវាងនៃភិក្ខុដែលសួធ្យបាលី គឺអ្នកសូធ្យ និងពោលប្រៀនប្រដៅទាំងអស់ និងក្នុងព្រះវិន័យក្នុងពុទ្ធសាសនា ខ្ញុំប្រាថ្នា គឺត្រូវការនូវឋានៈនោះ គឺតំណែងដែលភិក្ខុនោះបានទទួល ។

ខាងមុខអំពីនោះ កាលនឹងសម្តែងឧបាយក្នុងការធ្វើបុណ្យរបស់ខ្លួន ក៏ពោលពាក្យថា **ធនំ មេ អមិតំ ភោគំ** ដូច្នេះជាដើម ភ្ជាប់សេចក្តីក្នុងពាក្យនោះថា គំនរនៃភោគទ្រព្យរបស់ខ្ញុំព្រះអង្គប្រមាណមិនបាន គឺបុគ្គលមិនអាចនឹងឲ្យញាប់ញ័របាន គឺមិនអាចឲ្យរញ្ជួយបាន ឧបមាដូចសាគរ គឺដូចគ្នានឹងសាគរ ខ្ញុំព្រះអង្គបានសាងអារាមដល់ព្រះពុទ្ធ ដោយទ្រព្យនោះ គឺដោយទ្រព្យបែបនោះ ។ ពាក្យដ៏សេស មានអត្ថងាយយល់ហើយ ។

ភ្ជាប់សេចក្តីថា ព្រះសម្ពុទ្ធទ្រង់គង់ក្នុងពួកភិក្ខុ ទ្រង់ទទួលសង្ឃារាមដែលតាបសនោះសាង គឺឲ្យធ្វើហើយយ៉ាងល្អ បានត្រាស់ព្រះតម្រាស់នេះដែលសម្តែងអានិសង្សនៃអារាមនោះ ។

កាលឆ្លើយនឹងពាក្យសួរថា បានត្រាស់អានិសង្សដូចម្តេច ទើបព្រះពុទ្ធព្រះនាមបទុមុត្តរៈត្រាស់ថា **យោ សោ** ដូច្នេះជាដើម អធិប្បាយថា គឺតាបសអ្នកថ្វាយសង្ឃារាម បានថ្វាយសង្ឃារាមដែលសាងល្អហើយ គឺដែលចាត់ចែងរៀបរយ មានដូចជា កុដិ ទីសម្ងំ មណ្ឌប ប្រាសាទ ប្រាសាទត្រនិល និងកំពែងជាដើមដល់ព្រះពុទ្ធ គឺបានថ្វាយសព្វគ្រប់ គឺដោយចិត្តដែលប្រកបដោយសោមនស្ស ។ បទថា **តមហំ កិត្តយិស្សាមិ** សេចក្តីថា

តថាគតធ្វើតាបសនោះឲ្យប្រាកដ គឺធ្វើនឹងប្រកាស ។ បទថា **សុណាថ មម ភាសតោ** សេចក្តីថា អ្នកទាំងឡាយ ចូរស្តាប់ពាក្យរបស់ខ្ញុំ អធិប្បាយថា ចូរផ្ទៀងនូវសោតៈ គឺចូរមានចិត្តមិនរាយមាយ ធ្វើទុកក្នុងចិត្ត ។ កាលទ្រង់សម្តែងផលនៃអារាមដែលតាបសនោះថ្វាយ ទើបត្រាស់ពាក្យថា **ហត្ថី អស្សា រថា បត្តី** ដូច្នេះជាដើម ។ ពាក្យនោះ មានអត្ថងាយយល់ហើយ ។

បទថា **សង្ឃារាមស្សិទំ ផលំ** សេចក្តីថា ឥដ្ឋផល ពោល គឺសម្បត្តិដែលគប្បីសោយតទៅនេះជាផល គឺជាវិបាកនៃការថ្វាយសង្ឃារាម ។

បទថា **ឆឡាសីតិសហស្សានិ** សេចក្តីថា ពួកនារី គឺស្ត្រី ៨ ម៉ឺន ៦ ពាន់នាក់ ស្អិតស្អាងល្អហើយ គឺប្រដាប់តាក់តែងដ៏ស្អាត ស៊ីងស្លៀកសំពត់ និងគ្រឿងអាភរណៈដ៏វិចិត្រ គឺប្រកបដោយសំពត់ និងអាភរណៈទាំងឡាយដ៏វិចិត្រ គឺច្រើនបែប ។ បទថា **អាមុត្តមណិកុណ្ឌលា** បានដល់ ពាក់កុណ្ឌល កែវមុក្តាហារ និងកែវមណី ។

កាលទ្រង់សម្តែងដល់ភាពប្រសើរ គឺលម្អនៃរូបរបស់ស្រីទាំងនោះ ទើបពោលពាក្យថា **អាឡារបម្ហា** ដូច្នេះជាដើម ។ ក្នុងពាក្យនោះ មានវិនិច្ឆ័យដូចតទៅ ភ្នែកទាំងឡាយរបស់ស្រីពួកណាទូលាយ គឺធំ ដូចដុំកែវមណី ស្រីទាំងនោះ ឈ្មោះថា មានភ្នែកមូល អធិប្បាយថា មានភ្នែកថ្លា ដូចភ្នែកកមរទាំងឡាយ ញញឹមញញែម គឺ មានសេចក្តីរីករាយជាប្រក្រតី អធិប្បាយថា ជាអ្នកល្អដោយការកែក្រាយ ។ បទថា **សុសញ្ញា** បានដល់ ជាអ្នកមានអវយវៈនៃរាងកាយដែលគប្បីកាន់យកថាល្អ ។ បទថា **តនុមជ្ឈិមា** បានដល់

មានបរិវេណត្រង់ពោះវាង តូច ( ចង្កេះរៀវ ) ។ ពាក្យដ៏សេស មានអត្ថងាយយល់ហើយ ។

បទថា **តស្ស ធម្មេសុ ទាយាទោ** បានដល់ ជាទាយាទក្នុងធម៌ទាំងឡាយ គឺជាអ្នកមានចំណែកនៃកោដ្ឋាសក្នុងធម៌របស់ព្រះមានព្រះភាគ ព្រះនាមគោតមនោះ ។ បទថា **ឱរសោ** ប្រែថា កើតក្នុងទ្រូង អធិប្បាយថា ជាបុត្រដែលកើតក្នុងឱរា ព្រោះស្តាប់ធម៌ដែលទ្រង់សម្តែងប៉ះខ្ទប់ឋានៈទាំង ៥ គឺក ពិតាន និងបបូរមាត់ជាដើម ដែលបរិបូណ៌ដោយលក្ខណៈនៃក្នុងព្យញ្ជនៈ ១០ យ៉ាង មានសិថិល និងធនិតជាដើម ហើយធ្វើកិលេសទាំងពួងឲ្យអស់ទៅតាមលំដាប់មគ្គ មានសោតាបត្តិមគ្គជាដើម ហើយតាំងនៅក្នុងអរហត្ត ។ បទថា **ធម្មនិម្មិតោ** សេចក្តីថា កុលបុត្រនេះ នឹងជាអ្នកត្រូវនិម្មិត គឺនឹងជាអ្នកប្រាកដដោយធម៌ គឺដោយស្មើ ដោយមិនមានអាជ្ញា ដោយមិនមានសស្ត្រា ។ បទថា **ឧបាលិ នាម នាមេន** សេចក្តីថា បុគ្គលនោះ ឈ្មោះថា មន្តានីបុត្រ តាមឈ្មោះរបស់មាតាក៏ពិត តែនឹងជាសាវ័ករបស់ព្រះសាស្តា ដោយឈ្មោះថាឧបាលី ព្រោះស្និទ្ធ គឺនៅជិត ពួកព្រះអង្គម្ចាស់ មានការរាប់អានតាមផ្លូវកាយ និងផ្លូវចិត្ត នឹងព្រោះចេញបួស មួយអន្លើដោយស្តេចអនុរុទ្ធជាដើម ។

បទថា **វិនយេ បារមឹ បត្វា** សេចក្តីថា ដល់ គឺសម្រេចនូវទីបំផុត បានដល់ ការចេះក្នុងព្រះវិនយបិដក ។ បទថា **ឋានាដ្ឋានេ ច កោវិទោ** សេចក្តីថា ជាអ្នកឈ្លាស គឺជាអ្នកឈ្លាសក្នុងហេតុ និងមិនមែនហេតុ ។ បទ

ថា **ជិនសាសនំ ធារេន្តោ** សេចក្តីថា ទ្រទ្រង់នូវអនុសាសនី ដែលព្រះជិនស្រី ត្រាស់ បានដល់ ព្រះត្រៃបិដករបស់ព្រះជិនស្រី ដោយការរៀន ការស្តាប់ ការគិត និងការចងចាំជាដើម អធិប្បាយថា កំណត់ទុកបាន ។ បទថា **វិហរិស្សតិនាសវោ** សេចក្តីថា ជាអ្នកមិនមានកិលេសនាំ គឺបរិហារអត្តភាព មិនខ្វះខាត ដោយឥរិយាបថទាំង ៤ ។

បទថា **អបរិមេយ្យុបាទាយ** បានដល់ ធ្វើសែនឆ្នាំមិនមែនតិចឲ្យ ចំណុចចាប់ផ្តើម ។ បទថា **បត្ថេមិ តវ សាសនំ** សេចក្តីថា ខ្ញុំប្រាថ្នា គឺ ចង់បានពាក្យប្រាប់អំពីព្រះអង្គថា នឹងជាបុគ្គលប្រសើរជាងភិក្ខុ ជាអ្នកទ្រទ្រង់ វិន័យ ក្នុងសាសនានៃព្រះមានព្រះភាគព្រះនាមគោតម ។ បទថា **សោ មេ អត្ថោ** សេចក្តីថា សេចក្តីប្រាថ្នា ពោល គឺតំណែងឯតទគ្គៈនោះ ខ្ញុំបាន សម្រេចហើយ ។ បទថា **សព្វសំយោជនក្ខយោ** ភ្ជាប់សេចក្តីថា ការអស់ នូវសំយោជនៈទាំងពួង ខ្ញុំបានសម្រេចហើយ អធិប្បាយថា សម្រេចនិព្វាន ហើយ ភ្ជាប់សេចក្តីថា ប្រុស គឺបុរស ត្រូវគំរាម គឺត្រូវបៀតបៀនដោយ រាជអាជ្ញា ត្រូវដែកអណ្តាត គឺត្រូវដោតត្រង់ដែកស្រួចមិនបាន គឺមិនបាន សោយនូវសេចក្តីសុខ គឺសេចក្តីសុខត្រង់មុខដែកស្រួច រមែងត្រូវការរួចផុត គឺការរួចផុតទៅ យ៉ាងណា ។

ភ្ជាប់សេចក្តីថា បពិត្រព្រះមហាវីរៈ គឺបពិត្រព្រះវីរៈដ៏ឧត្តម ក្នុងរវាង វារជនទាំងឡាយ ខ្ញុំព្រះអង្គត្រូវគំរាម គឺត្រូវបៀតបៀនដោយអាជ្ញា គឺភព បានដល់ ដោយអាជ្ញា គឺជាតិ ត្រូវដោតត្រង់ដែកស្រួច គឺកម្ម បានដល់

ត្រូវដោតដោយដែកស្រួច គឺកុសលកម្ម និងអកុសលកម្ម ត្រូវវេទនា គឺការស្រេក បានដល់ ការរសាប់រសល់ ព្រោះការស្រេកបៀតបៀន គឺគ្របសង្កត់ធ្វើឲ្យមានទុក្ខ មិនជួប គឺមិនបាននូវសេចក្តីសុខក្នុងភព បានដល់ សេចក្តីសុខដែលធ្លាញ់ក្នុងសង្សារ ។ ខ្ញុំព្រះអង្គត្រូវដុតដោយភ្លើង ៣ កង ពោល គឺរាគគ្គិ ទោសគ្គិ មោហគ្គិ ឬភ្លើងក្នុងនរកដែលតាំងឡើងក្នុងកប្ប និងភ្លើងទុក្ខ ទើបស្វែងរក គឺស្វះស្វែងរកគ្រឿងរួចផុត គឺឧបាយជាគ្រឿងរួចផុតយ៉ាងនោះ ។ ក្តាប់សេចក្តីថា បុគ្គលដែលដល់ គឺត្រូវ បានដល់ ទទួលរាជអាជ្ញា រមែងស្វែងរកនូវការរួចផុត យ៉ាងណា ខ្ញុំព្រះអង្គបានទទួលអាជ្ញា គឺភព រមែងស្វែងរកនូវការរួចផុត ក៏យ៉ាងនោះ ។

កាលនឹងសម្តែងនូវការរួចផុតចាកសង្សារ ដោយឧបមាឧបមេយ្យទៀត ទើបព្រះថេរៈពោលពាក្យថា **យថា វិសាទោ** ដូច្នេះជាដើម ។ ក្នុងពាក្យនោះមានវិនិច្ឆ័យដូច្នេះ ឈ្មោះថា **វិសាទ** ព្រោះត្រូវពិស គឺពស់មានពិសខាំ គឺចឹកហើយ អធិប្បាយថា ត្រូវពស់ចឹក ។ ម្យ៉ាងទៀត ឈ្មោះថា **វិសាទ** ព្រោះបរិភោគ គឺលេបនូវពិស គឺថ្នាំពិសដ៏ខ្លាំងក្លា អធិប្បាយថា បរិភោគថ្នាំពិស ក្តាប់សេចក្តីថា បុរសណាត្រូវពស់ចឹក គឺត្រូវពិសនោះ គឺបែបនោះបៀតបៀន គប្បីរក គឺស្វែងរកថ្នាំ គឺឱសថ ដែលជាឧបាយដើម្បីបន្សាបពិស គឺដើម្បីទម្លាយ ដើម្បីដកនូវពិសនោះ កាលស្វែងរក ថ្នាំនោះ គប្បីជួប គឺ គប្បីឃើញថ្នាំ គឺឱសថសម្រាប់បន្សាបពិស គឺសម្រាប់កម្ចាត់ពិសឲ្យវិនាស បុរសនោះផឹកនូវឱសថ ដែលខ្លួនឃើញហើយ គប្បីជាអ្នកមានសេចក្តី

សុខសប្បាយព្រោះផុត គឺព្រោះហេតុដែលផុតចាកពិស យ៉ាងណា ។

បទថា **តថេវាហំ** សេចក្តីថា នរៈនោះត្រូវពិសបៀតបៀន គឺត្រូវពស់មានពិសខាំ ឬបរិភោគថ្នាំពិសចូលទៅ ផឹកនូវឱសថហើយ គប្បីមានសេចក្តីសុខដោយប្រការណា ខ្ញុំត្រូវអវិជ្ជា គឺមោហៈបៀតបៀនធ្ងន់ហើយ ដោយប្រការនោះ ។ បទថា **សទ្ធម្មាគធមេសហំ** សេចក្តីថា ខ្ញុំស្វែងរក គឺស្វះស្វែងនូវឱសថ ពោល គឺព្រះសទ្ធម្ម ។

បទថា **ធម្មាគធំ គវេសន្តោ** សេចក្តីថា ស្វែងរកឱសថ គឺធម៌ ដើម្បីកម្ចាត់ពិស គឺសង្សារទុក្ខ ។ បទថា **អទ្ទក្ខិំ សក្យសាសនំ** សេចក្តីថា ខ្ញុំបានឃើញសាសនារបស់ព្រះគោតម ដែលទ្រង់កើតចាកសក្យត្រកូល ។ បទថា **អគ្គំ សព្វោសធានំ តំ** សេចក្តីថា ក្នុងរវាងឱសថទាំងអស់ គឺធម៌ពោល គឺពាក្យប្រៀនប្រដៅរបស់ព្រះសក្យគោតមនោះជាកំពូល គឺឧត្តមបំផុត ។ បទថា **សព្វសល្លវិនោទនំ** ភ្ជាប់សេចក្តីថា ខ្ញុំផឹកនូវធម្មឱសថ បានដល់ ឱសថ គឺធម៌ ដែលជាគ្រឿងបន្ទោបង់ គឺជាគ្រឿងរម្ងាប់នូវកូនសរទាំងពួង មានកូនសរ គឺរាគៈជាដើម បានដកនូវពិសទាំងពួង បានដល់ ពិស គឺសង្សារទុក្ខទាំងមូល គឺធ្វើឲ្យវិនាសទៅ ។ បទថា **អជរាមរំ** ភ្ជាប់សេចក្តីថា ខ្ញុំដកពិស គឺនូវទុក្ខនោះហើយ បានពាល់ត្រូវ គឺបានធ្វើឲ្យប្រចក្សនូវព្រះនិព្វាន ដែលមិនចាស់ គឺមិនមានចាស់ ដែលមិនស្លាប់ គឺមិនមានការស្លាប់ ត្រជាក់ គឺជារបស់ត្រជាក់ ព្រោះមិនមានកម្តៅ មានកម្តៅ គឺរាគៈជាដើម ។

កាលទីងសម្តែងការប្រៀបធៀបនូវធ្ងនឹត គឺកិលេសទៀត ទើបព្រះថេរៈពោលពាក្យថា **យថា ភូតដ្ដិតោ** ដូច្នេះជាដើម ។ ក្នុងគាថានោះ មានវិនិច្ឆ័យដូចតទៅ បុគ្គល គឺបុរស ត្រូវភូតបិសាចគំរាម គឺត្រូវភូតបិសាចបានដល់ យក្ខបៀតបៀន បានទទួលសេចក្តីទុក្ខ គឺដល់នូវសេចក្តីទុក្ខ ព្រោះភូតបិសាចសណ្ឋិត គឺព្រោះត្រូវយក្ខចាប់ គប្បីស្វែងរកគ្រូខ្មោច ដើម្បីរួចផុត គឺដើម្បីផុតចាកអំពីបិសាច គឺអំពីយក្ខចាប់យ៉ាងណា គឺដោយប្រការណា ។

ក្តាប់សេចក្តីថា កាលស្វែងរកគ្រូខ្មោចនោះ ជួបគ្រូខ្មោចដែលជាអ្នកឈ្លាស គឺជាអ្នកប៉ិនប្រសព្វក្នុងវិជ្ជាបណ្តេញខ្មោច គ្រូខ្មោចនោះ គប្បីកម្ចាត់ភូតបិសាចដែលសណ្ឋិតក្នុងបុរសដែលត្រូវយក្ខចាប់នោះ គឺគប្បីធ្វើឲ្យវិនាសទៅ គឺគប្បីកម្ចាត់ព្រមទាំងឫសគល់ គឺព្រមទាំងមូលហេតុ ធ្វើមិនឲ្យសណ្ឋិតតទៅទៀត ។

ក្តាប់សេចក្តីក្នុងគាថានេះថា បពិត្រព្រះមហាវីរៈ ជាវីរបុរសដ៏ឧត្តម ខ្ញុំព្រះអង្គត្រូវបៀតបៀន ព្រោះធ្ងនឹត គឺព្រោះភាពធ្ងនឹត គឺកិលេសចាប់ ទើបខ្ញុំស្វែងរកពន្លឺ គឺញាណ បានដល់ ពន្លឺ គឺបញ្ញាដើម្បីឲ្យផុត គឺដើម្បីផុតអំពីធ្ងនឹត បានដល់ ការធ្ងនឹត ចាកការធ្ងនឹត គឺកិលេស ក៏យ៉ាងនោះដែរ គឺដោយប្រការនោះដូចគ្នា ។

ក្នុងគាថានេះ មានអធិប្បាយថា គ្រានោះ គឺក្នុងលំដាប់នោះ ខ្ញុំបានឃើញព្រះសក្យមុនី ទ្រង់ធ្វើនូវធ្ងនឹត គឺកិលេសឲ្យបរិសុទ្ធ គឺទ្រង់ធ្វើធ្ងនឹត គឺកិលេសឲ្យវិនាស ។ ព្រះសក្យមុនីនោះ ទ្រង់បានផ្តាច់បង់ គឺទ្រង់បានធ្វើឲ្យ

ឆ្ងាយអំពីងងឹត គឺអន្ធការ បានដល់ ការងងឹត គឺកិលេសឲ្យដល់ខ្ញុំ ដូចគ្រុឌចាប់ខ្មោច គឺដូចគ្រុឌចាប់ខ្មោចបណ្ដេញយក្ខ ដែលចូលក្នុងមនុស្ស ឲ្យអន្តរាយដូច្នោះ ។

សេចក្ដីក្នុងគាថានេះថា ខ្ញុំនោះរួចផុតយ៉ាងនេះហើយ កាត់បានដោយល្អនូវក្រសែតណ្ហា គឺការហូរទៅក្នុងសង្សារ ខ្ញុំហាមឃាត់នូវខ្សែ គឺតណ្ហា បានដល់ អន្ទង់ទឹកធំ គឺតណ្ហា គឺបានធ្វើឲ្យអស់ទៅ គឺឲ្យប្រព្រឹត្តទៅមិនបាន ។ បទថា **ភវំ ឧគ្ឃាដយឹ សព្វំ** សេចក្ដីថា ខ្ញុំដកនូវភពថ្មីទាំងអស់ មានកាមភពជាដើម គឺធ្វើឲ្យវិនាសទៅ ភ្ជាប់សេចក្ដីថា ខ្ញុំដកបានទាំងឫស ដូចគ្រុឌបណ្ដេញខ្មោច ព្រមទាំងមូលហេតុ ។

បន្ទាប់អំពីនោះ កាលនឹងសម្ដែងការប្រៀបធៀបក្នុងការស្វែងរកព្រះនិព្វានទើប ព្រះថេរៈពោលពាក្យថា **យថា** ដូច្នេះជាដើម ។ ក្នុងពាក្យនោះ ភ្ជាប់សេចក្ដីថា ដែលឈ្មោះថា គ្រុឌ ព្រោះលេបរបស់ធ្ងន់ គឺនាគ ។ម្យ៉ាងទៀត ឈ្មោះថា គ្រុឌ ព្រោះចាប់ គឺកាន់យករបស់ធ្ងន់ គឺនាគ បានដល់ស្ដេចគ្រុឌ ។ គ្រុឌនោះបោះពួយ គឺសម្រុបស្លាបចុះ ដើម្បីចាប់នាគ ដែលជាភិក្ខារបស់ខ្លួន គឺជាចំណីរបស់ខ្លួន បាននាមថា **បន្នគ** ព្រោះមិនទៅកាន់កណ្ដាប់ដៃរបស់អ្នកដទៃ ដោយប្រការណាមួយ ធ្វើស្រះធំ គឺមហាសមុទ្រ ១០០ យោជន៍ គឺទីប្រមាណ ១០០ យោជន៍ដោយជុំវិញឲ្យរញ្ជួយ គឺឲ្យខ្ចូងដោយខ្យល់ស្លាបរបស់ខ្លួន យ៉ាងណា ។

ភ្ជាប់សេចក្ដីក្នុងគាថានេះថា គ្រុឌនោះ ហើរទៅក្នុងអាកាស គឺមាន

ប្រក្រតីហើរទៅក្នុងអាកាស ចាប់នាគបានហើយ ធ្វើឲ្យក្បាលនាគសំយុងចុះ គឺធ្វើឲ្យលំបាក គឺបៀតបៀនដោយការបៀតបៀនផ្សេងៗ ក្នុងទីនោះៗ ចាប់យក គឺចាប់យ៉ាងមាំ ហើយហើរទៅ គឺទៅតាមប្រាថ្នា គឺក្នុងទីដែលខ្លួនត្រូវទៅ ។

ក្នុងវគ្គនេះ ភ្ជាប់សេចក្តីថា បពិត្រព្រះមហាវីរៈ គ្រុឌមានកម្លាំងចាប់នាគបានហើយ រមែងហើរទៅ យ៉ាងណា ខ្ញុំព្រះអង្គក៏យ៉ាងនោះដូចគ្នា ស្វែងរកព្រះនិព្វានដែលជាអសង្ខតៈ គឺដែលបច្ច័យទាំងឡាយតាក់តែងមិនបាន បានដល់ ស្វែងរក ដោយការញុំាងបដិបទាឲ្យបរិបូណ៌ ខ្ជាក់នូវទោសទាំងឡាយបានដល់ កិលេស ១៥០០ គឺខ្ញុំព្រះអង្គធ្វើឲ្យអស់ដោយពិសេស ដោយសមុច្ឆេទប្បហាន ។

ភ្ជាប់សេចក្តីថា គ្រុឌចាប់នាគបរិភោគ យ៉ាងណា ខ្ញុំព្រះអង្គក៏យ៉ាងនោះ ឃើញ គឺឃើញនូវធម៌ដ៏ប្រសើរ បានដល់ ធម៌ដ៏ឧត្តម កាន់យកសន្តិបទ គឺនិព្វានបទដ៏កំពូល គឺមិនមានវត្ថុដែលក្រៃលែងជាង ដោយមគ្គ និងផលទាំងឡាយ ប្រើប្រាស់ ។

ឥឡូវនេះ កាលនឹងសម្តែងភាពដែលព្រះនិព្វាន ជារបស់បានដោយក្រ ទើបព្រះថេរៈពោលពាក្យថា **អាសាវតី ឆាម លតា** ដូច្នេះជាដើម ។ ក្នុងពាក្យនោះ មានអធិប្បាយថា វល្លិឈ្មោះអាសាវតី ព្រោះទេវតាទាំងនោះមានសេចក្តីសង្ឃឹម គឺចង់បានក្នុងវល្លិនេះ វល្លិនេះកើត គឺកើតឡើងក្នុងចិត្តលតាវ័ន គឺក្នុងព្រៃ បានដល់ ក្នុងឧទ្យានដែលដេរដាសដោយវល្លិ ដែលវិចិត្រ

ល្អត្រកាល មិនមែនតិច ។ លុះណាតែ ១០០០ ឆ្នាំ គឺកន្លងទៅ ១០០០ ឆ្នាំ ទើបវល្លិនោះផ្លែមួយ គឺចេញផ្លែមួយ ។

បទថា **តំ ទេវា** ក្នុងសេចក្តីថា វល្លិអាសាវតីនោះយូរៗ ទើបមានផ្លែម្តង ពេលវេលាកន្លងទៅយូរប៉ុណ្ណោះ ទើបចេញផ្លែ គឺមានផ្លែ ពួកទេវតា គឺទេវតាជាន់តាវត្តិង្ស រមែងចូលទៅអង្គុយជិត គឺគប់រក ។ វល្លិឈ្មោះអាសាវតីនោះ ជាវល្លិដ៏ឧត្តម គឺជាវល្លិដ៏ប្រសើរក្នុងវល្លិទាំងឡាយ បានជាទីស្រឡាញ់របស់ពួកទេវតាយ៉ាងនេះ ។

បទថា **សតសហស្សុទានាយ** សេចក្តីថា ធ្វើនូវពេលវេលាមួយសែនឆ្នាំឲ្យជាចំណុចចាប់ផ្តើម ។ បទថា **តាហំ បរិចរេ មុនិ** សេចក្តីថា ញាណ ហៅថា **មោន** បពិត្រព្រះមុនី គឺព្រះដ៏មានញាណ បានដល់ ព្រះសព្វញ្ញូដ៏ចម្រើន ខ្ញុំព្រះអង្គបម្រើ គឺចូលទៅអង្គុយជិតព្រះមានព្រះភាគនោះ ។ បទថា **សាយំ បាតំ នមស្សាមិ** សេចក្តីថា ខ្ញុំព្រះអង្គនមស្ការ គឺធ្វើនមស្ការ ២ ដង គឺពេលល្ងាច និងពេលព្រឹក ក្នុងសេចក្តីថា ដូចទេវតា គឺដូចទេវតាទាំងឡាយជាន់តាវត្តិង្ស ចូលទៅអង្គុយជិតវល្លិអាសាវតីទាំងព្រឹកទាំងល្ងាច ។

បទថា **អវញ្ឈា បារិចរិយា** សេចក្តីថា ព្រោះបានឃើញព្រះពុទ្ធ ការសម្រេចដល់ព្រះនិព្វាន ទើបមាន ព្រោះហេតុនោះ ការបម្រើព្រះពុទ្ធ គឺការធ្វើវត្តបដិបត្តិ ទើបមិនឥតអំពើ គឺមិនសូន្យទទេ និងនមស្ការ គឺកិរិយាឱនលំទោន ទើបមិនជាមោឃ គឺមិនសូន្យទទេ ។ ពិតហើយ ខ្ញុំមកអំពីចម្ងាយ គឺមកអំពីទីឆ្ងាយ គឺបាកផ្លូវឆ្ងាយ គឺសង្សារ មានប្រាកដ ខណៈ គឺខណៈនេះ

គឺខណៈដែលព្រះពុទ្ធកើតឡើងនេះ មិនរំលង អធិប្បាយថា មិនកន្លងខ្ញុំទៅ ។

ក្តាប់សេចក្តីថា ខ្ញុំសម្រេចដល់ព្រះនិព្វាន ព្រោះបានឃើញព្រះពុទ្ធ ទើបជញ្ជឹងគិត គឺពិចារណានូវបដិសន្ធិរបស់ខ្ញុំ ក្នុងភពដែលកើតតទៅ ក៏មិនឃើញ ។ ក្តាប់សេចក្តីថា ខ្ញុំមិនមានឧបធិ គឺប្រាសចាកខន្ធូបធិ និងកិលេសូបធិទាំងឡាយ រួចស្រឡះ គឺជាអ្នកមិនមានកិលេសទាំងពួង ស្ងប់រម្ងាប់ គឺមានចិត្តស្ងប់ ព្រោះមិនមានការក្តៅក្រហាយព្រោះកិលេសត្រាច់ទៅ ។

កាលសម្តែងការប្រៀបធៀបក្នុងការឃើញព្រះពុទ្ធរបស់ខ្លួនទៀត ទើបពោលពាក្យថា **យថាបិ បទុមំ ឆាម** ដូច្នេះជាដើម ។ ក្នុងពាក្យនោះ មានអធិប្បាយថា ធម្មតាឈូក រមែងរីក គឺរមែងរីកព្រោះរស្មីព្រះអាទិត្យ គឺព្រោះប៉ះនឹងពន្លឺព្រះអាទិត្យ យ៉ាងណា បពិត្រព្រះអង្គមានព្យាយាមធំ គឺបពិត្រព្រះអង្គដ៏ឧត្តមជាងវីរជន ខ្ញុំព្រះអង្គក៏យ៉ាងនោះដូចគ្នា ជាអ្នករីកហើយ ព្រោះរស្មីរបស់ព្រះពុទ្ធ គឺព្រោះកើតអំពីរស្មី គឺព្រះធម៌ដែលព្រះមានព្រះភាគ ទ្រង់សម្តែងហើយ ។

កាលសម្តែងការឃើញព្រះនិព្វាន ព្រោះការបានឃើញព្រះពុទ្ធទៀត ទើបព្រះថេរៈពោលពាក្យថា **យថា ពលាកា** ដូច្នេះជាដើម ។ ក្នុងពាក្យនោះ មានវិនិច្ឆ័យដូចតទៅនេះ ក្នុងសព្វកាល គឺក្នុងកាលទាំងពួង កុកឈ្មោល មិនមាន ក្នុងកុកដែលឲ្យកំណើត គឺក្នុងជាតិជាកុកយ៉ាងណា ។

បើសួរថា បើមិនមានកុកឈ្មោល តើកុកតាំងគភ៌ដូចម្តេច ។ ឆ្លើយថា កាលមេឃក្រហឹម គឺផ្គរលាន់ កុកញីទាំងនោះ បានស្តាប់សំឡេងមេឃគំរាម

គឺបន្ទឺសំឡេង កុកញីទាំងនោះ បានស្តាប់សំឡេងមេឃគំរាម រមែងមានគភ៌ សព្វកាល គឺក្នុងកាលទាំងពួង អធិប្បាយថា រមែងទ្រទ្រង់នូវស៊ុត ។ មេឃមិនទាន់គំរាម គឺមេឃមិនទាន់ធ្វើសំឡេងដរាបណា គឺអស់កាលមានប្រមាណប៉ុនណា កុកញីទាំងឡាយក៏ទ្រទ្រង់គភ៌ គឺទ្រទ្រង់គភ៌អស់កាលយូរមានប្រមាណប៉ុណ្ណោះ គឺអស់កាលយូរមានប្រមាណប៉ុណ្ណោះ ។ កាលណា គឺកាលណាភ្លៀងធ្លាក់ចុះមក គឺគ្រហឹមដោយប្រភេទផ្សេងៗ ហើយធ្លាក់ចុះមក គឺហូរតំណក់ភ្លៀងធ្លាក់ចុះមក កាលនោះ គឺកាលនោះ កុកញីទាំងឡាយ រមែងផុតចាកភារៈ គឺការទ្រទ្រង់គភ៌ អធិប្បាយថា ទម្លាក់ស៊ុតចេញមកក្រៅ ។

បន្ទាប់អំពីនោះ កាលនឹងសម្តែងឧបមេយ្យ ទើបព្រះថេរៈពោលពាក្យថា **បទុមុត្តរ ពុទ្ធស្ស** ដូច្នេះជាដើម ។ ក្នុងពាក្យនោះ ភ្ជាប់សេចក្តីថា កាលព្រះពុទ្ធព្រះនាមបទុមុត្តរៈទ្រង់គំរាម គឺទ្រង់សម្តែង ដោយមេឃ គឺធម៌ គឺដោយមេឃ ពោល គឺវោហារបរមត្ថទេសនា ក្នុងកាលនោះ ខ្ញុំព្រះអង្គក៏យ៉ាងនោះ បានកាន់យកគភ៌ គឺព្រះធម៌ បានដល់ គភ៌ គឺបុញ្ញសម្ភារ មានទាន និងសីលជាដើម ដែលជាឧបនិស្ស័យនៃវិវដ្តៈ គឺព្រះនិព្វាន ។

ភ្ជាប់សេចក្តីថា ខ្ញុំព្រះអង្គអាស្រ័យរាប់សែនកប្ប គឺធ្វើមួយសែនកប្បឲ្យជាចំណុចចាប់ផ្តើម ទ្រទ្រង់នូវគភ៌ គឺបុណ្យ បានដល់ ធ្វើបុញ្ញសម្ភារមានទាន និងសីលជាដើមឲ្យពេញ ។ ធម្មមេឃ គឺព្រះធម្មទេសនា មិនទាន់គំរាម គឺព្រះពុទ្ធមិនទាន់សម្តែងដរាបណា ខ្ញុំព្រះអង្គក៏មិនទាន់រួចចាកផុតភារៈធ្ងន់ គឺមិនទាន់រួចរំដោះ បានដល់ មិនទាន់ជាបុគ្គលលះបង់ចាកភារៈ គឺចាក

កពការៈ ក្នុងសង្សារវដ្ដរាបនោះ ។

ភ្ជាប់សេចក្ដីក្នុងគាថានេះថា បពិត្រព្រះសក្យមុនី គឺខ្ញុំព្រះអង្គជាអ្នកសម្ភពក្នុងសក្យវង្សដ៏ចម្រើនក្នុងកាលណា ទ្រង់គំរាម គឺទ្រង់ប្រកាសធម្ម-មេឃក្នុងនគរកបិលពស្ដុ គឺក្នុងនគរដែលមានឈ្មោះថា កបិលពស្ដុ ដែលគួរជាទីត្រេកអរ គឺគួរជាទីរីករាយនៃព្រះបិតារបស់ព្រះអង្គ ព្រះនាមសុទ្ធោ-ទនមហារាជ ក្នុងកាលនោះ ខ្ញុំព្រះអង្គផុតហើយ គឺបានផុតហើយចាកការៈ គឺចាកគពការៈក្នុងសង្សារ ។

ខាងមុខអំពីនោះ កាលនឹងសម្ដែងមគ្គផលដែលខ្លួនបានសម្រេច ទើបពោលព្រះថេរៈពាក្យថា **សុញ្ញតំ** ដូច្នេះជាដើម ។ ក្នុងគាថានោះ ភ្ជាប់សេចក្ដីថា ខ្ញុំព្រះអង្គសម្រេច គឺចម្រើនអរិយមគ្គ ឈ្មោះថា សុញ្ញតវិមោក្ខ ព្រោះមិនមានការប្រកាន់ថាជាខ្លួន និងជារបស់ខ្លួន ឈ្មោះថា អនិមិត្តវិមោក្ខ ព្រោះមិនមានរាគៈ ទោសៈ មោហៈ និងកិលេសទាំងពួងជានិមិត្ត ដែលឈ្មោះថា អប្បណិហិតវិមោក្ខ ព្រោះមិនមានបណិធិ គឺតណ្ហា ។ បទថា **ចតុរោ ច ផលេ សព្វេ** សេចក្ដីថា បានធ្វើឲ្យជាក់ច្បាស់នូវសាមញ្ញផល ៤ ទាំង អស់ ។ បទថា **ធម្មេវំ វិជដយឹ អហំ** សេចក្ដីថា ខ្ញុំព្រះអង្គទម្លាយ គឺកម្ចាត់ជដៈ គឺព្រៃស្ដុកក្នុងធម៌ទាំងពួង ដោយប្រការដូច្នេះ ។

### ទុតិយភាណវារ ចប់

បន្ទាប់អំពីនោះ កាលនឹងសម្ដែងចំពោះគុណវិសេស ដែលលោកបានសម្រេច ទើបព្រះថេរៈពោលថា **អបរិមេយ្យុបាទាយ** ដូច្នេះជាដើម ។ ក្នុង

ពាក្យនោះ មានវិនិច្ឆ័យដូចតទៅ ឈ្មោះថា **អបរិមេយ្យ** ព្រោះប្រមាណមិនបាន អធិប្បាយថា មិនអាចប្រមាណ គឺនឹងរាប់ ដោយរាប់ជាឆ្នាំ ។ ខ្ញុំព្រះអង្គអាស្រ័យ គឺធ្វើកប្បប្រមាណមិនបាននោះ ឲ្យជាចំណុចចាប់ផ្ដើម ប្រាថ្នានូវសាសនារបស់ព្រះអង្គយ៉ាងនេះថា ខ្ញុំព្រះអង្គគប្បីប្រសើរជាង អ្នកទ្រទ្រង់វិន័យទាំងឡាយ ក្នុងសាសនារបស់ព្រះមានព្រះភាគព្រះនាមគោតម ក្នុងអនាគត ។ ពាក្យថា **បត្ថេមិ** ជាពាក្យបច្ចុប្បន្ន ប្រើក្នុងអត្ថជាអតីត មានសេចក្ដីស្មើគ្នានឹងបទថា **បត្ថេសឹ** ( ប្រាថ្នាហើយ ) ។ បទថា **សោ មេ អត្ថោ** សេចក្ដីថា ប្រយោជន៍ គឺសេចក្ដីត្រូវការនោះ ខ្ញុំព្រះអង្គបានសម្រេចហើយ គឺធ្វើឲ្យស្រេចហើយ ។ ភ្ជាប់សេចក្ដីថា ខ្ញុំព្រះអង្គបានដល់ គឺបានសម្រេចសន្តិបទ គឺព្រះនិព្វានដ៏កំពូល ។

ខ្ញុំព្រះអង្គនោះដល់នូវត្រើយ គឺដល់ទីបំផុតក្នុងព្រះវិន័យ គឺក្នុងវិនយ-បិដក ព្រោះជាអ្នកសម្រេចហើយ ។ បទថា **យថាបិ ចាបិកោ ឥសី** សេចក្ដីថា ឥសី គឺភិក្ខុដែលជាកំពូលនៃភិក្ខុអ្នកទ្រទ្រង់វិន័យទាំងឡាយ ក្នុងសាសនារបស់ព្រះមានព្រះភាគព្រះនាមបទុមុត្តរៈ បានជាអ្នកជំនាញក្នុងព្រះបាលី គឺជាអ្នកមានកេត្តិឈ្មោះយ៉ាងណា ខ្ញុំព្រះអង្គក៏យ៉ាងនោះដូចគ្នា ។ បទថា **ន មេ សមសមោ អត្ថិ** សេចក្ដីថា ព្រោះភាពជាអ្នកមានប្រក្រតីទ្រទ្រង់នូវព្រះវិន័យ អ្នកដទៃដែលស្មើដូចខ្ញុំព្រះអង្គមិនមាន អធិប្បាយថា ខ្ញុំព្រះអង្គញុំាងសាសនា គឺពាក្យប្រៀនប្រដៅ ពោល គឺឱវាទានុសាសនីឲ្យតាំងនៅ គឺឲ្យបរិបូណ៌ ។

កាលសម្តែងគុណវិសេសរបស់ខ្លួនដដែលទៀត ទើបព្រះថេរៈពោលពាក្យថា **វិនយេ ខន្ធកេ ចាបិ** ដូច្នេះជាដើម ។

បណ្តាបទទាំងនោះ បទថា **វិនយេ** បានដល់ ក្នុងឧភតោវិភង្គ ។ បទថា **ខន្ធកេ** បានដល់ ក្នុងមហាវគ្គ និងចុល្លវគ្គ ។ បទថា **តិកច្ឆេទេ** បានដល់ ក្នុងតិកសង្ឃាទិសេស និងតិកបាចិត្តិយៈជាដើម ។ បទថា **បញ្ចមេ** បានដល់ ក្នុងគម្ពីរបរិវារ ។ ក្នុងវិន័យនោះ គឺក្នុងវិនយបិដកទាំងមូលនេះ ខ្ញុំព្រះអង្គ មិនមានសេចក្តីសង្ស័យ គឺមិនមានការរារែកចិត្ត ។ បទថា **អក្ខរេ** បានដល់ ក្នុងអក្ខរៈ មាន **អ** អក្ខរៈជាដើម ដែលទាក់ទងក្នុងវិនយបិដក ។ បទថា **ព្យញ្ជនេ** ភ្ជាប់សេចក្តីថា ឬក្នុងព្យញ្ជនៈ មាន **ក** អក្ខរៈជាដើម ខ្ញុំព្រះអង្គមិនមានការស្រេពិចស្រេពិល គឺមិនមានការសង្ស័យឡើយ ។

បទថា **និគ្គហេ បដិកម្មេ ច** សេចក្តីថា ជាអ្នកឈ្លាស គឺជាអ្នកឈ្លាសក្នុងនិគ្គហកម្ម គឺការដាក់ទោសពួកភិក្ខុលាមក ក្នុងការចេញចាកអាបត្តិ មានការឲ្យបរិវាសជាដើម ដល់ភិក្ខុដែលមានអាបត្តិជាប់ខ្លួន ក្នុងហេតុដ៏គួរ និងមិនគួរ គឺក្នុងហេតុ និងមិនមែនហេតុ ភ្ជាប់សេចក្តីថា ជាអ្នកឈ្លាសក្នុងឱសារណាវិធី គឺក្នុងការឲ្យត្រឡប់ចូលពួក បានដល់ ក្នុងការឲ្យចូលពួកដោយការរម្ងាប់កម្ម មានតជ្ជនីយកម្មជាដើម និងក្នុងវុដ្ឋានបទវិធី គឺក្នុងការឲ្យចេញចាកអាបត្តិ បានដល់ ក្នុងការធ្វើមិនឲ្យមានអាបត្តិ ។ បទថា **សព្វត្ថ ចារមឹ គតោ** សេចក្តីថា ជាអ្នកដល់នូវទីបំផុតក្នុងវិនយកម្មគ្រប់យ៉ាង អធិប្បាយថា ជាអ្នកអាច ជាអ្នកឈ្លាស ។

បទថា **វិនយេ ខន្ធកេ ចាបិ** សេចក្តីថា តាំង គឺដាក់បទ បានដល់ សុតបទក្នុងវិន័យ និងខន្ធកៈ ដែលមានប្រការដូចពោលហើយ ។ បទថា **ឧភតោ វិនិវេឋេត្វា** សេចក្តីថា ឲ្យកើត គឺជម្រះភាពសាំញ៉ាំ នាំន័យមក អំពីឧភតោ គឺអំពីវិន័យ និងអំពីខន្ធកៈ ។ បទថា **រសតោ** គឺដោយកិច្ច ។ គប្បីហៅចូលពួក គឺធ្វើការហៅឲ្យចូលពួក ។

បទថា **និរុត្តិយា ច កុសលោ** សេចក្តីថា ជាអ្នកឈ្លាសក្នុងវោហារ ដូចជា **រុក្ខ** គឺដើមឈើ **បជ** គឺផ្ទាំងសំពត់ **កុម្ភ** គឺក្អម **មាលា** គឺកម្រងផ្កា **ចិត្ត** គឺចិត្ត ។ បទថា **អត្ថានត្ថេ ច កោវិទោ** សេចក្តីថា ជាអ្នកឈ្លាស គឺជំនាញក្នុងប្រយោជន៍ គឺសេចក្តីចម្រើន និងក្នុងវត្ថុមិនជាប្រយោជន៍ គឺសេចក្តីវិនាស ។ បទថា **អនញ្ញាតំ មយា នត្ថិ** សេចក្តីថា វត្ថុណាមួយ ដែលខ្ញុំព្រះអង្គមិនដឹង គឺមិនដឹងច្បាស់ មិនប្រាកដ ក្នុងវិនយបិដក ឬក្នុងព្រះត្រៃបិដកទាំងមូល មិនមាន ។ បទថា **ឯកគ្គោ សត្ថុ សាសនេ** សេចក្តីថា ខ្ញុំព្រះអង្គម្នាក់ឯងប៉ុណ្ណោះជាកំពូល គឺជាបុគ្គលប្រសើរឧត្តមជាងព្រះវិនយធរទាំងឡាយ ក្នុងពុទ្ធសាសនា ។

បទថា **រូបទក្ខេ អហំ អជ្ជ** ភ្លាប់សេចក្តីថា ថ្ងៃនេះ គឺក្នុងកាលឥឡូវនេះ ខ្ញុំព្រះអង្គបន្ទោបង់ គឺធ្វើឲ្យវិនាសនូវការស្រេពិចស្រេពិលទាំងពួង គឺការសង្ស័យទាំងអស់ ព្រោះជំនាញក្នុងរូប គឺព្រោះឃើញរូប បានដល់ ការវិនិច្ឆ័យវិន័យក្នុងសាសនា គឺបាវចនៈរបស់ព្រះមានព្រះភាគជាសក្យបុត្រ ។

បទថា **ឆិន្ទាមិ សព្វសំសយំ** សេចក្តីថា ខ្ញុំព្រះអង្គកាត់ គឺរម្ងាប់

បានដល់ កម្ចាត់ដោយឥតសេសសល់នូវសេចក្តីសង្ស័យទាំងអស់ ១៦ ប្រការ ដែលកើតឡើង ប្រារព្ធថា ក្នុងអតីត អាត្មាអញមានហើយ ឬមិនមានហ្ន៎ជាដើម ។

បទថា **បទំ អនុបទញ្ចាបិ** សេចក្តីថា បានដល់ បទ គឺបទមុខ អនុបទ គឺបទក្រោយ អក្ខរៈ គឺអក្ខរៈមួយតួៗ និងព្យញ្ជនៈ គឺរបៀបព្យញ្ជនៈ ១០ យ៉ាង មានសិថិល ធនិតជាដើម ។ បទថា **និធានេ** បានដល់ ក្នុងនិទាន មានពាក្យថា **តេន សមយេន** ដូច្នេះជាដើម ។ បទថា **បរិយោសានេ** បានដល់ ក្នុងបទខាងចុង ។ បទថា **សព្វត្ថ កោវិទោ** សេចក្តីថា ជាអ្នកឈ្លាសក្នុងឋានៈទាំងអស់ ៦ ប្រការ ។

ខាងមុខអំពីនេះទៅ កាលនឹងប្រកាសព្រះគុណទាំងឡាយរបស់ព្រះដ៏មានព្រះភាគនោះឯង ទើបពោលពាក្យថា **យថាបិ រាជា ពលវា** ដូច្នេះជាដើម ។ ក្នុងគាថានោះ មានអធិប្បាយថា ព្រះរាជាមានកម្លាំង គឺទ្រង់ដល់ព្រមដោយថាមពល ឬទ្រង់ដល់ព្រមដោយកម្លាំងសេនា ទ្រង់សង្កត់សង្កិនសេនារបស់ព្រះរាជាដទៃ គឺព្រះរាជាដែលជាសត្រូវ គឺចាប់បានទាំងអស់ ឬបណ្តេញឲ្យគេចទៅទាំងអស់ ហើយធ្វើឲ្យក្តៅក្រហាយ គឺឲ្យក្តៅ ឲ្យលំបាកយ៉ាងណា ។ បទថា **វិជិនិត្វាន សង្គាមំ** សេចក្តីថា ទ្រង់ឈ្នះ គឺឈ្នះដោយវិសេសនូវសង្គ្រាម គឺការតទល់ បានដល់ ការច្បាំងជាមួយនឹងសេនារបស់ព្រះរាជាដទៃ គឺទ្រង់បាននូវជ័យជម្នះហើយ ។ បទថា **នគរំ តត្ថ មាបយេ** សេចក្តីថា ទើបឲ្យសាង គឺឲ្យធ្វើនគរ គឺលំនៅដែលប្រដាប់ដោយប្រាសាទ

និងផ្ទះត្រនិលជាដើមក្នុងទីនោះ គឺក្នុងទីដែលទ្រង់ឈ្នះនោះ ។

បទថា **ចាការំ បរិខញ្ចាបិ** ក្តាប់សេចក្តីថា ឲ្យធ្វើកំពែង គឺកំពែងឥដ្ឋ ដែលបូកដោយបាយ-អ លាបពណ៌ស ក្នុងនគរដែលសាងនោះ ។ និងឲ្យធ្វើប្រឡាយ គឺគូកក់ គូទឹក គូស្ងួត ។ បទថា **ឯសិកំ ទ្វារកោដ្ឋកំ** បានដល់ ឲ្យធ្វើនូវបង្គ តាំងខ្លោងទ្វារធំ និងខ្លោងទ្វារ ៤ ជាន់ជាដើម ដើម្បីនគរស្អាត ។ បទថា **អដ្ដាលកេ ច វិវិធេ** ក្តាប់សេចក្តីថា នឹងឲ្យធ្វើ គឺឲ្យសាងប៉មដ៏ខ្ពស់ មានប៉ម ៤ ជាន់ជាដើមផ្សេងៗ គឺមានប្រការផ្សេងៗ ជាច្រើន ។

បទថា **សង្ឃាដកំ ចច្ចរញ្ច** ក្តាប់សេចក្តីថា ឲ្យសាងកំពែងជាដើមតែម្យ៉ាងក៏មិនមែន ឲ្យសាងផ្លូវដែលមានមុំ ៤ គឺផ្លូវបែកជា ៤ និងផ្លូវបែក គឺផ្លូវក្នុងវាំង ។ បទថា **សុវិភត្តន្តរាបណំ** សេចក្តីថា ឲ្យសាងរានផ្សារ គឺរានផ្សារច្រើនពាន់ ដែលចាត់ជារបៀប គឺត្រូវចែកជាចំណែក ។ បទថា **ការយេយ្យ សភំ តត្ថ** សេចក្តីថា ឲ្យសាងសភា គឺសាលាសម្រាប់កាត់ក្តីដោយធម៌ ក្នុងនគរដែលសាងនោះ ក្តាប់សេចក្តីថា ឲ្យសាងទីវិនិច្ឆ័យក្តី និងមិនមែនក្តី គឺសាលាវិនិច្ឆ័យ ដើម្បីធ្វើការវិនិច្ឆ័យសេចក្តីចម្រើន និងសេចក្តីមិនចម្រើន ។

បទថា **និគ្ឃាតត្ថំ អមិត្តានំ** សេចក្តីថា ដើម្បីការពារព្រះរាជាដែលជាបដិបក្ខ ។ បទថា **ឋិតាឋិតញ្ច ជានិតុំ** បានដល់ ដើម្បីនឹងដឹងទោស និងមិនមែនទោស ។ បទថា **ពលកាយស្ស រក្ខាយ** សេចក្តីថា ដើម្បីរក្សាកម្លាំងពល គឺពួកសេនា ដែលបានដល់ ពលដំរី ពលសេះ ពលរថ និង

ពលថ្មើរជើង ព្រះរាជាជាម្ចាស់នៃនគរនោះ ទ្រង់តាំង គឺទ្រង់ស្ថាបនាសេនាបតី គឺមហាមាត្យ ដែលនាំកងទ័ពក្នុងតំណែង ។

បទថា **អារក្ខត្ថាយ ភណ្ឌស្ស** ភ្ជាប់សេចក្តីថា ដើម្បីទីងរក្សា គឺដើម្បីគ្រប់គ្រងដោយជុំវិញនូវភណ្ឌៈរបស់ព្រះរាជា មានមាស ប្រាក់ កែវមុក្តា និងកែវមណីជាដើម ព្រះរាជានោះ ទ្រង់ក៏តាំងមនុស្ស គឺបុរសអ្នកឈ្លាសក្នុងការរក្សា គឺបុរសដែលឈ្លាស បានដល់ ប៉ិនប្រសព្វទុកដាក់ ឲ្យជាអ្នករក្សាទ្រព្យ គឺអ្នករក្សាទ្រព្យក្នុងឃ្លាំង ដោយបំណងថា ទ្រព្យរបស់អញ កុំបីវិនាសឡើយ ។

បទថា **មមត្តោ ហោតិ យោ រញ្ញោ** សេចក្តីថា បុគ្គលណាជាបណ្ឌិតជាអ្នកស្រឡាញ់ គឺជាបក្សរបស់ព្រះរាជា ។ បទថា **វុទ្ធឹ យស្ស ច ឥច្ឆតិ** ភ្ជាប់សេចក្តីថា បុគ្គលណារមែងប្រាថ្នា គឺរមែងត្រូវការសេចក្តីចម្រើន គឺដុះដាលដល់ព្រះរាជានោះ ព្រះរាជារមែងប្រទានភាពជាធំ ក្នុងការវិនិច្ឆ័យអធិករណ៍ដល់បុគ្គលនោះ ដែលជាបណ្ឌិតបែបនេះ ដើម្បីបដិបត្តិចំពោះមិត្រ គឺចំពោះភាពជាមិត្រ ។ បទថា **ឧប្បាទេសុ** បានដល់ ក្នុងឫក្សទាំងឡាយ មានឧក្កាបាតៈ គឺភ្លើងធ្លាក់ចុះមក និងទិសាឌាហៈ គឺទិសត្រូវភ្លើងឆេះជាដើម ។ បទថា **និមិត្តេសុ** បានដល់ ក្នុងតម្រាទាយនិមិត្ត មានត្រូវកណ្តុរកាត់សំពត់[១] និងក្នុងវិជ្ជាទាយយ៉ាងនេះថា នេះជានិមិត្តល្អ នេះជានិមិត្តមិនល្អជាដើម ។ បទ

---

១- តម្រានេះ គេទាយថា បើកណ្តុរកាត់សំពត់ក្នុងថ្ងៃអាទិត្យ មានផលយ៉ាងនេះៗជាដើម ។

ថា **លក្ខណេសុ** ច ក្លាប់សេចក្ដីថា ម្យ៉ាងទៀត ព្រះរាជានោះ ទ្រង់តាំង បុគ្គលអ្នកឈ្លាស គឺអ្នកឈ្លាសក្នុងតម្រាទាយនិមិត្តត្រង់ដៃ និងជើងរបស់ បុរសស្ត្រី ជាអ្នកប្រៀនប្រដៅ គឺប្រាប់ការព្យាករណ៍ដល់សិស្សមិនមែនតិច ជាអ្នកចេះចាំមន្ត គឺទ្រទ្រង់នូវមន្ត ពោល គឺត្រៃវេទ ជាបណ្ឌិត ក្នុងឋានៈ ជាបុរោហិត គឺក្នុងភាពជាបុរោហិត ។ បទថា **ឃតេហាវុត្ថោ សម្បន្នោ** ក្លាប់សេចក្ដីថា ព្រះរាជានោះទ្រង់បរិបូណ៌ គឺដល់ព្រមដោយអង្គ គឺអង្គ ប្រកបដែលមានប្រការដូចពោលមកនេះ ទើបមហាជនថ្វាយព្រះនាម គឺហៅ ថា ក្សត្រ ។ បទថា **សទា រក្ខន្តិ រាជានំ** សេចក្ដីថា អមាត្យ មាន សេនាបតីជាដើមនោះ តែងរក្សា គឺគ្រប់គ្រងព្រះរាជានោះសព្វកាល គឺអស់ កាលទាំងពួង ។ សួរថា ដូចអ្វី ឆ្លើយថា ដូចសត្វចាក្រពាករក្សាក្រុមញាតិ ដែលដល់នូវសេចក្ដីទុក្ខ ដូចសត្វចាក្រពាករក្សាញាតិរបស់ខ្លួន ដែលដល់នូវ សេចក្ដីទុក្ខ ។

បទថា **តវេវ ត្វំ មហាវីរ** ក្លាប់សេចក្ដីថា បពិត្រវីរបុរសដ៏ឧត្ដម ព្រះរាជានោះ ទ្រង់ដល់ព្រមដោយអង្គ មានអង្គនៃសេនាបតីជាដើម បិទទ្វារ ព្រះនគរ ទ្រង់អាស្រ័យនៅយ៉ាងណា ព្រះអង្គក៏យ៉ាងនោះដូចគ្នា ជាព្រះ ធម្មរាជា គឺព្រះរាជាដោយធម៌ដោយស្មើរបស់សត្វលោក ព្រមទាំងទេវលោក គឺរបស់សត្វលោក ដែលប្រព្រឹត្តទៅជាមួយទេវតាទាំងឡាយ ដូចក្សត្រិយ៍ ដែលកម្ចាត់សត្រូវហើយ គឺកម្ចាត់សត្រូវបានហើយ អ្នកផងតែងហៅព្រះអង្គ គឺហៅថា ព្រះធម្មរាជា ព្រោះទ្រង់ជាព្រះរាជាដោយទ្រង់បំពេញធម៌ គឺបារមី

១០ ឲ្យបរិបូណ៌ ។

បទថា **តិត្ថិយេ និហរិត្វាន** សេចក្តីថា ព្រោះព្រះធម្មរាជា ទើបទ្រង់នាំចេញ គឺនាំទៅដោយមិនសេសសល់នូវពួកតិរ្ថិយទាំងអស់ ដែលជាបដិបក្ខ ធ្វើឲ្យអស់ព្យសន៍ និងទ្រង់កម្ចាត់មារ ព្រមទាំងសេនា គឺវសវត្តីមារ ព្រមទាំងសេនាផងដែរ ។ បទថា **តមន្ធការំ វិធមិត្វា** សេចក្តីថា កម្ចាត់ គឺកម្ចាត់ងងឹត គឺមោហៈ ពោល គឺការងងឹត អធិប្បាយថា ទ្រង់ឲ្យសាង គឺទ្រង់និម្មិត បានដល់ ទ្រង់ប្រតិស្ឋានធម្មនគរ គឺនគរ ពោល គឺពោធិបក្ខិយធម៌ ៣៧ ប្រការ ឬពោល គឺធម៌ ដែលបានដល់ ខន្ធ អាយតនៈ ធាតុ បដិច្ចសមុប្បាទ ពល ពោជ្ឈង្គ និងសមន្តប្បដ្ឋាន ដែលមានន័យដ៏ជ្រាលជ្រៅ ។

បទថា **សីលំ ចាការកំ តត្ថ** បានដល់ ក្នុងធម្មនគរដែលឲ្យប្រតិស្ឋាននោះ មានបារិសុទ្ធិសីលជាកំពែង ។ បទថា **ញាណំ តេ ទ្វារកោដ្ឋកំ** សេចក្តីថា ញាណរបស់ព្រះអង្គ មានព្រះសព្វញ្ញុតញ្ញាណ អាសយានុសញ្ញាណ អនាគតំសញ្ញាណ និងអតីតំសញ្ញាណជាដើមនោះឯង ជាខ្លោងទ្វារ ។ បទថា **សទ្ធា តេ ឯសិកា វីរ** សេចក្តីថា បពិត្រព្រះអង្គដ៏ចម្រើន ទ្រង់មានព្យាយាមមិនធូរថយ សទ្ធា គឺការជឿរបស់ព្រះអង្គ ដែលមានព្រះសព្វញ្ញុតញ្ញាណជាហេតុ ផ្តើមអំពីបាទមូលរបស់ព្រះពុទ្ធទីបង្ករជាសសរ ដែលប្រដាប់ដោយគ្រឿងអលង្ការ ដែលលើកឡើង ។ បទថា **ទ្វារបាលោ ច សំវរោ** សេចក្តីថា សំវរៈដែលប្រព្រឹត្តទៅក្នុងទ្វារ ៦ របស់ព្រះអង្គ គឺការរក្សា ការការពារ និងការគ្រប់គ្រង ជានាយឆ្មាំទ្វារ គឺជាអ្នករក្សាទ្វារ ។

បទថា **សតិប្បដ្ឋានមដ្ដាលំ** សេចក្ដីថា ទ្រង់មានសតិប្បដ្ឋាន ៤ ជាប៉ម ដែលមានគ្រឿងជុំវិញ ។ បទថា **បញ្ញា តេ ចច្ចរំ មុនេ** សេចក្ដីថា បពិត្រព្រះមុនី ទ្រង់មានញាណដ៏ចម្រើន បញ្ញារបស់ទ្រង់មានប្រការផ្សេងៗ មានបាដិហារិយប្បញ្ញាជាដើម ជាផ្លូវបែកជា ៤ គឺជាប្រកផ្លូវ បានដល់ ជាផ្លូវទៅកាន់ព្រះនគរ ។ បទថា **ឥទ្ធិបាទញ្ច សិង្ឃាដំ** សេចក្ដីថា ឥទ្ធិបាទ ៤ ពោល គឺឆន្ទៈ វីរិយៈ ចិត្តៈ និងវីមង្សារបស់ព្រះអង្គ ជាផ្លូវត្រឡែងកែង គឺជាទីតរបស់ផ្លូវ ៤ ខ្សែ ។ បទថា **ធម្មវីថិ សុមាបិតំ** សេចក្ដីថា ធម្មនគរនោះ ទ្រង់សាង គឺតាក់តែងរៀបរយ ដោយផ្លូវ ពោល គឺពោធិបក្ខិយធម៌ ៣៧ ប្រការ ។

បទថា **សុត្តន្តំ អភិធម្មញ្ច** សេចក្ដីថា ក្នុងធម្មនគររបស់ព្រះអង្គនោះ មានព្រះសុត្តន្តបិដក ព្រះអភិធម្មបិដក និងព្រះវិនយបិដក គឺព្រះពុទ្ធវចនៈ មានអង្គ ៩ មានសុត្តៈ គេយ្យៈជាដើមទាំងមូល គឺទាំងអស់ ទាំងពួង ជាធម្មសភា គឺជាសាលាជម្រះអធិករណ៍តាមផ្លូវធម៌ ។

បទថា **សុញ្ញតំ អនិមិត្តញ្ច** សេចក្ដីថា សុញ្ញតវិហារធម៌ ដែលបានដោយអំណាចអនត្តានុបស្សនា និងអនិមិត្តវិហារធម៌ដែលបានដោយអំណាចអនិច្ចានុបស្សនា ។ បទថា **វិហារញ្ចប្បណិហិតំ** បានដល់ អប្បណិហិតវិហារធម៌ ដែលបានដោយអំណាចទុក្ខានុបស្សនា ។ បទថា **អានេញ្ជញ្ច** បានដល់ អានេញ្ជវិហារធម៌ ពោល គឺសាមញ្ញផល ៤ ដែលមិនញាប់ញ័រ មិនយោលយោង ។ បទថា **និរោធោ ច** បានដល់ ព្រះនិព្វានដែលជាទីរម្ងត់ទុក្ខ

ទាំងមូល ។ បទថា **ឯសោ ធម្មកុដី តវ** សេចក្តីថា វិហារធម៌នេះ ពោល គឺលោកុត្តរធម៌ទាំងអស់ ៩ ជាធម្មកុដិ គឺជាផ្ទះ ដែលជាលំនៅរបស់ព្រះអង្គ ។

បទថា **បញ្ញាយ អគ្គោ និទ្ទិដ្ឋោ** សេចក្តីថា ព្រះថេរៈដែលព្រះមានព្រះភាគទ្រង់តែងតាំង គឺទ្រង់តែងតាំងថា ជាបុគ្គលដ៏ប្រសើរជាងភិក្ខុទាំងឡាយ ខាងមានបញ្ញា ដោយអំណាចបញ្ញា ជាអ្នកវាងវៃ គឺជាអ្នកឈ្លាសក្នុងប្រាជ្ញា គឺក្នុងកិច្ចដែលគប្បីធ្វើដោយបញ្ញា ឬថា ក្នុងយុត្តមុត្តបដិភាណ ប្រាកដដោយនាមថា សារីបុត្រ ជាធម្មសេនាបតីរបស់ព្រះអង្គ គឺជាធំ ជាប្រធាន ដោយការចាំនូវធម៌ គឺព្រះត្រៃបិដក ដែលព្រះអង្គទ្រង់សម្តែងហើយ ធ្វើកិច្ចរបស់កងទ័ព ។

បទថា **ចុតូបបាតកុសលោ** សេចក្តីថា បពិត្រព្រះអង្គដ៏ចម្រើន ព្រះមោគ្គល្លានជាអ្នកឈ្លាស គឺជាអ្នកឈ្លាសក្នុងចុតិ និងបដិសន្ធិ គឺក្នុងការស្លាប់ និងក្នុងការកើត ។ បទថា **ឥទ្ធិយា បារមឹ គតោ** ក្លាប់សេចក្តីថា ព្រះមោគ្គល្លានត្ថេរ ឈ្មោះថា កោលិតៈ ជាអ្នកដល់ គឺសម្រេចបារមី គឺទីបំផុតនៃឫទ្ធិគ្រប់ប្រការ ដែលលោកពោលដោយន័យថា ធ្វើមនុស្សម្នាក់ ឲ្យជាច្រើននាក់ក៏បាន ធ្វើមនុស្សច្រើននាក់ ឲ្យមកជាម្នាក់ក៏បាន ជាបុរោហិតរបស់ព្រះអង្គ ។ បទថា **បោរាណកវំសធរោ** សេចក្តីថា បពិត្រព្រះមុនី មានញាណដ៏ចម្រើន ព្រះមហាកស្សបត្ថេរជាអ្នកទ្រទ្រង់ ឬជាអ្នកដឹងបន្តៗ មកនូវបុរាណវង្ស ជាអ្នកមានតេជះដ៏ខ្ពង់ខ្ពស់ គឺមានតេជះប្រាកដ ដែលគេគ្របសង្កត់បានដោយក្រ គឺមិនអាចធ្វើឲ្យអាក់អន់ គឺខ្ជាំងខ្ជប់ ។ បទថា **ធុតវាទី-**

**គុណេនគ្គោ** សេចក្ដីថា ព្រះមហាកស្សបត្ថេរ ជាអគ្គបុគ្គល គឺប្រសើរ ដោយធុតវាទិគុណ ពោល គឺពោលប្រៀនប្រដៅធុតង្គ ១៣ មានតេចីវរិ- កង្គធុតង្គជាដើម និងដោយធុតង្គគុណ ជាអ្នកសម្រាប់ពិភាក្សារបស់ព្រះអង្គ គឺជាប្រធានក្នុងការពិភាក្សា ។ បទថា **ពហុស្សុតោ ធម្មធរោ** សេចក្ដីថា បពិត្រព្រះមុនី ព្រះអានន្ទ ឈ្មោះថា ជាពហូសូត ព្រោះបានស្ដាប់ធម្មក្ខន្ធ ៨៤០០០ ដ៏ច្រើន និងព្រោះបានរៀនមកអំពីព្រះមានព្រះភាគ និងអំពីភិក្ខុសង្ឃ ឈ្មោះថា ជាអ្នកទ្រទ្រង់នូវធម៌ ព្រោះទ្រទ្រង់នូវធម៌ គឺនិកាយ រាប់បាន ៦ សែន និងបរមត្ថធម៌ មានសតិប្បដ្ឋានជាដើម មិនមែនតិច ។

បទថា **សព្វាចាបី ច សាសនេ** សេចក្ដីថា ព្រះថេរៈមានឈ្មោះថា អានន្ទ ឈ្មោះថា ជំនាញក្នុងព្រះបាលីទាំងពួង ព្រោះជាបុគ្គលប្រសើរ គឺប្រសើរជាងភិក្ខុទាំងពួង ជាអ្នកពោល គឺស្វាធ្យាយនូវព្រះបាលីទាំងពួង ក្នុងព្រះពុទ្ធសាសនា ។ បទថា **ធម្មារក្ខោ តវ** សេចក្ដីថា ជាអ្នករក្សា គឺអ្នករក្សាគ្រប់គ្រងនូវធម៌ បានដល់ កណ្ឌៈ គឺព្រះត្រៃបិដកធម៌របស់ព្រះអង្គ អធិប្បាយថា ជាឃ្លាំងធម៌ ។ បទថា **ឯតេ សព្វេ អតិក្កម្ម** សេចក្ដីថា ព្រះមានព្រះភាគ គឺព្រះសម្មាសម្ពុទ្ធអ្នកមានភាគ្យ គឺបុណ្យ ទ្រង់រំលង គឺទ្រង់វៀរព្រះថេរៈទាំងឡាយ ដែលជាអ្នកមានអានុភាពច្រើន មានព្រះសារីបុត្រជាដើមនេះចេញ ទ្រង់ប្រទាន គឺទ្រង់ធ្វើឲ្យសំខាន់ បានដល់ ទ្រង់ដាក់ព្រះហឫទ័យចំពោះខ្ញុំប៉ុណ្ណោះ ។ បទថា **វិនិច្ឆយំ មេ ចាទាសិ** សេចក្ដីថា ព្រះមានព្រះភាគ ទ្រង់ប្រគល់ គឺទ្រង់ប្រទានដោយចំពោះដល់ខ្ញុំព្រះអង្គ នូវការ

វិនិច្ឆ័យ គឺការពិចារណាទោសក្នុងព្រះវិន័យ ដែលបណ្ឌិតអ្នកចេះវិន័យសម្តែងហើយ គឺប្រកាសហើយ ។

បទថា **យោ កោចិ វិនយេ បញ្ហំ** សេចក្តីថា ភិក្ខុពុទ្ធសាវករូបណានីមួយ សួរនូវបញ្ហាដែលអាស្រ័យវិន័យនឹងខ្ញុំ ខ្ញុំព្រះអង្គមិនបាច់គិត គឺមិនស្រពិចស្រពិល សង្ស័យក្នុងបញ្ហាដែលសួរនោះ ភ្លាប់សេចក្តីថា ខ្ញុំព្រះអង្គពោលអត្ថនោះប៉ុណ្ណោះ គឺឆ្លើយតាមដែលសួរនោះ បានមួយរំពេច ។

បទថា **យាវតា ពុទ្ធក្ខេត្តម្ហិ** ភ្ជាប់សេចក្តីថា ក្នុងពុទ្ធអាណាខេត្ត ក្នុងទីមានកំណត់ត្រឹមណា គឺមានប្រមាណប៉ុនណា វៀរព្រះមហាមុនី គឺព្រះសម្មា-សម្ពុទ្ធនោះហើយ មិនមានបុគ្គលនឹងស្មើដោយខ្ញុំព្រះអង្គ គឺដូចគ្នានឹងខ្ញុំ ព្រះអង្គក្នុងរឿងវិន័យ គឺក្នុងវិនយបិដកនោះៗ ឬក្នុងការវិនិច្ឆ័យព្រះវិន័យ ខ្ញុំព្រះអង្គប៉ុណ្ណោះជាកំពូល បុគ្គលក្រៃលែងជាង គឺក្រៃលែងជាងខ្ញុំព្រះអង្គ នឹងមានមកអំពីណា ។

ព្រះមានព្រះភាគ ព្រះនាមគោតម ទ្រង់គង់ក្នុងជំនុំសង្ឃ គឺគង់ប្រថាប់ក្នុងកណ្តាលនៃភិក្ខុសង្ឃ ហើយទ្រង់ប្រកាសយ៉ាងនេះ គឺទ្រង់ធ្វើសីហនាទ ។ ទ្រង់ប្រកាសដូចម្តេច ទ្រង់ប្រកាសយ៉ាងនេះថា មិនមានអ្នកស្មើ គឺស្មាត់ជំនាញដូចឧបាលី ក្នុងរឿងវិន័យ គឺឧភតោវិភង្គ ក្នុងខន្ធកៈ គឺមហាវគ្គ ចុល្លវគ្គ ។ ដោយ ច សព្ទ សង្គ្រោះយកបរិវារវគ្គផង ។

បទថា **យាវតា** សេចក្តីថា នវង្គសត្ថុសាសនៈ មានសុត្តៈ គេយ្យៈជាដើមមានប្រមាណប៉ុនណា ដែលព្រះសម្ពុទ្ធត្រាស់ គឺទ្រង់សម្តែងទាំងអស់

ព្រះសាស្តា ទ្រង់ប្រកាសសម្រាប់បុគ្គលដែលឃើញយ៉ាងនេះថា នវង្គសត្ថុ-សាសនៈនោះ ឈមចុះក្នុងព្រះវិន័យ គឺប្រជុំខាងក្នុងព្រះវិន័យ មានព្រះវិន័យជាមូល ។ បទថា **មម កម្មំ សរិត្វាន** ក្នុងសេចក្តីថា ព្រះគោតមជាបុគ្គលប្រសើរក្នុងសក្យត្រកូល គឺជាប្រធានក្នុងសក្យវង្ស ទ្រង់វេក គឺទ្រង់ជ្រាបដោយប្រចក្ស ឃើញនូវអំពើរបស់ខ្ញុំ គឺសេចក្តីប្រាថ្នាក្នុងកាលមុនរបស់ខ្ញុំ ដោយអតីតំសញ្ញាណ យាងទៅកណ្តាលភិក្ខុសង្ឃ ទ្រង់តាំងខ្ញុំក្នុងតំណែងឯតទគ្គៈថា ម្នាលភិក្ខុទាំងឡាយ បណ្តាពួកភិក្ខុ អ្នកទ្រទ្រង់វិន័យ ស្រេចនឹងឧបាលិ ប្រសើរជាងគេ ដូច្នេះ ។

បទថា **សតសហស្សុបាទាយ** សេចក្តីថា ខ្ញុំបានប្រាថ្នាតំណែងនេះតាំងពីមួយសែនកប្បមុន សេចក្តីប្រាថ្នានោះ ខ្ញុំបានសម្រេចហើយ គឺដល់ហើយ បានមកហើយ ដល់នូវត្រើយ គឺដល់នូវកំពូលក្នុងព្រះវិន័យ ។

កាលពីដើម គឺក្នុងកាលមុន ខ្ញុំជាជាងកោរកាត់ ជាអ្នកបណ្តុះសេចក្តីត្រេកអរ គឺធ្វើឲ្យកើតសោមនស្សដល់ពួកសក្យៈ គឺដល់ព្រះរាជា ក្នុងសក្យ-វង្សទាំងឡាយ ។ ខ្ញុំលះ គឺបោះបង់ដោយវិសេសនូវកំណើតនោះ គឺត្រកូលនោះ បានដល់ កំណើតនោះ បានមកជាបុត្តរបស់ព្រះមហេសីសម្ពុទ្ធវិញ គឺរបស់ព្រះសម្មាសម្ពុទ្ធ អធិប្បាយថា ដល់នូវការរាប់ថា ជាសក្យបុត្រ ព្រោះទ្រទ្រង់នូវពាក្យប្រៀនប្រដៅ ។

បន្ទាប់អំពីនោះ កាលនឹងសម្តែងអបទានក្នុងកាលដែលលោកកើតក្នុងត្រកូលទាសៈ ទើបព្រះថេរៈពោលគាថាថា **ឥតោ ទុតិយកេ កប្បេ** ដូច្នេះ

ជាដើម ។ ក្នុងគាថានោះ ភ្ជាប់សេចក្តីថា ក្នុងកប្បទី ២ អំពីកប្បនេះទៅ មានខត្តិយរាជ គឺព្រះរាជាមួយអង្គ ព្រះនាមអញ្ជសៈ មានតេជះរកទីបំផុតគ្មាន គឺមានតេជានុភាពរាប់មិនបាន មានយសរាប់មិនបាន គឺមានបរិវាររាប់មិនបាន មានទ្រព្យច្រើន គឺមានទ្រព្យសែនកោដិ ទ្រង់ជាម្ចាស់ផែនដី គឺទ្រង់គ្រប់គ្រងរក្សាប្រឹថពី ។

បទថា **តស្ស រញ្ញោ** ភ្ជាប់សេចក្តីថា ខ្ញុំជាឱរសរបស់ព្រះរាជានោះ គឺបែបនោះ បានជាក្សត្រ គឺជាខត្តិយកុមារ នាមថា ចន្ទៈ អធិប្បាយថា ខ្ញុំនោះជាអ្នករឹងត្អឹង គឺរឹងរូស ប្រកាន់ខ្លួន ដោយសេចក្តីស្រវឹងព្រោះជាតិ សេចក្តីស្រវឹងព្រោះយស និងសេចក្តីស្រវឹងព្រោះភោគៈ ។

បទថា **នាគសតសហស្សានិ** ភ្ជាប់សេចក្តីថា ដំរីមាតង្គៈ គឺដំរីដែលកើតក្នុងត្រកូលមាតង្គៈ ១ សែន ចុះប្រេងក្នុងទីបីអន្លើ គឺប្រេងដែលធ្វើឲ្យកាច បានដល់ ប្រេងដែលហូរចេញអំពីទី ៣ កន្លែង គឺភ្នែក ត្រចៀក និងអណ្ឌៈ[១] ប្រដាប់ដោយគ្រឿងអលង្ការទាំងពួង គឺប្រដាប់ដោយគ្រឿងអលង្ការសម្រាប់ដំរីគ្រប់យ៉ាង ចោមរោមខ្ញុំសព្វៗ កាល គឺអស់កាលទាំងពួង ។

បទថា **សពលេហិ បរេតោហំ** ភ្ជាប់សេចក្តីថា ក្នុងកាលនោះ ខ្ញុំដែលពលរបស់ខ្លួន គឺពលនៃកងទ័ពចោមរោម បំណងទៅកាន់ឧទ្យាន ទើបឡើងផែលដំរីឈ្មោះសិរិកៈ ចេញអំពីព្រះនគរទៅ ។

---

១- ពាក្យថា អណ្ឌៈ យើងប្រែមកពីបាលីថា កោស តែលេខយោង ក្នុងបិដកខ្មែរលោកថា ស្នាប់ភ្លុក ទៅវិញ ។

គាថាថា **ចរណេន ច សម្បន្នោ** ជាដើម សេចក្តីថា ព្រះសម្ពុទ្ធ គឺព្រះបច្ចេកសម្ពុទ្ធ នាមថា ទេវលៈ ប្រកបដោយចរណៈ ១៥ មានសីល-សំវរៈជាដើម ជាអ្នកមានទ្វារគ្រប់គ្រង គឺបិទនូវទ្វារទាំង ៦ មានចក្ខុទ្វារជាដើម សង្រួមល្អ គឺរក្សាកាយ និងចិត្តដោយល្អ បានទិមន្តមក គឺមកចំពោះមុខ គឺត្រង់មុខរបស់ខ្ញុំ ។

គាថាថា **បេសេត្វា សិរិកំ នាគំ** ជាដើម សេចក្តីថា ខ្ញុំឃើញព្រះបច្ចេកសម្ពុទ្ធនោះមកហើយ ទើបពន្យុះដំរីឈ្មោះសិរិកៈទៅចំពោះមុខ ធ្វើដំរីឲ្យបៀតបៀន គឺឲ្យទៅក្បែរ បានដល់ ឲ្យប្រទូស្តព្រះបច្ចេកសម្ពុទ្ធ ។ បទថា **តតោ សញ្ញាតកោធោ សោ** សេចក្តីថា ព្រោះ គឺដោយហេតុនោះ គឺព្រោះការពន្យុះនោះ ដំរីនោះកើតនូវសេចក្តីក្រោធក្នុងខ្ញុំ មិនលើកជើង បានដល់ នៅស្ងៀម ។

ក្នុងគាថាថា **នាគំ ទុដ្ឋមនំ ទិស្វា** ជាដើម សេចក្តីថា ខ្ញុំឃើញដំរីមានចិត្តប្រទូស្ត គឺមានចិត្តក្រោធ ក៏ក្រេវក្រោធ គឺញុំាងទោសឲ្យកើតឡើងក្នុងព្រះបច្ចេកសម្ពុទ្ធ ។ បទថា **វិហេសយិត្វា សម្ពុទ្ធំ** ក្លាប់សេចក្តីថា ខ្ញុំបៀតបៀន គឺធ្វើព្រះទេវលបច្ចេកសម្ពុទ្ធឲ្យលំបាក ហើយបានទៅកាន់ឧទ្យាន ។

បទថា **សាតំ តត្ថ ន វិន្ទាមិ** សេចក្តីថា ខ្ញុំមិនបានជួបនូវការត្រេកអរព្រោះហេតុដែលធ្វើឲ្យអាក់អន់នោះ អធិប្បាយថា ខ្ញុំមិនបានសេចក្តីសុខ ដែលមានការអាក់អន់ជាហេតុ ។ បទថា **សិរោ បជ្ជលិតោ យថា** សេចក្តីថា ក្បាល គឺសីសៈរបស់ខ្ញុំដូចជាភ្លើងឆេះ គឺដូចភ្លើងឆេះសន្ធោសន្ធៅ ។ បទថា

**បរិឡាហេន ឧយ្ហាមិ** សេចក្តីថា ខ្ញុំធ្វើសេចក្តីក្រោធក្នុងព្រះបច្ចេកសម្ពុទ្ធ រមែងក្តៅក្រហាយ គឺមានចិត្តក្តៅ ដោយកម្តៅដែលតាមមក ។

ក្នុងគាថាថា **សាគរន្តា** ជាដើម សេចក្តីថា ព្រោះកម្លាំងនៃកម្មដ៏លាមក នោះឯង មហាប្រឹថពីទាំងមូល មានសាគរជាទីបំផុត គឺមានសាគរជាព្រំប្រទល់ រមែងប្រាកដដល់ខ្ញុំ ហាក់ដូចជាដុតកម្តៅខ្ញុំ គឺដូចភ្លើងឆេះទ្រលោមហើយ ។ បទថា **បិតុ សន្តិកុបាគម្ម** សេចក្តីថា កាលភ័យកើតឡើងហើយយ៉ាងនេះ ទើបខ្ញុំចូលគាល់ គឺចូលទៅកាន់សម្នាក់បិតារបស់ខ្លួន ហើយបានក្រាបទូល គឺពោលពាក្យនេះ ។

ក្នុងគាថាថា **អាសីវិសំវ កុបិតំ** ជាដើម ភ្ជាប់សេចក្តីថា ខ្ញុំធ្វើព្រះបច្ចេកសម្ពុទ្ធអង្គណាដែលនិមន្តមក ដែលជាព្រះពុទ្ធសយម្ភូ គឺជាព្រះពុទ្ធដោយខ្លួនឯង ដូចអាសិរពិសទាំងពួងដែលក្រោធ ដូចគំនរភ្លើងកំពុងឆេះ និងដូចកុញ្ជរ គឺដំរីដ៏ឧត្តម ដែលចុះប្រេង គឺហូរប្រេងក្នុងទីបីអន្លើ គឺឲ្យលោកអាក់អន់ គឺឲ្យមានចិត្តសៅហ្មង ។

បទថា **អាសាទិតោ មយា ពុទ្ធោ** ជាដើម សេចក្តីថា ព្រះបច្ចេក-សម្ពុទ្ធអង្គនោះ យើងខ្ញុំបៀតបៀនហើយ គឺធ្វើឲ្យថ្នាំងថ្នាក់ហើយ ជាអ្នកមានតបៈដ៏ខ្ពង់ខ្ពស់ គឺឈ្មោះថា ខ្ពង់ខ្ពស់ ព្រោះអ្នកដទៃមិនអាចតតាំងបាន ជាអ្នកមានតបៈដ៏ខ្ពស់ គឺមានតបៈប្រាកដ ជាព្រះជិនស្រី គឺឈ្នះមារទាំង ៥ អធិប្បាយថា ព្រះបច្ចេកសម្ពុទ្ធសម្បូរដោយគុណយ៉ាងនេះ ខ្ញុំបានបៀតបៀនហើយ ។ បទថា **បុរា សព្វេ វិនស្សាម** សេចក្តីថា ព្រោះការធ្វើនូវការមិន

អើពើក្នុងព្រះបច្ចេកសម្ពុទ្ធនោះ យើងខ្ញុំទាំងអស់គ្នានឹងវិនាស គឺនឹងវិនាសដោយអាការផ្សេងៗ អធិប្បាយថា នឹងដូចជាផេះផង់ធូលី ។ បទថា **១មា-បេស្សាម តំ មុនឹ** សេចក្ដីថា ពួកខ្ញុំនឹងឲ្យព្រះបច្ចេកសម្ពុទ្ធមុនីនោះអត់ទោសដរាបណាដែលពួកយើងមិនទាន់វិនាស ។

ក្នុងគាថាថា **នោ ចេ តំ និជ្ឈាបេស្សាម** ជាដើម សេចក្ដីថា បើយើងទាំងឡាយមិនញ៉ាំងព្រះបច្ចេកសម្ពុទ្ធនោះ ដែលមានខ្លួនទូន្មានហើយ គឺជាអ្នកមានចិត្តទូន្មានហើយ មានព្រះហឫទ័យខ្ជាប់ខ្ជួន គឺមានចិត្តជាឯកគ្គតា គឺឲ្យលោកអត់ទោស ។ ថយពីថ្ងៃទី ៧ គឺក្នុងចំណោកខាងក្នុង ៧ ថ្ងៃ បានដល់មិនលើស ៧ ថ្ងៃ ដែនដ៏សម្បូររបស់ពួកយើងមុខជាវិនាស គឺនឹងវិនាសអស់ ។

ក្នុងគាថាថា **សុមេខលោ កោសិយោ ច** ជាដើម សេចក្ដីថា ព្រះរាជា ៤ អង្គ គឺព្រះសុមេខលៈជាដើមនេះ បានបៀតបៀន គឺបៀតបៀនឥសីទាំងឡាយ បានដល់ ធ្វើនូវការមិនអើពើ មួយអន្ទើដោយអ្នកដែន គឺមួយអន្ទើដោយអ្នកជនបទក្នុងដែន បានទទួលសេចក្ដីទុក្ខ គឺនាំគ្នាដល់នូវសេចក្ដីវិនាស ។

ក្នុងគាថាថា **យទា កុប្បន្តិ ឥសយោ** ជាដើម ភ្ជាប់សេចក្ដីថា ក្នុងកាលណាឥសីទាំងឡាយដែលជាអ្នកសង្រួម គឺសង្រួមដោយសំវរៈតាមកាយជាដើម ជាអ្នកស្ងប់ ប្រព្រឹត្តព្រហ្មចរិយធម៌ គឺមានប្រក្រតីប្រព្រឹត្តយ៉ាងឧត្តម បានដល់ ប្រព្រឹត្តយ៉ាងប្រសើរ ក្រោធអាក់អន់ គឺជាបុគ្គលទោមនស្សក្នុងកាលនោះ នឹងធ្វើលោក ព្រមទាំងទេវលោក ព្រមទាំងសាគរ និងភ្នំឲ្យ

វិនាស ។

បទថា **តិយោជនសហស្សម្ហិ** ជាដើម ក្នុងសេចក្តីថា ខ្ញុំដឹងអានុភាពរបស់ឥសីទាំងនោះ ទើបឲ្យប្រជុំពួកបុរស ក្នុងប្រទេសប្រមាណ ៣ ពាន់យោជន៍ ដើម្បីសូមឲ្យលោកអត់ទោស គឺដើម្បីសម្តែង គឺដើម្បីប្រកាសទោស គឺកំហុស ។ បទថា **សយម្ភុំ ឧបសង្កមឹ** សេចក្តីថា ខ្ញុំចូលទៅរក គឺចូលទៅជិតព្រះសយម្ភូ គឺព្រះបច្ចេកសម្ពុទ្ធ ។

ក្នុងគាថាថា **អល្លវត្ថា** ជាដើម សេចក្តីថា ជនទាំងពួង មករួមជាមួយនឹងខ្ញុំ ស្លៀកសំពត់ទទឹក គឺមានសំពត់ជណ្តប់សើមដោយទឹក មានក្បាលទទឹក គឺមានសក់សើម ធ្វើក្រពុំម្រាមដៃ គឺធ្វើនូវក្រពុំនៃអញ្ជលី ដាក់លើសិរសា ក្រាបទៀប គឺក្រាបទៀបជើង គឺក្បែរជើងរបស់ព្រះពុទ្ធ គឺព្រះបច្ចេកមុនី បានពោលដូច្នោះ អធិប្បាយថា បានបន្លឺវាចា គឺមានពាក្យជាដើមថា បពិត្រព្រះមហាវីរៈ សូមទ្រង់អត់ទោសផងចុះ ។

បពិត្រព្រះមហាវីរៈ គឺបពិត្រព្រះអង្គមានសេចក្តីព្យាយាមដ៏ឧត្តម បានដល់ ព្រះបច្ចេកសម្ពុទ្ធដ៏ចម្រើន សូមព្រះអង្គរម្ងាប់ក្រវល់ក្រវាយ គឺសូមបន្ទោបង់នូវទោស ដែលខ្ញុំធ្វើក្នុងព្រះអង្គ ព្រោះការមិនដឹង អធិប្បាយថា សូមទ្រង់កុំដាក់ចិត្តឡើយ ។ ជន គឺពួកជន អង្វរព្រះមានព្រះភាគនោះថា សូមទ្រង់បន្ទោបង់នូវការក្រវល់ក្រវាយ គឺក្តៅក្រហាយព្រោះទុក្ខផ្លូវចិត្ត ដែលធ្វើដោយទោសៈ និងមោហៈដល់ពួកខ្ញុំ គឺសូមធ្វើឲ្យធូរស្បើយ អធិប្បាយថា សូមព្រះអង្គកុំធ្វើនូវដែន គឺអ្នកជនបទ ក្នុងដែនទាំងមូលរបស់ខ្ញុំឲ្យវិនាស

ឡើយ ។

ក្នុងគាថាថា **សទេវមានុសា សព្វេ** ជាដើម សេចក្តីថា ពួកមនុស្សទាំងពួង ព្រមទាំងទេវតា និងទានវៈ គឺព្រមទាំងអសុរ មានបហារទអសុរជាដើម ព្រមទាំងអារក្សទឹក នឹងយកដំបងដែក គឺដំបងធំវាយ គឺបំបែកក្បាលរបស់ខ្ញុំ គឺអំបែងក្បាលរបស់ខ្ញុំសព្វកាល គឺអស់កាលទាំងពួង ។

បន្ទាប់អំពីនេះទៅ កាលប្រកាសថា ព្រះពុទ្ធទាំងឡាយជាអ្នកឲ្យអភ័យ នឹងមិនក្រោធ ទើបព្រះបច្ចេកសម្ពុទ្ធពោលពាក្យថា **ឧកេ អគ្គិ ឩ សណ្ឋាតិ** ជាដើម ។ ក្នុងគាថានោះ មានអធិប្បាយថា ភ្លើងមិនស្ថិតនៅ គឺមិនឆេះក្នុងទឹក យ៉ាងណា ពូជ រមែងមិនដុះលើថ្ម គឺលើភ្នំថ្ម យ៉ាងណា ជន្តុ គឺសត្វមានជីវិត រមែងមិនតាំងនៅក្នុងថ្នាំ គឺឱសថ យ៉ាងណា សេចក្តីក្រោធ គឺចិត្តក្រោធអាក់អន់ បានដល់ ការមានចិត្តប្រទូស្ត រមែងមិនកើត គឺមិនកើតឡើងក្នុងព្រះពុទ្ធ គឺក្នុងព្រះបច្ចេកសម្ពុទ្ធដែលចាក់ផ្ទុះនូវសច្ចៈបានហើយ ដូច្នោះ ។

កាលប្រកាសអានុភាពរបស់ព្រះពុទ្ធទាំងឡាយទៀត ទើបព្រះបច្ចេក-សម្ពុទ្ធពោលពាក្យថា **យថា ច ភូមិ** ដូច្នេះជាដើម ។ ក្នុងពាក្យនោះ មានអធិប្បាយថា ដូចជាផែនដី គឺប្រឹថពីមិនកម្រើក គឺមិនញាប់ញ័រ យ៉ាងណា ព្រះពុទ្ធ ក៏ជាអ្នកមិនញាប់ញ័រ ក៏យ៉ាងនោះ ។ អធិប្បាយថា សមុទ្រសាគរ គឺមហាសមុទ្រ ប្រមាណមិនបាន គឺមិនអាចប្រមាណ គឺគណនា ( មិន ) បាន យ៉ាងណា ព្រះពុទ្ធ ក៏ប្រមាណមិនបាន ក៏យ៉ាងនោះ អធិប្បាយថា អាកាស គឺអាកាសដែលពាល់ត្រូវមិនបាន រកទីបំផុតគ្មាន គឺមិនមានព្រំដែន

យ៉ាងណា ព្រះពុទ្ធក៏យ៉ាងនោះ បុគ្គលណាមួយ ក៏ឲ្យកម្រើកមិនបាន គឺបុគ្គលណាមួយមិនអាចឲ្យកម្រើក គឺឲ្យរឹករេបានឡើយ ។

បន្ទាប់អំពីនោះ កាលនឹងសម្តែងពាក្យសូមខមាទោសចំពោះព្រះបច្ចេកសម្ពុទ្ធ ទើបព្រះថេរៈពោលពាក្យថា **សទា ខន្តា មហាវីរា** ដូច្នេះជាដើម ។ ក្នុងគាថានោះ មានការក្លាប់សេចក្តីថា ព្រះមហាវីរៈទាំងឡាយ គឺព្រះពុទ្ធជាអ្នកមានវីរិយៈដ៏ឧត្តម មានតបៈ គឺប្រកបដោយសេចក្តីព្យាយាម ដែលបាន ឈ្មោះថា តបៈ ព្រោះដុតនូវបាបទាំងឡាយ ជាអ្នកអត់ធន់ គឺដល់ព្រមដោយខន្តី ជាអ្នកអត់ទោស គឺអត់សង្កត់នូវកំហុសរបស់អ្នកដទៃសព្វកាល គឺសព្វកាលទាំងពួង ។ បទថា **ខន្តានំ ខមិតានញ្ច** សេចក្តីថា ព្រះពុទ្ធទាំងនោះ ជាអ្នកអត់ធន់ គឺប្រកបដោយខន្តី និងអត់ទោស គឺអត់សង្កត់នូវកំហុសរបស់អ្នកដទៃ មិនមានការលុះ គឺដល់នូវអគតិ មានឆន្ទាគតិជាដើម ។

ព្រះសម្ពុទ្ធ គឺព្រះបច្ចេកសម្ពុទ្ធកាលពោលពាក្យនេះ ដោយប្រការដូច្នេះហើយ កាលនឹងរម្ងាប់ គឺប្រាសចាកសេចក្តីក្រវល់ក្រវាយ គឺការក្តៅដែលកើតឡើងដល់សត្វទាំងឡាយហើយ ហោះទៅតាមអាកាស គឺហោះទៅក្នុងកាលនោះ ចំពោះមុខមហាជន គឺចំពោះមុខជនជាច្រើន ព្រមទាំងព្រះរាជាដែលមកប្រជុំគ្នា ។

ក្នុងគាថាថា **តេន កម្មេនហំ ធីរ** ជាដើម សេចក្តីថា បពិត្រព្រះធីរៈ គឺបពិត្រព្រះអង្គដែលសម្បូរដោយធិតិ ព្រោះកម្មនោះ គឺព្រោះកម្ម គឺការមិនអើពើ ដែលធ្វើក្នុងព្រះបច្ចេកសម្ពុទ្ធ ក្នុងអត្តភាពចុងក្រោយនេះ ទើបខ្ញុំព្រះអង្គ

ចូលទៅកាន់ គឺដល់ព្រមនូវភាពជាអ្នកថោកទាប គឺភាពលាមក បានដល់កើតជាជាងកោរកាត់របស់ព្រះរាជាទាំងឡាយ ។

បទថា **សមតិក្កម្ម តំ ជាតឹ** សេចក្ដីថា កន្លង គឺកន្លងផុតទៅដោយល្អនូវការកើត ដែលទាក់ទងដោយអ្នកដទៃនោះ ។ បទថា **ចារិសឹ អភយំ បុរំ** សេចក្ដីថា ខ្ញុំព្រះអង្គក៏បានចូលទៅកាន់ គឺបានចូលទៅកាន់និព្វានបុរី គឺនិព្វានមហានគរដែលផុតភ័យ ។

ក្នុងគាថាថា **តទាបិ មំ មហាវីរ** ជាដើម សេចក្ដីថា បពិត្រព្រះមហាវីរបុរសដ៏ឧត្ដម ក្នុងវេលានោះ គឺក្នុងសម័យដែលធ្វើព្រះបច្ចេកសម្ពុទ្ធឲ្យអាក់អន់នោះ ព្រះសយម្ភូ គឺព្រះបច្ចេកសម្ពុទ្ធទ្រង់បានបន្ទោបង់ គឺធ្វើឲ្យធ្លាយនូវការក្ដៅក្រហាយ គឺការក្រវល់ក្រវាយតាមកាយ និងចិត្តដែលកើតឡើងព្រោះហេតុនៃការអាក់អន់ ភ្ជាប់សេចក្ដីថា ព្រះសយម្ភូទ្រង់ឃើញខ្ញុំដែលត្រូវភ្លើងដុតរោល គឺ ក្ដៅក្រហាយ ដោយការក្ដៅក្រហាយក្នុងកាលជាខាងក្រោយចាកការធ្វើនោះឯង តាំងនៅបានល្អ គឺបញ្ឈប់បានល្អ ព្រោះឃើញទោសថាជាទោស ទើបអត់ទោសឲ្យ គឺ អត់សង្កត់នូវកំហុសនោះ ។

ក្នុងគាថាថា **អជ្ជាបិ មំ មហាវីរ** ជាដើម សេចក្ដីថា បពិត្រព្រះអង្គអ្នកមានសេចក្ដីព្យាយាមដ៏ឧត្ដម ក៏ក្នុងថ្ងៃនេះ គឺក្នុងវេលាសមាគមរបស់ខ្ញុំព្រះមានព្រះភាគ បានធ្វើខ្ញុំដែលត្រូវភ្លើងទាំង ៣ គឺរាគគ្គិ ទោសគ្គិ និងមោហគ្គិ ឬភ្លើងក្នុងនរក ភ្លើងក្នុងបិត្តិវិស័យ និងភ្លើងក្នុងសង្សារដុតរោល គឺឲ្យសោយទុក្ខ ឲ្យដល់ គឺឲ្យជួបនូវភាពត្រជាក់ បានដល់ ភាពត្រជាក់ ពោល

គឺការស្ងប់កាយ និងចិត្ត ព្រោះទោមនស្សវិនាសទៅ ឬឲ្យដល់នូវព្រះនិព្វាន នោះឯង ភ្ជាប់សេចក្តីថា ភ្លើង ៣ គឺភ្លើង ៣ កង ដែលមានប្រការដូចពោលហើយនោះឲ្យរលត់ គឺឲ្យស្ងប់ ។

កាលសម្តែងអបទានដ៏អាក្រក់របស់ខ្លួន ដល់ព្រះមានព្រះភាគ ដោយប្រការយ៉ាងនេះហើយ កាលនឹងពោលដឹកនាំឲ្យស្តាប់អបទានដ៏អាក្រក់ហើយជាស់តឿនអ្នកដទៃ ទើបព្រះឧបាលិត្ថេរពោលថា **យេសំ សោតាវធា អត្ថិ** ដូច្នេះជាដើម ។

ក្នុងគាថានោះ មានសេចក្តីថា ជនពួកណា មានការផ្ទៀងនូវសោតៈ គឺតម្កល់នូវសោតៈ ជនទាំងនោះ ចូរស្តាប់ គឺចូរដាក់ចិត្តស្តាប់នូវពាក្យរបស់ខ្ញុំដែលកំពុងពោល ។ បទថា **អត្ថំ តុម្ហំ បវក្ខាមិ** ភ្ជាប់សេចក្តីថា ខ្ញុំឃើញបទ គឺព្រះនិព្វានដោយប្រការណា ខ្ញុំនឹងពោលបរមត្ថប្រយោជន៍ គឺព្រះនិព្វានដល់អ្នកទាំងឡាយ ដោយប្រការនោះ ។

កាលសម្តែងអបទាននោះ ទើបព្រះថេរៈពោលថា **សយម្ភុំ តំ វិមា-នេត្វា** ដូច្នេះជាដើម ។ គប្បីជ្រាបវិនិច្ឆ័យក្នុងគាថានោះដូចតទៅ ខ្ញុំបានមើលងាយ គឺធ្វើនូវការមិនអើពើក្នុងព្រះសយម្ភូ គឺព្រះបច្ចេកសម្ពុទ្ធ ជាអ្នកត្រាស់ដឹងឯង កើតក្នុងអរិយជាតិ មានចិត្តស្ងប់រម្ងាប់ គឺមានចិត្តតាំងមាំ ដោយកម្មនោះ គឺព្រោះអកុសលដែលធ្វើហើយនោះ ទើបខ្ញុំមកកើត គឺជាអ្នកកើតក្នុងកំណើតថោកទាប គឺក្នុងកំណើតដែលត្រូវពឹងអ្នកដទៃ គឺកើតជាជាងកោរកាត់ ក្នុងថ្ងៃនេះ គឺក្នុងបច្ចុប្បន្ននេះ ។

បទថា **មា វោ ខណំ ឧបច្ចគា** សេចក្តីថា អ្នកទាំងឡាយ កុំបីកន្លងភ្លាត់ គឺកុំធ្វើឲ្យភ្លាត់នូវខណៈដែលព្រះពុទ្ធកើតឡើង ពិតហើយ សត្វទាំងឡាយដែលខណៈកន្លងហើយ គឺឈានកន្លងខណៈដែលព្រះពុទ្ធកើតឡើង រមែងសោកសៅ គឺសោយសោកយ៉ាងនេះថា ពួកយើងជាអ្នកមិនមានបុណ្យ មានបញ្ញាថោកថយ អ្នកទាំងឡាយគប្បីព្យាយាម គឺចូរធ្វើសេចក្តីព្យាយាមក្នុងប្រយោជន៍របស់ខ្លួន គឺក្នុងសេចក្តីចម្រើនរបស់ខ្លួន អធិប្បាយថា អ្នកទាំងឡាយ ចូរធ្វើខណៈ គឺសម័យដែលព្រះពុទ្ធកើតឡើង ឲ្យដល់ចំពោះ គឺឲ្យសម្រេច គឺឲ្យសម្រេចព្រម បានដល់ ទាន់ពេលវេលា ។

បន្ទាប់អំពីនោះ កាលនឹងសម្តែងទោសរបស់បុគ្គលដែលទៅក្នុងសង្សារ ដោយឧបមាឧបមេយ្យ ទើបព្រះថេរៈពោលថា **ឯកច្ចានញ្ច វមនំ** ដូច្នេះជាដើម ។ ក្នុងគាថានោះ ភ្ជាប់សេចក្តីថា ព្រះមានព្រះភាគត្រាស់ប្រាប់ថ្នាំក្អួត គឺថ្នាំធ្វើឲ្យក្អួតដល់ជនពួកខ្លះ គឺដល់បុគ្គលពួកខ្លះ ថ្នាំបញ្ចុះ គឺថ្នាំបន្ទោបង់ដល់បុគ្គលពួកខ្លះ ថ្នាំពិសដ៏ខ្លាំង គឺថ្នាំពិសដែលធ្វើឲ្យសន្ធប់ដល់បុគ្គលពួកខ្លះ និងថ្នាំ គឺឧបាយសម្រាប់ព្យាបាលដល់បុគ្គលពួកខ្លះដោយលំដាប់ ដោយប្រការដូច្នេះ ។

ក្នុងគាថាថា **វមនំ បដិបន្នានំ** ជាដើម ភ្ជាប់សេចក្តីថា ព្រះមានព្រះភាគត្រាស់ប្រាប់ នូវថ្នាំក្អួត គឺការលះសង្សារ បានដល់ ការផុតសង្សារ ដល់អ្នកបដិបត្តិ គឺបុគ្គលមានការដល់ព្រមដោយមគ្គ ភ្ជាប់សេចក្តីថា ត្រាស់ប្រាប់នូវការបន្ទោបង់ គឺការហូរចេញចាកសង្សារដល់បុគ្គលតាំងនៅក្នុងផល ។

ត្រាស់ប្រាប់ឱសថ គឺព្រះនិព្វាន ដល់បុគ្គលអ្នកបានទូវផល គឺបានផលហើយ តម្កល់ជីវិតនៅ ។ ត្រាស់ប្រាប់ព្រះសង្ឃ ដែលជាបុញ្ញក្ខេត្តដល់អ្នកស្វែងរក គឺស្វែងរកមនុស្សសម្បត្តិ ទេវសម្បត្តិ និងនិព្វានសម្បត្តិ ។

ក្នុងគាថាថា **សាសនេន វិរុទ្ធានំ** ជាដើម ក្បាប់សេចក្តីថា ត្រាស់ប្រាប់ថ្នាំពិសដ៏ខ្លាំង គឺការរឹករឹរ បានដល់ បាបអកុសលដល់បុគ្គលដែលជាបដិបក្ខចំពោះសាសនា ។ បទថា **យថា អាសីវិសោ** ក្បាប់សេចក្តីថា ថ្នាំពិសដ៏ខ្លាំងក្លា រមែងដុត គឺដុតនរៈនោះ គឺនរៈដែលមិនមែនសទ្ធា ធ្វើតែបាប បានដល់ ធ្វើឲ្យវិនស្តួតក្នុងអបាយ ៤ ដូចគ្នានឹងអាសិរពិស គឺដូចអាសិរពិស គឺពស់ឈ្មោះទិដ្ឋវិស ព្រោះធ្វើឲ្យក្លាយជាធូលី ដោយគ្រាន់តែឃើញ រមែងដុតនរៈដែលត្រូវពស់នោះចឹក គឺធ្វើឲ្យលំបាក ដូច្នោះ ។

ក្នុងគាថាថា **សកឹ បីតំ ហលាហលំ** ជាដើម សេចក្តីថា ថ្នាំពិសដ៏ខ្លាំងក្លាដែលផឹកចូលទៅ រមែងចូលបៀតបៀនជីវិត គឺធ្វើជីវិតឲ្យវិនាសទៅមួយម្តង គឺមួយគ្រាដល់បុគ្គលដែលប្រតិបត្តិខុស គឺធ្វើនូវកំហុសក្នុងព្រះសាសនា រមែងក្តៅក្រហាយ គឺរមែងត្រូវដុតអស់កោដិនៃកប្ប គឺអស់កប្បរាប់ដោយកោដិ ។

កាលសម្តែងផលវិបាករបស់បុគ្គល ដែលមិនមានសទ្ធាយ៉ាងនេះហើយ ឥឡូវនេះ កាលនឹងសម្តែងអានុភាពរបស់ព្រះពុទ្ធទាំងឡាយ ទើបព្រះថេរៈពោលថា **ខន្តិយា** ដូច្នេះជាដើម ។ ក្នុងគាថានោះ មានអធិប្បាយថា ព្រះសម្ពុទ្ធអង្គណា ត្រាស់ប្រាប់នូវការក្អួតជាដើម ព្រះសម្ពុទ្ធអង្គនោះ រមែងញ៉ាំង

លោក ព្រមទាំងទេវលោក គឺប្រព្រឹត្តទៅដោយទេវតាទាំងឡាយ ឲ្យឆ្លង គឺឈានកន្លង បានដល់ ឲ្យរម្ងត់ដោយការអត់ធន់ គឺការអត់ធន់ ដោយការមិនបៀតបៀន គឺមិនមានការបៀតបៀនសត្វទាំងឡាយ ដោយមានមេត្តាចិត្ត គឺដោយមានចិត្តមេត្តា ព្រោះហេតុនោះ ព្រះពុទ្ធទាំងឡាយ ដែលពួកអ្នកទាំងឡាយមិនគប្បីឲ្យត្តាំងត្តង គឺមិនអាចធ្វើឲ្យខុសប្រក្រតី អធិប្បាយថា គប្បីបដិបត្តិតាមពុទ្ធសាសនា ។

អធិប្បាយក្នុងគាថាតទៅថា ព្រះពុទ្ធទាំងឡាយមិនជាប់ជំពាក់ គឺមិនគប់រក មិនជាប់ក្នុងលាភ និងក្នុងការមិនមានលាភ ។ ព្រះពុទ្ធទាំងឡាយមិនញាប់ញ័រក្នុងការរាប់អាន គឺក្នុងការធ្វើនូវការអើពើ និងក្នុងការមើលងាយ គឺការធ្វើនូវការមិនអើពើ ព្រោះហេតុនោះ ព្រះពុទ្ធទាំងនោះ អ្នកទាំងឡាយឲ្យត្តាំងត្តងមិនបាន គឺមិនធ្វើខុស គឺមិនអាចឲ្យខុសប្រក្រតី ។ កាលនឹងសម្តែងថា ព្រះពុទ្ធទាំងឡាយ ទ្រង់ជាកណ្តាល ទើបព្រះថេរៈពោលថា **តេវតេត្ត** ដូច្នេះជាដើម ។ ក្នុងគាថានោះ មានអធិប្បាយថា ព្រះមុនី គឺព្រះពុទ្ធមុនី ជាអ្នកស្មើ គឺមានព្រះហឫទ័យស្មើក្នុងសត្វទាំងពួង ទាំងក្នុងនាយខ្មាន់ធ្នូ និងមិនមែននាយខ្មាន់ធ្នូ ។

បទថា **ឯតេសំ បដិឃោ ឧត្ថិ** ជាដើម ភ្ជាប់សេចក្តីថា សេចក្តីក្រោធ គឺការប្រទូស្ត បានដល់ ភាពជាអ្នកមានចិត្តប្រកបដោយទោសៈ មិនមានដល់ព្រះពុទ្ធទាំងនោះ ។ បទថា **រាគោមេសំ ឧ វិជ្ជតិ** សេចក្តីថា សូម្បីរាគៈ គឺតម្រេក បានដល់ ការជាប់ចិត្ត មិនមាន គឺរកមិនឃើញក្នុងព្រះពុទ្ធ

ទាំងនេះ ព្រោះហេតុនោះ ទើបព្រះពុទ្ធជាបុគ្គលស្មើ គឺមានព្រះហឫទ័យស្មើ ចំពោះសត្វទាំងពួង គឺចំពោះនាយខ្មាន់ធ្នូ និងព្រះរាជឱរស ។

កាលសម្តែងអានុភាពរបស់ព្រះពុទ្ធទាំងឡាយដដែលទៀត ទើបព្រះថេរៈពោលថា **បន្ថេ និស្វាន កាសាវំ** ដូច្នេះជាដើម ។ ក្នុងគាថានោះ មានអធិប្បាយថា បុគ្គលណាមួយ ឃើញសំពត់កាសាវៈ គឺចីវរជ្រលក់ដោយទឹកម្ចត់ ដែលប្រឡាក់ដោយលាមក គឺប្រឡាក់ប្រឡូសដោយលាមក ដែលជាទង់ជ័យរបស់ព្រះពុទ្ធ បានដល់ ជាទង់ គឺបរិក្ខាររបស់ព្រះអរិយៈទាំងឡាយ ដែលគេចោលក្នុងផ្លូវ គឺត្រង់ផ្លូវដើរ គប្បីធ្វើអញ្ជលី គឺធ្វើនូវការប្រជុំនូវម្រាមទាំង ១០ បានដល់ ផ្គងអញ្ជលីលើសិរសា ហើយថ្វាយបង្គំដោយត្បូង គឺគប្បីថ្វាយបង្គំ គប្បីរាប់អាន គប្បីបូជាទង់នៃឥសី គឺទង់នៃអរហត្ត បានដល់ ចីវរដែលសម្តែងថាជាព្រះពុទ្ធ ជាព្រះបច្ចេកសម្ពុទ្ធ និងព្រះសាវ័ក ។

បទថា **អព្ភតីតា** សេចក្តីថា ព្រះពុទ្ធទាំងឡាយណាកន្លងទៅហើយ គឺនិព្វានទៅហើយ ព្រះពុទ្ធពួកណាកំពុងប្រព្រឹត្តទៅក្នុងបច្ចុប្បន្នក្តី គឺកើតមកក្នុងឥឡូវនេះក្តី ព្រះពុទ្ធទាំងឡាយណាក្នុងអនាគត គឺមិនទាន់កើត មិនទាន់កើតឡើង មិនទាន់ឧប្បត្តិក គឺមិនទាន់ប្រាកដ ។ បទថា **ធជេនានេន សុជ្ឈន្តិ** សេចក្តីថា ព្រះពុទ្ធទាំងនោះ បរិសុទ្ធ គឺម៉ត់ចត់ផូរផង់ ស្អាតដោយទង់របស់ឥសី គឺដោយចីវរនេះ ព្រោះហេតុនោះ ទើបព្រះពុទ្ធទាំងនេះ ជាបុគ្គលគួរថ្វាយបង្គំ គួរនមស្ការ គួរវន្ទា ។ បាលីថា **ឯតំ នមស្សិយំ** ដូច្នេះក៏មាន ។ បាលីនោះ មានអត្ថថា គប្បីនមស្ការទង់ជ័យរបស់ឥសីនោះ ។

ខាងមុខអំពីនោះទៅ កាលនឹងសម្តែងគុណសម្បត្តិរបស់ខ្លួន ទើបព្រះថេរៈពោលថា **សត្ថុកប្បំ** ដូច្នេះជាដើម ។ ក្នុងគាថានោះមានអធិប្បាយថា ខ្ញុំទ្រទ្រង់ចាំដោយហទយៈ គឺដោយចិត្ត បានដល់ ពិចារណាដោយការស្តាប់ និងការទ្រទ្រង់ចាំជាដើមនូវវិន័យដោយប្រពៃ គឺព្រះវិន័យដ៏ល្អ បានដល់ ការទូន្មានទ្វារទាំង ៣ ដោយអាការដ៏ស្អាត ដូចគ្នានឹងព្រះសាស្តា គឺដូចគ្នានឹងព្រះពុទ្ធ អធិប្បាយថា ខ្ញុំតែងនមស្ការ គឺថ្វាយបង្គំព្រះវិន័យ បានដល់ វិនយ-បិដក ធ្វើនូវការអើពើក្នុងព្រះវិន័យ គឺសម្រេចការនៅសព្វៗ កាល បានដល់ ក្នុងកាលទាំងពួង ។

បទថា **វិនយោ អាសយោ មយ្ហំ** សេចក្តីថា ព្រះវិនយបិដកជាស្ថានទី គឺជាផ្ទះរបស់ខ្ញុំ ដោយអំណាចការស្តាប់ ការទ្រទ្រង់ចាំ មនសិការ ការរៀនសូត្រ ការសាកសួរ និងការប្រកាស ។ បទថា **វិនយោ ឋានចង្កមំ** សេចក្តីថា ព្រះវិន័យជាស្ថានទីឈរ និងជាស្ថានទីចង្ក្រម ដោយការធ្វើកិច្ច មានការស្តាប់ជាដើមរបស់ខ្ញុំ ។ បទថា **កប្បេមិ វិនយេ វាសំ** សេចក្តីថា ខ្ញុំតែងដេកនៅ គឺធ្វើការនៅ គឺការដេកក្នុងព្រះវិនយបិដក គឺក្នុងបែបផែននៃព្រះវិន័យ ដោយអំណាចការស្តាប់ ការចាំ និងការប្រកាស ។ បទថា **វិនយោ មម គោចរោ** សេចក្តីថា ព្រះវិនយបិដកជាគោចរ គឺជាអាហារ បានដល់ ជាភោជនរបស់ខ្ញុំ ដោយអំណាចការចាំ និងមនសិការជានិច្ច ។

បទថា **វិនយេ បារមិប្បត្តោ** បានដល់ ដល់នូវភាពកំពូល គឺទីបំផុតក្នុងវិនយបិដកទាំងមូល ។ បទថា **សមថេ ចាបិ កោវិទោ** សេចក្តីថា ជា

អ្នកឈ្លាសវៃ គឺជាអ្នកឈ្លាសក្នុងសមថៈ គឺធ្វើឲ្យរម្ងាប់ និងការចេញចាក អាបត្តិ ៧ កង មានបារាជិកជាដើម ។ម្យ៉ាងទៀត បានដល់ ជាអ្នកឈ្លាសក្រៃលែង គឺជាអ្នកឈ្លាសក្នុងអធិករណសមថៈ គឺក្នុងអធិករណ៍ ដែលលោកពោលថា

គេតែងដឹងថា អធិករណ៍ មាន ៤ គឺវិវាទាធិករណ៍ ១ អនុវាទាធិករណ៍ ១ អាបត្តាធិករណ៍ ១ កិច្ចាធិករណ៍ ១ ។

ក្នុងអធិករណៈ ៧ លោកពោលយ៉ាងនេះថា

សម្មុខាវិន័យ ១ សតិវិន័យ ១ អមូឡ្ហវិន័យ ១ បដិញ្ញាតករណៈ ១ យេភុយ្យសិកា ១ តស្សបាបិយសិកា ១ តិណវត្ថារកៈ ១ ។

បទថា **ឧបាលិ តំ មហាវីរ** សេចក្ដីថា បពិត្រព្រះអង្គដ៏ចម្រើន ទ្រង់មានព្យាយាមធំក្រៃលែង គឺមានសេចក្ដីព្យាយាមដើម្បីសម្រេចព្រះសព្វញ្ញុតញ្ញាណក្នុង ៤ អសង្ខេយ្យ និង ១ សែនកប្ប ព្រះឧបាលិភិក្ខុ តែងថ្វាយបង្គំ គឺសូមធ្វើនមស្ការនូវព្រះបាទា គឺត្រង់ព្រះយុគលបាទរបស់ព្រះសាស្ដា គឺជាអ្នកប្រៀនប្រដៅទេវតា និងមនុស្សទាំងឡាយ ។

ក្លាប់សេចក្ដីថា ខ្ញុំព្រះអង្គនោះបួសហើយ នមស្ការ គឺធ្វើការឱនលំទោនព្រះសម្មាសម្ពុទ្ធ និងដឹងថា ព្រះធម៌ គឺលោកុត្តរធម៌ ៩ ដែលព្រះមានព្រះភាគទ្រង់សម្ដែងហើយ ជាធម៌ល្អ គឺជាធម៌ស្អាត ទើបនមស្ការព្រះធម៌ ត្រាច់ទៅអំពីស្រុកកាន់ស្រុក អំពីបុរីមួយទៅកាន់បុរីមួយ គឺអំពីនគរទៅកាន់នគរ ។

បទថា **កិលេសា ឈាបិតា មយ្ហំ** សេចក្តីថា កិលេសទាំងអស់ ១៥០០ ដែលនៅក្នុងចិត្តសន្តានរបស់ខ្ញុំ ដែលខ្ញុំដុត គឺធ្វើឲ្យវិនាសស្ងួត វិនាសទៅហើយ ដោយអរហត្តមគ្គញ្ញាណ ដែលចាក់ធ្លុះហើយ ។ បទថា **ភវា សព្វេ សមូហតា** សេចក្តីថា ភពទាំងអស់ ៩ មានកាមភពជាដើម ខ្ញុំដកចោលហើយ គឺដកអស់ហើយ បានដល់ ធ្វើឲ្យអស់ហើយ កម្ចាត់ហើយ ។ បទថា **សព្វាសវា បរិក្ខីណា** សេចក្តីថា អាសវៈទាំង ៤ គឺកាមាសវៈ ភវាសវៈ ទិដ្ឋាសវៈ និងអវិជ្ជាសវៈ អស់ទៅដោយជុំវិញហើយ គឺដល់នូវការអស់ទៅដោយជុំវិញ អធិប្បាយថា ឥឡូវនេះ គឺក្នុងកាលដែលសម្រេចអរហត្តហើយនេះ ភពថ្មី គឺភពដែលហៅថា ការកើតជាថ្មី បានដល់ ការឧប្បត្តិក ការកើត មិនមាន ។ កាលបន្លឺឧទានដោយសោមនស្សយ៉ាងក្រៃលែង ទើបព្រះឧបាលិត្ថេរពោលពាក្យថា **ស្វាគតំ** ដូច្នេះជាដើម ។ ក្នុងគាថានោះ ភ្ជាប់សេចក្តីថា ការដែលខ្ញុំព្រះអង្គមកក្នុងសម្នាក់ គឺក្នុងទីជិត ឬនគរជាមួយគ្នានឹងព្រះសម្ពុទ្ធដ៏ប្រសើរ គឺព្រះសម្ពុទ្ធដ៏ឧត្តម ជាការមកល្អហើយ គឺជាដំណើរមកដោយល្អ ជាការមកយ៉ាងស្អាតដោយពិត គឺដោយចំណែកមួយ ។ បទថា **តិស្សោ វិជ្ជា** សេចក្តីថា ខ្ញុំព្រះអង្គបានសម្រេច គឺដល់ព្រមបានដល់ ធ្វើឲ្យប្រចក្សហើយនូវវិជ្ជា គឺបុព្វេនិវាសញ្ញាណ ទិព្វចក្ខុញ្ញាណ និងអាសវក្ខយញ្ញាណ ។ បទថា **កតំ ពុទ្ធស្ស សាសនំ** សេចក្តីថា សាសនា គឺការប្រៀនប្រដៅ ដែលព្រះពុទ្ធ គឺព្រះមានព្រះភាគទ្រង់សម្តែងហើយ ខ្ញុំធ្វើស្រេចហើយ គឺធ្វើឲ្យសម្រេចហើយ បានដល់ ញុំាងវត្តបដិបត្តិឲ្យបរិបូណ៌

មនសិការកម្មដ្ឋានហើយ ឲ្យសម្រេចដោយការសម្រេចអរហត្តមគ្គញ្ញាណ ។

បទថា **បដិសម្ភិទា ចតស្សោ** សេចក្តីថា បញ្ញា ៤ ប្រការ មាន អត្ថប្បដិសម្ភិទាជាដើម ខ្ញុំធ្វើឲ្យជាក់ច្បាស់ហើយ គឺធ្វើឲ្យប្រចក្សហើយ ។ បទថា **វិមោក្ខាបិ ច អដ្ឋិមេ** ក្តាប់សេចក្តីថា វិមោក្ខ គឺឧបាយជាគ្រឿងរួច ផុតចាកសង្សារទាំង ៨ ប្រការនេះ គឺមគ្គញ្ញាណ ៤ ផលញ្ញាណ ៤ ខ្ញុំធ្វើ ឲ្យជាក់ច្បាស់ហើយ ។

បទថា **ឆឡភិញ្ញា សច្ឆិកតា** សេចក្តីថា អភិញ្ញា ៦ ទាំងនេះ គឺ

ឥទ្ធិវិធ ១ ទិព្វសោត ១ ចេតោបរិយញ្ញាណ ១ បុព្វេនិវា-

សញ្ញាណ ១ ទិព្វចក្ខុ ១ អាសវក្ខយញ្ញាណ ១ ។

ខ្ញុំបានធ្វើឲ្យជាក់ច្បាស់ហើយ គឺធ្វើឲ្យប្រចក្សហើយ ពាក្យប្រៀនប្រដៅ របស់ព្រះពុទ្ធ ឈ្មោះថា ធ្វើស្រេចហើយ ព្រោះធ្វើញាណទាំងនេះ ឲ្យជាក់ ច្បាស់ ។

បទថា **ឥត្ថំ** បានដល់ ដោយប្រការដូចពោលមកហើយ ។ សព្ទថា **សុទំ** ជានិបាត ប្រើក្នុងអត្ថថា ធ្វើបទឲ្យពេញ ។ បទថា **អាយស្មា ឧបាលិ ថេរោ** សេចក្តីថា សាវ័កប្រកបដោយគុណ មានសីលដ៏មាំទាំជាដើម បាន សម្តែង គឺពោលគាថាទាំងនេះ ដែលសម្តែងអបទាន ដែលលោកប្រកាស មកក្នុងកាលមុន ។ល។

**អដ្ឋកថា ឧបាលិត្ថេរាបទាន ចប់**

# សុត្តន្តបិដក

## អញ្ញាកោណ្ឌញ្ញត្ថេរាបទានទី ៩

[ ៩ ] ខ្ញុំបានឃើញជាដំបូង នូវព្រះសម្ពុទ្ធ ព្រះនាមបទុមុត្តរៈ ព្រះអង្គជាច្បងក្នុងលោក ជាអ្នកដឹកនាំសត្វលោក ទ្រង់ដល់នូវពុទ្ធភូមិ ។ ពួកយក្ខទាំងអស់ មកជួបជុំគ្នា ចោមរោមធ្វើអញ្ជលី ថ្វាយបង្គំព្រះសម្ពុទ្ធ ទៀបគល់នៃពោធិព្រឹក្ស ។ ពួកទេវតាទាំងអស់នោះ មានចិត្តត្រេកអរ សញ្ចរទៅឰដ៏អាកាស ( ពោលថា ) ព្រះពុទ្ធអង្គនេះ ទ្រង់បានដល់ដោយលំដាប់ ទ្រង់កម្ចាត់បង់ងងឹត ដែលជាធម៌ធ្វើឲ្យខ្វាក់ ។ ពួកទេវតាទាំងអស់នោះ មានសេចក្តីរីករាយប្រព្រឹត្តទៅខាងមុខ សំឡេងកងរំពងដ៏ខ្លាំង ប្រព្រឹត្តទៅថា យើងទាំងឡាយ នឹងដុតបំផ្លាញនូវពួកកិលេស ក្នុងសាសនារបស់ព្រះសម្មាសម្ពុទ្ធ ។ លុះខ្ញុំដឹងពាក្យរបស់ទេវតាទាំងឡាយ ដែលពោលដោយវាចា ហើយក៏ត្រេកអរ បានថ្វាយចង្ហាន់ជាដំបូង ដោយចិត្តដែលត្រេកអរ ។ ព្រះសាស្តា ព្រះអង្គប្រសើរក្នុងលោក ទ្រង់ជ្រាបបំណងរបស់ខ្ញុំ ទ្រង់គង់ក្នុងកណ្តាលនៃពួកទេវបរិស័ទ ហើយត្រាស់គាថាទាំងនេះថា

តថាគតចេញទៅទ្រង់ព្រះផ្នួស អស់ ៧ ថ្ងៃ ក៏បានដល់នូវពោធិញ្ញាណ ភត្តជាដំបូងរបស់តថាគតនេះ ញុំាងព្រហ្មចារីបុគ្គលឲ្យប្រព្រឹត្តទៅបាន ។ បុគ្គលណា ចុះចាកស្ថានតុសិត មកកើតក្នុងមនុស្សលោកនេះ ហើយថ្វាយចង្ហាន់ដល់តថាគត តថាគតនឹង

សម្តែងសរសើរបុគ្គលនោះ អ្នកទាំងឡាយ ចូរស្តាប់តថាគតសម្តែងចុះ ។ បុគ្គលនេះ នឹងបានសោយរាជ្យ ជាស្តេចនៃទេវតាអស់ ៣០ ពាន់កប្ប នឹងគ្របសង្កត់ទេវតាទាំងអស់ ហើយនៅគ្រប់គ្រងទេវលោក ។ លុះច្យុតចាកទេវលោក មកកាន់អត្តភាពជាមនុស្ស នឹងបានជាស្តេចចក្រពត្តិ សោយរាជ្យក្នុងមនុស្សលោកនោះ អស់មួយពាន់ដង ។ កន្លងទៅមួយសែនកប្ប ព្រះសាស្តាព្រះនាមគោតម កើតក្នុងឱក្កាកត្រកូល នឹងបានត្រាស់ដឹងក្នុងលោក ។ កុលបុត្រនោះ ច្យុតចាកទេវលោក មកកាន់អត្តភាពជាមនុស្ស នឹងចេញចាកផ្ទះទៅបួស នៅអស់ ៦ វស្សា ។ លំដាប់អំពីនោះមក ព្រះពុទ្ធនឹងទ្រង់សម្តែងនូវអរិយសច្ច ក្នុងវស្សាជាគម្រប់ ៧ កុល-បុត្រមានឈ្មោះថា កោណ្ឌញ្ញៈ នឹងបានធ្វើឲ្យជាក់ច្បាស់នូវធម៌ជាដំបូង ។

ខ្ញុំបួសតាមព្រះពោធិសត្វ ដែលចេញទៅទ្រង់ព្រះផ្នួស ហើយបានធ្វើសេចក្តីព្យាយាមដោយប្រពៃ ខ្ញុំចូលទៅកាន់ផ្នួស ដើម្បីប្រយោជន៍ដុតបំផ្លាញនូវកិលេសទាំងឡាយ ។ ព្រះសព្វញ្ញុពុទ្ធលុះបានត្រាស់ដឹងក្នុងលោក ព្រមទាំងទេវលោកហើយ ទ្រង់យកសច្ចៈនេះទូន្មានស្អារ គឺអមតនិព្វាន ក្នុងព្រៃធំដល់ខ្ញុំ ។ ឥឡូវនេះ ខ្ញុំនោះ បានដល់នូវអមតនិព្វាន ជាសន្តិបទដ៏ប្រសើរ ជាអ្នកមិនមានអាសវៈ ព្រោះកំណត់ដឹងនូវអាសវៈទាំងពួង ។ បដិសម្ភិទា ៤

វិមោក្ខ ៨ និងអភិញ្ញា ៦ នេះ ខ្ញុំបានធ្វើឲ្យជាក់ច្បាស់ហើយ ទាំងសាសនារបស់ព្រះពុទ្ធ ខ្ញុំក៏បានប្រតិបត្តិហើយ ។

បានឮថា ព្រះអញ្ញាកោណ្ឌញ្ញត្ថេរមានអាយុ បានសម្តែងនូវគាថាទាំងនេះ ដោយប្រការដូច្នេះ ។

## អញ្ញាកោណ្ឌញ្ញត្ថេរាបទាន ចប់

# អដ្ឋកថា

## អញ្ញាកោណ្ឌញ្ញត្ថេរាបទាន

[ ៩ ] អបទានរបស់ព្រះអញ្ញាកោណ្ឌញ្ញត្ថេរ មានពាក្យផ្ដើមថា **បទុមុត្តរសម្ពុទ្ធំ** ដូច្នេះ ។

បានឮថា ព្រះថេរៈនេះ ជាអ្នកមានអធិការបានធ្វើហើយក្នុងព្រះពុទ្ធអង្គមុនៗ សន្សំបុណ្យទាំងឡាយដែលជាឧបនិស្ស័យនៃព្រះនិព្វាន ក្នុងភពនោះៗ ក្នុងកាលនៃព្រះមានព្រះភាគព្រះនាមបទុមុត្តរៈ កើតក្នុងត្រកូលនៃគហបតីមហាសាល ក្នុងហង្សវតីនគរ ដល់នូវភាពជាអ្នកដឹងក្ដីហើយ ថ្ងៃមួយ ស្ដាប់ធម៌ក្នុងសម្នាក់របស់ព្រះសាស្ដា ឃើញព្រះសាស្ដា ទ្រង់ស្ថាបនាភិក្ខុមួយរូបក្នុងតំណែងឯតទគ្គៈជាងភិក្ខុទាំងឡាយដែលជារត្តញ្ញូ គឺត្រាស់ដឹងធម៌មុនគេ ក្នុងព្រះសាសនារបស់ព្រះអង្គ ខ្លួនឯងក៏ប្រាថ្នាតំណែងនោះ ទើបថ្វាយមហាទានជាប់តគ្នា ៧ ថ្ងៃ ដល់ព្រះមានព្រះភាគ ដែលមានភិក្ខុមួយសែនជាបរិវារ ហើយបានធ្វើនូវសេចក្ដីប្រាថ្នា ។ ឯព្រះសាស្ដាទ្រង់ឃើញថា សេចក្ដីប្រាថ្នារបស់កុលបុត្រនោះមិនមានអន្តរាយ ទើបទ្រង់ព្យាករសម្បត្តិដែលកុលបុត្រនោះនឹងបាន ។ កុលបុត្រនោះ ធ្វើបុណ្យទាំងឡាយដរាបដល់អស់ជីវិត កាលព្រះសាស្ដាបរិនិព្វានហើយ កាលមហាជនកំពុងសាងព្រះចេតិយ កុលបុត្រនោះឲ្យគេសាងផ្ទះកែវក្នុងចេតិយ និងឲ្យសាងគ្រឿងប្រដាប់តាក់តែងធ្វើដោយកែវ មានតម្លៃរាប់ពាន់ ដាក់ជុំវិញព្រះចេតិយ ។

កុលបុត្រនោះ ធ្វើបុណ្យទាំងឡាយយ៉ាងនេះ ចុតិចាកជាតិនោះ អន្ទោលទៅក្នុងទេវតា និងមនុស្សទាំងឡាយ ក្នុងកាលនៃព្រះមានព្រះភាគព្រះនាម

វិបស្សី កើតជាកុដុម្ពិកៈ ឈ្មោះមហាកាល បានហែកដង្ហើមស្រូវសាលីក្នុងស្រែ មានប្រមាណ ៨ ករីស ហើយនាំដង្ហើមស្រូវសាលី ដែលបានមកនោះ ផ្សំជាបាយាសលាយដោយទឹកដោះដ៏បរិសុទ្ធ ដាក់ទឹកឃ្មុំ សប្បិ និងស្ករក្រាមក្នុងបាយាសនោះ ហើយថ្វាយដល់ព្រះសង្ឃ មានព្រះពុទ្ធជាប្រធាន ទីដែលកុលបុត្រនោះហែកដង្ហើមស្រូវសាលីហើយ ក៏ត្រឡប់ពេញបរិបូណ៌ដូចដើម ។ ក្នុងកាលស្រូវសាលីល្អមធ្វើអំបុកបាន ថ្វាយទានដ៏ប្រសើរដោយអំបុក ក្នុងកាលស្រូវទុំ បានថ្វាយទានដ៏ប្រសើរ ក្នុងកាលស្រូវទុំ ក្នុងកាលច្រូត បានថ្វាយទានដ៏ប្រសើរ ក្នុងកាលច្រូត ក្នុងកាលចងកណ្តាប់ បានថ្វាយទានដ៏ប្រសើរ ក្នុងកាលចងកណ្តាប់ ក្នុងកាលជញ្ជូន ក៏បានថ្វាយទានដ៏ប្រសើរ ក្នុងកាលជញ្ជូន ក្នុងកាលស្រូវដល់លាន ក៏បានថ្វាយទានដ៏ប្រសើរ ក្នុងកាលជញ្ជូនស្រូវដល់លាន ក្នុងកាលបោកបែន ក៏បានថ្វាយទានដ៏ប្រសើរ ក្នុងកាលបោកបែន ក្នុងកាលជញ្ជូនស្រូវដាក់ជង្រុក ក៏បានថ្វាយទានដ៏ប្រសើរ ក្នុងកាលជញ្ជូនស្រូវដាក់ជង្រុក រួមការថ្វាយដ៏ប្រសើរ ៩ ដង សម្រាប់សម្ទូងមួយរដូវ ដោយប្រការដូច្នេះ សម្ទូងក៏ត្រឡប់បរិបូណ៌ក្រៃលែងឡើង ។

កុលបុត្រនោះ ធ្វើបុណ្យទាំងឡាយ ដរាបដល់អស់ជីវិតយ៉ាងនេះហើយ ចុតិចាកជាតិនោះ កើតក្នុងទេវលោក អន្ទោលទៅក្នុងទេវតា និងមនុស្សទាំងឡាយ បានមកកើតក្នុងត្រកូលព្រាហ្មណមហាសាល ក្នុងស្រុកព្រាហ្មណ៍ឈ្មោះទោណវត្ថុ ដែលនៅមិនឆ្ងាយអំពីនគរកបិលវត្ថុ មុនព្រះមានព្រះភាគនៃយើងទាំងឡាយកើតឡើង ។ កុលបុត្តនោះ មានឈ្មោះតាមគោត្រថា

កោណ្ឌញ្ញៈ ។ កុលបុត្តចម្រើនវ័យហើយ រៀនចប់ត្រៃវេទ និងបានសិក្សាចប់ក្នុងមន្តទាយលក្ខណៈច្រើនយ៉ាង ។ សម័យនោះ ព្រះពោធិសត្វនៃយើងទាំងឡាយ ចុតិអំពីតុសិតបុរី កើតក្នុងព្រះរាជវាំងរបស់ព្រះបាទសុទ្ធោទនមហារាជ ក្នុងនគរកបិលពស្តុ ។ ក្នុងថ្ងៃថ្វាយព្រះនាមរបស់ព្រះរាជកុមារនោះ កាលព្រាហ្មណ៍ ១០៨ នាក់ បានទទួលការអញ្ជើញមកហើយ កោណ្ឌញ្ញព្រាហ្មណ៍ក្មេងជាងព្រាហ្មណ៍ទាំងអស់ ក្នុងចំនួនព្រាហ្មណ៍ ៨ នាក់ ដែលទទួលអញ្ជើញឲ្យចូលទៅកាន់ប្រាសាទ ដើម្បីពិចារណាលក្ខណៈ កោណ្ឌញ្ញៈឃើញការដល់ព្រមនៃព្រះលក្ខណៈរបស់ព្រះមហាបុរស ក៏សម្រេចចិត្តថា មហាបុរសនេះ នឹងបានជាព្រះពុទ្ធដោយពិត ទើបត្រាច់រង់ចាំការចេញមហាភិនិស្ក្រមណ៍ ។

ឯព្រះមហាសត្វចម្រើនដោយបរិវារធំ ទ្រង់ចម្រើនវ័យដោយលំដាប់ដល់នូវសេចក្តីចាស់ក្លានៃព្រះញាណហើយ ទើបចេញមហាភិនិស្ក្រមណ៍ក្នុងវស្សាទី ២៩ ទ្រង់បួសត្រង់ឆ្នេរស្ទឹងអនោមានទី យាងទៅតំបន់ឧរុវេលាដោយលំដាប់ ហើយផ្តើមបំពេញព្យាយាម ។ ក្នុងកាលនោះ កោណ្ឌញ្ញមាណពដឹងថា ព្រះមហាសត្វទ្រង់ព្រះផ្នួសហើយ មួយអន្លើដោយកូនរបស់ព្រាហ្មណ៍ដែលទាយលក្ខណៈ មានវប្បមាណពជាដើម មានខ្លួនជាគម្រប់ ៥ នាំគ្នាបួស ហើយចូលទៅកាន់សម្នាក់របស់ព្រះពោធិសត្វដោយលំដាប់ បម្រើព្រះពោធិសត្វអស់ ៦ វស្សា កើតសេចក្តីរង្កៀស ព្រោះព្រះពោធិសត្វនោះសោយព្រះក្រយាហារដែលគ្រោតគ្រាត ទើបចៀសចេញ ទៅកាន់ព្រៃឥសិ-

បតនមិគទាយវ័ន ។ លំដាប់នោះ ព្រះពោធិសត្វមានព្រះកម្លាំងកាយ ព្រោះទ្រង់បរិភោគអាហារគ្រោតគ្រាត ក្នុងថ្ងៃ ១៥ កើត ខែពិសាខ ទ្រង់គង់លើអបរាជិតបល្ល័ង្ក ត្រង់មណ្ឌលពោធិព្រឹក្ស ទ្រង់ជាន់នូវអំបែងក្បាលមារទាំង ៣ បានត្រាស់ជាអភិសម្ពុទ្ធហើយ ទ្រង់ញ៉ាំងកាល ៧ សប្តាហ៍កន្លងទៅត្រង់ពោធិមណ្ឌលដ្ឋាននោះឯង ទ្រង់ជ្រាបការចាស់ក្លានៃញាណរបស់បញ្ចវគ្គិយហើយ ទើបយាងទៅកាន់ឥសិបតនៈក្នុងថ្ងៃ ១៥ កើត ខែអាសាឍ ហើយត្រាស់ធម្មចក្កប្បវត្តនសូត្រដល់បញ្ចវគ្គិយទាំងនោះ ក្នុងកាលចប់ព្រះធម៌ទេសនា ព្រះកោណ្ឌញ្ញត្ថេរ និងព្រហ្ម ១៨ កោដិ តាំងនៅក្នុងសោតាបត្តិផល ។ ក្នុងតិថីទី ៥ នៃបក្ខ លោកបានធ្វើឲ្យជាក់ច្បាស់នូវអរហត្ត ដោយអនត្តលក្ខណសូត្រទេសនា ។

ព្រះកោណ្ឌញ្ញត្ថេរនោះ កាលសម្រេចអរហត្តហើយ ពិចារណាថា អាត្មាអញធ្វើកម្មអ្វី ទើបសម្រេចលោកុត្តរសុខ បានដឹងបុព្វកម្មរបស់ខ្លួនដោយប្រចក្ស កាលនឹងសម្តែងអបទាន ដែលលោកប្រព្រឹត្តមកក្នុងកាលមុនដោយអំណាចឧទាន ដោយសោមនស្ស ទើបពោលពាក្យថា **បុព្វុត្តរ-សម្ពុទ្ធំ** ដូច្នេះជាដើម ។ អត្ថនៃពាក្យថា **បុព្វុត្តរ** ខ្ញុំបានពោលខាងដើមហើយនោះឯង ។ បទថា **លោកជេដ្ឋំ វិនាយកំ** សេចក្តីថា ទ្រង់ជាប្រធាន គឺជាប្រធាននៃសត្វលោកទាំងមូល ។ ឈ្មោះថា **វិនាយក** ព្រោះទ្រង់នាំទៅដោយវិសេស គឺទ្រង់ញ៉ាំងពួកវេនេយ្យសត្វឲ្យដល់នូវត្រើយនៃសង្សារសាគរ គឺអមតមហានិព្វាន ដែលព្រះសម្មាសម្ពុទ្ធនោះ ទ្រង់នាំទៅដោយពិសេសនោះ ។

បទថា **ពុទ្ធភូមិមនុប្បត្តំ** សេចក្តីថា ដែលឈ្មោះថា **ពុទ្ធភូមិ** ព្រោះជាភូមិ គឺជាទីប្រតិស្ឋាននៃព្រះពុទ្ធ បានដល់ ព្រះសព្វញ្ញុតញ្ញាណ ។ ដែលឈ្មោះថា **អនុប្បត្ត** ព្រោះសម្រេចដល់ គឺចាក់ធ្លុះនូវព្រះសព្វញ្ញុតញ្ញាណនោះ ។ នូវព្រះសម្ពុទ្ធដែលទ្រង់សម្រេចពុទ្ធភូមិហើយនោះ ។ អធិប្បាយថា សម្រេចព្រះសព្វញ្ញុតញ្ញាណ គឺត្រាស់ជាព្រះពុទ្ធ ។ បទថា **បឋមំ អទ្ទសំ អហំ** សេចក្តីថា ខ្ញុំបានឃើញព្រះបទុមុត្តរសម្ពុទ្ធជាព្រះពុទ្ធ ក្នុងវេលាទៀបភ្លឺ គឺក្នុងថ្ងៃ ១៥ កើត ខែពិសាខ ជាគ្រាដំបូង ។

ក្នុងគាថាថា **យាវតា ពោធិយា មូលេ** ជាដើម ភ្ជាប់សេចក្តីថា យក្ខទាំងឡាយមានប្រមាណប៉ុនណា មកប្រជុំគ្នា គឺរួមគ្នាក្នុងទីជិតដើមពោធិ៍ ធ្វើអញ្ជលី ដាក់ក្រពុំអញ្ជលីដែលជាទីប្រជុំម្រាមទាំង ១០ លើសិរសា ថ្វាយបង្គំ គឺនមស្ការព្រះសម្មាសម្ពុទ្ធ គឺព្រះពុទ្ធអង្គនោះ ដែលបានត្រាស់ជាព្រះពុទ្ធ ។

ក្នុងគាថាថា **សព្វេ ទេវា តុដ្ឋមនា** ជាដើម ភ្ជាប់សេចក្តីថា ទេវតាទាំងអស់នោះ មកកាន់ទីនៃព្រះសម្មាសម្ពុទ្ធដែលជាព្រះពុទ្ធ មានចិត្តត្រេកអរត្រាច់ទៅក្នុងអាកាស ។ បទថា **អន្ធការតមោនុទោ** សេចក្តីថា ព្រះពុទ្ធអង្គនេះ ទ្រង់បន្ទោបង់ គឺធ្វើងងឹត គឺមោហៈឲ្យអស់ទៅ ទ្រង់សម្រេចហើយដោយលំដាប់ ។

គាថាថា **តេសំ ហាសបរេតានំ** ជាដើម ភ្ជាប់សេចក្តីថា សំឡេងកងរំពង គឺសំឡេងគឹកកងនៃទេវតាទាំងនោះ ដែលប្រកបដោយសេចក្តីត្រេកអរ គឺបីតិសោមនស្សប្រព្រឹត្តទៅ គឺផ្សាយទៅថា ពួកយើងនឹងដុតបំផ្លាញនូវពួក

កិលេស គឺសង្កិលេសធម៌ក្នុងសាសនារបស់ព្រះសម្មាសម្ពុទ្ធ ។

ក្នុងគាថាថា **ឃោសំ គិរមញ្ញាយ** ជាដើម ក្បាប់សេចក្ដីថា ខ្ញុំដឹងសំឡេងរបស់ពួកទេវតាដែលបន្លឺជាមួយពាក្យសរសើរដោយវាចា ទើបត្រេកអរបានថ្វាយកិក្ខាគ្រាដំបូង គឺអាហារដំបូងដល់ព្រះសម្ពុទ្ធ ដោយចិត្តត្រេកអរ គឺដោយចិត្តដែលប្រកបដោយសោមនស្ស ។

បទថា **សត្តាហំ អភិនិក្ខម្ម** សេចក្ដីថា តថាគតចេញ ( បួស ) ដើម្បីគុណដ៏ធំក្រៃលែង ហើយធ្វើសេចក្ដីព្យាយាម ៧ ថ្ងៃ ទើបសម្រេចព្រះពោធិញ្ញាណ ពោល គឺអរហត្តមគ្គញ្ញាណ ដែលជាបទដ្ឋាននៃព្រះសព្វញ្ញុតញ្ញាណ ។ បទថា **ឥទំ មេ បឋមំ ភត្តំ** សេចក្ដីថា ភត្តនេះជាគ្រឿងញុំាងសរីរៈឲ្យប្រព្រឹត្តទៅ ជាភត្តដែលទេវបុត្តនេះឲ្យគ្រាដំបូងដល់តថាគត ដែលជាព្រហ្មចារី គឺអ្នកប្រព្រឹត្តធម៌ដ៏ឧត្ដម ។

ក្នុងគាថាថា **តុសិតាហិ ឥធាគន្ត្វា** ជាដើម សេចក្ដីថា ទេវតាបុត្តណាចុតិអំពីកពតុសិត មកក្នុងមនុស្សលោកនេះ បង្អោនចូលមក គឺបានថ្វាយភិក្ខាដល់តថាគតៗ នឹងព្យាករ គឺនឹងពោល បានដល់ នឹងធ្វើទេវបុត្តនោះឲ្យប្រាកដ ក្បាប់សេចក្ដីថា អ្នកទាំងឡាយ ចូរស្ដាប់ពាក្យតថាគតពោល ។ តាំងអំពីនេះទៅ ខ្ញុំនឹងពណ៌នាចំពោះបទដែលមិនទាន់ជាក់ច្បាស់ ។

បទថា **តិធសា** បានដល់ ចាកកពតាវត្តិង្ស ។ បទថា **អគារា** ក្បាប់សេចក្ដីថា នឹងចេញចាកផ្ទះព្រាហ្មណ៍ ដែលកើតឡើងដល់ខ្លួន ហើយបួសជាមួយព្រះពោធិសត្វ ដែលបំពេញទុក្ករកិរិយា ៦ ឆ្នាំ ។

បទថា **តតោ សត្តមកេ វស្សេ** បានដល់ ក្នុងឆ្នាំទី ៧ ចាប់តាំងពីការដែលបួសហើយនោះ ។ បទថា **ពុទ្ធោ សច្ចំ អពុជ្ឈិតំ** សេចក្ដីថា ទ្រង់ធ្វើនូវទុក្ករកិរិយា ៦ ឆ្នាំហើយ ក្នុងឆ្នាំទី ៧ នឹងបានត្រាស់ជាព្រះពុទ្ធ ហើយត្រាស់សច្ចៈទាំង ៤ ពោល គឺទុក្ខសច្ច សមុទយសច្ច និរោធសច្ច និងមគ្គសច្ច ដោយធម្មចក្កប្បវត្តនសូត្រទេសនា នាព្រៃឥសិបតនមិគទាយវ័នជិតនគរពារាណសី ។ បទថា **កោណ្ឌញ្ញោ នាម នាមេន** សេចក្ដីថា ឈ្មោះថា កោណ្ឌញ្ញៈដោយនាម គឺដោយអំណាចឈ្មោះរបស់គោត្រ ។ បទថា **បឋមំ សច្ឆិកាហិតិ** សេចក្ដីថា នឹងធ្វើឲ្យជាក់ច្បាស់ គឺធ្វើឲ្យប្រចក្សនូវសោតាបត្តិមគ្គញាណមុន គឺអំពីដើមនោះឯង ក្នុងរវាងបញ្ចវគ្គិយ ។

បទថា **និក្ខន្តេនានុបព្វជឹ** សេចក្ដីថា ចេញបួស តាមព្រះពោធិសត្វដែលយាងចេញបួស អធិប្បាយថា ខ្ញុំបួសតាមយ៉ាងនោះ ធ្វើនូវសេចក្ដីព្យាយាមល្អហើយ គឺធ្វើដោយល្អ បានដល់ ធ្វើឲ្យមាំទាំ ។ បទថា **កិលេសេ ឈាបនត្ថាយ** សេចក្ដីថា ដើម្បីធ្វើកិលេសទាំងឡាយឲ្យក្រៀមស្ងួត គឺដើម្បីកម្ចាត់កិលេស ទើបខ្ញុំបួស គឺបដិបត្តិសាសនា ជាអ្នកមិនមានផ្ទះ គឺមិនទាក់ទងដល់ផ្ទះ បានដល់ វៀរចាកកម្ម មានការធ្វើស្រែ និងការជួញដូរជាដើម ។

ក្នុងគាថាថា **អភិគន្ត្វាន សព្វញ្ញូ** ជាដើម សេចក្ដីថា ព្រះពុទ្ធទ្រង់ដឹងអតីត អនាគត និងបច្ចុប្បន្ន ឬញេយ្យធម៌ដែលគួរដឹង ពោល គឺសង្ខារវិការ លក្ខណៈ និព្វាន និងបញ្ញត្តិ យាងទៅចំពោះ គឺយាងទៅកាន់ព្រៃដែលជាលំនៅរបស់ម្រឹគ គឺវិហារដែលឲ្យអភ័យដល់ម្រឹគ បានប្រហារ គឺវាយ

បានដល់ ទ្រង់សម្តែងអមតភេរី បានដល់ ភេរី គឺអមតមហានិព្វាន ដោយសោតាបត្តិមគ្គញាណនេះ ដែលខ្ញុំធ្វើឲ្យជាក់ច្បាស់ហើយ ក្នុងសត្វលោកដែលប្រព្រឹត្តទៅជាមួយទេវតាទាំងឡាយ ។

ក្នុងគាថាថា **សោ ឥានិ** ជាដើម សេចក្តីថា ខ្ញុំនោះ ជាព្រះសោតាបន្នអង្គដំបូង ឥឡូវនេះ បានដល់ គឺសម្រេចអមតនិព្វានដែលជាសន្តិបទ គឺមានសភាវៈស្ងប់ម្ងាប់ ជាបទ គឺគប្បីដល់ បានដល់ គប្បីសម្រេចនិព្វានដ៏ប្រសើរ គឺមិនមានវត្ថុដែលក្រៃលែងជាងដោយអរហត្តមគ្គញាណ ។ បទថា **សព្វាសវេ បរិញ្ញាយ** សេចក្តីថា ខ្ញុំកំណត់ដឹងអាសវៈទាំងពួង មានកាមាសវៈជាដើម គឺលះអាសវៈទាំងពួង ដោយបហានបរិញ្ញា ជាអ្នកមិនមានអាសវៈ គឺមិនមានកិលេស សម្រេចការនៅដោយឥរិយាបថវិហារ ។ គាថាថា **បដិសម្ភិទា ចតស្សោ** ជាដើម មានអត្ថដូចពោលហើយ ខាងដើមនោះឯង ។ ក្នុងកាលតមក ព្រះសាស្តាទ្រង់គង់លើបវរពុទ្ធាសនៈ ដែលគេក្រាលក្នុងកណ្តាលភិក្ខុសង្ឃ ក្នុងជេតពនមហាវិហារ កាលទ្រង់សម្តែងថា ព្រះថេរៈជាអ្នកដឹងច្បាស់នូវធម៌មុនអ្នកដទៃ ទើបទ្រង់ស្ថាបនាព្រះថេរៈនោះ ក្នុងតំណែងឯតទគ្គៈថា ម្នាលភិក្ខុទាំងឡាយ បណ្តាពួកភិក្ខុអ្នកដឹងរាត្រី ដែលជាសាវករបស់តថាគត ស្រេចនឹងអញ្ញាកោណ្ឌញ្ញៈ ប្រសើរជាងគេ ។

ព្រះអញ្ញាកោណ្ឌញ្ញត្ថេរនោះ បំណងនឹងចៀសវាងនូវការខ្វាចក្រែងដែលព្រះអគ្គសាវកទាំង ២ ធ្វើចំពោះខ្លួន និងការនៅប្រឡូកប្រឡំក្នុងសេនាសនៈជិតស្រុក និងមានបំណងនៅដោយសេចក្តីត្រេកអរក្នុងវិវេក ឃើញ

ថា ការដែលរង់ចាំធ្វើបដិសណ្ឋារៈដល់គ្រហស្ថ និងបព្វជិតទាំងឡាយ ដែលចូលមកកាន់សម្នាក់របស់ខ្លួន ថាជាធម៌ធ្វើឲ្យយឺតយូរ ទើបទូលលាព្រះសាស្តា ចូលទៅកាន់ហិមវន្តប្បទេស មានដំរីឆទ្ទន្តជាច្រើនរង់ចាំបម្រើ បាននៅត្រង់ស្រះឆទ្ទន្ត អស់ ១២ ឆ្នាំ ព្រះថេរៈនៅក្នុងទីនោះ ដោយអាការយ៉ាងនេះ ថ្ងៃមួយ សក្កទេវរាជចូលមករក ទ្រង់ថ្វាយបង្គំហើយ ឈរត្រាស់យ៉ាងនេះថា បពិត្រលោកម្ចាស់ ខ្ញុំសូមឱកាស សូមលោកម្ចាស់សម្តែងធម៌ដល់ខ្ញុំផងចុះ ព្រះថេរៈក៏សម្តែងធម៌ដល់សក្កៈនោះ ដែលពេញទៅដោយអរិយសច្ច ៤ សម្ផស្សជាមួយត្រៃលក្ខណ៍ ប្រកបដោយសុញ្ញតា វិចិត្រដោយន័យផ្សេងៗ ឈមចុះកាន់អមតៈ ដោយពុទ្ធលីលា ។ សក្កទេវរាជទ្រង់ស្តាប់ធម៌នោះហើយ កាលនឹងប្រកាសសេចក្តីជ្រះថ្លារបស់ព្រះអង្គ ទើបទ្រង់ពោលពាក្យសរសើរថា ( ក្នុងខុទ្ទកនិកាយ ថេរគាថា ) ថា

> ខ្ញុំនេះ បានស្តាប់ធម៌មានរសច្រើន ជ្រះថ្លាក្រៃលែង វិរាគធម៌
> ដែលលោកសម្តែងហើយ មិនកាន់យក ( ធម៌ណាមួយ )
> ដោយប្រការទាំងពួង ដូច្នេះ ។

ព្រះថេរៈនៅត្រង់ឆ្នេរស្រះឆទ្ទន្ត ១២ ឆ្នាំ កាលបរិនិព្វានខិតចូលមកដល់ ទើបចូលទៅគាល់ព្រះសាស្តា សូមឲ្យទ្រង់អនុញ្ញាតបរិនិព្វាន ហើយទៅកាន់ទីដើមវិញ បរិនិព្វានហើយ ។ល។

**អដ្ឋកថា អញ្ញាកោណ្ឌញ្ញត្ថេរាបទាន ចប់**

# សុត្តន្តបិដក

## បិណ្ឌបាលភារទ្វាជត្ថេរាបទានទី ១០

[ ១០ ] កាលនោះ ព្រះជិនស្រី ព្រះនាមបទុមុត្តរៈ ជាព្រះសយម្ភូ ជាអគ្គបុគ្គល ស្តេចគង់នៅនាភ្នំចិត្តកូដ ដែលនៅពីខាងមុខនៃព្រៃហិមពាន្ត ។ ខ្ញុំកើតជាស្តេចម្រឹគ ( រាជសីហ៍ ) មានជើង ៤ មានសភាពមិនចេះខ្លាច បាននៅនាភ្នំចិត្តកូដនោះ ដែលពួកជនជាច្រើនបានឮសំឡេងនោះហើយ រមែងតក់ស្លុត ។ ខ្ញុំកាន់ផ្កាឈូកដែលរីកល្អ ចូលទៅរកព្រះសម្ពុទ្ធព្រះអង្គប្រសើរជាងនរៈ ហើយបង្អោនចូលទៅបូជា ចំពោះព្រះសម្ពុទ្ធ ដែលទ្រង់ចេញអំពីសមាធិ ។ គ្រានោះខ្ញុំនមស្ការព្រះសម្ពុទ្ធដ៏ប្រសើរ ព្រះអង្គខ្ពង់ខ្ពស់ជាងនរៈ ញុំាំងចិត្តរបស់ខ្លួនឲ្យជ្រះថ្លា ហើយបន្លឺឡើងនូវសីហនាទ ក្នុងទិសទាំង ៤ ។ ព្រះសម្ពុទ្ធព្រះនាមបទុមុត្តរៈ ព្រះអង្គជ្រាបច្បាស់នូវត្រៃលោក ព្រះអង្គគួរទទួលនូវគ្រឿងបូជា ទ្រង់គង់លើអាសនៈរបស់ព្រះអង្គហើយត្រាស់គាថាទាំងឡាយនេះ ។

ពួកទេវតាទាំងអស់ បានដឹងនូវព្រះពុទ្ធដីកា របស់ព្រះសម្ពុទ្ធ
ហើយ ក៏មកជួបជុំគ្នា ( ដោយពាក្យថា ) ព្រះសម្ពុទ្ធដ៏ប្រសើរ
ជាងពួកអ្នកប្រាជ្ញ ទ្រង់ស្តេចមកហើយ ពួកយើង នឹងស្តាប់
ធម៌នោះ ។ ព្រះលោកនាយក ជាអ្នកប្រាជ្ញដ៏ប្រសើរ ព្រះអង្គ
ឃើញកាលវែង ទ្រង់សម្តែងសំឡេងរបស់ខ្ញុំ ក្នុងទីចំពោះមុខ

នៃទេវតាទាំងឡាយនោះ ដែលមានសេចក្តីរីករាយប្រព្រឹត្តទៅខាងមុខ ដូច្នេះថា

ផ្កាឈូកនេះ ដែលស្តេចម្រឹគណា ថ្វាយហើយក្តី សីហនាទដែលស្តេចម្រឹគណា បន្លឺឡើងហើយក្តី តថាគតនឹងសម្តែងសរសើរនូវស្តេចម្រឹគនោះ អ្នកទាំងឡាយ ចូរស្តាប់តថាគតសម្តែងចុះ ។ ស្តេចម្រឹគនោះ នឹងបានជាស្តេចចក្រពត្តិ ជាធំក្នុងទ្វីបទាំង ៤ បរិបូណ៌ដោយកែវ ៧ ប្រការ ក្នុងកប្បទី ៨ អំពីកប្បនេះ ។ ឯស្តេចចក្រពត្តិ ( នោះ ) ទ្រង់ព្រះនាមបទុមៈ មានកម្លាំងច្រើន នឹងបានសោយរាជ្យ ជាធំលើផែនដីប្រមាណ ៦៤ ។ កន្លងទៅមួយសែនកប្បទៀត ព្រះសាស្តាព្រះនាមគោតម ទ្រង់កើតក្នុងឱក្កាក-ត្រកូល នឹងបានត្រាស់ដឹងក្នុងលោក ។ កាលសាសនា ដែលព្រះសាស្តាព្រះនាមគោតម ទ្រង់ប្រកាសហើយ ស្តេចចក្រពត្តិនោះ នឹងកើតជាព្រាហ្មណ៍ នឹងចេញចាកភាពព្រាហ្មណ៍ ហើយទៅបួសក្នុងខណៈនោះ ។ កុលបុត្តនោះ មានចិត្តបញ្ជូនទៅកាន់ព្យាយាម មានចិត្តស្ងប់ មិនមានឧបធិក្កិលេស កំណត់ដឹងនូវអាសវៈទាំងពួង ជាអ្នកមិនមានអាសវៈ នឹងបរិនិព្វាន ។ កុលបុត្តនោះ កំណត់ដឹងនូវ

អាសវៈទាំងពួង ជាអ្នកមិនមានអាសវៈ នឹងបរិនិព្វានក្នុងសេនាសនៈដ៏ស្ងាត់ ដែលប្រាសចាកជន ដ៏កុះករដោយម្រឹគសាហាវ ។ បដិសម្ភិទា ៤ វិមោក្ខ ៨ និងអភិញ្ញា ៦ នេះ ខ្ញុំបានធ្វើឲ្យជាក់ច្បាស់ហើយ ទាំងសាសនារបស់ព្រះពុទ្ធ ខ្ញុំក៏បានប្រតិបត្តិហើយ ។

បានឮថា ព្រះបិណ្ឌោលភារទ្វាជត្ថេរមានអាយុ បានសម្តែងនូវគាថាទាំងនេះ ដោយប្រការដូច្នេះ ។

## បិណ្ឌោលភារទ្វាជត្ថេរាបទាន ចប់

# អដ្ឋកថា

## បិណ្ឌោលភារទ្វាជត្ថេរាបទាន

[ ១០ ] *អបទានរបស់ព្រះបិណ្ឌោលភារទ្វាជត្ថេរ មានពាក្យផ្ដើមថា* **បទុមុត្តរោ នាម ជិនោ** *ដូច្នេះជាដើម ។*

*ព្រះថេរៈនេះ ក៏មានអធិការបានធ្វើហើយក្នុងព្រះអង្គមុនៗ សន្សំបុណ្យទាំងឡាយដែលជាឧបនិស្ស័យនៃព្រះនិព្វានក្នុងភពនោះៗ ក្នុងកាលនៃព្រះមានព្រះភាគព្រះនាមបទុមុត្តរៈ កើតក្នុងកំណើតរាជសីហ៍ នៅក្នុងគុហាត្រង់ជើងភ្នំមួយកន្លែង ។ ដើម្បីធ្វើសេចក្ដីអនុគ្រោះដល់រាជសីហ៍នោះ ទើបព្រះមានព្រះភាគយាងចូលទៅកាន់គុហា ដែលជាលំនៅរបស់រាជសីហ៍នោះ ក្នុងកាលដែលចេញទៅរកចំណី ទ្រង់គង់ចូលនិរោធសមាបត្តិ រាជសីហ៍ចាប់ចំណីហើយ ត្រឡប់មកឈរត្រង់ទ្វារគុហា ឃើញព្រះមានព្រះភាគហើយ សប្បាយផង ត្រេកអរផង ទើបបូជាដោយផ្កា ដែលកើតក្នុងទឹក និងលើគោក ធ្វើចិត្តឲ្យជ្រះថ្លា ។ ដើម្បីរក្សាព្រះមានព្រះភាគ ក៏បន្លឺសីហនាទ ៣ ពេល ដើម្បីឲ្យម្រឹគកាចដទៃៗ គេចទៅ ឈរគាល់ដោយសតិរឭកដល់ព្រះពុទ្ធ បូជាអស់ ៧ ថ្ងៃ ដូចក្នុងថ្ងៃដំបូង ។ ព្រះមានព្រះភាគទ្រង់ព្រះតម្រិះថា កាលកន្លង ៧ ថ្ងៃហើយ គួរចេញអំពីនិរោធសមាបត្តិ ចំណែកនៃបុណ្យមានប្រមាណប៉ុណ្ណេះ ក៏ល្មមជាឧបនិស្ស័យដល់រាជសីហ៍នេះហើយ ។ កាលរាជសីហ៍នោះកំពុងសម្លឹងមើលនោះឯង ទើបទ្រង់ហោះទៅកាន់អាកាស ត្រឡប់ទៅកាន់ព្រះវិហារនោះឯង ។*

រាជសីហ៍មិនអាចអត់សង្កត់នូវសេចក្តីទុក្ខ ព្រោះព្រាត់ប្រាសចាកព្រះពុទ្ធ ទើបធ្វើកាលកិរិយា ហើយកើតក្នុងត្រកូលមានភោគៈច្រើន ក្នុងហង្សវតីនគរ លុះចម្រើនវ័យហើយ បានទៅកាន់ព្រះវិហារជាមួយអ្នកនគរ ស្តាប់ព្រះធម្មទេសនារបស់ព្រះសាស្តាហើយ ជ្រះថ្លា ញុំាងមហាទានឲ្យប្រព្រឹត្តទៅដល់ភិក្ខុសង្ឃមានព្រះពុទ្ធជាប្រធានជាប់តគ្នាអស់ ៧ ថ្ងៃ ធ្វើបុណ្យទាំងឡាយដរាបដល់អស់ជីវិត អន្ទោលទៅមកក្នុងទេវតា និងមនុស្សទាំងឡាយ ក្នុងកាលនៃព្រះមានព្រះភាគរបស់យើងទាំងឡាយ កើតជាបុត្តរបស់បុរោហិតនៃព្រះបាទឧទេនក្នុងនគរកោសម្ពី កុលបុត្តនោះ មានឈ្មោះថា ភារទ្វាជៈ ។ ភារទ្វាជៈនោះចម្រើនវ័យហើយ រៀនចប់ត្រៃវេទ បង្រៀនមន្តដល់មាណព ៥០០ ព្រោះភាពដែលខ្លួនជាអ្នកមានការប្រព្រឹត្តមិនសមគួរ ព្រោះភាពជាអ្នកបរិភោគច្រើន ត្រូវពួកមាណពទាំងនោះ បោះបង់ចោលគេចទៅ ទើបទៅកាន់នគររាជគ្រឹះ បានឃើញលាភសក្ការៈរបស់ព្រះសម្មាសម្ពុទ្ធ និងភិក្ខុសង្ឃ ទើបបួសក្នុងសាសនា ជាអ្នកមិនដឹងប្រមាណក្នុងការបរិភោគ ។ ព្រះសាស្តា ទ្រង់ឲ្យតាំងនៅក្នុងភាពជាអ្នកស្គាល់ប្រមាណដោយឧបាយ ទើបផ្តើមចម្រើនវិបស្សនា មិនយូរប៉ុន្មាន ក៏បានអភិញ្ញា ៦ កាលជាអ្នកបានអភិញ្ញា ៦ ហើយ ទើបបន្លឺសីហនាទចំពោះព្រះភក្ត្ររបស់ព្រះមានព្រះភាគថា វត្ថុណា ដែលសាវ័កទាំងឡាយគប្បីសម្រេច វត្ថុនោះ ខ្ញុំសម្រេចហើយ និងក្នុងភិក្ខុសង្ឃថា បុគ្គលណា មានសេចក្តីសង្ស័យក្នុងមគ្គ និងផល បុគ្គលនោះ ចូរសួរខ្ញុំចុះ ព្រោះហេតុនោះ ទើបព្រះមានព្រះភាគ ទ្រង់ស្ថាបនាព្រះថេរៈក្នុងតំណែងឯតទគ្គៈថា

ម្នាលភិក្ខុទាំងឡាយ បណ្ដាពួកភិក្ខុអ្នកបន្លឺសីហនាទ ស្រេចនឹងបិណ្ឌោលភារទ្វាជៈ ប្រសើរជាងគេ ។

ព្រះថេរៈនោះ កាលបានតំណែងឯតទគ្គៈយ៉ាងនេះហើយ រឭកដល់បុញ្ញសម្ភារ ដែលបានធ្វើក្នុងកាលមុន កាលនឹងសម្ដែងអបទានដែលជាបុញ្ញកម្មរបស់ខ្លួន ដោយសោមនស្ស ទើបពោលពាក្យថា **បទុមុត្តរោ** ដូច្នេះជាដើម ។ អត្ថនៃគាថានោះ បានពោលហើយខាងដើមនោះឯង ។ បទថា **បុរតោ ហិមវន្តស្ស** សេចក្ដីថា ក្នុងចំណែកនៃទិសខាងកើតនៃភ្នំហិមាល័យ ។ បទថា **ចិត្តកូដេ វសី តទា** ក្នុងកាលណា ខ្ញុំជារាជសីហ៍ គឺជាស្ដេចម្រឹគ នៅក្នុងទីជិតភ្នំហិមពាន្ត ក្នុងកាលនោះ ព្រះសាស្ដាទ្រង់ព្រះនាមបទុមុត្តរៈ ទ្រង់គង់នៅត្រង់ភ្នំឈ្មោះចិត្តកូដ គឺកំពូលភ្នំឈ្មោះចិត្តកូដ ព្រោះជាភ្នំមានពណ៌ច្រើន មានឱសថ និងរតនៈទាំងឡាយមិនមែនតិច ។

បទថា **អភីតរូបោ តត្ថាសឹ** សេចក្ដីថា ខ្ញុំបានជាស្ដេចម្រឹគ ដែលជាអ្នកមិនខ្លាចជាសភាវៈ គឺជាអ្នកមិនមានការខ្លាចជាសភាវៈ នៅក្នុងទីនោះ ។ បទថា **ចតុក្កមោ** សេចក្ដីថា ជាអ្នកឈានទៅ គឺអាចទៅបានក្នុងទិសទាំង ៤ ។ បទថា **យស្ស សទ្ទំ សុណិត្វាន** សេចក្ដីថា សត្វជាច្រើន គឺសត្វចំនួនច្រើន បានស្ដាប់សីហនាទរបស់ស្ដេចម្រឹគណា រមែងតក់ស្លុត គឺរមែងញាប់ញ័រដោយពិសេស បានដល់ រមែងខ្លាច ។

បទថា **សុផុល្លំ បទុមំ គយ្ហ** សេចក្ដីថា មានសេចក្ដីជ្រះថ្លាក្នុងព្រះមានព្រះភាគ បានពាំនូវផ្កាបទុមដែលរីកល្អហើយបង្អោនចូលទៅបូជា គឺចូលទៅ

ក្បែរព្រះសម្មាសម្ពុទ្ធ ព្រះអង្គប្រសើរជាងនរៈ គឺជាអ្នកអង់អាចឧត្តម គឺប្រសើរបំផុតជាងជនទាំងឡាយ ។ បទថា **វុដ្ឋិតស្ស សមាធិម្ហា** សេចក្តីថា ខ្ញុំបូជាផ្កានោះដល់ព្រះពុទ្ធ ដែលចេញអំពីនិរោធសមាបត្តិ ។ បទថា **ចតុទ្ទិសំ នមស្សិត្វា** សេចក្តីថា ខ្ញុំនមស្ការទិសទាំង ៤ ហើយញុំាងចិត្តរបស់ខ្លួនឲ្យជ្រះថ្លា គឺឲ្យតាំងនៅដោយការអើពើ ហើយបន្លឺឡើងនូវសីហនាទ គឺការបន្លឺដោយមិនខ្លាចក្រែង បានដល់ ធ្វើសីហនាទឲ្យគឹកកងហើយ ។

លំដាប់នោះ កាលនឹងប្រកាសការព្យាករណ៍ ដែលព្រះពុទ្ធប្រទានឲ្យ ទើបព្រះថេរៈពោលថា **បទុមុត្តរោ** ដូច្នេះជាដើម ។ ពាក្យនោះ មានអត្ថងាយយល់ហើយ ។

បទថា **វទតំ សេដ្ឋោ** ក្លាប់សេចក្តីថា ព្រះពុទ្ធដ៏ប្រសើរ គឺឧត្តមជាងពួកអញ្ញតិរ្ថិយដែលពោលថា យើងទាំងឡាយជាព្រះពុទ្ធ យើងទាំងឡាយជាព្រះពុទ្ធ ដូច្នេះ យាងមកហើយ ។ អធិប្បាយថា យើងទាំងឡាយ នឹងស្តាប់ធម៌នោះ របស់ព្រះមានព្រះភាគដែលយាងមកហើយនោះ ។

បទថា **តេសំ ហាសបរេតានំ** សេចក្តីថា របស់ទេវតា និងមនុស្សទាំងនោះ ដែលមាន គឺគ្របសង្កត់ បានដល់ ដែលប្រកបដោយការត្រេកអរ គឺដោយសោមនស្ស ។ បទថា **លោកនាយកោ** សេចក្តីថា ព្រះមហាមុនី គឺព្រះមុនីជាធំក្រៃលែង ក្នុងរវាងមុនីទាំងឡាយ ព្រះអង្គឃើញកាលវែង គឺទ្រង់ឃើញអនាគតកាល ជាលោកនាយក គឺទ្រង់ញុំាងសត្វលោកឲ្យដល់ស្ថានសួគ៌ និងនិព្វាន ទ្រង់ប្រកាស បានដល់ ត្រាស់ដល់សំឡេងរបស់ខ្ញុំ គឺ

សំឡេងបន្លឺដូចរាជសីហ៍របស់ខ្ញុំ ។ គាថាដ៏សេសងាយយល់ហើយ ។

គាថាតទៅ មានសេចក្តីថា រាជសីហ៍នឹងបានជាស្តេចចក្រពត្តិ ព្រះនាម បទុម ដោយព្រះនាម និងគ្រប់គ្រងភាពជាធំ គឺឥស្សរភាព បានដល់ រាជ-សម្បត្តិ ៦៤ ដង ។

បទថា **កប្បសតសហស្សម្ហិ** នេះ ជាសត្តមីវិភត្តិ ប្រើក្នុងអត្ថនៃឆដ្ឋី-វិភត្តិ អធិប្បាយថា ក្នុងទីបំផុតនៃមួយសែនកប្ប ។

បទថា **បកាសិតេ ចាវចនេ** សេចក្តីថា កាលព្រះត្រៃបិដក ដែលព្រះមានព្រះភាគព្រះនាមគោតមនោះទ្រង់ប្រកាសហើយ គឺទ្រង់សម្តែងហើយ ។ បទថា **ព្រហ្មពន្ធុ ភវិស្សតិ** សេចក្តីថា ក្នុងកាលនោះ គឺក្នុងកាលនៃព្រះមានព្រះភាគព្រះនាមគោតម រាជសីហ៍ គឺស្តេចម្រឹគនេះ នឹងកើតក្នុងត្រកូលព្រាហ្មណ៍ ។ បទថា **ព្រហ្មញ្ញា អភិនិក្ខម្ម** ភ្ជាប់សេចក្តីថា នឹងចេញចាកត្រកូលព្រាហ្មណ៍ បួសក្នុងសាសនារបស់ព្រះមានព្រះភាគអង្គនោះ ។

បទថា **បធានបហិតត្តោ** បានដល់ មានចិត្តបញ្ជូនទៅដើម្បីធ្វើសេចក្តីព្យាយាម ឈ្មោះថា ជាអ្នកមិនមានឧបធិក្កិលេស ព្រោះមិនមានកិលេសទាំងឡាយ ដែលហៅថា ឧបធិ ។ ឈ្មោះថា ជាអ្នកមានចិត្តស្ងប់ ព្រោះមិនមានកិលេសធ្វើឲ្យក្រវល់ក្រវាយ កំណត់ដឹង គឺលះនូវអាសវៈទាំងពួង បានដល់

*អាសវៈទាំងមូល ជាអ្នកមិនមានអាសវៈ គឺមិនមានកិលេស នឹងបរិនិព្វាន គឺនឹងជាបុគ្គលបរិនិព្វាន ដោយខន្ធបរិនិព្វាន ។*

*បទថា* **វិជនេ បន្តសេយ្យម្ហិ** *សេចក្តីថា ក្នុងសេនាសនៈព្រៃ ដែលឆ្ងាយ មិនអឺងកងដោយពួកមនុស្ស ។ បទថា* **វាឡមិគសមាកុលេ** *សេចក្តីថា ដ៏កុះករ គឺ ដេរដាសដោយពួកសត្វសាហាវ មានសីហៈខ្លាជាដើម ។ ពាក្យដ៏សេស មានអត្ថដូចពោលហើយនោះឯង ។*

**អដ្ឋកថា បិណ្ឌោលភារទ្វាជត្ថេរាបទាន ចប់**

# សុត្តន្តបិដក

## ខទិរវនិយវគ្គេភាណវារទី ១១

[ ១១ ] មានស៊ីងមួយ ឈ្មោះភាគីរសី ហូរចេញអំពីព្រៃហិមពាន្ត ( កាលនោះ ) ខ្ញុំកើតជានាយទូកក្នុងកំពង់មិនល្អ ជាកំពង់សម្រាប់ឆ្លងមកកាន់ត្រើយអាយ ។ ព្រះសម្ពុទ្ធជានាយក ព្រះនាមបទុមុត្តរៈ ព្រះអង្គ ប្រសើរជាងសត្វជើងពីរ បម្រុងនឹងឆ្លងខ្សែទឹកក្នុងស៊ីង ជាមួយនឹងភិក្ខុសង្ឃ មួយសែនអង្គ ។ ខ្ញុំបានប្រមូលទូកជាច្រើនមក ហើយ ធ្វើជំបូលទូក ដែលពួកជាងឈើតាក់តែងល្អហើយ ទៅទទួលព្រះនរាសភៈ ។ ព្រះសម្ពុទ្ធ ទ្រង់ស្ដេចមកឡើងគង់លើទូក ព្រះសាស្ដាទ្រង់ស្ថិតត្រង់កណ្ដាលទឹកស៊ីង ហើយត្រាស់គាថាទាំងនេះថា

បុគ្គលណា បានចម្លងព្រះសម្ពុទ្ធ ព្រមទាំងភិក្ខុសង្ឃ ជាអ្នកមិនមានអាសវៈ បុគ្គលនោះ នឹងត្រេកអរក្នុងទេវលោក ដោយចិត្តជ្រះថ្លានោះឯង ។ វិមានមានសណ្ឋានដូចទូក ដែលបុញ្ញកម្មធ្វើល្អហើយ នឹងកើតដល់អ្នក វិមាននោះ នឹងទ្រទ្រង់នូវជំបូល ជាវិការនៃផ្កាឈូកដ៏អាកាសសព្វៗ កាល ។ ក្នុងកប្បទី ៥៨ បុគ្គលនោះ នឹងបានជាស្ដេចចក្រពត្តិព្រះនាមតារណៈ ( ជាឥស្សរៈលើផែនដី ) មានសមុទ្រទាំង ៤ ជាទីបំផុត ទ្រង់ឈ្នះសង្គ្រាម ។ ក្នុងកប្បទី ៥៧ នឹងបានជាស្ដេច ព្រះនាមចម្ពកៈ មានកម្លាំងច្រើន រុងរឿងដូចព្រះអាទិត្យកំពុងរះ ។ ក្នុងកប្បទីមួយសែន ព្រះសាស្ដាព្រះនាមគោតម

កើតក្នុងត្រកូលឱក្កាកត្រកូល នឹងត្រាស់ដឹងក្នុងលោក ។ ស្តេចចម្អក: ( នោះ ) ច្យុតចាកទេវលោក មកកាន់អត្តភាពជាមនុស្ស នឹងកើតជាព្រាហ្មណ៍ ឈ្មោះរេវត: ។ រេវតកុមារនោះ ត្រូវកុសលមូលដាស់តឿន នឹងចេញចាកផ្ទះ ទៅបួសក្នុងសាសនា នៃព្រះមានព្រះភាគព្រះនាមគោតម ។ រេវតភិក្ខុនោះ លុះបួសរួចហើយ ក្នុងកាលជាខាងក្រោយ ប្រកបសេចក្តីព្យាយាម ខំចម្រើនវិបស្សនា កំណត់ដឹងអាសវ:ទាំងពួង ជាអ្នកមិនមានអាសវ: នឹងបរិនិព្វាន ។ សេចក្តីព្យាយាមរបស់ខ្ញុំ គួរដើម្បីនាំមកនូវធុរ: ជាទីនាំមកនូវធម៌ដ៏ក្សេមចាកយោគ: ខ្ញុំទ្រទ្រង់រាងកាយ មានក្នុងទីបំផុត គឺបច្ឆិមជាតិក្នុងសាសនានៃព្រះសម្ពុទ្ធ ។ បដិសម្ភិទា ៤ វិមោក្ខ ៨ និងអភិញ្ញា ៦ នេះ ខ្ញុំបានធ្វើឲ្យជាក់ច្បាស់ហើយ ទាំងសាសនារបស់ព្រះពុទ្ធ ខ្ញុំក៏បានប្រតិបត្តិហើយ ។

បានឮថា ព្រះខទិរវនិយរេវតត្ថេរមានអាយុ បានសម្តែងនូវគាថាទាំងនេះ ដោយប្រការដូច្នេះ ។

**ខទិរវនិយរេវតត្ថេរាបទាន ចប់**

# អដ្ឋកថា

## ខទិរវនិយត្ថេរាបទាន

[ ១១ ] *អបទានរបស់ព្រះខទិរវនិយត្ថេរ មានពាក្យផ្ដើមថា* **គង្គា ភាគី រថី នាម** *ដូច្នេះ ។*

*ព្រះថេរៈនេះ ក៏មានអធិការបានធ្វើហើយ ក្នុងព្រះពុទ្ធអង្គមុនៗ សន្សំបុណ្យទាំងឡាយ ដែលជាឧបនិស្ស័យនៃព្រះនិព្វានក្នុងភពនោះៗ ក្នុងកាលនៃព្រះមានព្រះភាគព្រះនាមបទុមុត្តរៈ កើតក្នុងត្រកូលរបស់នាយទូកក្នុងនគរហង្សវតី ធ្វើនូវការងារត្រង់កំពង់ឈ្មោះបយាគតិត្ថៈ ក្បែរស្ទឹងធំ ។ ថ្ងៃមួយបានឃើញព្រះមានព្រះភាគ មួយអន្លើដោយពួកសាវក យាងចូលទៅកាន់ឆ្នេរស្ទឹង មានចិត្តជ្រះថ្លា ទើបចងទូកភ្ជាប់គ្នា ជូនចម្លងត្រើយ ដោយបូជាសក្ការដ៏ធំ បានឃើញភិក្ខុមួយរូបដែលព្រះសាស្ដា ទ្រង់ស្ថាបនាក្នុងតំណែងឯតទគ្គៈនៃភិក្ខុទាំងឡាយអ្នកនៅព្រៃ ប្រាថ្នាតំណែងនោះ បានញុំាងមហាទានឲ្យប្រព្រឹត្តទៅដល់ព្រះមានព្រះភាគ និងភិក្ខុសង្ឃ ហើយធ្វើនូវសេចក្ដីប្រាថ្នា ។ ព្រះមានព្រះភាគទ្រង់ព្យាករថា សេចក្ដីប្រាថ្នារបស់កុលបុត្តនេះ មិនឥតអំពើឡើយ ។*

*ចាប់តាំងអំពីនោះមក កុលបុត្តនោះសន្សំបុណ្យច្រើនយ៉ាង អន្ទោលទៅក្នុងទេវតា និងមនុស្សទាំងឡាយ សោយសម្បត្តិក្នុងលោកទាំង ២ ក្នុងពុទ្ធុប្បាទកាលនេះ កើតក្នុងគភ៌របស់នាងព្រាហ្មណីឈ្មោះរូបសារី ក្នុងស្រុកនាលកៈ ដែនមគធៈ ។ កុលបុត្តនោះចម្រើនវ័យហើយ មាតាបិតាបំណាងនឹងរៀបចំឲ្យមានគូស្រករ ទើបប្រាប់ឲ្យដឹង ។ កុលបុត្តនោះ បានស្ដាប់ថា ព្រះ*

សារីបុត្តត្ថេរបួសហើយ ទើបគិតថា ឧបតិស្សៈ ជារៀមច្បងរបស់ខ្ញុំ គង់លះនូវទ្រព្យសម្បត្តិនេះចេញបួស អញនឹងសោយដុំទឹកមាត់ ដែលបងរៀមច្បងនោះខ្ជាក់ចោលហើយបានដូចម្ដេច កើតនូវសេចក្ដីសង្វេគ ដូចម្រឹគដើរចូលទៅជិតអន្ទាក់ ទើបបញ្ឆោតពួកញាតិ ។ កុលបុត្តនោះ ដែលហេតុសម្បត្តិជាស់តឿន ទើបទៅកាន់សម្នាក់របស់ភិក្ខុទាំងឡាយ រួចប្រាប់ឲ្យជ្រាបថា ខ្ញុំជាប្អូនប្រុសរបស់ព្រះធម្មសេនាបតី ហើយប្រាប់ថា ខ្ញុំពេញចិត្តនឹងបួស ។ ភិក្ខុទាំងឡាយក៏ឲ្យបព្វជ្ជា លុះមានអាយុ ២០ គ្រប់បរិបូណ៌ ក៏ឲ្យឧបសម្បទា ហើយនឹងបបួលឲ្យខ្វល់ខ្វាយក្នុងកម្មដ្ឋាន លោករៀនកម្មដ្ឋានហើយ ចូលទៅកាន់ព្រៃគគីរសម្រាក ព្យាយាមមិនយូរប៉ុន្មាន ក៏បានអរហត្តមានអភិញ្ញា ៦ ព្រោះជាអ្នកចាស់ក្លានៃញាណ កាលបានជាព្រះអរហន្តហើយទើបទុកដាក់សេនាសនៈ ហើយកាន់យកបាត្រ និងចីវរ ធ្វើដំណើរទៅថ្វាយបង្គំព្រះសាស្ដា និងថ្វាយបង្គំព្រះធម្មសេនាបតី ដល់ក្រុងសាវត្ថីដោយលំដាប់ ទើបចូលទៅកាន់វត្តជេតពន ថ្វាយបង្គំព្រះសាស្ដា និងថ្វាយបង្គំព្រះធម្មសេនាបតីហើយ សម្រាកនៅក្នុងវត្តជេតពន ២-៣ ថ្ងៃ ។ គ្រានោះ ព្រះសាស្ដា ទ្រង់គង់ក្នុងកណ្ដាលព្រះអរិយៈ ទ្រង់ស្ថាបនាព្រះថេរៈក្នុងតំណែងឯតទគ្គៈជាងភិក្ខុទាំងឡាយ ដែលនៅព្រៃជាវត្ត ដោយព្រះតម្រាស់ថា ម្នាលភិក្ខុទាំងឡាយ បណ្ដាពួកភិក្ខុអ្នកនៅក្នុងព្រៃ ស្រេចនឹងរេវតខទិរវនិយៈប្រសើរជាងគេ ។

ព្រះថេរៈកាលបានតំណែងឯតទគ្គៈយ៉ាងនេះហើយ រឭកដល់បុព្វកម្ម

របស់ខ្លួន កាលប្រកាសអបទានដែលខ្លួនប្រព្រឹត្តមកក្នុងកាលមុន អំណាចបីតិសោមនស្ស ទើបពោលពាក្យថា **គង្គា ភាគី រថី** ដូច្នេះជាដើម ។

បណ្តាបទទាំងនោះ បទថា **គង្គា** សេចក្តីថា ឈ្មោះថា **គង្គា** ព្រោះច្រៀង គឺធ្វើនូវសំឡេងគឹកកងហើរទៅ ។ ម្យ៉ាងទៀត ផែនដី លោកហៅថា គោ ឈ្មោះថា **គង្គា** ព្រោះហូរជុំវិញផែនដីនោះ ។ ស្ទឹងគង្គា ក្នុងទីដែលធ្វើការហូរជុំវិញអនោតត្តស្រះ ៣ ជុំ ហើយហូរទៅ ឈ្មោះថា **អាវដ្តគង្គា** ក្នុងទីដែលហូរទៅលើកំពូលភ្នំ ឈ្មោះថា **ពហលគង្គា** ក្នុងទីដែលប្រោះទម្លុះភ្នំហូរទៅ ឈ្មោះថា **ឧម្មង្គគង្គា** ក្នុងទីដែលប៉ះនឹងភ្នំនោះ ហើយបាញ់ទៅលើអាកាស ៥ យោជន៍ ឈ្មោះថា **អាកាសគង្គា** ស្ទឹងពេលដែលទឹកធ្លាក់ចុះហើយដក់ជាស្រះធម្មជាតិ ទំហំ ៥ យោជន៍ ហើយទម្លាយច្រាំងស្រះក្នុងទីនោះឯង ញែកជាស្ទឹង ៥ ខ្សែ ដូចម្រាមដៃ ៥ មានឈ្មោះ ៥ គឺគង្គា យមុនា សរភូ មហី និងអចិរវតី ហើយចែកជម្ពូទ្វីបទាំងមូលឲ្យជា ៥ ភាគ ៥ ចំណែក ហើយហូរទៅ គឺចែកជា ៥ ភាគ ៥ ចំណែក ហេតុនោះ ទើបឈ្មោះថា **ស្ទឹងភាគីរថី** ។ ស្ទឹងនោះ ញែកចេញអំពីគ្នាផង ព្រោះហេតុនោះទើបឈ្មោះថា **គង្គាភាគីរថី** ។ គប្បីឃើញថា កាលពោលថា **គង្គា ភាគី រថី** ដើម្បីងាយស្រួលក្នុងការចងគាថា ទើបពោលដូចធ្លាប់ប្រព្រឹត្តមកថា **ភាគី រថី គង្គា** ។ បទថា **ហិមវន្តា បភាវិតា** សេចក្តីថា ឈ្មោះថា **ហិម** ព្រោះបៀតបៀនពួកសត្វ គឺបៀតបៀនរុកកួន ធ្វើឲ្យរីករវរដោយរងា ។ ឈ្មោះថា **ហិមវា** ព្រោះភ្នំនោះ មានសន្សើម ។ ឈ្មោះថា **ហិមវន្តបភាវិតា** ព្រោះ

កើត គឺប្រព្រឹត្តទៅ បានដល់ ហូរទៅ ចាប់តាំងពីភ្នំហិមពាន្តនោះ ។ បទថា **កុតិត្តេ នាវិកោ អាសឹ** សេចក្តីថា ខ្ញុំកើតក្នុងត្រកូលអ្នកប្រមង់ បានជានាយទូក ត្រង់កំពង់មិនរាបស្មើ មានក្រសែហូរខ្ចួលខ្លាញ់របស់ស្ទឹងគង្គានោះ ។ បទថា **ឱរមេ ច តរឹ អហំ** សេចក្តីថា ខ្ញុំឲ្យពួកមនុស្សដែលមកដល់ហើយឆ្លងចាកត្រើយខាងអាយ ទៅកាន់ត្រើយខាងនាយ ។

បទថា **បទុមុត្តរោ នាយកោ** សេចក្តីថា ព្រះបទុមុត្តរសម្ពុទ្ធដ៏ឧត្តមជាងពួកសត្វជើង ២ ទ្រង់នាំ គឺទ្រង់ញុំាងសត្វឲ្យដល់នូវព្រះនិព្វាន ទ្រង់ធ្វើនូវបុញ្ញសម្បត្តិរបស់ខ្ញុំឲ្យសម្រេច ភ្ជាប់សេចក្តីថា ទ្រង់មកកាន់កំពង់ទឹកដើម្បីឆ្លងស្ទឹងគង្គា មួយអន្លើដោយសាវក ដែលមានវសីមួយសែនរូប គឺព្រះខីណាស្រពមួយសែនរូប ។

បទថា **ពហូ នាវា សមានេត្វា** សេចក្តីថា ខ្ញុំឃើញព្រះសម្មាសម្ពុទ្ធនោះយាងដល់ហើយ ទើបនាំទូកជាច្រើនមកតម្រៀបគ្នា គឺចងទូក ២ ឲ្យជាប់គ្នា ហើយប្រក់ដំបូលជាបារាំ ដែលពួកជាងធ្វើ គឺធ្វើសម្រេចអំពីខាងលើទូកនោះ ហើយទៅទទួលបូជាព្រះនរាសភ គឺព្រះសម្ពុទ្ធព្រះនាមបទុមុត្តរៈ ។

បទថា **អាគន្ត្វាន ច សម្ពុទ្ធោ** ភ្ជាប់សេចក្តីថា កាលយកទូកចងគ្នាយ៉ាងនោះហើយ ព្រះសម្មាសម្ពុទ្ធយាងមកក្នុងទីនោះ ហើយឡើងកាន់ទូក គឺនាវាដ៏ល្អនោះ ។ បទថា **វារិមជ្ឈេ ឋិតោ សត្ថា** ភ្ជាប់សេចក្តីថា ព្រះសាស្តាយាងឡើងទូកហើយ កំពុងគង់នៅកណ្តាលស្ទឹង ក្នុងស្ទឹងគង្គា បានពោលភាសិត គឺត្រាស់គាថាដែលប្រកបដោយសោមនស្សទាំងនេះ ។

បទថា **យោ សោ តារេសិ សម្ពុទ្ធំ** សេចក្តីថា នាយទូកនោះ បាននិមន្តព្រះសម្ពុទ្ធឲ្យឆ្លងក្រសែនៃស្ទឹងគង្គា ។ បទថា **សង្ឃញ្ចាបិ អនាសវំ** សេចក្តីថា នាយទូកនោះ មិនមែននិមន្តព្រះសម្ពុទ្ធឲ្យឆ្លងតែម្យ៉ាងប៉ុណ្ណោះទេ សូម្បីព្រះសង្ឃ ដែលមិនមានអាសវៈអស់នូវកិលេស ក៏និមន្តឲ្យឆ្លងទៅដែរ ។ បទថា **តេន ចិត្តប្បសាទេន** សេចក្តីថា មានចិត្តជ្រះថ្លា ប្រកបដោយសោមនស្ស ដែលកើតឡើងក្នុងកាលអុំទូកនោះ បុគ្គលនោះនឹងត្រេកអរ គឺនឹងសោយទិព្វសម្បត្តិក្នុងទេវលោក គឺក្នុងកាមាវចរសួគ៌ ៦ ជាន់ ។

បទថា **និព្វត្តិស្សតិ តេ ព្យម្ហំ** សេចក្តីថា វិមានដែលធ្វើរៀបរយ គឺសម្រេចហើយ មានសណ្ឋានដូចទូក គឺមានទ្រង់ទ្រាយដូចទូក នឹងកើត គឺនឹងប្រាកដដល់អ្នក ដែលកើតឡើងក្នុងទេវលោក ។ បទថា **អាកាសេ បុប្ផឆទនំ** ភ្ជាប់សេចក្តីថា ព្រោះវិបាកនៃកម្មដែលបានធ្វើបាំងលើទូក ដំបូលប្រក់ដោយផ្កា នឹងបាំងក្នុងអាកាសសព្វកាល ក្នុងទីដែលទៅហើយ ។

បទថា **អដ្ឋបញ្ញាសកប្បម្ហិ** ភ្ជាប់សេចក្តីថា កន្លងទៅ ៥៨ កប្ប តាំងអំពីកាលដែលធ្វើបុណ្យនេះ នឹងបានជាស្តេចចក្រពត្តិ មានឈ្មោះថា តារកៈ មានសមុទ្រទាំង ៤ ជាទីបំផុត គឺជាអ្នកមានជ័យជម្នះក្នុងទ្វីបទាំង ៤ ។ គាថាដ៏សេស មានអត្ថងាយយល់ហើយ ។

បទថា **រេវតោ នាម នាមេន** សេចក្តីថា នឹងជាបុត្តនៃព្រាហ្មណ៍ បានដល់ ជាបុត្តរបស់ព្រាហ្មណ៍ គឺនឹងកើតក្នុងត្រកូលព្រាហ្មណ៍ មានឈ្មោះថា រេវតៈ ព្រោះកើតក្នុងរេវតីឫក្ស ។

បទថា **និព្វាយិស្សតិ នាសវោ** សេចក្ដីថា ជាអ្នកអស់កិលេស នឹងបរិនិព្វានដោយខន្ធបរិនិព្វាន ។ បទថា **វីរិយំ មេ ធុរធោរយ្ហំ** សេចក្ដីថា ខ្ញុំដែលព្រះមានព្រះភាគ ព្រះនាមបទុមុត្តរៈទ្រង់ព្យាករយ៉ាងនេះហើយ សេចក្ដីព្យាយាមរបស់ខ្ញុំដល់ទីបំផុតនៃបារមីដោយលំដាប់ ជាការព្យាយាមមិនធូរថយ គួរដើម្បីនាំមកនូវការៈ គឺជាទីទទួលធុរៈ ជាគ្រឿងនាំមកនូវព្រះនិព្វានដែលជាដែនក្សេមចាកយោគៈទាំងឡាយ ។ បទថា **ធារេមិ អន្តិមំ ទេហំ** ភ្ជាប់សេចក្ដីថា ឥឡូវនេះ ខ្ញុំទ្រទ្រង់នូវសរីរៈចុងក្រោយ ក្នុងសាសនារបស់ព្រះសម្មាសម្ពុទ្ធ ។

ក្នុងកាលតមក ព្រះថេរៈនោះត្រឡប់ទៅកាន់មាតុភូមិរបស់ខ្លួន នាំក្មួយ ៣ នាក់ គឺនាយចាលា នាយឧបចាលា និងនាយសីសូបចាលា ដែលជាកូនរបស់ប្អូនស្រី ៣ នាក់ គឺនាងចាលា នាងឧបចាលា និងនាងសីសូបចាលា មកឲ្យបួស ហើយឲ្យនូវកម្មដ្ឋាន ។ ក្មួយទាំងនោះខ្វល់ខ្វាយ ប្រកបក្នុងកម្មដ្ឋានយ៉ាងមាំទាំ ។

សម័យនោះ អាពាធណាមួយកើតឡើងដល់ព្រះថេរៈ ព្រះសារីបុត្តបានស្ដាប់ដូច្នោះ ទើបចូលទៅរកដោយបំណងថា នឹងសាកសួរដល់ជំងឺ និងសួរដល់ការសម្រេចមគ្គផលរបស់ព្រះរេវតៈៗ ឃើញព្រះធម្មសេនាបតីនិមន្តមកអំពីចម្ងាយ កាលនឹងទូន្មាន ដើម្បីសាមណេរទាំងនោះមានស្មារតី ទើបពោលគាថាថា **ចាលេ**[១] ជាដើម ។ ពាក្យថា **ចាលេ ឧបចាលេ សីសូ-**

---

១- គាថានេះ មានក្នុងខុទ្ទកនិកាយ ថេរគាថាឯណោះ ឯបទដែលលើកមកពន្យល់ខាងក្រោយនេះ ក៏ជាបទក្នុងថេរគាថានោះឯង ។

**បចាលេ** ក្នុងគាថានោះ ជាពាក្យហៅសាមណេរទាំងនោះ ។ ក្មេងទាំង ៣ នាក់ ដែលបានឈ្មោះថា ជាភេទស្រី ថាចាលា ឧបចាលា សីសូបចាលា សូម្បី បួសហើយ ក៏នៅតែហៅឈ្មោះតាមនោះ ។ អាចារ្យពួកខ្លះពោលថា ក្មេងទាំង នោះឈ្មោះថា ចាលី ឧបចាលី សីសូបចាលី ដូច្នេះក៏មាន ។ ព្រះរេវតត្ថេរ កាលសម្តែងបំណាង ដែលលោកហៅមកដោយពាក្យថា **ចាលេ** ដូច្នេះជាដើម ទើបពោលថា អ្នកទាំងឡាយ ចូរជាអ្នកមានសតិខ្ជាប់ខ្ជួនចុះ ហើយពោល ហេតុ ក្នុងការហៅមកនោះថា ដ្បិតព្រះសារីបុត្តជាអ៊ំរបស់អ្នកទាំងឡាយ បាន មកត្រង់ហើយ ដូចអ្នកបាញ់រោមកន្ទុយទ្រាយ ដូច្នេះ ។ បទថា **បតិស្សតា** ប្រែថា ជាអ្នកមានសតិ ។ សព្ទថា **ខោ** ប្រើក្នុងអវធារណៈ គឺហាមអត្ថដទៃ ។ បទថា **អាគតោ** ប្រែថា មកហើយ ។ បទថា **វោ** ស្មើគ្នានឹង **តុម្ហាកំ** របស់ពួកអ្នក ។ បទថា **វាលំ វិយ វេធិ** ប្រែថា ដូចគ្នានឹងខ្នាន់ធ្នូ ។ ក្នុង គាថានេះ មានសេចក្តីសង្ខេបដូចតទៅនេះថា ព្រះថេរៈជាអ៊ំរបស់ពួកអ្នក មានសភាពដូចខ្នាន់ធ្នូ គឺដូចគ្នានឹងព្រះសាស្តា ព្រោះមានបញ្ញារហ័ស មាន បញ្ញាជាគ្រឿងស្ទុះទៅ និងមានបញ្ញាទម្លាយកិលេសនិមន្តមកដល់ហើយ ព្រោះ ហេតុនោះ ចូរអ្នកទាំងឡាយ តាំងសមណសញ្ញា គឺចូរជាអ្នកប្រកបដោយ សតិសម្បជញ្ញៈចុះ គឺចូរជាអ្នកមិនប្រមាទក្នុងធម៌ជាគ្រឿងនៅ តាមដែលបាន សម្រេចហើយចុះ ។

សាមណេរទាំងនោះបានស្តាប់ដូច្នោះ ទើបនាំគ្នាធ្វើវត្ត មានការទទួល ជាដើម ដល់ព្រះធម្មសេនាបតី ក្នុងវេលាដែលព្រះថេរៈជាអ៊ំទាំងពីរ ធ្វើបដិ-

សណ្ឋារៈដល់គ្នានិងគ្នា បានអង្គុយចូលសមាធិក្នុងទីមិនឆ្ងាយ ។ ព្រះធម្ម-សេនាបតី ធ្វើបដិសណ្ឋារៈជាមួយព្រះរេវតៈហើយ ក្រោកចាកអាសនៈ ចូលទៅរកពួកសាមណេរទាំងនោះ កាលព្រះថេរៈចូលទៅរក សាមណេរទាំងនោះបានក្រោកឡើង ថ្វាយបង្គំ ហើយឈរ ព្រោះបានកំណត់កាលយ៉ាងនោះ ។ ព្រះថេរៈសួរថា ពួកអ្នកនៅដោយធម៌ជាគ្រឿងនៅដូចម្ដេច កាលសាមណេរទាំងនោះប្រាប់ឲ្យជ្រាប ទើបសរសើរ សរសើរព្រះថេរៈថា ប្អូនប្រុសរបស់ខ្ញុំទូន្មានកុមារបានបែបនេះ ជាអ្នកមានប្រក្រតីពោលពាក្យពិត ជាអ្នកមានប្រក្រតីប្រព្រឹត្តធម៌ សមគួរដល់ធម៌ហើយ និមន្តទៅ ។ ពាក្យដ៏សេសក្នុងគាថានេះមានអត្ថងាយយល់ហើយ ។៚

## អដ្ឋកថា ខទិរវនិយរេវតត្ថេរាបទាន ចប់

# សុត្តន្តបិដក

## អានន្ទុត្តោភាបទានទី ១២

[ ១២ ] ព្រះមហាមុនី ព្រះនាមបទុមុត្តរៈ កាលស្តេចចេញអំពីទ្វារអារាម ហើយបង្អុរភ្លៀង គឺអមតៈ ញុំាងមហាជនឲ្យរលត់ទុក្ខ ។ ពួកអ្នកប្រាជ្ញ មួយសែននាក់ បានអភិញ្ញា ៦ ជាអ្នកមានឫទ្ធិធំ តែងហែហមព្រះសម្ពុទ្ធ ដូចស្រមោល អន្ទោលតាមប្រាណ ។ ( លំដាប់នោះ ) ខ្ញុំជិះលើ-កដំរី បានឃើញស្វេតច្ឆត្រដ៏ឧត្តមប្រសើរ មានសភាពសមរម្យដោយសរសៃសូត្រ ខ្ញុំក៏មានបីតិកើតឡើង ។ ខ្ញុំចុះអំពីកដំរី ចូលទៅគាល់ព្រះនរាសភសម្ពុទ្ធ ខ្ញុំយកឆត្ររបស់ខ្ញុំជាវិការនៃកែវ បាំងថ្វាយព្រះសម្ពុទ្ធដ៏ប្រសើរ ។ ព្រះបទុមុត្តរៈ ព្រះអង្គស្វែងរកគុណដ៏ធំ ទ្រង់ជ្រាបបំណងរបស់ខ្ញុំហើយ ទ្រង់បញ្ឈប់កថានោះ ទើបត្រាស់គាថាទាំងឡាយនេះថា

កុលបុត្តណា បានបាំងឆត្រ ដ៏ស្អិតស្អាងដោយគ្រឿងអលង្ការជាវិការនៃមាស តថាគតនឹងសម្តែងសរសើរកុលបុត្តនោះ អ្នកទាំងឡាយ ចូរស្តាប់តថាគតសម្តែងចុះ ។ បុរសនេះ នឹងទៅអំពីលោកនេះហើយ នឹងគ្រប់គ្រងស្ថានតុសិត សោយទិព្វសម្បត្តិ មានពួកស្រីអប្សរចោមរោម ។ មិនតែប៉ុណ្ណោះ បុរសនេះ នឹងបានសោយរាជ្យ ជាស្តេចនៃទេវតា អស់ ៣៤ ដង នឹងបានជាធំជាងពួកនរៈគ្រប់គ្រងផែនដី ៨ រយដង ។ នឹងបានជាស្តេចចក្រពត្តិអស់ ៥៨ ដង ( រួចពីនោះ ) នឹងបានសោយប្រទេសរាជ្យ ដ៏ធំទូលាយលើផែនដី ។

កន្លងទៅមួយសែនកប្បទៀត ព្រះសាស្ដាព្រះនាមគោតម កើតក្នុងឱក្កាកត្រកូល នឹងបានត្រាស់ដឹងក្នុងលោក ។ បុរសនេះ នឹងបានជាព្រះញាតិផៅពង្ស នៃព្រះពុទ្ធជាទង់ក្នុងត្រកូលរបស់ពួកសក្យៈ មាននាមថាអានន្ទ ជាឧបដ្ឋាករបស់ព្រះពុទ្ធ ទ្រង់ស្វែងរកនូវគុណធំ ។ នឹងជាអ្នកមានព្យាយាម មានប្រាជ្ញាចាស់ វាងវៃក្នុងសភាពជាពហុស្សូត ប្រព្រឹត្តឱនលំទោន មិនរឹងត្អឹង ទ្រទ្រង់នូវពុទ្ធវចនៈទាំងអស់ ។ អានន្ទនោះ នឹងផ្គងព្យាយាម មានចិត្តបញ្ជូនទៅកាន់សមាធិ មានចិត្តស្ងប់ មិនមានឧបធិក្កិលេស កំណត់ដឹងអាសវៈទាំងពួង ជាអ្នកមិនមានអាសវៈ នឹងបរិនិព្វាន ។

ហត្ថិនាគមាតង្គៈទាំងឡាយ មានអាយុ ៦០ ទើបថយកម្លាំងនៅក្នុងព្រៃ ចុះប្រេងដោយអាការ ៣ ប្រការ មានក្ដុក-ងដូចចន្ទោល មានភ្លៅដ៏មាំមួន ។ ហត្ថិនាគទាំងអស់នោះ មានច្រើនសែន ជាសត្វបណ្ឌិត មានឫទ្ធិច្រើន ក៏មិនហ៊ានមើលងាយព្រះពុទ្ធនាគ ។ ខ្ញុំនឹងនមស្ការព្រះពុទ្ធនាគ ក្នុងបឋមយាម មជ្ឈិមយាម និងបច្ឆិមយាម ខ្ញុំមានចិត្តជ្រះថ្លា មានចិត្តរីករាយ បម្រើព្រះពុទ្ធដ៏ប្រសើរ ។ ខ្ញុំមានព្យាយាម មានប្រាជ្ញាចាស់ មានសតិ និងសម្បជញ្ញៈ ដល់នូវសោតាបត្តិផល វាងវៃក្នុងសេក្ខភូមិទាំងឡាយ ។ ព្រោះហេតុដែលខ្ញុំបានសន្សំអំពើជាកុសល ក្នុងកប្បទីមួយសែន អំពីកន្លងកប្បនេះ ទើបខ្ញុំបានដល់នូវឧបដ្ឋាកភូមិនោះ ហើយជំនឿ ( របស់ខ្ញុំ ) ក៏តាំង

នៅសិប់សួន ជាជំនឿមានផលច្រើន ។ ឱ ! ដំណើរដែលខ្ញុំមកក្នុងសម្នាក់នៃព្រះពុទ្ធដ៏ប្រសើរ ជាដំណើរមកប្រពៃហើយ វិជ្ជា ៣ ខ្ញុំបានដល់ហើយ ដោយលំដាប់ ទាំងសាសនារបស់ព្រះពុទ្ធ ខ្ញុំបានធ្វើហើយ ។ បដិសម្ភិទា ៤ វិមោក្ខ ៨ និងអភិញ្ញា ៦ នេះ ខ្ញុំបានធ្វើឲ្យជាក់ច្បាស់ហើយ ទាំងសាសនារបស់ព្រះពុទ្ធ ខ្ញុំក៏បានប្រតិបត្តិហើយ ។

បានឮថា ព្រះអានន្ទត្ថេរ មានអាយុ បានសម្ដែងនូវគាថាទាំងនេះ ដោយប្រការដូច្នេះ ។

## អានន្ទត្ថេរាបទាន ចប់

## ឧទាន

រឿងព្រះពុទ្ធ ១ ព្រះបច្ចេកពុទ្ធ ១ ព្រះសារីបុត្ត ១ កោលិតៈ គឺព្រះមោគ្គល្លាន ១ ព្រះកស្សបៈ ១ ព្រះអនុរុទ្ធៈ ១ ព្រះបុណ្ណត្ថេរ ១ ព្រះឧបាលិ ១ ព្រះកោណ្ឌញ្ញៈ ១ ព្រះបិណ្ឌោលភារទ្វាជៈ ១ ព្រះរេវតៈ ១ ព្រះអានន្ទជាបណ្ឌិត ១ ឯគាថា ៦៥០ សុទ្ធតែជាគាថាពេញលេញទាំងអស់ ។

## អបទាន ពុទ្ធវគ្គទី ១ ចប់

# អដ្ឋកថា

## អានន្ទត្ថេរាបទាន

[ ១២ ] អបទានរបស់ព្រះអានន្ទត្ថេរ មានពាក្យថា **អារាមទ្វារា និក្ខម្ម** ដូច្នេះជាដើម ។

ព្រះថេរៈនេះ ក៏ជាអ្នកមានអធិការបានធ្វើហើយ ក្នុងព្រះពុទ្ធអង្គមុន សន្សំបុណ្យទាំងឡាយ ដែលជាឧបនិស្ស័យនៃព្រះនិព្វាន ក្នុងភពនោះៗ ក្នុងសាសនានៃព្រះមានព្រះភាគព្រះនាមបទុមុត្តរៈ កើតជាប្អូនប្រុសមាតាដទៃជាមួយនឹងព្រះសាស្តា ក្នុងនគរហង្សវតី ។ កុលបុត្តនោះបានឈ្មោះថា សុមនៈ ។ ព្រះបិតារបស់សុមនៈនោះ ជាព្រះរាជាព្រះនាមនន្ទៈ ព្រះបាទនន្ទៈនោះ កាលសុមនកុមារជាឱរសរបស់ព្រះអង្គចម្រើនវ័យហើយ បានប្រទាននគរឲ្យគ្រប់គ្រង ក្នុងទីឆ្ងាយអំពីនគរហង្សវតី ១២០ យោជន៍ ។ សុមនកុមារនោះ មកគាល់ព្រះសាស្តា និងព្រះបិតាម្តងម្កាល កាលនោះ ព្រះរាជាទ្រង់ទំនុកបម្រុងព្រះសាស្តា និងភិក្ខុសង្ឃ ប្រមាណមួយសែនអង្គ ដោយគោរព ដោយព្រះអង្គឯង មិនព្រមឲ្យអ្នកដទៃទំនុកបម្រុង ។

សម័យនោះ បច្ចន្តជនបទបះបោរ ព្រះរាជកុមារមិនក្រាបទូលព្រះរាជាឲ្យជ្រាបថា បច្ចន្តជនបទបះបោរ ទ្រង់យាងទៅបង្ក្រាបឯង ព្រះរាជាបានស្តាប់ដូច្នោះ ទ្រង់ត្រេកអរត្រាស់ថា នែបុត្ត បិតាឲ្យពរដល់បុត្ត ចូរបុត្តទទួលយក ។ ព្រះរាជកុមារក្រាបទូលថា ទូលបង្គំប្រាថ្នាទំនុកបម្រុងព្រះសាស្តា និងភិក្ខុសង្ឃ ធ្វើជីវិតមិនឲ្យឥតអំពើ ព្រះរាជាត្រាស់ថា រឿងនោះធ្វើមិនបាន ចូរសូមរបស់ដទៃចុះ ព្រះរាជកុមារក្រាបទូលថា បពិត្រសម្មតិទេព ធម្មតាក្សត្រទាំងឡាយ

មិនមានព្រះតម្រាស់បែកជា ២ សូមទ្រង់ប្រទានការទំនុកបម្រុងព្រះសាស្តានោះ ដល់ទូលបង្គំចុះ ទូលបង្គំមិនត្រូវការរបស់ដទៃ ។ ព្រះរាជាត្រាស់ថា បើព្រះសាស្តាទ្រង់អនុញ្ញាត ក៏ស្មើគ្នានឹងព្រះរាជទានពរនោះ ។ ព្រះរាជកុមារនោះ ក៏យាងទៅកាន់វិហារ ដោយចង់ដឹងថា ព្រះសាស្តាទ្រង់មានព្រះតម្រិះដូចម្តេច ។ សម័យនោះ ព្រះសាស្តាយាងចូលព្រះគន្ធកុដិហើយ ។ ព្រះរាជកុមារយាងទៅរកភិក្ខុទាំងឡាយ ហើយត្រាស់ថា បពិត្រលោកម្ចាស់ ខ្ញុំមកដើម្បីគាល់ព្រះសាស្តា សូមលោកម្ចាស់ទាំងឡាយ ឲ្យខ្ញុំគាល់ព្រះសាស្តាផងចុះ ។ ភិក្ខុទាំងឡាយទូលថា ព្រះថេរៈឈ្មោះសុមនៈជាឧបដ្ឋាករបស់ព្រះសាស្តា សូមទ្រង់យាងទៅកាន់សម្នាក់របស់ព្រះថេរៈនោះ ។ ទើបព្រះរាជកុមារ យាងទៅកាន់សម្នាក់របស់ព្រះថេរៈ ហើយត្រាស់ថា បពិត្រលោកម្ចាស់ សូមលោកម្ចាស់ឲ្យខ្ញុំគាល់ព្រះសាស្តាផងចុះ ។

លំដាប់នោះ ព្រះថេរៈកាលព្រះរាជកុមារកំពុងឃើញនោះឯង បានមុជដីចូលទៅគាល់ព្រះមានព្រះភាគ ហើយក្រាបទូលថា បពិត្រព្រះអង្គដ៏ចម្រើន ព្រះរាជបុត្តយាងមកដើម្បីសូមគាល់ព្រះអង្គ ។ ព្រះសាស្តាត្រាស់ថា ម្នាលភិក្ខុ បើដូច្នោះ ចូរអ្នកក្រាលអាសនៈខាងក្រៅ ។ ព្រះថេរៈកាន់យកពុទ្ធាសនៈ ហើយមុជក្នុងផែនដីខាងក្នុងព្រះគន្ធកុដិម្តងទៀត កាលព្រះរាជកុមារនោះកំពុងឃើញ ក៏ប្រាកដខ្លួនត្រង់បរិវេណខាងក្រៅ ក្រាលអាសនៈក្នុងបរិវេណព្រះគន្ធកុដិ ។ ព្រះរាជកុមារឃើញដូច្នោះ ទើបធ្វើការគិតឲ្យកើតឡើងថា ភិក្ខុនេះធំក្រៃលែងហ្ន៎ ។

ឯព្រះមានព្រះភាគ យាងចេញអំពីព្រះគន្ធកុដិ ទ្រង់គង់លើអាសនៈដែលគេក្រាល ។ ព្រះរាជបុត្តថ្វាយបង្គំព្រះសាស្តា ទ្រង់ធ្វើបដិសណ្ឋារៈ ហើយទូលសួរថា បពិត្រព្រះអង្គដ៏ចម្រើន ព្រះថេរៈនេះ ប្រហែលជាទីប្រោសប្រាណក្នុងសាសនារបស់ព្រះអង្គ ។ ព្រះសាស្តាត្រាស់ថា ថ្វាយព្រះពរព្រះរាជកុមារ ភិក្ខុនេះជាទីប្រោសប្រាណ ។ ព្រះរាជបុត្តទូលសួរថា ព្រះថេរៈនេះជាទីប្រោសប្រាណ ព្រោះធ្វើកម្មដូចម្តេច ព្រះសាស្តាត្រាស់ថា ព្រោះធ្វើបុណ្យ មានឲ្យទានជាដើម ព្រះរាជបុត្តនោះទូលថា បពិត្រព្រះមានព្រះភាគខ្ញុំក៏ប្រាថ្នានឹងជាទីប្រោសប្រាណ ក្នុងសាសនារបស់ព្រះពុទ្ធក្នុងអនាគត ដូចព្រះថេរៈនេះ ហើយថ្វាយភត្តាហារដល់ភិក្ខុសង្ឃ មានព្រះពុទ្ធជាប្រធាន ត្រង់ព្រះពន្លាអស់ ៧ ថ្ងៃ ក្នុងថ្ងៃទី ៧ ក្រាបទូលថា បពិត្រព្រះអង្គដ៏ចម្រើន ខ្ញុំព្រះអង្គបានទទួលពរអំពីព្រះរាជបិតាឲ្យបដិបត្តិព្រះអង្គ ៣ ខែ សូមទ្រង់ទទួលនិមន្តរបស់ខ្ញុំ ក្នុងការនៅចាំវស្សាអស់កាល ៣ ខែ ទ្រង់ជ្រាបថា ព្រះសាស្តាទទួលនិមន្តហើយ ទើបនាំព្រះមានព្រះភាគ មួយអន្លើដោយបរិវារទៅ ហើយឲ្យសាងវិហារទាំងឡាយ ដែលសមគួរសម្រាប់ជាលំនៅរបស់ព្រះសាស្តា និងភិក្ខុសង្ឃ ក្នុងទីមួយយោជន៍ ១ ហើយនិមន្តឲ្យទ្រង់គង់ក្នុងវិហារនោះៗ ហើយនិមន្តឲ្យយាងចូលទៅកាន់វិហារ ដែលសាងដោយទ្រព្យមួយសែន ក្នុងឧទ្យានឈ្មោះសោភណៈ ដែលទិញដោយទ្រព្យមួយសែនក្នុងទីជិត ទីប្រថាប់គង់របស់ព្រះអង្គ ហើយច្រួចទឹក ដោយព្រះតម្រាស់ថា

បពិត្រព្រះមហាមុនី សូមទ្រង់ទទួលឧទ្យាន ឈ្មោះថាសោភណៈ

ដែលខ្ញុំទិញដោយទ្រព្យមួយសែន ហើយឲ្យសាងដោយទ្រព្យមួយសែន ។

ក្នុងថ្ងៃចូលវស្សា រាជបុត្តបានញុំាងមហាទានឲ្យប្រព្រឹត្តទៅដល់ព្រះសាស្តា ហើយទ្រង់បបួលព្រះរាជឱរស ព្រះជាយា និងពួកអមាត្យ ក្នុងការឲ្យទាន និងការធ្វើកិច្ចផ្សេងៗ ថា អ្នកទាំងឡាយ គប្បីឲ្យទាន ដោយទំនងនេះ ។ ចំណែកព្រះអង្គឯង ប្រថាប់នៅក្នុងទីជិតលំនៅរបស់ព្រះសុមនត្ថេរ ទ្រង់បម្រើព្រះសាស្តាអស់ត្រៃមាស ក្នុងទីប្រថាប់នៅរបស់ព្រះអង្គ ដោយប្រការដូច្នេះ ។ កាលជិតថ្ងៃបវារណា ក៏យាងទៅកាន់ស្រុក ញុំាងមហាទានឲ្យប្រព្រឹត្តទៅអស់ ៧ ថ្ងៃ ក្នុងថ្ងៃទី ៧ ទ្រង់ដាក់ត្រៃចីវរទៀបបាទមូលរបស់ព្រះសាស្តា និងភិក្ខុសង្ឃ ទ្រង់នមស្ការហើយ បានធ្វើសេចក្តីប្រាថ្នាថា បពិត្រព្រះអង្គដ៏ចម្រើន បុណ្យដែលខ្ញុំព្រះអង្គធ្វើមក តាំងអំពីកាលបោះព្រះពន្លានោះ នឹងធ្វើដើម្បីជាប្រយោជន៍ដល់សក្កសម្បត្តិជាដើមក៏មិនមែន ដោយពិតខ្ញុំព្រះអង្គគប្បីជាឧបដ្ឋាក ជាទីប្រោសប្រាណរបស់ព្រះពុទ្ធអង្គណាមួយ ក្នុងអនាគត ដូចព្រះសុមនត្ថេរនេះ ។ ព្រះសាស្តាទ្រង់ឃើញថា សេចក្តីប្រាថ្នានោះ មិនមានអន្តរាយ ទើបទ្រង់ព្យាករយាងទៅ ។

ក្នុងកាលនោះ កុលបុត្តនោះធ្វើបុណ្យអស់មួយសែនឆ្នាំ បន្ទាប់អំពីពុទ្ធុប្បាទកាលនោះទៅ ក៏បានសន្សំបុញ្ញកម្មជាច្រើនក្នុងភពនោះៗ អន្ទោលទៅក្នុងទេវតា និងមនុស្ស ក្នុងកាលនៃព្រះមានព្រះភាគព្រះនាមកស្សបៈ មកកើតក្នុងផ្ទះមានត្រកូល ដល់នូវភាពជាអ្នកដឹងក្តីហើយ កាលព្រះថេរៈមួយរូប

កំពុងត្រាច់បិណ្ឌបាត បានប្រគេនសាច់ល្អ ដើម្បីជាទម្របាត្រ ហើយបានធ្វើការបូជា ។ កុលបុត្តនោះ ទៅកើតក្នុងស្ថានសួគ៌ទៀត ចុតិពីស្ថានសួគ៌ហើយមកកើតជាព្រះបាទពារាណសី បានឃើញព្រះបច្ចេកសម្ពុទ្ធ ៨ អង្គ ទើបនិមន្តព្រះបច្ចេកសម្ពុទ្ធនោះឲ្យឆាន់ ស្រេចហើយ ឲ្យសាងបណ្ណសាលា ៨ ក្នុងឧទ្យាន ដែលជាមង្គលរបស់ព្រះអង្គ រួចវេរប្រគេនតាំងដែលធ្វើដោយរតនៈគ្រប់យ៉ាង និងជើងទម្រកែវមណី ៨ សម្រាប់ ដើម្បីជាទីអង្គុយរបស់ព្រះបច្ចេកសម្ពុទ្ធទាំងនោះ ហើយឧបដ្ឋាកអស់ ១ ម៉ឺនឆ្នាំ ។ ស្ថានទីទាំងនេះគង់នៅប្រាកដ ។

កុលបុត្តនោះ សន្សំបុណ្យទាំងឡាយក្នុងភពនោះៗ អស់សែនកប្បហើយបានកើតក្នុងតុសិតបុរី មួយអន្លើដោយព្រះពោធិសត្វនៃយើងទាំងឡាយ ចុតិចាកតុសិតនោះហើយ មកកើតក្នុងព្រះរាជវាំងរបស់ព្រះបាទអមិតោ-ទនសក្យៈ មានឈ្មោះថា អានន្ទ ព្រោះកើតមកធ្វើពួកញាតិឲ្យត្រេកអរ ។ ព្រះអានន្ទនោះ ចម្រើនវ័យឡើងដោយលំដាប់ កាលព្រះមានព្រះភាគ ទ្រង់យាងចេញអភិនិស្ក្រមណ៍ ទ្រង់សម្រេចសម្មាសម្ពោធិញ្ញាណ ហើយទ្រង់ប្រកាសព្រះធម្មចក្កដ៏ប្រសើរ ហើយយាងទៅកាន់នគរកបិលពស្តុគ្រាដំបូង បន្ទាប់អំពីនោះ ( ព្រះមានព្រះភាគ ) យាងចេញអំពីនគរកបិលពស្តុនោះ ទើបព្រះអានន្ទ យាងទៅជាមួយស្តេចកត្តិយៈជាដើម ដែលចេញបួសដើម្បីជាបរិវាររបស់ព្រះមានព្រះភាគអង្គនោះ ហើយបួសក្នុងសម្នាក់របស់ព្រះមានព្រះភាគ បានស្តាប់ធម្មកថា ក្នុងសម្នាក់របស់ព្រះបុណ្ណមន្តានីបុត្ត តាំងនៅ

ក្នុងសោតាបត្តិផល ។

សម័យនោះ ក្នុងបឋមពោធិកាល អស់កាល ២០ ឆ្នាំ ព្រះមានព្រះភាគ មិនមានអ្នកឧបដ្ឋានទៀងទាត់ ជួនកាល ព្រះនាគសមាលៈ កាន់បាត្រ និងចីវរ ត្រាច់ទៅ ជួនកាល ព្រះនាគិតៈ ជួនកាលព្រះឧបវាណ ជួនកាល ព្រះសុនក្ខត្ត ជួនកាល ព្រះចុន្ទសមណុទ្ទេស ជួនកាល ព្រះសាគតៈ ជួនកាល ព្រះមេឃិយៈ លោកទាំងនោះ ដោយច្រើន មិនបានធ្វើព្រះសាស្តាឲ្យពេញព្រះហឫទ័យ ។ ថ្ងៃមួយ ព្រះមានព្រះភាគ មានភិក្ខុសង្ឃចោមរោម ទ្រង់គង់លើបវរពុទ្ធាសនៈ ដែលគេក្រាលក្នុងបរិវេណព្រះគន្ធកុដិ ត្រាស់ហៅភិក្ខុទាំងឡាយមកថា ម្នាលភិក្ខុទាំងឡាយ ឥឡូវនេះ តថាគតចាស់ហើយ ភិក្ខុពួកខ្លះកាលតថាគតប្រាប់ថា ទៅផ្លូវនេះចុះ បែរជាទៅផ្លូវដទៃ ភិក្ខុពួកខ្លះ ដាក់បាត្រនិងចីវររបស់តថាគតលើផែនដី ពួកអ្នក ចូរជ្រើសរើសភិក្ខុមួយរូប ឲ្យឧបដ្ឋាកតថាគតជាប្រចាំចុះ ភិក្ខុទាំងឡាយ បានស្តាប់ដូច្នោះ កើតនូវធម្មសង្វេគ ។ លំដាប់នោះ ព្រះសារីបុត្ត ក្រោកឡើង ថ្វាយបង្គំព្រះមានព្រះភាគ ហើយក្រាបទូលថា បពិត្រព្រះអង្គដ៏ចម្រើន ខ្ញុំព្រះអង្គនឹងឧបដ្ឋាកព្រះអង្គ ព្រះមានព្រះភាគទ្រង់ក៏ហាម ។ ដោយឧបាយនេះ ព្រះមហាសាវ័កទាំងពួង មានព្រះមហាមោគ្គល្លានជាដើម វៀរតែព្រះអានន្ទ ក្រោកឡើងក្រាបទូលថា ខ្ញុំព្រះអង្គនឹងជាឧបដ្ឋាក ខ្ញុំព្រះអង្គនឹងជាឧបដ្ឋាក ព្រះមានព្រះភាគទ្រង់ក៏ហាមព្រះមហាសាវ័កទាំងនោះ ។

ឯព្រះអានន្ទអង្គុយនៅស្ងៀម ។ លំដាប់នោះ ភិក្ខុទាំងឡាយក៏ពោលនឹង

ព្រះអានន្ទថា អាវុសោ សូម្បីលោក ក៏ចូរទូលសូមតំណែងឧបដ្ឋាកព្រះសាស្តាចុះ ព្រះអានន្ទពោលថា ឈ្មោះថា ការឧបដ្ឋាក ដែលបានមកដោយការសូម តើនឹងមានតម្លៃអ្វី ព្រះសាស្តា បើទ្រង់សព្វព្រះហឫទ័យ ក៏នឹងត្រាស់ឯង ។ លំដាប់នោះ ព្រះមានព្រះភាគត្រាស់ថា ម្នាលភិក្ខុទាំងឡាយ បុគ្គលដទៃៗ មិនអាចបម្រើអានន្ទបានទេ អានន្ទដឹងឯងហើយ នឹងឧបដ្ឋាកតថាគត ។ លំដាប់នោះ ភិក្ខុទាំងឡាយក៏ពោលថា ក្រោកឡើងអានន្ទ ចូរទូលសូមតំណែងឧបដ្ឋាកព្រះសាស្តាចុះ ។ ព្រះថេរៈក្រោកឡើងហើយ ក្រាបទូលថា បពិត្រព្រះអង្គដ៏ចម្រើន បើទ្រង់មិនប្រទានចីវរដ៏ប្រណីត ដែលទ្រង់បានមកដល់ខ្ញុំព្រះអង្គ ១ មិនប្រទានបិណ្ឌបាតដ៏ប្រណីត ១ មិនឲ្យនៅក្នុងព្រះគន្ធកុដិជាមួយទ្រង់ ១ មិននាំទៅកាន់ទីដែលនិមន្ត ១ កាលបើដូច្នេះ ខ្ញុំព្រះអង្គនឹងឧបដ្ឋាកព្រះមានព្រះភាគ ការបដិសេធ ៤ នេះ ដើម្បីនឹងដោះពាក្យតិះដៀលថា កាលបាននូវគុណប្រយោជន៍មានប្រមាណប៉ុណ្ណោះ ការឧបដ្ឋាកព្រះសាស្តានឹងធ្ងន់ប៉ុនណា បពិត្រព្រះអង្គដ៏ចម្រើន បើទ្រង់យាងទៅកាន់ទីនិមន្ត ដែលខ្ញុំព្រះអង្គបានទទួលនិមន្ត ១ ខ្ញុំព្រះអង្គបាននាំបុគ្គលដែលមកហើយអំពីបទេសដទៃ ចូលគាល់បានភ្លាមៗ ១ កាលណាខ្ញុំព្រះអង្គកើតសេចក្តីសង្ស័យ សូមឲ្យបានចូលគាល់សាកសួរព្រះមានព្រះភាគក្នុងកាលនោះ ១ បើទ្រង់ប្រាប់ធម៌ដែលទ្រង់សម្តែងក្នុងទីកំបាំង ដល់ខ្ញុំព្រះអង្គម្តងទៀត ១ កាលបើបានយ៉ាងនេះ ខ្ញុំព្រះអង្គនឹងឧបដ្ឋាកព្រះមានព្រះភាគ ។ ការសូម ៤ យ៉ាងនេះ ដើម្បីដោះនូវពាក្យនិន្ទាថា គ្រាន់តែរឿងប៉ុណ្ណោះ ព្រះថេរៈមិនបាន

នូវការអនុគ្រោះអំពីព្រះសាស្តា នឹងដើម្បីធ្វើធម្មកណ្ឌាគារិកឲ្យបរិបូណ៌ សរុបសេចក្តីថា ព្រះថេរៈបានពរ ៨ ប្រការនេះហើយ ទើបឧបដ្ឋាកប្រចាំ ព្រះថេរៈបានសម្រេចផលនៃបារមីទាំងឡាយ ដែលបានបំពេញមកអស់ ១ សែនកប្បក៏ដើម្បីតំណែងនេះ ។

តាំងអំពីថ្ងៃដែលបានតំណែងជាឧបដ្ឋាក ព្រះថេរៈបានឧបដ្ឋាកព្រះទសពលដោយកិច្ចច្រើនយ៉ាង ដូចជា ដោយទឹក ២ ចំណែក ដោយឈើស្ទន់ ៣ ជង ដោយការគក់ច្របាច់ព្រះហស្ត និងព្រះបាទ ដោយការគក់ច្របាច់ព្រះបិដ្ឋិ និងបោសបរិវេណព្រះគន្ធកុដិ រង់ចាំមើលថែក្នុងទីជិតៗ អស់ចំណែកនៃថ្ងៃ ដោយបំណងថា ក្នុងពេលនេះ ព្រះសាស្តាគួរបានវត្ថុឈ្មោះនេះ អញគួរធ្វើវត្ថុឈ្មោះនេះ ឯក្នុងពេលយប់ បានកាន់ប្រទីបធំមានជង ដើរជុំវិញបរិវេណព្រះគន្ធកុដិ ៩ ជង ដើម្បីថ្វាយពាក្យតប ក្នុងកាលព្រះសាស្តាត្រាស់ហៅ និងដើម្បីបន្ទោបង់នូវការងងុយ ។ លំដាប់នោះ ព្រះសាស្តា ទ្រង់គង់ក្នុងកណ្តាលពួកអរិយៈ ក្នុងវត្តជេតពន ត្រាស់សរសើរព្រះអានន្ទត្ថេរ ដោយអនេកបរិយាយ ហើយទ្រង់ស្ថាបនាក្នុងតំណែងឯតទគ្គៈ ជាងភិក្ខុទាំងឡាយដែលជាពហូសូត ជាអ្នកមានសតិ ជាអ្នកមានគតិ ជាអ្នកមានធិតិ និងជាអ្នកឧបដ្ឋាក ។

ព្រះថេរៈនេះ កាលព្រះសាស្តាទ្រង់តែងតាំងក្នុងតំណែងឯតទគ្គៈ ក្នុងឋានៈ ៥ ដោយប្រការដូច្នេះ ជាអ្នកប្រកបដោយធម៌ដែលគួរអស្ចារ្យ មិនធ្លាប់មាន ៤ ប្រការ ជាអ្នកប្រកបដោយធម៌ដែលគួរអស្ចារ្យ មិនធ្លាប់មាន ៤

ប្រការ ជាអ្នករក្សាឃ្លាំងធម៌របស់ព្រះសាស្តា តែលោកនៅជាព្រះសេក្ខៈនៅឡើយ កាលព្រះសាស្តាបរិនិព្វានហើយ ភិក្ខុទាំងឡាយ ជាស់តឿនឲ្យអាចហ៊ាន និងត្រូវទេវតាឲ្យសង្វេគ ដោយន័យដូចពោលហើយខាងដើម កើតឧស្សាហ៍ឡើងថា ស្អែកនេះ នឹងធ្វើសង្គាយនាព្រះធម៌ កាលដែលអញនៅជាព្រះសេក្ខៈ មានកិច្ចដែលត្រូវធ្វើ នឹងទៅចូលទីប្រជុំដើម្បីសង្គាយនាព្រះធម៌ជាមួយព្រះថេរៈ ដែលជាអសេក្ខៈ មិនសមគួរឡើយ ទើបផ្តើមវិបស្សនាធ្វើវិបស្សនាកម្មមួយយប់ទល់ភ្លឺ មិនបានបន្ថែមនូវសេចក្តីព្យាយាម ឲ្យសមគួរក្នុងការចង្រ្កម បន្ទាប់អំពីនោះ ក៏ចូលទៅកាន់វិហារ ហើយអង្គុយចុះលើទីដេក មានបំណងនឹងដេក ទើបទម្រេតកាយ ។ សីសៈមិនទាន់ដល់ខ្នើយជើងគ្រាន់តែផុតអំពីដី ក្នុងរវាងនេះ ចិត្តក៏ផុតចាកអាសវៈទាំងឡាយ ដោយមិនប្រកាន់មាំ បានជាអ្នកមានអភិញ្ញា ៦ ។ ព្រះថេរៈប្រកបដោយគុណ មានអភិញ្ញា ៦ ជាដើម សម្រេចតំណែងឯតទគ្គៈដោយគុណ មានភាពជាឧបដ្ឋាកជាដើមយ៉ាងនេះ ហើយរឭកដល់បុព្វកម្មរបស់ខ្លួន កាលប្រកាសឲ្យដឹងដល់អបទាន ដែលប្រព្រឹត្តមកក្នុងកាលមុន ដោយសោមនស្ស ទើបពោលពាក្យថា **អារាមទ្វារា និក្ខម្ម** ដូច្នេះជាដើម ។

បណ្តាបទទាំងនោះ បទថា **អារាមទ្វារា** សេចក្តីថា ព្រះមហាមុនី-សម្មាសម្ពុទ្ធព្រះនាមបទុមុត្តរៈ យាងចេញចាកទ្វារវិហារ ហើយប្រថាប់គង់លើបវរពុទ្ធាសនៈដែលក្រាលរៀបរយ ត្រង់កណ្តាលមណ្ឌប ដែលសាងក្បែរទ្វារខាងក្រៅ ដើម្បីសម្តែងធម៌ដល់សត្វទាំងពួង ។ បទថា **វស្សន្តោ អមតំ**

**វុដ្ឋី** សេចក្តីថា ភ្លៀង គឺធម៌ ដោយផ្ការនៃមហាអមតៈ គឺព្រះធម្មទេសនា ។ បទថា **និព្វាបេសិ មហាជនំ** សេចក្តីថា ទ្រង់ធ្វើនូវភ្លើង គឺកិលេសដែលនៅក្នុងចិត្តសន្តានរបស់មហាជនឲ្យរលត់ គឺឲ្យស្ងប់រម្ងាប់ អធិប្បាយថា ទ្រង់ញ៉ាំងមហាជនឲ្យដល់នូវការស្ងប់ គឺការត្រជាក់ ដោយឲ្យផឹកអមតៈ គឺព្រះនិព្វាន ។

កាលទីងសម្តែងបរិវារសម្បត្តិ ( របស់ព្រះពុទ្ធ ) ទើបព្រះថេរៈពោលថា **សតសហស្សំ តេ ធីរា** ដូច្នេះ ។ អធិប្បាយថា ព្រះខីណាស្រព ១ សែនទាំងនោះជាអ្នកប្រាជ្ញ ប្រកបដោយអភិញ្ញា ៦ គឺគំនរនៃញាណ មានឥទ្ធិវិធញ្ញាណជាដើម ឈ្មោះថា ជាអ្នកមានឫទ្ធិធំ ព្រោះជាអ្នកប្រកបដោយឫទ្ធិទាំងឡាយ ដែលអាចទៅក្នុងច្រើនសែនចក្កវាឡបានដោយមួយរំពេច នាំគ្នាចោមរោមព្រះសម្មាសម្ពុទ្ធ គឺព្រះមានព្រះភាគព្រះនាមបទុមុត្តរៈអង្គនោះ ដូចស្រមោលអន្ទោលទៅតាមប្រាណ មិនទៅកាន់ទីដទៃ អធិប្បាយថា ចោមរោមស្តាប់ធម៌ ។

បទថា **ហត្ថិក្ខន្ធគតោ អាសឹ** សេចក្តីថា ក្នុងកាលនោះ គឺក្នុងសម័យសម្តែងធម៌របស់ព្រះមានព្រះភាគ ខ្ញុំបានអង្គុយលើខ្នងដំរី ។ បទថា **សេតច្ឆត្តំ វរុត្តមំ** សេចក្តីថា ខ្ញុំអង្គុយលើខ្នងដំរី បាំងនូវស្វេតច្ឆត្រដ៏ឧត្តម ដែលមនុស្សចង់បានទុកលើសិរសារបស់ខ្ញុំ ។ បទថា **សុចារុរូបំ ទិស្វាន** សេចក្តីថា បីតិ គឺការត្រេកអរ បានដល់ សោមនស្ស កើតឡើងដល់ខ្ញុំ ព្រោះបានឃើញព្រះពុទ្ធមានរូបល្អ ជាទីជាប់ចិត្ត កំពុងសម្តែងធម៌ ។

បទថា **ឱរុយ្ហ ហត្ថិក្ខន្ធម្ហា** សេចក្តីថា ខ្ញុំឃើញព្រះមានព្រះភាគទ្រង់គង់ ទើបចុះអំពីខ្នងដំរី ហើយចូលទៅគាល់ គឺទៅកាន់ទីជិតព្រះនរាសភ-សម្ពុទ្ធ គឺបុគ្គលប្រសើរជាងនរជន ។ បទថា **រតនមយឆត្តំ មេ** ក្លាប់សេចក្តីថា ខ្ញុំបាំងឆត្ររបស់ខ្ញុំដែលប្រដាប់ដោយរតនៈ លើសិរសានៃព្រះសម្មា-សម្ពុទ្ធដ៏ប្រសើរ ។

បទថា **មម សង្កប្បមញ្ញាយ** សេចក្តីថា ព្រះមានព្រះភាគព្រះនាមបទុមុត្តរៈនោះ ទ្រង់ជាធំក្នុងរវាងឥសីទាំងឡាយ ទ្រង់ជ្រាបព្រះតម្រិះដែលកើតឡើង ដោយការជ្រះថ្លារបស់ខ្ញុំហើយ ។ បទថា **តំ កថំ ឋបយិត្វាន** សេចក្តីថា ព្រះអង្គទ្រង់បញ្ឈប់ព្រះធម្មកថា ដែលទ្រង់កំពុងសម្តែងនោះហើយ បានភាសិត គឺត្រាស់គាថាទាំងនេះ ដើម្បីព្យាករខ្ញុំ ។

បើមានពាក្យសួរថា ទ្រង់ព្យាករដូចម្តេច ទើបត្រាស់ពាក្យថា **យោ សោ** ដូច្នេះជាដើម ។ ក្នុងពាក្យនោះ ក្លាប់សេចក្តីថា ព្រះរាជកុមារនោះ ទ្រង់បាំងឆត្រដែលប្រដាប់ដោយគ្រឿងអលង្ការដែលជាមាស លើសិរសារបស់ព្រះតថាគត ។ បទថា **តមហំ កិត្តយិស្សាមិ** សេចក្តីថា តថាគតនឹងសម្តែងនូវព្រះរាជកុមារនោះ គឺធ្វើឲ្យប្រាកដ ។ បទថា **សុណោថ មម ភាសតោ** សេចក្តីថា អ្នកទាំងឡាយ ចូរស្តាប់ គឺចូរផ្ទៀងនូវសោតៈ ចូរមនសិការពាក្យ តថាគតនឹងពោល ។

បទថា **ឥតោ គន្ត្វា អយំ ពោសោ** សេចក្តីថា ព្រះរាជកុមារនេះចុតិចាកមនុស្សលោកនេះហើយ នឹងទៅកាន់ស្ថានតុសិតហើយ គឺនឹងនៅក្នុង

កពតុសិតនោះ ។ ក្នុងពាក្យនោះ ភ្ជាប់សេចក្តីថា មានស្រីទេពអប្សរទាំងឡាយចោមរោម គឺហែហម នឹងសោយសម្បត្តិក្នុងស្ថានតុសិត ។

បទថា **ចតុត្តឹសក្ខត្តុំ** ភ្ជាប់សេចក្តីថា ចុតិចាកស្ថានតុសិតហើយ កើតក្នុងស្ថានតាវត្តិង្ស នឹងបានជាស្តេចនៃទេវតា គ្រងរាជសម្បត្តិ ៣៤ ដង ។ បទថា **ពលាធិបោ អដ្ឋសតំ** សេចក្តីថា ចុតិចាកស្ថានតាវត្តិង្ស មកកើតក្នុងមនុស្សលោក នឹងបានជាធំគ្រប់គ្រងផែនដី គឺជាប្រធានក្នុងកងទ័ព ដែលប្រកបដោយអង្គ ៤ នឹងជាស្តេចផែនដី ៨០០ ដង គ្រប់គ្រងផែនដី គឺប្រឹថពីដ៏ប្រសើរ ដោយរតនៈមិនមែនតិច គឺនឹងនៅក្នុងផែនដី ។

បទថា **អដ្ឋបញ្ញាសក្ខត្តុំ** សេចក្តីថា នឹងជាស្តេចចក្រពត្តិ ៥៨ ជាតិ នឹងគ្រប់គ្រងភាពជាស្តេចបទេសរាជ្យដ៏ធំទូលំទូលាយ គឺរាប់មិនអស់ គឺក្នុងផែនដីជម្ពូទ្វីបទាំងមូល ។ បទថា **សក្យានំ កុលកេតុស្ស** សេចក្តីថា នឹងបានជាញាតិរបស់ព្រះពុទ្ធដែលជាទង់ជ័យនៃសក្យរាជត្រកូល ។

បទថា **អាតាបី** ប្រែថា មានសេចក្តីព្យាយាម ។ បទថា **និបកោ** បានដល់ ជាអ្នកប្រកបដោយបញ្ញា ដែលហៅបញ្ញាគ្រប់គ្រងខ្លួន ជាអ្នកឈ្លាសក្នុងពហុសច្ច គឺភាពជាពហូសូត បានដល់ ក្នុងការទ្រទ្រង់ព្រះត្រៃបិដក ភ្ជាប់សេចក្តីថា នឹងជាអ្នកប្រព្រឹត្តឱនលំទោន គឺជាអ្នកមិនមើលងាយអ្នកដទៃ ជាអ្នកមិនរឹងត្អឹង គឺប្រាសចាកការរឹងត្អឹង មានការគ្តាំគ្តងផ្លូវកាយជាដើម ជា

អ្នកទ្រទ្រង់នូវពុទ្ធវចនៈទាំងអស់ គឺនឹងជាអ្នកមានប្រក្រតីទ្រទ្រង់ព្រះត្រៃបិដកទាំងមូលបាន ។

បទថា **បធានបហិតត្តោ សោ** សេចក្តីថា ព្រះអានន្ទត្ថេរនោះ ជាអ្នកមានចិត្តបញ្ជូនទៅដើម្បីធ្វើសេចក្តីព្យាយាម ។ បទថា **ឧបសន្តោ និរុបធិ** សេចក្តីថា ជាអ្នកវៀរឧបធិ គឺរាគៈ ទោសៈ និងមោហៈ ជាអ្នកមានចិត្តស្ងប់ គឺជាអ្នកមានកាយ និងចិត្តស្ងប់ ព្រោះលះពួកកិលេសដែលគប្បីលះដោយសោតាបត្តិមគ្គ ។

បទថា **សន្តិ អារញ្ញកា** សេចក្តីថា មានក្នុងព្រៃ គឺកើតក្នុងព្រៃធំ ។ បទថា **សដ្ឋិហាយនា** សេចក្តីថា មានកម្លាំងថមថយទៅ ក្នុងកាលមានអាយុ ៦០ ឆ្នាំ ។ បទថា **តិធា បភិន្នា** សេចក្តីថា ចុះប្រេងក្នុងទី ៣ កន្លែង គឺត្រង់ភ្នែក ត្រង់ត្រចៀក និងត្រង់អណ្ឌៈ ។ បទថា **មាតង្គា** ប្រែថា កើតក្នុងត្រកូលដំរីឈ្មោះមាតង្គៈ ។ បទថា **ឦសាទន្តា** ប្រែថា មានភ្លុកដូចចន្ទោលរថ ។ មានភ្លៅមាំមួន គឺជារាជពាហនៈ ។ ដំរីដ៏ប្រសើរដែលហៅថា កុញ្ជរ បានដល់ ស្តេចដំរី មានប្រាកដយ៉ាងណា បណ្ឌិត ហៅថា ព្រះខីណាស្រព បានដល់ ព្រះអរហន្តនាគដែលមានឫទ្ធិ រាប់ដោយសែន មានព្រះអរហន្តនាគទាំងអស់នោះ ក៏មកជាសាវករបស់ស្តេចដំរីដ៏ប្រសើរ គឺព្រះ

*សម្ពុទ្ធក៏យ៉ាងនោះ ។ បទថា* **ន ហោន្តិ បណ្ឌិតា តេ** *សេចក្តីថា បណ្ឌិតទាំងនោះ រមែងមិនដូច្នោះ ក្នុងសេចក្តីប្រាថ្នា អធិប្បាយថា បណ្ឌិតទាំងអស់នោះ មិនបានខ្លាចភ័យ ព្រោះមិនអាចគ្រប់គ្រងខ្លួន ។ ពាក្យដ៏សេសមានអត្ថងាយយល់ហើយ ព្រោះមានន័យដូចពោលហើយនោះឯង ។ល។*

**អដ្ឋកថា អានន្ទត្ថេរាបទាន ចប់**

**ពុទ្ធវគ្គទី ១ ដោយលំដាប់ពាក្យមានប្រមាណប៉ុណ្ណោះ ចប់**

**បឋមភាគ ចប់**

# ក្បាលទី ៥៩

# សុត្តន្តបិដក ចាលីប្រែ -៧២

## សន្ទឹកចង្អុលប្រាប់មាតិកា

មាតិកា ទំព័រ

### ពុទ្ធវគ្គទី ១


ពុទ្ធាបទានទី ១ ...... ...... ...... ...... ២
អដ្ឋកថាពុទ្ធាបទានទី ១ ...... ...... ...... ...... ១៣
និទានកថា ...... ...... ...... ...... ១៥
ទូរេនិទានកថា ...... ...... ...... ...... ១៦
សុមេធកថា ...... ...... ...... ...... ១៧
សុរុចិព្រាហ្មណកថា ...... ...... ...... ...... ៧៦
អវិទូរេនិទានកថា ...... ...... ...... ...... ១២១
សន្តិកេនិទានកថា ...... ...... ...... ...... ១៨១
ពណ៌នាអព្ភន្តរនិទាន ...... ...... ...... ...... ២២២
អដ្ឋកថាពុទ្ធាបទានទី ១ ...... ...... ...... ...... ២៣០
បច្ចេកពុទ្ធាបទានទី ២ ...... ...... ...... ...... ២៩២
អដ្ឋកថាសំសគ្គគាថា ...... ...... ...... ...... ៣៥២
អដ្ឋកថាមិត្តសុហជ្ជគាថា ...... ...... ...... ...... ៣៦១
អដ្ឋកថាវំសក្កឡីរគាថា ...... ...... ...... ...... ៣៦៦
អដ្ឋកថាមិគោអរញ្ញគាថា ...... ...... ...... ...... ៣៧០
អដ្ឋកថាអាមន្តនាគាថា ...... ...... ...... ...... ៣៨១
អដ្ឋកថាខិឌ្ឌារតិគាថា ...... ...... ...... ...... ៣៨៣
អដ្ឋកថាចាតុទ្ទិសគាថា ...... ...... ...... ...... ៣៨៥

| | | |
|---|---|---|
| អដ្ឋកថាទុស្សន្តហគាថា | ...... ...... ...... ...... | ៣៩០ |
| អដ្ឋកថាកោវិឡារគាថា | ...... ...... ...... ...... | ៣៩៣ |
| អដ្ឋកថាសហាយគាថា | ...... ...... ...... ...... | ៣៩៦ |
| អដ្ឋកថាអទ្ធាបសំសាគាថា | ...... ...... ...... ...... | ៤០០ |
| អដ្ឋកថាសុវណ្ណវលយគាថា | ...... ...... ...... ...... | ៤០៣ |
| អដ្ឋកថាអាយតិភយគាថា | ...... ...... ...... ...... | ៤០៥ |
| អដ្ឋកថាកាមគាថា | ...... ...... ...... ...... | ៤១០ |
| អដ្ឋកថាព្យតិគាថា | ...... ...... ...... ...... | ៤១៣ |
| អដ្ឋកថាសីតាលុកគាថា | ...... ...... ...... ...... | ៤១៥ |
| អដ្ឋកថានាគគាថា | ...... ...... ...... ...... | ៤១៧ |
| អដ្ឋកថាអដ្ឋានគាថា | ...... ...... ...... ...... | ៤២១ |
| អដ្ឋកថាទិដ្ឋីវិសូកគាថា | ...... ...... ...... ...... | ៤២៥ |
| អដ្ឋកថានិល្លោលុបគាថា | ...... ...... ...... ...... | ៤២៧ |
| អដ្ឋកថាបាបសហាយគាថា | ...... ...... ...... ...... | ៤៣១ |
| អដ្ឋកថាពហុស្សុតគាថា | ...... ...... ...... ...... | ៤៣៣ |
| អដ្ឋកថាវិភូសដ្ឋានគាថា | ...... ...... ...... ...... | ៤៣៧ |
| អដ្ឋកថាបុត្តទារគាថា | ...... ...... ...... ...... | ៤៣៩ |
| អដ្ឋកថាសន្តគាថា | ...... ...... ...... ...... | ៤៤០ |
| អដ្ឋកថាសន្ទាលគាថា | ...... ...... ...... ...... | ៤៤៣ |
| អដ្ឋកថាឱក្ខិត្តចក្ខុគាថា | ...... ...... ...... ...... | ៤៤៥ |
| អដ្ឋកថាបារិច្ឆត្តគាថា | ...... ...... ...... ...... | ៤៤៧ |
| អដ្ឋកថាសេគេជគាថា | ...... ...... ...... ...... | ៤៤៩ |
| អដ្ឋកថាអាវរណគាថា | ...... ...... ...... ...... | ៤៥២ |
| អដ្ឋកថាវិបិដ្ឋិគាថា | ...... ...... ...... ...... | ៤៥៤ |

អដ្ឋកថាអាវទ្ធវិរិយគាថា ...... ...... ...... ...... ៤៥៦

អដ្ឋកថាបដិសល្លានគាថា ...... ...... ...... ...... ៤៦១

អដ្ឋកថាតណ្ហក្ខយគាថា ...... ...... ...... ...... ៤៦៣

អដ្ឋកថាសីហាទិគាថា ...... ...... ...... ...... ៤៦៦

អដ្ឋកថាទាឋពលីគាថា ...... ...... ...... ...... ៤៧០

អដ្ឋកថាអប្បមញ្ញាគាថា ...... ...... ...... ...... ៤៧៣

អដ្ឋកថាជីវិតសង្ខយគាថា ...... ...... ...... ...... ៤៧៥

អដ្ឋកថាគាថាដ៏សេស ...... ...... ...... ...... ៤៧៧

សារីបុត្តត្ថេរាបទានទី ៣ ...... ...... ...... ...... ៤៨៨

អដ្ឋកថាសារីបុត្តត្ថេរាបទាន ...... ...... ...... ...... ៥១៦

អត្ថរបស់ថេរសព្ទ ...... ...... ...... ...... ៥១៦

មហាមោគ្គល្លានត្ថេរាបទានទី ៤ ...... ...... ...... ...... ៥៨៦

អដ្ឋកថាមហាមោគ្គល្លានត្ថេរាបទាន ...... ...... ...... ...... ៥៨៩

មហាកស្សបត្ថេរាបទានទី ៥ ...... ...... ...... ...... ៦១៨

អដ្ឋកថាមហាកស្សបត្ថេរាបទាន ...... ...... ...... ...... ៦២១

អនុរុទ្ធត្ថេរាបទានទី ៦ ...... ...... ...... ...... ៦៥៧

អដ្ឋកថាអនុរុទ្ធត្ថេរាបទាន ...... ...... ...... ...... ៦៥៩

បុណ្ណមន្តានីបុត្តត្ថេរាបទានទី ៧ ...... ...... ...... ...... ៦៦៩

អដ្ឋកថាបុណ្ណមន្តានីបុត្តត្ថេរាបទាន ...... ...... ...... ...... ៦៧១

ឧបាលិត្ថេរាបទានទី ៨ ...... ...... ...... ...... ៦៧៧

អដ្ឋកថាឧបាលិត្ថេរាបទាន ...... ...... ...... ...... ៦៩៧

អញ្ញាកោណ្ឌញ្ញត្ថេរាបទានទី ៩ ...... ...... ...... ...... ៧៤៥

អដ្ឋកថាអញ្ញាកោណ្ឌញ្ញត្ថេរាបទាន ...... ...... ...... ...... ៧៤៨

បិណ្ឌោលភារទ្វាជត្ថេរាបទានទី ១០ ...... ...... ...... ...... ៧៥៧

អដ្ឋកថាបិណ្ឌោលភារទ្វាជត្ថេរាបទាន ...... ...... ...... ...... ៧៦០
ខទិរវនិយរេវតត្ថេរាបទានទី ១១ ...... ...... ...... ...... ៧៦៦
អដ្ឋកថាខទិរវនិយរេវតត្ថេរាបទាន ...... ...... ...... ...... ៧៦៨
អានន្ទត្ថេរាបទានទី ១២ ...... ...... ...... ...... ៧៧៦
អដ្ឋកថាអានន្ទត្ថេរាបទាន ...... ...... ...... ...... ៧៧៩